# ព្រះត្រៃបិដក

## ប្រែរួមនឹង ព្រះអដ្ឋកថា

## ភាគ៥២

បាលីប្រែ ៦៣

ពុទ្ធសករាជ ២៥៥៣

ច្បាប់ពិនិត្យ លើកទី២

# ព្រះ

# សុត្តន្តបិដក

និង

## ជាតកដ្ឋកថា

### សេចក្តីប្រែជាភាសាខ្មែរ

## ខុទ្ទកនិកាយ ជាតក

## ទ្វាទសមភាគ

## ៥២

## បាលីប្រែ ៦៣



*បោះពុម្ពលើកទី ១ ពុទ្ធសករាជ ២៥៥៣*

# ក្បាលទី ៥២
# ខុទ្ទកនិកាយ មហានិបាត ជាតក

## មហាជនកស្សប ជាតក

[ ១ ] ( *អភិសម្ពុទ្ធគាថា* ) *ព្រះរាជារបស់ពួកជនអ្នកនៅក្នុងដែនវិទេហៈជាក្សត្រទ្រង់ព្រះនាមអង្គតិ មានយានច្រើន មានទ្រព្យច្រើន មានពួកពលមិនមានទីបំផុត ។ នៅពេលបឋមយាមដែលមិនទាន់កន្លងនៃរាត្រីជាគម្រប់ ១៥ ជាទីបំផុតនៃខែភ្លៀង ៤ ខែ ជាទីរីកនៃផ្កាកុមុទ ព្រះអង្គទ្រង់ប្រជុំអមាត្យទាំងឡាយជាបណ្ឌិតបរិបូណ៌ដោយការស្តាប់ ជាអ្នកញញឹមមុននិយាយ ជាអ្នកមានប្រាជ្ញាឈ្មោះវិជយៈ ១ ឈ្មោះសុនាមៈ ១ និងសេនាបតីឈ្មោះអលាតៈ ១ ។ ព្រះបាទវិទេហៈ ទ្រង់សួរអមាត្យនោះជាលំដាប់ថា អ្នកទាំងឡាយចូរពោលតាមសេចក្តីពេញចិត្តផ្សេងៗគ្នា ថ្ងៃនេះជារាត្រីជាទីបំផុតនៃខែភ្លៀង ៤ ខែ ជាទីរីកនៃផ្កាកុមុទ មណ្ឌលព្រះចន្ទដ៏សកម្ចាត់បង់ងងឹត ថ្ងៃនេះយើងទាំងឡាយ នឹងនៅដោយសេចក្តីត្រេកអរដូចម្តេចក្នុងរាត្រីរដូវនេះ ។*

[ ២ ] *លំដាប់នោះសេនាបតីរបស់ព្រះរាជាឈ្មោះអលាតៈបានក្រាបទូលដូច្នេះថា យើងខ្ញុំនឹងចាត់ចែងយាន ពលនិងសេនាទាំងអស់ដែលមានចិត្តរីករាយហើយ ។ បពិត្រព្រះសម្មតិទេព យើងខ្ញុំមានពួកពលមិនមានទីបំផុតនឹងចេញទៅដើម្បីច្បាំង ពួកព្រះរាជាណាមិនមកចុះអំណាច យើងនឹង*

នាំចូលមកចុះអំណាចព្រះអង្គ នេះជាសេចក្ដីយល់ផ្ដាល់ខ្លួន របស់ទូលព្រះបង្គំជាខ្ញុំ ពួកទូលព្រះបង្គំជាខ្ញុំនឹងផ្ចាញ់សត្រូវដែលមិនទាន់ផ្ចាញ់ ។ ( បពិត្រព្រះសម្មតិទេព សូមព្រះអង្គត្រេកអរក្នុងចម្បាំង នេះជាសេចក្ដីចូលចិត្តរបស់ទូលព្រះបង្គំជាខ្ញុំ ) ។

[ ៣ ] អាមាត្យឈ្មោះសុនាមៈ បានស្ដាប់ពាក្យអលាតសេនាបតីហើយក៏ក្រាបទូលដូច្នេះថា បពិត្រមហារាជ ពួកសត្រូវទាំងអស់មកចុះអំណាចព្រះអង្គស្រាប់ហើយតើ ។ ពួកសត្រូវមានគ្រឿងសស្ត្រាដាក់ចុះហើយ តែងប្រព្រឹត្តបន្ទន់បន្ទាប មហោស្រពដ៏ឧត្ដមនឹងមានក្នុងថ្ងៃនេះ ការច្បាំងទូលព្រះបង្គំជាខ្ញុំមិនពេញចិត្តទេ ។ ជនទាំងឡាយចូរនាំយកបាយ ទឹកនិងបង្អែមយ៉ាងឆាប់មកថ្វាយព្រះអង្គ បពិត្រព្រះសម្មតិទេព សូមព្រះអង្គត្រេកអរក្នុងការរាំច្រៀងនិងគ្រឿងប្រគំដោយកាមទាំងឡាយចុះ ។

[ ៤ ] វិជយាមាត្យបានស្ដាប់ពាក្យសុនាមអាមាត្យហើយក៏ក្រាបទូលដូច្នេះថា បពិត្រមហារាជ កាមទាំងអស់ប្រាកដដល់ព្រះអង្គជានិច្ចហើយតើ ។ បពិត្រព្រះសម្មតិទេព កាមទាំងនេះព្រះអង្គមិនមែនបានដោយក្រទេ កាលបើព្រះអង្គ ( ប្រាថ្នា ) រីករាយដោយកាមទាំងឡាយ កាមទាំងឡាយព្រះអង្គបានសព្វៗ កាលនេះមិនមែនជាសេចក្ដីពេញចិត្តរបស់ទូលព្រះបង្គំជាខ្ញុំទេ ។ សមណព្រាហ្មណ៍ណាអ្នកដឹងអត្ថនិងធម៌ ជាអ្នកស្វែងរកគុណ គប្បីបន្ទោបង់សេចក្ដីសង្ស័យនៃយើងទាំងឡាយ ក្នុងថ្ងៃនេះបានយើងទាំងឡាយនឹងចូលទៅរកសមណព្រាហ្មណ៍ជាពហុស្សូតនោះ ។

[ ៥ ] ព្រះរាជាទ្រង់ព្រះនាមអង្គតិ ទ្រង់ព្រះសណ្ដាប់ពាក្យនៃវិជយាមាត្យហើយទ្រង់ត្រាស់ថា ការណ៍នេះពេញចិត្តដល់យើងដូចវិជយាមាត្យពោល ។ សមណព្រាហ្មណ៍ណាជាអ្នកដឹងអត្ថនិងធម៌ ជាអ្នកស្វែងរកគុណ គប្បីបន្ទោបង់សេចក្ដីសង្ស័យនៃយើងទាំងឡាយបាន ក្នុងថ្ងៃនេះយើងទាំងឡាយ នឹងចូលទៅរកសមណព្រាហ្មណ៍ជាពហុស្សូតនោះ ។ អ្នកទាំងអស់គ្នាចូរធ្វើសេចក្ដីយល់ចុះ យើងគួរចូលទៅរកបណ្ឌិតណាដែលជាអ្នកដឹងអត្ថនិងធម៌ ជាអ្នកស្វែងរកគុណ បន្ទោបង់សេចក្ដីសង្ស័យនៃពួកយើងបានក្នុងថ្ងៃនេះ ។

[ ៦ ] អលាតសេនាបតីបានស្ដាប់ព្រះបន្ទូលនៃព្រះបាទវិទេហៈហើយក៏ក្រាបទូលដូច្នេះថា មានអចេលកៈ ១ អង្គនេះដែលគេសន្មតថាជាអ្នកប្រាជ្ញគង់ក្នុងមិគទាយវ័ន ។ អចេលកៈនេះឈ្មោះគុណៈ ជាកស្សបគោត្ត ជាអ្នកចេះដឹង ជាអ្នកពោលពាក្យដ៏វិចិត្រ ជាគណាចារ្យ បពិត្រព្រះសម្មតិទេព យើងគួរចូលទៅរកអចេលកៈនោះ លោកនឹងបន្ទោបង់សេចក្ដីសង្ស័យនៃពួកយើងបាន ។

[ ៧ ] ព្រះរាជាទ្រង់ព្រះសណ្ដាប់ពាក្យនៃអលាតសេនាបតីហើយ ទ្រង់បង្គាប់នាយសារថីថា យើងនឹងទៅកាន់មិគទាយវ័ន អ្នកចូរនាំយកនូវយានដែលទឹមហើយមកក្នុងទីនេះ ។

[ ៨ ] ពួកនាយសារថីបានទឹមថ្វាយព្រះរាជានោះនូវយាន ជាវិការៈនៃភ្លុក មានទ្រពងជាវិការៈនៃប្រាក់ មានប្រដាប់ជាបរិវារដ៏សរលង់ហាក់ដូចមុខនៃរាត្រីដែលប្រាសចាកទោស ឬដូចព្រះចន្ទ ( ពេញវង់ ) ក្នុងរថនោះ

នាយសារថីបានទឹមសេះសិន្ធព ៤ មានសម្បុរដូចផ្កាកុមុទមានសន្ទុះលឿន ប្រហែលនឹងសន្ទុះខ្យល់ដែលបង្ហាត់ល្អហើយ ប្រដាប់ដោយកម្រងផ្កា ជាវិការៈនៃមាស ។ មានព្រះក្លស់ស រថស សេះស ស៊ែស ព្រះបាទវិទេហៈយាងទៅ ( ដោយរថនោះ ) ជាមួយនឹងពួកអាមាត្យក៏ល្អដូចជាព្រះចន្ទ ។ ពលដ៏ច្រើនជាអ្នកទ្រទ្រង់លំពែងនិងដាវ ទាំងពួកជនអ្នកក្លាហាន ក៏ជិះលើខ្នងសេះហើយតាមដង្ហែព្រះរាជានោះដែលជាធំដ៏ប្រសើរជាងនរៈ ។ ព្រះបាទវិទេហៈ ជាក្សត្រនោះ ក៏យាងទៅកាន់ឧទ្យានដោយមួយរំពេច ទ្រង់ចុះពីយានយាងផ្ទាល់ព្រះបាទជាមួយនឹងអាមាត្យ ក៏យាងទៅរកអាជីវកឈ្មោះគុណៈ ។ គ្រានោះព្រាហ្មណ៍និងគហបតីទាំងឡាយណា ដែលមកប្រជុំគ្នាក្នុងឧទ្យាននោះ ព្រះរាជាក៏មិនបណ្តេញព្រាហ្មណ៍និងគហបតីទាំងនោះ ដែលមកកាន់ទីដែលមិនបានធ្វើឱកាស ។

[ ៩ ] លំដាប់នោះព្រះរាជានោះចូលទៅក្នុងទីដ៏សមគួរ ( ប្រថាប់ ) លើពូកមានសម្ផស្សទន់ លើកម្រាលដ៏វិចិត្រមានសម្ផស្សទន់ លើទីដែលគេក្រាលដោយកម្រាលដ៏ទន់ ។ ព្រះរាជាលុះគង់ហើយក៏រីករាយ ( ជាមួយ ) អចេលកៈលំដាប់នោះទ្រង់ត្រាស់នូវពាក្យគួររឭកថា បពិត្រលោកដ៏ចម្រើន សរីរៈរបស់លោកអាចប្រព្រឹត្តទៅបានទេឬ ធាតុខ្យល់មិនប្រព្រឹត្តទៅ ( ស្រួលក្នុងសរីរៈ ) ទេឬ ។ ការប្រព្រឹត្តិ ( ចិញ្ចឹមជីវិត ) របស់លោកមិនលំបាកទេឬ លោកបានដុំបាយខ្វះដែរឬ លោកមិនមានអាពាធទេឬ ចក្ខុរបស់លោកមិនសាបសូន្យទេឬ ។

[ ១០ ] អចេលកៈឈ្មោះគុណៈបានក្រាបទូលព្រះបាទវិទេហៈដែលទ្រង់ត្រេកអរក្នុងវិន័យដោយពាក្យថា បពិត្រមហារាជ អាត្មាភាពល្មមញុំាងសរីរៈឲ្យប្រព្រឹត្តទៅបាន ខាងដើមដំណើរទាំងអស់នុ៎ះ ដំណើរទាំងពីរដែលព្រះអង្គត្រាស់សួរហើយនោះ ( ក៏ស្រួលដែរ ) ។ បពិត្រព្រះបាទវិទេហៈបច្ចន្តគ្រាមទាំងឡាយរបស់ព្រះអង្គមិនបះបោរទេឬ យានរបស់ព្រះអង្គមិនខូចខាតទេឬ វាហនៈនៅប្រព្រឹត្តទៅបានទេឬ ព្យាធិទាំងឡាយដែលដុតកម្ដៅសរីរៈរបស់ព្រះអង្គមិនមានទេឬ ។

[ ១១ ] លំដាប់នោះព្រះរាជាព្រះអង្គប្រសើរក្នុងរថ ទ្រង់ប្រាថ្នាធម៌ក៏ក្រាបទូលបទើបសួរអត្ថផង ធម៌ផង ហេតុដែលគួរដឹងផងថា បពិត្រកស្សបគោត្ត សត្វគប្បីប្រព្រឹត្តធម៌ក្នុងមាតាបិតាតើដូចម្ដេច គប្បីប្រព្រឹត្តក្នុងអាចារ្យតើដូចម្ដេច គប្បីប្រព្រឹត្តក្នុងកូននិងប្រពន្ធតើដូចម្ដេច ។ គប្បីប្រព្រឹត្តក្នុងពួកមនុស្សចាស់តើដូចម្ដេច ក្នុងសមណព្រាហ្មណ៍តើដូចម្ដេច ក្នុងពួកពលតើដូចម្ដេច គប្បីប្រព្រឹត្តក្នុងជនបទតើដូចម្ដេច ។ សត្វទាំងឡាយប្រព្រឹត្តធម៌ដូចម្ដេចលះលោកនេះហើយទៅកាន់សុគតិ សត្វពួកខ្លះឋិតនៅក្នុងអធម៌មានក្បាលសំយុងចុះធ្លាក់ទៅកាន់នរកតើដូចម្ដេច ។

[ ១២ ] អចេលកៈជាកស្សបគោត្តបានស្ដាប់ព្រះបន្ទូលព្រះបាទវិទេហៈហើយក៏ទូលដូច្នេះថា បពិត្រមហារាជ សូមព្រះអង្គទ្រង់ព្រះសណ្ដាប់នូវបទដែលពិត មិនឃ្លៀងឃ្លាតរបស់អាត្មាភាពចុះ ។ ផលល្អនិងអាក្រក់របស់បុគ្គលអ្នកប្រព្រឹត្តធម៌មិនមានទេ បពិត្រព្រះសម្មតិទេព បរលោកក៏មិនមានដែរព្រោះ

ជាក្នុងលោកនេះមាននរណាមកពីបរលោក ។ បពិត្រព្រះសម្មតិទេព មួយទៀតមាតាបិតាមិនមានទេ មាតានឹងមានពីណា បិតានឹងមានពីណា បុគ្គលដែលឈ្មោះថា អាចារ្យមិនមានទេ បុគ្គលណានឹងទូន្មានបុគ្គល ដែលទូន្មានមិនបាន ។ សត្វទាំងឡាយមានតុល្យភាពស្មើៗគ្នា សត្វទាំងឡាយជាអ្នកគោរពចំពោះបុគ្គលចាស់មិនមានទេ កម្លាំងក្តី ព្យាយាមក្តីក៏មិនមានដែរ បុរសអ្នកព្យាយាមនឹងមានពីណា ។ ព្រោះថា សត្វទាំងឡាយទៀងដូចទូកតូចចងភ្ជាប់នឹងទូកធំ សត្វរមែងបានរបស់ដែលត្រូវបាន ផលទានក្នុងបរលោកនោះនឹងមានពីណា ។ បពិត្រព្រះសម្មតិទេព ផលទានមិនមានទេ បពិត្រព្រះសម្មតិទេព សេចក្តីព្យាយាមមិនមានអំណាចទេ ទានគឺពួកជនពាលទេតើបញ្ញត្តមក ពួកបណ្ឌិតចាំតែទទួលយកនូវទាននោះ ពួកជនពាលជាអ្នកមិនមានអំណាចសំគាល់ខ្លួនថាជាបណ្ឌិត រមែងឲ្យទានដល់បណ្ឌិតទាំងឡាយ ។

[ ១៣ ] ភ្លើង ដី ទឹក ខ្យល់ សុខ ទុក្ខនិងជីវិតទាំង ៧ នេះឈ្មោះថាពួកទៀងជាសភាវៈឲ្យដាច់មិនបាន ឲ្យកម្រើកមិនបាន ។ ពួកទៀងទាំង ៧ នេះគប្បីរស់នៅជាដរាបដែលបុគ្គលកាត់ហើយមិនឈ្មោះថាកាត់ បុគ្គលអ្នកសម្លាប់ក្តី បុគ្គលអ្នកកាត់ក្តីមិនមាន អ្នកណាឈ្មោះថាសម្លាប់អ្នកណាបាន ។ គ្រឿងសស្ត្រាទាំងឡាយគ្រាន់តែចូលទៅក្នុងចន្លោះនៃពួក ( ទៀង ) ប៉ុណ្ណោះ បុគ្គលណា យកដាវដែលសំលៀងហើយកាត់ក្បាលជនដទៃ បុគ្គលនោះមិនឈ្មោះថាកាត់ពួក ( ទៀង ) ទាំងនោះទេ ផលនៃបាបក្នុងការកាត់នោះនឹងមានពីណា ។ សត្វទាំងអស់កាលអន្ទោលអស់មហាកប្ប ៨៤ ទើបបរិសុទ្ធិឯង

កាលបើមិនទាន់ដល់កាលនោះបុគ្គលសូម្បីសង្រួមក៏មិនបរិសុទ្ធិ ។ កាលបើមិនទាន់ដល់កំណត់នោះ ពួកសត្វសូម្បីប្រព្រឹត្តល្អច្រើនក៏មិនបរិសុទ្ធិ ទុកជាធ្វើបាបច្រើនក៏មិនកន្លងហួសនូវខណៈនោះដែរ ។ សេចក្តីបរិសុទ្ធិនៃយើងទាំងឡាយតាមលំដាប់នៃកប្ប ៨៤ យើងទាំងឡាយមិនកន្លងហួស ( កម្រិត ) ដ៏ទៀងនោះទេដូចសាគរមិនកន្លងហួសច្រាំង ។

[ ១៤ ] អលាតសេនាបតីលុះស្តាប់ពាក្យអចេលកៈជាកស្សបគោត្តហើយក៏ពោលដូច្នេះថា លោកដ៏ចម្រើនពោលយ៉ាងណា ពាក្យនោះពេញចិត្តខ្ញុំដែរ ។ ខ្ញុំរឭកជាតិរបស់ខ្លួនក្នុងកាលមុនដែលអន្ទោលទៅហើយថា ក្នុងកាលមុនខ្ញុំកើតជាមនុស្សប្រព្រឹត្តអាក្រក់ឈ្មោះបិង្គលៈ ជាអ្នកសម្លាប់គោ ។ ខ្ញុំបានធ្វើបាបដ៏ច្រើនក្នុងក្រុងពារាណសី ជាក្រុងសម្បូរ ខ្ញុំបានសម្លាប់សត្វដ៏ច្រើនគឺក្របី ជ្រូក ពពែ ។ លុះខ្ញុំច្យុតចាកអត្តភាពនោះ ក៏បានមកកើតក្នុងត្រកូលសេនាបតីដ៏ស្តុកស្តម្ភក្នុងទីនេះ ផលបាបរបស់ខ្ញុំមិនមានពិត បានជាខ្ញុំមិនទៅនរក ។

[ ១៥ ] គ្រានោះក្នុងក្រុងមិថិលា មានបុគ្គលកម្សត់ម្នាក់ជាទាសៈឈ្មោះវីជកៈរក្សាឧបោសថហើយចូលទៅកាន់សំណាក់នៃអចេលកៈឈ្មោះគុណៈ ។ វីជកៈលុះស្តាប់ពាក្យរបស់គុណៈ ជាកស្សបគោត្ត និងពាក្យដែលអលាតសេនាបតីពោលហើយក៏ដកដង្ហើមចេញដ៏ក្តៅរឿយៗ យំបង្ហូរទឹកភ្នែក ។

[ ១៦ ] ព្រះបាទវិទេហៈទ្រង់ត្រាស់សួរវីជកៈនោះថា ម្នាលសម្លាញ់ អ្នកយំតើដើម្បីអ្វី អ្នកបានឮឬបានឃើញអ្វី អ្នកដល់នូវទុក្ខវេទនាដូចម្តេច ចូរ

ប្រាប់ឲ្យយើងដឹងផង ។

[ ១៧ ] វីជកៈ បានស្តាប់ព្រះបន្ទូលព្រះបាទវិទេហៈហើយក្រាបបង្គំទូលថា បពិត្រមហារាជ ទុក្ខវេទនារបស់ទូលព្រះបង្គំជាខ្ញុំមិនមានទេ សូមព្រះអង្គទ្រង់ព្រះសណ្តាប់ចុះ ។ ទូលព្រះបង្គំជាខ្ញុំ រឭកឃើញនូវសេចក្តីសុខរបស់ទូលព្រះបង្គំជាខ្ញុំក្នុងជាតិមុន កាលដែលបានកើតជាភាវសេដ្ឋី ជាអ្នកត្រេកអរក្នុងគុណធម៌ក្នុងបុរីឈ្មោះ សាកេត ។ ទូលព្រះបង្គំជាខ្ញុំត្រូវពួកព្រាហ្មណ៍និងគហបតីសរសើរហើយ ជាជាអ្នកត្រេកអរក្នុងការចែករំលែកទាន ជាអ្នកមានការងារដ៏ស្អាត តែទូលព្រះបង្គំជាខ្ញុំ មិនហ៊ានទឹកនានូវអំពើអាក្រក់របស់ខ្លួនដែលធ្វើហើយទេ ។ បពិត្រព្រះបាទវិទេហៈ ទូលព្រះបង្គំជាខ្ញុំលុះច្យុតចាកអត្តភាពនោះក៏មកកើតក្នុងគភ៌នៃកុម្ភទាសី ជាស្រីទុគ៌តក្នុងក្រុងមិថិលានេះ តាំងពីកើតមកទូលព្រះបង្គំជាខ្ញុំទុគ៌តក្រៃពេក ។ សូម្បីទូលព្រះបង្គំជាខ្ញុំទុគ៌តយ៉ាងនេះក៏តាំងនៅក្នុងការប្រព្រឹត្តិស្មើ តែងឲ្យកត្តពាក់កណ្តាលដល់បុគ្គលអ្នកត្រូវការ ។ តែងរក្សា ( ឧបោសថ ) អស់ថ្ងៃទី ១៤ និងថ្ងៃទី ១៥ សព្វៗកាល ទាំងមិនបៀតបៀនសត្វផង បានវៀរបង់ការលួចលាក់ផង ។ អំពើដែលសន្សំល្អហើយទាំងអស់នេះ ជារបស់ឥតផលដោយពិត ទូលព្រះបង្គំជាខ្ញុំសំគាល់ថា សីលនេះមិនមានប្រយោជន៍ទេ ដូចជាអលាតសេនាបតីពោលដែរ ។ ដែលទូលព្រះបង្គំជាខ្ញុំទទួលទុក្ខទោសដោយជាក់ស្តែងនេះដូចជាអ្នកលេងដែលមិនមានសិល្បៈ ឬដូចជាអលាតសេនាបតីជាអ្នកលេងស្កាបានរៀនហើយ ក៏បានទទួលការឈ្នះ ។ ទូលព្រះបង្គំមិនឃើញទ្វារសម្រាប់ទៅសុគតិ

សោះ បពិត្រព្រះរាជា ព្រោះហេតុនោះបានជាទូលព្រះបង្គំជាខ្ញុំយំទួញព្រោះបានស្តាប់ភាសិតនៃអចេលកៈជាកស្សបគោត្ត ។

[ ១៨ ] ព្រះរាជាព្រះនាមអង្គតិ ទ្រង់ព្រះសណ្តាប់ពាក្យវីជកៈហើយទ្រង់ត្រាស់ថា ម្នាលវីជកៈ ទ្វារនៃសុគតិមិនមានទេអ្នកចូរសង្ឃឹមការដ៏ទៀងចុះ ។ បានឮថា សុខឬទុក្ខជារបស់ទៀង ដែលពួកសត្វរមែងតែបានសេចក្តីបរិសុទ្ធិព្រោះសង្សាររបស់សត្វទាំងអស់ ( រមែងមាន ) អ្នកកុំប្រញាប់ចង់ឃើញក្នុងកាលដែលមិនទាន់ដល់ ( កំណត់នោះ ) ឡើយ ។ ក្នុងកាលមុនយើងជាបុគ្គលល្អបានខ្វល់ខ្វាយ ( បម្រើ ) នូវពួកព្រាហ្មណ៍និងគហបតី កាលប្រៀនប្រដៅនូវវោហារ ( រាជកិច្ច ) ក៏សាបសូន្យចាកសេចក្តីត្រេកអរ ( ក្នុងកាមគុណ ) ជាលំដាប់ ។

[ ១៩ ] ព្រះរាជាទ្រង់ត្រាស់នឹងអចេលកៈជាកស្សបគោត្តថា បពិត្រលោកដ៏ចម្រើន ប្រសិនបើមានការប្រជុំយើងនឹងជួបគ្នាម្តងទៀត ។ ព្រះបាទវិទេហៈទ្រង់ត្រាស់ព្រះតម្រាស់នេះហើយ ទ្រង់ត្រឡប់ទៅកាន់ព្រះនិវេសន៍របស់ព្រះអង្គវិញ ។

[ ២០ ] លំដាប់នោះលុះរាត្រីអស់ហើយ ព្រះបាទអង្គតិទ្រង់ប្រជុំពួកអាមាត្យក្នុងទីជាទីបម្រើហើយត្រាស់ព្រះតម្រាស់ដូច្នេះថា អាមាត្យទាំងឡាយចូរចាត់ចែងកាមទាំងឡាយ ក្នុងវិមានចន្ទក៍របស់យើងសព្វៗកាល នាកាលសេចក្តីកំបាំងនិងសេចក្តីជាក់ស្តែងកើតឡើងហើយ អាមាត្យឯណានីមួយកុំមករកយើងឡើយ ។ អាមាត្យឈ្មោះវិជយៈ ១ ឈ្មោះសុនាមៈ ១ អលាត

សេនាបតី ១ ទាំង ៣ នេះជាអ្នកឈ្លាសវៃក្នុងវោហារ ( រាជកិច្ច ) ចូរអង្គុយក្នុងទីជាទីវិនិច្ឆ័យសេចក្ដីនេះចុះ ។ ព្រះបាទវិទេហៈលុះទ្រង់ត្រាស់ព្រះតម្រាស់នេះហើយ ក៏សំគាល់កាមទាំងឡាយដ៏ច្រើន ឈប់ខ្វល់ខ្វាយចំពោះព្រាហ្មណ៍គហបតីនិងសេចក្ដីណានីមួយ ។

[ ២១ ] តាំងពីកាលនោះមករហូតដល់រាត្រី ១៤ នាងរាជកញ្ញារបស់ព្រះបាទវិទេហៈព្រះនាមរុចាជាធីតាបង្កើត ជាទីស្រឡាញ់ បានពោលចំពោះមេនំថា នៃម៉ែ សូមម៉ែប្រដាប់ស្អិតស្អាងខ្ញុំ ទាំងពួកស្ត្រីជាសម្លាញ់របស់ខ្ញុំក៏ចូរប្រដាប់ស្អិតស្អាងដែរ ស្អែកជាថ្ងៃទី ១៥ ជាថ្ងៃទិព្វខ្ញុំនឹងទៅកាន់សំណាក់បិតា ។ ស្ត្រីទាំងឡាយបាននាំមកនូវផ្កាកម្រង ខ្លឹមចន្ទន៍ កែវមណី ស័ង្ខ កែវមុក្ដាមានតម្លៃដ៏ច្រើននិងសំពត់អម្ពរណ៍មានពណ៌ក្រហមផ្សេងៗថ្វាយព្រះរាជកញ្ញានោះ ។ ពួកស្ត្រីដ៏ច្រើនបានចោមរោមព្រះរាជកញ្ញាព្រះនាមរុចានោះ ដែលមានសម្បុរដ៏រុងរឿងកំពុងគង់លើតាំងជាវិការៈនៃមាស ។

[ ២២ ] ឯនាងរុចានោះ ស្អិតស្អាងដោយគ្រឿងអាភរណៈទាំងពួងឋិតនៅក្នុងកណ្ដាលនៃពួកស្ត្រីជាសម្លាញ់បានចូលទៅកាន់វិមានចន្ទក៍ ដូចជាផ្លេកបន្ទោរអាស្រ័យមេឃ ។ លុះចូលទៅដល់ហើយក៏ថ្វាយបង្គំព្រះបាទវិទេហៈដែលទ្រង់ត្រេកអរក្នុងវិន័យហើយយាងចូលទៅគង់លើតាំងដែលវិចិត្រដោយមាសក្នុងទីសមគួរ ។

[ ២៣ ] ព្រះបាទវិទេហៈ ទ្រង់ទតឃើញការប្រជុំនោះដូចជាទីប្រជុំពួកស្ត្រីទេពអប្សរ ទើបត្រាស់ព្រះតម្រាស់នេះនឹងនាងរុចា ដែលឋិតនៅត្រង់

កណ្តាលនៃពួកស្ត្រីជាសម្លាញ់ថា នាងត្រេកអរក្នុងប្រាសាទ ស្រះបោក្ខរណីខាងក្នុងដែរឬ ពួកជនបាននាំមកនូវបង្អែមមានប្រការដ៏ច្រើនដល់នាងសព្វកាលដែរឬ ។ នាងទាំងឡាយជាកុមារីបានក្រងកម្រងផ្កាដ៏ច្រើន ជាស្ត្រីនៅលេងល្បែងត្រេកអរដោយសេចក្តីសប្បាយ បានធ្វើផ្ទះតូចៗទាំងឡាយផ្សេងៗគ្នាខ្វះដែរឬ ។ មួយទៀតនាងខ្វះខាតដោយវត្ថុអ្វី ជនទាំងឡាយបាននាំមកយ៉ាងឆាប់ដល់នាងដែរឬ ម្នាលនាងមានភក្ត្រផាត់លាបល្អ នាងចូរធ្វើតាមចិត្តចុះ សូម្បីរបស់ស្មើដោយព្រះចន្ទ្រក៏ឪពុកផ្តល់ឲ្យនាងដែរ ។

[ ២៤ ] នាងរុចាបានស្តាប់ព្រះរាជឱង្ការព្រះបាទវិទេហៈហើយ ទូលតបព្រះបិតាថា បពិត្រមហារាជ របស់ទាំងអស់នុ៎ះ ខ្ញុំម្ចាស់តែងបានក្នុងសំណាក់របស់ព្រះអង្គជាឥស្សរៈ ។ ស្អែកជាថ្ងៃទី ១៥ ជាទិព្វ សូមឲ្យពួកជននាំកហាបណៈមួយពាន់ ដល់ខ្ញុំម្ចាស់ៗនឹងឲ្យទានចំពោះវណិព្វកៈទាំងអស់តាមទំនងដែលខ្ញុំម្ចាស់ធ្លាប់ឲ្យហើយ ។

[ ២៥ ] ព្រះរាជាអង្គតិ ទ្រង់ព្រះសណ្តាប់ពាក្យនាងរុចាហើយ ទ្រង់ត្រាស់ថា ទ្រព្យដ៏ច្រើនឈ្មោះថានាងធ្វើឲ្យវិនាស ធ្វើឲ្យឥតប្រយោជន៍ ធ្វើឲ្យឥតផលហើយ ។ នាងរក្សាឧបោសថ មិនបរិភោគបាយទឹកជានិច្ច ឯបាយនិងទឹកដែលនាងមិនបរិភោគនេះជារបស់ទៀង បុណ្យមិនមានដល់បុគ្គលដែលមិនបរិភោគទេ ដូចយ៉ាងទាសៈឈ្មោះ វីជកៈ បានស្តាប់ភាសិតអចេលកៈជាកស្សបគោត្ត ក្នុងកាលនោះក៏ដកដង្ហើមចេញដ៏ក្តៅរឿយៗយំសម្រក់ទឹកភ្នែក ។ ម្នាលនាងរុចា នាងកាលរស់នៅដរាបណា កុំអត់បាយឡើយម្នាលនាងដ៏

ចម្រើន បរលោកមិនមានទេព្រោះហេតុអ្វីនាងប្រឹងឲ្យលំបាកឥតប្រយោជន៍ ។

[ ២៦ ] នាងរុចាមានសម្បុរដ៏រុងរឿង បានស្តាប់ព្រះបន្ទូលព្រះបាទវិទេហៈ កាលដឹងធម៌ខាងដើមនិងខាងចុងទើបពោលពាក្យនេះនឹងបិតាថា ពីដើមខ្ញុំម្ចាស់គ្រាន់តែឮ ( ថ្ងៃនេះ ) រឿងនេះខ្ញុំម្ចាស់ឃើញជាក់ច្បាស់ហើយថា បុគ្គលណាសេពគប់នឹងជនពាល បុគ្គលនោះទៅជាបុគ្គលពាលដែរ ។ ដ្បិតថាបុគ្គលវង្វេងអាស្រ័យនឹងបុគ្គលវង្វេង រមែងដល់នូវសេចក្តីវង្វេងដ៏លើសលុប អលាតសេនាបតីនិងទាសៈឈ្មោះវីជកៈគួរវង្វេងទៅចុះ ( តែព្រះអង្គកុំវង្វេងឡើយ ) ។

[ ២៧ ] បពិត្រព្រះសម្មតិទេព ព្រះអង្គប្រកបដោយបញ្ញា ជាអ្នកប្រាជ្ញឈ្លាសក្នុងសេចក្តីចម្រើនហេតុអ្វីព្រះអង្គប្រហែលនឹងពួកជនពាលហើយលុះទិដ្ឋិថោកទាប ។ ប្រសិនបើសត្វបរិសុទ្ធដោយគន្លងនៃសំសារបព្វជ្ជានៃអចេលកៈឈ្មោះគុណៈក៏មិនមានប្រយោជន៍ដែរ អចេលកៈឈ្មោះគុណៈជាអ្នកវង្វេងដោយមោហៈ ដល់នូវភាពជាអ្នកអាក្រាតដូចជាសត្វកណ្តូបទម្លាក់ខ្លួនក្នុងភ្លើងកំពុងឆេះ ។ ជនទាំងឡាយច្រើននាក់កាលមិនដឹងត្រូវអចេលកៈឈ្មោះគុណៈទូន្មានហើយក្នុងកាលមុនថា សេចក្តីបរិសុទ្ធព្រោះសំសារ ដូច្នេះក៏បដិសេធនូវកម្មចេញ ប្រយោជន៍ដែលជនកាន់មិនល្អហើយក្នុងកាលមុនក៏ទៅជាទោសដូចត្រីដែលលួចអំពីសន្ទូចបានដោយក្រ ។

[ ២៨ ] បពិត្រមហារាជ ខ្ញុំម្ចាស់នឹងធ្វើឧបមាថ្វាយព្រះអង្គ ដើម្បីប្រយោជន៍ដល់ព្រះអង្គ ព្រោះថាបណ្ឌិតពួកខ្លះក្នុងលោកនេះ រមែងដឹងសេចក្តី

ដោយពាក្យឧបមា ។ ទូករបស់ពួកឈ្មួញផ្ទុកការៈធ្ងន់ហួសប្រមាណនាំទៅនូវការៈធ្ងន់លើសលុបរមែងលិចក្នុងសមុទ្ទយ៉ាងណា នរជនកាលសន្សំបាបបន្តិចម្តងៗឈ្មោះថាជាអ្នកកាន់យកនូវការៈដ៏លើសលុប រមែងលិចក្នុងនរកយ៉ាងនោះដែរ ។ បពិត្រព្រះអង្គជាម្ចាស់ផែនដី ការៈដ៏ធ្ងន់របស់អលាតសេនាបតីមិនទាន់ពេញប្រៀបនៅឡើយ អលាតសេនាបតីទៅកាន់ទុគ្គតិព្រោះបាបណា គាត់នៅតែសន្សំបាបនោះ ។ បពិត្រព្រះអង្គជាម្ចាស់ផែនដី អលាតសេនាបតីបានធ្វើបុណ្យហើយក្នុងកាលមុន បពិត្រព្រះសម្មតិទេព ឯអលាតសេនាបតីនុ៎ះ បានសុខព្រោះអានិសង្សបុណ្យដែលគាត់ធ្វើហើយក្នុងកាលមុននោះឯង ។ បុណ្យនោះរបស់គាត់អស់ហើយបានជាគាត់ត្រេកអរក្នុងអកុសលកម្ម លះបង់នូវផ្លូវត្រង់ហើយដើរទៅតាមផ្លូវវៀចវិញ ។ កាលវត្ថុធ្ងន់ដែលគេដាក់ក្នុងមណ្ឌលនៃជញ្ជីង ជញ្ជីងក៏បះ កាលបើការៈគេដាក់ចេញហើយក្បាលជញ្ជីងក៏ងើបឡើងយ៉ាងណាមិញ ។ នរជនកាលសន្សំបុណ្យសូម្បីបន្តិចម្តងៗដូចជាទាសៈឈ្មោះវីជកៈកាលប្រាថ្នាឋានសួគ៌ត្រេកអរក្នុងកុសលកម្មមានផលល្អក៏យ៉ាងនោះដែរ ។ បាបណាដែលវីជកៈនោះបានធ្វើទុកក្នុងកាលមុន ទាសៈឈ្មោះវីជកៈឃើញទុក្ខណាចំពោះខ្លួនក្នុងថ្ងៃនេះព្រោះគាត់បានធ្វើបាបក្នុងជាតិមុន បានជាគាត់ទទួលទុក្ខនោះ ។ បាបរបស់គាត់នោះអស់បានជាគាត់ត្រេកអរក្នុងវិន័យ សូមព្រះអង្គកុំគប់រកអចេលកៈឈ្មោះ គុណៈជាកស្សបគោត្តហើយមកកាន់ផ្លូវខុសឡើយ ។

[ ២៩ ] បពិត្រព្រះរាជា បុគ្គលគប់រកបុគ្គលណា ៗ ជាសប្បុរសឬ

ជាអសប្បុរស មានសីលឬមិនមានសីល រមែងលុះនូវអំណាចនៃបុគ្គលនោះៗ ឯង ។ បុគ្គលធ្វើបុគ្គលបែបណាឲ្យជាមិត្តផង សេពបុគ្គលបែបណាផង បុគ្គលនោះរមែងប្រាកដដូចបុគ្គលនោះដែរ ព្រោះថាការនៅរួមគ្នារមែងប្រាកដ ដូច្នោះ ។ អាចារ្យដែលកូនសិស្សពាល់ត្រូវហើយរមែងប្រឡាក់កូនសិស្ស ដែលមិនទាន់ប្រឡាក់ កាលកូនសិស្សពាល់ត្រូវអាចារ្យដទៃ រមែងប្រឡាក់ ដូចព្រួញលាបថ្នាំពិស ប្រឡាក់បំពង់ព្រួញដូច្នោះ អ្នកប្រាជ្ញមិនត្រូវមានសម្លាញ់ ដ៏លាមក ព្រោះខ្លាចអំពីការប្រឡាក់ ។ ជនណាខ្ចប់ត្រីស្អុយដោយស្បូវភ្លាំង ស្បូវភ្លាំងរបស់ជននោះទៅជាមានក្លិនស្អុយផ្សាយទៅយ៉ាងណាមិញ ការសេព នឹងបុគ្គលពាលក៏យ៉ាងនោះដែរ ។ ជនណាខ្ចប់ក្រស្នាដោយស្លឹកឈើ ស្លឹកឈើ របស់ជននោះ ទៅជាមានក្លិនក្រអូបផ្សាយទៅយ៉ាងណាមិញ ការសេពបុគ្គល ជាអ្នកប្រាជ្ញក៏យ៉ាងនោះដែរ ។ ព្រោះហេតុនោះបណ្ឌិតកាលដឹងច្បាស់នូវភាពនៃ ខ្លួនដែលប្រែប្រួលបាន ដូចជាកញ្ចប់នៃស្លឹកឈើ មិនត្រូវសេពអសប្បុរសទេ ត្រូវសេពតែពួកសប្បុរស ព្រោះថាពួកអសប្បុរសតែងនាំទៅកាន់នរក ពួក សប្បុរសតែងឲ្យដល់សុគតិ ។

[ ៣០ ] ខ្ញុំម្ចាស់បានរឭកឃើញនូវភាពនៃខ្លួនដែលអន្ទោលទៅមកអស់ ៧ ជាតិមកហើយនិង ៧ ជាតិ ( ទៀត ) ដែលខ្ញុំម្ចាស់នឹងច្យុតចាកអត្តភាព នេះទៅក្នុងអនាគត ។ បពិត្រព្រះអង្គជាធំជាងជន ក្នុងកាលមុនជាតិណា របស់ខ្ញុំម្ចាស់ជាគម្រប់ ៧ ( ក្នុងជាតិនោះ ) ខ្ញុំម្ចាស់បានកើតជាកូនជាងមាស ក្នុងរាជគហបុរីក្នុងដែនមគធៈ ។ បាបដ៏ច្រើនខ្ញុំម្ចាស់បានធ្វើហើយ ព្រោះ

អាស្រ័យសម្លាញ់ដ៏លាមក ខ្ញុំម្ចាស់ទាំងពីរនាក់កាលបៀតបៀនប្រពន្ធនៃបុគ្គលដទៃ ប្រព្រឹត្ត ( ខ្លួន ) ដូចមិនស្លាប់ ។ អំពើនោះកប់នៅដូចភ្លើងដែលកប់ក្នុងផេះ បពិត្រមហារាជ តទៅខ្ញុំម្ចាស់បានកើតក្នុងវិសកូមិ ក្រុងកោសម្ពីជាកូនប្រុសតែមួយមានគេធ្វើសក្ការបូជាជានិច្ច ក្នុងត្រកូលសេដ្ឋីជាត្រកូលស្តុកស្តម្ភសម្បូរមានទ្រព្យច្រើនដោយកម្មដទៃ ។ ក្នុងកាលនោះខ្ញុំម្ចាស់ បានសេពគប់មិត្តសម្លាញ់ អ្នកត្រេកអរក្នុងកុសល ជាបណ្ឌិតអ្នកបរិបូណ៌ដោយការចេះដឹងមិត្តនោះបានតម្កល់ខ្ញុំម្ចាស់ក្នុងអំពើជាប្រយោជន៍ ។ ខ្ញុំម្ចាស់បានរក្សាឧបោសថអស់រាត្រីទី ១៤ និងទី ១៥ ដ៏ច្រើនកម្មនោះនៅកប់ដូចកំណប់ក្នុងទឹក ។ ក៏បណ្តាបាបកម្មទាំងឡាយបរទារកកម្មណាដែល ខ្ញុំម្ចាស់បានធ្វើហើយក្នុងដែនមគធៈ ផល ( នៃបរទារកកម្ម ) នោះផ្តល់ក្នុងកាលជាខាងក្រោយ ដូចបុគ្គលអ្នកបរិភោគភោជនដែលលាយដោយពិសដ៏កាចដូច្នោះ ។ បពិត្រព្រះបាទវិទេហៈ ខ្ញុំម្ចាស់ច្យុតចាកត្រកូលសេដ្ឋីនោះមក ក៏ឆេះក្នុងរោរុពនរកអស់កាលដ៏យូរដោយកម្មរបស់ខ្លួន ខ្ញុំម្ចាស់កាលរឭកឃើញទុក្ខក្នុងនរកនោះរមែងមិនបានសេចក្តីសុខ ។ ខ្ញុំម្ចាស់ញ៉ាំងសេចក្តីទុក្ខដ៏ច្រើនឲ្យអស់ទៅក្នុងរោរុព-នរកនោះអស់ពួកនៃឆ្នាំដ៏ច្រើន បានមកកើតជាពពែ គេក្រៀវអណ្ឌៈ ក្នុងក្រុងភិន្នាគតៈ ។

[ ៣១ ] ខ្ញុំម្ចាស់ បាននាំពួកកូនអាមាត្យដោយខ្នងផង ដោយរថផង ( ការឆេះក្នុងរោរុពនរកជាដើមនោះ ) ជាផលកម្ម គឺការគប់រកប្រពន្ធបុគ្គលដទៃនៃខ្ញុំម្ចាស់នោះ ។ បពិត្រព្រះបាទវិទេហៈ ខ្ញុំម្ចាស់ច្យុតចាកអត្តភាពនោះ

ហើយក៏កើតជាស្វាក្នុងព្រៃធំ ត្រូវស្វាជាម្ចាស់ហ្វូងជាសត្វឃ្មើសឃ្មង ខាំកាត់ពូជចេញ នេះជាផលកម្ម គឺការគប់រកប្រពន្ធបុគ្គលដទៃនៃខ្ញុំម្ចាស់នោះ ។ បពិត្រព្រះបាទវិទេហៈ ខ្ញុំម្ចាស់ច្យុតចាកអត្តភាពនោះហើយ បានកើតជាគោក្នុងដែនទសន្នៈ ជាគោដ៏ចម្រើន មានសន្ទុះលឿនត្រូវគេក្រៀវ ខ្ញុំម្ចាស់បានអូសរទេះអស់កាលដ៏យូរ នេះជាផលកម្ម គឺការគប់រកប្រពន្ធអ្នកដទៃនៃខ្ញុំម្ចាស់នោះ ។ បពិត្រព្រះបាទវិទេហៈ ខ្ញុំម្ចាស់ច្យុតចាកអត្តភាពនោះហើយបានមក ( កើត ) ក្នុងត្រកូលក្នុងដែនវជ្ជី ក្នុងភាពជាមនុស្សដែលគេបានដោយក្រ តែមិនមែនស្រី មិនមែនប្រុស ( ខ្ទើយ ) នេះជាផលកម្ម គឺការគប់រកប្រពន្ធបុគ្គលដទៃនៃខ្ញុំម្ចាស់នោះ ។ បពិត្រព្រះបាទវិទេហៈ ខ្ញុំម្ចាស់ច្យុតចាកអត្តភាពនោះហើយបានកើតជាស្រីអប្សរ មានវណ្ណៈគួរប្រាថ្នាក្នុងនន្ទនវនឧទ្យានក្នុងឋានតាវត្តិង្ស ។ មានសំពត់និងគ្រឿងអាភរណៈដ៏វិចិត្រ ពាក់កុណ្ឌលជាវិការៈនៃកែវមណី ជាស្រីឈ្លាសក្នុងការរាំនិងច្រៀង ជាស្រីបម្រើទេវរាជឈ្មោះសក្កៈ ។ បពិត្រព្រះបាទវិទេហៈ ខ្ញុំម្ចាស់ឋិតនៅក្នុងឋានតាវត្តិង្សនោះរឭកឃើញជាតិ ៧ ដែលខ្ញុំម្ចាស់នឹងទៅក្នុងអនាគត ។ កុសលណាដែលខ្ញុំម្ចាស់បានធ្វើហើយក្នុងក្រុងកោសម្ពី កុសលនោះតាមមកឲ្យផល ខ្ញុំម្ចាស់ច្យុតចាកអត្តភាពជាទេពធីតាទុះនឹងអន្ទោលទៅហើយក្នុងទេវលោកនិងមនុស្សលោក ។ បពិត្រមហារាជ ខ្ញុំម្ចាស់ដែលគេធ្វើសក្ការបូជាជានិច្ចអស់ជាតិទាំងឡាយ ៧ តែខ្ញុំម្ចាស់ នឹងមិនរួចហើយចាកភាពជាស្រីអស់គតិ ៦ នេះ ។ បពិត្រព្រះសម្មតិទេព ក្នុងគតិជាគម្រប់ ៧ ខ្ញុំម្ចាស់នឹងកើតជាទេវតាប្រុស ជាទេវបុត្ត

មានឫទ្ធិច្រើនដ៏ឧត្តមក្នុងពួកទេវតា ។ ក៏ក្នុងថ្ងៃនេះនាងទេពកញ្ញាទាំងឡាយនៅកំពុងតែក្រងផ្កាជាផ្កាំងក្នុងនន្ទនវ័ន ទេវបុត្តឈ្មោះជវៈ ( ជាស្វាមីខ្ញុំម្ចាស់នោះ ) កំពុងទទួលកម្រងផ្កាដើម្បីខ្ញុំម្ចាស់ ។ ១៦ ឆ្នាំក្នុងជាតិរបស់ខ្ញុំម្ចាស់នេះហាក់ដូចជាកាលទិព្វនោះមួយរំពេច មួយយប់មួយថ្ងៃទិព្វនោះជា ១០០ ឆ្នាំរបស់មនុស្ស ។ កម្មទាំងឡាយរមែងអន្ទោលតាមអស់ជាតិជាអសង្ខេយ្យដូច្នេះឯង ដ្បិតថាកម្មល្អក្តី លាមកក្តីមិនវិនាសទេ ។

[ ៣២ ] បុរសណា ប្រាថ្នាឲ្យបានជាភេទបុរសរាល់ៗជាតិ ត្រូវវៀរប្រពន្ធបុគ្គលដទៃ ដូចជាបុគ្គលអ្នកមានជើងលាងហើយវៀរបង់នូវភក់ដូច្នោះ ។ ស្ត្រីណាប្រាថ្នាឲ្យបានជាបុរសរាល់ៗជាតិ ត្រូវគោរពប្តីដូចជាពួកស្រីអប្សរជាអ្នកបម្រើគោរពព្រះឥន្ទដូច្នោះ ។ បុគ្គលណា ចង់បានភោគៈជាទិព្វ អាយុយសនិងសុខជាទិព្វ ត្រូវវៀរបង់អំពើបាបទាំងឡាយ ប្រព្រឹត្តសុចរិតធម៌ ៣ យ៉ាង ។ ស្ត្រីក្តី បុរសក្តី ជាអ្នកមិនធ្វេសប្រហែសដោយកាយវាចាចិត្តមានប្រាជ្ញាជាគ្រឿងពិចារណាឈ្មោះថាកើតមកដើម្បីប្រយោជន៍របស់ខ្លួន ។ ពួកមនុស្សណានីមួយក្នុងជីវលោកជាអ្នកមានយស មានភោគៈបរិបូណ៌ទាំងអស់ពួកមនុស្សទាំងនោះ បានសន្សំកម្មល្អហើយក្នុងកាលមុន ដោយឥតសង្ស័យសត្វទាំងអស់ជាច្រើន សុទ្ធតែមានកម្មជារបស់ខ្លួន ។ បពិត្រព្រះសម្មតិទេពសូមព្រះអង្គទ្រង់ត្រិះរិះរឿយៗដោយព្រះអង្គឯងចុះ បពិត្រព្រះអង្គជាធំជាងជនស្ត្រីទាំងឡាយណារបស់ព្រះអង្គ ប្រាកដស្មើដោយស្រីអប្សរ មានខ្លួនប្រដាប់ហើយបិទបាំងដោយបណ្តាញមាស តើស្ត្រីទាំងនេះរបស់ព្រះអង្គ មានអ្វីជា

ហេតុ ។ ព្រះរាជកញ្ញាព្រះនាមរុចាញុំាងព្រះបាទអង្គតិជាព្រះបិតាឲ្យត្រេកអរ យ៉ាងនេះដូច្នេះឯង នាងជាអ្នកមានវត្តល្អបានប្រាប់ផ្លូវ ( សុគតិ ) ដល់ព្រះបិតា ( ដូចបុគ្គលប្រាប់ផ្លូវ ) ដល់មនុស្សវង្វេង នាងបានសំដែងសុចរិតធម៌ ។

[ ៣៣ ] គ្រានោះ នារទព្រហ្មមកពីព្រហ្មលោក មកកាន់គន្លងជារបស់មនុស្សប្រមើលមើលជម្ពូទ្វីប ក៏បានឃើញព្រះបាទអង្គតិ ។ លំដាប់នោះនារទព្រហ្មឋិតនៅត្រង់អាកាសក្នុងប្រាសាទខាងមុខនៃព្រះបាទវិទេហៈ នាងរុចាបានឃើញនារទព្រហ្មនោះ ដែលមកដល់ហើយ ក៏ថ្វាយបង្គំនារទព្រហ្មដែលដំណែងខ្លួនជាឥសី ។

[ ៣៤ ] គ្រានោះព្រះរាជា មានព្រះហឫទ័យតក់ស្លុត ក៏ចុះអំពីអាសនៈហើយសាកសួរនារទព្រហ្ម ទើបត្រាស់ព្រះបន្ទូលដូច្នេះថា លោកមានវណ្ណៈដូចទេវតា ញុំាងទិសទាំងអស់ឲ្យភ្លឺដូចព្រះចន្ទ តើទើបនឹងមកអំពីទីណា យើងសួរហើយលោកចូរប្រាប់នាមនិងគោត្ត មនុស្សទាំងឡាយក្នុងមនុស្សលោកតើគេស្គាល់ដូចម្តេចបាន ។

[ ៣៥ ] ( នារទព្រហ្ម... ) អាត្មាភាព ទើបនឹងមកអំពីទេវលោកក្នុងកាលឥឡូវនេះ ញុំាងទិសទាំងអស់ឲ្យភ្លឺដូចព្រះចន្ទ អាត្មាភាពដែលព្រះអង្គសួរហើយនឹងទូលនាមនិងគោត្តថា មនុស្សទាំងឡាយស្គាល់អាត្មាភាពថាឈ្មោះនារទៈ ជាកស្សបគោត្ត ។

[ ៣៦ ] ( ព្រះរាជា... ) សណ្ឋានរបស់លោក ប្រាកដយ៉ាងណាផង

លោកកំពុងដើរក្តី កំពុងឈរក្តី ពួជ៏អាកាសផង ( នេះ ) មានសភាពជាអស្ចារ្យ បពិត្រនារទ: ខ្ញុំសួរសេចក្តីនេះនឹងលោក តើឫទ្ធិរបស់លោកនេះមានដោយហេតុអ្វី ។

[ ៣៧ ] ( នារទព្រហ្ម... ) សច្ច: ១ ធម៌ ១ ទម: ១ ចាគ: ១ គុណធម៌នេះ អាត្មាភាពបានសាងមកហើយអំពីជាតិមុន អាត្មាភាពមានសន្ទុះចិត្តទៅតាមប្រាថ្នាបានព្រោះធម៌ដែលអាត្មាភាពសេពល្អហើយទាំងនោះឯង ។

[ ៣៨ ] ( ព្រះរាជា... ) ឥឡូវនេះ លោកប្រាប់ការសម្រេចនៃបុណ្យជារបស់អស្ចារ្យហើយ បពិត្រនារទ: ប្រសិនបើដូចជាលោកពោលយ៉ាងនេះមែន ខ្ញុំសូមសួរសេចក្តីនេះនឹងលោកទៀត បើខ្ញុំសួរហើយសូមលោកឆ្លើយឲ្យប្រពៃចុះ ។

[ ៣៩ ] ( នារទព្រហ្ម... ) បពិត្រព្រះរាជា ជាភូមិបាល ព្រះអង្គធ្វើសេចក្តីសង្ស័យណាសូមទ្រង់សួរអាត្មាភាពចុះ អាត្មាភាពជាប្រយោជន៍របស់ព្រះអង្គហើយ អាត្មាភាពនឹងញ៉ាំងព្រះអង្គឲ្យដល់នូវភាពជាអ្នកមិនមានសេចក្តីសង្ស័យដោយន័យ ដោយញាណនិងដោយហេតុទាំងឡាយ ។

[ ៤០ ] ( ព្រះរាជា... ) បពិត្រនារទ: ខ្ញុំសូមសួរសេចក្តីនេះនឹងលោក បពិត្រនារទ: ខ្ញុំសួរហើយ លោកកុំពោលមុសាវាទឡើយ នរជនបានសួរថា ទេវតាមានឬ មាតាបិតាមានឬ បរលោកមានឬ ។

[ ៤១ ] ( នារទព្រហ្ម... ) នរជនបានពោលថា ទេវតាមាន មាតាបិតាមាន បរលោកមាន ពួកជនជាអ្នកជាប់ក្នុងកាម ជាអ្នកវង្វេងប្រកបដោយ

មោហៈរមែងមិនបានដឹងនូវបរលោកឡើយ ។

[ ៤២ ] ( ព្រះរាជា... ) បពិត្រនារទៈ ប្រសិនបើលោកជឿថា លំនៅនៃជនទាំងឡាយដែលស្លាប់ទៅហើយមានក្នុងបរលោកមែន លោកចូរឲ្យកហាបណៈ ៥០០ ដល់ខ្ញុំក្នុងលោកនេះចុះ ខ្ញុំនឹងសងកហាបណៈជា ១ ពាន់ដល់លោកក្នុងបរលោកវិញ ។

[ ៤៣ ] ( នារទព្រហ្ម... ) ប្រសិនបើយើងដឹង ( នូវអ្នកដ៏ចម្រើន ) ថាមានសីល ជាអ្នកដឹងនូវពាក្យស្តម យើងនឹងឲ្យកហាបណៈ ៥០០ ដល់អ្នកដ៏ចម្រើន ប៉ុន្តែបើអ្នកដ៏ចម្រើននោះជាមនុស្សអាក្រក់នៅក្នុងនរក តើបុគ្គលណានឹងទារកហាបណៈ ១ ពាន់ក្នុងបរលោកបាន ។ សូម្បីក្នុងលោកនេះបុគ្គលណាមិនមានធម៌ជាប្រក្រតី មានមារយាទដ៏លាមក ជាអ្នកខ្ជិលច្រអូស មានការងារអាក្រក់ ពួកបណ្ឌិតក៏មិនឲ្យបុគ្គលនោះបុលទ្រព្យទេព្រោះថា ការបាន ( ទ្រព្យ ) អំពីបុគ្គលមានប្រការដូច្នោះមិនមានឡើយ ។ ពួកមនុស្សដឹងនូវបុរសថាជាអ្នកប៉ិនប្រសប់ មានព្យាយាម មានសីល ជាអ្នកដឹងពាក្យស្តម រមែងអញ្ជើញខ្លួនឯងដោយភោគៈទាំងឡាយថា អ្នកធ្វើការងារហើយគប្បីសងយើងវិញ ។

[ ៤៤ ] បពិត្រព្រះរាជា បើព្រះអង្គច្យុតចាកអត្តភាពនេះទៅនឹងទតឃើញខ្លួនព្រះអង្គដែលហ្វូងក្អែកកំពុងចឹកជញ្ជែងក្នុងនរកនោះ ព្រះអង្គគង់ក្នុងនរកដែលហ្វូងក្អែក ត្មាត និងឆ្កែកំពុងទំពាស៊ី មានខ្លួនជុះជ្លាយកំពុងហូរឈាម តើបុគ្គលណានឹងទៅទារកហាបណៈ ១ ពាន់ក្នុងបរលោកបាន ។

[ ៤៥ ] សេចក្តីងងឹតខ្លាំងរមែងមានក្នុងនរកនោះ ព្រះចន្ទ និងព្រះអាទិត្យក៏មិនមាន នរកនោះមានងងឹតដ៏ក្រាស់សព្វកាល មានសភាពគួរខ្លាច យប់ក៏មិនប្រាកដ ថ្ងៃក៏មិនប្រាកដ នរណាជាអ្នកត្រូវការដោយទ្រព្យគប្បីត្រាច់ទៅក្នុងនរកដូច្នោះបាន ។

[ ៤៦ ] ឆ្កែពពាលនិងឆ្កែលឿងទាំងពីរពួកមានកាយធាត់ធំ មានកម្លាំងតែងខាំស៊ីនូវសត្វដែលច្យុតអំពីលោកនេះ ធ្លាក់ទៅក្នុងបរលោកដោយធ្មេញជាវិការៈនៃដែក ។ ព្រះអង្គកាលនៅក្នុងនរកត្រូវពួកឆ្កែដ៏កាចអាក្រក់នាំមកនូវសេចក្តីទុក្ខខាំស៊ី មានខ្លួនជុះធ្លាយ កំពុងហូរឈាម តើនរណានឹងទារកហាបណៈ ១ ពាន់ក្នុងបរលោកបាន ។

[ ៤៧ ] ពួកនាយនិរយបាលឈ្មោះ កាលូបកាលៈ ក្នុងនរកគួរខ្លាចដ៏ពន្លឹក ជាបច្ចាមិត្តតែងសម្លាប់ឬចាក់នរជន ដែលធ្វើអំពើអាក្រក់ក្នុងកាលមុនដោយព្រួញនិងលំពែងដែលសំលៀងមុតហើយ ។ ព្រះអង្គកាលទៅក្នុងនរកត្រូវនាយនិរយបាលចាក់ត្រង់ក្លៀក ត្រង់ឆ្អឹងជំនីរ វះពោះ មានខ្លួនជុះធ្លាយមានឈាមហូរចេញ តើនរណានឹងទារកហាបណៈ ១ ពាន់ក្នុងបរលោកបាន ។

[ ៤៨ ] ក្នុងនរកនោះមានភ្លៀងបង្អុរចុះជាអាវុធផ្សេងៗ គឺលំពែង ព្រួញលំពែងស្នែងក្របីនិងច្បូក ភ្លៀងអាវុធមានអណ្តាតដូចជារងើកភ្លើងរមែងធ្លាក់លើក្បាល រន្ទះថ្មរមែងបង្អុរចុះលើបុគ្គលអ្នកមានអំពើអាក្រក់ ។ ក្នុងនរកនោះមានខ្យល់ដ៏ក្តៅដែលអត់ធន់បានដោយក្រ ព្រះអង្គដែលមានកម្មអាក្រក់រមែងមិនបានសេចក្តីសុខតិចតួចក្នុងនរកនោះឡើយ តើនរណានឹងទារកហាបណៈ

១ ពាន់ក្នុងបរលោកនឹងព្រះអង្គនោះ ដែលក្ដៅក្រហាយជានិច្ច ស៊ុះទៅមកមិនមានទីពួន ។

[ ៤៩ ] ព្រះអង្គស៊ុះទៅស៊ុះមកដែលនាយនិរយបាលទឹមក្នុងរថ ព្រះអង្គជាន់ផែនដីមានអណ្ដាតភ្លើងសន្ធោសន្ធៅ ដែលនាយនិរយបាលកំពុងចាក់ដោយជន្លួញ តើនរណានឹងទារកហាបណៈ ១ ពាន់ក្នុងបរលោកបាន ។

[ ៥០ ] ព្រះអង្គឡើងកាន់ភ្នំដ៏ដេរដាសដោយកាំបិត ជាភ្នំគួរស្ញើបមានអណ្ដាតភ្លើងប្រាលរន្ទាលធ្ងិនធ្ងៅគួរខ្លាច ព្រះអង្គមានខ្លួនដុះដាយ កំពុងហូរឈាម តើនរណានឹងទារកហាបណៈ ១ ពាន់ក្នុងបរលោកបាន ។

[ ៥១ ] ព្រះអង្គឡើងកាន់គំនររងើកភ្លើងប្រាកដស្មើដោយភ្នំដ៏ប្រាលធ្លៅគួរខ្លាច មានខ្លួនឆេះសព្វ ជាសត្វកំព្រាទួញយំ តើនរណានឹងទារកហាបណៈ ១ ពាន់ក្នុងបរលោកបាន ។

[ ៥២ ] ដើមឈើដ៏ខ្ពស់ស្មើនឹងពពក វិចិត្រដោយបន្លាដ៏មុត ជាវិការៈនៃដែក ជាបន្លាផឹកឈាមរបស់នរជន ។ ពួកស្ត្រីនិងបុរសដែលក្បត់ប្រពន្ធនៃបុគ្គលដទៃត្រូវពួកនាយនិរយបាលមានដាវក្នុងដៃជាអ្នកធ្វើតាមពាក្យរបស់យមរាជចាក់ហើយ រមែងឡើងដើមឈើនោះ ។ ព្រះអង្គនឹងឡើងដើមរកាក្នុងនរក មានកាយរាត់រាយប្រឡាក់ដោយឈាម មានស្បែករបេក ក្ដៅក្រហាយជានិច្ច មានវេទនាដ៏ខ្លាំង ។ ដកដង្ហើមក្ដៅរឿយៗមានកំហុសព្រោះបុព្វកម្មមានខ្លួនរបេកស្បែកនៅលើចុងរកា តើនរណានឹងទារទ្រព្យនោះនឹងព្រះអង្គបាន ។

[ ៥៣ ] ដើមឈើខ្ពស់ស្មើនឹងពពក វិចិត្រដោយស្លឹកជាដាវ ជាវិការៈនៃដែកដ៏មុត ជាស្លឹកផឹកឈាមនៃនរជន ។ ព្រះអង្គនឹងឡើងដើមរកាមានស្លឹកជាដាវ ត្រូវនាយនិរយបាលកាប់ដោយដាវដ៏មុត មានខ្លួនធ្លុះធ្លាយកំពុងហូរឈាម តើនរណានឹងទារកហាបណៈ ១ ពាន់ក្នុងបរលោកបាន ។

[ ៥៤ ] ព្រះអង្គ នឹងដើរចេញអំពីនរកមានដើមរកា មានស្លឹកជាដាវនោះហើយ ក៏ធ្លាក់ទៅក្នុងស្ទឹងនរកឈ្មោះវេត្តរណី តើនរណានឹងទារទ្រព្យនោះនឹងព្រះអង្គបាន ។

[ ៥៥ ] ស្ទឹងនរកឈ្មោះវេត្តរណីដ៏កាច មានទឹកផ្សាក្តៅ ធ្ងន់បានដោយកម្រ ដ៏ដេរដាសដោយស្លឹកឈូកជាវិការៈនៃដែករមែងហូរទៅតាមស្លឹកដ៏មុត ។ ព្រះអង្គមានខ្លួនធ្លុះធ្លាយ ប្រឡាក់ដោយឈាម ដែលខ្សែទឹកហូរក្តួចទៅក្នុងស្ទឹងនរកឈ្មោះវេត្តរណីនោះ ជាស្ទឹងមិនមានអ្វីតោងទេ តើនរណានឹងទារទ្រព្យនោះនឹងព្រះអង្គបាន ។

[ ៥៦ ] ( ព្រះរាជា... ) ខ្ញុំញាប់ញ័រដូចជាដើមឈើបម្រុងបាក់ ខ្ញុំវង្វេងសញ្ញាមិនដឹងទិស ក្តៅក្រហាយរឿយៗព្រោះភ័យ ( នឹងបាបដែលខ្លួនធ្វើហើយ ) បពិត្រឥសី ភ័យដ៏ធំកើតឡើងដល់ខ្ញុំព្រោះបានស្តាប់គាថាដែលលោកសំដែងហើយ ។ បពិត្រឥសី សូមលោកជាទីពឹងរបស់ខ្ញុំដូចជាបុគ្គលកាលចុះទៅកាន់ទីពាក់កណ្តាលទឹកព្រោះកាយត្រូវភ្លើងកំពុងឆេះឬដូចជាកោះរបស់ពួកជនដែលធ្លាយសំពៅក្នុងអន្លង់ធំក្នុងមហាសមុទ្រ ឬក៏ដូចជាប្រទីបរបស់ពួកជនអ្នកទៅក្នុងទីងងឹត ។ បពិត្រឥសី សូមលោកប្រៀនប្រដៅអត្ថនិងធម៌ខ្ញុំ

ផង កំហុសខ្ញុំបានប្រព្រឹត្តកន្លងហើយអស់កាលយូរ បពិត្រនារទៈ សូមលោកប្រាប់ផ្លូវសេចក្ដីបរិសុទ្ធដល់ខ្ញុំ កុំឲ្យខ្ញុំធ្លាក់ទៅនរកឡើយ ។

[ ៥៧ ] ( នារទព្រហ្ម... ) ព្រះបាទធតរដ្ឋ ១ វេស្សាមិត្ត ១ អដ្ឋកៈ ១ យមទគ្គិ ១ ឧសិន្នរៈ ១ ( សិវិ ១ ) ព្រះរាជាទាំង ៦ អង្គនេះនិងពួកព្រះរាជដទៃ ជាអ្នកបម្រើសមណព្រាហ្មណ៍ទៅកាន់វិស័យឋានសួគ៌យ៉ាងណា ។ បពិត្រព្រះអង្គជាធំលើផែនដី ព្រះអង្គចូរវៀរអធម៌ហើយប្រព្រឹត្តធម៌យ៉ាងនោះចុះ ម្យ៉ាងទៀតពួករាជបុរសអ្នកកាន់យកបាយក្នុងប្រាសាទរបស់ព្រះអង្គក្ដី ក្នុងបុរីរបស់ព្រះអង្គក្ដីចូរឃោសនាថា នរណាឃ្លាន នរណាស្រេក នរណាចង់បានកម្រងផ្កា នរណាចង់បានគ្រឿងលាប នរណាអាក្រាត ចង់ស្លៀកដណ្ដប់សំពត់ជ្រលក់ពណ៌ផ្សេងៗ ។ នរណាចង់បាំងឆត្រដើរក្នុងផ្លូវ នរណាចង់បានស្បែកជើងដ៏ទន់ល្អ ពួករាជបុរសចូរឃោសនាក្នុងបុរីរបស់ព្រះអង្គរាល់ព្រឹករាល់ល្ងាចដូច្នេះឯង ។ សូមព្រះអង្គកុំទឹមគោនិងសេះជាសត្វចិញ្ចឹមចាស់ៗដូចក្នុងកាលមុនឡើយ ( សត្វណា ) មានកម្លាំងធ្វើឧបការៈច្រើនដល់ព្រះអង្គៗចូរប្រទានការរក្សា ( ដល់សត្វនោះ ) ផង ។

[ ៥៨ ] កាយរបស់ព្រះអង្គ ចូរសំគាល់ថាដូចរថ មានចិត្តជានាយសារថី ជាកាយរហ័សរហួន មានការមិនបៀតបៀនជាភ្លៅដែលគេសម្រេចល្អហើយ មានការចែករំលែកទានជាផ្លូវ មានការសង្រួមជើងជាខ្នងកង់ មានការសង្រួមដៃជាគ្រពង មានការសង្រួមផ្ទៃជាប្រេងលាប មានការសង្រួមវាចាជាស្ងួរមិនលាន់ឮ ។ មានពាក្យពិតជាអង្គនៃរថដ៏បរិបូណ៌ មានការមិន

ញុះញង់ជាដំណាប់ដ៏ល្អ មានវាចាពីរោះជាអង្គនៃរថមិនមានទោស គឺជាវលើង មានការពោលល្មមប្រមាណជាគ្រឿងចង ។ មានសទ្ធានិងអលោភៈជាគ្រឿងប្រដាប់រថ មានការបន្ទន់បន្ទាបនិងអញ្ជលីកម្មជាទូក មានការមិនរឹងត្អឹងជាចន្ទោលរថ មានការសង្រួមសីលជាព្រ័ត្រជ្រាម ។ មានការមិនក្រោធជាការមិនសណ្តក មានសុចរិតធម៌ជាឆត្រស មានពាហុសច្ចៈជាខ្សែចន្ទោល មានចិត្តតាំងនៅនឹងជាអាសនៈ មានការដឹងកាលជាឈើខ្លឹមដ៏វិចិត្រ មានសេចក្តីក្លៀវក្លាជាចន្ទល់ មានការប្រព្រឹត្តិបន្ទន់ខ្លួនជាខ្សែ មានការមិនមើលងាយជានឹមដ៏ស្រាល ។ មានចិត្តមិនរួញរាជាកម្រាល មានការសេពសេចក្តីចម្រើន ( ដោយបញ្ញា ) ជាអំបោស សតិរបស់ព្រះអង្គជាអ្នកប្រាជ្ញទុកជាជន្ទញ មានព្យាយាមដ៏មាំនិងការប្រកបជាខ្សែបរ ។ ចិត្តដែលទូន្មានល្អហើយរមែងទៅកាន់ផ្លូវ ( ដូចរថដែលទៅកាន់ផ្លូវត្រង់ ) ដោយសារសេះទាំងឡាយដែលនាយសារថីហ្វឹកហ្វឺនល្អហើយ ព្រោះសេចក្តីប្រាថ្នានិងសេចក្តីលោភជាផ្លូវខុស ការសង្រួមជាផ្លូវត្រង់ ។ បពិត្រព្រះរាជា កាលបើរថ គឺកាយ ( របស់ព្រះអង្គ ) ស្ទុះទៅក្នុងរូប សំឡេង រស ក្លិន តួបញ្ញាជាជន្ទញសម្រាប់គោះងខ្លួនព្រះអង្គជានាយសារថីក្នុងរថនោះ ។ បពិត្រព្រះរាជា ប្រសិនបើការប្រព្រឹត្តស្មើនិងសេចក្តីព្យាយាមដ៏មាំដោយយាន គឺកាយនោះ ការបង្ករសេចក្តីប្រាថ្នាគ្រប់យ៉ាងក៏កើតមាន សត្វមិនទៅកាន់នរកដោយដាច់ខាត ។

[ ៥៩ ] អលាតសេនាបតី គឺទេវទត្ត សុនាមអាមាត្យ គឺកទូជិ វិជយអាមាត្យ គឺសារីបុត្ត វីជកទាសៈ គឺមោគ្គល្លាន ។ អចេលកៈឈ្មោះគុណៈ

គឺសុនក្ខត្តលិច្ឆវីបុត្ត នាងរុចាណាបានញ៉ាំងព្រះរាជាឲ្យជ្រះថ្លានាងរុចានោះ គឺអានន្ទ ។ ព្រះរាជា ( អង្គតិ ) ដែលមានទិដ្ឋិអាក្រក់ក្នុងកាលនោះ គឺឧរុវេលកស្សប មហាព្រហ្ម គឺពោធិសត្វ អ្នកទាំងឡាយចូរចាំទុកនូវជាតកដូចសំដែងមកនេះ ។

## ចប់មហានារទកស្សបជាតកទី ៨ ។

# អដ្ឋកថា

# មហានារទកស្សប ជាតក

[ ១-៥៩ ] ព្រះសាស្ដាកាលគង់នៅក្នុងព្រៃឡោតជំទង់ ទ្រង់ប្រារព្ធដល់ការដែលទ្រង់ទូន្មានឧរុវេលកស្សបៈ ត្រាស់ធម្មទេសនានេះ មានពាក្យផ្ដើមថា **អហុ រាជា វិទេហានំ** ដូច្នេះ ។

នឹងពោលដោយពិស្ដារ ដូចតទៅនេះថា ក្នុងកាលដែលព្រះសាស្ដាទ្រង់ប្រកាសធម្មចក្រដ៏ប្រសើរ ទ្រង់ទូន្មានជដិល ៣ នាក់បងប្អូន មានឧរុវេលកស្សបជដិលជាដើមចោមរោមដោយបុរាណជដិល ១០០០ នាក់ ទ្រង់យាងទៅកាន់ឧទ្យានឡោតជំទង់ដើម្បីដោះនូវបេ្ដជ្ញាដែលទ្រង់បានសន្យាដល់ព្រះបាទពិម្ពិសារដែលជាស្ដេចផែនដីនៃមគធរដ្ឋ ។ ក្នុងកាលនោះព្រះបាទពិម្ពិសារស្ដេចផែនដីនៃមគធរដ្ឋមួយអន្លើដោយបរិស័ទប្រមាណ ១២ ម៉ឺន យាងមកថ្វាយបង្គំព្រះទសពលហើយគង់ប្រថាប់ ខណៈនោះព្រាហ្មណគហបតីក្នុងរាជបរិស័ទកើតបរិវិតក្កឡើងថា ឧរុវេលកស្សបៈប្រព្រឹត្តព្រហ្មចរិយៈក្នុងសម្នាក់ព្រះមហាសមណគោតម ឬព្រះមហាសមណគោតមប្រព្រឹត្តព្រហ្មចរិយៈក្នុងសម្នាក់ឧរុវេលកស្សបៈ ។

សម័យនោះព្រះមានព្រះភាគ ទ្រង់ជ្រាបបរិវិតក្កនៃចិត្តរបស់ពួកបរិស័ទទាំងនោះដោយព្រះហឫទ័យ ទើបទ្រង់ព្រះតម្រិះថានឹងត្រូវប្រកាសភាវៈដែលកស្សបៈមកបួសក្នុងសម្នាក់របស់តថាគតឲ្យជនទាំងនេះដឹង ដូច្នេះហើយទើបត្រាស់គាថានេះថា

អ្នកឯងនៅក្នុងឧរុវេលាប្រទេស ជាអ្នកប្រដៅពួកតាបស តើ
អ្នកឃើញអ្វីបានជាលះបង់ការបូជាភ្លើងចោលចេញ ។ ម្នាល
កស្សប តថាគតសួរសេចក្តីនេះនឹងអ្នក ការបូជាភ្លើងដែល
អ្នកលះបង់ហើយតើព្រោះហេតុអ្វី ។

ឯព្រះថេរៈក៏ជ្រាបពុទ្ធបំណងរបស់ព្រះសុគត ប្រាថ្នាសម្តែងហេតុ ទើបក្រាបទូលថា

ជនទាំងឡាយ តែងពោលសរសើរចំពោះនូវកាមទាំងឡាយ
គឺរូប សំឡេងព្រមទាំងរសផង នូវស្រីទាំងឡាយផងព្រោះ
ការបូជា ខ្ញុំព្រះអង្គដឹងថា កាមគុណមានរូបជាដើមនេះជា
គ្រឿងសៅហ្មងក្នុងឧបធិទាំងឡាយ ព្រោះហេតុដូច្នោះខ្ញុំព្រះអង្គ
មិនត្រេកអរក្នុងការបូជាធំនិងការបូជាតូច ( គឺការគោរពភ្លើង
រាល់ថ្ងៃ ) ។

កាលឧរុវេលកស្សបៈពោលគាថាដូច្នេះហើយ ដើម្បីប្រកាសភាវៈដែលខ្លួនជាពុទ្ធសាវ័ក ទើបឱនសីសៈលើខ្នងព្រះបាទារបស់ព្រះសាស្តាប្រកាសថា ព្រះមានព្រះភាគ ទ្រង់ជាសាស្តារបស់ខ្ញុំ ខ្ញុំជាសាវ័ករបស់ព្រះអង្គ ដូច្នេះហើយ ហោះឡើងទៅកាន់អាកាស ៧ ដង គឺលើកទី ១ កម្ពស់មួយដូវត្នោត លើកទី ២ កម្ពស់ពីរដូវត្នោត លើកទី ៣ កម្ពស់បីដូវត្នោតរហូតដល់លើកទី ៧ កម្ពស់ប្រាំពីរដូវត្នោត ហើយចុះមកថ្វាយបង្គំព្រះតថាគត អង្គុយក្នុងទីសមគួរនាចំណែកម្ខាង ។ មហាជនឃើញបាដិហារ្យដូច្នោះក៏បានពោលសរសើរគុណ

របស់ព្រះសាស្តាថា គួរអស្ចារ្យពិត ព្រះពុទ្ធមានអានុភាពច្រើន សូម្បីឧរុ-
វេលកស្សបដែលមានមិច្ឆាទិដ្ឋិដ៏មានកម្លាំងដល់ម៉្លេះ សម្គាល់ខ្លួនថាជាព្រះ
អរហន្ត ក៏ព្រះតថាគតទម្លាយសំណាញ់ គឺទិដ្ឋិហើយទូន្មានបាន ។

ព្រះមានព្រះភាគទ្រង់បានស្តាប់ដូច្នោះហើយទើបត្រាស់ថា ម្នាលឧបាសក
ទាំងឡាយ តថាគតដល់នូវសព្វញ្ញុតញ្ញាណ ទូន្មានឧរុវេលកស្សបៈនេះក្នុង
កាលឥឡូវនេះមិនអស្ចារ្យដូចក្នុងកាលមុនឡើយ ក្នុងកាលដែលតថាគតនៅ
មានរាគៈ ទោសៈ និងមោហៈ ជាព្រហ្មឈ្មោះនារទៈ ទម្លាយនូវបណ្តាញ
គឺទិដ្ឋិរបស់ឧរុវេលកស្សបៈធ្វើឲ្យអស់ព្យសន៍ទើបគួរអស្ចារ្យ ដូច្នេះហើយ
ទ្រង់តុណ្ហីភាព កាលបរិស័ទទូលអារាធនាទើបទ្រង់នាំអតីតនិទានមកសម្តែង
ដូចតទៅនេះថា

ក្នុងអតីតកាលមានព្រះរាជាមួយព្រះអង្គព្រះនាមថា ព្រះបាទអង្គតិរាជ
សោយរាជសម្បត្តិក្នុងនគរមិថិលាក្នុងវិទេហរដ្ឋ ទ្រង់តាំងនៅក្នុងធម៌ ជាធម្ម-
រាជា ទ្រង់មានព្រះរាជធីតាមួយអង្គព្រះនាមថា ព្រះនាងរុចារាជកុមារី មាន
រូបឆោមលោមពណ៌គួរមើល គួរសរសើរ មានបុណ្យច្រើនបានតាំងបណិធាន
ធ្វើសេចក្តីប្រាថ្នាទុកអស់សែននៃកប្ប ទើបបានមកកើតក្នុងផ្ទៃនៃអគ្គមហេសី
ឯព្រះទេវីក្រៅអំពីនោះ ១៦០០០ អង្គជាស្រីអារទាំងអស់ ដូច្នោះទើបព្រះ
នាងរុចារាជកុមារីនោះបានជាទីប្រោសប្រាណរបស់ព្រះរាជាពន់ពេក ទ្រង់រៀប
ចំសំពត់សាច់ម៉ដ្ឋក្រៃលែង ដែលមានតម្លៃកាត់ថ្លៃមិនបានមួយអន្ទើនឹងប្រអប់ផ្កា
២៥ ប្រអប់ដែលពេញទៅដោយបុប្ផជាតិច្រើនប្រភេទ ព្រះរាជទានដល់ព្រះ

រាជធីតារាល់ៗថ្ងៃ ដោយទ្រង់បំណងឲ្យព្រះរាជធីតាប្រដាប់ខ្លួនប្រាណដោយរបស់ទាំងនេះនិងរបស់សោយ គឺខាទនីយនិងភោជនីយដែលមានតម្លៃប្រមាណមិនបាន ។ រៀងរាល់កន្លះខែទ្រង់បានព្រះរាជទានទ្រព្យ ១០០០ ដល់ព្រះរាជធីតាដោយត្រាស់ថា ចំណែកនេះចូរកូនឲ្យទានចុះ ទ្រង់មានអាមាត្យ ៣ នាក់ គឺវិជយអាមាត្យ ១ សុនាមអាមាត្យ ១ អលាតអាមាត្យ ១ ។

លុះដល់រាត្រីពាក់កណ្ដាលខែកត្តិក ជាខែដែលផ្កាកុមុទរីកស្គុសស្គាយ ជាកាលដែលលេងមហោស្រព មហាជននាំគ្នាតាក់តែងព្រះនគរនិងខាងក្នុងព្រះរាជដ្ឋានទុកយ៉ាងល្អដូចទេវនគរ ។ ព្រះបាទអង្គតិរាជទ្រង់ស្រោចស្រង់លាបស្រឡាបព្រះកាយ ប្រដាប់គ្រឿងអលង្ការ សោយព្រះក្រយាហារស្រេចហើយគង់ប្រថាប់លើរាជអាសនៈ លើផ្ទៃមហាប្រាសាទក្បែរមាត់បង្អួច មានពួកអាមាត្យចោមរោម ទតមើលចន្ទមណ្ឌលដែលពុំមានរស្មី អណ្ដែតលើផ្ទៃនភាទើបមានរាជតម្រាស់សួរពួកអាមាត្យថា អ្នកដ៏ចម្រើនទាំងឡាយ រាត្រីដ៏បរិសុទ្ធបែបនេះគួរត្រេកអរហ្ន៎ ថ្ងៃនេះយើងគប្បីត្រេកអរដោយរឿងអ្វីល្អហ្ន៎ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហា** វីអាចិធមិឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសាន្ទូវព្រះគាថាដូច្នេះថា

*ព្រះរាជារបស់ពួកជនអ្នកនៅក្នុងដែនវិទេហៈ ជាក្សត្រទ្រង់ព្រះ*
*នាមអង្គតិមានយានច្រើន មានទ្រព្យច្រើន មានពួកពលមិន*

មានទីបំផុត ។ នៅពេលបឋមយាមដែលមិនទាន់កន្លងនៃរាត្រី
ជាគម្រប់ ១៥ ជាទីបំផុតនៃខែភ្លៀង ៤ ខែ ជាទីរីកនៃផ្កាកុមុទ
ព្រះអង្គ ទ្រង់ប្រជុំអាមាត្យទាំងឡាយជាបណ្ឌិត បរិបូណ៌ដោយ
ការស្តាប់ ជាអ្នកញញឹមមុននិយាយ ជាអ្នកមានប្រាជ្ញាឈ្មោះ
វិជយៈ ១ ឈ្មោះសុនាមៈ ១ និងសេនាបតីឈ្មោះ អលាតៈ
១ ។ ព្រះបាទវិទេហៈទ្រង់សួរអាមាត្យនោះជាលំដាប់ថា អ្នក
ទាំងឡាយចូរពោលតាមសេចក្តីពេញចិត្តផ្សេងៗគ្នា ថ្ងៃនេះ
ជារាត្រីជាទីបំផុតនៃខែភ្លៀង ៤ ខែ ជាទីរីកនៃផ្កាកុមុទ មណ្ឌល
ព្រះចន្ទដ៏សកម្ចាត់បង់ងងឹត ថ្ងៃនេះយើងទាំងឡាយនឹងនៅ
ដោយសេចក្តីត្រេកអរដូចម្តេចក្នុងរាត្រីរដូវនេះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បហូតយោគ្គោ** សេចក្តីថា ព្រះអង្គប្រកប ដោយពលដំរី ពលសេះជាដើមច្រើន ។ បទថា **អនន្តពលចោរិសោ** បាន ដល់ ទ្រង់មានពលយោធាច្រើនហួសនឹងរាប់ ។ បទថា **អនាគតេ** សេចក្តី ថា មិនទាន់មកដល់ គឺមិនកន្លងដល់ទីបំផុត ។ បទថា **ចាតុមាសា** បាន ដល់ ក្នុងរាត្រីដែលជាថ្ងៃចុងក្រោយនៃខែ ដែលមានក្នុងរដូវវស្សា ៤ ខែ ។ បទថា **កោមុទិយា** បានដល់ ផ្កាកុមុទរីក ។ បទថា **មិតបុព្វេ** សេចក្តីថា មានប្រក្រតីញញឹមមុនហើយនិយាយក្នុងកាលជាក្រោយ ។ បទថា **តម-នុបុច្ឆិ** សេចក្តីថា ត្រាស់សួរតាមលំដាប់អាមាត្យម្តងមួយៗក្នុងអាមាត្យទាំង ៣ នោះ ។ បទថា **បច្ចេកំ ព្រូថ សំរុចឹ** សេចក្តីថា ពួកអ្នកទាំងឡាយ ចូរ

និទានរឿងដែលសមគួរដល់អធ្យាស្រ័យរៀងៗខ្លួន ដែលពេញចិត្តរបស់ខ្លួនម្នាក់មួយរឿងដល់យើង ។ បទថា **កោមុទដ្ឋ** កាត់បទជា **កោមុទី អដ្ឋ** ប្រែថា ពន្លឺព្រះចន្ទ ។ បទថា **ជុណ្ហំ** សេចក្ដីថា ព្រះចន្ទដែលមានក្នុងរាត្រី ខែភ្លឺរះឡើងហើយ ។ បទថា **ព្យបហាតំ តមំ** សេចក្ដីថា ពន្លឺព្រះចន្ទនោះកម្ចាត់ងងឹតទាំងពួងចេញបាន ។ បទថា **ឧតុំ** សេចក្ដីថា ថ្ងៃនេះយើងនឹងញ៉ាំងរាត្រី គឺរដូវបែបនេះឲ្យរស់នៅដោយសេចក្ដីត្រេកអរដូចម្ដេចហ្ន៎ ។

លំដាប់នោះព្រះរាជា ក៏ត្រាស់សួរពួកអាមាត្យទាំងឡាយ អាមាត្យទាំងនោះត្រូវព្រះរាជាត្រាស់សួរហើយ ទើបក្រាបទូលពាក្យដែលសមគួរដល់អធ្យាស្រ័យរៀងៗខ្លួន ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** វីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសានូវព្រះគាថាដូច្នេះថា

> លំដាប់នោះសេនាបតីរបស់ព្រះរាជាឈ្មោះអលាតៈបានក្រាបទូលដូច្នេះថា យើងខ្ញុំនឹងចាត់ចែងយាន ពលនិងសេនាទាំងអស់ដែលមានចិត្តរីករាយហើយ ។ បពិត្រព្រះសម្មតិទេព យើងខ្ញុំមានពួកពលមិនមានទីបំផុតនឹងចេញទៅដើម្បីច្បាំង ពួកព្រះរាជាណាមិនមកចុះអំណាច យើងនឹងនាំចូលមកចុះអំណាចព្រះអង្គ នេះជាសេចក្ដីយល់ផ្ទាល់ខ្លួន របស់ទូលព្រះបង្គំជាខ្ញុំ ពួកទូលព្រះបង្គំជាខ្ញុំ នឹងផ្ចាញ់សត្រូវដែលមិនទាន់ផ្ចាញ់ ។

( បពិត្រព្រះសម្មតិទេព សូមព្រះអង្គត្រេកអរក្នុងចម្បាំង នេះជាសេចក្ដីចូលចិត្តរបស់ទូលព្រះបង្គំជាខ្ញុំ ) ។

អាមាត្យឈ្មោះសុនាមៈ បានស្ដាប់ពាក្យអលាតសេនាបតីហើយក៏ក្រាបទូលដូច្នេះថា បពិត្រមហារាជ ពួកសត្រូវទាំងអស់មកចុះអំណាចព្រះអង្គស្រាប់ហើយតើ ។ ពួកសត្រូវមានគ្រឿងសស្ត្រាដាក់ចុះហើយតែងប្រព្រឹត្តបន្ទន់បន្ទាប មហោស្រពដ៏ឧត្តមទីងមានក្នុងថ្ងៃនេះ ការច្បាំងទូលព្រះបង្គំជាខ្ញុំមិនពេញចិត្តទេ ។ ជនទាំងឡាយចូរនាំយកបាយ ទឹកនិងបង្អែមយ៉ាងឆាប់មកថ្វាយព្រះអង្គ បពិត្រព្រះសម្មតិទេព សូមព្រះអង្គត្រេកអរក្នុងការរាំច្រៀងនិងគ្រឿងប្រគំ ដោយកាមទាំងឡាយចុះ ។

វិជយាមាត្យបានស្ដាប់ពាក្យសុនាមអាមាត្យហើយ ក៏ក្រាបទូលដូច្នេះថា បពិត្រមហារាជ កាមទាំងអស់ប្រាកដដល់ព្រះអង្គជានិច្ចហើយតើ ។ បពិត្រព្រះសម្មតិទេព កាមទាំងនេះព្រះអង្គមិនមែនបានដោយក្រទេ កាលបើព្រះអង្គ ( ប្រាថ្នា ) រីករាយដោយកាមទាំងឡាយ កាមទាំងឡាយព្រះអង្គបានសព្វៗកាល នេះមិនមែនជាសេចក្ដីពេញចិត្តរបស់ទូលព្រះបង្គំជាខ្ញុំទេ ។ សមណព្រាហ្មណ៍ណា អ្នកដឹងអត្ថនិងធម៌ ជាអ្នកស្វែងរកគុណ គប្បីបន្ទោបង់សេចក្ដីសង្ស័យ នៃយើងទាំងឡាយក្នុង

ថ្ងៃនេះបាន យើងទាំងឡាយ នឹងចូលទៅរកសមណព្រាហ្មណ៍ ជាពហុស្សូតនោះ ។

ព្រះរាជាទ្រង់ព្រះនាមអង្គតិទ្រង់ព្រះសណ្ដាប់ពាក្យនៃវិជយាមាត្យហើយទ្រង់ត្រាស់ថា ការណ៍នេះពេញចិត្តដល់យើងដូចវិជយាមាត្យពោល ។ សមណព្រាហ្មណ៍ណា ជាអ្នកដឹងអត្ថនិងធម៌ ជាអ្នកស្វែងរកគុណ គប្បីបន្ទោបង់សេចក្ដីសង្ស័យនៃយើងទាំងឡាយបានក្នុងថ្ងៃនេះ យើងទាំងឡាយនឹងចូលទៅរកសមណព្រាហ្មណ៍ជាពហុស្សូតនោះ ។ អ្នកទាំងអស់គ្នាចូរធ្វើសេចក្ដីយល់ចុះ យើងគួរចូលទៅរកបណ្ឌិតណាដែលជាអ្នកដឹងអត្ថនិងធម៌ ជាអ្នកស្វែងរកគុណ បន្ទោបង់សេចក្ដីសង្ស័យនៃពួកយើងបានក្នុងថ្ងៃនេះ ។

អលាតសេនាបតី បានស្ដាប់ព្រះបន្ទូលនៃព្រះបាទវិទេហៈហើយក៏ក្រាបទូលដូច្នេះថា មានអចេលកៈ ១ អង្គនេះដែលគេសន្មតថាជាអ្នកប្រាជ្ញ គង់ក្នុងមិគទាយវ័ន ។ អចេលកៈនេះឈ្មោះគុណៈ ជាកស្សបគោត្ត ជាអ្នកចេះដឹង ជាអ្នកពោលពាក្យដ៏វិចិត្រ ជាគណាចារ្យ បពិត្រព្រះសម្មតិទេព យើងគួរចូលទៅរកអចេលកៈនោះ លោកនឹងបន្ទោបង់សេចក្ដីសង្ស័យនៃពួកយើងបាន ។

ព្រះរាជាទ្រង់ព្រះសណ្ដាប់ពាក្យនៃអលាតសេនាបតីហើយ

ទ្រង់បង្គាប់នាយសារថីថា យើងនឹងទៅកាន់មិគទាយវ័ន អ្នក
ចូរនាំយកនូវយានដែលទឹមហើយមកក្នុងទីនេះ ដូច្នេះ ។

បទថា **ហាដ្ឋំ** ប្រែថា ត្រេកអរក្រៃលែង ។ បទថា **ឱជិនាមសេ** សេចក្តីថា ពួកយើងនឹងយកជ័យជម្នះដែលពួកយើងមិនឈ្នះ នេះជាអធ្យាស្រ័យរបស់ខ្ញុំដូច្នេះ ព្រះរាជាទ្រង់ស្តាប់ពាក្យរបស់អលាតសេនាបតីទ្រង់មិនជំទាស់ទ្រង់មិនត្រេកអរ ។ បទថា **ឃតធញ្ញាវិ** សេចក្តីថា សុនាមអាមាត្យបានឃើញព្រះរាជាទ្រង់មិនត្រេកអរ មិនជំទាស់ពាក្យរបស់អលាតសេនាបតីគិតថា ព្រះរាជានេះមិនមានអធ្យាស្រ័យក្នុងចម្បាំង អញនឹងកាន់យកការគិតរបស់ព្រះអង្គហើយសរសើរការត្រេកអរក្រៃលែងក្នុងកាមគុណ ទើបពោលពាក្យជាដើមថា **សព្វេ តុយ្ហំ** ដូច្នេះ ។ បទថា **វិជយោ ឃតធញ្ញាវិ** សេចក្តីថា ព្រះរាជាទ្រង់ស្តាប់ពាក្យរបស់សុនាមអាមាត្យហើយក៏មិនត្រេកអរ មិនជំទាស់ ។

លំដាប់នោះទើបវិជយអាមាត្យគិតថា ព្រះរាជានេះស្តាប់ពាក្យរបស់ជនទាំង ២ នេះហើយបានគង់ស្ងៀមនោះឯង ធម្មតាបណ្ឌិតទាំងឡាយជាអ្នកស្តាប់ធម៌ អញនឹងសរសើរការស្តាប់ធម៌ដល់ព្រះអង្គ ដូច្នេះហើយទើបពោលពាក្យជាដើមថា **សព្វេ កាមា** ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **តវ មុបដ្ឋិតា** សេចក្តីថា បម្រើទ្រង់ ។ បទថា **មោទិតុំ** សេចក្តីថា កាលទ្រង់មានសេចក្តីត្រេកអរ ទ្រង់បាននូវកាមគុណទាំងនេះដោយមិនលំបាក ។ បទថា **នេតំ ចិត្តមតំ មម** សេចក្តីថា ឈ្មោះថា ការអភិរមដោយកាមគុណរបស់ទ្រង់នេះមិនមែនត្រឹមតែជាមតិរបស់ខ្ញុំ ការគិតរបស់ខ្ញុំមិនបានសំដៅដល់សេចក្តីនេះ ។

បទថា **យោ ឆដ្ឋ** កាត់បទជា **យោ ឆោ អដ្ឋ** ។ បទថា **អត្ថធម្មវិទូ** បានដល់ ជាអ្នកដឹងនូវអត្ថនៃបាលីនិងធម៌នៃបាលី ។ បទថា **ឥសេ** បានដល់ ឥសី គឺ បុគ្គលមានគុណស្វែងរកហើយ ។ បទថា **អង្គតិ មត្យាវិ** កាត់បទជា **អង្គតិ អត្យាវិ** ។ បទថា **មយ្ហំ បេតំ វ រុច្ចតិ** សេចក្តីថា ឯខ្ញុំក៏យល់ក្នុងសេចក្តីនោះដូចគ្នា ។ បទថា **សព្វេវ សន្តា** សេចក្តីថា ពួកអ្នកទាំងអស់មានក្នុងទីនេះចូរធ្វើ គឺចូរគិតនូវមតិ ។ បទថា **អលាតោ ឯតទព្រវិ** សេចក្តីថា អលាតសេនាបតីស្តាប់ពាក្យរបស់ព្រះរាជានោះហើយគិតថា អាជីវកឈ្មោះគុណៈជាអ្នកចូលកាន់ត្រកូលរបស់អញនៅក្នុងរាជឧទ្យាន អញនឹងសរសើរអាជីវកនោះធ្វើឲ្យជាបុគ្គលចូលដល់រាជត្រកូល ក៏បានពោលពាក្យជាដើមថា **អត្ថាយំ** ដូច្នេះ ។ បទថា **ធីរសម្មតោ** បានដល់ សន្មតថាជាបណ្ឌិត ។ បទថា **កស្សបគោត្តាយំ** កាត់បទជា **កស្សបគោត្តោ អយំ** ។ បទថា **សុតោ** បានដល់ ជាអ្នកបានស្តាប់មកហើយច្រើន ។ បទថា **គណី** សេចក្តីថា ជាគ្រូរបស់គណៈ ។ បទថា **ចោទេសិ** បានដល់ បានបញ្ជាហើយ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហា** វីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូត្យសានូវព្រះគាថាដូច្នេះថា

ពួកនាយសារថីបានទឹមថ្វាយព្រះរាជានោះ នូវយានជាវិការៈ
នៃក្លុក មានទ្រូពងជាវិការៈនៃប្រាក់ មានប្រដាប់ជាបរិវាររដ៏ស
រលង់ហាក់ដូចមុខនៃរាត្រីដែលប្រាសចាកទោស ឬដូចព្រះចន្ទ

( ពេញវង់ ) ក្នុងរថនោះនាយសារថីបានទឹមសេះសិន្ធព ៤ មានសម្បុរដូចផ្កាកុមុទ មានសន្ទុះលឿនប្រហែលនឹងសន្ទុះខ្យល់ ដែលបង្ហាត់ល្អហើយប្រដាប់ដោយកម្រងផ្កាជាវិការៈនៃមាស ។ មានព្រះក្លស់ស រថស សេះស ស៊ែស ព្រះបាទវិទេហៈ យាងទៅ ( ដោយរថនោះ ) ជាមួយនឹងពួកអាមាត្យក៏ល្អដូចជាព្រះចន្ទ ។ ពលដ៏ច្រើនជាអ្នកទ្រទ្រង់លំពែងនិងដាវ ទាំងពួកជនអ្នកក្លាហានក៏ជិះលើខ្នងសេះហើយតាមដង្ហែព្រះរាជានោះ ដែលជាធំដ៏ប្រសើរជាងនរៈ ។ ព្រះបាទវិទេហៈ ជាក្សត្រនោះក៏យាងទៅកាន់ឧទ្យានដោយមួយរំពេច ទ្រង់ចុះពីយាន យាងផ្ទាល់ព្រះបាទជាមួយនឹងអាមាត្យ ក៏យាងទៅរកអាជីវកឈ្មោះគុណៈ ។ គ្រានោះព្រាហ្មណ៍និងគហបតីទាំងឡាយណាដែលមកប្រជុំគ្នាក្នុងឧទ្យាននោះ ព្រះរាជាក៏មិនបណ្តេញព្រាហ្មណ៍និងគហបតីទាំងនោះ ដែលមកកាន់ទីដែលមិនបានធ្វើឱកាសដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តស្ស យានំ** សេចក្តីថា ពួកនាយសារថីបានរៀបចំយានថ្វាយដល់ព្រះរាជានោះ ។ បទថា **ទន្តំ** បានដល់ សម្រេចដោយភ្លុក ។ បទថា **រូបិយបក្ខរំ** បានដល់ មានទ្រនាប់ជាប្រាក់ ។ បទថា **សុក្កមដ្ឋបរិវារំ** សេចក្តីថា មានគ្រឿងបរិវារថដ៏ស្អាតរលោង មិនគ្រោតគ្រាត ។ បទថា **ចោសិនា មុខំ** សេចក្តីថា ដូចព្រះចន្ទពេញវង់ដែលប្រាស

បាកទោស គឺមន្ទិល ។ បទថា **តត្រាសុំ** បានដល់ មានក្នុងរថនោះ ។ បទថា **កុមុទា** បានដល់ ដូចពណ៌នៃផ្កាកុមុទ ។ បទថា **សិន្ធវា** បានដល់ សេះដែលមានសម្ទុះជើងរហ័ស ជាពូជសេះសិន្ធព ។ បទថា **អនិលុប្បសមុ-ប្បាតា** បានដល់ សេះដែលមានកម្លាំង ដូចគ្នានឹងកម្លាំងខ្យល់ ។ បទថា **សេតច្ឆត្តំ** សេចក្តីថា សូម្បីឆត្រដែលគេលើកឡើងលើរថនោះ ក៏មានពណ៌ស ។ បទថា **សេតរថោ** សេចក្តីថា សូម្បីរថនោះក៏មានពណ៌សដូចគ្នា ។ បទថា **សេតស្សា** សេចក្តីថា សូម្បីសេះក៏មានពណ៌ស ។ បទថា **សេតវីជនី** សេចក្តីថា សូម្បីផ្លិតវាលវីជនីក៏មានពណ៌ស ។ បទថា **និយំ** សេចក្តីថា ព្រះបាទវិទេហរាជចោមរោមទៅដោយពួកអាមាត្យ យានទៅដោយរថប្រាក់នោះរមែងល្អដូចចន្ទទេវបុត្ត ។ បទថា **នរា នរវរាធិបំ** សេចក្តីថា ជាអធិបតីនៃនរជនដ៏ប្រសើរ ជាព្រះរាជាក្រៃលែងជាងព្រះរាជា ។ បទថា **សោ មុហុត្តំវ យាយិត្វា** សេចក្តីថា ព្រះរាជានោះយានចូលទៅកាន់ព្រះរាជឧទ្យានមួយស្របក់ប៉ុណ្ណោះ ។ បទថា **បត្តិ គុណាមុបាគមិ** សេចក្តីថា ទ្រង់ព្រះរាជដំណើរចូលទៅរកគុណាជីវក ។ បទថា **យេបិ តត្ថ តទា អាសុំ** សេចក្តីថា ក្នុងកាលនោះពួកព្រាហ្មណគហបតីទាំងឡាយទៅមុនក្នុងឧទ្យាននោះ ចូលទៅអង្គុយជិតអាជីវកនោះ ។ បទថា **ន តេ អបនយិ** សេចក្តីថា ព្រះរាជាត្រាស់ថា ទោសជារបស់ពួកយើងប៉ុណ្ណោះ ពួកយើងមកក្រោយ ពួកអ្នកកុំវិតក្កឡើយ ទើបមិនឲ្យពួកព្រាហ្មណ៍និងគហបតីធ្វើឱកាស គឺក្រោកឡើងចៀសចេញទៅដើម្បីជាប្រយោជន៍ដល់ព្រះរាជា ។ បទថា **ភូមិមាគតេ** សេចក្តីថា

ពួកគេទាំងនោះដែលមកកាន់ទីប្រជុំ ដែលព្រះរាជាមិនចាំបាច់ឲ្យក្រោកឡើងចៀសចេញទៅ ។

ព្រះបាទអង្គតិរាជនោះចោមរោមទៅដោយបរិស័ទរួមគ្នាហើយប្រថាប់គង់ក្នុងទីសមគួរនាចំណែកម្ខាង ហើយទ្រង់ធ្វើបដិសណ្ឋារៈ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសានូវព្រះគាថាដូច្នេះថា

លំដាប់នោះព្រះរាជានោះចូលទៅក្នុងទីដ៏សមគួរ ( ប្រថាប់ ) លើពូកមានសម្ផស្សទន់ លើកម្រាលដ៏វិចិត្រមានសម្ផស្សទន់ លើទីដែលគេក្រាលដោយកម្រាលដ៏ទន់ ។ ព្រះរាជាលុះគង់ហើយក៏រីករាយ ( ជាមួយ ) អចេលកៈ លំដាប់នោះទ្រង់ត្រាស់នូវពាក្យគួររឭកថា បពិត្រលោកដ៏ចម្រើន សរីរៈរបស់លោកអាចប្រព្រឹត្តទៅបានទេឬ ធាតុខ្យល់មិនប្រព្រឹត្តទៅ ( ស្រួលក្នុងសរីរៈ ) ទេឬ ។ ការប្រព្រឹត្ត ( ចិញ្ចឹមជីវិត ) របស់លោកមិនលំបាកទេឬ លោកបានដុំបាយខ្វះដែរឬ លោកមិនមានអាពាធទេឬ ចក្ខុរបស់លោកមិនសាបសូន្យទេឬ ។

អចេលកៈឈ្មោះគុណៈ បានរីករាយតបនឹងព្រះបាទវិទេហៈដែលទ្រង់ត្រេកអរក្នុងវិន័យដោយពាក្យថា បពិត្រមហារាជអាត្មាភាព ល្មមញុំាងសរីរៈឲ្យប្រព្រឹត្តទៅបាន ខាងដើមដំណើរ

ទាំងអស់ទុំះ ដំណើរទាំងពីរដែលព្រះអង្គត្រាស់សួរហើយនោះ ( ក៏ស្រួលដែរ ) ។ បពិត្រព្រះបាទវិទេហៈ បច្ចត្ថាមិត្រទាំងឡាយរបស់ព្រះអង្គមិនបះបោរទេឬ យានរបស់ព្រះអង្គមិនខូចខាតទេឬ វាហនៈនៅប្រព្រឹត្តទៅបានទេឬ ព្យាធិទាំងឡាយដែលដុតកម្តៅសរីរៈរបស់ព្រះអង្គមិនមានទេឬ ។

លំដាប់នោះព្រះរាជាព្រះអង្គប្រសើរក្នុងរថ ទ្រង់ប្រាថ្នាធម៌ក៏រីករាយតបទើបសួរអត្ថផង ធម៌ផង ហេតុដែលគួរដឹងផងថា បពិត្រកស្សបគោត្ត សត្វគប្បីប្រព្រឹត្តធម៌ក្នុងមាតាបិតាតើដូចម្តេច គប្បីប្រព្រឹត្តក្នុងអាចារ្យតើដូចម្តេច គប្បីប្រព្រឹត្តក្នុងកូននិងប្រពន្ធតើដូចម្តេច ។ គប្បីប្រព្រឹត្តក្នុងពួកមនុស្សចាស់តើដូចម្តេច ក្នុងសមណព្រាហ្មណ៍តើដូចម្តេច ក្នុងពួកពលតើដូចម្តេច គប្បីប្រព្រឹត្តក្នុងជនបទតើដូចម្តេច ។ សត្វទាំងឡាយប្រព្រឹត្តធម៌ដូចម្តេចលះលោកនេះហើយទៅកាន់សុគតិ សត្វពួកខ្លះឋិតនៅក្នុងអធម៌ មានក្បាលសំយុងចុះធ្លាក់ទៅកាន់នរកតើដូចម្តេច ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មុទុកា ភិសិយា** សេចក្តីថា ដោយពូកដែលមានសម្ផស្សទន់ ។ បទថា **មុទុចិត្តកសន្ថតេ** សេចក្តីថា លើកម្រាលដ៏វិចិត្រមានសម្ផស្សជាសុខ ។ បទថា **មុទុបច្ចត្ថតេ** សេចក្តីថា ដែលក្រាលដោយកម្រាលដ៏ទន់ ។ បទថា **សម្មោទិ** សេចក្តីថា បានធ្វើសម្មោទនីយកថា

ជាមួយអាជីវក ។ បទថា **តតោ** សេចក្តីថា បន្ទាប់ពីការអង្គុយនោះឯងបាន ពោលសារាណីយកថា ។ បទថា **កច្ចិ យាបនិយំ** សេចក្តីថា បពិត្រ លោកម្ចាស់ លោករស់នៅជាសុខឬ លោកអាចញុំាងអត្តភាពឲ្យប្រព្រឹត្ត ទៅដោយបច្ច័យដ៏ប្រណីតឬ ។ បទថា **វាតានមាពាធិកា** សេចក្តីថា ខ្យល់ក្នុងរាងកាយរបស់លោក ប្រព្រឹត្តទៅជាសុខឬ រោគខ្យល់មិនកម្រើកទេឬ អធិប្បាយថា ខ្យល់ដែលកើតឡើងជាពួកក្នុងរាងកាយទាំងនោះរបស់លោក មិនបៀតបៀនលោកទេឬ ។ បទថា **អកសិរា** បានដល់ មិនមានសេចក្តី លំបាក ។ បទថា **វុត្តិ** បានដល់ ការប្រព្រឹត្តទៅនៃជីវិត ។ បទថា **អប្បា-ពាធោ** សេចក្តីថា វៀរចាកអាពាធដែលកាច់បំបាក់ឥរិយាបថ ។ ដោយ បទថា **ចក្ខុ** នេះព្រះរាជាត្រាស់សួរថា ឥន្ទ្រិយមានចក្ខុន្ទ្រិយជាដើមរបស់ លោកមិនវិនាសទេឬ ។ បទថា **បដិសម្មោទិ** សេចក្តីថា អាជីវកឈ្មោះ គុណពោលតបដោយសម្មោទនីយកថា ។ បណ្តាបទទាំងនោះ បទថា **សព្វ-មេតំ** សេចក្តីថា ពាក្យដែលលោកពោលថា ធាតុខ្យល់មិនប្រព្រឹត្តទៅទេ ឬជាដើម ទាំងអស់នោះក៏យ៉ាងនោះឯង ។ បទថា **តទុភយំ** សេចក្តីថា សូម្បីពាក្យដែលពោលថា លោកមិនមានអាពាធទេឬ ចក្ខុរបស់លោកមិន សាបសូន្យទេឬ ទាំង ២ នោះក៏យ៉ាងនោះដូចគ្នា ។ បទថា **ន ពលីយរេ** បានដល់ មិនគ្របសង្កត់ មិនកម្រើក ។ ដោយបទថា **អឆន្ទា** នេះព្រះ រាជាសួរបញ្ហាក្នុងលំដាប់អំពីបដិសណ្ឋារៈ ។ បណ្តាបទទាំងនោះ បទថា **អត្ថំ ធម្មញ្ច ញាយញ្ច** បានដល់ អត្ថនៃបាលី ធម៌នៃបាលីនិងអត្ថធម៌

ដែលប្រកបទៅដោយហេតុ ។ ឯព្រះរាជានោះកាលត្រាស់សួរថា **កថំ ធម្ម-ញ្ញូរេ** ទើបសួរអត្ថធម៌និងការប្រព្រឹត្តល្អនេះថា សូមលោកប្រាប់អត្ថនៃបាលីធម៌នៃបាលី និងអត្ថធម៌ដែលសមគួរដល់ហេតុ ដែលសម្តែងការបដិបត្តិក្នុងមាតានិងបិតាជាដើមដល់ខ្ញុំ ។ បណ្តាបទទាំងនោះ បទថា **កថញ្ញូកោ អ-ធម្មដ្ឋា** សេចក្តីថា ជនពួកខ្លះតាំងនៅក្នុងអធម៌ ហេតុអ្វីទើបមនុស្សពួកខ្លះសំយុងក្បាលទៅនរកយកជើងឡើងលើធ្លាក់ទៅក្នុងអបាយ ។

បញ្ហានោះ ជាបញ្ហាដែលព្រះរាជាគួរត្រាស់សួរបុគ្គលដែលមានសក្តិធំមុនទៅតាមលំដាប់ដល់ជនក្រោយៗ គឺក្នុងបណ្តាព្រះសព្វញ្ញុពុទ្ធ ព្រះបច្ចេកពុទ្ធព្រះពុទ្ធសាវក និងព្រះមហាពោធិសត្វ តែបែរជាត្រាស់សួរគុណាជីវកដែលជាអ្នកអាក្រាតកាយមិនមានសិរី ជាបុគ្គលអន្ធពាលមិនដឹងបញ្ហាអ្វីសោះ ។ គុណាជីវកនោះកាលត្រូវសួរយ៉ាងនេះហើយទើបមិនឃើញផ្លូវនៃព្យាករដែលសមគួរដល់រាជបុច្ឆាដូចយកដំបងវាយគោដែលកំពុងដើរទៅឬដូចចាក់សំរាមក្នុងអាហារដែលជួសហើយដូច្នោះតែបានទូលសូមឱកាសថា បពិត្រមហារាជសូមទ្រង់ស្តាប់ចុះហើយចាប់ផ្តើមនូវមិច្ឆាវាទរបស់ខ្លួន ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** វីអាចិធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសានូវព្រះគាថាដូច្នេះថា

អចេលកៈជាកស្សបគោត្តបានស្តាប់ព្រះបន្ទូលព្រះបាទវិទេហៈ
ហើយក៏ទូលដូច្នេះថា បពិត្រមហារាជ សូមព្រះអង្គទ្រង់ព្រះ

សណ្តាប់នូវបទដែលពិត មិនឃ្មៀងឃ្លាតរបស់អាត្មាភាពចុះ ។ ផលល្អនិងអាក្រក់របស់បុគ្គលអ្នកប្រព្រឹត្តធម៌ មិនមានទេ បពិត្រព្រះសម្មតិទេព បរលោកក៏មិនមានដែរ ព្រោះថាក្នុងលោកនេះមាននរណាមកពីបរលោក ។ បពិត្រព្រះសម្មតិទេព មួយទៀតមាតាបិតា(១)មិនមានទេ មាតានឹងមានពីណា បិតានឹងមានពីណា បុគ្គលដែលឈ្មោះថា អាចារ្យមិនមានទេ បុគ្គលណានឹងទូន្មានបុគ្គលដែលទូន្មានមិនបាន ។ សត្វទាំងឡាយមានតុល្យភាពស្មើៗគ្នា សត្វទាំងឡាយជាអ្នកគោរពចំពោះបុគ្គលចាស់មិនមានទេ កម្លាំងក្តី ព្យាយាមក្តីក៏មិនមានដែរ បុរសអ្នកព្យាយាមនឹងមានពីណា ។ ព្រោះថា សត្វទាំងឡាយទៀងដូចទូកតូចចងភ្ជាប់នឹងទូកធំ សត្វរមែងបានរបស់ដែលត្រូវបាន ផលទានក្នុងបរលោកនោះនឹងមានពីណា ។ បពិត្រព្រះសម្មតិទេព ផលទានមិនមានទេ បពិត្រព្រះសម្មតិទេព សេចក្តីព្យាយាមមិនមានអំណាចទេ ទានគឺពួកជនពាលទេតើបញ្ញត្តមក ពួកបណ្ឌិតចាំតែទទួលយកនូវទាននោះ ពួកជនពាលជាអ្នកមិនមានអំណាចសំគាល់ខ្លួនថាជាបណ្ឌិតរមែងឲ្យទានដល់បណ្ឌិតទាំងឡាយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឥធាគតោ** សេចក្តីថា ឈ្មោះថា បុគ្គល

---

១-បាលីថា បិតរោ អដ្ឋកថាប្រាប់ថា ជីដូនជីតា ដូច្នេះប្រែថា ជីដូនជីតា មិនមានទេក៏គួរ ។

ចេញអំពីបរលោកនោះមកកាន់លោកនេះមិនមាន ។ បទថា **បិតរោ វា** សេចក្តីថា បពិត្រព្រះសម្មតិទេព បិយជនទាំងឡាយមានជីដូនជីតាជាដើម រមែងមិនមាន បើលោកទាំងនោះមិនមាន មាតានឹងមានមកពីណា បិតានឹងមានមកអំពីណា ។ បទថា **យថា គោដវិសោ តថា** សេចក្តីថា ទូកដែលចងខាងក្រោយទូកហៅថា **គោដវិសោ** ។ គុណាជីវកទូលថា ទូកតូចដែលចងត្រង់កន្សៃទូកធំជាប់តាមទៅយ៉ាងណា សត្វទាំងនេះក៏យ៉ាងនោះដូចគ្នា រមែងជាប់តាមទៅយ៉ាងពិតប្រាកដអស់ ៨៤ កប្ប ។ បទថា **អវសោ ទេវ វីរិយោ** សេចក្តីថា កាលផលរបស់ទានមិនមានដោយអាការយ៉ាងនេះ បុគ្គលពាលណាមួយរមែងឈ្មោះថា ឲ្យទាន គុណាជីវកសម្តែងទុកថា បុគ្គលពាលនោះមិនមានអំណាច មិនមានសេចក្តីព្យាយាមរមែងឲ្យទានដោយអំណាច គឺដោយកម្លាំងរបស់ខ្លួនមិនមាន តែរមែងជឿចំពោះអន្ធពាលដទៃ ទើបឲ្យដោយសម្គាល់ថា ផលទានរមែងមាន ។ បទថា **ពាលេហិ ទានំ បញ្ញត្តំ** សេចក្តីថា បុគ្គលពាលប៉ុណ្ណោះរមែងឲ្យទាននោះ បណ្ឌិតរមែងរង់ចាំទទួលទានដែលអន្ធពាលបញ្ញត្តទុក គឺអនុញ្ញាតទុកថាគួរឲ្យទាន ដូច្នេះ ។

កាលគុណាជីវកទូលពណ៌នាការៈដែលទានជារបស់មិនមានផលយ៉ាងនេះហើយ ឥឡូវនេះដើម្បីពណ៌នាដល់បាបដែលមិនមានផលក៏ពោលថា

ភ្លើង ដី ទឹក ខ្យល់ សុខ ទុក្ខនិងជីវិតទាំង ៧ នេះឈ្មោះ
ថាពួកទៀង ជាសភាវៈឲ្យដាច់មិនបាន ឲ្យកម្រើកមិនបាន ។
ពួកទៀងទាំង ៧ នេះគប្បីរស់នៅជាដរាប ដែលបុគ្គលកាត់

ហើយមិនឈ្មោះថាកាត់ បុគ្គលអ្នកសម្លាប់ក្តី បុគ្គលអ្នកកាត់ក្តីមិនមាន អ្នកណាឈ្មោះថា សម្លាប់អ្នកណាបាន ។ គ្រឿងសស្ត្រាទាំងឡាយគ្រាន់តែចូលទៅក្នុងចន្លោះនៃពួក ( ទៀង ) ប៉ុណ្ណោះ បុគ្គលណាយកដាវដែលសំលៀងហើយកាត់ក្បាលជនដទៃ បុគ្គលនោះមិនឈ្មោះថាកាត់ពួក ( ទៀង ) ទាំងនោះទេ ផលនៃបាបក្នុងការកាត់នោះនឹងមានពីណា ។ សត្វទាំងអស់កាលអន្ទោលអស់មហាកប្ប ៨៤ ទើបបរិសុទ្ធិឯង កាលបើមិនទាន់ដល់កាលនោះ បុគ្គលសូម្បីសង្រួមក៏មិនបរិសុទ្ធិ ។ កាលបើមិនទាន់ដល់កំណត់នោះ ពួកសត្វសូម្បីប្រព្រឹត្តល្អច្រើនក៏មិនបរិសុទ្ធិ ទុកជាធ្វើបាបច្រើនក៏មិនកន្លងហួសនូវខណៈនោះដែរ ។ សេចក្តីបរិសុទ្ធនៃយើងទាំងឡាយតាមលំដាប់នៃកប្ប ៨៤ យើងទាំងឡាយមិនកន្លងហួស ( កម្រិត ) ដ៏ទៀងនោះទេដូចសាគរមិនកន្លងហួសច្រាំង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កាយា** ប្រែថា ពួក ។ បទថា **អវិកោ-បិនោ** បានដល់ មិនអាចបំបែកគ្នាបាន ។ បទថា **ជីវេ** កែជា **ជីវោ** បាឋៈថា **ជីវោ** ៩ ដូច្នេះក៏មាន ឯអត្ថដូចគ្នាតែមួយនោះឯង ។ បទថា **សត្តិមេ កាយា** បានដល់កាយទាំង ៧ នេះ ។ បទថា **ហាញ្ញេ វាបិ កោចិនំ** សេចក្តីថា បុគ្គលអ្នកបៀតបៀនក៏មិនមាន ។ បទថា **សត្ថានិ វីតិវត្តរេ** សេចក្តីថា សស្ត្រាទាំងឡាយចូលទៅក្នុងកាយទាំង ៧ នេះមិនអាចនឹងកាត់

បាន ។ បទថា **សិរមាទាយ** សេចក្តីថា ចាប់ក្បាលនៃជនដទៃ ។ បទថា **ឆិសិតាសិនា** សេចក្តីថា លោកពោលថា កាត់ដោយដាវដ៏មុត លោកសម្តែងទុកថា បុគ្គលនោះចាក់ពួកនោះដោយកាយធាតុដីក៏ចូលទៅក្នុងធាតុដី ធាតុទឹកក៏ចូលទៅក្នុងធាតុទឹកជាដើម សុខ ទុក្ខនិងជីវិតរមែងស្ទុះទៅកាន់អាកាស ។ បទថា **សំសរំ** សេចក្តីថា បពិត្រមហារាជ សត្វទាំងនេះទោះធ្វើផែនដីនេះឲ្យក្លាយជាលានដាក់សាច់ក្តី ត្រាច់ទៅអស់កប្បមានប្រមាណប៉ុណ្ណេះក្តីក៏បរិសុទ្ធិមិនបាន ពិតហើយ បុគ្គលឈ្មោះថាអាចជម្រះពួកសត្វឲ្យបរិសុទ្ធិចាកសង្សាររមែងមិនមាន សត្វទាំងអស់រមែងបរិសុទ្ធិដោយសង្សារនោះឯង ។ បទថា **អនាគតេ តម្ហិ កាលេ** សេចក្តីថា កាលមួយតាមដែលពោលហើយមិនទាន់ដល់អនាគតកាល អ្នកដែលសង្រួមល្អក្តី មានសីលបរិសុទ្ធក្តីក្នុងចន្លោះ រមែងមិនបរិសុទ្ធិ ។ បទថា **តំ ១ណំ** បានដល់អស់កាលមានប្រការដូចពោលហើយនោះ ។ បទថា **អនុបុព្វេន នោ សុទ្ធិ** សេចក្តីថា ក្នុងវាទៈរបស់ខ្ញុំសេចក្តីបរិសុទ្ធរមែងមានដោយលំដាប់ អធិប្បាយថា សេចក្តីបរិសុទ្ធនៃយើងទាំងពួង រមែងមានដោយលំដាប់ ។ បទថា **តំ ៗលំ** បានដល់ អស់កាលមានប្រការដូចពោលហើយនោះ ។

គុណាជីវកដែលមានវាទៈថា ដាច់សូន្យ កាលនឹងញុំាងវាទៈរបស់ខ្លួនឲ្យសម្រេចតាមកម្លាំងរបស់ខ្លួនទើបក្រាបទូលដោយមិនមានគោលច្បាស់លាស់ ។ ( ព្រះសាស្តាកាលទ្រង់ប្រកាសសេចក្តីនោះទើបត្រាស់ថា )

អលាតសេនាបតី លុះស្តាប់ពាក្យអចេលកៈ ជាកស្សបគោត្ត

ហើយក៏ពោលដូច្នេះថា លោកដ៏ចម្រើនពោលយ៉ាងណា ពាក្យ
នោះពេញចិត្តខ្ញុំដែរ ។ ខ្ញុំរឭកជាតិរបស់ខ្លួនក្នុងកាលមុនដែល
អន្ទោលទៅហើយថា ក្នុងកាលមុន ខ្ញុំកើតជាមនុស្សប្រព្រឹត្ត
អាក្រក់ឈ្មោះបិង្គលៈ ជាអ្នកសម្លាប់គោ ។ ខ្ញុំបានធ្វើបាបដ៏
ច្រើនក្នុងក្រុងពារាណសី ជាក្រុងសម្បូរ ខ្ញុំបានសម្លាប់សត្វ
ដ៏ច្រើនគឺ ក្របី ជ្រូក ពពែ ។ លុះខ្ញុំច្យុតចាកអត្តភាពនោះ
ក៏បានមកកើតក្នុងត្រកូលសេនាបតីដ៏ស្តុកស្តម្ភក្នុងទីនេះ ផល
បាបរបស់ខ្ញុំមិនមានពិត បានជាខ្ញុំមិនទៅនរក ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អលាតោ ឋតេនព្រាំ** សេចក្ដីថា បានឮ
ថា អលាតសេនាបតីនោះធ្វើនូវការបូជាដោយកម្រងផ្កានោងត្រង់ចេតិយក្នុង
សាសនានៃព្រះទសពលព្រះនាមកស្សបៈក្នុងកាលមុន ក្នុងមរណសម័យត្រូវ
កម្មដទៃបន្សាត់ទៅតាមអានុភាពអន្ទោលទៅក្នុងសង្សារដោយផលនៃបាបកម្ម
ឯណានីមួយទើបកើតក្នុងត្រកូលនៃគោឃាតកៈ បានធ្វើបាបកម្មដ៏ច្រើន ក្នុង
កាលដែលគាត់ស្លាប់ បុញ្ញកម្មនោះដែលតាំងនៅអស់កាលមានប្រមាណប៉ុណ្ណោះ
បានឲ្យឱកាសដូចភ្លើងដែលផេះបិទបាំងដូច្នោះ ដោយអានុភាពនៃកម្មនោះទើប
គាត់មកកើតក្នុងទីនេះ បានទទួលសម្បត្តិបែបនេះហើយរឭកជាតិបាន កាល
មិនអាចរឭកដល់កម្មដទៃចាកកម្មក្នុងជាតិបន្ទាប់ទៅ ទើបគាំទ្រវាទៈរបស់
គុណាជីវកនោះដោយសម្គាល់ថា អញបានធ្វើកម្ម គឺការសម្លាប់គោទើបកើត
ក្នុងទីនេះទើបបានពោលពាក្យនេះថា **យថា ភន្តេ** ដូច្នេះជាដើម ។

បណ្ដាបទទាំងនោះ បទថា **សរេ សំសរិតត្ថតោ** សេចក្ដីថា រឭកដល់ជាតិដែលខ្លួនអន្ទោលទៅបាន ។ បទថា **សេនាបតិកុលេ** បានដល់ ខ្ញុំកើតក្នុងត្រកូលនៃសេនាបតី ។

គ្រានោះក្នុងក្រុងមិថិលា មានបុគ្គលកម្សត់ម្នាក់ជាទាសៈឈ្មោះ
វីជកៈរក្សាឧបោសថហើយចូលទៅកាន់សំណាក់នៃអចេលកៈ
ឈ្មោះគុណៈ ។ វីជកៈលុះស្ដាប់ពាក្យរបស់គុណៈជាកស្សប-
គោត្តនិងពាក្យដែលអលាតសេនាបតីពោលហើយក៏ដកដង្ហើម
ចេញដ៏ក្ដៅរឿយៗ យំបង្ហូរទឹកភ្នែក ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អថេត្ថ** សេចក្ដីថា កាលនោះក្នុងក្រុងមិថិលានោះ ។ បទថា **បដដ្ឋិរ** បានដល់ មនុស្សក្រីក្រកំព្រា ។ បទថា **គុណាសន្តិ-កុចាគមិ** សេចក្ដីថា បានទៅកាន់សម្នាក់របស់គុណាជីវក គប្បីជ្រាបថា ចូលទៅជិតដោយតាំងចិត្តថា ខ្ញុំនឹងស្ដាប់ហេតុខុះនោះឯង ។

ព្រះបាទវិទេហៈទ្រង់ត្រាស់សួរវីជកៈនោះថា ម្នាលសម្លាញ់ អ្នក
យំតើដើម្បីអ្វី អ្នកបានឮឬបានឃើញអ្វី អ្នកដល់នូវទុក្ខវេទនា
ដូចម្ដេច ចូរប្រាប់ឲ្យយើងដឹងផង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កឹ មំ វេទេសិ វេទនំ** សេចក្ដីថា អ្នកបានទទួលវេទនាផ្លូវកាយ ឬផ្លូវចិត្តយ៉ាងណាទើបយំយ៉ាងនេះ ចូរប្រាប់ឲ្យយើងជ្រាប អ្នកធ្វើខ្លួនឲ្យលំបាកដូចម្ដេច ចូរប្រាប់យើងចុះ ។

វីជកៈបានស្ដាប់ព្រះបន្ទូលព្រះបាទវិទេហៈហើយក្រាបបង្គំទូល

ថា បពិត្រមហារាជ ទុក្ខវេទនារបស់ទូលព្រះបង្គំជាខ្ញុំ មិនមាន
ទេ សូមព្រះអង្គទ្រង់ព្រះសណ្ដាប់ចុះ ។ ទូលព្រះបង្គំជាខ្ញុំរឭក
ឃើញនូវសេចក្ដីសុខ របស់ទូលព្រះបង្គំជាខ្ញុំ ក្នុងជាតិមុនកាល
ដែលបានកើតជាកាវសេដ្ឋី ជាអ្នកត្រេកអរក្នុងគុណធម៌ ក្នុង
បុរីឈ្មោះសាកេត ។ ទូលព្រះបង្គំជាខ្ញុំ ត្រូវពួកព្រាហ្មណ៍និង
គហបតីសរសើរហើយថាជាអ្នកត្រេកអរក្នុងការចែករំលែកទាន
ជាអ្នកមានការងារដ៏ស្អាត តែទូលព្រះបង្គំជាខ្ញុំមិនហ៊ានទឹកនា
នូវអំពើអាក្រក់របស់ខ្លួនដែលធ្វើហើយទេ ។ បពិត្រព្រះបាទ
វិទេហៈ ទូលព្រះបង្គំជាខ្ញុំលុះច្យុតចាកអត្តភាពនោះ ក៏មកកើត
ក្នុងគភ៌នៃកុម្ភទាសីជាស្រីទុគ៌តក្នុងក្រុងមិថិលានេះ តាំងពីកើត
មកទូលព្រះបង្គំជាខ្ញុំ ទុគ៌តក្រៃពេក ។ សូម្បីទូលព្រះបង្គំជាខ្ញុំ
ទុគ៌តយ៉ាងនេះ ក៏តាំងនៅក្នុងការប្រព្រឹត្តិស្មើ តែងឲ្យភត្តពាក់
កណ្ដាលដល់បុគ្គលអ្នកត្រូវការ ។ តែងរក្សា ( ឧបោសថ )
អស់ថ្ងៃទី ១៤ និងថ្ងៃទី ១៥ សព្វៗកាល ទាំងមិនបៀតបៀន
សត្វផង បានវៀរបង់ការលួចលាក់ផង ។ អំពើដែលសន្សំល្អ
ហើយទាំងអស់នេះជារបស់ឥតផលដោយពិត ទូលព្រះបង្គំជាខ្ញុំ
សំគាល់ថា សីលនេះមិនមានប្រយោជន៍ទេដូចជាអលាតសេ-
នាបតីពោលដែរ ។ ដែលទូលព្រះបង្គំជាខ្ញុំ ទទួលទុក្ខទោស
ដោយជាក់ស្ដែងនេះដូចជាអ្នកលេងដែលមិនមានសិល្បៈឬដូច

ជាអលាតសេនាបតីជាអ្នកលេងស្កា បានរៀនហើយក៏បានទទួល
ការឈ្នះ ។ ទូលព្រះបង្គំមិនឃើញទ្វារសម្រាប់ទៅសុគតិសោះ
បពិត្រព្រះរាជា ព្រោះហេតុនោះបានជាទូលព្រះបង្គំជាខ្ញុំយំទួញ
ព្រោះបានស្តាប់ភាសិតនៃអចេលកៈជាកស្សបគោត្ត ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ភាវសេដ្ឋី** សេចក្តីថា សេដ្ឋីដែលមាន
សម្បត្តិ ៨០ កោដិដែលមានឈ្មោះយ៉ាងនេះ ។ បទថា **គុណោរតោ** ប្រែ
ថា ត្រេកអរក្នុងគុណ ។ បទថា **សម្មតោ** សេចក្តីថា ដែលខ្ញុំនអប់រំល្អហើយ ។
បទថា **សុចិ** បានដល់ ជាអ្នកមានកម្មដ៏ស្អាត ។ បទថា **ឥធ ជាតោ ទុរិ-
ត្ថិយា** សេចក្តីថា ខ្ញុំកើតក្នុងផ្ទៃកុម្ភទាសី ដែលជាស្រីទុគ៌តក្រីក្រកំព្រាក្នុង
មិថិលានគរនេះ ។

បានឮមកថា ក្នុងកាលនៃព្រះពុទ្ធព្រះនាមថាកស្សបៈ នាយវីជកបុរស
នោះកើតជាកង្វាលគោ ស្វែងរកគោដែលបាត់ទៅក្នុងព្រៃត្រូវភិក្ខុមួយរូបដែល
ជាអ្នកវង្វេងផ្លូវសួររកផ្លូវបាននៅស្ងៀម ត្រូវលោកសួរម្តងទៀតក៏ក្រោធហើយ
ពោលថា សមណៈខ្ញុំគេនេះមាត់រឹង ប្រហែលជាខ្ញុំគេទើបមាត់រឹងពន់ពេក ។
កម្មមិនបានឲ្យផលក្នុងជាតិនោះ តាំងនៅដូចភ្លើងដែលមានផេះបិទបាំងដូច្នោះ
លុះដល់កាលស្លាប់កម្មដទៃក៏ប្រាកដ ទើបគាត់អន្ទោលក្នុងសង្សារតាមលំដាប់
នៃកម្មព្រោះផលនៃកុសលកម្មណាមួយទើបបានជាសេដ្ឋី មានប្រការដូចពោល
ហើយក្នុងសាកេតបុរី បានធ្វើបុណ្យមានទានជាដើម ។ កម្មដែលគាត់ជេរភិក្ខុ
វង្វេងផ្លូវនោះបិតនៅដូចកំណប់ទ្រព្យដែលកប់ទុកក្នុងផែនដី បានឱកាសទើប

ឲ្យផល ។ ចំណែកបាបកម្មដែលគាត់បានធ្វើទុកក្នុងកាលដេរកិក្ខុវង្វេងផ្លូវបាន ឲ្យផលដល់គាត់ក្នុងអត្តភាពនេះ ។ កាលគាត់មិនដឹង ទើបពោលយ៉ាងនោះ ដោយសម្គាល់ថា សុចរិតកម្មនេះទើបអញកើតក្នុងផ្ទៃរបស់នាងកុម្ភទាសី ។ បទថា **យតោ ជាតោ សុទុគ្គតោ** នាយវីជកៈសម្តែងថា តាំងពីកើតមក ទូលបង្គំជាខ្ញុំទុគ៌តក្រៃពេក ។ បទថា **សមចរិយមធិដ្ឋិតោ** សេចក្តីថា ខ្ញុំ តាំងនៅក្នុងការប្រព្រឹត្តស្មើនោះឯង ។ បទថា **ឧឌ្ឍនេតំ** បានដល់ យ៉ាងនោះ ដោយចំណែកមួយ ។ បទថា **មញ្ញេ ធំ សីលំ** សេចក្តីថា បពិត្រព្រះសម្មតិទេព ធម្មតាសីលនេះប្រហែលជាឥតប្រយោជន៍ ។ បទថា **អលាតោ** សេចក្តីថា អលាតសេនាបតីនេះពោលថា ខ្ញុំធ្វើកម្មអាក្រក់ គឺបាណាតិបាតទុកច្រើនក្នុង ភពមុន ទើបបានតំណែងសេនាបតី ព្រោះហេតុណាហេតុនោះទើបខ្ញុំសម្គាល់ ថាសីលឥតប្រយោជន៍ ។ បទថា **កលិមេវ** សេចក្តីថា បុគ្គលមិនមានសិប្បៈ មិនបានសិក្សា ជាអ្នកលេងបាស្កាកាន់យកការបរាជ័យយ៉ាងណា ខ្ញុំរមែងកាន់ យកយ៉ាងនោះពិត គប្បីឲ្យសម្បត្តិរបស់ខ្លួនក្នុងភពមុនវិនាសទៅ ឥឡូវនេះ ទើបខ្ញុំសោយទុក្ខ ។ ដោយបទថា **កស្សបភាសិតំ** នាយវីជកៈពោលថា ខ្ញុំ បានស្តាប់ភាសិតរបស់អចេលកស្សបគោត្ត ។

ព្រះរាជាព្រះនាមអង្គតិទ្រង់ព្រះសណ្តាប់ពាក្យវីជកៈហើយ ទ្រង់ ត្រាស់ថា ម្នាលវីជកៈ ទ្វារនៃសុគតិមិនមានទេ អ្នកចូរសង្ឃឹម ការដ៏ទៀងចុះ ។ បានឮថា សុខឬទុក្ខជារបស់ទៀងដែលពួក សត្វរមែងតែបាន សេចក្តីបរិសុទ្ធព្រោះសង្សាររបស់សត្វទាំង

អស់ ( រមែងមាន ) អ្នកកុំប្រញាប់ចង់ឃើញក្នុងកាលដែលមិន
ទាន់ដល់ ( កំណត់នោះ ) ឡើយ ។ ក្នុងកាលមុនយើងជាបុគ្គល
ល្អ បានខ្វល់ខ្វាយ ( បម្រើ ) នូវពួកព្រាហ្មណ៍និងគហបតី
កាលប្រៀនប្រដៅនូវវោហារ ( រាជកិច្ច ) ក៏សាបសូន្យចាក
សេចក្តីត្រេកអរ ( ក្នុងកាមគុណ ) ជាលំដាប់ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អង្គតិមព្រាវិ** សេចក្តីថា ព្រះបាទអង្គតិរាជ ស្តាប់ពាក្យរបស់ជនទាំង ៣ គឺរបស់ជនទាំង ២ មុននិងរបស់វីជកៈក្នុងកាលឯក្រោយក៏កើតនូវមិច្ឆាទិដ្ឋិឡើងហើយពោលពាក្យជាដើមថា ទ្វារនៃសុគតិមិនមានទេ ។ បទថា **ឆិយតំ កដ្ឋំ** សេចក្តីថា នែវីជកៈសម្លាញ់ ឯងចូរពិនិត្យមើលតែសេចក្តីដែលទៀងប៉ុណ្ណោះ ។ ព្រះបាទអង្គតិរាជត្រាស់យ៉ាងនេះដោយអធិប្បាយថា សេចក្តីពិតកាលមានប្រមាណ ៨៤ មហាកប្បប៉ុណ្ណោះរមែងញុំាងសត្វទាំងឡាយឲ្យបរិសុទ្ធិបាន នែវីជកៈអ្នកកុំប្រញាប់ប្រញាល់ពេកអី ។ បទថា **អនាគតេ** សេចក្តីថា កាលមិនទាន់ដល់ពេលនោះ ឯងកុំរួសរាន់ថាអញនឹងទៅកាន់ទេវលោកក្នុងចន្លោះបាន ។ បទថា **ធាវ៉ដោ** សេចក្តីថា កុំមានសេចក្តីខ្វល់ខ្វាយដោយការធ្វើ មានធ្វើការខ្វល់ខ្វាយផ្លូវកាយមានការឲ្យទានជាដើមដល់ជនទាំងឡាយនោះ គឺក្នុងពួកព្រាហ្មណ៍និងគហបតីទាំងឡាយ ។ បទថា **វោហារំ** សេចក្តីថា អង្គុយក្នុងទីជាទីវិនិច្ឆ័យ ហើយទូន្មានតាមបញ្ញត្តនៃរាជកិច្ច ។ បទថា **រតិហីនោ តទន្តរា** សេចក្តីថា លះចាកការត្រេកអរក្នុងកាមគុណអស់កាលមានប្រមាណប៉ុណ្ណោះ កាលព្រះរាជាត្រាស់យ៉ាងនេះ

ហើយក៏ត្រាស់លាគុណាជីវកថា នៃកស្សបគោត្ត ពួកខ្ញុំប្រមាទមកហើយអស់កាលមានប្រមាណប៉ុណ្ណេះ តែឥឡូវនេះពួកខ្ញុំបាននូវអាចារ្យហើយ ចាប់ពីពេលនេះទៅពួកខ្ញុំនឹងត្រេកអរតែក្នុងកាមគុណប៉ុណ្ណោះសូម្បីការស្តាប់ធម៌ក្នុងសម្នាក់លោកម្ចាស់ឲ្យក្រៃលែងជាងនេះទៀតក៏ជាការយឺតយូររបស់ពួកខ្ញុំទទេ សូមលោកម្ចាស់ឈប់ចុះ ពួកខ្ញុំនឹងលាទៅដូច្នេះ ទើបត្រាស់កន្លះគាថានេះថា

ព្រះរាជាទ្រង់ត្រាស់នឹងអចេលកៈជាកស្សបគោត្តថា បពិត្រ
លោកដ៏ចម្រើន ប្រសិនបើមានការប្រជុំយើងនឹងជួបគ្នាម្តង
ទៀត ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សង្គតិ ចេ** សេចក្តីថា បើការប្រជុំរបស់ពួកយើងនឹងមានក្នុងទីណាមួយ បើផលបុណ្យរបស់ពួកខ្ញុំមិនមានប្រយោជន៍អ្វីដោយលោកដែលខ្ញុំនឹងមកសួរសុខទុក្ខ ។

ព្រះបាទវិទេហៈទ្រង់ត្រាស់ព្រះតម្រាស់នេះហើយ ទ្រង់ត្រឡប់
ទៅកាន់ព្រះនិវេសន៍របស់ព្រះអង្គវិញ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សន្និវេសនំ** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ ព្រះបាទវិទេហរាជកាលត្រាស់ពាក្យនេះហើយទើបយាងឡើងកាន់រថព្រះទីន័ងត្រឡប់ទៅកាន់ចន្ទកប្រាសាទដែលជាព្រះរាជនិវេសន៍របស់ទ្រង់ ។

ដំបូងព្រះរាជាយាងទៅកាន់សម្នាក់របស់គុណាជីវក ទ្រង់នមស្ការរួចទើបត្រាស់សួរបញ្ហា កាលទ្រង់ត្រឡប់ទ្រង់មិននមស្ការឡើយ ។ គុណាជីវកមិនបានទទួលការថ្វាយបង្គំ ព្រោះជាអ្នកមិនមានគុណ ធ្វើម្តេចនឹងបានទទួលព្រះ

រាជទានសក្ការៈមានដុំបាយជាដើម ។ ឯព្រះរាជាទ្រង់ញ៉ាំងរាត្រីនោះឲ្យកន្លងទៅ ស្អែកឡើង ទើបឲ្យនូវការប្រជុំពួកអាមាត្យហើយត្រាស់ថា ពួកអ្នកចូរបម្រើកាមគុណចុះ ចាប់តាំងអំពីថ្ងៃនេះទៅយើងនឹងសោយសុខក្នុងកាមគុណប៉ុណ្ណោះ កុំចាំបាច់ប្រាប់កិច្ចការដទៃឲ្យយើងដឹងឡើយ បុគ្គលណាមួយចូរធ្វើការវិនិច្ឆ័យចុះ កាលត្រាស់ដូច្នេះហើយទ្រង់ស្រវឹងត្រេកអរតែក្នុងកាមគុណប៉ុណ្ណោះ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហា** វីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូត្រសានូវព្រះគាថាដូច្នេះថា

លំដាប់នោះ លុះរាត្រីអស់ហើយ ព្រះបាទអង្គតិទ្រង់ប្រជុំពួក
អាមាត្យ ក្នុងទីជាទីបម្រើ ហើយត្រាស់ព្រះតម្រាស់ដូច្នេះថា
អាមាត្យទាំងឡាយ ចូរចាត់ចែងកាមទាំងឡាយក្នុងវិមានចន្ទក៍
របស់យើងសព្វៗកាល នាកាលសេចក្តីកំបាំងនិងសេចក្តីជាក់
ស្តែងកើតឡើងហើយ អាមាត្យឯណានីមួយកុំមករកយើង
ឡើយ ។ អាមាត្យឈ្មោះវិជយៈ ១ ឈ្មោះសុនាមៈ ១
អលាតសេនាបតី ១ ទាំង ៣ នេះជាអ្នកឈ្លាសវៃក្នុងវោហារ
( រាជកិច្ច ) ចូរអង្គុយក្នុងទីជាទីវិនិច្ឆ័យសេចក្តីនេះចុះ ។ ព្រះ
បាទវិទេហៈលុះទ្រង់ត្រាស់ព្រះតម្រាស់នេះហើយ ក៏សំគាល់កាម
ទាំងឡាយដ៏ច្រើន ឈប់ខ្វល់ខ្វាយ ចំពោះព្រាហ្មណ៍គហបតី

និងសេចក្តីណាទីមួយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧបដ្ឋានម្ហិ** បានដល់ ក្នុងទីបម្រើរបស់ព្រះអង្គ ។ បទថា **ចន្ទកេ មេ** បានដល់ ក្នុងចន្ទកប្រាសាទដែលជាសម្នាក់របស់យើង ។ បទថា **វិធេន្តុ មេ** សេចក្តីថា ចូររៀបចំ គឺចូរបម្រើតាមគុណទាំងឡាយដល់យើងជានិច្ច ។ បទថា **គុយ្ហចាកាសិយេសុ** សេចក្តីថា កាលរឿងកំបាំងក្តី មិនកំបាំងក្តីកើតឡើងអ្នកណាក៏កុំមករកយើង ។ បទថា **អត្ថេ** បានដល់ ក្នុងទីវិនិច្ឆ័យហេតុផល ។ បទថា **និសីទន្តុ** សេចក្តីថា ចូរអង្គុយជាមួយអាមាត្យដ៏សេសដើម្បីធ្វើកិច្ចការដែលយើងគប្បីធ្វើ ។

តាំងពីកាលនោះមករហូតដល់រាត្រី ១៤ នាងរាជកញ្ញារបស់ព្រះបាទវិទេហៈ ព្រះនាមរុចាជាធីតាបង្កើត ជាទីស្រឡាញ់បានពោលចំពោះមេនំថា នែម៉ែ សូមម៉ែប្រដាប់ស្អិតស្អាងខ្ញុំទាំងពួកស្ត្រីជាសម្លាញ់របស់ខ្ញុំក៏ចូរប្រដាប់ស្អិតស្អាងដែរ ស្អែកជាថ្ងៃទី ១៥ ជាថ្ងៃទិព្វ ខ្ញុំនឹងទៅកាន់សំណាក់បិតា ។ ស្ត្រីទាំងឡាយបាននាំមកនូវផ្កាកម្រង ខ្លឹមចន្ទន៍ កែវមណី ស័ង្ខ កែវមុក្តាមានតម្លៃដ៏ច្រើននិងសំពត់អម្ពរណ៍មានពណ៌ក្រហមផ្សេងៗ ថ្វាយព្រះរាជកញ្ញានោះ ។ ពួកស្ត្រីដ៏ច្រើនបានចោមរោមព្រះរាជកញ្ញាព្រះនាមរុចានោះដែលមានសម្បុរដ៏រុងរឿង កំពុងគង់លើតាំងជាវិការៈនៃមាស ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តតោ** សេចក្តីថា ចាប់តាំងពីថ្ងៃដែលព្រះ

រាជាជាប់ក្នុងកក់ គឺកាមគុណនោះ ។ បទថា **ចុទ្ទសរត្តស្ស** ប្រែថា ក្នុងថ្ងៃទី ១៤ ។ បទថា **ញាតិមាតរមព្រវិ** សេចក្ដីថា ជាអ្នកប្រាប្ជានឹងទៅកាន់សម្នាក់របស់ព្រះរាជបិតា ទើបពោលនឹងកីលៀងទាំងឡាយ ។

បានឮមកថា ក្នុងថ្ងៃទី ១៤ ព្រះនាងរុចារាជធីតានាំសំពត់ពណ៌ផ្សេងៗ ចោមរោមទៅដោយពួកកុមារី ៥០០ នាំពួកកីលៀងចុះអំពីប្រាសាទ ៧ ជាន់ ដោយសិរីវិលាសធំក្រៃលែងយាងទៅកាន់ចន្ទកប្រាសាទដើម្បីគាល់ព្រះជនកលំដាប់នោះព្រះបាទវិទេហៈទតឃើញព្រះរាជធីតា ទ្រង់មានព្រះហឫទ័យត្រេកអរឲ្យរៀបចំមហាសក្ការៈទទួល កាលនឹងបញ្ជូនត្រឡប់ទើបព្រះរាជទានទ្រព្យ ១០០០ ហើយបញ្ជូនទៅដោយពាក្យថា នែកូន ចូរនាងឲ្យទាន ព្រះនាងរុចាយាងទៅកាន់និវេសន៍របស់ខ្លួនហើយ ស្អែកឡើងព្រះនាងរក្សាឧបោសថសីល ឲ្យទានដល់មនុស្សកំព្រាអ្នកដើរផ្លូវឆ្ងាយ យាចកនិងស្មូមជាច្រើន ។

បានឮថា ជនបទមួយព្រះបាទវិទេហរាជបានព្រះរាជទានដល់ព្រះធីតា ព្រះនាងរុចាបានធ្វើកិច្ចទាំងពួង បានចំណូលអំពីជនបទនោះតែក្នុងកាលនោះ ក៏ល្បីពេញព្រះនគរថា ព្រះរាជាទ្រង់អាស្រ័យគុណាជីវកទ្រង់ក៏កាន់យកនូវមិច្ឆាទិដ្ឋិ ។ ពួកកីលៀងបានឮដូច្នោះទើបមកទូលព្រះនាងរុចាថា បានឮមកថា ព្រះជនករបស់ព្រះនាងស្ដាប់ពាក្យអាជីវកហើយទ្រង់ដល់នូវមិច្ឆាទិដ្ឋិនិងបានឮថា ព្រះរាជានោះត្រាស់ឲ្យរើរោងទានត្រង់ទ្វារនគរទាំង ៤ ហើយទ្រង់សេពគប់នឹងស្ត្រីនិងទារិកាដែលអ្នកដទៃហួងហែង ទ្រង់មិនពិចារណាដល់ករណីយកិច្ចឡើយ ទ្រង់ឆប់ជ្រប់តែក្នុងកាមគុណ ។ ព្រះនាងរុចាបានស្ដាប់

ពាក្យរបស់កីលៀងទាំងនោះ ព្រះនាងសង្កេតទើបព្រះតម្រិះថា ព្រោះហេតុអ្វីហ្ន៎ទើបព្រះជនករបស់អញយាងទៅសួរបញ្ហានឹងគុណាជីវក ដែលប្រាសចាកគុណ មិនមានខ្មាសជាអ្នកអាក្រាតកាយដូច្នេះ សមណព្រាហ្មណ៍ដែលមានធម៌ជាកម្មវាទីគួរចូលទៅសួរមានមិនមែនឬ តែវៀរអញហើយអ្នកដែលដោះនូវមិច្ឆាទិដ្ឋិរបស់ព្រះជនកនៃអញ ឲ្យត្រឡប់តាំងនៅក្នុងសម្មាទិដ្ឋិវិញមិនមានទេ ឯអញរឭកជាតិបានរហូត ១៤ ជាតិ គឺក្នុងអតីត ៧ ជាតិនិងអនាគត ៧ ជាតិព្រោះដូច្នោះអញនឹងទូលនូវកម្មអាក្រក់ដែលខ្លួនធ្វើក្នុងជាតិមុននិងសម្តែងផលនៃកម្មអាក្រក់ ជាស់តឿននូវព្រះជនករបស់អញឲ្យភ្ញាក់ តែបើអញចូលទៅក្នុងថ្ងៃនេះសោត ព្រះជនករបស់អញគង់នឹងសួរថា ពីមុនកូនធ្លាប់មករៀងរាល់កន្ទះ ព្រោះហេតុអ្វីទើបថ្ងៃនេះប្រញាប់មក បើអញទូលថា ខ្ញុំមកក្នុងថ្ងៃនេះព្រោះបានឮថា ទ្រង់កាន់យកនូវមិច្ឆាទិដ្ឋិ ដូច្នេះពាក្យរបស់អញមិនមានតម្លៃឡើយ ព្រោះដូច្នោះអញមិនត្រូវគាល់ក្នុងថ្ងៃនេះឡើយ ចាំ ១៤ ថ្ងៃទៀត ក្នុងថ្ងៃ ១៤ ក្នុងកាឡបក្ខអញធ្វើជាមិនដឹង ចូលទៅគាល់ដោយអាការដែលធ្លាប់ចូលទៅគាល់ក្នុងកាលមុនៗ ក្នុងគ្រាត្រឡប់អញនឹងទូលសូមទ្រព្យមួយពាន់មកធ្វើទាន កាលនោះ ព្រះជនករបស់អញនឹងបង្ហាញមិច្ឆាទិដ្ឋិដល់អញ វេលានោះអញនឹងបានឱកាសឲ្យទ្រង់លះបង់មិច្ឆាទិដ្ឋិនោះបាន ដោយកម្លាំងនៃខ្លួន ។ ព្រោះដូច្នោះក្នុងថ្ងៃ ១៤ ទើបព្រះនាងរុចារាជធីតាប្រាថ្នាទៅគាល់ព្រះជនកទើបត្រាស់យ៉ាងនោះ ។

បណ្តាបទទាំងនោះ បទថា **សខិយោ** ច សេចក្តីថា ស្រីសម្លាញ់នឹង

កុមារិកាប្រមាណ ៥០០ របស់អញទាំងអស់ ចូរប្រដាប់ដោយគ្រឿងអលង្ការផ្សេងៗ ម្នាក់មួយបែបកុំឲ្យដូចគ្នា គឺដោយផ្កា គ្រឿងក្រអូបនិងគ្រឿងលាបមានពណ៌ផ្សេងៗ ។ បទថា **ធិព្យោ** ប្រែថា ថ្ងៃទិព្វ ។ ដែលឈ្មោះថា ទិព្វព្រោះប្រជុំគ្នាប្រដាប់គ្រឿងអលង្ការដូចទេវតាក៏មាន ។ បទថា **គច្ឆំ** សេចក្ដីថា អញនឹងទៅគាល់ព្រះបាទវិទេហរាជដែលជាព្រះជនក ដើម្បីឲ្យនាំទានវត្តរបស់អញមក ។ បទថា **អភិហរឹសុ** សេចក្ដីថា បានឮមកថា ឲ្យផ្ទួតដោយក្អមទឹក ១៦ ក្អមហើយនាំទៅដើម្បីប្រដាប់តាក់តែងនាងកុមារិកា ។ បទថា **បរិកិរិយ** បានដល់ ចោមរោមហើយ ។ បទថា **អសោភឹសុ** សេចក្ដីថា ថ្ងៃនោះស្រីបរិវារនាំគ្នាចោមរោមព្រះនាងរុចារាជធីតាដែលល្អក្រៃពេកដូចទេវកញ្ញា ។

> ឯនាងរុចានោះស្អិតស្អាងដោយគ្រឿងអាភរណៈទាំងពួង ឋិតនៅក្នុងកណ្ដាល នៃពួកស្ត្រីជាសម្លាញ់ បានចូលទៅកាន់វិមានចន្ទក៏ដូចជាផ្ទេកបន្ទោរអាស្រ័យមេឃ ។ លុះចូលទៅដល់ហើយក៏ថ្វាយបង្គំព្រះបាទវិទេហៈ ដែលទ្រង់ត្រេកអរក្នុងវិន័យ ហើយយាងចូលទៅគង់លើតាំង ដែលវិចិត្រដោយមាស ក្នុងទីសមគួរ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សតេរិតា** បានដល់ ដូចផ្ទេកបន្ទោរ ។ បទថា **អព្ភមិវ** បានដល់ វាសចេញអំពីស្រទាប់ពពក ។ បទថា **បាវិសី** សេចក្ដីថា ចូលទៅកាន់ចន្ទកប្រាសាទ ដែលជាទីប្រថាប់របស់ព្រះជនក ។

បទថា **សុវណ្ណាចិតេ** បានដល់ តាំងដែលធ្វើអំពីមាស វិចិត្រដោយរតនៈ ៧ ប្រការ ។

ព្រះបាទវិទេហៈ ទ្រង់ទតឃើញការប្រជុំនោះដូចជាទីប្រជុំពួកស្ត្រីទេពអប្សរ ទើបត្រាស់ព្រះតម្រាស់នេះនឹងនាងរុចា ដែលឋិតនៅត្រង់កណ្តាលនៃពួកស្ត្រីជាសម្លាញ់ថា នាងត្រេកអរក្នុងប្រាសាទ ស្រះបោក្ខរណីខាងក្នុងដែរឬ ពួកជនបាននាំមកនូវបង្អែមមានប្រការដ៏ច្រើនដល់នាងសព្វកាលដែរឬ ។ នាងទាំងឡាយជាកុមារីបានក្រងកម្រងផ្កាដ៏ច្រើន ជាស្ត្រីនៅលេងល្បែងត្រេកអរដោយសេចក្តីសប្បាយ បានធ្វើផ្ទះតូចៗទាំងឡាយផ្សេងៗគ្នាខ្លះដែរឬ ។ មួយទៀតនាងខ្វះខាតដោយវត្ថុអ្វី ជនទាំងឡាយបាននាំមកយ៉ាងឆាប់ដល់នាងដែរឬ ម្នាលនាងមានភក្ត្រផាត់លាបល្អ នាងចូរធ្វើតាមចិត្តចុះសូម្បីរបស់ស្មើដោយព្រះចន្ទ្រក៏ឪពុកផ្តល់ឲ្យនាងដែរ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អច្ឆរានំវ សង្ឃំ** សេចក្តីថា ទតឃើញសមាគមនោះដូចសមាគមនៃទេពអប្សរ ។ បទថា **ធាសាទេ** សេចក្តីថា នៃកូន នាងត្រេកអរក្នុងរតិវឌ្ឍនប្រាសាទដែលស្មើនឹងវេជយន្តប្រាសាទដែលឪពុកសាងទុកដើម្បីនាងដែរឬ ។ បទថា **អន្តោ ពោក្ខរណឹ បតិ** សេចក្តីថា នាងនៅលេងទឹក ត្រេកអរក្នុងស្រះបោក្ខរណី ដែលមានចំណែកប្រៀបដូចនន្ទបោក្ខរណីដែលឪពុកសាងទុកខាងក្នុងឧទ្យានដើម្បីកូនដែរឬទេ ។ ដោយ

បទថា **មាល្យំ** សេចក្តីថា ព្រះបាទវិទេហរាជត្រាស់ថា នែកូន ឪពុកនឹងបញ្ជូនប្រអប់ផ្កា ២៥ ប្រអប់ដល់កូនរាល់ៗថ្ងៃ កុមារិកាទាំងឡាយនៅក្រងផ្កានោះលេងដោយសេចក្តីត្រេកអរជានិច្ចជាមួយកូនដែរឬ នៅធ្វើផ្ទះតូចៗលេងដោយសេចក្តីត្រេកអរដែរឬ ពួកនាងធ្វើផ្ទះផ្កា បន្ទប់ផ្កា អាសនៈផ្កា ទីដេកផ្កាដូចប្រណាំងប្រជែងដោយចំពោះយ៉ាងនេះថា អញនឹងធ្វើឲ្យល្អជាងដែរឬ ។ បទថា **វិកលំ** ប្រែថា ខ្វះខាត ។ បទថា **មន ការស្សុ** សេចក្តីថា ចូរញុំាងចិត្តឲ្យកើត ។ ដោយបទថា **កុដ្ឋមុខី** ព្រះបាទវិទេហរាជត្រាស់នឹងព្រះនាងរុចានោះយ៉ាងនោះ ព្រោះព្រះនាងមានមុខផូរផង់ដោយម្សៅគ្រាប់ស្ពៃពិតហើយ ស្រីទាំងឡាយធ្វើមុខឲ្យផូរផង់ លាបមុខដោយម្សៅគ្រាប់ស្ពៃមុនដើម្បីកម្ចាត់ពកដែលមានលោហិតដែលមានត្រង់មុខជាមុន បន្ទាប់អំពីនោះលាបដោយលម្អិតដីដើម្បីធ្វើលោហិតឲ្យស្មើ បន្ទាប់អំពីនោះលាបដោយម្សៅល្ងដើម្បីធ្វើស្បែកឲ្យផូរផង់ ។ បទថា **ចន្ទសមំ ហិ តេ** សេចក្តីថា ឈ្មោះថា របស់ដែលរកបានក្រជាងព្រះចន្ទមិនមាន នាងគាប់ចិត្តក្នុងរបស់បែបនោះ ចូរប្រាប់ឪពុកៗនឹងចាត់ចែងឲ្យដល់កូន ។

នាងរុចាបានស្តាប់ព្រះរាជឱង្ការព្រះបាទវិទេហៈហើយ ទូលតប
ព្រះបិតាថា បពិត្រមហារាជ របស់ទាំងអស់នុ៎ះ ខ្ញុំម្ចាស់តែង
បានក្នុងសំណាក់របស់ព្រះអង្គជាឥស្សរៈ ។ ស្អែកជាថ្ងៃទី ១៥
ជាទិព្វ សូមឲ្យពួកជននាំកហាបណៈមួយពាន់ដល់ខ្ញុំម្ចាស់ ៗ
នឹងឲ្យទាន ចំពោះវណិព្វកៈទាំងអស់ តាមទំនងដែលខ្ញុំម្ចាស់

ធ្លាប់ឲ្យហើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សព្វាសណីសុ្វហំ** សេចក្ដីថា ខ្ញុំនឹងឲ្យទានក្នុងបណ្ដាស្នូមទាំងពួង ។

ព្រះរាជាអង្គតិទ្រង់ព្រះសណ្ដាប់ពាក្យនាងរុចាហើយទ្រង់ត្រាស់ថា ទ្រព្យដ៏ច្រើនឈ្មោះថា នាងធ្វើឲ្យវិនាសធ្វើឲ្យឥតប្រយោជន៍ធ្វើឲ្យឥតផលហើយ ។ នាងរក្សាឧបោសថមិនបរិភោគបាយទឹកជានិច្ច ឯបាយនិងទឹកដែលនាងមិនបរិភោគនេះ ជារបស់ទៀងបុណ្យមិនមានដល់បុគ្គលដែលមិនបរិភោគទេ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អង្គតិមព្រវិ** សេចក្ដីថា ម្នាលភិក្ខុទាំងឡាយព្រះបាទអង្គតិរាជនោះ សូម្បីព្រះរាជធីតាធ្លាប់ទូលសូម ក៏បានឲ្យទ្រព្យមួយពាន់ដោយត្រាស់ថា នែកូន ចូរនាងឲ្យទានតែត្រូវព្រះរាជធីតាទូលសូមក្នុងថ្ងៃនោះ ក៏មិនឲ្យព្រោះកាន់យកមិច្ឆាទិដ្ឋិទើបត្រាស់ពាក្យនេះថា ទ្រព្យដ៏ច្រើនឈ្មោះថា នាងធ្វើឲ្យវិនាស ជាដើម ។ បទថា **ឆិយតេតំ អត្តត្តពុំ** សេចក្ដីថា នាងមិនបរិភោគអាហារនេះដោយអំណាចត្រូវកំណត់ទុក បុណ្យរមែងមិនមានដល់បុគ្គលដែលបរិភោគក្ដី មិនបរិភោគក្ដី មនុស្សទាំងពួងគប្បីបរិសុទ្ធិបានដោយមិនរំលង ៨៤ មហាកប្បឡើយ ។

ដូចយ៉ាងទាសៈឈ្មោះ វីជកៈ បានស្ដាប់កាសិតអចេលកៈជាកស្សបគោត្ត ក្នុងកាលនោះ ក៏ដកដង្ហើមចេញដ៏ក្ដៅរឿយៗយំសម្រក់ទឹកភ្នែក ។ ម្នាលនាងរុចានាងកាលរស់នៅជាបណ្ណា

កុំអត់បាយឡើយ ម្នាលនាងដ៏ចម្រើន បរលោកមិនមានទេ

ព្រោះហេតុអ្វីនាងប្រឹងឲ្យលំបាកឥតប្រយោជន៍ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វីជកោបិ** សេចក្តីថា ព្រះបាទអង្គតិរាជទ្រង់នាំរឿងវីជកបុរសមកជាឧទាហរណ៍ដល់ព្រះរាជធីតាថា សូម្បីវីជកបុរសធ្វើកល្យាណកម្មក្នុងកាលមុន ព្រោះផលនៃកម្មនោះទើបកើតក្នុងផ្ទៃទាសី ។ បទថា **ឥត្ថិ ភទ្ទេ** សេចក្តីថា នៃនាងដ៏ចម្រើន គុណាចារ្យពោលយ៉ាងនេះថា លោកនេះមិនមាន លោកដទៃមិនមាន មាតាមិនមាន បិតាមិនមាន សត្វទាំងឡាយដែលជាឧបបាតិកៈមិនមាន សមណព្រាហ្មណ៍ដែលជាអ្នកត្រេកអរក្នុងការព្រមព្រៀងបដិបត្តិប្រពៃមិនមានក្នុងលោក កាលបរលោកមាន លោកខាងមុខឈ្មោះថាគប្បីមាន លោកនេះឯងរមែងមិនមាន កាលមាតាបិតាមានបុត្តធីតាឈ្មោះថាមាននោះឯងតែមាតាបិតាមិនមាន កាលធម៌មាន សមណ-ព្រាហ្មណ៍ដែលតាំងនៅក្នុងធម៌គប្បីមាននោះឯង តែសមណព្រាហ្មណ៍ទាំងនោះមិនមាន កូនឲ្យទានធ្វើអ្វី រក្សាសីលធ្វើអ្វី ក្តៅក្រហាយធ្វើអ្វីមិនមានប្រយោជន៍ទេ ។

នាងរុចា មានសម្បុរដ៏រុងរឿងបានស្តាប់ព្រះបន្ទូលព្រះបាទវិទេហៈ កាលដឹងធម៌ខាងដើមនិងខាងចុងទើបពោលពាក្យនេះនឹងបិតាថា ពីដើមខ្ញុំម្ចាស់គ្រាន់តែឮ ( ថ្ងៃនេះ ) រឿងនេះខ្ញុំម្ចាស់ឃើញជាក់ច្បាស់ហើយថា បុគ្គលណាសេពគប់នឹងជនពាល បុគ្គលនោះទៅជាបុគ្គលពាលដែរ ។ ដ្បិតថា បុគ្គលវង្វេង

អាស្រ័យនឹងបុគ្គលវង្វេង រមែងដល់នូវសេចក្តីវង្វេងដ៏លើស
លុប អលាតសេនាបតីនិងទាសៈឈ្មោះវីជកៈគួរវង្វេងទៅចុះ
( តែព្រះអង្គកុំវង្វេងឡើយ ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បុព្វាបរំ ធម្មំ** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ ព្រះនាងរុចារាជធីតាបានស្តាប់ព្រះតម្រាស់របស់ព្រះជនក ព្រះនាងដឹងធម៌ក្នុងកាលមុន គឺក្នុងអតីត ៧ ជាតិនិងធម៌ដែលមិនទាន់មកដល់ គឺអនាគត ៧ ជាតិ បំណងនឹងដោះព្រះជនកអំពីមិច្ឆាទិដ្ឋិទើបត្រាស់ពាក្យនេះ មានពាក្យផ្តើមថា **សុតមេវ** ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **សមបជ្ជថ** សេចក្តីថា បុគ្គលណាគប់រកបុគ្គលពាល បុគ្គលនោះក៏សម្រេចជាបុគ្គលពាលទៅដែរ ដូច្នេះពាក្យនេះខ្ញុំបានឮមកពីមុននោះឯងតែថ្ងៃនេះខ្ញុំឃើញប្រចក្សហើយ ។ បទថា **មុឡ្ហោ ហិ** សេចក្តីថា សូម្បីមនុស្សវង្វេងដោយអំណាចទិដ្ឋិអាស្រ័យមនុស្សវង្វេងដោយអំណាចទិដ្ឋិរមែងដល់នូវការវង្វេងក្រៃលែងឡើង វង្វេងខ្លាំងឡើងដូចមនុស្សវង្វេងផ្លូវអាស្រ័យមនុស្សវង្វេងផ្លូវដូច្នោះ ។ បទថា **អលាតេន** សេចក្តីថា បពិត្រព្រះសម្មតិទេព ការដែលទ្រង់អាស្រ័យគុណាជីវកដែលជាបុគ្គលពាល មិនមានខ្នាសដូចក្មេងអ្នកស្រុក ហើយមកវង្វេងជាមួយនឹងអលាតសេនាបតី ដែលវិនាសចាកជាតិ គោត្ត ត្រកូល ប្រទេស ភាពជាធំ បុណ្យនិងបញ្ញានិងជាមួយវីជកទាសៈគ្មានបញ្ញា ជាអ្នកសាបសូន្យហើយដោយចំណែកមួយជាការមិនសមគួរ ព្រោះហេតុអ្វីទើបទ្រង់វង្វេងជាមួយបុគ្គលបែបនោះ ។

ព្រះនាងរុចារាជធីតាតិះដៀលជនទាំង ២ យ៉ាងនេះហើយ កាលព្រះនាងសរសើរព្រះជនក ដោយបំណងនឹងដោះចាកមិច្ឆាទិដ្ឋិទើបក្រាបទូលថា

បពិត្រព្រះសម្មតិទេព ព្រះអង្គប្រកបដោយបញ្ញា ជាអ្នកប្រាជ្ញ
ឈ្លាសក្នុងសេចក្តីចម្រើន ហេតុអ្វីព្រះអង្គប្រហែលនឹងពួក
ជនពាល ហើយលុះទិដ្ឋិថោកទាប ។ ប្រសិនបើសត្វបរិសុទ្ធ
ដោយគន្លងនៃសំសារបព្វជ្ជានៃអចេលកៈឈ្មោះគុណៈ ក៏មិន
មានប្រយោជន៍ដែរ អចេលកៈឈ្មោះគុណៈ ជាអ្នកវង្វេងដោយ
មោហៈ ដល់នូវភាពជាអ្នកអាក្រាត ដូចជាសត្វកណ្តូបទម្លាក់ខ្លួន
ក្នុងភ្លើងកំពុងឆេះ ។ ជនទាំងឡាយច្រើននាក់កាលមិនដឹង ត្រូវ
អចេលកៈឈ្មោះ គុណៈទូន្មានហើយក្នុងកាលមុនថា សេចក្តី
បរិសុទ្ធព្រោះសំសារដូច្នេះក៏បដិសេធនូវកម្មចេញ ប្រយោជន៍
ដែលជនកាន់មិនល្អហើយក្នុងកាលមុនក៏ទៅជាទោស ដូចត្រី
ដែលរួចអំពីសន្ទូចបានដោយក្រ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សប្បញ្ញោ** សេចក្តីថា ទ្រង់ជាអ្នកមានបញ្ញាដោយបញ្ញាដែលបានដោយអំណាចយស វ័យ បុណ្យ សេចក្តីព្យាយាម យោនិសោមនសិការៈនិងការសន្ទនាធម៌ឈ្មោះថា **ធីរោ** ព្រោះហេតុនោះដូចគ្នាឈ្មោះថា **កោវិទោ** ព្រោះឈ្លាសក្នុងប្រយោជន៍និងមិនមែនប្រយោជន៍ គឺក្នុងហេតុនិងមិនមែនហេតុព្រោះភាពជាអ្នកប្រាជ្ញ ។ បទថា **ពាលេហិ ស-ទិសោ** សេចក្តីថា ទ្រង់ជាអ្នកចូលដល់ទិដ្ឋិដ៏អាក្រក់ដូចមនុស្សពាលទាំងនោះ

ចូលដល់បានដូចម្តេច ។ បទថា **អចាបតំ** កាត់បទជា **អបិ អាបតំ** អធិប្បាយថា កំពុងធ្លាក់ទៅ ។ ព្រះរាជធីតាត្រាស់បរិយាយទុកថា បពិត្រព្រះជនក បើការបរិសុទ្ធដោយសង្សារមានសូម្បីគុណាជីវកក៏លះកាមគុណ ៥ ហើយដល់នូវភាពជាមនុស្សអាក្រាតកាយមិនមានសិរី មិនមានការខ្មាស មិនមានការត្រេកអរព្រោះវង្វេងដោយអំណាចមោហៈ ដូចកណ្ដូបឃើញភ្លើងឆេះសន្ធោសន្ធៅក្នុងចំណែកនៃរាត្រី មិនដឹងដល់ទុក្ខដែលមានគំនរភ្លើងនោះជាបច្ច័យ ធ្លាក់ក្នុងគំនរភ្លើងនោះដល់នូវទុក្ខធំដូច្នោះ ។ បទថា **បុរេ ឆវិជ្ជា** សេចក្ដីថា បពិត្រព្រះជនក ជនជាច្រើនស្តាប់ពាក្យរបស់កស្សបគោត្តថា សេចក្ដីបរិសុទ្ធរមែងមានដោយសង្សារវដ្ដ ជឿស៊ប់នោះឯង ព្រោះកាន់យកថា ផលនៃកម្មដែលធ្វើល្អនិងធ្វើអាក្រក់រមែងមិនមាន កាលមិនដឹង ក៏កាន់យកវត្ថុដែលមិនជាប្រយោជន៍ដោយការឃើញខុសទើបបដិសេធកម្ម អធិប្បាយថា កាលបដិសេធកម្មនោះក៏ឈ្មោះថា បដិសេធផលនៃកម្មដូចគ្នា កាលពួកជនទាំងនោះកាន់យកទោសដែលជាភាពបរាជ័យខាងដើមយ៉ាងនេះ ក៏ឈ្មោះថា កាន់យកខុស ។ បទថា **ទុម្មោចយា ពលិសា អម្ពុជោវ** សេចក្ដីថា ជនពាលទាំងនោះ កាលមិនដឹងយ៉ាងនេះ កាន់យកសេចក្ដីវិនាសដោយការឃើញខុសតាំងនៅរមែងឈ្មោះថា ដោះអំពីសេចក្ដីវិនាសនោះបានដោយលំបាកដូចត្រីដែលលេបផ្ទៃសន្ទូចចូលទៅ ដោះចេញបានដោយក្រដូច្នោះ ។

ព្រះនាងរុចារាជធីតា កាលត្រាស់ដូច្នេះហើយ កាលព្រះនាងទូន្មានព្រះរាជាឲ្យក្រៃលែងទើបត្រាស់គាថាទាំងនេះថា

បពិត្រមហារាជ ខ្ញុំម្ចាស់នឹងធ្វើឧបមាថ្វាយព្រះអង្គ ដើម្បីប្រយោជន៍ដល់ព្រះអង្គព្រោះថាបណ្ឌិតពួកខ្លះក្នុងលោកនេះរមែងដឹងសេចក្ដីដោយពាក្យឧបមា ។ ទូករបស់ពួកឈ្មួញផ្ទុកភារៈធ្ងន់ហួសប្រមាណ នាំទៅនូវភារៈធ្ងន់លើសលុប រមែងលិចក្នុងសមុទ្រយ៉ាងណា នរជនកាលសន្សំបាបបន្តិចម្ដងៗឈ្មោះថា ជាអ្នកកាន់យកនូវភារៈដ៏លើសលុប រមែងលិចក្នុងនរកយ៉ាងនោះដែរ ។ បពិត្រព្រះអង្គជាម្ចាស់ផែនដី ភារៈដ៏ធ្ងន់របស់អលាតសេនាបតីមិនទាន់ពេញប្រៀបនៅឡើយ អលាតសេ-នាបតីទៅកាន់ទុគ្គតិព្រោះបាបណា គាត់នៅតែសន្សំបាបនោះ ។ បពិត្រព្រះអង្គជាម្ចាស់ផែនដី អលាតសេនាបតី បានធ្វើបុណ្យហើយក្នុងកាលមុន បពិត្រព្រះសម្មតិទេព ឯអលាតសេនាបតីនុ៎ះបានសុខព្រោះអានិសង្សបុណ្យដែលគាត់ធ្វើហើយក្នុងកាលមុននោះឯង ។ បុណ្យនោះរបស់គាត់អស់ហើយបានជាគាត់ត្រេកអរក្នុងអកុសលកម្ម លះបង់នូវផ្លូវត្រង់ហើយដើរទៅតាមផ្លូវវៀចវិញ ។ កាលវត្ថុធ្ងន់ដែលគេដាក់ក្នុងមណ្ឌលនៃជញ្ជីង ជញ្ជីងក៏បះ កាលបើភារៈគេដាក់ចេញហើយ ក្បាលជញ្ជីងក៏ងើបឡើងយ៉ាងណាមិញ ។ នរជនកាលសន្សំបុណ្យសូម្បីបន្តិចម្ដងៗដូចជាទាសៈឈ្មោះវីជកៈ កាលប្រាថ្នាឋានសួគ៌ត្រេកអរក្នុងកុសលកម្មមានផលល្អក៏យ៉ាងនោះដែរ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **និរយេ** បានដល់ មហានរក ៨ រណ្ដៅ ឧស្សទនរក ១៦ រណ្ដៅនិងលោកន្តរនរក ។ បទថា **ភាគោ** សេចក្ដីថា បពិត្រព្រះអង្គ អាលាតសេនាបតីនោះមានអកុសលភារៈមិនទាន់ពេញប្រៀបនៅឡើយ ។ បទថា **តស្ស** សេចក្ដីថា ប្រការដែលអលាតសេនាបតីនោះ បាននូវសេចក្ដីសុខព្រោះបុណ្យនោះជាបច្ច័យ នុ៎ះជាផលនៃបុញ្ញកម្មដែលខ្លួនធ្វើទុកក្នុងជាតិមុន បពិត្រព្រះអង្គ សេចក្ដីពិតការបានសេចក្ដីសុខនោះមិនមែនផលនៃកម្ម គឺការសម្លាប់គោនុ៎ះ មិនមែនជាឋានៈដែលគប្បីមានឡើយ ដែលជាផលនៃកម្មដែលជាបាបអកុសលដែលឲ្យផលគួរប្រាថ្នា គួរពេញចិត្តនោះ ។ បទថា **អគុណោ រតោ** សេចក្ដីថា ពិតហើយឥឡូវនេះគេរមែងត្រេកអរតែក្នុងអកុសលកម្ម ។ បទថា **ឧជុមគ្គំ** សេចក្ដីថា លះនូវផ្លូវកុសលកម្មបថ ១០ ។ បទថា **កុម្មគ្គំ** សេចក្ដីថា ស្ទុះទៅក្នុងផ្លូវអកុសល-កម្មបថ ១០ ដែលជាផ្លូវទៅកាន់នរក ។ បទថា **ឱហិតេ តុលមណ្ឌលេ** សេចក្ដីថា កាលយកជញ្ជីងថ្លឹងនូវរបស់ ។ បទថា **ឧណ្ណមេតិ** សេចក្ដីថា រមែងបះឡើងទៅលើ ។ បទថា **អាចិនំ** សេចក្ដីថា កាលនរជនសន្សំបុណ្យបន្តិចម្ដងៗ ដោះនូវបាបដែលធ្ងន់ឲ្យស្រាលចុះ លើកកល្យាណកម្មឡើងលើក្បាលហើយទៅកាន់ទេវលោក ។ បទថា **សគ្គាតិមានោ** សេចក្ដីថា ឆ្ពោះទៅក្នុងស្ថានសួគ៌ ត្រេកអរក្រៃលែងក្នុងកល្យាណកម្មដែលជាសុខ ញុំាងសត្វឲ្យដល់ស្ថានសួគ៌បាលីថា **សគ្គាធិមានោ** ដូច្នេះក៏មាន អធិប្បាយថា មានចិត្តតាំងមាំ ធ្វើស្ថានសួគ៌ជាទីទៅខាងមុខ ។ បទថា **សាតវេ រតោ**

សេចក្តីថា វីជកទាសៈនោះត្រេកអរក្នុងកុសលកម្មដែលនាំមកនូវសេចក្តីសុខ មានផលជាទីត្រេកអរ ពេលបាបកម្មនេះអស់ទៅគេនឹងកើតក្នុងទេវលោក ព្រោះផលនៃកល្យាណកម្ម តែឥឡូវនេះគេចូលដល់ភាពជាទាសៈណា ភាពជាទាសៈនោះមិនមែនជាផលនៃកល្យាណកម្មឡើយ សេចក្តីពិតកម្មដែលឲ្យប្រព្រឹត្តទៅមានសភាពយ៉ាងនោះ ជាបាបកម្មដែលគេធ្វើទុកក្នុងកាលមុនព្រោះហេតុនោះក្នុងសេចក្តីនេះទើបសរុបបាន ដូចពោលមកនេះឯង ។ ព្រះនាងរុចារាជធីតាកាលប្រកាសសេចក្តីនេះទើបត្រាស់ថា

> បាបណាដែលវីជកៈនោះបានធ្វើទុកក្នុងកាលមុន ទាសៈឈ្មោះវីជកៈឃើញទុក្ខណាចំពោះខ្លួនក្នុងថ្ងៃនេះព្រោះគាត់បានធ្វើបាបក្នុងជាតិមុន បានជាគាត់ទទួលទុក្ខនោះ ។ បាបរបស់គាត់នោះអស់ បានជាគាត់ត្រេកអរក្នុងវិន័យ សូមព្រះអង្គកុំគប់រកអចេលកៈឈ្មោះគុណៈជាកស្សបគោត្ត ហើយមកកាន់ផ្លូវខុសឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មា ហេវុប្បថមាគមា** សេចក្តីថា ព្រះនាងរុចារាជធីតាទូលថា បពិត្រព្រះអង្គ ទ្រង់កុំចូលទៅរកកស្សបគុណាជីវកជាអ្នកអាក្រាតនេះ ទ្រង់កុំចូលទៅរកផ្លូវខុសដែលជាផ្លូវទៅនរក គឺកុំធ្វើនូវបាបឡើយ ។

ឥឡូវនេះព្រះនាងរុចារាជធីតា កាលព្រះនាងសម្តែងទោសក្នុងការធ្វើនូវបាបនិងគុណក្នុងការគប់រកកល្យាណមិត្តដល់ព្រះរាជាទើបត្រាស់ថា

បពិត្រព្រះរាជា បុគ្គលគប់រកបុគ្គលណាៗជាសប្បុរស ឬជាអសប្បុរស មានសីលឬមិនមានសីល រមែងលុះនូវអំណាចនៃបុគ្គលនោះៗឯង ។ បុគ្គលធ្វើបុគ្គលបែបណាឲ្យជាមិត្តផង សេពបុគ្គលបែបណាផង បុគ្គលនោះ រមែងប្រាកដដូចបុគ្គលនោះដែរព្រោះថា ការនៅរួមគ្នារមែងប្រាកដដូច្នោះ ។ អាចារ្យដែលកូនសិស្សពាល់ត្រូវហើយ រមែងប្រឡាក់កូនសិស្សដែលមិនទាន់ប្រឡាក់ កាលកូនសិស្សពាល់ត្រូវអាចារ្យដទៃ រមែងប្រឡាក់ដូចព្រួញលាបថ្នាំពិសប្រឡាក់បំពង់ព្រួញដូច្នោះ អ្នកប្រាជ្ញមិនត្រូវមានសម្លាញ់ដ៏លាមកព្រោះខ្លាចអំពីការប្រឡាក់ ។ ជនណាខ្ចប់ត្រីស្អុយដោយស្បូវក្លាំង ស្បូវក្លាំងរបស់ជននោះទៅជាមានក្លិនស្អុយផ្សាយទៅយ៉ាងណាមិញ ការសេពនឹងបុគ្គលពាលក៏យ៉ាងនោះដែរ ។ ជនណាខ្ចប់ក្រស្នា ដោយស្លឹកឈើ ស្លឹកឈើរបស់ជននោះ ទៅជាមានក្លិនក្រអូបផ្សាយទៅយ៉ាងណាមិញ ការសេពបុគ្គលជាអ្នកប្រាជ្ញក៏យ៉ាងនោះដែរ ។ ព្រោះហេតុនោះបណ្ឌិតកាលដឹងច្បាស់នូវភាពនៃខ្លួន ដែលប្រែប្រួលបានដូចជាកញ្ចប់នៃស្លឹកឈើមិនត្រូវសេពអសប្បុរសទេ ត្រូវសេពតែពួកសប្បុរស ព្រោះថាពួកអសប្បុរស តែងនាំទៅកាន់នរក ពួកសប្បុរសតែងឲ្យដល់សុគតិ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សន្តំ វា** បានដល់ សប្បុរសក្តី ។ បទថា

**យទិ វា អសំ** បានដល់ អសប្បុរសក្តី ។ បទថា **សរោ ទុដ្ឋោ កលាបំវ** សេចក្តីថា បពិត្រព្រះរាជបិតា មិត្តអាក្រក់កាលសេពគប់ជាមួយបុគ្គលដទៃនិងជិតស្និទ្ធជាមួយបុគ្គលដទៃ រមែងធ្វើបុរសដែលមិនបានប្រឡាក់ជាមួយបាបឲ្យមានអធ្យាស្រ័យដូចគ្នាជាមួយខ្លួន ចូលទៅប្រឡាក់ គឺធ្វើឲ្យប្រឡាក់បាបដូចគ្នា ដូចព្រួញលាបដោយថ្នាំពិសដ៏ពន្ទឹកដែលដាក់ក្នុងបំពង់ព្រួញ ថ្នាំពិសរមែងប្រឡាក់បំពង់ព្រួញដែលមិនប្រឡាក់ គឺរមែងធ្វើបំពង់ព្រួញឲ្យពេញដោយថ្នាំពិសដូច្នេះ ។ បទថា **វាយន្តិ** សេចក្តីថា សូម្បីស្លឹកឈើទាំងនោះខ្ចប់របស់នោះក៏រមែងមានក្លិនស្អុយផ្សាយទៅ ។ បទថា **តគរញ្ច** សេចក្តីថា ស្លឹកឈើខ្ចប់នូវក្រស្នា និងគន្ធជាតិដែលសម្បូរដោយក្លិនដទៃ រមែងមានក្លិនក្រអូបដែរ ។ បទថា **ឯវំ** សេចក្តីថា ចូលទៅគប់អ្នកប្រាជ្ញយ៉ាងនោះដូចគ្នាពិតហើយអ្នកប្រាជ្ញធ្វើបុគ្គលដែលគប់រកខ្លួន ឲ្យជាអ្នកប្រាជ្ញដូចគ្នា ។ បទថា **តស្មា បត្តបុដស្សេវ** សេចក្តីថា ព្រោះហេតុដែលស្លឹកឈើដែលខ្ចប់របស់ក្រអូបមានក្រស្នាជាដើមរមែងមានក្លិនក្រអូបផងដែរ ហេតុនោះគប្បីដឹងយ៉ាងនេះថា សូម្បីអាត្មាអញក៏ជាបណ្ឌិតព្រោះការសេពនឹងបណ្ឌិត ដូចស្លឹកឈើសម្រាប់ខ្ចប់ដូច្នោះ ។ បទថា **ញត្វា សម្បាកមត្តនោ** សេចក្តីថា កាលដឹងនូវការចាស់ក្លា ការប្រែប្រួលទៅភាពជាបណ្ឌិតរបស់ខ្លួនហើយ គប្បីលះអសប្បុរសគប់រកតែសប្បុរស ដែលជាបណ្ឌិត ។ ក្នុងបទថា **និរយំ នេន្តិ** នេះ បណ្ឌិតគប្បីនាំឧទាហរណ៍ដោយអំណាចឧទានថា ឈ្មោះថា នាំនរកមកដោយរឿងទេវទត្តជាដើមនិងនាំសុគតិមកដោយរឿងព្រះសារីបុត្តត្ថេរជាដើម ។

ព្រះរាជធីតាកាលសម្តែងធម៌ដល់ព្រះជនកដោយគាថា ៦ យ៉ាងនេះហើយ ឥឡូវនេះកាលសម្តែងដល់ទុក្ខដែលខ្លួនធ្លាប់សោយមកក្នុងអតីតទើបត្រាស់ថា

ខ្ញុំម្ចាស់បានរឭកឃើញនូវភាពនៃខ្លួន ដែលអន្ទោលទៅមកអស់ ៧ ជាតិមកហើយនិង ៧ ជាតិ ( ទៀត ) ដែលខ្ញុំម្ចាស់នឹងច្យុតចាកអត្តភាពនេះ ទៅក្នុងអនាគត ។ បពិត្រព្រះអង្គជាធំជាងជន ក្នុងកាលមុនជាតិណារបស់ខ្ញុំម្ចាស់ជាគម្រប់ ៧ ( ក្នុងជាតិនោះ ) ខ្ញុំម្ចាស់បានកើតជាកូនជាងមាសក្នុងរាជគហបុរី ក្នុងដែនមគធៈ ។ បាបដ៏ច្រើនខ្ញុំម្ចាស់បានធ្វើហើយព្រោះអាស្រ័យសម្លាញ់ដ៏លាមក ខ្ញុំម្ចាស់ទាំងពីរនាក់ កាលបៀតបៀនប្រពន្ធនៃបុគ្គលដទៃ ប្រព្រឹត្ត ( ខ្លួន ) ដូចមិនស្លាប់ ។ អំពើនោះកប់នៅដូចភ្លើងដែលកប់ក្នុងផេះ បពិត្រមហារាជ តទៅខ្ញុំម្ចាស់បានកើតក្នុងវំសភូមិក្រុងកោសម្ពី ជាកូនប្រុសតែមួយ មានគេធ្វើសក្ការបូជាជានិច្ចក្នុងត្រកូលសេដ្ឋី ជាត្រកូលស្តុកស្តម្ភសម្បូរ មានទ្រព្យច្រើនដោយកម្មដទៃ ។ ក្នុងកាលនោះខ្ញុំម្ចាស់បានសេពគប់មិត្តសម្លាញ់ អ្នកត្រេកអរក្នុងកុសល ជាបណ្ឌិត អ្នកបរិបូណ៌ដោយការចេះដឹង មិត្តនោះបានតម្កល់ខ្ញុំម្ចាស់ក្នុងអំពើជាប្រយោជន៍ ។ ខ្ញុំម្ចាស់បានរក្សាឧបោសថអស់រាត្រីទី ១៤ និងទី ១៥ ដ៏ច្រើន កម្មនោះនៅកប់ដូចកំណប់ក្នុងទឹក ។ ក៏បណ្តាបាបកម្មទាំងឡាយ បរទារកកម្ម

ណាដែលខ្ញុំម្ចាស់បានធ្វើហើយក្នុងដែនមគធៈ ផល ( នៃបរទារកកម្ម ) នោះផ្តល់ក្នុងកាលជាខាងក្រោយដូចបុគ្គលអ្នកបរិភោគភោជនដែលលាយដោយពិសដ៏កាចដូច្នោះ ។ បពិត្រព្រះបាទវិទេហៈ ខ្ញុំម្ចាស់ច្យុតចាកត្រកូលសេដ្ឋីនោះមក ក៏ឆេះក្នុងរោរុវនរកអស់កាលដ៏យូរដោយកម្មរបស់ខ្លួន ខ្ញុំម្ចាស់កាលរឭកឃើញទុក្ខក្នុងនរកនោះ រមែងមិនបានសេចក្តីសុខ ។ ខ្ញុំម្ចាស់ញ៉ាំងសេចក្តីទុក្ខដ៏ច្រើន ឲ្យអស់ទៅក្នុងរោរុវនរកនោះអស់ពួកនៃឆ្នាំដ៏ច្រើន បានមកកើតជាពពែគេក្រៀវអណ្ឌៈ ក្នុងក្រុងភិន្នាគតៈ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សត្ត** សេចក្តីថា បពិត្រព្រះអង្គ ឈ្មោះថាលោកនេះនិងលោកខាងមុខនិងផលនៃកម្មដែលសត្វធ្វើល្អនិងធ្វើអាក្រក់រមែងមានសង្សារ មិនអាចជម្រះសត្វទាំងឡាយឲ្យបរិសុទ្ធិបានឡើយ ដ្បិតថាសត្វទាំងឡាយរមែងបរិសុទ្ធិដោយកម្មប៉ុណ្ណោះ អលាតសេនាបតីនិងវីជកៈដែលជាទាសៈរមែងរឭកបានត្រឹមតែជាតិមួយប៉ុណ្ណោះ មិនមែនតែគេប៉ុណ្ណោះដែលរឭកជាតិបាន សូម្បីខ្ញុំក៏រឭកដល់ភាពដែលខ្លួនអន្ទោលទៅក្នុងអតីតបាន ៧ ជាតិផង រឭកដល់ជាតិដែលគប្បីទៅក្នុងអនាគត ៧ ជាតិផងដូចគ្នា ។ បទថា **យា មេ សា** សេចក្តីថា ជាតិទី ៧ ក្នុងអតីតរបស់ខ្ញុំក៏មាន ។ បទថា **កម្មារបុត្តោ** សេចក្តីថា ក្នុងជាតិទី ៧ នោះខ្ញុំកើតជាកូនជាងមាសក្នុងក្រុងរាជគ្រឹះ មគធរដ្ឋ ។ បទថា **បទារស្ស ហោថេន្តា** បានដល់ បៀត

បៀនកិរិយារបស់អ្នកដទៃ គឺខុសក្នុងកណ្ឌៈដែលមនុស្សដទៃថែរក្សា ។ បទថា **អជ្ឈា** បានដល់ កម្មអាក្រក់នោះដែលខ្ញុំធ្វើក្នុងពេលនោះ មិនបានឱកាស បានរក្សាទុក តែកាលបានឱកាសទើបឲ្យផលដូចភ្លើងដែលបិទបាំងដោយផេះ ដូច្នោះ ។ បទថា **វិសភូមិយំ** ប្រែថា ក្នុងវិសរដ្ឋ ។ បទថា **ឯកបុត្តោ** សេចក្ដីថា ខ្ញុំជាកូនទោលតែមួយក្នុងត្រកូលសេដ្ឋីមានសម្បត្តិ ៨០ កោដិ ។ បទថា **សាធវេ រតំ** សេចក្ដីថា ត្រេកអរក្រៃលែងក្នុងកល្យាណកម្ម ។ បទថា **សោ មំ** បានដល់ គេបានជាសម្លាញ់បានដឹកនាំខ្ញុំឲ្យតាំងនៅក្នុងវត្ថុជាប្រយោជន៍ គឺក្នុងកុសលកម្ម ។ បទថា **តំ កម្មំ** សេចក្ដីថា កល្យាណកម្មរបស់ខ្ញុំនោះ មិនទាន់បានឱកាសក្នុងកាលនោះ កាលបានឱកាសទើបឲ្យផល ។ បទថា **ឧទកន្តិកេ** សេចក្ដីថា បានជាកំណប់ទ្រព្យកប់ទុកក្នុងទឹក ។ បទថា **យមេតំ** សេចក្ដីថា លំដាប់ក្នុងកម្មអាក្រក់មានប្រមាណប៉ុណ្ណេះរបស់ខ្ញុំ បទារកកម្មណាដែលខ្ញុំធ្វើហើយ ក្នុងមគធរដ្ឋទើបផលនៃកម្មនោះជាប់តាមខ្ញុំក្នុងកាលខាងក្រោយ សួរថា ដូចអ្វី ឆ្លើយថា ដូចបុគ្គលបរិភោគថ្នាំពិសដូច្នោះ អធិប្បាយថា កម្មនោះរមែងមកដល់ខ្ញុំដូចថ្នាំពិសដ៏អាក្រក់មានកម្លាំងខ្លាំងក្លា កម្រើកដល់បុគ្គលដែលបរិភោគភោជនដែលមានថ្នាំពិសដូច្នោះ ។ បទថា **តតោ** បានដល់ ចេញ ( ស្លាប់ ) អំពីត្រកូលសេដ្ឋីក្នុងក្រុងកោសម្ពីនោះ ។ បទថា **តំ សរំ** សេចក្ដីថា ខ្ញុំកាលរឭកដល់ទុក្ខដែលខ្ញុំសោយក្នុងនរកនោះរមែងមិនបានទទួលនូវការសប្បាយចិត្តឡើយភ័យនោះឯងរមែងកើតដល់ខ្ញុំ ។ បទថា **ភិន្នាគតេ** សេចក្ដីថា ក្នុងភិន្នាគតរដ្ឋឬក្នុងនគរឈ្មោះថា

កិន្នាគត: ។ បទថា **ឧទ្ធតប្ផលោ** បានដល់ ពូជដែលត្រូវគេក្រៀវ ។

ឯពពែនោះបានជាសត្វសម្បូរដោយកម្លាំង ។ មនុស្សទាំងឡាយឡើងជិះពពែលើខ្នងពពែ ក៏បាននាំពពែនោះទៅ ទឹមពពែនោះត្រង់យានតូច ។ ព្រះនាងរុចារាជធីតាកាលប្រកាសសេចក្តីនោះទើបពោលថា

ខ្ញុំម្ចាស់ បាននាំពួកកូនអាមាត្យដោយខ្នងផង ដោយរថផង
( ការចេះក្នុងភរិយាបុរសដទៃជាដើមនោះ ) ជាផលកម្ម គឺការគប់
រកប្រពន្ធបុគ្គលដទៃនៃខ្ញុំម្ចាស់នោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សាតបុត្តា** បានដល់ បុត្តនៃអាមាត្យទាំងឡាយ ។ បទថា **តស្ស កម្មស្ស** សេចក្តីថា បពិត្រព្រះសម្មតិទេព ការដែលខ្ញុំចេះក្នុងមហាភរិយ: និងការដែលខ្ញុំត្រូវក្រៀវក្នុងកាលជាពពែ ការផ្ទុកភារៈនិងការទឹមដោយយានទាំងអស់នោះជាផលនៃកម្មនោះ គឺកម្មដែលខ្ញុំសហាយស្មន់នឹងភរិយារបស់អ្នកដទៃ ។

កាលខ្ញុំចុតិចាកជាតិពពែនោះហើយ បដិសន្ធិក្នុងកំណើតស្វា ក្នុងព្រៃក្នុងថ្ងៃដែលខ្ញុំកើត ពួកស្វាទាំងនោះនាំខ្ញុំទៅបង្ហាញដល់ស្វាដែលជាម្ចាស់ហ្វូងស្វាម្ចាស់ហ្វូងពោលថា ចូរនាំកូនមកឲ្យយើង ដូច្នេះហើយចាប់យ៉ាងមាំរួចខាំអណ្តូ:របស់ស្វានោះ ទោះបីស្វានោះស្រែកក៏មិនលែង ។ កាលព្រះនាងរុចាប្រកាសសេចក្តីនោះទើបក្រាបទូលថា

បពិត្រព្រះបាទវិទេហ: ខ្ញុំម្ចាស់ច្យុតចាកអត្តភាពនោះហើយក៏
កើតជាស្វាក្នុងព្រៃធំ ត្រូវស្វាជាម្ចាស់ហ្វូង ជាសត្វឃ្លើសឃ្លង

ខាំកាត់ពូជចេញ នេះជាផលកម្ម គឺការគប់រកប្រពន្ធបុគ្គល
ដទៃនៃខ្ញុំម្ចាស់នោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឆិលុញ្ឆិតជលោយេវ** សេចក្តីថា ខ្ញុំត្រូវស្វាមេហ្វូងដែលជាសត្វឃ្មើសឃ្មងក្នុងព្រៃនោះខាំផ្តាច់នូវពូជនោះឯង ។ កាលព្រះនាងរុចារាជធីតាសម្តែងជាតិដទៃៗទើបទូលថា

បពិត្រព្រះបាទវិទេហៈ ខ្ញុំម្ចាស់ច្យុតចាកអត្តភាពនោះហើយបាន
កើតជាគោក្នុងដែនទសន្នៈ ជាគោដ៏ចម្រើន មានសន្ទុះលឿន
ត្រូវគេក្រៀវ ខ្ញុំម្ចាស់បានអូសរទេះអស់កាលដ៏យូរ នេះជាផល
កម្ម គឺការគប់រកប្រពន្ធអ្នកដទៃនៃខ្ញុំម្ចាស់នោះ ។ បពិត្រ
ព្រះបាទវិទេហៈ ខ្ញុំម្ចាស់ច្យុតចាកអត្តភាពនោះហើយ បានមក
( កើត ) ក្នុងត្រកូលក្នុងដែនវជ្ជី ក្នុងភាពជាមនុស្សដែល
គេបានដោយក្រ តែមិនមែនស្រី មិនមែនប្រុស ( ខ្ទើយ )
នេះជាផលកម្ម គឺការគប់រកប្រពន្ធបុគ្គលដទៃនៃខ្ញុំម្ចាស់នោះ ។
បពិត្រព្រះបាទវិទេហៈ ខ្ញុំម្ចាស់ច្យុតចាកអត្តភាពនោះហើយបាន
កើតជាស្រីអប្សរ មានវណ្ណៈគួរប្រាថ្នាក្នុងនន្ទនវនឧទ្យានក្នុងឋាន
តាវត្តិង្ស ។ មានសំពត់និងគ្រឿងអាករណៈដ៏វិចិត្រ ពាក់
កុណ្ឌលជាវិការៈនៃកែវមណី ជាស្រីឈ្លាសក្នុងការរាំនិងច្រៀង
ជាស្រីបម្រើទេវរាជឈ្មោះសក្កៈ ។ បពិត្រព្រះបាទវិទេហៈ ខ្ញុំ
ម្ចាស់ឋិតនៅក្នុងឋានតាវត្តិង្សនោះ រឭកឃើញជាតិ ៧ ដែលខ្ញុំ

ម្ចាស់នឹងទៅក្នុងអនាគត ។ កុសលណាដែលខ្ញុំម្ចាស់បានធ្វើហើយក្នុងក្រុងកោសម្ពី កុសលនោះតាមមកឲ្យផល ខ្ញុំម្ចាស់ច្យុតចាកអត្តភាពជាទេពធីតានុ៎ះ នឹងអន្ទោលទៅហើយក្នុងទេវលោកនិងមនុស្សលោក ។ បពិត្រមហារាជ ខ្ញុំម្ចាស់ដែលគេធ្វើសក្ការបូជាជានិច្ចអស់ជាតិទាំងឡាយ ៧ តែខ្ញុំម្ចាស់នឹងមិនរួចហើយចាកភាពជាស្រីអស់គតិ ៦ នេះ ។ បពិត្រព្រះសម្មតិទេព ក្នុងគតិជាគម្រប់ ៧ ខ្ញុំម្ចាស់នឹងកើតជាទេវតាប្រុស ជាទេវបុត្តមានឫទ្ធិច្រើនដ៏ឧត្តមក្នុងពួកទេវតា ។ ក៏ក្នុងថ្ងៃនេះ នាងទេពកញ្ញាទាំងឡាយនៅកំពុងតែក្រងផ្កាជាផ្កាំងក្នុងនន្ទនវ័ន ទេវបុត្តឈ្មោះជវៈ ( ជាស្វាមីខ្ញុំម្ចាស់នោះ ) កំពុងទទួលកម្រងផ្កាដើម្បីខ្ញុំម្ចាស់ ។ ១៦ ឆ្នាំក្នុងជាតិរបស់ខ្ញុំម្ចាស់នេះហាក់ដូចជាកាលទិព្វនោះមួយរំពេច មួយយប់មួយថ្ងៃទិព្វនោះជា ១០០ ឆ្នាំរបស់មនុស្ស ។ កម្មទាំងឡាយរមែងអន្ទោលតាមអស់ជាតិជាអសង្ខេយ្យដូច្នេះឯង ដ្បិតថាកម្មល្អក្តី លាមកក្តីមិនវិនាសទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧសភេសុ** ប្រែថា ក្នុងទសន្នវដ្ត ។ បទថា **បសុ** ប្រែថា កើតជាគោ ។ បទថា **អហុំ** កែជា **អហោសិ** ប្រែថា បានកើតហើយ ។ បទថា **និលុញ្ឆិតោ** សេចក្តីថា ក្នុងកាលដែលខ្ញុំជាកូនគោនោះឯង គេបានក្រៀវពូជរបស់ខ្ញុំដោយគិតថានឹងជាទីពេញចិត្ត ដោយប្រការ

ដូច្នេះខ្ញុំត្រូវគេក្រៀវហើយ គឺត្រូវជកពូជ បានជាគោដែលមានកម្លាំងខ្លាំង ។ ដោយបទថា **វជ្ជីសុ កុលមាគមា** នេះ ព្រះនាងរុចារាជធីតាសម្តែងថា ខ្ញុំច្យុតអំពីកំណើតគោហើយ កើតក្នុងត្រកូលអ្នកមានភោគៈច្រើនក្នុងដែនវជ្ជី ។ ដោយបទថា **នេវិត្ថី ន បុមា** នេះ លោកពោលសំដៅដល់ខ្ទើយ ។ បទថា **ភវនេ តាវត្តឹសាហំ** សេចក្តីថា ខ្ញុំកើតក្នុងស្ថានតាវត្តិង្ស ។

បទថា **តត្ថ មិតាហំ វេទេហ សរាមិ ជាតិយោ ឥមា** សេចក្តីថា បានឮថា ព្រះនាងរុចានោះនៅក្នុងទេវលោកនោះពិនិត្យមើលថា អញមកកាន់ទេវលោកបែបនេះមកអំពីណាហ្ន៎ ឃើញហើយនូវការកើតក្នុងទេវលោកនោះ ចុតិចាកភាពជាខ្ទើយក្នុងត្រកូលដែលមានភោគៈច្រើនក្នុងដែនវជ្ជី បន្ទាប់អំពីនោះព្រះនាងរុចារាជធីតារំពឹងមើលថាព្រោះកម្មអ្វីហ្ន៎ ទើបអញកើតក្នុងទីដែលគួរត្រេកអរបែបនេះ ឃើញហើយនូវកុសល មានទានដែលខ្លួនធ្វើហើយជាដើមធ្វើឲ្យកើតក្នុងត្រកូលសេដ្ឋីក្នុងក្រុងកោសម្ពី ដឹងហើយថាអញកើតឡើងដោយផលកម្មនោះ ពិចារណាមើលថា អញកើតក្នុងអត្តភាពជាខ្ទើយក្នុងអតីតជាលំដាប់មកអំពីណា ដូច្នេះបានដឹងហើយថាខ្លួនធ្លាប់សោយទុក្ខធំក្នុងកំណើតគោក្នុងទសន្នរដ្ឋ កាលរឭកដល់ជាតិបន្ទាប់អំពីនោះបានឃើញខ្លួនត្រូវក្រៀវក្នុងកំណើតស្វា កាលរឭកដល់ជាតិបន្ទាប់អំពីនោះទើបរឭកដល់ភាវៈដែលខ្លួនត្រូវក្រៀវក្នុងកំណើតពពែ ក្នុងភិន្នាគតរដ្ឋ កាលរឭកដល់ជាតិបន្ទាប់អំពីនោះ បានរឭកដល់ភាវៈដែលខ្លួនកើតក្នុងរោរុវនរក ។

លំដាប់នោះកាលព្រះនាងរុចារាជធីតា រឭកដល់ភាវៈដែលខ្លួនឆេះក្នុងនរក

និងទុក្ខដែលខ្លួនសោយក្នុងកំណើតតិរច្ឆានការខ្លាចក៏កើតឡើង ។ លំដាប់នោះ ព្រះនាងរុចារាជធីតា កាលរឭកដល់ជាតិទី ៦ ថា អញសោយទុក្ខបែបនេះ ព្រោះកម្មអ្វីហ្ន៎ ក៏ឃើញកល្យាណកម្មដែលខ្លួនធ្វើក្នុងក្រុងកោសម្ពីក្នុងជាតិនោះ ហើយពិចារណាមើលជាតិទី ៧ បានឃើញកម្ម គឺការគប់រកកិរិយាអ្នកដទៃ ដែលខ្លួនធ្វើព្រោះអាស្រ័យមិត្តអាក្រក់ក្នុងមគធរដ្ឋទើបបានដឹងថា អញសោយ ទុក្ខធំនោះ ព្រោះផលនៃកម្មនោះ ។ លំដាប់នោះព្រះនាងពិចារណាមើលថា អញចុតិអំពីជាតិនេះហើយ កើតក្នុងភពណាក្នុងអនាគតបានដឹងថា អញកើត ជាបាទបរិចារិការបស់ព្រះឥន្ទ្រនោះឯងទៀត តាំងនៅដរាបដល់អស់ជីវិត កាល ព្រះនាងបានសម្លឹងមើលរឿយៗយ៉ាងនេះបានដឹងថា ក្នុងអត្តភាពទី ៣ នឹង កើតជាបាទបរិចារិកានៃព្រះឥន្ទ្រនោះឯង ក្នុងជាតិទី ៤ ក្នុងជាតិទី ៥ ក៏ដូច គ្នា គឺដឹងថាអញនឹងកើតជាអគ្គមហេសីរបស់ជវនទេវបុត្តក្នុងទេវលោកនោះ ឯង ហើយពិចារណាមើលបន្ទាប់អំពីជាតិនោះទៅដឹងថា ក្នុងអត្តភាពទី ៦ អញចុតិអំពីតាវត្តិង្សនោះហើយកើតក្នុងព្រះឧទររបស់អគ្គមហេសីនៃព្រះបាទ អង្គតិ អញនឹងមានឈ្មោះថា រុចាដូច្នេះទើបពិចារមើលថា បន្ទាប់អំពីជាតិ នោះនឹងកើតក្នុងទីណាដឹងថាក្នុងជាតិទី ៧ ចុតិអំពីជាតិនោះហើយនឹងកើតជា ទេវបុត្តអ្នកមានឫទ្ធិច្រើនក្នុងស្ថានតាវត្តិង្ស នឹងផុតចាកភាពជាស្រីព្រោះហេតុ នោះទើបព្រះនាងរុចារាជធីតាត្រាស់ថា បពិត្រព្រះបាទវិទេហៈ ខ្ញុំម្ចាស់ឋិតនៅ ក្នុងឋានតាវត្តិង្សនោះរឭកឃើញជាតិ ៧ ដែលខ្ញុំម្ចាស់នឹងទៅក្នុងអនាគត ។

បទថា **បរិយាគតំ** បានដល់ ផលមកតាមវារៈរបស់ខ្លួនដោយបរិយាយ

( ហេតុ ) ។ បទថា **សត្ត ជច្ចា** សេចក្តីថា ព្រះនាងត្រាស់ថា ៧ ជាតិ គឺក្នុងទេវលោក ៥ ជាតិនិងជាតិដែលជាខ្ទើយក្នុងដែនវជ្ជីនិងក្នុងជាតិទី ៦ នេះ ព្រះនាងសម្តែងថា ខ្ញុំជាបុគ្គលដែលគេបូជាជានិច្ចអស់ ៧ ជាតិនោះ ។ ដោយបទថា **ឆដ្ឋាវ គតិយោ** នេះ ព្រះនាងពោលថា អញទីងមិនផុតកាពជាស្រីអស់ទាំង ៦ គតិនេះ គឺក្នុងទេវលោក ៥ គតិនិងក្នុងជាតិនេះ ១ គតិ ។ បទថា **សត្តមី ច** សេចក្តីថា ចុតិបន្ទអំពីនោះហើយជាជាតិទី៧ ។ បទថា **សន្តានមយំ** សេចក្តីថា ទេពអប្សរទាំងឡាយក្រងនូវកម្រងផ្កាបន្តអំពីដែលខ្ញុំធ្វើដោយអំណាចទងជាមួយគ្នាជាដើមសូម្បីរាល់ថ្ងៃនេះអ្នកបម្រើរបស់ខ្ញុំក៏មិនដឹងចុតិរបស់ខ្ញុំក្នុងនន្ទនវ័ន នៅក្រងកម្រងផ្កាបន្តមកដើម្បីជាប្រយោជន៍ដល់ខ្ញុំនៅឡើយ ។ បទថា **សោ មេ មាលំ បដិច្ឆតិ** សេចក្តីថា បពិត្រមហារាជ ក្នុងជាតិនេះបន្ទាប់អំពីនេះទេវបុត្តឈ្មោះថាជវៈ ជាប្តីរបស់ខ្ញុំ នៅទទួលកម្រងផ្កាដែលខ្ញុំឲ្យជ្រុះអំពីដើម ។ បទថា **សោឡស** សេចក្តីថា បពិត្រមហារាជ ពោលដោយជាតិរបស់ខ្ញុំមកទល់ឥឡូវនេះបាន ១៦ ឆ្នាំតែកាលប្រមាណប៉ុណ្ណោះដូចជាមួយភ្លែតរបស់ទេវតា ក៏ព្រោះហេតុនោះទើបស្រីបម្រើទាំងនោះមិនដឹងដល់ ( ការ ) ចុតិរបស់ខ្ញុំ នៅតែក្រងផ្កាដើម្បីខ្ញុំនោះឯង ។ បទថា **មានុសី** សេចក្តីថា អាស្រ័យការរាប់ឆ្នាំរបស់មនុស្ស ។ បទថា **សរទោសតំ** សេចក្តីថា ជា ១០០ ឆ្នាំរបស់មនុស្ស ទេវតាទាំងឡាយមានអាយុវែងយ៉ាងនេះ ។ បពិត្រព្រះសម្មតិទេព ដោយហេតុនេះ សូមទ្រង់ជ្រាបភាពដែលបរលោក កម្មល្អនិងកម្មអាក្រក់ថាមាន ។

បទថា **អន្វេន្តិ** សេចក្តីថា កម្មល្អនិងកម្មអាក្រក់រមែងជាប់តាមយើងគ្រប់ៗ ជាតិយ៉ាងនេះ ។ បទថា **ន ហិ កម្មំ វិនស្សតិ** សេចក្តីថា ទិដ្ឋធម្មវេទនីយកម្ម រមែងឲ្យផលក្នុងអត្តភាពនោះឯង ឧបបជ្ជវេទនីយកម្មរមែងឲ្យ ផលក្នុងអត្តភាពបន្ទាប់ ឯអបរាបរវេទនីយកម្មបើមិនទាន់ឲ្យផលនឹងមិនវិនាស ទៅឡើយ ។ ព្រះនាងរុចារាជធីតាសំដៅយកអបរាបរវេទនីយកម្មនោះទើប ត្រាស់ថា **ន ហិ កម្មំ វិនស្សតិ** ដូច្នេះហើយទើបត្រាស់ថា បពិត្រព្រះ សម្មតិទេព ព្រោះផលនៃកម្មដែលខ្ញុំធ្វើជាមួយនឹងភរិយាអ្នកដទៃ ទើបខ្ញុំឆេះ ក្នុងនរកហើយសោយទុក្ខធំក្នុងកំណើតតិរច្ឆាន បើឥឡូវនេះទ្រង់ជឿពាក្យរបស់ គុណាជីវកនឹងធ្វើយ៉ាងនេះ ទ្រង់នឹងសោយទុក្ខដូចខ្ញុំសោយហើយនោះឯង ព្រោះហេតុនោះទ្រង់កុំធ្វើយ៉ាងនោះឡើយ ។

លំដាប់នោះព្រះនាងរុចារាជធីតា កាលសម្តែងធម៌ឲ្យក្រៃលែងឡើងដល់ ព្រះរាជបិតាទើបត្រាស់ថា

ប្រុសណាប្រាថ្នាឲ្យបានជាភេទប្រុសរាល់ៗជាតិត្រូវវៀរប្រពន្ធ
បុគ្គលដទៃ ដូចជាបុគ្គលអ្នកមានជើងលាងហើយ វៀរបង់នូវ
ភក់ដូច្នោះ ។ ស្ត្រីណាប្រាថ្នាឲ្យបានជាប្រុសរាល់ៗជាតិ ត្រូវ
គោរពប្តីដូចជាពួកស្រីអប្សរជាអ្នកបម្រើគោរពព្រះឥន្ទ្រដូច្នោះ ។
បុគ្គលណាចង់បានភោគៈជាទិព្វ អាយុ យសនិងសុខជាទិព្វត្រូវ
វៀរបង់អំពើបាបទាំងឡាយ ប្រព្រឹត្តសុចរិតធម៌ ៣ យ៉ាង ។
ស្ត្រីក្តី បុរសក្តី ជាអ្នកមិនធ្វេសប្រហែសដោយកាយ វាចាចិត្ត

មានប្រាជ្ញាជាគ្រឿងពិចារណាឈ្មោះថា កើតមកដើម្បីប្រយោជន៍របស់ខ្លួន ។ ពួកមនុស្សណានីមួយក្នុងជីវលោក ជាអ្នកមានយស មានភោគៈបរិបូណ៌ទាំងអស់ ពួកមនុស្សទាំងនោះបានសន្សំកម្មល្អហើយក្នុងកាលមុនដោយឥតសង្ស័យ សត្វទាំងអស់ជាច្រើនសុទ្ធតែមានកម្មជារបស់ខ្លួន ។ បពិត្រព្រះសម្មតិទេព សូមព្រះអង្គទ្រង់ត្រិះរិះរឿយៗដោយព្រះអង្គឯងចុះ បពិត្រព្រះអង្គជាធំជាងជន ស្រ្តីទាំងឡាយណារបស់ព្រះអង្គ ប្រាកដស្មើដោយស្រីអប្សរ មានខ្លួនប្រដាប់ហើយបិទបាំងដោយបណ្តាញមាស តើស្រ្តីទាំងនេះរបស់ព្រះអង្គមានអ្វីជាហេតុ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ហោតុំ** ប្រែថា ដើម្បីជា ។ បទថា **សព្វ-សមង្គភោគា** បានដល់ មានភោគៈយ៉ាងបរិបូណ៌ ។ បទថា **សុចិណ្ណំ** បានដល់ សន្សំទុកដោយល្អ គឺធ្វើកល្យាណកម្ម ។ បទថា **កម្មស្សកា សេ** សេចក្តីថា មានកម្មជារបស់ខ្លួន គឺសោយផលនៃកម្មដែលខ្លួនធ្វើនោះឯង មិនមែនកម្មដែលមាតាបិតាធ្វើហើយឲ្យផលដល់កូនប្រុសស្រី មិនមែនកម្មដែលកូនប្រុសស្រីធ្វើហើយឲ្យផលដល់មាតាបិតា កម្មដែលមនុស្សក្រៅពីនោះធ្វើនឹងឲ្យផលដល់មនុស្សក្រៅពីនោះដូចម្តេចកើត ។ សព្ទថា **ឥង្ឃ** ជានិបាតប្រើក្នុងអត្ថថា ចោទសួរ ។ បទថា **អនុចិន្តេសិ** បានដល់ គប្បីគិតរឿយៗ ។ បទថា **យា តេ ឥមា** សេចក្តីថា បពិត្រព្រះសម្មតិទេព ជាបឋមគប្បីគិតដោយខ្លួនឯងដូច្នេះថា ស្រីបម្រើព្រះអង្គ ១៦០០០ នាក់នេះ ទ្រង់ផ្តល់លក់បាន

មក ឬបានមកព្រោះការបួទ់តាមផ្លូវ ឬកាត់ទីតជាដើមបានមក ឬបានមក ព្រោះអាស្រ័យកល្យាណកម្មជាដើម ។

ព្រះរាជកញ្ញាព្រះនាមរុចា ញ៉ាំងព្រះបាទអង្គតិ ជាព្រះបិតាឲ្យ
ត្រេកអរយ៉ាងនេះដូច្នេះឯង នាងជាអ្នកមានវត្តល្អ បានប្រាប់
ផ្លូវ ( សុគតិ ) ដល់ព្រះបិតា ( ដូចបុគ្គលប្រាប់ផ្លូវ ) ដល់
មនុស្សវង្វេង នាងបានសំដែងសុចរិតធម៌ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឥច្ចេវំ** សេចក្ដីថា ម្នាលភិក្ខុទាំងឡាយ ព្រះរាជកញ្ញានោះញ៉ាំងព្រះរាជបិតាឲ្យត្រេកអរដោយពាក្យដ៏ពីរោះយ៉ាងនេះដោយប្រការដូច្នេះ ។ ព្រះនាងប្រាប់ផ្លូវសុគតិដល់ព្រះបិតានោះដូចមនុស្សប្រាប់ផ្លូវដល់អ្នកវង្វេងផ្លូវដូច្នោះ កាលព្រះនាងពោលធម៌ដល់ព្រះបិតានោះឯង បានពោលសុចរិតធម៌ដោយន័យផ្សេងៗ ។ បទថា **សុព្វតា** បានដល់ មានវត្តល្អ ។

ព្រះនាងរុចារាជធីតា បានទូលដល់ជាតិដែលខ្លួនកើតមកហើយក្នុងអតីត និងសម្ដែងធម៌ថ្វាយដល់ព្រះបិតាតាំងពីព្រឹកដល់យប់រហូតទល់ភ្លឺហើយក្រាបទូលថា បពិត្រព្រះសម្មតិទេព ទ្រង់កុំកាន់យកពាក្យរបស់អចេលកៈដែលជាមិច្ឆាទិដ្ឋិឡើយ លោកនេះមាន លោកខាងមុខមាន សមណព្រាហ្មណ៍មាន ផលនៃកម្មល្អកម្មអាក្រក់ក៏មាន សូមទ្រង់ស្ដាប់ពាក្យរបស់កល្យាណមិត្តដូចជាខ្ញុំពោលនេះចុះ ទ្រង់កុំស្ទុះទៅក្នុងទីដែលមិនមែនជាកំពង់ឡើយ កាលព្រះនាងរុចារាជធីតាក្រាបទូលយ៉ាងនេះ ក៏មិនអាចដោះព្រះបិតាចាកមិច្ឆាទិដ្ឋិបាន

ឯព្រះបាទអង្គតិរាជស្តាប់វាចាដ៏ពីរោះរបស់ព្រះរាជធីតានោះហើយ ទ្រង់ត្រេកអរ ។ ពិតហើយមាតាបិតារមែងស្រឡាញ់ពាក្យសម្តីរបស់កូនជាទីស្រឡាញ់តែពាក្យនោះមិនធ្វើឲ្យបិតាលះមិច្ឆាទិដ្ឋិបានឡើយ ។ អ្នកនគរក៏ល្បីខ្សឹបខ្សៀវថា ព្រះនាងរុចារាជធីតាសម្តែងធម៌ឲ្យព្រះជនកលះមិច្ឆាទិដ្ឋិ មហាជននាំគ្នាត្រេកអរថា ព្រះរាជធីតាជាបណ្ឌិត ដោះនូវមិច្ឆាទិដ្ឋិព្រះបិតាបានហើយនឹងធ្វើសួស្តី ឲ្យដល់អ្នកនគរទាំងឡាយក្នុងថ្ងៃនេះ ។ ព្រះនាងរុចារាជធីតាកាលមិនអាចដាស់ព្រះបិតាឲ្យភ្ញាក់បាន ក៏មិនលះសេចក្តីព្យាយាម ព្រះនាងត្រិះរិះរកឱកាសបន្តថានឹងរកឧបាយឯណាមួយមកធ្វើសួស្តីដល់ព្រះជនក ហើយផ្គងអញ្ជលីលើសិរសាថ្វាយបង្គំទិសទាំង ១០ ហើយអធិដ្ឋានថា ក្នុងលោកនេះរមែងមានសមណព្រាហ្មណ៍ដែលជាអ្នកតាំងនៅក្នុងធម៌ មានស្តេចលោកបាល ស្តេចមហាព្រហ្មដែលជាអ្នករក្សាលោក ខ្ញុំសូមអញ្ជើញលោកទាំងនោះមកដោះមិច្ឆាទិដ្ឋិរបស់ព្រះបិតានៃខ្ញុំដោយកម្លាំងរបស់ខ្លួន កាលគុណនៃបិតាមិនមាន សូមអញ្ជើញលោក ( ទាំងនោះ ) ដោយកម្លាំងនិងដោយសច្ចៈរបស់ខ្ញុំ សូមមកជួយដោះនូវមិច្ឆាទិដ្ឋិនេះ សូមមកធ្វើសួស្តីដល់សកលលោក ។

ក្នុងកាលនោះព្រះពោធិសត្វកើតជាមហាព្រហ្មឈ្មោះថា នារទៈ ធម្មតាព្រះពោធិសត្វមានអធ្យាស្រ័យធំ ដោយមេត្តាភាវនា ត្រាច់មើលលោកតាមកាលសមគួរ ដើម្បីមើលពួកសត្វដែលបដិបត្តិល្អ អាក្រក់ ក្នុងថ្ងៃនោះរំពឹងមើលលោកឃើញព្រះនាងរុចារាជធីតានោះ កំពុងថ្វាយបង្គំពួកទេវតាដែលថែ

រក្សាលោកដើម្បីដោះព្រះបិតាចាកមិច្ឆាទិដ្ឋិទើបត្រិះរិះថា អ្នកដទៃក្រៅអំពីអញ មិនអាចដោះមិច្ឆាទិដ្ឋិព្រះបាទអង្គតិរាជនោះបានឡើយ ថ្ងៃនេះ អញគួរទៅធ្វើសេចក្ដីសង្គ្រោះព្រះរាជធីតានិងធ្វើសួស្ដីដល់ព្រះរាជាមួយអន្ទើដោយបរិវារជន តែគួរទៅដោយភេទដូចម្ដេចល្អហ្ន៎ ក៏ឃើញថា ភេទបព្វជិត ជាទីស្រឡាញ់ ជាទីគោរព មានវាចាជាទីជឿស្ដាប់ ជាទីរាប់អាននៃពួកមនុស្ស ព្រោះដូច្នោះ អញនឹងទៅដោយភេទបព្វជិត ។ កាលសម្រេចចិត្តដូច្នេះហើយក៏កាឡាខ្លួនជាមនុស្សមានពណ៌ដូចមាស គួរជ្រះថ្លា ព័ទ្ធព័ន្ធនូវជដាមណ្ឌលគួរជាទីពេញចិត្ត ដោតនូវស្នៀតសក់មាសក្នុងរវាងជដា ស្លៀកសំពត់ពណ៌ក្រហមខាងក្នុង ទ្រទ្រង់សំពត់សម្បកឈើដែលជ្រលក់ដោយទឹកម្ចត់អំពីខាងក្រៅ ធ្វើសំពត់ស្បែកខ្លាដែលសម្រេចដោយប្រាក់តៀងស្មាម្ខាង ដែលរំលេចដោយមាស ហើយកាន់យកកិក្ខាភាជនៈមាសដាក់សង្រែក ដែលប្រដាប់ដោយមុក្ដាម្ខាង យកកុណ្ឌីកែវប្រវាឡដាក់ក្នុងសង្រែកម្ខាងទៀត រួចហើយក៏យកដងរែកមាសដែលមានចុងពីរឡើងដាក់លើស្មាហើយហោះមកតាមអាកាស ដោយភេទជាឥសីរុងរឿងដូចព្រះចន្ទពេញបូណ៌មីដែលអណ្ដែតព្វដ៏នភាមកកាន់ចន្ទុកប្រាសាទ បានឈរចំពោះព្រះភក្ត្ររបស់ព្រះបាទអង្គតិរាជ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសានូវព្រះគាថាដូច្នេះថា

គ្រានោះ នារទព្រហ្មមកពីព្រហ្មលោក មកកាន់គន្លងជារបស់

មនុស្សប្រមើលមើលជម្ពូទ្វីប ក៏បានឃើញព្រះបាទអង្គតិ ។
លំដាប់នោះនារទព្រហ្ម ឋិតនៅឰដ៏អាកាសក្នុងប្រាសាទខាងមុខ
នៃព្រះបាទវិទេហៈ នាងរុចា បានឃើញនារទព្រហ្មនោះដែល
មកដល់ហើយក៏ថ្វាយបង្គំនារទព្រហ្ម ដែលដំណែងខ្លួនជាឥសី
ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អទ្ទស** សេចក្ដីថា នារទមហាព្រហ្មដែលស្ថិតនៅក្នុងព្រហ្មលោកនោះឯង បានសម្លឹងមើលជម្ពូទ្វីប បានឃើញព្រះបាទអង្គតិរាជដែលប្រកាន់ខុសក្នុងសម្នាក់របស់គុណាជីវក អធិប្បាយថា ព្រោះហេតុនោះទើបមក ។ បទថា **តតោ បតិដ្ឋ** សេចក្ដីថា បន្ទាប់អំពីនោះព្រហ្មនោះកាលសម្ដែងស្នាកស្នាមក្នុងទីដែលមិនមានស្នាមនោះ ក្នុងប្រាសាទនោះខាងមុខរបស់ព្រះរាជានោះដែលចោមរោមទៅដោយពួកអាមាត្យ ប្រថាប់នៅទើបឈរនៅលើអាកាស ។ បទថា **អនុប្បត្តំ** ប្រែថា ដល់ហើយ គឺមកដល់ហើយ ។ បទថា **ឥសឹ** សេចក្ដីថា ព្រះសាស្ដាត្រាស់ហៅថា **ឥសឹ** ព្រោះមកដោយភេទនៃឥសី ។ បទថា **អវន្ទឲ** សេចក្ដីថា ព្រះនាងរុចារាជធីតានោះត្រេកអរថា ទេវរាជនោះនឹងមកធ្វើសេចក្ដីករុណាក្នុងព្រះជនករបស់អញដើម្បីអនុគ្រោះដល់អញ ដូច្នេះទើបបង្អោនកាយនមស្ការនារទមហាព្រហ្មដូចដើមចេកមាសដែលខ្យល់បក់ត្រូវឱនទៅដូច្នោះ ។

ឯព្រះរាជាកាលឃើញនារទមហាព្រហ្ម ត្រូវតេជៈនៃព្រហ្មគំរាមហើយមិនអាចតាំងនៅលើរាជអាសនៈរបស់ទ្រង់បាន ទើបយាងចុះអំពីរាជអាសនៈ

ប្រថាប់ឈរលើផែនដីហើយត្រាស់សួរនារទៈដល់ហេតុដែលយាងមក ដោយនាមនិងគោត្ត ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសាន្ទូវព្រះគាថាដូច្នេះថា

គ្រានោះព្រះរាជាមានព្រះហឫទ័យតក់ស្លុត ក៏ចុះអំពីអាសនៈ
ហើយសាកសួរនារទព្រហ្មទើបត្រាស់ព្រះបន្ទូលដូច្នេះថា លោក
មានវណ្ណៈដូចទេវតា ញុំាំងទិសទាំងអស់ឲ្យភ្លឺដូចព្រះចន្ទ តើ
ទើបនឹងមកអំពីទីណា យើងសួរហើយ លោកចូរប្រាប់នាម
និងគោត្ត មនុស្សទាំងឡាយក្នុងមនុស្សលោក តើគេស្គាល់ដូច
ម្តេចបាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ព្យម្ហិតមានសោ** បានដល់ ជាបុគ្គលមានចិត្តខ្លាច ។ បទថា **កុតោ នុ** សេចក្តីថា ព្រះរាជាទ្រង់សម្គាល់ថា បុគ្គលនេះប្រហែលជាវិជ្ជាធរឬហ្ន៎ ទើបទ្រង់មិនថ្វាយបង្គំហើយសួរយ៉ាងនេះ ។

លំដាប់នោះនារទឥសីគិតថា ព្រះរាជានេះសម្គាល់ថា បរលោកមិនមានអញនឹងសួរចំពោះបរលោកដល់ព្រះរាជានោះមុនដូច្នេះហើយទើបពោលគាថានេះថា

អាត្មាភាពទើបនឹងមកអំពីទេវលោក ក្នុងកាលឥឡូវនេះ ញុំាំង
ទិសទាំងអស់ឲ្យភ្លឺដូចព្រះចន្ទ អាត្មាភាពដែលព្រះអង្គសួរ

ហើយនឹងទូលនាមនិងគោត្តថា មនុស្សទាំងឡាយស្គាល់អាត្មា
ភាពថាឈ្មោះ នារទៈ ជាកស្សបគោត្ត ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ទេវតោ** ប្រែថា អំពីទេវលោក ។ បទថា **នារទោ កស្សបោ ច** សេចក្តីថា មនុស្សទាំងឡាយស្គាល់អាត្មាដោយឈ្មោះថា នារទៈនិងដោយគោត្តថា កស្សបៈ ។

លំដាប់នោះព្រះបាទអង្គតិរាជទ្រង់ព្រះតម្រិះថា រឿងបរលោក អញទុកសួរជាក្រោយ អញនឹងសួរដល់ហេតុដែលលោកបានឫទ្ធិនេះមុនហើយទើបត្រាស់គាថាថា

សណ្ឋានរបស់លោកប្រាកដយ៉ាងណាផង លោកកំពុងដើរក្តី
កំពុងឈរក្តី ឰដ៏អាកាសផង (នេះ) មានសភាពជាអស្ចារ្យ
បពិត្រនារទៈ ខ្ញុំសួរសេចក្តីនេះនឹងលោក តើឫទ្ធិរបស់លោក
នេះមានដោយហេតុអ្វី ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យានិសញ្ញុ** សេចក្តីថា សណ្ឋានរបស់លោកយ៉ាងណា លោកហោះទៅនិងឈរនៅលើអាកាសបានដូចម្តេច នេះគួរអស្ចារ្យ ។ លំដាប់នោះនារទឥសីក៏ទូលថា

សច្ចៈ ១ ធម៌ ១ ទមៈ ១ ចាគៈ ១ គុណធម៌នេះ អាត្មាភាព
បានសាងមកហើយអំពីជាតិមុន អាត្មាភាពមានសន្ទុះចិត្តទៅតាម
ប្រាថ្នាបាន ព្រោះធម៌ដែលអាត្មាភាពសេពល្អហើយទាំងនោះ
ឯង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សច្ចំ** បានដល់ វចីសច្ចៈ ។ បទថា **ធម្មោ** បានដល់ សុចរិតធម៌ ៣ ប្រការនិងឈានធម៌ដែលកើតអំពីការបរិកម្មកសិណ ។ បទថា **ទមោ** បានដល់ ការទូន្មានឥន្ទ្រិយ ។ បទថា **ចាគោ** បានដល់ ការលះកិលេសនិងការលះទេយ្យធម៌ ។ បទថា **បករា បុរាណា** នាងទេសីសម្ដែងថា ខ្ញុំបានធ្វើទុកក្នុងភពមុន ។ បទថា **តេហេវ ធម្មេហិ សុសេវិតេហិ** សេចក្ដីថា ដោយគុណធម៌ទាំងពួងនោះដែលអាត្មាបានសេពល្អហើយ គឺបានអប់រំមកហើយ ។ បទថា **មនោជវោ** បានដល់ រហ័សទាន់ចិត្ត ។ បទថា **យេន កាមំ គតោស្មិ** សេចក្ដីថា អាត្មាទៅកាន់ដែនរបស់ទេវតានិងដែនមនុស្សបានតាមប្រាថ្នា ។

កាលព្រះពោធិសត្វក្រាបទូលយ៉ាងនេះ ព្រះបាទអង្គតិរាជក៏ទ្រង់មិនជឿបរលោកព្រោះទ្រង់ប្រកាន់មិច្ឆាទិដ្ឋិនោះស៊ប់ល្អហើយទើបត្រាស់គាថាថា ផលរបស់បុណ្យមានឬ ហើយត្រាស់គាថាដូច្នេះ

ឥឡូវនេះលោកប្រាប់ការសម្រេចនៃបុណ្យ ជារបស់អស្ចារ្យ
ហើយ បពិត្រនារទៈ ប្រសិនបើដូចជាលោកពោលយ៉ាងនេះ
មែន ខ្ញុំសូមសួរសេចក្ដីនេះនឹងលោកទៀត បើខ្ញុំសួរហើយសូម
លោកឆ្លើយឲ្យប្រពៃចុះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បុញ្ញសិទ្ធី** សេចក្ដីថា លោកកាលនឹងប្រាប់សេចក្ដីសម្រេចនៃបុណ្យ គឺភាពដែលបុណ្យឲ្យផល ឈ្មោះថា រមែងប្រាប់ភាពអស្ចារ្យ ។

នារទឥសីក៏ទូលថា

បពិត្រព្រះរាជាជាភូមិបាល ព្រះអង្គធ្វើសេចក្តីសង្ស័យណា សូមទ្រង់សួរអាត្មាភាពចុះ អាត្មាភាពជាប្រយោជន៍របស់ព្រះអង្គហើយ អាត្មាភាពនឹងញ៉ាំងព្រះអង្គឲ្យដល់នូវភាពជាអ្នកមិនមានសេចក្តីសង្ស័យដោយន័យ ដោយញាណនិងដោយហេតុទាំងឡាយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តវេស អត្ថោ** សេចក្តីថា សេចក្តីដែលទ្រង់គប្បីសួរនោះ ។ បទថា **យំ សំសយំ** សេចក្តីថា ទ្រង់សង្ស័យក្នុងអត្ថឯណានីមួយ សូមទ្រង់សួរសេចក្តីនោះនឹងអាត្មាចុះ ។ បទថា **និស្សំសយតំ** សេចក្តីថា អាត្មានឹងធ្វើឲ្យទ្រង់អស់សេចក្តីសង្ស័យ ។ បទថា **នយេហិ** បានដល់ ដោយពាក្យដែលជាហេតុ ។ បទថា **ញាយេហិ** បានដល់ ដោយញាណ ។ បទថា **ហេតុភិ** បានដល់ ដោយបច្ច័យ អធិប្បាយថា អាត្មាមិនក្រាបទូលដោយហេតុត្រឹមតែបេ្តជ្ញាទុកប៉ុណ្ណោះ នឹងធ្វើឲ្យទ្រង់អស់សេចក្តីសង្ស័យដោយការកំណត់ដោយញាណ ហើយពោលហេតុ និងដោយបច្ច័យដែលជាហេតុឲ្យធម៌ទាំងនោះតាំងឡើង ។ ព្រះរាជាក៏ត្រាស់សួរថា

បពិត្រនារទៈខ្ញុំសូមសួរសេចក្តីនេះនឹងលោកបពិត្រនារទៈ ខ្ញុំសួរហើយ លោកកុំពោលមុសាវាទឡើយ នរជនបានសួរថា ទេវតាមានឬ មាតាបិតាមានឬ បរលោកមានឬ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ជនោ យមាហ** សេចក្តីថា ដែលនរជន

និយាយគ្នាយ៉ាងនេះ ។ ព្រះបាទអង្គតិរាជសួរថា ការដែលពោលយ៉ាងនេះថា ទេវតាមាន មាតាបិតាមាន បរលោកមាន ទាំងអស់នេះមានពិតឬ ។

នារទៈក៏ក្រាបទូលថា

នរជនបានពោលថា ទេវតាមាន មាតាបិតាមាន បរលោកមាន

ពួកជនជាអ្នកជាប់ក្នុងកាម ជាអ្នកវង្វេង ប្រកបដោយមោហៈ

រមែងមិនបានដឹងនូវបរលោកឡើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អត្ថេវ** សេចក្ដីថា មហាបពិត្រ ទេវតាមាន មាតាបិតាមាន ។ ការដែលនរជនពោលថា បរលោកមាននោះជាការពិតនោះឯង ។ បទថា **ន វិទូ** សេចក្ដីថា នរជនជាប់ក្នុងកាមនិងវង្វេងព្រោះមោហៈ ទើបមិនដឹង គឺរមែងមិនជ្រាបបរលោក ។

ព្រះបាទអង្គតិរាជបានស្ដាប់ដូច្នោះទ្រង់ក៏សើចត្រាស់ថា

បពិត្រនារទៈ ប្រសិនបើលោកជឿថា លំនៅនៃជនទាំងឡាយ

ដែលស្លាប់ទៅហើយ មានក្នុងបរលោកមែន លោកចូរឲ្យ

កហាបណៈ ៥០០ ដល់ខ្ញុំក្នុងលោកនេះចុះ ខ្ញុំនឹងសងកហា-

បណៈជា ១ ពាន់ ដល់លោកក្នុងបរលោកវិញ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **និវេសនំ** បានដល់ ទីនៅអាស្រ័យ ។ បទថា **បញ្ចសតានិ** បានដល់ ៥០០ កហាបណៈ ។

លំដាប់នោះព្រះពោធិសត្វកាលពោលតិះដៀលក្នុងកណ្ដាលបរិស័ទ ទើបទូលថា

ប្រសិនបើយើងដឹង ( នូវអ្នកដ៏ចម្រើន ) ថាមានសីល ជាអ្នក
ដឹងនូវពាក្យសួម យើងនឹងឲ្យកហាបណៈ ៥០០ ដល់អ្នកដ៏
ចម្រើន ប៉ុន្តែបើអ្នកដ៏ចម្រើននោះជាមនុស្សអាក្រក់នៅក្នុងនរក
តើបុគ្គលណានឹងទារកហាបណៈ ១ ពាន់ក្នុងបរលោកបាន ។
សូម្បីក្នុងលោកនេះ បុគ្គលណាមិនមានធម៌ជាប្រក្រតី មាន
មារយាទដ៏លាមក ជាអ្នកខិលច្រអូស មានការងារអាក្រក់
ពួកបណ្ឌិត ក៏មិនឲ្យបុគ្គលនោះបុលទ្រព្យទេព្រោះថា ការបាន
( ទ្រព្យ ) អំពីបុគ្គលមានប្រការដូច្នោះមិនមានឡើយ ។
ពួកមនុស្សដឹងនូវបុរសថាជាអ្នកប៉ិនប្រសប់ មានព្យាយាម
មានសីល ជាអ្នកដឹងពាក្យសួម រមែងអញ្ជើញខ្លួនឯងដោយ
គោគៈទាំងឡាយថា អ្នកធ្វើការងារហើយគប្បីសងយើងវិញ
ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ជញ្ញាម ចេ** សេចក្តីថា បើអាត្មាដឹងថា មហាបពិត្រជាអ្នកមានសីលដឹងនូវបំណង គឺដឹងថាសមណព្រាហ្មណ៍ ដែលទ្រទ្រង់ធម៌មានសេចក្តីត្រូវការដោយរបស់នេះ ក្នុងពេលនេះ ជាអ្នកធ្វើកិច្ចនោះៗឈ្មោះថា ដឹងបំណង កាលបើដូច្នេះទើបអាត្មាឲ្យទ្រព្យដល់ទ្រង់ ៥០០ កហាបណៈ តែមហាបពិត្រជាមនុស្សគ្រោតគ្រាត ឃោរឃៅ កាន់យកនូវមិច្ឆាទិដ្ឋិ រើរោងទាន ខុសក្នុងកិរិយារបស់អ្នកដទៃ ចុតិពីលោកនេះហើយទៅកើតក្នុងនរក នរណានឹងទៅក្នុងនរកទារទ្រព្យជាមួយមហាបពិត្រ ដែលជា

អ្នកគ្រោតគ្រាតជាអ្នកនៅក្នុងនរកដោយពាក្យថា សូមលោកឲ្យទ្រព្យ ១០០០ កហាបណៈដល់ខ្ញុំ ។ បទថា **តថាវិធម្ហា** សេចក្ដីថា បុគ្គលដូច្នោះជាអ្នកខ្ជិលច្រអូសឈ្មោះថា មកទារបំណុលនេះដែលឲ្យហើយរមែងមិនមាន ។ បទថា **ធនំ** បានដល់ ឈ្លាសក្នុងការញុំាងទ្រព្យឲ្យកើត ។ បទថា **បុនមាហរេសិ** សេចក្ដីថា អ្នកធ្វើការងាររបស់ខ្លួនហើយញុំាងទ្រព្យឲ្យកើតហើយ នាំទ្រព្យដែលមានមកសងឲ្យខ្ញុំវិញ ។ បទថា **និមន្តយន្តិ** សេចក្ដីថា មនុស្សទាំងឡាយរមែងអញ្ជើញដោយភោគទ្រព្យដោយខ្លួនឯង ។

ព្រះបាទអង្គតិរាជកាលនារទឥសីពោលសង្កត់សង្កិនដោយប្រការដូច្នេះក៏អស់បដិភាណដើម្បីនឹងឆ្លើយឆ្លង ។ មហាជនក៏នាំគ្នាត្រេកអរ ល្បីពេញព្រះនគរថា ថ្ងៃនេះនារទឥសី ជាទេវតាមានឫទ្ធិច្រើនដោះនូវមិច្ឆាទិដ្ឋិរបស់ព្រះរាជាបាន ។ ដោយអានុភាពនៃព្រះមហាសត្វអ្នកមិថិលាដែលនៅឆ្ងាយសូម្បី ៧ យោជន៍ក៏បានឮព្រះធម្មទេសនារបស់ព្រះមហាសត្វក្នុងខណៈនោះគ្រប់គ្នា ។ លំដាប់នោះព្រះមហាសត្វគិតថា ព្រះរាជានេះកាន់យកមិច្ឆាទិដ្ឋិស៊ប់ហើយ អញនឹងគំរាមដោយភ័យក្នុងនរក ឲ្យលះមិច្ឆាទិដ្ឋិហើយឲ្យត្រេកអរក្នុងទេវលោកក្នុងកាលជាក្រោយ ដូច្នេះហើយទើបក្រាបទូលថា សូមថ្វាយព្រះពរ បើទ្រង់មិនលះមិច្ឆាទិដ្ឋិសោត ក៏នឹងត្រូវយាងទៅកាន់នរក ដែលពេញដោយទុក្ខមិនមានទីបំផុតហើយផ្ដើមនូវនិរយកថាដូច្នេះថា

បពិត្រព្រះរាជា បើព្រះអង្គច្យុតចាកអត្តភាពនេះទៅនឹងទតឃើញខ្លួនព្រះអង្គ ដែលហ្វូងក្អែកកំពុងចឹកជញ្ជែងក្នុងនរកនោះ

ព្រះអង្គគង់ក្នុងនរកដែលហ្វូងក្អែកត្មាតនិងក្អែកកំពុងទំពាស៊ី មាន
ខ្លួនដុះធ្លាយកំពុងហូរឈាម តើបុគ្គលណានឹងទៅទារកហាប-
ណៈ ១ ពាន់ក្នុងបរលោកបាន ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កាកោលសង្ឃេហិ** បានដល់ ហ្វូងក្អែកចំពុះដែក ។ បទថា **វិកស្សមានំ** សេចក្ដីថា ទ្រង់នឹងឃើញខ្លួនឯងត្រូវហ្វូងក្អែកជញ្ជែងស៊ីក្នុងនរកនោះ ។ បទថា **តំ** បានដល់ មហាបពិត្រនោះ ។

កាលនាងទេវសីពណ៌នាដល់នរកដែលពេញដោយហ្វូងក្អែកដល់ព្រះរាជាហើយក៏ក្រាបទូលថា បើទ្រង់មិនទៅកើតក្នុងទីនោះក៏នឹងកើតក្នុងលោកន្តរនរក ដើម្បីទូលឲ្យជាក់ច្បាស់នូវលោកន្តរនរកនោះ ទើបពោលគាថានេះថា

សេចក្ដីងងឹតខ្លាំងរមែងមានក្នុងនរកនោះ ព្រះចន្ទនិងព្រះអាទិត្យ
ក៏មិនមាន នរកនោះមានងងឹតដ៏ក្រាស់សព្វកាល មានសភាព
គួរខ្លាច យប់ក៏មិនប្រាកដថ្ងៃក៏មិនប្រាកដ នរណាជាអ្នកត្រូវ
ការដោយទ្រព្យគប្បីត្រាច់ទៅក្នុងនរកដូច្នោះបាន ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អន្ធតមំ** សេចក្ដីថា បពិត្រមហារាជ មិច្ឆាទិដ្ឋិបុគ្គលកើតក្នុងលោកន្តរនរកណា ក្នុងលោកន្តរនរកនោះងងឹតបំផុត ជាទីមិនកើតឡើងនៃចក្ខុវិញ្ញាណ ។ បទថា **សទា តុមុលោ** សេចក្ដីថា នរកនោះមានភាពងងឹតជានិច្ច ។ បទថា **ឃោររូបោ** សេចក្ដីថា នរកនោះជាទីតក់ស្លុតគួរខ្លាចក្រៃលែង គឺមានជាតិគួរតក់ស្លុត ។ បទថា **សា នេវ រត្តិ ន ទិវា** សេចក្ដីថា ក្នុងនរកនោះពេលយប់និងពេលថ្ងៃមិនប្រាកដដូចក្នុងលោក

នេះឡើយ ។ បទថា **កោ វិចរេ** សេចក្ដីថា នរណានឹងត្រាច់ទៅញ៉ាំង សេចក្ដីព្យាយាមឲ្យសម្រេចនោះ ។

កាលនារទឥសីពណ៌នាលោកន្តរនរកនោះថ្វាយដល់ព្រះបាទអង្គតិរាជ ដោយពិស្ដារហើយទើបទូលចន្លុលបង្ហាញបន្តថា សូមថ្វាយព្រះពរ បើទ្រង់ មិនលះមិច្ឆាទិដ្ឋិនឹងត្រូវទទួលទុក្ខវេទនាដទៃៗទៀតមិនមានទីបំផុតហើយពោល គាថានេះថា

ក្អែកពាលនិងក្អែកលៀងទាំងពីរពួក មានកាយធាត់ធំ មាន កម្លាំង តែងខាំស៊ីនូវសត្វដែលច្យុតអំពីលោកនេះ ធ្លាក់ទៅក្នុង បរលោកដោយធ្មេញជាវិការៈនៃដែក ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឥតោ បនុណ្ណំ** សេចក្ដីថា ទ្រង់ចុតិអំពី មនុស្សលោកនេះ សូម្បីក្នុងនរកដទៃក៏ន័យនេះដូចគ្នា ។ ព្រោះហេតុនោះ បណ្ឌិតទាំងឡាយ គប្បីឲ្យស្គាល់នទីនរកទាំងអស់នោះពិស្ដារ ដោយន័យដែល ពោលហើយខាងដើមមួយអន្លើដោយសេចក្ដីព្យាយាមរបស់នាយនិរយបាល នោះឯងហើយគប្បីពណ៌នាបទដែលលំបាកក្នុងគាថានោះៗថា

ព្រះអង្គកាលនៅក្នុងនរក ត្រូវពួកក្អែដ៏កាចអាក្រក់ នាំមកនូវ សេចក្ដីទុក្ខខាំស៊ី មានខ្លួនធុះធ្លាយកំពុងហូរឈាម តើនរណា នឹងទារកហាបណៈ ១ ពាន់ក្នុងបរលោកបាន ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **លុទ្ទេហិ** ប្រែថា ទារុណ ។ បទថា **កាឡេហិ** ប្រែថា ឃោរឃៅ ។ បទថា **អយម្មិគេហិ** សេចក្ដីថា ដែលនាំនូវការ

បង្អៀតបង្អល់មកឲ្យ គឺនាំសេចក្តីទុក្ខមកឲ្យ ។

ពួកនាយនិរយបាលឈ្មោះ កាលូបកាលៈក្នុងនរក គួរខ្លាចដ៏ពន្លឹក ជាបច្ចាមិត្តតែងសម្លាប់ឬចាក់នរជនដែលធ្វើអំពើអាក្រក់ក្នុងកាលមុន ដោយព្រួញនិងលំពែង ដែលសំលៀងមុតហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ហនន្តិ វិជ្ឈន្តិ ច** សេចក្តីថា ពួកនិរយបាលយកដាវនិងលំពែងកាប់និងចាក់ ធ្វើរាងកាយទាំងមូលឲ្យជាកំណាត់តូចធំ ឲ្យធ្លាក់ទៅលើផែនដីដែក ដែលភ្លើងឆេះសន្ធោសន្ធៅ ។ បទថា **កាលូប-កាលា** បានដល់ និរយបាលទាំងឡាយមានឈ្មោះយ៉ាងនេះ ។ បទថា **និរ-យម្ហិ** សេចក្តីថា និរយបាលពោលគឺ កាលូបកាលាដែលនៅក្នុងនរកនោះឯង ។ បទថា **ទុក្កដកម្មការី** បានដល់ អ្នកធ្វើកម្មអាក្រក់ដោយអំណាចមិច្ឆាទិដ្ឋិ ។

ព្រះអង្គកាលទៅក្នុងនរក ត្រូវនាយនិរយបាលចាក់ត្រង់ក្លៀក ត្រង់ឆ្អឹងជំនីរ វៈពោះ មានខ្ទង់ទ្រូងធ្លាយ មានឈាមហូរចេញ តើនរណានឹងទារកហាបណៈ ១ ពាន់ក្នុងបរលោកបាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តំ** សេចក្តីថា ជាមួយមហាបពិត្រដែលត្រូវគេកាប់ចិញ្ច្រាំ ចាក់ទម្លុះយ៉ាងនោះក្នុងនរកនោះ ។ បទថា **វជន្តំ** សេចក្តីថា ធ្វេច្ចទៅក្នុងទិសផ្សេងៗ ។ បទថា **កុច្ឆិស្មឹ** បានដល់ ត្រូវចាក់ត្រង់ពោះនិងឆ្អឹងជំនីរ ។

ក្នុងនរកនោះមានភ្លៀងបង្អុរចុះជាអាវុធផ្សេងៗ គឺលំពែង ព្រួញ

លំពែងស្នែងក្របីនិងច្បូក ភ្លៀងអាវុធមានអណ្តាតដូចជារងើក
ភ្លើងរមែងធ្លាក់លើក្បាល រន្ទះថ្មរមែងបន្ទរចុះលើបុគ្គលអ្នកមាន
អំពើអាក្រក់ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អង្គារមិវច្ចិមន្តោ** សេចក្តីថា ភ្លៀងអាវុធដ៏រន្ទាលប្រាលភ្លៅដូចរងើកភ្លើងធ្លាក់លើអំបែងក្បាល ។ បទថា **សិលាសនី** បានដល់ រន្ទះថ្មដ៏ប្រាលភ្លៅរមែងធ្លាក់ចុះ ។ បទថា **លុទ្ទកម្មេ** សេចក្តីថា ភ្លៀងអសនីសិលាដ៏សន្ធោសន្ធៅតាំងឡើងលើអាកាស ហើយធ្លាក់លើអំបែងក្បាលសត្វដែលធ្វើកម្មអាក្រក់ទាំងនោះ ដូចរន្ទះដែលធ្លាក់ចុះក្នុងកាលដែលមានភ្លៀងធ្លាក់ ។

ក្នុងនរកនោះមានខ្យល់ដ៏ក្តៅដែលអត់ធន់បានដោយក្រ ព្រះអង្គ
ដែលមានកម្មអាក្រក់រមែងមិនបានសេចក្តីសុខតិចតួចក្នុងនរក
នោះឡើយ តើនរណានឹងទារកហាបណៈ ១ ពាន់ក្នុងបរលោក
នឹងព្រះអង្គនោះ ដែលក្តៅក្រហាយជានិច្ច ស្ទុះទៅមកមិនមានទី
ពួន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឥត្តរំបិ** ប្រែថា សូម្បីតិចតួច ។ បទថា **ធាវន្តំ** ប្រែថា ស្ទុះទៅ ។

ព្រះអង្គស្ទុះទៅស្ទុះមកដែលនាយនិរយបាលទឹមក្នុងរថ ព្រះអង្គ
ជាន់ផែនដីមានអណ្តាតភ្លើងសន្ធោសន្ធៅដែលនាយនិរយបាល
កំពុងចាក់ដោយជន្ទញ តើនរណានឹងទារកហាបណៈ ១ ពាន់

ក្នុងបរលោកបាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **រថេសុ យុត្តំ** សេចក្តីថា ទឹមដោយរថលោហៈដែលឆេះសន្ធោសន្ធៅនោះៗ តាមវារៈដោយវារៈ ។ បទថា **កមន្តំ** ប្រែថា កំពុងជាន់ ។ បទថា **សុចោទយន្តំ** បានដល់ ត្រូវតឹងទារដោយល្អ ។

ព្រះអង្គឡើងកាន់ភ្នំដ៏ដេរដាសដោយកាំបិតជាភ្នំ គួរស្ញើបមាន
អណ្តាតភ្លើងប្រាលរទ្ធាលធ្ងិនខ្លៅគួរខ្លាច ព្រះអង្គមានខ្លួនធ្ងុះ
ធ្លាយកំពុងហូរឈាម តើនរណានឹងទារកហាបណៈ ១ ពាន់
ក្នុងបរលោកបាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តមារុហន្តំ** សេចក្តីថា ជាមួយមហាបពិត្រ ដែលជាអ្នកអត់ធន់ក្នុងការប្រហារដោយអាវុធ ដែលឆេះសន្ធោសន្ធៅមិនបាន ហើយរត់ឡើងភ្នំលោហៈដែលឆេះសន្ធោសន្ធៅ ដេរដាសដោយដាវ លំពែងដ៏ពន្លឹក ។

ព្រះអង្គឡើងកាន់គំនររងើកភ្លើង ប្រាកដស្មើដោយភ្នំដ៏ប្រាល
ខ្លៅគួរខ្លាច មានខ្លួនឆេះសព្វ ជាសត្វកំព្រាទួញយំ តើនរណា
នឹងទារកហាបណៈ ១ ពាន់ក្នុងបរលោកបាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សន្ធ្វូឡគត្តំ** បានដល់ រាងកាយដែលត្រូវភ្លើងឆេះដោយទូទៅ ។

ដើមឈើដ៏ខ្ពស់ស្មើនឹងពពកវិចិត្រដោយបន្លាដ៏មុត ជាវិការៈនៃ
ដែក ជាបន្លាផឹកឈាមរបស់នរជន ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កណ្ហកាហិ ចិតា** បានដល់ ពេញទៅដោយបន្លាដ៏ប្រាលផ្លោ ។ ដោយបទថា **អយោមយេហិ** នេះ លោកពោលដើម្បីសម្ដែងដល់ដើមឈើដែលពេញដោយបន្លាជាវិការៈនៃដែក ។

ពួកស្ត្រីនិងបុរសដែលក្បត់ប្រពន្ធនៃបុគ្គលដទៃ ត្រូវពួកនាយ
និរយបាលមានដាវក្នុងដៃជាអ្នកធ្វើតាមពាក្យរបស់យមរាជចាក់
ហើយរមែងឡើងដើមឈើនោះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **តមារុហន្តិ** សេចក្ដីថា រមែងឡើងដើមរកាបែបនោះ ។ បទថា **យមនិទ្ទេសការិភិ** សេចក្ដីថា ដែលនាយនិរយបាលធ្វើតាមពាក្យរបស់ស្ដេចយម ។

ព្រះអង្គនឹងឡើងដើមរកាក្នុងនរកមានកាយរាត់រាយប្រឡាក់ដោយ
ឈាម មានស្បែករបកក្ដៅក្រហាយជានិច្ច មានវេទនាដ៏ខ្លាំង ។
ដកដង្ហើមក្ដៅរឿយៗមានកំហុសព្រោះបុព្វកម្ម មានខ្លួនរបកស្បែក
នៅលើចុងរកា តើនរណានឹងទារទ្រព្យនោះ នឹងព្រះអង្គបាន
ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **វិទទ្ធកាយំ** បានដល់ មានកាយត្រូវបែកហើយ ។ បទថា **វិតចំ** សេចក្ដីថា ដូចផ្ការលួសផ្អុងនិងផ្កាចារព្រោះត្រូវកាត់ស្បែកនិងសាច់ ។

ដើមឈើខ្ពស់ស្មើនឹងពពក វិចិត្រដោយស្លឹកជាដាវ ជាវិការៈ
នៃដែកដ៏មុត ជាស្លឹកផឹកឈាមនៃនរជន ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អសិបត្តចិតា** បានដល់ ពេញទៅដោយស្លឹកដាវជាវិការនៃដែក ។

ព្រះអង្គនឹងឡើងដើមរកាមានស្លឹកជាដាវ ត្រូវនាយនិរយបាលកាប់ដោយដាវដ៏មុត មានខ្លួនដុះដាយ កំពុងហូរឈាម តើនរណានឹងទារកហាបណៈ ១ ពាន់ក្នុងបរលោកបាន ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **តមារុហន្តំ** សេចក្ដីថា ជាមួយមហាបពិត្រដែលកំពុងឡើងលើដើមរកានោះ ជាសត្វអត់ធន់មិនបានចំពោះអាវុធនិងគ្រឿងប្រហាររបស់និរយបាល ។

ព្រះអង្គនឹងដើរចេញអំពីនរកមានដើមរកា មានស្លឹកជាដាវនោះ ហើយក៏ធ្លាក់ទៅក្នុងស្ទឹងនរកឈ្មោះវេត្តរណី តើនរណានឹងទារទ្រព្យនោះនឹងព្រះអង្គបាន ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សម្បតិតំ** បានដល់ ធ្លាក់ចុះ ។

ស្ទឹងនរកឈ្មោះវេត្តរណីដ៏កាច មានទឹកផ្សាក្ដៅឆ្អូងបានដោយកម្រ ដ៏ដេរដាសដោយស្លឹកឈូក ជាវិការៈនៃដែករមែងហូរទៅតាមស្លឹកដ៏មុត ។

បណ្ដាបទទាំងនោះ បទថា **ខរា** បានដល់ គ្រោតគ្រាត គឺក្ដៅផ្សា ។ បទថា **អយោបោក្ខរសញ្ឆន្នា** សេចក្ដីថា បិទបាំងដោយស្លឹកឈូកដែកដ៏មុតដោយជុំវិញ ។ បទថា **បវត្តហិ** សេចក្ដីថា ស្ទឹងនោះហូរខ្វលខ្វាញ់ឆ្ងងកាត់ស្លឹកទាំងនោះ ។

ព្រះអង្គមានខ្លួនថ្ពុះធ្លាយ ប្រឡាក់ដោយឈាម ដែលខ្សែទឹកហូរ
ក្ជួចទៅក្នុងស្ទឹងនរកឈ្មោះវេត្តរណីនោះ ជាស្ទឹងមិនមានអ្វីគោង
ទេ តើនរណានឹងទាញទ្រព្យនោះនឹងព្រះអង្គបាន ។

បណ្តាបទទាំងនោះ បទថា **វេត្តរញ្ញោ** សេចក្តីថា ក្នុងវេតរណីនទី គឺក្នុងស្ទឹងទឹកក្រុតឈ្មោះវេត្តរណី ។

## និរយកណ្ឌ ចប់

ឯព្រះបាទអង្គតិរាជបានស្តាប់និរយកថារបស់ព្រះមហាសត្វនោះ ក៏មានព្រះទ័យតក់ស្លុត សង្វេគ កាលទ្រង់ស្វែងរកទីពឹងជាមួយព្រះមហាសត្វទើបត្រាស់ថា

ខ្ញុំញាប់ញ័រដូចជាដើមឈើបម្រុងបាក់ ខ្ញុំវង្វេងសញ្ញាមិនដឹងទិស ក្តៅក្រហាយរឿយៗព្រោះភ័យ ( នឹងបាបដែលខ្ញុំធ្វើហើយ ) បពិត្រឥសី ភ័យដ៏ធំកើតឡើងដល់ខ្ញុំព្រោះបានស្តាប់គាថាដែលលោកសំដែងហើយ ។ បពិត្រឥសី សូមលោកជាទីពឹងរបស់ខ្ញុំ ដូចជាបុគ្គលកាលចុះទៅកាន់ទីពាក់កណ្តាលទឹកព្រោះកាយត្រូវភ្លើងកំពុងឆេះ ឬដូចជាកោះរបស់ពួកជនដែលធ្លាយសំពៅក្នុងអន្លង់ធំក្នុងមហាសមុទ្ទ ឬក៏ដូចជាប្រទីបរបស់ពួកជនអ្នកទៅក្នុងទីងងឹត ។បពិត្រឥសី សូមលោកប្រៀន

ប្រដៅអត្ថនិងធម៌ខ្ញុំផង កំហុស ខ្ញុំបានប្រព្រឹត្តកន្លងហើយអស់
កាលយូរ បពិត្រនារទៈ សូមលោកប្រាប់ផ្លូវសេចក្តីបរិសុទ្ធ
ដល់ខ្ញុំ កុំឲ្យខ្ញុំធ្លាក់ទៅនរកឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ភយានុតប្បាមិ** សេចក្តីថា រមែងក្តៅក្រហាយព្រោះភ័យនៃបាបដែលខ្លួនធ្វើទុក ។ បទថា **មហា ច មេ ភយា** សេចក្តីថា និរយភ័យធំកើតឡើងដល់ខ្ញុំ ។ បទថា **ទីបំវោយេ** សេចក្តីថា ដូចជាកោះក្នុងអន្លង់ទឹកដូច្នោះ លោកអធិប្បាយទុកថា បពិត្រឥសី សូមលោកជាទីពឹងរបស់ខ្ញុំដូចទឹកកាលកាយក្តៅ ដូចកោះរបស់បុគ្គលដែលមានទូកលិចមិនបានទីពឹងក្នុងអន្លង់ទឹកឬមហាសមុទ្ទ ដូចពន្លឺភ្លឺស្វាងដល់បុគ្គល ដែលនៅក្នុងទីងងឹត ។ បទថា **អតីតមទ្ធា អបរាធិតំ មយា** សេចក្តីថា ខ្ញុំបានធ្វើនូវកំហុសដែលជាកម្មអាក្រក់ក្នុងអតីត កន្លងបង់នូវកុសល ធ្វើតែអកុសលដោយចំណែកមួយប៉ុណ្ណោះ ។

កាលព្រះមហាសត្វប្រាប់ផ្លូវបរិសុទ្ធដល់ព្រះបាទអង្គតិរាជនោះ កាលនឹងសម្តែងសម្មាបដិបទារបស់ព្រះរាជាក្នុងកាលមុន ដោយលើកជាឧទាហរណ៍ទើបពោលថា

ព្រះបាទធតរដ្ឋ ១ វេស្សាមិត្ត ១ អដ្ឋកៈ ១ យមទគ្គិ ១
ឧសិន្នរៈ ១ ( សិវិ ១ ) ព្រះរាជាទាំង ៦ អង្គនេះនិងពួក
ព្រះរាជាដទៃ ជាអ្នកបម្រើសមណព្រាហ្មណ៍ ទៅកាន់វិស័យ
ឋានសួគ៌យ៉ាងណា ។ បពិត្រព្រះអង្គជាធំលើផែនដី ព្រះអង្គ

ចូរវៀរអធម៌ ហើយប្រព្រឹត្តធម៌យ៉ាងនោះចុះ ម្យ៉ាងទៀតពួករាជបុរសអ្នកកាន់យកបាយក្នុងប្រាសាទរបស់ព្រះអង្គក្តី ក្នុងបុរីរបស់ព្រះអង្គក្តីចូរឃោសនាថា នរណាឃ្លាន នរណាស្រេក នរណាចង់បានកម្រងផ្កា នរណាចង់បានគ្រឿងលាប នរណាអាក្រាតចង់ស្លៀកដណ្តប់សំពត់ជ្រលក់ពណ៌ផ្សេងៗ ។ នរណាចង់បាំងឆត្រដើរក្នុងផ្លូវ នរណាចង់បានស្បែកជើងដ៏ទន់ល្អ ពួករាជបុរស ចូរឃោសនាក្នុងបុរីរបស់ព្រះអង្គ រាល់ព្រឹករាល់ល្ងាចដូច្នេះឯង ។ សូមព្រះអង្គកុំទឹមគោនិងសេះជាសត្វចិញ្ចឹមចាស់ៗដូចក្នុងកាលមុនឡើយ ( សត្វណា ) មានកម្លាំងធ្វើឧបការៈច្រើនដល់ព្រះអង្គៗ ចូរប្រទានការរក្សា ( ដល់សត្វនោះ ) ផង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឃតេ ច** សេចក្តីថា ព្រះរាជាទាំង ៦ អង្គ គឺ ព្រះបាទធតរដ្ឋ ព្រះបាទវេស្សាមិត្ត ព្រះបាទអដ្ឋកៈ ព្រះបាទយាមតគ្គិ ព្រះបាទឧសិន្នរៈ ព្រះបាទសិវិរាជនិងព្រះរាជាដទៃៗ បានប្រព្រឹត្តធម៌ហើយចូលដល់សក្កវិស័យយ៉ាងណា ទ្រង់ក៏គប្បីវៀរអធម៌ គប្បីប្រព្រឹត្តធម៌យ៉ាងនោះ ។ បទថា **កោ ឆាតោ** សេចក្តីថា បពិត្រមហារាជ ពួករាជបុរសដែលកាន់យកអាហារ ចូរប្រកាសក្នុងវិមាន ក្នុងបុរី ក្នុងរាជនិវេសន៍និងក្នុងព្រះនគររបស់ព្រះអង្គថា អ្នកណាឃ្លាន អ្នកណាស្រេកដូច្នេះ ដើម្បីឲ្យទានដល់ជនទាំងនោះ ។ បទថា **កោ មាលំ** សេចក្តីថា ចូរប្រកាសថា អ្នកណា

ប្រាថ្នាកម្រងផ្កា អ្នកណាចង់បានគ្រឿងលាប អ្នកណាចង់បានសំពត់ពណ៌ក្រហមផ្សេងៗឯណានីមួយចូរឲ្យសំពត់ពណ៌នោះៗ អ្នកណាជាមនុស្សអាក្រាតកាយចូរស្លៀកដណ្ដប់ ។ បទថា **កោ បន្ថេ ជគ្គមានេតិ** សេចក្ដីថា អ្នកណាចង់បាំងឆត្រក្នុងការដើរផ្លូវ ។ បទថា **ឋាទុកា ច** សេចក្ដីថា អ្នកណាប្រាថ្នាស្បែកជើងទន់និងស្អាត ។ បទថា **ជិណ្ណំ ចោសំ** សេចក្ដីថា បុគ្គលណាជាឧបដ្ឋាកនៃទ្រង់ឬជាអាមាត្យ ឬអ្នកដទៃដែលធ្វើឧបការៈមុន ក្នុងកាលដែលចាស់ព្រោះជរា មិនអាចធ្វើការងារបានដូចក្នុងកាលមុន ។ សូម្បីគោនិងសេះជាដើមក្នុងពេលសត្វទាំងនោះចាស់ក៏មិនអាចធ្វើការងារបាន ។ បណ្ដាគោនិងសេះជាដើម សូម្បីតែមួយសូមទ្រង់កុំប្រើក្នុងការងារទាំងឡាយ ដូចក្នុងកាលមុន ។ ពិតហើយក្នុងកាលគ្រាចាស់សត្វទាំងនោះមិនអាចធ្វើការងារទាំងនោះបាន ។ ការរក្សាក្នុងបទថា **បរិហារញ្ច** នេះ លោកពោលដល់សក្ការៈ ។ លោកអធិប្បាយថា បុគ្គលណាជាកម្លាំងរបស់ទ្រង់ គឺជាការធ្វើឧបការៈមកពីមុនដោយភាពជាភ្នាក់ងារ ទ្រង់គប្បីថែរក្សាដល់បុគ្គលនោះដូចក្នុងកាលមុន ពិតហើយអសប្បុរសក្នុងកាលដែលបុគ្គលអាចធ្វើឧបការៈដល់ខ្លួន រមែងធ្វើនូវការរាប់អាន ក្នុងពេលជននោះមិនអាចក៏មិនថែរក្សាឡើយ ឯសប្បុរសក្នុងពេលដែលអាចក្តី មិនអាចក្តីរមែងធ្វើសក្ការៈយ៉ាងនោះ ដល់បុគ្គលនោះ ព្រោះហេតុនោះទ្រង់គប្បីធ្វើយ៉ាងនោះឯង ។

សម័យនោះព្រះមហាសត្វកាលសម្ដែងទានកថានិងសីលកថាហើយ ឥឡូវនេះព្រោះហេតុដែលព្រះរាជានេះត្រេកអរក្នុងការពណ៌នាដោយប្រៀបធៀបរថ

នឹងអត្តភាពរបស់ខ្លួន ព្រោះហេតុនោះកាលនឹងសម្តែងធម៌ ដោយយករថមក ប្រៀបធៀបឲ្យទ្រង់ពេញចិត្តទើបពោលថា

កាយរបស់ព្រះអង្គ ចូរសំគាល់ថាដូចរថ មានចិត្តជានាយសារថី ជាកាយរហ័សរហួន មានការមិនបៀតបៀនជាភ្លៅដែលគេសម្រេចល្អហើយ មានការចែករំលែកទានជាផ្ចឹរ មានការសង្រួមជើងជាខ្នងកង់ មានការសង្រួមដៃជាត្រពង មានការសង្រួមផ្ទៃជាប្រេងលាប មានការសង្រួមវាចាជាស្ងួរមិនលាន់ឮ ។ មានពាក្យពិតជាអង្គនៃរថដ៏បរិបូណ៌ មានការមិនញុះញង់ជាដំណាប់ជិតល្អ មានវាចាពីរោះ ជាអង្គនៃរថមិនមានទោសគឺជារលីង មានការពោលល្មមប្រមាណជាគ្រឿងចង ។ មានសទ្ធានិងអលោភៈជាគ្រឿងប្រដាប់រថ មានការបន្ទន់បន្ទាបនិងអញ្ជលីកម្មជាទូក មានការមិនរឹងត្អឹងជាចន្ទោលរថ មានការសង្រួមសីលជាព្រ័ត្រជ្រាម ។ មានការមិនក្រោធជាការមិនសណ្តក មានសុចរិតធម៌ជាឆត្រស មានពាហុសច្ចៈជាខ្សែចន្ទោល មានចិត្តតាំងនៅនឹងជាអាសនៈ មានការដឹងកាលជាឈើខ្ទឹមដ៏វិចិត្រ មានសេចក្តីក្លៀវក្លាជាចន្ទល់ មានការប្រព្រឹត្តបន្ទន់ខ្លួនជាខ្សែ មានការមិនមើលងាយជានឹមដ៏ស្រាល ។ មានចិត្តមិនរួញរាជាកម្រាល មានការសេពសេចក្តីចម្រើន ( ដោយបញ្ញា ) ជាអំបោស សតិរបស់ព្រះអង្គជាអ្នកប្រាជ្ញ ទុកជាជន្ទួញ

មានព្យាយាមដ៏មាំនិងការប្រកបជាខ្សែបរ ។ ចិត្តដែលទូន្មានល្អ ហើយរមែងទៅកាន់ផ្លូវ ( ដូចរថដែលទៅកាន់ផ្លូវត្រង់ ) ដោយសារសេះទាំងឡាយដែលនាយសារថីហ្វឹកហ្វឺនល្អហើយព្រោះសេចក្តីប្រាថ្នានិងសេចក្តីលោភ ជាផ្លូវខុស ការសង្រួមជាផ្លូវត្រង់ ។ បពិត្រព្រះរាជា កាលបើរថ គឺកាយ ( របស់ព្រះអង្គ ) ស្ទុះទៅក្នុងរូប សំឡេង រស ក្លិន តួបញ្ញាជាជន្លួញសម្រាប់គោះ ឯខ្លួនព្រះអង្គជានាយសារថីក្នុងរថនោះ ។ បពិត្រព្រះរាជា ប្រសិនបើការប្រព្រឹត្តស្មើនិងសេចក្តីព្យាយាមដ៏មាំដោយយានគឺកាយនោះ ការបង្ហូរសេចក្តីប្រាថ្នាគ្រប់យ៉ាងក៏កើតមាន សត្វមិនទៅកាន់នរកដោយដាច់ខាត ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **រថសញ្ញាតោ** សេចក្តីថា បពិត្រមហារាជ ទ្រង់សម្គាល់ថា ព្រះវរកាយរបស់ទ្រង់ថាដូចជារថ ។ បទថា **មនោសារ-ថិកោ** សេចក្តីថា ប្រកបដោយកុសលចិត្តជានាយសារថី ។ បទថា **លទ្ធោ** បានដល់ ជាអ្នកស្រោលព្រោះប្រាសចាកថីនមិទ្ធៈ ។ បទថា **អវិហឹសាសារិតក្ខោ** សេចក្តីថា ប្រកបដោយភ្លៅដែលជាគ្រឿងស្ទុះទៅសម្រេចល្អហើយ ដោយអវិហិង្សា ។ បទថា **សំវិភាគបដិច្ឆទោ** សេចក្តីថា ប្រកបដោយដំបូលដែលសម្រេចដោយការចែកទាន ។ បទថា **បាទសញ្ញមនេមិយោ** បានដល់ ប្រកបដោយខ្នងកង់ដែលសម្រេចដោយការសង្រួមជើង ។ បទថា **ហត្ថសញ្ញមប-ក្ខរោ** សេចក្តីថា ប្រកបដោយទ្រុងដែលសម្រេចដោយការសង្រួមដៃ ។

បទថា **កុច្ឆិសញ្ញមនក្ខន្តោ** សេចក្តីថា បន្ទក់ដោយប្រេងដែលសម្រេចដោយភោជនល្មមប្រមាណ ពោលគឺសង្រួមផ្ទៃ ។ បទថា **វាចាសញ្ញមក្កុជនោ** បានដល់ មានការស្ងប់ស្ងាត់ដោយការសង្រួមវាចា ។ បទថា **សច្ចវាក្យស-មត្តង្គោ** សេចក្តីថា មានការពោលពាក្យសច្ចជាអង្គរថបរិបូណ៌មិនខ្វះខាត ។ បទថា **អបេសុញ្ញសុសញ្ញតោ** សេចក្តីថា មានការមិនពោលពាក្យញុះញង់ជាការសង្រួមផស្សៈយ៉ាងល្អ ។ បទថា **គិរាសខិលនេលង្គោ** សេចក្តីថា មានការពោលពាក្យពីរោះគួរសេពគប់ជាមិត្ត ជាគ្រឿងរថដ៏រលីងមិនមានទោស ។ បទថា **មិតភាណិសិលេសិតោ** សេចក្តីថា មានការពោលល្មមប្រមាណសមរម្យជាគ្រឿងចងដោយល្អ ។ បទថា **សទ្ធាលោភសុសង្ខារោ** សេចក្តីថា ប្រកបដោយគ្រឿងប្រដាប់ដ៏ស្អាតដែលសម្រេចដោយសទ្ធា ពោលគឺការជឿកម្មនិងផលនៃកម្មសម្រេចដោយអលោភៈ ។ បទថា **និវាតញ្ជលិកុព្វរោ** សេចក្តីថា ប្រកបដោយទូករថដែលសម្រេចដោយការប្រព្រឹត្តបន្ទន់បន្ទាបនិងសម្រេចដោយអញ្ជលីកម្មដល់អ្នកមានសីល ។ បទថា **អថទ្ធតានតីសាកោ** សេចក្តីថា មិនមានការរឹងត្អឹងតិចតួចជាចន្ទោលរថ ព្រោះមិនមានការរឹងត្អឹងពោលគឺភាពជាអ្នកមានវាចាគួរសេពគប់ជាសម្លាញ់និងមានវាចានាំមកនូវការត្រេកអរ ។ បទថា **សីលសំវរនន្ទនោ** សេចក្តីថា ប្រកបដោយខ្សែជ្រាមពោលគឺមានសីល ៥ មិនដាច់និងមានការសង្រួមចក្ខុន្ទ្រិយជាដើម ។ បទថា **អក្កោធនមនុគ្ឃាដិ** សេចក្តីថា ប្រកបដោយការមិនទ្រគោះបោះបោកពោលគឺភាពជាអ្នកមិនក្រោធ ។ បទថា **ធម្មបណ្ឌរឆត្តកោ** បានដល់

ប្រកបដោយឆត្រសម្ផូរផង់ ពោលគឺកុសលកម្មបថ ១០ ។ បទថា **ពាហុ-សច្ចមុចាលម្ពោ** បានដល់ ប្រកបដោយខ្សែចន្ទោលដែលសម្រេចដោយភាពជាពហូសូតអាស្រ័យប្រយោជន៍ ។ បទថា **ឋិតិចិត្តមុចាធិយោ** សេចក្តីថា ប្រកបដោយគ្រឿងកម្រាលដ៏កំពូលឬដោយរាជអាសនៈដែលតាំងមាំ ពោលគឺភាពជាបុគ្គលមានអារម្មណ៍តែមួយ តាំងមាំដោយល្អ ដោយការៈមិនញាប់ញ័រដោយលោកធម៌ ។ បទថា **កាលញ្ញុតាចិត្តសារោ** សេចក្តីថា ប្រកបដោយចិត្ត គឺដោយកុសលចិត្តដែលជាសារៈដែលស្គាល់កាលហើយ ទើបធ្វើ ពោលគឺភាពជាអ្នកស្គាល់កាលយ៉ាងនេះថា កាលនេះគួរឲ្យទាន កាលនេះគួររក្សាសីល មានពាក្យអធិប្បាយថា បពិត្រមហារាជ ទ្រង់គួរប្រាថ្នាទព្វសម្ភារៈទាំងអស់ តាំងអំពីស្នៀតនៃរថនិងវត្ថុដែលបរិសុទ្ធិ សម្រេចអំពីវត្ថុដែលជាសារៈយ៉ាងណា រថនោះក៏គួរដល់ការតាំងនៅបានយូរយ៉ាងនោះ សូម្បីរថ គឺកាយរបស់ទ្រង់ក៏ដូចគ្នា មានចិត្តបរិសុទ្ធដឹងកាលហើយទើបធ្វើ ចូរប្រកបដោយកុសលសារៈមានទានជាដើម ។ បទថា **វេសារជ្ជតិឧណ្ហកោ** សេចក្តីថា កាលពោលក្នុងកណ្តាលបរិស័ទ ចូរប្រកបដោយឈើចំពាម ៣ ពោលគឺភាពជាអ្នកក្លៀវក្លា ។ បទថា **និវាតវុត្តិយោត្តង្គោ** សេចក្តីថា ប្រកបដោយខ្សែទាមដ៏ទន់ ពោលគឺការប្រព្រឹត្តក្នុងឱវាទ ពិតហើយសេះសិន្ធពរមែងនាំរថដែលចងដោយខ្សែទាមដ៏ទន់ទៅបានដោយស្រួលយ៉ាងណា ព្រះវរកាយរបស់ព្រះអង្គក៏ដូចគ្នា កាលចងដោយការប្រព្រឹត្តក្នុងឱវាទរបស់បណ្ឌិតទាំងឡាយរមែងស្ទុះទៅបានយ៉ាងស្រួល ។ បទថា **អនតិមានយុគោ លហុ**

សេចក្ដីថា ប្រកបដោយនឹមស្រោល ពោលគឺការមិនតម្កើងខ្លួន ។ បទថា **អលីនចិត្តសន្ថារោ** សេចក្ដីថា រថ គឺព្រះវរកាយរបស់ទ្រង់ចូរមានចិត្តកុំរួញរា កុំរៀចរេរជាកម្រាលដោយកុសល មានទានជាដើមដូចគ្នានឹងរថរមែងស្អាតដោយកម្រាលដ៏ឧត្តម សម្រេចដោយភ្ញុកដូច្នោះ ។ បទថា **វុឡ្ហិសេវី រជោហតោ** សេចក្ដីថា រថកាលស្ទុះតាមផ្លូវដែលមានធូលីដែលមិនស្មើប្រឡាក់ទៅដោយធូលីរមែងមិនស្អាត កាលរត់ទៅដោយផ្លូវដែលស្មើរមែងប្រាសចាកធូលីរមែងស្អាតយ៉ាងណា សូម្បីរថ គឺកាយរបស់ទ្រង់ក៏យ៉ាងនោះប្រព្រឹត្តទៅតាមផ្លូវត្រង់មានផ្ទៃរាបស្មើ ព្រោះសេពនឹងបុគ្គលដែលចម្រើនដោយបញ្ញាទើបកម្ចាត់ធូលីបាន ។ បទថា **សតិ បតោទោ ធីរស្ស** សេចក្ដីថា សតិតាំងមាំល្អរបស់អ្នកប្រាជ្ញ គឺបណ្ឌិតជាជន្ទួញត្រង់រថរបស់ព្រះអង្គនោះ ។ បទថា **ធិតិ យោគោ ច រស្មិយោ** សេចក្ដីថា មានការតាំងមាំពោលគឺមានការព្យាយាមមិនដាច់ខ្សែនិងសេចក្ដីព្យាយាម ពោលគឺការប្រកបក្នុងបដិបទាដែលជាប្រយោជន៍ចាត់ជាបង្ហៀរដ៏មាំទាំ ដែលចងក្នុងរថរបស់ទ្រង់នោះ ។ បទថា **មនោ ទន្តំ បថំ នេតិ សមទន្តេហិ វាជិភិ** សេចក្ដីថា រថដែលស្ទុះទៅក្រៅផ្លូវដោយសេះដែលបង្ហឹកមិនរាបស្មើ តែរថដែលទឹមដោយសេះបង្ហឹកល្អហើយ ទូន្មានល្អហើយរមែងស្ទុះទៅតាមផ្លូវត្រង់នោះឯង យ៉ាងណា សូម្បីចិត្តរបស់ទ្រង់ដែលទូន្មានហើយក៏យ៉ាងនោះ រមែងលះផ្លូវអាក្រក់មិនសេពនូវផ្លូវខុសកាន់យកតែផ្លូវត្រូវដូច្នោះ ។ ព្រោះហេតុនោះទើបចិត្តដែលទូន្មានល្អហើយសម្បូរដោយអាចារៈញុាំងកិច្ចនៃសេះសិន្ធពនៃរថ គឺព្រះវរកាយ

របស់ទ្រង់ឲ្យសម្រេច ។ បទថា **ឥច្ឆា លោភោ ច** សេចក្តីថា ក្នុងការប្រាថ្នានិងការលោភទាំងនោះ ការប្រាថ្នាមានក្នុងវត្ថុដែលមិនទាន់មកដល់ ឯការលោភមានក្នុងវត្ថុដែលមកដល់ហើយ ព្រោះហេតុនោះទើបសេចក្តីប្រាថ្នានិងសេចក្តីលោភនេះឈ្មោះថាជាផ្លូវខុស ជាផ្លូវកោង ជាផ្លូវមិនត្រង់រមែងនាំទៅកាន់អបាយតែម្យ៉ាង តែការសង្រួមក្នុងសីលដែលប្រព្រឹត្តទៅដោយអំណាចនៃកុសលកម្មបថ ១០ ឬមគ្គមានអង្គ ៨ ឈ្មោះថា ផ្លូវត្រង់ ផ្លូវត្រង់នោះចូរជាផ្លូវនៃរថ គឺព្រះវរកាយរបស់ព្រះអង្គ ។ បទថា **រូបេ** សេចក្តីថា សូមទ្រង់មានបញ្ញាជាគ្រឿងជាស់តឿនរថ គឺព្រះវរកាយរបស់ទ្រង់ ដែលស្ទុះទៅកាន់យកនិមិត្តក្នុងកាមគុណមានរូបជាដើម ដែលជាទីគាប់ចិត្តទាំងនោះដូចជន្លួញសម្រាប់គោះហាមនូវសេះសិន្ធពនៃរាជរថដែលស្ទុះចេញក្រៅផ្លូវ បញ្ញានោះតាមឃាត់នូវរថ គឺព្រះវរកាយនោះអំពីការស្ទុះទៅខុសផ្លូវ ឲ្យឡើងកាន់ផ្លូវត្រង់ គឺសុចរិត ។ បទថា **តត្ថ អត្តាវ** សេចក្តីថា ឈ្មោះថា នាយសារថីដទៃរមែងមិនមានក្នុងរថ គឺព្រះវរកាយរបស់ទ្រង់នោះទ្រង់នោះឯងជាសារថីរបស់ទ្រង់ ។ បទថា **សចេ ឯតេន យានេន** សេចក្តីថា បើរថណាមានយានជាគ្រឿងស្ទុះទៅបែបនោះមាន ។ បទថា **សមចរិយា ទឡ្ហា ឋិតិ** សេចក្តីថា ការប្រព្រឹត្តស្មើនិងការតាំងមាំជាថាវរៈរបស់យានណាមានរថ គឺព្រះវរកាយនោះនឹងទៅដោយយាន គឺការប្រព្រឹត្តស្មើជាដើមនោះ មហាបពិត្រ ព្រោះហេតុដែលរថនោះ រមែងឲ្យនូវការប្រាថ្នាទាំងពួង គឺរមែងឲ្យនូវសេចក្តីប្រាថ្នាទាំងពួងតាមដែលមហាបពិត្រប្រាថ្នា ព្រោះហេតុនោះទ្រង់មិនទៅនរក

ដោយពិត ព្រះអង្គទ្រទ្រង់នូវយាននោះទុកដោយចំណែកមួយ ព្រះអង្គមិនទៅនរកដោយយានបែបនោះ ទ្រង់ត្រាស់សេចក្ដីណានឹងអាត្មាថា បពិត្រនារទៈសូមលោកប្រាប់ផ្លូវសេចក្ដីបរិសុទ្ធដល់ខ្ញុំ កុំឲ្យខ្ញុំធ្លាក់ទៅនរកឡើយ សេចក្ដីនេះអាត្មាបានប្រាប់ដល់ទ្រង់ហើយដោយអនេកបរិយាយដោយប្រការដូច្នេះ ។ កាលនារទឥសីសម្ដែងធម៌ថ្វាយព្រះបាទអង្គតិរាជ ឲ្យទ្រង់លះបង់នូវមិច្ឆាទិដ្ឋិ ឲ្យតាំងនៅក្នុងសីលយ៉ាងនេះហើយក៏ថ្វាយឱវាទដល់ព្រះរាជាថា តាំងអំពីនេះទៅសូមទ្រង់លះបាបមិត្តចូលទៅរកកល្យាណមិត្ត ទ្រង់កុំប្រមាទអស់កាលជានិច្ច ដូច្នេះហើយពណ៌នាគុណរបស់ព្រះនាងរុចារាជធីតា ឲ្យឱវាទដល់រាជ-បរិស័ទមួយអន្លើដោយស្រីស្នំ កាលមហាជនកំពុងមើលនោះឯង បានត្រឡប់ទៅកាន់ព្រហ្មលោកដោយអានុភាពធំ ។ ព្រះបាទអង្គតិរាជទ្រង់តាំងនៅក្នុងឱវាទរបស់នារទព្រហ្មលះមិច្ឆាទិដ្ឋិ បំពេញបារមីមានទានជាដើម ជាអ្នកមានស្ថានសួរជាទីទៅខាងមុខ ។

ព្រះសាស្ដាកាលទ្រង់នាំព្រះធម្មទេសនានេះមកសម្ដែងហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន តថាគតក៏ទម្លាយសំណាញ់ គឺទិដ្ឋិ ទូន្មានឧរុវេលកស្សបៈនោះឯងដូចគ្នា កាលទ្រង់ប្រជុំជាតកទើបត្រាស់គាថាទាំងនេះក្នុងគ្រាអវសានថា

អលាតសេនាបតី គឺទេវទត្ត សុនាមអាមាត្យ គឺភទ្ទជិ វិជយ-
អាមាត្យ គឺសារីបុត្ត វិជកទាសៈ គឺមោគ្គល្លាន ។ អចេលកៈ
ឈ្មោះគុណៈ គឺសុនក្ខត្តលិច្ឆវីបុត្ត នាងរុចាណាបានញ៉ាំងព្រះ

រាជាឲ្យជ្រះថ្លា នាងរុចានោះ គឺអានន្ទ ។ ព្រះរាជា ( អង្គតិ ) ដែលមានទិដ្ឋិអាក្រក់ក្នុងកាលនោះ គឺឧរុវេលកស្សប មហាព្រហ្ម គឺពោធិសត្វ អ្នកទាំងឡាយចូរចាំទុកនូវជាតកដូចសំដែងមកនេះ ដូច្នេះ ។

## អដ្ឋកថា មហានារទកស្សបជាតក ចប់

# វិធុរជាតក

[ ៦០ ] ( វរុណនាគរាជសួរថា ) នាងមានសម្បុរល្អឿង ស្គាំងស្គម មានកម្លាំងតិច ពីដើមរូបសម្បុររបស់នាងមិនមែនបែបនេះទេ ម្នាលនាងវិមលា ខ្ញុំសួរហើយ នាងចូរប្រាប់ តើវេទនាក្នុងសរីរៈរបស់នាងដូចម្ដេច ។

[ ៦១ ] ( នាងវិមលាទូលថា ) បពិត្រព្រះអង្គជាធំជាងនាគជន ទំនៀមរបស់ស្ត្រីទាំងឡាយក្នុងពួកមនុស្ស ( ដែលមានគភ៌ ) គេហៅថា ចំណង់ប្លែក បពិត្រព្រះអង្គជាកុញ្ជររបស់នាគ ខ្ញុំម្ចាស់ចង់បានដួងហឫទ័យរបស់វិធុរបណ្ឌិត ដែលត្រូវនាំយកមកដោយធម៌ ។

[ ៦២ ] ( វរុណនាគរាជ... ) ម្នាលនាងវិមលា នាងចង់បាន ( ដួងហឫទ័យរបស់វិធុរបណ្ឌិតនោះដូចបុគ្គលប្រាថ្នា ) ព្រះចន្ទ ព្រះអាទិត្យ ឬព្រះពាយ ព្រោះថាការជួបប្រទះនឹងវិធុរបណ្ឌិតគេគប្បីបានដោយក្រ នរណានឹងនាំព្រះវិធុរបណ្ឌិតមកក្នុងពិភពនាគនេះបាន ។

[ ៦៣ ] ( នាងឥរន្ទតី... ) បពិត្របិតា ហេតុអ្វីហ្ន៎ ព្រះអង្គសញ្ជប់សញ្ជឹងព្រះភក្ត្ររបស់ព្រះអង្គដូចជាផ្កាឈូកដែលគេឈ្ងីដោយដៃ បពិត្រព្រះអង្គជាឥស្សរៈ ព្រះអង្គតូចព្រះហឫទ័យដូចម្ដេច បពិត្រព្រះអង្គអ្នកញ៉ាំងសត្រូវឲ្យក្ដៅ សូមព្រះអង្គកុំទ្រង់សោយសោកឡើយ ។

[ ៦៤ ] ( វរុណនាគរាជ... ) ម្នាលនាងឥរន្ទតី មាតារបស់នាងចង់បានហឫទ័យរបស់វិធុរបណ្ឌិតតែការជួបប្រទះនឹងវិធុរបណ្ឌិត គេគប្បីបានដោយក្រ នរណានឹងនាំវិធុរបណ្ឌិតមកក្នុងពិភពនាគនេះបាន ។

[ ៦៥ ] កស្តាណា នាំវិធុរបណ្ឌិតមកក្នុងទីនេះបាន នាងចូរត្រាច់ទៅស្វែងរកកស្តានោះចុះ ។ នាងឥរន្ទតីនោះ លុះបានស្តាប់បន្ទូលព្រះបិតាហើយ ក៏ចេញទៅក្នុងវេលារាត្រី ជាស្រីជោកជាំ ( ដោយរាគៈ ) បានត្រាច់ទៅ ( ស្វែងរកព្រះកស្តា ) ។

[ ៦៦ ] ( នាងឥរន្ទតី... ) នរណាទោះជាគន្ធព្វក្តី នរណាទោះជាអារក្សទឹកឬជានាគក្តី នរណាទោះជាកិន្នរឬជាមនុស្សក្តី នរណាទោះជាបណ្ឌិតដែលឲ្យសេចក្តីប្រាថ្នាទាំងពួងក្តី អ្នកនោះនឹងជាកស្តារបស់ខ្ញុំ អស់កាលមានរាត្រីដ៏វែង ។

[ ៦៧ ] ( បុណ្ណកយក្ស... ) ម្នាលនាងមានក្អែកគេតិះដៀលមិនបាន នាងចូរជកជង្ហើមស្រួល ( ត្រេកអរ ) ចុះ ខ្ញុំនឹងជាប្តីរបស់នាង នឹងជាកស្តារបស់នាងដោយសារបញ្ញារបស់ខ្ញុំមានសភាពដូច្នោះ នាងចូរជកជង្ហើមស្រួលចុះ នាងនឹងជាភរិយារបស់ខ្ញុំ ។

[ ៦៨ ] នាងឥរន្ទតី ក៏មានចិត្តក្ដួចកាន់ តាមគន្លងដែលធ្លាប់ជាប្តីក្នុងជាតិមុនបាននិយាយនឹងបុណ្ណកយក្សថា អ្នកចូរមកយើងនឹងនាំគ្នាទៅឯសំណាក់បិតាខ្ញុំ បិតានោះនឹងប្រាប់សេចក្តីនុ៎ះដល់អ្នក ។

[ ៦៩ ] ( អភិសម្ពុទ្ធគាថា ) នាងឥរន្ទតីតាក់តែងខ្លួន ស្លៀកដណ្តប់ល្អ ទ្រង់កម្រងផ្កាប្រោះព្រំដោយខ្លឹមចន្ទន៍ ចាប់ដៃបុណ្ណកយក្សនាំចូលទៅកាន់សំណាក់បិតា ។

[ ៧០ ] ( បុណ្ណកយក្ស... ) បពិត្រព្រះអង្គប្រសើរជាងពួកនាគ សូម

ព្រះអង្គទ្រង់ព្រះសណ្ដាប់ពាក្យរបស់ខ្ញុំព្រះអង្គ សូមព្រះអង្គទ្រង់ទទួលសួយដ៏សមគួរ ( ដល់ត្រកូលនិងប្រទេសរបស់ព្រះអង្គ ) ខ្ញុំព្រះអង្គចង់បាននាងឥរន្ទតី សូមព្រះអង្គធ្វើខ្ញុំព្រះអង្គឲ្យមូលមិត្តជាមួយនឹងនាងឥរន្ទតីនោះ ។ បពិត្រព្រះអង្គដ៏ប្រសើរ សូមព្រះអង្គទ្រង់ទទួលនូវសួយទាំងនោះ គឺដំរី ១០០ សេះ ១០០ រថទឹមដោយសេះអស្សតរ ១០០ និងរទេះដែលផ្ទុកពេញដោយរតនវត្ថុផ្សេងៗទាំងអស់ ១០០ សូមព្រះអង្គទ្រង់ព្រះរាជទានធីតាឈ្មោះនាងឥរន្ទតីឲ្យទាន ។

[ ៧១ ] ( ព្រះបាទវរុណ... ) អ្នកចូររង់ចាំយើងប្រឹក្សានឹងពួកញាតិមិត្ត ឬសម្លាញ់ដ៏ស្និទ្ធស្នាលសិន អំពើដែលយើងធ្វើដោយមិនបានប្រឹក្សាណា អំពើនោះរមែងក្ដៅក្រហាយក្នុងកាលខាងក្រោយ ។

[ ៧២ ] លំដាប់នោះ វរុណនាគនោះ ចូលទៅកាន់លំនៅហើយប្រឹក្សានឹងភរិយា ហើយពោលពាក្យនេះថា បុណ្ណកយក្សនេះសូមនាងឥរន្ទតីនឹងយើង យើងនឹងឲ្យនាងឥរន្ទតី ជាទីស្រឡាញ់របស់យើងដល់បុណ្ណកយក្សនោះដោយការបានវត្ថុជាទីត្រេកអរច្រើនជាថ្នូរ ។

[ ៧៣ ] ( នាងវិមលា... ) បុណ្ណកយក្សមិនត្រូវបាននាងឥរន្ទតីជាធីតារបស់យើងដោយទ្រព្យ មិនត្រូវបានដោយវត្ថុជាទីត្រេកអរទេ តែបើបុណ្ណកយក្សបានហឫទ័យរបស់បណ្ឌិតដោយធម៌ហើយនាំមកក្នុងពិភពនាគនេះ ទើបត្រូវបាននាងកុមារី ដោយសារវត្ថុជាទីត្រេកអរនុ៎ះ យើងមិនចង់បានទ្រព្យដទៃតទៅទៀតទេ ។

[ ៧៤ ] លំដាប់នោះវរុណនាគនោះចេញអំពីលំនៅ ហៅបុណ្ណកយក្ស មកនិយាយពាក្យនេះថា អ្នកមិនត្រូវបាននាងឥរន្ទតី ជាធីតារបស់យើងដោយទ្រព្យ មិនត្រូវបានដោយវត្ថុជាទីត្រេកអរជាថ្នូរទេ បើអ្នកបានហឫទ័យរបស់បណ្ឌិតដោយធម៌ហើយនាំមកក្នុងពិភពនាគនេះ ទើបអ្នកត្រូវបាននាងកុមារីដោយសារវត្ថុជាទីត្រេកអរនុ៎ះ យើងមិនចង់បានទ្រព្យដទៃតទៅទៀតទេ ។

[ ៧៥ ] ( បុណ្ណកយក្ស... ) បពិត្រព្រះអង្គដ៏ប្រសើរ បុគ្គលពួកខ្លះក្នុងលោកនេះហៅមនុស្សណាថាជាបណ្ឌិត បុគ្គលឯទៀតបែរជាហៅបុគ្គលនោះថាជាពាលវិញ ពួកជនតែងជជែកគ្នាក្នុងរឿងនេះ សូមព្រះអង្គត្រាស់ប្រាប់ដល់ខ្ញុំព្រះអង្គឲ្យទាន បពិត្រនាគ ព្រះអង្គត្រាស់ហៅអ្នកណាថាជាបណ្ឌិត ។

[ ៧៦ ] ( ព្រះបាទវរុណ... ) អាមាត្យឈ្មោះវិធុរៈរបស់ធនញ្ជយកោរព្យរាជ អ្នកក៏ធ្លាប់បានឮហើយ បើអ្នកបានបណ្ឌិតនោះដោយធម៌ហើយនាំមក នាងឥរន្ទតីចូរបានជាអ្នកបម្រើជើងរបស់អ្នកចុះ ។

[ ៧៧ ] ចំណែកបុណ្ណកយក្ស លុះបានស្តាប់ព្រះបន្ទូលរបស់វរុណនាគនេះហើយក៏ក្រោកឡើង ត្រេកអរក្រៃលែងហើយសម្លំនៅក្នុងទីនោះ បង្គាប់បុរស ( អ្នកបម្រើរបស់ខ្លួន ) ថា អ្នកចូរនាំសេះអាជានេយ្យដែលបានសម្រិតសម្រាំងយកមកក្នុងទីនេះ ។ ត្រចៀក ( របស់សេះនោះ ) ប្រដាប់ដោយមាស ក្រចកប្រដាប់ដោយកែវមណីមានពណ៌ក្រហម គ្រឿងបិទបាំងឰដ៏ទ្រូងប្រដាប់ដោយមាសឆ្អិនឈ្មោះជម្ពូនទ ។

[ ៧៨ ] ( អភិសម្ពុទ្ធគាថា ) បុណ្ណកយក្សតាក់តែងខ្លួន កាត់កោរ

សក់និងពុកមាត់ស្រេចហើយក៏ឡើងជិះសេះដែលជាយាន ដូចជាពាហនៈនៃទេវតាហោះទៅឰដ៏អាកាសវេហា ។ បុណ្ណកយក្សនោះជាប់ចំពាក់ដោយកាមរាគប្រាថ្នានាងឥរន្ធតីជាកញ្ញានៃនាគ បានទៅក្រាបទូលព្រះបាទវេស្សវណកុវេរៈដ៏ទ្រង់យសជាម្ចាស់ពួកយក្សនោះដូច្នេះថា មន្ទីរឈ្មោះភោគវតីគេហៅថា វាសៈ ( ព្រោះជាលំនៅនៃស្តេចនាគ ) គេហៅថា ហិរញ្ញវតី ( ព្រោះជាទីដែលបិទបាំងដោយកំពែងប្រាក់ ) ជានគរសម្រេចអំពីមាសដែលសាងសម្រេចដល់នាគមានមណ្ឌលនៃក្អេន ។ ប៉មមានសណ្ឋានដូចកអូដ្ឋធ្វើអំពីកែវមណីក្រហមនិងកែវមរកត ប្រាសាទក្នុងពិភពនាគធ្វើអំពីកែវមណីប្រក់ដោយរតនៈ គឺមាស ។ ដើមឈើទាំងឡាយ គឺដើមស្វាយ ដើមទ្រមូច ដើមព្រីង ដើមសត្ត បណ្ណ ( ឈើមានសន្លឹក ៧ ) ដើមរាំងអន្ទក់ ដើមកេតក៏ ដើមបិយង្គុ ដើមរាជព្រឹក្សព្រមទាំងដើមបារិច្ឆត្តព្រឹក្ស ដើមឈើទាលខ្សាច់ ( មានក្នុងពិភពនាគនោះ ) ។ ដើមចម្ប៉ា ដើមខ្នឹង ម្ទិះ នួនស្រីនិងដើមក្រថៅមានក្នុងក្រុងពិភពនាគនោះ ដើមឈើទាំងនោះទន់ទោរល្អរុងរឿងក្នុងមន្ទីរនៃនាគ ។ ព្រះបាទវរុណៈជាឱបបាតិកៈកំណើតមានឫទ្ធិច្រើននៅក្នុងពិភពនាគណា ពួកដើមផ្អាវជាច្រើនដ៏ហើយដោយកែវឥន្ទនីល មានផ្កាជានិច្ច ជាវិការៈនៃមាសក្នុងពិភពនាគនោះ ។ នាងវិមលាជាភរិយារបស់ព្រះបាទវរុណនាគនោះ ជាស្រីនៅក្មេងមានរាងកាយភ្លឺផ្លេកដូចមាស មានព្រះថនាដូចផ្លែស្គោ គួរជាទីរមិលដោយសេចក្តីពេញចិត្ត ឬដូចត្រួយវល្លិប្រេងខ្ចី ។ នាងវិមលាមានសម្បុរថ្លៃក្រហមដូចពណ៌លក្ខដូចផ្កាកណ្ណិការរីកក្នុងទីមិនមានខ្យល់ ឬដូចស្រីអប្សរនៅក្នុងឋានត្រៃត្រិង្ស ឬក៏ដូច

ផ្ទុកបន្ទោរជាលប្រវាត់ចេញអំពីស្រទាប់ពពក ។ នាងវិមលានោះជាស្រីមាន ចំណង់ប្លែកអស្ចារ្យក្រៃលែង ចង់បានហឫទ័យនៃវិធុរបណ្ឌិត បពិត្រព្រះអង្គ ជាឥស្សរៈ ខ្ញុំនឹងឲ្យហឫទ័យវិធុរបណ្ឌិតនោះដល់នាគទាំងឡាយនោះ នាគទាំងនោះនឹងឲ្យនាងឥរន្ទតីដល់ខ្ញុំដោយហេតុនោះ ។

[ ៧៩ ] បុណ្ណកយក្សនោះទូលថា ព្រះបាទវេស្សវណកុវេរៈជាម្ចាស់នៃភូត ជាព្រះរាជាមានយសហើយសម្ងំនៅក្នុងទីនោះ បង្គាប់បុរស ( អ្នកបម្រើខ្លួន ) ថា អ្នកចូរនាំសេះអាជានេយ្យដែលបានស្អិតស្អាងយកមកក្នុងទីនេះ ។ ត្រចៀក ( របស់សេះនោះ ) ប្រដាប់ដោយមាស ក្រចកសេះប្រដាប់ដោយកែវមណីមានពណ៌ក្រហម គ្រឿងបិទបាំងទ្រូងដ៏ទ្រទ្រង់ប្រដាប់ដោយមាសផ្អិនឈ្មោះជម្ពោនទ បុណ្ណកយក្សតាក់តែងខ្លួន កាត់កោរសក់និងពុកមាត់ស្រេច ហើយក៏ឡើងជិះសេះដែលជាយាន ដូចជាពាហនៈនៃទេវតាហោះទៅឰដ៏អាកាសវេហា ។

[ ៨០ ] បុណ្ណកយក្សនោះបានទៅកាន់នគររាជគ្រឹះ ជាទីរីករាយដ៏ក្រៃលែង ជាក្រុងរបស់ព្រះបាទអង្គរាជ ដែលសត្រូវចូលមកបានដោយក្រ ជាក្រុងមានភក្សាហារច្រើន មានបាយនិងទឹកច្រើនដូចជាភពឈ្មោះមសក្កសារៈរបស់វាសវៈ ។ នគរនោះគឹកកងដោយហ្វូងនៃក្ងោកនិងក្រៀល គឹកកងដោយសត្វស្វាប ដែលពួកសត្វស្វាបអាស្រ័យនៅ មានសូរសំឡេងនៃពួកបក្សីផ្សេងៗ មានព្រះលានដ៏ល្អ ដេរដាសដោយផ្កាដូចជាភ្នំហិមវន្ត ។ បុណ្ណកយក្សនោះឡើងទៅកាន់ភ្នំឈ្មោះវេបុលៈ ជាទីអាស្រ័យនៅនៃពួកកិន្នរហើយស្វែងរកកែវ

មណីដ៏ប្រសើរបានឃើញកែវមណីនោះត្រង់កណ្តាលកំពូលភ្នំ ។

[ ៨១ ] បុណ្ណកយក្ស ឃើញកែវមណីមានជាតិ ( ផ្សេងៗ ) ជាទីផ្សាយចេញនៃរស្មីរុងរឿង ជាកែវមណីដ៏ប្រសើរអាចនាំមកនូវទ្រព្យ ជាកែវរុងរឿង ជាកែវមានយសជាងយសក្តិរុងរឿងដូចផ្កេកបន្ទោរឰដ៏អាកាស ក៏បានកាន់យកកែវមណីឈ្មោះមនោហរៈនោះ ជាកែវពៃទូរ្យមានតម្លៃច្រើន មានអានុភាពច្រើន ជាអ្នកមានភេទមិនថោកទាប ឡើងជិះសេះអាជានេយ្យហោះទៅឰដ៏អាកាសវេហា ។

[ ៨២ ] បុណ្ណកយក្សនោះ បានទៅកាន់ក្រុងឥន្ទបត្ត ចុះ ( អំពីសេះ ) ហើយចូលទៅកាន់ទីប្រជុំនៃអ្នកដែនកុរុ មិនកោតញញើតព្រះរាជា ១០១ អង្គដែលព្រមព្រៀងគ្នាមកប្រជុំ ( នៅទីនោះ ) បបួលថា បណ្តាពួកព្រះរាជាក្នុងរាជសមាគមនេះ ព្រះរាជាអង្គណាឈ្នះយើង ( ត្រូវយក ) កែវដ៏ប្រសើរ ( របស់យើង ) បើយើងឈ្នះព្រះរាជាអង្គណាវិញ ( ត្រូវយក ) ទ្រព្យដ៏ប្រសើរឬយើងឈ្នះព្រះរាជាអង្គណា ( នឹងយក ) កែវដ៏ប្រសើរថ្លៃថ្លាក៏បានចំណែកព្រះរាជាអង្គណាឈ្នះយើងវិញ ( នឹងយក ) ទ្រព្យដ៏ប្រសើរក៏បាន ។

[ ៨៣ ] ( ព្រះបាទកោរព្យៈ... ) ជាតិភូមិរបស់អ្នកនៅក្នុងដែនណាពាក្យរបស់អ្នកនេះមិនមែនជាពាក្យរបស់អ្នកដែនកុរុទេ អ្នកមានវាចាអង់អាចមិនកោតខ្លាចយើងទាំងអស់គ្នា អ្នកចូរប្រាប់ឈ្មោះនិងផៅពង្សដល់យើង ។

[ ៨៤ ] ( បុណ្ណកយក្ស... ) បពិត្រព្រះរាជា ខ្ញុំជាមាណពកច្ចាយនគោត្ត ពួកញាតិនិងផៅពង្សរបស់ខ្ញុំក្នុង ( កាលចម្បាកនគរ ) ដែនអង្គៈ

តែងហៅខ្ញុំថា មាណពមានឈ្មោះមិនថោកទាប បពិត្រព្រះសម្មតិទេព ខ្ញុំមកក្នុងទីនេះដើម្បីលេងល្បែងភ្នាល់ ។

[ ៨៥ ] ( ព្រះបាទកោរព្យ... ) អ្នកលេងល្បែងភ្នាល់ កាលបើឈ្នះអ្នកគប្បីយកកែវទាំងឡាយណា កែវទាំងនោះរបស់មាណពឯងមានដែរឬ ឯកែវរបស់ព្រះរាជាមានចំនួនច្រើន អ្នកជាមនុស្សទាល់ក្រនឹងបបួលព្រះរាជាទាំងនោះដូចម្តេចបាន ។

[ ៨៦ ] ( បុណ្ណកយក្ស... ) ឯកែវមណីរបស់ខ្ញុំនេះអាចនាំមកនូវទ្រព្យបាន អ្នកលេងល្បែងភ្នាល់បើលេងឈ្នះខ្ញុំហើយ គប្បីយកកែវមណីដ៏ប្រសើរ ជាកែវអាចនាំមកនូវទ្រព្យនេះ ១ និងសេះអាជានេយ្យអាចបង្ក្រាបសត្រូវនេះ ១ របស់ខ្ញុំចុះ ។

[ ៨៧ ] ( ព្រះបាទកោរព្យ... ) ម្នាលមាណព កែវមណីមួយនឹងធ្វើអ្វីបានទាំងសេះអាជានេយ្យមួយនឹងធ្វើអ្វីបាន ( ព្រោះ ) កែវទាំងឡាយរបស់ព្រះរាជាមានចំនួនច្រើន សេះអាជានេយ្យរបស់ព្រះរាជាមានសន្ទុះដូចខ្យល់ក៏មានចំនួនមិនតិចទេ ។

ចប់ ទោហឡកណ្ឌ ។

[ ៨៨ ] ( បុណ្ណកយក្ស... ) បពិត្រព្រះអង្គប្រសើរជាងសត្វជើងពីរ សូមព្រះអង្គទ្រង់ទតកែវមណីរបស់ខ្ញុំនេះចុះ ក្នុងកែវមណីនេះ មានរាងកាយរបស់ស្រ្តី មានរាងកាយរបស់បុរស ។ មានរាងកាយរបស់ម្រឹគ មានរាងកាយ

របស់បក្សីប្រាកដក្នុងកែវមណីនេះ សូមព្រះអង្គទ្រង់ទត នាគរាជនិងគ្រុឌជារូបនិម្មិតក្នុងកែវមណី ។

[ ៨៩ ] សូមព្រះអង្គទ្រង់ទតសេនាមានអង្គ ៤ គឺពលដំរី ១ ពលរថ ១ ពលសេះ ១ ពលថ្មើរជើងមានគ្រឿងក្រោះ ១ ជារូបនិម្មិតក្នុងកែវមណី ។ សូមព្រះអង្គទ្រង់ទតពលដំរីនិងពួកសេនា ពលរថនិងពលថ្មើរជើង គឺពួកពលដែលរៀបជាព្យុហៈ ជារូបនិម្មិតក្នុងកែវមណី ។

[ ៩០ ] សូមព្រះអង្គ ទ្រង់ទតនគរដ៏បរិបូណ៌ដោយប៉ម មានកំពែងនិងខ្លោងទ្វារដ៏ច្រើនជាន់ មានផ្លូវបែកជា ៤ និងផែនដីដ៏ល្អ ជារូបនិម្មិតក្នុងកែវមណី ។ សូមព្រះអង្គទ្រង់ទតសសរខឿន គូ រនុកទ្វារ គន្លឹះទ្វារ ប៉មនិងទ្វារប៉ម ជារូបនិម្មិតក្នុងកែវមណី ។

[ ៩១ ] សូមព្រះអង្គ ទ្រង់ទតពួកបក្សីផ្សេងៗជាច្រើន ទៀបខ្លោងទ្វារនិងផ្លូវ គឺហ្វូងហង្ស ក្រៀល ក្ងោក ចាក្រពាក អក សូមព្រះអង្គទ្រង់ទតទីក្រុងដ៏ដេរដាសដោយបក្សីផ្សេងៗ គឺតាវៅខ្មៅ តាវៅពព្រុស ក្ងោកនិងប៉ោលតោកជាច្រើន ជារូបនិម្មិតក្នុងកែវមណី ។

[ ៩២ ] សូមព្រះអង្គទ្រង់ទតទីក្រុងមានកំពែងល្អអស្ចារ្យ ចម្លែកគួរព្រឺរោម មានទង់ជ័យលើកឡើង ក្រាលដោយដីខ្សាច់ដែលមានសម្បុរដូចមាស គួរជាទីរីករាយ ។ សូមព្រះអង្គទ្រង់ទតរានផ្សារដ៏បរិបូណ៌ដោយទំនិញដែលគេចែកជាជួរជាសង្កាត់តាមចំណែកមានផ្ទះនិងទីផ្ទះ តំណនៃផ្ទះ ច្រកទាល់និងផ្លូវទាំងឡាយ ។

[ ៩៣ ] សូមព្រះអង្គ ទ្រង់ទតពេងសុរា អ្នកលេងសុរា អ្នកគ្រួ ផ្ទះបាយ ពួកឈ្មួញនិងពួកស្រីពេស្យា ជារូបនិម្មិតក្នុងកែវមណី ។ សូមព្រះអង្គទ្រង់ទត ពួកជនអ្នកធ្វើផ្កាកម្រង ជាងជ្រលក់ អ្នកធ្វើគ្រឿងក្រអូប អ្នកត្បាញសំពត់ ជាងមាសនិងជាងកែវមណី ជារូបនិម្មិតក្នុងកែវមណី ។ សូមព្រះអង្គទ្រង់ទត ពួកជនអ្នកធ្វើសម្ល ជនធ្វើបាយ អ្នករបាំ នាយរបាំ អ្នកច្រៀង អ្នកច្រៀង ទះដៃនិងអ្នកវាយស្គរ ជារូបនិម្មិតក្នុងកែវមណី ។

[ ៩៤ ] សូមព្រះអង្គ ទ្រង់ទតស្គរសម្ភោរ ស័ង្ខ ខ្លុយ ស្គរជ័យនិង គ្រឿងភ្លេងទាំងអស់ ជារូបនិម្មិតក្នុងកែវមណី ។ សូមព្រះអង្គទ្រង់ទតក្រាប់ ឈឹង ពិណ របាំ ចម្រៀងប្រគំដែលគឹកកងដោយតូរ្យតន្ត្រីដ៏វងំ ជារូបនិម្មិត ក្នុងកែវមណី ។ សូមព្រះអង្គទ្រង់ទតពួកជនអ្នកលោត អ្នកប្រដាល់ អ្នកធ្វើ ខាងកលមាយានិងស្រីប្រុសដ៏ល្អក្នុងកែវមណីនេះ ទាំងពួកអ្នកជាស់តៀនគេ នឹងអ្នកកាត់កោរសក់ ជារូបនិម្មិតក្នុងកែវមណី ។

[ ៩៥ ] មហោស្រពទាំងឡាយដ៏មីរជេរជាស ដោយបុរសនិងស្ត្រី ក៏មានក្នុងកែវមណីនេះ សូមព្រះអង្គទ្រង់ទតគ្រែតូចនិងគ្រែធំនិងទី ( នៃ មហោស្រព ) ជារូបនិម្មិតក្នុងកែវមណី ។ សូមព្រះអង្គទ្រង់ទតពួកអ្នកចំបាប់ ដែលចំបាប់គ្នាដោយដៃទាំងពីរក្នុងទីមហោស្រព សូមព្រះអង្គទ្រង់ទតពួកអ្នក ឈ្នះនិងអ្នកចាញ់ ជារូបនិម្មិតក្នុងកែវមណី ។

[ ៩៦ ] សូមព្រះអង្គ ទ្រង់ទតពួកម្រឹគផ្សេងៗជាច្រើនទៀបជើងភ្នំ គឺ រាជសីហ៍ ខ្លាធំ ជ្រូកព្រៃ ខ្លាឃ្មុំ ឆ្កែព្រៃ ខ្លាឯិន ។ សត្វរមាស គោ ក្របី

រមាំង ប្រើស ទ្រាយ សរកម្រឹគ ក្ដាន់ ជ្រូក ស្រុក ។ ឈ្លូស ពួក ចិត្រម្រឹគជាច្រើន ខ្លាត្រី ទន្សាយនិងកង្កែន សូមព្រះអង្គទ្រង់ទតដើងភ្នំដ៏ដេរដាសដោយពួកម្រឹគផ្សេងៗ ជារូបនិម្មិតក្នុងកែវមណី ។

[ ៩៧ ] ស្ទឹងទាំងឡាយមានកំពង់រាបទាបល្អ ដែលក្រាលដោយខ្សាច់មាសមានទឹកថ្លា មានពួកត្រីអាស្រ័យតែងហូរទៅ ។ ពួកក្ដាម មករ ក្រពើ អណ្ដើក ត្រីស្លាត ត្រីសណ្ដាយ ត្រីឆ្តោ ត្រីឆ្ពិន មានក្នុងកែវមណីនេះ ។ សូមព្រះអង្គទ្រង់ទតស្រះបោក្ខរណីដែលធ្វើដោយថែនថ្ម ជាវិការៈនៃកែវពៃទូរ្យ ដ៏ដេរដាសដោយពួកសត្វស្លាបផ្សេងៗ មានពួកឈើផ្សេងៗជាជួរ ជារូបនិម្មិតក្នុងកែវមណី ។

[ ៩៨ ] សូមព្រះអង្គទ្រង់ទតស្រះបោក្ខរណីក្នុងកែវមណីនេះ ដែលចាត់ចែងដោយល្អទាំង ៤ ទិសដ៏ដេរដាសដោយពួកសត្វស្លាបផ្សេងៗ ដែលត្រីធំអាស្រ័យនៅ សូមព្រះអង្គទតផែនដីដ៏បរិបូណ៌ដោយទឹកព័ទ្ធជុំវិញជាកុណ្ឌលនៃសាគរប្រកបដោយជួរដងព្រៃទាំងឡាយ ជារូបនិម្មិតក្នុងកែវមណី ។

[ ៩៩ ] សូមព្រះអង្គ ទ្រង់ទតមើលទ្វីបទាំង ៤ គឺបុព្វវិទេហទ្វីបខាងកើត អបរគោយានទ្វីបខាងលិច ឧត្តរកុរុទ្វីបនិងជម្ពូទ្វីប ជារូបនិម្មិតក្នុងកែវ-មណី ។ សូមព្រះអង្គទ្រង់ទតព្រះចន្ទនិងព្រះអាទិត្យ កំពុងបំភ្លឺទិសទាំង ៤ សូមព្រះអង្គទ្រង់ទត ( ព្រះចន្ទនិងព្រះអាទិត្យនោះ ) កំពុងដើរក្រឡឹងភ្នំសិនេរុ ជារូបនិម្មិតក្នុងកែវមណី ។ សូមព្រះអង្គទ្រង់ទតភ្នំសិនេរុ ភ្នំហិមពាន្ត សមុទ្ទសាគរ ដែលមានឫទ្ធិច្រើននិងមហារាជទាំង ៤ អង្គ ជារូបនិម្មិតក្នុង

កែវមណី ។ សូមព្រះអង្គទ្រង់ទតសួនច្បារ ព្រៃ គុម្ព ឈើ ខ្នងថ្មភ្នំ ហាក់ដូចជាគេក្រាលតម្កល់ទុកដ៏ដេរដាសដោយពួកកិន្នរ គួរជាទីរីករាយ ជារូបនិម្មិតក្នុងកែវមណី ។ សូមព្រះអង្គទ្រង់ទតបារុសកវ័ន ចិត្តលតាវ័ន មិស្សកវ័ន នន្ទនវ័ននិងវេជយន្តប្រាសាទ ជារូបនិម្មិតក្នុងកែវមណី ។ សូមព្រះអង្គទ្រង់ទតសុធម្មសភាឋានតាវត្តិង្ស ដើមបារិច្ឆត្តព្រឹក្សមានផ្ការីក ស្តេចដំរីឈ្មោះឯរាវ័ណ ជារូបនិម្មិតក្នុងកែវមណី ។ សូមព្រះអង្គទ្រង់ទតពួកស្រីទេពកញ្ញាដែលភ្លឺផ្លេកដូចជាផ្លេកបន្ទោរចេញចាកពពក កំពុងត្រាច់ទៅក្នុងនន្ទនវ័ន ជារូបនិម្មិតក្នុងកែវមណី ។ សូមព្រះអង្គទ្រង់ទតពួកទេពកញ្ញាប្រលោមទេវបុត្តនិងពួកទេវបុត្តកំពុងរីករាយក្នុងនន្ទនវ័ន ជារូបនិម្មិតក្នុងកែវមណី ។

[ ១០០ ] សូមព្រះអង្គទ្រង់ទតប្រាសាទច្រើនជាងពាន់ដែលក្រាលដោយផែនក្តារកែវពៃទូរ្យមានសម្បុររុងរឿង ជារូបនិម្មិតក្នុងកែវមណី ។ សូមព្រះអង្គទ្រង់ទតឋានតាវត្តិង្ស យាមា តុសិត និម្មានរតី បរនិម្មិតវសវត្តី ជារូបនិម្មិតក្នុងកែវមណី ។ សូមព្រះអង្គទ្រង់ទតស្រះបោក្ខរណី ក្នុងជាន់នោះៗមានទឹកថ្លាស្អាតដ៏ដេរដាសដោយផ្កាចង្កុលណី ផ្កាឈូកនិងផ្កាឧប្បល ក្នុងឋានសួគ៌ទុំះ ។

[ ១០១ ] ក្នុងកែវមណីនេះ មានធ្នូតស ១០ ធ្នូតក្រហម ៦ និង ១៥ ( ជា៣១ ) ធ្នូតលឿង ១៤ គួរជាទីរមិលមើល ជាទីរីករាយនៃចិត្ត ។ ធ្នូតមាស ២០ ធ្នូតប្រាក់ ២០ ធ្នូតមានពន្លឺ ដូចជាពណ៌នៃអណ្តើកមាស ៣០ ប្រាកដនៅក្នុងកែវមណីនេះ ។ ធ្នូតខ្មៅ ១៦ ធ្នូតហង្សបាទ ២៥ ធ្នូតលាយ

ដោយផ្កាច្បា វិចិត្រដោយផ្កាឧប្បលខៀវ មានក្នុងកែវមណីនេះ ។ បពិត្រមហារាជប្រសើរជាងសត្វជើងពីរ សូមព្រះអង្គទ្រង់ទត ( កែវមណី ) មានរស្មី ជាទីផ្សាយចេញនៃពន្លឺដ៏ប្រកបដោយអង្គទាំងពួងយ៉ាងនេះ ( អ្នកណាលេងឈ្នះខ្ញុំ ) ចំណែកនៃស្លួយ ( ចូរបានទៅអ្នកនោះចុះ ) ។

## ចប់ មណិកណ្ឌ ។

[ ១០២ ] ( បុណ្ណកយក្ស... ) បពិត្រព្រះរាជា ( ការរៀបចំរោងល្បែង ) សម្រេចហើយ សូមព្រះអង្គស្តេចចូលមកកាន់ទីជាទីក្រសាលល្បែង កែវមណីប្រាកដដូច្នេះរបស់ព្រះអង្គមិនមានទេ យើងគប្បីឈ្នះគ្នាដោយធម៌មិនបាច់កំហែងទេ មួយទៀតព្រះអង្គបើខ្ញុំឈ្នះហើយសូមសងឲ្យឆាប់ ។

[ ១០៣ ] បពិត្រព្រះបាទបញ្ចាលដ៏ល្បីល្បាញ សូមព្រះបាទសុរសេនព្រះបាទមច្ឆៈ ព្រះបាទមទ្ទៈ ព្រមទាំងព្រះបាទកេកកៈទាំងនោះទ្រង់ទតចម្បាំងល្បែងដោយការមិនអួតអាងរបស់យើងចុះ ក្សត្រទាំងឡាយសុទ្ធតែធ្វើ ( ជាសាក្សី ) របស់យើងក្នុងរោង ។

[ ១០៤ ] ( អភិសម្ពុទ្ធគាថា ) ព្រះរាជារបស់អ្នកដែនកុរុនិងបុណ្ណកយក្សនោះជាអ្នកស្រវឹងជ្រុលជ្រប់ក្នុងល្បែងភ្នាល់ ចូលមក ( កាន់រោងល្បែង ) ព្រះរាជាជ្រើសយកកូនបាសកាជាទោស ( ខាងចាញ់ ) បុណ្ណកយក្សចាប់យកកូនបាសកាខាងឈ្នះ ជនទាំងពីរនោះបានលេងបាសការួមគ្នាក្នុងរោងបាសកានោះហើយបុណ្ណកយក្សឈ្នះព្រះរាជា មានព្យាយាមប្រសើរជាង

នរៈក្នុងសំណាក់នៃពួកព្រះរាជា ក្នុងកណ្តាលនៃពួកសាក្សី សំឡេងគឹកកង សំឡេងហ៊ោកញ្ជ្រៀវក៏កើតមានក្នុងទីនោះ ។

[ ១០៥ ] ( បុណ្ណកយក្ស... ) បពិត្រមហារាជ បណ្តាពួកយើងដែលខំប្រឹងព្យាយាម ការឈ្នះនិងការចាញ់គង់មានដល់អ្នកណាមួយ បពិត្រព្រះអង្គជាធំជាងជន ឥឡូវនេះខ្ញុំព្រះអង្គឈ្នះហើយ ( ត្រូវយក ) ទ្រព្យដ៏ប្រសើរព្រះអង្គ ដែលខ្ញុំឈ្នះហើយសូមសងឲ្យឆាប់ ។

[ ១០៦ ] ( ព្រះបាទកោរព្យៈ... ) ម្នាលមាណពកច្ចាយនគោត្ត ដំរី គោ សេះ កែវមណីនិងកុណ្ឌល ឬកែវណាមួយរបស់ខ្ញុំលើផែនដី បណ្តាទ្រព្យទាំង ( នោះ ) អ្នកចូរយកទ្រព្យណាដែលប្រសើរនោះចុះ អ្នកចូរកាន់យកទៅតាមសេចក្តីពេញចិត្តចុះ ។

[ ១០៧ ] ( បុណ្ណកយក្ស... ) ដំរី គោ សេះ កែវមណីនិងកុណ្ឌល ឬកែវណាមួយរបស់ព្រះអង្គលើផែនដី វិធុរបណ្ឌិតអាមាត្យទុកជាទ្រព្យប្រសើរជាងទ្រព្យទាំងនោះ ព្រះអង្គដែលខ្ញុំឈ្នះហើយសូមព្រះរាជទានវិធុរបណ្ឌិតនោះមកខ្ញុំ ។

[ ១០៨ ] ( ព្រះបាទកោរព្យៈ... ) វិធុរបណ្ឌិតនោះ ទុកដូចជាខ្លួនខ្ញុំ ទាំងជាទីពឹង ជាគតិ ជាប្រទីប ជាទីពំនាក់ ជាទីបង្អែករបស់ខ្ញុំ វិធុរបណ្ឌិតនោះ គេមិនគប្បីប្រៀបផ្ទឹមដោយទ្រព្យរបស់បានទេ វិធុរបណ្ឌិតនោះ ជាអាមាត្យប្រាកដស្មើដោយជីវិតរបស់ខ្ញុំ ។

[ ១០៩ ] ( បុណ្ណកយក្ស... ) ការវិវាទរបស់ខ្ញុំ និងព្រះអង្គនាំឲ្យយូរ

ទេ យើងត្រូវទៅសួរសេចក្តីពិតនឹងវិធុរបណ្ឌិតនោះវិញ សូមឲ្យវិធុរបណ្ឌិតទុំះញែកសេចក្តីទុំះដល់យើង បើវិធុរបណ្ឌិតពោលពាក្យណា ពាក្យ ( នោះ ) ចូរសម្រេចដល់យើងទាំងពីរនាក់ចុះ ។

[ ១១០ ] ( ព្រះបាទកោរព្យ:... ) ម្នាលមាណពអ្នកនិយាយនេះទៀងទាត់ពិតហើយមិនមែននិយាយទាំងគំរាមទេ យើងនឹងទៅសួរវិធុរបណ្ឌិតនោះចុះ យើងទាំង ២ នាក់នឹងត្រេកអរតាមវិធុរបណ្ឌិតនោះ ។

[ ១១១ ] ( បុណ្ណកយក្ស... ) ពួកទេព្តាសរសើរអ្នកឈ្មោះវិធុរៈថាជាអាមាត្យឋិតនៅក្នុងធម៌របស់អ្នកដែនកុរុពិតមែនឬ អ្នកជាទាសៈ ឬជាញាតិរបស់ព្រះរាជា ការរាប់ ( អ្នក ) ថា វិធុរៈ តើអ្នកជាអ្វីក្នុងលោក ។

[ ១១២ ] ( វិធុរបណ្ឌិត... ) បុគ្គលពួកខ្លះជាទាសៈ កើតក្នុងផ្ទៃខ្ញុំស្រី ពួកខ្លះជាទាសៈគេលោះដោយទ្រព្យ ពួកខ្លះជាទាសៈចូលទៅនៅខ្លួនឯង ពួកខ្លះបោះបង់ ( ទីលំនៅ ) ព្រោះភ័យទៅនៅជាទាសៈគេ ទាសៈរបស់ជនទាំងឡាយមាន ៤ ពួកនេះឯង ។ ឯយើងពិតជាទាសៈកើតអំពីកំណើតព្រះរាជាមានសេចក្តីចម្រើនក្តី ព្រះរាជាមានសេចក្តីមិនចម្រើនក្តី ( យើងមិនអាចនឹងពោលកុហកបានទេ ) យើងបើទុកជាទៅកាន់ទីដទៃក៏គង់នៅជាទាសៈរបស់ព្រះសម្មតិទេព ម្នាលមាណព ព្រះរាជាគួរប្រទានយើងដល់អ្នកដោយធម៌ ។

[ ១១៣ ] ( បុណ្ណកយក្ស... ) នេះឯងជាជ័យជម្នះទី ២ របស់ខ្ញុំក្នុងថ្ងៃនេះព្រោះថា ( វិធុរៈ ) អាមាត្យដែលខ្ញុំសួរហើយក៏ញែកប្រស្នាហើយ ឱហ្ន៎ព្រះរាជាដ៏ប្រសើរមិនតាំងនៅក្នុងធម៌ ទ្រង់មិនអនុញ្ញាតឲ្យនូវវិធុរបណ្ឌិត ជា

អ្នកពោលពាក្យពីរោះដល់ខ្ញុំ ។

[ ១១៤ ] ( ព្រះបាទកោរព្យ:... ) បើវិធុរបណ្ឌិតនោះញែកប្រស្នាដល់យើងយ៉ាងនេះថា ខ្ញុំជាទាសៈមិនមែនជាញាតិទេ ម្នាលកច្ចាន: អ្នកចូរយកវិធុរបណ្ឌិតជាទ្រព្យដ៏ប្រសើរជាងទ្រព្យទាំងឡាយចុះ អ្នកចូរយកទៅតាមពេញចិត្តចុះ ។

## ចប់ អក្ខកណ្ឌ ។

[ ១១៥ ] ( ព្រះបាទកោរព្យ:... ) ម្នាលវិធុរ: កាលបុគ្គលជាគ្រហស្ថនៅគ្រប់គ្រងផ្ទះរបស់ខ្លួន តើគួរមានការប្រព្រឹត្តដ៏ក្សេមក្សាន្ត ដោយប្រការដូចម្ដេច គួរមានការសង្គ្រោះដោយប្រការដូចម្ដេចហ្ន៎ ។ គួរមានការមិនមានទុក្ខដោយប្រការដូចម្ដេច មាណពឈ្មោះថា ពោលពាក្យពិត តើដោយប្រការដូចម្ដេច បុគ្គលជាគ្រហស្ថចេញចាកលោកនេះទៅកាន់លោកខាងមុខ លុះទៅកាន់លោកខាងមុខហើយរមែងមិនសោកស្ដាយ តើដោយប្រការដូចម្ដេច ។

[ ១១៦ ] ( អភិសម្ពុទ្ធគាថា ) វិធុរបណ្ឌិត អ្នកមានញាណគតិ មានព្យាយាម មានប្រាជ្ញា យល់អត្ថ យល់ធម៌ទាំងពួងបានឆ្លើយប្រស្នាន៎ុះ នឹងព្រះរាជានោះក្នុងរោងធម្មសភានោះថា គ្រហស្ថមិនគប្បីជាអ្នកមានប្រពន្ធសាធារណ: មិនគួរបរិភោគអាហារមានរសឆ្ងាញ់តែម្នាក់ឯង មិនគួរគប់រករឿងផ្ដេសផ្ដាសដែលទាក់ទងនឹងលោក ( ព្រោះ ) រឿងបែបន៎ុះមិនមែនជាគ្រឿងចម្រើនប្រាជ្ញាទេ ។ គ្រហស្ថគួរជាអ្នកមានសីលបរិបូណ៌ដោយវត្តមិនប្រហែស

មានប្រាជ្ញាវាងវៃ ជាអ្នកប្រព្រឹត្តឱនលំទោន មិនរឹងត្អឹង ជាអ្នកស្លូតបូត មានពាក្យទន់ពីរោះ មានអាការដ៏ទន់ភ្លន់ ។ ជាអ្នកសង្គ្រោះមិត្តទាំងឡាយ ជាអ្នកចែករំលែកទាន មានការចាត់ចែងដ៏ល្អញ៉ាំងសមណព្រាហ្មណ៍ឲ្យឆ្អែតស្កប់ស្កល់ដោយបាយនិងទឹកក្នុងកាលទាំងពួង ។ ជាអ្នកប្រាថ្នាសុចរិតធម៌ ទ្រទ្រង់ការចេះដឹងជាអ្នកសាកសួរ ឧស្សាហ៍ចូលទៅរកអ្នកមានសីលជាពហុស្សូតដោយគោរព ។ កាលបុគ្គលជាគ្រហស្ថនៅគ្រប់គ្រងផ្ទះរបស់ខ្លួនគួរមានការប្រព្រឹត្តិដ៏ក្សេមក្សាន្តយ៉ាងនេះ គួរមានការសង្គ្រោះយ៉ាងនេះ ។ គ្រហស្ថគួរជាអ្នកមិនមានទុក្ខយ៉ាងនេះ មាណពឈ្មោះថាពោលពាក្យពិតយ៉ាងនេះ គ្រហស្ថចេញចាកលោកនេះទៅកាន់លោកខាងមុខ លុះទៅកាន់លោកខាងមុខហើយរមែងមិនសោកស្តាយយ៉ាងនេះ ។

## ចប់ ឃរាវាសបញ្ហា ។

[ ១១៧ ] ( បុណ្ណកយក្ស... ) លោកចូរមក យើងនឹងទៅឥឡូវនេះ លោក ( ដែលព្រះបាទធនញ្ជ័យ ) ជាឥស្សរៈបានព្រះរាជទានដល់ខ្ញុំហើយ ចូរប្រតិបត្តិឲ្យជាប្រយោជន៍ដល់ខ្ញុំ នេះជាទំនៀមរបស់អ្នកប្រាជ្ញក្នុងកាលមុន ។

[ ១១៨ ] ( វិធុរបណ្ឌិត... ) ម្នាលមាណព ខ្ញុំដឹងថាខ្លួនខ្ញុំនៅក្នុងកណ្តាប់ដៃអ្នកហើយ ( ព្រោះ ) ខ្ញុំត្រូវព្រះបាទធនញ្ជ័យជាឥស្សរៈព្រះរាជទានដល់អ្នកហើយ តែយើងសូមឲ្យអ្នកនៅក្នុងផ្ទះយើងអស់ ៣ ថ្ងៃ ទម្រាំយើងប្រៀនប្រដៅកូននិងប្រពន្ធសិន ។

[ ១១៩ ] ( បុណ្ណកយក្ស... ) លោកពោលពាក្យណា ពាក្យនោះចូរមានដល់ខ្ញុំដោយប្រការដូច្នោះ យើងគប្បីនៅអស់ ៣ ថ្ងៃ លោកដ៏ចម្រើនចូរធ្វើកិច្ចក្នុងផ្ទះ ( របស់លោក ) ក្នុងថ្ងៃនេះចុះ លោកដ៏ចម្រើនចូរប្រៀនប្រដៅបុត្តនិងភរិយាក្នុងថ្ងៃនេះចុះ កាលបើលោកចេញទៅ ( បុត្តនិងភរិយារបស់លោក ) បានសេចក្តីសុខយ៉ាងណា ( សូមប្រៀនប្រដៅយ៉ាងនោះ ) ។

[ ១២០ ] ( អភិសម្ពុទ្ធគាថា ) បុណ្ណកយក្សមានភោគៈជាគ្រឿងប្រាថ្នាច្រើនបានពោលថា សាធុដូច្នេះក៏ចៀសចេញទៅជាមួយនឹងវិធុរបណ្ឌិត ឯវិធុរបណ្ឌិតជាបុគ្គលប្រសើរថ្លៃថ្លា ចូលទៅកាន់ខាងក្នុងបុរីនោះដែលបរិបូណ៌ដោយដំរីនិងសេះអាជានេយ្យ ។

[ ១២១ ] បណ្តាប្រាសាទទាំងនោះ គឺកោញ្ចប្រាសាទ មយូរប្រាសាទ បិយកេតប្រាសាទ ព្រះមហាសត្វ ( នាំបុណ្ណកយក្ស ) ចូលទៅកាន់ប្រាសាទជាទីរីករាយក្រៃលែង ជាប្រាសាទមានភក្សាហារច្រើន មានបាយនិងទឹកច្រើនដូចជា ( ភព ) មសក្កសារៈនៃព្រះវាសវៈ ។

[ ១២២ ] នាងនារីទាំងឡាយតាក់តែងខ្លួនដ៏សមរម្យល្អ រាំច្រៀងហៅរកដ៏ប្រសើរក្រៃលែងក្នុងប្រាសាទនោះ ដូចស្រីអប្សរក្នុងទេវលោក ។ ព្រះមហាសត្វអ្នករក្សាធម៌ ធ្វើបុណ្ណកយក្សឲ្យបរិបូណ៌ដោយពួកនារីជាទីរីករាយផងដោយបាយនិងទឹកផង ហើយជ្រើសរើសតែសេចក្តីយ៉ាងសំខាន់ទើបចូលទៅក្នុងសំណាក់ភរិយាក្នុងកាលនោះ ។ មហាសត្វនិយាយនឹងភរិយាដែលមានខ្លួនប្រោះព្រំដោយទឹកក្រអូបនៃខ្លឹមចន្ទន៍ មានសម្បុរប្រាកដស្មើដោយផ្កានៃមាស

ជម្ពូនទថា ម្នាលនាងដ៏ចម្រើនមានភ្នែកក្រហមនាងចូរមក ចូរស្តាប់ខ្ញុំ ចូរហៅបុត្តនិងធីតាមក ។ នាងអនោជាបានស្តាប់ពាក្យរបស់ប្តីហើយ ក៏និយាយនឹងកូនប្រសាស្រីមានក្រចកក្រហម មានភ្នែកល្អថា ម្នាលនាងមានសម្បុរដូចផ្ការាជព្រឹក្ស នាងចូរហៅបុត្តនិងធីតា ដែលទ្រទ្រង់ប្រជាប់ទាំងនោះមក ។

[ ១២៣ ] ព្រះមហាសត្វជាអ្នករក្សាធម៌ ឥតមានញាប់ញ័រនឹងកូនទាំងឡាយ ថើបក្បាលកូនទាំងឡាយនោះដែលមកដល់ហើយហៅមកនិយាយពាក្យថា អញត្រូវព្រះរាជាក្នុងក្រុងឥន្ទបត្តនេះប្រទានដល់មាណពហើយ ។ ថ្ងៃនេះអញមានសេចក្តីសុខក្នុងខ្លួនទេ ( តអំពី ៣ ថ្ងៃទៅ ) អញនឹងជាអ្នកបម្រើមាណពនោះ មាណពនោះនាំអញទៅតាមសេចក្តីត្រូវការ ចំណែកខាងអញដែលមកនេះ ដើម្បីប្រៀនប្រដៅអ្នកទាំងឡាយ ( ព្រោះថា ) អញនឹងទៅដោយមិនបានការពារ ( មុន ) ដូចម្តេចបាន ។ បើព្រះរាជានៅក្នុងដែនកុរុជាអ្នកភ្ជាប់មិត្តជន មានភោគៈជាទីប្រាថ្នាច្រើនសួរកូនឯងទាំងឡាយថា អ្នកទាំងឡាយ ដឹងច្បាស់នូវដំណើរបុរាណក្នុងកាលមុនដែរឬ បិតារបស់អ្នកទាំងឡាយបានប្រៀនប្រដៅក្នុងកាលមុនដូចម្តេចខ្លះ មួយទៀតពួកអ្នកទាំងអស់គ្នាចូរមានអាសនៈស្មើនឹងយើងចុះ ( ព្រោះ ) ក្នុងរាជត្រកូលនេះរកមនុស្សណារបស់ព្រះរាជាជាអ្នកខ្ពង់ខ្ពស់ ( ឲ្យស្មើនឹងពួកអ្នក ) មិនមានទេ ពួកកូនឯងគប្បីធ្វើអញ្ជលីទូលព្រះរាជាយ៉ាងនេះថា បពិត្រព្រះសម្មតិទេព សូមព្រះអង្គកុំត្រាស់យ៉ាងនេះព្រោះថានេះមិនមែនជាបវេណីធម៌ទេ បពិត្រព្រះសម្មតិទេព សត្វចចកមានជាតិថោកទាប គប្បីមានអាសនៈស្មើនឹងកេសរសីហៈដូចម្តេច

បាន ។

## ចប់ លក្ខកណ្ឌ ។

[ ១២៤ ] ( អភិសម្ពុទ្ធគាថា ) វិធុរបណ្ឌិតនោះមានសេចក្ដីត្រិះរិះ ដោយចិត្តមិនរួញរាបាននោលពាក្យនេះនឹងបុត្ត អាមាត្យ ញាតិ សម្លាញ់ថា ម្នាលកូនសម្លាញ់ទាំងឡាយ ចូរអ្នកទាំងឡាយមកអង្គុយស្ដាប់រាជវសតិធម៌ ( ច្បាប់សម្រាប់នៅក្នុងរាជត្រកូល ) របស់អញដែលជាច្បាប់សម្រាប់បុរសចូលទៅកាន់រាជត្រកូលរមែងបាននូវយស ។

[ ១២៥ ] រាជសេវកៈដែលចូលទៅកាន់រាជត្រកូល ( មានគុណសម្បត្តិ ) មិនប្រាកដរមែងមិនបានយសទេ រាជសេវកៈមិនត្រូវជាអ្នកក្លៀវក្លាពេក មិនត្រូវជាអ្នកខ្លាចពេក មិនត្រូវធ្វេសប្រហែសក្នុងកាលណាឡើយ ។ ព្រះរាជាជ្រាបច្បាស់នូវអាចារសម្បត្តិនិងសេចក្ដីចេះដឹង ព្រមទាំងសេចក្ដីស្អាតរបស់រាជសេវកៈនោះក្នុងកាលណា ព្រះរាជាក៏រមែងស្និទ្ធស្នាលចំពោះរាជសេវកៈនោះក្នុងកាលណោះ ទាំងមិនលាក់នូវអាថ៌កំបាំង ( របស់ព្រះអង្គ ) នឹងរាជសេវកៈនោះទេ ។

[ ១២៦ ] រាជសេវកៈដែលព្រះរាជាត្រាស់ប្រើ ( ក្នុងរាជកិច្ចណាមួយ ) មិនគប្បីធ្វើរាជកិច្ចនោះឲ្យកម្រើក ( ល្អៀង ) ទេ ត្រូវធ្វើឲ្យដូចជាជញ្ជីងដែលគេលើកឡើងហើយមានដងស្មើទៀងល្អ ។ រាជសេវកៈ ធ្វើរាជកិច្ចទាំងពួងដូចជញ្ជីងដែលគេលើកឡើងហើយមានដងស្មើទៀងល្អ រាជសេវកៈនោះទើប

គួរនៅក្នុងរាជត្រកូល ។

[ ១២៧ ] រាជសេវកៈជាអ្នកឈ្លាសវៃក្នុងរាជកិច្ចទាំងឡាយដែលព្រះរាជាត្រូវប្រើក្នុងវេលាថ្ងៃឬក្នុងវេលាយប់ មិនគប្បីធ្វើរាជកិច្ចនោះឲ្យកម្រើក រាជសេវកៈនោះ ទើបគួរនៅក្នុងរាជត្រកូល ។ រាជសេវកៈជាអ្នកឈ្លាសវៃក្នុងរាជកិច្ចទាំងឡាយ ធ្វើរាជកិច្ចគ្រប់យ៉ាងក្នុងវេលាថ្ងៃឬក្នុងវេលាយប់ ( ឲ្យសម្រេចដោយរៀបរយ ) រាជសេវកៈនោះទើបគួរនៅក្នុងរាជត្រកូល ។ ផ្លូវណាដែលគេធ្វើល្អ ចាត់ចែងល្អសម្រាប់ព្រះរាជា រាជសេវកៈដែលព្រះរាជាត្រាស់ហើយ មិនត្រូវដើរទៅតាមផ្លូវនោះ រាជសេវកៈនោះទើបគួរនៅក្នុងរាជត្រកូល ។

[ ១២៨ ] រាជសេវកៈមិនគួរប្រើប្រាស់កាមភោគៈស្មើនឹងព្រះរាជាក្នុងកាលណាឡើយ ត្រូវដើរខាងក្រោយក្នុងកាមគុណគ្រប់យ៉ាង រាជសេវកៈនោះទើបគួរនៅក្នុងរាជត្រកូល ។ រាជសេវកៈមិនត្រូវប្រើប្រាស់សំពត់ មិនត្រូវប្រើប្រាស់ផ្កាកម្រង មិនត្រូវប្រើប្រាស់គ្រឿងលាបឲ្យដូចរបស់ព្រះរាជា មិនត្រូវប្រព្រឹត្តកិរិយាឬការនិយាយស្តីឲ្យដូចព្រះរាជា ត្រូវធ្វើអាកប្បកិរិយាដទៃវិញ រាជសេវកៈនោះទើបគួរនៅក្នុងរាជត្រកូល ។

[ ១២៩ ] ព្រះរាជាទ្រង់ក្រសាលនឹងរាជសេវកៈ មានស្រីស្នំគាល់បម្រើ អាមាត្យជាបណ្ឌិតមិនត្រូវធ្វើសេចក្តីស្និទ្ធស្នាលចំពោះពួកស្រីស្នំរបស់ព្រះរាជាទេ ។ រាជសេវកៈជាអ្នកមិនឆ្មើងឆ្មៃ មិនឃ្នើសឃ្នង ជាអ្នកមានប្រាជ្ញាខ្ជាប់ខ្ជួន សង្រួមឥន្ទ្រិយដ៏ល្អបរិបូណ៌ដោយការតម្កល់ចិត្ត រាជសេវកៈនោះទើបគួរនៅក្នុង

រាជត្រកូល ។

[ ១៣០ ] រាជសេវកៈ មិនត្រូវប្រឡែង មិនត្រូវនៅក្នុងទីស្ងាត់ប្រឹក្សាជាមួយនឹងពួកស្រីស្នំរបស់ព្រះរាជា មិនត្រូវលួចយកព្រះរាជទ្រព្យអំពីឃ្លាំងរបស់ព្រះរាជានោះទេ រាជសេវកៈនោះទើបគួរនៅក្នុងរាជត្រកូល ។ រាជសេវកៈមិនគប្បីសំគាល់ការដេកច្រើន មិនត្រូវផឹកសុរាឲ្យស្រវឹង មិនត្រូវបៀតបៀនពួកម្រឹគដែលទ្រង់ឲ្យអភ័យ រាជសេវកៈនោះទើបគួរនៅក្នុងរាជត្រកូល ។ រាជសេវកៈមិនត្រូវឡើងកាន់តាំង មិនត្រូវឡើងកាន់បល្ល័ង្ក មិនត្រូវឡើងកាន់កៅអី មិនត្រូវឡើងកាន់នាវា ឬកាន់រថរបស់ព្រះរាជាដោយគិតថាខ្លួនអញព្រះរាជាប្រោសប្រាណហើយដូច្នេះទេ រាជសេវកៈនោះទើបគួរនៅក្នុងរាជត្រកូល ។ រាជសេវកៈជាអ្នកវាងវៃ ត្រូវគាល់ព្រះរាជាក្នុងទីមិនឆ្ងាយពេកមិនជិតពេក គប្បីឋិតនៅល្មមតែព្រះរាជាទតឃើញទាំងខ្លួនឯងក៏មើលឃើញព្រះរាជាជាម្ចាស់ ។ រាជសេវកៈ ( គួរគិតថា ) ព្រះរាជាមិនមែនជាសម្លាញ់របស់អញទេ ព្រះរាជាមិនមែនជាគូកន ( របស់អញទេ ) ធម្មតាព្រះរាជាទាំងឡាយរមែងខ្វាល់ឆាប់ ដូចភ្នែកដែលត្រូវលំអងមានកន្ទុយស្រូវ ( ជាដើម ) ប៉ះពាល់ ។ ជនជាបណ្ឌិតអ្នកមានប្រាជ្ញាមិនត្រូវសំគាល់ថា ព្រះរាជាបូជាអញហើយក៏ពិតទូលហេតុអាក្រក់ចំពោះព្រះរាជាដែលយាងមកកាន់បរិស័ទ ។

[ ១៣១ ] រាជសេវកៈទុកជាបានអនុញ្ញាតទ្វារហើយ ត្រូវបានអនុញ្ញាតទ្វារ ( ទៀតសឹមចូល ) មិនត្រូវទុកចិត្តចំពោះព្រះរាជាទាំងឡាយ គប្បីប្រយ័ត្នដូចភ្លើង រាជសេវកៈនោះទើបគួរនៅក្នុងរាជត្រកូល ។ ព្រះរាជាជាក្សត្រិយ៍ទ្រង់

លើកតម្កើងព្រះរាជបុត្តឬក្សត្រិយ៍ជាបងប្អូនរបស់ព្រះអង្គ ដោយស្រុកឬនិគម ដោយដែនឬជនបទ រាជសេវកៈត្រូវនៅស្ងៀមរំពឹងមើលមិនត្រូវនិយាយពីគុណ ឬទោសឡើយ ។

[ ១៣២ ] ព្រះរាជាទ្រង់បន្ថែមបៀវត្សដល់ពលដំរី ពលរថ ពលថ្មើរជើងទាំងនោះ ដោយការប្រគល់ឲ្យចំពោះការងារ រាជសេវកៈមិនត្រូវធ្វើឲ្យអន្តរាយ ( លាភ ) របស់ពលទាំងនោះ រាជសេវកៈនោះទើបគួរនៅក្នុងរាជត្រកូល ។ រាជសេវកៈជាអ្នកប្រាជ្ញត្រូវឱនលំទោនដូចជាដងធ្នូ ត្រូវញាប់ញ័រដូចជាឫស្សី មិនត្រូវប្រព្រឹត្តទទឹងទាស់ទេ រាជសេវកៈនោះទើបគួរនៅក្នុងរាជត្រកូល ។ រាជសេវកៈត្រូវមានពោះដូចជួចបន្ទោះធ្នូ មិនត្រូវមានអណ្តាតដូចត្រីត្រូវស៊ីតិច មានប្រាជ្ញារក្សាខ្លួន ក្លៀវក្លា រាជសេវកៈនោះទើបគួរនៅក្នុងរាជត្រកូល ។

[ ១៣៣ ] រាជសេវកៈមិនត្រូវប៉ះពាល់គប់ស្រី ជាហេតុឲ្យអស់តេជះខ្លាំងពេកទេ សេវកៈដែលអស់ប្រាជ្ញារមែងដល់នូវរោគក្អក ហឺត ទុរន់ទុរា មានកម្លាំងថយ ។ រាជសេវកៈមិនត្រូវនិយាយហួសកម្រិត មិនត្រូវស្ងៀមគ្រប់កាលទាំងពួងទេ ត្រូវពោលពាក្យមិនរាយរាយ ល្មមប្រមាណក្នុងកាលដែលត្រូវការ ។ រាជសេវកៈគប្បីជាអ្នកមិនក្រោធ មិនបៀតបៀនគេ មានពាក្យសច្ចៈ ផ្អែមល្ហែម មិនញុះញង់ មិននិយាយពាក្យឥតប្រយោជន៍ រាជសេវកៈនោះទើបគួរនៅក្នុងរាជត្រកូល ។

[ ១៣៤ ] រាជសេវកៈត្រូវចិញ្ចឹមមាតានិងបិតា ត្រូវមានសេចក្តីគោរព

ចំពោះបុគ្គលជាធំក្នុងត្រកូល មានវាចាផ្អែមល្ហែម ពោលពាក្យម៉ត់ហ្មង រាជសេវកៈនោះទើបគួរនៅក្នុងរាជត្រកូល ។ សេវកៈត្រូវមានសណ្ដាប់ធ្នាប់ មានសិល្បសាស្ត្រ មានឥន្ទ្រិយទូន្មានហើយ មានខ្លួនធ្វើហើយ ( បេះស្មាត់ ) ជាអ្នកនឹងនួន មានអធ្យាស្រ័យទន់ភ្លន់ មិនធ្វេសប្រហែស ជាអ្នកស្អាតទាំងឈ្លាសវៃ រាជសេវកៈនោះទើបគួរនៅក្នុងរាជត្រកូល ។ រាជសេវកៈត្រូវមានសេចក្ដីប្រព្រឹត្តឱនលំទោន កោតក្រែងគោរពចំពោះបុគ្គលចម្រើន ( ដោយវ័យជាដើម ) ជាអ្នកស្លូតត្រង់នៅរួមជាសុខ រាជសេវកៈនោះទើបគួរនៅក្នុងរាជត្រកូល ។ រាជសេវកៈគប្បីវៀរឲ្យឆ្ងាយចេញ នូវជនដែលព្រះរាជាជទែបញ្ជូនមកដើម្បីការស្ងាត់កំបាំង គប្បីរំពៃមើលចំពោះព្រះរាជាជាម្ចាស់ ( របស់ខ្លួន ) មិនត្រូវនិយាយចំពោះព្រះរាជាដទៃទេ ។

[ ១៣៥ ] រាជសេវកៈគប្បីគប់រកចំពោះសមណៈនិងព្រាហ្មណ៍អ្នកមានសីលជាពហុស្សូតដោយគោរព រាជសេវកៈនោះ ទើបគួរនៅក្នុងរាជត្រកូល ។ រាជសេវកៈគួរប្រព្រឹត្តតាមពួកសមណៈនិងព្រាហ្មណ៍អ្នកមានសីលជាពហុស្សូតដោយគោរព រាជសេវកៈនោះទើបគួរនៅក្នុងរាជត្រកូល ។ រាជសេវកៈគួរញុំាងសមណៈនិងព្រាហ្មណ៍ អ្នកមានសីលជាពហុស្សូតឲ្យឆ្អែតស្កប់ស្កល់ដោយបាយនិងទឹក រាជសេវកៈនោះទើបគួរនៅក្នុងរាជត្រកូល ។ រាជសេវកៈកាលបើប្រាថ្នាសេចក្ដីចម្រើនដល់ខ្លួន គប្បីចូលទៅគប់រកសមណៈនិងព្រាហ្មណ៍អ្នកមានសីលជាពហុស្សូត ជាបណ្ឌិត ។

[ ១៣៦ ] រាជសេវកៈមិនត្រូវញុំាងទានដែលព្រះរាជាធ្លាប់ព្រះរាជទាន

ដល់សមណៈនិងព្រាហ្មណ៍ឲ្យសាបសូន្យ ទាំងមិនគួរឃាត់វត្ថុណាមួយចំពោះពួកស្តូមក្នុងកាលជាទីព្រះរាជទាន ។ រាជសេវកៈជាអ្នកមានប្រាជ្ញា បរិបូណ៌ដោយឧបាយ ជាអ្នកឆ្លៀវឆ្លាសក្នុងវិធីចាត់ចែង ជាអ្នកដឹងកាល ( ជាទីធ្វើបុណ្យ ) ដឹងសម័យ ( ប្រកបការងារ ) រាជសេវកៈនោះទើបគួរនៅក្នុងរាជត្រកូល ។ រាជសេវកៈជាអ្នកខ្នះខ្នែង មិនប្រមាទ ឈ្លាសវៃចាត់ចែងការងារដ៏ល្អក្នុងក្រសួងការងារទាំងឡាយ ត្រូវមានសេចក្តីព្យាយាម ចាត់ចែងរាជកិច្ចឲ្យប្រព្រឹត្តទៅដោយស្រួល រាជសេវកៈនោះទើបគួរនៅក្នុងរាជត្រកូល ។

[ ១៣៧ ] រាជសេវកៈគួរទៅ ( ត្រួតត្រាមើល ) លានស្រូវ រោងចិញ្ចឹមសត្វនិងស្រែចម្ការ ( របស់ព្រះរាជា ) ឲ្យរឿយៗ គប្បីទុកដាក់ស្រូវដែលវាល់ហើយផង ឲ្យគេចម្អិនអង្ករដែលវាល់ហើយក្នុងផ្ទះផង ។ មិនត្រូវលើកតម្កើងកូនឬបងប្អូនរបស់ខ្លួន ដែលមិនតាំងនៅក្នុងសីលាចារវត្ត ព្រោះថាជនទាំងនោះជាមនុស្សពាល មិនឈ្មោះថាជាអវយវៈ ( របស់ខ្លួន ) ជនទាំងនោះទុកដូចជាមនុស្សស្លាប់ហើយ តែជាត្រូវឲ្យសំពត់និងជុំបាយដល់ជនទាំងនោះដែលមកអង្គុយជិតហើយ គប្បីតម្កល់ពួកបុរសជាទាស កម្មករដែលជាអ្នកខ្ជាប់ខ្ជួនល្អក្នុងសីលាចារវត្ត ជាអ្នកឈ្លាសវៃ បរិបូណ៌ដោយសេចក្តីឃ្មាតខ្មីក្នុងទីជាអធិបតី ( ក្នុងការងារ ) ។

[ ១៣៨ ] រាជសេវកៈត្រូវមានសីល មិនលោភ ជាអ្នកប្រព្រឹត្តតាមព្រះរាជា ជាគុណដល់ព្រះរាជាទាំងក្នុងទីចំពោះព្រះភក្ត្រ និងទីកំបាំងព្រះភក្ត្រ រាជសេវកៈនោះទើបគួរនៅក្នុងរាជត្រកូល ។ រាជសេវកៈជាអ្នកស្គាល់បំណង

របស់ព្រះរាជានោះផង តាំងនៅដូចព្រះហឫទ័យរបស់ព្រះរាជានោះផង ជាអ្នកមិនប្រព្រឹត្តទទឹងទាស់នឹងព្រះរាជានោះផង រាជសេវកៈនោះទើបគួរនៅក្នុងរាជត្រកូល ។ រាជសេវកៈគប្បីឱនក្បាលលាងព្រះបាទ ( របស់ព្រះរាជា ) ក្នុងកាលជាទីទ្រង់ព្រះពស្ត្រ ឬក្នុងកាលជាទីស្រង់ព្រះគង្គា សូម្បីព្រះរាជាទ្រង់ខ្ញាល់ក៏មិនគប្បីទឹងតបវិញទេ រាជសេវកៈនោះទើបគួរនៅក្នុងរាជត្រកូល ។

[ ១៣៩ ] ប៉ុនអម្បាលបុរសប្រាថ្នាសេចក្តីចម្រើន គង់ធ្វើអញ្ជលីចំពោះក្អមទឹកឬធ្វើបទក្សិណចំពោះបក្សីក្អែក បុគ្គលមិនទនមស្ការចំពោះព្រះរាជា ជាបណ្ឌិតខ្ពង់ខ្ពស់ ព្រះអង្គប្រទានសេចក្តីប្រាថ្នាគ្រប់យ៉ាងដូចម្តេចបាន ព្រោះព្រះអង្គប្រទានទីដេក សំពត់ យានទិងផ្ទះសម្រាប់សំណាក់អាស្រ័យ ទ្រង់បង្អុរភោគសម្ប័ទដូចមេឃបង្អុរភ្លៀងដល់ពួកសត្វ ។ ម្នាលកូនសម្លាញ់ទាំងឡាយ នេះជារាជវសតិធម៌ដែលនរជនប្រព្រឹត្តតាមរមែងញុំាងព្រះរាជាឲ្យប្រោសប្រាណរមែងបានការបូជាអំពីចៅហ្វាយនាយទាំងឡាយ ។

**ចប់ រាជវសតីកណ្ឌ ។**

[ ១៤០ ] ( អភិសម្ពុទ្ធគាថា ) វិធុរបណ្ឌិតមានប្រាជ្ញាវាងវៃ ប្រៀនប្រដៅពួកញាតិយ៉ាងនេះហើយ ក៏ចូលទៅគាល់ព្រះរាជា ដោយមានពួកញាតិចោមរោម វិធុរបណ្ឌិតថ្វាយបង្គំព្រះបាទាដោយត្បូង ធ្វើបទក្សិណព្រះអង្គ ផ្គងអញ្ជលីក្រាបបង្គំទូលព្រះរាជាថា បពិត្រព្រះអង្គជាអ្នកបង្ក្រាបសត្រូវ មាណពនេះមានប្រាថ្នានឹងធ្វើតាមអធ្យាស្រ័យ នឹងនាំខ្ញុំព្រះអង្គទៅ ខ្ញុំព្រះអង្គនឹង

និយាយពាក្យជាប្រយោជន៍ដល់ពួកញាតិ សូមព្រះអង្គទ្រង់ព្រះសណ្ដាប់នូវពាក្យនោះ ។ សូមព្រះអង្គ ទ្រង់ទតមើលកូនទាំងឡាយរបស់ខ្ញុំព្រះអង្គផងនិងទ្រព្យដទៃក្នុងផ្ទះរបស់ខ្ញុំព្រះអង្គផង កាលបើខ្ញុំព្រះអង្គទៅហើយ សូមកុំឲ្យពួកញាតិវិនាសក្នុងកាលខាងក្រោយឡើយ ប្រសិនបើទូលព្រះបង្គំមានសេចក្ដីភ្ញាំងភ្ញាត់ទូលព្រះបង្គំនឹងឃើញកំហុសនោះវិញ ដូចជាបុរសភ្ជាត់ដួលលើផែនដីហើយឈរស៊ប់លើផែនដីវិញ ។

[ ១៤១ ] ( ព្រះរាជា... ) សេចក្ដីគាប់ចិត្តខ្ញុំថា អ្នកមិនគួរទៅទេ ខ្ញុំគាប់ចិត្តថា ឲ្យអ្នកកាប់សម្លាប់មាណពកច្ចាយនៈក្នុងទីនេះ ហើយនៅក្នុងទីនេះចុះ ម្នាលបណ្ឌិតមានប្រាជ្ញាឧត្ដមដូចផែនដី អ្នកកុំទៅ ។

[ ១៤២ ] ( មហាសត្វ... ) សូមព្រះអង្គកុំតម្កល់ព្រះហឫទ័យក្នុងភាពមិនមែនជាធម៌ សូមប្រកបក្នុងប្រយោជន៍ផង ក្នុងធម៌ផង ថ្វីយបុគ្គលធ្វើកម្មណាហើយទៅកាន់នរកក្នុងកាលខាងក្រោយ កម្មនោះជាអំពើអកុសល មិនប្រសើរ ។ បពិត្រព្រះអង្គជាធំជាងជន ព្រោះថាធម្មតាម្ចាស់ជាធំរបស់ទាសៈចង់សម្លាប់ ចង់ដុតពេលបៀតបៀនក៏បាន តែនេះមិនមែនជាធម៌ ( របស់បុរាណបណ្ឌិតទេ ) ទាំងមិនមែនជាកិច្ចគួរប្រព្រឹត្តឡើយ សេចក្ដីក្រោធនៃខ្ញុំព្រះអង្គមិនមានទេ ខ្ញុំព្រះអង្គសូមលាទៅ ។

[ ១៤៣ ] ( អភិសម្ពុទ្ធគាថា ) ព្រះមហាសត្វនោះមានព្រះនេត្រពេញដោយទឹកភ្នែកចូលទៅឱបរឹត ( ធម្មបាលកុមារ ) ជាបុត្តច្បង លុះបន្ទោបង់សេចក្ដីក្រវល់ក្រវាយក្នុងហឫទ័យហើយក៏ចូលទៅកាន់ផ្ទះធំ ។

[ ១៤៤ ] ពួកបុត្តនិងភរិយារបស់វិធុរបណ្ឌិត ដេក ( បម្រះនទៀល ) ក្នុងលំនៅដូចជាដើមរាំងដែលត្រូវខ្យល់បក់បោកញាំញី ។ ស្ត្រីជាប្រពន្ធ ១ ពាន់នាក់និងទាសី ៧ រយនាក់ផ្គងដៃខ្សឹកខ្សួល កន្ទក់កន្ទេញក្នុងលំនៅនៃវិធុរបណ្ឌិត ។ ពួកស្រីស្នំ ពួកកុមារ ពួកអ្នកជំនួញនិងពួកព្រាហ្មណ៍ផ្គងដៃ ខ្សឹកខ្សួល កន្ទក់កន្ទេញក្នុងលំនៅនៃវិធុរបណ្ឌិត ។ ពួកពលដំរី ពលសេះ ពលរថ ពលថ្មើរជើងផ្គងដៃខ្សឹកខ្សួល កន្ទក់កន្ទេញក្នុងលំនៅនៃវិធុរបណ្ឌិត ។ ពួកអ្នកជនបទមកជួបជុំគ្នា ទាំងពួកអ្នកនិគមក៏មកជួបជុំគ្នា ផ្គងដៃខ្សឹកខ្សួល កន្ទក់កន្ទេញក្នុងលំនៅនៃវិធុរបណ្ឌិត ។ ស្ត្រីជាប្រពន្ធ ១ ពាន់នាក់និងទាសី ៧ រយនាក់ផ្គងដៃខ្សឹកខ្សួលកន្ទក់កន្ទេញថា ហេតុអ្វីទើបលោកលះចោលពួកយើង ។ ពួកស្រីស្នំ ពួកកុមារ ពួកអ្នកជំនួញនិងពួកព្រាហ្មណ៍ផ្គងដៃខ្សឹកខ្សួល កន្ទក់កន្ទេញថា ហេតុអ្វីទើបលោកលះចោលពួកយើង ។ ពួកពលដំរី ពលសេះ ពលរថ ពលថ្មើរជើងផ្គងដៃខ្សឹកខ្សួលកន្ទក់កន្ទេញថា ហេតុអ្វីទើបលោកលះចោលពួកយើង ។ ពួកអ្នកជនបទមកជួបជុំគ្នា ទាំងពួកអ្នកនិគមក៏មកជួបជុំគ្នាផ្គងដៃខ្សឹកខ្សួលកន្ទក់កន្ទេញថា ហេតុអ្វីទើបលោកលះចោលពួកយើង ។

[ ១៤៥ ] ព្រះមហាសត្វបានធ្វើកិច្ចទាំងឡាយក្នុងផ្ទះ ប្រៀនប្រដៅជនរបស់ខ្លួន គឺពួកមិត្ត អាមាត្យ ជនអ្នកនៅអាស្រ័យ បុត្ត ភរិយានិងផៅពង្ស ។ ព្រះមហាសត្វចាត់ចែងការងារ ប្រាប់នូវទ្រព្យក្នុងផ្ទះនិងកំណប់និងការឲ្យបុលហើយពោលពាក្យនេះនឹងបុណ្ណកយក្សថា អ្នកបានស្នាក់នៅក្នុងផ្ទះ

របស់ខ្ញុំអស់ ៣ ថ្ងៃហើយ កិច្ចក្នុងផ្ទះខ្ញុំធ្វើហើយ ទាំងបុត្តនិងភរិយាខ្ញុំក៏បាន ប្រៀនប្រដៅហើយ អ្នកចូរធ្វើកិច្ចទាំងឡាយតាមអធ្យាស្រ័យរបស់អ្នកចុះ ។

[ ១៤៦ ] ( បុណ្ណកយក្ស... ) បពិត្រអ្នកជាអាមាត្យ បើអ្នកបាន ប្រៀនប្រដៅបុត្ត ភរិយានិងពួកជនអ្នកចិញ្ចឹមជីវិតដោយសារហើយ អើអ្នកចូរ ប្រញាប់ប្រញាល់មកក្នុងកាលឥឡូវនេះចុះ ព្រោះថាផ្លូវខាងមុខនេះជាផ្លូវដាច់ ស្រយាលវែងឆ្ងាយ ។ អ្នកកុំភ័យ ចូរចាប់តោងកន្ទុយសេះអាជានេយ្យចុះ នេះជាការឃើញនូវជីវលោកជាទីបំផុតរបស់អ្នក ។

[ ១៤៧ ] ( ព្រះមហាសត្វ... ) បុគ្គលទៅកាន់ទុគ្គតិដោយអំពើណា ដែលកើតអំពីកាយវាចាចិត្ត អំពើអាក្រក់ ( នោះ ) របស់ខ្ញុំមិនមានទេ ខ្ញុំនឹង ខ្លាចចំពោះអំពើអ្វី ។

[ ១៤៨ ] ( អភិសម្ពុទ្ធគាថា ) ស្តេចសេះនោះនាំវិធុរបណ្ឌិតហោះ ទៅឰដ៏អាកាសវេហាស៍ឥតប៉ះទង្គិចនឹងមែកឈើឬភ្នំ ក៏ចូលទៅកាន់កាឡាគិរី បពិតដោយឆាប់រហ័ស ។

[ ១៤៩ ] ស្ត្រីជាប្រពន្ធ ១ ពាន់នាក់និងទាសី ៧ រយនាក់ផ្គងដៃ ខ្សឹកខ្សួលកន្ទក់កន្ទេញថា យក្សក្លែងភេទជាព្រាហ្មណ៍នាំវិធុរបណ្ឌិតទៅ ។ ពួក ស្រីស្នំ ពួកកុមារ ពួកអ្នកជំនួញនិងពួកព្រាហ្មណ៍ ផ្គងដៃខ្សឹកខ្សួលកន្ទក់កន្ទេញ ថា យក្សក្លែងភេទជាព្រាហ្មណ៍នាំវិធុរបណ្ឌិតទៅ ។ ពួកពលដំរី ពលសេះ ពលរថ ពលថ្មើរជើងផ្គងដៃខ្សឹកខ្សួលកន្ទក់កន្ទេញថា យក្សក្លែងភេទជាព្រាហ្ម-ណ៍នាំវិធុរបណ្ឌិតទៅ ។ ពួកអ្នកជនបទមកជួបជុំគ្នា ទាំងពួកអ្នកនិគមក៏មកជួប

ជុំគ្នាផ្គងដៃខ្សឹកខ្សួលកន្ទក់កន្ទេញថា យក្សក្លែងភេទជាព្រាហ្មណ៍នាំវិធុរបណ្ឌិតទៅ ។ ស្ត្រីជាប្រពន្ធ ១ ពាន់នាក់និងទាសី ៧ រយនាក់ផ្គងដៃខ្សឹកខ្សួលកន្ទក់កន្ទេញថា វិធុរបណ្ឌិតទៅក្នុងទីណាហ្ន៎ ។ ពួកស្រីស្នំ ពួកកុមារ ពួកអ្នកជំនួញនិងពួកព្រាហ្មណ៍ ផ្គងដៃខ្សឹកខ្សួលកន្ទក់កន្ទេញថា វិធុរបណ្ឌិតទៅក្នុងទីណាហ្ន៎ ។ ពួកពលដំរី ( ពលសេះ ) ពលរថ ពលថ្មើរជើង ផ្គងដៃខ្សឹកខ្សួលកន្ទក់កន្ទេញថា វិធុរបណ្ឌិតនោះទៅក្នុងទីណាហ្ន៎ ។ ពួកអ្នកជនបទមកជួបជុំគ្នាទាំងពួកអ្នកនិគមក៏មកជួបជុំគ្នាផ្គងដៃខ្សឹកខ្សួលកន្ទក់កន្ទេញថា វិធុរបណ្ឌិតនោះទៅក្នុងទីណាហ្ន៎ ។

[ ១៥០ ] ( មហាជន... ) បើបណ្ឌិតនោះនឹងមិនត្រឡប់មកក្នុងរវាង ៧ រាត្រីវិញទេ ពួកទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នានឹងចូលភ្លើង ពួកទូលព្រះបង្គំជាខ្ញុំមិនមានសេចក្តីត្រូវការដោយជីវិតឡើយ ។

[ ១៥១ ] ( ព្រះរាជា... ) បណ្ឌិតជាបុគ្គលឈ្លាសវៃ អាចសំដែង ( ប្រយោជន៍ ) និងមិនមែនប្រយោជន៍ មានប្រាជ្ញាឈ្វេងយល់ រមែងដោះខ្លួនបានដោយឆាប់ អ្នកទាំងឡាយកុំខ្លាចឡើយ បណ្ឌិតនោះគង់តែនឹងត្រឡប់មកវិញ ។

## ចប់ អន្តរបេយ្យាលៈ ។

[ ១៥២ ] ( អភិសម្ពុទ្ធគាថា ) បុណ្ណកយក្សនោះកាលទៅលើកំពូលភ្នំកាឡាគិរីនោះក៏គិតថា គំនិតទាំងឡាយរមែងជាធម្មជាតិខ្ពស់និងទាប អញ

មិនមែនមានកិច្ចតិចតួចដោយជីវិតរបស់វិធុរបណ្ឌិតនេះ ( ក្នុងភពនាគនោះទេ ) អញនឹងសម្លាប់វិធុរបណ្ឌិតនេះហើយនាំយកតែដួងហឫទ័យទៅ ។

[ ១៥៣ ] មាណពកច្ចាយនគោត្តនោះ មានចិត្តប្រទូស្ត បានទៅក្នុងចន្លោះភ្នំនោះហើយចូលទៅខាងក្នុងភ្នំ ចាប់ព្រះមហាសត្វយកក្បាលចុះក្រោម ( គ្រវែងទៅ ) ក្នុងប្រទេសនៃផែនដីដែលមិនមានអ្វីប៉ះពាល់ឡើយ ។

[ ១៥៤ ] វិធុរបណ្ឌិតនោះជាអាមាត្យដ៏ប្រសើររបស់អ្នកដែនកុរុ កាលសំយុងចុះទៅក្នុងរណ្តៅជ្រោះ ជាទីមានភ័យដ៏ធំគួរព្រួចព្រឺរោម ដែលលំបាកនឹងទៅក្រៃលែងតែមិនតក់ស្លុតហើយពោលនឹងបុណ្ណកយក្សយ៉ាងនេះថា អ្នកជាមនុស្សមិនប្រសើរតែធ្វើដូចជាប្រសើរ ជាអ្នកមិនសង្រួមតែមានអាការហាក់ដូចជាអ្នកសង្រួម អ្នកធ្វើអំពើអាក្រក់ឥតប្រយោជន៍ ចំណែកកុសលតិចតួចឥតមានក្នុងចិត្តនៃអ្នកទេ ។ អ្នកចង់ទម្លាក់ខ្ញុំទៅក្នុងរណ្តៅជ្រោះដោយហេតុណា ប្រយោជន៍ដូចម្តេចដោយការសម្លាប់ខ្ញុំនឹងមានដល់អ្នក ដោយហេតុនោះក្នុងថ្ងៃនេះអ្នកមានភេទ ដូចជាមិនមែនភេទនៃមនុស្សទេ ចូរអ្នកប្រាប់ខ្ញុំ អ្នកជាទេវតាឬជាអ្វី ។

[ ១៥៥ ] ( បុណ្ណកយក្ស... ) ខ្ញុំនោះឈ្មោះបុណ្ណកយក្ស ជាអាមាត្យព្រះបាទកុវេរៈដែលអ្នកធ្លាប់បានឮហើយ នាគរាជព្រះនាមវរុណៈ ជាអ្នកទ្រទ្រង់ផែនដីមានទំហំនិងកម្ពស់ មានទ្រង់ទ្រាយដ៏ស្អាតបរិបូណ៌ដោយពណ៌និងកម្លាំង ។ ម្នាលអ្នកប្រាជ្ញ ខ្ញុំចង់បានធីតាជាអនុជាតនៃព្រះបាទវរុណនាគនោះ នាគកញ្ញានោះឈ្មោះឥរន្ទតី ខ្ញុំព្យាយាមសម្លាប់អ្នកព្រោះហេតុនាងឥរន្ទតី មាន

ចង្កេះល្អជាទីស្រឡាញ់នោះ ។

[ ១៥៦ ] ( ព្រះមហាសត្វ... ) ម្នាលយក្ស សេចក្តីវង្វេងកុំមានដល់អ្នកឡើយ ពួកសត្វលោកជាច្រើនវិនាសហើយ ព្រោះអំពើដែលខ្លួនប្រកាន់ខុស ចុះអ្នកមានកិច្ចអ្វីដោយការសម្លាប់ខ្ញុំ ( ព្រោះនាគកញ្ញា ) មានចង្កេះល្អជាទីស្រឡាញ់ សូមអញ្ជើញប្រាប់ខ្ញុំនឹងស្តាប់ការទាំងអស់មើល ។

[ ១៥៧ ] ( បុណ្ណកយក្ស... ) ខ្ញុំចង់បានធីតារបស់ព្រះបាទវរុណនាគជាធំ មានអានុភាពច្រើន ខ្ញុំជាអ្នកស៊ីឈ្នួលរបស់ពួកញាតិព្រោះហេតុពួកញាតិដឹងនូវខ្ញុំថាជាអ្នកត្រូវកាមទង់ទាញដោយពិត ( បានជា ) ឪពុកក្មេកខ្ញុំពោលនឹងខ្ញុំដែលសូមនាងឥរន្ទតីនោះថា យើងនឹងឲ្យកូនក្រមុំមានរាងកាយល្អ មានភ្នែកល្អ មានទ្រង់ទ្រាយធើតឆាយ មានខ្លួនលាបដោយខ្លឹមចន្ទន៍ដល់អ្នក បើអ្នកបានដួងហឫទ័យ របស់វិធុរបណ្ឌិតមកដោយធម៌ ហើយនាំមកក្នុងភពនាគនេះ ។ អ្នកត្រូវបាននាងកុមារីដោយទ្រព្យជាទីត្រេកអរនុ៎ះ យើងមិនប្រាថ្នាទ្រព្យដទៃក្រៃលែងទេ ម្នាលបណ្ឌិតជាអាមាត្យ ខ្ញុំមិនវង្វេងដូចអ្នកថាទេ អ្នកចូរស្តាប់ចុះ ។ មួយទៀតអំពើតិចតួចដែលខ្ញុំប្រកាន់ខុសមិនមានទេ កាលខ្ញុំបានហឫទ័យរបស់អ្នកដោយធម៌ ពួកនាគនឹងឲ្យនាគកញ្ញាឈ្មោះឥរន្ទតី ។ ព្រោះហេតុនោះទើបខ្ញុំលៃលកសម្លាប់អ្នក ខ្ញុំមានសេចក្តីត្រូវការដោយការសម្លាប់អ្នកយ៉ាងនេះឯង ខ្ញុំនឹងទម្លាក់អ្នកក្នុងរណ្តៅនេះសម្លាប់អ្នកហើយ នឹងនាំយកតែហឫទ័យទៅ ។

[ ១៥៨ ] ( មហាសត្វ... ) ម្នាលកច្ចាយនៈ បើអ្នកមានកិច្ចត្រូវ

ការដោយហឫទ័យរបស់ខ្ញុំ ចូរអ្នកលើកខ្ញុំដោយឆាប់រហ័ស ដ្បិតសាធុនរធម៌ ( ធម៌ល្អរបស់នរៈ ) របស់ខ្ញុំណាមួយ ខ្ញុំនឹងសំដែងសាធុនរធម៌ទាំងអស់នោះដល់អ្នកក្នុងថ្ងៃនេះ ។

[ ១៥៩ ] ( អភិសម្ពុទ្ធគាថា ) បុណ្ណកយក្សនោះ ដាក់វិធុរបណ្ឌិតជាអាមាត្យដ៏ប្រសើររបស់អ្នកដែនកុរុ លើកំពូលភ្នំឆាប់រហ័ស ឃើញវិធុរបណ្ឌិតជាអាមាត្យមានប្រាជ្ញា មិនថោកទាប អង្គុយដកដង្ហើមស្រួលហើយក៏សាកសួរថា អ្នកគឺខ្ញុំលើកឡើងចាករណ្ដៅហើយ ក្នុងថ្ងៃនេះខ្ញុំត្រូវការដោយហឫទ័យរបស់អ្នក អ្នកចូរសំដែងសាធុនរធម៌ទាំងអស់នោះដល់ខ្ញុំក្នុងថ្ងៃនេះ ។

[ ១៦០ ] ( មហាសត្វ... ) ខ្ញុំគឺអ្នកលើកឡើងចាករណ្ដៅហើយ បើអ្នកត្រូវការដោយហឫទ័យរបស់ខ្ញុំ ខ្ញុំនឹងសំដែងសាធុនរធម៌ទាំងអស់នោះដល់អ្នកក្នុងថ្ងៃនេះ ។

[ ១៦១ ] ម្នាលមាណព អ្នកចូរដើរតាមផ្លូវដែលគេដើរហើយ អ្នកចូរវៀរ គឺកុំដុតបាតដៃទាំងទទឹក អ្នកកុំប្រទូស្តមិត្តក្នុងកាលណាមួយ អ្នកកុំលុះអំណាចនៃស្រីដែលប្រកបដោយអសទ្ធម្ម ។

[ ១៦២ ] ( បុណ្ណកយក្ស... ) បុគ្គលដែលឈ្មោះថាដើរទៅកាន់ផ្លូវដែលគេដើរហើយតើដូចម្ដេច គេដុតបាតដៃទាំងទទឹកតើដូចម្ដេច ស្រីដូចម្ដេចឈ្មោះថាស្រីប្រកបដោយអសទ្ធម្ម នរណាឈ្មោះថាជាអ្នកប្រទូស្តមិត្ត ខ្ញុំសួរហើយអ្នកចូរប្រាប់សេចក្ដីនុ៎ះ ។

[ ១៦៣ ] ( វិធុរបណ្ឌិត... ) បុគ្គលណាអញ្ជើញមនុស្សដែលមិន

ធ្លាប់នៅជាមួយគ្នា ឬមិនធ្លាប់ឃើញគ្នាសូម្បីដោយអាសនៈ បុរសត្រូវធ្វើប្រយោជន៍តបស្នងដល់បុគ្គលនោះឯង បណ្ឌិតទាំងឡាយពោលថា អ្នកនោះឯងជាអ្នកដើរតាមផ្លូវដែលគេដើរហើយ ។ បុរសស្នាក់នៅក្នុងផ្ទះរបស់បុគ្គលណាសូម្បីមួយយប់ បានបាយនិងទឹកក្នុងសំណាក់បុគ្គលណា មិនត្រូវគិតអំពើអាក្រក់ដល់បុគ្គលនោះ សូម្បីដោយចិត្ត បុគ្គលអ្នកប្រទូស្តមិត្តឈ្មោះថាដុតបាតដៃទាំងទទឹក ។ បុគ្គលអង្គុយឬដេកក្នុងម្លប់ឈើណា មិនត្រូវកាប់មែកឈើនោះ ព្រោះថាបុគ្គលប្រទូស្តមិត្តជាបុគ្គលអាក្រក់ ។ បុរសណាឲ្យផែនដីនេះដែលពេញដោយទ្រព្យដល់ស្រីដែលខ្លួនសន្មតថា ( ល្អ ) ស្រីនោះបានឱកាស ( ក្បត់ចិត្ត ) គប្បីមើលងាយបុរសនោះវិញ បុគ្គលមិនត្រូវលុះអំណាចស្រីដែលប្រកបដោយអសទ្ធម្មនោះទេ ។ បុគ្គលឈ្មោះថាដើរទៅកាន់ផ្លូវដែលគេដើរហើយយ៉ាងនេះ ឈ្មោះថាដុតបាតដៃទាំងទទឹកយ៉ាងនេះ ស្រីនោះឈ្មោះថាប្រកបដោយអសទ្ធម្ម បុរសនោះឈ្មោះថាជាអ្នកប្រទូស្តមិត្ត អ្នកចូរជាអ្នកប្រកបដោយធម៌ចូរលះបង់អំពើមិនមែនធម៌ចេញ ។

**ចប់ សាធុនរធម្មកណ្ឌ ។**

[ ១៦៤ ] ( បុណ្ណកយក្ស... ) ខ្ញុំបាននៅអាស្រ័យក្នុងផ្ទះរបស់អ្នកអស់ ៣ ថ្ងៃ ដែលអ្នកបានទំនុកបម្រុងខ្ញុំដោយបាយនិងទឹក អ្នកសូមជាមិត្តរបស់ខ្ញុំទាំងខ្ញុំក៏លែងអ្នកដែរ ម្នាលបណ្ឌិតមានប្រាជ្ញាខ្ពង់ខ្ពស់ ចូរអ្នកអញ្ជើញទៅកាន់ផ្ទះរបស់អ្នក តាមប្រាថ្នាចុះ ។ ទាំងសេចក្តីត្រូវការរបស់ត្រកូលនាគ

ក៏សាបសូន្យទៅចុះ អំពើព្រោះហេតុនៃនាងនាគកញ្ញាក៏ល្មមដល់ខ្ញុំហើយ ម្នាលអ្នកមានប្រាជ្ញា អ្នកបានរួចចាកការសម្លាប់របស់ខ្ញុំក្នុងថ្ងៃនេះ ព្រោះសុភាសិតជារបស់ខ្លួន ។

[ ១៦៥ ] ( ព្រះមហាសត្វ... ) ម្នាលយក្ស ណ្ហើយអ្នកចូរនាំខ្ញុំទៅកាន់សំណាក់ឪពុកក្មេករបស់អ្នកចុះ អ្នកចូរប្រព្រឹត្តឲ្យជាប្រយោជន៍ចំពោះខ្ញុំផ្សិតខ្ញុំចង់ឃើញនាគរាជជាអធិបតីនិងវិមានរបស់នាគរាជដែលខ្ញុំមិនធ្លាប់ឃើញ ។

[ ១៦៦ ] ( បុណ្ណកយក្ស... ) របស់ណាដែលប្រព្រឹត្តទៅមិនជាប្រយោជន៍ដល់នរជន ជនមានប្រាជ្ញាមិនគួរឃើញរបស់នោះទេ ម្នាលបណ្ឌិតមានប្រាជ្ញាខ្ពង់ខ្ពស់ កាលបើដូច្នេះអ្នកប្រាថ្នាទៅកាន់ស្រុករបស់សត្រូវដោយហេតុដូចម្តេច ។

[ ១៦៧ ] ( ព្រះមហាសត្វ... ) ខ្ញុំប្រាកដជាដឹងហេតុនុ៎ះ ជនមានប្រាជ្ញាមិនគួរឃើញសត្រូវនោះទេតែអំពើអាក្រក់ខ្ញុំមិនបានធ្វើទុកក្នុងទីណាមួយព្រោះហេតុនោះខ្ញុំមិនរង្កៀសចំពោះសេចក្តីស្លាប់ដែលនឹងមកដល់ឡើយ ។

[ ១៦៨ ] ( បុណ្ណកយក្ស... ) ម្នាលអ្នកជាអាមាត្យ បើដូច្នោះអ្នកនឹងឃើញឋានដែលមានអានុភាពប្រៀបមិនបានជាមួយនឹងខ្ញុំ អ្នកចូរមកចុះ នាគរមែងនៅដោយការរាំនិងច្រៀងក្នុងទីណា ដូចជាព្រះបាទវេស្សវណ នៅក្នុងរាជធានីឈ្មោះ និឡិញ្ញ: ។ ទីនោះមានពួកនៃនាងនាគកញ្ញាត្រាច់ទៅដោយពួកៗលេងអស់ថ្ងៃនិងយប់ជានិច្ច ជាទីមានផ្កាកម្រងច្រើន ដេរដាសដោយផ្កាឈើច្រើនបែប ភ្លឺផ្លេកដូចផ្លេកបន្ទោរព្ធដ៏អាកាស ។ ភពនៃនាគនោះមានភាព

សម្បូណ៌ដោយបាយនិងទឹកនិងការរាំច្រៀងប្រគំ បរិបូណ៌ដោយពួកនាងនាគកញ្ញាដែលតាក់តែងខ្លួនដោយសំពត់និងគ្រឿងប្រដាប់ល្អធើតឆាយ ។

[ ១៦៩ ] ( *អភិសម្ពុទ្ធគាថា* ) បុណ្ណកយក្សនោះបានអញ្ជើញវិធុរបណ្ឌិតជាអាមាត្យដ៏ប្រសើររបស់អ្នកដែនកុរុឲ្យអង្គុយលើអាសនៈអំពីខាងក្រោយ នាំវិធុរបណ្ឌិតជាអាមាត្យមានប្រាជ្ញាមិនថោកទាប ចូលទៅកាន់គពនៃនាគរាជ ។ វិធុរបណ្ឌិតជាអាមាត្យលុះដល់ទីដែលមានអានុភាពប្រៀបមិនបាន ក៏ឈរខាងក្រោយបុណ្ណកយក្ស ចំណែកនាគរាជ ក្រឡេកមើលឃើញបុណ្ណកយក្សមានសេចក្តីស្មោះសរបានត្រាស់នឹងកូនប្រសាមុនថា

[ ១៧០ ] ( *នាគរាជ...* ) អ្នកកាលស្វែងរកហឫទ័យរបស់បណ្ឌិតបានទៅកាន់មនុស្សលោក ហើយនាំអាមាត្យមានប្រាជ្ញាមិនថោកទាបមកដល់ក្នុងទីនេះដោយសួស្តីហើយឬ ។

[ ១៧១ ] ( *បុណ្ណកយក្ស...* ) ព្រះអង្គប្រាថ្នាបណ្ឌិតណា បណ្ឌិតនោះមកដល់ហើយ បណ្ឌិតអ្នករក្សាធម៌ គឺខ្ញុំព្រះអង្គរកបានមកដោយធម៌ហើយ សូមព្រះអង្គទ្រង់ទតបណ្ឌិតនោះ ដែលកំពុងនិយាយក្នុងទីចំពោះព្រះភក្ត្រនៃព្រះអង្គ ការជួបជុំដោយសប្បុរសទាំងឡាយ ជាហេតុនាំមកនូវសេចក្តីសុខដោយពិត ។

**ចប់ កាលាគិរិកណ្ឌ ។**

[ ១៧២ ] ( នាគរាជ... ) អ្នកជាមនុស្សមានមច្ចុភ័យគ្របសង្កត់ តក់ស្លុត ព្រោះឃើញភពនាគដែលខ្លួនមិនធ្លាប់ឃើញ ទើបមិនថ្វាយបង្គំ ( ខ្ញុំ ) ដំណើរនេះមិនមែនជាបុគ្គលមានប្រាជ្ញាទេ ។

[ ១៧៣ ] ( មហាសត្វ... ) បពិត្រនាគ ខ្ញុំព្រះអង្គមិនមែនជាអ្នកតក់ស្លុតទេ មិនមានមច្ចុភ័យគ្របសង្កត់ទេ ព្រោះអ្នកទោសដែលត្រូវគេសម្លាប់មិនគប្បីថ្វាយបង្គំ ( នូវពេជ្ឈឃាត ) ឬពេជ្ឈឃាតក៏មិនគប្បីថ្វាយបង្គំអ្នកទោសដែលត្រូវគេសម្លាប់ដែរ ។ ជនប្រាថ្នាសម្លាប់អ្នកណាគប្បីថ្វាយបង្គំ ( អ្នកនោះ ) ឬឲ្យ ( អ្នកនោះ ) ថ្វាយបង្គំ ( ខ្លួន ) ដូចម្ដេចកើត កម្មនោះមិនសម្រេចទៅជាអ្វីទេ ។

[ ១៧៤ ] ( នាគរាជ... ) ម្នាលបណ្ឌិតដំណើរនុ៎ះដូចអ្នកពោលមែន អ្នកពោលពាក្យពិត អ្នកទោសដែលត្រូវគេសម្លាប់មិនគប្បីថ្វាយបង្គំពេជ្ឈឃាត ឬពេជ្ឈឃាតក៏មិនគប្បីថ្វាយបង្គំអ្នកទោសដែលត្រូវគេសម្លាប់ដែរ ។ នរជនប្រាថ្នាសម្លាប់អ្នកណាគប្បីថ្វាយបង្គំ ( អ្នកនោះ ) ឬឲ្យ ( អ្នកនោះ ) ថ្វាយបង្គំ ( ខ្លួន ) ដូចម្ដេចកើត កម្មនោះមិនកើតទៅជាអ្វីទេ ។

[ ១៧៥ ] ( មហាសត្វ... ) វិមាននេះទាំងឫទ្ធិ សេចក្ដីរុងរឿង កម្លាំងកាយ សេចក្ដីព្យាយាមនិងការកើត ( ក្នុងភពនាគ ) របស់ព្រះអង្គមិនទៀងតែដូចជារបស់ទៀង បពិត្រនាគរាជ ខ្ញុំព្រះអង្គសូមសួរសេចក្ដីនុ៎ះនឹងព្រះអង្គថា វិមាននេះព្រះអង្គបានហើយដោយប្រការដូចម្ដេច ។ វិមាននេះព្រះអង្គបានព្រោះអាស្រ័យ ( ភពនាគ ) ឬកើតអំពីរដូវប្រែប្រួល ឬព្រះអង្គកសាង

ដោយព្រះអង្គឯង ឬមួយទេវតាថ្វាយ បពិត្រនាគរាជ វិមាននេះព្រះអង្គបាន ហើយដោយប្រការណា សូមព្រះអង្គប្រាប់សេចក្តីនុ៎ះដល់ខ្ញុំព្រះអង្គដោយប្រការដូច្នោះ ។

[ ១៧៦ ] ( នាគរាជ... ) វិមាន ( នេះ ) មិនមែនខ្ញុំបានព្រោះអាស្រ័យ ( កពនាគ ) មិនមែនកើតអំពីរដូវប្រែប្រួល មិនមែនខ្ញុំធ្វើខ្លួនឯងទាំងមិនមែនទេវតាឲ្យទេ វិមាននេះខ្ញុំបានដោយបុញ្ញកម្មមិនអាក្រក់របស់ខ្លួន ។

[ ១៧៧ ] ( មហាសត្វ... ) អ្វីជាវត្តរបស់ព្រះអង្គ អ្វីជាព្រហ្មចរិយៈរបស់ព្រះអង្គ បពិត្រនាគ ឫទ្ធិ សេចក្តីរុងរឿង កម្លាំងកាយ សេចក្តីព្យាយាមនិងការកើត ( ក្នុងកពនាគ ) ទាំងវិមានធំរបស់ព្រះអង្គនេះ នេះជាផលនៃកម្មដែលព្រះអង្គសន្សំល្អហើយដូចម្តេច ។

[ ១៧៨ ] ( នាគរាជ... ) ខ្ញុំនិងភរិយាទាំងពីរនាក់ ( កាលនៅ ) ក្នុងមនុស្សលោកជាអ្នកមានសទ្ធា ជាម្ចាស់នៃទានក្នុងកាលនោះ ផ្ទះរបស់ខ្ញុំដូចជាអណ្តូង ( នៃមហាជន ) ទាំងពួកសមណៈនិងព្រាហ្មណ៍ ខ្ញុំក៏បានឲ្យឆ្អែតស្កប់ស្កល់ ខ្ញុំ ( កាលនៅ ) ក្នុងកាលចម្បានគរនោះបានឲ្យទានដោយគោរព គឺឲ្យកម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប គ្រឿងប្រទីប ទីដេក ទីសំណាក់អាស្រ័យ សំពត់សម្រាប់ស្លៀកដណ្តប់ កម្រាលដេក បាយ ទឹក ។ នោះជាវត្ត នោះជាព្រហ្មចរិយៈរបស់ខ្ញុំ នៃអ្នកប្រាជ្ញ ឯឫទ្ធិ សេចក្តីរុងរឿង កម្លាំងកាយ សេចក្តីព្យាយាមនិងការកើត ( ក្នុងកពនាគ ) ទាំងវិមានធំរបស់ខ្ញុំនេះ នេះជាផលនៃកម្មដែលខ្ញុំសន្សំល្អហើយនោះ ។

[ ១៧៩ ] ( មហាសត្វ... ) បើវិមាននេះព្រះអង្គបានហើយយ៉ាងនេះ ឈ្មោះថា ព្រះអង្គជ្រាបកំណើតនៃផលរបស់បុណ្យ ព្រោះហេតុនោះព្រះអង្គកុំប្រហែស សូមប្រព្រឹត្តធម៌ជាហេតុឲ្យគ្រប់គ្រងវិមាននេះតទៅទៀត ។

[ ១៨០ ] ( នាគរាជ... ) នែបណ្ឌិតជាអាមាត្យ ខ្ញុំគប្បីឲ្យបាយនិងទឹកដល់ពួកសមណៈនិងព្រាហ្មណ៍ណា ពួកសមណៈនិងព្រាហ្មណ៍នោះមិនមានក្នុងភពនាគនេះទេ ខ្ញុំសួរហើយអ្នកចូរប្រាប់សេចក្ដីនុ៎ះ ដែលជាហេតុឲ្យខ្ញុំនៅគ្រប់គ្រងវិមានតទៅ ។

[ ១៨១ ] ( មហាសត្វ... ) ពួកនាគ គឺបុត្ត ភរិយានិងអ្នករស់នៅដោយសារដែលចូលមកកើតក្នុងភពនាគនេះ សូមព្រះអង្គជាអ្នកមិនប្រទូស្តក្នុងពួកនាគនោះដោយពាក្យឬដោយការងាររអស់កាលជានិច្ច ។ បពិត្រនាគ សូមព្រះអង្គរក្សាសេចក្ដីមិនប្រទូស្តដោយពាក្យឬដោយការងារយ៉ាងនេះចុះ ព្រះអង្គនឹងឋិតនៅក្នុងវិមាននេះរហូតអស់ព្រះជន្មាយុហើយនឹងបានទៅកាន់ទេវលោកជាន់ខាងលើអំពីភពនាគនេះ ។

[ ១៨២ ] ( នាគរាជ... ) អ្នកជាអាមាត្យរបស់ព្រះរាជាណា ព្រះរាជាដ៏ប្រសើរនោះ បើវៀរចាកអ្នកហើយរមែងសោកស្ដាយដោយពិត បុរសសូម្បីត្រូវសេចក្ដីទុក្ខគ្របសង្កត់ឬសូម្បីមានជំងឺធ្ងន់ បើបានជួបនឹងអ្នកហើយ ក៏នឹងបានសុខវិញ ។

[ ១៨៣ ] ( មហាសត្វ... ) បពិត្រនាគ ព្រះអង្គពោលធម៌របស់សប្បុរសជាធម៌ប្រសើរជាចំណែកនៃប្រយោជន៍ដែលសទ្យល្អដោយពិត ឯសេចក្ដី

វិសេសរបស់បណ្ឌិតទាំងឡាយបែបខ្ញុំព្រះអង្គ រមែងប្រាកដក្នុងអន្តរាយទាំងឡាយបែបនេះ ។

[ ១៨៤ ] ( នាគរាជ... ) អ្នកចូរប្រាប់យើងមកចុះ បុណ្ណកយក្សនេះបានអ្នកមកដោយទទេឬ អ្នកចូរប្រាប់យើងមកចុះ បុណ្ណកយក្សនេះឈ្នះអ្នកដោយល្បែងភ្នាល់ឬ បុណ្ណកយក្សនេះបាននិយាយថា បណ្ឌិតខ្ញុំបាននាំមកដោយធម៌ តើអ្នកមកនៅក្នុងកណ្ដាប់ដៃនៃបុណ្ណកយក្សនេះដោយប្រការដូចម្ដេច ។

[ ១៨៥ ] ( មហាសត្វ... ) ព្រះរាជារបស់ខ្ញុំព្រះអង្គណាជាធំក្នុងក្រុងឥន្ទបត្តដែនកុរុនោះ បុណ្ណកយក្សនេះបានឈ្នះល្បែងស្កានឹងព្រះរាជានោះ ដោយការភ្នាល់ ព្រះរាជាដែលបុណ្ណកយក្សឈ្នះហើយនោះ បានប្រទានខ្ញុំព្រះអង្គដល់បុណ្ណកយក្សនេះ បុណ្ណកយក្សឈ្មោះថា បានខ្ញុំព្រះអង្គមកដោយធម៌ មិនមែនដោយការកំហែងទេ ។

[ ១៨៦ ] ( អភិសម្ពុទ្ធគាថា ) នាគរាជដ៏ប្រសើរ មានចិត្តត្រេកអររីករាយហើយ ព្រោះបានស្ដាប់សុភាសិតនៃវិធុរបណ្ឌិតជាអ្នកប្រាជ្ញ ក៏ចាប់ដៃវិធុរបណ្ឌិតមានប្រាជ្ញាមិនថោកទាប នាំចូលទៅក្នុងសំណាក់នៃនាងវិមលាជាភរិយាក្នុងកាលនោះ ( ត្រាស់ថា ) ម្នាលនាងវិមលា នាងមានសម្បុរលឿងដោយហេតុណា ឬនាងមិនឆ្ងាញ់បាយដោយហេតុណា គុណ ( នៃវិធុរបណ្ឌិត ) បែបនេះមិនមាន ( ដល់នាង ) ដោយហេតុនោះទេ វិធុរបណ្ឌិតនេះឯងជាអ្នកបន្ទោបង់នូវងងឹត ។ នាងមានសេចក្ដីត្រូវការដោយហឫទ័យរបស់វិធុរបណ្ឌិតណា វិធុរបណ្ឌិតនេះជាអ្នកធ្វើពន្លឺមកដល់ហើយ នាងចូរផ្ទៀងស្ដាប់ពាក្យរបស់

វិធុរបណ្ឌិតនោះចុះ ( ព្រោះ ) ការជួបប្រទះ ( នូវវិធុរបណ្ឌិត ) ទៀតជាកិច្ចបានដោយកម្រ ។

[ ១៨៧ ] ព្រះនាងវិមលា ទ្រង់ទតឃើញវិធុរបណ្ឌិតដែលជាអ្នកមានប្រាជ្ញាក្រាស់ដូចផែនដីនោះ ក៏មានព្រះទ័យត្រេកអរសោមនស្ស ទ្រង់លើកប្រាមដៃទាំង ១០ ផ្គងអញ្ជលីហើយត្រាស់នឹងវិធុរបណ្ឌិតជាអាមាត្យដ៏ប្រសើររបស់អ្នកដែនកុរុយ៉ាងនេះថា អ្នកជាមនុស្សមានមច្ចុភ័យគ្របសង្កត់ តក់ស្លុតព្រោះឃើញភពនៃនាគដែលខ្លួនមិនធ្លាប់ឃើញទើបមិនថ្វាយបង្គំ ( ខ្ញុំ ) ដំណើរនេះដូចមិនមែនជាអាការរបស់បុគ្គលមានប្រាជ្ញាទេ ។

[ ១៨៨ ] ( មហាសត្វ... ) បពិត្រព្រះនាងនាគី ខ្ញុំព្រះអង្គមិនមែនជាអ្នកតក់ស្លុតទេ មិនមានមច្ចុភ័យគ្របសង្កត់ទេ អ្នកទោសដែលត្រូវគេសម្លាប់មិនគប្បីថ្វាយបង្គំ ( ពេជ្ឈឃាត ) ឬពេជ្ឈឃាតក៏មិនគប្បីថ្វាយបង្គំអ្នកទោសដែលត្រូវគេសម្លាប់ដែរ ។ ជនប្រាថ្នាសម្លាប់អ្នកណាគប្បីថ្វាយបង្គំ ( អ្នកនោះ ) ឬឲ្យ ( អ្នកនោះ ) ថ្វាយបង្គំ ( ខ្លួន ) ដូចម្តេចកើត កម្មនោះមិនកើតជាអ្វីទេ ។

[ ១៨៩ ] ( ព្រះនាងវិមលា... ) ម្នាលបណ្ឌិត ដំណើរនុ៎ះដូចអ្នកពោលមែន អ្នកពោលពាក្យពិត អ្នកទោសដែលត្រូវគេសម្លាប់ មិនគប្បីថ្វាយបង្គំពេជ្ឈឃាត ឬពេជ្ឈឃាតក៏មិនគប្បីថ្វាយបង្គំអ្នកទោស ដែលត្រូវគេសម្លាប់ដែរ ។ ជនប្រាថ្នាសម្លាប់អ្នកណាគប្បីថ្វាយបង្គំ ( អ្នកនោះ ) ឬឲ្យ ( អ្នកនោះ ) ថ្វាយបង្គំ ( ខ្លួន ) ដូចម្តេចកើត កម្មនោះមិនកើតទេ ។

[ ១៩០ ] ( មហាសត្វ... ) វិមាននេះទាំងឫទ្ធិ សេចក្តីរុងរឿង សេចក្តីព្យាយាម និងការកើតក្នុងភពនាគរបស់ព្រះនាងមិនទៀង តែហាក់ដូចជារបស់ទៀង បពិត្រនាគកញ្ញា ខ្ញុំព្រះអង្គសួរសេចក្តីនុ៎ះនឹងព្រះនាងថា វិមាននេះព្រះនាងបានហើយដោយប្រការដូចម្តេច ។ វិមានដែលព្រះនាងបានព្រោះអាស្រ័យ ( ភពនាគ ) ឬកើតអំពីរដូវប្រែប្រួល ឬព្រះនាងធ្វើខ្លួនឯង ឬមួយទេវតាថ្វាយ បពិត្រនាគកញ្ញា វិមាននេះព្រះនាងបានហើយដោយប្រការណា សូមព្រះនាងប្រាប់សេចក្តីនុ៎ះដល់ខ្ញុំដោយប្រការនោះ ។

[ ១៩១ ] ( ព្រះនាងវិមលា... ) វិមាននេះមិនមែនខ្ញុំបានព្រោះអាស្រ័យភពនាគ មិនមែនកើតអំពីរដូវប្រែប្រួល មិនមែនធ្វើខ្លួនឯងទាំងមិនមែនទេវតាឲ្យទេ វិមាននេះខ្ញុំបានដោយបុញ្ញកម្មមិនអាក្រក់ជារបស់ខ្លួន ។

[ ១៩២ ] ( មហាសត្វ... ) អ្វីជាវត្ត អ្វីជាព្រហ្មចរិយៈរបស់ព្រះនាង បពិត្រព្រះនាងនាគី ឫទ្ធិអំណាច សេចក្តីរុងរឿង កម្លាំងកាយ សេចក្តីព្យាយាម និងការកើត ( ក្នុងភពនាគ ) ទាំងវិមានធំរបស់ព្រះនាងនេះ នេះជាផលនៃកម្មដែលព្រះនាងសន្សំល្អហើយដូចម្តេច ។

[ ១៩៣ ] ( ព្រះនាងវិមលា... ) ខ្ញុំនិងស្វាមីទាំងពីរនាក់ជាអ្នកមានសទ្ធា ជាម្ចាស់ទាន ផ្ទះរបស់ខ្ញុំដូចអណ្តូងជាទីចុះផឹកនៃ ( មហាជន ) ទាំងសមណព្រាហ្មណ៍ ខ្ញុំក៏បានឲ្យឆ្អែតស្កប់ស្កល់ ។ ខ្ញុំ ( កាលនៅ ) ក្នុងកាលចម្បានគរនោះបានឲ្យទានដោយគោរព គឺឲ្យផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាប គ្រឿងប្រទីប ទីដេក ទីសំណាក់អាស្រ័យ សំពត់សម្រាប់ស្លៀកដណ្តប់

កម្រាលដេក បាយនិងទឹក ។ នោះជាវត្ត នោះជាព្រហ្មចរិយៈរបស់ខ្ញុំ នៃអ្នកប្រាជ្ញ ឯឫទ្ធិ សេចក្ដីរុងរឿង កម្លាំងកាយ សេចក្ដីព្យាយាមនិងការកើត ( ក្នុងភពនាគ ) ទាំងវិមានធំរបស់ខ្ញុំនេះ នេះជាផលនៃកម្មដែលខ្ញុំសន្សំល្អហើយនោះ ។

[ ១៩៤ ] ( មហាសត្វ... ) បើវិមាននេះ គឺព្រះនាងបានហើយយ៉ាងនេះ ឈ្មោះថា ព្រះនាងជ្រាបកំណើតនៃផលរបស់បុណ្យទាំងឡាយ ព្រោះហេតុនោះ ព្រះនាងកុំប្រហែស សូមប្រព្រឹត្តធម៌ជាហេតុឲ្យបានគ្រប់គ្រងវិមាននេះតទៅ ។

[ ១៩៥ ] ( ព្រះនាងវិមលា... ) នែបណ្ឌិតជាអាមាត្យ ខ្ញុំគប្បីឲ្យបាយនិងទឹកដល់ពួកសមណៈនិងព្រាហ្មណ៍ណា ពួកសមណៈនិងព្រាហ្មណ៍ ( ទាំងនោះ ) មិនមានក្នុងភពនាគនេះទេ ខ្ញុំសួរហើយអ្នកចូរប្រាប់សេចក្ដីនុ៎ះដែលជាហេតុឲ្យខ្ញុំនៅគ្រប់គ្រងវិមានតទៅ ។

[ ១៩៦ ] ( មហាសត្វ... ) ពួកនាគគឺ បុត្ត ស្វាមីនិងអ្នករស់នៅដោយសារ ដែលកើតមានក្នុងភពនាគនេះ សូមព្រះនាងជាអ្នកមិនប្រទូស្តក្នុងពួកនាគនោះ ដោយពាក្យឬដោយការងាររអស់កាលជានិច្ច ។ បពិត្រព្រះនាងនាគី សូមព្រះនាងរក្សាសេចក្ដីមិនប្រទូស្តដោយពាក្យ ឬដោយការងារយ៉ាងនេះចុះ ព្រះនាងនឹងឋិតនៅក្នុងវិមាននេះរហូតអស់ជន្មាយុហើយនឹងបានទៅកាន់ទេវលោកជាន់ខាងលើអំពីភពនាគនេះ ។

[ ១៩៧ ] ( ព្រះនាងវិមលា... ) អ្នកជាអាមាត្យរបស់ព្រះរាជាណា ព្រះរាជាដ៏ប្រសើរនោះ បើវៀរចាកអ្នកហើយរមែងសោកស្ដាយដោយពិត

បុរសសូម្បីត្រូវសេចក្ដីទុក្ខគ្របសង្កត់ ឬសូម្បីមានជំងឺធ្ងន់ បើបានជួបនឹងអ្នក ហើយក៏នឹងបានសុខវិញ ។

[ ១៩៨ ] ( មហាសត្វ... ) បពិត្រព្រះនាងនាគី ព្រះនាងពោលធម៌របស់សប្បុរស ជាធម៌ប្រសើរ ជាចំណែកនៃប្រយោជន៍ដែលសន្សំល្អដោយពិត ឯសេចក្ដីវិសេសរបស់បណ្ឌិតទាំងឡាយបែបខ្ញុំព្រះអង្គ រមែងប្រាកដក្នុងអន្តរាយទាំងឡាយបែបនេះ ។

[ ១៩៩ ] ( ព្រះនាងវិមលា... ) អ្នកចូរប្រាប់យើងមកចុះ បុណ្ណកយក្សនេះបានអ្នកមកដោយទទេឬ អ្នកចូរប្រាប់យើងមកចុះ បុណ្ណកយក្សនេះឈ្នះអ្នកដោយល្បែងភ្នាល់ឬ បុណ្ណកយក្សនេះបាននិយាយថា បណ្ឌិតខ្ញុំបានមកដោយធម៌ តើអ្នកមកនៅក្នុងកណ្ដាប់ដៃបុណ្ណកយក្សនេះដោយប្រការដូចម្ដេច ។

[ ២០០ ] ( មហាសត្វ... ) ព្រះរាជារបស់ខ្ញុំព្រះអង្គណាជាធំក្នុងក្រុងឥន្ទបត្តដែនកុរុនោះ បុណ្ណកយក្សនេះបានឈ្នះល្បែងស្កានឹងព្រះរាជានោះដោយការភ្នាល់ ព្រះរាជាដែលបុណ្ណកយក្សឈ្នះហើយនោះបានប្រទានខ្ញុំព្រះអង្គដល់បុណ្ណកយក្សនេះ ឯបុណ្ណកយក្សឈ្មោះថា បានខ្ញុំព្រះអង្គដោយធម៌ មិនមែនដោយកំហែងទេ ។

[ ២០១ ] ( អភិសម្ពុទ្ធគាថា ) វរុណនាគរាជ បានសួរប្រស្នានឹងវិធុរបណ្ឌិតយ៉ាងណា ព្រះនាងនាគកញ្ញាក៏បានសួរប្រស្នានឹងវិធុរបណ្ឌិតយ៉ាងនោះដែរ ។ វិធុរបណ្ឌិតជាអ្នកប្រាជ្ញដែលវរុណនាគត្រាស់សួរហើយក៏បានញុំាងវរុណនាគ ឲ្យត្រេកអរយ៉ាងណា វិធុរបណ្ឌិតជាអ្នកប្រាជ្ញដែលព្រះនាងនាគ

កញ្ញាសួរហើយក៏បានញុំាងព្រះនាងនាគកញ្ញាឲ្យត្រេកអរយ៉ាងនោះដែរ ។ វិធុរបណ្ឌិតជាអ្នកប្រាជ្ញ លុះដឹងច្បាស់ថានាគរាជដ៏ប្រសើរនិងនាងនាគកញ្ញាទាំងពីរព្រះអង្គនោះមានព្រះទ័យរីករាយហើយក៏មិនតក់ស្លុត មិនខ្លាច មិនព្រឺរោមបានទូលវរុណនាគរាជដូច្នេះថា បពិត្រនាគ ព្រះអង្គកុំខ្វាល់ឡើយ ខ្ញុំនេះហើយជាសេចក្ដីត្រូវការរបស់ព្រះអង្គ នេះសរីរៈ សូមព្រះអង្គធ្វើកិច្ចដោយសាច់ហឫទ័យចុះ ខ្ញុំនឹងធ្វើតាមអធ្យាស្រ័យរបស់ព្រះអង្គដោយខ្លួនឯង ។

[ ២០២ ] ( នាគរាជ... ) បញ្ញាហ្នឹងឯងជាដួងហឫទ័យរបស់បណ្ឌិតទាំងឡាយ យើងទាំងនោះត្រេកអរក្រៃលែងដោយប្រាជ្ញារបស់អ្នក យក្សមានឈ្មោះមិនខ្វះខាត គឺបុណ្ណកៈ ចូរបានកិរិយាក្នុងថ្ងៃនេះចុះ ចូរញុំាងអ្នកឲ្យទៅដល់ដែនកុរុក្នុងថ្ងៃនេះចុះ ។

[ ២០៣ ] ( អភិសម្ពុទ្ធគាថា ) បុណ្ណកយក្សនោះមានចិត្តត្រេកអររីករាយព្រោះបាននាងនាគកញ្ញាឈ្មោះឥរន្ធតី មានចិត្តត្រេកអរសប្បាយហើយបានពោលនឹងវិធុរបណ្ឌិតជាអាមាត្យដ៏ប្រសើររបស់អ្នកដែនកុរុដូច្នេះថា អ្នកធ្វើខ្ញុំឲ្យបានព្រមព្រៀងដោយភរិយា បពិត្រវិធុរបណ្ឌិត ខ្ញុំសូមធ្វើកិច្ច ( តបគុណ ) ដល់អ្នក ខ្ញុំនឹងឲ្យកែវមណីនេះដល់អ្នក ទាំងញុំាងអ្នកឲ្យដល់ដែនកុរុក្នុងថ្ងៃនេះឯង ។

[ ២០៤ ] ( មហាសត្វ... ) ម្នាលកច្ចាន: មេត្រីជាគុណជាតិ គឺបុគ្គលផ្ទាញ់មិនបាននេះចូរមានដល់អ្នកព្រមទាំងភរិយាជាទីស្រឡាញ់ អ្នកមានចិត្តត្រេកអរទួទៅ មានចិត្តល្អ មានចិត្តរីករាយឲ្យកែវមណីដល់ខ្ញុំហើយ ចូរនាំខ្ញុំ

ទៅកាន់ឥន្ទបត្តនគរចុះ ។

[ ២០៥ ] ( អភិសម្ពុទ្ធគាថា ) បុណ្ណកយក្សនោះឡើងជិះសេះអាជានេយ្យ មានវណ្ណៈមិនថោកទាបហើយអញ្ជើញវិធុរ បណ្ឌិតជាអាមាត្យដ៏ប្រសើររបស់ពួកអ្នកដែនកុរុឲ្យអង្គុយលើអាសនៈអំពីខាងមុខ ហោះទៅឰដ៏អាកាសវេហា ។ ចិត្តរបស់មនុស្សរមែងស្ទុះទៅ ( កាន់អារម្មណ៍ក្នុងទីឆ្ងាយ ) យ៉ាងណា ដំណើរសន្ទុះរបស់សេះអាជានេយ្យនោះក៏ឆាប់រហ័សក្រៃលែងជាងចិត្តនោះក៏យ៉ាងនោះដែរ បុណ្ណកយក្សនោះនាំវិធុរបណ្ឌិត ជាអាមាត្យដ៏ប្រសើររបស់អ្នកដែនកុរុទៅកាន់ឥន្ទបត្តនគរ ។

[ ២០៦ ] ( បុណ្ណកយក្ស... ) ទុំះក្រុងឥន្ទបត្តដែលឃើញច្បាស់ ទុំះព្រៃស្វាយគួរជាទីរីករាយដោយចំណែកៗ ខ្ញុំក៏បានព្រមព្រៀងដោយកិរិយាទាំងអ្នកក៏បានមកដល់ទីលំនៅរបស់ខ្លួន ។

[ ២០៧ ] ( អភិសម្ពុទ្ធគាថា ) បុណ្ណកយក្សនោះញុំាងវិធុរបណ្ឌិតជាអាមាត្យដ៏ប្រសើររបស់ពួកអ្នកដែនកុរុ ឲ្យចុះក្នុងកណ្តាលធម្មសភាហើយឡើងជិះសេះអាជានេយ្យ ជាអ្នកមានវណ្ណៈមិនថោកទាបហោះទៅឰដ៏អាកាសវេហា ។ ព្រះរាជាទតឃើញមហាសត្វនោះហើយ ព្រះអង្គមានព្រះហឫទ័យសោមនស្សដ៏ក្រៃលែង ទ្រង់ក្រោកឡើងយកព្រះហស្តស្រវាឱប ទ្រង់មិនបានឲ្យកម្រើកហើយអញ្ជើញព្រះមហាសត្វឲ្យអង្គុយលើអាសនៈ ក្នុងកណ្តាលធម្មសភាចំពោះព្រះភក្ត្រ ។

[ ២០៨ ] ( ព្រះរាជា... ) អ្នកជាអ្នកណែនាំយើង ដូចនាយសារថីនាំ

យករថដែលបាត់ទៅ ( មកឲ្យ ) អ្នកដែនកុរុទាំងឡាយត្រេកអរព្រោះបាន ឃើញអ្នក ខ្ញុំសួរហើយអ្នកចូរប្រាប់សេចក្តីនុ៎ះ អ្នករួចអំពីមាណពដោយប្រការ ដូចម្តេច ។

[ ២០៩ ] ( មហាសត្ត... ) បពិត្រព្រះអង្គជាធំជាងជន មានព្យាយាម ដ៏ប្រសើរជាងជន ព្រះអង្គត្រាស់ហៅបុរសណាថាមាណព បុរសនោះមិនមែន ជាមនុស្សទេ គឺជាយក្សឈ្មោះបុណ្ណកៈព្រះអង្គក៏ធ្លាប់បានឮមកហើយ បុណ្ណក-យក្សនោះជាអាមាត្យនៃព្រះបាទកុវេរៈ មានស្តេចនាគមួយឈ្មោះវរុណៈ គ្រប់ គ្រងផែនដីមានទំហំនិងកម្ពស់ស្អាត បរិបូណ៌ដោយពណ៌សម្បុរនិងកម្លាំង ឯ បុណ្ណកយក្សនោះចង់បានធីតាជាអនុជាតនៃវរុណនាគនោះ ( ធ្វើជាប្រពន្ធ ) នាង នាគកញ្ញានោះឈ្មោះ ឥរន្ទតី ។ បុណ្ណកយក្សព្យាយាមដើម្បីសម្លាប់ខ្ញុំព្រះអង្គ ព្រោះហេតុនៃនាងឥរន្ទតីនោះមានចង្កេះល្អ គួរជាទីស្រឡាញ់ ឥឡូវនេះបុណ្ណក យក្សនោះ បានព្រមព្រៀងដោយករិយា ចំណែកខ្ញុំព្រះអង្គក៏បុណ្ណកយក្ស អនុញ្ញាតហើយទាំងកែវមណីខ្ញុំព្រះអង្គក៏បានហើយ ។

[ ២១០ ] ( ព្រះរាជា... ) ដើមឈើដុះទៀបទ្វារដំណាក់របស់យើង មានដើមសម្រេចដោយប្រាជ្ញា មែករបស់ឈើនោះសម្រេចដោយសីល ដើម ឈើ ( នោះ ) សម្រេចដោយប្រាជ្ញាខ្ជាប់ខ្ជួន តាំងនៅក្នុងអត្ថនិងធម៌ មានផ្លែ ជាបញ្ចគោរស ដេរដាសដោយដំរីគោនិងសេះ ។ កាលដើមឈើនោះគឹកកង ដោយការរាំ ការច្រៀងនិងតន្ត្រី បុរស ( ខ្មៅម្នាក់ ) កាត់ដើមឈើនោះ ហើយញុំាងសេនា ( ឲ្យរត់ទៅ ) បណ្ឌិតនេះទុកដូចជាដើមឈើរបស់យើងនោះ

មកកាន់លំនៅរបស់ខ្លួនវិញហើយ អ្នកទាំងឡាយចូរធ្វើសេចក្តីកោតក្រែងដើមឈើនេះ ។ ជនទាំងឡាយណានីមួយមានចិត្តត្រេកអរ ( ដោយយស ) ព្រោះបច្ច័យនៃយើង ពួកជនទាំងអស់នោះចូរធ្វើ ( ចិត្តរបស់ខ្លួន ) ឲ្យប្រាកដក្នុងថ្ងៃនេះចុះ អ្នកទាំងឡាយធ្វើបណ្ណាការឲ្យច្រើន ចូរធ្វើសេចក្តីកោតក្រែងដល់ដើមឈើនេះចុះ ។ ពួកសត្វណានីមួយដែលគេចងទុកក្នុងដែនរបស់យើង ពួកសត្វទាំងអស់នោះចូរឲ្យរួចចាកចំណង វិធុរបណ្ឌិតនេះរួចចាកចំណងយ៉ាងណា ពួកសត្វទាំងនុ៎ះ គប្បីរួចចាកចំណងយ៉ាងនោះ ។ ចូរពួកប្រជាជនទុកដាក់នង្គ័លធ្វើ ( មហោស្រព ) អស់មួយខែនេះចុះ ពួកព្រាហ្មណ៍ ចូរបរិភោគបាយលាយដោយសាច់ ពួកអ្នកមិនផឹកទឹកស្រវឹងគួរផឹកទឹកស្រវឹង ចូរផឹកដោយភាជនៈដ៏ពេញហូរហៀរ ។ ស្រីពេស្យាទាំងឡាយ ( អាស្រ័យ ) ផ្លូវធំចូរហៅរកបុរសអ្នកត្រូវការអស់កាលជានិច្ចចុះ មួយទៀតរាជបុរសទាំងឡាយ ចូរចាត់ចែងការរក្សាឲ្យមាំមួនក្នុងដែន កុំឲ្យពួកមនុស្សបៀតបៀនគ្នានឹងគ្នា អ្នកទាំងឡាយចូរធ្វើសេចក្តីកោតក្រែងចំពោះដើមឈើនេះ ។

[ ២១១ ] ពួកស្នំ ពួករាជកុមារ ពួកអ្នកជំនួញនិងពួកព្រាហ្មណ៍នាំយកបាយនិងទឹកដ៏ច្រើនមកជូនវិធុរបណ្ឌិត ។ ពលដំរី ( ពលសេះ ) ពលរថពលថ្មើរជើងនាំយកបាយនិងទឹកដ៏ច្រើនមកជូនវិធុរបណ្ឌិត ។ ពួកអ្នកជនបទមកជួបជុំគ្នា ពួកអ្នកនិគមមកជួបជុំគ្នា នាំយកបាយនិងទឹកដ៏ច្រើនមកជូនវិធុរបណ្ឌិត ។ ប្រជាជនជាច្រើន ជាអ្នកមានចិត្តជ្រះថ្លាព្រោះឃើញបណ្ឌិតមកដល់ហើយ កាលបណ្ឌិតមកដល់ការលើកទង់ក៏ប្រព្រឹត្តទៅ ។

**ចប់ វិធុរជាតក ទី ៩ ។**

# អដ្ឋកថា

# វិធុរជាតក

[ ៦០-២១១ ] ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធបញ្ញាបារមី ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **បណ្ឌុ កិសិយាសិ ទុព្វលា** ដូច្នេះជាដើម ។

សេចក្តីពិស្តារថា ថ្ងៃមួយភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងរោងធម្មសភាថា អាវុសោទាំងឡាយ គួរអស្ចារ្យពិតហ្ន៎ ព្រះសាស្តាទ្រង់មានមហាបញ្ញា មានបុថុបញ្ញា មានគម្ភីរបញ្ញា មានជវនបញ្ញា មានហាសបញ្ញា មានតិក្ខបញ្ញា មាននិព្វេធិកបញ្ញាញ៉ាំញីពាក្យរបស់អ្នកដទៃ ទ្រង់បំផ្លាញនូវប្រស្នាដ៏ល្អិតដែលក្សត្រនិងបណ្ឌិតជាដើមចងឡើងបានដោយអានុភាពនៃបញ្ញារបស់ទ្រង់ ទ្រង់ទូន្មានជនទាំងនោះឲ្យអស់ព្យសន៍ ហើយឲ្យតាំងនៅក្នុងសរណៈនិងសីលនិងឲ្យប្រព្រឹត្តទៅតាមគន្លង ដែលនាំសត្វទៅកាន់អមតមហានិព្វាន ព្រះសាស្តាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ កាលភិក្ខុទាំងនោះទូលឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គដោយរឿងឈ្មោះ នេះទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតសម្រេចបរមាភិសម្ពោធិញ្ញាណ អាចទម្លាយបង់នូវពាក្យដែលអ្នកដទៃពោលឲ្យខ្ចាត់ខ្ចាយ ទូន្មានជនទាំងឡាយមានស្តេចជាដើមបាននេះ មិនគួរអស្ចារ្យទេ ព្រោះថាកាលតថាគតកំពុងស្វែងរកអនុត្តរសម្មាសម្ពោធិញ្ញាណ ក្នុងកពមុនក៏ជាអ្នកមានបញ្ញា ញ៉ាំញីនូវពាក្យដែលអ្នកដទៃពោលឲ្យខ្ចាត់ខ្ចាយទៅដូចគ្នា ។

ពិតហើយ ក្នុងកាលដែលតថាគតជាវិធុរបណ្ឌិត ទូន្មានសេនាបតីយក្ខឈ្មោះបុណ្ណកៈបានដោយកម្លាំងញាណលើកំពូលភ្នំគីរីកាឡាបពិតកម្ពស់ ៦០ យោជន៍ ធ្វើឲ្យរាបអស់ព្យសន៍ឲ្យ តាំងនៅក្នុងសីល ៥ រហូតប្រគល់ជីវិតឲ្យតថាគតដូច្នេះហើយទ្រង់ក៏នៅស្ងៀម កាលភិក្ខុទាំងឡាយទូលអារាធនាហើយ ទើបទ្រង់នាំរឿងក្នុងអតីតមកត្រាស់ដូចតទៅនេះថា

ក្នុងអតីតកាលព្រះរាជាព្រះនាមថា ធនញ្ជយកោរព្យរាជ ទ្រង់សោយរាជ្យក្នុងក្រុងឥន្ទបត្តបុរីដែនកុរុ ។ អាមាត្យឈ្មោះវិធុរបណ្ឌិតបានជារាជសេវកៈរបស់ព្រះបាទធនញ្ជយកោរព្យរាជនោះ ជាអ្នកថ្វាយអត្ថនិងធម៌ ជាអ្នកមានពាក្យពីរោះ ជាមហាធម្មកថិក លួងលោមព្រះរាជាក្នុងជម្ពូទ្វីបទាំងមូលដោយធម្មទេសនាដ៏ពីរោះរបស់ខ្លួន ដូចខ្សែពិណញ៉ាំងដំរីឲ្យស្រឡាញ់ដូច្នោះ ព្រះរាជាទាំងនោះមិនព្រមយាងត្រឡប់ទៅកាន់ដែនរបស់ព្រះអង្គ សម្ដែងធម៌ដល់មហាជនដោយពុទ្ធលីលា អាស្រ័យនៅក្នុងនគរនោះដោយយសធំ ។ ក្នុងក្រុងពារាណសីនោះមានព្រាហ្មណមហាសាល ៤ នាក់ ធ្លាប់ជាសម្លាញ់ជាមួយគ្នាក្នុងកាលជាគ្រហស្ថ ក្នុងវេលាដែលខ្លួនចាស់ឃើញទោសក្នុងកាមទាំងឡាយ លះបង់ផ្ទះសម្បែងចូលទៅកាន់ហិមវន្តប្បទេស បួសជាឥសី ញ៉ាំងអភិញ្ញានិងសមាបត្តិឲ្យកើតហើយ មានឫសឈើនិងផ្លែឈើក្នុងព្រៃជាអាហារនៅក្នុងព្រៃហិមពាន្តនោះអស់កាលយូរ ទើបចារិកទៅដើម្បីរសជូរនិងប្រៃទៅដល់កាឡចម្បាកនគរក្នុងដែនអង្គៈ នាំគ្នាសម្រាកក្នុងព្រះរាជឧទ្យាន ស្អែកឡើងទើបចូលទៅបិណ្ឌបាតក្នុងព្រះនគរ ។

ក្នុងកាឡចម្បាកនគរនោះមានកុដុម្ពិកៈ ៤ នាក់ជាសម្លាញ់នឹងគ្នា ជ្រះថ្លាក្នុងឥរិយាបថរបស់ឥសីទាំងនោះ ក៏នាំគ្នាថ្វាយបង្គំទទួលយកកាជនៈសម្រាប់ដាក់អាហារនាំមកកាន់ផ្ទះរៀងៗខ្លួន អង្គាសដោយអាហារដ៏ប្រណីត ក៏សូមនូវបដិញ្ញាហើយឲ្យនៅក្នុងឧទ្យាន ។ តាបសទាំង ៤ កាលឆាន់អាហារក្នុងផ្ទះកុដុម្ពិកៈទាំង ៤ ស្រេចហើយមានបំណងនឹងសម្រាកពេលថ្ងៃ ឥសីមួយអង្គទៅកាន់ស្ថានតាវត្តិង្ស មួយអង្គទៅកាន់ភពនាគ មួយអង្គទៅកាន់ស្ថានគ្រុឌ មួយអង្គទៅកាន់ព្រះរាជឧទ្យានឈ្មោះមិគាជិនៈ របស់ព្រះបាទកោរព្យ ។ បណ្ដាតាបសទាំង ៤ អង្គដែលទៅសម្រាកពេលថ្ងៃក្នុងទេវលោក បានឃើញឥស្សរិយយសរបស់សក្កទេវរាជទើបពណ៌នាឥស្សរិយយសនោះដល់កុដុម្ពិកៈដែលជាឧបដ្ឋាករបស់ខ្លួន មួយអង្គទៅសម្រាកពេលថ្ងៃក្នុងស្ថាននាគ បានឃើញសម្បត្តិរបស់ស្ដេចនាគ លុះត្រឡប់មកដល់ហើយ ក៏ពណ៌នាសម្បត្តិរបស់ស្ដេចនាគនោះឯងដល់កុដុម្ពិកៈដែលជាឧបដ្ឋាករបស់ខ្លួន មួយអង្គដែលទៅសម្រាកពេលថ្ងៃក្នុងស្ថានគ្រុឌ បានឃើញគ្រឿងអលង្ការរបស់ស្ដេចគ្រុឌកាលត្រឡប់មកហើយ ក៏ពណ៌នាគ្រឿងប្រដាប់របស់ស្ដេចគ្រុឌនោះ ដល់កុដុម្ពិកៈដែលជាឧបដ្ឋាករបស់ខ្លួន មួយអង្គដែលទៅសម្រាកពេលថ្ងៃក្នុងព្រះរាជឧទ្យានរបស់ព្រះបាទកោរព្យ បានឃើញសម្បត្តិដ៏ប្រសើរ គឺសិរីរបស់ព្រះបាទធនញ្ជយៈ កាលត្រឡប់មក បានពណ៌នាភោគសម្បត្តិរបស់ព្រះបាទធនញ្ជយៈនោះដល់កុដុម្ពិកៈដែលជាឧបដ្ឋាករបស់ខ្លួន ។ កុដុម្ពិកៈ ៤ នាក់ជាសម្លាញ់នឹងគ្នានោះ កាលប្រាថ្នាឋានៈនោះៗ ខំបំពេញបុណ្យមានទានជាដើម

ទីបំផុតនៃអាយុម្នាក់កើតជាសក្កទេវរាជ ម្នាក់មួយអន្ទើដោយបុត្តនិងកិរិយា កើតជាស្តេចនាគក្នុងនាគពិភព ម្នាក់កើតជាស្តេចគ្រុឌក្នុងសិម្ពលីរុក្ខវិមាន ម្នាក់កើតក្នុងផ្ទៃនៃអគ្គមហេសីរបស់ព្រះបាទធនញ្ជយៈ ។ តាបសទាំង ៤ នោះមានឈានមិនសាបសូន្យធ្វើកាលកិរិយាហើយកើតក្នុងព្រហ្មលោក ។ បណ្តាកុដុម្ពិកៈទាំង ៤ នាក់នោះ កុដុម្ពិកៈដែលជាកោរព្យកុមារ ចម្រើនវ័យឡើងហើយកាលព្រះរាជបិតាសោយទិវង្គត ក៏ឡើងគ្រងរាជសម្បត្តិបន្តសន្តតិវង្សគ្រងរាជ្យដោយធម៌ ។ ព្រះបាទកោរព្យនោះទ្រង់ពេញព្រះហឫទ័យ ក្នុងការលេងបាស្កា តាំងនៅក្នុងឱវាទរបស់វិធុរបណ្ឌិត ទ្រង់បំពេញទាន រក្សាបញ្ចសីលនិងឧបោសថសីល ថ្ងៃមួយទ្រង់សមាទានឧបោសថហើយ ទ្រង់ព្រះតម្រិះថា អញនឹងចម្រើនវិវេក ដូច្នេះហើយយាងទៅកាន់ព្រះរាជឧទ្យានប្រថាប់គង់ក្នុងទីដែលគួរត្រេកអរ ទ្រង់ចម្រើនសមណធម៌ ។ ចំណែកសក្កទេវរាជទ្រង់សមាទានឧបោសថហើយទ្រង់ព្រះតម្រិះថា ក្នុងទេវលោកនៅមានកង្វល់នៅឡើយ ដូច្នេះហើយទើបយាងទៅកាន់ព្រះរាជឧទ្យាន ក្នុងមនុស្សលោកនោះឯង បានប្រថាប់គង់ចម្រើនសមណធម៌ក្នុងទីដែលគួរត្រេកអរ ។ ឯវរុណនាគរាជសមាទានឧបោសថហើយគិតថាក្នុងនាគពិភពមានសេចក្តីកង្វល់ទើបទៅកាន់ព្រះរាជឧទ្យាននោះ អង្គុយចម្រើនសមណធម៌ក្នុងទីដែលគួរត្រេកអរចំណែកមួយ ។ ឯស្តេចគ្រុឌសមាទានឧបោសថហើយក៏ត្រិះរិះថាក្នុងពិភពគ្រុឌមានបលិពោធ ទើបទៅក្នុងព្រះរាជឧទ្យាននោះហើយអង្គុយចម្រើនសមណធម៌ក្នុងទីដែលគួរត្រេកអរនាចំណែកមួយ ។ ព្រះរាជាទាំង ៤ ព្រះ

អន្តនោះក្នុងពេលល្ងាច ចេញអំពីលំនៅរៀងៗខ្លួន ទៅជួបគ្នាត្រង់ប្រាំងស្រះបោក្ខរណីដែលជាមង្គល លុះឃើញគ្នានឹងគ្នា ក៏មានការព្រមព្រៀងត្រេកអរចូលទៅតាំងទុកនូវចិត្ត មានមេត្តាដល់គ្នានឹងគ្នា រាក់ទាក់ដោយពាក្យពីរោះដោយអំណាចនៃការស្រឡាញ់ ដែលធ្លាប់មានដល់គ្នានឹងគ្នាក្នុងកាលមុន ឯសក្កទេវរាជគង់ប្រថាប់លើផ្ទាំងសិលាដែលជាមង្គល ចំណែកព្រះរាជាទាំង ៣ នោះ ទ្រង់ដឹងឱកាសដែលគួរដល់ទ្រង់រៀងៗខ្លួន ។ លំដាប់នោះសក្កទេវរាជក៏ត្រាស់នឹងព្រះរាជាទាំង ៣ នោះថា ពួកយើងទាំង ៤ សុទ្ធតែជាស្តេចសមាទានឧបោសថតែក្នុងបណ្តាយើងទាំង ៤ នរណាមានសីលច្រើនជាងគេ ។ លំដាប់នោះវរុណនាគរាជបាននិយាយឡើងថា សីលរបស់ខ្ញុំប៉ុណ្ណោះច្រើនជាងសីលរបស់ពួកលោកទាំង ៣ សក្កទេវរាជត្រាស់សួរថា ព្រោះហេតុអ្វីទើបរឿងនេះលោកពោលយ៉ាងនេះ វរុណនាគរាជពោលថា ព្រោះស្តេចគ្រុឌនេះជាសត្រូវរបស់ខ្ញុំ ទាំងដែលកើតហើយនិងមិនទាន់កើត សូម្បីខ្ញុំឃើញស្តេចគ្រុឌដែលជាសត្រូវ ដែលអាចប្រទូស្តខ្ញុំឲ្យអស់ជីវិតបានបែបនេះ ក៏មិនបានធ្វើសេចក្តីក្រោធចំពោះស្តេចគ្រុឌនោះឡើយ ព្រោះហេតុនោះទើបសីលរបស់ខ្ញុំច្រើនជាងសីលរបស់លោកទាំង ៣ ដូច្នេះហើយក៏ត្រាស់គាថាទី ១ ក្នុងចតុបោសថជាតក ក្នុងទសកនិបាតដូច្នេះថា

បុគ្គលណាជាសប្បុរស មិនធ្វើនូវសេចក្តីក្រោធក្នុងបុគ្គលគួរ
ក្រោធនិងមិនក្រោធក្នុងកាលណាមួយ បុគ្គលជាសប្បុរសនោះ
បើទុកជាក្រោធ ក៏មិនធ្វើសេចក្តីក្រោធឲ្យប្រាកដ បណ្ឌិតទាំង

ឡាយហៅជននោះឯងថាជាសមណៈក្នុងលោក ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យោ** បានដល់ ក្នុងបណ្តាជនទាំងឡាយមានក្សត្រជាដើមណាមួយ ។ បទថា **កោបនេយ្យេ** សេចក្តីថា មិនធ្វើសេចក្តីក្រោធក្នុងបុគ្គលដែលគួរក្រោធ ដូចខន្តិវាទីតាបសដូច្នោះ ។ បទថា **ករោតិ** សេចក្តីថា បុគ្គលណាមិនធ្វើសេចក្តីក្រោធក្នុងកាលណាៗ ។ បទថា **កុជ្ឈាមិ** សេចក្តីថា បើបុគ្គលនោះជាសប្បុរសរមែងក្រោធសោត ឬក្រោធហើយក៏មិនធ្វើសេចក្តីក្រោធនោះឲ្យប្រាកដ ដូចចូឡពោធិតាបសដូច្នោះ ។ បទថា **តំ វេ ឆរំ** សេចក្តីថា បពិត្រមហារាជ បណ្ឌិតទាំងឡាយរមែងហៅបុគ្គលនោះដែលជាសប្បុរសថាជាអ្នកស្ងប់ក្នុងលោក ព្រោះស្ងប់បាបបាន គុណធម៌ទាំងនេះមាននៅក្នុងខ្ញុំ ព្រោះដូច្នោះទើបសីលរបស់ខ្ញុំប៉ុណ្ណោះច្រើនជាងសីលរបស់លោកទាំង ៣ ។

ស្តេចគ្រុឌបានស្តាប់ដូច្នោះទើបពោលថា នាគនេះជាអាហារយ៉ាងល្អរបស់ខ្ញុំ តែខ្ញុំឃើញនាគដែលជាអាហារយ៉ាងធ្ងាញ់បែបនេះហើយ ក៏ទប់នូវចំណង់បាន មិនធ្វើបាបព្រោះតែអាហារ ព្រោះដូច្នោះទើបសីលរបស់ខ្ញុំច្រើនជាង ដូច្នេះហើយទើបពោលគាថានេះថា

ជនណាមានពោះដូរអត់ទ្រាំនូវសេចក្តីស្រេកឃ្លាន បានទូន្មាន
នូវឥន្ទ្រិយ ជាអ្នកមានតបធម៌មានទឹកនិងភោជនល្មមប្រមាណ
មិនធ្វើនូវបាបព្រោះហេតុនៃអាហារឡើយ បណ្ឌិតទាំងឡាយ
ហៅជននោះថាជាសមណៈក្នុងលោក ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ទន្តោ** បានដល់ ប្រកបដោយការទូន្មាននូវឥន្ទ្រិយ ។ បទថា **តបស្សី** បានដល់ អាស្រ័យសេចក្ដីព្យាយាមជាគ្រឿងដុតបំផ្លាញកិលេស ។ បទថា **អាហារហេតុ ន ករោតិ ចាបំ** សេចក្ដីថា បុគ្គលសូម្បីត្រូវសេចក្ដីឃ្លានបៀតបៀន ក៏មិនធ្វើកម្មដ៏លាមក ដូចព្រះធម្មសេនាបតីសារីបុត្ត តែខ្ញុំក្នុងថ្ងៃនេះមិនធ្វើអាក្រក់ព្រោះហេតុនៃអាហារ ព្រោះដូច្នោះទើបសីលរបស់ខ្ញុំច្រើនជាង ។

លំដាប់នោះសក្កទេវរាជក៏ត្រាស់ថា ខ្ញុំលះសម្បត្តិក្នុងទេវលោកដែលមានសេចក្ដីសុខជាហេតុមានប្រការផ្សេងៗ មកកាន់មនុស្សលោកដើម្បីរក្សាសីល ព្រោះដូច្នោះទើបសីលរបស់ខ្ញុំច្រើនជាង ដូច្នេះហើយត្រាស់គាថានេះថា

> ជនណាលះបង់នូវល្បែង ( ដោយកាយនិងវាចា ) និងសេចក្ដី
> ត្រេកអរ ( ក្នុងកាមគុណ ) ទាំងពួង ទាំងមិនពោលនូវពាក្យ
> ឡេះឡោះតិចតួចក្នុងលោក វៀរចាកហេតុជាទីតាំងនៃការស្អិត
> ស្អាងនិងមេថុនធម្ម បណ្ឌិតទាំងឡាយហៅជននោះឯងថា ជា
> សមណៈក្នុងលោក ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ខិឌ្ឌំ** បានដល់ ការលេងផ្លូវកាយ និងការលេងផ្លូវវាចា ។ បទថា **រតឹ** បានដល់ សេចក្ដីត្រេកអរក្នុងកាមគុណជាទិព្វ ។ បទថា **កិញ្ចិ** បានដល់ មានប្រមាណតិច ។ បទថា **វិភូសដ្ឋានា** សេចក្ដីថា ការតាក់តែងមាន ២ យ៉ាង គឺតាក់តែងសាច់ ១ តាក់តែងពណ៌សម្បុរ ១ ក្នុងការតាក់តែង ២ យ៉ាងនោះ អាហារដែលលេបចូលទៅឈ្មោះ

ថា តាក់តែងសាច់ ការតាក់តែងដោយផ្កាកម្រងនិងគ្រឿងក្រអូបជាដើមឈ្មោះថា តាក់តែងពណ៌សម្បុរ បុគ្គលត្រេកអរដោយអកុសលចិត្តណា អកុសលចិត្តនោះឈ្មោះថា ឋានៈនៃពាក្យនោះបុគ្គលវៀរចាកឋានៈនោះ ។ បទថា **មេថុនស្មា** សេចក្តីថា បុគ្គលណាវៀរចាកនូវការសេពមេថុន អ្នកប្រាជ្ញទាំងឡាយហៅបុគ្គលនោះថា អ្នកស្ងប់ក្នុងលោក ថ្ងៃនេះខ្ញុំលះទេពអប្សរទាំងឡាយមកក្នុងមនុស្សលោកនេះ ធ្វើសមណធម៌ ព្រោះហេតុនោះទើបសីលរបស់ខ្ញុំច្រើនជាង ។

សក្កទេវរាជទ្រង់សរសើរសីលរបស់ទ្រង់ប៉ុណ្ណោះដោយប្រការដូច្នេះ ។

ព្រះបាទធនញ្ជយៈបានស្តាប់ដូច្នោះក៏ត្រាស់ថា ថ្ងៃនេះខ្ញុំលះរាជសម្បត្តិដែលហួងហែងជាច្រើននិងព្រះរាជវាំងដែលដល់ព្រមដោយស្រីរបាំទាំងឡាយ ១៦០០០ នាក់ មកបំពេញសមណធម៌ក្នុងព្រះរាជឧទ្យាននេះ ដូច្នោះទើបសីលរបស់ខ្ញុំច្រើនជាង ដូច្នេះហើយទើបត្រាស់គាថានេះថា

> ជនណាកំណត់ដឹងហើយលះបង់នូវទ្រព្យសម្បត្តិផង លោកៈ
> ទាំងពួងផង បណ្ឌិតទាំងឡាយហៅជនដែលមានខ្លួនទូន្មាន មាន
> សភាពខ្ជាប់ខ្ជួន មិនមានសេចក្តីប្រកាន់ថាអញមិនមានសេចក្តី
> ប្រាថ្នានោះឯងថាជាសមណៈក្នុងលោក ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បរិគ្គហំ** បានដល់ វត្ថុកាមមានប្រការផ្សេងៗ ។ បទថា **លោភជម្មំ** បានដល់ តណ្ហាដែលកើតឡើងព្រោះវត្ថុកាមនោះ ។ បទថា **បរិញ្ញាយ** សេចក្តីថា កំណត់ដឹងដោយបរិញ្ញា ៣ គឺញាតបរិញ្ញា ១

តីរណប្បរិញ្ញា ១ បហានប្បរិញ្ញា ១ ក្នុងបណ្ដាបរិញ្ញា ៣ យ៉ាងនោះ ការដឹងសភាវៈនៃខន្ធជាដើមឈ្មោះថា ញាតប្បរិញ្ញា កិរិយាដែលពិចារណាឃើញទោសក្នុងខន្ធទាំងឡាយឈ្មោះថា តីរណប្បរិញ្ញា កិរិយាឃើញទោសក្នុងខន្ធទាំងនោះហើយប្រាសចាកការគិតដោយអំណាចការពេញចិត្តឈ្មោះថា បហានប្បរិញ្ញា ជនពួកណាកំណត់ដឹងដោយបរិញ្ញាទាំង ៣ នេះ ហើយលះវត្ថុកាមនិងកិលេសកាម ។ បទថា **ឥន្តំ** បានដល់ អស់ព្យសន៍ហើយ ។ បទថា **ឋិតត្តំ** បានដល់ មានភាវៈតាំងនៅដោយការមិនមាននៃមិច្ឆាវិតក្ក ។ បទថា **អមមំ** បានដល់ មិនមានតណ្ហាជាហេតុនៃសេចក្ដីប្រកាន់ថាជារបស់អញ ។ បទថា **និរាសំ** បានដល់ មានចិត្តអស់នូវការជាប់ជំពាក់ ក្នុងកូននិងប្រពន្ធជាដើម ។ បទថា **តំ វេ ឆរំ** សេចក្ដីថា បណ្ឌិតទាំងឡាយរមែងហៅបុគ្គលបែបនោះថាជាអ្នកស្ងប់ដូច្នេះ ។

លំដាប់នោះព្រះរាជា ៤ អង្គ ក៏សរសើរសើលរៀងៗខ្លួនប៉ុណ្ណោះថាមានច្រើនជាងគេ ដូច្នេះហើយក៏ត្រាស់សួរព្រះបាទធនញ្ជយៈថា បពិត្រមហារាជអ្នកណាមួយ ជាបណ្ឌិតក្នុងសម្នាក់របស់ព្រះអង្គដែលអាចបន្ទោបង់នូវសេចក្ដីសង្ស័យរបស់ពួកយើងមានដែរឬ ។ ព្រះបាទធនញ្ជយៈត្រាស់ថា មានមហារាជ គឺវិធុរបណ្ឌិត ដែលតាំងនៅក្នុងតំណែងជាអ្នកបង្រៀនអត្ថនិងធម៌ ជាអ្នកទ្រទ្រង់នូវបញ្ញាមិនមានបុគ្គលស្មើ អាចបន្ទោបង់សេចក្ដីសង្ស័យរបស់ពួកយើងបាន ពួកយើងចូរនាំគ្នាទៅកាន់សម្នាក់របស់វិធុរបណ្ឌិតនោះចុះ ។ ព្រះរាជាទាំង ៣ អង្គនោះទទួលយល់ព្រមហើយ ។ លំដាប់នោះព្រះរាជាទាំង

នោះនាំគ្នាចេញអំពីព្រះរាជឧទ្យានទៅកាន់ធម្មសភា ត្រាស់ឲ្យតាក់តែងធម្មាសនៈ អញ្ជើញឲ្យព្រះពោធិសត្វអង្គុយត្រង់បល្ល័ង្កដ៏ប្រសើរ ធ្វើបដិសណ្ឋារៈហើយ ប្រថាប់គង់ក្នុងចំណែកម្ខាងត្រាស់ថា នែបណ្ឌិត សេចក្តីសង្ស័យកើតឡើងដល់ពួកយើង ចូរអ្នកបន្ទោបង់សេចក្តីសង្ស័យនោះចុះ ដូច្នេះហើយត្រាស់គាថានេះថា

ម្នាលអ្នកមានប្រាជ្ញាមិនថោកថយ យើងទាំងឡាយសូមសួរ
ចំពោះអ្នកជាអ្នកធ្វើ ( នូវហេតុដែលគួរធ្វើ ) ការជជែក
ចំពោះពាក្យទាំងឡាយ កើតមានដល់យើង សូមអ្នកកាត់នូវ
សេចក្តីងឿងឆ្ងល់និងសេចក្តីសង្ស័យចេញក្នុងថ្ងៃនេះ យើង
ទាំងអស់គ្នាគប្បីឆ្លងនូវសេចក្តីសង្ស័យនោះក្នុងថ្ងៃនេះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កត្តារំ** បានដល់ លោកជាអ្នកអាចដឹងហេតុនិងមិនមែនហេតុ បានដល់ ហេតុដែលគួរធ្វើនិងមិនគួរធ្វើ ។ បទថា **វិគ្គហោ អត្ថិ ជាតោ** សេចក្តីថា ការពោលជំទាស់គ្នាក្នុងរឿងសីល គឺការប្រកែកគ្នាក្នុងរឿងសីលកើតឡើង ។ បទថា **ឆិន្ទជ្ជ** សេចក្តីថា ថ្ងៃនេះ ចូរអ្នកកាត់សង្ស័យ គឺការអល់អែកនោះរបស់យើងទាំងឡាយដូចសក្កទេវរាជកាត់នូវកំពូលភ្នំសិនេរុ ដោយវជិរាវុធដូច្នោះ ។ បទថា **វិតរេមុ** បានដល់ពួកយើងគប្បីឆ្លងទៅបាន ។

គ្រានោះវិធុរបណ្ឌិតបានស្តាប់ព្រះតម្រាស់របស់ព្រះរាជាទាំង ៤ អង្គនោះ ក៏ទូលថា បពិត្រមហារាជ រឿងប្រកែកគ្នាអាស្រ័យសីលរបស់ទ្រង់ទាំងឡាយ

កើតហើយនោះ ទូលព្រះបង្គំដឹងបានដូចម្ដេចថារឿងនោះដូចម្ដេចខុស ដូចម្ដេចត្រូវ ដូច្នេះហើយទើបពោលគាថានេះថា

បណ្ឌិតណាជាអ្នកយល់សេចក្ដី បណ្ឌិតនោះរមែងពោលដោយឧបាយ នៃប្រាជ្ញាក្នុងកាលគួរក្នុងពាក្យជជែកនោះ បពិត្រព្រះអង្គជាធំជាងជនទាំងឡាយ ពួកជនអ្នកឈ្លាស គប្បីយល់នូវសេចក្ដីនៃពាក្យពោលដែលគេមិនទាន់និយាយ ដោយប្រការដូចម្ដេចបាន ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អត្ថទសា** សេចក្ដីថា ជាអ្នកឃើញអត្ថ ។ បទថា **តត្ថ កាលេ** សេចក្ដីថា ក្នុងកាលដែលដើមចោទនិងចុងចោទប្រាប់សេចក្ដីដែលទាស់ទែងគ្នានោះ កាលដែលគួរនិងមិនគួរ បណ្ឌិតទាំងឡាយកាលប្រាប់អត្ថនោះ រមែងពោលដោយឧបាយ ។ បទថា **អត្ថំ ឆយេយ្យុំ កុសលា** សេចក្ដីថា បពិត្រព្រះអង្គជាកំពូលនៃរាស្ត្រ បណ្ឌិតទាំងឡាយសូម្បីជាអ្នកឈ្លាសវៃបើដើមចោទនិងចុងចោទ មិនប្រាប់សេចក្ដីឲ្យជាក់ច្បាស់គប្បីពិចារណាសេចក្ដីនោះបានដូចម្ដេច ។ វិធុរបណ្ឌិតហៅព្រះរាជាទាំងឡាយថា **ជនិន្ទ** ។ ព្រោះដូច្នោះ សូមទ្រង់ត្រាស់សេចក្ដីនេះដល់ទូលព្រះបង្គំជាមុនហើយទូលបន្តថា

ស្ដេចនាគពោលដូចម្ដេច ស្ដេចគ្រុឌវេនតេយ្យពោលដូចម្ដេច ស្ដេចគន្ធព្វ ( ព្រះឥន្ទ ) ពោលដូចម្ដេច ស្ដេចដ៏ប្រសើររបស់អ្នកដែនកុរុពោលដូចម្ដេច ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **គន្ធព្វរាជា** វិធុរបណ្ឌិតពោលសំដៅយកសក្កទេវរាជ ។

លំដាប់នោះព្រះរាជាទាំង ៤ អង្គ បានត្រាស់គាថាតបនឹងព្រះមហាសត្វនោះថា

ស្ដេចនាគពោលចំពោះខន្តិធម៌តែម្យ៉ាង ស្ដេចគ្រុឌវេនតេយ្យ
ពោលចំពោះអាហារតិច ស្ដេចគន្ធព្វពោលចំពោះការលះបង់
សេចក្ដីត្រេកអរ ស្ដេចដ៏ប្រសើររបស់អ្នកដែនកុរុពោលចំពោះ
ការមិនមានកង្វល់ ដូច្នេះ ។

គប្បីជ្រាបពាក្យដែលជាគាថានោះដូចតទៅនេះថា នែបណ្ឌិត ស្ដេចនាគសរសើរអធិវាសនខន្តិ ពោលគឺការមិនក្រោធក្នុងបុគ្គលដែលគួរក្រោធ ស្ដេចគ្រុឌពោលសរសើរការមិនធ្វើអាក្រក់ព្រោះហេតុនៃអាហារ ពោលគឺការបរិភោគអាហារតិច សក្កទេវរាជទ្រង់សរសើរការលះសេចក្ដីត្រេកអរក្នុងកាមគុណ ៥ ព្រះបាទកុរុរដ្ឋទ្រង់សរសើរការមិនមានកង្វល់ ។

ព្រះមហាសត្វបានស្ដាប់រឿងរបស់ព្រះរាជាទាំង ៤ អង្គហើយទើបពោលគាថានេះថា

ពាក្យទាំងអស់នេះជាសុភាសិត ពាក្យជាទុព្ភាសិតសូម្បីបន្តិច
បន្តួចក៏មិនមានក្នុងប្រស្នានេះទេ ម្យ៉ាងទៀតពាក្យទាំងនេះតាំង
នៅស៊ប់ប្រជុំចុះដោយល្អ ក្នុងបុគ្គលណា ដូចជាកាំរទេះដែល
គេបញ្ចុះស៊ប់ក្នុងដុំ បណ្ឌិតទាំងឡាយ ហៅបុគ្គលដែលព្រម

ព្រៀងដោយធម៌ ៤ យ៉ាងនោះឯង ថាជាសមណៈក្នុងលោក ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឯតានិ** សេចក្ដីថា គុណជាតទាំង ៤ ប្រការនេះតាំងមាំល្អក្នុងបុគ្គលណា ដូចកាំរទេះរួមបញ្ចូលគ្នាត្រង់ដុំតែមួយដូច្នោះ បណ្ឌិតទាំងឡាយហៅបុគ្គលនោះដែលប្រកបដោយធម៌ទាំង ៤ ប្រការនេះថា ជាអ្នកស្ងប់រម្ងាប់ក្នុងលោកដូច្នោះ ។

ព្រះមហាសត្វបានធ្វើសីលរបស់ព្រះរាជាទាំង ៤ ឲ្យមានគុណស្មើគ្នាយ៉ាងនេះ ។

ព្រះរាជាទាំង ៤ បានស្ដាប់ដូច្នោះមានព្រះហឫទ័យត្រេកអរ កាលទ្រង់សរសើរព្រះមហាសត្វទើបពោលគាថានេះថា

អ្នកជាបុគ្គលប្រសើរ អ្នកជាបុគ្គលមិនមានអ្នកណាវិសេសជាង អ្នកជាបុគ្គលដល់នូវត្រើយនៃធម៌ ចេះដឹងនូវធម៌មានយោបល់ដ៏ល្អ កំណត់ដឹងនូវប្រស្នាដោយប្រាជ្ញា អ្នកជាអ្នកប្រាជ្ញបានផ្ដាច់សេចក្ដីសង្ស័យចេញហើយ អ្នកបានកាត់នូវសេចក្ដីសង្ស័យនិងសេចក្ដីងឿងឆ្ងល់ ដូចជាគេកាត់នូវក្ដុកនៃដំរីដោយរណារ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ត្វមនុត្តរោសិ** សេចក្ដីថា លោកជាបុគ្គលកំពូលមិនមានអ្នកដទៃប្រៀបឈ្មោះថា មិនមានអ្នកដទៃប្រៀបស្មើនឹងលោក ។ បទថា **ធម្មគូ** សេចក្ដីថា ជាអ្នករក្សានូវធម៌និងដឹងធម៌ ។ បទថា **ធម្មវិទូ**

សេចក្តីថា ជាអ្នកមានធម៌ដែលប្រាកដទូទៅហើយ ។ បទថា **សុមេធោ** សេចក្តីថា ជាអ្នកមានបញ្ញាល្អ ។ បទថា **បញ្ញាយ** សេចក្តីថា សិក្សាបញ្ហារបស់ពួកយើងយ៉ាងល្អ ដោយបញ្ញារបស់ខ្លួនហើយក៏ដឹងសេចក្តីពិតថា ក្នុងរឿងនេះមានហេតុយ៉ាងនេះ ។ បទថា **អច្ឆេជ្ជិ** សេចក្តីថា លោកជាអ្នកប្រាជ្ញ សូមកាត់សេចក្តីសង្ស័យរបស់ពួកយើង កាលកាត់យ៉ាងនេះសូមធ្វើពាក្យសំណូមពររបស់ពួកយើងនេះថា ចូរកាត់សេចក្តីសង្ស័យ គឺវិចិកិច្ឆារបស់ពួកយើងឲ្យដាច់ទៅក្នុងថ្ងៃនេះ ។ បទថា **ចុន្ទោ យថា នាគទន្តំ ខរេន** សេចក្តីថា ចូរអ្នកជួយកាត់នូវការសង្ស័យ ដូចជាងភ្លុកកាត់នូវភ្លុកដំរីដោយរណារដែលមានមុខដ៏មុតដូច្នោះ ។

ព្រះរាជាទាំង ៤ អង្គនោះកាលត្រាស់សរសើរព្រះមហាសត្វយ៉ាងនោះហើយ ទ្រង់ពេញព្រះហឫទ័យដោយព្យាករបញ្ហារបស់ព្រះមហាសត្វ លំដាប់នោះសក្កទេវរាជទ្រង់បូជាព្រះមហាសត្វ ដោយសំពត់ទុកូលពស្ត្រដែលជាទិព្វ ស្តេចគ្រុឌបូជាដោយផ្កាកម្រងមាស វរុណនាគរាជបូជាដោយកែវមណី ព្រះបាទធនញ្ជយៈបូជាដោយវត្ថុផ្សេងៗមានមេគោទឹកដោះ ១០០០ ជាដើម ព្រះរាជាទាំង ៤ អង្គនោះបានត្រាស់យ៉ាងនេះថា

បពិត្រអ្នកប្រាជ្ញ ខ្ញុំត្រេកអរនឹងការដោះនូវប្រស្នាហើយជូនសំពត់នេះ មានពន្លឺដូចផ្កាឧប្បលខៀវ មិនមានមន្ទិល ជាសំពត់កាត់ថ្លៃមិនបាន មានពណ៌ស្មើដោយផ្សែងដើម្បីបូជានូវធម៌របស់អ្នក ។

បពិត្រអ្នកប្រាជ្ញ ខ្ញុំត្រេកអរនឹងការដោះនូវប្រស្នាហើយជូននូវកម្រងផ្កាមាស ដែលរីកសំពោងដោយត្របកច្រើនស្រទាប់ ប្រកបដោយលម្អងដ៏ប្រដាប់ដោយកែវដ៏ច្រើន ដើម្បីបូជានូវធម៌របស់អ្នក ។

បពិត្រអ្នកប្រាជ្ញ ខ្ញុំត្រេកអរនឹងការដោះស្រាយ នូវប្រស្នាហើយជូននូវកែវមណី ដែលកាត់ថ្លៃមិនបាន ជាកែវដ៏រុងរឿងមានពន្លឺផ្លេក ៗ សម្រាប់ពាក់ឰដ៏កដែលស្អិតស្អាងដោយកែវមណីដើម្បីបូជានូវធម៌របស់អ្នក ។

ខ្ញុំត្រេកអរនឹងការដោះស្រាយនូវប្រស្នា ហើយជូននូវគោមួយពាន់ទាំងគោឧសភផង ដំរីផង រថ ១០ ដែលទឹមដោយសេះអាជានេយ្យនេះផង ស្រុកសួយ ១៦ ផងដល់អ្នក ។

ព្រះរាជាទាំង ៤ អង្គ មានសក្កទេវរាជជាដើម កាលទ្រង់បូជាព្រះមហាសត្វហើយបានយាងទៅកាន់ទីលំនៅរបស់ព្រះអង្គវិញដោយប្រការដូច្នេះ ។

**ចតុបោសថកណ្ឌ ចប់**

បណ្តាព្រះរាជា ៤ ព្រះអង្គនោះ ស្តេចនាគមានព្រះជាយាឈ្មោះថា ព្រះនាងវិមលាទេវី ។ ព្រះនាងកាលមិនឃើញគ្រឿងប្រដាប់ គឺកែវមណីដែលពាក់ត្រង់កស្តេចនាគក៏ទូលសួរថា កែវមណីរបស់ព្រះអង្គបាត់ទៅណា ស្តេចនាគឆ្លើយថា អញបានស្តាប់ធម្មកថារបស់វិធុរបណ្ឌិត កូនរបស់ចន្ទព្រាហ្មណ៍

មានចិត្តជ្រះថ្លាទើបបូជាកែវមណី មិនមែនបូជាតែអញម្នាក់ប៉ុណ្ណោះទេ សូម្បីសក្កទេវរាជក៏ទ្រង់បូជាដោយទុកូលពស្ត្រដែលជាទិព្វ ស្ដេចគ្រុឌបូជាដោយកម្រងផ្កាមាស ព្រះបាទធនញ្ជយៈបូជាដោយវត្ថុផ្សេងៗ មានមេគោទឹកដោះ ១០០០ ជាដើម ។ នាងវិមលាទូលសួរថា វិធុរបណ្ឌិតនោះជាធម្មកថិកឬ ។ ស្ដេចនាគពោលគុណរបស់វិធុរបណ្ឌិតថា នែនាង នាងនិយាយអ្វីស្ដេច ១០១ ក្នុងជម្ពូទ្វីបទាំងមូលសុទ្ធតែពេញព្រះហឫទ័យក្នុងធម្មកថាដ៏ពីរោះរបស់លោក ដូចកាលកើតឡើងនៃព្រះពុទ្ធ ប្រព្រឹត្តទៅក្នុងជម្ពូទ្វីបទាំងមូល រហូតមិនយាន្តរូបទៅកាន់ដែនវៀងៗខ្លួន ដូចខ្សែពិណឈ្មោះហត្ថិកន្តៈ លួងលោមដំរីចុះប្រេងឲ្យប្រាថ្នា លោកជាធម្មកថិកឯកសម្ដែងធម៌ដ៏ពីរោះជាប់ចិត្តក្រៃលែង ។ ព្រះនាងបានស្ដាប់គុណកថានៃវិធុរបណ្ឌិត ប្រាថ្នានឹងស្ដាប់ធម្មកថារបស់លោក ទើបព្រះនាងព្រះតម្រិះថា បើអញទូលថា ខ្ញុំម្ចាស់ប្រាថ្នាស្ដាប់ធម្មកថារបស់វិធុរបណ្ឌិត សូមទ្រង់អញ្ជើញលោកមកក្នុងនាគពិភព ដូច្នេះទ្រង់នឹងមិនអញ្ជើញមកឲ្យអញ ណ្ហើយចុះអញគួរពុតធ្វើជាឈឺថា ខ្ញុំម្ចាស់ចាញ់គភ៌បង់បានដួងហឫទ័យរបស់វិធុរបណ្ឌិតនោះ កាលធ្វើយ៉ាងនោះហើយ ឲ្យសញ្ញាដល់ស្រីស្នំ ទើបយាងចូលទៅផ្ទំក្នុងព្រះទែនដ៏ប្រកបដោយសិរី ។ ស្ដេចនាគកាលមិនឃើញព្រះនាងវិមលាទៅក្នុងគ្រាចូលគាល់ ទើបត្រាស់សួរថា ព្រះនាងវិមលាទៅណា កាលស្រីស្នំក្រាបទូលថា ព្រះនាងប្រឈួនទើបទ្រង់ក្រោកចាករាជអាសនៈ ចូលទៅកាន់សម្នាក់នាងវិមលានោះ ប្រឋាប់គង់ចំហៀងព្រះទែន ស្ទាបសរីរកាយរបស់ព្រះនាងត្រាស់គាថាទី ១ ថា

នាងមានសម្បុរល្អៀង ស្គាំងស្គម មានកម្លាំងតិច ពីដើមរូប
សម្បុររបស់នាងមិនមែនបែបនេះទេ ម្នាលនាងវិមលា ខ្ញុំសួរ
ហើយនាងចូរប្រាប់ តើវេទនាក្នុងសរីរៈរបស់នាងដូចម្តេច
ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បណ្ឌុ** បានដល់ មានពណ៌សម្បុរដូចស្លឹកឈើទុំ ។ បទថា **កីសិយា** ប្រែថា ស្គាំងស្គម ។ បទថា **ទុព្វលា** បានដល់ មានកម្លាំងតិច ។ បទថា **វណ្ណរូបំ ន តវេទិសំ បុរេ** សេចក្តីថា រូប ពោលគឺវណ្ណៈនៃនាងមិនដូចអំពីមុនឡើយ គឺក្នុងកាលមុនមិនមានទោស មិនសៅហ្មងតែឥឡូវនេះរូបនោះបានប្រែប្រួលទៅ មានការៈមិនជាទីត្រេកអរឡើយ ។ ស្តេចនាគត្រាស់ហៅព្រះនាងវិមលាទេវីថា **វិមលេ** ដូច្នេះ ។

លំដាប់នោះព្រះនាងវិមលាទេវីកាលប្រាប់សេចក្តីនោះដល់ស្តេចនាគទើបពោលគាថាទី ២ ថា

បពិត្រព្រះអង្គជាធំជាងនាគជន ទំនៀមរបស់ស្ត្រីទាំងឡាយ
ក្នុងពួកមនុស្ស ( ដែលមានគភ៌ ) គេហៅថា ចំណង់ប្លែក
បពិត្រព្រះអង្គជាកុញ្ជររបស់នាគ ខ្ញុំម្ចាស់ចង់បានដួងហឫទ័យ
របស់វិធុរបណ្ឌិត ដែលត្រូវនាំយកមកដោយធម៌ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ធម្មោ** បានដល់ សភាវៈ ។ បទថា **មាតីនំ** បានដល់ របស់ស្រីទាំងឡាយ ។ បទថា **ជនិន្ទ** បានដល់ ជាធំជាងពួកនាគ ។ បទថា **ធម្មាហដំ នាគកុញ្ជរ វិធុរស្ស ហទយាភិបត្ថយេ** សេចក្តី

ថា បពិត្រនាគដ៏ប្រសើរ ខ្ញុំចង់បានបេះដូងរបស់វិធុរបណ្ឌិតដែលទ្រង់នាំមកបានដោយធម៌មិនមែនដោយកម្មដែលឃោរឃៅ ជីវិតរបស់ខ្ញុំនឹងទ្រទ្រង់នៅបាន បើមិនបានសោតខ្ញុំប្រហែលជាមរណៈក្នុងទីនេះឯង ព្រះនាងមានសវនីយ៍យ៉ាងនោះសំដៅដល់បញ្ញារបស់វិធុរបណ្ឌិតនោះ ។

ស្ដេចនាគបានស្ដាប់ដូច្នោះ ទើបត្រាស់ថា

ម្នាលនាងវិមលា នាងចង់បាន ( ដួងហឫទ័យរបស់វិធុរបណ្ឌិតនោះដូចបុគ្គលប្រាថ្នា ) ព្រះចន្ទ ព្រះអាទិត្យ ឬព្រះពាយព្រោះថា ការជួបប្រទះនឹងវិធុរបណ្ឌិតគេគប្បីបានដោយក្រ នរណានឹងនាំព្រះវិធុរបណ្ឌិតមកក្នុងពិភពនាគនេះបាន ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ទុល្លភំ ហិ វិធុរស្ស ទស្សនំ** សេចក្ដីថា ការឃើញវិធុរបណ្ឌិតដែលមានសំឡេងពីរោះ មិនមានបុគ្គលស្មើនោះជាការកម្រក្រៃលែង ដ្បិតថាព្រះរាជាក្នុងជម្ពូទ្វីបទាំងមូលទ្រង់រៀបចំការរក្សាការពារវិធុរបណ្ឌិតយ៉ាងតឹងរ៉ឹងប្រកបដោយធម៌ បុគ្គលណាមួយក៏ឃើញមិនបាន អ្នកណានឹងនាំវិធុរបណ្ឌិតនោះមកឋាននាគនេះបាន ។

ព្រះនាងវិមលាទេវីស្ដាប់ព្រះស្វាមីដូច្នោះក៏ទូលថា បើខ្ញុំម្ចាស់មិនបាននឹងស្លាប់ក្នុងទីនេះឯងហើយបែរព្រះកក្ដ្រឲ្យខ្នងដល់ព្រះស្វាមី យកជាយព្រះភូសាបិទព្រះកក្ត្រផ្ទំស្ងៀម ។ ស្ដេចនាគយាងទៅកាន់បន្ទប់ ដែលប្រកបដោយសិរីរបស់ទ្រង់ ប្រថាប់គង់លើព្រះទែនបន្ទំទ្រង់គិតថា ព្រះនាងវិមលាទេវីឲ្យយកសាច់ហទយៈរបស់វិធុរបណ្ឌិតមកឲ្យ ទើបទ្រង់ព្រះតម្រិះថា កាលព្រះនាង

វិមលាមិនបានហទយៈវិធុរបណ្ឌិតជីវិតរបស់នាងមិនមាន អញនឹងធ្វើដូចម្ដេចហ្ន៎ ទើបអញបានសាច់ហទយៈរបស់វិធុរបណ្ឌិតនោះ ។

លំដាប់នោះនាគកញ្ញាឈ្មោះឥរន្ទតី ដែលជាធីតារបស់ស្ដេចនាគនោះ ប្រដាប់ដោយគ្រឿងអលង្ការសព្វយ៉ាង មកកាន់ទីគាល់របស់ព្រះបិតាដោយសិរីវិលាសធំ ថ្វាយបង្គំព្រះបិតាហើយឈរក្នុងទីសមគួរនាចំណែកម្ខាងឃើញព្រះឥន្ទ្រិយព្រះបិតាខុសប្រក្រតីទើបទូលថា បពិត្រព្រះបិតា មើលទៅទ្រង់ហាក់ដូចជាស្រពាប់ស្រពោនព្រះហឫទ័យក្រៃលែង តើព្រោះហេតុអ្វីហ្ន៎ ដូច្នេះហើយទើបត្រាស់គាថានេះថា

បពិត្របិតា ហេតុអ្វីហ្ន៎ព្រះអង្គសញ្ជប់សញ្ជឹង ព្រះភក្ត្ររបស់ព្រះអង្គដូចជាផ្កាឈូកដែលគេឈ្លីដោយដៃ បពិត្រព្រះអង្គជាឥស្សរៈ ព្រះអង្គតូចព្រះហឫទ័យដូចម្ដេច បពិត្រព្រះអង្គអ្នកញ៉ាំងសត្រូវឲ្យក្ដៅ សូមព្រះអង្គកុំទ្រង់សោយសោកឡើយដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បជ្ឈាយសិ** បានដល់ សញ្ជប់សញ្ជឹង ។ បទថា **ហត្ថគតំ** សេចក្ដីថា ព្រះភក្ត្ររបស់ទ្រង់ ដូចផ្កាឈូកដែលច្របាច់ដោយដៃ ។ បទថា **ឥស្សរ** សេចក្ដីថា បពិត្របិតាជាធំក្នុងនាគមណ្ឌលដែលមានប្រមាណ ៥០០ យោជន៍ ។

ស្ដេចនាគទ្រង់ស្ដាប់ពាក្យព្រះរាជធីតាកាលទ្រង់ប្រាប់រឿងនោះទើបត្រាស់ព្រះគាថានេះថា

ម្នាលនាងឥរន្ទតី មាតារបស់នាង ចង់បានហឫទ័យរបស់វិធុរ

បណ្ឌិត តែការជួបប្រទះនឹងវិធុរបណ្ឌិត គេគប្បីបានដោយក្រ

នរណានឹងនាំវិធុរបណ្ឌិតមកក្នុងពិភពនាគនេះបាន ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ធនិយ្យតិ** បានដល់ រមែងប្រាថ្នា ។ លំដាប់នោះស្ដេចនាគក៏ត្រាស់នឹងនាងថា នៃកូនស្រី បុគ្គលដែលអាចនាំវិធុរបណ្ឌិតមកក្នុងសម្នាក់របស់យើងបានក៏មិនមាន ចូរនាងឲ្យជីវិតដល់មាតាចុះ ចូរនាងទៅស្វែងរកកស្ដាដែលអាចនាំដួងហទយៈរបស់វិធុរបណ្ឌិតមកឲ្យបាន កាលបញ្ជូនធីតាទៅទើបត្រាស់កន្លះគាថានេះថា

កស្ដាណានាំវិធុរបណ្ឌិតមកក្នុងទីនេះបាន នាងចូរត្រាច់ទៅស្វែង

រកកស្ដានោះចុះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ចរ** បានដល់ ចូរត្រាច់ទៅ ។

ស្ដេចនាគបានត្រាស់ពាក្យដែលមិនសមគួរដល់ធីតា ព្រោះត្រូវកិលេសគ្របសង្កត់ដោយប្រការដូច្នេះ ព្រោះហេតុនោះទើបព្រះសាស្ដាត្រាស់ថា

នាងឥរន្ទតីនោះ លុះបានស្ដាប់បន្ទូលព្រះបិតាហើយក៏ចេញទៅ

ក្នុងវេលារាត្រី ជាស្រីជោកជាំ ( ដោយរាគៈ ) បានត្រាច់ទៅ

( ស្វែងរកព្រះកស្ដា ) ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អវស្សុតី ចរិ** សេចក្ដីថា ម្នាលភិក្ខុទាំងឡាយ នាគមាណវិកានោះ បានស្ដាប់ពាក្យព្រះបិតាហើយ ទើបលួងលោមព្រះបិតាឲ្យស្បើយព្រះហឫទ័យ ហើយទៅកាន់សម្នាក់ព្រះមាតាលួងលោមឲ្យ

ជូរស្បៀយហើយទៅកាន់បន្ទប់ដែលប្រកបដោយសិរីរបស់ខ្លួន ប្រដាប់តាក់តែងគ្រឿងអលង្ការ ស្លៀកសំពត់ពណ៌ដកតាំមួយផ្ទាំង ធ្វើចៀងស្មាមួយផ្ទាំង ធ្វើទឹកឲ្យបែកជា ២ ចំណែក ចេញអំពីនាគពិភពក្នុងរាត្រីនោះឯងហោះទៅកាន់កាឡគិរីបព៌តដែលជាភ្នំតាន់ មានពណ៌ដូចផ្កាអញ្ជ័ន កម្ពស់ ៦០ យោជន៍ តាំងនៅក្បែរឆ្នេរសមុទ្រក្នុងហិមវន្តប្បទេស ជាអ្នកមានចិត្តជោកជាំដោយរាគៈ គឺជាអ្នកមានចិត្តជោកជាំ ដោយអំណាចកិលេស បានត្រាច់ចរស្វែងរកកស្តាហើយ ។

ព្រះនាងឥរន្ទតីនាគកញ្ញានោះបេះផ្កាក្នុងហិមវន្តប្បទេសនោះ ដែលសម្បូរដោយពណ៌និងក្លិនមកតាក់តែងកំពូលភ្នំទាំងមូលឲ្យដូចជាភ្នំកែវមណី ក្រាលផ្កាខាងលើបព៌តនោះ ច្រៀងរាំដោយអាកប្បកិរិយាល្វតល្វន់និងដោយសំឡេងដ៏ពីរោះហើយពោលគាថាទី ៧ ថា

> នរណាទោះជាគន្ធព្វក្តី នរណាទោះជាអារក្សទឹក ឬជានាគក្តី
> នរណា ទោះជាកិន្នរឬជាមនុស្សក្តី នរណាទោះជាបណ្ឌិតដែល
> ឲ្យសេចក្តីប្រាថ្នាទាំងពួងក្តី អ្នកនោះ នឹងជាកស្តារបស់ខ្ញុំអស់
> កាលមានរាត្រីដ៏វែង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កោ គន្ធព្វោ រក្ខសោ ច នាគោ** សេចក្តីថា គន្ធព្វ អារក្ខ ឬនាគក៏ដោយ ។ បទថា **កោ បណ្ឌិតោ សព្វកាមទទោ** សេចក្តីថា ក្នុងបណ្តាគន្ធព្វជាដើមនោះ បុគ្គលណាជាអ្នកឈ្លាសអាចឲ្យនូវសម្បត្តិដែលគួរប្រាថ្នាគ្រប់យ៉ាង កាលទាំមនោរថរបស់មាតាខ្ញុំដែលប្រាថ្នាដួងហទយៈ

របស់វិធុរបណ្ឌិតមក បុគ្គលនោះនឹងបានជាកស្តាររបស់ខ្ញុំអស់កាលយូរ ។

ខណៈនោះបុណ្ណកយក្ខសេនាបតី ដែលជាក្មួយរបស់វេស្សវណ្ណមហារាជ ផែលសេះមនោម័យសិន្ធព កម្ពស់ប្រមាណ ៣ គាវុតហោះទៅកាន់យក្ខសមាគមត្រង់ផ្ទៃមនោសិលាលើកំពូលភ្នំកាឡគិរីបព៌ត បានឮសំឡេងច្រៀងរបស់នាងឥរន្ទតីនាគកញ្ញានោះ ។ សំឡេងច្រៀងរបស់នាងឥរន្ទតី បានមុតស្បែកសាច់របស់បុណ្ណកយក្ខចូលទៅដល់ខួរក្នុងឆ្អឹង ព្រោះធ្លាប់នៅរួមគ្នាក្នុងអត្តភាពមុន បុណ្ណកយក្ខនោះមានចិត្តប្រតិព័ទ្ធទាញសេះត្រឡប់ អង្គុយលើខ្នងសេះសិន្ធពនោះឯងលួងលោមនាងឲ្យត្រេកអរថា ម្នាលប្អូនស្រី ខ្ញុំជាអ្នកអាចនាំដួងហទយៈ របស់វិធុរបណ្ឌិតមកឲ្យបានដោយធម៌ តាមបញ្ញារបស់ខ្ញុំ នាងកុំគិតថ្វីឡើយហើយពោលគាថាទី ៨ ថា

ម្នាលនាងមានភ្នែកគេតិះដៀលមិនបាន នាងចូរដកដង្ហើមស្រួល
( ត្រេកអរ ) ចុះ ខ្ញុំនឹងជាប្តីរបស់នាង នឹងជាកស្តាររបស់នាង
ដោយសារបញ្ញារបស់ខ្ញុំមានសភាពដូច្នោះ នាងចូរដកដង្ហើម
ស្រួលចុះ នាងនឹងជាភរិយារបស់ខ្ញុំ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អនិន្ទលោចនេ** បានដល់ ជាអ្នកមានភ្នែកល្អដែលគេតិះដៀលមិនបាន ។ បទថា **តថាវិធាហំ** សេចក្តីថា ដែលអាចនាំមកនូវសាច់ហទយៈរបស់វិធុរបណ្ឌិតមកបាន ។ បទថា **អស្សាស** សេចក្តីថា ចូរនាងត្រេកអរ ធូរស្បើយ មានចិត្តត្រេកអរចុះ ។ បទថា **ហេស្សសិ** សេចក្តីថា នាងនឹងជា ( ភរិយារបស់ខ្ញុំ ) ។

ព្រោះហេតុនោះទើបព្រះសាស្តាត្រាស់ថា

នាងឥរន្ទតី ក៏មានចិត្តក្ងួចកាន់តាមគន្ធងដែលធ្លាប់ជាប្តីក្នុងជាតិមុនបាននិយាយនឹងបុណ្ណកយក្សថា អ្នកចូរមកយើងនឹងនាំគ្នាទៅឯសំណាក់បិតាខ្ញុំ បិតានោះនឹងប្រាប់សេចក្តីនុ៎ះ ដល់អ្នកដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បុព្វបថានុគតេន ចេតសា** សេចក្តីថា នាងមានចិត្តត្រេកអរ ស្រឡាញ់បុណ្ណកយក្ខនោះ ព្រោះធ្លាប់ជាស្វាមីក្នុងអត្តភាពមុនព្រោះធ្លាប់រួមអភិរមក្នុងកាលមុននោះឯង ។ បទថា **ឯហិ គច្ឆាម** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ បុណ្ណកយក្ខសេនាបតីនោះ កាលពោលយ៉ាងនេះហើយក៏គិតថា អញនឹងបីនាងដាក់លើខ្នងសេះនាំទៅ ហើយចុះពីលើកំពូលបពិតក៏លាដៃចាប់នាងឥរន្ទតីនោះ ឯនាងឥរន្ទតីមិនឲ្យចាប់ដៃរបស់ខ្លួនតែចាប់ដៃបុណ្ណកយក្ខ ដែលលាមកនោះឯងហើយពោលថា នៃលោក ខ្ញុំមិនមែនមនុស្សឥតទីពឹង ស្តេចនាគឈ្មោះថាវរុណជាបិតារបស់ខ្ញុំ ព្រះនាងវិមលាទេវីជាមាតារបស់ខ្ញុំ មកខ្ញុំនឹងនាំលោកទៅកាន់សម្នាក់បិតារបស់ខ្ញុំ យើងទាំង ២ គួរធ្វើមង្គលដោយប្រការណា ទ្រង់នឹងត្រាស់ប្រាប់សេចក្តីនោះ ដោយប្រការនោះ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសានូវព្រះគាថាដូច្នេះថា

នាងឥរន្ទតីតាក់តែងខ្លួនស្លៀកដណ្តប់ល្អ ទ្រង់កម្រងផ្កា ប្រោះព្រំដោយខ្លឹមចន្ទន៍ ចាប់ដៃបុណ្ណកយក្សនាំចូលទៅកាន់សំណាក់បិតា ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បិតុ សន្តិកមុបាគមិ** សេចក្តីថា ចូលទៅកាន់សម្នាក់ព្រះបិតា ។ ឯបុណ្ណកយក្ខទៅកាន់សម្នាក់ស្តេចនាគ កាលទូលសូមនាងឥរន្ទតីក៏ទូលថា

បពិត្រព្រះអង្គ ប្រសើរជាងពួកនាគ សូមព្រះអង្គទ្រង់ព្រះសណ្តាប់ពាក្យរបស់ខ្ញុំព្រះអង្គ សូមព្រះអង្គទ្រង់ទទួលស្នួយដ៏សមគួរ ( ដល់ត្រកូលនិងប្រទេសរបស់ព្រះអង្គ ) ខ្ញុំព្រះអង្គចង់បាននាងឥរន្ទតី សូមព្រះអង្គធ្វើខ្ញុំព្រះអង្គឲ្យមូលមិត្តជាមួយនឹងនាងឥរន្ទតីនោះ ។ បពិត្រព្រះអង្គដ៏ប្រសើរ សូមព្រះអង្គទ្រង់ទទួលនូវស្នួយទាំងនោះ គឺដំរី ១០០ សេះ ១០០ រថទឹមដោយសេះអស្សតរ ១០០ និងរទេះដែលផ្ទុកពេញដោយរតនវត្ថុផ្សេងៗទាំងអស់ ១០០ សូមព្រះអង្គទ្រង់ព្រះរាជទានធីតាឈ្មោះនាងឥរន្ទតីឲ្យទាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សុណោហិ** សេចក្តីថា សូមទ្រង់បដិបត្តិ គឺសូមទ្រង់ទទួលយកទ្រព្យ គឺបណ្ណាការដើម្បីព្រះរាជធីតា តាមសមគួរដល់ត្រកូលនិងប្រទេសរបស់ទ្រង់ចុះ ។ បទថា **តាយ សមង្គឹ ករោហិ មំ តុវំ** សេចក្តីថា សូមទ្រង់ធ្វើខ្ញុំឲ្យជាអ្នកនៅរួមជាមួយនាងឥរន្ទតីរាជធីតានោះចុះ ។

បទថា **វលភិយោ** បានដល់ រទេះដែលពេញដោយទ្រព្យ ។ បទថា **ឆា-ឆារត្តស្ស កោវលា** សេចក្ដីថា សុទ្ធតែពេញដោយរតនៈច្រើនប្រភេទ ។

លំដាប់នោះស្ដេចនាគក៏ត្រាស់នឹងបុណ្ណកយក្ខនោះដោយគាថានេះថា

អ្នកចូរផងចាំយើងប្រឹក្សានឹងពួកញាតិមិត្ត ឬសម្លាញ់ដ៏ស្និទ្ធ

ស្នាលសិន អំពើដែលយើងធ្វើដោយមិនបានប្រឹក្សាណា អំពើ

នោះរមែងក្ដៅក្រហាយក្នុងកាលខាងក្រោយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **យាវ អាមន្តយេ** សេចក្ដីថា នែយក្ខសេនាបតីដ៏ចម្រើន យើងនឹងឲ្យធីតាដល់លោកឬមិនឲ្យក៏មិនមែន តែសូមលោកបង្អង់សិន យើងនឹងពិភាក្សា ជាមួយពួកញាតិមិត្តនិងមិត្តសម្លាញ់ស្និទ្ធស្នាលជាមុនសិន ។ បទថា **តំ បច្ឆា អនុតប្បតិ** សេចក្ដីថា ស្ដេចវរុណនាគរាជពោលថា ព្រោះថាស្រីទាំងឡាយជូនកាលក៏ត្រេកអរស្រឡាញ់ ជូនកាលក៏មិនត្រេកអរ កម្មដែលយើងធ្វើដោយមិនបានប្រឹក្សាក្នុងកាលដែលគេមិនត្រេកអរ ញាតិនិងមិត្តនិងសម្លាញ់ជិតស្និទ្ធរមែងមិនជួយខ្វល់ខ្វាយដោយហេតុ គឺកម្មដែលយើងធ្វើដោយមិនប្រឹក្សាជាមួយគេ ដូច្នេះកម្មនោះរមែងនាំមកនូវការក្ដៅក្រហាយក្នុងកាលជាក្រោយ ។

លំដាប់នោះវរុណនាគនោះចូលទៅកាន់លំនៅហើយប្រឹក្សានឹង

កិរិយាហើយពោលពាក្យនេះថា បុណ្ណកយក្សនេះសូមនាងឥរន្ទតី

នឹងយើង យើងនឹងឲ្យនាងឥរន្ទតី ជាទីស្រឡាញ់របស់យើង

ដល់បុណ្ណកយក្សនោះ ដោយការបានវត្ថុជាទីត្រេកអរច្រើនជាថ្នូរ

ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បរិសិត្វា** សេចក្តីថា ឲ្យបុណ្ណកយក្ខឲ្យនៅក្នុងទីនោះឯង ទ្រង់ក៏ក្រោកឡើងយាងចូលទៅកាន់ព្រះរាជនិវេសន៍ដែលព្រះជាយាផ្ទំមួយរំពេច ។ បទថា **បិយំ មម** សេចក្តីថា ទ្រង់ត្រាស់សួរថា យើងនឹងឲ្យធីតាដែលជាទីស្រឡាញ់របស់យើងដល់យក្ខនោះដោយបានទ្រព្យជាគ្រឿងត្រេកអរនៃចិត្តជាច្រើនឬ ។

ព្រះនាងវិមលាទេវីត្រាស់ថា

*បុណ្ណកយក្សមិនត្រូវបាននាងឥរន្ទតីជាធីតារបស់យើង ដោយទ្រព្យ មិនត្រូវបានដោយវត្ថុជាទីត្រេកអរទេតែបើបុណ្ណកយក្សបានហឫទ័យរបស់បណ្ឌិត ដោយធម៌ហើយនាំមកក្នុងពិភពនាគនេះទើបត្រូវបាននាងកុមារីដោយសារវត្ថុជាទីត្រេកអរនុ៎ះ យើងមិនចង់បានទ្រព្យដទៃតទៅទៀតទេ ដូច្នេះ ។*

បណ្តាបទទាំងនោះ បទថា **អម្ហំ ឥរន្ទតី** សេចក្តីថា ឥរន្ទតីធីតានៃយើង ។ បទថា **ឯតេន វិត្តេន** សេចក្តីថា ដោយអាការដែលត្រេកអរនោះឯង ។

*លំដាប់នោះវរុណនាគនោះ ចេញអំពីលំនៅហៅបុណ្ណកយក្សមកនិយាយពាក្យនេះថា អ្នកមិនត្រូវបាននាងឥរន្ទតីជាធីតារបស់យើងដោយទ្រព្យ មិនត្រូវបានដោយវត្ថុជាទីត្រេកអរជាថ្នូរទេ បើអ្នកបានហឫទ័យ របស់បណ្ឌិតដោយធម៌ ហើយនាំមកក្នុង*

ពិភពនាគនេះ ទើបអ្នកត្រូវបាននាងកុមារី ដោយសារវត្ថុជាទី
ត្រេកអរទ្រុំះ យើងមិនចង់បានទ្រព្យដទៃតទៅទៀតទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បុណ្ណកាមន្តយិត្វាន** បានដល់ ហៅបុណ្ណ-
កយក្ខមក ។

បុណ្ណកយក្ខទូលថា

បពិត្រព្រះអង្គដ៏ប្រសើរ បុគ្គលពួកខ្លះក្នុងលោកនេះហៅមនុស្ស
ណាថាជាបណ្ឌិត បុគ្គលឯទៀតបែរជាហៅបុគ្គលនោះថាជា
ពាលវិញ ពួកជនតែងជជែកគ្នាក្នុងរឿងនេះ សូមព្រះអង្គត្រាស់
ប្រាប់ដល់ខ្ញុំព្រះអង្គឲ្យទាន បពិត្រនាគ ព្រះអង្គត្រាស់ហៅអ្នក
ណាថាជាបណ្ឌិត ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យំ បណ្ឌិតោតេ្យកេ** សេចក្តីថា បានឮថា
បុណ្ណកយក្ខបានស្តាប់ពាក្យថា ហឫទ័យរបស់បណ្ឌិតដូច្នេះគិតថា បុគ្គលខ្លះ
ហៅមនុស្សខ្លះថាជាបណ្ឌិត តែមនុស្សពួកដទៃហៅបុគ្គលនោះឯងថាជាពាល
សូម្បីនាងឥរន្ទតីក៏ប្រាប់យើងថា វិធុរបណ្ឌិតដោយពិត តែទោះជាយ៉ាងនោះ
អញនឹងទូលសួរព្រះរាជាឲ្យជាក់ច្បាស់ជាងនោះ ព្រោះហេតុនោះ ទើបបាន
ពោលយ៉ាងនោះ ។

ស្តេចនាគត្រាស់ថា

អាមាត្យឈ្មោះវិធុរៈរបស់ធនញ្ជយកោរព្យរាជ អ្នកក៏ធ្លាប់បាន
ឮហើយ បើអ្នកបានបណ្ឌិតនោះដោយធម៌ហើយនាំមក នាង

ឥវន្ទតីចូរបានជាអ្នកបម្រើជើងរបស់អ្នកចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ធម្មលទ្ធា** បានដល់ បានមកហើយដោយធម៌ ។ បទថា **បទចារី** បានដល់ ជាស្រីបម្រើ ។

ចំណែកបុណ្ណកយក្ស លុះបានស្តាប់ព្រះបន្ទូលរបស់វរុណនាគនេះហើយ ក៏ក្រោកឡើង ត្រេកអរក្រៃលែងហើយសម្ងំនៅក្នុងទីនោះបង្គាប់បុរស ( អ្នកបម្រើរបស់ខ្លួន ) ថា អ្នកចូរនាំសេះអាជានេយ្យដែលបានសម្រិតសម្រាំងយកមកក្នុងទីនេះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អសំសិ** បានដល់ ប្រាប់ដល់អ្នកបម្រើនៃខ្លួន ។ បទថា **អាជញ្ញំ** បានដល់ សេះសិន្ធពជាអ្នកដឹងហេតុនិងមិនមែនហេតុ ។ បទថា **យុត្តំ** បានដល់ ប្រកបស្រេចហើយ ។

( បុរាណាចារ្យពោលពណ៌នាសេះសិន្ធពនោះទុកថា )

ត្រចៀក ( របស់សេះនោះ ) ប្រដាប់ដោយមាស ក្រចកប្រដាប់ដោយកែវមណីមានពណ៌ក្រហម គ្រឿងបិទបាំងទ្រូងដ៏ទ្រូងប្រដាប់ដោយមាសឆ្អិនឈ្មោះជម្ពោនទ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ជាតរូបមយា** សេចក្តីថា កាលនឹងពោលពណ៌នាសេះសិន្ធពនោះឯង ទើបពោលយ៉ាងនោះ ពិតហើយសេះសិន្ធពមនោម័យមានត្រចៀកទាំង ២ សម្រេចហើយដោយមាស ។ បទថា **កាចម្ហិចមយា ខុរា** សេចក្តីថា សេះសិន្ធពនោះមានក្រចកសម្រេចដោយកែវមណីក្រហម ។ បទថា **ជម្ពោនទស្ស ចាកស្ស** សេចក្តីថា មានគ្រឿង

ប្រដាប់ទ្រូងសម្រេចដោយមាសជម្ពូនទ មានពណ៌ក្រហមធ្លិនធ្លៅ ។

បុរសអ្នកបម្រើនោះនាំសេះសិន្ធពមកក្នុងខណៈនោះឯង បុណ្ណកយក្សឡើងផែលសេះសិន្ធពអាជានេយ្យនោះ ហោះទៅកាន់សម្នាក់របស់ព្រះបាទវេស្សវណ្ណ តាមអាកាសហើយពណ៌នាកពនៃនាគប្រាប់រឿងនោះ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** វីអាចិធមិឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសានូវព្រះគាថាដូច្នេះថា

បុណ្ណកយក្សតាក់តែងខ្លួន កាត់កោរសក់និងពុកមាត់ស្រេច
ហើយក៏ឡើងជិះសេះដែលជាយាន ដូចជាពាហនៈនៃទេវតា
ហោះទៅតួដ៏អាកាសវេហា ។ បុណ្ណកយក្សនោះ ជាប់ចំពាក់
ដោយកាមរាគ ប្រាថ្នានាងឥរន្ទតីជាកញ្ញានៃនាគ បានទៅក្រាប
ទូលព្រះបាទវេស្សវណកុវេរៈដ៏ទ្រង់យស ជាម្ចាស់ពួកយក្ស
នោះដូច្នេះថា មន្ទីរឈ្មោះភោគវតី គេហៅថា វាសៈ ( ព្រោះ
ជាលំនៅនៃស្តេចនាគ ) គេហៅថា ហិរញ្ញវតី ( ព្រោះជាទីដែល
បិទបាំងដោយកំពែងប្រាក់ ) ជានគរសម្រេចអំពីមាស ដែល
សាងសម្រេចដល់នាគមានមណ្ឌលនៃភ្នែន ។ បមមានសណ្ឋាន
ដូចកអូដ្ឋ ធ្វើអំពីកែវមណីក្រហមនិងកែវមរកត ប្រាសាទក្នុង
ពិកពនាគធ្វើអំពីកែវមណីប្រក់ដោយរតនៈ គឺមាស ។ ដើម
ឈើទាំងឡាយ គឺដើមស្វាយ ដើមទ្រមួច ដើមព្រីង ដើមសត្ត

បណ្ណ ( ឈើមានសន្ទឹក ៧ ) ដើមរាំងអន្ទក់ ដើមកេតក៍ ដើមបិយង្គុ ដើមរាជព្រឹក្ស ព្រមទាំងដើមបារិច្ឆត្តព្រឹក្ស ដើមឈើទាលខ្យាច់ ( មានក្នុងពិភពនាគនោះ ) ។ ដើមចម្ប៉ា ដើមខ្ទឹង ម្ទះ នួនស្រីនិងដើមក្រជៅ មានក្នុងក្រុងពិភពនាគនោះ ដើមឈើទាំងនោះទន់ទោរល្អរុងរឿងក្នុងមន្ទីរនៃនាគ ។ ព្រះបាទវរុណៈជាឱបបាតិកៈកំណើតមានឫទ្ធិច្រើន នៅក្នុងពិភពនាគណា ពួកដើមផ្កាវជាច្រើនដ៏ហើយដោយកែវឥន្ទនីលមានផ្កាជានិច្ច ជាវិការៈនៃមាសក្នុងពិភពនាគនោះ ។ នាងវិមលាជាភរិយារបស់ព្រះបាទវរុណនាគនោះជាស្រីនៅក្មេង មានរាងកាយភ្លឺផ្លេកដូចមាស មានព្រះថនាដូចផ្លែស្គៅ គួរជាទីរមិលដោយសេចក្តីពេញចិត្តឬដូចត្រួយវល្លិប្រេងខ្ចី ។ នាងវិមលាមានសម្បុរថ្ងៃក្រហមដូចពណ៌ល័ក្ត ដូចផ្កាកណ្ណិការរីកក្នុងទីមិនមានខ្យល់ ឬដូចស្រីអប្សរនៅក្នុងឋានត្រៃត្រិង្ស ឬក៏ដូចផ្លេកបន្ទោរជាលប្រវាត់ចេញអំពីស្រទាប់ពពក ។ នាងវិមលានោះជាស្រីមានចំណង់ប្លែកអស្ចារ្យក្រៃលែង ចង់បានហឫទ័យ នៃវិធុរបណ្ឌិត បពិត្រព្រះអង្គជាឥស្សរៈ ខ្ញុំនឹងឲ្យហឫទ័យវិធុរបណ្ឌិតនោះដល់នាគទាំងឡាយនោះ នាគទាំងនោះនឹងឲ្យនាងឥវន្ទតីដល់ខ្ញុំដោយហេតុនោះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **នេវាយាវហាំ** មានវិគ្គហៈថា ឈ្មោះថា **វាយា**

ព្រោះអត្ថថា គប្បីនាំទៅ ឈ្មោះថា **ទេវវាហវហំ** ព្រោះអត្ថថា នាំ **វាហា** ពោលគឺ ទេវតាទៅ ។ បទថា **យានំ** មានវិគ្គហៈថា ឈ្មោះថា **យានំ** ព្រោះជាគ្រឿងនាំទៅ គឺជាគ្រឿងទៅ ។ បទថា **កប្បិតកេសមស្សុ** សេចក្តីថា កាត់សក់និងកោពុកមាត់ល្អហើយដោយអំណាចការតាក់តែង ។ សួរថា ធម្មតា ការកាត់សក់និងកោរពុកមាត់របស់ទេវតាទាំងឡាយ រមែងមិនមាន ឆ្លើយថា ការពោលនេះក៏ពោលគ្រាន់តែធ្វើពាក្យឲ្យវិចិត្រ ។ បទថា **ឯតីសំ** បានដល់ បំណង ។ បទថា **វេស្សវណោ** បានដល់ ព្រះរាជាជាធំក្នុងវិសាណរាជធានី ។ បទថា **កុវេរោ** បានដល់ បុគ្គលឈ្មោះថា កុវេរៈយ៉ាងនោះ ។ បទថា **ភោគវតី នាម** បានដល់ ដែលបានឈ្មោះយ៉ាងនោះ ព្រោះជាប្រទេសមានភោគសម្បត្តិបរិបូណ៌ ។ បទថា **មន្ទិរេ** សេចក្តីថា ព្រះរាជមន្ទីរគឺព្រះរាជវាំង ។ បទថា **វាសា ហិរញ្ញវតី** សេចក្តីថា លោកហៅថា វាសនគរព្រោះជាទីគង់នៅរបស់ស្តេចនាគនិងហៅថា ហិរញ្ញវតី ព្រោះជានគរព័ទ្ធដោយកំពែងមាស ។ បទថា **នគរេ និមិតេ្ត** កែជា **នគរំ និមិត្តំ** ។ បទថា **កាញ្ចនមយេ** បានដល់ សម្រេចហើយដោយមាស ។ បទថា **មណ្ឌលស្ស** បានដល់ ប្រកបដោយកោគមណ្ឌល ។ បទថា **និដ្ឋិតំ** បានដល់ សម្រេចព្រោះការធ្វើ ។ បទថា **ឧជុគតិយោ** បានដល់ ធ្វើដោយសណ្ឋានដូចកអូដ្ឋ ។ បទថា **លោហិតង្គស្ស មសារគល្លិនោ** បានដល់ ប៉មនិងខ្លោងទ្វារសម្រេចដោយកែវមណីក្រហមនិងសម្រេចដោយកែវមកិត ។ បទថា **បាសាទេត្ថ** បានដល់ ប្រាសាទក្នុងនាគពិភពនេះ ។ បទថា **សិលាមយា** បានដល់

សម្រេចដោយកែវសិលាមណី ។ បទថា **សោវណ្ណរតនេន** សេចក្ដីថា ប្រក់ដោយរតនៈ ពោលគឺមាស គឺដោយក្បឿងដែលសម្រេចដោយមាស ។ បទថា **សហា** បានដល់ ដើមស្វាយក្រអូប ។ បទថា **ឧបរិ ភណ្ឌកា** បានដល់ ដើមបារិច្ឆត្តកៈ ។ បទថា **ឧទ្ទាលកា** បានដល់ ដើមរាជព្រឹក្ស ។ បទថា **ចម្ពេយ្យកា នាគមល្លិកា** បានដល់ ដើមចម្ប៉ា ដើមខ្ទឹងនិង ដើមម្លិះវល្លិ ។ បទថា **ភគិនីមាលា អត្តេត្ត កោលិយា** បានដល់ ម្លិះលា និងដើមក្រពៅរមែងមានក្នុងនាគពិភពនេះ ។ បទថា **ឯតេ ទុមា បរិណាមិ-តា** សេចក្ដីថា ដើមឈើដែលចេញផ្កា ចេញផ្លែទាំងនោះមានមែកទោរទន់ ព័ទ្ធព័ន្ធគ្នានឹងគ្នា ។ បទថា **ខជ្ជុរេត្ថ** បានដល់ ដើមផ្អាវមានក្នុងនាគពិភព នោះ ។ បទថា **សិលាមយា** បានដល់ សម្រេចដោយកែវឥន្ទនិល ។ បទថា **សោវណ្ណធុវបុប្ផិតា** សេចក្ដីថា ដើមឈើទាំងនោះមានផ្កាសម្រេច ដោយមាសរីកជានិច្ច ។ បទថា **យត្ថ វសោបបាតិកោ** សេចក្ដីថា ស្ដេច នាគកើតក្នុងភពនាគណា ។ បទថា **កាញ្ចនវេល្លិវិគ្គហា** បានដល់ មាន សរីរៈដូចគ្នានឹងពន្លកមាស ។ បទថា **កាឡា តរុណាវ ឧគ្គតា** សេចក្ដីថា ផុសឡើងហើយដូចត្រួយវល្លិប្រេង ដែលត្រូវខ្យល់បក់ព្រោះប្រកបដោយ លម្អ ។ បទថា **បុចិមន្ទត្ថនី** បានដល់ សុដន់ទាំង ២ មានសណ្ឋាន ដូចផ្លែស្ដៅ ។ បទថា **លាខារសរត្តសុច្ឆវី** នេះ យក្ខពោលសំដៅដល់ព្រះ ឆវីវណ្ណនៃផ្ទៃព្រះហស្តនិងផ្ទៃព្រះបាទ ។ បទថា **តិធិវោក្កចរា** បានដល់ ដែលត្រាច់ទៅក្នុងស្ថានត្រៃត្រឹង្ស ។ បទថា **វិជ្ជុវព្ភឃនា** សេចក្ដីថា ប្រៀប

ដូចផ្លែកបន្ទោរដែលជាលប្រវាត់អំពីស្រទាបពពក គឺចេញអំពីស្រទាប់ពពកដ៏ក្រាស់ ។ បទថា **តំ តេសំ ទទាមិ** សេចក្ដីថា ខ្ញុំនឹងឲ្យជូនហទយៈរបស់វិធុរបណ្ឌិតដល់ពួកគេ សូមទ្រង់ដឹងយ៉ាងនេះ ។ បុណ្ណកយក្ខហៅម្ចាស់អ៊ំថា **ឥស្សរ** ប្រែថា អ្នកជាធំ ។

ព្រះបាទវេស្សវ័ណមិនទាន់អនុញ្ញាត បុណ្ណកយក្ខនោះក៏មិនអាចទៅបាន ទើបពោលគាថាមានប្រមាណប៉ុណ្ណោះ ដើម្បីទូលឲ្យព្រះបាទវេស្សវ័ណទ្រង់អនុញ្ញាតដោយប្រការដូច្នេះ ។ ព្រះបាទវេស្សវ័ណទ្រង់មិនបានឮពាក្យរបស់បុណ្ណកយក្ខនោះ ។ មានពាក្យសួរថា ព្រោះហេតុអ្វីទើបព្រះបាទវេស្សវ័ណមិនបានឮពាក្យរបស់បុណ្ណកយក្ខ ឆ្លើយថា ព្រោះព្រះបាទវេស្សវ័ណកំពុងកាត់ក្ដីរបស់ទេវបុត្ត ២ អង្គ ដែលវិវាទគ្នាព្រោះរឿងវិមាន ។ បុណ្ណកយក្ខដឹងថា ព្រះបាទវេស្សវ័ណមិនបានឮពាក្យរបស់ខ្លួនទើបទៅឈរក្បែរទេវបុត្តដែលឈ្នះក្ដី ។ ព្រះបាទវេស្សវ័ណទ្រង់កាត់ក្ដីហើយមិនឲ្យទេវបុត្តដែលចាញ់ក្រោកឡើង ត្រាស់នឹងទេវបុត្តដែលឈ្នះថា ចូរអ្នកទៅក្នុងវិមានរបស់អ្នកចុះ ក្នុងខណៈដែលស្ដេចវេស្សវ័ណត្រាស់ថា អ្នកចូរទៅដូច្នេះ បុណ្ណកយក្ខប្រាប់ទេវបុត្ត ២-៣ អង្គទុកជាបន្ទាល់ថា លោកទាំងឡាយចូរដឹងថា ម្ចាស់អ៊ំរបស់ខ្ញុំឲ្យខ្ញុំទៅហើយ ឲ្យនាំសេះសិន្ធពមកឡើងផែលសេះហោះទៅដោយន័យដែលពោលហើយខាងដើម ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** វីអាចិធមិឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូល

សូធ្យសានូវព្រះគាថាដូច្នេះថា

បុណ្ណកយក្សនោះ ទូលលាព្រះបាទវេស្សវណកុវេរៈ ជាម្ចាស់នៃកូត ជាព្រះរាជាមានយសហើយសម្ងំនៅក្នុងទីនោះ បង្គាប់បុរស ( អ្នកបម្រើខ្លួន ) ថា អ្នកចូរនាំសេះអាជានេយ្យដែលបានស្អិតស្អាងយកមកក្នុងទីនេះ ។ ត្រចៀក ( របស់សេះនោះ ) ប្រដាប់ដោយមាស ក្រចកសេះប្រដាប់ដោយកែវមណីមានពណ៌ក្រហម គ្រឿងបិទបាំងទ្រូងដ៏ទ្រូងប្រដាប់ដោយមាសឆ្អិនឈ្មោះជម្ពូនទ បុណ្ណកយក្សតាក់តែងខ្លួន កាត់កោរសក់និងពុកមាត់ស្រេចហើយក៏ឡើងជិះសេះដែលជាយានដូចជាពាហនៈនៃទេវតាហោះទៅឰដ៏អាកាសវេហា ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អាមន្តយ** បានដល់ ទូលលាហើយ ។

បុណ្ណកយក្ខនោះហោះទៅតាមអាកាសនោះឯងគិតថា វិធុរបណ្ឌិតមានបរិវារច្រើន អញមិនអាចចាប់គេបាន តែព្រះបាទធនញ្ជយកោរព្យរាជចូលចិត្តលេងបាស្កា អញលេងឲ្យឈ្នះទ្រង់ហើយនឹងភ្នាល់យកវិធុរបណ្ឌិត កែវក្នុងឃ្លាំងរបស់ទ្រង់មានច្រើន ទ្រង់គង់នឹងលេងដោយកែវដែលជារបស់ភ្នាល់ដែលមានតម្លៃតិចតួច បុគ្គលឈ្នះព្រះរាជាបានគួរនាំយកកែវមណីដែលមានតម្លៃច្រើនមក ព្រះរាជាទ្រង់នឹងមិនទទួលកែវដទៃ កែវមណីជាគ្រឿងប្រើប្រាស់របស់ស្តេចចក្រពត្តិ មានក្នុងចន្លោះវេបុលបព៌តជិតក្រុងរាជគ្រឹះ អញត្រូវយកកែវមណីដែលមានអានុភាពច្រើននោះមកល្បួងលោមព្រះរាជា ទើប

អញឈ្នះព្រះរាជាបាន ។ បុណ្ណកយក្ខបានធ្វើយ៉ាងនោះ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហា** វីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូត្រសាទូវព្រះគាថាដូច្នេះថា

បុណ្ណកយក្សនោះបានទៅកាន់នគររាជគ្រឹះ ជាទីរីករាយដ៏ក្រៃលែង ជាក្រុងរបស់ព្រះបាទអង្គរាជ ដែលសត្រូវចូលមកបានដោយក្រ ជាក្រុងមានភក្សាហារច្រើន មានបាយនិងទឹកច្រើន ដូចជាកពណ្ហោះ មសក្កសារៈរបស់វាសវៈ ។ នគរនោះគឹកកងដោយហ្វូងនៃក្ងោកនិងក្រៀល គឹកកងដោយសត្វស្លាប ដែលពួកសត្វស្លាបអាស្រ័យនៅ មានសូរសំឡេងនៃពួកបក្សីផ្សេងៗ មានព្រះលានដ៏ល្អដេរដាសដោយផ្កាដូចជាភ្នំហិមវន្ត ។ បុណ្ណកយក្សនោះឡើងទៅកាន់ភ្នំឈ្មោះវេបុលៈ ជាទីអាស្រ័យនៅនៃពួកកិន្នរ ហើយស្វែងរកកែវមណីដ៏ប្រសើរ បានឃើញកែវមណីនោះត្រង់កណ្ដាលកំពូលភ្នំ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អង្គស្ស រញ្ញោ** សេចក្ដីថា ក្នុងកាលនោះព្រះបាទអង្គរាជបានគ្រប់គ្រងមគធរដ្ឋដោយហេតុនោះទើបត្រាស់ទុក ។ បទថា **ទុរាសទំ** សេចក្ដីថា ដែលសត្រូវចូលទៅរកបានលំបាក ។ បទថា **មសក្ក-សារំ វិយ វាសវស្ស** សេចក្ដីថា ដូចកពនៃស្ដេចវាសវៈដែលបានឈ្មោះថាមសក្កសារៈ ព្រោះសាងទុកក្បែរភ្នំសិនេរុ ពោលគឺមសក្កសារៈ ។ បទថា

**ទិជាភិឃុដ្ឋំ** សេចក្តីថា ជាទីនៅគឹកកងដោយហ្វូងបក្សីដទៃៗ ។ បទថា **នានាសកុណាភិរុទំ** សេចក្តីថា ហ្វូងបក្សីច្រើនប្រភេទយំដោយសំឡេងដ៏ពីរោះលេងល្ហើយ ។ បទថា **សុវគ្គុណំ** សេចក្តីថា មានទួលដ៏ស្អាតមានផ្ទៃរាបស្មើជាទីគួរបម្រើនចិត្ត ។ បទថា **ហិមវំវ បព្វតំ** បានដល់ ដូចភ្នំហិមពាន្ត ។ បទថា **វេបុលមាភិរុយ្ហ** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ បុណ្ណកយក្ខនោះឡើងកាន់វេបុលបព៌តនោះ ។ បទថា **បព្វតក្កូដមជ្ឈេ** សេចក្តីថា បានឃើញកែវមណីនោះក្នុងចន្លោះនៃកំពូលភ្នំ ។

បុណ្ណកយក្សឃើញកែវមណី មានជាតិ ( ផ្សេងៗ ) ជាទីផ្សាយចេញនៃរស្មីរុងរឿង ជាកែវមណីដ៏ប្រសើរ អាចនាំមកនូវទ្រព្យ ជាកែវរុងរឿង ជាកែវមានយសជាងយស ភ្លឺរុងរឿងដូចផ្លេកបន្ទោរព្ធដ៏អាកាសក៏បានកាន់យកកែវមណីឈ្មោះមនោហរៈនោះ ជាកែវពៃទូរ្យមានតម្លៃច្រើន មានអានុភាពច្រើន ជាអ្នកមានភេទមិនថោកទាបឡើងជិះសេះអាជានេយ្យហោះទៅព្ធដ៏អាកាសវេហា ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ធនាហរំ** សេចក្តីថា អាចនាំទ្រព្យមកបានតាមបំណង ។ បទថា **ឧទ្ធល្វមានំ** បានដល់ រុងរឿងក្រៃលែង ។ បទថា **យសសា** បានដល់ ដោយពួកកែវមណីមានបរិវារច្រើន ។ បទថា **ឱភាសតី** សេចក្តីថា កែវមណីនោះភ្លឺរុងរឿងដូចផ្លេកបន្ទោរព្ធដ៏អាកាសដូច្នោះ ។ បទថា **តមគ្គហី** សេចក្តីថា បានកាន់យកកែវមណីនោះ ។ បទថា **មនោ-**

**ហរំ ឆាម** សេចក្តីថា បានឈ្មោះយ៉ាងនេះថា កែវមណីនោះអាចនាំមកនូវទ្រព្យដូចចិត្តប៉ង ។

យក្ខមួយរូបឈ្មោះកុម្ភិរៈមានពួកកុម្ភណ្ឌមួយសែនជាបរិវាររក្សាកែវមណីនោះតែកុម្ភិរយក្ខនោះគ្រាន់តែបុណ្ណកយក្ខធ្វើអាកប្បកិរិយាជាក្រោធ បើកភ្នែកសម្លឹងមើលប៉ុណ្ណោះក៏ខ្លាចមានខ្លួនញ័ររត់ទៅពួនត្រង់ភ្នំកណ្តាប់ចក្កវាឡហើយសម្លឹងមើល ។ បុណ្ណកយក្ខនោះដេញកុម្ភិរយក្ខឲ្យរត់ទៅ ហើយក៏កាន់យកកែវមណីជិះសេះទៅតាមអាកាសដល់នគរនោះ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** វីអាចិធមិឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសួច្យសានូវព្រះគាថាដូច្នេះថា

បុណ្ណកយក្សនោះបានទៅកាន់ក្រុងឥន្ទបត្ត ចុះ ( អំពីសេះ ) ហើយចូលទៅកាន់ទីប្រជុំនៃអ្នកដែនកុរុ មិនកោតញញើតព្រះរាជា ១០១ អង្គ ដែលព្រមព្រៀងគ្នាមកប្រជុំ ( នៅទីនោះ ) បបួលថា បណ្តាពួកព្រះរាជាក្នុងរាជសមាគមនេះ ព្រះរាជាអង្គណាឈ្នះយើង ( ត្រូវយក ) កែវដ៏ប្រសើរ ( របស់យើង ) បើយើងឈ្នះព្រះរាជាអង្គណាវិញ ( ត្រូវយក ) ទ្រព្យដ៏ប្រសើរ ឬយើងឈ្នះព្រះរាជាអង្គណា ( នឹងយក ) កែវដ៏ប្រសើរថ្លៃថ្លាក៏បាន ចំណែកព្រះរាជាអង្គណាឈ្នះយើងវិញ ( នឹងយក ) ទ្រព្យដ៏ប្រសើរក៏បាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឱរុយ្ហុ ចាគញ្ចិ សកំ តុរង្គំ** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ បុណ្ណកយក្ខនោះចុះអំពីខ្នងសេះហើយ ចងសេះដែលមានរូបដែលគេមិនឃើញហើយចូលទៅកាន់សភានៃអ្នកកុរុរដ្ឋ ដោយភាពជាមាណព ។ បទថា **ឯកសតំ** សេចក្តីថា មិនកោតខ្លាចព្រះរាជា ១០១ អង្គ បានពោលរាក់ទាក់ដោយល្បែងបាស្កាដោយន័យជាដើមថា បណ្តាពួកព្រះរាជាក្នុងរាជសមាគមនេះ ព្រះរាជាអង្គណា...។ បទថា **កោធីធ** សេចក្តីថា ព្រះរាជាអង្គណាហ្ន៎ក្នុងរាជសមាគមនេះ ។ បទថា **រញ្ញំ** សេចក្តីថា ក្នុងរវាងព្រះរាជាទាំងឡាយ ។ បទថា **វរមាភិជេតិ** សេចក្តីថា ព្រះរាជាអង្គណាដែលជណ្តើមយកកែវដ៏ប្រសើររបស់យើងបានគឺអាចពោលបានថា យើងឈ្នះដូច្នេះ ។ បទថា **កមាភិជេយ្យាម** សេចក្តីថា ឬពួកយើងគប្បីឈ្នះនរណា ។ បទថា **វរទ្ធនេន** បានដល់ ដោយទ្រព្យដ៏ឧត្តម ។ បទថា **កមនុត្តរំ** សេចក្តីថា ពួកយើងកាលនឹងឈ្នះ ចូរឈ្នះនូវទ្រព្យដ៏ប្រសើរនឹងព្រះរាជាអង្គណា ។ បទថា **កោ វាបិ នោ ជេតិ** សេចក្តីថា ឬព្រះរាជាអង្គណាឈ្នះពួកយើងដោយទ្រព្យដ៏ប្រសើរ ។ បុណ្ណកយក្ខនោះនិយាយដឹកនាំព្រះបាទកោរព្យរាជនោះដោយគាថា ៤ បទដោយប្រការដូច្នេះ ។

លំដាប់នោះព្រះបាទកោរព្យរាជ ទ្រង់ព្រះតម្រិះថា មុនអំពីនេះយើងមិនធ្លាប់ឃើញនរណានិយាយក្លាហានបែបនេះ នេះជានរណាហ្ន៎ កាលទ្រង់សួរទើបត្រាស់គាថានេះថា

ជាតិភូមិរបស់អ្នកនៅក្នុងដែនណា ពាក្យរបស់អ្នកនេះមិនមែន

ជាពាក្យរបស់អ្នកដែនកុរុទេ អ្នកមានវាចាអង់អាច មិនកោត
ខ្លាចយើងទាំងអស់គ្នា អ្នកចូរប្រាប់ឈ្មោះនិងផៅពង្សដល់យើង
ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កោរព្យស្សេ** សេចក្តីថា ពាក្យរបស់អ្នក មិនមែនជាពាក្យរបស់អ្នកនៅក្នុងដែនកុរុឡើយ ។

ចំណែកបុណ្ណកយក្ខបានស្តាប់ដូច្នោះទើបគិតថា ព្រះរាជានេះរមែងសួរឈ្មោះរបស់អញ ទាសៈឈ្មោះបុណ្ណកៈមានម្នាក់ បើអញទូលប្រាប់ឈ្មោះបុណ្ណកៈសោតទ្រង់នឹងមើលងាយអញថា ព្រោះហេតុអ្វីទើបទាសៈពោលនឹងអញដោយការឃ្នើសឃ្នងយ៉ាងនេះ ណ្ហើយចុះ អញទូលឈ្មោះរបស់អញក្នុងអតីតជាតិដែលជាលំដាប់ដល់ទ្រង់ហើយពោលគាថានេះថា

បពិត្រព្រះរាជា ខ្ញុំជាមាណពកច្ចាយនគោត្ត ពួកញាតិនិងផៅ
ពង្សរបស់ខ្ញុំក្នុង ( កាលចម្បាកនគរ ) ដែនអង្គៈតែងហៅខ្ញុំថា
មាណពមានឈ្មោះមិនថោកទាប បពិត្រព្រះសម្មតិទេព ខ្ញុំមក
ក្នុងទីនេះដើម្បីលេងល្បែងភ្នាល់ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អនូនណាមោ** សេចក្តីថា បានពោលបិទបាំងចំពោះឈ្មោះបុណ្ណៈប៉ុណ្ណោះ ដោយឈ្មោះអនូនៈនោះ ។ បទថា **ឥតិ មវ្ហយន្តិ** សេចក្តីថា ពួកញាតិរមែងហៅខ្ញុំដូច្នេះ ។ បទថា **អង្គេសុ** សេចក្តីថា នៅក្នុងនគរកាលចម្បាកក្នុងដែនអង្គៈ ។ បទថា **អក្ខេន ទេវស្មិ** សេចក្តីថា បពិត្រព្រះសម្មតិទេព ខ្ញុំមកដល់ទីនេះដោយបំណាងនឹងលេងបាស្កា ។

លំដាប់នោះព្រះរាជាកាលត្រាស់សួរបុណ្ណកយក្ខនោះថា នែមាណព អ្នកដែលព្រះរាជាឈ្នះដោយបាស្កានឹងថ្វាយអ្វីដល់ព្រះរាជា អ្នកមានអ្វីឬក៏ត្រាស់គាថាដូច្នេះថា

អ្នកលេងល្បែងភ្នាល់កាលបើឈ្នះ អ្នកគប្បីយកកែវទាំងឡាយ

ណា កែវទាំងនោះ របស់មាណពឯង មានដែរឬ ឯកែវ

របស់ព្រះរាជា មានចំនួនច្រើន អ្នកជាមនុស្សទាល់ក្រ នឹង

បបួលព្រះរាជាទាំងនោះដូចម្តេចបាន ដូច្នេះ ។

ពាក្យដែលជាគាថានោះមានអធិប្បាយដូច្នេះថា កែវទាំងនោះរបស់មាណពឯងមានឬ ។ បទថា **យេ តំ ជិនន្តោ** សេចក្តីថា ព្រះរាជាត្រាស់ថា បុគ្គលដែលជំនាញក្នុងការលេងបាស្កា កាលឈ្នះហើយពោលថា ចូរនាំទ្រព្យមកដូច្នេះហើយគប្បីនាំរតនៈពួកណាទៅ តែកែវជាច្រើនមាននៅក្នុងនិវេសន៍របស់ព្រះរាជាទាំងឡាយ អ្នកជាបុគ្គលក្រីក្រនឹងធ្វើការភ្នាល់ជាមួយព្រះរាជាទាំងនោះដែលមានទ្រព្យច្រើនយ៉ាងនេះបានដូចម្តេច ។

លំដាប់នោះបុណ្ណកយក្ខទូលថា

ឯកែវមណីរបស់ខ្ញុំនេះអាចនាំមកនូវទ្រព្យបាន អ្នកលេងល្បែង

ភ្នាល់ បើលេងឈ្នះខ្ញុំហើយគប្បីយកកែវមណីដ៏ប្រសើរ ជា

កែវអាចនាំមកនូវទ្រព្យនេះ ១ និងសេះអាជានេយ្យ អាច

បង្ក្រាបសត្រូវនេះ ១ របស់ខ្ញុំចុះ ដូច្នេះ ។

ក្នុងបាលីបោត្ថកៈលោករចនាទុកថា កែវមណីរបស់ខ្ញុំនេះ មានពណ៌ក្រហម

កែវនោះជាកែវពៃទូរ្យព្រោះដូច្នោះពាក្យនេះឯងទើបសមគ្នា ។ បណ្ដាបទទាំងនោះ បទថា **អាជញ្ញំ** សេចក្ដីថា អ្នកលេងដែលជំនាញក្នុងការលេងបាស្កា ឈ្នះហើយគប្បីនាំវត្ថុទាំង ២ របស់ខ្ញុំនេះ គឺសេះអាជានេយ្យនិងកែវមណីនេះទៅ ព្រោះហេតុនោះបុណ្ណកយក្ខកាលបង្ហាញសេះក៏ពោលយ៉ាងនោះ ។ ព្រះរាជាកាលស្ដាប់ដូច្នោះហើយ ទើបត្រាស់គាថានេះថា

ម្នាលមាណព កែវមណីមួយនឹងធ្វើអ្វីបានទាំងសេះអាជានេយ្យ
មួយនឹងធ្វើអ្វីបាន ( ព្រោះ ) កែវទាំងឡាយរបស់ព្រះរាជាមាន
ចំនួនច្រើន សេះអាជានេយ្យរបស់ព្រះរាជាមានសន្ទុះដូចខ្យល់
ក៏មានចំនួនមិនតិចទេ ដូច្នេះ ។

## ទោហឡកណ្ឌ ចប់

បុណ្ណកយក្ខនោះស្ដាប់ព្រះតម្រាស់របស់ព្រះរាជាដូច្នេះហើយ ក្រាបទូលព្រះរាជាថា បពិត្រមហារាជ ព្រោះហេតុអ្វីទើបទ្រង់ត្រាស់ដូច្នោះ សេះរបស់ទូលព្រះបង្គំមួយស្មើគ្នានឹងសេះ ១០០០ កែវមណីរបស់ទូលបង្គំមួយស្មើគ្នានឹងកែវដទៃ ១០០០ សេះទាំងពួងមិនអាចប្រៀបផ្ទឹមនឹងសេះរបស់ទូលព្រះបង្គំតែមួយបានឡើយ សូមទ្រង់ទតនូវភាពវាងវៃរបស់សេះនេះសិន ហើយឡើងផែលសេះបំផាយខាងលើកំពែងព្រះនគរទំហំ ៧ យោជន៍ បានប្រាកដហាក់ដូចជាសេះយកកទល់គ្នាតម្រៀបព័ទ្ធព្រះនគរ បើសេះរត់រហ័សជាង

លំដាប់នោះទៅក៏មិនប្រាកដ ។ សូម្បីយក្ខក៏មិនប្រាកដឃើញតែសំពត់ពណ៌ក្រហមប៉ុណ្ណោះ គឺប្រាកដដូចជាសំពត់ក្រហមមួយផ្ទាំង ព័ទ្ធជុំវិញព្រះនគរ បុណ្ណកយក្ខចុះអំពីលើខ្នងសេះមកក្រាបទូលថា បពិត្រមហារាជ ទ្រង់ទតឃើញកម្លាំងរហ័សរបស់សេះហើយឬ កាលព្រះរាជាត្រាស់ថា អើមាណព យើងឃើញហើយទើបក្រាបទូលថា បពិត្រមហារាជ សូមទ្រង់ទតមើលទៀតក្នុងកាលឥឡូវនេះហើយជិះសេះទៅលើផ្ទៃទឹកក្នុងស្រះបោក្ខរណី ត្រង់ឧទ្យានខាងក្នុងព្រះនគរ សេះបានរត់ទៅមិនឲ្យចុងក្រចកសើមឡើយ ។ គ្រានោះបុណ្ណកយក្ខឲ្យសេះរត់ជាន់លើស្លឹកឈូក ទះដៃហើយលាដៃចេញ សេះរត់មកទំលើបាតដៃ ។ លំដាប់នោះបុណ្ណកយក្ខក្រាបទូលថា បពិត្រព្រះអង្គជាធំជាងជន សេះបែបនេះគួរចាត់ជាសេះកែវមិនមែនឬ កាលទ្រង់ត្រាស់ថា គួរមាណព ទើបក្រាបទូលទៀតថា បពិត្រមហារាជ អស្សរតនៈលើកទុកចុះ សូមទ្រង់ទតអានុភាពនៃកែវមណី ដូច្នេះហើយកាលប្រកាសអានុភាពនៃកែវមណីនោះទើបពោលថា

បពិត្រព្រះអង្គប្រសើរជាងសត្វជើងពីរ សូមព្រះអង្គទ្រង់ទត
កែវមណីរបស់ខ្ញុំនេះចុះ ក្នុងកែវមណីនេះមានរាងកាយរបស់
ស្ត្រី មានរាងកាយរបស់បុរស ។ មានរាងកាយរបស់ម្រឹគ មាន
រាងកាយរបស់បក្សីប្រាកដក្នុងកែវមណីនេះ សូមព្រះអង្គទ្រង់
ទតនាគរាជនិងគ្រុឌ ជារូបនិម្មិតក្នុងកែវមណី ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឥត្ថីធំ** សេចក្ដីថា រូបស្រីមិនមែនតិចដែល

ប្រជាប់តាក់តែងក្នុងកែវមណីនោះ រូបបុរសក៏ដូចគ្នា ពួកម្រឹគនិងបក្សីមានប្រការផ្សេងៗ ពួកសេនាជាដើមរមែងប្រាកដ កាលនឹងប្រកាសវត្ថុទាំងនោះ ទើបបុណ្ណកយក្ខទូលយ៉ាងនោះ ។ បទថា **និម្មិតំ** នេះ បុណ្ណកយក្ខពោលថា សូមទ្រង់ទតវត្ថុដែលគួរអស្ចារ្យបែបនេះ ដែលធម្មជាតិសាងទុកក្នុងកែវមណីនេះ លុះសម្ដែងវត្ថុដទៃៗទើបពោលគាថានេះថា

*សូមព្រះអង្គទ្រង់ទតសេនាមានអង្គ ៤ គឺពលដំរី ១ ពលរថ ១ ពលសេះ ១ ពលថ្មើរជើងមានគ្រឿងក្រោះ ១ ជារូបនិម្មិតក្នុងកែវមណី ។ សូមព្រះអង្គទ្រង់ទតពលដំរីនិងពួកសេនាពលរថនិងពលថ្មើរជើង គឺពួកពលដែលរៀបជាព្យុហៈជារូបនិម្មិតក្នុងកែវមណី ដូច្នេះ ។*

បណ្ដាបទទាំងនោះ បទថា **ពលគ្គានិ** បានដល់ កងពលនោះឯង ។ បទថា **វិយូហានិ** បានដល់ ដោយអំណាចក្បួនព្យូហយាត្រា ។

*សូមព្រះអង្គទ្រង់ទតនគរដ៏បរិបូណ៌ដោយប៉ម មានកំពែងនិងខ្លោងទ្វារដ៏ច្រើនជាន់ មានផ្លូវបែកជា ៤ និងផែនដីដ៏ល្អ ជារូបនិម្មិតក្នុងកែវមណី ។ សូមព្រះអង្គទ្រង់ទតសសរខឿន គូរនុកទ្វារ គន្លឹះទ្វារ ប៉មនិងទ្វារប៉ម ជារូបនិម្មិតក្នុងកែវមណី ដូច្នេះ ។*

បណ្ដាបទទាំងនោះ បទថា **បុរំ** ប្រែថា ព្រះនគរ ។ បទថា **អដ្ដាលសម្បន្នំ** បានដល់ សម្បូរដោយប៉មនិងកំពែង ។ បទថា **ពហុធាការតោរណំ**

បានដល់ មានកំពែងនិងទ្វារខ្ពស់ ។ បទថា **សិង្ឃាដកេ** បានដល់ ផ្លូវបែកជា ៤ ។ បទថា **សុភូមិយោ** សេចក្តីថា មានផ្ទៃដីរាបស្មើ វិចិត្រដោយឧបចារនៃនគរ ។ បទថា **ឯសិកា** បានដល់ សសរខឿនរបងដែលតាំងឡើងត្រង់ទ្វារព្រះនគរ ។ បទថា **បលិឃំ** បានដល់ រនុកទ្វារលោហៈ ម្យ៉ាងទៀតបាលីក៏យ៉ាងនោះដូចគ្នា ។ បទថា **អគ្គឡានិ** បានដល់ ទ្វារនិងបង្អួចព្រះនគរ ។ បទថា **អដ្ដាលកេ ច** បានដល់ ប៉ម ។

សូមព្រះអង្គទ្រង់ទតពួកបក្សីផ្សេងៗជាច្រើន ទៀបខ្លោងទ្វារនិងផ្លូវ គឺហ្វូងហង្ស ក្រៀល ក្ងោក ចាក្រពាក អក សូមព្រះអង្គទ្រង់ទតទីក្រុងដ៏ដេរដាសដោយបក្សីផ្សេងៗ គឺតាវ៉ៅខ្មៅ តាវ៉ៅពព្រុស ក្ងោកនិងប៉ោលតោកជាច្រើន ជារូបនិម្មិតក្នុងកែវមណី ។

បណ្តាបទទាំងនោះ បទថា **តោរណមគ្គេសុ** បានដល់ ខ្លោងទ្វារនិងផ្លូវក្នុងព្រះនគរនេះ ។ បទថា **កុណាលកា** បានដល់ សត្វតាវ៉ៅខ្មៅ ។ បទថា **ចិត្រា** បានដល់ សត្វតាវ៉ៅពព្រុស ។

សូមព្រះអង្គទ្រង់ទតទីក្រុងមានកំពែងល្អអស្ចារ្យចម្លែក គួរព្រឺរោម មានទង់ជ័យលើកឡើង ក្រាលដោយដីខ្សាច់ដែលមានសម្បុរដូចមាសគួរជាទីរីករាយ ។ សូមព្រះអង្គទ្រង់ទតរានផ្សារដ៏បរិបូណ៌ដោយទំនិញ ដែលគេចែកជាជួរ ជាសង្កាត់តាមចំណែកមានផ្ទះ និងទីផ្ទះតំណនៃផ្ទះ ប្រកទាល់និងផ្លូវទាំង

ឡាយ ។

បណ្ដាបទទាំងនោះ បទថា **សុចាការំ** បានដល់ ព័ទ្ធទៅដោយកំពែងមាស ។ បទថា **បណ្ណសាលាយោ** បានដល់ រានផ្កាដែលដល់ព្រមទៅដោយទំនិញច្រើនប្រភេទ ។ បទថា **និវេសនេ និវេសេ ច** បានដល់ ផ្ទះនិងវត្ថុក្នុងផ្ទះ ។ បទថា **សន្ធិព្យូហោ** បានដល់ ទីតនៃផ្ទះនិងច្រកទាល់ ។ បទថា **បថទ្ធិយោ** បានដល់ ច្រកមិនទាល់ ( ផ្លូវធំ ) ។

*សូមព្រះអង្គទ្រង់ទតរោងសុរា អ្នកលេងសុរា អ្នកគ្រួ ផ្ទះបាយ ពួកឈ្មួញនិងពួកស្រីពេស្យា ជារូបនិម្មិតក្នុងកែវមណី ។ សូមព្រះអង្គទ្រង់ទតពួកជនអ្នកធ្វើផ្កាកម្រង ជាងជ្រលក់ អ្នកធ្វើគ្រឿងក្រអូប អ្នកត្បាញសំពត់ ជាងមាសនិងជាងកែវមណី ជារូបនិម្មិតក្នុងកែវមណី ។ សូមព្រះអង្គទ្រង់ទតពួកជនអ្នកធ្វើសម្លជនធ្វើបាយ អ្នករបាំ នាយរបាំ អ្នកច្រៀង អ្នកច្រៀងទះដៃនិងអ្នកវាយស្គរ ជារូបនិម្មិតក្នុងកែវមណី ។*

បណ្ដាបទទាំងនោះ បទថា **សោណ្ឌេ ច** សេចក្ដីថា រោងសុរាដែលប្រកបដោយគ្រឿងប្រដាប់កនិងគ្រឿងប្រដាប់ត្រចៀក ដែលសមគួរដល់ខ្លួននិងអ្នកលេងសុរាដែលអង្គុយរៀបចំទីផឹកសុរា ។ បទថា **អាឡារិកេ** បានដល់ អ្នកធ្វើនំ ។ បទថា **សូទេ** បានដល់ អ្នកផ្សំអាហារ ។ បទថា **ចា-ណិស្សរេ** សេចក្ដីថា ច្រៀងដោយការទះដៃ ។ បទថា **កុម្ភថូណិកេ** បានដល់ ពួកអ្នកប្រគំដោយសំឡេងឈិង ។

សូមព្រះអង្គទ្រង់ទតស្គរសម្ភោរ ស័ង្ខ ខ្ទយ ស្គរជ័យនិងគ្រឿងភ្លេងទាំងអស់ ជារូបនិម្មិតក្នុងកែវមណី ។ សូមព្រះអង្គទ្រង់ទតក្រាប់ ឈិង ពិណ របាំ ចម្រៀង ប្រគំ ដែលគឹកកងដោយតូរ្យតន្ត្រីដ៏រងំ ជារូបនិម្មិតក្នុងកែវមណី ។ សូមព្រះអង្គទ្រង់ទតពួកជនអ្នកលោត អ្នកប្រដាល់ អ្នកធ្វើខាងកលមាយានិងស្រីប្រុសដ៏ល្អក្នុងកែវមណីនេះ ទាំងពួកអ្នកជាស់តៀនគេ និងអ្នកកាត់កោរសក់ ជារូបនិម្មិតក្នុងកែវមណី ។

បណ្តាបទទាំងនោះ បទថា **សម្មតាលំ** បានដល់ សម្ភោរដែលធ្វើដោយដើមគគីរជាដើមនិងក្រាប់ ។ បទថា **តុរិយតាលិតសង្ឃុដ្ឋំ** បានដល់ គ្រឿងតន្ត្រីផ្សេងៗដែលគេប្រគំយ៉ាងគគ្រឹកគគ្រេង ។ បទថា **មុដ្ឋិកា** បានដល់ អ្នកប្រដាល់ ។ បទថា **សោភិយា** បានដល់ ស្រីនគរសោភិណីនិងប្រុសរូបស្អាត ។ បទថា **វេតាលិកេ** បានដល់ អ្នកប្រាប់កាលវេលាឲ្យក្រោកឡើង ។ បទថា **ជល្លេ** បានដល់ ជាងកាត់សក់កំពុងកាត់សក់និងកោរពុកមាត់ ។

មហោស្រពទាំងឡាយដ៏មីរដេរដាសដោយបុរសនិងស្ត្រីក៏មានក្នុងកែវមណីនេះ សូមព្រះអង្គទ្រង់ទតគ្រែតូច និងគ្រែធំនិងទី ( នៃមហោស្រព ) ជារូបនិម្មិតក្នុងកែវមណី ។

បណ្តាបទទាំងនោះ បទថា **មញ្ចាតិមញ្ចេ** បានដល់ គ្រែដែលចងដាក់ខាងលើគ្រែធំ ។ បទថា **ភូមិយោ** បានដល់ ភូមិដែលសម្តែងមហោស្រពគួរជាទីត្រេកអរ ។

*សូមព្រះអង្គទ្រង់ទតពួកអ្នកចំបាប់ ដែលចំបាប់គ្នាដោយដៃទាំង ពីរក្នុងទីមហោស្រព សូមព្រះអង្គទ្រង់ទតពួកអ្នកឈ្នះនិងអ្នក ចាញ់ ជារូបនិម្មិតក្នុងកែវមណី ដូច្នេះ ។*

បណ្ដាបទទាំងនោះ បទថា **សមជ្ជស្មឹ** បានដល់ ក្នុងទីលានប្រជាល់ ។ បទថា **និហតេ** បានដល់ ដែលកម្ចាត់ គឺអ្នកឈ្នះ ។ បទថា **និហតមានេ** បានដល់ អ្នកចាញ់ ។

*សូមព្រះអង្គទ្រង់ទតពួកម្រឹគផ្សេងៗ ជាច្រើនទៀតជើងភ្នំ គឺ រាជសីហ៍ ខ្លាធំ ជ្រូកព្រៃ ខ្លាឃ្មុំ ឆ្កែព្រៃ ខ្លារខិន ។ សត្វ រមាស គោ ក្របី រមាំង ប្រើស ទ្រាយ សរកម្រឹគ ក្ដាន់ ជ្រូកស្រុក ។ ឈ្លូស ពួកចិត្រម្រឹគជាច្រើន ខ្លាត្រី ទន្សាយនិង កង្ហែន សូមព្រះអង្គទ្រង់ទតជើងភ្នំ ដ៏ដេរដាសដោយពួកម្រឹគ ផ្សេងៗ ជារូបនិម្មិតក្នុងកែវមណី ។*

បណ្ដាបទទាំងនោះ បទថា **បលាសាទា** ប្រែថា រមាស បាលីថា **បលតា** ដូច្នេះក៏មាន ។ បទថា **គវជា** បានដល់ គោព្រៃ ។ បទថា **វរា- ហា** បានដល់ ម្រឹគមួយប្រភេទឬក្ដាន់និងជ្រូកស្រុកក៏បាន ។ បទថា **ពហូ ចិត្រា** បានដល់ ម្រឹគដែលវិចិត្រដោយប្រការផ្សេងៗ ។ បទថា **វិឡារា** ប្រែ ថា ឆ្មាដែលនៅក្នុងព្រៃ ( ខ្លាត្រី ) ។ បទថា **សសកណ្ណកា** បានដល់ ទន្សាយ និងកង្ហែន ។

*ស្ទឹងទាំងឡាយមានកំពង់រាបទាបល្អ ដែលក្រាលដោយខ្សាច់*

មាស មានទឹកថ្លា មានពួកត្រីអាស្រ័យតែងហូរទៅ ។ ពួក
ឆ្លាម មករ ក្រពើ អណ្តើក ត្រីស្វាត ត្រីសណ្តាយ ត្រីឆ្តោ
ត្រីឆ្តិន មានក្នុងកែវមណីនេះ ។

បណ្តាបទទាំងនោះ បទថា **ឆជ្ជាយោ** ប្រែថា ស៊ីង ។ បទថា **សោ-វណ្ណវាលុកសន្ថតា** បានដល់ មានផ្ទៃតាំងនៅរាបស្មើដោយខ្សាច់មាស ។ បទថា **កុម្ភិលា** សេចក្តីថា សត្វទាំងនោះមានរូបបែបនេះ ត្រាច់សញ្ចរទៅ មកក្នុងស៊ីងសូមទ្រង់ទតសត្វទាំងនោះ ដែលជម្មជាតិសាងទុកក្នុងកែវមណីនេះ ។

សូមព្រះអង្គទ្រង់ទតស្រះបោក្ខរណី ដែលធ្វើដោយផែនថ្ម ជា
វិការៈនៃកែវពៃទូរ្យ ដ៏ដេរដាសដោយពួកសត្វស្លាបផ្សេងៗ
មានពួកឈើផ្សេងៗជាជួរ ជារូបនិម្មិតក្នុងកែវមណី ។

បណ្តាបទទាំងនោះ បទថា **វេឡុរិយផលកាវាធាយោ** សេចក្តីថា ហ្វូងបក្សីត្រសេះនាំគ្នាបោះផ្តាំងថ្ម ដែលសម្រេចហើយដោយកែវពៃទូរ្យ បន្លឺសំឡេងដោយសំឡេងកែវមណីនោះ ។

សូមព្រះអង្គទ្រង់ទតស្រះបោក្ខរណីក្នុងកែវមណីនេះ ដែលចាត់
ចែងដោយល្អទាំង ៤ ទិស ដ៏ដេរដាសដោយពួកសត្វស្លាប
ផ្សេងៗដែលត្រីធំអាស្រ័យនៅ សូមព្រះអង្គទតផែនដីដ៏បរិបូណ៌
ដោយទឹកព័ទ្ធជុំវិញ ជាកុណ្ឌលនៃសាគរ ប្រកបដោយជួរដង
ព្រៃទាំងឡាយ ជារូបនិម្មិតក្នុងកែវមណី ។

បណ្តាបទទាំងនោះ បទថា **បុប្ផលោមច្ឆសេវិតា** បានដល់ ជាទីនៅអាស្រ័យនៃហ្វូងត្រីធំៗ ។ បទថា **វនកាជេហិ** បានដល់ស្អាមទីតរបស់ព្រៃ ។ បាលីក៏យ៉ាងនេះដូចគ្នា ។

សូមព្រះអង្គទ្រង់ទតមើលទ្វីបទាំង ៤ គឺបុព្វវិទេហទ្វីបខាងកើត អបរគោយានទ្វីបខាងលិច ឧត្តរកុរុទ្វីប និងជម្ពូទ្វីបជារូបនិម្មិតក្នុងកែវមណី ។ សូមព្រះអង្គទ្រង់ទត ព្រះចន្ទនិងព្រះអាទិត្យកំពុងបំភ្លឺទិសទាំង ៤ សូមព្រះអង្គទ្រង់ទត ( ព្រះចន្ទនិងព្រះអាទិត្យនោះ ) កំពុងដើរក្រឡឹងភ្នំសិនេរុ ជារូបនិម្មិតក្នុងកែវមណី ។ សូមព្រះអង្គទ្រង់ទតភ្នំសិនេរុ ភ្នំហិមពាន្ត សមុទ្ទសាគរដែលមានឫទ្ធិច្រើននិងមហារាជទាំង ៤ អង្គ ជារូបនិម្មិតក្នុងកែវមណី ។ សូមព្រះអង្គទ្រង់ទតសួនច្បារ ព្រៃ គុម្ពឈើខ្ទង់ថ្មភ្នំហាក់ដូចជាគេក្រាលតម្កល់ទុក ដ៏ដេរដាសដោយពួកកិន្នរគួរជាទីរីករាយ ជារូបនិម្មិតក្នុងកែវមណី ។ សូមព្រះអង្គទ្រង់ទតបារុសកវ័ន ចិត្តលតាវ័ន មិស្សកវ័ន នន្ទនវ័ននិងវេជយន្តប្រាសាទ ជារូបនិម្មិតក្នុងកែវមណី ។ សូមព្រះអង្គទ្រង់ទតសុធម្មសភាឋានតាវត្តិង្ស ដើមបារិច្ឆត្តព្រឹក្សមានផ្ការីក ស្តេចដំរីឈ្មោះឯរាវ័ណ ជារូបនិម្មិតក្នុងកែវមណី ។ សូមព្រះអង្គទ្រង់ទតពួកស្រីទេពកញ្ញាដែលភ្លឺផ្លេកដូចជាផ្លេកបន្ទោរ ចេញចាកពពក កំពុងត្រាច់ទៅក្នុងនន្ទនវ័ន ជារូបនិម្មិតក្នុងកែវមណី ។

សូមព្រះអង្គទ្រង់ទតពួកទេពកញ្ញាប្រលោមទេវបុត្ត និងពួកទេវបុត្តកំពុងរីករាយក្នុងនន្ទនវ័ន ជារូបនិម្មិតក្នុងកែវមណី ។

បណ្ដាបទទាំងនោះ បទថា **វិទេហោ** បានដល់ បុព្វវិទេហទ្វីប ។ បទថា **គោយានិយេ ច** បានដល់ អមរគោយានទ្វីប ។ បទថា **កុរុយោ ជម្ពុទីបញ្ច** បានដល់ ឧត្តរកុរុទ្វីបនិងជម្ពូទ្វីប ។ បទថា **អនុបរិយាយន្តេ** សេចក្ដីថា ដែលព្រះចន្ទនិងព្រះអាទិត្យទាំងនោះគោចរជុំវិញភ្នំសិនេរុ ។ បទថា **ឆាដិយេ** សេចក្ដីថា លើផ្ទាំងថ្មដូចគេក្រាលទុក ។

សូមព្រះអង្គទ្រង់ទតប្រាសាទច្រើនជាងពាន់ ដែលក្រាលដោយផែនក្ដារកែវពៃទូរ្យមានសម្បុររុងរឿងជារូបនិម្មិតក្នុងកែវមណី ។ សូមព្រះអង្គទ្រង់ទតឋានតាវត្តិង្ស យាមា តុសិត និម្មានរតី បរនិម្មិតវសវត្តី ជារូបនិម្មិតក្នុងកែវមណី ។ សូមព្រះអង្គទ្រង់ទតស្រះបោក្ខរណី ក្នុងជាន់នោះៗមានទឹកថ្លាស្អាតដ៏ជេរជាសដោយផ្កាចង្កុលណី ផ្កាឈូក និងផ្កាឧប្បលក្នុងឋានសួគ៌ទុំះ ។

បណ្ដាបទទាំងនោះ បទថា **បរោសហស្សំ** សេចក្ដីថា ប្រាសាទច្រើនជាងពាន់ក្នុងស្ថានតាវត្តិង្ស ។

ក្នុងកែវមណីនេះ មានធ្នូតស ១០ ធ្នូតក្រហម ៦ និង ១៥ ( ជា ៣១ ) ធ្នូតលឿង ១៤ គួរជាទីរមិលមើល ជាទីរីករាយនៃចិត្ត ។ ធ្នូតមាស ២០ ធ្នូតប្រាក់ ២០ ធ្នូតមានពន្លឺដូចជាពណ៌នៃអណ្ដើកមាស ៣០ ប្រាកដនៅក្នុងកែវមណីនេះ ។

ឆ្ទតខ្មៅ ១៦ ឆ្ទតហង្សបាទ ២៥ ឆ្ទតលាយដោយផ្កាច្បាវិចិត្រ ដោយផ្កាឧប្បលខៀវមានក្នុងកែវមណីនេះ ។ បពិត្រមហារាជ ប្រសើរជាងសត្វជើងពីរ សូមព្រះអង្គទ្រង់ទត ( កែវមណី ) មានរស្មីជាទីផ្សាយចេញនៃពន្លឺ ដ៏ប្រកបដោយអង្គទាំងពួងយ៉ាងនេះ ( អ្នកណាលេងឈ្នះខ្ញុំ ) ចំណែកនៃសួយ ( ចូរបានទៅអ្នកនោះចុះ ) ។

បណ្ដាបទទាំងនោះ បទថា **ទសេត្ថ រាជិយោ** សេចក្ដីថា ឆ្ទតស ១០ កន្លែងមាននៅក្នុងកែវមណីនោះ ។ បទថា **ឯ បិង្គលា បណ្ណរស** បានដល់ ឆ្ទតក្រហម ២១ ។ បទថា **ហលិទ្ទា** បានដល់ ឆ្ទតលឿងដូចរមៀត ១៤ កន្លែង ។ បទថា **តឹសតិ** សេចក្ដីថា ឆ្ទតដូចអណ្ដើកមាស ៣០ កន្លែង ។ បទថា ឥ ឥ សេចក្ដីថា ឆ្ទតពណ៌ខ្មៅ ១៦ កន្លែង ។ បទថា **មញ្ជេដ្ឋា បញ្ចវីសតិ** សេចក្ដីថា សូមទតឆ្ទតពណ៌ហង្សបាទ ២៥ កន្លែង ។ បទថា **មិស្សា ពន្ធុកបុប្ផេហិ** សេចក្ដីថា សូមទតឆ្ទតពណ៌ខ្មៅនិងឆ្ទតពណ៌ក្រហម ដ៏វិចិត្រ ដែលលាយដោយផ្កាទាំងនោះដ៏វិចិត្រ ។ ពិតហើយក្នុងកែវមណីនេះ មានឆ្ទតពណ៌ខ្មៅលាយដោយផ្កាច្បា ឆ្ទតពណ៌ក្រហមដោយផ្កាឧប្បលខៀវ ។ បទថា **ឱជិសុត្តំ** បានដល់ ជាចំណែកតម្លៃសម្រាប់ភ្នាល់ ។ បុណ្ណកយក្ខពោលថា អ្នកឈ្នះខ្ញុំដោយការលេងបាស្កា កែវមណីនេះនឹងជាចំណែកការភ្នាល់របស់បុគ្គលនោះ ។ បាលីក្នុងអដ្ឋកថាថា **ហោតុ សុត្តំ មហារាជ** បពិត្រមហារាជ កែវមណីចូរជាតម្លៃភ្នាល់ ដូច្នេះក៏មាន ។ ពាក្យនោះមានអធិប្បាយថា បពិត្រព្រះអង្គឧត្តមជាងសត្វជើងពីរ សូមទ្រង់ទតកែវមណីនេះ

គឺបែបនេះ បពិត្រមហារាជ កែវមណីនេះជាស្នួយរបស់ខ្ញុំ បុគ្គលណាឈ្នះខ្ញុំ ដោយការលេងបាស្កា កែវមណីនេះជាស្នួយរបស់បុគ្គលនោះ ។

**មណិកណ្ឌ ចប់**

បុណ្ណកយក្ខកាលពោលយ៉ាងនោះហើយសួរថា បពិត្រមហារាជ បើទ្រង់ឈ្នះទូលព្រះបង្គំដោយបាស្កា ទូលព្រះបង្គំនឹងថ្វាយកែវមណីនេះ តែបើទូលព្រះបង្គំឈ្នះទ្រង់ប្រទានអ្វីដល់ទូលព្រះបង្គំ ព្រះបាទធនញ្ជយៈត្រាស់ថា នែបា វៀរតែយើងស្វេតច្ឆត្រនិងអគ្គមហេសីចេញរបស់ដ៏សេសដែលជារបស់យើងៗឲ្យជាស្នួយសម្រាប់ឯង ។ បុណ្ណកយក្ខទូលថា បពិត្រព្រះសម្មតិទេព បើដូច្នោះទ្រង់កុំបង្អែបង្អង់ឡើយ ព្រោះទូលព្រះបង្គំមកអំពីចម្ងាយ សូមទ្រង់ចាត់ចែងរោងសម្រាប់លេងចុះ ។ ព្រះរាជាត្រាស់ឲ្យពួកអាមាត្យរៀបចំហើយ ។ អាមាត្យទាំងនោះចាត់ចែងរោងសម្រាប់លេងបាស្កាដោយរហ័ស ក្រាលព្រះទីន័ងដោយកម្រាលដ៏វិចិត្រសម្រាប់ព្រះរាជា តាក់តែងអាសនៈថ្វាយព្រះរាជាដ៏សេសនិងតាក់តែងអាសនៈដ៏សមគួរដល់បុណ្ណកយក្ខ ស្រេចហើយក្រាបបង្គំទូលកំណត់កាលដល់ព្រះរាជា ។

លំដាប់នោះបុណ្ណកយក្ខបានក្រាបទូលព្រះរាជាដោយគាថានេះថា

បពិត្រព្រះរាជា ( ការរៀបចំរោងល្បែង ) សម្រេចហើយ<br>
សូមព្រះអង្គស្តេចចូលមកកាន់ទីជាទីក្រសាលល្បែង កែវមណី<br>
ប្រាកដដូច្នេះរបស់ព្រះអង្គមិនមានទេ យើងគប្បីឈ្នះគ្នាដោយ

ធម៌ មិនបាច់កំហែងទេ មួយទៀតព្រះអង្គបើខ្ញុំឈ្នះហើយសូម

សងឲ្យឆាប់ ដូច្នេះ ។

ពាក្យដែលជាគាថានោះមានអធិប្បាយថា បពិត្រមហារាជ កម្មក្នុងរោងបាស្កាចូលដល់ហើយ គឺសម្រេចហើយ តែវមណីបែបនេះមិនមានដល់ទ្រង់ សូមទ្រង់កុំធ្វើឲ្យយឺតយូរ ។ បទថា **ឧបេហិ លក្ខំ** សេចក្តីថា សូមទ្រង់ចូលមកកាន់រោងបាស្កាដែលជាទីសម្រាប់លេង កាលបើលេង យើងទាំងឡាយគប្បីឈ្នះចាញ់ដោយធម៌ប៉ុណ្ណោះ ការឈ្នះចូរមានដល់យើងទាំងឡាយដោយស្ងប់ចុះ បើទ្រង់គប្បីឈ្នះសោតកាលបើដូច្នេះសូមទ្រង់កុំយឺតយូរ គឺកុំធ្វើឲ្យយឺតយូរ គប្បីឲ្យទ្រព្យដែលទូលព្រះបង្គំឈ្នះ ។

លំដាប់នោះព្រះរាជាក៏ត្រាស់នឹងបុណ្ណកយក្ខនោះថា នែមាណព ឯងកុំខ្លាចយើងថាជាព្រះរាជា ឈ្នះឬចាញ់នឹងមានដោយធម៌ប៉ុណ្ណោះ ការឈ្នះនិងការចាញ់របស់យើងនឹងមានដោយស្ងប់ ។

បុណ្ណកយក្ខ បានស្តាប់ដូច្នោះទើបទូលថា សូមទ្រង់ទាំងឡាយជ្រាបការឈ្នះនិងការចាញ់របស់យើងទាំងពីរ ដោយធម៌ប៉ុណ្ណោះ ដូច្នេះហើយកាលធ្វើព្រះរាជាទាំងនោះឲ្យជាបន្ទាល់ទើបពោលគាថានេះថា

បពិត្រព្រះបាទបញ្ចាល ដ៏ល្បីល្បាញ សូមព្រះបាទសុរសេន

ព្រះបាទមច្ឆៈ ព្រះបាទមទ្ទៈព្រមទាំងព្រះបាទកេកកៈ ទាំងនោះ

ទ្រង់ទតចម្បាំងល្បែង ដោយការមិនអួតអាង របស់យើងចុះ

ក្សត្រទាំងឡាយសុទ្ធតែធ្វើ ( ជាសាក្សី ) របស់យើងក្នុងរោង

ដូច្នេះ ។

បណ្ដាបទទាំងនោះ បុណ្ណកយក្ខហៅព្រះបាទបញ្ចាលថា **បច្ចុគ្គតា** ព្រោះជាអ្នកល្បីល្បាញ គឺជាអ្នកប្រាកដជាក់ច្បាស់ ។ បទថា **មច្ឆា ច** សេចក្ដីថា បពិត្រសម្លាញ់ ទ្រង់ជាព្រះរាជាក្នុងមច្ឆរដ្ឋ ។ បទថា **មទ្ទា** សេចក្ដីថា បពិត្រព្រះបាទមទ្ទរាជ ។ បទថា **សហ កេកកេភិ** សេចក្ដីថា បពិត្រព្រះបាទវត្តមានកេកកករាជមួយអន្លើដោយអ្នកជនបទឈ្មោះកេកកៈ ។ ម្យ៉ាងទៀត បណ្ឌិតដាក់ **សហ** សព្ទទុកខាងក្រោយបទថា **កេកកេភិ** និងធ្វើសព្ទថា **បច្ចុគ្គត** ឲ្យជាបទវិសេសនៈនៃបទថា **សូរសេន** ហើយគប្បីជ្រាបសេចក្ដីក្នុងគាថានេះយ៉ាងនេះថា បពិត្រព្រះបាទសូរសេនមច្ឆៈ ដែលប្រាកដក្នុងដែនបញ្ចាលនិងព្រះបាទមទ្ទៈនិងព្រះរាជាដ៏សេសមួយអន្លើដោយអ្នកជនបទឈ្មោះថា កេកកៈ ។ បទថា **បស្សន្តុ នោ តេ** សេចក្ដីថា សូមព្រះរាជាទាំងនោះ មើលនូវការលេងនិងដាក់ពិន្ទុដោយបាសកា ដែលមិនវៀចវេរបស់យើងទាំង ២ ។ បទថា **នោ** ក្នុងបទថា **ន នោ សភាយំ ន ករោន្តិ កិញ្ចិ** នេះ ត្រឹមតែជានិបាត សេចក្ដីថា ក្សត្រទាំងឡាយក្ដី ព្រាហ្មណ៍ទាំងឡាយក្ដី មិនធ្វើបុគ្គលណា ឲ្យជាបន្ទាល់ក្នុងទីប្រជុំរមែងមិនមាន ព្រោះហេតុនោះទើបបុណ្ណកយក្ខបានធ្វើព្រះរាជាឲ្យជាបន្ទាល់យ៉ាងនេះថា ទ្រង់ទាំងឡាយនឹងមិនបានពោលថា ហេតុដែលមិនសមគួរ អ្វីរមែងកើតឡើង ពួកយើងមិនបានឮ ពួកយើងមិនឃើញ ពួកអ្នកចូរជាអ្នកមិនប្រមាទចុះ ។

លំដាប់នោះព្រះបាទធនញ្ចយកោរព្យរាជ មានព្រះរាជា ១០១ អង្គចោម

ពោមជាបរិវារ ទ្រង់នាំបុណ្ណកយក្ខចូលកាន់រោងសម្រាប់លេង ព្រះរាជាទាំងអស់និងបុណ្ណកយក្ខក៏ប្រថាប់គង់និងអង្គុយលើអាសនៈដែលសមគួរហើយ ។ ក្នាក់ងារក៏លើកក្តារបាស្កាដែលធ្វើដោយប្រាក់និងកូនបាស្កា ដែលធ្វើដោយមាសមកដាក់ត្រង់កណ្តាល ។ ឯបុណ្ណកយក្ខ បានក្រាបទូលថា បពិត្រមហារាជប្រលោះ ( ក្រឡា ) បាស្កាទាំងឡាយចាត់ជា ២៤ មានឈ្មោះថា មាលីសាវត្តី ពហុលនិងសន្តិភទ្ទជាដើម ក្នុងក្រឡាទាំងនោះសូមទ្រង់កាន់យកក្រឡាដែលគាប់ព្រះហឫទ័យទ្រង់ចុះ ។ ព្រះរាជាត្រាស់ថា សាធុ ហើយទ្រង់កាន់យកក្រឡាដែលឈ្មោះថា ពហុល បុណ្ណកយក្ខកាន់យកក្រឡាដែលឈ្មោះថា សាវត្តី ខណៈនោះព្រះរាជាត្រាស់នឹងបុណ្ណកយក្ខថា នែមាណព បើដូច្នោះចូរអ្នកដើរកូនបាស្កាមុន ។ បុណ្ណកយក្ខក្រាបទូលថា បពិត្រមហារាជ វារៈដែលទូលព្រះបង្គំដើរមិនទាន់ដល់ សូមទ្រង់ដើរមុនចុះ ព្រះរាជាត្រាស់ថា សាធុ ។ អារក្ខទេវតាដែលធ្លាប់ជាមាតារបស់ព្រះរាជាក្នុងអត្តភាពទី ៣ មានព្រះរាជាទ្រង់ឈ្នះបាស្កា ព្រោះអានុភាពនៃអារក្ខទេវតានោះ ។ អារក្ខទេវតានោះបានស្ថិតនៅក្នុងទីជិតនៃព្រះរាជា ។ ព្រះរាជាទ្រង់រឭកដល់ទេពធីតានោះកាលទ្រង់ច្រៀងចម្រៀងបាស្កាទើបត្រាស់ព្រះគាថានេះថា

បពិត្រមាតាសូមទ្រង់ថែរក្សាខ្ញុំផង ឲ្យជ័យជម្នះប្រាកដដល់ខ្ញុំ
បពិត្រមាតាសូមព្រះមាតាអនុគ្រោះដល់ខ្ញុំ ការឈ្នះដ៏ច្រើននឹង
មានដល់ខ្ញុំ កូនបាស្កាដែលធ្វើដោយមាសជម្ពូនទក្រឡា ៤
ជ្រុង ទទឹងនិងបណ្តោយ ៨ ធ្នាប់ រុងរឿងក្នុងកណ្តាលបរិស័ទ

ដូចកែវមណីមានរស្មីភ្លឺស្វាងដែលខ្ញុំដើរក្នុងកាលឥឡូវនេះ សូមឲ្យប្រែត្រឡប់តាមចិត្តប៉ង បពិត្រទេវតា សូមឲ្យនូវជ័យជម្នះដល់ខ្ញុំ សូមឃើញដល់ខ្ញុំដែលមានភោគសម្បត្តិតិច ជាបុគ្គលដែលមាតាធ្លាប់ជួយអនុគ្រោះស្រោចហើយ នឹងជួបតែសេចក្តីចម្រើនគ្រប់កាល កូនបាស្កាឈ្មោះ មាលី លោកពោលថាមាន ៨ កូនបាស្កាឈ្មោះសាវត្តី លោកពោលថាមាន ៦ កូនបាស្កាឈ្មោះពហុលមាន ៤ កូនបាស្កាឈ្មោះសន្តិកទូមាន ២ ក្តារបាស្កានោះអ្នកប្រាជ្ញប្រកាសថា មានក្រឡា ២៤ ។

ព្រះរាជាកាលទ្រង់ច្រៀងចម្រៀងបាស្កាហើយ ទ្រង់ត្រឡប់កូនបាស្កាដោយដៃបោះទៅក្នុងអាកាស ដោយអានុភាពនៃបុណ្ណកយក្ខ កូនបាស្កាញុំាងព្រះរាជាឲ្យបរាជ័យ រមែងធ្លាក់ចុះមិនល្អ ។ ព្រះរាជាទ្រង់ឈ្លាសក្នុងសិប្បសាស្ត្រខាងល្បែងបាស្កា កាលទ្រង់ជ្រាបថា កូនបាស្កាវិលធ្លាក់ចុះធ្វើទ្រង់ឲ្យបរាជ័យ ទ្រង់ក៏ចាប់មកវិញក្នុងអាកាស ហើយទ្រង់បោះទៅក្នុងអាកាសសាជាថ្មី ក្នុងគ្រាទី ២ ទ្រង់ដឹងថា កូនបាស្កាធ្លាក់ធ្វើឲ្យទ្រង់បរាជ័យទ្រង់ក៏ចាប់យ៉ាងនោះដូចគ្នា ។ លំដាប់នោះបុណ្ណកយក្ខត្រិះរិះថា ព្រះរាជាអង្គនេះលេងបាស្កាជាមួយយក្ខដូចអញនៅតែលូកដៃមកចាប់កូនបាស្កាដែលកំពុងធ្លាក់បានព្រោះហេតុអ្វីហ្ន៎ កាលដឹងថាព្រោះអានុភាពរបស់អារក្ខទេវតា ទើបបើកភ្នែកសម្លឹងអារក្ខទេវតានោះ សម្តែងអាកប្បកិរិយាដូចជាក្រោធ អារក្ខទេវតាគ្រាន់តែបុណ្ណកយក្ខសម្លឹងមើលប៉ុណ្ណោះក៏ភ័យខ្លាច រត់ទៅដល់ទីបំផុតនៃភ្នំកណ្តាប់

ចក្កវាឡ បានឈរពួនមើលទាំងខ្ទួនញ័រចំប្រប់ ។ ព្រះរាជាទ្រង់បោះកូនបាស្កា ក្នុងគ្រាទី ៣ សូម្បីទ្រង់ដឹងថាកូនបាស្កាធ្លាក់ចុះហើយ នឹងធ្វើទ្រង់ឲ្យបរាជ័យ ក៏ទ្រង់មិនអាចលាព្រះហស្តចាប់ទាន់ព្រោះអានុភាពនៃបុណ្ណកយក្ខ កូនបាស្កា ធ្លាក់ចុះមិនល្អធ្វើព្រះរាជាឲ្យបរាជ័យ ។ លំដាប់នោះបុណ្ណកយក្ខដឹងថា ព្រះរាជាបរាជ័យ មានចិត្តត្រេកអរទះដៃសើចដោយសំឡេងដ៏ខ្លាំង ៣ ដងថា ខ្ញុំឈ្នះហើយ ខ្ញុំឈ្នះហើយដូច្នេះ ។ សំឡេងនោះបានផ្សាយឮទៅពេញជម្ពូទ្វីប ។

**តមត្ថំ បកាសេន្តោ សត្ថា អាហា** វីអាចិធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថៃងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសាទូវព្រះគាថាដូច្នេះថា

ព្រះរាជារបស់អ្នកដែនកុរុនិងបុណ្ណកយក្សនោះ ជាអ្នកស្រវឹង
ជ្រុលជ្រប់ក្នុងល្បែងភ្នាល់ ចូលមក ( កាន់រោងល្បែង )
ព្រះរាជាជ្រើសយកកូនបាសកា ជាទោស ( ខាងចាញ់ )
បុណ្ណកយក្សចាប់យកកូនបាសកាខាងឈ្នះ ជនទាំងពីរនោះបាន
លេងបាសការួមគ្នា ក្នុងរោងបាសកានោះហើយ បុណ្ណកយក្ស
ឈ្នះព្រះរាជាមានព្យាយាមប្រសើរជាងនរៈក្នុងសំណាក់នៃពួក
ព្រះរាជា ក្នុងកណ្តាលនៃពួកសាក្សី សំឡេងគឹកកង សំឡេង
ហ៊ោកញ្ជ្រៀវ ក៏កើតមានក្នុងទីនោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ចាវិសុំ** សេចក្តីថា ចូលទៅក្នុងរោងបាស្កា ។ បទថា **វិចិនំ** សេចក្តីថា ព្រះរាជាទ្រង់ជ្រើសរើសក្នុងក្រឡា ២៤ បានកាន់

យកក្នុងក្រឡាដែលមានទោស គឺកាន់យកក្នុងក្រឡាបរាជ័យ ។ បទថា **កដមគ្គហិ** សេចក្តីថា ចំណែកបុណ្ណកយក្ខកាន់យកក្រឡាជ័យជម្នះ ។ បទថា **តេ តត្ថ ជូតេ ឧភយោ សមាគតេ** សេចក្តីថា ព្រះរាជានិងបុណ្ណកយក្ខទាំង ២ នោះកាលភ្នាក់ងារយកបាស្កាមកព្រមគ្នាក្នុងរោងលេងបាស្កានោះ ជនទាំងពីរបានលេងបាស្កាហើយ ។ បទថា **រញ្ញំ** សេចក្តីថា កាលបុណ្ណកយក្ខនោះឈ្នះព្រះរាជាដែលក្លៀវក្លា ប្រសើរជាងនរជននៅក្នុងកណ្តាលនៃព្រះរាជា ១០១ និងសាក្សីដ៏សេស ។ បទថា **តត្ថប្បនាទោ តុមុលោ ពភូវ** សេចក្តីថា សំឡេងលាន់ឮមានឡើងក្នុងមណ្ឌលល្បែងនោះ ៣ ដងថា សូមទ្រង់ទាំងឡាយជ្រាបភាពដែលព្រះរាជាទ្រង់បរាជ័យហើយ ខ្ញុំឈ្នះហើយ ខ្ញុំឈ្នះហើយ ។

ព្រះរាជា កាលទ្រង់បរាជ័យហើយ ទ្រង់មានព្រះហឫទ័យទោមនស្សជាកម្លាំង គ្រានោះបុណ្ណកយក្ខកាលលួងលោមព្រះរាជា ឲ្យស្រាកស្រាន្តក្នុងព្រះហឫទ័យទើបពោលគាថានេះថា

បពិត្រមហារាជ បណ្តាពួកយើងដែលខំប្រឹងព្យាយាម ការឈ្នះ
និងការចាញ់គង់មាន ដល់អ្នកណាមួយ បពិត្រព្រះអង្គជាធំ
ជាងជន ឥឡូវនេះខ្ញុំព្រះអង្គឈ្នះហើយ ( ត្រូវយក ) ទ្រព្យ
ដ៏ប្រសើរ ព្រះអង្គដែលខ្ញុំឈ្នះហើយសូមសងឲ្យឆាប់ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អាយុហតំ** សេចក្តីថា បណ្តាយើងទាំងពីរដែលព្យាយាមលេងបាស្កា ការឈ្នះនិងការចាញ់ រមែងមានដល់បុគ្គលណា

ម្នាក់ជាធម្មតា ព្រោះហេតុនោះទ្រង់កុំគិតថា អញជាអ្នកចាញ់ឡើយ ។ បទថា **ជិន្នោសិ** សេចក្តីថា ទ្រង់ជាអ្នកសាបសូន្យហើយ ។ បទថា **វរទ្ធនេន** បាន ដល់ ចាកទ្រព្យដ៏ប្រសើរ ។ បទថា **ទិប្បមាការោហិ** សេចក្តីថា សូមទ្រង់ព្រះរាជទានទ្រព្យសម្រាប់ជាថ្លៃជ័យជម្នះដោយរួសរាន់ចុះ ។

លំដាប់នោះព្រះរាជាកាលត្រាស់នឹងបុណ្ណកយក្ខថា ចូរទទួលយកចុះទើបត្រាស់ព្រះគាថានេះថា

ម្នាលមាណពកច្ចាយនគោត្ត ដំរី គោ សេះ កែវមណីនិងកុណ្ឌល ឬកែវណាមួយរបស់ខ្ញុំលើផែនដី បណ្តាទ្រព្យទាំង ( នោះ ) អ្នកចូរយកទ្រព្យណាដែលប្រសើរនោះចុះ អ្នកចូរកាន់យកទៅតាមសេចក្តីពេញចិត្តចុះ ។

បុណ្ណកយក្សក្រាបទូលថា

ដំរី គោ សេះ កែវមណីនិងកុណ្ឌល ឬកែវណាមួយរបស់ព្រះអង្គលើផែនដី វិធុរបណ្ឌិតអាមាត្យ ទុកជាទ្រព្យប្រសើរជាងទ្រព្យទាំងនោះ ព្រះអង្គដែលខ្ញុំឈ្នះហើយសូមព្រះរាជទានវិធុរបណ្ឌិតនោះមកខ្ញុំ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សោ មេ ជិតោ** សេចក្តីថា ខ្ញុំឈ្នះទ្រង់ហើយ រតនៈដ៏ឧត្តមខ្ញុំឈ្នះក្នាល់បានហើយ ឯវិធុរបណ្ឌិតក៏ជាបុគ្គលប្រសើរជាងរតនៈទាំងពួងព្រោះហេតុនោះឈ្មោះថា ខ្ញុំឈ្នះក្នាល់បានវិធុរបណ្ឌិតហើយ សូមទ្រង់ព្រះរាជទានវិធុរបណ្ឌិតដល់ខ្ញុំចុះ ។ ព្រះរាជាក៏ត្រាស់ព្រះគាថាថា

វិធុរបណ្ឌិតនោះទុកដូចជាខ្លួនខ្ញុំ ទាំងជាទីពឹង ជាគតិ ជាប្រទីប ជាទីពំនាក់ ជាទីបង្អែករបស់ខ្ញុំ វិធុរបណ្ឌិតនោះគេមិនគប្បី ប្រៀបផ្ទឹមដោយទ្រព្យរបស់បានទេ វិធុរបណ្ឌិតនោះជាអាមាត្យ ប្រាកដស្មើដោយជីវិតរបស់ខ្ញុំ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អត្តា ច មេ សោ** សេចក្តីថា វិធុរបណ្ឌិតនោះឈ្មោះថាជាខ្លួនរបស់យើង យើងបានពោលហើយថា វៀរតែខ្លួននៃយើង ស្វេតច្ឆត្រនិងអគ្គមហេសីចេញ ក្រៅពីនោះយើងឲ្យដល់អ្នក ព្រោះហេតុនោះ អ្នកកុំកាន់យកវិធុរបណ្ឌិតនោះ វិធុរបណ្ឌិតនោះ មិនមែនត្រឹមតែជាខ្លួនរបស់ខ្ញុំប៉ុណ្ណោះទេ ដោយពិតវិធុរបណ្ឌិតនោះជាទីពឹង ជាគតិ ជាកោះ ជាទីជ្រកកោននិងជាទីទៅខាងមុខរបស់យើងទៀតផង ។ បទថា **អសន្តុលេយ្យោ មម សោ ធនេន** សេចក្តីថា អ្នកមិនគួរប្រៀបធៀបវិធុរបណ្ឌិតនឹងទ្រព្យ ៧ ប្រការរបស់យើងឡើយ ។ បុណ្ណកយក្ខពោលថា

ការវិវាទរបស់ខ្ញុំនិងព្រះអង្គនាំឲ្យយូរទេ យើងត្រូវទៅសួរសេចក្តីពិតនឹងវិធុរបណ្ឌិតនោះវិញ សូមឲ្យវិធុរបណ្ឌិតទុំរំញែកសេចក្តីទុំដល់យើង បើវិធុរបណ្ឌិតពោលពាក្យណា ពាក្យ ( នោះ ) ចូរសម្រេចដល់យើងទាំងពីរនាក់ចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វិវរតុ ឯតមត្ថំ** សេចក្តីថា សូមវិធុរបណ្ឌិតនោះឯងជាអ្នកប្រកាសថា លោកជាខ្លួនរបស់ទ្រង់មែនឬមិនមែន ។ បទថា **ហោតុ កថា ឧភិន្នំ** សេចក្តីថា ពាក្យវិធុរបណ្ឌិតនោះឯង ចូរជាប្រមាណ

ដល់យើងទាំងពីរ ។

ព្រះរាជាត្រាស់ថា

ម្នាលមាណព អ្នកនិយាយនេះទៀងទាត់ពិតហើយ មិនមែន
និយាយទាំងគំរាមទេ យើងនឹងទៅសួរវិធុរបណ្ឌិតនោះចុះ យើង
ទាំង ២ នាក់ នឹងត្រេកអរតាមវិធុរបណ្ឌិតនោះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ន ច មាណវ សាហសំ** សេចក្ដីថា អ្នកកុំពោលសន្ដត់សន្ដិនដោយការរួសរាន់ឡើយ ។

កាលព្រះរាជាត្រាស់យ៉ាងនេះហើយ ទ្រង់ត្រេកអរនាំព្រះរាជា ១០១ អង្គ និងបុណ្ណកយក្ខចូលទៅកាន់រោងធម្មសភាដោយរហ័ស ។ វិធុរបណ្ឌិតចុះចាកអាសនៈ ថ្វាយបង្គំព្រះរាជាហើយ បានឈរក្នុងទីដ៏សមគួរទាចំណែកម្ខាង លំដាប់នោះបុណ្ណកយក្ខ ចរចាប្រាស្រ័យនឹងព្រះមហាសត្វថា បពិត្របណ្ឌិត កិត្តិសព្ទរបស់លោកបានប្រាកដទៅក្នុងសកលលោកថា លោកតាំងនៅក្នុងធម៌ រមែងមិននិយាយកុហកព្រោះហេតុនៃជីវិត ខ្ញុំដឹងភាពដែលលោកតាំងនៅក្នុងធម៌បានក្នុងថ្ងៃនេះឯង ហើយពោលគាថានេះថា

ពួកទេវតាសរសើរអ្នកឈ្មោះ វិធុរៈថាជាអាមាត្យឋិតនៅក្នុងធម៌
របស់អ្នកដែនកុរុពិតមែនឬ អ្នកជាទាសៈ ឬជាញាតិរបស់ព្រះ
រាជា គេរាប់ ( អ្នក ) ថាវិធុរៈ តើអ្នកជាអ្វីក្នុងលោក ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សច្ចំ នុ ទេវា វិទហូ កុរូនំ ធម្មេ ឋិតំ វិធុរន្នាមមច្ចំ** សេចក្ដីថា ខ្ញុំសូមសួរថា ទេវតាទាំងឡាយហៅ គឺពោល

ប្រកាសយ៉ាងនេះថា អាមាត្យឈ្មោះវិធុរបណ្ឌិតក្នុងធម៌នៃដែនកុរុ តាំងនៅក្នុងធម៌ មែនមិនពោលមុសាសូម្បីហេតុនៃជីវិត ទេវតាទាំងនោះកាលជ្រាបច្បាស់យ៉ាងនេះពោលតែពាក្យពិតឬពោលតែពាក្យមិនពិត ។ បទថា **វិធុរោតិ សង្ខ្យាកតមោសិ លោកេ** សេចក្តីថា ឈ្មោះរបស់លោកប្រាកដក្នុងលោកថា វិធុរៈ អ្នកនោះជានរណាចូរប្រាប់ គឺជាទាសៈ ជាបុគ្គលថោកថយ ឬជាបុគ្គលស្មើ ឬក្រៃលែងជាង ឬជាញាតិរបស់ព្រះរាជា ពាក្យដែលខ្ញុំសួរមកហើយនេះ ចូរប្រាប់ដល់ខ្ញុំជាមុនថា លោកជាទាសៈឬជាព្រះញាតិរបស់ព្រះរាជា ។

លំដាប់នោះព្រះមហាសត្វត្រិះរិះថា មាណពនេះសួរអញយ៉ាងនេះ អញនឹងប្រាប់ថា ខ្ញុំជាញាតិរបស់ព្រះរាជា ខ្ញុំជាបុគ្គលខ្ពស់ជាងព្រះរាជាឬមិនជាអ្វីនឹងគ្នាឡើយរបស់ព្រះរាជាដូច្នេះក៏បានដូចគ្នា តែឈ្មោះថាទីពឹងក្នុងលោកនេះស្មើដោយសច្ចៈមិនមានឡើយ អញគួរពោលពាក្យពិតប៉ុណ្ណោះ ដើម្បីសម្តែងថា នែមាណព ខ្ញុំមិនជាព្រះញាតិរបស់ព្រះរាជានិងមិនមែនជាបុគ្គលខ្ពស់ជាងព្រះរាជាតែខ្ញុំជាទាសៈណាមួយ បណ្តាទាសៈទាំង ៤ ពួកទើបពោលគាថា ២ ថា

> បុគ្គលពួកខ្លះជាទាសៈកើតក្នុងផ្ទៃខ្ញុំស្រី ពួកខ្លះជាទាសៈគេលោះដោយទ្រព្យ ពួកខ្លះជាទាសៈចូលទៅនៅខ្លួនឯង ពួកខ្លះបោះបង់ ( ទីលំនៅ ) ព្រោះភ័យទៅនៅជាទាសៈគេ ទាសៈរបស់ជនទាំងឡាយមាន ៤ ពួកនេះឯង ។ ឯយើងពិតជាទាសៈកើតអំពីកំណើត ព្រះរាជាមានសេចក្តីចម្រើនក្តី ព្រះរាជាមានសេចក្តី

មិនចម្រើនក្តី ( យើងមិនអាចនឹងពោលកុហកបានទេ ) យើង
បើទុកជាទៅកាន់ទីដទៃ ក៏គង់នៅជាទាសៈរបស់ព្រះសម្មតិទេព
ម្នាលមាណព ព្រះរាជាគួរប្រទានយើងដល់អ្នកដោយធម៌ ។

បណ្តាបទទាំងនោះ បទថា **អាមាយទាសា** បានដល់ ទាសៈដែលកើតក្នុងផ្ទៃនៃទាសីដែលមានប្តីជាទាសៈ ។ បទថា **សយំបិ ហោកេ ឧបយន្តិ ទាសា** សេចក្តីថា មនុស្សពួកណានីមួយកើតមកជាអ្នកបម្រើគេទាំងអស់នោះឈ្មោះថា ទាសៈដែលគេដល់នូវភាពជាទាសៈឯង ។ បទថា **ភយា បនុន្នា** សេចក្តីថា បុគ្គលដែលជាឈ្លើយត្រូវដេញចេញអំពីលំនៅរបស់ខ្លួន ដោយរាជភ័យឬចោរភ័យ សូម្បីទៅកាន់ដែននៃសត្រូវក៏ឈ្មោះថាជាទាសៈដូចគ្នា ។ បទថា **អទ្ធា ហិ យោនិតោ អហំបិ ជាតោ** សេចក្តីថា នៃមាណព ខ្ញុំក៏ជាទាសៈកើតអំពីកំណើតទាសៈនោះឯង រួមនៅក្នុងកំណើតទាសៈ ៤ ពួកដោយចំណែកមួយពិត ។ បទថា **ភវោ ច រញ្ញោ អភវោ ច រញ្ញោ** សេចក្តីថា ការចម្រើនឬការវិនាសមានដល់ព្រះរាជាក៏ដោយ ខ្ញុំមិនអាចនិយាយកុហកបានឡើយ ។ បទថា **បរំបិ** សេចក្តីថា ខ្ញុំសូម្បីទៅក្នុងទីឆ្ងាយក៏ត្រូវជាទាសៈរបស់ព្រះរាជាដដែល ។ បទថា **ធម្មា** សេចក្តីថា ព្រះរាជាលះបង់ខ្ញុំដោយទ្រព្យដែលអ្នកឈ្នះ គប្បីនាំទៅព្រះរាជទានដល់អ្នក ក៏គប្បីព្រះរាជទានដោយធម៌ គឺដោយសេចក្តីពិតនោះឯង ។

បុណ្ណកយក្ខបានឮដូច្នោះក៏ត្រេកអរទេះដៃម្តងទៀត ហើយបានពោលគាថានេះថា

នេះឯងជាជ័យជម្នះទី ២ របស់ខ្ញុំក្នុងថ្ងៃនេះ ព្រោះថា ( វិធុរៈ ) អាមាត្យដែលខ្ញុំសួរហើយក៏ញែកប្រស្នាហើយ ឱហ្ន៎ ព្រះរាជាដ៏ប្រសើរមិនតាំងនៅក្នុងធម៌ ទ្រង់មិនអនុញ្ញាតឲ្យនូវវិធុរបណ្ឌិតជាអ្នកពោលពាក្យពីរោះដល់ខ្ញុំ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **រាជសេដ្ឋោ** សេចក្ដីថា ព្រះរាជាដ៏ប្រសើរនេះមិនតាំងនៅក្នុងធម៌ហ្ន៎ ។ បទថា **សុភាសិតំ** សេចក្ដីថា វិធុរបណ្ឌិតពោលល្អហើយ គឺវិនិច្ឆ័យល្អហើយ ។ បទថា **ឆាន្ទុជាឆាសិ មយ្ហំ** សេចក្ដីថា បុណ្ណកយក្ខពោលថា ព្រោះហេតុអ្វីទើបទ្រង់មិនព្រមឲ្យវិធុរបណ្ឌិតដល់ខ្ញុំ ទ្រង់មិនឲ្យព្រោះអ្វី ។

ព្រះរាជាបានស្ដាប់ដូច្នោះទ្រង់ទោមនស្សគិតថា វិធុរបណ្ឌិតនេះមិនឃើញដល់បុគ្គលដែលមានឧបការគុណដែលឲ្យលាភ ឲ្យយសដូចជាអញ ឃើញដល់មាណព ដែលទើបតែឃើញគ្នាអម្បាញ់មិញនេះ ហើយទ្រង់ពិរោធដល់ព្រះមហាសត្វ ត្រាស់នឹងបុណ្ណកយក្ខថា នែមាណព បើវិធុរបណ្ឌិតជាទាសៈចូរអ្នកយកទៅចុះ ដូច្នេះហើយទើបត្រាស់គាថានេះថា

បើវិធុរបណ្ឌិតនោះញែកប្រស្នាដល់យើងយ៉ាងនេះថា ខ្ញុំជាទាសៈមិនមែនជាញាតិទេ ម្នាលកច្ចាន: អ្នកចូរយកវិធុរបណ្ឌិតជាទ្រព្យដ៏ប្រសើរជាងទ្រព្យទាំងឡាយចុះ អ្នកចូរយកទៅតាមពេញចិត្តចុះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឯវញ្ចេ នោ សោ វិវរេត្ថ បញ្ហំ** សេចក្ដី

ថា បើវិធុរបណ្ឌិតបើកផ្សារនូវបញ្ហាយ៉ាងនេះថា ខ្ញុំជាទាសៈមិនមែនជាញាតិទេ ចូរអ្នកទទួលយកវិធុរបណ្ឌិតដែលជារតនៈដ៏ប្រសើរជាងទ្រព្យទាំងឡាយក្នុងលោកទាំងមូល នាំទៅតាមសេចក្តីប្រាថ្នាក្នុងបណ្តាបរិស័ទមណ្ឌលរបស់អ្នកចុះ ។

## អក្ខកណ្ឌ ចប់

កាលព្រះរាជាត្រាស់យ៉ាងនេះហើយ ទើបទ្រង់ព្រះតម្រិះថា មាណពនាំវិធុរបណ្ឌិតទៅតាមគាប់ចិត្ត តាំងពីថ្ងៃដែលវិធុរបណ្ឌិតចេញទៅ អញលែងបានស្តាប់ធម្មកថាដ៏ពីរោះ ណ្ហើយចុះ អញគួរឲ្យវិធុរបណ្ឌិតសម្រាកនៅក្នុងទីកដីរបស់ខ្លួនសួរបញ្ហាក្នុងឃរាវាសធម៌ជាមុនសិន ។ គ្រានោះព្រះរាជាទ្រង់អារាធនាមហាសត្វយ៉ាងនេះថា បពិត្របណ្ឌិត កាលអ្នកចេញទៅហើយខ្ញុំលែងបានស្តាប់ធម្មកថាដ៏ពីរោះ ចូរអ្នកសម្រាកក្នុងទីកដីរបស់ខ្លួនសិន សូមអង្គុយលើធម្មាសនៈដែលប្រដាប់ហើយ សម្តែងបញ្ហាក្នុងឃរាវាសធម៌ដល់ខ្ញុំនាកាលឥឡូវនេះ ។ ព្រះមហាសត្វទទួលព្រះរាជឱង្ការថា សាធុ ហើយអង្គុយលើធម្មាសនៈដែលប្រដាប់ហើយ វិសជ្ជនាបញ្ហាដែលព្រះរាជាត្រាស់សួរក្នុងឃរាវាសធម៌នោះដូចតទៅនេះថា

ម្នាលវិធុរៈ កាលបុគ្គលជាគ្រហស្ថ នៅគ្រប់គ្រងផ្ទះរបស់ខ្លួន
តើគួរមានការប្រព្រឹត្តិដ៏ក្សេមក្សាន្តដោយប្រការដូចម្តេច គួរមាន
ការសង្គ្រោះដោយប្រការដូចម្តេចហ្ន៎ ។ គួរមានការមិនមានទុក្ខ

ដោយប្រការដូចម្តេច មាណពឈ្មោះថា ពោលពាក្យពិត តើ
ដោយប្រការដូចម្តេច បុគ្គលជាគ្រហស្ថ ចេញចាកលោកនេះ
ទៅកាន់លោកខាងមុខ លុះទៅកាន់លោកខាងមុខហើយរមែង
មិនសោកស្តាយ តើដោយប្រការដូចម្តេច ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ខេមា វុត្តិ កថំ អស្ស** សេចក្តីថា គ្រហស្ថដែលនៅគ្រប់គ្រងផ្ទះគប្បីប្រព្រឹត្តខ្លួនឲ្យផុតភ័យបានដូចម្តេច ។ បទថា **កថន្នុ អស្ស សង្គហោ** សេចក្តីថា បុគ្គលគប្បីមានការសង្គ្រោះ ពោលគឺសង្គហវត្ថុ ៤ ប្រការដូចម្តេច ។ បទថា **អព្យាបជ្ឈំ** បានដល់ ភាពជាអ្នកប្រាសចាកទុក្ខ ។ បទថា **សច្ចវាទី ច** សេចក្តីថា ទោះជាយ៉ាងណាមាណពគប្បីឈ្មោះថា ពោលតែពាក្យពិត ។ បទថា **បេច្ច** បានដល់ ទៅកាន់បរលោក ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសានូវព្រះគាថាដូច្នេះថា

វិធុរបណ្ឌិត អ្នកមានញាណគតិ មានព្យាយាម មានប្រាជ្ញា
យល់អត្ថ យល់ធម៌ទាំងពួង បានឆ្លើយប្រស្នានុ៎ះនឹងព្រះរាជា
នោះក្នុងរោងធម្មសភានោះថា គ្រហស្ថមិនគប្បីជាអ្នកមានប្រពន្ធ
សាធារណៈ មិនគួរបរិភោគអាហារ មានរសឆ្ងាញ់តែម្នាក់ឯង
មិនគួរគប់រករឿងផ្តេសផ្តាសដែលទាក់ទងនឹងលោក ( ព្រោះ )
រឿងបែបនុ៎ះមិនមែនជាគ្រឿងចម្រើនប្រាជ្ញាទេ ។ គ្រហស្ថគួរជា

អ្នកមានសីលបរិបូណ៌ដោយវត្តមិនប្រហែស មានប្រាជ្ញាវាងវៃ ជាអ្នកប្រព្រឹត្តឱនលំទោន មិនរឹងត្អឹង ជាអ្នកស្លូតបូត មានពាក្យទន់ពីរោះ មានអាការដ៏ទន់ភ្លន់ ។ ជាអ្នកសង្គ្រោះមិត្តទាំងឡាយ ជាអ្នកចែករំលែកទាន មានការចាត់ចែងដ៏ល្អ ញុំាងសមណព្រាហ្មណ៍ឲ្យឆ្អែតស្កប់ស្កល់ដោយបាយនិងទឹកក្នុងកាលទាំងពួង ។ ជាអ្នកប្រាថ្នាសុចរិតធម៌ ទ្រទ្រង់ការចេះដឹង ជាអ្នកសាកសួរ ឧស្សាហ៍ចូលទៅរកអ្នកមានសីលជាពហុស្សូតដោយគោរព ។ កាលបុគ្គលជាគ្រហស្ថនៅគ្រប់គ្រងផ្ទះរបស់ខ្លួនគួរមានការប្រព្រឹត្តដ៏ក្សេមក្សាន្តយ៉ាងនេះ គួរមានការសង្គ្រោះយ៉ាងនេះ ។ គ្រហស្ថគួរជាអ្នកមិនមានទុក្ខយ៉ាងនេះ មាណពឈ្មោះថា ពោលពាក្យពិតយ៉ាងនេះ គ្រហស្ថចេញចាកលោកនេះ ទៅកាន់លោកខាងមុខ លុះទៅកាន់លោកខាងមុខហើយរមែងមិនសោកស្តាយយ៉ាងនេះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តំ តត្ថ** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ វិធុរបណ្ឌិត បានសម្តែងយកវាសធម៌ថ្វាយព្រះរាជាក្នុងធម្មសភានោះ ។ បទថា **គតិមា** សេចក្តីថា ឈ្មោះថា មានគតិដោយញាណគតិដ៏ប្រសើរ ។ បទថា **ធិតិមា** បានដល់ ជាអ្នកមាំទាំព្រោះមានសេចក្តីព្យាយាមមិនដាច់ ។ បទថា **មតិមា** សេចក្តីថា ឈ្មោះថា ជាអ្នកមានបញ្ញា ព្រោះមានបញ្ញាបរិបូណ៌ដូចផែនដី ។ បទថា **អត្ថទស្សិនា** សេចក្តីថា ជាអ្នកឃើញអត្ថ

ដ៏សុខុម គឺឃើញអត្ថដោយញាណ ។ បទថា **សង្ខាតា** សេចក្តីថា វិធុរបណ្ឌិតកំណត់ដឹងធម៌បានទាំងអស់ដោយបញ្ញា គឺញាណជាគ្រឿងកំណត់ដឹង ហើយក្រាបទូលពាក្យជាដើមថា អ្នកគ្រប់គ្រងផ្ទះមិនគួរសេពគប់ស្រីសាធារណៈជាភរិយា ។ ក្នុងយកវាសធម៌នោះ បុគ្គលណាខុសក្នុងភរិយារបស់អ្នកដទៃ បុគ្គលនោះឈ្មោះថា មានស្រីសាធារណៈជាភរិយា បុគ្គលមិនគួរជាបុគ្គលបែបនោះ ។ បទថា **សាធុមេកកោ** សេចក្តីថា បុគ្គលនៅគ្រប់គ្រងផ្ទះមិនឲ្យប្រណីតភោជនដែលមានរសឆ្ងាញ់ដល់អ្នកដទៃ មិនគប្បីបរិភោគតែម្នាក់ឯង ។ បទថា **លោកាយតិកំ** សេចក្តីថា មិនគួរសេពនូវវាទៈដែលទាក់ទងក្នុងផ្លូវមិនចម្រើនដែលជាពាក្យឲ្យគេជឿ មិនអាស្រ័យប្រយោជន៍ មិនជាផ្លូវឲ្យទៅកាន់ស្ថានសួគ៌ មិននាំចេញចាកទុក្ខ ។ បទថា **នេតំ បញ្ញាយ វឌ្ឍនំ** សេចក្តីថា ក្នុងសេចក្តីនោះជាផ្លូវធ្វើលោកឲ្យវឹកវរ មិនធ្វើឲ្យបញ្ញាចម្រើនឡើយ ។ បទថា **សីលវា** បានដល់ ប្រកបដោយសីល ៥ ជាប់មិនដាច់ ។ បទថា **វត្តសម្បន្នោ** សេចក្តីថា កាលនៅគ្រប់គ្រងផ្ទះត្រូវប្រព្រឹត្តទៅតាមអាណត្តិរបស់ព្រះរាជា ។ បទថា **អប្បមត្តោ** សេចក្តីថា ជាអ្នកមិនប្រមាទក្នុងកុសលធម៌ ។ បទថា **និវាតវុត្តិ** សេចក្តីថា មិនធ្វើនូវការតម្កើងខ្លួន ប្រព្រឹត្តបន្ទន់បន្ទាបទទួលយកនូវឱវាទានុសាសនី ។ បទថា **អត្ថទ្ធោ** សេចក្តីថា វៀរចាកការកំណាញ់ស្វិតស្វាញ ។ បទថា **សុរតោ** សេចក្តីថា ប្រកបដោយការស្ងប់ស្ងៀម ។ បទថា **សខិលោ** បានដល់ ជាអ្នកមានវាចាជាទីតាំងនៃសេចក្តីស្រឡាញ់ ។ បទថា **មុទុ** បានដល់ មិនគ្រោតគ្រាតដោយ

កាយ វាចានិងចិត្ត ។ បទថា **សង្គហេតា ច មិត្តានំ** សេចក្តីថា បុគ្គល គ្រប់គ្រងផ្ទះគប្បីជាអ្នកធ្វើការសង្គ្រោះមិត្តដែលល្អ គឺគប្បីសង្គ្រោះក្នុងទានជាដើម ដែលជាគ្រឿងសង្គ្រោះគ្នានោះ ។ បទថា **សំវិភាគី** បានដល់ ធ្វើនូវការចែកទានដល់សមណព្រាហ្មណ៍ ដែលតាំងនៅក្នុងធម៌ជាដើមនិងដល់មនុស្សកំព្រាជាដើម ។ បទថា **វិធានវា** សេចក្តីថា គប្បីជាអ្នកដល់ព្រមដោយការចាត់ចែងក្នុងកិច្ចទាំងអស់យ៉ាងនេះថា ក្នុងពេលនេះគួរភ្ជួរ ពេលនេះគួរសាបព្រោះ ។ បទថា **តប្បេយ្យ** សេចក្តីថា គប្បីឲ្យរហូតស្កប់ស្កល់ដោយដាក់ភាជនៈដែលខ្លួនទទួលហើយឲ្យពេញ ។ បទថា **ធម្មកាមោ** សេចក្តីថា ជាអ្នកគ្រប់គ្រងផ្ទះ គប្បីជាអ្នកប្រាថ្នាបវេណីធម៌ខ្លះ សុចរិតធម៌ខ្លះ ។ បទថា **សុតាធារោ** សេចក្តីថា ជាអ្នកទ្រទ្រង់នូវសុតៈ ។ បទថា **បរិបុច្ឆកោ** សេចក្តីថា អ្នកគ្រប់គ្រងផ្ទះគប្បីចូលទៅរកសមណព្រាហ្មណ៍ដែលទ្រទ្រង់ធម៌ ហើយមានប្រក្រតីសាកសួរ ដោយពាក្យជាដើមថា អ្វីជាកុសលជាដើម ។ បទថា **សក្កច្ចំ** បានដល់ ដោយសេចក្តីគោរព ។ បទថា **ឯវំ នុ អស្ស សង្គហោ** សេចក្តីថា អ្នកនៅគ្រប់គ្រងផ្ទះសូម្បីការសង្គ្រោះក៏សមគួរធ្វើដូច្នោះ ។ បទថា **សច្ចវាទី** សេចក្តីថា អ្នកគ្រប់គ្រងផ្ទះបដិបត្តិបានយ៉ាងនេះឈ្មោះថា ជាអ្នកពោលពាក្យសច្ចៈ ។

ព្រះមហាសត្វ សម្តែងបញ្ហាក្នុងឃរាវាសធម៌ថ្វាយដល់ព្រះរាជាយ៉ាងនេះ ហើយចុះចាកបល្ល័ង្ក ថ្វាយបង្គំព្រះរាជា ឯព្រះរាជាទ្រង់ធ្វើមហាសក្ការៈដល់ព្រះមហាសត្វនោះមានព្រះរាជា ១០១ អង្គ ចោមរោមជាបរិវារយាងត្រឡប់

ទៅកាន់ព្រះរាជនិវេសន៍របស់ទ្រង់ ។

## យាវាសប្បញ្ហា ចប់

ចំណែកព្រះមហាសត្វត្រឡប់ទៅកាន់ផ្ទះរបស់ខ្លួនហើយ ។ លំដាប់នោះ បុណ្ណកយក្សក៏ពោលថា

លោកចូរមក យើងនឹងទៅឥឡូវនេះ លោក ( ដែលព្រះបាទ
ធនញ្ជ័យ ) ជាឥស្សរៈ បានព្រះរាជទានដល់ខ្ញុំហើយ ចូរ
ប្រតិបត្តិឲ្យជាប្រយោជន៍ដល់ខ្ញុំ នេះជាទំនៀមរបស់អ្នកប្រាជ្ញ
ក្នុងកាលមុន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **នោ** ក្នុងបទថា **ឥទានិ នោ** នេះ ត្រឹមតែជានិបាត អធិប្បាយថា លោកកាលព្រះបាទធនញ្ចយៈជាឥស្សរាធិបតី បានព្រះរាជទានហើយដល់ខ្ញុំ ។ បទថា **ឯស ធម្មោ សនន្តនោ** សេចក្តីថា ព្រោះកាលលោកបដិបត្តិ ឲ្យជាប្រយោជន៍ដល់ខ្ញុំឈ្មោះថា បដិបត្តិឲ្យជាប្រយោជន៍ដល់ចៅហ្វាយរបស់ខ្លួន ការធ្វើឲ្យជាប្រយោជន៍ដល់ចៅហ្វាយរបស់ខ្លួននោះឈ្មោះថា បុរាណធម៌ គឺលំនាំរបស់បណ្ឌិតក្នុងកាលមុនពិត ។

វិធុរបណ្ឌិតពោលគាថាថា

ម្នាលមាណព ខ្ញុំដឹងថា ខ្លួនខ្ញុំនៅក្នុងកណ្តាប់ដៃអ្នកហើយ
( ព្រោះ ) ខ្ញុំត្រូវព្រះបាទធនញ្ជ័យជាឥស្សរៈ ព្រះរាជទានដល់
អ្នកហើយតែយើងសូមឲ្យអ្នកនៅក្នុងផ្ទះយើងអស់ ៣ ថ្ងៃ ទម្រាំ

យើងប្រៀនប្រដៅកូននិងប្រពន្ធសិន ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **តយាហមស្មិ** សេចក្ដីថា ខ្ញុំរមែងដឹងថាអ្នកបានខ្ញុំហើយ គឺកាលបានខ្ញុំមិនមែនបានដោយប្រការដទៃ ។ បទថា **ធិន្នោហមស្មិ តវ ឥស្សរេន** សេចក្ដីថា ខ្ញុំជាបុគ្គលដែលព្រះរាជាជាឥស្សរាធិបតីរបស់ខ្ញុំ បានព្រះរាជទានដល់អ្នកហើយ ។ បទថា **តីហាញុ** សេចក្ដីថា នៃមាណព ខ្ញុំជាអ្នកមានឧបការៈច្រើនដល់អ្នក ព្រោះមិនស្រេបតាមព្រះរាជានិយាយតាមពិតប៉ុណ្ណោះ ព្រោះហេតុនោះទើបខ្ញុំជាបុគ្គលដែលអ្នកបានហើយ ចូរអ្នកដឹងថាខ្ញុំជាធំដល់ខ្លួន ពួកយើងនឹងស្នាក់នៅក្នុងផ្ទះ ៣ ថ្ងៃ ព្រោះដូច្នោះ ចូរអ្នកបង្អង់ឲ្យខ្ញុំទូន្មានកូនប្រពន្ធសិន ។

បុណ្ណកយក្ខបានស្ដាប់ដូច្នោះហើយគិតថា បណ្ឌិតនេះនិយាយពិត គេមានឧបការៈច្រើនដល់អញ បើគេសូមឲ្យអញបង្អង់ ៧ ថ្ងៃក្ដី កន្លះខែក្ដី អញត្រូវរង់ចាំដោយពិត ដូច្នេះហើយទើបពោលគាថានេះថា

> លោកពោលពាក្យណា ពាក្យនោះចូរមានដល់ខ្ញុំ ដោយប្រការដូច្នោះយើងគប្បីនៅអស់ ៣ ថ្ងៃ លោកដ៏ចម្រើន ចូរធ្វើកិច្ចក្នុងផ្ទះ ( របស់លោក ) ក្នុងថ្ងៃនេះចុះ លោកដ៏ចម្រើន ចូរប្រៀនប្រដៅបុត្តនិងភរិយាក្នុងថ្ងៃនេះចុះ កាលបើលោកចេញទៅ ( បុត្តនិងភរិយារបស់លោក ) បានសេចក្ដីសុខយ៉ាងណា ( សូមប្រៀនប្រដៅយ៉ាងនោះ ) ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **តម្មេ** សេចក្ដីថា ពាក្យដែលលោកសូមទាំង

អស់នោះ ខ្ញុំធ្វើតាមចិត្តលោក ។ បទថា **ភវដ្ឋ** សេចក្តីថា លោកដ៏ចម្រើន ចូរប្រៀនប្រដៅកូនប្រពន្ធ ៣ ថ្ងៃ ចាប់ពីថ្ងៃនេះទៅ ។ បទថា **តយី បេត្ថ** សេចក្តីថា ចូរលោកប្រៀនប្រដៅ ដោយប្រការដែលលោកទៅហើយបុត្តនិង ភរិយារបស់លោកក្នុងកាលជាក្រោយគប្បីមានសេចក្តីសុខ ។

បុណ្ណកយក្ខបានពោលដូច្នោះហើយចូលទៅកាន់និវេសន៍របស់ព្រះមហា- សត្វនោះឯង ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** វីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទ ព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូល សូត្រសានូវព្រះគាថាដូច្នេះថា

> បុណ្ណកយក្សមានភោគៈជាគ្រឿងប្រាថ្នាច្រើនបានពោលថា សាធុ
> ដូច្នេះ ក៏ចៀសចេញទៅជាមួយនឹងវិធុរបណ្ឌិត ឯវិធុរបណ្ឌិត
> ជាបុគ្គលប្រសើរថ្លៃថ្លា ចូលទៅកាន់ខាងក្នុងបុរីនោះ ដែល
> បរិបូណ៌ដោយដំរីនិងសេះអាជានេយ្យ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បហូតកាមោ** បានដល់ ជាអ្នកមានភោគ ទ្រព្យច្រើន ។ បទថា **តំ កុញ្ជរាជញ្ញហយានុចិណ្ណំ** សេចក្តីថា សន្ស៊ំ គឺ បរិបូណ៌ដោយដំរីនិងសេះអាជានេយ្យ ។ បទថា **អរិយសេដ្ឋោ** សេចក្តីថា ជាបុគ្គលឧត្តមក្នុងមារយាទដ៏ប្រសើរបំផុត ។

បុណ្ណកយក្ខចូលទៅក្នុងផ្ទះនៃវិធុរបណ្ឌិតហើយ ឯព្រះមហាសត្វមាន ប្រាសាទ ៣ ដើម្បីជាទីសម្រាកសម្រាន្តក្នុងរដូវទាំង ៣ ។ ក្នុងប្រាសាទ ៣

នោះ ប្រាសាទ ១ ឈ្មោះថាកោញ្ចៈ ប្រាសាទ ១ ឈ្មោះថាមយូរៈ ប្រាសាទ ១ ឈ្មោះថា បិយកេតៈ ។ ព្រះមានព្រះភាគទ្រង់សំដៅយកប្រាសាទ ៣ នោះទើបត្រាស់ព្រះគាថានេះថា

បណ្ដាប្រាសាទទាំងនោះ គឺកោញ្ចប្រាសាទ មយូរប្រាសាទ
បិយកេតប្រាសាទ ព្រះមហាសត្វ ( នាំបុណ្ណកយក្ស ) ចូល
ទៅកាន់ប្រាសាទ ជាទីរីករាយក្រៃលែង ជាប្រាសាទមាន
ភក្សាហារច្រើន មានបាយនិងទឹកច្រើន ដូចជា ( ភព )
មសក្កសារៈនៃព្រះវាសវៈ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **តត្ថ** សេចក្ដីថា បណ្ដាប្រាសាទទាំង ៣ នោះ ព្រះមហាសត្វ នាំបុណ្ណកយក្ខចូលទៅកាន់ប្រាសាទដែលជាលំនៅនៃខ្លួន ក្នុងសម័យនោះជាទីគួរត្រេកអរក្រៃពេក កាលចូលទៅហើយឲ្យចាត់ចែងបន្ទប់ដែលជាទីសម្រាប់ដេកនិងបន្ទប់ធំ ក្នុងជាន់ទី ៧ នៃប្រាសាទដែលតាក់តែងទុកហើយ ឲ្យក្រាលទីដេកដ៏ជាសិរី ទំនុកបម្រុងបាយនិងទឹកជាដើមរួចប្រគល់ដល់បុណ្ណកយក្ខនោះដោយពាក្យថា ស្រី ៥០០ ដូចទេពកញ្ញាទាំងនេះ ចូរជាស្រីបម្រើរបស់អ្នក អ្នកកុំធុញទ្រាន់ ចូរនៅក្នុងទីនេះចុះ កាលប្រគល់ឲ្យហើយទើបទៅកាន់លំនៅរបស់ខ្លួន ។ កាលមហាសត្វទៅហើយ ស្រីបម្រើទាំងនោះចាប់គ្រឿងតន្ត្រីផ្សេងៗផ្ដើមនូវការប្រគំមានច្រៀងរាំជាដើម បម្រើបុណ្ណកយក្ខ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូល

សូម្បីសានូវព្រះគាថាដូច្នេះថា

នាងនារីទាំងឡាយតាក់តែងខ្លួនដ៏សមរម្យល្អ រាំ ច្រៀង ហៅ
រកដ៏ប្រសើរក្រៃលែងក្នុងប្រាសាទនោះ ដូចស្រីអប្សរក្នុងទេវ-
លោក ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អវ្ហាយន្តិ** បានដល់ រមែងច្រៀងហៅរក ។ បទថា **វរាវរំ** សេចក្តីថា អ្នកបម្រើទាំងនោះប្រដាប់អង្គ ទ្រទ្រង់នូវគ្រឿងអលង្ការដ៏ស្អាត នាំគ្នាច្រៀងរាំនិងប្រគំជាសំឡេងតែមួយដ៏ពីរោះ ។

ព្រះមហាសត្វអ្នករក្សាធម៌ ធ្វើបុណ្ណកយក្ស ឲ្យបរិបូណ៌ដោយ
ពួកនារីជាទីរីករាយផង ដោយបាយនិងទឹកផង ហើយជ្រើស
រើសតែសេចក្តីយ៉ាងសំខាន់ ទើបចូលទៅក្នុងសំណាក់ភរិយា
ក្នុងកាលនោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បមុទាហិ** សេចក្តីថា ព្រះមហាសត្វបានបុណ្ណកយក្ខដោយស្រីបម្រើ ដែលគួរត្រេកអរនិងដោយបាយទឹក ។ បទថា **ធម្មបាលោ** បានដល់ ជាអ្នករក្សាធម៌ គឺជាអ្នកគ្រប់គ្រងធម៌ ។ បទថា **អត្ថត្ថមេវ** បានដល់ នូវប្រយោជន៍ដ៏ប្រសើរនោះឯង ។ បទថា **ឧបាគមិ ភរិយាយ** សេចក្តីថា បានចូលទៅជិតភរិយាដែលប្រសើរជាងស្រីទាំងពួង ។

មហាសត្វនិយាយនឹងភរិយា ដែលមានខ្លួនប្រោះព្រំដោយទឹក
ក្រអូបនៃខ្លឹមចន្ទន៍ មានសម្បុរប្រាកដស្មើដោយផ្កានៃមាស
ជម្ពូនទថា ម្នាលនាងដ៏ចម្រើន មានភ្នែកក្រហម នាងចូរមក

ចូរស្តាប់ខ្ញុំ ចូរហៅបុត្តនិងធីតាមក ។

បណ្តាបទទាំងនោះ បទថា **ភរិយំ អវច** កែជា **ភរិយំ អវោច** ។ បទថា **អាមន្តយ** បានដល់ ចូរហៅមក ។

នាងអនោជា បានស្តាប់ពាក្យរបស់ប្តីហើយ ក៏និយាយនឹងកូន
ប្រសាស្រីមានក្រចកក្រហម មានភ្នែកល្អថា ម្នាលនាងមាន
សម្បុរដូចផ្កាពជព្រឹក្ស នាងចូរហៅបុត្តនិងធីតា ដែលទ្រទ្រង់
ប្រដាប់ទាំងនោះមក ។

បណ្តាបទទាំងនោះ បទថា **អនោជា** បានដល់ ករិយាមានឈ្មោះយ៉ាង នោះ ។ បទថា **សុណិសំ អវច តម្ពនខី សុនេត្តំ** សេចក្តីថា នាងអនោជា បានស្តាប់ពាក្យរបស់ស្វាមី ជាអ្នកមានមុខជោកដោយទឹកភ្នែកគិតថា អញ មិនគួរទៅហៅកូនដោយខ្លួនឯង អញនឹងបញ្ជូនឲ្យកូនប្រសាស្រីទៅ ដូច្នេះ ហើយទៅកាន់លំនៅរបស់កូនប្រសានោះ បានពោលនឹងកូនប្រសាដែលមាន ក្រចកក្រហម មានភ្នែកល្អ ។ បទថា **អាមន្តយ** បានដល់ ចូរហៅមក ។ បទថា **ចម្មធរាណិ** សេចក្តីថា ជាអ្នកទ្រទ្រង់នូវគ្រឿងបិទបាំងស្បែក ជាអ្នក ក្ៀវក្លាអង់អាច ។ គ្រឿងអាភរណៈនោះឯងលោកបំណងយកថា **ចម្ម** គឺ គ្រឿងបិទបាំងស្បែកក្នុងទីនេះ ព្រោះហេតុនោះ ទើបមានសេចក្តីថាជាអ្នកទ្រទ្រង់ទុកនូវគ្រឿងអាភរណៈដូច្នេះក៏មាន ។ នាងអនោជាហៅកូនប្រសាស្រីថា **ចេតេ** ។ បទថា **បុត្តាណិ** បានដល់ បុត្តនិងធីតារបស់យើង ។ បទថា **ឥន្ទីវារបុប្ផសាមេ** សេចក្តីថា រមែងហៅបុគ្គលនោះ ។

កូនប្រសាទទូលពាក្យថា សាធុ ហើយដើរទៅតាមប្រាសាទហៅមិត្តស្និទ្ធស្នាលរបស់ព្រះមហាសត្វ បុត្តនិងធីតាគ្រប់គ្នាឲ្យមកប្រជុំគ្នាថា នែអ្នកទាំងឡាយ លោកឪពុកត្រូវការឲ្យឱវាទ ទើបហៅអ្នកទាំងឡាយមក បានឮថា អ្នកទាំងឡាយឃើញបិតាគ្រានេះជាការឃើញចុងក្រោយរបស់អ្នកទាំងឡាយ ។ ឯធម្មបាលកុមារបានឮពាក្យនោះហើយ ក៏នាំបងប្អូនយំទៅកាន់សម្នាក់បិតា ។ ឯវិធុរបណ្ឌិតឃើញកូនប្រុសស្រីទាំងនោះ មិនអាចតាំងនៅក្នុងប្រក្រតីបាន មានមុខជោកដោយទឹកភ្នែក ឱបក្រសោប ថើបនូវក្បាលកូនប្រុសស្រីទាំងនោះ ឲ្យបុត្តច្បងអង្គុយលើភ្លៅមួយស្របក់ហើយ ក៏លើកចុះអំពីភ្លៅ ចេញអំពីបន្ទប់ដ៏មានសិរី ឡើងអង្គុយលើបល្ល័ង្កត្រង់មហាប្រាសាទ ឲ្យឱវាទដល់កូនទាំង ១០០០ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូត្រសាន្ទូវព្រះគាថាដូច្នេះថា

ព្រះមហាសត្វជាអ្នករក្សាធម៌ ឥតមានញាប់ញ័រនឹងកូនទាំងឡាយ ថើបក្បាលកូនទាំងឡាយនោះដែលមកដល់ ហើយហៅមកនិយាយពាក្យថា អញត្រូវព្រះរាជាក្នុងក្រុងឥន្ទបត្តនេះប្រទានដល់មាណពហើយ ។ ថ្ងៃនេះអញមានសេចក្តីសុខក្នុងខ្លួនទេ ( តអំពី ៣ ថ្ងៃទៅ ) អញនឹងជាអ្នកបម្រើមាណពនោះ មាណពនោះ នាំអញទៅតាមសេចក្តីត្រូវការ ចំណែក

ខាងអញដែលមកនេះដើម្បីប្រៀនប្រដៅអ្នកទាំងឡាយ ( ព្រោះ
ថា ) អញនឹងទៅដោយមិនបានការពារ ( មុន ) ដូចម្ដេចបាន ។
បើព្រះរាជានៅក្នុងដែនកុរុ ជាអ្នកភ្ជាប់មិត្តជន មានភោគៈជាទី
ប្រាថ្នាច្រើនសួរកូនឯងទាំងឡាយថា អ្នកទាំងឡាយដឹងច្បាស់
នូវដំណើរបុរាណក្នុងកាលមុនដែរឬ បិតារបស់អ្នកទាំងឡាយ
បានប្រៀនប្រដៅក្នុងកាលមុនដូចម្ដេចខ្លះ មួយទៀតពួកអ្នកទាំង
អស់គ្នា ចូរមានអាសនៈស្មើនឹងយើងចុះ ( ព្រោះ ) ក្នុងរាជ
ត្រកូលនេះរកមនុស្សណារបស់ព្រះរាជា ជាអ្នកខ្ពង់ខ្ពស់ ( ឲ្យ
ស្មើនឹងពួកអ្នក ) មិនមានទេ ពួកកូនឯងគប្បីធ្វើអញ្ជលី ទូល
ព្រះរាជាយ៉ាងនេះថា បពិត្រព្រះសម្មតិទេព សូមព្រះអង្គកុំ
ត្រាស់យ៉ាងនេះ ព្រោះថានេះមិនមែនជាបវេណីធម៌ទេ បពិត្រ
ព្រះសម្មតិទេព សត្វចចកមានជាតិថោកទាបគប្បីមានអាសនៈ
ស្មើនឹងកេសរសីហៈដូចម្ដេចបាន ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ធម្មចារេលោ** បានដល់ ព្រះមហាសត្វ ។ បទថា **ឱដ្ឋាហាំ** សេចក្ដីថា អញជាបុគ្គលដែលព្រះរាជាលះបង់ជាទ្រព្យក្នុងជ័យជម្នះព្រះរាជទានដល់មាណព ។ បទថា **តស្សជ្ជហាំ អត្តសុខី វិធេយ្យោ** សេចក្ដីថា បិតាមានសេចក្ដីសុខក្នុងអំណាចនៃខ្លួនបានត្រឹមតែ ៣ ថ្ងៃ ផុតអំពី ៣ ថ្ងៃនេះទៅ បិតាក៏ប្រព្រឹត្តទៅក្នុងអំណាចនៃមាណព ក្នុងថ្ងៃទី ៤ មាណពនេះ នឹងនាំបិតាទៅក្នុងទីណា ដែលគេប្រាថ្នាដោយចំណែកមួយ ។ បទថា

**អបរិត្តាយ** សេចក្ដីថា បិតាមកដើម្បីទូន្មានអ្នកទាំងឡាយ ដោយគិតថា បើបិតាមិនបានធ្វើគ្រឿងការពារដល់ពួកអ្នក គប្បីទៅបានដូចម្ដេច ហេតុនោះ ទើបបិតាមកដើម្បីទូន្មានពួកឯង ។ បទថា **ជនសន្ធោ** សេចក្ដីថា ព្រះរាជា ធ្វើជនដែលជាមិត្តឲ្យមាំទាំដោយការចងមិត្ត ។ បទថា **បុរេ បុរាណំ** សេចក្ដីថា ក្នុងកាលមុនអំពីនេះ ពួកអ្នករមែងដឹងហេតុការណ៍ពីបុរាណអ្វីខ្លះ ។ បទថា **អនុសាសេ** បានដល់ តាមប្រៀនប្រដៅ ។ អ្នកទាំងឡាយដែលព្រះរាជាត្រាស់សួរយ៉ាងនេះគប្បីទូលថា ឪពុករបស់ខ្ញុំទាំងឡាយ បានឲ្យឱវាទយ៉ាងនេះៗ ។ បទថា **សមានាសនា ហោថ** សេចក្ដីថា បើពួកអ្នកទូលប្រាប់ឱវាទដែលបិតាឲ្យនេះ ព្រះរាជានឹងមានព្រះឱង្ការថា ពួកអ្នកទាំងពួង ចូរអង្គុយលើអាសនៈ ស្មើគ្នានឹងយើងក្នុងថ្ងៃនេះ ក្នុងរាជត្រកូលនេះអ្នកណាក្រៅអំពីអ្នកដែលនាំប្រយោជន៍មកឲ្យដល់ព្រះរាជាបាន ហើយគប្បីឲ្យអង្គុយលើអាសនៈរបស់ព្រះអង្គ ពេលនោះពួកអ្នកគប្បីធ្វើអញ្ជលីថ្វាយបង្គំទូលយ៉ាងនេះជាមួយព្រះរាជានោះថា បពិត្រមហារាជ សូមទ្រង់កុំត្រាស់យ៉ាងនោះព្រោះសេចក្ដីនោះ មិនត្រូវតាមទំនៀមរបស់ទូលព្រះបង្គំទាំងឡាយឡើយ ។ បទថា **វិយគ្ឃរាជស្ស** បានដល់ កេសររាជសីហ៍ ។ បទថា **និហីនជច្ចោ** សេចក្ដីថា បពិត្រព្រះសម្មតិទេព ចចកចាស់គប្បីមានអាសនៈស្មើគ្នាបានដូចម្ដេច អធិប្បាយ ចចករមែងមិនជាអ្នកមានអាសនៈស្មើដោយរាជសីហ៍យ៉ាងណា ខ្ញុំព្រះអង្គក៏ដូច្នោះដូចគ្នា មិនគួរមានអាសនៈស្មើនឹងទ្រង់ឡើយ ។

ឯពួកបុត្តធីតា ញាតិដែលមានចិត្តល្អនិងទាសកម្មករទាំងអស់នោះ បាន

ស្តាប់ពាក្យរបស់ព្រះមហាសត្វដូច្នេះ មិនអាចតាំងនៅបានតាមប្រក្រតី ក៏នាំគ្នាយំរៀបរាប់តាមគ្នា ។ ព្រះមហាសត្វបានដាស់តឿនជនទាំងនោះ ឲ្យប្រាសចាកសេចក្តីសោក មានស្មារតីហើយដោយប្រការដូច្នេះ ។

## លក្ខកណ្ឌ ចប់

លំដាប់នោះវិធុរបណ្ឌិតឃើញបុត្តជីតានិងពួកញាតិចូលទៅរកខ្លួន អង្គុយស្ងៀមទើបពោលថា នែអ្នកទាំងឡាយ ពួកអ្នកកុំគិតថ្វី កុំសោកស្តាយ កុំខ្វីកខ្វល់ឡើយ សង្ខារទាំងពួងមិនទៀង មិនស្ថិតស្ថេរ មានការប្រែប្រួលទៅជាធម្មតា សម្បត្តិធម៌ដែលបានឈ្មោះថា យសរមែងមានវិបត្តិជាទីបំផុត យើងនឹងសម្តែងចរិយាវត្តរបស់ព្រះរាជសេវកៈឈ្មោះថា រាជវសតិធម៌ ដែលជាហេតុឲ្យកើតយសដល់ពួកអ្នកៗចូរតាំងចិត្តស្តាប់រាជវសតិធម៌នោះ លុះពោលដូច្នេះហើយទើបផ្តើមសម្តែងរាជវសតិធម៌ដោយពុទ្ធលីលា ។

**តមត្ថំ បកាសេន្តោ សត្ថា អាហា** វីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសានូវព្រះគាថាដូច្នេះថា

> វិធុរបណ្ឌិតនោះមានសេចក្តីត្រិះរិះ ដោយចិត្តមិនរួញរា បាន
> ពោលពាក្យនេះនឹងបុត្ត អាមាត្យ ញាតិ សម្លាញ់ថា ម្នាល
> កូនសម្លាញ់ទាំងឡាយ ចូរអ្នកទាំងឡាយមកអង្គុយស្តាប់រាជ-
> វសតិធម៌ ( ច្បាប់សម្រាប់នៅក្នុងរាជត្រកូល ) របស់អញ

ដែលជាច្បាប់សម្រាប់បុរសចូលទៅកាន់រាជត្រកូលរមែងបាន

នូវយស ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សុហាឧជ្ជនេ** បានដល់ បុគ្គលដែលមានហឫទ័យល្អ ។ បទថា **ឯថយ្យោ** កាត់ជា **ឯថ អយ្យោ** សេចក្ដីថា វិធុរបណ្ឌិតនោះហៅបុត្តនិងធីតាដោយពាក្យហៅគួរជាទីស្រឡាញ់ ។ បទថា **រាជ-វសតី** សេចក្ដីថា ពួកអ្នកចូរស្ដាប់ការបម្រើព្រះរាជាដែលយើងនឹងពោល ។ បទថា **យថា** បានដល់ ដោយហេតុណា ។ បទថា **រាជកុលំ បត្តោ** សេចក្ដីថា បុគ្គលចូលទៅកាន់រាជត្រកូល គឺចូលទៅក្នុងសម្នាក់ព្រះរាជាតែងបាននូវយស ពួកអ្នកចូរស្ដាប់ហេតុនោះ អញនឹងពោលដូចតទៅនេះ

រាជសេវកៈ ដែលចូលទៅកាន់រាជត្រកូល ( មានគុណ

សម្បត្តិ ) មិនប្រាកដរមែងមិនបានយសទេ រាជសេវកៈមិន

ត្រូវជាអ្នកក្លៀវក្លាពេក មិនត្រូវជាអ្នកខ្លាចពេក មិនត្រូវធ្វេស

ប្រហែសក្នុងកាលណាឡើយ ។ ព្រះរាជាជ្រាបច្បាស់នូវអា-

ចារសម្បត្តិនិងសេចក្ដីចេះដឹង ព្រមទាំងសេចក្ដីស្អាត របស់

រាជសេវកៈនោះក្នុងកាលណា ព្រះរាជាក៏រមែងស្និទ្ធស្នាល

ចំពោះរាជសេវកៈនោះ ក្នុងកាលណោះទាំងមិនលាក់នូវអាថ៌

កំបាំង ( របស់ព្រះអង្គ ) នឹងរាជសេវកៈនោះទេ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អញ្ញាតោ** បានដល់ ដែលមានគុណមិនប្រាកដ មានផលនៃការងារមិនទាន់ប្រាកដច្បាស់ ។ បទថា **ឆាតិស្សរោ** បាន

ដល់ បុគ្គលមិនក្លៀវក្លា ។ បទថា **ជាតិទុម្មេធោ** បានដល់ មិនមានជាតិនៃបុគ្គលខ្លាច ។ បទថា **យទាស្ស សីលំ** សេចក្តីថា កាលណាព្រះរាជាទ្រង់ជួបនូវសីល បញ្ញា ការស្អាត គឺទ្រង់ជ្រាបអាចារសម្បត្តិ កម្លាំងនៃញាណនិងភាពជាអ្នកស្អាតរបស់សេវកៈនោះ ។ បទថា **អថ វិស្សាសតេ តម្හិ** សេចក្តីថា កាលនោះព្រះរាជាទ្រង់ទុកចិត្តក្នុងសេវកៈនោះ គឺទ្រង់ធ្វើសេចក្តីស្និទ្ធស្នាល មិនចាំបាច់រក្សា មិនចាំបាច់បិទបាំងរបស់ព្រះអង្គ ទ្រង់រមែងបើកផ្សារដល់រាជសេវកៈនោះ ។

> រាជសេវកៈដែលព្រះរាជាត្រាស់ប្រើ ( ក្នុងរាជកិច្ចណាមួយ )
> មិនគប្បីធ្វើរាជកិច្ចនោះឲ្យកម្រើក ( ល្អៀង ) ទេ ត្រូវធ្វើឲ្យ
> ដូចជាជញ្ជីងដែលគេលើកឡើងហើយមានដងស្មើ ទៀងល្អ ។
> រាជសេវកៈធ្វើរាជកិច្ចទាំងពួង ដូចជញ្ជីងដែលគេលើកឡើង
> ហើយមានដងស្មើទៀងល្អ រាជសេវកៈនោះទើបគួរនៅក្នុងរាជ
> ត្រកូល ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តុលា យថា** សេចក្តីថា រាជសេវកៈដែលព្រះរាជាទ្រង់ប្រើ គឺត្រាស់បញ្ជាក្នុងរាជកិច្ចណាមួយថា អ្នកចូរធ្វើកម្មនេះ មិនគប្បីធ្វើឲ្យឃ្លៀងឃ្លាត ដោយអំណាចការដល់នូវអគតិ មានឆន្ទាគតិជាដើម គឺគប្បីជាបុគ្គលស្មើក្នុងកិច្ចទាំងពួង ដូចជញ្ជីងដែលផ្គងទុកល្អហើយដែលមានប្រការដូចពោលហើយនេះ រមែងមិនស្រុតចុះ មិនបះឡើងដូច្នោះ ។ បទថា **ស រាជវសតី** សេចក្តីថា រាជសេវកៈបែបនេះគប្បីនៅក្នុងរាជត្រកូល គប្បី

ប្រណិប័តន៍ព្រះរាជា កាលប្រណិប័តន៍យ៉ាងនេះ គប្បីបានយស ។ បទថា **សព្វានិ អភិសម្ភោន្តោ** សេចក្តីថា ធ្វើនូវរាជកិច្ចគ្រប់យ៉ាង ។

រាជសេវកៈ ជាអ្នកឈ្លាសវៃក្នុងរាជកិច្ចទាំងឡាយ ដែលព្រះរាជាត្រូវប្រើក្នុងវេលាថ្ងៃ ឬក្នុងវេលាយប់ មិនគប្បីធ្វើរាជកិច្ចនោះឲ្យកម្រើក រាជសេវកៈនោះទើបគួរនៅក្នុងរាជត្រកូល ។ រាជសេវកៈជាអ្នកឈ្លាសវៃក្នុងរាជកិច្ចទាំងឡាយ ធ្វើរាជកិច្ចគ្រប់យ៉ាងក្នុងវេលាថ្ងៃ ឬក្នុងវេលាយប់ ( ឲ្យសម្រេចដោយរៀបរយ ) រាជសេវកៈនោះទើបគួរនៅក្នុងរាជត្រកូល ។ ផ្លូវណាដែលគេធ្វើល្អ ចាត់ចែងល្អសម្រាប់ព្រះរាជា រាជសេវកៈដែលព្រះរាជាត្រាស់ហើយ មិនត្រូវដើរទៅតាមផ្លូវនោះ រាជ-សេវកៈនោះទើបគួរនៅក្នុងរាជត្រកូល ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ន វិកម្បេយ្យ** សេចក្តីថា រាជសេវកៈមិនគប្បីញាប់ញ័រ បដិបត្តិរាជកិច្ចទាំងនោះ ។ បទថា **យោ ចស្ស** សេចក្តីថា ផ្លូវដែលគេតាក់តែងទុកយ៉ាងល្អ ដើម្បីជាមគ្គវិថីសម្រាប់ព្រះរាជា ។ បទថា **សុបដិយាទិតោ** សេចក្តីថា ផ្លូវដែលគេតាក់តែងទុករៀបរយល្អហើយ រាជសេវកៈសូម្បីបានព្រះរាជានុញ្ញាតថា អ្នកចូរទៅផ្លូវនេះ ក៏មិនគួរដើរផ្លូវនោះឡើយ ។

រាជសេវកៈ មិនគួរប្រើប្រាស់កាមភោគៈស្មើនឹងព្រះរាជា ក្នុងកាលណាឡើយ ត្រូវដើរខាងក្រោយក្នុងកាមគុណគ្រប់យ៉ាង

រាជសេវកៈនោះទើបគួរនៅក្នុងរាជត្រកូល ។ រាជសេវកៈមិនត្រូវប្រើប្រាស់សំពត់ មិនត្រូវប្រើប្រាស់ផ្កាកម្រង មិនត្រូវប្រើប្រាស់គ្រឿងលាបឲ្យដូចរបស់ព្រះរាជា មិនត្រូវប្រព្រឹត្តកិរិយាឬការនិយាយស្តីឲ្យដូចព្រះរាជា ត្រូវធ្វើអាកប្បកិរិយាដទៃវិញ រាជសេវកៈនោះទើបគួរនៅក្នុងរាជត្រកូល ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ន រញ្ញោ** សេចក្តីថា ជារាជសេវកៈមិនគប្បីបរិភោគសម្បត្តិដែលខ្លួនប្រាថ្នាប្រៀបផ្ទឹមស្មើនឹងព្រះរាជា ព្រោះព្រះរាជារមែងពិរោធចំពោះបុគ្គលបែបនោះ ។ បទថា **សព្យគ្គ** សេចក្តីថា គប្បីដើរតាមក្រោយព្រះរាជា បដិបត្តិឲ្យទាបជាងក្នុងកាមគុណទាំងពួង មានរូបជាដើម ។ បទថា **អញ្ញំ ការយេ្យ** សេចក្តីថា គប្បីធ្វើអាកប្បកិរិយាដទៃក្រៅពីរាជអាកប្បកិរិយា ។ បទថា **ស រាជវសតី វសេ** សេចក្តីថា បុគ្គលនោះគប្បីចូលទៅគាល់ព្រះរាជាហើយគប្បីនៅ ។

ព្រះរាជា ទ្រង់ក្រសាលនឹងរាជសេវកៈ មានស្រីស្នំគាល់បម្រើ អាមាត្យជាបណ្ឌិត មិនត្រូវធ្វើសេចក្តីស្និទ្ធស្នាលចំពោះពួកស្រីស្នំរបស់ព្រះរាជាទេ ។ រាជសេវកៈជាអ្នកមិនធ្មើងឆ្មៃ មិនឃ្នើសឃ្នង ជាអ្នកមានប្រាជ្ញាខ្ជាប់ខ្ជួន សង្រួមឥន្ទ្រិយដ៏ល្អ បរិបូណ៌ដោយការតម្កល់ចិត្ត រាជសេវកៈនោះទើបគួរនៅក្នុងរាជត្រកូល ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ភាវំ** បានដល់ បំណងដោយអំណាចការ

ស្និទ្ធស្នាល ។ បទថា **អចបលោ** បានដល់ មិនជាអ្នកឃ្នើសឃ្នងជាប្រក្រតី ។ បទថា **និបកោ** បានដល់ មានញាណចាស់ក្លា ។ បទថា **សំវុតិន្ទ្រិយោ** បានដល់ ជាអ្នកសង្រួមការពារនូវឥន្ទ្រិយ ៦ បានហើយ គឺមិនគប្បីសម្លឹងមើលអវយវៈតូចធំរបស់ព្រះរាជានិងមិនគប្បីសម្លឹងមើលស្រីស្នំ នៃព្រះរាជានោះ ។ បទថា **មនោបណិធិសម្បន្នោ** បានដល់ ដែលប្រកបដោយចិត្តមិនញាប់ញ័រ គឺតម្កល់ទុកដោយល្អ ។

រាជសេវកៈមិនត្រូវប្រឡែង មិនត្រូវនៅក្នុងទីស្ងាត់ប្រឹក្សាជាមួយនឹងពួកស្រីស្នំរបស់ព្រះរាជា មិនត្រូវលួចយកព្រះរាជទ្រព្យអំពីឃ្លាំងរបស់ព្រះរាជានោះទេ រាជសេវកៈនោះ ទើបគួរនៅក្នុងរាជត្រកូល ។ រាជសេវកៈមិនគប្បីសំគាល់ការដេកច្រើន មិនត្រូវផឹកសុរាឲ្យស្រវឹង មិនត្រូវបៀតបៀនពួកម្រឹគ ដែលទ្រង់ឲ្យអភ័យ រាជសេវកៈនោះទើបគួរនៅក្នុងរាជត្រកូល ។ រាជ-សេវកៈមិនត្រូវឡើងកាន់តាំង មិនត្រូវឡើងកាន់បល្ល័ង្ក មិនត្រូវឡើងកាន់កៅអី មិនត្រូវឡើងកាន់នាវាឬកាន់រថរបស់ព្រះរាជា ដោយគិតថា ខ្លួនអញព្រះរាជាប្រោសប្រាណហើយ ដូច្នេះទេ រាជសេវកៈនោះ ទើបគួរនៅក្នុងរាជត្រកូល ។ រាជសេវកៈជាអ្នកវាងវៃ ត្រូវគាល់ព្រះរាជាក្នុងទីមិនឆ្ងាយពេក មិនជិតពេក គប្បីឋិតនៅល្មមតែព្រះរាជាទតឃើញ ទាំងខ្លួនឯងក៏មើលឃើញព្រះរាជាជាម្ចាស់ ។ រាជសេវកៈ ( គួរគិតថា ) ព្រះរាជាមិនមែន

ជាសម្លាញ់របស់អញ ទេព្រះរាជាមិនមែនជាគូកន ( របស់អញទេ ) ធម្មតាព្រះរាជាទាំងឡាយរមែងខ្វាល់ឆាប់ ដូចភ្នែកដែលត្រូវលំអង មានកន្ទុយស្រូវ ( ជាដើម ) ប៉ះពាល់ ។ ជនជាបណ្ឌិតអ្នកមានប្រាជ្ញាមិនត្រូវសំគាល់ថា ព្រះរាជាបូជាអញហើយ ក៏ពិតទូលហេតុអាក្រក់ ចំពោះព្រះរាជាដែលយាងមកកាន់បរិស័ទ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ន មន្តេយ្យ** សេចក្តីថា ជារាជសេវកៈមិនគួរប្រឡែងជាមួយពួកស្នំ មិនគប្បីចរចាប្រាស្រ័យក្នុងទីកំបាំង ។ បទថា **កោសា ធនំ** សេចក្តីថា កុំលបលួចយកព្រះរាជទ្រព្យអំពីឃ្លាំងរបស់ព្រះរាជា ។ បទថា **ន មទាយ** សេចក្តីថា នៃបានិងមេទាំងឡាយ រាជសេវកៈមិនគប្បីផឹកស្រារហូតស្រវឹងឡើយ ។ បទថា **ទាយេ** សេចក្តីថា មិនគប្បីសម្លាប់ មិនគប្បីបៀតបៀនម្រឹគដែលព្រះរាជទានអភ័យ ។ បទថា **កោច្ឆំ** បានដល់ ព្រះទែនដែលមានបង្អែក ។ បទថា **សម្មតោម្ហិ** សេចក្តីថា រាជសេវកៈកុំលើកខ្លួនថា អញជាទីប្រោសប្រាណធ្វើតាមទំនើងចិត្ត ។ បទថា **សមេក្ខញស្ស តិដ្ឋេយ្យ** សេចក្តីថា រាជសេវកៈគប្បីឈរខាងមុខរបស់ព្រះរាជាក្នុងទីដែលមិនឆ្ងាយពេក មិនជិតពេក ល្មមបានឮព្រះតម្រាស់ដែលត្រាស់ប្រើ ។ បទថា **សន្ទិស្សន្តោ សកត្តុនោ** សេចក្តីថា រាជសេវកៈនោះគប្បីឈរក្នុងទីដែលព្រះរាជាទតឃើញបាន ។ បទថា **សុកោឆ** សេចក្តីថា ជារាជសេវកៈកុំអាងថាព្រះរាជាជាសម្លាញ់របស់អញនិងជាដៃគូជាមួយអញ ព្រោះព្រះរាជា

ទាំងឡាយទ្រង់រមែងក្រោធរហ័សដូចភ្នែកដែលប៉ះធូលីរមែងខុសប្រក្រតីមួយរំពេចដូច្នោះ ។ បទថា **ន បូជិតោ មញ្ញមានោ** សេចក្ដីថា ជារាជសេវកៈមិនគប្បីប្រកាន់ខ្លួនថាអញជាបុគ្គលដែលព្រះរាជាទ្រង់រាប់អានបូជា ។ បទថា **ផរុសំ** សេចក្ដីថា មិនគប្បីចរចាប្រាស្រ័យដោយពាក្យដែលជាហេតុឲ្យព្រះរាជាទ្រង់ខ្ញាល់ ។

រាជសេវកៈទុកជាបានអនុញ្ញាតទ្វារហើយ ត្រូវបានអនុញ្ញាតទ្វារ (ទៀតសឹមចូល) មិនត្រូវទុកចិត្តចំពោះព្រះរាជាទាំងឡាយគប្បីប្រយ័ត្នដូចភ្លើង រាជសេវកៈនោះទើបគួរនៅក្នុងរាជត្រកូល ។ ព្រះរាជាជាក្សត្រិយ៍ទ្រង់លើកតម្កើងព្រះរាជបុត្ត ឬក្សត្រិយ៍ជាបងប្អូនរបស់ព្រះអង្គដោយស្រុកឬនិគម ដោយដែនឬជនបទ រាជសេវកៈ ត្រូវនៅស្ងៀមរំពឹងមើល មិនត្រូវនិយាយពីគុណឬទោសឡើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **លទ្ធទ្វារោ លភេ ទ្វារំ** សេចក្ដីថា អញជាសេវកៈ អញមិនមែនអ្នកយាមទ្វារតែបានទ្វារជាពិសេស ទ្រង់មិនអនុញ្ញាតមិនគប្បីចូលទៅទោះបីបានទ្វារទៀត កាលបានទទួលអនុញ្ញាតសឹមចូលទៅ ។ បទថា **សំយតោ** បានដល់ ជាអ្នកមិនប្រមាទ ។ បទថា **ភាតរំ សំ វា** បានដល់ ព្រះរាជវង្សខាងព្រះអង្គ ។ បទថា **សម្បគ្គណ្ហាតិ** សេចក្ដីថា ក្នុងកាលណាព្រះរាជាត្រាស់នឹងសេវកៈទាំងឡាយថា ខ្ញុំនឹងឲ្យស្រុកនោះ ឬនិគមនោះដល់បុគ្គលនោះ ។ បទថា **ន ភណេ ឆេកបាបកំ** សេចក្ដីថា

សេវកៈមិនគប្បីពោលសរសើរគុណឬទោសក្នុងកាលនោះ ។

ព្រះរាជាទ្រង់បន្ថែមបៀវត្សដល់ពលដំរី ពលរថ ពលថ្មើរជើង ទាំងនោះ ដោយការប្រគល់ឲ្យចំពោះការងារ រាជសេវកៈមិន ត្រូវធ្វើឲ្យអន្តរាយ ( លាភ ) របស់ពលទាំងនោះ រាជសេវកៈ នោះទើបគួរនៅក្នុងរាជត្រកូល ។ រាជសេវកៈជាអ្នកប្រាជ្ញ ត្រូវ ឱនលំទោនដូចជាជង្ហ្ន ត្រូវញាប់ញ័រដូចជាឫស្សី មិនត្រូវ ប្រព្រឹត្តទទឹងទាស់ទេ រាជសេវកៈនោះទើបគួរនៅក្នុងរាជ- ត្រកូល ។ រាជសេវកៈត្រូវមានពោះតូចដូចបន្ទោះធ្នូ មិនត្រូវមាន អណ្តាតដូចត្រី ត្រូវស៊ីតិច មានប្រាជ្ញារក្សាខ្លួន ក្លៀវក្លា រាជ សេវកៈនោះទើបគួរនៅក្នុងរាជត្រកូល ។

បណ្តាបទទាំងនោះ បទថា **ន តេសំ អន្តរា គច្ឆេ** សេចក្តីថា ជារាជ- សេវកៈមិនគួរទូលជំទាស់ធ្វើឲ្យបាត់បង់លាភរបស់បុគ្គលទាំងនោះ ។ បទថា **វំសោ វា** សេចក្តីថា គប្បីជាអ្នកមានចិត្តទន់ភ្លន់ក្នុងកាលដែលព្រះរាជាត្រាស់ ដូចចុងឫស្សី ដែលខ្ពស់ជាងគេក្នុងគុម្ពឫស្សី រមែងទោរទន់ក្នុងគ្រាដែលត្រូវ ខ្យល់បក់ដូច្នោះ ។ បទថា **ចាបោវូនុទរោ** សេចក្តីថា ជារាជសេវកៈមិនគប្បី ជាអ្នកមានពោះធំដូចបន្ទោះធ្នូដូច្នោះ ។ បទថា **អជិវ្ហតា** សេចក្តីថា គប្បីជា បុគ្គលមិនមានអណ្តាតដោយការនិយាយតិចតួចដូចត្រីរមែងមិនពោល ព្រោះ មិនមានអណ្តាត ។ បទថា **អប្បាសិ** សេចក្តីថា គប្បីជាអ្នកស្គាល់ប្រមាណ ក្នុងភោជន ។

រាជសេវកៈមិនត្រូវប៉ះពាល់គប់ស្រី ជាហេតុឲ្យអស់តេជៈខ្លាំងពេកទេ សេវកៈដែលអស់ប្រាជ្ញារមែងដល់នូវរោគក្អក ហឺតទុរន់ទុរា មានកម្លាំងថយ ។ រាជសេវកៈមិនត្រូវនិយាយហួសកម្រិត មិនត្រូវស្ងៀមគ្រប់កាលទាំងពួងទេ ត្រូវពោលពាក្យមិនរាយរាយ ល្មមប្រមាណក្នុងកាលដែលត្រូវការ ។ រាជសេវកៈគប្បីជាអ្នកមិនក្រោធ មិនបៀតបៀនគេ មានពាក្យសច្ចៈផ្អែមល្ហែម មិនញុះញង់ មិននិយាយពាក្យឥតប្រយោជន៍ រាជសេវកៈនោះទើបគួរនៅក្នុងរាជត្រកូល ។

បណ្តាបទទាំងនោះ បទថា **ន ពាឡ្ហំ** សេចក្តីថា សេវកៈមិនគប្បីស្រវឹងដោយស្រីរឿយៗ ។ បទថា **តេជសង្ខ្យំ** សេចក្តីថា ព្រោះថាបុរស កាលប្រព្រឹត្តយ៉ាងនោះរមែងអស់នូវតេជៈ កាលប៉ះពាល់នូវហេតុដែលឲ្យអស់តេជៈនោះកុំស្រវឹងច្រើនឡើយ ។ បទថា **ឧរំ** បានដល់ ការក្រវល់ក្រវាយនៃកាយ ។ បទថា **ពាល្យំ** បានដល់ ដល់នូវការខ្សោយកម្លាំង ។ បទថា **ទីណមេធោ** សេចក្តីថា បុរសដែលអស់ប្រាជ្ញា ដោយអំណាចការត្រេកអរដោយកិលេសរឿយៗ រមែងដល់នូវការកើតរោគក្អកជាដើម ។ បទថា **ឆាតិវេលំ** សេចក្តីថា នៃបានិងមេទាំងឡាយ សេវកៈមិនគប្បីនិយាយច្រើនហួសប្រមាណ ក្នុងសម្នាក់របស់ព្រះរាជាទាំងឡាយឡើយ ។ បទថា **បត្តេ កាលេ** សេចក្តីថា កាលដល់ពេលដែលត្រូវនិយាយ ។ បទថា **អសង្ឃដ្តោ** បានដល់ មិនពោលទ្រគោះបោះបោកអ្នកដទៃ ។ បទថា **សម្ភំ** បានដល់ ពាក្យ

គ្មានប្រយោជន៍ ។ បទថា **គិរំ** បានដល់ វាចា ។

*រាជសេវកៈ ត្រូវចិញ្ចឹមមាតានិងបិតា ត្រូវមានសេចក្ដីគោរព ចំពោះបុគ្គលជាធំក្នុងត្រកូលមានវាចាផ្អែមល្ហែម ពោលពាក្យ ម៉ត់ហ្មត់ រាជសេវកៈនោះទើបគួរនៅក្នុងរាជត្រកូល ។ រាជ-សេវកៈត្រូវមានសណ្ដាប់ធ្នាប់ មានសិល្បសាស្ត្រ មានឥន្ទ្រិយទូន្មានហើយ មានខ្លួនធ្វើហើយ ( បេះស្ងាត់ ) ជាអ្នកនឹងនួនមាន អធ្យាស្រ័យទន់ភ្លន់ មិនធ្វេសប្រហែស ជាអ្នកស្អាតទាំងឈ្លាសវៃ រាជសេវកៈនោះ ទើបគួរនៅក្នុងរាជត្រកូល ។ រាជសេវកៈត្រូវមានសេចក្ដីប្រព្រឹត្តឱនលំទោន កោតក្រែងគោរពចំពោះបុគ្គលចម្រើន ( ដោយវ័យជាដើម ) ជាអ្នកស្លូតត្រង់ នៅរួមជាសុខ រាជសេវកៈនោះ ទើបគួរនៅក្នុងរាជត្រកូល ។ រាជសេវកៈគប្បីវៀរឲ្យឆ្ងាយចេញ នូវជនដែលព្រះរាជាដទៃបញ្ជូនមក ដើម្បីការស្ងាត់កំបាំង គប្បីរំពៃមើលចំពោះព្រះរាជាជាម្ចាស់ ( របស់ខ្លួន ) មិនត្រូវនិយាយចំពោះព្រះរាជាដទៃទេដូច្នេះ ។*

បណ្ដាបទទាំងនោះ បទថា **វិណីតោ** បានដល់ ជាអ្នកបរិបូណ៌ដោយមារយាទ ។ បទថា **សិប្បវា** បានដល់ ជាអ្នកប្រកបដោយសិប្បៈដែលគប្បីសិក្សាក្នុងត្រកូលរបស់ខ្លួន ។ បទថា **ឥន្ទ្រា** បានដល់ មិនប្រើទ្វារទាំង ៦ ក្នុងផ្លូវខុស ។ បទថា **កតត្តោ** បានដល់ ជាអ្នកមានខ្លួនដល់ព្រមហើយ

( ទាំងវិជ្ជានិងចរិយាសម្បត្តិ ) ។ បទថា **និយតោ** បានដល់ ជាអ្នកមានសភាវៈមិនញាប់ញ័រព្រោះអាស្រ័យយសជាដើម ។ បទថា **មុទុ** បានដល់ ជាអ្នកទន់ភ្លន់មិនតម្កើងខ្លួន ។ បទថា **អប្បមត្តោ** បានដល់ ជាអ្នកវៀរចាកការធ្វេសប្រហែសក្នុងរាជកិច្ចដែលគួរធ្វើ ។ បទថា **ទក្ខោ** បានដល់ ជាអ្នកឈ្លាសក្នុងការបម្រើ ។ បទថា **និវាតវុត្តិ** បានដល់ ជាអ្នកមានការប្រព្រឹត្តឱនលំទោន ។ បទថា **សប្បតិស្សោ** បានដល់ ជាអ្នកមានប្រក្រតីនៅរួមគ្នាដោយសេចក្តីគោរព ។ បទថា **សណ្ឋិតុំ បហិតំ** សេចក្តីថា ទូតដែលព្រះរាជាបញ្ជូនទៅកាន់រាជសម្នាក់ ដោយអំណាចរក្សាសេចក្តីកំបាំងនិងធ្វើនូវការកំបាំងឲ្យប្រាកដ ។ រាជសេវកៈកាលនឹងពោលទូលបែបនោះគប្បីពោលចំពោះព្រះភក្ត្រព្រះរាជា ។ បទថា **ភត្តារវញ្ញុ និក្ខេយ្យ** សេចក្តីថា គប្បីយកចិត្តទុក ដាក់ចំពោះចៅហ្វាយរបស់ខ្លួនប៉ុណ្ណោះ ។ បទថា **ន ច អញ្ញស្ស រាជិនោ** សេចក្តីថា រាជសេវកៈមិនគប្បីពោល ( រឿងសម្ងាត់ ) ក្នុងសម្នាក់របស់ព្រះរាជាដទៃ ។

រាជសេវកៈគប្បីគប់រកចំពោះសមណៈនិងព្រាហ្មណ៍ អ្នកមានសីល ជាពហុស្សូតដោយគោរព រាជសេវកៈនោះទើបគួរនៅក្នុងរាជត្រកូល ។ រាជសេវកៈគួរប្រព្រឹត្តតាមពួកសមណៈនិងព្រាហ្មណ៍ អ្នកមានសីលជាពហុស្សូតដោយគោរព រាជសេវកៈនោះទើបគួរនៅក្នុងរាជត្រកូល ។ រាជសេវកៈគួរញុំាងសមណៈនិងព្រាហ្មណ៍ អ្នកមានសីលជាពហុស្សូត ឲ្យឆ្អែតស្កប់ស្កល់

ដោយបាយនិងទឹក រាជសេវកៈនោះទើបគួរនៅក្នុងរាជត្រកូល ។ រាជសេវកៈកាលបើប្រាថ្នាសេចក្តីចម្រើនដល់ខ្លួន គប្បីចូលទៅគប់រកសមណៈនិងព្រាហ្មណ៍ អ្នកមានសីល ជាពហុស្សូត ជាបណ្ឌិត ។

បណ្តាបទទាំងនោះ បទថា **សក្កច្ចំ បយិរុបាសេយ្យ** សេចក្តីថា រាជ-សេវកៈគប្បីចូលទៅរករឿយៗដោយសេចក្តីគោរព ។ បទថា **អនុវាសេយ្យ** សេចក្តីថា គប្បីធ្វើឧបោសថ ។ បទថា **តប្បេយ្យ** សេចក្តីថា គប្បីចិញ្ចឹមដោយការឲ្យរបហូតល្មមសមគួរដល់សេចក្តីត្រូវការ ។ បទថា **អាសជ្ជ** បានដល់ ចូលទៅជិត ។ បទថា **បញ្ញោ** បានដល់ ដែលជាបណ្ឌិត ។ម្យ៉ាងទៀតបាលីថា **អាសជ្ជ បញ្ញាំ** ដូច្នេះក៏មាន ។ បទថា **បញ្ញាំ** សេចក្តីថា គប្បីសួរដល់ហេតុដែលជាកុសលនិងអកុសល ដែលបណ្ឌិតទាំងឡាយគប្បីធ្វើដោយបញ្ញា ។

រាជសេវកៈមិនត្រូវញុំាំងទាន ដែលព្រះរាជាធ្លាប់ព្រះរាជទានដល់សមណៈនិងព្រាហ្មណ៍ឲ្យសាបសូន្យ ទាំងមិនគួរឃាត់វត្ថុណាមួយចំពោះពួកស្មូម ក្នុងកាលជាទីព្រះរាជទាន ។ រាជសេវកៈជាអ្នកមានប្រាជ្ញា បរិបូណ៌ដោយឧបាយ ជាអ្នកឈ្លៀវឆ្លាសក្នុងវិធីចាត់ចែងជាអ្នកដឹងកាល ( ជាទីធ្វើបុណ្យ ) ដឹងសម័យ ( ប្រកបការងារ ) រាជសេវកៈនោះទើបគួរនៅក្នុងរាជត្រកូល ។ រាជសេវកៈជាអ្នកខ្នះខ្នែង មិនប្រមាទ ឈ្លាស

វៃចាត់ចែងការងារដ៏ល្អក្នុងក្រសួងការងារទាំងឡាយ ត្រូវមាន
សេចក្ដីព្យាយាម ចាត់ចែងរាជកិច្ចឲ្យប្រព្រឹត្តទៅដោយស្រួល
រាជសេវកៈនោះទើបគួរនៅក្នុងរាជត្រកូល ។

បណ្ដាបទទាំងនោះ បទថា **និដ្ឋបុត្តំ** បានដល់ ទានវត្ថុដែលរៀបចំទុកដោយល្អ ។ បទថា **សមណព្រាហ្មណោ** បានដល់ ក្នុងសមណៈឬព្រាហ្មណ៍ ។ បទថា **វនិព្វកេ** សេចក្ដីថា រាជសេវកៈឃើញពួកស្មូមមកក្នុងទីព្រះរាជទានមិនគប្បីហាមឃាត់ឡើយ ។ បទថា **បញ្ញវា** បានដល់ បុគ្គលប្រកបដោយបញ្ញាជាគ្រឿងពិចារណា ។ បទថា **ពុទ្ធិសម្បន្នោ** បានដល់ ជាអ្នកបរិបូណ៌ដោយការដឹងមិនខ្វះខាត ។ បទថា **វិធានវិធិកោវិទោ** បានដល់ បុគ្គលឈ្លាសក្នុងចំណែកជាគ្រឿងចាត់ចែងទាសៈកម្មករនិងបុរសជាដើមមានប្រការផ្សេងៗ ។ បទថា **កាលញ្ញូ** សេចក្ដីថា រាជសេវកៈគប្បីដឹងថា កាលនេះជាកាលគួរដើម្បីនឹងឲ្យទាន កាលនោះជាកាលគួរដើម្បីរក្សាសីល កាលនេះជាកាលដើម្បីធ្វើឧបោសថកម្ម ។ បទថា **សមយញ្ញូ** សេចក្ដីថា រាជសេវកៈគប្បីដឹងថា សម័យនេះជាសម័យគួរភ្ជួរ សម័យនេះជាសម័យគួរសាបព្រោះ សម័យនេះជាសម័យដែលគួរលក់ សម័យនេះជាសម័យគួរទំនុកបម្រុង ។ បទថា **កម្មធេយ្យេសុ** បានដល់ ក្នុងការងារដែលខ្លួនគួរធ្វើ ។

រាជសេវកៈគួរទៅ ( ត្រួតត្រាមើល ) លានស្រូវ គោពពែម
សត្វនិងស្រែចម្ការ ( របស់ព្រះរាជា ) ឲ្យរឿយៗ គប្បីទុក
ដាក់ស្រូវដែលវាល់ហើយផងឲ្យគេចម្អិនអង្ករដែលវាល់ហើយ

ក្នុងផ្ទះផង ។ មិនត្រូវលើកតម្កើងកូនឬបងប្អូនរបស់ខ្លួន ដែល
មិនតាំងនៅក្នុងសីលាចារវត្តព្រោះថាជនទាំងនោះជាមនុស្សពាល
មិនឈ្មោះថាជាអវយវៈ ( របស់ខ្លួន ) ជនទាំងនោះទុកដូចជា
មនុស្សស្លាប់ហើយ តែថាត្រូវឲ្យសំពត់និងដុំបាយ ដល់ជនទាំង
នោះ ដែលមកអង្គុយជិតហើយ គប្បីតម្កល់ពួកបុរសជាទាស
កម្មករដែលជាអ្នកខ្ជាប់ខ្ជួនល្អក្នុងសីលាចារវត្ត ជាអ្នកឈ្លាស
វៃបរិបូណ៌ដោយសេចក្ដីឃ្មាតខ្មីក្នុងទីជាអធិបតី ( ក្នុងការងារ ) ។

បណ្ដាបទទាំងនោះ បទថា **បសុំ ខេត្តំ** បានដល់ ហ្វូងគោនិងទីសាបព្រោះ
ស្រូវ ។ បទថា **គន្ត្វា** បានដល់ មានការទៅជាប្រក្រតី ។ បទថា **មិតំ**
សេចក្ដីថា គួរវាល់ឲ្យដឹងថា ស្រូវមានប្រមាណប៉ុណ្ណេះ ហើយរក្សាទុកក្នុង
ជង្រុក ។ បទថា **ឃរេ** សេចក្ដីថា គប្បីរាប់បរិវារក្នុងផ្ទះ ឲ្យចម្អិនល្មម
ប្រមាណដូចគ្នា ។ បទថា **សីលេសុ អសមាហិតំ** សេចក្ដីថា មិនតាំងកូន
ឬបងប្អូន ញាតិវង្សដែលមិនតាំងនៅក្នុងសីលាចារវត្ត ទុកក្នុងតំណែងជាធំ
ណាមួយ ។ បទថា **អនង្គវា ហិ តេ ពាលា** សេចក្ដីថា ពាក្យថា អង្គនេះ
សត្វលោកពោលសំដៅដល់ភាពជាញាតិ បងប្អូននៃមនុស្ស ។ ញាតិបងប្អូន
លោកពោលថាជាអង្គាវយវៈ តែជនទាំងនេះជាអ្នកទ្រុស្តសីល ព្រោះហេតុ
នោះទើបមិនស្មើអវយវៈ ម្យ៉ាងទៀតមនុស្សស្លាប់ដែលគេលះបង់ហើយ ក្នុង
ព្រៃខ្មោចយ៉ាងណា ញាតិទាំងនោះក៏យ៉ាងនោះដូចគ្នា ព្រោះហេតុនោះទើប
មិនគួរតាំងញាតិបែបនោះទុកក្នុងតំណែងជាធំ ព្រោះជនទាំងនោះរមែងបំផ្លាញ

ទ្រព្យឲ្យវិនាស និងបំផ្លាញទ្រព្យឬមនុស្ស រហូតញុំាងរាជកិច្ចមិនឲ្យសម្រេចបរិបូណ៌បាន ។ បទថា **អាសីនានំ** សេចក្តីថា មកដល់ហើយអង្គុយចុះ ។ បុគ្គលកាលឲ្យគប្បីឲ្យវត្ថុត្រឹមតែអាហារនិងគ្រឿងស្លៀកដណ្តប់ ដូចឲ្យមតកកត្តដល់អ្នកស្លាប់ដូច្នោះ ។ បទថា **ឧដ្ឋានសម្បន្នេ** បានដល់ ដែលប្រកបដោយការឧស្សាហ៍ខ្មីឃ្មាត ។

រាជសេវកៈត្រូវមានសីល មិនលោភ ជាអ្នកប្រព្រឹត្តតាមព្រះរាជា ជាគុណដល់ព្រះរាជា ទាំងក្នុងទីចំពោះព្រះភក្ត្រនិងទីកំបាំងព្រះភក្ត្រ រាជសេវកៈនោះទើបគួរនៅក្នុងរាជត្រកូល ។ រាជសេវកៈ ជាអ្នកស្គាល់បំណងរបស់ព្រះរាជានោះផង តាំងនៅដូចព្រះហឫទ័យរបស់ព្រះរាជានោះផង ជាអ្នកមិនប្រព្រឹត្តទទឹងទាស់នឹងព្រះរាជានោះផង រាជសេវកៈនោះ ទើបគួរនៅក្នុងរាជត្រកូល ។ រាជសេវកៈ គប្បីឱនក្បាលលាងព្រះបាទ ( របស់ព្រះរាជា ) ក្នុងកាលជាទីទ្រង់ព្រះពស្ត្រឬក្នុងកាលជាទីស្រង់ព្រះគង្គា សូម្បីព្រះរាជាទ្រង់វាយក៏មិនគប្បីខឹងតបវិញទេ រាជសេវកៈនោះទើបគួរនៅក្នុងរាជត្រកូល ។

បណ្តាបទទាំងនោះ បទថា **អលោភោ** បានដល់ ជាអ្នកមិនលោភលន់ ។ បទថា **អនុវត្តោ ច រាជិនោ** សេចក្តីថា គប្បីជាអ្នកអនុវត្តតាមព្រះរាជបំណង ។ បទថា **ចិត្តដ្ឋោ** បានដល់ តាំងនៅក្នុងចិត្ត អធិប្បាយថា នៅក្នុងអំណាចនៃចិត្តរបស់ព្រះរាជា ។ បទថា **អសង្កុសកវុត្តិស្ស** សេចក្តីថា មិន

គប្បីប្រព្រឹត្តជំទាស់ជាមួយព្រះរាជា ។ បទថា **អធោសិរំ** សេចក្ដីថា រាជ-សេវកៈសូម្បីលាងព្រះបាទគប្បីឱនក្បាលចុះ ឱនមុខចុះក្រោមមិនគប្បីមើលមុខព្រះរាជា ។

បុ៉នអម្បាលបុរសប្រាជ្ញាសេចក្ដីចម្រើន គង់ធ្វើអញ្ជលីចំពោះក្អមទឹក ឬធ្វើបទក្សិណចំពោះបក្សីក្អែក បុគ្គលមិននមស្ការចំពោះព្រះរាជា ជាបណ្ឌិតខ្ពង់ខ្ពស់ ព្រះអង្គប្រទានសេចក្ដីប្រាថ្នាគ្រប់យ៉ាងដូចម្ដេចបាន ព្រោះព្រះអង្គប្រទានទីដេក សំពត់យាននិងផ្ទះសម្រាប់សំណាក់អាស្រ័យ ទ្រង់បង្អុរភោគសម្បទដូចមេឃបង្អុរភ្លៀងដល់ពួកសត្វ ។ ម្នាលកូនសម្លាញ់ទាំងឡាយនេះជារាជវសតិធម៌ដែលនរជនប្រព្រឹត្តតាម រមែងញុំាងព្រះរាជាឲ្យប្រោសប្រាណ រមែងបានការបូជាអំពីចៅហ្វាយនាយទាំងឡាយ ។

បណ្ដាបទទាំងនោះ បទថា **កុម្ភិម្ហិ បញ្ជលី កយិរា ចាតំ ចាបិ បទក្ខិណំ** សេចក្ដីថា បុរសដែលប្រាថ្នាសេចក្ដីចម្រើនដល់ខ្លួន ឃើញក្អមដែលពេញដោយទឹកគប្បីធ្វើអញ្ជលីដល់ក្អមទឹកនោះ សូម្បីត្រឹមតែសត្វក្អែកក៏ធ្វើប្រទក្សិណបាន កាលគេធ្វើអញ្ជលីហើយធ្វើប្រទក្សិណដល់វត្ថុណា វត្ថុទាំងនោះរមែងមិនអាចនឹងឲ្យអ្វីបាន ។ បទថា **កិមេវ** សេចក្ដីថា ព្រះរាជាដែលជាអ្នកប្រាជ្ញ ព្រះរាជទានសម្បត្តិដែលគួរប្រាថ្នាគ្រប់យ៉ាង ហេតុអ្វីក៏មិននមស្ការព្រះរាជានោះ។ ព្រះរាជាប៉ុណ្ណោះដែលគប្បីនមស្ការនិងគប្បីឲ្យប្រោស

ប្រាណ ។ បទថា **បជ្ជុន្នោរិវ** ប្រែថា ដូចភ្លៀង ។ បទថា **ឯសេយ្យា រាជវសតី** សេចក្តីថា នែបាទាំងឡាយ នេះឯងឈ្មោះថា រាជវសតិដែលអញពោលហើយនេះ ជាអនុសាសនីសម្រាប់រាជសេវកៈទាំងឡាយ ។ បទថា **យថា** សេចក្តីថា រាជវសតិនេះដែលនរជនប្រព្រឹត្តតាមរមែងជាហេតុឲ្យព្រះរាជាទ្រង់ប្រោសប្រាណនិងរមែងបានទទួលការបូជា អំពីសម្នាក់ព្រះរាជាទាំងឡាយ ។

វិធុរបណ្ឌិតជាអ្នកមានធុរកិច្ចដែលមិនមានអ្នកដទៃស្មើ បានសម្តែងរាជវសតិធម៌អប់រំបុត្តភរិយា ញាតិនិងមិត្តដោយពុទ្ធលីលាចប់ដោយប្រការដូច្នេះឯង ។

## រាជវសតិកណ្ឌ ចប់

កាលព្រះមហាសត្វទូន្មានបុត្ត ភរិយា ញាតិនិងមិត្តជាដើមយ៉ាងនេះឯងចប់ស្រេចបាច់ ក៏ដល់ថ្ងៃជាគម្រប់ ៣ ។ ព្រះមហាសត្វនោះកាលដឹងថាគ្រប់កំណត់ថ្ងៃហើយក៏ងូតទឹកអំពីព្រលឹម បរិភោគភោជនាហារមានរសដ៏ប្រសើរផ្សេងៗគិតថា អញមួយអន្ទើដោយមាណពនឹងទូលលាព្រះរាជាទៅ ដូច្នេះហើយចោមរោមដោយពួកញាតិ ទៅកាន់ព្រះរាជនិវេសន៍ ថ្វាយបង្គំព្រះរាជាហើយឈរក្នុងទីសមគួរនាចំណែកម្ខាង បានក្រាបទូលពាក្យដែលសមគួរដែលខ្ញុំគប្បីក្រាបទូល ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូត្យសានូវព្រះគាថាដូច្នេះថា

វិធុរបណ្ឌិត មានប្រាជ្ញាវាងវៃ ប្រៀនប្រដៅពួកញាតិយ៉ាងនេះ
ហើយក៏ចូលទៅគាល់ព្រះរាជា ដោយមានពួកញាតិចោមរោម
វិធុរបណ្ឌិត ថ្វាយបង្គំព្រះបាទាដោយត្បូង ធ្វើបទក្សិណព្រះអង្គ
ផ្គងអញ្ជលីក្រាបបង្គំទូលព្រះរាជាថា បពិត្រព្រះអង្គជាអ្នក
បង្ក្រាបសត្រូវ មាណពនេះមានប្រាថ្នានឹងធ្វើតាមអធ្យាស្រ័យ
នឹងនាំខ្ញុំព្រះអង្គទៅ ខ្ញុំព្រះអង្គ នឹងនិយាយពាក្យជាប្រយោជន៍
ដល់ពួកញាតិ សូមព្រះអង្គ ទ្រង់ព្រះសណ្តាប់នូវពាក្យនោះ ។
សូមព្រះអង្គទ្រង់ទតមើលកូនទាំងឡាយ របស់ខ្ញុំព្រះអង្គផង
និងទ្រព្យដទៃក្នុងផ្ទះរបស់ខ្ញុំព្រះអង្គផង កាលបើខ្ញុំព្រះអង្គទៅ
ហើយ សូមកុំឲ្យពួកញាតិវិនាស ក្នុងកាលខាងក្រោយឡើយ
ប្រសិនបើទូលព្រះបង្គំមានសេចក្តីភ្លាំងភ្លាត់ ទូលព្រះបង្គំនឹង
ឃើញកំហុសនោះវិញ ដូចជាបុរសភ្លាត់ជួលលើផែនដីហើយ
ឈរសើបលើផែនដីវិញ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សុហាតេហិ** បានដល់ ដែលញាតិនិងមិត្តជាដើមជាអ្នកមានចិត្តល្អ ។ បទថា **យញ្ចមញ្ញំ** សេចក្តីថា សូមទ្រង់ប៉ុណ្ណោះមើលថែទ្រព្យសម្បត្តិដទៃទាំងអស់នោះ ដែលនឹងរាប់ប្រមាណមិនបាន ដែល

ទ្រង់និងព្រះរាជាដទៃ ព្រះរាជទានសម្រាប់ផ្ទះរបស់ទូលបង្គំ ។ បទថា **បច្ឆា** បានដល់ ក្នុងកាលជាខាងក្រោយ ។ បទថា **១លតិ** បានដល់ រមែងភ្លាត់ដួល ។ បទថា **ឯវេតំ** កាត់បទជា **ឯវំ ឯតំ** ។ ព្រោះការភ្លាំងភ្លាត់ក្នុងទ្រង់ទូលព្រះបង្គំនឹងឃើញកំហុសនោះវិញដូចមុន ដូចបុគ្គលដួលលើផែនដីរមែងក្រោកឡើងលើផែនដីនោះឯង ។ បទថា **ឯតំ បស្សាមិ** សេចក្តីថា កាលទូលព្រះបង្គំត្រូវមាណពសួរថា ព្រះរាជាជាអ្វីនឹងអ្នក ក៏មិនសម្លឹងមើលទ្រង់ប្រាជ្ញាតែពាក្យពិតពោលថា ខ្ញុំជាទាសៈ នេះជាទោសរបស់ទូលព្រះបង្គំៗឃើញទោសនេះ តែទោសរបស់ព្រះអង្គមិនមាន សូមទ្រង់អត់ទោសនោះដល់ទូលព្រះបង្គំចុះ សូមកុំធ្វើទោសនោះទុកក្នុងហឫទ័យចាប់កំហុសក្នុងបុត្តនិងកិរិយារបស់ទូលព្រះបង្គំក្នុងកាលខាងក្រោយឡើយ ។

ព្រះរាជាកាលទ្រង់ស្តាប់ដូច្នោះហើយ កាលទ្រង់សម្តែងថា នែបណ្ឌិត ការទៅរបស់អ្នកមិនគាប់ចិត្តយើងឡើយ យើងនឹងធ្វើឧបាយហៅមាណពបញ្ជាឲ្យគេយកទៅសម្លាប់ហើយបិទបាំងរឿងនេះមិនឲ្យអ្នកណាដឹង សេចក្តីនោះឯងគាប់ចិត្តយើង ដូច្នេះទើបត្រាស់គាថានេះថា

> សេចក្តីគាប់ចិត្តខ្ញុំថា អ្នកមិនគួរទៅទេ ខ្ញុំគាប់ចិត្តថា ឲ្យអ្នក
> កាប់សម្លាប់មាណពកច្ចាយនៈ ក្នុងទីនេះហើយនៅក្នុងទីនេះចុះ
> ម្នាលបណ្ឌិតមានប្រាជ្ញាឧត្តមដូចផែនដី អ្នកកុំទៅ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ជេត្វា** សេចក្តីថា យើងនឹងវាយមាណពឲ្យស្លាប់ ហើយបិទបាំងទុកក្នុងនគររាជគ្រឹះនេះឯង ។

ព្រះមហាសត្វបានស្តាប់ដូច្នោះ ទើបក្រាបទូលថា បពិត្រព្រះសម្មតិទេព ព្រះរាជអធ្យាស្រ័យបែបនេះ មិនគួរដល់ទ្រង់ឡើយ ដូច្នេះហើយពោលគាថានេះថា

សូមព្រះអង្គកុំតម្កល់ព្រះហឫទ័យក្នុងភាពមិនមែនជាធម៌ សូមប្រកបក្នុងប្រយោជន៍ផង ក្នុងធម៌ផង ប្តីយបុគ្គលធ្វើកម្មណាហើយទៅកាន់នរកក្នុងកាលខាងក្រោយ កម្មនោះ ជាអំពើអកុសលមិនប្រសើរ ។ បពិត្រព្រះអង្គជាធំជាងជន ព្រោះថាធម្មតាម្ចាស់ជាធំរបស់ទាសៈ ចង់សម្លាប់ ចង់ដុតរោលបៀតបៀនក៏បានតែនេះមិនមែនជាធម៌ ( របស់បុរាណបណ្ឌិតទេ ) ទាំងមិនមែនជាកិច្ចគួរប្រព្រឹត្តឡើយ សេចក្តីក្រោធនៃខ្ញុំព្រះអង្គមិនមានទេ ខ្ញុំព្រះអង្គសូមលាទៅ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មា ហោវធម្មេសុ** សេចក្តីថា បពិត្រព្រះអង្គ ទ្រង់កុំតាំងព្រះរាជហឫទ័យទុកក្នុងអធម៌ គឺក្នុងអនត្ថៈ បានដល់ ក្នុងអំពើអាក្រក់ឡើយ ។ បទថា **បច្ឆា** សេចក្តីថា បុគ្គលដែលធ្វើកម្មណាហើយមិនចាស់ មិនស្លាប់រមែងមិនមាន ដោយពិតបុគ្គលដែលធ្វើកម្មនោះរមែងចូលដល់នរកក្នុងកាលខាងក្រោយ ។ បទថា **ធិរត្ថុ កម្មំ** សេចក្តីថា កម្មនោះគួរតិះដៀល គឺជាកម្មដែលបណ្ឌិតក្នុងកាលមុន តិះដៀលហើយ ។ បទថា **ណេវេស** សេចក្តីថា នេះមិនមែនជាសភាវធម៌ នៃបុរាណបណ្ឌិតឡើយ ។ បទថា **អយិរោ** បានដល់ ម្ចាស់ ។ បទថា **ឃាតេតុ** ព្រះ

មហាសត្វពោលថា ធម្មតាម្ចាស់ជាធំនៃទាសៈ នឹងធ្វើការសម្លាប់ជាដើមនោះ ក៏ធ្វើបាន គឺរមែងធ្វើកម្មទាំងអស់នោះបាន តែទូលព្រះបង្គំមិនមានសេចក្តីក្រោធ សូម្បីមានប្រមាណតិចតួចក្នុងមាណព ។ រាប់តាំងពីពេលដែលទ្រង់ប្រទានទូលព្រះបង្គំដល់មាណពនេះ សូមទ្រង់តាំងព្រះហឫទ័យឲ្យទៀងត្រង់បពិត្រព្រះអង្គជាធំជាងជន ទូលព្រះបង្គំនឹងលាទៅ ។

ព្រះមហាសត្វកាលក្រាបទូលយ៉ាងនោះហើយ ក៏ថ្វាយបង្គំលាព្រះរាជាទៅទូន្មានស្រីស្នំនិងរាជបរិស័ទ កាលជនទាំងនោះអត់សង្កត់នូវសេចក្តីសោកតាមប្រក្រតីមិនបាន ទ្រហោយំខ្សឹកខ្សួលជំកន្ទងបានចេញអំពីព្រះរាជនិវេសន៍ទៅ ។ អ្នកនគរទាំងមូលបាននិយាយគ្នាថា បានឮថា វិធុរបណ្ឌិតទៅជាមួយមាណព ពួកយើងមក យើងនឹងទៅសួរសុខទុក្ខលោក ដូច្នេះហើយក៏ទៅប្រជុំគ្នា ទៅសួរសុខទុក្ខព្រះមហាសត្វត្រង់លានព្រះរាជវាំង ។ លំដាប់នោះព្រះមហាសត្វបានទូន្មានអ្នកនគរទាំងនោះថា ពួកអ្នកកុំគិតប្ញីឡើយ សង្ខារទាំងពួងមិនទៀង សរីរៈមិនស្ថិតស្ថេរ សម្បត្តិធម៌ដែលបានឈ្មោះថា យស តែងមានវិបត្តិជាទីបំផុត ម្យ៉ាងទៀតអ្នកទាំងឡាយ ចូរកុំប្រមាទក្នុងបុណ្យកុសលមានទានជាដើមដូច្នេះហើយបានបែរមុខទៅកាន់ផ្ទះរបស់ខ្លួន ។ ខណៈនោះធម្មបាលកុមារ នាំបងប្អូនប្រុសស្រីចេញទៅដោយបំណងថា នឹងទទួលបិតា បានព្រមព្រៀងគ្នានៅរង់ចាំត្រង់ទ្វារផ្ទះ ព្រះមហាសត្វឃើញធម្មបាលកុមារហើយមិនអាចអត់ធន់នឹងសេចក្តីសោក បានឱបធម្មបាលកុមារត្រង់ទ្រូងរួចពាទៅកាន់ផ្ទះ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសានូវព្រះគាថាដូច្នេះថា

ព្រះមហាសត្វនោះមានព្រះនេត្រពេញដោយទឹកភ្នែក ចូលទៅ
ឱបរឹត ( ធម្មបាលកុមារ ) ជាបុត្តច្បង លុះបន្ទោបង់សេចក្តី
ក្រវល់ក្រវាយក្នុងហឫទ័យហើយក៏ចូលទៅកាន់ផ្ទះធំ ដូច្នេះ ។

ព្រះមហាសត្វនោះ មានកូនប្រុស ១០០០ កូនស្រី ១០០០ ប្រពន្ធ ១០០០និងនាងវណ្ណទាសី ៧០០ ពេញនិវេសន៍របស់វិធុរបណ្ឌិត អឺងកងទៅដោយជនទាំងនោះ មួយអន្ទើដោយទាសៈ កម្មករ ញាតិនិងមិត្តដ៏សេសដូចព្រៃរាំងត្រូវខ្យល់ព្យុះបោកបក់ដួលទៅដូច្នោះ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសានូវព្រះគាថាដូច្នេះថា

ពួកបុត្តនិងភរិយារបស់វិធុរបណ្ឌិត ដេក ( បម្រះនទៀល )
ក្នុងលំនៅដូចជាដើមរាំង ដែលត្រូវខ្យល់បក់បោកញាំញី ។
ស្ត្រីជាប្រពន្ធ ១ ពាន់នាក់និងទាសី ៧ រយនាក់ ផ្គងដៃខ្សឹក
ខ្សួល កន្ទក់កន្ទេញក្នុងលំនៅនៃវិធុរបណ្ឌិត ។ ពួកស្រីស្នំ
ពួកកុមារ ពួកអ្នកជំនួញនិងពួកព្រាហ្មណ៍ផ្គងដៃខ្សឹកខ្សួលកន្ទក់
កន្ទេញ ក្នុងលំនៅនៃវិធុរបណ្ឌិត ។ ពួកពលដំរី ពលសេះ

ពលរថ ពលថ្មើរជើង ផ្គងដៃខ្សឹកខ្សួល កន្ទក់កន្ទេញក្នុងលំនៅនៃវិធុរបណ្ឌិត ។ ពួកអ្នកជនបទមកជួបជុំគ្នាទាំងពួកអ្នកនិគមក៏មកជួបជុំគ្នាផ្គងដៃខ្សឹកខ្សួល កន្ទក់កន្ទេញក្នុងលំនៅនៃវិធុរបណ្ឌិត ។ ស្ត្រីជាប្រពន្ធ ១ ពាន់នាក់និងទាសី ៧ រយនាក់ផ្គងដៃខ្សឹកខ្សួល កន្ទក់កន្ទេញថា ហេតុអ្វីទើបលោកលះចោលពួកយើង ។ ពួកស្រីស្នំ ពួកកុមារ ពួកអ្នកជំនួញនិងពួកព្រាហ្មណ៍ផ្គងដៃខ្សឹកខ្សួល កន្ទក់កន្ទេញថា ហេតុអ្វីទើបលោកលះចោលពួកយើង ។ ពួកពលដំរី ពលសេះ ពលរថ ពលថ្មើរជើង ផ្គងដៃខ្សឹកខ្សួលកន្ទក់កន្ទេញថា ហេតុអ្វីទើបលោកលះចោលពួកយើង ។ ពួកអ្នកជនបទមកជួបជុំគ្នា ទាំងពួកអ្នកនិគមក៏មកជួបជុំគ្នា ផ្គងដៃខ្សឹកខ្សួលកន្ទក់កន្ទេញថា ហេតុអ្វីទើបលោកលះចោលពួកយើង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សេន្តិ** សេចក្តីថា ( បុត្ត ១០០០ ធីតា ១០០០ ភរិយា ១០០០ វណ្ណៈទាសី ៧០០ ) បម្រះនទៀលដួលលើគ្នាដូចបុគ្គលដែលមានជើងដាច់ដួលចុះលើមហាប្រឹថពីដូច្នោះ ។ បទថា **ភរិយានំ** បានដល់ ស្រី គឺប្រពន្ធ ១០០០ ។ បទថា **កស្មា នោ** សេចក្តីថា នាំគ្នាខ្សឹកខ្សួលថា ព្រោះហេតុអ្វីទើបលោកលះបង់ពួកយើងទៅ ។

ព្រះមហាសត្វ លួងលោមមហាជនទាំងអស់ ឲ្យប្រាសចាកសេចក្តីសោក ធ្វើកិច្ចដែលសេសសល់ឲ្យសម្រេច ទូន្មានអន្តោជននិងពាហិរជន ប្រាប់រឿង

ដែលគួរប្រាប់គ្រប់យ៉ាងដល់កូននិងប្រពន្ធស្រេចហើយ ក៏ទៅកាន់សម្នាក់នៃបុណ្ណកយក្ខ ប្រាប់កិច្ចរបស់ខ្លួនដែលធ្វើស្រេចហើយដល់បុណ្ណកយក្ខនោះ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** វីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសាទនូវព្រះគាថាដូច្នេះថា

ព្រះមហាសត្វ បានធ្វើកិច្ចទាំងឡាយក្នុងផ្ទះ ប្រៀនប្រដៅជនរបស់ខ្លួន គឺពួកមិត្ត អាមាត្យ ជនអ្នកនៅអាស្រ័យ បុត្តភរិយានិងផៅពង្ស ។ ព្រះមហាសត្វចាត់ចែងការងារប្រាប់នូវទ្រព្យក្នុងផ្ទះនិងកំណប់និងការឲ្យបុល ហើយពោលពាក្យនេះនឹងបុណ្ណកយក្សថា អ្នកបានស្នាក់នៅក្នុងផ្ទះរបស់ខ្ញុំ អស់ ៣ ថ្ងៃហើយ កិច្ចក្នុងផ្ទះខ្ញុំធ្វើហើយ ទាំងបុត្តនិងភរិយា ខ្ញុំក៏បានប្រៀនប្រដៅហើយ អ្នកចូរធ្វើកិច្ចទាំងឡាយតាមអធ្យាស្រ័យរបស់អ្នកចុះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កម្មន្តំ សំវិធេត្វាន** សេចក្ដីថា រៀបចំកិច្ចដែលគួរធ្វើក្នុងផ្ទះថា គួរធ្វើយ៉ាងនេះនិងយ៉ាងនេះ ។ បទថា **និធឹ** បានដល់ទ្រព្យដែលកប់ក្នុងទីនោះៗ ។ បទថា **ឥណាទានំ** បានដល់ ទ្រព្យដែលប្រគបទៅដោយបំណុល ។ បទថា **យថាមតី តេ** សេចក្ដីថា ឥឡូវនេះចូរអ្នកធ្វើតាមអធ្យាស្រ័យរបស់អ្នកចុះ ។

លំដាប់នោះបុណ្ណកយក្ខពោលនឹងព្រះមហាសត្វថា

បពិត្រអ្នកជាអាមាត្យ បើអ្នកបានប្រៀនប្រដៅបុត្ត ភរិយានិង ពួកជនអ្នកចិញ្ចឹមជីវិតដោយសារហើយ អើអ្នក ចូរប្រញាប់ ប្រញាល់មកក្នុងកាលឥឡូវនេះចុះ ព្រោះថាផ្លូវខាងមុខនេះជា ផ្លូវដាច់ស្រយាលវែងឆ្ងាយ ។ អ្នកកុំភ័យ ចូរចាប់តោងកន្ទុយ សេះអាជានេយ្យចុះ នេះជាការឃើញនូវជីវលោក ជាទីបំផុត របស់អ្នក ដូច្នេះ ។

បុណ្ណកយក្ខដល់នូវសោមនស្សហៅព្រះមហាសត្វថា **កត្តេ** ។ ក្នុងគាថា នោះ បទថា **អទ្ធាបិ** សេចក្តីថា ត្រឹមតែផ្លូវដែលគប្បីទៅក៏ឆ្ងាយណាស់ ។ បទថា **អជម្ពិតោវ** បានដល់ កុំតក់ស្លុតឡើយ ។ បុណ្ណកយក្ខនោះមិនចូល ខាងក្រោមប្រាសាទ បំណាងនឹងចៀសចេញទៅអំពីទីនោះ ទើបពោលយ៉ាង នោះ ។

លំដាប់នោះព្រះមហាសត្វពោលនឹងបុណ្ណកយក្ខនោះថា

បុគ្គលទៅកាន់ទុគ្គតិដោយអំពើណា ដែលកើតអំពីកាយវាចា ចិត្ត អំពើអាក្រក់ ( នោះ ) របស់ខ្ញុំមិនមានទេ ខ្ញុំនឹងខ្លាច ចំពោះអំពើអ្វី ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សោហំ កិស្សាមិ ភាយិស្សំ** សេចក្តីថា ព្រះ មហាសត្វត្រូវបុណ្ណកយក្ខពោលថា អ្នកកុំខ្លាចឡើយ ចូរកាន់យកចុះដូច្នេះ ទើប ពោលយ៉ាងនេះ ។

ព្រះមហាសត្វ បន្លឺសីហនាទដោយប្រការយ៉ាងនេះ មិនមែនតក់ស្លុតទេ

ព្រោះជាអ្នកមិនមានភ័យ អង់អាចដូចស្តេចកេសរសីហៈ ធ្វើអធិដ្ឋានបារមីឲ្យជាបុរេចារិកថា សំពត់សាដករបស់អាត្មាអញនេះ ចូរកុំរហូតចាកកាយនៃអញឡើយ ហើយស្លៀកសំពត់យ៉ាងខ្ជាប់ ចាប់កន្ទុយសេះដោយដៃទាំង ២ យ៉ាងមាំ យកជើងទាំង ២ កៀបភ្លៅសេះយ៉ាងណែនពោលថា នៃមាណព ខ្ញុំចាប់កន្ទុយសេះហើយ ចូរអ្នកទៅតាមគាប់ចិត្តចុះ ខណៈនោះបុណ្ណកយក្ខបានឲ្យសញ្ញាដល់សេះមនោមយសិន្ធព ។ ឯសេះមនោមយសិន្ធពនោះ បាននាំវិធុរបណ្ឌិតនោះហោះពួយទៅក្នុងអាកាស ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូត្រសាន្ធូវព្រះគាថាដូច្នេះថា

ស្តេចសេះនោះ នាំវិធុរបណ្ឌិត ហោះទៅឰដ៏អាកាសវេហាស៍
ឥតប៉ះទង្គិចនឹងមែកឈើ ឬភ្នំ ក៏ចូលទៅកាន់កាឡាគិរីបព៌ត
ដោយឆាប់រហ័ស ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សាខាសុ សេលេសុ អសជ្ជមានោ** សេចក្តីថា បានឮថា បុណ្ណកយក្ខគិតថា អញមកឆ្ងាយហើយ អញគួរបោកវិធុរ-បណ្ឌិតនេះឲ្យស្លាប់ត្រង់ដើមឈើនិងភ្នំក្នុងហិមវន្តប្បទេស កាន់យកតែសាច់បេះដូង បោលសាកសពក្នុងញកភ្នំហើយទៅកាន់ស្ថាននាគ ថ្វាយសាច់ហទយៈនោះដល់ព្រះនាងវិមលាទេវីក្នុងនាគពិភព ហើយទទួលយកនាងឥរន្ធតីត្រឡប់មក ។

បុណ្ណកយក្ខនោះបោកព្រះមហាសត្វត្រង់ដើមឈើនិងភ្នំ បរសេះទៅក្នុងវាំងផ្លូវដែលមានដើមឈើនិងភ្នំនោះឯង ដោយអានុភាពនៃព្រះមហាសត្វ ដើមឈើក្តី ភ្នំក្តី ក៏ញែកចេញអំពីកន្ទុយសេះ និងសរីរៈរបស់ព្រះមហាសត្វម្ខាងមួយហត្ថ បុណ្ណកយក្ខងាកមើលក្រោយសម្លឹងមុខព្រះពោធិសត្វ ព្រោះចង់ដឹងថា ស្លាប់ហើយឬនៅ ឃើញមុខព្រះពោធិសត្វថ្លូរថង់ដូចកញ្ចក់មាស ដឹងថា ធ្វើយ៉ាងនេះព្រះពោធិសត្វមិនស្លាប់ ទើបបោកព្រះមហាសត្វត្រង់ដើមឈើនិងភ្នំ ៣ ដង ដោយបរសេះទៅក្នុងវាំងដើមឈើ និងភ្នំក្នុងហិមវន្តប្បទេសនោះទៀត ដើមឈើក្តី ភ្នំក្តី រមែងញែកចៀសចេញផុតពីកន្ទុយសេះដូចមុននោះឯង ។ ព្រះមហាសត្វបានទទួលសេចក្តីលំបាកកាយក្រៃលែង ។ បុណ្ណកយក្ខគិតថា អញនឹងធ្វើបុរសនេះឲ្យក្លាយជាលម្អិតតូចជាំក្នុងគំនរខ្យល់ក្នុងកាលឥឡូវនេះហើយជិះសេះកាត់ទីដែលមានខ្យល់ខ្លាំង ងាកមើលដោយគិតថា បុរសនេះស្លាប់ហើយឬនៅ ឃើញមុខមហាសត្វស្រស់ថ្លូរថង់ដូចផ្កាឈូកដែលរីក ក៏មានសេចក្តីក្រោធជាកម្លាំង ជិះសេះកាត់គំនរខ្យល់ត្រឡប់ទៅត្រឡប់មកអស់ ៧ ដង ដោយអានុភាពនៃព្រះពោធិសត្វ គំនរខ្យល់ក៏ញែកជា ២ ឲ្យឱកាសដល់ព្រះមហាសត្វ ។ លំដាប់នោះបុណ្ណកយក្ខក៏ជិះសេះទៅកាន់គំនរខ្យល់ឈ្មោះវេរម្ភវាត ។ សូម្បីខ្យល់វេរម្ភវាត ដែលមានសន្ទឹកគគ្រាំគគ្រេង ដូចរន្ទះធ្លាក់ចុះរាប់សែនដង ក៏បើកឱកាសដល់ព្រះពោធិសត្វ ។ ចំណែកបុណ្ណកយក្ខកាលឃើញព្រះពោធិសត្វមិនមានអន្តរាយដោយខ្យល់វេរម្ភវាតនោះក៏ជិះសេះមកកាន់កាឡាគិរីបព៌ត ។ ព្រោះហេតុនោះទើប

ព្រះសាស្តាត្រាស់ព្រះគាថានេះថា

ស្តេចសេះនោះ នាំវិធុរបណ្ឌិត ហោះទៅតួដ៏អាកាសវេហាស៍
ឥតប៉ះទង្គិចនឹងមែកឈើ ឬភ្នំ ក៏ចូលទៅកាន់កាឡាគិរីបពិត
ដោយឆាប់រហ័ស ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អសជ្ជមានោ** សេចក្តីថា មិនទើសទាក់ មិនប៉ះទង្គិច នាំវិធុរបណ្ឌិតទៅកាន់កំពូលភ្នំកាឡាគិរីបពិត ។

ក្នុងកាលដែលបុណ្ណកយក្ខនាំមហាសត្វទៅយ៉ាងនោះ បិយជនទាំងឡាយមានកូននិងប្រពន្ធជាដើមនៃវិធុរបណ្ឌិត ទៅកាន់ទីសម្រាកនៃបុណ្ណកយក្ខមិនឃើញមហាសត្វ ទើបកន្ទក់កន្ទេញបម្រះនទៀលទៅមកដូចមានជើងដាច់ នាំគ្នាស្រែកយំខ្សឹកខ្សួលដោយសំឡេងខ្លាំង ។

**តមត្ថំ បកាសេន្តោ សត្ថា អាហា** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសាធុនូវព្រះគាថាដូច្នេះថា

ស្ត្រីជាប្រពន្ធ ១ ពាន់នាក់និងទាសី ៧ រយនាក់ ផ្គងដៃខ្សឹកខ្សួលកន្ទក់កន្ទេញថា យក្សក្លែងភេទជាព្រាហ្មណ៍នាំវិធុរបណ្ឌិតទៅ ។ ពួកស្រីស្នំ ពួកកុមារ ពួកអ្នកជំនួញនិងពួកព្រាហ្មណ៍ផ្គងដៃខ្សឹកខ្សួលកន្ទក់កន្ទេញថា យក្សក្លែងភេទជាព្រាហ្មណ៍នាំវិធុរបណ្ឌិតទៅ ។ ពួកពលដំរី ពលសេះ ពលរថ ពលថ្មើរជើង ផ្គងដៃខ្សឹកខ្សួល កន្ទក់កន្ទេញថា យក្សក្លែងភេទជា

ព្រាហ្មណ៍នាំវិធុរបណ្ឌិតទៅ ។ ពួកអ្នកជនបទមកជួបជុំគ្នា ទាំង ពួកអ្នកនិគមក៏មកជួបជុំគ្នា ផ្គងដៃខ្សឹកខ្សួល កន្ទក់កន្ទេញថា យក្សក្លែងភេទជាព្រាហ្មណ៍នាំវិធុរបណ្ឌិតទៅ ។ ស្រ្តីជាប្រពន្ធ ១ ពាន់នាក់និងទាសី ៧ រយនាក់ ផ្គងដៃខ្សឹកខ្សួល កន្ទក់ កន្ទេញថា វិធុរបណ្ឌិតទៅក្នុងទីណាហ្ន៎ ។ ពួកស្រីស្នំ ពួក កុមារ ពួកអ្នកជំនួញនិងពួកព្រាហ្មណ៍ ផ្គងដៃខ្សឹកខ្សួលកន្ទក់ កន្ទេញថា វិធុរបណ្ឌិតទៅក្នុងទីណាហ្ន៎ ។ ពួកពលដំរី ( ពល សេះ ) ពលរថ ពលថ្មើរជើង ផ្គងដៃខ្សឹកខ្សួលកន្ទក់កន្ទេញ ថា វិធុរបណ្ឌិតនោះទៅក្នុងទីណាហ្ន៎ ។ ពួកអ្នកជនបទមកជួប ជុំគ្នា ទាំងពួកអ្នកនិគមក៏មកជួបជុំគ្នា ផ្គងដៃខ្សឹកខ្សួលកន្ទក់ កន្ទេញថា វិធុរបណ្ឌិតនោះទៅក្នុងទីណាហ្ន៎ ដូច្នេះ ។

ជនទាំងអស់នោះឃើញនិងបានដឹងថា បុណ្ណកយក្ខនាំព្រះមហាសត្វទៅ តាមអាកាស នាំគ្នាខ្សឹកខ្សួលហើយយ៉ាងនេះ នាំគ្នាកន្ទក់កន្ទេញព្រមដោយ អ្នកនគរទាំងមូលបាននាំគ្នាទៅកាន់ព្រះរាជវាំង ។ ព្រះរាជាទ្រង់ស្តាប់សំឡេង យំសោកដ៏ខ្លាំង ទ្រង់បើកបង្អួចទតមើលក៏ត្រាស់សួរថា ពួកអ្នកយំរៀបរាប់ ព្រោះហេតុអ្វី ។ លំដាប់នោះអ្នកនគរទាំងនោះទូលប្រាប់សេចក្តីនោះដល់ព្រះ រាជាថា បពិត្រព្រះសម្មតិទេព មាណពនោះមិនមែនព្រាហ្មណ៍ជាយក្ខកាឡា ខ្លួនជាព្រាហ្មណ៍មកយកវិធុរបណ្ឌិតទៅ ទូលព្រះបង្គំទាំងឡាយ ព្រាត់ប្រាស ចាកវិធុរបណ្ឌិតនោះហើយនឹងមិនមានជីវិត បើវិធុរបណ្ឌិតមិនត្រឡប់មកក្នុង

ថ្ងៃទី ៧ រាប់អំពីថ្ងៃនេះសោត ពួកទូលព្រះបង្គំនឹងជញ្ជូនឧសមកដោយរទេះ មួយរយ ដោយរទេះមួយពាន់ ដុតឲ្យឆេះជាគំនរភ្លើងដ៏សន្ធោសន្ធៅហើយ ចូលទៅកាន់គំនរភ្លើង ដូច្នេះហើយទូលគាថានេះថា

បើបណ្ឌិតនោះនឹងមិនត្រឡប់មកក្នុងរវាង ៧ រាត្រីវិញទេ ពួក
ទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នានឹងចូលភ្លើង ពួកទូលព្រះបង្គំជាខ្ញុំ
មិនមានសេចក្តីត្រូវការដោយជីវិតឡើយ ដូច្នេះ ។

ក្នុងកាលបរិនិព្វាននៃព្រះសម្មាសម្ពុទ្ធ ទេវតានិងមនុស្សទាំងឡាយ មិនមានអ្នកនិយាយថា ពួកយើងនឹងចូលទៅកាន់គំនរភ្លើងឲ្យស្លាប់ដូច្នេះ ក្នុងព្រះនគរព្រះមហាសត្វគ្រប់គ្រងដោយល្អហើយនោះឯង ។ ព្រះរាជាទ្រង់ស្តាប់ពាក្យរបស់ជនទាំងនោះហើយមានព្រះរាជតម្រាស់ថា ពួកអ្នកកុំនាំគ្នាវិតក្កឡើយ កុំសោយសោកថ្វីឡើយ វិធុរបណ្ឌិតជាអ្នកសម្តែងធម៌ពីរោះ ក្នុងបទដើម បទកណ្តាលនិងបទចុង ទូន្មានមាណពដោយធម្មកថា ឲ្យក្រាបចុះទៀបបាតជើងរបស់ខ្លួន មិនយូរប៉ុន្មានក៏នឹងមកជូតមុខរបស់ពួកយើងដែលពេញទៅដោយទឹកភ្នែកឲ្យរីករាយ ពួកអ្នកកុំសោយសោកថ្វីឡើយ ដូច្នេះហើយត្រាស់គាថានេះថា

បណ្ឌិតជាបុគ្គលឈ្លាសវៃ អាចសំដែង ( ប្រយោជន៍ ) និង
មិនមែនប្រយោជន៍ មានប្រាជ្ញាឈ្វេងយល់ រមែងដោះខ្លួនបាន
ដោយឆាប់ អ្នកទាំងឡាយកុំខ្លាចឡើយ បណ្ឌិតនោះគង់តែនឹង
ត្រឡប់មកវិញ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វិយត្តោ** សេចក្តីថា ប្រកបដោយភាពជា

អ្នកឈ្លាសវៃ គឺដោយបញ្ញាជាគ្រឿងពិចារណា ។ បទថា **វិភាវី** សេចក្តីថា ជាអ្នកអាចសម្តែង ដល់ប្រយោជន៍និងមិនមែនប្រយោជន៍ ហេតុនិងមិនមែនហេតុឲ្យជាក់ច្បាស់ ។ បទថា **វិចក្ខណោ** សេចក្តីថា ប្រកបដោយបញ្ញាដែលជាគ្រឿងដឹងច្បាស់ដល់ហេតុដែលកើតឡើងតាមឋានៈ ក្នុងខណៈនោះៗឯង ។ បទថា **មា ភាយិត្ថ** សេចក្តីថា ព្រះរាជាទ្រង់លួងលោមថា ពួកអ្នកកុំភ័យឡើយ វិធុរបណ្ឌិតដោះខ្លួនឲ្យផុតហើយ នឹងត្រឡប់មកដោយរួសរាន់ ។

ឯអ្នកនគរក៏បាននូវការកក់ក្តៅគិតថា វិធុរបណ្ឌិតទូលព្រះរាជាហើយទើបទៅដោយប្រការដូច្នេះឯង ។

## អន្តរបេយ្យាល ចប់

ចំណែកបុណ្ណកយក្ខ ដាក់ព្រះពោធិសត្វលើកំពូលភ្នំកាឡាគិរីបព៌តហើយ ទើបគិតថា កាលវិធុរបណ្ឌិតនេះនៅមានជីវិតឈ្មោះថា សេចក្តីចម្រើនរមែងមិនមានដល់អញ អញត្រូវសម្លាប់វិធុរបណ្ឌិតនេះឲ្យស្លាប់ កាន់យកសាច់ហទយៈ ទៅថ្វាយព្រះនាងវិមលាឯស្ថាននាគ នឹងទទួលនាងឥរន្ទតីទៅកាន់ទេវលោក ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** វីអាចិធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសានូវព្រះគាថាដូច្នេះថា

បុណ្ណកយក្សនោះកាលទៅលើកំពូលភ្នំកាឡាគិរីនោះ ក៏គិតថា គំនិតទាំងឡាយ រមែងជាធម្មជាតិខ្ពស់និងទាប អញមិនមែនមានកិច្ចតិចតួចដោយជីវិតរបស់វិធុរបណ្ឌិតនេះ ( ក្នុងភពនាគនោះទេ ) អញនឹងសម្លាប់វិធុរបណ្ឌិតនេះហើយនាំយកតែដួងហឫទ័យទៅ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សោ** បានដល់ បុណ្ណកយក្ខនោះ ។ បទថា **តត្ថ គន្ត្វាន** សេចក្ដីថា ទៅឈរលើកំពូលភ្នំកាឡាគិរីនោះ ។ បទថា **ចេតណា** សេចក្ដីថា ការគិតដែលកើតឡើងគ្រប់ខណៈចិត្តរមែងជាគំនិតខ្ពស់ខ្លះទាបខ្លះតែការគិតជាហេតុឲ្យជីវិតដល់មហាសត្វ ជាឋានៈដែលគប្បីកើតឡើងមិនមានឡើយ ព្រោះហេតុនោះបុណ្ណកយក្ខបានធ្វើតាមការសម្រេចចិត្តថា អញមិនត្រូវការដោយការរស់នៅរបស់វិធុរបណ្ឌិតនេះសូម្បីតែតិចតួចឡើយ អញនឹងសម្លាប់វិធុរបណ្ឌិតនេះនាំយកតែដួងហឫទ័យទៅប៉ុណ្ណោះ ។

លំដាប់នោះបុណ្ណកយក្ខគិតថា បើដូច្នោះអញមិនគប្បីសម្លាប់វិធុរបណ្ឌិតនេះដោយដៃរបស់អញ នឹងឲ្យស្លាប់ដោយការបង្ហាញរូបដែលគួរខ្លាច ទើបកាឡាខ្លួនជាយក្ខដែលគួរខ្លាច ចូលមកសម្លុតព្រះមហាសត្វ ប្រាទព្រះមហាសត្វឲ្យដួល ចាប់ជើងទាំង ២ យកទៅញាត់ក្នុងចន្លោះធ្មេញ ធ្វើអាការដូចបំណងនឹងទំពាស៊ី ទោះធ្វើអាការយ៉ាងនោះការតក់ស្លុត សូម្បីត្រឹមតែធ្វើឲ្យព្រឺរោមព្រឺស្បែក មិនមានដល់មហាសត្វឡើយ ។ លំដាប់នោះបុណ្ណកយក្ខកាឡាខ្លួនជាកេសរសីហៈខ្លះ ជាដំរីចុះប្រេងដ៏ធំខ្លះ រត់មកធ្វើដូចជាខាំដោយ

ចង្កូមនិងបុសដោយភ្លុក កាលព្រះមហាសត្វមិនតក់ស្លុតដោយអាការយ៉ាងនោះ ក៏និម្មិតជាពស់ធំប្រមាណប៉ុនទូកកម្រោល លូនមកព័ទ្ធព័ន្ធរាងកាយរបស់ព្រះមហាសត្វដោយជុំវិញហើយបើកពពារលើក្បាលបញ្ចេញសំឡេងយូយូសូម្បីហេតុធ្វើឲ្យខ្លាចត្រឹមតែការព្រឺរោម ក៏មិនមានដល់ព្រះមហាសត្វ ។ លំដាប់នោះបុណ្ណកយក្ខក៏ដាក់ព្រះមហាសត្វលើកំពូលភ្នំ បណ្ដាលជាព្យុះធំឲ្យបក់មកដោយបំណងថា នឹងធ្វើមហាសត្វឲ្យធ្លាក់ចុះបែកជាលម្អិតតូចធំ តែមហាព្យុះនោះមិនអាចធ្វើសូម្បីត្រឹមតែចុងសក់ ឲ្យកម្រើកបាន ។ លំដាប់នោះបុណ្ណក-យក្ខដាក់មហាសត្វលើកំពូលភ្នំនោះឯង ចាប់ភ្នំអង្រួនទៅមកដូចដីរអង្រួនដើមល្មើដូច្នោះ តែទោះជាយ៉ាងនោះក៏មិនអាចធ្វើមហាសត្វឲ្យកម្រើកឃ្លាតចាកទីសូម្បីត្រឹមមួយចម្រៀកសក់បានឡើយ ។

ខណៈនោះបុណ្ណកយក្ខក៏ជ្រែកចូលទៅខាងក្នុងភ្នំ ស្រែកឡើងដោយសំឡេងខ្លាំងធ្វើផែនដីនិងអាកាសឲ្យមានសំឡេងកងរំពងតែមួយដោយបំណងថា នឹងបំបែកដួងហទយៈរបស់មហាសត្វឲ្យស្លាប់ ដោយការភ័យខ្លាចអំពីសំឡេង ទោះបីធ្វើអាការយ៉ាងនោះហេតុដែលធ្វើឲ្យខ្លាចសូម្បីត្រឹមតែការព្រឺរោមព្រឺស្បែកមិនមានដល់មហាសត្វឡើយ ។ ពិតហើយមហាសត្វរមែងដឹងថា ការកាឡាខ្លួនជាយក្ខ ជារាជសីហ៍ ជាដំរី ជាស្ដេចនាគមកក្ដី ធ្វើខ្យល់និងអង្រួនភ្នំក្ដី ជ្រែកចូលទៅខាងក្នុងភ្នំហើយបន្លឺសីហនាទក្ដី គឺជាការធ្វើរបស់មាណពនោះឯង មិនមែនអ្នកដទៃឡើយ ។ លំដាប់នោះបុណ្ណកយក្ខគិតថា អញមិនអាចឲ្យវិធុរបណ្ឌិតនេះស្លាប់ ដោយសេចក្ដីព្យាយាមក្រៅអំពីនេះបាន

ឡើយ បើដូច្នោះអញនឹងឲ្យគេស្លាប់ដោយដៃអញនេះឯង គិតដូច្នេះហើយ ក៏ចាប់ព្រះមហាសត្វដាក់លើកំពូលភ្នំហើយចុះទៅកាន់ជើងភ្នំ ជ្រែកក្នុងភ្នំផុស ឡើង ដូចបុគ្គលជោតអំបោះចូលទៅក្នុងកែវមណី ស្រែកដោយសំឡេងខ្លាំង ចាប់ព្រះមហាសត្វយ៉ាងខ្ជាប់ហើយគ្រវីលើក្បាល បោះទៅក្នុងអាកាសដែល មិនទីទើសទាក់ ។

ព្រោះហេតុនោះទើបព្រះសាស្តាត្រាស់ថា

> មាណពកច្ចាយនគោត្តនោះមានចិត្តប្រទូស្ត បានទៅក្នុងចន្លោះ
> ភ្នំនោះហើយចូលទៅខាងក្នុងភ្នំ ចាប់ព្រះមហាសត្វយកក្បាល
> ចុះក្រោម ( គ្រវែងទៅ ) ក្នុងប្រទេសនៃផែនដីដែលមិនមាន
> អ្វីប៉ះពាល់ឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **គន្ត្វា** សេចក្តីថា បុណ្ណកយក្ខចុះអំពីកំពូលភ្នំ ទៅកាន់ជើងភ្នំ ហើយដាក់វិធុរបណ្ឌិតត្រង់ចន្លោះភ្នំមុជទៅខាងក្នុង មកប្រាកដ ខាងក្រោមព្រះមហាសត្វ ដែលឈរលើកំពូលភ្នំ ចាប់ព្រះមហាសត្វបោះទៅ កាន់ផែនដីដែលមិនមានអ្វីរាំង ។ បទថា **ធារយិ** សេចក្តីថា ដំបូងចាប់ព្រះ មហាសត្វនោះឲ្យមានក្បាលចុះក្រោម ។

បុណ្ណកយក្ខឈរលើកំពូលភ្នំនោះឯង បោះព្រះពោធិសត្វឲ្យធ្លាក់ទៅលើ ផែនដី ព្រះមហាសត្វខ្ទាតទៅទីប្រមាណ ១៥ យោជន៍ ហើយលាដៃចេញទៅ ចាប់ជើងទាំង ២ របស់ព្រះមហាសត្វលើកឡើងឲ្យមានក្បាលចុះក្រោមសម្លឹង មើលមុខដឹងថាមិនទាន់ស្លាប់ ទើបគ្រវែងព្រះមហាសត្វម្តងទៀត លើកទី ២

ព្រះមហាសត្វខ្ទាតទៅចម្ងាយ ៣០ យោជន៍ ហើយលាដៃចាប់ព្រះមហាសត្វលើកឡើងដោយទំនងនោះដូចគ្នាមើលមុខដឹងថានៅមានជីវិត ទើបគិតថាម្តងនេះអញនឹងធ្វើគេឲ្យខ្ទាតទៅប្រមាណ ៦០ យោជន៍ បើមិនស្លាប់សោតអញនឹងចាប់ជើងបោកត្រង់កំពូលភ្នំនេះឲ្យស្លាប់ ។ លំដាប់នោះបុណ្ណកយក្ខ បានគ្រវែងព្រះមហាសត្វក្នុងលើកទី ៣ ព្រះមហាសត្វខ្ទាតទៅចម្ងាយ ៦០ យោជន៍ រួចទើបលាដៃចាប់ជើងព្រះមហាសត្វលើកឡើងមើលមុខ ។ ឯព្រះមហាសត្វគិតថា មាណពនេះបោកអញទៅជំបូងចម្ងាយ ១៥ យោជន៍ លើកទី ២ ៣០ យោជន៍ លើកទី ៣ ៦០ យោជន៍ ឥឡូវនេះ មាណពនេះមិនគ្រវែងអាត្មាអញទៅទៀត គេនឹងលើកអញឡើងបោកផ្ទប់នឹងកំពូលភ្នំនេះ ឲ្យស្លាប់ពិត អាត្មាអញដែលមានក្បាលចុះក្រោមយ៉ាងនេះ នឹងសួរដល់ហេតុនៃការសម្លាប់ ក្នុងពេលដែលបុណ្ណកយក្ខលើកព្រះមហាសត្វឡើង បោកត្រង់កំពូលភ្នំ ព្រះមហាសត្វមិនបានតក់ស្លុត បានធ្វើដូចមុននោះឯង ។

ដោយហេតុនោះទើបព្រះសាស្តាត្រាស់ថា

> វិធុរបណ្ឌិតនោះ ជាអាមាត្យដ៏ប្រសើររបស់អ្នកដែនកុរុ កាលសំយុងចុះទៅក្នុងរណ្តៅជ្រោះ ជាទីមានភ័យដ៏ធំគួរព្រួចព្រឺរោម ដែលលំបាកនឹងទៅក្រែលែង តែមិនតក់ស្លុតហើយពោលនឹងបុណ្ណកយក្សយ៉ាងនេះថា អ្នកជាមនុស្សមិនប្រសើរ តែធ្វើដូចជាប្រសើរ ជាអ្នកមិនសង្រួមតែមានអាការហាក់ដូចជាអ្នកសង្រួម អ្នកធ្វើអំពើអាក្រក់ឥតប្រយោជន៍ ចំណែកកុសលតិចតួចឥត

មានក្នុងចិត្តនៃអ្នកទេ ។ អ្នកចង់ទម្លាក់ខ្ញុំទៅក្នុងរណ្ដៅជ្រោះ ដោយហេតុណា ប្រយោជន៍ដូចម្ដេច ដោយការសម្លាប់ខ្ញុំនឹងមានដល់អ្នក ដោយហេតុនោះក្នុងថ្ងៃនេះអ្នកមានភេទដូចជាមិនមែនភេទនៃមនុស្សទេ ចូរអ្នកប្រាប់ខ្ញុំ អ្នកជាទេវតាឬជាអ្វីដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សោ លទ្ធមានោ** សេចក្ដីថា វិធុរបណ្ឌិតជាអ្នកប្រាជ្ញដ៏ប្រសើររបស់អ្នកកុរុ កាលមានក្បាលសំយុងចុះទៅក្នុងជ្រោះដែលជាវារៈទី ៣ ។ បទថា **អរិយាវកាសោ** សេចក្ដីថា អ្នកមានរូបដូចជាបុគ្គលប្រសើរ មានពណ៌សម្បុរដូចទេវបុត្តត្រាច់ទៅ ។ បទថា **អសញ្ញតោ** សេចក្ដីថា អ្នកជាបុគ្គលមិនសង្រួមកាយជាដើម ជាអ្នកទ្រុស្តសីល ។ បទថា **អច្ចាហិតំ** បានដល់ នូវកម្មដែលកន្លងបង់នូវប្រយោជន៍ ឬកម្មដែលមិនជាប្រយោជន៍ក្រៃលែង ។ បទថា **ភាវេ ច តេ** សេចក្ដីថា កុសលកម្មសូម្បីតិចតួច មិនមានក្នុងចិត្តរបស់អ្នក ។ បទថា **អមានុសស្សេវ តវជ្ជ វណ្ណោ** សេចក្ដីថា ថ្ងៃនេះហេតុរបស់អ្នកជាហេតុនៃអមនុស្សនោះឯង ។ បទថា **កាត-មាសិ ទេវតា** សេចក្ដីថា លោកជាយក្ខឈ្មោះអ្វីក្នុងរវាងយក្ខទាំងឡាយ ។

លំដាប់នោះបុណ្ណកយក្ខពោលនឹងមហាសត្វជាគាថាយ៉ាងនេះថា

ខ្ញុំនោះឈ្មោះបុណ្ណកយក្ស ជាអាមាត្យព្រះបាទកុវេរៈ ដែលអ្នកធ្លាប់បានឮហើយ នាគរាជព្រះនាមវរុណៈ ជាអ្នកទ្រទ្រង់ផែនដីមានទំហំនិងកម្ពស់ មានទ្រង់ទ្រាយដ៏ស្អាតបរិបូណ៌ដោយពណ៌

និងកម្លាំង ។ ម្នាលអ្នកប្រាជ្ញ ខ្ញុំចង់បានធីតាជាអនុជាតនៃព្រះ
បាទវរុណនាគនោះ នាគកញ្ញានោះឈ្មោះឥរន្ទតី ខ្ញុំព្យាយាម
សម្លាប់អ្នកព្រោះហេតុនាងឥរន្ទតីមានចង្កេះល្អ ជាទីស្រឡាញ់
នោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សជិញ្ញោ** បានដល់ ជាអាមាត្យអ្នកធ្វើរាជកិច្ច ។ បទថា **ព្រហា** សេចក្តីថា ដល់ព្រមដោយកម្ពស់និងទំហំ ។ បទថា **សុចិ** បានដល់ ដូចរូបមាសដែលលើកឡើងហើយ ។ បទថា **វណ្ណពលូ-បបន្នោ** សេចក្តីថា ចូលដល់ដោយលម្អនៃសរីរៈនិងដោយកម្លាំងកាយ ។ បទថា **តស្សានុជំ** បានដល់ កូនស្រីបង្កើតរបស់ស្តេចនាគនោះ ។ បទថា **បត្ថារយឹ** សេចក្តីថា ខ្ញុំញុំាងចិត្តឲ្យប្រព្រឹត្តទៅហើយ គឺបានធ្វើការសម្រេចចិត្តហើយ ។

ព្រះមហាសត្វ បានស្តាប់ដូច្នោះទើបគិតថា លោកនេះរមែងវិនាសព្រោះការប្រកាន់ខុស បុណ្ណកយក្ខ កាលប្រាថ្នានាគមាណវិកា សម្លាប់អញដោយប្រយោជន៍អ្វី អញនឹងសួរឲ្យដឹងហេតុនោះឲ្យជាក់ច្បាស់ជាមុនសិនទើបពោលគាថានេះថា

ម្នាលយក្សសេចក្តីវង្វេងកុំមានដល់អ្នកឡើយ ពួកសត្វលោក
ជាច្រើនវិនាសហើយ ព្រោះអំពើដែលខ្ជួនប្រកាន់ខុស ចុះអ្នក
មានកិច្ចអ្វីដោយការសម្លាប់ខ្ញុំ ( ព្រោះនាគកញ្ញា ) មានចង្កេះល្អ
ជាទីស្រឡាញ់ សូមអញ្ជើញប្រាប់ ខ្ញុំនឹងស្តាប់ការទាំងអស់

មើល ដូច្នេះ ។

លំដាប់នោះបុណ្ណកយក្ខកាលប្រាប់ដល់ព្រះមហាសត្វទើបពោលថា ខ្ញុំចង់បានធីតារបស់ព្រះបាទវរុណនាគជាធំ មានអានុភាពច្រើន ខ្ញុំជាអ្នកស៊ីឈ្នួលរបស់ពួកញាតិ ព្រោះហេតុពួកញាតិដឹងនូវខ្ញុំថាជាអ្នកត្រូវកាមទង់ទាញដោយពិត ( បានជា ) ឪពុកក្មេកខ្ញុំពោលនឹងខ្ញុំដែលសូមនាងឥរន្ទតីនោះថា យើងនឹងឲ្យកូនក្រមុំមានរាងកាយល្អ មានភ្នែកល្អ មានទ្រង់ទ្រាយតើតឆាយ មានខ្លួនលាបដោយខ្លឹមចន្ទន៍ដល់អ្នក បើអ្នកបានដួងហឫទ័យរបស់វិធុរបណ្ឌិតមកដោយធម៌ ហើយនាំមកក្នុងភពនាគនេះ ។ អ្នកត្រូវបាននាងកុមារីដោយទ្រព្យជាទីត្រេកអរនុ៎ះ យើងមិនប្រាថ្នាទ្រព្យដទៃក្រៃលែងទេ ម្នាលបណ្ឌិតជាអាមាត្យ ខ្ញុំមិនវង្វេងដូចអ្នកថាទេ អ្នកចូរស្តាប់ចុះ ។ មួយទៀតអំពើតិចតួចដែលខ្ញុំប្រកាន់ខុសមិនមានទេ កាលខ្ញុំបានហឫទ័យរបស់អ្នកដោយធម៌ ពួកនាគនឹងឲ្យនាគកញ្ញាឈ្មោះឥរន្ទតី ។ ព្រោះហេតុនោះទើបខ្ញុំលៃលកសម្លាប់អ្នក ខ្ញុំមានសេចក្តីត្រូវការដោយការសម្លាប់អ្នកយ៉ាងនេះឯង ខ្ញុំនឹងទម្លាក់អ្នកក្នុងរណ្តៅនេះសម្លាប់អ្នកហើយនឹងនាំយកតែហឫទ័យទៅ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ធីតុកាមោ** សេចក្តីថា ខ្ញុំចង់បាន គឺប្រាថ្នាកូនស្រីទើបត្រាច់ទៅដើម្បីធីតា ។ បទថា **ញាតិភតោហមស្មិ** សេចក្តីថា

ខ្ញុំជាអ្នកទទួលយកអាសាពួកញាតិរបស់នាងឥរន្ទតីនោះមក ។ បទថា **តំ** ប្រែថា នូវនាគមាណវិកានោះ ។ បទថា **យាចមានំ** បានដល់ នឹងខ្ញុំដែលជាអ្នកសូម ។ បទថា **យថា មំ** សេចក្តីថា ព្រោះហេតុនោះវរុណនាគរាជក៏បានត្រាស់នឹងខ្ញុំដែលជាអ្នកទូលសូម ។ បទថា **អញ្ញឹសុ** សេចក្តីថា ញាតិទាំងឡាយដឹងហើយ ។ បទថា **សុកាមនីតំ** សេចក្តីថា ញាតិទាំងនោះបានសម្គាល់ គឺដឹងថា ខ្ញុំត្រូវសេចក្តីស្រឡាញ់នាំទៅដោយល្អ គឺដោយចំណែកមួយ ព្រោះហេតុនោះ វរុណនាគរាជដែលជាបិតាក៏បានប្រាប់ខ្ញុំដែលទៅសូមនាងឥរន្ទតីនាគកញ្ញានោះថា យើងទាំងឡាយគប្បីឲ្យកូនស្រីដល់អ្នកជាដើម ។ បណ្តាបទទាំងនោះ បទថា **ឧជ្ជេមុ** បានដល់ យើងទាំងឡាយគប្បីឲ្យ ។ បទថា **សុតនុំ** បានដល់ មានរូបដ៏ស្អាត ។ បទថា **ឥធ មាហរេសិ** សេចក្តីថា អ្នកគប្បីនាំមកក្នុងនាគពិភពនេះ ។

ព្រះមហាសត្វបានស្តាប់ពាក្យបុណ្ណកយក្ខនោះគិតថា ព្រះនាងវិមលាមិនមែនត្រូវការបេះដូងរបស់អញឡើយ តែព្រះបាទវរុណនាគរាជស្តាប់ធម្មកថារបស់អញកើតសេចក្តីជ្រះថ្លា យកកែវមណីបូជាអញ ត្រឡប់ទៅដល់នាគពិភពនោះហើយនឹងពណ៌នាភាពដែលអញជាធម្មកថិកដល់ព្រះនាងពិត កាលបើដូច្នោះការប្រាថ្នាដោយធម្មកថារបស់អញ នឹងកើតឡើងដល់ព្រះនាងវិមលាស្តេចវរុណនាគរាជ ក៏នឹងកាន់យកខុស ទើបបង្គាប់បុណ្ណកយក្ខឲ្យកាន់យកខុសទៅតាមទ្រង់ មកសម្លាប់អញឲ្យស្លាប់ ភាវៈដែលអញជាបណ្ឌិតបានធ្វើអញឲ្យបានទទួលទុក្ខដល់ម្ល៉េះ ភាពដែលអញជាអ្នកអាច ក្នុងការត្រិះរិះរកនិក្ខេប

ហេតុនិង ( ហេតុ ) កើតឡើងបាននោះបើបុណ្ណកយក្ខសម្លាប់អញឲ្យស្លាប់ ហើយនឹងធ្វើប្រយោជន៍អ្វីបាន ណ្ហើយចុះ អញនឹងជាស់តឿនមាណពនោះឲ្យដឹងខ្លួន ដូច្នេះហើយពោលថា នែមាណព ខ្ញុំដឹងសាធុនរធម៌ក្នុងខណៈដែលខ្ញុំមិនទាន់ស្លាប់ ចូរអ្នកញ៉ាំងខ្ញុំឲ្យអង្គុយលើកំពូលភ្នំហើយតាំងចិត្តស្តាប់សាធុនរធម៌សិន គប្បីធ្វើកិច្ចដែលអ្នកប្រាថ្នានឹងធ្វើក្នុងកាលជាក្រោយ ហើយគិតថា អញគប្បីពណ៌នាសាធុនរធម៌ ញ៉ាំងបុណ្ណកយក្ខឲ្យប្រគល់ជីវិតដល់អញ ព្រះមហាសត្វមានក្បាលសំយុងចុះយ៉ាងនោះឯងពោលគាថានេះថា

ម្នាលកច្ចាយនៈ បើអ្នកមានកិច្ចត្រូវការដោយហឫទ័យរបស់ខ្ញុំ
ចូរអ្នកលើកខ្ញុំដោយឆាប់រហ័ស ដ្បិតសាធុនរធម៌ ( ធម៌ល្អ
របស់នរៈ ) របស់ខ្ញុំណាមួយ ខ្ញុំនឹងសំដែងសាធុនរធម៌ទាំង
អស់នោះដល់អ្នកក្នុងថ្ងៃនេះ ដូច្នេះ ។

បុណ្ណកយក្ខបានស្តាប់ដូច្នោះត្រិះរិះថា បានឮថា ធម៌នេះជាធម៌ដែលបណ្ឌិតមិនធ្លាប់សម្តែងដល់ទេវតានិងមនុស្សទាំងឡាយ ណ្ហើយចុះយើងនឹងលើកបណ្ឌិតនេះឡើងស្តាប់សាធុនរធម៌ជាមុនសិន ដូច្នេះហើយទើបលើកព្រះមហាសត្វឡើងឲ្យអង្គុយលើកំពូលភ្នំ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសានូវព្រះគាថាដូច្នេះថា

បុណ្ណកយក្សនោះដាក់វិធុរបណ្ឌិត ជាអាមាត្យដ៏ប្រសើររបស់

អ្នកដែនកុរុលើកំពូលភ្នំដាច់រហ័ស ឃើញវិធុរបណ្ឌិតជាអាមាត្យមានប្រាជ្ញាមិនថោកទាប អន្ទ្រយដកដង្ហើមស្រួលហើយ ក៏សាកសួរថា អ្នកគឺខ្ញុំលើកឡើងចាករណ្ដៅហើយ ក្នុងថ្ងៃនេះ ខ្ញុំត្រូវការដោយហឫទ័យរបស់អ្នក អ្នកចូរសំដែងសាធុនរធម៌ទាំងអស់នោះដល់ខ្ញុំក្នុងថ្ងៃនេះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អស្សត្ថមាសីនំ** បានដល់ ជាអ្នកបាននូវការដកដង្ហើមស្រួល ។ បទថា **សមេក្ខិយាន** បានដល់ ឃើញហើយ ។ បទថា **សាធុ នរស្ស ធម្មា** បានដល់ ធម៌ល្អរបស់នរជន គឺធម៌ស្អាត ។ ព្រះមហាសត្វពោលថា

ខ្ញុំគឺអ្នកលើកឡើងចាករណ្ដៅហើយ បើអ្នកត្រូវការដោយហឫទ័យរបស់ខ្ញុំ ខ្ញុំនឹងសំដែងសាធុនរធម៌ទាំងអស់នោះដល់អ្នកក្នុងថ្ងៃនេះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សមុទ្ធតោ ត្យស្មិ** សេចក្ដីថា ខ្ញុំដែលអ្នកលើកឡើងហើយ ។

លំដាប់នោះព្រះមហាសត្វពោលនឹងបុណ្ណកយក្ខនោះថា ខ្ញុំជាអ្នកមានសរីរៈសៅហ្មង នឹងសូមងូតទឹកជម្រះកាយជាមុនសិន បុណ្ណកយក្ខទទួលថា សាធុ ហើយនាំទឹកសម្រាប់ងូតមក ក្នុងកាលព្រះមហាសត្វងូតទឹកស្រេចបាន ឲ្យសំពត់ទិព្វ គ្រឿងក្រអូប និងផ្កាទិព្វជាដើមដល់ព្រះមហាសត្វ ក្នុងវេលាគាត់តែងស្រេចហើយបានឲ្យភោជនាហារដ៏ជាទិព្វ ដល់ព្រះមហាសត្វ ។ ព្រះ

មហាសត្វ បរិភោគភោជនាហារស្រេចហើយ ឲ្យប្រដាប់កំពូលភ្នំកាឡគិរីនិង តាក់តែងអាសនៈហើយទើបអង្គុយលើអាសនៈ ដែលបុណ្ណកយក្ខប្រដាប់ហើយ កាលនឹងសម្ដែងសាធុនរធម៌ ទើបពោលគាថាដោយពុទ្ធលីលាថា

ម្នាលមាណព អ្នកចូរដើរតាមផ្លូវដែលគេដើរហើយ អ្នកចូរវៀរ គឺកុំជុតបាតដៃទាំងទទឹក អ្នកកុំប្រទូស្តមិត្តក្នុងកាលណាមួយ អ្នកកុំលុះអំណាចនៃស្រី ដែលប្រកបដោយអសទ្ធម្ម ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អល្លញ្ច បាណឹ បរិវជ្ជយស្សុ** សេចក្ដីថា ចូរអ្នកកុំជុតបាតដៃទាំងទទឹក គឺកុំធ្វើបាតដៃដែលសើមឲ្យឆេះ ។

បុណ្ណកយក្ខមិនអាចឈមចុះកាន់សាធុនរធម៌ ៤ ប្រការដែលមហាសត្វសម្ដែងដោយសង្ខេបបានទើបសួរដោយសេចក្ដីពិស្ដារថា

បុគ្គលដែលឈ្មោះថា ដើរទៅកាន់ផ្លូវដែលគេដើរហើយ តើដូចម្ដេច គេជុតបាតដៃទាំងទទឹកតើដូចម្ដេច ស្រីដូចម្ដេចឈ្មោះថាស្រីប្រកបដោយអសទ្ធម្ម នរណាឈ្មោះថា ជាអ្នកប្រទូស្តមិត្ត ខ្ញុំសួរហើយអ្នកចូរប្រាប់សេចក្ដីនុ៎ះ ដូច្នេះ ។

ឯព្រះមហាសត្វបានសម្ដែងសាធុនរធម៌ដល់បុណ្ណកយក្ខថា

បុគ្គលណាអញ្ជើញមនុស្សដែលមិនធ្លាប់នៅជាមួយគ្នា ឬមិនធ្លាប់ឃើញគ្នា សូម្បីដោយអាសនៈ បុរសត្រូវធ្វើប្រយោជន៍តបស្នងដល់បុគ្គលនោះឯង បណ្ឌិតទាំងឡាយពោលថា អ្នក

នោះឯងជាអ្នកដើរតាមផ្លូវដែលគេដើរហើយ ។ បុរសស្នាក់នៅ
ក្នុងផ្ទះរបស់បុគ្គលណា សូម្បីមួយយប់ បានបាយនិងទឹកក្នុង
សំណាក់បុគ្គលណា មិនត្រូវគិតអំពើអាក្រក់ ដល់បុគ្គលនោះ
សូម្បីដោយចិត្ត បុគ្គលអ្នកប្រទូស្តមិត្តឈ្មោះថា ដុតបាតដៃទាំង
ទទឹក ។ បុគ្គលអង្គុយឬដេកក្នុងម្លប់ឈើណា មិនត្រូវកាប់មែក
ឈើនោះព្រោះថា បុគ្គលប្រទូស្តមិត្តជាបុគ្គលអាក្រក់ ។ បុរស
ណាឲ្យផែនដីនេះដែលពេញដោយទ្រព្យដល់ស្រីដែលខ្លួនសន្មត
ថា ( ល្អ ) ស្រីនោះបានឱកាស ( ក្បត់ចិត្ត ) គប្បីមើលងាយ
បុរសនោះវិញ បុគ្គលមិនត្រូវលុះអំណាចស្រី ដែលប្រកប
ដោយអសទ្ធម្មនោះទេ ។ បុគ្គលឈ្មោះថាដើរទៅកាន់ផ្លូវដែល
គេដើរហើយយ៉ាងនេះ ឈ្មោះថាដុតបាតដៃទាំងទទឹក យ៉ាងនេះ
ស្រីនោះឈ្មោះថា ប្រកបដោយអសទ្ធម្ម បុរសនោះឈ្មោះថា
ជាអ្នកប្រទូស្តមិត្ត អ្នកចូរជាអ្នកប្រកបដោយធម៌ ចូរលះបង់
អំពើមិនមែនធម៌ចេញ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អសន្ថុតំ** សេចក្តីថា មិនធ្លាប់នៅរួមជាមួយ សូម្បីត្រឹមតែមួយថ្ងៃ ឬពីរថ្ងៃ ។ បទថា **យោ អាសនេនាបិ** សេចក្តីថា បុគ្គលណាមិនអញ្ជើញបុគ្គលមិនស្និទ្ធស្នាលបែបនេះដោយអាសនៈ នឹងពោល ថ្វីដល់ការអញ្ជើញដោយបាយនិងទឹកនោះ ។ បទថា **តស្សេវ** សេចក្តីថា ជាបុរសរមែងធ្វើប្រយោជន៍តបស្នងដល់បុព្វការីបុគ្គលនោះដោយពិត ។ បទថា

**យាតានុយាយិ** *សេចក្តីថា បណ្ឌិតទាំងឡាយ រមែងពោលយ៉ាងនេះថាជាបុគ្គលដើរតាមផ្លូវដែលបុព្វការីដើរទៅហើយ បុគ្គលធ្វើមុនឈ្មោះថា អ្នកធ្វើដំណើរ ឯអ្នកធ្វើក្រោយឈ្មោះថា អ្នកដើរតាម បពិត្រទេវរាជ នេះឈ្មោះថា សាធុនរធម៌ទី ១ ។ បទថា* **អល្លញ្ច បាណឹ** *សេចក្តីថា ពិតហើយបុគ្គលដុតបាតដៃ ដែលជាគ្រឿងប្រើប្រាស់របស់ខ្លួន ដែលនាំភត្តាហារមកពីចម្ងាយ ឈ្មោះថាជាអ្នកទ្រុស្តមិត្ត ការមិនដុតបាតដៃដែលទទឹកនេះឈ្មោះថា សាធុនរធម៌ទី ២ ដោយប្រការដូច្នេះ ។ បទថា* **ន តស្ស** *សេចក្តីថា មិនគប្បីបំផ្លាញមែក ស្លឹក ពន្លកនៃដើមឈើនោះ ព្រោះហេតុអ្វី ព្រោះបុគ្គលទ្រុស្តមិត្តជាបុគ្គលលាមកដូច្នោះ បុគ្គលធ្វើអាក្រក់សូម្បីចំពោះដើមឈើដែលមិនមានចេតនាដែលបានប្រើប្រាស់និងអាស្រ័យម្លប់ ឈ្មោះថាជាអ្នកប្រទូស្តចំពោះមិត្ត នឹងពោលទៅថ្វីដល់បុគ្គលធ្វើអាក្រក់ចំពោះមនុស្ស ។ ការមិនប្រទូស្តចំពោះមិត្តយ៉ាងនេះ ឈ្មោះថា សាធុនរធម៌ទី ៣ ។ បទថា* **ទជ្ជិ-ត្ថិយា** *សេចក្តីថា គប្បីឲ្យដល់ស្រី ។ បទថា* **សម្មតាយ** *សេចក្តីថា ស្រីដែលប្តីលើកតម្កើងដោយល្អយ៉ាងនេះថា អញប៉ុណ្ណោះនឹងឲ្យសេចក្តីសុខដល់ស្រីនេះបុរសដទៃមិនដូចអញឡើយ ស្រីនោះរមែងប្រាថ្នាតែអញប៉ុណ្ណោះ ។ បទថា* **លទ្ធា ខណំ** *សេចក្តីថា បានឱកាសនៃការប្រព្រឹត្តកន្លង ។ បទថា* **អសតីនំ** *បានដល់ ស្រីដែលប្រកបដោយអសទ្ធម្ម ។ ដូច្នោះការមិនធ្វើអំពើអាក្រក់ព្រោះអាស្រ័យមាតុគ្រាម នេះឈ្មោះថា សាធុនរធម៌ទី ៤ ។ បទថា* **សោ ធម្មិកោ ហោហិ** *សេចក្តីថា បពិត្រទេវរាជ លោកជាអ្នកប្រកបដោយ*

សាធុនរធម៌ ៤ នេះ ឈ្មោះថាជាអ្នកតាំងនៅក្នុងធម៌នោះឯង ។

ព្រះមហាសត្វសម្តែងសាធុនរធម៌ដល់បុណ្ណកយក្ខដោយពុទ្ធលីលាដោយប្រការដូច្នេះ បុណ្ណកយក្ខកាលស្តាប់សាធុនរធម៌ ៤ ប្រការនោះហើយកំណត់ក្នុងចិត្តថា បណ្ឌិតសូមនូវជីវិតរបស់ខ្លួនក្នុងទី ៤ ស្ថាន បណ្ឌិតនេះបានធ្វើសក្ការៈដល់អញដែលខ្លួនមិនធ្លាប់ស្និទ្ធ អញបានសោយនូវយសធំក្នុងផ្ទះរបស់បណ្ឌិតនោះអស់ ៣ ថ្ងៃ តែកាលអញធ្វើកម្មអាក្រក់បែបនេះក៏ព្រោះអាស្រ័យមាតុគ្រាមទើបធ្វើ បើអញប្រទូស្តចំពោះបណ្ឌិត ឈ្មោះថាប្រទូស្តមិត្ត ក្នុងទីគ្រប់អន្ទើនោះឯង ឈ្មោះថា មិនប្រព្រឹត្តតាមសាធុនរធម៌ ប្រយោជន៍អ្វីដោយនាគមាណវិកា អញនឹងជូតមុខដែលពេញដោយទឹកភ្នែក របស់អ្នកឥន្ទបត្តនគរឲ្យមានមុខស្រស់ស្រាយ នាំបណ្ឌិតនេះទៅដោយរហ័ស ឲ្យចុះត្រង់ធម្មសភា ត្រិះរិះដូច្នេះហើយទើបពោលគាថានេះថា

ខ្ញុំបាននៅអាស្រ័យក្នុងផ្ទះរបស់អ្នកអស់ ៣ ថ្ងៃ ដែលអ្នកបាន
ទំនុកបម្រុងខ្ញុំដោយបាយនិងទឹក អ្នកសូមជាមិត្តរបស់ខ្ញុំ ទាំងខ្ញុំ
ក៏លែងអ្នកដែរ ម្នាលបណ្ឌិតមានប្រាជ្ញាខ្ពង់ខ្ពស់ ចូរអ្នកអញ្ជើញ
ទៅកាន់ផ្ទះរបស់អ្នកតាមប្រាថ្នាចុះ ។ ទាំងសេចក្តីត្រូវការរបស់
ត្រកូលនាគក៏សាបសូន្យទៅចុះ អំពើព្រោះហេតុនៃនាងនាគកញ្ញា
ក៏ល្មមដល់ខ្ញុំហើយ ម្នាលអ្នកមានប្រាជ្ញា អ្នកបានរួចចាកការ
សម្លាប់របស់ខ្ញុំក្នុងថ្ងៃនេះព្រោះសុភាសិតជារបស់ខ្លួន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧបដ្ឋិតោស្មិ** សេចក្តីថា ខ្ញុំជាបុគ្គលដែល

អ្នកទំនុកបម្រុងហើយ ។ បទថា **វិសជ្ជាមហំ តំ** សេចក្តីថា ខ្ញុំនឹងលែងអ្នកទៅ ។ បទថា **ភាគំ** បានដល់ ដោយចំណែកមួយ ។ បទថា **វធាយ** បានដល់ ដែលនឹងត្រូវសម្លាប់ ។ បទថា **បញ្ហ** ប្រែថា បពិត្រលោកអ្នកមានបញ្ហា ។

លំដាប់នោះព្រះមហាសត្វពោលនឹងបុណ្ណកយក្ខនោះថា នែមាណព អ្នកកុំរវើរវាយបញ្ជូនខ្ញុំទៅផ្ទះឡើយ ចូរនាំខ្ញុំទៅកាន់កពនាគចុះ ទើបពោលគាថាដូច្នេះថា

ម្នាលយក្ស ណ្ហើយ អ្នកចូរនាំខ្ញុំទៅកាន់សំណាក់ឪពុកក្មេក
របស់អ្នកចុះ អ្នកចូរប្រព្រឹត្តឲ្យជាប្រយោជន៍ចំពោះខ្ញុំ ដ្បិតខ្ញុំចង់
ឃើញនាគរាជជាអធិបតីនិងវិមានរបស់នាគរាជដែលខ្ញុំមិនធ្លាប់
ឃើញ ដូច្នេះ ។

បណ្តាបទទាំងនោះ សព្ទថា **ហន្ទ** ត្រឹមតែជានិបាតប្រើក្នុងអត្ថនៃឧបសគ្គ ។ បទថា **សស្សុរំ តេ អត្ថំ មយិ ចរស្សុ** សេចក្តីថា សូមនាំទៅកាន់សម្នាក់នៃឪពុកក្មេករបស់លោក សូមប្រព្រឹត្តប្រយោជន៍ក្នុងខ្ញុំ គឺកុំធ្វើប្រយោជន៍នោះឲ្យវិនាសឡើយ ។ បទថា **នាគាធិបតីវិមានំ** សេចក្តីថា ខ្ញុំគួរឃើញស្តេចវរុណ ដែលជាអធិបតីនៃនាគនិងវិមានរបស់ទ្រង់ ដែលខ្ញុំមិនធ្លាប់ឃើញ ។

បុណ្ណកយក្ខស្តាប់ដូច្នោះក៏ពោលថា

របស់ណាដែលប្រព្រឹត្តទៅមិនជាប្រយោជន៍ដល់នរជន ជនមាន

ប្រាជ្ញា មិនគួរឃើញរបស់នោះទេ ម្នាលបណ្ឌិតមានប្រាជ្ញាខ្ពង់ខ្ពស់ កាលបើដូច្នេះអ្នកប្រាថ្នាទៅកាន់ស្រុករបស់សត្រូវដោយហេតុដូចម្តេច ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អមិត្តគាមំ** សេចក្តីថា ជាលំនៅរបស់សត្រូវ គឺសមាគមនៃអមិត្ត ។

លំដាប់នោះមហាសត្វបានពោលនឹងបុណ្ណកយក្ខនោះថា

ខ្ញុំប្រាកដជាដឹងហេតុនុ៎ះ ជនមានប្រាជ្ញា មិនគួរឃើញសត្រូវនោះទេ តែអំពើអាក្រក់ខ្ញុំមិនបានធ្វើទុកក្នុងទីណាមួយ ព្រោះហេតុនោះ ខ្ញុំមិនរង្កៀសចំពោះសេចក្តីស្លាប់ ដែលនឹងមកដល់ឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មរណាគមាយ** សេចក្តីថា ចំពោះមរណៈដែលមកដល់ខ្លួន ។ នៃទេវរាជ ម្យ៉ាងទៀតលោកជាបុគ្គលគ្រោតគ្រាត រឹងត្អឹងដល់ម៉េះ គង់ខ្ញុំលួងលោមដោយធម្មកថាធ្វើឲ្យទន់បាន ដូចលោកពោលនឹងខ្ញុំអម្បាញ់មិញនេះឯងថា ខ្ញុំមិនត្រូវការនាគមាណវិកាឡើយ សូមអ្នកត្រឡប់ទៅកាន់ផ្ទះរបស់ខ្លួនចុះ ការធ្វើស្តេចនាគឲ្យទោទន់ជាកិច្ចរបស់ខ្ញុំ អ្នកចូរនាំខ្ញុំទៅក្នុងនាគពិភពនោះ ។

បុណ្ណកយក្ខបានស្តាប់ដូច្នោះ ទទួលពាក្យរបស់មហាសត្វថា សាធុ ក៏ពោលគាថានេះថា

ម្នាលអ្នកជាអាមាត្យ បើដូច្នោះអ្នកនឹងឃើញឋាន ដែលមាន

អានុភាពប្រៀបមិនបានជាមួយនឹងខ្ញុំ អ្នកចូរមកចុះ នាគរមែង នៅដោយការរាំ និងច្រៀងក្នុងទីណា ដូចជាព្រះបាទវេស្សវណ្ណ នៅក្នុងរាជធានីឈ្មោះ និឡិញ្ញៈ ។ ទីនោះមានពួកនៃនាងនាគ កញ្ញាត្រាច់ទៅដោយពួកៗ លេងអស់ថ្ងៃនិងយប់ជានិច្ច ជាទី មានផ្កាកម្រងច្រើន ដេរដាសដោយផ្កាឈើច្រើនបែប ភ្លឺផ្លេក ដូចផ្លេកបន្ទោរពួដ៏អាកាស ។ ភពនៃនាគនោះមានភាពសម្បូណ៌ ដោយបាយនិងទឹកនិងការរាំច្រៀងប្រគំ បរិបូណ៌ដោយពួកនាង នាគកញ្ញា ដែលតាក់តែងខ្លួនដោយសំពត់និងគ្រឿងប្រដាប់ល្អ ឆើតឆាយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ហន្ទ ច** នេះ ត្រឹមតែជានិបាតប៉ុណ្ណោះ ។ បទថា **ឋានំ** បានដល់ ទីដែលជាទីប្រថាប់របស់ស្ដេចនាគ ។ បទថា **និឡិញ្ញំ** បានដល់ រាជធានីឈ្មោះថា និឡិញ្ញៈ ។ បទថា **ចរិតំ គណេន** សេចក្ដីថា ទីប្រថាប់របស់ស្ដេចនាគនោះជាទីដែលពួកនាងនាគកញ្ញាត្រាច់ទៅ ។ បទថា **និកីឡិតំ** សេចក្ដីថា ដែលពួកនាងនាគកញ្ញាលេងជាពួក អស់ថ្ងៃ និងយប់ជានិច្ច ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់បែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសានូវព្រះគាថាដូច្នេះថា

បុណ្ណកយក្សនោះបានអញ្ជើញវិធុរបណ្ឌិត ជាអាមាត្យដ៏ប្រសើរ

របស់អ្នកដែនកុរុឲ្យអង្គុយលើអាសនៈអំពីខាងក្រោយ នាំវិធុរបណ្ឌិតជាអាមាត្យមានប្រាជ្ញាមិនថោកទាប ចូលទៅកាន់ភពនៃនាគរាជ ។ វិធុរបណ្ឌិតជាអាមាត្យ លុះដល់ទីដែលមានអានុភាពប្រៀបមិនបានក៏ឈរខាងក្រោយបុណ្ណកយក្ស ចំណែកនាគរាជក្រឡេកមើល ឃើញបុណ្ណកយក្សមានសេចក្តីស្មោះសរ បានត្រាស់នឹងកូនប្រសាមុនថា ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សោ បុណ្ណកោ** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ បុណ្ណកយក្ខនោះពណ៌នានាគពិភពយ៉ាងនេះហើយ ទើបលើកបណ្ឌិតដ៏ប្រសើរដាក់លើខ្នងសេះអាជានេយ្យរបស់ខ្លួន នាំទៅកាន់នាគពិភព ។ បទថា **ឋានំ** បានដល់ ទីដែលជាទីប្រថាប់របស់ស្តេចនាគ ។ បទថា **បច្ឆតោ បុណ្ណកស្ស** សេចក្តីថា បានឮថា បុណ្ណកយក្ខមានការគិតយ៉ាងនេះថា បើស្តេចនាគទតឃើញបណ្ឌិតហើយនឹងមានព្រះទ័យទន់ភ្លន់ ទុំះជាការល្អ បើទ្រង់មិនមានព្រះទ័យទន់ភ្លន់ កាលទ្រង់មិនទាន់ឃើញបណ្ឌិតនោះ អញនឹងលើកបណ្ឌិតឡើងកាន់ខ្នងសេះអាជានេយ្យទៅ ។ លំដាប់នោះទើបដាក់ឲ្យនៅអំពីខាងក្រោយ ។ ដោយហេតុនោះទើបលោកពោលថា ក៏ឈរខាងក្រោយបុណ្ណកយក្សដូច្នេះ ។ បទថា **សាមគ្គិបេក្ខី** សេចក្តីថា សម្លឹងដល់ការសាមគ្គី ។ បាលីថា **សាមំ អបេក្ខិ** ដូច្នេះក៏មាន ។ អធិប្បាយថា ស្តេចនាគទតឃើញបុណ្ណកយក្ខកូនប្រសារបស់ខ្លួនទើបត្រាស់រាក់ទាក់មុននោះឯងដោយព្រះគាថាដូច្នេះថា

អ្នកកាលស្វែងរកហឫទ័យរបស់បណ្ឌិត បានទៅកាន់មនុស្ស
លោកហើយនាំអាមាត្យមាន ប្រាជ្ញាមិនថោកទាបមកដល់ក្នុងទី
នេះដោយសួស្តីហើយឬ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កច្ចិ សមិទ្ធេន** សេចក្តីថា ស្តេចនាគត្រាស់សួរថា អ្នកបានទៅកាន់មនុស្សលោក ហើយត្រឡប់មកកាន់ពិភពនាគនេះដោយមនោរថរបស់អ្នកដែលសម្រេចហើយឬ ។

បុណ្ណកយក្ខក៏ទូលថា

ព្រះអង្គប្រាថ្នាបណ្ឌិតណា បណ្ឌិតនោះមកដល់ហើយ បណ្ឌិត
អ្នករក្សាធម៌ គឺខ្ញុំព្រះអង្គរកបានមកដោយធម៌ហើយ សូមព្រះ
អង្គទ្រង់ទតបណ្ឌិតនោះដែលកំពុងនិយាយក្នុងទីចំពោះព្រះភក្ត្រ
នៃព្រះអង្គ ការជួបជុំដោយសប្បុរសទាំងឡាយ ជាហេតុនាំ
មកនូវសេចក្តីសុខដោយពិត ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យំ ត្វមិច្ឆសិ** កាត់បទជា **យំ ត្វំ ឥច្ឆសិ** ។ បាលីថា **យន្តុ មិច្ឆសិ** ដូច្នេះក៏មាន ។ បទថា **ភាសមានំ** សេចក្តីថា សូមទ្រង់ទតវិធុរបណ្ឌិតនោះ ដែលជាអ្នករក្សាធម៌ប្រាកដក្នុងលោកដែល ជាអ្នកសម្តែងធម៌ដោយសំឡេងដ៏ពីរោះ ចំពោះព្រះភក្ត្រក្នុងកាលឥឡូវនេះ ធម្មតាការជួបសប្បុរសទាំងឡាយក្នុងទីជាមួយគ្នា រមែងជាហេតុនាំសុខមកឲ្យ ។

**កាឡាគិរិកណ្ឌ ចប់**

ស្តេចនាគទតឃើញព្រះមហាសត្វហើយ ត្រាស់ព្រះគាថានេះថា

អ្នកជាមនុស្សមានមច្ចុភ័យគ្របសង្កត់ តក់ស្លុតព្រោះឃើញកព
នាគដែលខ្លួនមិនធ្លាប់ឃើញទើបមិនថ្វាយបង្គំ ( ខ្ញុំ ) ដំណើរ
នេះមិនមែនជាបុគ្គលមានប្រាជ្ញាទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឰម្ភិតោ** បានដល់ ត្រូវសេចក្តីខ្លាចគំរាម ។ លោកអធិប្បាយទុកថា នែបណ្ឌិត អ្នកឃើញនាគពិកពដែលខ្លួនមិនធ្លាប់ឃើញ ជាអ្នកត្រូវភ័យ គឺការស្លាប់គំរាមហើយ ទើបមិនថ្វាយបង្គំខ្ញុំ ហេតុនេះមិនមែនអាការរបស់បុគ្គលដែលមានប្រាជ្ញាឡើយ ។

កាលស្តេចនាគទ្រង់បំណាំងឲ្យថ្វាយបង្គំយ៉ាងនេះមហាសត្វមិនទូលត្រង់ៗថា ខ្ញុំមិនគួរថ្វាយបង្គំទ្រង់ដូច្នេះឡើយព្រោះជាអ្នកឈ្លាសក្នុងឧបាយទូលដោយប្រាជ្ញារបស់ខ្លួនថា ខ្ញុំមិនថ្វាយបង្គំទ្រង់ព្រោះខ្ញុំត្រូវសម្លាប់ ដូច្នេះហើយទើបទូលដោយគាថា ២ ថា

បពិត្រនាគ ខ្ញុំព្រះអង្គមិនមែនជាអ្នកតក់ស្លុតទេ មិនមានមច្ចុភ័យ
គ្របសង្កត់ទេ ព្រោះអ្នកទោសដែលត្រូវគេសម្លាប់ មិនគប្បី
ថ្វាយបង្គំ ( នូវពេជ្ឈឃាត ) ឬពេជ្ឈឃាត ក៏មិនគប្បីថ្វាយបង្គំ
អ្នកទោសដែលត្រូវគេសម្លាប់ដែរ ។ ជនប្រាថ្នាសម្លាប់អ្នកណា
គប្បីថ្វាយបង្គំ ( អ្នកនោះ ) ឬឲ្យ ( អ្នកនោះ ) ថ្វាយបង្គំ ( ខ្លួន )
ដូចម្តេចកើត កម្មនោះមិនសម្រេចទៅជាអ្វីទេ ដូច្នេះ ។

ពាក្យដែលជាគាថានោះ មានអធិប្បាយថា បពិត្រស្តេចនាគ ខ្ញុំមកឃើញ

នាគពិភពដែលខ្លួនមិនធ្លាប់ឃើញរមែងមិនខ្លាច ភ័យ គឺការស្លាប់គំរាមមិនបាន ទេព្រោះឈ្មោះថា ភ័យ គឺសេចក្ដីស្លាប់រមែងមិនមានដល់បុគ្គលដូចខ្ញុំម្យ៉ាង ទៀតអ្នកទោសដែលត្រូវសម្លាប់ មិនគប្បីថ្វាយបង្គំពេជ្ឈឃាតដែលសម្លាប់ខ្លួន ឬពេជ្ឈឃាតមិនគប្បីញ៉ាំងអ្នកទោសដែលនឹងត្រូវសម្លាប់ឲ្យថ្វាយបង្គំខ្លួន នរជន គប្បីថ្វាយបង្គំបុគ្គលដែលប្រាថ្នានឹងសម្លាប់ខ្លួនបានដូចម្ដេចហ្ន៎ ឬបុគ្គលប្រាថ្នានឹង សម្លាប់គេគប្បីញ៉ាំងបុគ្គលដែលខ្លួននឹងសម្លាប់ ឲ្យថ្វាយបង្គំខ្លួនដូចម្ដេច ព្រោះ កម្ម គឺការថ្វាយបង្គំរបស់បុគ្គលត្រូវសម្លាប់និងការឲ្យថ្វាយបង្គំនៃបុគ្គល ដែល នឹងសម្លាប់នោះ រមែងមិនសម្រេចប្រយោជន៍ដល់គេឡើយ ទូលបង្គំបានជ្រាប ហើយថា ទ្រង់ត្រាស់ឲ្យគេសម្លាប់ខ្ញុំក្នុងទីនេះ ហេតុនោះខ្ញុំនឹងថ្វាយបង្គំទ្រង់ដូច ម្ដេចកើត ។

ស្ដេចនាគ ទ្រង់ស្ដាប់ដូច្នោះ ទ្រង់ពេញព្រះហឫទ័យ កាលទ្រង់ធ្វើនូវការ សរសើរព្រះមហាសត្វទ្រង់បានភាសិតគាថា ២ ថា

ម្នាលបណ្ឌិត ដំណើរនុ៎ះដូចអ្នកពោលមែន អ្នកពោលពាក្យ
ពិត អ្នកទោសដែលត្រូវគេសម្លាប់មិនគប្បីថ្វាយបង្គំពេជ្ឈឃាត
ឬពេជ្ឈឃាតក៏មិនគប្បីថ្វាយបង្គំអ្នកទោសដែលត្រូវគេសម្លាប់
ដែរ ។ នរជនប្រាថ្នាសម្លាប់អ្នកណាគប្បីថ្វាយបង្គំ ( អ្នកនោះ )
ឬឲ្យ ( អ្នកនោះ ) ថ្វាយបង្គំ ( ខ្លួន ) ដូចម្ដេចកើត កម្មនោះ
មិនកើតទៅជាអ្វីទេ ដូច្នេះ ។

ឥឡូវនេះព្រះមហាសត្វកាលធ្វើបដិសណ្ឋារៈជាមួយស្ដេចនាគ ទើបទូល

ថា

វិមាននេះទាំងឫទ្ធិ សេចក្តីរុងរឿង កម្លាំងកាយ សេចក្តីព្យាយាម និងការកើត ( ក្នុងភពនាគ ) របស់ព្រះអង្គមិនទៀង តែដូចជារបស់ទៀង បពិត្រនាគរាជ ខ្ញុំព្រះអង្គសូមសួរសេចក្តីនុ៎ះនឹងព្រះអង្គថា វិមាននេះព្រះអង្គបានហើយដោយប្រការដូចម្តេច ។ វិមាននេះព្រះអង្គបានព្រោះអាស្រ័យ ( ភពនាគ ) ឬកើតអំពីរដូវប្រែប្រួល ឬព្រះអង្គកសាងដោយព្រះអង្គឯង ឬមួយទេវតាថ្វាយ បពិត្រនាគរាជ វិមាននេះព្រះអង្គបានហើយដោយប្រការណា សូមព្រះអង្គប្រាប់សេចក្តីនុ៎ះ ដល់ខ្ញុំព្រះអង្គដោយប្រការដូច្នោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តវយិទំ** សេចក្តីថា វិមានដែលកើតអំពីយស សម្រាប់ជាព្រះកិត្តិយសរបស់ព្រះរាជាអង្គនេះ ដែលជារបស់មិនទៀង តែប្រាកដដូចរបស់ទៀង ទ្រង់កុំធ្វើសេចក្តីអាក្រក់ព្រោះអាស្រ័យយសឡើយ ព្រោះដូច្នោះដោយបទនេះ ទើបព្រះមហាសត្វសូមជីវិតរបស់ខ្លួនទុក ។ បទថា **ឥទ្ធិ** សេចក្តីថា ឫទ្ធិរបស់នាគក្តី ការរុងរឿងនៃនាគក្តី កម្លាំងកាយក្តី ការព្យាយាមដែលប្រព្រឹត្តទៅផ្លូវចិត្តក្តី ការដែលទ្រង់កើតឡើង ក្នុងនាគពិភពក្តី មានដល់ទ្រង់គ្រប់យ៉ាង ខ្ញុំសូមទូលសួរសេចក្តីនោះ បពិត្រស្តេចនាគ ខ្ញុំសូមទូលសួរសេចក្តីនោះនឹងទ្រង់ វិមាននេះទ្រង់បានមកដូចម្តេចហ្ន៎ វិមាននេះគឺនាគពិភពដែលបរិបូណ៌យ៉ាងនេះទ្រង់បានដោយមិនមានហេតុឬហ្ន៎ ឬជារបស់

កើតឡើងតាមរដូវកាល ឬទ្រង់ធ្វើដោយដៃឯង ឬទេវតាទាំងឡាយឲ្យទ្រង់ បពិត្រស្ដេចនាគជាម្ចាស់បាតដាល វិមាននេះទ្រង់បានដោយប្រការណា សូមទ្រង់ត្រាស់ប្រាប់សេចក្ដីនោះដល់ខ្ញុំដោយប្រការដូច្នេះ ។ ស្ដេចនាគស្ដាប់ហើយ ត្រាស់តបថា

វិមាន ( នេះ ) មិនមែនខ្ញុំបានព្រោះអាស្រ័យ ( ភពនាគ )
មិនមែនកើតអំពីរដូវប្រែប្រួល មិនមែនខ្ញុំធ្វើខ្លួនឯង ទាំងមិន
មែនទេវតាឲ្យទេ វិមាននេះខ្ញុំបានដោយបុញ្ញកម្ម មិនអាក្រក់
របស់ខ្លួន ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អបាបកេហិ** បានដល់ មិនថោកថយ ។ ព្រះមហាសត្វស្ដាប់ដូច្នោះក៏ទូលសួរថា

អ្វីជាវត្តរបស់ព្រះអង្គ អ្វីជាព្រហ្មចរិយៈរបស់ព្រះអង្គ បពិត្រ
នាគ ឫទ្ធិ សេចក្ដីរុងរឿង កម្លាំងកាយ សេចក្ដីព្យាយាមនិង
ការកើត ( ក្នុងភពនាគ ) ទាំងវិមានធំរបស់ព្រះអង្គនេះ នេះ
ជាផលនៃកម្មដែលព្រះអង្គសន្សំល្អហើយដូចម្ដេច ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **កិន្តេ វតំ** សេចក្ដីថា បពិត្រស្ដេចនាគ ក្នុងភពមុន អ្វីជាវត្តរបស់ទ្រង់ ម្យ៉ាងទៀតអ្វីជាការនៅប្រព្រឹត្តព្រហ្មចរិយៈរបស់ទ្រង់ ឥដ្ឋវិបុលផលមានភាពជាអ្នកមានឫទ្ធិជាដើមនេះ ជាវិបាកសុចរិតដូចម្ដេច ។

ស្ដេចនាគត្រាស់គាថាថា

ខ្ញុំនិងកិរិយាទាំងពីរនាក់ ( កាលនៅ ) ក្នុងមនុស្សលោក ជាអ្នកមានសទ្ធា ជាម្ចាស់នៃទាន ក្នុងកាលនោះផ្ទះរបស់ខ្ញុំដូចជាអណ្តូង ( នៃមហាជន ) ទាំងពួកសមណៈនិងព្រាហ្មណ៍ ខ្ញុំក៏បានឲ្យឆ្អែតស្កប់ស្កល់ ខ្ញុំ ( កាលនៅ ) ក្នុងកាលចម្បានគរនោះ បានឲ្យទានដោយគោរព គឺឲ្យកម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប គ្រឿងប្រទីប ទីដេក ទីសំណាក់អាស្រ័យ សំពត់សម្រាប់ស្លៀកដណ្តប់ កម្រាលដេក បាយ ទឹក ។ នោះជាវត្តនោះជាព្រហ្មចរិយៈរបស់ខ្ញុំ នៃអ្នកប្រាជ្ញ ឯឫទ្ធិសេចក្តីរុងរឿងកម្លាំងកាយ សេចក្តីព្យាយាមនិងការកើត ( ក្នុងកពនាគ ) ទាំងវិមានធំរបស់ខ្ញុំនេះ នេះជាផលនៃកម្មដែលខ្ញុំសន្សំល្អហើយនោះដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មនុស្សលោកេ** បានដល់ ក្នុងកាលចម្បានគរដែនអង្គៈ ។ បទថា **តំ មេ វតំ** សេចក្តីថា ទានដែលខ្ញុំឲ្យដោយគោរពនោះឯងជាការសមាទានវត្តនិងព្រហ្មចរិយៈនៃយើង ឥដ្ឋវិបុលផល មានឫទ្ធិជាដើមនេះជាវិបាកនៃសុចរិតដែលខ្ញុំប្រព្រឹត្តល្អហើយនោះ ។ ព្រះមហាសត្វបានស្តាប់ហើយទូលសួរថា

បើវិមាននេះព្រះអង្គបានហើយយ៉ាងនេះឈ្មោះថា ព្រះអង្គជ្រាបកំណើតនៃផលរបស់បុណ្យ ព្រោះហេតុនោះព្រះអង្គកុំប្រហែសសូមប្រព្រឹត្តធម៌ ជាហេតុឲ្យគ្រប់គ្រងវិមាននេះតទៅទៀត

ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ជាធាសិ** សេចក្ដីថា បើវិមាននោះព្រះអង្គទ្រង់បានដោយអានុភាពនៃទានយ៉ាងនេះ កាលបើដូច្នេះទ្រង់ឈ្មោះថា ជ្រាបផលនៃបុណ្យទាំងឡាយនិងទ្រង់ជ្រាបការកើតក្នុងវិមានដែលកើតឡើងដោយផលនៃបុណ្យ ។ បទថា **តស្មា** សេចក្ដីថា ព្រោះហេតុដែលវិមាននេះទ្រង់បានមកព្រោះហេតុនៃបុណ្យ ។ បទថា **បុន មាវសេសិ** សេចក្ដីថា សូមទ្រង់ប្រព្រឹត្តធម៌ឲ្យបាន សូមទ្រង់នៅគ្រប់គ្រងពិភពនាគនេះតទៅ ស្ដេចនាគបានឮហើយក៏ត្រាស់ព្រះគាថានេះថា

នៃបណ្ឌិតជាអាមាត្យ ខ្ញុំគប្បីឲ្យបាយនិងទឹក ដល់ពួកសមណៈនិងព្រាហ្មណ៍ណា ពួកសមណៈនិងព្រាហ្មណ៍នោះ មិនមានក្នុងភពនាគនេះទេ ខ្ញុំសួរហើយអ្នកចូរប្រាប់សេចក្ដីនុ៎ះ ដែលជាហេតុឲ្យខ្ញុំនៅគ្រប់គ្រងវិមានតទៅ ដូច្នេះ ។

ព្រះមហាសត្វទូលថា

ពួកនាគ គឺបុត្ត ភរិយានិងអ្នករស់នៅដោយសារ ដែលចូលមក កើតក្នុងភពនាគនេះ សូមព្រះអង្គជាអ្នកមិនប្រទូស្តក្នុងពួកនាគនោះដោយពាក្យឬដោយការងាររអស់កាលជានិច្ច ។ បពិត្រនាគ សូមព្រះអង្គរក្សាសេចក្ដីមិនប្រទូស្តដោយពាក្យ ឬដោយការងារយ៉ាងនេះចុះ ព្រះអង្គនឹងឋិតនៅក្នុងវិមាននេះរហូតអស់ព្រះជន្មាយុហើយនឹងបានទៅកាន់ទេវលោក ជាន់ខាងលើអំពី

ភពនាគនេះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ភោគី** បានដល់ នាគទាំងឡាយដែលជាសត្វមានរង្វេល ។ បទថា **តេសុ** សេចក្ដីថា សូមទ្រង់កុំប្រទូស្តជានិច្ចដោយកាយកម្មនិងវចីកម្មក្នុងនាគ មានព្រះឱរសនិងព្រះធីតាជាដើមនោះ ។ បទថា **អនុបាលយ** សេចក្ដីថា ចូរតាមរក្សាការមិនប្រទូស្ត ពោលគឺការមានមេត្តាចិត្ត ក្នុងព្រះរាជឱរសនិងព្រះរាជធីតាជាដើមនិងក្នុងសត្វដ៏សេសយ៉ាងនេះ ។ បទថា **ឧទ្ធំ ឥតោ** សេចក្ដីថា ទ្រង់នឹងយាងទៅកាន់ទេវលោកខ្ពស់ជាងនាគពិភពនេះ ព្រោះមេត្តាចិត្តចាត់ថាជាបុណ្យក្រៃលែងជាងទាន ។

ស្ដេចនាគ បានស្ដាប់ធម្មកថារបស់មហាសត្វយ៉ាងនេះហើយ ទ្រង់ពេញព្រះហឫទ័យហើយ ទើបទ្រង់ព្រះតម្រិះថា បណ្ឌិតមិនអាចធ្វើនូវការឃើតយូរខាងក្រៅ អញគួរបង្ហាញវិធុរបណ្ឌិតដល់ព្រះនាងវិមលាឲ្យព្រះនាងបានស្ដាប់សុភាសិតស្ងប់រម្ងាប់នូវសេចក្ដីប្រាថ្នា ហើយបញ្ជូនបណ្ឌិតត្រឡប់ទៅឲ្យព្រះបាទធនញ្ជយៈ ទ្រង់សោមនស្សទើបត្រាស់ព្រះគាថាថា

> អ្នកជាអាមាត្យរបស់ព្រះរាជាណា ព្រះរាជាដ៏ប្រសើរនោះ បើវៀរចាកអ្នកហើយរមែងសោកស្ដាយដោយពិត បុរសសូម្បីត្រូវសេចក្ដីទុក្ខគ្របសង្កត់ឬសូម្បីមានជំងឺធ្ងន់ បើបានជួបនឹងអ្នកហើយក៏នឹងបានសុខវិញ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សជ្ជិញ្ញោ** បានដល់ អ្នកធ្វើរាជកិច្ច ។ បទថា **សមេច្ច** សេចក្ដីថា មកព្រមជាមួយនឹងអ្នក ។ បទថា **អាតុរោបិ** សេចក្ដី

ថា សូម្បីជាអ្នកមានជំងឺធ្ងន់ ។

ព្រះមហាសត្វ ស្តាប់ព្រះតម្រាស់ដូច្នោះហើយ កាលធ្វើនូវការសរសើរស្តេចនាគទើបទូលគាថាទៀតថា

បពិត្រនាគ ព្រះអង្គពោលធម៌របស់សប្បុរសជាធម៌ប្រសើរ ជាចំណែកនៃប្រយោជន៍ដែលសន្សំល្អដោយពិត ឯសេចក្តីវិសេសរបស់បណ្ឌិតទាំងឡាយបែបខ្ញុំព្រះអង្គ រមែងប្រាកដក្នុងអន្តរាយទាំងឡាយបែបនេះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សតំ** សេចក្តីថា ទ្រង់សម្តែងធម៌របស់សប្បុរស គឺបណ្ឌិតទាំងឡាយដោយពិត ។ បទថា **អត្ថបទំ** បានដល់ចំណែកដែលជាប្រយោជន៍ ។ បទថា **ឯតាទិសិយាសុ** សេចក្តីថា គុណវិសេសរបស់បុគ្គលដែលមានបញ្ញាដូចខ្ញុំ រមែងប្រាកដក្នុងកាលដែលបានជួបអន្តរាយបែបនេះ គឺភ័យបែបនេះ ។

ស្តេចនាគទ្រង់ស្តាប់ដូច្នោះទ្រង់ត្រេកអរក្រៃលែង ហើយត្រាស់ព្រះគាថានេះថា

អ្នកចូរប្រាប់យើងមកចុះ បុណ្ណកយក្សនេះ បានអ្នកមកដោយទទេឬ អ្នកចូរប្រាប់យើងមកចុះបុណ្ណកយក្សនេះឈ្នះអ្នកដោយល្បែងភ្នាល់ឬ បុណ្ណកយក្សនេះបាននិយាយថា បណ្ឌិតខ្ញុំបាននាំមកដោយធម៌ តើអ្នកមកនៅក្នុងកណ្តាប់ដៃ នៃបុណ្ណកយក្សនេះដោយប្រការដូចម្តេច ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អក្ខាហិ នោ** សេចក្តីថា ចូរអ្នកប្រាប់ដល់ ខ្ញុំ ។ បទថា **តាយំ** កាត់បទជា **តំ អយំ** ។ បទថា **មុធានុលទ្ធោ** សេចក្តី ថា បុណ្ណកយក្ខនេះបានអ្នកមកទទេ ៗ ឬឈ្នះដោយការលេងបាស្កា ទើបបាន អ្នកមក ។ បទថា **ឥតិមាយមាហ** សេចក្តីថា បុណ្ណកយក្ខនេះនិយាយថា ខ្ញុំបានបណ្ឌិតមកដោយប្រពៃតាមធម៌ ។ បទថា **កថំ នុវំ ហត្ថមិមស្ស មាគតោ** សេចក្តីថា អ្នកមកដល់កណ្តាប់ដៃរបស់បុណ្ណកយក្ខនេះបានដូចម្តេច ។

លំដាប់នោះមហាសត្វទូលនឹងស្តេចនាគនោះដោយគាថានេះថា

ព្រះរាជារបស់ខ្ញុំព្រះអង្គណា ជាធំក្នុងក្រុងឥន្ទបត្តដែនកុរុនោះ បុណ្ណកយក្សនេះ បានឈ្នះល្បែងស្កានឹងព្រះរាជានោះ ដោយ ការភ្នាល់ ព្រះរាជាដែលបុណ្ណកយក្សឈ្នះហើយនោះ បាន ប្រទានខ្ញុំព្រះអង្គដល់បុណ្ណកយក្សនេះ បុណ្ណកយក្សឈ្មោះថា បានខ្ញុំព្រះអង្គមកដោយធម៌មិនមែនដោយការកំហែងទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យោ មិស្សរោ** កាត់បទជា **យោ មេ ឥស្សរោ** ។ បទថា **ឥមស្សទាសិ** សេចក្តីថា បានឲ្យដល់បុណ្ណកយក្ខនេះ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** វីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទ ព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូល សូត្យសាទូវព្រះគាថាដូច្នេះថា

នាគរាជដ៏ប្រសើរ មានចិត្តត្រេកអររីករាយហើយ ព្រោះបាន ស្តាប់សុភាសិតនៃវិធុរបណ្ឌិតជាអ្នកប្រាជ្ញ ក៏ចាប់ដៃវិធុរបណ្ឌិត

មានប្រាជ្ញាមិនថោកទាប នាំចូលទៅក្នុងសំណាក់នៃនាងវិមលា ជាកិរិយាក្នុងកាលនោះ ( ត្រាស់ថា ) ម្នាលនាងវិមលា នាងមានសម្បុរលឿងដោយហេតុណា ឬនាងមិនឆ្ងាញ់បាយដោយហេតុណា គុណ ( នៃវិធុរបណ្ឌិត ) បែបនេះមិនមាន ( ដល់នាង ) ដោយហេតុនោះទេ វិធុរបណ្ឌិតនេះឯង ជាអ្នកបន្ទោបង់នូវងងឹត ។ នាងមានសេចក្តីត្រូវការ ដោយហឫទ័យរបស់វិធុរបណ្ឌិតណា វិធុរបណ្ឌិតនេះជាអ្នកធ្វើពន្លឺ មកដល់ហើយ នាងចូរផ្ទៀងស្តាប់ពាក្យរបស់វិធុរបណ្ឌិតនោះចុះ ( ព្រោះ ) ការជួបប្រទះ ( នូវវិធុរបណ្ឌិត ) ទៀត ជាកិច្ចបានដោយកម្រដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឆាវេត្វិ** បានដល់ ចូលទៅហើយ ។ បទថា **យេន** សេចក្តីថា នៃនាងវិមលា នាងស្គមលឿងព្រោះហេតុអ្វីនិងព្រោះហេតុណា ទើបនាងមិនសោយព្រះក្រយាហារ ។ បទថា **ឆ ច មេតាទិសោ វ-ណ្ណោ** សេចក្តីថា កិត្តិគុណនៃវិធុរបណ្ឌិតបែបនេះ យើងនិងបុគ្គលដទៃមិនមាន បានផ្សាយខ្ទរខ្ទាទៅពេញផ្ទៃប្រឹថពីនិងទេវលោក ។ បទថា **អយមេសោ តមោនុទោ** សេចក្តីថា វិធុរបណ្ឌិតដែលនាងត្រូវការបេះដូងនោះ ជាអ្នកបន្ទោបង់នូវងងឹតនៃសត្វលោកទាំងមូល ។ ដោយបទថា **បុន** នេះស្តេចនាគពោលថា ឈ្មោះថា ការឃើញវិធុរបណ្ឌិតនេះទៀត រកបានដោយក្រ ។

ព្រះនាងវិមលាទ្រង់ទតឃើញវិធុរបណ្ឌិត ដែលជាអ្នកមានប្រាជ្ញា

ក្រាស់ដូចផែនដីនោះ ក៏មានព្រះទ័យត្រេកអរសោមនស្ស ទ្រង់លើកម្រាមដៃទាំង ១០ ផ្គងអញ្ជលីហើយត្រាស់នឹងវិធុរបណ្ឌិតជាអាមាត្យដ៏ប្រសើររបស់អ្នកដែនកុរុ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ហដ្ឋេន ភាវេន** សេចក្ដីថា ជាអ្នកមានចិត្តត្រេកអរ ។ បទថា **បតីតរូបា** បានដល់ កើតនូវសោមនស្ស ។ ខាងមុខអំពីនេះទៅព្រះនាងវិមលាទេវីក៏ត្រាស់ថា

អ្នកជាមនុស្សមានមច្ចុភ័យគ្របសង្កត់ តក់ស្លុត ព្រោះឃើញភពនៃនាគដែលខ្លួនមិនធ្លាប់ឃើញ ទើបមិនថ្វាយបង្គំ ( ខ្ញុំ ) ដំណើរនេះ ដូចមិនមែនជាអាការរបស់បុគ្គលមានប្រាជ្ញាទេ ដូច្នេះ ។

វិធុរបណ្ឌិតក្រាបទូលថា

បពិត្រព្រះនាងនាគី ខ្ញុំព្រះអង្គមិនមែនជាអ្នកតក់ស្លុតទេ មិនមានមច្ចុភ័យគ្របសង្កត់ទេ អ្នកទោសដែលត្រូវគេសម្លាប់ មិនគប្បីថ្វាយបង្គំ ( ពេជ្ឈឃាត ) ឬពេជ្ឈឃាតក៏មិនគប្បីថ្វាយបង្គំអ្នកទោសដែលត្រូវគេសម្លាប់ដែរ ។ ជនប្រាថ្នាសម្លាប់អ្នកណាគប្បីថ្វាយបង្គំ ( អ្នកនោះ ) ឬឲ្យ ( អ្នកនោះ ) ថ្វាយបង្គំ ( ខ្លួន ) ដូចម្ដេចកើត កម្មនោះមិនកើតជាអ្វីទេ ដូច្នេះ ។

ព្រះនាងវិមលាត្រាស់ថា

ម្នាលបណ្ឌិត ដំណើរនុ៎ះដូចអ្នកពោលមែន អ្នកពោលពាក្យ

ពិត អ្នកទោសដែលត្រូវគេសម្លាប់មិនគប្បីថ្វាយបង្គំពេជ្ឈឃាត ឬពេជ្ឈឃាតក៏មិនគប្បីថ្វាយបង្គំអ្នកទោសដែលត្រូវគេសម្លាប់ដែរ ។ ជនប្រាថ្នាសម្លាប់អ្នកណា គប្បីថ្វាយបង្គំ ( អ្នកនោះ ) ឬឲ្យ ( អ្នកនោះ ) ថ្វាយបង្គំ ( ខ្លួន ) ដូចម្ដេចកើត កម្មនោះមិនកើតទេ ដូច្នេះ ។

លំដាប់នោះព្រះមហាសត្វកាលធ្វើបដិសណ្ឋារៈជាមួយនឹងព្រះនាងវិមលាទេវីទើបក្រាបទូលថា

វិមាននេះ ទាំងឫទ្ធិ សេចក្ដីរុងរឿង សេចក្ដីព្យាយាមនិងការកើតក្នុងភពនាគរបស់ព្រះនាង មិនទៀង តែហាក់ដូចជារបស់ទៀង បពិត្រនាគកញ្ញា ខ្ញុំព្រះអង្គសួរសេចក្ដីនុ៎ះនឹងព្រះនាងថា វិមាននេះព្រះនាងបានហើយ ដោយប្រការដូចម្ដេច ។ វិមានដែលព្រះនាងបានព្រោះអាស្រ័យ ( ភពនាគ ) ឬកើតអំពីរដូវប្រែប្រួល ឬព្រះនាងធ្វើខ្លួនឯង ឬមួយទេវតាថ្វាយ បពិត្រនាគកញ្ញា វិមាននេះព្រះនាងបានហើយដោយប្រការណា សូមព្រះនាងប្រាប់សេចក្ដីនុ៎ះដល់ខ្ញុំដោយប្រការនោះ ដូច្នេះ ។

លំដាប់នោះព្រះនាងវិមលាត្រាស់ដល់ព្រះមហាសត្វថា

វិមាននេះមិនមែនខ្ញុំបានព្រោះអាស្រ័យភពនាគ មិនមែនកើតអំពីរដូវប្រែប្រួល មិនមែនធ្វើខ្លួនឯងទាំងមិនមែនទេវតាឲ្យទេ វិមាននេះខ្ញុំបានដោយបុញ្ញកម្មមិនអាក្រក់ជារបស់ខ្លួន ដូច្នេះ ។

ព្រះមហាសត្វពោលថា

អ្វីជាវត្ត អ្វីជាព្រហ្មចរិយៈរបស់ព្រះនាង បពិត្រព្រះនាងនាគី ឫទ្ធិអំណាច សេចក្តីរុងរឿង កម្លាំងកាយ សេចក្តីព្យាយាមនិងការកើត ( ក្នុងភពនាគ ) ទាំងវិមានធំរបស់ព្រះនាងនេះ នេះជាផលនៃកម្មដែលព្រះនាងសន្សំល្អហើយដូចម្តេច ដូច្នេះ ។

លំដាប់នោះព្រះនាងវិមលាទេវីត្រាស់ប្រាប់មហាសត្វថា

ខ្ញុំនិងស្វាមីទាំងពីរនាក់ ជាអ្នកមានសទ្ធា ជាម្ចាស់ទាន ផ្ទះរបស់ខ្ញុំដូចអណ្តូងជាទីចុះផឹកនៃ ( មហាជន ) ទាំងសមណ-ព្រាហ្មណ៍ ខ្ញុំក៏បានឲ្យឆ្អែតស្កប់ស្កល់ ។ ខ្ញុំ ( កាលនៅ ) ក្នុងកាលចម្បានគរនោះ បានឲ្យទានដោយគោរព គឺឲ្យផ្កាកម្រងគ្រឿងក្រអូប គ្រឿងលាប គ្រឿងប្រទីប ទីដេក ទីសំណាក់អាស្រ័យ សំពត់សម្រាប់ស្លៀកដណ្តប់ កម្រាលដេក បាយនិងទឹក ។ នោះជាវត្តនោះជាព្រហ្មចរិយៈរបស់ខ្ញុំ នៃអ្នកប្រាជ្ញ ឯឫទ្ធិ សេចក្តីរុងរឿង កម្លាំងកាយ សេចក្តីព្យាយាមនិងការកើត ( ក្នុងភពនាគ ) ទាំងវិមានធំរបស់ខ្ញុំនេះ នេះជាផលនៃកម្មដែលខ្ញុំសន្សំល្អហើយនោះ ដូច្នេះ ។

លំដាប់នោះព្រះមហាសត្វក្រាបទូលព្រះនាងវិមលាទេវីនោះថា

បើវិមាននេះ គឺព្រះនាងបានហើយយ៉ាងនេះឈ្មោះថា ព្រះនាងជ្រាបកំណើតនៃផលរបស់បុណ្យទាំងឡាយ ព្រោះហេតុនោះ

ព្រះនាងកុំប្រហែស សូមប្រព្រឹត្តធម៌ជាហេតុឲ្យបានគ្រប់គ្រង វិមាននេះតទៅ ដូច្នេះ ។

ព្រះនាងវិមលាទេវីត្រាស់ថា

នែបណ្ឌិតជាអាមាត្យ ខ្ញុំគប្បីឲ្យបាយនិងទឹកដល់ពួកសមណៈ និងព្រាហ្មណ៍ណា ពួកសមណៈនិងព្រាហ្មណ៍ ( ទាំងនោះ ) មិនមានក្នុងភពនាគនេះទេ ខ្ញុំសួរហើយអ្នកចូរប្រាប់សេចក្ដីនុ៎ះ ដែលជាហេតុឲ្យខ្ញុំនៅគ្រប់គ្រងវិមានតទៅ ដូច្នេះ ។

ព្រះមហាសត្វក្រាបទូលថា

ពួកនាគ គឺបុត្ត ស្វាមីនិងអ្នករស់នៅដោយសារដែលកើតមាន ក្នុងភពនាគនេះ សូមព្រះនាងជាអ្នកមិនប្រទូស្តក្នុងពួកនាគនោះ ដោយពាក្យឬដោយការងាររអស់កាលជានិច្ច ។ បពិត្រព្រះនាង នាគី សូមព្រះនាងរក្សាសេចក្ដីមិនប្រទូស្តដោយពាក្យឬដោយ ការងារយ៉ាងនេះចុះ ព្រះនាងនឹងឋិតនៅក្នុងវិមាននេះរហូតអស់ ជន្មាយុហើយនឹងបានទៅកាន់ទេវលោក ជាន់ខាងលើអំពីភព នាគនេះ ដូច្នេះ ។

ព្រះនាងវិមលាស្ដាប់ហើយមានព្រះតម្រាស់ថា

អ្នកជាអាមាត្យរបស់ព្រះរាជាណា ព្រះរាជាដ៏ប្រសើរនោះ បើ វៀរចាកអ្នកហើយ រមែងសោកស្ដាយដោយពិត បុរសសូម្បី ត្រូវសេចក្ដីទុក្ខគ្របសង្កត់ ឬសូម្បីមានជំងឺធ្ងន់ បើបានជួបនឹង

អ្នកហើយក៏នឹងបានសុខវិញ ដូច្នេះ ។

ព្រះមហាសត្វបានស្តាប់ហើយក៏ក្រាបទូលថា

បពិត្រព្រះនាងនាគី ព្រះនាងពោលធម៌របស់សប្បុរស ជាធម៌ប្រសើរ ជាចំណែកនៃប្រយោជន៍ ដែលសន្សំល្អដោយពិត ឯសេចក្តីវិសេសរបស់បណ្ឌិតទាំងឡាយ បែបខ្ញុំព្រះអង្គ រមែងប្រាកដក្នុងអន្តរាយទាំងឡាយបែបនេះ ដូច្នេះ ។

លំដាប់នោះព្រះនាងវិមលាទេវីក៏ត្រាស់ថា

អ្នកចូរប្រាប់យើងមកចុះ បុណ្ណកយក្សនេះ បានអ្នកមកដោយទទេឬ អ្នកចូរប្រាប់យើងមកចុះ បុណ្ណកយក្សនេះឈ្នះអ្នកដោយល្បែងភ្នាល់ឬ បុណ្ណកយក្សនេះបាននិយាយថា បណ្ឌិតខ្ញុំបានមកដោយធម៌ តើអ្នក មកនៅក្នុងកណ្តាប់ដៃបុណ្ណកយក្សនេះដោយប្រការដូចម្តេច ដូច្នេះ ។

គ្រានោះព្រះមហាសត្វក្រាបទូលព្រះនាងវិមលាទេវីនោះថា

ព្រះរាជារបស់ខ្ញុំព្រះអង្គណា ជាធំក្នុងក្រុងឥន្ទបត្តដែនកុរុនោះ បុណ្ណកយក្សនេះ បានឈ្នះល្បែងស្កានឹងព្រះរាជានោះ ដោយការភ្នាល់ ព្រះរាជាដែលបុណ្ណកយក្សឈ្នះហើយនោះ បានប្រទានខ្ញុំព្រះអង្គ ដល់បុណ្ណកយក្សនេះ ឯបុណ្ណកយក្សឈ្មោះថា បានខ្ញុំព្រះអង្គដោយធម៌មិនមែនដោយកំហែងទេ ដូច្នេះ ។

បណ្ឌិតគប្បីជ្រាបអត្ថគាថានេះ ដោយន័យដែលខ្ញុំបានពោលមកហើយ

នោះចុះ ។

ព្រះនាងវិមលាទេវីស្តាប់ពាក្យរបស់មហាសត្វ ព្រះនាងមានព្រះហឫទ័យត្រេកអរក្រៃលែង ព្រះនាងនាំមហាសត្វទៅស្រង់ទឹកក្រអូប ១០០០ ក្អម ក្នុងពេលស្រង់ស្រេច ព្រះនាងប្រទានគ្រឿងប្រដាប់ មានសំពត់ទិព្វនិងគ្រឿងក្រអូបនិងកម្រងផ្កាទិព្វជាដើម ដល់ព្រះមហាសត្វ ក្នុងគ្រាប្រដាប់តាក់តែងស្រេចហើយបានប្រទានទិព្វភោជន មហាសត្វបរិភោគភោជនាហារហើយឲ្យក្រាលអាសនៈដែលគេប្រដាប់ទុកហើយ អង្គុយលើធម្មាសនៈដែលគេប្រដាប់ហើយសម្តែងធម៌ដោយពុទ្ធលីលា ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសាទូវព្រះគាថាដូច្នេះថា

> វរុណនាគរាជបានសួរប្រស្នានឹងវិធុរបណ្ឌិតយ៉ាងណា ព្រះនាងនាគកញ្ញាក៏បានសួរប្រស្នានឹងវិធុរបណ្ឌិតយ៉ាងនោះដែរ ។ វិធុរបណ្ឌិតជាអ្នកប្រាជ្ញដែលវរុណនាគត្រាស់សួរហើយក៏បានញ៉ាំងវរុណនាគឲ្យត្រេកអរយ៉ាងណា វិធុរបណ្ឌិតជាអ្នកប្រាជ្ញដែលព្រះនាងនាគកញ្ញាសួរហើយ ក៏បានញ៉ាំងព្រះនាងនាគកញ្ញាឲ្យត្រេកអរយ៉ាងនោះដែរ ។ វិធុរបណ្ឌិត ជាអ្នកប្រាជ្ញ លុះដឹងច្បាស់ថា នាគរាជដ៏ប្រសើរនិងនាងនាគកញ្ញាទាំងពីរព្រះអង្គនោះ មានព្រះទ័យរីករាយហើយក៏មិនតក់ស្លុត មិនខ្លាច មិន

ព្រឺរោមបានទូលវរុណនាគរាជដូច្នេះថា បពិត្រនាគ ព្រះអង្គ
កុំខ្លាចឡើយ ខ្ញុំនេះហើយជាសេចក្តីត្រូវការរបស់ព្រះអង្គ
នេះសរីរៈ សូមព្រះអង្គធ្វើកិច្ចដោយសាច់ហឫទ័យចុះ ខ្ញុំនឹងធ្វើ
តាមអធ្យាស្រ័យរបស់ព្រះអង្គដោយខ្លួនឯង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អច្ឆម្ភី** បានដល់ មិនតក់ស្លុត ។ បទថា **អលោមហដ្ឋោ** បានដល់ មិនព្រឺរោម ព្រឺស្បែកព្រោះការខ្លាច ។ បទថា **ឥច្ចព្រវិ** សេចក្តីថា បានពោលដូច្នោះដោយអំណាចការពិចារណា ។ បទថា **មា ភាយិ** សេចក្តីថា ទ្រង់កុំខ្លាចឡើយថាអញធ្វើកម្ម គឺការទ្រុស្តមិត្ត កុំសន្ទិះសង្ស័យថា ឥឡូវនេះអញនឹងសម្លាប់បណ្ឌិតនេះ ឬក៏យ៉ាងណាហ្ន៎ ។ វិធុរបណ្ឌិតហៅវរុណនាគរាជថា **ឆាគ** ។ បទថា **អយាហមស្មិ** កាត់បទជា **អយំ អហមស្មិ** បាលីក៏យ៉ាងនេះដូចគ្នា ។ បទថា **សយំ ករិស្សាមិ** សេចក្តីថា បើទ្រង់មិនអាចសម្លាប់ខ្ញុំដោយគិតថាអញបានស្តាប់ធម៌ក្នុងសម្នាក់របស់បណ្ឌិតនេះសោត ខ្ញុំនឹងធ្វើឯងឲ្យសមនឹងអធ្យាស្រ័យរបស់ទ្រង់ ។

ស្តេចនាគត្រាស់ថា

បញ្ញាហ្នឹងឯង ជាដួងហឫទ័យរបស់បណ្ឌិតទាំងឡាយ យើង
ទាំងនោះ ត្រេកអរក្រៃលែងដោយប្រាជ្ញារបស់អ្នក យក្សមាន
ឈ្មោះមិនខ្វះខាត គឺបុណ្ណកៈចូរបានកិរិយាក្នុងថ្ងៃនេះចុះ ចូរញ៉ាំង
អ្នកឲ្យទៅដល់ដែនកុរុក្នុងថ្ងៃនេះចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តេ តុដ្ឋា** សេចក្តីថា ខ្ញុំទាំងពីរនាក់នេះ

ត្រេកអរដោយបញ្ញារបស់អ្នក ។ បទថា **អជ្ជេវធាមោ** បានដល់ យក្ខសេ-នាបតីមានឈ្មោះមិនខ្វះខាត គឺបុណ្ណកយក្ខនេះ ។ បទថា **លភតជ្ជ ធារំ** សេចក្ដីថា ថ្ងៃនេះបុណ្ណកយក្ខសេនាបតីចូរបាននូវកិរិយា យើងនឹងឲ្យឥរន្ទតីធីតាដល់បុណ្ណកយក្ខ ។ បទថា **ចាបយាតុ** សេចក្ដីថា ក្នុងថ្ងៃនេះបុណ្ណក-យក្ខ ចូរជូនអ្នកឲ្យដល់ឥន្ទបត្តនគរដែនកុរុនោះឯង ។

ស្ដេចវរុណនាគរាជ កាលត្រាស់យ៉ាងនេះហើយ បានព្រះរាជទាននាងឥរន្ទតីឲ្យដល់បុណ្ណកយក្ខៗនោះបាននាងឥរន្ទតីសមតាមប្រាថ្នាដូច្នោះ ក៏មានចិត្តត្រេកអរបានចរចាប្រាស្រ័យជាមួយព្រះមហាសត្វហើយ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូត្រសានូវព្រះគាថាដូច្នេះថា

> បុណ្ណកយក្សនោះមានចិត្តត្រេកអររីករាយ ព្រោះបាននាងនាគ
> កញ្ញាឈ្មោះឥរន្ទតី មានចិត្តត្រេកអរសប្បាយហើយបានពោល
> នឹងវិធុរបណ្ឌិតជាអាមាត្យដ៏ប្រសើររបស់អ្នកដែនកុរុ ដូច្នេះថា
> អ្នកធ្វើខ្ញុំឲ្យបានព្រមព្រៀងដោយភរិយា បពិត្រវិធុរបណ្ឌិត ខ្ញុំ
> សូមធ្វើកិច្ច ( តបគុណ ) ដល់អ្នក ខ្ញុំនឹងឲ្យកែវមណីនេះដល់
> អ្នក ទាំងញ៉ាំងអ្នកឲ្យដល់ដែនកុរុក្នុងថ្ងៃនេះឯង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **មណិរតនំ** សេចក្ដីថា នែបណ្ឌិត ខ្ញុំជ្រះថ្លាក្នុងឧបការគុណរបស់លោក យើងគួរធ្វើកិច្ចដែលសមគួរដល់លោក ព្រោះ

ដូច្នោះខ្ញុំនឹងឲ្យកែវមណីដែលជាគ្រឿងប្រើប្រាស់របស់ស្តេចចក្រពត្តិនេះ ដល់លោកហើយខ្ញុំនឹងជូនលោកឲ្យដល់ឥន្ទបត្តនគរដែនកុរុក្នុងថ្ងៃនេះឯង ។

លំដាប់នោះព្រះមហាសត្វកាលធ្វើនូវការសរសើរ ដល់បុណ្ណកយក្ខនោះ បានពោលគាថាក្រៅអំពីនេះថា

ម្នាលកច្ចាន: មេត្រីជាគុណជាតិ គឺបុគ្គលផ្ចាញ់មិនបាននេះ
ចូរមានដល់អ្នក ព្រមទាំងកិរិយាជាទីស្រឡាញ់ អ្នកមានចិត្ត
ត្រេកអរទួទៅ មានចិត្តល្អ មានចិត្តរីករាយឲ្យកែវមណីដល់
ខ្ញុំហើយចូរនាំខ្ញុំទៅកាន់ឥន្ទបត្តនគរចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អជេយ្យមេសា** សេចក្តីថា នែកច្ចាយនគោត្រ លោកនិងកិរិយាជាទីស្រឡាញ់របស់លោក ចូរមានសេចក្តីព្រមព្រៀងមានការស្រឡាញ់គ្នារហូតទៅ សូមជាបុគ្គលមានសួស្តីដែលបុគ្គលណាមួយបំបែកមិនបាន ។ ព្រះមហាសត្វពោលភាពដែលបុណ្ណកយក្ខនោះ មានការដល់ព្រមដោយបីតិនិងដោយពាក្យជាដើមថា **អានន្ទចិត្តោ** ជាអ្នកមានចិត្តត្រេកអរដូច្នេះ ។ បទថា **នយិន្ទបត្ថំ** កាត់បទជា **នយ ឥន្ទបត្ថំ** ។ ព្រោះហេតុនោះទើបព្រះសាស្តាត្រាស់ថា

បុណ្ណកយក្សនោះឡើងជិះសេះអាជានេយ្យ មានវណ្ណៈមិនថោក
ទាបហើយអញ្ជើញវិធុរ បណ្ឌិតជាអាមាត្យដ៏ប្រសើររបស់ពួក
អ្នកដែនកុរុ ឲ្យអង្គុយលើអាសនៈអំពីខាងមុខ ហោះទៅឰដ៏
អាកាសវេហា ។ ចិត្តរបស់មនុស្សរមែងស្ទុះទៅ ( កាន់អារម្មណ៍

ក្នុងទិច្ឆាយ ) យ៉ាងណា ដំណើរសន្ទុះរបស់សេះអាជានេយ្យនោះ ក៏ចាប់រហ័សក្រៃលែងជាងចិត្តនោះក៏យ៉ាងនោះដែរ បុណ្ណកយក្ស នោះនាំវិធុរបណ្ឌិតជាអាមាត្យដ៏ប្រសើររបស់អ្នកដែនកុរុទៅកាន់ ឥន្ទបត្តនគរ ដូច្នេះ ។

លំដាប់នោះបុណ្ណកយក្ខពោលនឹងព្រះមហាសត្វថា

នុ៎ះក្រុងឥន្ទបត្តដែលឃើញច្បាស់ នុ៎ះព្រៃស្វាយគួរជាទីរីករាយ ដោយចំណែកៗ ខ្ញុំក៏បានព្រមព្រៀងដោយភរិយាទាំងអ្នកក៏បាន មកដល់ទីលំនៅរបស់ខ្លួន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យថាបិ គច្ឆេ** សេចក្តីថា ឈ្មោះថា ចិត្ត រមែងមិនទៅ តែកាលចិត្តកាន់យកអារម្មណ៍ក្នុងទិច្ឆាយ ទើបលោកហៅថា ចិត្តទៅហើយ ព្រោះហេតុនោះគប្បីឃើញអត្ថក្នុងបទនេះយ៉ាងនេះថា ការទៅ នៃសេះសិន្ធពមនោមយនោះ បានជាការទៅដែលរហ័សជាងចិត្តដែលកាន់យក អារម្មណ៍ ។ បទថា **ឯតិន្ទបត្តំ** សេចក្តីថា បុណ្ណកយក្ខកាលបង្ហាញដល់ មហាសត្វដែលអង្គុយលើខ្នងសេះនោះឯងទើបពោលយ៉ាងនោះ ។ ដោយបទ ថា **សកំ និកេតំ** សេចក្តីថា បុណ្ណកយក្ខពោលថា អ្នកដល់លំនៅរបស់ អ្នកហើយ ។

ក្នុងថ្ងៃនោះពេលទាបភ្លឺព្រះបាទធនញ្ជយកោរព្យរាជ ទ្រង់ព្រះសុបិនដែល មិនធ្លាប់សុបិនថា មានដើមឈើធំមួយដើមតាំងនៅក្បែរទ្វារព្រះរាជនិវេសន៍ ដើមប្រកបដោយបញ្ញា មែកប្រកបដោយសីល ផ្លែពេញទៅដោយបញ្ចគោ-

រស របងព័ទ្ធទៅដោយដីរនិងសេះដែលប្រដាប់ហើយ ។ មហាជននាំគ្នាធ្វើសក្ការៈយ៉ាងធំ ផ្គងអញ្ជលីដល់ដើមឈើនោះជាច្រើន ។ លំដាប់នោះមានបុរសសម្បុរខ្មៅម្នាក់ ស្លៀកសំពត់ពណ៌ក្រហម ទ្រទ្រង់នូវផ្កាពណ៌ក្រហម កាន់យកអាវុធមកកាត់ឫសឈើនោះឲ្យដាច់ហើយ កាលមហាជនស្រែកយំបរិទេវនាការបានអូសដើមឈើនោះទៅ មិនបានប៉ុន្មានថ្ងៃក៏នាំយកមកឲ្យវិញក្នុងទីដើម ហើយចៀសចេញទៅដូច្នេះ ។ ព្រះរាជាទ្រង់ពិចារណាព្រះសុបិននោះទ្រង់សន្និដ្ឋានថា អ្នកដទៃដែលដូចនឹងដើមឈើធំមិនមាន គឺពិតជាវិធុរបណ្ឌិត អ្នកដទៃប្រៀបដូចបុរសដែលមកកាត់ឫសឈើនោះ កាលមហាជនកំពុងបរិទេវនាការអូសយកទៅហើយមិនមាន គឺពិតជាមាណពដែលនាំយកវិធុរបណ្ឌិតទៅ ស្អែកនេះមាណពនឹងនាំវិធុរបណ្ឌិតមកប្រតិស្ឋាន ត្រង់ទ្វារនៃរោងធម្មសភា ហើយចៀសចេញទៅ ប្រៀបដូចបុរសដែលនាំយកដើមឈើនោះមកឲ្យវិញនោះឯង ថ្ងៃនេះនឹងបានឃើញវិធុរបណ្ឌិត ដោយពិតប្រាកដ កាលទ្រង់សន្និដ្ឋានដូច្នេះហើយ ទ្រង់មានព្រះទ័យសោមនស្ស ទើបមានព្រះតម្រាស់ឲ្យប្រដាប់នគរទាំងមូល ឲ្យរៀបចំរោងធម្មសភា តម្កល់ធម្មាសនៈត្រង់រតនមណ្ឌប កាលស្រេចហើយទ្រង់យាងទៅកាន់ទីប្រថាប់ត្រង់រោងធម្មសភា មានព្រះរាជា ១០១ អង្គនិងពួកអមាត្យ ប្រជានុរាស្ត្រក្នុងនគរទាំងមូលចោមរោម ទ្រង់រង់ចាំការមកនៃវិធុរបណ្ឌិត លួងលោមមហាជនឲ្យត្រេកអរថា ពួកអ្នកនឹងឃើញបណ្ឌិតក្នុងថ្ងៃនេះ កុំនាំគ្នាវិតក្កឡើយ ។ ឯបុណ្ណកយក្ខនាំបណ្ឌិតប្រតិស្ឋានត្រង់កណ្តាលបរិស័ទទៀបទ្វារធម្មសភា លាព្រះមហាសត្វ

ហើយនាំនាងឥរន្ទតីទៅកាន់ទេវនគររបស់ខ្លួនហើយ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហា** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសានូវព្រះគាថាដូច្នេះថា

បុណ្ណកយក្សនោះញុំាំងវិធុរបណ្ឌិត ជាអាមាត្យដ៏ប្រសើររបស់ពួកអ្នកដែនកុរុឲ្យចុះក្នុងកណ្ដាលធម្មសភា ហើយឡើងជិះសេះអាជានេយ្យ ជាអ្នកមានវណ្ណៈមិនថោកទាប ហោះទៅឰដ៏អាកាសវេហា ។ ព្រះរាជា ទតឃើញមហាសត្វនោះហើយ ព្រះអង្គមានព្រះហឫទ័យសោមនស្ស ដ៏ក្រៃលែង ទ្រង់ក្រោកឡើងយកព្រះហស្តស្រវាឱប ទ្រង់មិនបានឲ្យកម្រើក ហើយអញ្ជើញព្រះមហាសត្វ ឲ្យអង្គុយលើអាសនៈក្នុងកណ្ដាលធម្មសភា ចំពោះព្រះភក្ត្រ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អនោមវណ្ណោ** បានដល់ មានពណ៌សម្បុរមិនថោកថយ គឺជាអ្នកមានពណ៌សម្បុរដ៏ឧត្ដម ។ បទថា **អវិកម្បយំ** សេចក្ដីថា ម្នាលភិក្ខុទាំងឡាយ ព្រះរាជានោះទ្រង់ផ្គងវិធុរបណ្ឌិតមិនកម្រើក មិនធូររលុងក្នុងកណ្ដាលមហាជន ចាប់ដៃទាំង ២ ឲ្យអង្គុយលើអាសនៈដែលតាក់តែង ឲ្យបែរមុខត្រង់ព្រះភក្ត្ររបស់ព្រះអង្គ ។

លំដាប់នោះព្រះរាជាទ្រង់ត្រេកអរនឹងព្រះមហាសត្វនោះ កាលនឹងធ្វើបដិសណ្ឋារៈដោយវាចាដ៏ពីរោះ ទើបត្រាស់ព្រះគាថានេះថា

អ្នកជាអ្នកណែនាំយើង ដូចនាយសារថីនាំយករថ ដែលបាត់
ទៅ ( មកឲ្យ ) អ្នកដែនកុរុទាំងឡាយត្រេកអរព្រោះបានឃើញ
អ្នក ខ្ញុំសួរហើយអ្នកចូរប្រាប់សេចក្តីនុ៎ះ អ្នករួចអំពីមាណព
ដោយប្រការដូចម្តេច ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឆន្នំ** សេចក្តីថា អ្នកជួយនាំយើងក្នុងការធ្វើប្រយោជន៍ដោយហេតុ គឺដោយន័យដូចនាយសារថីនាំរថដែលបាត់ទៅហើយឲ្យត្រឡប់មកបានដូច្នោះ ។ បទថា **ឆន្ទន្តិ តំ** សេចក្តីថា អ្នកកុរុរដ្ឋទាំងនេះ ឃើញអ្នករមែងត្រេកអរ ។ បទថា **មាណវស្ស** សេចក្តីថា អ្នកបានផុតចាកសម្នាក់របស់មាណពបានដូចម្តេច ការដែលមាណពដោះលែងឲ្យអ្នករួចផុតព្រោះហេតុអ្វី ។

លំដាប់នោះព្រះមហាសត្វក្រាបទូលព្រះរាជាថា

បពិត្រព្រះអង្គជាធំជាងជន មានព្យាយាមដ៏ប្រសើរជាងជន ព្រះ
អង្គត្រាស់ហៅបុរសណាថា មាណព បុរសនោះមិនមែនជា
មនុស្សទេ គឺជាយក្សឈ្មោះបុណ្ណកៈ ព្រះអង្គក៏ធ្លាប់បានឮមក
ហើយ បុណ្ណកយក្សនោះជាអាមាត្យនៃព្រះបាទកុវេរៈ មានស្តេច
នាគមួយឈ្មោះវរុណៈ គ្រប់គ្រងផែនដីមានទំហំនិងកម្ពស់ស្អាត
បរិបូណ៌ដោយពណ៌សម្បុរនិងកម្លាំង ឯបុណ្ណកយក្សនោះចង់
បានធីតាជាអនុជាតនៃវរុណនាគនោះ ( ធ្វើជាប្រពន្ធ ) នាងនាគ
កញ្ញានោះឈ្មោះឥរន្ទតី ។ បុណ្ណកយក្សព្យាយាមដើម្បីសម្លាប់

ខ្ញុំព្រះអង្គ ព្រោះហេតុនៃនាងឥរន្ទតីនោះ មានចង្កេះល្អគួរជាទីស្រឡាញ់ ឥឡូវនេះបុណ្ណកយក្សនោះ បានព្រមព្រៀងដោយភរិយា ចំណែកខ្ញុំព្រះអង្គក៏បុណ្ណកយក្សអនុញ្ញាតហើយ ទាំងកែវមណីខ្ញុំព្រះអង្គក៏បានហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យំ មាណវោ ត្យាភិវទិ** សេចក្តីថា ព្រះមហាសត្វក្រាបទូលព្រះរាជាថា បពិត្រព្រះអង្គជាកំពូលនៃពួកជន ទ្រង់ហៅបុគ្គលណាថា មាណព បុគ្គលនោះមិនមែនមនុស្សឡើយ ជាយក្ខឈ្មោះបុណ្ណកៈ ។ បទថា **ភូមិន្ធរោ** បានដល់ ជាអ្នកទ្រទ្រង់នូវផែនដី គឺនៅក្នុងភពនាគ ។ បទថា **សា នាគកញ្ញា** សេចក្តីថា បុណ្ណកយក្ខនោះប្រាថ្នានាងឥរន្ទតីនាគកញ្ញា ដែលជាកូនស្រីរបស់ស្តេចនាគនោះ ព្យាយាមសម្លាប់ខ្ញុំឲ្យស្លាប់ ។ បទថា **បិយាយ ហោតុ** សេចក្តីថា បពិត្រមហារាជ ស្តេចនាគនោះជ្រះថ្លាក្នុងការស្រោយប្រស្នាក្នុងចតុបោសថ បូជាខ្ញុំដោយកែវមណីហើយត្រឡប់ទៅកាន់ស្ថាននាគ កាលព្រះនាងវិមលាទេវីទូលសួរថា កែវមណីរបស់ព្រះអង្គបាត់ទៅឯណា ទើបទ្រង់ពណ៌នាភាពដែលខ្ញុំជាធម្មកថិក ។ ព្រះនាងវិមលាទេវីនោះមានបំណងនឹងស្តាប់ធម្មកថារបស់ខ្ញុំ បានញ៉ាំងសេចក្តីប្រាថ្នាដោយដួងហឫទ័យរបស់ខ្ញុំឲ្យកើតឡើង ។ ស្តេចនាគយល់ខុសត្រាស់នឹងនាងឥរន្ទតីដែលជាបុត្រីរបស់ខ្លួនថា មាតារបស់នាងប្រាថ្នាបេះដូងរបស់វិធុរបណ្ឌិត ចូរនាងទៅស្វែងរកប្តី ដែលអាចនាំហទយៈរបស់វិធុរបណ្ឌិតនោះមកបាន ។ នាងឥរន្ទតីកំពុងដើររកប្តីបានជួបបុណ្ណកយក្ខដែលជាក្មួយនៃស្តេចកុវេរវេស្ស-

វណា ដឹងថាបុណ្ណកយក្ខនោះមានចិត្តប្រតិព័ទ្ធក្នុងខ្លួន ទើបនាំទៅកាន់សម្នាក់បិតា ។ លំដាប់នោះស្តេចនាគត្រាស់នឹងបុណ្ណកយក្ខថា បើឯងអាចនាំបេះដូងរបស់វិធុរបណ្ឌិតមកបាន ឯងនឹងបាននាងឥរន្ទតីកូនស្រីរបស់យើង ។ បុណ្ណកយក្ខក៏ទៅនាំយកកែវមណី ដែលជាគ្រឿងប្រើប្រាស់របស់ស្តេចចក្រពត្តិ អំពីភ្នំវេបុលបព៌ត មកលេងបាស្កាភ្នាល់ជាមួយទ្រង់ បានខ្ញុំហើយស្នាក់នៅត្រង់ផ្ទះរបស់ខ្ញុំ ៣ ថ្ងៃ ប្រាប់ឲ្យខ្ញុំចាប់កន្ទុយសេះហើយនាំទៅវាយខ្ញុំត្រង់ដើមឈើខ្លះ ត្រង់ភ្នំខ្លះក្នុងហិមវន្តប្រទេស កាលមិនអាចឲ្យខ្ញុំស្លាប់បានទើបបែរមុខទៅកាន់ខ្យល់វេរម្ភៈ ឲ្យសេះបោលទៅក្នុងគំនរខ្យល់អស់ ៧ ដង ទើបយកខ្ញុំទៅដាក់លើភ្នំកាលគិរីដែលមានកម្ពស់ ៦០ យោជន៍ ធ្វើកម្មយ៉ាងនេះខ្លះ យ៉ាងនោះខ្លះ មានរាជសីហ៍ជាដើម ក៏មិនអាចធ្វើខ្ញុំឲ្យស្លាប់បាន ខ្ញុំសួរដល់ហេតុដែលគេសម្លាប់ គេប្រាប់ហេតុនោះឲ្យជ្រាបសព្វគ្រប់ កាលបើដូច្នោះខ្ញុំក៏សម្តែងសាធុនរធម៌ដល់គេ គេបានស្តាប់សាធុនរធម៌នោះមានចិត្តជ្រះថ្លាប្រាថ្នានាំខ្ញុំមកកាន់ទីនេះ កាលគេមានបំណងដូច្នោះខ្ញុំក៏នាំគេទៅកាន់ភពនាគ សម្តែងធម៌ថ្វាយស្តេចនាគ និងព្រះនាងវិមលាទេវី នាគបរិស័ទទាំងអស់នាំគ្នាជ្រះថ្លាក្នុងធម្មទេសនានោះ ។ ក្នុងកាលស្តេចនាគទ្រង់ត្រេកអរក្នុងធម្មទេសនារបស់ខ្ញុំ បានប្រទាននាងឥរន្ទតីដល់បុណ្ណកយក្ខៗបាននាងឥរន្ទតីហើយ មានចិត្តជ្រះថ្លាក៏បូជាខ្ញុំដោយកែវមណី ដែលស្តេចនាគទ្រង់ប្រាប់ឲ្យបញ្ជូនខ្ញុំមកទើបលើកខ្ញុំដាក់លើខ្នងសេះមនោមយសិន្ធព ឯខ្លួនឯងអង្គុយលើអាសនៈកណ្តាល ឲ្យខ្ញុំអង្គុយខាងមុខ ឲ្យនាងឥរន្ទតីអង្គុយឯក្រោយ នាំខ្ញុំមកក្នុងទីនេះ ញុំាងខ្ញុំ

ឲ្យចុះត្រង់កណ្តាលបរិស័ទហើយនាំនាងឥរន្ទតីទៅកាន់នគររបស់ខ្លួនហើយ ។ បពិត្រមហារាជ ព្រោះតែនាងឥរន្ទតីដែលមានចង្កេះល្អ គួរស្រឡាញ់ ទើបបុណ្ណកយក្ខព្យាយាមសម្លាប់ខ្ញុំដោយប្រការដូច្នេះ ។ តែបុណ្ណកយក្ខអាស្រ័យខ្ញុំក្នុងកាលនោះឯង ទើបជាអ្នកដល់ព្រមជួបគ្នាជាមួយភរិយា ។ ស្តេចនាគទ្រង់ស្តាប់ធម្មទេសនារបស់ខ្ញុំ ទ្រង់ជ្រះថ្លាហើយ ទ្រង់អនុញ្ញាតឲ្យបញ្ជូនខ្ញុំត្រឡប់ ខ្ញុំបានកែវមណីដែលជាគ្រឿងប្រើប្រាស់របស់ស្តេចចក្រពត្តិ ដែលអាចឲ្យវត្ថុគួរប្រាថ្នាបានគ្រប់យ៉ាង ខ្ញុំបានមកអំពីសម្នាក់នៃបុណ្ណកយក្ខ បពិត្រសម្មតិទេព សូមទ្រង់ទទួលកែវមណីនេះ គ្រាក្រាបទូលដូច្នេះហើយបានថ្វាយកែវមណីដល់ព្រះរាជា ។

បន្ទាប់អំពីនោះព្រះរាជា កាលត្រាស់នូវនិទានព្រះសុបិនដែលទ្រង់ឃើញក្នុងវេលាទៀបភ្លឺដល់អ្នកនគរទើបត្រាស់ថា នែអ្នកដ៏ចម្រើនទាំងឡាយ ពួកអ្នកចូរស្តាប់សុបិនដែលយើងឃើញក្នុងគ្រានេះ ហើយត្រាស់គាថានេះថា

ដើមឈើដុះទៀបទ្វារដំណាក់របស់យើង មានដើមសម្រេច
ដោយប្រាជ្ញា មែករបស់ឈើនោះសម្រេចដោយសីល ដើម
ឈើ ( នោះ ) សម្រេចដោយប្រាជ្ញាខ្ជាប់ខ្ជួន តាំងនៅក្នុងអត្ថ
និងធម៌ មានផ្លែជាបញ្ចគោរស ដេរដាសដោយដំរីគោនិងសេះ ។
កាលដើមឈើនោះ គឹកកងដោយការរាំ ការច្រៀងនិងតន្ត្រី
បុរស ( ខ្មៅម្នាក់ ) កាត់ដើមឈើនោះហើយញ៉ាំងសេនា
( ឲ្យរត់ទៅ ) បណ្ឌិតនេះទុកដូចជាដើមឈើរបស់យើងនោះមក

កាន់លំនៅរបស់ខ្លួនវិញហើយ អ្នកទាំងឡាយ ចូរធ្វើសេចក្តីកោតក្រែងដើមឈើនេះ ។ ជនទាំងឡាយណានីមួយ មានចិត្តត្រេកអរ ( ដោយយស ) ព្រោះបច្ច័យនៃយើង ពួកជនទាំងអស់នោះចូរធ្វើ ( ចិត្តរបស់ខ្លួន ) ឲ្យប្រាកដក្នុងថ្ងៃនេះចុះ អ្នកទាំងឡាយធ្វើបណ្ណាការឲ្យច្រើន ចូរធ្វើសេចក្តីកោតក្រែងដល់ដើមឈើនេះចុះ ។ ពួកសត្វណានីមួយដែលគេចងទុកក្នុងដែនរបស់យើង ពួកសត្វទាំងអស់នោះ ចូរឲ្យរួចចាកចំណងវិធុរបណ្ឌិតនេះរួចចាកចំណងយ៉ាងណា ពួកសត្វទាំងនុ៎ះគប្បីរួចចាកចំណងយ៉ាងនោះ ។ ចូរពួកប្រជាជនទុកដាក់នង្គ័លធ្វើ ( មហោស្រព ) អស់មួយខែនេះចុះ ពួកព្រាហ្មណ៍ចូរបរិភោគបាយលាយដោយសាច់ ពួកអ្នកមិនផឹកទឹកស្រវឹង គួរផឹកទឹកស្រវឹង ចូរផឹកដោយភាជនៈដ៏ពេញហូរហៀរ ។ ស្រីពេស្យាទាំងឡាយ ( អាស្រ័យ ) ផ្លូវធំចូរហៅរកបុរសអ្នកត្រូវការអស់កាលជានិច្ចចុះ មួយទៀតរាជបុរសទាំងឡាយ ចូរចាត់ចែងការរក្សាឲ្យមាំមួនក្នុងដែន កុំឲ្យពួកមនុស្សបៀតបៀនគ្នានឹងគ្នា អ្នកទាំងឡាយ ចូរធ្វើសេចក្តីកោតក្រែង ចំពោះដើមឈើនេះដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សីលមយស្ស** សេចក្តីថា មែករបស់ដើមឈើនេះសម្រេចហើយដោយសីល ។ បទថា **អត្ថេ ច ធម្មេ ច** សេចក្តីថា

ដើមឈើនោះតាំងនៅក្នុងសេចក្ដីចម្រើននិងក្នុងសភាវធម៌ ។ បទថា **ឋិតា-កោ** សេចក្ដីថា ដើមឈើនោះសម្រេចដោយបញ្ញាប្រតិស្ឋានហើយ ។ បទថា **គរុប្បលោ** សេចក្ដីថា ដើមឈើនោះមានផ្លែសម្រេចហើយ ដោយបញ្ចគោរស ។ បទថា **ហត្ថិគវាស្សជេន្នោ** សេចក្ដីថា ដើមឈើនោះដេរដាសទៅដោយហ្វូងដំរី ហ្វូងគោនិងហ្វូងសេះដែលប្រជាប់ហើយ ។ បទថា **ឆច្ចគីតតុរិយាភិនាទិតេ** សេចក្ដីថា កាលមហាជនធ្វើនូវការបូជានូវដើមឈើនោះគគ្រឹកគគ្រេងទៅដោយការរាំ ការច្រៀងជាដើមត្រង់ដើមឈើនោះ ។ កាលនោះមានបុរសខ្មៅម្នាក់ មកដកដើមឈើនោះហើយដេញសេនា ដែលឈរជុំវិញឲ្យគេចទៅ ដើមឈើនោះ ត្រឡប់មកប្រតិស្ឋានត្រង់ទីដើមនៃទ្វាររបស់យើង ដើមឈើធំនោះបានដល់បណ្ឌិតនោះឯង ដែលត្រឡប់មកត្រង់លំនៅរបស់យើង ឥឡូវនេះពួកអ្នកទាំងពួងចូរធ្វើសក្ការៈកោតក្រែង គោរពដល់ដើមឈើ គឺបណ្ឌិតនេះឲ្យច្រើន ។ បទថា **មម បច្ចយេន** សេចក្ដីថា បណ្ដាអាមាត្យ ដែលមានចិត្តត្រេកអរដោយយសដែលខ្លួនអាស្រ័យយើងបានហើយទាំងអស់នោះ ចូរធ្វើចិត្តរបស់ខ្លួនឲ្យប្រាកដក្នុងថ្ងៃនេះ ។ បទថា **តិព្វានិ** បានដល់ ច្រើន គឺធំ ។ បទថា **ឧទាយនានិ** បានដល់ គ្រឿងបណ្ណាការទាំងឡាយ ។ បទថា **យេកេចិ** សេចក្ដីថា ដោយហោចសំដៅយកម្រឹគនិងបក្សីដែលបង្ខាំងទុកដើម្បីមើល ។ បទថា **មុញ្ចរេ** បានដល់ ចូរដោះលែង ។ បទថា **ឧន្នង្គលា មាសមិមំ ករោន្តុ** សេចក្ដីថា សូមពួកអ្នកស្រែ អ្នកចម្ការទាំងពួង ចូរឈប់ធ្វើស្រែធ្វើចម្ការអស់ខែនេះ ឲ្យមនុស្ស

វាយស្គរត្រាច់ប្រកាសទៅ ។ អ្នកនគរចូរព្រមព្រៀងគ្នាមកប្រជុំដ៏ធំ ។ បទថា **ភក្ខយន្តុ** សេចក្តីថា សូមអញ្ជើញបរិភោគ ។ **អ** អក្ខរៈក្នុងបទថា **អមជ្ជទា** នេះត្រឹមតែជានិបាត អធិប្បាយថា ពួកអ្នកលេងសុរាគួរផឹកសុរា រមែងមកប្រជុំគ្នាផឹកត្រង់រានផ្សាររៀងៗខ្លួន ។ បទថា **បុណ្ណាហិ ថាលាហិ** បានដល់ដោយថាសដ៏ពេញ ។ បទថា **បលិស្សុតាហិ** សេចក្តីថា ហូរចេញអំពីថាសព្រោះមានសុរាពេញ ។ បទថា **មហាបថំ និច្ច សមវ្ហយន្តុ** សេចក្តីថា ពួកស្រីពេស្យាដែលនៅប្រចាំតាមផ្លូវធំដែលគេតាក់តែងទុក គឺត្រង់ផ្លូវធំ ចូរលួងលោមបុរស ដែលមានសេចក្តីត្រូវការដោយកិលេសជានិច្ច ។ បទថា **តិព្វំ** បានដល់ ឲ្យមាំមួន ។ បទថា **យថា** សេចក្តីថា ចូរអ្នកទាំងឡាយរៀបចំរក្សាដើមឈើដូចពួកអ្នកស្រែរៀបចំរក្សាដើមឈើដោយល្អ ធ្វើនូវសេចក្តីកោតក្រែងចំពោះដើមឈើ មិនបៀតបៀនគ្នានឹងគ្នា ។ កាលព្រះរាជាត្រាស់ដូច្នោះហើយ

ពួកស្នំ ពួករាជកុមារ ពួកអ្នកជំនួញនិងពួកព្រាហ្មណ៍ នាំយកបាយនិងទឹកដ៏ច្រើនមកជូនវិធុរបណ្ឌិត ។ ពលដំរី ( ពលសេះ ) ពលរថ ពលថ្មើរជើង នាំយកបាយនិងទឹកដ៏ច្រើនមកជូនវិធុរបណ្ឌិត ។ ពួកអ្នកជនបទមកជួបជុំគ្នា ពួកអ្នកនិគមមកជួបជុំគ្នា នាំយកបាយនិងទឹកដ៏ច្រើនមកជូនវិធុរបណ្ឌិត ។ ប្រជាជនជាច្រើន ជាអ្នកមានចិត្តជ្រះថ្លាព្រោះឃើញបណ្ឌិតមកដល់ហើយ កាលបណ្ឌិតមកដល់ ការលើកទង់ក៏ប្រព្រឹត្តទៅ

ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អភិហារយុំ** សេចក្ដីថា ស្រីស្នំជាដើម នោះ ដែលព្រះរាជាត្រាស់ហើយយ៉ាងនេះនិងត្រាស់ឲ្យមហាជនដោះលែងសត្វទាំងពួងអំពីទីឃុំឃាំងនិងចំណង រៀបចំបណ្ណាការមានប្រការផ្សេងៗ បញ្ចូលបាយនិងទឹក មួយអន្លើដោយគ្រឿងបណ្ណាការនោះទៅជូនបណ្ឌិត ។ បទថា **បណ្ឌិតមាគតេ** សេចក្ដីថា មហាជនកាលបណ្ឌិតមកដល់ហើយ បានឃើញបណ្ឌិតក៏មានចិត្តជ្រះថ្លា ។

ព្រះនគរមានមហោស្រពអស់កាលមួយខែ ទើបចប់សព្វគ្រប់ ។ ព្រះមហាសត្វ សម្ដែងធម៌ដល់មហាជន ទូន្មានព្រះរាជាដូចជាបំពេញពុទ្ធកិច្ចឲ្យសម្រេច បំពេញបុណ្យមានទានជាដើម តាំងនៅដរាបដល់អស់អាយុ កាលអស់អាយុមានស្ថានសួគ៌ជាទីទៅខាងមុខ ។

អ្នកកុរុរដ្ឋទាំងអស់តាំងអំពីព្រះរាជាតាំងនៅក្នុងឱវាទរបស់ព្រះមហាសត្វ នាំគ្នារក្សាសីល បំពេញបុណ្យមានទានជាដើម បំពេញផ្លូវឲ្យទៅកាន់ស្ថានសួគ៌ឲ្យបរិសុទ្ធកាលអស់អាយុហើយបានទៅតាមយថាកម្មរបស់ខ្លួននោះឯង ។

ព្រះសាស្ដា កាលទ្រង់នាំព្រះធម្មទេសនានេះមកសម្ដែងហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយមិនមែនតែឥឡូវនេះទេ សូម្បីក្នុងកាលមុនតថាគតក៏ដល់ព្រមដោយបញ្ញា ឈ្លាសក្នុងឧបាយដូចគ្នា ដូច្នេះហើយទើបប្រកាសសច្ចៈទាំងឡាយ ហើយទ្រង់ប្រជុំជាតកថា

មាតាបិតារបស់បណ្ឌិតក្នុងកាលនោះ កាលត្រឡប់ជាតិទៅមក បានជា

ត្រកូលមហារាជក្នុងកាលឥឡូវនេះ ភរិយាធំរបស់បណ្ឌិតក្នុងកាលនោះបាន មកជារាហុលមាតា បុត្តច្បងរបស់បណ្ឌិតក្នុងកាលនោះ បានមកជារាហុល ព្រះនាងវិមលាក្នុងកាលនោះបានមកជានាងឧប្បលវណ្ណា ស្តេចវរុណនាគរាជ ក្នុងកាលនោះបានមកជាសារីបុត្ត ស្តេចគ្រុឌក្នុងកាលនោះ បានមកជាមោគ្គ-ល្លាន សក្កទេវរាជក្នុងកាលនោះបានមកជាអនុរុទ្ធ ព្រះបាទកោរព្យរាជក្នុង កាលនោះបានមកជាអានន្ទ បុណ្ណកយក្ខក្នុងកាលនោះបានមកជាឆន្នភិក្ខុ សេះ មនោមយក្នុងកាលនោះ បានមកជាសេះឈ្មោះកណ្ឋកៈ បរិស័ទក្រៅអំពីនោះ បានមកជាពុទ្ធបរិស័ទក្នុងកាលឥឡូវនេះ ឯវិធុរបណ្ឌិតក្នុងកាលនោះ គឺតថា-គត អរហន្តសម្មាសម្ពុទ្ធនេះឯង ។

## អដ្ឋកថា វិធុរជាតកទី ៩ ចប់

# វេស្សន្តរជាតក

[ ២១២ ] ( ព្រះឥន្ទ្រាធិរាជទ្រង់ត្រាស់ថា ) ម្នាលនាងផុស្សតីដ៏មានពន្លឺនៃសម្បុរដ៏ប្រសើរ មានអវយវៈខាងដើមដ៏ល្អ នាងចូរទទួលពរ ១០ ប្រការលើផែនដីដែលជាពរពេញចិត្តរបស់នាង ។

[ ២១៣ ] ( នាងផុស្សតីទេវធីតាក្រាបបង្គំទូលថា ) បពិត្រទេវរាជ ខ្ញុំម្ចាស់សូមថ្វាយបង្គំព្រះអង្គ ចុះខ្ញុំម្ចាស់បានធ្វើអំពើអាក្រក់ដូចម្តេចបានជាព្រះអង្គ មកញុំាងខ្ញុំម្ចាស់ឲ្យឃ្លាតចាករមណីយដ្ឋាន ដូចជាខ្យល់ដែលបក់រំលើងដើមឈើដូច្នោះ ។

[ ២១៤ ] ( ព្រះឥន្ទ្រា... ) នាងឥតបានធ្វើអំពើអាក្រក់ទេ មួយទៀតនាងមិនមែនជាទីស្អប់នៃខ្ញុំទេ តែថានាងអស់បុណ្យហើយ បានជាខ្ញុំនិយាយនឹងនាងយ៉ាងនេះ ។ នាងមានសេចក្តីស្លាប់កៀកជិតណាស់ហើយ មុខជានឹងមានសេចក្តីព្រាត់ប្រាស កាលបើខ្ញុំឲ្យនូវពរ ១០ ប្រការនេះ នាងចូរទទួលយកចុះ ។

[ ២១៥ ] ( នាងផុស្សតី... ) បពិត្រសក្កទេវរាជដ៏ចម្រើន ជាឥស្សរៈលើពួកទេវតាទាំងអស់ បើព្រះអង្គទ្រង់ប្រទានពរដល់ខ្ញុំម្ចាស់ ខ្ញុំម្ចាស់សូមឲ្យបានទៅក្នុងព្រះរាជនិវេសន៍នៃព្រះបាទសិវិរាជនោះ ១ សូមឲ្យមាននេត្រាដ៏ខ្មៅដូចជាកូនម្រឹគញីមានភ្នែកខ្មៅ ១ សូមឲ្យមានចិញ្ចើមខ្មៅ ១ បពិត្រព្រះអង្គ ទ្រង់បានបំពេញទានក្នុងកាលមុន ខ្ញុំម្ចាស់ទៅកើតក្នុងព្រះរាជនិវេសន៍នោះសូមឲ្យមានឈ្មោះថា ផុស្សតី ( ដូចដើម ) សូមឲ្យបានបុត្តដ៏ប្រសើរដែលចូលចិត្តឲ្យទាន

ជាអ្នកគួរដល់ស្តូម មិនមានសេចក្តីកំណាញ់ ជាបុគ្គលដែលព្រះរាជាប្រទេស ដទៃបូជា ជាអ្នកមានកេរ្តិ៍ឈ្មោះ មានយស ១ ។ កាលខ្ញុំម្ចាស់ទ្រទ្រង់គភ៌ សូមកុំឲ្យមានពោះប៉ោងឡើង ដូចជាធ្នូដែលគេសិតស្មើដូច្នោះ ១ ។ បពិត្រព្រះវាសវៈ ខ្ញុំម្ចាស់សូមកុំឲ្យមានដោះយារវែង ១ សក់ខ្ញុំម្ចាស់សូមកុំឲ្យមានសក់ស្កូវ ១ ខ្ញុំម្ចាស់សូមកុំឲ្យធូលីជាប់លើកាយ ១ ខ្ញុំម្ចាស់សូមដោះលែងចោរ ដែលមានកំហុសគួរគេសម្លាប់ ១ ។ បពិត្រទេវរាជដ៏ចម្រើន ខ្ញុំម្ចាស់សូមឲ្យបានជាអគ្គមហេសី ជាទីស្រឡាញ់នៃព្រះបាទសិវិក្នុងព្រះរាជនិវេសន៍នោះ ដែលជាទីកងរំពងដោយសំឡេងក្ងោកនិងក្រៀល ប្រកបដោយពួកនាងនារីដ៏ប្រសើរ ដេរដាសដោយមនុស្សគមនិងមនុស្សគៀ ជាព្រះរាជនិវេសន៍ដែលពួកអ្នកសូទ្រៈនិងពួកអ្នកមគធៈសរសើរហើយដ៏គឹកកងដោយសំឡេងនៃសន្ទះទ្វារបង្អួចដ៏ពិចិត្រដែលជាទីមានពួកជនជាស់គ្នាឲ្យផឹកសុរានិងឲ្យបរិភោគសាច់ ។

[ ២១៦ ] ( *ព្រះឥន្ទ្រ...* ) ម្នាលនាងមានអវយវៈទាំងអស់ដ៏ល្អ ពរ ១០ ប្រការណាដែលខ្ញុំឲ្យដល់នាងហើយ នាងនឹងបានពរទាំងអស់នោះក្នុងដែននៃព្រះបាទសិវិ ។

[ ២១៧ ] ( *អភិសម្ពុទ្ធគាថា* ) ព្រះមឃវៈទេវរាជសុជម្បតិវាសវៈ លុះទ្រង់មានព្រះបន្ទូលយ៉ាងនេះហើយក៏ប្រទានពរដល់ព្រះនាងផុស្សតីហើយ ក៏មានព្រះហឫទ័យរីករាយ ។

**ចប់ គាថាទសពរ ។**

[ ២១៨ ] ( អភិសម្ពុទ្ធគាថា ) នាងផុស្សតីទេវធីតានោះ ច្យុតចាកទេវលោកនោះមកហើយក៏ទៅកើតក្នុងខត្តិយត្រកូល បាននៅរួមនឹងព្រះបាទសញ្ជ័យ ក្នុងនគរជេតុត្តរ ។ ព្រះនាងទេវីទ្រង់ព្រះនាមផុស្សតី ទ្រង់គភ៌អស់ ១០ ខែ ក៏ធ្វើប្រទក្សិណព្រះរាជបុរី រួចប្រសូតតថាគតត្រង់កណ្តាលផ្លូវនៃពួកឈ្មួញ ។ នាមតថាគតមិនមែនជារបស់មាតា ទាំងមិនមែនកើតមកពីបិតាទេ តថាគតកើតត្រង់ ( កណ្តាល ) ផ្លូវនៃពួកឈ្មួញព្រោះហេតុនោះបានជាតថាគតឈ្មោះវេស្សន្តរ ។ កាលដែលតថាគតនៅក្មេងតូចទើបនឹងមានអាយុ ៨ ឆ្នាំអំពីកំណើតតថាគត បានអង្គុយលើប្រាសាទរិះគិតនឹងឲ្យទានថា បើមានស្មូមណាមួយមកបន្ទឹវាចាសុំអាត្មាអញៗគួរឲ្យបេះដូង គួរឲ្យភ្នែក គួរឲ្យសាច់ គួរឲ្យឈាម គួរឲ្យរាងកាយ ( ដល់ស្មូមនោះឯង ) ។ កាលតថាគតនោះកំពុងគិតសភាវធម៌ដែលមិនកម្រើក មិនតាំងនៅក្នុងកាលនោះ ប្រឹថពីមានភ្នំសិនេរុនិងព្រៃជាគ្រឿងប្រដាប់ពីខាងលើក៏ញាប់ញ័រ ។

[ ២១៩ ] ( ព្រះបាទវេស្សន្តរ... ) ពួកព្រាហ្មណ៍មានរោមក្លៀកនិងក្រចកដុះវែង មានធ្មេញប្រកបដោយមន្ទិល មានក្បាលប្រឡាក់ដោយធូលីផ្គងដើមដៃខាងស្តាំ តើសុំអ្វីនឹងអញ ។

[ ២២០ ] ( ពួកព្រាហ្មណ៍... ) បពិត្រព្រះសម្មតិទេព ពួកទូលព្រះបង្គំសុំហត្ថិរតន៍ ដែលញុំាងដែននៃពួកអ្នកសិវិរាស្ត្រឲ្យចម្រើន សូមព្រះអង្គទ្រង់ប្រទានដំរីដ៏ប្រសើរ ដែលមានភ្លុកងទន្ទាំអាចញុំាញីសត្រូវបាន ។

[ ២២១ ] ( ព្រះបាទវេស្សន្តរ... ) ព្រាហ្មណ៍ទាំងឡាយសុំដំរីណានឹង

អញ ជាដំរីចុះប្រេង ជាកុញ្ជរជាតិ មានភ្លុកដ៏ល្អ ជាដំរីដ៏ប្រសើរ គួរជារាជពាហនៈ អញនឹងឲ្យ ( ដំរីនោះ ) អញមិនញាប់ញ័រទេ ។

[ ២២២ ] ( អភិសម្ពុទ្ធគាថា ) ព្រះរាជាដែលជាអ្នកញុំាំងពួកអ្នកសិវិរាស្រ្តឲ្យចម្រើន ទ្រង់មានព្រះហឫទ័យប្រាថ្នាយ៉ាងលើសលុបក្នុងការបរិច្ចាគ ទ្រង់ចុះចាកកនៃដំរី រួចទ្រង់ប្រទាន ( ដំរី ) ជាទានដល់ពួកព្រាហ្មណ៍ ។

[ ២២៣ ] កាលដែលព្រះរាជាទ្រង់ប្រទានដំរីដ៏ប្រសើរ ផែនដីកម្រើកញាប់ញ័រ ការកើតហេតុគួរខ្លាច គួរព្រឺរោមក៏មានក្នុងកាលនោះ ។ កាលព្រះរាជាទ្រង់ប្រទានដំរីដ៏ប្រសើរ ការកើតហេតុគួរខ្លាច គួរព្រឺរោមក៏មានក្នុងកាលនោះ អ្នកនគរក៏ជ្រួលជ្រើមក្នុងកាលនោះ ។ កាលព្រះរាជាទ្រង់ប្រទានដំរី ដ៏ប្រសើរ ដែលជាដំរីញុំាំងពួកអ្នកសិវិរាស្រ្តឲ្យចម្រើន អ្នកបុរីក៏ជ្រួលច្របល់ទាំងសំឡេងក៏គឹកកងរំពងខ្លាំង ។

[ ២២៤ ] កាលព្រះរាជា ទ្រង់ប្រទាននូវដំរីដ៏ប្រសើរ គ្រានោះសំឡេងយ៉ាងខ្លាំងពន្លឹក ជាសំឡេងគួរខ្លាចក៏ប្រព្រឹត្តទៅក្នុងនគរនោះ ក្នុងកាលនោះអ្នកនគរក៏ជ្រួលជ្រើម ។ កាលព្រះរាជាទ្រង់ប្រទានដំរីដ៏ប្រសើរ ជាដំរីញុំាំងពួកអ្នកសិវិរាស្រ្តឲ្យចម្រើន គ្រានោះសំឡេងយ៉ាងខ្លាំងពន្លឹក គួរខ្លាចប្រព្រឹត្តទៅក្នុងនគរនោះ ។

[ ២២៥ ] ពួកជនអ្នកមានកេរ្តិ៍ឈ្មោះ ពួករាជបុត្ត ពួកអ្នកជំនួញ ពួកព្រាហ្មណ៍ ពួកទាហានដំរី ទាហាន ( សេះ ) ទាហានរថនិងពលថ្មើរជើង អ្នកនិគមទាំងអស់និងពួកអ្នកសិវិរាស្រ្តក៏មកប្រជុំគ្នា ពួកជនទាំងនោះបានឃើញ

ដំរីដែលពួកព្រាហ្មណ៍កំពុងនាំទៅក៏ក្រាបទូលចំពោះព្រះរាជា ( ទ្រង់ព្រះនាម សញ្ជ័យ ) ថា បពិត្រព្រះសម្មតិទេព ដែនរបស់ព្រះអង្គសាបសូន្យហើយ ព្រះវេស្សន្តរជាព្រះរាជបុត្ររបស់ព្រះអង្គ ម្តេចក៏ប្រទានដំរីដ៏ប្រសើររបស់យើង ជាដំរីដែលអ្នកដែនបូជាហើយ ម្តេចក៏ប្រទានដំរីកុញ្ជររបស់យើងដែលជាដំរី មានភ្លុកងទន្ទាំអាចញាំញីសត្រូវបាន ជាសត្វស្គាល់ខេត្តចម្បាំងទាំងអស់ ជាដំរីដ៏ឧត្តម សសុទ្ធ ។ ដំរីនោះមានខ្នងពាសដោយសំពត់កម្ពលលឿង ជាដំរីចុះប្រេង ញាំញីសត្រូវបាន មានភ្លុកដ៏ល្អប្រកបដោយស៊ែ ជាដំរីសប្រហែលនឹងភ្នំកៃលាស ។ ព្រះរាជបុត្ររបស់ព្រះអង្គបានប្រទានដំរីរាជពាហនៈជាយានដ៏ប្រសើរព្រមទាំងស្វេតច្ឆត្រ ព្រមទាំងកម្រាលសម្រាប់ក្រាលលើខ្នង ព្រមទាំងពេទ្យ ព្រមទាំងអ្នករក្សាដំរីទៅជាទានដល់ពួកព្រាហ្មណ៍ ។

[ ២២៦ ] ព្រះរាជបុត្ររបស់ព្រះអង្គនោះ គួរតែឲ្យបាយទឹក សំពត់និងសេនាសនៈ ( ព្រោះថា ) វត្ថុទាំងឯងជារបស់គួរដល់ទាន វត្ថុទាំងឯងជារបស់គួរដល់ព្រាហ្មណ៍ ។ បពិត្រព្រះបាទសញ្ជ័យ ព្រះវេស្សន្តរជាបុត្ររបស់ព្រះអង្គនោះ ជាព្រះឱរសកើតក្នុងវង្សរបស់ព្រះអង្គ ជាអ្នកញាំងពួកអ្នកសិវិរាស្ត្រឲ្យចម្រើន ម្តេចក៏ចែកដំរីទៅឲ្យព្រាហ្មណ៍ ។ ថាបើព្រះអង្គនឹងមិនធ្វើតាមសំដីរបស់ពួកអ្នកដែនសិវិនេះទេ មុខជាពួកអ្នកសិវិរាស្ត្រធ្វើព្រះអង្គព្រមទាំងព្រះរាជបុត្តឲ្យឋិតនៅក្នុងកណ្តាប់ដៃមិនខាន ។

[ ២២៧ ] ( ព្រះរាជា... ) ជនបទសាបសូន្យទៅចុះ ទាំងដែនទៀតក៏វិនាសទៅចុះ យើងនឹងមិនបណ្តេញរាជបុត្តដែលជាអ្នកមិនប្រទូស្ត ឲ្យចេញ

ចាកដែនរបស់ខ្លួន តាមសំដីពួកអ្នកសិវិរាស្ត្រទេ ដ្បិតកូនប្រុសនេះពិតជាកើតអំពីទ្រូងរបស់យើង ។ ជនបទសាបសូន្យទៅចុះ ទាំងដែនទៀតក៏វិនាសទៅចុះ យើងនឹងមិនបណ្តេញរាជបុត្ត ដែលជាអ្នកមិនប្រទូស្ត ឲ្យចេញចាកដែនរបស់ខ្លួនតាមសំដីពួកអ្នកសិវិរាស្ត្រទេ ដ្បិតកូនប្រុសនេះពិតជាកើតអំពីខ្លួនរបស់យើង ។ មួយទៀតយើងមិនគួរប្រទូស្តចំពោះកូនយើងនោះទេ ព្រោះថាកូនយើងនោះជាអ្នកមានសីលនិងវត្តដ៏ប្រសើរ តំណិះដំណៀលនឹងមានដល់យើងផង យើងត្រូវសោយបាបច្រើនផង យើងនឹងសម្លាប់វេស្សន្តរជាកូនដោយគ្រឿងសស្ត្រាដូចម្តេចបាន ។

[ ២២៨ ] ( ពួកអ្នកដែន... ) សូមព្រះអង្គកុំសម្លាប់ព្រះរាជបុត្តនោះដោយដំបងឬគ្រឿងសស្ត្រាឡើយ ព្រោះព្រះរាជបុត្តនោះ មិនគួរដល់ចំណងទេ ព្រះអង្គគ្រាន់តែបណ្តេញព្រះរាជបុត្តនោះចេញអំពីដែនទៅចុះ សូមឲ្យព្រះរាជបុត្តនោះទៅគង់នៅឯវង្កបព៌តចុះ ។

[ ២២៩ ] ( ព្រះរាជា... ) ថាបើពួកអ្នកដែនសិវិ មានចំណង់បែបនេះហើយយើងក៏មិនអាចបន្ទាបង់ចំណង់នេះបានទេ តែសូមឲ្យកូនយើងនោះនៅបរិភោគកាមបានមួយរាត្រីនេះសិនចុះ ។ នាកាលរាត្រីនោះអស់ហើយ ព្រះអាទិត្យរះឡើង ទើបសូមឲ្យពួកអ្នកសិវិរាស្ត្រព្រមព្រៀងគ្នាបណ្តេញកូនរបស់យើងនោះចេញអំពីដែនចុះ ។

[ ២៣០ ] នែអាមាត្យ អ្នកចូរក្រោកឡើង អ្នកចូរប្រញាប់ទៅប្រាប់វេស្សន្តរថា បពិត្រព្រះទេវៈ ពួកអ្នកសិវិរាស្ត្រ ពួកអ្នកនិគម ពួកអ្នកមាន

កេ្តីឈ្មោះ ពួករាជបុត្ត ពួកអ្នកជំនួញនិងពួកព្រាហ្មណ៍មកប្រជុំគ្នាទីងនឹងព្រះអង្គហើយ ។ ពួកទាហានដំរី ទាហាន ( សេះ ) ទាហានរថនិងពលថ្មើរជើង ពួកអ្នកនិគមទាំងអស់និងពួកអ្នកសិវិរាស្រ្តក៏មកប្រជុំគ្នាដែរ លុះរាត្រីនេះអស់ហើយ ព្រះអាទិត្យរះឡើងពួកអ្នកដែនសិវិព្រមព្រៀងគ្នានឹងបណ្តេញព្រះអង្គចាកដែន ។

[ ២៣១ ] អាមាត្យនោះ លុះព្រះបាទសិវិទ្រង់បញ្ជូនទៅ ក៏ប្រញាប់ប្រញាល់ងូតទឹកកក់ក្បាល ពាក់គ្រឿងប្រដាប់ដៃ ស្លៀកសំពត់ល្អ ប្រោះព្រំដោយខ្លឹមចន្ទន៍ ពាក់កុណ្ឌលកែវមណីចូលទៅកាន់ព្រះរាជនិវេសន៍នៃព្រះបាទវេស្សន្តរដែលជាទីបុរីរម្យ ។ អាមាត្យនោះបានឃើញព្រះរាជកុមារ ( វេស្សន្តរ ) កំពុងរីករាយក្នុងបុរីរបស់ព្រះអង្គនោះដ៏កុះករដោយពួកអាមាត្យដូចព្រះវាសវៈរបស់ទេវតាជាន់ត្រៃត្រិង្ស ។

[ ២៣២ ] អាមាត្យនោះ ប្រញាប់ប្រញាល់ទៅក្នុងបុរីនោះហើយ ក្រាបទូលព្រះបាទវេស្សន្តរថា បពិត្រព្រះអង្គដ៏ប្រសើរក្នុងរថ ទូលព្រះបង្គំជាខ្ញុំនឹងក្រាបទូលសេចក្តីទុក្ខរបស់ព្រះអង្គ សូមព្រះអង្គកុំខ្ញាល់នឹងទូលព្រះបង្គំជាខ្ញុំឡើយ ។ អាមាត្យនោះលុះថ្វាយបង្គំហើយក៏យំទួញក្រាបបង្គំទូលព្រះរាជាថា បពិត្រមហារាជ ព្រះអង្គរមែងនាំនូវរសជាទីប្រាថ្នាគ្រប់យ៉ាង មកចិញ្ចឹមទូលព្រះបង្គំៗនឹងក្រាបទូលសេចក្តីទុក្ខរបស់ព្រះអង្គ សូមលួងលោមព្រះបាទឲ្យទូលព្រះបង្គំដកដង្ហើមស្រួលក្នុងដំណើរក្រាបទូលនោះ ។ បពិត្រព្រះទេវៈ ពួកអ្នកសិវិរាស្រ្ត ពួកអ្នកនិគម ពួកអ្នកមានកេ្តីឈ្មោះ ពួករាជបុត្ត ពួកអ្នកជំនួញ

និងពួកព្រាហ្មណ៍ ប្រជុំគ្នាទឹងទឹងព្រះអង្គហើយ ។ ពួកទាហានដំរី ទាហាន ( សេះ ) ពលរថនិងពលថ្មើរជើង ព្រមទាំងអ្នកនិគមទាំងអស់និងពួកអ្នកសិវិរាស្រ្តក៏មកប្រជុំគ្នាដែរ ។ លុះរាត្រីនោះអស់ហើយ ព្រះអាទិត្យក៏រះឡើង ពួកអ្នកសិវិរាស្រ្តព្រមព្រៀងគ្នាទឹងបណ្តេញព្រះអង្គចាកដែន ។

[ ២៣៣ ] ( ព្រះវេស្សន្តរ... ) ព្រោះដំណើរដូចម្តេចបានជាពួកអ្នកសិវិរាស្រ្តទឹងទឹងយើង ដ្បិតយើងរកមិនឃើញអំពើអាក្រក់ទេ ម្នាលអាមាត្យ អ្នកចូរប្រាប់ដំណើរនោះដល់យើង ព្រោះហេតុអ្វីបានជាគេបណ្តេញ ។

[ ២៣៤ ] ( អាមាត្យ... ) ពួកអ្នកមានកេរ្តិ៍ឈ្មោះ ពួករាជបុត្ត ពួកអ្នកជំនួញ ពួកព្រាហ្មណ៍ ពួកទាហានដំរី ទាហាន ( សេះ ) ពលរថនិងពលថ្មើរជើងទឹងទឹងព្រះអង្គ ព្រោះតែការប្រទានដំរី ហេតុនោះបានជាគេបណ្តេញព្រះអង្គ ។

[ ២៣៥ ] ( ព្រះវេស្សន្តរ... ) យើងចង់ឲ្យបេះដូងឬភ្នែកផង ទ្រព្យជាខាងក្រៅរបស់យើង គឺប្រាក់ មាស កែវមុក្តា កែវពិទូរ្យនិងកែវមណីជាប្រយោជន៍អ្វី បើយើងបានឃើញស្មូមមកសុំដៃស្តាំឬដៃឆ្វេងគួរតែឲ្យ មិនគប្បីរំភើបទេ ( ព្រោះថា ) ចិត្តរបស់យើងរីករាយក្នុងការឲ្យ ( ទាន ) ។ ពួកអ្នកសិវិរាស្រ្តទាំងអស់នោះចង់បណ្តេញឬចង់សម្លាប់យើងក៏ដោយចុះ យើងនឹងមិនវៀរចាកការឲ្យ ( ទាន ) ទេ អ្នកដែនទាំងអស់ចង់កាត់យើងជាប្រាំពីរកំណាត់ក៏ដោយចុះ ។

[២៣៦] ( អាមាត្យ... ) ពួកអ្នកសិវិរាស្រ្តនិងពួកអ្នកនិគម ប្រជុំ

គ្មានិយាយអំពីព្រះអង្គយ៉ាងនេះថា ពួកអ្នកទោសត្រូវនិរទេសតែងទៅតាមផ្លូវទន្ទេកោន្តិមារាណា ព្រះបាទវេស្សន្តរដែលមានវត្តល្អ ចូរយាងសំដៅទៅកាន់ភ្នំអារញ្ញភាគតាមផ្លូវទន្ទេកោន្តិមារានោះចុះ ។

[ ២៣៧ ] ( ព្រះវេស្សន្តរ... ) ពួកជនអ្នកប្រទូស្តតែងទៅតាមផ្លូវណា យើងនឹងទៅតាមផ្លូវនោះឯង តែសូមឲ្យអ្នកទាំងឡាយអត់ទោសឲ្យយើងបានមួយយប់មួយថ្ងៃចាំយើងឲ្យទានសិន ។

[ ២៣៨ ] ព្រះរាជាទ្រង់ត្រាស់ហៅព្រះនាងមទ្រីទេវី ដែលមានអវយវៈល្អទាំងអស់នោះមកប្រាប់ថា ទ្រព្យស្រូវណាមួយដែលយើងឲ្យដល់នាងនៅមានក្តី ប្រាក់មាសកែវមុក្តាកែវពិទូរ្យណាដ៏ច្រើនក្តី ទ្រព្យណាជារបស់ព្រះបិតានាងក្តី នាងគប្បីកប់ទ្រព្យទាំងអស់នោះទុកចុះ ។

[ ២៣៩ ] ព្រះរាជបុត្រីទ្រង់ព្រះនាមមទ្រី ដែលមានអវយវៈល្អទាំងអស់បានក្រាបបង្គំទូលសួរព្រះរាជានោះថា បពិត្រព្រះទេវៈ ខ្ញុំម្ចាស់នឹងកប់ក្នុងទីណា ខ្ញុំម្ចាស់ក្រាបទូលសួរហើយ សូមព្រះអង្គប្រាប់ដំណើរនោះ ។

[ ២៤០ ] ( ព្រះវេស្សន្តរ... ) ម្នាលនាងមទ្រី នាងគួរឲ្យទានចំពោះអ្នកមានសីលទាំងឡាយតាមសមគួរ ព្រោះថាទីពឹងរបស់សព្វសត្វដទៃក្រៅអំពីទានមិនមានទេ ។

[ ២៤១ ] ម្នាលនាងមទ្រី នាងត្រូវមេត្តាបុត្ត ព្រះមាតាក្មេកនិងព្រះបិតាក្មេក មួយទៀតបើអ្នកណាសំគាល់ថានឹងធ្វើជាប្តីនាង នាងចូរបម្រើអ្នកនោះដោយគោរពចុះ ។ បើគ្មានគេសំគាល់ថានឹងធ្វើជាប្តីនាងទេ កាលនាងព្រាត់

ប្រាសអំពីយើងទៅហើយនាងចូរស្វែងរកប្តីដទៃទៀតចុះ កុំឲ្យនាងលំបាកព្រោះព្រាត់ប្រាសអំពីយើងឡើយ ។

[ ២៤២ ] ព្រោះយើងនឹងទៅកាន់ព្រៃ ប្រកបដោយម្រឹគសាហាវពន្លឹក សេចក្តីសង្ស័យនឹងជីវិតរមែងមានដល់យើងដែលនៅម្នាក់ឯងក្នុងព្រៃធំ ។

[ ២៤៣ ] ព្រះរាជបុត្រី ទ្រង់ព្រះនាមមទ្រី មានអវយវៈល្អទាំងអស់ នាងបានក្រាបទូលព្រះបាទវេស្សន្តរនោះថា ប្តីក៏ព្រះអង្គមានព្រះបន្ទូលនូវព្រះវាចាដែលមិនធ្លាប់មាន ព្រះអង្គមានព្រះបន្ទូលនូវព្រះវាចាដ៏អាក្រក់អ្វីម្ល៉េះ ។ បពិត្រមហារាជ ដំណើរនោះមិនត្រូវតាមធម៌ទេដ្បិតព្រះអង្គទ្រង់ស្តេចយាងទៅតែមួយអង្គឯង បពិត្រក្សត្រិយ៍ ព្រះអង្គស្តេចយាងទៅតាមផ្លូវណា ខ្ញុំម្ចាស់នឹងទៅតាមផ្លូវនោះដែរ ។ សេចក្តីស្លាប់ជាមួយនឹងព្រះអង្គក្តី សេចក្តីរស់នៅតែព្រាត់ប្រាសចាកព្រះអង្គក្តី សេចក្តីស្លាប់នោះឯងប្រសើរជាង ខ្ញុំម្ចាស់រស់នៅតែព្រាត់ប្រាសចាកព្រះអង្គមិនប្រសើរទេ ។ ខ្ញុំម្ចាស់នឹងដុតភ្លើង ឲ្យមានអណ្តាតឆេះមូលទ្រលោម សេចក្តីស្លាប់នៅក្នុងភ្លើងនោះឯង ប្រសើរជាង ខ្ញុំម្ចាស់រស់នៅតែព្រាត់ប្រាសចាកព្រះអង្គមិនប្រសើរទេ ។ មេដំរីតែងដើរតាមដំរីឈ្មោលដែលមានភ្លុកល្អដែលនៅក្នុងព្រៃ កាលត្រាច់ទៅក្នុងជ្រោះជ្រលង ភ្នំស្មើខ្លះ មិនស្មើខ្លះយ៉ាងណាមិញ ។ ខ្ញុំម្ចាស់នឹងនាំបុត្តទាំងឡាយដើរតាមក្រោយព្រះអង្គយ៉ាងនោះដែរ ខ្ញុំម្ចាស់ជាស្រីដែលព្រះអង្គចិញ្ចឹមបានដោយងាយ មិនមែនជាស្រីដែលព្រះអង្គចិញ្ចឹមបានដោយក្រទេ ។

[ ២៤៤ ] ព្រះអង្គកាលទតឃើញកុមារទាំងនេះដែលមានសំឡេងពីរោះ

និយាយសំដីជាទីស្រឡាញ់ អន្ទ្រយក្បែរគុម្ពឈើនឹងមិនរលីកពជសម្បត្តិ ។ ព្រះអង្គកាលទតឃើញកុមារទាំងនេះ មានសំឡេងពីរោះ និយាយសម្តីជាទីស្រឡាញ់កំពុងលេងក្បែរគុម្ពឈើនឹងមិនរឭករាជសម្បត្តិ ។ ព្រះអង្គកាលទតឃើញកុមារទាំងនេះមានសំឡេងពីរោះ និយាយពាក្យជាទីស្រឡាញ់ក្នុងអាស្រមជារមណីយដ្ឋាន នឹងមិនរឭករាជសម្បត្តិ ។ ព្រះអង្គកាលទតឃើញរាជកុមារទាំងនេះមានសំឡេងពីរោះ និយាយពាក្យជាទីស្រឡាញ់ កំពុងលេងក្បែរអាស្រមជាទីត្រេកអរនឹងមិនរឭករាជសម្បត្តិ ។ ព្រះអង្គកាលទតឃើញកុមារទាំងនេះពាក់កម្រងផ្កា មានខ្លួនប្រដាប់ហើយក្នុងអាស្រមជារមណីយដ្ឋាន នឹងមិនរឭករាជសម្បត្តិ ។ ព្រះអង្គកាលទតឃើញកុមារទាំងនេះពាក់កម្រងផ្កា មានខ្លួនប្រដាប់ហើយកំពុងលេងក្បែរអាស្រមដែលជាទីត្រេកអរ នឹងមិនរឭករាជសម្បត្តិ ។ កាលណាព្រះអង្គទតឃើញកុមារ ពាក់កម្រងផ្កាកំពុងរាំក្នុងអាស្រមជារមណីយដ្ឋាន នឹងមិនរឭករាជសម្បត្តិ ។ កាលណាព្រះអង្គទតឃើញកុមារពាក់កម្រងផ្កាកំពុងរាំលេងក្នុងអាស្រមជាទីត្រេកអរ នឹងមិនរឭករាជសម្បត្តិ ។ កាលណាព្រះអង្គទតឃើញដំរីធំជាកុញ្ជរជាតិ មានអាយុ ៦០ ឆ្នាំត្រាច់ទៅក្នុងព្រៃតែម្នាក់ឯង នឹងមិនរឭករាជសម្បត្តិ ។ កាលណាព្រះអង្គទតឃើញដំរីធំ ជាកុញ្ជរជាតិ មានអាយុ ៦០ ឆ្នាំ ត្រាច់ទៅមករាល់ល្ងាចរាល់ព្រឹកនឹងមិនរឭករាជសម្បត្តិ ។ កាលណាដំរីធំ ជាកុញ្ជរជាតិ មានអាយុ ៦០ ឆ្នាំ កាលដើរទៅខាងមុខនៃហ្វូងដំរីញីនិងហ្វូងដំរីឈ្មោលហើយបន្លឺកោញ្ចនាទ ព្រះអង្គបានទ្រង់ព្រះសណ្តាប់ដំរីបន្លឺកោញ្ចនាទនោះហើយនឹងមិនរឭក

រាជសម្បត្តិ ។ កាលណាព្រះអង្គទតឃើញជនព្រៃសងខាងផ្លូវ ជាទីឲ្យសេចក្តីប្រាថ្នាក្នុងព្រៃដ៏ដេរដាសដោយម្រឹគសាហាវ នឹងមិនរឭករាជសម្បត្តិ ។ ព្រះអង្គទតឃើញម្រឹគជាបញ្ចមាលិនីដើរមក នឹងឃើញពួកកិន្នរដែលកំពុងរាំក្នុងវេលាល្ងាចនឹងមិនរឭករាជសម្បត្តិ ។ កាលណាព្រះអង្គឮសូរសំឡេងគឹកកងនៃទន្លេកំពុងហូរទៅផង ឮចម្រៀងនៃពួកកិន្នរផង នឹងមិនរឭករាជសម្បត្តិ ។ កាលណាព្រះអង្គឮសូរសំឡេងគឹកកងនៃសត្វមៀមដែលត្រាច់ក្នុងញកនៃភ្នំ នឹងមិនរឭករាជសម្បត្តិ ។ កាលណាព្រះអង្គឮសូរសំឡេងគឹកកងនៃ ម្រឹគសាហាវក្នុងព្រៃ គឺរាជសីហ៍ ខ្លាធំ រមាស គោព្រៃ នឹងមិនរឭករាជសម្បត្តិ ។ កាលណាព្រះអង្គទតឃើញក្ងោកឈ្មោលដែលមានពួកក្ងោកញីចោមរោម ជាសត្វដេរដាសដោយសំណុំកន្ទុយទំលើកំពូលភ្នំកំពុងពែនពន់ នឹងមិនរឭករាជស-ម្បត្តិ ។ កាលណាព្រះអង្គទតឃើញក្ងោកឈ្មោល ដែលមានក្ងោកញីចោមរោម ជាអណ្ឌជាតិ មានក្នែកដ៏វិចិត្រកំពុងពែនពន់ នឹងមិនរឭករាជសម្បត្តិ ។ កាលណាព្រះអង្គទតឃើញក្ងោកឈ្មោលដែលមានក្ងោកញីចោមរោម ជាសត្វមានផ្នត់កខៀវ មានកំប៉ោយកំពុងពែនពន់ នឹងមិនរឭករាជសម្បត្តិ ។ កាលណាព្រះអង្គទតឃើញដើមឈើទាំងឡាយ មានផ្ការីកក្នុងហេមន្តរដូវ ផ្សព្វផ្សាយដោយក្លិនក្រអូប នឹងមិនរឭករាជសម្បត្តិ ។ កាលណាព្រះអង្គទតឃើញផែនដីមានស្មៅខៀវខ្ចី ក្នុងខែខាងក្នុងហេមន្តរដូវដ៏ដេរដាសដោយមេភ្លៀង នឹងមិនរឭករាជសម្បត្តិ ។ កាលណាព្រះអង្គទតឃើញដើមឈើទាំងឡាយ ដែលមានផ្ការីកស្គុសស្គាយក្នុងហេមន្តរដូវផង ដើមខ្វែងគន់និងឈើដែលមានត្រួយ មាន

ស្ពឹកក្រហមផង ដើមលោទនិងដើមឈូកមានផ្ការីក ផ្សព្វផ្សាយក្លិនក្រអូបផង នឹងមិនរឭករាជសម្បត្តិ ។ កាលណាព្រះអង្គទតឃើញព្រៃ មានផ្ការីកក្នុងខែខាងក្នុងហេមន្តរដូវផង ឈូកទាំងឡាយមានផ្កាជ្រុះហើយផង នឹងមិនរឭករាជសម្បត្តិ ។

**ចប់ ហិមវន្ត ។**

[ ២៤៥ ] ( អភិសម្ពុទ្ធគាថា ) ព្រះនាងផុស្សតី ជារាជបុត្រីមានយស បានទ្រង់ព្រះសណ្ដាប់ការចរចា នៃព្រះរាជបុត្តនិងព្រះរាជសុណិសាទាំងនោះ ហើយទ្រង់ព្រះកន្សែង មុខគួរអាណោចអធម្មថា ឱអាត្មាអញគួរតែបរិភោគថ្នាំពិស ឬអាត្មាអញលោតទម្លាក់ខ្លួនក្នុងជ្រោះ ... ពុំនោះ ចង ( ក ) នឹងខ្សែ ( ឲ្យស្លាប់ ) ប្រសើរជាង ។ ម្ដេចឡើយក៏ពួកអ្នកសិវិរាស្ត្រ បណ្ដេញបាវេស្សន្តរជាកូនអញដែលជាអ្នកមិនប្រទូស្ត ។ ម្ដេចឡើយក៏ពួកអ្នកសិវិរាស្ត្របណ្ដេញបាវេស្សន្តរជាកូនអញដែលជាអ្នកចេះចប់ត្រៃវេទជាម្ចាស់ទាន ជាអ្នកគួរដល់សូម ឥតមានសេចក្ដីកំណាញ់ ជាអ្នកមិនប្រទូស្ត ។ ម្ដេចឡើយក៏ពួកអ្នកសិវិរាស្ត្របណ្ដេញបាវេស្សន្តរ ជាកូនអញដែលពួកព្រះរាជាប្រទេសដទៃបូជា មានកិត្តិយស ជាអ្នកមិនប្រទូស្ត ។ ម្ដេចឡើយក៏ពួកអ្នកសិវិរាស្ត្របណ្ដេញបាវេស្សន្តរជាកូនអញដែលជាបុគ្គលចិញ្ចឹមមាតានិងបិតា ជាអ្នកគោរពចំពោះបុគ្គលជាធំក្នុងត្រកូល ជាអ្នកមិនប្រទូស្ត ។ ម្ដេចឡើយក៏ពួកអ្នកសិវិរាស្ត្របណ្ដេញបាវេស្សន្តរជាកូនអញ ជាប្រយោជន៍ដល់ព្រះរាជា ជាប្រយោជន៍ដល់

ទេវតា ជាប្រយោជន៍ដល់ពួកញាតិនិងសម្លាញ់ ជាប្រយោជន៍ដល់អ្នកដែនទាំងអស់ ជាអ្នកមិនប្រទូស្ត ។

[ ២៤៦ ] ដែនរបស់ព្រះអង្គមុខជានឹងសាធារណ៍ដល់ជនទាំងឡាយដូចផ្ចិតឃ្មុំដែលមេឃ្មុំហើរចោល ពុំនោះដូចផ្លែស្វាយដែលជ្រុះលើផែនដី ( ព្រោះ ) ពួកអ្នកសិវិរាស្ត្របណ្តេញវេស្សន្តរ ជាអ្នកមិនប្រទូស្ត ។ ព្រះអង្គដែលពួកអាមាត្យបោះបង់ហើយ ជាព្រះរាជាម្នាក់ឯងរមែងនឿយព្រួយ ដូចហង្សដែលអស់ស្លាបលើភក់ដែលគ្មានទឹក ។ បពិត្រមហារាជ ព្រោះហេតុនោះបានជាខ្ញុំម្ចាស់ក្រាបទូលព្រះអង្គ កុំឲ្យប្រយោជន៍កន្លងផុតព្រះអង្គឡើយ សូមព្រះអង្គកុំបំបរបង់វេស្សន្តរដែលជាអ្នកមិនប្រទូស្តនោះ តាមសម្តីពួកអ្នកសិវិរាស្ត្រឡើយ។

[ ២៤៧ ] ( ព្រះរាជា... ) យើងបណ្តេញបាវេស្សន្តរដែលជាទង់ជ័យនៃពួកអ្នកសិវិរាស្ត្រ ឈ្មោះថាធ្វើនូវសេចក្តីគោរពចំពោះបវេណីធម៌ ទុកជាបាវេស្សន្តរជាទីស្រឡាញ់ដ៏លើសជាងជីវិតរបស់យើង ក៏យើងនៅតែបណ្តេញបាវេស្សន្តរដែលជាកូនរបស់យើងមិនខាន ។

[ ២៤៨ ] ( ព្រះនាងផុស្សតីទេវី... ) ក្នុងកាលមុនចុងទង់ជ័យទាំងឡាយ ដូចជាផ្កាកណិការរីករមែងទៅតាមបាវេស្សន្តរណាកាលទៅ ( កាន់ឧទ្យានជាដើម ) តែក្នុងថ្ងៃនេះបាវេស្សន្តរនោះនឹងទៅតែម្នាក់ឯង ។ ក្នុងកាលមុនចុងទង់ជ័យទាំងឡាយដូចជាព្រៃផ្កាកណិការ រមែងទៅតាមបាវេស្សន្តរណាកាលទៅ ( កាន់ឧទ្យានជាដើម ) តែក្នុងថ្ងៃនេះបាវេស្សន្តរនោះនឹងទៅតែម្នាក់

ឯង ។ ក្នុងកាលមុនពលទាំងឡាយ ដូចជាដើមកណិការរីក រមែងទៅតាមបាវេស្សន្តរណាកាលទៅ ( កាន់ឧទ្យានជាដើម ) តែក្នុងថ្ងៃនេះបាវេស្សន្តរនោះនឹងទៅតែម្នាក់ឯង ។ ក្នុងកាលមុនពលទាំងឡាយដូចជាព្រៃផ្កាកណិការរមែងទៅតាមបាវេស្សន្តរណា កាលទៅ ( កាន់ឧទ្យានជាដើម ) តែក្នុងថ្ងៃនេះបាវេស្សន្តរនោះនឹងទៅតែម្នាក់ឯង ។ ពួកសេនាស្លៀកសំពត់កម្ពល មានពណ៌លឿងដែលកើតក្នុងដែនគន្ធារៈ មានរស្មីដូចជាសម្បុរមេភ្លៀងរមែងទៅតាមបាវេស្សន្តរណាកាលទៅ ( កាន់ឧទ្យានជាដើម ) តែក្នុងថ្ងៃនេះបាវេស្សន្តរនោះនឹងទៅតែម្នាក់ឯង ។ ក្នុងកាលមុនបាវេស្សន្តរណាទៅដោយដំរី ដោយសាលៀននិងរថ តែក្នុងថ្ងៃនេះព្រះរាជាវេស្សន្តរនោះ នឹងដើរទៅដូចម្តេចបាន ។ បាវេស្សន្តរ ដែលមានអវយវៈលាបដោយខ្លឹមចន្ទន៍ ធ្លាប់ភ្ញាក់រឭកដោយរបាំនិងចម្រៀង ( ស្លៀកដណ្តប់ ) ស្បែកខ្លាទាំងក្រចកគ្រោតគ្រាតផង រែកអម្រែកទម្ងន់មួយខារិផងដូចម្តេចកើត ។ ព្រោះហេតុដូចម្តេច ក៏ជនទាំងឡាយមិននាំសំពត់កាសាវៈផង ស្បែកខ្លាផងដើម្បីបាវេស្សន្តរកាលចូលទៅក្នុងព្រៃធំ ព្រោះហេតុអ្វីក៏ជនទាំងឡាយមិនត្បាញសំពត់សម្បកឈើថ្វាយ ។ ពួកជនជារាជ-បព្វជិតនឹងស្លៀកសំពត់សម្បកឈើ ដូចម្តេចកើត នាងមទ្រីនឹងស្លៀកសំពត់ដែលក្រងដោយស្បូវភ្លាំងដូចម្តេចកើត ។ នាងមទ្រីធ្លាប់តែស្លៀកសំពត់ដែលកើតក្នុងដែនកាសីផង សំពត់ដែលកើតក្នុងដែនខោមៈនិងដែនកោទុម្ពរៈផង ឥឡូវនេះមកស្លៀកសំពត់ដែលក្រងដោយស្បូវភ្លាំង តើនឹងធ្វើអ្វីកើត ។ នាងមទ្រីនោះមានអវយវៈគួរសរសើរ ធ្លាប់ទៅដោយវព្រះសាលៀននិងរថ ក្នុង

ថ្ងៃនេះនឹងដើរដោយជើងតាមផ្លូវដូចម្ដេចបាន ។ នាងមទ្រីណា មានផ្ទៃដៃដ៏ទន់ មានចិត្តញាប់ញ័រ ធ្លាប់ឋិតនៅក្នុងសេចក្ដីសុខ ថ្ងៃនេះនាងមទ្រីមានអវយវៈគួរសរសើរនោះនឹងដើរដោយជើងតាមផ្លូវដូចម្ដេចបាន ។ នាងមទ្រីណា មានផ្ទៃជើងដ៏ទន់ មានចិត្តញាប់ញ័រធ្លាប់ឋិតនៅក្នុងសេចក្ដីសុខ នាងមទ្រីមានអវយវៈគួរសរសើរនោះ តែងពាក់ស្បែកជើងមាសហើយដើរទៅ ថ្ងៃនេះនឹងដើរដោយជើងទៅតាមផ្លូវដូចម្ដេចបាន ។ នាងមទ្រីណាតែងពាក់កម្រងផ្កា ដើរទៅខាងមុខនៃស្ត្រីមួយពាន់ ថ្ងៃនេះនាងមទ្រីមានអវយវៈគួរសរសើរនោះ នឹងដើរទៅព្រៃតែម្នាក់ឯងដូចម្ដេចបាន ។ នាងមទ្រីណាដែលនៅក្នុងបុរី គ្រាន់តែបានឮសំឡេងចចកលូវៀយៗ រមែងតក់ស្លុត ថ្ងៃនេះនាងមទ្រីមានអវយវៈគួរសរសើរនោះជាស្ត្រីវន្ធត់នឹងទៅព្រៃដូចម្ដេចបាន ។ នាងមទ្រីណាគ្រាន់តែបានឮសំឡេងមៀមជាកោសិយគោត្ត កាលស្រែកបន្លឺក៏ខ្លាចរន្ធត់ ដូចមេមត់ដែលខ្មោចចូល ថ្ងៃនេះនាងមទ្រីមានអវយវៈគួរសរសើរនោះ ជាស្ត្រីមានសេចក្ដីរន្ធត់នឹងដើរទៅព្រៃដូចម្ដេចបាន ។ ខ្ញុំម្ចាស់លុះមកកាន់បុរីនេះសូន្យទទេហើយ មុខជានឹងឆេះដោយសេចក្ដីទុក្ខអស់កាលយូរដូចមេបក្សីដែលបាត់កូនឃើញតែសម្បុកសូន្យទទេដូច្នោះ ។ ខ្ញុំម្ចាស់កាលមិនឃើញកូន ( ទាំងពីរ ) ហើយមុខជានឹងស្គមស្លេកស្លាំងដូចជាមេបក្សីដែលបាត់កូន ឃើញតែសម្បុកសូន្យទទេដូច្នោះ ។ ខ្ញុំម្ចាស់កាលមិនឃើញកូន ( ទាំងពីរ ) ជាទីស្រឡាញ់ហើយមុខជានឹងស្ទុះទៅតាមទីនោះៗដូចជាមេបក្សីដែលបាត់កូន ឃើញតែសម្បុកសូន្យទទេដូច្នោះ ។ ខ្ញុំម្ចាស់លុះមកកាន់បុរីនេះសូន្យទទេហើយ នឹងឆេះដោយសេចក្ដីទុក្ខអស់កាល

យូរដូចមេអកដែលបាត់កូនឃើញតែសម្បុកសូន្យទទេដូច្នោះ ។ ខ្ញុំម្ចាស់កាលមិនឃើញកូន ( ទាំងពីរ ) ជាទីស្រឡាញ់ហើយមុខជានឹងស្គមស្លេកស្លាំងដូចជាមេអកដែលបាត់កូន ឃើញតែសម្បុកសូន្យទទេដូច្នោះ ។ ខ្ញុំម្ចាស់កាលមិនឃើញកូន ( ទាំងពីរ ) ជាទីស្រឡាញ់ហើយមុខជានឹងស្ទុះទៅតាមទីនោះៗដូចជាមេអកដែលបាត់កូនឃើញតែសម្បុកសូន្យទទេដូច្នោះ ។ ខ្ញុំម្ចាស់នោះមកកាន់បុរីនេះសូន្យទទេហើយ មុខជានឹងឆេះដោយសេចក្តីទុក្ខអស់កាលយូរដោយពិតដូចជាមេចាក្រពាកដែល ( សំកុក ) លើភក់មិនមានទឹក ។ ខ្ញុំម្ចាស់នោះមិនឃើញកូន ( ទាំងពីរ ) ជាទីស្រឡាញ់ហើយ មុខជានឹងស្គមស្លេកស្លាំងដោយពិតដូចជាមេចាក្រពាកដែល ( សំកុក ) នៅលើភក់មិនមានទឹក ។ ខ្ញុំម្ចាស់កាលមិនឃើញកូន ( ទាំងពីរ ) ជាទីស្រឡាញ់ហើយមុខជានឹងស្ទុះទៅតាមទីនោះៗដោយពិតដូចជាមេចាក្រពាកដែលនៅលើភក់មិនមានទឹក ។ កាលបើខ្ញុំម្ចាស់យំរៀបរាប់យ៉ាងនេះហើយព្រះអង្គនៅតែបណ្តេញរាជបុត្តនោះដែលជាអ្នកមិនប្រទូស្តឲ្យចេញចាកដែន ខ្ញុំម្ចាស់ទំនងជានឹងលះបង់ជីវិតមិនខាន ។

[ ២៤៩ ] ( អភិសម្ពុទ្ធគាថា ) ពួកកញ្ញារបស់ព្រះបាទសិវិទាំងអស់ដែលនៅក្នុងបុរី លុះបានឮទំនួញរៀបរាប់នៃព្រះនាងផុស្សតីនោះហើយ ក៏មកជួបជុំគ្នាផ្គងដើមដៃកន្ទក់កន្ទេញ ។ កូននិងប្រពន្ធទាំងឡាយក៏ដួលដេកក្នុងព្រះរាជនិវេសន៍ព្រះបាទវេស្សន្តរ ដូចដើមឈើដែលត្រូវខ្យល់បក់បោកខ្ទេចខ្ទី ។ ពួកស្រីស្នំ ពួករាជ កុមារ ពួកអ្នកជំនួញនិងពួកព្រាហ្មណ៍ ផ្គងដើមដៃកន្ទក់កន្ទេញក្នុងព្រះរាជនិវេសន៍ព្រះបាទវេស្សន្តរ ។ ពួកពលដំរី ពល ( សេះ ) ពល

រថ ពលច្បើរជើងផ្គងដើមដែកទ្ទក់កន្ទេញក្នុងព្រះរាជនិវេសន៍ព្រះបាទវេស្សន្តរ ។ រាត្រីនោះអស់ហើយព្រះអាទិត្យរះឡើង គ្រានោះព្រះបាទវេស្សន្តរស្តេចចូលទៅដើម្បីឲ្យទាន ។ មានព្រះរាជបញ្ជាថា អ្នកទាំងឡាយ ចូរឲ្យសំពត់ដល់ពួកជនដែលត្រូវការសំពត់ ឲ្យសុរាដល់ពួកអ្នកលេង ឲ្យភោជនដល់ពួកអ្នកត្រូវការដោយភោជន ចូរឲ្យដោយប្រពៃចុះ ។ អ្នកទាំងឡាយកុំបៀតបៀនពួកវណិព្វកៈដែលមកក្នុងទីនេះតិចតួចឡើយ អ្នកទាំងឡាយចូរញ៉ាំងពួកវណិព្វកៈឲ្យស្កប់ស្កល់ដោយបាយនិងទឹក ពួកវណិព្វកៈដែលយើងបានឲ្យរួចហើយចូរទៅចុះ ។ ( លំដាប់នោះស្រាប់តែសំឡេងគ្រលួចយ៉ាងពន្លឹកប្រព្រឹត្តទៅក្នុងព្រះនគរនោះថា ពួកអ្នកសិវិរាស្ត្របានបណ្តេញព្រះអង្គព្រោះតែឲ្យទាន ឥឡូវនេះព្រះអង្គឲ្យទានទៀតហើយ ) ។

[ ២៥០ ] កាលមហារាជព្រះអង្គញ៉ាំងពួកអ្នកសិវិរាស្ត្រឲ្យចម្រើន ទ្រង់យានចេញទៅ វណិព្វកៈទាំងនោះក៏ដួលចុះដូចជាបុគ្គលស្រវឹងឬដូចជាបុគ្គលនឿយហត់ខ្លាំង ( ដោយពាក្យថា ) ម្នាលអ្នកទាំងឡាយដ៏ចម្រើន ពួកអ្នកសិវិរាស្ត្របានបណ្តេញព្រះបាទវេស្សន្តរដែលជាអ្នកមិនប្រទូស្ត ឲ្យចេញចាកដែនដូចគេកាត់ផ្តាច់ដើមឈើជាឈើឲ្យផ្លែផ្សេងៗ ។ម្នាលអ្នកទាំងឡាយដ៏ចម្រើន ពួកអ្នកសិវិរាស្ត្របានបណ្តេញព្រះបាទវេស្សន្តរដែលជាអ្នកមិនប្រទូស្ត ឲ្យចេញចាកដែនដូចជាគេកាត់ចោលនូវដើមឈើជាឈើទ្រទ្រង់ផ្លែផ្សេងៗ ។ ម្នាលអ្នកទាំងឡាយដ៏ចម្រើន ពួកអ្នកសិវិរាស្ត្របានបណ្តេញព្រះបាទវេស្សន្តរដែលជាអ្នកមិនប្រទូស្តឲ្យចេញចាកដែនដូចជាគេកាត់ដើមឈើ ជាឈើឲ្យសេចក្តីប្រាថ្នា

គ្រប់យ៉ាង ។ ម្នាលអ្នកទាំងឡាយដ៏ចម្រើន ពួកអ្នកសិវិរាស្ត្របានបណ្តេញព្រះបាទវេស្សន្តរដែលជាអ្នកមិនប្រទូស្តឲ្យចេញចាកដែន ដូចជាគេកាត់ដើមឈើ ជាឈើនាំមកនូវរសជាទីប្រាថ្នាគ្រប់យ៉ាង ។ ពួកជនណាដែលចាស់ក្តី ពួកជនណាដែលនៅក្មេងក្តី ពួកជនណាដែលមានវ័យកណ្តាលក្តី ជនទាំងនោះ កាលដែលមហារាជ ព្រះអង្គញុំាងដែនរបស់ពួកអ្នកសិវិរាស្ត្រឲ្យចម្រើន ទ្រង់យាងចេញទៅក៏ផ្គងដៃកន្ទក់កន្ទេញ ។ កាលមហារាជ ព្រះអង្គញុំាងដែនអ្នកសិវិឲ្យចម្រើនទ្រង់យាងចេញទៅ ពួកពេទ្យចាប់ខ្មោច ពួកអ្នករក្សាស្រីស្នំ និងពួកស្រីស្នំរបស់ព្រះរាជាក៏ផ្គងដើមដៃកន្ទក់កន្ទេញ ។ កាលមហារាជ ព្រះអង្គញុំាងអ្នកដែនសិវិឲ្យចម្រើន ទ្រង់យាងចេញទៅពួកស្ត្រីដែលនៅក្នុងព្រះនគរនោះក៏កន្ទក់កន្ទេញ ។ ពួកព្រាហ្មណ៍ សមណៈនិងវណិព្វកៈដទៃៗផ្គងដើមដៃកន្ទក់កន្ទេញថា ម្នាលគ្នាយើងដ៏ចម្រើន បានឮថា នេះមិនមែនជាធម៌ទេ ។ ដូចយ៉ាងព្រះបាទវេស្សន្តរកាលបូជាក្នុងបុរីរបស់ព្រះអង្គ ទ្រង់យាងចេញចាកដែនរបស់ព្រះអង្គ ព្រោះហេតុតែសម្តីពួកអ្នកសិវិរាស្ត្រ ។ ព្រះបាទវេស្សន្តរទុ៎ះ បានប្រទានដំរីមាតង្គៈប្រាំពីររយដែលស្អិតស្អាង ដោយគ្រឿងអលង្ការទាំងពួង មានខ្សែជង្គន់មាស មានគ្រឿងប្រដាប់ក្បាលជាវិការៈនៃមាស ដែលពួកហ្មដំរីមានលំពែងស្នែងក្របីនិងកង្វេរក្នុងដៃឡើងជិះហើយ ក៏យាងចេញទៅចាកដែនរបស់ព្រះអង្គ ។ ព្រះបាទវេស្សន្តរទុ៎ះ បានប្រទានសេះអាជានីយប្រាំពីររយ ជាសេះសិន្ធពដោយជាតិ ជាពាហនៈមានសន្ទុះលឿន ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកអ្នកជិះសេះកាន់ស៊ែនិងធ្នូឡើងជិះហើយ ក៏

យានចេញចាកដែនរបស់ព្រះអង្គ ។ ព្រះបាទវេស្សន្តរទ្រង់ បានប្រទានរថប្រាំពីររយដែលប្រដាប់ហើយ មានទង់លើកឡើងហើយ បិទបាំងដោយស្បែកខ្លាធំបងនិងស្បែកខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួងដែលពួកនាយសារថី មានធ្នូក្នុងដៃនិងពាក់អាវក្រោះឡើងជិះហើយ ក៏យានចេញចាកដែនរបស់ព្រះអង្គ ។ ព្រះបាទវេស្សន្តរទ្រង់ បានប្រទានស្ត្រីប្រាំពីររយឋិតនៅលើរថមួយម្នាក់ៗ ដែលស្អិតស្អាងហើយ ប្រដាប់ដោយខ្សែជាវិការៈនៃមាសផ្កាមានគ្រឿងប្រដាប់លឿង មានសម្លៀកបំពាក់លឿង ស្អិតស្អាងដោយគ្រឿងអាភរណៈលឿង មានថ្ពាល់និងភ្នែកដ៏ល្អ ញញឹមហើយទើបនិយាយ ជាស្ត្រីមានត្រគាកល្អ មានចង្កេះរៀវ ក៏យានចេញចាកដែនរបស់ព្រះអង្គ ។ ព្រះបាទវេស្សន្តរទ្រង់ បានប្រទានមេគោប្រាំពីររយព្រមទាំងកាជន៍មាសសម្រាប់ត្រងទឹកដោះទាំងអស់ហើយយានចេញចាកដែនរបស់ព្រះអង្គ ។ ព្រះបាទវេស្សន្តរទ្រង់ បានប្រទានខ្ញុំស្រីប្រាំពីររយ ខ្ញុំប្រុសប្រាំពីររយហើយយានចេញចាកដែនរបស់ព្រះអង្គ ។ ព្រះបាទវេស្សន្តរទ្រង់ បានប្រទានដំរី សេះ រថនិងនាងនារីដែលប្រដាប់ហើយក៏យានចេញចាកដែនរបស់ព្រះអង្គ ។ កាលដែលព្រះបាទវេស្សន្តរប្រទានមហាទាន ការស្ញប់ស្ញែង ការព្រឺរោមក៏កើតមាន ក្នុងកាលនោះផែនដីក៏ញាប់ញ័រ ។ ព្រះរាជាដែលមហាជនកំពុងផ្គងអញ្ជលី ទ្រង់យានចេញចាកដែនរបស់ព្រះអង្គដោយហេតុណា ហេតុនោះជាការគួរស្ញប់ស្ញែង គួរព្រឺរោមកើតមានក្នុងកាលនោះ ។

[ ២៥១ ] ( អភិសម្ពុទ្ធគាថា ) គ្រានោះសំឡេងគ្រលួចយ៉ាងពន្លឹក

ប្រព្រឹត្តទៅក្នុងព្រះរាជនិវេសន៍នុ៎ះថា ពួកអ្នកសិវិរាស្រ្តបណ្តេញព្រះវេស្សន្តរ នោះព្រោះតែឲ្យទាន ព្រះវេស្សន្តរនោះនៅតែឲ្យទានទៀត ។

[ ២៥២ ] កាលមហារាជ ព្រះអង្គញ៉ាំងពួកអ្នកសិវិរាស្រ្តឲ្យចម្រើន យានចេញទៅ ពួកវណិព្វកៈទាំងនោះក៏ដួលចុះដូចបុគ្គលស្រវឹង ឬដូចបុគ្គល នឿយហត់ខ្លាំង ។

[ ២៥៣ ] ព្រះបាទវេស្សន្តរបានក្រាបទូលព្រះរាជាព្រះនាមសញ្ជ័យ ជា ធម្មិករាជដ៏ប្រសើរថា បពិត្រព្រះទេវៈ ព្រះអង្គទ្រង់បណ្តេញទូលព្រះបង្គំជា ខ្ញុំ ទូលព្រះបង្គំជាខ្ញុំនឹងទៅឯវង្កបព៌ត ។ បពិត្រមហារាជ សត្វទាំងឡាយ ណាមួយកើតហើយក្តី ទាំងសត្វទាំងឡាយណានឹងកើតក្តី ( ពួកសត្វដែល កំពុងកើតក្តី ) សត្វទាំងនោះសុទ្ធតែមិនឆ្អែតដោយកាមទាំងអស់ រមែងទៅ កាន់ទីរបស់យមៈ ។ ទូលព្រះបង្គំជាខ្ញុំនោះ កាលឲ្យទានក្នុងបុរីជារបស់ខ្លួន ឈ្មោះថា បៀតបៀនពួកអ្នកដែនរបស់ខ្លួន ទូលព្រះបង្គំជាខ្ញុំកាលចេញចាកដែន របស់ខ្លួន ព្រោះហេតុតែសម្តីពួកអ្នកសិវិរាស្រ្ត ទូលព្រះបង្គំក៏នឹងរងទុក្ខក្នុងព្រៃ ដែលច្របូកច្របល់ដោយម្រឹគសាហាវ ដែលរមាសនិងខ្លាដំបងអាស្រ័យហើយ ទូលព្រះបង្គំជាខ្ញុំនឹងធ្វើបុណ្យទាំងឡាយ ឯព្រះអង្គលិចក្នុងភក់ គឺកាមចុះ ។

[ ២៥៤ ] ( ព្រះវេស្សន្តរ... ) បពិត្រព្រះមាតា សូមទ្រង់អនុញ្ញាត ទូលព្រះបង្គំជាខ្ញុំ ទូលព្រះបង្គំជាខ្ញុំ គាប់ចិត្តនឹងបព្វជ្ជា ទូលព្រះបង្គំជាខ្ញុំនោះ កាលឲ្យទានក្នុងបុរីជារបស់ខ្លួន ឈ្មោះថាបៀតបៀនពួកអ្នកដែនរបស់ខ្លួន ទូល ព្រះបង្គំជាខ្ញុំកាលចេញចាកដែនរបស់ខ្លួន ព្រោះហេតុតែសម្តីពួកអ្នកសិវិរាស្រ្ត

ទូលព្រះបង្គំជាខ្ញុំនឹងសោយទុក្ខក្នុងព្រៃដែលប្រកបច្របល់ដោយម្រឹគសាហាវ ដែលរមាសនិងខ្លាដំបងអាស្រ័យហើយ ទូលព្រះបង្គំជាខ្ញុំ តែងធ្វើបុណ្យទាំងឡាយនឹងទៅឯគិរីវង្កត ។

[ ២៥៥ ] ( ព្រះនាងផុស្សតីទេវី... ) ម្នាលកូន យើងអនុញ្ញាតអ្នកហើយ បព្វជ្ជាចូរសម្រេចដល់អ្នកចុះតែនាងមទ្រីកល្យាណីនេះនាងមានត្រគាកដ៏ល្អ មានចង្កេះរៀវ ចូរនៅជាមួយនឹងកូនទាំងពីរចុះ នាងនឹងធ្វើអ្វីក្នុងព្រៃ ។

[ ២៥៦ ] ( ព្រះវេស្សន្តរ... ) សូម្បីតែទាសីដែលប្រាថ្នានឹងទៅ ទូលព្រះបង្គំជាខ្ញុំក៏មិនអាចនាំទៅកាន់ព្រៃទេ ប្រសិនបើនាងមទ្រីចង់ចូរទៅតាមចុះ បើមិនចង់ចូរនៅចុះ ។

[ ២៥៧ ] លំដាប់នោះ មហារាជទ្រង់យាងទៅអង្វរព្រះសុណិសាថា ម្នាលនាងមានរាងកាយប្រោះព្រំដោយខ្លឹមចន្ទន៍ នាងកុំស្លៀកដណ្ដប់សំពត់ឲ្យប្រឡាក់ក្អែលឡើយ ។ នាងធ្លាប់ស្លៀកដណ្ដប់សំពត់អ្នកដែនកាសី ហើយត្រឡប់ជាស្លៀកដណ្ដប់សំពត់ដែលក្រងដោយស្បូវក្លាំងវិញ ការនៅក្នុងព្រៃតែងនាំមកនូវសេចក្ដីទុក្ខ ម្នាលនាងមានលក្ខណ៍នាងកុំទៅឡើយ ។

[ ២៥៨ ] ព្រះរាជបុត្រី ព្រះនាមមទ្រី មានអវយវៈទាំងអស់ដ៏ល្អបានក្រាបបង្គំទូលព្រះបិតាក្មេកថា ខ្ញុំម្ចាស់បើប្រាសចាកព្រះវេស្សន្តររបស់ខ្ញុំម្ចាស់ហើយ មិនចង់បានសេចក្ដីសុខទេ ។

[ ២៥៩ ] មហារាជជាអ្នកញុំាងពួកអ្នកសិវិរាស្ត្រឲ្យចម្រើន មានព្រះបន្ទូលនឹងនាងមទ្រីនោះថា ម្នាលនាងមទ្រី បើដូច្នោះនាងចូរស្ដាប់សេចក្ដីអន្តរាយ

ទាំងឡាយដែលនាងអត់ទ្រាំបានដោយក្រក្នុងព្រៃចុះ ។ កណ្តុប របោម មូស និងឃ្មុំដ៏ច្រើន សត្វទាំងនោះគប្បីបៀតបៀននាងក្នុងព្រៃនោះ ការបៀតបៀននោះមុខជានាំមកនូវទុក្ខយ៉ាងខ្លាំងដល់នាង ។ នាងចូរមើលពួកសត្វដទៃដែលគួរឲ្យតក់ស្លុតដែលអាស្រ័យនៅនឹងទន្លេ គឺពស់ថ្លាន់ ពស់ទាំងនោះមិនមានពិសទេតែមានកម្លាំងច្រើន ។ ពស់ថ្លាន់ទាំងនោះតែងយកក្មេងរឺតមនុស្ស ឬម្រឹគដែលមកជិតវាហើយនាំមកកាន់អំណាចខ្លួន ។ ខ្លាឃ្មុំដទៃទៀតមានសម្បុរខ្មៅរោមរីង ជាម្រឹគឲ្យទុក្ខ បុរសដែលខ្លាទាំងនោះឃើញហើយរត់ឡើងដើមឈើក៏មិនរួច ។ ក្របីជាសត្វប្រហារតែងវែធនឹងស្នែងមានចុងដ៏មុត តែងត្រាច់ទៅមកក្នុងព្រៃនោះជិតទន្លេឈ្មោះសោតុម្ពា ។ ម្នាលនាងមទ្រី នាងដូចជាមេគោដែលមានចិត្តជាប់នឹងកូន ឃើញគោឈ្មោលកំពុងទៅតាមហ្វូងម្រឹគក្នុងព្រៃ នឹងធ្វើដូចម្តេច ។ ម្នាលនាងមទ្រី ភ័យធំមុខជានឹងមានដល់នាងដែលជាស្ត្រីមិនដឹងទីខេត្តព្រោះឃើញស្វាទាំងឡាយដ៏ពន្លឹកដែលផ្តុំគ្នាក្បែរផ្លូវ ដែលទៅមកបានដោយក្រ ។ ម្នាលនាងមទ្រី ក្នុងបុរីនាងគ្រាន់តែឮ ( សូរសំឡេង ) ចចករមែងតក់ស្លុតរឿយៗ ដល់ទៅគិរីវង្កតតើនឹងធ្វើដូចម្តេចទៅ ។ កាលដែលពួកបក្សីប្រជុំគ្នាក្នុងវេលាដែលព្រះអាទិត្យឋិតនៅត្រង់កណ្តាល ( ថ្ងៃត្រង់ ) ព្រៃធំក៏លាន់ឮសំឡេងគឹកកង ចុះនាងចង់ទៅក្នុងព្រៃធំនោះធ្វើអ្វី ។

[ ២៦០ ] ព្រះរាជបុត្រីព្រះនាមមទ្រី មានអវយវៈទាំងអស់ដ៏ល្អ បានក្រាបបង្គំទូលព្រះរាជបិតាក្មេកនោះថា ព្រះអង្គទ្រង់ត្រាស់ប្រាប់ដល់ខ្ញុំម្ចាស់នូវភ័យដែលមានចំពោះមុខទាំងឡាយណាក្នុងព្រៃ ឯខ្ញុំម្ចាស់អាចទទួលអត់ទ្រាំ

ភ័យដែលមានចំពោះមុខទាំងអស់នោះបាន បពិត្រព្រះអង្គដ៏ប្រសើរក្នុងរថ ខ្ញុំម្ចាស់នឹងទៅពុំខានឡើយ ។ ខ្ញុំម្ចាស់នឹងយកទ្រូងរុលវែកដើមអំពៅព្រៃ ស្បូវភ្លាំង ស្មៅសសិត ស្មៅរណ្តាស ស្មៅយាប្លងនិងស្មៅជំណោកទន្សាយ ( ដើរមុខព្រះវេស្សន្តរជាប្តីខ្ញុំម្ចាស់ ) ខ្ញុំម្ចាស់នឹងនាំព្រះភស្តាទៅមិនឲ្យលំបាក ។ កុមារីរមែងបានប្តីដោយការប្រព្រឹត្តិវត្តដ៏ច្រើន គឺដោយការបិទពោះ ( បន្ថយអាហារឲ្យពោះតូច ) ដោយការដំចង្កេះដោយឈើមានសណ្ឋានដូចចង្កាគោ និងការរឹតចង្កេះខ្លួនដោយឈ្នួត ( ធ្វើឲ្យចង្កេះរៀវ ) ដោយការបម្រើភ្លើង ( អាំងភ្លើង ) និងដោយការដុសលាងសម្អាតដោយទឹក ភាពជាស្ត្រីមេម៉ាយរមែងក្តៅក្រហាយក្នុងលោក បពិត្រព្រះអង្គប្រសើរក្នុងរថ ខ្ញុំម្ចាស់នឹងទៅពុំខានឡើយ ។ ម្យ៉ាងទៀតបុរសមិនគួរបរិភោគរបស់សំណល់អំពីស្ត្រីមេម៉ាយនោះ បុរសណាសូម្បី ( មានជាតិទាបបុរសនោះ ) ក៏ចាប់ដៃទង់ទាញស្ត្រីមេម៉ាយនោះដែលមិនប្រាថ្នាផង ភាពជាស្ត្រីមេម៉ាយ រមែងក្តៅក្រហាយក្នុងលោក បពិត្រព្រះអង្គដ៏ប្រសើរក្នុងរថ ខ្ញុំម្ចាស់នឹងទៅពុំខានឡើយ ។ បុរសតែងឲ្យសេចក្តីទុក្ខយ៉ាងច្រើនលើសលុបដោយការចាប់សក់កញ្ឆក់ឡើង ដោយការផ្តួលលើផែនដីហើយក៏មិនដើរចេញទៅណា ( នៅឈរមើលព្រងើយ ) ភាពជាស្ត្រីមេម៉ាយរមែងក្តៅក្រហាយក្នុងលោក បពិត្រព្រះអង្គដ៏ប្រសើរក្នុងរថ ខ្ញុំម្ចាស់នឹងទៅមិនខានឡើយ ។ ពួកបុរសដែលមានសម្បុរស ជាអ្នកត្រូវការនឹងស្ត្រីមេម៉ាយ ប្រកាន់ខ្លួនថាមានលំអដ៏ប្រសើរ បានឲ្យ ( ទ្រព្យបន្តិចបន្តួច ) ហើយទង់ទាញស្ត្រីមេម៉ាយដែលមិនត្រូវការនឹងខ្លួន ដូចក្អែកដែល

ធាបមៀមដូច្នោះ ភាពជាស្ត្រីមេម៉ាយរមែងក្តៅក្រហាយក្នុងលោក បពិត្រព្រះអង្គដ៏ប្រសើរក្នុងរថ ខ្ញុំម្ចាស់នឹងទៅពុំខានឡើយ ។ ម្យ៉ាងទៀតស្ត្រីមេម៉ាយកាលនៅក្នុងត្រកូលញាតិដ៏ស្តុកស្តម្ភ រុងរឿងដោយកាជន៍មាស ក៏នៅតែបានពាក្យតិះដៀលអំពីបងប្អូនប្រុសនិងពួកស្ត្រីជាសម្លាញ់ពុំខាន ភាពជាស្ត្រីមេម៉ាយរមែងក្តៅក្រហាយក្នុងលោក បពិត្រព្រះអង្គដ៏ប្រសើរក្នុងរថ ខ្ញុំម្ចាស់នឹងទៅពុំខានឡើយ ។ ទន្លេដែលគ្មានទឹកហៅថា ទន្លេស្រោត ដែនដែលគ្មានព្រះរាជាហៅថា ដែនស្រោត ចំណែកស្ត្រីមេម៉ាយបើទុកជាមានបងប្អូនប្រុសដល់ ១០ នាក់ ក៏ហៅថា ស្ត្រីស្រោត ភាពជាស្ត្រីមេម៉ាយរមែងក្តៅក្រហាយក្នុងលោក បពិត្រព្រះអង្គដ៏ប្រសើរក្នុងរថ ខ្ញុំម្ចាស់នឹងទៅពុំខានឡើយ ។ ទង់ជាគ្រឿងប្រាកដរបស់រថ ផ្សែងជាគ្រឿងប្រាកដរបស់ភ្លើង ព្រះរាជាជាគ្រឿងប្រាកដរបស់ដែន ភស្តាជាគ្រឿងប្រាកដរបស់ស្ត្រី ភាពជាស្ត្រីមេម៉ាយរមែងក្តៅក្រហាយក្នុងលោក បពិត្រព្រះអង្គដ៏ប្រសើរក្នុងរថ ខ្ញុំម្ចាស់នឹងទៅពុំខានឡើយ ។ ស្ត្រីណាដែលមានកេរ្តិ៍ឈ្មោះ កាលស្វាមីទ័លក្រក៏ជាស្ត្រីទ័លក្រ ( ជាមួយ ) កាលស្វាមីស្តុកស្តម្ភក៏ជាស្ត្រីស្តុកស្តម្ភ ( ជាមួយ ) ពួកទេវតារមែងសរសើរស្ត្រីនោះឯង ព្រោះថាស្ត្រីនោះធ្វើអំពើដែលគេធ្វើបានដោយក្រ ។ ខ្ញុំម្ចាស់នឹងស្លៀកសំពត់កាសាយៈហើយដើរតាមប្តីសព្វៗកាល ភាពជាស្ត្រីមេម៉ាយទោះបីមានផែនដីមិនបែក ( បានជាធំលើផែនដីទាំងមូល ) ក៏នៅតែក្តៅក្រហាយដែរ ។ ម្យ៉ាងទៀតខ្ញុំម្ចាស់បើប្រាសព្រាត់ព្រះវេស្សន្តរជាប្តីហើយ មិនចង់បានផែនដីដែលមានសមុទ្ទព័ទ្ធជុំវិញទ្រទ្រង់ទ្រព្យដ៏ច្រើន ជាផែនដីបរិបូណ៌ដោយ

រតនៈផ្សេងៗទេ ។ ពួកស្ត្រីណាជាស្ត្រីរៀវរូសយ៉ាងក្រៃលែងកាលដែលស្វាមីដល់នូវសេចក្តីទុក្ខហើយ ប្រាថ្នាសេចក្តីសុខដល់ខ្លួនតែម្យ៉ាង ហឫទ័យរបស់ស្ត្រីទាំងនោះនឹងទៅជាដូចម្តេចហ្ន៎ ។ កាលបើមហារាជដែលញុំាងពួកអ្នកសិវិរាស្ត្រឲ្យចម្រើន ទ្រង់ចេញទៅហើយ ខ្ញុំម្ចាស់នឹងទៅតាមមហារាជនោះព្រោះថា ព្រះអង្គជាអ្នកឲ្យវត្ថុជាទីប្រាថ្នាគ្រប់យ៉ាងដល់ខ្ញុំម្ចាស់ ។

[ ២៦១ ] ព្រះបាទសញ្ជយមហារាជ មានព្រះរាជឱង្ការនឹងព្រះនាងមទ្រីដែលមានអវយវៈទាំងអស់ដ៏ល្អនោះថា ម្នាលនាងមានលក្ខណ៍ នាងចូរទុកកូនតូចទាំងពីររបស់នាង គឺបាជាលីនិងនាងកណ្ហាជិនានេះ ហើយទៅចុះយើងនឹងចិញ្ចឹមកូនតូចទាំងនោះ ។

[ ២៦២ ] ព្រះរាជបុត្រីព្រះនាមមទ្រី ដែលមានអវយវៈទាំងអស់ដ៏ល្អបានក្រាបទូលព្រះរាជានោះវិញថា បពិត្រព្រះទេវៈ កូនតូចទាំងពីរ គឺបាជាលីនិងនាងកណ្ហាជិនាជាទីស្រឡាញ់របស់ខ្ញុំម្ចាស់ កូនតូចទាំងពីរនោះនឹង ( ញុំាងហឫទ័យ ) នៃយើងខ្ញុំដែលមិនទាន់ប្រាសចាកសេចក្តីសោកឲ្យត្រេកអរក្នុងព្រៃនោះបាន ។

[ ២៦៣ ] ព្រះបាទសញ្ជយមហារាជ ទ្រង់ញុំាងពួកអ្នកសិវិរាស្ត្រឲ្យចម្រើន មានព្រះបន្ទូលនឹងព្រះនាងមទ្រីនោះថា ក្មេងទាំងពីរធ្លាប់បរិភោគបាយអង្ករសាលីលាយដោយសាច់ដ៏ស្អាត នឹងបរិភោគផ្លែឈើធ្វើម្តេចកើត ។ ក្មេងទាំងពីរធ្លាប់បរិភោគភោជនក្នុងភាជន៍មាសដែលមានទម្ងន់ ១០០ បល្ៈ មានស្នាមចម្លាក់មួយ ១០០ នឹងបរិភោគភោជនដែលដាក់ក្នុងស្លឹកឈើ ធ្វើម្តេច

កើត ។ ក្មេងទាំងពីរធ្លាប់ស្លៀកដណ្ដប់សំពត់អ្នកដែនកាសីផង សំពត់ខោមៈផង សំពត់កោទុម្ពរៈផង នឹងស្លៀកដណ្ដប់សំពត់ដែលក្រងដោយស្បូវក្លាំងធ្វើម្ដេចកើត ។ ក្មេងទាំងពីរធ្លាប់ទៅដោយវ ដោយគ្រែស្នែង ដោយរថ នឹងដើរទៅដោយជើងធ្វើម្ដេចកើត ។ ក្មេងទាំងពីរធ្លាប់ដេកក្នុងផ្ទះមានកំពូល មានសន្ទះទ្វារនិងបង្អួចដ៏ជិតស្និទ្ធ ខ្យល់ចេញចូលមិនបាន នឹងដេកទៀបគល់ឈើធ្វើម្ដេចកើត ។ ក្មេងទាំងពីរធ្លាប់ដេកលើបល្ល័ង្ក លើកម្រាលរោមវែងនិងលើកម្រាលដ៏ពិចិត្រ នឹងដេកលើកម្រាលស្មៅធ្វើម្ដេចកើត ។ ក្មេងទាំងពីរធ្លាប់លាបស្រឡាបដោយគ្រឿងក្រអូប គឺខ្លឹមក្រស្នា ខ្លឹមចន្ទន៍ នឹងស្លៀកដណ្ដប់សំពត់ប្រឡាក់ក្អែល ធ្វើម្ដេចកើត ។ ក្មេងទាំងពីរធ្លាប់ឋិតនៅក្នុងសេចក្ដីសុខមានអវយវៈ គេតែងបក់ដោយផ្លិតរោមចាមរីនិងសំណុំកន្ទុយក្ងោក ត្រូវរបោមមូសប៉ះពាល់នឹងធ្វើដូចម្ដេចកើត ។

[ ២៦៤ ] ព្រះរាជបុត្រីទ្រង់ព្រះនាមមទ្រី ដែលមានអវយវៈទាំងអស់ដ៏ល្អក្រាបទូលព្រះរាជបិតានោះថា បពិត្រព្រះទេវៈ ព្រះអង្គកុំទ្រង់ព្រះកន្សែងឡើយ សូមព្រះអង្គកុំមានព្រះហឫទ័យអាក់អន់ឡើយ ខ្ញុំម្ចាស់ទាំងពីរនាក់នឹងរស់នៅយ៉ាងណា ក្មេងទាំងពីរនាក់ក៏រស់នៅយ៉ាងនោះដែរ ។ ព្រះនាងមទ្រីដែលមានអវយវៈទាំងអស់ដ៏ល្អដ៏ទ្រង់លក្ខណ៍ លុះបានពោលពាក្យយ៉ាងនេះហើយក៏នាំព្រះរាជបុត្រាបុត្រីទៅតាមផ្លូវដែលព្រះបាទសិវិ ( វេស្សន្តរ ) ទ្រង់ស្ដេចទៅ ។

[ ២៦៥ ] លំដាប់នោះព្រះវេស្សន្តរជាក្សត្រទ្រង់បានឲ្យទានហើយ ក៏

ថ្វាយបង្គំព្រះបិតានិងព្រះមាតា ធ្វើប្រទក្សិណព្រះបិតានិងព្រះមាតានោះ ។ ព្រះវេស្សន្តរឡើងកាន់រថដែលទឹមដោយសេះ ៤ មានសន្ទុះដ៏លឿននាំបុត្រាបុត្រីនិងព្រះជាយា ស្តេចទៅកាន់គិរីវង្កត ។

[ ២៦៦ ] លំដាប់នោះព្រះរាជាទ្រង់ព្រះនាមវេស្សន្តរ ទ្រង់បររថសំដៅទៅរកទីដែលមានជនច្រើនហើយត្រាស់ថា យើងសូមលាអ្នករាល់គ្នាទៅហើយ សូមឲ្យពួកញាតិកុំមានរោគឡើយ ។

[ ២៦៧ ] ( អភិសម្ពុទ្ធគាថា ) កាលដែលព្រះបាទវេស្សន្តរ ស្តេចចេញអំពីព្រះនគរ ហើយងាកក្រឡេកទតព្រះរាជនិវេសន៍ គ្រានោះឯងផែនដីដែលមានភ្នំសិនេរុនិងព្រៃជាគ្រឿងប្រដាប់ក៏ញាប់ញ័រ ។

[ ២៦៨ ] ( ព្រះវេស្សន្តរ... ) នែនាងមទ្រី នាងចូរគន់មើលចុះ ( នុ៎ះ ) និវេសន៍របស់ព្រះបាទសិវិដ៏ប្រសើរ ( នុ៎ះ ) វាំងរបស់យើងដែលព្រះបិតាប្រទានឲ្យ ប្រាកដជារូបគួរត្រេកអរ ។

[ ២៦៩ ] ពួកព្រាហ្មណ៍ បានទៅតាមព្រះបាទវេស្សន្តរនោះ ព្រាហ្មណ៍ទាំងនោះ បានសុំសេះទាំងឡាយអំពីព្រះបាទវេស្សន្តរនោះ ព្រះបាទវេស្សន្តរ លុះពួកព្រាហ្មណ៍សុំហើយ ក៏បានប្រទានសេះទាំង ៤ ដល់ព្រាហ្មណ៍ទាំង ៤ នាក់ ។

[ ២៧០ ] ( ព្រះបាទវេស្សន្តរ... ) នែមទ្រី នាងចូរគន់មើលចុះ ម្រឹគទាំងឡាយមានភេទជារមាំងនាំខ្ញុំទៅដូចសេះដែលគេទូន្មានល្អហើយប្រាកដជារូបដ៏វិចិត្រ ។

[ ២៧១ ] លំដាប់នោះព្រាហ្មណ៍ទី ៥ ក៏មកក្នុងព្រៃនោះ ព្រាហ្មណ៍នោះបានសុំរថអំពីព្រះបាទវេស្សន្តរនោះ ព្រះបាទវេស្សន្តរក៏ប្រទានរថដល់ព្រាហ្មណ៍នោះ ព្រះហឫទ័យរបស់ព្រះបាទវេស្សន្តរមិនបានរួញរាឡើយ ។

[ ២៧២ ] ព្រះបាទវេស្សន្តរទ្រង់ឲ្យជន គឺព្រះទេវី បុត្រាបុត្រីរបស់ព្រះអង្គ ( ចុះពីរថនោះ ) រួចប្រទានអស្សរថដល់ព្រាហ្មណ៍អ្នកស្វែងរកទ្រព្យ ។

[ ២៧៣ ] ( ព្រះបាទវេស្សន្តរ... ) នៃមទ្រី នាងចូរពរកណ្ហាចុះ ដ្បិតកណ្ហានុ៎ះជាប្អូននៅតូចស្រាល ខ្ញុំនឹងពរជាលីដ្បិតជាលីនោះជាបងដ៏ធ្ងន់ ។

[ ២៧៤ ] ព្រះរាជាទ្រង់ពរជាលីកុមារ ចំណែកព្រះរាជបុត្រីទ្រង់ពរនាងកណ្ហាជិនា ទ្រង់យាងទៅមានព្រះបន្ទូលព្រះវាចាជាទីស្រឡាញ់សំណេះសំណាលទៅវិញទៅមក ។

**ចប់ ទានកណ្ឌ ។**

[ ២៧៥ ] ( អភិសម្ពុទ្ធគាថា ) ( ក្សត្រទាំងនោះមានព្រះបន្ទូលសំណេះសំណាលថា ) ប្រសិនបើពួកមនុស្សណាមួយមកជួបក្នុងផ្លូវជាលំដាប់ យើងនឹងសួររកផ្លូវនឹងមនុស្សទាំងនោះថា វង្កតបព៌តនៅក្នុងទីណា ។ មនុស្សទាំងនោះ បានឃើញយើងក្នុងទីនោះហើយ សមជាទួញយំមុខគួរឲ្យអណោចអធម្ម មនុស្សទាំងនោះក៏ប្រាប់សេចក្តីទុក្ខថា វង្កតបព៌តនៅក្នុងទីឆ្ងាយ ។

[ ២៧៦ ] បើក្មេងទាំងពីរបានឃើញដើមឈើដែលមានផ្លែក្នុងព្រៃ ក្មេងទាំងពីររមែងយំទារព្រោះហេតុចង់បានផ្លែឈើទាំងនោះ ។ ដើមឈើទាំងឡាយ

ដ៏ខ្ពស់ឃើញក្មេងទាំងពីរកំពុងយំ ក៏ទោរទន់មកជិតក្មេងទាំងពីរដោយខ្លួនឯងតែម្តង ។ ព្រះនាងមទ្រីដែលមានអវយវៈទាំងអស់ដ៏ល្អ បានឃើញហេតុនេះជាហេតុអស្ចារ្យ ចម្លែកគួរឲ្យព្រឺរោមក៏ញុំាងសាធុការឲ្យប្រព្រឹត្តទៅថា ឱហ្ន៎ ( នេះ ) គួរអស្ចារ្យណាស់ចម្លែកណាស់ គួរឲ្យព្រឺរោមក្នុងលោក ដើមឈើទាំងឡាយស្រាប់តែទោរចុះមកឯង ដោយតេជះនៃព្រះវេស្សន្តរ ។

[ ២៧៧ ] យក្ខទាំងឡាយបំប្រួញផ្លូវដោយសេចក្តីអនុគ្រោះចំពោះក្មេងទាំងពីរ ក្សត្រទាំងនោះបានទៅដល់ដែនឈ្មោះចេតៈ តែមួយថ្ងៃរាប់ពីស្តេចចេញទៅ ។

[ ២៧៨ ] ក្សត្រទាំងនោះ យាងទៅកាន់ផ្លូវឆ្ងាយ ក៏បានដល់ដែនឈ្មោះចេតៈ ដែលជាជនបទស្តុកស្តម្ភជំទូលាយមានសាច់ សុរានិងទឹកច្រើន ។

[ ២៧៩ ] អ្នកដែនចេតៈទាំងឡាយបានឃើញព្រះនាងមទ្រី ដែលប្រកបដោយលក្ខណៈ ស្តេចមកដល់ហើយក៏នាំគ្នាចោមរោមចរចាថា ឱហ្ន៎ ព្រះនាងម្ចាស់ជាសុខុមាលជាតិ ស្តេចសញ្ចរមកដោយព្រះបាទទទេ ។ សម្តេចព្រះមទ្រីនោះធ្លាប់ស្តេចទៅដោយវ គ្រែស្នែងនិងរថតែក្នុងថ្ងៃនេះស្តេចទៅក្នុងព្រៃដោយព្រះបាទទទេ ។

[ ២៨០ ] ព្រះរាជាចេតៈទាំងឡាយ លុះបានឃើញព្រះបាទវេស្សន្តរនោះហើយក៏ទ្រង់ព្រះកន្សែងចូលទៅជិតថា បពិត្រព្រះទេវៈ ព្រះអង្គសុខស្រួលទេឬ បពិត្រព្រះទេវៈ ព្រះអង្គមិនមានជំងឺតម្កាត់ទេឬ ។ ព្រះបិតារបស់ព្រះអង្គមិនមានរោគទេឬ ពួកអ្នកសិវិរាស្ត្រមិនមានជំងឺតម្កាត់ទេឬ បពិត្រមហារាជ ទៅ

ណាទៅពួកពលរបស់ព្រះអង្គ ទៅណាទៅរថមណ្ឌលរបស់ព្រះអង្គ ។ ព្រះអង្គទ្រង់ស្តេចមកកាន់ផ្លូវឆ្ងាយ មិនមានសេះ មិនមានរថ ពួកបច្ចាមិត្តគ្របសង្កត់ព្រះអង្គឬទើបស្តេចយាងមកកាន់ទិសនេះ ។

[ ២៨១ ] ( ព្រះបាទវេស្សន្តរ... ) ម្នាលសម្លាញ់ទាំងឡាយ យើងមានសេចក្តីសុខស្រួលទេ ម្នាលសម្លាញ់ទាំងឡាយ យើងមិនមានជំងឺតម្កាត់អ្វីទេ ព្រះបិតារបស់យើងក៏មិនមានរោគទេទាំងពួកអ្នកសិវិរាស្ត្រក៏មិនមានជំងឺតម្កាត់ដែរ ។ យើងបានឲ្យដំរីមានភ្លុកងទន្ទាំអាចពុះពារសត្រូវ ស្គាល់ខេត្តនៃចម្បាំងគ្រប់យ៉ាង ជាដំរីដ៏ឧត្តម សសុទ្ធ បិទបាំងដោយសំពត់កម្ពលលឿង ជាដំរីចុះប្រេងអាចញាំញីសត្រូវបាន មានភ្លុក ( ល្អ ) ប្រកបដោយស៊ែ ជាដំរីសប្រហែលនឹងភ្នំកៃលាស ។ ខ្ញុំបានឲ្យដំរីនោះព្រមទាំងស្វេតច្ឆត្រ ព្រមទាំងកម្រាលលើខ្នងដ៏ល្អ ព្រមទាំងពេទ្យ ព្រមទាំងអ្នករក្សា ជាយានដ៏ប្រសើរ ជារាជពាហនៈដល់ពួកព្រាហ្មណ៍ ។ ព្រោះដំណើរនោះហើយបានជាពួកអ្នកសិ-វិរាស្ត្រខឹងនឹងខ្ញុំ ទាំងព្រះបិតាក៏មានព្រះហឫទ័យអាក់អន់នឹងខ្ញុំ ព្រះរាជាទ្រង់ដេញខ្ញុំ ខ្ញុំនឹងទៅឯភ្នំវង្កត នៃសម្លាញ់ទាំងឡាយ អ្នកទាំងឡាយចូរដឹងឱកាសជាទីនៅក្នុងព្រៃ ។

[ ២៨២ ] ( ពួកព្រះរាជាចេតៈ... ) បពិត្រមហារាជ ព្រះអង្គទ្រង់យាងមកស្រួលហើយ ព្រះអង្គមិនមែនយាងមកដោយអាក្រក់ទេ ព្រះអង្គជាធំ ទ្រង់ស្តេចមកដល់ហើយ សូមព្រះអង្គ មានព្រះបន្ទូលប្រាប់របស់ដែលមានក្នុងទីនេះ ។ បពិត្រមហារាជ សូមព្រះអង្គទ្រង់សោយអន្ទក់ ក្រអៅឈូក ទឹកឃ្មុំ

សាច់និងបាយនៃអង្ករស្រូវសាលីដ៏ស្អាត ផ្សិតព្រះអង្គយាងមកហើយទុកជាភ្ញៀវរបស់ទូលព្រះបង្គំជាខ្ញុំទាំងឡាយ ។

[ ២៨៣ ] ( ព្រះវេស្សន្តរ... ) វត្ថុណាដែលអ្នកទាំងអស់ធ្វើឲ្យជារបស់មានតម្លៃបានឲ្យដល់ខ្ញុំ វត្ថុនោះខ្ញុំក៏បានទទួលហើយ ( តែថា ) ព្រះរាជាទ្រង់បណ្តេញខ្ញុំ ខ្ញុំនឹងទៅឯភ្នំវង្កត នៃសម្លាញ់ទាំងឡាយ អ្នកទាំងឡាយចូរដឹងឱកាសជាទីនៅក្នុងព្រៃ ។

[ ២៨៤ ] ( ពួកព្រះរាជាចេតៈ... ) បពិត្រព្រះអង្គដ៏ប្រសើរក្នុងរថ សូមព្រះអង្គស្តេចគង់នៅក្នុងដែនឈ្មោះចេតៈនេះសិនចុះ ទម្រាំពួកព្រះរាជាចេតៈនឹងទៅកាន់សំណាក់ព្រះរាជាដើម្បីទូលអង្វរ ។ ពួកព្រះរាជាចេតត្រេកអរបានទីពឹងហើយហែហមចោមរោមព្រះអង្គទៅ ដើម្បីញ៉ាំងមហារាជដែលញ៉ាំងពួកអ្នកសិវិរាស្ត្រឲ្យចម្រើន ឲ្យលើកទោសចោល បពិត្រក្សត្រ សូមព្រះអង្គទ្រង់ជ្រាបយ៉ាងនេះចុះ ។

[ ២៨៥ ] ( ព្រះបាទវេស្សន្តរ... ) អ្នកទាំងឡាយ កុំពេញចិត្តនឹងការទៅកាន់សំណាក់ព្រះរាជា ដើម្បីទូលអង្វរមហារាជឲ្យលើកទោសចោលព្រោះព្រះរាជាមិនជាធំក្នុងការនោះទេ ។ ព្រោះថាពួកអ្នកសិវិរាស្ត្រណាជានាយពលក្តី ជាអ្នកនិគមក្តីសុទ្ធតែជាអ្នកខឹង ពួកអ្នកសិវិរាស្ត្រនោះចង់បណ្តេញទាំងព្រះរាជាព្រោះហេតុតែយើងផង ។

[ ២៨៦ ] ( ពួកព្រះរាជាចេតៈ... ) បពិត្រព្រះអង្គអ្នកញ៉ាំងដែនឲ្យចម្រើនបើដំណើរហ្នឹងមានក្នុងដែនទុ៎ះមែន សូមព្រះអង្គដែលពួកព្រះរាជាចេតៈ

ចោមរោមទ្រង់សោយរាជ្យក្នុងដែននេះចុះ ។ ឯដែននេះជាដែនស្តុកស្តម្ភទូលាយ ជនបទក៏ស្តុកស្តម្ភធំ បពិត្រព្រះទេវៈ សូមព្រះអង្គទ្រង់ធ្វើសេចក្តីពេញព្រះហឫទ័យដើម្បីនឹងគ្រប់គ្រងរាជ្យ ។

[ ២៨៧ ] ( ព្រះបាទវេស្សន្តរ... ) យើងដែលគេបណ្តេញអំពីដែនហើយ មិនមានសេចក្តីប្រាថ្នា មិនមានសេចក្តីពេញចិត្ត ដើម្បីនឹងគ្រប់គ្រងរាជ្យទេ ម្នាលពួកចេតបុត្តអ្នកចូរស្តាប់ខ្ញុំ ។ បើពួកព្រះរាជាចេតៈអភិសេកយើងដែលគេបណ្តេញចាកដែនក្នុងរាជ្យហើយ ពួកអ្នកសិវិរាស្រ្តណាជានាយពលក្តី ជាអ្នកនិគមក្តី ពួកអ្នកសិវិរាស្ត្រនោះមិនត្រេកអរទេ ។ ទាំងមិនមានសេចក្តីស្មោះស្ម័គ្រនឹងអ្នកទាំងឡាយព្រោះហេតុតែខ្ញុំដោយពិត ខ្ញុំមិនគាប់ចិត្តនឹងការប្រកួតប្រកាន់ ទាស់ទែងជាមួយពួកអ្នកសិវិរាស្ត្រ ។ តទៅនឹងកើតមានការប្រកួតប្រកាន់ដ៏ពន្លឹក ការវាយដំគ្នាយ៉ាងសម្បើមនឹងមានមិនខាន ជនជាច្រើនគប្បីបៀតបៀនគ្នាព្រោះហេតុតែខ្ញុំម្នាក់ឯង ។ វត្ថុណាដែលអ្នកទាំងអស់គ្នាធ្វើឲ្យជារបស់មានតម្លៃបានឲ្យដល់ខ្ញុំ វត្ថុនោះខ្ញុំបានទទួលហើយ ព្រះរាជាទ្រង់បណ្តេញខ្ញុំ ខ្ញុំនឹងទៅភ្នំវង្កត ម្នាលសម្លាញ់ទាំងឡាយ អ្នកទាំងឡាយ ចូរដឹងឱកាសជាទីនៅក្នុងព្រៃ ។

[ ២៨៨ ] ( ពួកព្រះរាជាចេតៈ... ) ពួករាជបព្វជិត ជាអ្នកឈ្លាសជាអ្នកបូជាភ្លើង មានចិត្តតម្កល់មាំតែងគង់នៅក្នុងទីណា ពួកទូលព្រះបង្គំជាខ្ញុំនឹងក្រាបទូលដល់ព្រះអង្គយ៉ាងនោះ បពិត្រមហារាជ ព្រះអង្គគង់នៅជាមួយព្រះរាជបុត្តព្រមទាំងព្រះអគ្គជាយាក្បែរភ្នំណាភ្នំនោះហៅថា ភ្នំគន្ធមាទន៍ ជា

វិការៈនៃថ្មសុទ្ធ ។

[ ២៨៩ ] ពួកព្រះរាជាចេតៈកាលយំមានមុខជោកដោយទឹកភ្នែក ក៏ក្រាបទូលព្រះបាទវេស្សន្តរនោះថា បពិត្រមហារាជ សូមព្រះអង្គទ្រង់យាងទៅអំពីទីនេះសំដៅត្រង់ទៅទិសខាងជើង ។ បពិត្រព្រះអង្គដ៏ចម្រើន គ្រានោះព្រះអង្គនឹងទតឃើញភ្នំឈ្មោះ វេបុល្លៈ ជាភ្នំដេរដាសដោយពួកឈើផ្សេងៗ មានម្លប់ត្រជាក់ជាទីរីករាយចិត្ត ។ បពិត្រព្រះអង្គដ៏ចម្រើន លុះព្រះអង្គឆ្លងផុតភ្នំនោះហើយនឹងបានឃើញស្ទឹងមួយជាទីហូរទៅនៃទឹកឈ្មោះ កេតុមតី ជាស្ទឹងជ្រៅហូរចេញអំពីផ្ទៃភ្នំ ។ ដេរដាសដោយហ្វូងត្រីច្រើន មានកំពង់រាបស្មើល្អមានទឹកច្រើន ព្រះអង្គស្រង់ផង សោយផង លួងលោមព្រះរាជបុត្ររបស់ព្រះអង្គក្នុងស្ទឹងនោះ ។ បពិត្រព្រះអង្គដ៏ចម្រើន តទៅព្រះអង្គនឹងទតឃើញដើមជ្រៃមានផ្លែផ្អែម ដុះនៅលើកំពូលភ្នំជាទីត្រេកអរ មានម្លប់ត្រជាក់ជាទីរីករាយនៃចិត្ត ។ បពិត្រព្រះអង្គដ៏ចម្រើន លំដាប់នោះព្រះអង្គនឹងទតឃើញភ្នំមួយឈ្មោះនាលិកៈ ជាវិការៈនៃថ្ម ដេរដាសដោយពួកសត្វស្លាបផ្សេងៗកុះករដោយពួកកិន្នរ ។ នៅភាគខាងជើងឆៀងខាងកើតនៃភ្នំនោះ មានស្រះឈ្មោះមុចលិន្ទ ដេរដាសដោយឈូកសផង ឧប្បលសផង ចន្ទលណីផង ។ ព្រះអង្គចូលទៅកាន់ព្រៃដូចផ្ទៃមេឃ មានស្មៅចិញ្ចៀនខៀវស្រស់ជានិច្ច ចូលទៅកាន់ដងព្រៃដេរដាសដោយឈើមានផ្កានិងឈើមានផ្លែទាំងពីរ ដូចសីហៈប្រាថ្នាចំណី ។ ក្នុងព្រៃនោះមានបក្សីជាច្រើន មានសម្បុរប្លែកៗគ្នា មានសំឡេងមូល មានសំឡេងពីរោះស្រែកយំឆ្លងឆ្លើយគ្នាទៅមកលើដើមឈើមាន

ផ្លារីកតាមរដូវ ។ ព្រះអង្គទ្រង់ស្តេចទៅកាន់ជង្ហុកភ្នំនិងកន្លែងកកើតនៃស្ទឹងទាំងឡាយទើបបានទតឃើញស្រះបោក្ខរណី ដេរដាសដោយដើមកញ្ជើបាយដាចនិងដើមថ្នាន់ ។ ជាស្រះដេរដាសដោយហ្វូងត្រីដ៏ច្រើនមានកំពង់រាបស្មើល្អ មានទឹកច្រើន មានសណ្ឋាន ៤ ជ្រុងស្មើ មានទឹកមានរសឆ្ងាញ់ មានក្លិនមិនគួរខ្ពើម ។ សូមព្រះអង្គទ្រង់សាងបណ្ណសាលា ត្រង់ទិសខាងជើងធៀងខាងកើតនៃស្រះបោក្ខរណីនោះ លុះទ្រង់បានសាងបណ្ណសាលាហើយសូមទ្រង់ព្យាយាមត្រាច់ស្វែងរកផលាផលចិញ្ចឹមព្រះអង្គចុះ ។

**ចប់ វនប្បវេសន៍ ។**

[ ២៩០ ] ( អភិសម្ពុទ្ធគាថា ) មានព្រាហ្មណ៍ម្នាក់ឈ្មោះជូជក នៅក្នុងដែនកលិង្គៈ ឯភរិយារបស់គាត់នៅក្មេងឈ្មោះនាងអមិត្តតាបនា ។ ពួកស្រីជាអ្នកដងទឹកស្ទឹងក្នុងស្រុកនោះ បានទៅស្តីថានាងអមិត្តតាបនានោះ ផ្អើលជ្រួលជ្រើមចោមរោមជេរប្រទេចនាងអមិត្តតាបនានោះថា ម្តាយនាងជាសត្រូវពិត ឪពុកនាងជាសត្រូវពិត បានជាឲ្យនាងដែលនៅកំពុងក្រមុំយ៉ាងនេះដល់ព្រាហ្មណ៍ចាស់ ។ ពួកញាតិរបស់នាងនាំគ្នាទៅប្រឹក្សាក្នុងទីស្ងាត់ មិនជាប្រយោជន៍ដល់នាងពិតហើយ បានជានាំគ្នាលើកនាងដែលនៅកំពុងក្រមុំយ៉ាងនេះឲ្យដល់ព្រាហ្មណ៍ចាស់ ។ ពួកញាតិរបស់នាងនាំគ្នាទៅប្រឹក្សាក្នុងទីស្ងាត់ជាការអាក្រក់របស់នាងប្រាកដហើយ បានជានាំគ្នាលើកនាង ដែលនៅក្រមុំយ៉ាងនេះឲ្យដល់ព្រាហ្មណ៍ចាស់ ។ ពួកញាតិរបស់នាងនាំគ្នាទៅប្រឹក្សាក្នុងទី

ស្ងាត់ ជាការលាមករបស់នាងប្រាកដហើយបានជានាំគ្នាលើកនាងដែលនៅក្រមុំយ៉ាងនេះ ឲ្យដល់ព្រាហ្មណ៍ចាស់ ។ ពួកញាតិរបស់នាងនាំគ្នាទៅប្រឹក្សាក្នុងទីស្ងាត់មិនជាទីគាប់ចិត្តរបស់នាងពិតហើយបានជានាំគ្នាលើកនាងដែលនៅក្រមុំយ៉ាងនេះឲ្យដល់ព្រាហ្មណ៍ចាស់ ។ នាងនៅទាំងមិនគាប់ចិត្តជាមួយនឹងប្តីចាស់ ដ្បិតនាងនៅក្នុងផ្ទះនៃប្តីចាស់បែបនេះ នាងស្លាប់ទៅប្រសើរជាងការរស់នៅ ។ នៃនាងមានលំអយ៉ាងធេ៏ត មាតាបិតារបស់នាងជាក់ជារកប្តីដទៃឲ្យនាងមិនបាន បានជានាំគ្នាលើកនាងដែលនៅក្រមុំយ៉ាងនេះឲ្យដល់ព្រាហ្មណ៍ចាស់ ។ នាងបានធ្វើការបូជាមិនល្អក្នុងថ្ងៃទី ៩ ទាំងមិនបានធ្វើការបូជាព្រះអគ្គិ បានជាពួកញាតិនាំគ្នាលើកនាងដែលនៅក្រមុំយ៉ាងនេះឲ្យដល់ព្រាហ្មណ៍ចាស់ ។ នាងជាក់ជាជេរប្រទេចពួកសមណៈនិងព្រាហ្មណ៍ មានព្រហ្មចរិយៈប្រព្រឹត្តទៅខាងមុខ ជាអ្នកមានសីល មានការចេះដឹងច្រើនក្នុងលោក បានជានាងដែលនៅក្រមុំយ៉ាងនេះនៅ ( ក្នុងផ្ទះ ) ព្រាហ្មណ៍ចាស់ ។ ពស់ចឹកមិនទាន់ជាទុក្ខទេ ទាំងលំពែងមុតក៏មិនទាន់ជាទុក្ខដែរ ត្រង់នាងឃើញប្តីចាស់នោះទើបជាទុក្ខ ទាំងជាគ្រឿងក្តៅក្រហាយ ។ ល្បែងមិនមាន តម្រេកមិនមាន ការចរចាទៅមកជាមួយនឹងប្តីចាស់មិនមាន ទាំងការសើចក៏មិនសមល្អ ។ កាលណាប្តីក្មេងប្រពន្ធក្មេងទៅប្រឹក្សាគ្នាក្នុងទីស្ងាត់ កាលណោះសេចក្តីសោកគ្រប់យ៉ាងណាមួយ ដែលអាស្រ័យនៅហឫទ័យ ក៏រមែងវិនាសបាត់ទៅ នាងក្មេងមានរូបល្អរមែងជាទីប្រាថ្នានៃពួកបុរសណាស់ ចូរនាងវិលទៅនៅឯត្រកូលញាតិវិញទៅ ព្រាហ្មណ៍ចាស់នឹងធ្វើនាងឲ្យរីករាយដូចម្តេចកើត ។

[ ២៩១ ] ( នាងអមិត្តតាបនា... ) នែព្រាហ្មណ៍ ខ្ញុំមិនទៅដងទឹកស៊ីង ឲ្យអ្នកទេ នែព្រាហ្មណ៍ដ្បិតពួកស្រីៗដែរប្រទេចខ្ញុំព្រោះតែអ្នកចាស់ ។

[ ២៩២ ] ( ជូជក... ) នាងកុំធ្វើកិច្ចការឲ្យអញឡើយ នាងកុំដងទឹក មកឲ្យអញឡើយ អញនឹងដងទឹក ( ខ្លួនឯង ) ម្នាលនាងដ៏ចម្រើន នាងកុំក្រេវក្រោធឡើយ ។

[ ២៩៣ ] ( នាងអមិត្តតាបនា... ) ខ្ញុំមិនមែនកើតក្នុងត្រកូល ( ស្រីអ្នកប្រើប្ដី ) នោះទេ អ្នកដងទឹកណា ( ខ្ញុំមិនត្រូវការទឹកនោះទេ ) នែព្រាហ្មណ៍ អ្នកចូរដឹងយ៉ាងនេះចុះ ខ្ញុំនឹងមិននៅក្នុងផ្ទះអ្នកទេ ។ នែព្រាហ្មណ៍ បើអ្នកមិន នាំខ្ញុំប្រុសឬខ្ញុំស្រីមកឲ្យខ្ញុំទេ នែព្រាហ្មណ៍ អ្នកចូរដឹងយ៉ាងនេះចុះខ្ញុំមិននៅក្នុង សំណាក់អ្នកទេ ។

[ ២៩៤ ] ( ជូជក... ) ម្នាលនាងព្រាហ្មណី ហេតុជាទីតាំងនៃសិល្បៈ ក្ដី ទ្រព្យក្ដី ស្រូវក្ដីរបស់អញមិនមានទេ អញនឹងនាំយកខ្ញុំប្រុស ឬខ្ញុំស្រីមក ឲ្យនាងដ៏ចម្រើនអំពីណាបាន អញនឹងបម្រើ នាងដ៏ចម្រើន នាងដ៏ចម្រើន កុំក្រេវក្រោធឡើយ ។

[ ២៩៥ ] ( នាងអមិត្តតាបនា... ) អ្នកចូរមក ខ្ញុំនឹងប្រាប់អ្នកតាមពាក្យ ដែលខ្ញុំឮមកថា ព្រះរាជាទ្រង់ព្រះនាមវេស្សន្តរនោះ ស្ដេចគង់នៅនាគិរីវង្កត ។ ម្នាលព្រាហ្មណ៍ អ្នកចូរទៅសុំខ្ញុំប្រុសខ្ញុំស្រីនិងព្រះបាទវេស្សន្តរនោះ ។ ក្សត្រ នោះដែលអ្នកសុំហើយ មុខជាប្រទានខ្ញុំប្រុសខ្ញុំស្រីដល់អ្នកពុំខាន ។

[ ២៩៦ ] ( ជូជក... ) អញចាស់ហើយមានកម្លាំងថយ ទាំងផ្លូវក៏

ឆ្ងាយលំបាកទៅណាស់ នាងដ៏ចម្រើនកុំយំយែកឡើយ នាងដ៏ចម្រើនកុំអាក់អន់ចិត្តឡើយ អញនឹងបម្រើនាងដ៏ចម្រើន នាងដ៏ចម្រើនកុំក្រេវក្រោធឡើយ ។

[ ២៩៧ ] ( នាងអមិត្តតាបនា... ) ទាហានមិនទាន់ទៅធ្វើសង្គ្រាម មិនទាន់ច្បាំងចាញ់មុនទៅហើយ ម្នាលព្រាហ្មណ៍ អ្នកមិនទាន់ទាំងទៅផងចាញ់យ៉ាងនោះដែរ ។ នែព្រាហ្មណ៍ បើអ្នកមិននាំខ្ញុំប្រុសខ្ញុំស្រីមកឲ្យខ្ញុំទេ នែព្រាហ្មណ៍ អ្នកចូរដឹងយ៉ាងនេះចុះ ខ្ញុំនឹងមិននៅក្នុងផ្ទះអ្នកទេ ខ្ញុំនឹងធ្វើអំពើមិនគាប់ចិត្តដល់អ្នក អំពើនោះនឹងជាទុក្ខដល់អ្នកមិនខានកាលណាអ្នកនឹងឃើញខ្ញុំតាក់តែង ( ខ្លួន ) ត្រេកត្រអាលជាមួយនឹងពួកប្រុសឯទៀតក្នុងថ្ងៃនក្ខត្តឫក្សក្នុងខាងដើមរដូវទាំងឡាយ ដំណើរនោះនឹងជាទុក្ខដល់អ្នកក្នុងកាលនោះ ។ ម្នាលព្រាហ្មណ៍ កាលអ្នកជាបុគ្គលចាស់ទួញយំរៀបរាប់ព្រោះតែមិនបានឃើញខ្ញុំ ខ្នងរឹតតែកោងទៅ សក់នឹងស្កូវច្រើនឡើង ។

[ ២៩៨ ] ( អភិសម្ពុទ្ធគាថា ) លំដាប់នោះព្រាហ្មណ៍នោះភិតភ័យ លុះក្នុងអំណាចនាងព្រាហ្មណី ត្រូវកាមរាគគ្របសង្កត់បានពោលនឹងនាងព្រាហ្មណីយ៉ាងនេះថា ម្នាលនាងព្រាហ្មណី នាងចូរធ្វើទ្រាបល្ងផង ទ្រាបលាជផង នំទឹកឃ្មុំដែលគេធ្វើល្អហើយផង កត្ត គឺសដូវផងឲ្យជាស្បៀងដល់អញ ។ អញនឹងនាំកុមារជាខ្ញុំពីរនាក់មានជាតិគោត្តត្រកូលនិងប្រទេសដើម្បីនាង កុមារទាំងនោះនឹងបម្រើនាងទាំងយប់ទាំងថ្ងៃមិនខ្ជិលច្រអូសឡើយ ។

[ ២៩៩ ] ជូជកជាព្រហ្មពន្ធុ លុះពោលយ៉ាងនេះហើយក៏ពាក់ស្បែកជើងលំដាប់នោះ គាត់ផ្តេផ្តាំកិរិយាហើយប្រទក្សិណាចៀសចេញទៅ ព្រាហ្មណ៍នោះ

មានមុខយំសស្រោក់បានសមាទានវត្តត្រាច់ទៅកាន់នគររបស់ពួកអ្នកសិវិរាស្ត្រ ជានគរធំទូលាយ ស្វែងរកខ្ញុំប្រុសខ្ញុំស្រី ។

[ ៣០០ ] ព្រាហ្មណ៍នោះបានដើរទៅក្នុងនគរនោះសាកសួរជនទាំងឡាយដែលប្រជុំគ្នាក្នុងនគរនោះថា ព្រះបាទវេស្សន្តរស្តេចយាងទៅក្នុងទីណា យើងគប្បីគាល់ក្សត្រអង្គនោះក្នុងទីណា ។ ពួកជនដែលមកប្រជុំគ្នាក្នុងទីនោះៗបាននិយាយនឹងព្រាហ្មណ៍នោះថា ម្នាលព្រាហ្មណ៍ ក្សត្រត្រូវពួកអ្នកធ្វើឲ្យខ្ទាត់ខ្ទាត់ទៅព្រោះអតិទាន ( ទានប្រសើរ ) គេបំបរបង់ចាកដែនរបស់ព្រះអង្គៗទៅគង់ឯគិរីវង្កត ។ ម្នាលព្រាហ្មណ៍ ក្សត្រត្រូវពួកអ្នកធ្វើឲ្យខ្ទាត់ខ្ទាត់ទៅព្រោះអតិទាន ទ្រង់នាំព្រះឱរសនិងព្រះទេវីទៅគង់នៅឯគិរីវង្កត ។

[ ៣០១ ] ជូជកនោះដែលនាងព្រាហ្មណីដាស់តឿនហើយ ជាបុគ្គលមានសេចក្តីជាប់ចំពាក់នឹងកាម រងទុក្ខក្នុងព្រៃដេរដាសដោយម្រឹគសាហាវជាទីដែលរមាសនិងខ្លាដំបងអាស្រ័យនៅហើយ ។ ព្រាហ្មណ៍នោះបានកាន់ដំបងមានសម្បុរដូចផ្លែព្នៅនិងវែកសម្រាប់បូជាភ្លើង ព្រមទាំងកុណ្ឌីចូលទៅកាន់ព្រៃធំ ដែលគាត់បានឮថាជាទីដែលព្រះវេស្សន្តរព្រះអង្គឲ្យសេចក្តីប្រាថ្នា ( គង់នៅ ) ។ ឆ្កែទាំងឡាយបានចោមរោមគាត់កំពុងចូលទៅកាន់ព្រៃធំនោះ គាត់វង្វេងផ្លូវ ស្រែកទ្រហោយំស្មុះឃ្លាតទៅក្នុងទីឆ្ងាយអំពីផ្លូវ ( ដែលជាទីទៅកាន់គិរីវង្កត ) ។ លំដាប់នោះព្រាហ្មណ៍ដែលល្មោភក្នុងភោគៈមិនសង្រួមទៅវង្វេងនៅក្នុងផ្លូវដែលជាទីទៅកាន់គិរីវង្កត ( ត្រូវពួកឆ្កែទាំងឡាយចោមព័ទ្ធក៏ឡើងទៅអង្គុយនៅលើដើមឈើ ) បានពោលគាថាទាំងនេះថា

[ ៣០២ ] ជនណាហ្ន៎ ប្រាប់ព្រះវេស្សន្តរដែលជារាជបុត្តដ៏ប្រសើរ ឈ្នះសេចក្តីកំណាញ់មិនចាលចាញ់ ជាអ្នកឲ្យសេចក្តីក្សេមក្នុងកាលមានភ័យដល់ខ្ញុំ ។ ព្រះបាទវេស្សន្តរណាជាទីពឹងនៃពួកអ្នកស្នូមដូចជាផែនដីជាទីពឹងនៃពួកសត្វ នរណាហ្ន៎ ប្រាប់ព្រះវេស្សន្តរមហារាជ មានឧបមាដូចផែនដីដល់ខ្ញុំ ។ ព្រះបាទវេស្សន្តរណាជាទីទៅរបស់ពួកស្នូម ដូចជាសាគរជាទីទៅនៃផ្លូវទឹកទាំងឡាយ នរណាហ្ន៎ ប្រាប់ព្រះវេស្សន្តរមហារាជមានឧបមាដូចជាសមុទ្ទដល់ខ្ញុំ ។ នរណាហ្ន៎ ប្រាប់ព្រះវេស្សន្តរមហារាជមានឧបមា ដូចជាអន្លង់ទឹកមានកំពង់ល្អងាយផឹក មានទឹកត្រជាក់ជាទីមនោរម្យដេរដាសដោយផ្កាឈូកសប្រកបដោយលំអងផ្កាដល់ខ្ញុំ ។ នរណាហ្ន៎ ប្រាប់ព្រះវេស្សន្តរមហារាជមានឧបមាដូចជាដើមពោធិ៍បាយដែលដុះក្បែរផ្លូវ មានម្លប់ត្រជាក់ជាទីមនោរម្យ ជាទីសម្រាករបស់បុគ្គលនឿយហត់ ជាទីពំនាក់នៃបុគ្គលដែលលំបាកដល់ខ្ញុំ ។ នរណាហ្ន៎ ប្រាប់ព្រះវេស្សន្តរមហារាជ មានឧបមាដូចជាដើមជ្រៃដែលដុះក្បែរផ្លូវ មានម្លប់ត្រជាក់ ជាទីមនោរម្យ ជាទីសម្រាកនៃបុគ្គលនឿយហត់ ជាទីពំនាក់នៃបុគ្គលដែលលំបាកដល់ខ្ញុំ ។ នរណាហ្ន៎ ប្រាប់ព្រះវេស្សន្តរមហារាជ មានឧបមាដូចដើមស្វាយ មានម្លប់ត្រជាក់ជាទីមនោរម្យ ជាទីសម្រាកនៃបុគ្គលនឿយហត់ ជាទីពំនាក់នៃបុគ្គលដែលលំបាកដល់ខ្ញុំ ។ នរណាហ្ន៎ ប្រាប់ព្រះវេស្សន្តរមហារាជ មានឧបមាដូចដើមរាំងដែលដុះក្បែរផ្លូវ មានម្លប់ត្រជាក់ជាទីមនោរម្យ ជាទីសម្រាកនៃបុគ្គលនឿយហត់ ជាទីពំនាក់នៃបុគ្គលដែលលំបាកដល់ខ្ញុំ ។ នរណាហ្ន៎ ប្រាប់ព្រះវេស្សន្តរមហារាជ មានឧបមាដូចដើម

ឈើដែលដុះក្បែរផ្លូវ មានម្លប់ត្រជាក់ជាទីមនោរម្យ ជាទីសម្រាកនៃបុគ្គលនឿយហត់ ជាទីពំនាក់នៃបុគ្គលដែលលំបាកដល់ខ្ញុំ ។ ម្យ៉ាងទៀតបុគ្គលណានិយាយប្រាប់ថា ខ្ញុំឯងស្គាល់កន្លែងនៅនៃព្រះបាទវេស្សន្តរដូច្នេះដល់ខ្ញុំ ដែលចូលមកក្នុងព្រៃធំកំពុងយំរៀបរាប់យ៉ាងនេះបុគ្គលនោះឈ្មោះថា ញ៉ាំងសេចក្តីត្រេកត្រអាលឲ្យកើតដល់ខ្ញុំ ។ មួយទៀតបុគ្គលណានិយាយប្រាប់ថា ខ្ញុំដឹងទីលំនៅនៃព្រះបាទវេស្សន្តរដូច្នេះដល់ខ្ញុំ ដែលចូលមកក្នុងព្រៃធំ កំពុងយំរៀបរាប់យ៉ាងនេះ បុគ្គលនោះរមែងប្រទះបុណ្យដ៏ច្រើនព្រោះតែសម្តីមួយមាត់នោះឯង ។

[ ៣០៣ ] ចេតបុត្តព្រានព្រៃ អ្នកចូលទៅក្នុងព្រៃបានស្រដីតបទៅនឹងជូជកព្រាហ្មណ៍នោះថា នៃព្រាហ្មណ៍ ក្សត្រត្រូវពួកអ្នកធ្វើឲ្យខ្ចាត់ខ្ចាត់ទៅព្រោះអតិទានត្រូវគេបណ្តេញចេញចាកដែនរបស់ព្រះអង្គទៅគង់ឯគិរីវង្កត ។ ម្នាលព្រាហ្មណ៍ ក្សត្រត្រូវពួកអ្នកធ្វើឲ្យខ្ចាត់ខ្ចាត់ទៅព្រោះអតិទាន ទ្រង់នាំព្រះរាជបុត្តនិងព្រះទេវីទៅគង់ឯគិរីវង្កត ។ អ្នកជាបុគ្គលឥតប្រាជ្ញាមិនខំប្រឹងធ្វើការងារចេញអំពីដែនចូលមកកាន់ព្រៃធំដើរស្វែងរកព្រះរាជបុត្ត ដូចជាកុកស្វែងរកត្រីក្នុងទឹក ។ នៃព្រាហ្មណ៍ យើងមុខជាមិនឲ្យជីវិតដល់អ្នកនោះក្នុងទីនេះទេព្រោះថា ព្រួញនេះដែលយើងបាញ់សំដៅអ្នកហើយ មុខជាផឹកឈាមអ្នក ។ ម្នាលព្រាហ្មណ៍ យើងមុខជានឹងកាត់ក្បាលអ្នក ពន្លះកាត់យកបេះដូងព្រមទាំងទងហើយបូជាបន្ថសកុណយញ្ញ ( បូជាទេវតាក្នុងផ្លូវ ) ដោយសាច់របស់អ្នក ។ ម្នាលព្រាហ្មណ៍ យើងនឹងកាត់យកបេះដូងរបស់អ្នករួចផ្គងការបូជាដោយសាច់

ខ្លាញ់ខាប់និងក្បាលរបស់អ្នក ។ ម្នាលព្រាហ្មណ៍ ការបូជានោះដោយសាច់របស់អ្នកនោះឈ្មោះថា យើងបូជាល្អហើយ មួយទៀតអ្នកនឹងនាំព្រះទេពីនិងព្រះរាជបុត្រាបុត្រីនៃព្រះរាជបុត្តមិនបានទេ ។

[ ៣០៤ ] ( ជូជក... ) នែចេតបុត្ត អ្នកចូរស្តាប់យើងព្រាហ្មណទូត អ្នកមិនត្រូវសម្លាប់ទេព្រោះហេតុនោះឯងបានជាគេមិនសម្លាប់ទូត នេះជាធម៌មានមកយូរយារណាស់ហើយ ពួកអ្នកសិវិរាស្ត្រទាំងអស់បាត់ខឹងហើយ ព្រះបិតាចង់ជួបព្រះបាទវេស្សន្តរនោះទាំងព្រះមាតាព្រះអង្គក៏មានកម្លាំងថយ ពុំយូរឡើយមុខជានឹងងងឹតព្រះនេត្រ ( ដោយទ្រង់ព្រះពិលាប ) ។ នែចេតបុត្ត អ្នកចូរស្តាប់ពាក្យយើង យើងជារាជទូតដែលក្សត្រទាំងនោះបញ្ជូនមកហើយ យើងនឹងនាំទៅនូវព្រះរាជបុត្ត បើអ្នកដឹងអ្នកចូរប្រាប់យើង ។

[ ៣០៥ ] ( ចេតបុត្ត... ) នែព្រាហ្មណ៍ អ្នកជាទូតជាទីស្រឡាញ់នៃព្រះបាទវេស្សន្តរដែលជាទីស្រឡាញ់របស់យើង យើងខ្ញុំនឹងឲ្យកាជន៍ដ៏ពេញដោយទឹកផង តុម្ពទឹកឃ្មុំនេះផង ភ្លៅម្រឹគ ( ដែលចម្អិនស្រេច ) ផងដល់អ្នក មួយទៀតព្រះបាទវេស្សន្តរដែលជាអ្នកឲ្យវត្ថុជាទីប្រាថ្នា គង់នៅក្នុងប្រទេសណា យើងនឹងប្រាប់ប្រទេសនោះដល់អ្នក ។

**ចប់ ជូជកបព្វៈ ។**

[ ៣០៦ ] ( ចេតបុត្ត... ) នែមហាព្រាហ្មណ៍ នោះហ្ន៎ ភ្នំគន្ធមាទន៍ជាវិការៈនៃថ្ម ដែលព្រះបាទវេស្សន្តរ ស្តេចគង់នៅជាមួយនឹងព្រះរាជបុត្តនិង

ព្រះទេពី ។ ព្រះរាជាទ្រទ្រង់ភេទអ្នកបួសដ៏ប្រសើរផង មានតម្ពក់និងវែកសម្រាប់បូជាភ្លើងនិងជដាផង ទ្រង់ស្លៀកជណ្តប់ស្បែកខ្លា ផ្ទំលើផែនដីនមស្ការនូវភ្លើង ។ ឈើទាំងឡាយនុ៎ះ ដ៏ខៀវទ្រទ្រង់ផ្លែផ្សេងៗដ៏ខ្ពស់មានកំពូលទើសមេឃដ៏ខៀវដូចក្នុំផ្កាអញ្ចន ។ មានដើមត្របែកព្រៃ ដើមត្រចៀកប្រើស ដើមគគីរ ដើមរាំងដើមពន្រនិងដើមជ្រៃទោរទន់ទៅមកដោយខ្យល់ដូចជាមាណពទើបផឹក ( ស្រា ) មួង ។ នៅខាងលើមែកឈើទាំងឡាយពួសួរស័ព្ទដូចជាចម្រៀងទិព្វ ( ព្រោះ ) មានហ្វូងប៉ោលតោកនិងតាវៅ ចុះទំពីឈើមួយទៅឈើមួយ ។ មែកឈើនិងស្លឹកឈើទាំងឡាយដែលខ្យល់បក់ត្រូវហើយឮដូចជាហៅរកជនកំពុងដើរ ដូចជារីករាយនឹងជនដែលមកដល់ត្រេកត្រអាលនឹងជនដែលនៅអាស្រ័យ ។ អ្នកនឹងចូលទៅក្នុងអាស្រមដែលជាកន្លែងព្រះបាទវេស្សន្តរ ស្តេចគង់នៅជាមួយនឹងព្រះរាជបុត្រាបុត្រីទាំងឡាយ ស្តេចទ្រទ្រង់ភេទជាអ្នកបួសដ៏ប្រសើរមានតម្ពក់និងវែកសម្រាប់បូជានិងព្រះជដា ទ្រង់ស្លៀកស្បែកខ្លា ផ្ទំលើផែនដី នមស្ការភ្លើង ។

[ ៣០៧ ] ក្នុងទីនុ៎ះមានដើមស្វាយ ខ្វិត ខ្នុរ រាំង ព្រីង សម៉ពិភេទក៍ សម៉ក្កុក កន្ទួតព្រៃ ពោធិ ពុទ្រា ទន្លាប់មាស ជ្រៃនិងក្រសាំង មាក់សាង មានផ្លែដ៏ផ្អែមរុងរឿងនិងល្វាមានផ្លែទុំ ដើមទាបៗមានចេកអំបូងក្កុក ចេកអំបូងស្នែងនិងចន្ទន៍មានផ្លែផ្អែមដូចទឹកឃ្មុំ គេតែងយកឃ្មុំឥតមេក្នុងទីនោះមកជារបស់ខ្លួនហើយបរិភោគ ។ ក្នុងទីនុ៎ះមានស្វាយខ្លះកំពុងផ្កា ស្វាយខ្លះទើបជាក្បាលរុយ ស្វាយខ្លះមានផ្លែខ្ចីនិងទុំ ផ្លែទាំងពីរបែបនោះមានសម្បុរដូចខ្នងកញ្ចាញ់

ចេក ។ ក្នុងទីនុ៎ះ បុរស ( ឈើ ) ខាងក្រោមបេះផ្លែស្វាយទុំទាំងឡាយ ស្វាយទាំងឡាយទាំងខ្ចីទាំងទុំ មានសម្បុរក្លិននិងរសដ៏ឧត្តម ។ ខ្ញុំតែងមានសេចក្ដីអស្ចារ្យក្រៃពេក ទាំងការលាន់ឮថាហ៊ឹងៗក៏ប្រាកដដល់ខ្ញុំ ប្រទេសនោះឧបមាដោយនន្ទនវ័ន ល្អដូចជាទីនៅរបស់ពួកទេវតា ។ ត្នោតដូងដុះចម្រុះគ្នាក្នុងព្រៃល្មើដ៏ធំ ផ្កាទាំងឡាយដូចជាកម្រងដែលគេក្រងហើយ ឬប្រាកដដូចជាជាយទង់ជ័យ ។ ខ្លែងគង់ គុម្ពកោដ្ឋ គុម្ពក្រស្នា ប្រទៀង បុន្នាគតូច បុន្នាគធំនិងរលួសមានផ្កាពណ៌ផ្សេងៗ រីកស្គុសស្គាយដូចផ្កាយដែលភ្លឺព្រោងព្រាតឮដ៏អាកាស ។ រាជព្រឹក្ស ខ្ទញ កំញាន រាក់ខ្មៅ ជ្រៃធំ ទន្ទានិងធ្នង់ជាច្រើនបញ្ចេញផ្កាក្នុងទីនោះ ។ ខ្លែងគង់ ស្រល់ ស្មោល សង្ក័រ ខ្នុរ សម្ពត្របែកព្រៃនិងរាំងជ្រុះផ្កាក្នុងទីនោះ ដូចជាលានចំបើង ។ ក្នុងភូមិភាគជាទីមនោរម្យជិតអាស្រមនោះមានស្រះបោក្ខរណី ដេរដាសដោយផ្កាឈូកនិងផ្កាព្រលិតដូចជាក្នុងនន្ទនវ័នរបស់ពួកទេវតា ។ មួយទៀតពួកតាវៅដែលស្រវឹងដោយរសផ្កាយំពីរោះនៅលើឈើដែលមានផ្ការីកតាមរដូវ ញុំាងព្រៃនោះឲ្យលាន់ឮគឹកកង ។ លំអងដែលរោយរាយចេញអំពីកេសរដែលមាននៅគ្រប់ស្លឹកឈូកមានរសផ្អែម បើខ្យល់បក់ផាត់មកក្នុងទីអាស្រមនុ៎ះ អំពីទិសខាងត្បូងនិងខាងលិច ។ អាស្រមក៏ដេរដាសដោយលំអងកេសរផ្កាឈូកក្នុងស្រះបោក្ខរណីនុ៎ះ មានផ្លែក្រចាប់ដ៏ថ្លោសៗនិងស្រូវសាលីជ្រុះរោយរាយលើផែនដី ។ មួយទៀតមានត្រី អណ្ដើកនិងក្ដាមច្រើនបែបហែបហែលទៅមកក្នុងស្រះនោះ រសដែលហូរចេញអំពីក្រអៅឈូកមានឱជាដូចទឹកឃ្មុំនិងរស ដែលហូរចេញអំពីមើម

ឈូកមានឱជាដូចទឹកដោះស្រស់និងទឹកដោះថ្លា ព្រៃនោះមានក្លិនក្រអូបផ្សេងៗ ផ្សព្វផ្សាយក្លិនឈ្ងុយឈ្ងប់ ។ ព្រៃនោះដូចជា ( ញុំាងជនដែលមកដល់ ) ឲ្យរីករាយ ដោយក្លិន ដោយផ្កានិងមែកឈើ កន្ទង់ទាំងឡាយក៏ញុំាងព្រៃឲ្យគឹកកងដោយជុំវិញព្រោះតែក្លិនផ្កា ។ មិនតែប៉ុណ្ណោះសោត មានសត្វបក្សីទ្វិជាតិជាច្រើន មានសម្បុរផ្សេងៗគ្នា ត្រេកត្រអាលជាមួយនឹងមេយំរកគ្នាទៅវិញទៅមកក្នុងស្រះនោះ ។ ពួកបក្សីដែលនៅក្នុងស្រះបោក្ខរណី គឺសត្វនន្ទិកា ១ សត្វជីវបុត្តា ១ សត្វជីវបុត្តាបិយាចនោ ១ សត្វបិយាបុត្តាបិយានន្ទា ១ ។ ផ្កាទាំងឡាយដូចជាកម្រងផ្កាដែលគេក្រងហើយ ប្រាកដដូចជាជាយទង់ជ័យ ពុំនោះដូចជាកម្រងផ្កា ដែលមាលាការដ៏ឈ្លាសក្រងយ៉ាងល្អ ដោយផ្កាមានពណ៌ផ្សេងៗ ។ ក្នុងទីដែលព្រះបាទវេស្សន្តរ ទ្រង់គង់នៅជាមួយនឹងព្រះរាជបុត្រាបុត្រី ព្រះអង្គទ្រង់ភេទជាអ្នកបួសដ៏ប្រសើរ មានតម្ពក់និងវែកសម្រាប់បូជាភ្លើងផងនិងព្រះជដា ទ្រង់ស្លៀកស្បែកខ្លា ផ្ទំនៅលើផែនដី នមស្ការភ្លើង ។

[ ៣០៨ ] ( ជូជក... ) កត្ត គឺសដូវនេះដែលយើងលាយហើយដោយទឹកឃ្មុំ យើងនឹងឲ្យនូវទឹកឃ្មុំដែលយើងធ្វើល្អហើយផងនិងកត្ត គឺសដូវផងដល់អ្នក ។

[ ៣០៩ ] ( ចេតបុត្ត... ) ស្បៀងចូរនៅជារបស់អ្នកឯងចុះ យើងមិនត្រូវការស្បៀងទេ នែព្រាហ្មណ៍ អ្នកចូរយកស្បៀងអំពីនេះទៅ នែព្រាហ្មណ៍ អ្នកចូរទៅតាមស្រួលចុះ ។ ផ្លូវនេះជាផ្លូវល្មមដើរចុះបុគ្គលម្នាក់ ត្រង់ទៅកាន់អាស្រម ក្នុងអាស្រមនោះមានឥសីឈ្មោះអច្ចុតៈមានធ្មេញប្រកបដោយមន្ទិល

មានសរីរៈប្រឡាក់ដោយធូលី ទ្រទ្រង់ភេទជាអ្នកបួសដ៏ប្រសើរផង តម្កល់ផង វែកសម្រាប់បូជាភ្លើងផង ជដាផង ។ ឥសីឈ្មោះអច្ចុតៈនោះ ជាអ្នកស្លៀកស្បែកខ្លា ដេកនៅលើកម្រាលស្លឹកឈើលើផែនដី នមស្ការភ្លើង អ្នកចូរទៅសួរលោកចុះ លោកនឹងប្រាប់ផ្លូវដល់អ្នកពុំខាន ។

[ ៣១០ ] ជូជកជាព្រហ្មពន្ធុ លុះបានឮពាក្យនេះហើយក៏មានចិត្តរីករាយ ប្រទក្សិណាចេត្តបុត្តព្រានព្រៃ រួចដើរតម្រង់ទៅកាន់អច្ចុតឫសី ។

**ចប់ ចុល្លវនវណ្ណនា ។**

[ ៣១១ ] កាលជូជកព្រាហ្មណ៍នោះដើរទៅជួបឥសីឈ្មោះអច្ចុតៈ លុះជូជកបានឃើញឥសីនោះហើយក៏សំណេះសំណាលជាមួយនឹងឥសីថា លោកដ៏ចម្រើន សុខសប្បាយទេឬ លោកដ៏ចម្រើនមិនមានរោគាពាធទេឬ លោកចិញ្ចឹមជីវិតដោយការស្វែងរក ( ស្រួល ) ទេឬ មើមឈើនិងផ្លែឈើមានច្រើនដែរឬ ។ ពួករបោម មូស ពស់មានតិចទេឬ ក្នុងព្រៃដេរដាសដោយម្រឹគសាហាវមិនមានការបៀតបៀនទេឬ ។

[ ៣១២ ] ( តាបស... ) ម្នាលព្រាហ្មណ៍ អាត្មាសុខសប្បាយទេ អាត្មាមិនមានរោគាពាធទេ មួយទៀតអាត្មាចិញ្ចឹមជីវិតដោយការស្វែងរក ( ស្រួល ) ទេ ទាំងមើមឈើផ្លែឈើក៏មានច្រើនដែរ ។ មួយវិញទៀតពួករបោម មូស ពស់មានតិចទេ ក្នុងព្រៃដ៏ដេរដាសដោយម្រឹគសាហាវមិនមានការបៀតបៀនអាត្មាទេ ។ អាត្មានៅក្នុងអាស្រមនេះអស់ប្រជុំនៃឆ្នាំជាច្រើន អាត្មាមិនដែល

ស្គាល់អាពាធ មិនជាទីត្រេកអរនៃចិត្តកើតហើយទេ ។ នែមហាព្រាហ្មណ៍ អ្នកមកល្អហើយអ្នកមិនមែនមកអាក្រក់ទេ ម្នាលព្រាហ្មណ៍ដ៏ចម្រើន អ្នកអញ្ជើញចូលមកខាងក្នុង អ្នកចូរលាងជើងទាំងឡាយរបស់អ្នកចុះ ។ នែព្រាហ្មណ៍ អ្នកចូរបរិភោគផ្លែទន្លាប់ ផ្លែទ្រយឹង ផ្លែមាក់សាង ផ្លែមាក់ដោកមានរសឆ្ងាញ់ពីសាដូចជាទឹកឃ្មុំ ។ ទាំងទឹកត្រជាក់នេះអាត្មាបានដងមកអំពីជ្រោះភ្នំ នែមហាព្រាហ្មណ៍ អ្នកចូរផឹកទឹកនោះចុះប្រសិនបើអ្នកត្រូវការ ។

[ ៣១៣ ] ( ជូជក... ) វត្ថុដែលលោកបានឲ្យ ខ្ញុំបានទទួលយកហើយ ដែលលោកបានធ្វើឲ្យជាជំនូនដល់ខ្ញុំទាំងអស់ ខ្ញុំមកដើម្បីចង់ចួបនឹងព្រះរាជបុត្តបង្កើតរបស់ព្រះបាទសញ្ជ័យដែលពួកអ្នកសិវិរាស្ត្របំបរបង់ហើយនោះ ប្រសិនបើលោកជ្រាប សូមប្រាប់ខ្ញុំផង ។

[ ៣១៤ ] ( តាបស... ) អ្នកមិនមែនមកគាល់ព្រះបាទសិវិដើម្បីបុណ្យទេ អ្នកទំនងជាចង់បានព្រះទេពីរបស់ព្រះរាជាដែលជាស្ត្រីប្រតិបត្តិក្នុងកស្តា ។ អ្នកទំនងជាចង់បានកុមារីឈ្មោះកណ្ហាជិនាធ្វើជាទាសីនិងកុមារឈ្មោះជាលីធ្វើជាទាសៈ ឬក៏អ្នកមកដើម្បីនាំយកជនទាំង ៣ នាក់ គឺមាតានិងបុត្រីបុត្រាទៅអំពីព្រៃ នែព្រាហ្មណ៍ ឯព្រះបាទវេស្សន្តរនោះមិនមានភោគៈ មិនមានទ្រព្យ មិនមានធញ្ញជាតិទេ ។

[ ៣១៥ ] ( ជូជក... ) ខ្ញុំមិនមែនមានសភាពជាអ្នកទីងទីងលោកទេ ខ្ញុំមិនមែនមកដើម្បីសូមទេ កាលចួបប្រទះនឹងពួកលោកដ៏ប្រសើរជាការល្អ ការនៅរួមនាំមកនូវសេចក្តីសុខសព្វៗកាល ។ ព្រះបាទសិវិដែលពួកអ្នកសិវិរាស្ត្រ

បំបរបង់ហើយ ខ្ញុំមិនដែលបានឃើញបានជាខ្ញុំមកគាល់ព្រះអង្គ ប្រសិនបើលោកជ្រាបសូមប្រាប់ខ្ញុំផង ។

[ ៣១៦ ] ( តាបស... ) នៃមហាព្រាហ្មណ៍ នុ៎ះហ្ន៎ភ្នំគន្ធមាទន៍ជាវិការៈនៃថ្មដែលព្រះបាទវេស្សន្តរស្តេចគង់នៅជាមួយព្រះរាជបុត្តនិងព្រះទេពី ។ ព្រះរាជាទ្រទ្រង់ភេទនៃបព្វជិតដ៏ប្រសើរ មានតម្ពក់និងវែកសម្រាប់បូជាភ្លើង សក់កណ្តាញ់ ស្លៀកដណ្តប់ស្បែកខ្លា ផ្ទំផ្ទាល់ផែនដី នមស្ការភ្លើង ។ ពួកឈើដែលមើលទៅឃើញនុ៎ះ ជាឈើមានពណ៌ខៀវទ្រទ្រង់ផ្លែផ្សេងៗ ខ្ពស់មានចុងស្មើនឹងពពក មានពណ៌ខៀវដូចភ្នំផ្កាអញ្ជន គឺដើមត្របែកព្រៃ ត្រចៀកប្រើស គគីរ រាំងភ្នំ ពង្រនិងជ្រៃ ញ័រទ្រេតទ្រោតដោយខ្យល់ដូចពួកមាណពទើបផឹក ( សុរា ) ម្តង ។ ( សំឡេងរបស់ពួកសត្វស្លាបផ្សេងៗ ) លើមែកឈើទាំងឡាយលាន់ឮដូចចម្រៀង ( ទិព្វ ) ពួកសត្វប៉ោលតោក សត្វតាវៅនាំគ្នាហើរធ្មៀលធ្មាត់អំពីដើមឈើមួយទៅកាន់ដើមឈើមួយ ។ អស់ទាំងមែកឈើមានស្លឹកដែលត្រូវខ្យល់បក់មក ក៏ហាក់ដូចជាដង្ហោយហៅជនដែលកំពុងដើរ ដូចជាត្រេកអរនឹងជនដែលមកដល់ រីករាយនឹងជនដែលនៅអាស្រ័យ ។ ( អ្នកនឹងឃើញសម្បត្តិនៃអាស្រមបទ ) ក្នុងអាស្រមដែលព្រះបាទវេស្សន្តរស្តេចគង់នៅជាមួយព្រះរាជបុត្តនិងព្រះទេពី ព្រះអង្គទ្រទ្រង់ភេទបព្វជិតដ៏ប្រសើរ មានតម្ពក់និងវែកសម្រាប់បូជាភ្លើងនិងសក់កណ្តាញ់ ស្លៀកដណ្តប់ស្បែកខ្លា ផ្ទំផ្ទាល់ផែនដី នមស្ការភ្លើង ។ មានផ្កាទន្លាប្រជុះរោយរាយដេរដាសលើភូមិភាគជាទីត្រេកអរនៃចិត្ត ទាំងផ្ទៃផែនដីក៏មានពណ៌ខៀវស្រងាត់ដោយ

ស្មៅចិញ្ចៀនឥតមានធូលីហុយក្នុងទីនោះឡើយ ។ ទាំងស្មៅសោតក៏មានពណ៌ដូចជាផ្ចិតកនៃក្ងោក មានឧបមាស្មើដោយសម្ផស្សនៃសំឡី មិនហួសអំពី ៤ ធ្នាប់ដោយជុំវិញ ។ មានស្វាយ ព្រីង ក្រិដ្ឋ ល្វាមានផ្លែទុំក្នុងទីទាបព្រៃនោះ សម្រាប់ញុំាងតម្រេកឲ្យចម្រើន ដោយពួកឈើសម្រាប់បរិភោគ ។ ទឹកស្អាត មានក្លិនក្រអូបមានសម្បុរប្រហែលគ្នានឹងពណ៌នៃកែវពៃទូរ្យ កុះករដោយហ្វូងត្រីរមែងហូរទៅក្នុងព្រៃនោះ ។ ក្នុងទីជិតនៃអាស្រមបទនោះមានស្រះបោក្ខរណីដ៏ដេរដាសដោយឈូកនិងឧប្បល ក្នុងភូមិភាគជាទីត្រេកអរនៃចិត្ត ដូចជាក្នុងនន្ទនវ័ននៃពួកទេវតា ។ ម្នាលព្រាហ្មណ៍ ក្នុងស្រះនោះសឹងធូកធ្លាស់ដោយឧប្បលជាតបី ( នេះ ) គឺឧប្បលខៀវ ឧប្បលសនិងឧប្បលក្រហម ។

[ ៣១៧ ] ក្នុងស្រះនោះ ( ស ) ដូចជាសំពត់សម្បកឈើ ស្រះនោះឈ្មោះថាមុចលិន្ទស្រះ ដេរដាសដោយព្រលឹតនិងស្គន់ទាំងឡាយផង ដោយត្រកួនទាំងឡាយផង ។ មួយទៀតពួកផ្កាឈូកក្នុងស្រះនោះ រីកស្គុសស្គាយឃើញហាក់ដូចជាគ្មានទីបំផុត ខ្លះក៏រីកក្នុងគិម្ហរដូវ ខ្លះរីកក្នុងហេមន្តរដូវឋិតនៅក្នុងទឹកត្រឹមជង្គង់ ។ ផ្ទៃទឹកនោះសឹងវិចិត្រល្អដ៏ដេរដាសដោយផ្កាមានក្លិនក្រអូបឈ្ងុយឈ្ងប់បក់ផ្សាយទៅ ពួកមេឃ្មុំ កន្ទង់ទ្រហឹងអឹងកងជុំវិញព្រោះក្លិនផ្កា ។

[ ៣១៨ ] ម្នាលព្រាហ្មណ៍ មួយទៀតមានពួកដើមឈើ គឺក្ទម្ព ប្រទៀងនិងរលួសផ្អុង មានផ្ការីកស្គុសស្គាយដុះក្បែរមាត់ទឹកមុចលិន្ទស្រះនុ៎ះ ។ មានទាំងដើមព្រូស ជន្ទូស ស្វាត ខ្ទឹង មានផ្ការីក អមសងខាងមុចលិន្ទស្រះ ។

មានពួកជីរខ្មៅ ជីរស ឈូកត្រាញ់ គណ្ឋីស គណ្ឋីខ្មៅ ធ្មង់ បញ្ចេញផ្កាក្បែរមុចលិន្ទស្រះនុ៎ះ មានក្លិនក្រអូបបក់ផ្សាយទៅ ។ មានពួកដើមសុក្រំ ដកពពពូលថ្ម ម្រុំមានផ្ការីក ពួកដើមកេតកៈ កណិការ ច្បាទេសមានផ្ការីក ។ ពួកថ្ងាន់ស ថ្ងាន់ខ្មៅ ជន្ទាត់ដែមានផ្ការីកមានត្រួយរីកល្អដុះនៅប្រាលរទាលដូចជាផ្កាចារ ។ ពួកដើមសត្បាស សត្បាខ្មៅ ដើមចេកមាស ដើមដកគាំ ( ព្រៃនោះរុងរឿង ) ដោយផ្កាទឹកដោះខ្លានិងគន្ធាផង ដោយផ្កាធ្មង់និងទន្លាផង ។ ដើមដកខិម រកា អំពៅព្រៃ អង្គាជី ក្រស្នា គ្រញូង កោដ្ឋស កោដ្ឋខ្មៅ មានផ្ការីក ។ ព្រឹក្សា ( ទាំងនោះ ) ទោះខ្វីសឹងមានដើមដ៏ត្រង់មានផ្ការីកក្បែរមុចលិន្ទស្រះនុ៎ះ ដុះនៅទាំងសងខាងអាស្រម ( ព័ន្ធព័ទ្ធ ) ជុំវិញរោងភ្លើង ។

[ ៣១៩ ] មួយទៀតមានទាំងស្ទឹកត្រែ សណ្តែកបាយ សណ្តែករាជមាសជាច្រើន សារាយនិងកំពឹងពួយជាច្រើន ដុះក្បែរមាត់ទឹកមុចលិន្ទស្រះនុ៎ះ ។ ( ទឹកនោះ ) មានប្រាំងជាទំនប់ត្រូវខ្យល់បក់មករលកក៏ខ្វាយខ្វរឡើង មានពួកមេឃ្មុំយំដោយសំឡេងដ៏ពីរោះ ហើរឆ្វៀលឆ្វាត់គុម្ពឈើមានម្លូក្ទំ ស្វាស្នាប់ ស្វាធំ ក្នុងទីទំនាបទៀបមុចលិន្ទស្រះនោះមានត្រកួនជាច្រើន ។ ម្នាលព្រាហ្មណ៍ ពួកព្រឹក្សាសឹងដ៏ដេរដាសដោយពួកវល្លិឈ្មោះឯឡម្ពកៈ ដុះនៅក្លិនរបស់ផ្កានៃវល្លិទាំងនោះដែលគេទ្រទ្រង់អស់ ៧ ថ្ងៃ មិនទាន់បាត់ក្រអូបឡើយ ។ ពួកផ្កាដុះនៅក្នុងចំណែកទាំងពីរនៃមុចលិន្ទស្រះ ព្រៃនោះដ៏ដេរដាសដោយពួកផ្កាលំចង់ដ៏រុងរឿង ក្លិនរបស់ផ្កាទាំងនោះដែលគេទ្រទ្រង់អស់កន្លះខែក៏មិនទាន់បាត់ក្រអូបឡើយ ។ រីឯអញ្ចាញខៀវ អញ្ចាញស អញ្ចាញលឿងមានផ្ការីកស្គុះ

ស្គាយ ព្រៃនោះដ៏ដេរដាសដោយម្ទិះរួត ម្ទិះលា ។ រីឯព្រៃនោះដូចជា ( ញុំាង ជនដែលមកដល់ ) ឲ្យរីករាយដោយក្លិនផង ដោយមែកមានផ្កាទាំងឡាយផង ឯពួកកន្ទង់មានសូរសព្ទទ្រហឹងអឺងកងជុំវិញ ព្រោះក្លិនផ្កា ។ ម្នាលព្រាហ្មណ៍ ក្នុងមុចលិន្ទស្រះនោះមានពួកត្រឡាចបីមុខ គឺមួយពួកផ្លែប៉ុនក្អម ពីរពួកទៀត ផ្លែប៉ុនសម្ភោរ ។

[ ៣២០ ] មួយទៀតមានស្លែដ៏ច្រើននិងខ្ទឹមសលាយដោយខ្ទឹមក្រហម ជាច្រើន ដើមរកាទាំងឡាយដុះនៅដូចជាដើមត្នោត មានទាំងពួកលំចង់ដ៏ច្រើន ដែលគេគប្បីក្តិច ដុះនៅក្បែរមុចលិន្ទស្រះនុ៎ះ ។ មានវល្លិម្ទិះរួត ម្ទិះលា ក្លាំពាក់ ឈើឯម ពួកអសោកព្រឹក្សនិងដើមទៀនព្រៃ ល្ពៅ វល្លិផ្តៅធ្មាំង ។ ស្មៅកន្ទុយ ដំរី ននោងព្រៃ ដើមខ្ទឹម ដើមម្ទិះសឹងដ៏មានផ្ការីកស្គុសស្គាយ វល្លិចារមាន ផ្ការីកដុះព័ទ្ធព័ន្ធដើមឈើ ។ ពួកឈើនាងនួន មៀនព្រៃ យុថ្កាមានក្លិនដូចជា ទឹកឃ្មុំ ម្ទិះវល្លិ ម្ទិះប្រក្រតី ច្បា បទុមុត្តរព្រឹក្សសឹងដ៏រុងរឿងល្អ ។ ពួកប្រទៀង កប្បាសសមុទ្ទ កណិការសឹងដ៏មានផ្ការីកស្គុសស្គាយ ប្រាកដដូចជាបណ្តាញ មាស សឹងដ៏រុងរឿងល្អដូចជាអណ្តាតភ្លើង ។ ពួកផ្កាណាកើតលើគោកនិងកើត ក្នុងទឹក ពួកផ្កាទាំងអស់នោះប្រាកដក្នុងមុចលិន្ទស្រះនោះ មុចលិន្ទស្រះទ្រទ្រង់ ទឹកច្រើន គួរឲ្យត្រេកអរយ៉ាងនេះឯង ។

[ ៣២១ ] មួយទៀតក្នុងស្រះបោក្ខរណីនោះ មានពួកសត្វដែលត្រាច់ ទៅក្នុងទឹកជាច្រើន គឺត្រីឆ្ពិន ត្រីរ៉ស់ ត្រីអណ្តែង ក្រពើ មករ ឆ្លាម ។ មានទាំងផ្ទិតឃ្មុំ ឈើឯម ធ្នាំពូ ប្រយង្គុ ស្មៅក្រវាញជ្រូក ស្មៅមាត់ក្អែក

ដើមសត្តបុស្ស សម្បុរល្វែង ។ ដើមពុំសែន ដើមឫសសាមសិប ក្រស្នា វល្លិ៍ ជណ្តើរស្វា ឈូកត្រាញ់ ក្រវាន់ កោដ្ឋ ព្រហូត បាយម៉ាត ។ ពួករមៀត ហរតាន យ៉ាងណា ហិរិវេរព្រឹក្ស គ្រើល សម៉ពិភេទក៍ ប្រោះ កប្បូរ វន្តក្រហម ។

[ ៣២២ ] មួយទៀតក្បែរស្រះបោក្ខរណីនោះមានពួករាជសីហ៍ ខ្លាធំ យក្ខិនីមានមុខដូចជាមុខមេសេះ ដំរី ទ្រាយ ស្វាន រមាំង សរកម្រឹគ ។ ហ្វូងចចក ទន្សាយ ធ្នាបា ឆ្កែព្រៃ មានសម្បុរដូចជាផ្កាបបុស ចាមរី ទោច ឈ្លូស ស្វាព្រាម ស្វាក្រិស ស្វា ខាល ។ ទន្សោង ខ្ទីង ខ្លាឃ្មុំ គោព្រៃ ជាច្រើន ហ្វូងរមាស ជ្រូក ព្រៃ ស្កា កង្កែនដោយច្រើនក្បែរមុចលិន្ទស្រះនុ៎ះ ។ មានទាំងហ្វូងក្របី ឆ្កែព្រៃ ចចក មានស្នាប់ឫស្សីធំព័ន្ធព័ទ្ធជុំវិញអាស្រមបទ ទន្សង បចលាកម្រឹគ វិចិត្តម្រឹគ ខ្លាដំបង ។ ហ្វូងទន្សាយ ត្មាត កេសរសីហៈ កោកនិសាតកម្រឹគ សរកៈ ក្ងោក ក្ងាន អាអូតភ្លើង ។ ពួកមាន់ទឹក មាន់ព្រៃ ដំរី ស្រែកយំឆ្លើយឆ្លងរកគ្នាទៅវិញទៅមក ពួកកុកសាប់ កុកក្រក ប៉ោលតោក ត្រដេវវិច ក្រៀល រនាល ។ ពួកខ្លែង ប្រមង់ ចង្កៀលខ្យង ចាបស្រុក ចចាត ទទា ខ្វែក អាអូត ។ ពួកចចាតធំ ប្រវៀ្ឡ ក្រួច ទទា ចាបស្រុក ចាបព្រៃ សាលិកាកែវគោ គ្រលីងគ្រលោង ។ ពួកករវិកផង ត្របៀកកាំផង មៀមផង អកផង ( មុចលិន្ទស្រះនោះ ) កុះករដោយហ្វូង បក្សីផ្សេងៗ ជាទីទ្រហឹងអឺងកងដោយសំឡេងផ្សេងៗ ។

[ ៣២៣ ] មួយទៀតក្បែរមុចលិន្ទស្រះនុ៎ះមានសត្វស្លាបទាំងឡាយ គឺពួក សាលិកាកែវ មានសំឡេងពីរោះស្រែកយំឆ្លើយឆ្លងរកគ្នាទៅវិញទៅមក រីក

រាយជាមួយនឹងញី ( របស់ខ្លួន ) ។ មួយទៀតក្បែរមុចលិន្ទស្រះនុ៎ះ មានពួកសត្វស្លាបកើតពីវេជង មានសំឡេងពីរោះ មានរង្វង់ភ្នែកស មានភ្នែកល្អ កើតក្នុងពង មានស្លាបដ៏វិចិត្រ ។ មួយទៀតក្បែរមុចលិន្ទស្រះនុ៎ះ មានពួកបក្សីមានសំឡេងពីរោះ គឺក្ងោក មានករទៀវស្រែកយំឆ្លើយឆ្លងគ្នាទៅវិញទៅមក ។ អាអូតភ្លើង មាន់ព្រៃ កោដ្ឋបក្សីពញាក់ ត្រចៀកកាំសមុទ្ទ ខ្វែងជ្រក បក្សីប្រវឹក សេកនិងសាលិកា ។ មួយទៀតក្បែរមុចលិន្ទស្រះនុ៎ះមានពួកហង្សច្រើនមានសម្បុរលឿង ក្រហម ស សត្វហត្ថលិង្គ សម្បកត្រពាំង ប្រវឹក សេកនិងតាវៅ ។ ពួកអន្ទត់ខ្មៅ អន្ទត់ស ហង្ស រអាត ខ្វែងស្រាក ចាកហង្សកុកគ្រោង ប៉ោលតោក ចាបស្រុក ។ ហ្វូងព្រាប គ្រលែងវែក ចាក្រពាកក្អែកទឹក វារណបក្សី មានសំឡេងគួរឲ្យត្រេកអរស្រែកយំហៅគ្នាក្នុងកាលទាំងពីរ គឺព្រឹកល្ងាច មួយទៀតក្បែរមុច្ចលិន្ទស្រះនុ៎ះមានពួកសត្វស្លាបកើតពីវេជង មានសម្បុរផ្សេងៗជាច្រើនស្រែកយំឆ្លើយឆ្លងគ្នាទៅវិញទៅមក រីករាយជាមួយនឹងញី ។ មួយទៀតក្បែរមុចលិន្ទស្រះនុ៎ះ មានពួកសត្វស្លាបមានកំណើតពីវេជង មានសម្បុរផ្សេងៗជាច្រើន សុទ្ធតែមានសំឡេងពីរោះស្រែកស័ព្ទស៊ានត្រង់ឆ្នេរទាំងសងខាងមុចលិន្ទស្រះ ។ មួយទៀតក្បែរមុចលិន្ទស្រះនុ៎ះមានពួកករវិក សត្វទាំងនោះមានកំណើតពីវេជង រមែងស្រែកហៅគ្នារីករាយជាមួយនឹងញី ។ មួយទៀតក្បែរមុចលិន្ទស្រះនុ៎ះមានពួកករវិក សត្វទាំងនោះមានកំណើតពីវេជង សុទ្ធតែមានសំឡេងដ៏ពីរោះ ស្រែកស័ព្ទស៊ានត្រង់ឆ្នេរទាំងសងខាងមុចលិន្ទស្រះ ។ ព្រៃ ( ជិតស្រះបោក្ខរណីនោះ ) ដែលពួកដំរីអាស្រ័យ

នៅហើយ សឹងដ៏កុះករដោយទ្រាយ ស្វាន ទាំងដេរដាសដោយពួកវល្លិផ្សេងៗ ដែលពួកសត្វឈ្មួសអាស្រ័យនៅហើយ ។ មួយយ៉ាងទៀតក្បែរមុចលិន្ទស្រះនុ៎ះ មានស្រងែច្រើន ស្គួយច្រើន ពោតច្រើន ស្រូវសាលីដុះឯងមិនបាច់មានអ្នកណាក្ដូរាស់ដាំឡើយ ទាំងអំពៅសោតក៏មានច្រើន ដុះក្បែរមុចលិន្ទស្រះនុ៎ះ ។ ផ្លូវដើរនេះចុះតែជើងមួយ បុគ្គលដើរទៅត្រង់អាស្រមដល់ទៅទីនោះហើយ ក៏មិនបានសម្រេកគម្ហាននិងសេចក្ដីអផ្សុកឡើយ ។ ជាអាស្រមដែលព្រះបាទវេស្សន្តរគង់នៅព្រមទាំងព្រះរាជបុត្តនិងព្រះរាជទេពី ព្រះអង្គទ្រទ្រង់ភេទបព្វជិតដ៏ប្រសើរ មានតម្លក់និងវែកសម្រាប់បូជាភ្លើងនិងសក់កណ្ដាញ់ ទ្រង់ស្បែកខ្លា ផ្ទំផ្ទាល់ផែនដី នមស្ការភ្លើង ។

[ ៣២៤ ] ( អភិសម្ពុទ្ធគាថា ) ជូជកជាផៅពង្សនៃព្រហ្ម ឮពាក្យនេះហើយក៏ធ្វើប្រទក្សិណឥសី មានចិត្តត្រេកអរក៏ដើរចេញទៅសំដៅទៅអាស្រមដែលព្រះបាទវេស្សន្តរគង់នៅ ។

**ចប់ មហាវនវណ្ណនា ។**

[ ៣២៥ ] ( ព្រះវេស្សន្តរ... ) ហៃបាជាលី អ្នកចូរក្រោកឈរឡើង ( ដំណើរមករបស់ស្លូម ) ប្រាកដដូចជាដំណើរមកអំពីមុនៗ បិតាមើលទៅឃើញដូចជាព្រាហ្មណ៍ សេចក្ដីរីករាយក៏មកស្រោចស្រពលើបិតា ។

[ ៣២៦ ] ( ជាលីកុមារ... ) បពិត្រព្រះវរបិតា ខ្ញុំមិលមើលទៅឃើញប្រាកដដូចជាព្រាហ្មណ៍ ដូចជាមានអ្នកដំណើរមក នឹងជាភ្ញៀវរបស់យើង ។

[ ៣២៧ ] ( ជូជក... ) ព្រះអង្គបានសេចក្តីសុខសប្បាយទេឬ ព្រះអង្គមិនមានរោគាពាធទេឬ ព្រះអង្គចិញ្ចឹមជីវិតដោយការស្វែងរក ( ស្រួល ) ទេឬ មើមឈើនិងផ្លែឈើមានច្រើនឬ ។ ពួករបោម មូស ពស់មានតិចទេឬ ក្នុងព្រៃដ៏កុះករដោយម្រឹគយង់ឃ្នងមិនមានការបៀតបៀនព្រះអង្គទេឬ ។

[ ៣២៨ ] ( ព្រះពោធិសត្វ... ) ម្នាលព្រាហ្មណ៍ យើងបានសេចក្តីសុខសប្បាយទេ ម្នាលព្រាហ្មណ៍ មួយទៀតយើងមិនមានរោគាពាធទេ យើងចិញ្ចឹមជីវិតដោយការស្វែងរកស្រួលទេ ទាំងមើមឈើនិងផ្លែឈើក៏មានច្រើនដែរ ។ មួយវិញទៀត ពួករបោម មូស ពស់ក៏មានតិចទេ ក្នុងព្រៃដ៏កុះករដោយម្រឹគយង់ឃ្នងមិនមានការបៀតបៀនយើងទេ ។ យើងនៅក្នុងព្រៃអស់ ៧ ខែហើយ រស់នៅទាំងទុក្ខសោកទើបតែនឹងបានឃើញព្រាហ្មណ៍ឯងជាជំបូងមានភេទដ៏ប្រសើរ កាន់ឈើប្រត់មានសម្បុរដូចផ្លែព្នៅទុំ មានវែកសម្រាប់បូជាភ្លើងនិងកុណ្ឌី ។ ហៃមហាព្រាហ្មណ៍ អ្នកមកល្អហើយ មួយទៀតអ្នកមិនមែនមកអាក្រក់ទេ អ្នកចូរចូលមកខាងក្នុង សេចក្តីចម្រើន ( ចូរមាន ) ដល់អ្នកអ្នកចូរលាងជើងរបស់អ្នក ។ ម្នាលព្រាហ្មណ៍ អ្នកចូរបរិភោគផ្លែឈើដ៏ឆ្ងាញ់ពីសាដូចទឹកឃ្មុំ គឺផ្លែទន្លាប់ ផ្លែទ្រយឹង ផ្លែមាក់ប្រាង ផ្លែ មាក់ដោក ។ ទឹកដ៏ត្រជាក់នេះឯងដែលជនមកអំពីជ្រោះភ្នំ ម្នាលមហាព្រាហ្មណ៍ បើអ្នកប្រាថ្នាចង់ផឹក ចូរជនយកអំពីរោងទឹកនោះហើយផឹកចុះ ។ អ្នកមកដល់ព្រៃធំដោយហេតុដូចម្តេច ដោយបច្ច័យដូចម្តេច យើងសួរហើយអ្នកចូរប្រាប់ហេតុនោះ ។

[ ៣២៩ ] ( ជូជក... ) ផ្លូវទឹក ( មានទន្លេនិងស្ទឹងជាដើម ) ដ៏ពេញ

ប្រៀបមិនចេះអស់ទៅសព្វកាលយ៉ាងណាមិញ ទូលព្រះបង្គំជាខ្ញុំមកដើម្បីសូមទានព្រះអង្គ ទូលព្រះបង្គំជាខ្ញុំសូមហើយ សូមប្រទានព្រះរាជបុត្តទាំងពីរក៏យ៉ាងនោះដែរ ។

[ ៣៣០ ] ( ព្រះមហាសត្វ... ) ម្នាលព្រាហ្មណ៍ យើងឲ្យ យើងមិនរួញរាទេ អ្នកជាម្ចាស់ ( នៃពួកបុត្តរបស់យើង ) ចូរនាំយកទៅចុះ រាជបុត្រី ( ជាមាតានៃបុត្តទាំងពីរនុ៎ះ ) បានចេញទៅរកផលានុផលអំពីព្រឹក នាងនឹងត្រឡប់មកអំពីការស្វែងរកក្នុងវេលាល្ងាច ម្នាលព្រាហ្មណ៍ អ្នកចូរឈប់សម្រាកបានមួយយប់សិន លុះព្រឹកឡើងសឹមទៅចុះ ។ ម្នាលព្រាហ្មណ៍ អ្នកឈប់សម្រាកបានមួយយប់ លុះព្រឹកឡើង ( សឹមនាំយក ) កុមារទាំងពីរនោះដែលមាតានោះដុសក្បាលហើយប្រដាប់ដោយផ្កាកម្រងហើយទៅចុះ ។ ម្នាលព្រាហ្មណ៍ អ្នកចូរនាំយក ( កុមារទាំងពីរនោះ ) ដែលពាក់ដោយផ្កាផ្សេងៗស្អិតស្អាងដោយគ្រឿងក្រអូបផ្សេងៗ សម្បូណ៌ដោយមើមឈើនិងផ្លែឈើផ្សេងៗហើយទៅចុះ ។

[ ៣៣១ ] ( ជូជក... ) បពិត្រព្រះអង្គប្រសើរក្នុងរថ ទូលព្រះបង្គំមិនគាប់ចិត្តនឹងការនៅទេ គាប់ចិត្តតែនឹងការទៅ ក្រែងអន្តរាយមានដល់ទូលព្រះបង្គំ ឯទូលព្រះបង្គំនឹងទៅខានពុំបាន ។ ធម្មតាពួកស្រីនុ៎ះ មិនមែនជាអ្នកគួរដល់សូមទេតែងធ្វើសេចក្ដីអន្តរាយ ពួកស្រីរមែងចេះកិច្ចកលមាយា តែងកាន់យកកិច្ចការទាំងពួងដោយខាងឆ្វេង ។ បពិត្រព្រះអង្គប្រសើរក្នុងរថ កាលបើព្រះអង្គប្រទានដោយសទ្ធា សូមកុំឲ្យ ( ទូលព្រះបង្គំជាខ្ញុំ ) ចួបនឹងព្រះ

មាតា ( របស់កុមារទាំងនោះឡើយ ) ក្រែងព្រះនាងនោះធ្វើសេចក្តីអន្តរាយទូលព្រះបង្គំនឹងទៅខានពុំបាន ។ សូមព្រះអង្គត្រាស់ហៅបុត្តទាំងគូរបស់ព្រះអង្គមក កុំឲ្យបុត្តទាំងនោះបានឃើញព្រះមាតាឡើយ កាលបើព្រះអង្គប្រទានដោយសទ្ធា បុណ្យតែងចម្រើនលូតលាស់យ៉ាងនេះ ។ សូមព្រះអង្គត្រាស់ហៅបុត្តទាំងគូរបស់ព្រះអង្គមក កុំឲ្យបុត្តទាំងនោះបានឃើញព្រះមាតាឡើយ បពិត្រព្រះរាជា លុះព្រះអង្គប្រទានព្រះរាជទ្រព្យដល់បុគ្គលប្រាកដដូចជាខ្ញុំហើយ ព្រះអង្គនឹងយាងទៅកាន់ឋានសួគ៌ ។

[ ៣៣២ ] ( ព្រះវេស្សន្តរ... ) បើអ្នកមិនប្រាថ្នាចង់ចូបនឹងកិរិយារបស់យើងដែលជាស្ត្រីមានវត្តក្នុងស្វាមីទេ អ្នកចូរឲ្យកុមារទាំងពីរ គឺជាលីនិងកណ្ហាជិនានេះដល់ព្រះអយ្យកោចុះ ។ ព្រះអយ្យកោនោះទ្រង់ទតឃើញកុមារទាំងនេះដែលមានសំដីពីរោះ និយាយពាក្យជាទីស្រឡាញ់ហើយទ្រង់សប្បាយរីករាយត្រេកអរនឹងប្រទានទ្រព្យច្រើនដល់អ្នក ។

[ ៣៣៣ ] ( ជូជក... ) បពិត្រព្រះរាជបុត្ត សូមព្រះអង្គទ្រង់ព្រះសណ្តាប់ ( ពាក្យ ) របស់ទូលព្រះបង្គំ ទូលព្រះបង្គំខ្លាចក្រែងព្រះអយ្យកោដណ្តើមយក ( ព្រះរាជកុមារ ) ព្រះអយ្យកោនឹងប្រទានទូលព្រះបង្គំ ( ដល់ពួកអាមាត្យ ) ដើម្បីព្រះរាជទណ្ឌឬលក់ពិន័យ ពុំនោះសោតនឹងសម្លាប់ពុំខានទូលព្រះបង្គំមុខជានឹងដាច់ចាកទ្រព្យផង ចាកពួកទាសៈផង ត្រូវនាងព្រាហ្មណីតិះដៀលផង ។

[ ៣៣៤ ] ( ព្រះវេស្សន្តរ...) ព្រះមហារាជទ្រង់ឋិតនៅក្នុងធម៌ ញុំាង

ពួកអ្នកសិវិរាស្ត្រឲ្យចម្រើន ទ្រង់ទតឃើញកុមារទាំងនេះដែលមានសម្តីពីរោះ និយាយពាក្យជាទីស្រឡាញ់ ទ្រង់បានបីតិនិងសោមនស្ស នឹងព្រះរាជទានព្រះរាជទ្រព្យជាច្រើនដល់អ្នក ។

[ ៣៣៥ ] ( ជូជក... ) ទូលព្រះបង្គំមិនធ្វើតាមព្រះបន្ទូលដែលទ្រង់បង្គាប់នោះទេ ទូលព្រះបង្គំសូមនាំយកទារកទាំងពីរទៅឲ្យបម្រើនាងព្រាហ្មណី ។

[ ៣៣៦ ] ( អភិសម្ពុទ្ធគាថា ) លំដាប់នោះព្រះរាជកុមារទាំងពីរ គឺជាលីនិងកណ្ហាជិនា លុះឮសម្តីព្រាហ្មណ៍ឈ្លានពានហើយក៏តក់ស្លុតនាំគ្នាស្ទុះរត់ទៅតាមទីនោះៗ ។

[ ៣៣៧ ] ( ព្រះមហាសត្វ... ) ហៃបា ជាកូនស្ងួនសម្លាញ់ កូនចូរមកអាយ ចូរបំពេញបារមីរបស់បិតា កូនចូរស្រោចស្រពហឫទ័យរបស់បិតា កូនចូរធ្វើតាមពាក្យរបស់បិតា ។ កូនចូរដូចជាយាននាវារបស់បិតាឲ្យនឹងថ្កល់ក្នុងសាគរ គឺភព បិតានឹងឆ្លងចាកត្រើយ គឺជាតិ នឹងចម្លងមនុស្សព្រមទាំងទេវតា ( ទៅកាន់ត្រើយគឺព្រះនិព្វាន ) ។ ហៃធីតាស្ងួនសម្លាញ់ ( ឪពុក ) នាងចូរមកព្រោះទានបារមីជាសម្លាញ់របស់បិតា នាងចូរស្រោចស្រពហឫទ័យរបស់បិតា ចូរធ្វើតាមពាក្យរបស់បិតា ។ នាងចូរដូចជាយាននាវារបស់បិតាឲ្យនឹងថ្កល់ក្នុងសាគរ គឺភព បិតានឹងឆ្លងចាកត្រើយ គឺជាតិ នឹងចម្លងពួកមនុស្សព្រមទាំងទេវតា ។

[ ៣៣៨ ] ( អភិសម្ពុទ្ធគាថា ) លំដាប់នោះព្រះបរមពោធិសត្វញ៉ាំងពួកអ្នកសិវិរាស្ត្រឲ្យចម្រើន ទ្រង់នាំយកកុមារទាំងពីរ គឺជាលីនិងកណ្ហាជិនា

ហើយទ្រង់ប្រទានដល់ព្រាហ្មណ៍ ។ ក្នុងលំដាប់នោះព្រះរាជាទ្រង់មានព្រះហ-ឫទ័យរីករាយនាំយកកុមារទាំងពីរ គឺជាលីនិងកណ្ហាជិនាជាបុត្ត ឲ្យជាទានដ៏ឧត្តមដល់ព្រាហ្មណ៍ ។ ហេតុដែលគួរឲ្យស្ញប់ស្ញែង ក៏កើតមានក្នុងកាលនោះ សេចក្ដីព្រឺព្រួចរោមក៏កើតមានក្នុងកាលនោះ កាលដែលព្រះរាជាបានប្រទានកុមារទាំងពីរហើយផែនដីក៏កម្រើកញាប់ញ័រ ។ ហេតុដែលគួរឲ្យស្ញប់ស្ញែងក៏កើតមានក្នុងកាលនោះ សេចក្ដីព្រឺព្រួចរោមក៏កើតមានក្នុងកាលនោះព្រោះព្រះរាជាញុំាងពួកអ្នកសិវិរាស្ត្រឲ្យចម្រើន ទ្រង់ផ្គងអញ្ជលីបានប្រទានកុមារទាំងពីរដ៏ចម្រើនដោយសេចក្ដីសុខឲ្យជាទានដល់ព្រាហ្មណ៍ ។

[ ៣៣៩ ] លំដាប់នោះព្រាហ្មណ៍ជាអ្នកល្មោភនោះ បានទាំកាត់វល្លិដោយធ្មេញទាំងឡាយហើយចងដៃទាំងឡាយ ដោយវល្លិហើយយកវល្លិវាយបណ្ដើរ ។ លំដាប់តពីនោះមកព្រាហ្មណ៍នោះកាន់ខ្សែផង កាន់ឈើច្រត់ផងវាយកុមារទាំងពីរនោះនាំបណ្ដើរទៅ ( ក្នុងទី ) ចំពោះព្រះភក្ត្រនៃព្រះបាទសិវិ ( វេស្សន្តរ ) ។

[ ៣៤០ ] ក្នុងកាលដែលព្រាហ្មណ៍នាំទៅនោះ កុមារទាំងពីរបានរបូតរួច ( អំពីចំណង ) នៃព្រាហ្មណ៍ហើយរត់ចៀសចេញទៅ កុមារនោះមាននេត្រាទាំងពីរដ៏ពោរពេញដោយទឹកភ្នែក ងើបមើលព្រះបិតា ។ កុមារក៏ញាប់ញ័រចំប្រប់ដូចជាស្លឹកពោធិ៍ ថ្វាយបង្គំព្រះបាទទាំងគូរបស់ព្រះបិតា លុះថ្វាយបង្គំព្រះបាទទាំងគូរបស់ព្រះបិតាហើយបានពោលពាក្យនេះថា បពិត្រព្រះបិតា ព្រះមាតាចេញទៅព្រៃហើយ បពិត្រព្រះបិតា ឯព្រះអង្គប្រទានយើងខ្ញុំ បពិត្រ

ព្រះបិតា ចាំយើងខ្ញុំចួបនឹងព្រះមាតាសិនសឹមព្រះអង្គប្រទានយើងខ្ញុំ ។ បពិត្រព្រះបិតា ព្រះមាតាចេញទៅព្រៃហើយ បពិត្រព្រះបិតា ឯព្រះអង្គប្រទានយើងខ្ញុំ បពិត្រព្រះបិតា ព្រះអង្គកុំអាលប្រទានយើងខ្ញុំឡើយ រង់ចាំព្រះមាតារបស់យើងខ្ញុំត្រឡប់មកសិន ។ ក្នុងពេលនោះព្រាហ្មណ៍នេះ ចង់លក់ឬចង់សម្លាប់ក៏តាមប្រាថ្នាចុះ ( ដូជកព្រាហ្មណ៍នេះ ) មានជើងត្រប៉ាត ក្រចកស្អុយមួយទៀតមានដុំសាច់យុរយារ បបូមាត់ខាងលើវែងមានទឹកមាត់ហៀរ ចេញធ្មេញស្រេញ ( ដូចខ្លាយជ្រូក ) ប្រមុះបាក់ ។ មានពោះធំកំប៉ោង ខ្នងកោងភ្នែកស្រលៀង ពុកមាត់ពុកចង្កាក្រហម សក់លឿង ស្បែកជ្រួញជ្រីវទុះដោយអាចម៍រុយ ។ មានភ្នែកលៀនក្លោត ( ដូចភ្នែកឆ្មា ) ចង្កេះ ខ្នង កវៀច សន្ទាក់ឆ្អឹងលាន់ឮប្រសៗ ធំជំបង ឈ្មានពានទុកជាស្បៀកដណ្តប់ស្បែកខ្លាក៏ដូចជាអមនុស្សគួរស្បើម ។ បពិត្រព្រះបិតា ( ព្រាហ្មណ៍នេះ ) ជាមនុស្សឬជាយក្ស ជាអ្នកស៊ីសាច់និងឈាមចេញអំពីស្រុកមកកាន់ព្រៃ សូមទ្រព្យ គឺកូននឹងព្រះបិតាទេដឹង ។ បពិត្រព្រះបិតា យើងខ្ញុំត្រូវបិសាចកំពុងនាំទៅ ព្រះបិតាទ្រង់ទតឃើញឬទេ ព្រះហឫទ័យរបស់ព្រះបិតា ( ធ្ងន់ដូចថ្ម ) ឬដូចជាចំណងដែកដ៏មាំ ព្រះអង្គមិនជ្រាបយើងខ្ញុំដែលព្រាហ្មណ៍ជាអ្នកស្វែងរកទ្រព្យល្មោភហួសប្រមាណ ចាប់ចងហើយវាយយើងខ្ញុំដូចជាគេវាយគោ ។ នាងកណ្ហាជិនាចូរនៅក្នុងទីនេះចុះ ដ្បិតនាងមិនទាន់ដឹងក្តីនៅឡើយ រមែងកន្ទក់កន្ទេញដូចជាកូនម្រឹគនៅបៅដោះហើយព្រាត់ប្រាសចាកហ្វូង ។

[ ៣៨១ ] ទុក្ខដូច្នោះនេះមិនមែនជាទុក្ខដល់អញទេ ព្រោះទុក្ខនេះបុរស

( ដែលវង្គាត់ទៅក្នុងកព ) ត្រូវបាន អញមិនឃើញព្រះមាតាណា ការមិនឃើញព្រះមាតានោះ ជាសេចក្តីទុក្ខក្រៃលែងរបស់អញជាងសេចក្តីទុក្ខដែលព្រាហ្មណ៍វាយដំនេះទៅទៀត ។ ទុក្ខដូច្នោះនេះមិនមែនជាទុក្ខដល់អញទេព្រោះទុក្ខនេះបុរសត្រូវបាន អញមិនឃើញព្រះមាតាណាការមិនឃើញព្រះមាតានោះជាសេចក្តីទុក្ខក្រៃលែងរបស់អញ ជាងសេចក្តីទុក្ខដែលព្រាហ្មណ៍វាយដំនេះទៅទៀត ។ ព្រះមាតានោះជាមនុស្សកំព្រាពិត កាលបើមិនឃើញកុមារីឈ្មោះកណ្ហាជិនាល្អគួរមើល មុខជានឹងទ្រង់ព្រះកន្សែងអស់កាលយូរ ។ ព្រះបិតានោះជាមនុស្សកំព្រាដោយពិតកាលបើមិនឃើញកុមារីឈ្មោះកណ្ហាជិនា ល្អគួរមើលមុខជានឹងទ្រង់ព្រះកន្សែងអស់កាលយូរ ។ ព្រះមាតានោះជាមនុស្សកំព្រាពិតកាលបើមិនឃើញកុមារីឈ្មោះកណ្ហាជិនា ល្អគួរមើលមុខជានឹងទ្រង់ព្រះកន្សែងក្នុងអាស្រមអស់កាលយូរ ។ ព្រះបិតានោះជាមនុស្សកំព្រាពិត កាលបើមិនឃើញកុមារីឈ្មោះ កណ្ហាជិនាល្អគួរមើល មុខជានឹងទ្រង់ព្រះកន្សែងក្នុងអាស្រមអស់កាលយូរ ។ ព្រះមាតានោះជាមនុស្សកំព្រាពិត ( រឭកពួកយើង ) ក្នុងពាក់កណ្តាលអធ្រាត្រ ឬក្នុងរាត្រីទាំងមូល នឹងទ្រង់ព្រះកន្សែងអស់កាលយូរ នឹងរីងស្ងួតដូចស្ទឹង ។ ព្រះបិតានោះជាមនុស្សកំព្រាដោយពិត ( រឭកពួកយើង ) ក្នុងកណ្តាលអធ្រាត្រឬក្នុងរាត្រីទាំងមូល នឹងទ្រង់ព្រះកន្សែងអស់កាលយូរ នឹងរីងស្ងួតដូចជាស្ទឹង ។ រុក្ខជាតិផ្សេងៗទាំងនេះ គឺដើមព្រីង ឈើទាលខ្សាច់ មានមែកត្រសុំត្រសាយ ថ្ងៃនេះយើងនឹងបោះបង់ពួករុក្ខជាតិទាំងនោះចោលហើយ ។ ពួកផលជាតិផ្សេងៗទាំងនេះ គឺពោធិ៍ ខ្នុរ ជ្រៃ ក្រសាំង

ថ្ងៃនេះយើងនឹងបោះបង់ផលជាតិទាំងនោះចោលហើយ ។ នេះស្ទួនច្បារ នេះស្ទឹងមានទឹកត្រជាក់ ពីដើមយើងលេងក្នុងទីណា ថ្ងៃនេះយើងនឹងបោះបង់ទីទាំងនោះ ។ ពីដើមពួកយើងទ្រទ្រង់ផ្កាណាច្រើនយ៉ាងលើភ្នំនេះ ថ្ងៃនេះយើងនឹងបោះបង់ផ្កាទាំងនោះ ។ ពីដើមពួកយើងបរិភោគផ្លែឈើណាច្រើនយ៉ាង លើភ្នំនេះ ថ្ងៃនេះយើងនឹងបោះបង់ផ្លែឈើទាំងនោះ ។ នេះរូបដំរី រូបសេះរបស់យើង នេះរូបគោរបស់យើង ពីដើមយើងលេងដោយរូបណា ថ្ងៃនេះយើងនឹងបោះបង់រូបទាំងនោះ ។

[ ៣៤២ ] កុមារទាំងនោះ កាលជូជកព្រាហ្មណ៍កំពុងនាំទៅបានពោលនឹងព្រះបិតាដូច្នេះថា បពិត្រព្រះបិតា សូមព្រះអង្គប្រាប់នូវភាព ( របស់យើងខ្ញុំ ) ជាបុគ្គលមិនមានរោគដល់ព្រះមាតាផង ទាំងព្រះអង្គសោតក៏សូមឲ្យបានសេចក្ដីសុខ ។ នេះរូបដំរី រូបសេះរបស់យើងខ្ញុំ នេះរូបគោរបស់យើងខ្ញុំ សូមព្រះអង្គប្រទានរូបទាំងនោះដល់ព្រះមាតាៗនឹងបន្ទោបង់សំណោកព្រោះរូបទាំងនោះ ។ នេះរូបដំរី រូបសេះរបស់យើងខ្ញុំ នេះរូបគោរបស់យើងខ្ញុំ ព្រះមាតាកាលបើក្រឡេកឃើញរូបទាំងនោះហើយនឹងបន្ទោបង់សំណោកចេញបាន ។

[ ៣៤៣ ] លំដាប់នោះព្រះបាទវេស្សន្តរជាក្សត្រិយ៍ ទ្រង់ដាក់ទានរួចហើយក៏យាងចូលទៅកាន់បណ្ណសាលាហើយខ្សឹកខ្សួលគួរឲ្យអាណោចអាធ័ម ។ ( ព្រះមហាសត្វទ្រង់ព្រះពិលាបថា ) ក្នុងថ្ងៃនេះទារកទាំងពីរមានសេចក្ដីស្រេកឃ្លានហើយយំទាំរនេវណា អ្នកណាហ្ន៎នឹងឲ្យភោជនដល់ទារកទាំងពីរនោះក្នុងកាលជាទីអង្គាស ( អាហារ ) ក្នុងវេលាល្ងាច ។ ក្នុងថ្ងៃនេះទារកទាំងពីរ

មានសេចក្តីស្រេកឃ្លានហើយយំទារនរណា បពិត្រព្រះមាតា យើងខ្ញុំមានសេចក្តីស្រេកឃ្លានហើយ សូមព្រះមាតាប្រទានភោជនដល់យើងខ្ញុំក្នុងកាលជាទីអង្គាស ( អាហារ ) ក្នុងវេលាល្ងាច ។ ទារកទាំងពីរដើរទៅដោយជើងទទេ មិនមានស្បែកជើង នឿយហត់ មានជើងទាំងពីរដ៏ពុះពងទៅកាន់ផ្លូវដូចម្តេចបាន អ្នកណានឹងដឹកដៃទារកទាំងនោះទៅ ។ កោតតែព្រាហ្មណ៍នោះហ៊ានវាយកូនទាំងពីររបស់អញ ជាអ្នកមិនមានកំហុសក្នុងទីចំពោះមុខ មិនអៀនខ្មាស ព្រាហ្មណ៍នេះហៅពេញជាមនុស្សឥតអៀនខ្មាស ។ អ្នកណាមានសេចក្តីអៀនខ្មាស នឹងវាយពួកជនសូម្បីជាខ្ញុំស្រីខ្ញុំប្រុស ឬថាអ្នកបម្រើដទៃរបស់អញ ដែលលះឲ្យហើយនោះ ។ ព្រាហ្មណ៍ហ៊ានជេរ ហ៊ានវាយដំកូនសម្លាញ់របស់អញដែលកំពុងមើលឃើញ ដូចជាត្រីដែលជាប់នៅក្នុងមាត់លប ។

[ ៣៨៤ ] អញនឹងកាន់យកធ្នូ ស្ពាយព្រះខាន់លើស្មាខាងឆ្វេងហើយនាំយកកូនទាំងពីររបស់ខ្លួនមកវិញឬ ព្រោះថាការដែលគេវាយដំកូនទាំងពីរនាំមកនូវសេចក្តីទុក្ខ ។ កុមារទាំងពីរគប្បីលំបាកដោយហេតុណា ហេតុនុ៎ះមិនមែនជាទីតាំងមានសភាពជាទុក្ខទេ នរណាយល់ធម៌របស់ពួកសប្បុរសហើយឲ្យទានរមែងក្តៅក្រហាយរឿយៗ ។

[ ៣៨៥ ] ( ជាលីកុមារ... ) បានឮថា ជនពួកខ្លះក្នុងលោកនេះបាននោលពាក្យពិតយ៉ាងនេះថា បុគ្គលណាមិនមានមាតាបង្កើត បុគ្គលនោះឈ្មោះថា មិនមានបិតាដូចគ្នាដែរ ។ នែនាងកណ្ហាប្អូន នាងចូរមកយើងមុខជានឹងស្លាប់ យើងមិនមានសេចក្តីត្រូវការដោយជីវិតទេ ដោយយើងត្រូវព្រះជនិន្ទប្រទាន

ដល់ព្រាហ្មណ៍អ្នកស្វែងរកទ្រព្យ ជាមនុស្សកំណាចលើសលន់ វាយដំយើង ដូចជាគេវាយហ្វូងគោ ។ នៃនាងកណ្ហា ពួករុក្ខជាតិផ្សេងៗនេះ គឺដើមព្រីង ឈើទាលខ្សាច់ មានមែកត្រសុំត្រសាយ យើងនឹងបោះបង់រុក្ខជាតិទាំងនោះ នៃនាងកណ្ហា ពួកផលជាតិផ្សេងៗនេះ គឺពោធិ៍ ខ្នុរ ជ្រៃ ក្រសាំង យើងនឹងបោះបង់ផលជាតិទាំងនោះ ។ ហៃនាងកណ្ហា នេះសួនច្បារ នេះស្ទឹងមានទឹកត្រជាក់ ពីដើមយើងលេងក្នុងទីណា យើងនឹងបោះបង់ទីទាំងនោះ ហៃនាងកណ្ហា ពីដើមយើងទ្រទ្រង់ផ្កាទាំងឡាយណាផ្សេងៗលើភ្នំនេះ យើងនឹងបោះបង់ផ្កាទាំងនោះ ។ ហៃនាងកណ្ហា ពីដើមយើងបរិភោគផ្លែឈើផ្សេងៗទាំងឡាយណា យើងនឹងបោះបង់ផ្លែឈើទាំងនោះ ។ ហៃនាងកណ្ហា នេះរូបដំរី រូបសេះរបស់យើង នេះរូបគោរបស់យើង ជារូបដែលយើងធ្លាប់លេង យើងនឹងបោះបង់រូបនោះ ។

[ ៣៨៦ ] ( អភិសម្ពុទ្ធគាថា ) កុមារទាំងពីរនោះ គឺជាលីនិងកណ្ហាជិនា កាលដែលព្រាហ្មណ៍កំពុងនាំទៅក៏របូតចេញ ( អំពីចំណង ) ហើយនាំគ្នាស្ទុះចូលទៅក្នុងទីនោះក្នុងខណៈនោះ ។

[ ៣៨៧ ] លំដាប់នោះជូជកព្រាហ្មណ៍នោះ កាន់យកខ្សែនិងឈើច្រត់ វាយដំកុមារទាំងពីរនោះ ហើយនាំទៅក្នុងទីចំពោះព្រះភក្ត្រនៃព្រះបាទសិវិ ( វេស្សន្តរ ) ។

[ ៣៨៨ ] នាងកណ្ហាជិនាបានពោលនឹងព្រះបិតានោះថា បពិត្រព្រះបិតា ព្រាហ្មណ៍នេះវាយដំខ្ញុំម្ចាស់ដោយឈើច្រត់ ដូចជាទាសីដែលកើតក្នុងផ្ទះ ។

បពិត្រព្រះបិតា នេះមិនមែនជាព្រាហ្មណ៍ទេ ដ្បិតពួកព្រាហ្មណ៍ជាអ្នកប្រកបដោយធម៌ បពិត្រព្រះបិតា យក្សក្លែងភេទជាព្រាហ្មណ៍នាំយើងខ្ញុំយកទៅស៊ីទេដឹង បពិត្រព្រះបិតា យើងខ្ញុំត្រូវបិសាចកំពុងនាំទៅ ហេតុអ្វីក៏ព្រះអង្គទ្រង់ទតព្រងើយ ។

[ ៣៤៩ ] ជើងទាំងឡាយរបស់យើងខ្ញុំនេះក៏សែនលំបាក ផ្លូវសោតក៏ឆ្ងាយដាច់ស្រយាល លំបាកនឹងដើរទៅណាស់ ព្រះសុរិយាក៏កាន់តែទន់ទាបជិតអស្តង្គតណាស់ហើយ ព្រាហ្មណ៍ក៏នាំយើងខ្ញុំទៅប្រញាប់ប្រញាល់ ។ យើងខ្ញុំសូមថ្វាយបង្គំនូវពួកភូតដែលនៅអាស្រ័យលើភ្នំនិងព្រៃ សូមថ្វាយបង្គំដោយសិរសា នូវពួកទេវតាដែលរក្សាស្រះនិងទេវតាដែលនៅអាស្រ័យក្នុងស្ទឹងមានកំពង់ដ៏ល្អ ។ ( យើងខ្ញុំសូមថ្វាយបង្គំ ) នូវពួកទេវតាដែលនៅអាស្រ័យលើស្មៅនិងវល្លិនិងឈើឱសថនិងភ្នំនិងព្រៃ សូមទេវតាទាំងឡាយទូលព្រះមាតានូវភាពរបស់យើងខ្ញុំជាអ្នកមិនមានរោគ ដ្បិតព្រាហ្មណ៍នេះកំពុងនាំយកយើងខ្ញុំទៅ ។ សូមពួកលោកដ៏ចម្រើន ទូលដល់ព្រះមទ្រីជាព្រះមាតារបស់យើងខ្ញុំថាបើលោកចង់អញ្ជើញមកតាមយើងខ្ញុំ គប្បីអញ្ជើញមកឲ្យឆាប់ ។ ផ្លូវនេះដើរចុះតែជើងមួយ ត្រង់ទៅកាន់អាស្រម ព្រះមាតាគប្បីស្តេចអញ្ជើញមកតាមផ្លូវនោះឯងមុខជានឹងឃើញយើងខ្ញុំភ្លាម ។ បពិត្រព្រះមាតា ដ៏មានជដាអើយ ទុក្ខនោះនឹងមានដល់លោក ដែលនាំមើមឈើនិងផ្លែឈើអំពីព្រៃមកព្រោះឃើញអាស្រមស្ងាត់ជ្រងំ ។ ព្រះមាតាបាន ( មើមឈើនិងផ្លែឈើអំពីព្រៃនិងចំណី ) ច្រើនដោយការស្វែងរកហួសវេលា មិនជ្រាបយើងខ្ញុំដែល

ព្រាហ្មណ៍អ្នកស្វែងរកទ្រព្យ កំណាចលើសលន់ ចងវាយជំយើងខ្ញុំដូចជាគេវាយហ្វូងគោ ថ្ងៃនេះយើងខ្ញុំសូមថ្វាយបង្គំព្រះមាតាដែលអញ្ជើញមកអំពីការស្វែងរកផ្លែឈើក្នុងវេលាល្ងាច ។ ព្រះមាតាគប្បីប្រទានផ្លែឈើលាយដោយទឹកឃ្មុំដល់ព្រាហ្មណ៍ៗនេះបានបរិភោគផ្លែឈើនោះឆ្អែតហើយ មុខជាមិនបង្ខំនាំយើងខ្ញុំទៅ ។ កុមារទាំងពីរមានសេចក្ដីជាប់ចិត្តក្នុងព្រះមាតា ពិលាបក្នុងកាលនោះថា ឱហ្ន៎ បាតជើងទាំងឡាយរបស់យើងពុរពងអស់ហើយ ព្រាហ្មណ៍ដឹកនាំយើងទៅប្រញាប់ប្រញាល់ខ្លាំងណាស់ ។

**ចប់ ទារកបព្វៈ ។**

[ ៣៥១ ] ( ព្រះនាងមទ្រី... ) ជ្រនីកធ្លាក់ចុះ ( អំពីដៃ ) របស់អញ ភ្នែកស្តាំក៏កម្រើកទាំងដើមឈើមានផ្លែក៏ប្រែជាមិនមានផ្លែ អញវង្វេងទិសទាំងអស់ ។ កាលដែលអញនោះមកកាន់អាស្រមក្នុងវេលាល្ងាចក្នុងពេល ដែលព្រះអាទិត្យអស្តង្គតហើយក៏មានពួកម្រឹគសាហាវមកឈរវាំងក្នុងផ្លូវ កាលបើព្រះអាទិត្យទៀបអស្តង្គតហើយ អាស្រមក៏នៅឆ្ងាយណាស់ អញនឹងនាំយកមើមឈើនិងផ្លែឈើណាអំពីទីនេះដើម្បីជនទាំងនោះ ជនទាំងនោះគប្បីនាំគ្នាបរិភោគមើមឈើនិងផ្លែឈើនោះជាភោជន ។ ក្សត្រិយ៍នោះគង់នៅតែមួយអង្គឯងក្នុងបណ្ណសាលាពិត ម៉្លេះសមឃើញអាត្មាអញដែលមិនទាន់មកដល់ ក៏ខំលួងលោមទារកទាំងពីរដែលមានសេចក្ដីស្រេកឃ្លាន ។ កូនតូចទាំងនោះរបស់អញជាស្ត្រីកំព្រាកម្សត់ដោយពិត នៅអង្គុយ ( ចាំមើលផ្លូវ ) ដូចកូនម្រឹគ

នៅផឹកទឹកដោះក្នុងវេលាល្ងាចឬក្នុងវេលាដែលបរិភោគ ។ កូនតូចទាំងនោះរបស់អញជាស្ត្រីកំព្រា កម្សត់ដោយពិត នៅអន្ទ្រយ ( ចាំមើលផ្លូវ ) ដូចកូនម្រឹគប្រាថ្នារកទឹកផឹកក្នុងវេលាល្ងាច ឬក្នុងវេលាដែលបរិភោគ ។ កូនតូចទាំងនោះរបស់អញជាស្ត្រីកំព្រា កម្សត់ដោយពិត នាំគ្នាឈរចាំទទួលអញដូចជាពួកកូនគោតូចឈរចាំទទួលមេ ។ កូនតូចទាំងនោះរបស់អញជាស្ត្រីកំព្រា កម្សត់ដោយពិត នាំគ្នាឈរចាំទទួលអញដូចជាពួកហង្សឈរនៅលើភក់ ។ កូនតូចទាំងនោះរបស់អញជាស្ត្រីកំព្រា កម្សត់ដោយពិត នាំគ្នាឈរចាំទទួលអញក្នុងទីមិនឆ្ងាយអំពីអាស្រម ។ ផ្លូវតែមួយចុះបានតែដើងនៃបុគ្គលម្នាក់ ក្បែរខាងផ្លូវមានស្រះ មានជ្រោះ អញមិនឃើញផ្លូវដទៃសម្រាប់ទៅកាន់អាស្រមបានទេ ។ បពិត្រម្រឹគទាំងឡាយ ខ្ញុំសូមថ្វាយបង្គំលោកទាំងឡាយជាស្តេចមានកម្លាំងច្រើនក្នុងព្រៃធំ សូមលោកជាបងប្អូននឹងគ្នាដោយធម៌ លោកទាំងឡាយ កាលបើខ្ញុំអង្វរហើយក៏សូមឲ្យផ្លូវដល់ខ្ញុំ ។ ខ្ញុំជាភរិយារបស់ព្រះរាជបុត្តដ៏មានសិរីដែលគេនិរទេស ខ្ញុំមិនហ៊ានមើលងាយព្រះរាជស្វាមីនោះ ដូចនាងសិតាជាស្ត្រីមានវត្តមិនហ៊ានមើលងាយព្រះរាម ។ លោកទាំងឡាយ ចូរឃើញបុត្តទាំងឡាយចុះ ចំណែកខ្ញុំសូមឃើញស្វាមីនិងបុត្តទាំងពីរ គឺជាលីនិងកណ្ហាជិនាក្នុងពេលល្ងាច គឺកាលជាទីទទួលចំណី ។ មើមឈើនិងផ្លែឈើនេះសោតក៏ច្រើន ចំណីនេះមិនមែនតិចទេ ខ្ញុំនឹងបែងចំណីនោះពាក់កណ្តាលជូនលោកទាំងឡាយ កាលបើខ្ញុំអង្វរហើយសូមឲ្យផ្លូវខ្ញុំ ។ ព្រះមាតារបស់យើងជាព្រះរាជបុត្រី ព្រះបិតារបស់យើងជាព្រះរាជបុត្រា លោកទាំងឡាយ ចូរជា

បងប្អូនដោយធម៌ លោកទាំងឡាយ កាលបើខ្ញុំអង្វរហើយសូមឲ្យផ្លូវខ្ញុំ ។

[ ៣៥២ ] ( អភិសម្ពុទ្ធគាថា ) ពួកម្រឹគសាហាវបានស្តាប់វាចាពីរោះពិសា ជាវាចាប្រកបដោយសេចក្តីករុណាច្រើនរបស់នាងមទ្រីនោះដែលកំពុងលួងលោមហើយក៏នាំគ្នាថយចេញអំពីផ្លូវបាត់ទៅ ។

[ ៣៥៣ ] ( ព្រះនាងមទ្រី... ) កូនតូចទាំងពីរប្រឡាក់ដោយអាចម៍ដីរមែងឈរចាំទទួលអញក្នុងប្រទេសនេះ ដូចជាពួកកូនគោឈរចាំទទួលមេ ។ កូនតូចទាំងពីរប្រឡាក់ដោយអាចម៍ដីរមែងឈរចាំទទួលអញក្នុងប្រទេសនេះ ដូចជាពួកហង្សឈរនៅលើកក់ ។ កូនតូចទាំងពីរប្រឡាក់ដោយអាចម៍ដី រមែងឈរចាំទទួលអញក្នុងប្រទេសនេះក្នុងទីជិតអាស្រម ។ កូនតូចទាំងនោះធ្លាប់តែស្ទុះមកព័ទ្ធជុំវិញ មានសេចក្តីត្រេកអររីករាយ នាំគ្នាលោតមកហាក់ដូចជា ( ញ៉ាំងហឫទ័យរបស់មាតា ) ឲ្យរម្រើកដូចកូនម្រឹគទាំងឡាយ ( ឃើញមេ ) ហើយជំទ្បើងស្លឹកត្រចៀក ( អើតកចូលទៅជិតមេរីករាយត្រេកអរស្ទុះទៅព័ទ្ធជុំវិញ ) ថ្ងៃនេះអញមិនបានឃើញកូនទាំងពីរ គឺជាលីនិងនាងកណ្ហាជិនានោះ ។ អញលះបង់កូនទាំងពីរហើយចេញទៅ ដូចមេពពែឬមេម្រឹគលះបង់កូន ដូចមេបក្សីចេញអំពី ( សម្បុក ) ឬដូចមេសីហៈប្រាថ្នាសាច់ ( លះបង់កូនរបស់ខ្លួនដើរចេញទៅរកចំណី ) ថ្ងៃនេះអញមិនបានឃើញកូនទាំងពីរ គឺជាលីនិងនាងកណ្ហាជិនានោះ ។ នេះស្នាមជើងនៃកូនទាំងនោះដូច ( ស្នាមជើង ) នៃហ្វូងដំរីក្បែរភ្នំពំនូកខ្សាច់ដែលកូនទាំងពីរនាំគ្នាពូនក៏ខ្ចាត់ខ្ចាយក្នុងទីជិតនៃអាស្រម ថ្ងៃនេះអញមិនបានឃើញកូនទាំងពីរ គឺជាលីនិងនាងកណ្ហាជិនានោះ ។ កូនតូច

ទាំងពីរពោយពាយដោយខ្សាច់ ប្រឡាក់ដោយអាចម៍ដី រមែងស្ទុះមកព័ទ្ធជុំវិញ អញមិនបានឃើញទារកទាំងនោះ ។ កាលពីដើមកូនទាំងពីរណាទទួលអញ ដែលមកអំពីព្រៃឆ្ងាយ ថ្ងៃនេះអញមិនបានឃើញកូនទាំងពីរនោះ គឺជាលីនិង នាងកណ្ហាជិនា ។ ទារកទាំងពីរតែងរមិលមើលផ្លូវអញក្នុងទីឆ្ងាយ ដូចកូន ម្រឹគទទួលមេពពែឬម្រឹគជាមេ ។ ផ្លែញ្ចៀលឿនទីដែលជ្រុះមកនេះឯងជាល្បែង របស់ទារកទាំងនោះ ថ្ងៃនេះអញមិនបានឃើញកូនទាំងពីរ គឺជាលីនិងនាង កណ្ហាជិនានោះ ។ ស្តនរបស់អញទាំងពីរនេះពេញ ( ដោយទឹកដោះ ) ទាំង ទ្រូងសោតក៏ស្ទើរតែនឹងធ្លាយ អញមិនបានឃើញកូនទាំងពីរ គឺជាលីនិងនាង កណ្ហាជិនានោះ ។ កូនមួយពាររកផ្លែឈើក្នុងថ្នក់របស់អញ កូនមួយតោងដោះ ទាំងគូរបស់អញ ថ្ងៃនេះអញមិនបានឃើញកូនទាំងពីរ គឺជាលីនិងនាងកណ្ហា-ជិនានោះ ។ វេលាថ្ងៃល្ងាចកូនតូចទាំងពីរប្រឡាក់ដោយអាចម៍ដី ននៀលលើ ភ្លៅរបស់អញ អញមិនបានឃើញទារកទាំងនោះ ។ កាលពីដើមអាស្រមនេះ ប្រាកដដល់អញ ( ដូចជា ) កន្ទែងមហោស្រព ថ្ងៃនេះអាស្រមហាក់ដូចវិល ដល់អញដែលមិនបានឃើញកូនទាំងនោះ ។ ហេតុដូចម្តេចបានជាអាស្រមនេះ ហាក់ដូចជាស្ងាត់ស្ងួនឲ្យឈឹងប្រាកដដល់អញ សូម្បីពួកក្អែកព្រៃក៏មិនកញ្ជ្រៀវ ទារកទាំងពីររបស់អញប្រាកដជាស្លាប់ហើយ ។ ហេតុដូចម្តេចបានជាអាស្រម នេះហាក់ដូចជាស្ងាត់ស្ងួនឲ្យឈឹងប្រាកដដល់អញ សូម្បីពួកសត្វហើរក៏មិន កញ្ជ្រៀវ ទារកទាំងពីររបស់អញបាកដជាស្លាប់ហើយ ។

[ ៣៥៤ ] ហេតុនេះដូចម្តេច បានជាព្រះអង្គគង់ស្ងៀម ចិត្តរបស់ខ្ញុំម្ចាស់

ហាក់ដូច ( យល់សប្តិ ) ក្នុងរាត្រី សូម្បីពួកក្អែកព្រៃក៏មិនកញ្ជ្រៀវ ទារកទាំងពីររបស់ខ្ញុំម្ចាស់ ប្រាកដជាស្លាប់ហើយ ។ ហេតុដូចម្តេចបានជាព្រះអង្គគង់ស្ងៀម ចិត្តរបស់ខ្ញុំម្ចាស់ហាក់ដូចជា ( យល់សប្តិ ) ក្នុងរាត្រី សូម្បីពួកសត្វហើរក៏មិនកញ្ជ្រៀវ ទារកទាំងពីររបស់ខ្ញុំម្ចាស់ ប្រាកដជាស្លាប់ហើយ ។ បពិត្រព្រះអយ្យបុត្ត ពួកម្រឹគស៊ីទារកទាំងពីររបស់ខ្ញុំម្ចាស់ហើយទេដឹង ឬនរណានាំយកទារករបស់ខ្ញុំម្ចាស់ទៅក្នុងព្រៃដ៏ស្ងាត់ឥតជាតិជៅ ។ ព្រះអង្គធ្វើទារកទាំងនោះឲ្យជាទូត ហើយប្រើទៅឬ ឬក៏ទារកទាំងនោះជាអ្នកពោលពាក្យពីរោះដេកលក់អស់ហើយ ឬទារកទាំងនោះខ្វល់ខ្វាយក្នុងល្បែងទាំងឡាយ ហើយនាំគ្នាចេញទៅខាងក្រៅ ។ សក់ទាំងឡាយក្តី ដៃជើងទាំងឡាយក្តីដ៏វិចិត្រ ដោយបណ្តាញរបស់ទារកទាំងនោះក៏មិនឃើញសោះ ក្រែងពួកបក្សីធាបនាំយកទៅទេដឹង ឬនរណានាំយកទារករបស់ខ្ញុំម្ចាស់ទៅ ។

[ ៣៥៥ ] ការដែលព្រះអង្គមិនមានព្រះបន្ទូលនេះជាទុក្ខក្រៃលែង ជាងទុក្ខរបស់ខ្ញុំម្ចាស់ ដែលមិនឃើញកូនទាំងពីរ គឺជាលីនិងនាងកណ្ហាជិនានោះ ដូចជាដំបៅដែលមុតដោយព្រួញ នេះជាព្រួញទីពីរ គឺត្រង់ដែលខ្ញុំម្ចាស់មិនឃើញបុត្តទាំងពីរ ១ ដែលព្រះអង្គមិនត្រាស់ប្រាប់ខ្ញុំម្ចាស់ ១ នាំឲ្យកម្រើកហឫទ័យរបស់ខ្ញុំម្ចាស់ ។ បពិត្រព្រះរាជបុត្ត បើព្រះអង្គមិនត្រាស់ប្រាប់ដល់ខ្ញុំម្ចាស់អស់រាត្រីនេះក្នុងថ្ងៃនេះទេ ព្រះអង្គមុខជានឹងឃើញខ្ញុំម្ចាស់ អស់ជីវិតស្លាប់ក្នុងពេលព្រឹកមិនខាន ។

[ ៣៥៦ ] ( ព្រះមហាសត្វ... ) ក្រែងនាងមទ្រីមានកម្ពស់និងទំហំ ដ៏

ប្រសើរ ជារាជបុត្រីមានយសប្ញ នាងទៅដើម្បីស្វែងរក ( ផ្លែឈើតូចធំ ) តាំងពីពេលព្រឹក ហេតុដូចម្តេចបានជាដល់ពេលល្ងាចហើយទើបមក ។

[ ៣៥៧ ] ( ព្រះនាងមទ្រី... ) ក្រែងព្រះអង្គទ្រង់ព្រះសណ្តាប់សំឡេងទ្រហឹងអឺងកងនៃសីហៈនិងខ្លាដែលស្រែកបន្លឺឡើង ( ព្រមទាំងម្រឹគដទៃមានដំរីជាដើម ) ដែលមកកាន់ស្រះ ( នេះ ) ដើម្បីផឹកទឹកដែរឬទេ ។ បុព្វនិមិត្តបានកើតឡើងដល់ខ្ញុំម្ចាស់ដែលដើរវង្វាត់ក្នុងព្រៃធំ ជ្រនីកក៏ធ្លាក់អំពីដៃរបស់ខ្ញុំម្ចាស់ ទាំងកញ្ច្រែងដែលលីលើចង្កេះយស្មាក៏ធ្លាក់អំពីស្មា ។ ក្នុងពេលនោះខ្ញុំម្ចាស់មានសេចក្តីកិតក័យក្រៃពេកក៏ប្រណម្យអញ្ជលីនមស្ការគ្រប់ទិសផ្សេងៗ សូមឲ្យសួស្តីគប្បីមានព្រោះការនមស្ការនេះ ។ សូមកុំឲ្យសីហៈនិងខ្លាដំបងបៀតបៀនព្រះរាជបុត្តរបស់យើងបាន មួយទៀតសូមកុំឲ្យខ្លាឃ្មុំ ឆ្កែព្រៃនិងខ្លារខិនចាប់ខាំស៊ីទារកទាំងពីរបាន ពួកពាឡម្រឹគទាំងបីក្នុងព្រៃ គឺសីហៈមួយ ខ្លាធំមួយ ខ្លាដំបងមួយរាំងផ្លូវខ្ញុំម្ចាស់ ព្រោះហេតុនោះបានជាខ្ញុំម្ចាស់មកក្នុងវេលាល្ងាច ។

[ ៣៥៨ ] ខ្ញុំម្ចាស់មានសក់កណ្តាញ់ប្រព្រឹត្តធម៌ដ៏ប្រសើរ ស្រវាស្រទេញ ( ផ្គត់ផ្គង់ ) ប្តីផង បុត្តទាំងពីរផងអស់ថ្ងៃនិងយប់ដូចជាមាណព ( ផ្គត់ផ្គង់ ) អាចារ្យ ។ ហៃបុត្តកម្សត់ទាំងពីរ មាតាស្លៀកដណ្តប់ស្បែកខ្លាខំស្វែងរកមើមឈើនិងផ្លែឈើក្នុងព្រៃទាំងថ្ងៃទាំងយប់ ព្រោះតែសេចក្តីស្រឡាញ់កូនឯងទាំងពីរ ។ រមៀតមានពណ៌ដូចជាមាសនិងផ្លែញ្ញៅនេះ មាតាបាននាំមកដល់ហើយ មាតាបាននាំទាំងផ្លែឈើទាំងឡាយ ( ឯទៀតផង ) ហៃបុត្តកម្សត់ទាំងពីរ ផ្លែ

ឈើទាំងនេះជាល្បែងរបស់កូនឯងទាំងពីរ ។ មើមឈូក ក្រអៅឧប្បល ក្រចាប់នេះ បពិត្រក្សត្រិយ៍ សូមព្រះអង្គព្រមទាំងបុត្តទាំងពីរសោយ ( វត្ថុទាំងនោះ ) ដែលលាយដោយទឹកឃ្មុំចុះ ។ បពិត្រព្រះបាទសិវិ សូមព្រះអង្គប្រទានផ្កាឈូកដល់ជាលី សូមព្រះអង្គប្រទានផ្កាកុមុទដល់នាងកុមារី សូមទត ( កុមារទាំងពីរ ) ដែលប្រដាប់ដោយកម្រងផ្កាហើយរាំ សូមព្រះអង្គត្រាស់ហៅបុត្តទាំងពីរមក ។ បពិត្រព្រះអង្គជាធំក្នុងរថ បណ្តាបុត្តទាំងពីរនោះបុត្រីឈ្មោះកណ្ហាជិនារមែងទៅ សូមព្រះអង្គទ្រង់ព្រះសណ្តាប់ ( សំឡេង ) របស់វាដែលពីរោះគួរចាប់ចិត្ត ពាក្យពីរោះចូលទៅកាន់អាស្រម ។ បពិត្រព្រះបាទសិវិ យើងទាំងពីរនាក់ត្រូវគេនិរទេសចាកដែនហើយជាអ្នករួមសុខរួមទុក្ខជាមួយគ្នា ព្រះអង្គឃើញបុត្តទាំងពីរ គឺជាលីនិងកណ្ហាជិនាដែរឬ ។ ខ្ញុំម្ចាស់បានជេរប្រទេចពួកស្រមណ៍និងព្រាហ្មណ៍ក្នុងលោក មានព្រហ្មចរិយធម៌ប្រព្រឹត្តទៅខាងមុខ មានសីលជាពហុស្សូតដោយពិតបានជាខ្ញុំម្ចាស់មិនឃើញបុត្តទាំងពីរ គឺជាលីនិងកណ្ហាជិនានោះក្នុងថ្ងៃនេះ ។

[ ៣៥៩ ] នេះរុក្ខជាតិផ្សេងៗ គឺព្រីង ឈើទាលខ្យាច់ មានមែកត្រសុំត្រសាយ កុមារទាំងនោះអញមិនបានឃើញ ។ នេះផលជាតិផ្សេងៗ គឺពោធិ៍ ខ្នុរ ជ្រៃ ក្រសាំង កុមារទាំងនោះអញមិនបានឃើញ ។ នេះសួនច្បារទាំងឡាយនេះស្ទឹងមានទឹកត្រជាក់ ជាទីដែលកុមារទាំងពីរធ្លាប់លេង កុមារទាំងនោះអញមិនបានឃើញ ។ ផ្កាឈើច្រើនយ៉ាងលើភ្នំនេះជាផ្កាដែលកុមារទាំងពីរធ្លាប់ទ្រទ្រង់ កុមារទាំងនោះអញមិនបានឃើញ ។ ផ្លែឈើច្រើនយ៉ាងលើភ្នំនេះជាផ្លែដែល

កុមារទាំងពីរធ្លាប់បរិភោគ កុមារទាំងនោះអញមិនបានឃើញសោះ ។ រូបដំរី រូបសេះទាំងនេះក្តី រូបគោទាំងនេះក្តីជារូបដែលកុមារទាំងពីរធ្លាប់លេង កុមារទាំងនោះអញមិនបានឃើញ ។

[ ៣៦០ ] រូបម្រឹគមានសម្បុរពព្រុស រូបទន្សាយ រូបមៀម រូបម្រឹគឈ្លូសជាច្រើនទាំងនេះ ជារូបដែលកុមារទាំងពីរធ្លាប់លេង កុមារទាំងនោះអញមិនបានឃើញ ។ រូបហង្ស រូបក្រៀល រូបក្ងោកមានស្លាបដ៏វិចិត្រជារូបដែលកុមារទាំងពីរធ្លាប់លេង កុមារទាំងនោះអញមិនបានឃើញ ។

[ ៣៦១ ] គុម្ពឈើទាំងនេះមានផ្ការីកសព្វកាល ជាផ្កាដែលកុមារទាំងពីរធ្លាប់លេង កុមារទាំងនោះអញមិនបានឃើញ ។ ស្រះបោក្ខរណីទាំងនេះគួរជាទីត្រេកអរ ទ្រហឹងអឹងកងដោយសត្វចាក្រពាក ដេរដាសដោយផ្កាមណ្ឌាលកៈផង ដោយផ្កាឈូកនិងផ្កាឧប្បលផង ជាទីដែលកុមារទាំងពីរធ្លាប់លេង កុមារទាំងនោះអញមិនបានឃើញ ។

[ ៣៦២ ] ឧសទាំងឡាយព្រះអង្គមិនកាប់ ទឹកព្រះអង្គមិនដង ភ្លើងព្រះអង្គមិនបង្កាត់ ហេតុអ្វីបានជាព្រះអង្គសញ្ជប់សញ្ជឹង ដូចមនុស្សខ្វៅ ។ ( ព្រះវេស្សន្តរ ) ជាទីស្រឡាញ់ ( របស់ខ្ញុំម្ចាស់ ) សេចក្តីព្រួយតែងរសាយព្រោះបានជួបជុំដោយព្រះអង្គជាទីស្រឡាញ់ ក្នុងថ្ងៃនេះខ្ញុំម្ចាស់មិនឃើញបុត្តទាំងពីរ គឺជាលីនិងនាងកណ្ហាជិនានោះ ។

[ ៣៦៣ ] បពិត្រព្រះទេវៈ ខ្ញុំម្ចាស់មិនឃើញបុត្តរបស់យើងទាំងពីរសោះ ខ្ញុំម្ចាស់មិនដឹងជា ( អ្នកណា ) នាំយកបុត្តទាំងនោះទៅ ទាំងពួកក្អែក

ព្រៃសោតក៏មិនកញ្រៀវ ទារកទាំងពីររបស់ខ្ញុំម្ចាស់ ប្រាកដជាស្លាប់ហើយ ។ បពិត្រព្រះទេវៈ ខ្ញុំម្ចាស់មិនឃើញបុត្តរបស់យើងទាំងពីរសោះ ខ្ញុំម្ចាស់មិនដឹងជា ( អ្នកណា ) នាំយកបុត្តទាំងនោះទៅ ទាំងពួកសត្វស្លាបសោតក៏មិនកញ្រៀវ ទារកទាំងពីររបស់ខ្ញុំម្ចាស់ប្រាកដជាស្លាប់ហើយ ។

[ ៣៦៤ ] ( អភិសម្ពុទ្ធគាថា ) នាងមទ្រីនោះ ( បានត្រាច់ទៅ ) កាន់ភ្នំនិងព្រៃឈើក្នុងទីនោះហើយត្រឡប់មកអាស្រមវិញ ក៏ទ្រង់ព្រះកន្សែងក្នុងសំណាក់ព្រះរាជស្វាមីថា បពិត្រព្រះទេវៈ ខ្ញុំម្ចាស់មិនឃើញ ( បុត្តទាំងពីរ ) របស់យើងសោះ ខ្ញុំម្ចាស់មិនដឹងជា ( អ្នកណា ) នាំយកបុត្តទាំងនោះទៅ ទាំងពួកក្អែកព្រៃសោតក៏មិនកញ្រៀវ ទារកទាំងពីររបស់ខ្ញុំម្ចាស់ប្រាកដជាស្លាប់ហើយ ។ បពិត្រព្រះទេវៈ ខ្ញុំម្ចាស់មិនឃើញ ( បុត្តទាំងពីរ ) របស់យើងសោះ ខ្ញុំម្ចាស់មិនដឹងជា ( អ្នកណា ) នាំយកបុត្តទាំងនោះទៅ ទាំងពួកសត្វស្លាបសោតក៏មិនកញ្រៀវ ទារកទាំងពីររបស់ខ្ញុំម្ចាស់ ប្រាកដជាស្លាប់ហើយ ។ បពិត្រព្រះទេវៈ ខ្ញុំម្ចាស់មិនឃើញ ( បុត្តទាំងពីរ ) របស់យើងសោះ ខ្ញុំម្ចាស់មិនដឹងជា ( អ្នកណា ) នាំយកបុត្តទាំងនោះទៅ ម្នាលភិក្ខុទាំងឡាយ នាងមទ្រីត្រាច់ទៅក្រោមម្លប់ឈើនិងភ្នំនិងគុហា ។ នាងមទ្រីមានកម្ពស់និងទំហំដ៏ប្រសើរ ជារាជបុត្រីមានយស ក៏ផ្គងដើមដៃទាំងពីរកន្ទក់កន្ទេញយ៉ាងនេះហើយក៏ដួលទៅលើផែនដីក្នុងទីនោះ ។

[ ៣៦៥ ] ព្រះបាទវេស្សន្តរ ទ្រង់ស្រោចស្រពព្រះរាជបុត្រីនោះដែលបានមកដល់សំណាក់ព្រះអង្គ បន្ទាប់អំពីនោះមកព្រះអង្គជ្រាបព្រះរាជបុត្រី

នោះដែលស្រួលចិត្តហើយ ទើបបានត្រាស់នឹងព្រះរាជបុត្រីនោះយ៉ាងនេះថា ហៃនាងមទ្រី អញមិនចង់ប្រាប់សេចក្តីទុក្ខដល់នាងអំពីដំបូងទេ មានព្រាហ្មណ៍ចាស់កម្សត់ជាស្មូមបានមកកាន់លំនៅ ។ ហៃនាងមទ្រី អញបានឲ្យបុត្តទាំងពីរដល់ព្រាហ្មណ៍នោះហើយ នាងកុំកិតភ័យអ្វី នាងចូរស្រួលចិត្តចុះ ហៃនាងមទ្រី នាងចូរមើលមកអញកុំមើលបុត្តទាំងពីរ កុំខ្សឹកខ្សួលខ្លាំងឡើយ កាលបើយើងរស់នៅបានសុខសប្បាយ ក៏គង់បាន ( ចួបប្រទះ ) នឹងបុត្តវិញ ។ សប្បុរសបានឃើញពួកស្មូមមកហើយគប្បីឲ្យកូន សត្វចិញ្ចឹម ធញ្ញជាតិនិងទ្រព្យដទៃដែលមានក្នុងផ្ទះជាទាន ហៃនាងមទ្រី នាងចូររីករាយតាមនូវអំណោយបុត្តដ៏ឧត្តមរបស់អញ ។

[ ៣៦៦ ] ( ព្រះនាងមទ្រី... ) បពិត្រព្រះទេវៈ ខ្ញុំម្ចាស់សូមរីករាយតាមនូវអំណោយបុត្តដ៏ឧត្តមរបស់ព្រះអង្គ ព្រះអង្គប្រទានហើយ សូមធ្វើព្រះហឫទ័យឲ្យជ្រះថ្លាចុះ សូមព្រះអង្គទ្រង់ឲ្យទានជាកិយ្យោភាពចុះ ។ បពិត្រព្រះជនាធិបៈ កាលដែលពួកមនុស្សកំពុងមានសេចក្តីកំណាញ់ ព្រះអង្គជាអ្នកញុំាងអ្នកសិវិរាស្ត្រឲ្យចម្រើន ទ្រង់បានដាក់ទានដល់ព្រាហ្មណ៍ ។

[ ៣៦៧ ] ព្រះអង្គបានញុំាងផែនដីឲ្យខ្ទរខ្ទារ កិត្តិសព្ទរបស់ព្រះអង្គទៅដល់ទេវលោក ផ្លេកបន្ទោរពុំដូកាលដាលប្រវាត់ជុំវិញព្រៃហិមពាន្ត ដូចជាសំឡេងលាន់នៃភ្នំទាំងឡាយ ។

[ ៣៦៨ ] ពួកទេវតាទាំងពីរក្រុម គឺនារទៈនិងបព្វតៈ ព្រមទាំងព្រះឥន្ទព្រះព្រហ្មនិងបជាបតិទេវបុត្តសោមទេវបុត្តព្រះបាទយមៈ និងព្រះបាទវេស្ស-

វណាក៏នាំគ្នាវិករាយតាមព្រះអង្គនោះ ពួកទេវតាទាំងអស់ ដែលកើតក្នុងឋាន តាវត្តិង្សព្រមទាំងព្រះឥន្ទក៏រីករាយតាម ។ ( ព្រះសាស្តាបានត្រាស់គាថានេះថា ) ព្រះនាងមទ្រីមានកម្ពស់និងទំហំដ៏ប្រសើរ ជារាជបុត្រីមានយស បានរីករាយតាមនូវអំណោយបុត្តដ៏ឧត្តមរបស់ព្រះបាទវេស្សន្តរដោយប្រការដូច្នេះ ។

**ចប់ មទ្ទីបព្វៈ ។**

[ ៣៦៩ ] ( អភិសម្ពុទ្ធគាថា ) លំដាប់នោះក្នុងកាលដែលរាត្រីកន្លងទៅហើយព្រះអាទិត្យក៏រះឡើង សក្កទេវរាជមានភេទជាព្រាហ្មណ៍ប្រាកដដល់ក្សត្រទាំងពីរនោះក្នុងពេលព្រឹក ។

[ ៣៧០ ] ( សក្កទេវរាជ... ) ព្រះអង្គសុខសប្បាយទេឬ ព្រះអង្គមិនមានរោគាពាធទេឬ ព្រះអង្គញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយការស្វែងរកស្រួលទេឬ មើមឈើនិងផ្លែឈើមានច្រើនដែរឬ ។ ពួករបោម មូសនិងពស់មានតិចទេឬ ក្នុងព្រៃដ៏កុះករដោយម្រឹគយង់ឃ្នងមិនមានការបៀតបៀនទេឬ ។

[ ៣៧១ ] ( ព្រះមហាសត្វ... ) ម្នាលព្រាហ្មណ៍ ពួកយើងសុខសប្បាយទេ ម្នាលព្រាហ្មណ៍ មិនមានរោគាពាធអ្វីទេ មួយទៀតយើងញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយការស្វែងរកស្រួលទេ មើមឈើនិងផ្លែឈើទាំងឡាយដ៏បរិបូណ៌ដែរទេ ។ ទាំងពួករបោម មូសនិងពស់មានតិចទេ ក្នុងព្រៃដ៏កុះករដោយម្រឹគយង់ឃ្នងមិនមានការបៀតបៀនយើងទេ ។ យើងនៅក្នុងព្រៃអស់ ៧ ខែ រស់នៅទាំងសំណោក ទើបឃើញព្រាហ្មណ៍ជាគម្រប់ពីរនេះ មានភេទដ៏ប្រសើរ

កាន់ឈើប្រត់ មានពណ៌ដូចជាផ្លែញ៉ៅទុំ ទ្រទ្រង់ស្បែកខ្លាទាំងក្រចក ។ នែមហាព្រាហ្មណ៍ អ្នកមកល្អហើយ មួយទៀតអ្នកមិនមែនមកអាក្រក់ទេ អញ្ជើញអ្នកចូលទៅខាងក្នុង សេចក្តីចម្រើន ( ចូរមាន ) ដល់អ្នក អ្នកចូរលាងជើងទាំងឡាយរបស់អ្នក ។ ម្នាលព្រាហ្មណ៍ អ្នកចូរបរិភោគផ្លែឈើយ៉ាងឆ្ងាញ់ៗដូចទឹកឃ្មុំ គឺផ្លែទន្លាប់ ទ្រយឹង មាក់ប្រាង មាក់ដោក ។ ទឹកត្រជាក់នេះដងមកអំពីជ្រោះភ្នំ ម្នាលមហាព្រាហ្មណ៍ អ្នកចូរផឹកទឹកនេះចុះបើអ្នកប្រាថ្នាចង់ផឹក ។ យើងសូមសួរអ្នក អ្នកបានមកដល់ព្រៃធំដោយរឿងដូចម្តេច ឬដោយហេតុដូចម្តេច អ្នកកាលបើយើងសួរហើយចូរប្រាប់រឿងនោះ ។

[ ៣៧២ ] ( សក្កទេវរាជ... ) ផ្លូវទឹកដ៏ពេញប្រៀបមិនអស់ទៅសព្វកាលយ៉ាងណាមិញ ទូលបង្គំជាខ្ញុំមកដើម្បីសូមទានព្រះអង្គ ទូលបង្គំជាខ្ញុំសូមហើយសូមព្រះអង្គប្រទានករិយាក៏យ៉ាងនោះដែរ ។

[ ៣៧៣ ] ( ព្រះមហាសត្វ... ) ម្នាលព្រាហ្មណ៍ យើងឲ្យរបស់ដែលអ្នកសូមនឹងយើង យើងមិនរួញរាទេ យើងមិនលាក់លៀមវត្ថុដែលមាន ចិត្តរបស់យើងត្រេកអរក្នុងទាន ។

[ ៣៧៤ ] ( អភិសម្ពុទ្ធគាថា ) ព្រះបាទវេស្សន្តរ ជាអ្នកញុំាងពួកអ្នកសិវិរាស្ត្រឲ្យចម្រើន ចាប់ដៃនាងមទ្រីនិងកុណ្ឌីទឹកហើយបានដាក់ទានដល់ព្រាហ្មណ៍ ។ កាលដែលព្រះវេស្សន្តរទ្រង់លះបង់ព្រះនាងមទ្រី ហេតុដែលគួរស្ញប់ស្ញែងក៏កើតមានក្នុងកាលនោះ សេចក្តីព្រឺរោមក៏កើតមានក្នុងកាលនោះផែនដីក៏ញាប់ញ័រ ។ ព្រះនាងមទ្រីមិនមានមុខក្រញូវ មិនអៀន មិនយំ ព្រះនាង

ស្មៀមសម្លឹង ( ព្រះភក្ត្រ ) របស់ព្រះបាទវេស្សន្តរនោះ ( ដោយគិតថា ) ព្រះរាជានេះជ្រាបហេតុដ៏ប្រសើរ ។

[ ៣៧៥ ] តថាគតកាលដែលលះរាជបុត្រាឈ្មោះជាលី រាជធីតាឈ្មោះកណ្ហាជិនានិងនាងទេវីឈ្មោះមទ្រី ដែលមានវត្តដ៏ល្អក្នុងប្តីមិនគិត ( ស្តាយ ) ព្រោះហេតុតែពោធិញ្ញាណដោយពិត ។ បុត្តទាំងពីរមិនមែនជាទីស្អប់របស់តថាគតទេ នាងទេវីឈ្មោះមទ្រីមិនមែនមិនជាទីស្រឡាញ់របស់តថាគតទេ សព្វញ្ញុតញ្ញាណជាទីស្រឡាញ់របស់តថាគត ព្រោះហេតុនោះបានជាតថាគតឲ្យជនទាំង ៣ នាក់ជាទីស្រឡាញ់ ( ដល់ព្រាហ្មណ៍ ) ។

[ ៣៧៦ ] ( ព្រះនាងមទ្រី... ) ខ្ញុំម្ចាស់ជាភរិយារបស់ព្រះអង្គអំពីក្មេង ព្រះអង្គជាស្វាមី ជាឥស្សរៈរបស់ខ្ញុំម្ចាស់ស្រាប់ហើយ ចង់ឲ្យខ្ញុំម្ចាស់ដល់អ្នកណា គប្បីឲ្យដល់អ្នកនោះចុះ ចង់លក់ឬចង់សម្លាប់ ( ក៏បាន ) ។

[ ៣៧៧ ] ( អភិសម្ពុទ្ធគាថា ) ព្រះឥន្ទ្រជាធំជាងទេវតាជ្រាបសេចក្តីត្រិះរិះរបស់ជនទាំងនោះហើយក៏បានពោលដូច្នេះថា ពួកសត្រូវទាំងអស់ដែលឃាត់នូវទិព្វសម្បត្តិនិងមនុស្សសម្បត្តិ ព្រះអង្គក៏បានឈ្នះហើយ ព្រះអង្គបានញុំាងផែនដីឲ្យខ្ទរខ្ទារ កិត្តិសព្ទរបស់ព្រះអង្គផ្សាយទៅដល់ទេវលោក ផ្គរបន្ទោរក៏ដាលប្រវាត់ជុំវិញដូចជាសំឡេងលាន់នៃភ្នំទាំងឡាយ ។ ពួកទេវតាទាំង ២ ក្រុម គឺនារទៈនិងបព្វតៈ ទាំងព្រះឥន្ទ ព្រះព្រហ្មនិងបជាបតិទេវបុត្តសោមទេវបុត្ត ព្រះបាទយមៈនិងព្រះបាទវេស្សវណ រីករាយតាមព្រះអង្គនោះ ពួកទេវតាទាំងអស់ក៏រីករាយតាម ( យ៉ាងនេះថា ) មែនពិតព្រះបាទវេស្សន្តរ

នោះធ្វើអំពើដែលគេធ្វើបានដោយកម្រ ។ កាលដែលពួកជនកំពុងឲ្យវត្ថុ ដែលគេឲ្យបានដោយកម្រ កំពុងធ្វើអំពើដែលគេធ្វើបានដោយកម្រ ពួកអសប្បុរសរមែងមិនធ្វើតាម ( អំពើនោះ ) ឡើយ ធម៌របស់ពួកសប្បុរស គឺគេដឹងបានដោយក្រ ។ ព្រោះហេតុនោះដំណើរទៅអំពីលោកនេះ ( ទៅកាន់បរលោក ) នៃពួកសប្បុរសនិងពួកអសប្បុរសជាដំណើរផ្សេងគ្នា ពួកអសប្បុរសទៅកាន់នរក ពួកសប្បុរសមានឋានសួគ៌ប្រព្រឹត្តទៅក្នុងខាងមុខ ។ ព្រះអង្គកាលដែលគង់នៅក្នុងព្រៃបានប្រទានកុមារទាំងពីរ ទាំងបានប្រទានករិយា ទានទាំងពីរនោះឈ្មោះថាជាយានដ៏ប្រសើរ មិននាំចុះទៅ ( កាន់អបាយភូមិ ) ទេ យានដ៏ប្រសើរនោះ សូមសម្រេចដល់ព្រះអង្គក្នុងឋានសួគ៌ ។

[ ៣៧៨ ] ( សក្កោទេវរាជ... ) ឥឡូវខ្ញុំសូមថ្វាយនាងមទ្រីជាស្ត្រីមានសពាង្គដ៏ល្អ ជាករិយារបស់ព្រះអង្គវិញ ព្រះអង្គសមគួរនឹងនាងមទ្រីដោយពិត នាងមទ្រីក៏សមគួរនឹងព្រះអង្គដែលជាភស្តាដែរ ។ វត្ថុទាំងពីរ គឺទឹកដោះស្រស់មួយ ស័ង្ខមួយមានសម្បុរស្មើគ្នាយ៉ាងណាមិញ ព្រះអង្គនឹងនាងមទ្រីមានព្រះហឫទ័យស្មើគ្នាក៏យ៉ាងនោះដែរ ។ ព្រះអង្គទាំងពីរជាក្សត្រិយ៍បរិបូណ៌ដោយគោត្ត មានព្រះជាតិល្អខាងមាតានិងបិតា ត្រូវគេនិរទេសមកគង់នៅក្នុងអាស្រមនាព្រៃនេះ ព្រះអង្គគប្បីធ្វើបុណ្យ ឲ្យទានតាមសមគួរតៗទៅ ។

[ ៣៧៩ ] ខ្ញុំជាទេវិន្ទឈ្មោះសក្កៈ បានមកក្នុងសំណាក់ព្រះអង្គ បពិត្រព្រះរាជា ជាឥសី សូមព្រះអង្គទទួលយកពរចុះ ខ្ញុំសូមថ្វាយពរ ៨ យ៉ាងចំពោះព្រះអង្គ ។

[ ៣៨០ ] ( ព្រះពោធិសត្វ... ) បពិត្រសក្កៈជាធំជាងទេវតាទាំងពួង បើព្រះអង្គនឹងប្រទានពរដល់ខ្ញុំ ( ខ្ញុំ ) សូមព្រះបិតាស្រុះស្រួលទទួលខ្ញុំដែលទៅអំពីព្រៃនេះដល់សំណាក់របស់ខ្លួន សូមអញ្ជើញខ្ញុំដោយអាសនៈ ( រាជសម្បត្តិ ) ខ្ញុំសូមពរទី ១ នេះ ។ ខ្ញុំសូមមិនចូលចិត្តនឹងការសម្លាប់បុរស ខ្ញុំសូមដោះអំពីការសម្លាប់នូវមនុស្សដែលគេត្រូវសម្លាប់ សូម្បីមនុស្សនោះធ្វើអំពើមោះមៃ ( មានកំហុសក្នុងព្រះរាជា ) ក៏ដោយ ខ្ញុំសូមពរទី ២ នេះ ។ សូមឲ្យពួកបុរសទាំងចាស់ក្មេង ទាំងកណ្តាលរស់នៅអាស្រ័យនឹងខ្ញុំ ខ្ញុំសូមពរទី ៣ នេះ ។ ខ្ញុំសូមមិនគប់រកប្រពន្ធអ្នកដទៃ ខ្ញុំសូមជាអ្នកខ្វល់ខ្វាយចំពោះតែប្រពន្ធរបស់ខ្លួន ខ្ញុំសូមមិនលុះក្នុងអំណាចពួកស្ត្រី ខ្ញុំសូមពរទី ៤ នេះ ។ បពិត្រសក្កៈ បុត្តរបស់ខ្ញុំកើតហើយ សូមឲ្យបុត្តនោះមានអាយុវែង សូមឲ្យបានគ្រួតត្រាផែនដីដោយធម៌ ខ្ញុំសូមពរទី ៥ នេះ ។ តអំពីនោះមកនាកាលរាត្រីកន្លងទៅព្រះអាទិត្យរះឡើង សូមចំណីជាទិព្វទាំងឡាយមានប្រាកដ ខ្ញុំសូមពរទី ៦ នេះ ។ កាលបើខ្ញុំកំពុងឲ្យសូម ( ទេយ្យធម៌ ) កុំបីអស់ទៅ លុះខ្ញុំឲ្យហើយសូមកុំឲ្យក្តៅក្រហាយស្តាយក្រោយ ខ្ញុំកំពុងឲ្យសូមឲ្យចិត្តជ្រះថ្លា ខ្ញុំសូមពរទី ៧ នេះ ។ កាលបើខ្ញុំច្យុតចាកអត្តភាពនេះ សូមឲ្យបានទៅកាន់ឋានសួគ៌ដល់នូវឋានដ៏វិសេស គឺកើតក្នុងតុសិតបុរី ( កាលបើខ្ញុំច្យុតចាកតុសិតភពនោះមក ) សូមកុំឲ្យកើត ( ក្នុងភពថ្មីទៀត ) ខ្ញុំសូមពរទី ៨ នេះ ។

[ ៣៨១ ] ( អភិសម្ពុទ្ធគាថា ) ព្រះឥន្ទ្រជាធំជាងទេវតា បានទ្រង់ព្រះសណ្តាប់ព្រះបន្ទូលព្រះបាទវេស្សន្តរនោះ ហើយក៏ពោលពាក្យយ៉ាងនេះថា

ព្រះបិតាបង្កើតរបស់ព្រះអង្គ មិនយូរទេនឹងមកចួបព្រះអង្គ ។ មឃទេវរាជជាប្តីនៃនាងសុជាតា លុះត្រាស់ព្រះតម្រាស់នេះហើយប្រទានពរ ដល់ព្រះបាទវេស្សន្តរហើយក៏ចៀសចេញទៅកាន់ពួកទេវតាក្នុងឋានសួគ៌ ។

**ចប់ សក្កបព្វៈ ។**

[ ៣៨២ ] ( ព្រះបាទសញ្ជ័យ... ) មុខអ្នកណានុ៎ះ ភ្លឺដូចមាសដែលគេរំលាយដោយភ្លើងឬដូចមាសត្រោរ ភ្លឺចិញ្ចែងចិញ្ចាចក្នុងមាត់បាវ ។ កុមារទាំងពីរមានអវយវៈស្រដៀងគ្នា កុមារទាំងពីរមានលក្ខណៈស្រដៀងគ្នា កុមារម្នាក់ស្រដៀងនឹងជាលី កុមារីម្នាក់ដូចនាងកណ្ហាជិនា ។ កុមារទាំងពីរបរិបូណ៌ដោយរូបសម្បត្តិដូចជាពួកសីហៈ ដែលចេញអំពីរូង ទារកទាំងនេះប្រាកដដូចរូបជាវិការៈនៃមាស ។

[ ៣៨៣ ] ម្នាលភារទ្វាជៈ អ្នកនាំទារកទាំងពីរនេះ មកអំពីទីណាហ្ន៎ ម្នាលព្រាហ្មណ៍ អ្នកមកដល់ដែនក្នុងថ្ងៃនេះ តើអ្នកមកអំពីទីណា ។

[ ៣៨៤ ] ( ជូជក... ) បពិត្រព្រះទេវៈទ្រង់ព្រះនាមសញ្ជ័យ ព្រះបាទវេស្សន្តរ ទ្រង់មានព្រះហឫទ័យត្រេកអរ បានប្រទានទារកទាំងនោះដល់ទូលព្រះបង្គំជាខ្ញុំ តាំងពីថ្ងៃដែលទូលព្រះបង្គំជាខ្ញុំបានទារកមក ១៥ រាត្រី ក្នុងថ្ងៃនេះហើយ ។

[ ៣៨៥ ] ( ព្រះបាទសញ្ជ័យ... ) អ្នកឯងធ្វើយើងឲ្យជឿដោយពាក្យជាទីស្រឡាញ់តាមហេតុត្រឹមត្រូវដូចម្តេចបាន នរណាហ៊ានលើកបុត្តទាំងពីរឲ្យជា

ទានដ៏ឧត្តមហើយឲ្យដល់អ្នក ។

[ ៣៨៦ ] ( ជូជក... ) ព្រះបាទវេស្សន្តរណាជាទីពឹងរបស់ពួកស្មូម ដូចជាព្រះធរណីជាទីពឹងរបស់ពួកសត្វ ព្រះបាទវេស្សន្តរនោះទ្រង់គង់នៅក្នុងព្រៃ បានប្រទានបុត្តទាំងពីរដល់ទូលព្រះបង្គំជាខ្ញុំ ។ ព្រះវេស្សន្តរណា ជាទីប្រព្រឹត្តទៅនៃពួកស្មូមដូចសាគរជាទីប្រព្រឹត្តទៅនៃស្ទឹងទាំងឡាយ ព្រះបាទវេស្សន្តរនោះទ្រង់គង់នៅក្នុងព្រៃ បានប្រទានបុត្តទាំងពីរដល់ទូលព្រះបង្គំជាខ្ញុំ ។

[ ៣៨៧ ] ( ពួកអាមាត្យ... ) ម្នាលគ្នាយើង ព្រះរាជាកាលទ្រង់គង់នៅក្នុងព្រះរាជដំណាក់ ទ្រង់មានសទ្ធាធ្វើអាក្រក់ណាស់ ព្រះបាទវេស្សន្តរត្រូវគេនិរទេសទៅគង់នៅក្នុងព្រៃហើយ ម្តេចក៏នៅតែប្រទានបុត្តទាំងពីរទៀត ។ នៃអ្នកដ៏ចម្រើនទាំងឡាយ អ្នកទាំងប៉ុន្មាននាក់ដែលបានមកចួបជុំគ្នាក្នុងទីនេះ ចូរស្តាប់រឿងនេះចុះ ហេតុដូចម្តេចបានជាព្រះបាទវេស្សន្តរ ទៅគង់នៅក្នុងព្រៃហើយក៏ប្រទានបុត្តទាំងពីរ ។ ព្រះអង្គគួរប្រទានទាសា ទាសី សេះ រថដែលទឹមដោយសេះអស្សតរផង គួរប្រទានដំរីកុញ្ជរផង ហេតុដូចម្តេចបានជាដាក់ទានទារកទាំងពីរទៀត ។

[ ៣៨៨ ] ( ជាលីកុមារ... ) បពិត្រព្រះអយ្យកោ ទាសៈ សេះឬរថដែលទឹមដោយសេះអស្សតរនិងដំរីកុញ្ជរមិនមានក្នុងផ្ទះនៃបុគ្គលណា បុគ្គលនោះនឹងឲ្យដូចម្តេចកើត ។

[ ៣៨៩ ] ( ព្រះបាទសញ្ជ័យ... ) នៃចៅ យើងសរសើរទានបិតារបស់អ្នក យើងមិនមែនបន្ទុះបង្អាប់ទេ ចុះហឫទ័យ ( នៃបិតារបស់បា ) តើដូច

ម្ដេចបានជាឲ្យបាទាំងពីរដល់ស្មូម ។

[ ៣៩០ ] ( ជាលីកុមារ... ) បពិត្រមហារាជ ( ការណ៍ដែល ) ព្រះបិតារបស់ទូលព្រះបង្គំជាខ្ញុំ ទ្រង់ប្រទានយើងខ្ញុំដល់ស្មូម ( នោះ ) សូមព្រះអង្គទ្រង់ព្រះសណ្ដាប់នូវវាចាគួរឲ្យអាណោចអាធ័មដែលនាងកណ្ហាជិនាជាប្អូនពោលចុះ ។

[ ៣៩១ ] ហឫទ័យនៃព្រះបិតារបស់ទូលព្រះបង្គំជាខ្ញុំនោះ ជាទុក្ខទាំងទ្រង់មានអស្សាសបស្សាសៈដ៏ក្ដៅ ព្រះបិតាមានព្រះនេត្រក្រហមដូចជាផ្កាយរោហិណី ទ្រង់សម្រក់ទឹកព្រះនេត្រ ។

[ ៣៩២ ] នាងកណ្ហាជិនាបានពោលនឹងព្រះបិតានោះថា បពិត្រព្រះបិតា ព្រាហ្មណ៍នេះវាយខ្ញុំម្ចាស់ដោយឈើច្រត់ដូច ( ម្ចាស់ ) វាយទាសីដែលកើតក្នុងផ្ទះ ។ បពិត្រព្រះបិតា អ្នកនេះមិនមែនជាព្រាហ្មណ៍ទេ ព្រោះពួកព្រាហ្មណ៍តែងជាអ្នកប្រព្រឹត្តធម៌ បពិត្រព្រះបិតា យក្សក្លែងភេទជាព្រាហ្មណ៍នាំពួកយើងខ្ញុំយកទៅស៊ីទេដឹង ។ បពិត្រព្រះបិតា យើងខ្ញុំកាលបិសាចនាំយកទៅ ហេតុអ្វីក៏ព្រះអង្គទ្រង់ទតព្រងើយ ។

[ ៣៩៣ ] ( ព្រះបាទសញ្ជ័យ... ) មាតារបស់អ្នកជាព្រះរាជបុត្រី បិតារបស់អ្នកជាព្រះរាជបុត្រា ក្នុងកាលពីដើមបាទាំងពីរឡើងកាន់ភ្លៅនរបស់អញចុះហេតុអ្វីបានជាបាទាំងពីរឋិតនៅក្នុងទីឆ្ងាយ ។

[ ៣៩៤ ] ( ជាលីកុមារ... ) ព្រះមាតារបស់ពួកទូលព្រះបង្គំជាខ្ញុំ ជាព្រះរាជបុត្រី ព្រះបិតារបស់ពួកទូលព្រះបង្គំជាខ្ញុំជាព្រះរាជបុត្រា ទូលព្រះបង្គំ

ជាខ្ញុំទាំងពីរនាក់ ជាទាសារបស់ព្រាហ្មណ៍ ហេតុនោះបានជាទូលព្រះបង្គំជាខ្ញុំ ឋិតនៅក្នុងទីឆ្ងាយ ។

[ ៣៩៥ ] ( ព្រះបាទសញ្ជ័យ... ) នៃចៅសម្លាញ់ទាំងពីរ បាទាំងពីរ កុំពោលយ៉ាងនេះឡើយនាំឲ្យក្តៅហឫទ័យរបស់ជីតាណាស់ កាយរបស់ជីតា ហាក់ដូចជា ( គេលើកដាក់ ) លើជើងថ្ករ ជីតាមិនបានសុខលើអាសនៈទេ ។

[ ៣៩៦ ] នៃចៅសម្លាញ់ទាំងពីរ បាទាំងពីរកុំពោលយ៉ាងនេះឡើយ បា ឯងរឹងរឹតតែញុំាងសំណោកឲ្យកើតដល់ជីតា ជីតានឹងលោះដោះសាបាដោយ ទ្រព្យមិនឲ្យបានៅជាទាសាគេទេ ។ នៃបា បិតារបស់បាបានកាត់ថ្លៃប៉ុន្មានហើយ បានឲ្យបាទាំងពីរដល់ព្រាហ្មណ៍ បាចូរប្រាប់ដល់ជីតាឲ្យត្រង់ ពួកអាមាត្យ ចូរ ញុំាងព្រាហ្មណ៍ឲ្យទទួលទ្រព្យ ។

[ ៣៩៧ ] ( ជាលីកុមារ... ) បពិត្រព្រះអយ្យកោ ព្រះបិតាបានប្រទាន ទូលព្រះបង្គំជាខ្ញុំដល់ព្រាហ្មណ៍ដោយកាត់ថ្លៃមួយពាន់និក្ខៈ ប្រទានកញ្ញាឈ្មោះ កណ្ហាជិនាជាប្អូនស្រីដោយកាត់ថ្លៃមួយរយនៃវត្ថុគ្រប់មុខ មានដំរីជាដើម ។

[ ៣៩៨ ] ( ព្រះបាទសញ្ជ័យ... ) នៃនាយអាមាត្យ អ្នកចូរក្រោក ឲ្យឆាប់ហើយចូរឲ្យទាសី ១០០ ទាសា ១០០ គោ ១០០ ដំរី ១០០ គោបា ១០០ ( សេះ ១០០ និក្ខៈ ១០០ ) និងមាស ១០០០ តម្លឹងដល់ព្រាហ្មណ៍ ឲ្យជាតម្លៃលោះយកចៅទាំងពីរ ។

[ ៣៩៩ ] ( អភិសម្ពុទ្ធគាថា ) លំដាប់នោះពួកនាយអាមាត្យក៏ប្រញាប់ ប្រញាល់ឲ្យទាសី ១០០ ទាសា ១០០ គោ ១០០ ដំរី ១០០ គោបា ១០០

( សេះ ១០០ និក្ខ: ១០០ ) និងមាស ១០០០ តម្លឹងដល់ព្រាហ្មណ៍ ឲ្យជាតម្លៃលោះយកព្រះរាជនត្តាទាំងពីរ ។

[ ៤០០ ] ( នាយអាមាត្យបានឲ្យទ្រព្យទាំងអស់មួយរយៗគឺទាសី ១០០ ទាសា ១០០ គោ ១០០ ដំរី ១០០ គោបា ១០០ រថទឹមដោយសេះ ១០០ និងមាស ១០០០ តម្លឹងដល់ព្រាហ្មណ៍ជាអ្នកស្វែងរកទ្រព្យ ជាមនុស្សឈ្លានពានលើសលន់ ឲ្យជាតម្លៃលោះយកព្រះរាជនត្តាទាំងពីរ ។

[ ៤០១ ] ក្សត្រទាំងពីរព្រះអង្គបានលោះទារកទាំងពីរហើយផ្ងូតទឹក ឲ្យបរិភោគភោជន ប្រដាប់ដោយគ្រឿងប្រដាប់ទាំងឡាយរួចឲ្យអង្គុយលើភ្លៅ ។ ព្រះរាជាជាព្រះអយ្យកោ ដាក់ជាលីកុមារលើភ្លៅហើយសាកសួរទារកទាំងពីរ ដែលកក់សីសៈហើយ មានសំពត់ដ៏ស្អាត ស្អិតស្អាងដោយអាភរណៈគ្រប់យ៉ាង ។ ព្រះរាជាបានដាក់លើភ្លៅនូវកុមារទាំងពីរ ដែលមានកុណ្ឌលឮសូរគឹកកង មានផ្កាកម្រង ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួងហើយត្រាស់ព្រះរាជតម្រាស់នេះថា នែជាលី មាតានិងបិតារបស់បាទាំងពីរនោះសុខសប្បាយទេឬ ប្រព្រឹត្តចិញ្ចឹមជីវិតដោយការស្វែងរក ( ផលាផល ) ស្រួលទេឬ ទាំងមើមឈើនិងផ្លៃឈើមានច្រើនដែរឬ ពួករបោម មូសនិងពស់មានតិចតួចទេឬ ក្នុងព្រៃដ៏កុះករដោយម្រឹគយង់ឃ្នងមិនមានការបៀតបៀនទេឬ ។

[ ៤០២ ] ( ជាលីកុមារ... ) បពិត្រព្រះទេវៈ មាតានិងបិតារបស់ទូលព្រះបង្គំជាខ្ញុំទាំងពីរនោះសុខសប្បាយជាទេ ប្រព្រឹត្តចិញ្ចឹមជីវិតដោយការស្វែងរក ( ផលាផល ) ស្រួលទេ មើមឈើនិងផ្លៃឈើមានច្រើន ។ ឯពួករបោម

មូសនិងពស់មានតិចទេ ក្នុងព្រៃដ៏កុះករដោយម្រឹគយង់ឃ្នងមិនមានការបៀតបៀនព្រះអង្គទេ ។ ព្រះមាតានោះជីកយកមើមដំឡូងស្បា ដំឡូងដូង ដំឡូងដៃខ្លា ដំឡូងទៀន ទាំងបាននាំយកផ្លែពុទ្រា ផ្លែពក់ខ្មៅ ផ្លែញ្ញៅ មកចិញ្ចឹមយើងខ្ញុំផង ។ បើព្រះមាតានោះជាអ្នកនាំយកមើមឈើនិងផ្លែឈើក្នុងព្រៃ នាំយកវត្ថុណាមក យើងខ្ញុំទាំងអស់គ្នាក៏មកជុំគ្នាបរិភោគវត្ថុនោះតែក្នុងវេលាយប់ មិនបានបរិភោគក្នុងវេលាថ្ងៃទេ ។ ព្រះមាតារបស់យើងខ្ញុំជាស្រីធ្លាប់សុខស្រួល ខំនាំយកផ្លែឈើមកក៏ទៅជាមានកាយស្គមស្លេកស្លាំង ដោយត្រូវខ្យល់និងកម្តៅថ្ងៃដូចជាផ្កាឈូកដែលគេឈ្លីដោយដៃ ។ ព្រះកេសាទាំងឡាយរបស់ព្រះមាតាក៏ជ្រុះព្រោះត្រាច់ទៅក្នុងព្រៃធំ ជាព្រៃដ៏កុះករដោយម្រឹគយង់ឃ្នង ជាទីដែលរមាសនិងខ្លាដំបងអាស្រ័យហើយ ។ ព្រះបិតាបួងផ្នួងសក់ទាំងឡាយ ទ្រទ្រង់ញើសក្អែល ព្ធដ៏ក្បៀក ( ទ្រទ្រង់ភេទនៃបព្វជិតដ៏ប្រសើរ ទ្រទ្រង់ទម្ពក់ ស្លាបព្រាសម្រាប់បូជាភ្លើងនិងជដា ) ស្លៀកពាក់ស្បែកខ្លា ផ្តុំលើផែនដី នមស្ការភ្លើង ។

[ ៤០៣ ] បុត្តជាទីស្រឡាញ់នៃមនុស្សលោក ចម្លែកតែសេចក្តីស្នេហាក្នុងបុត្តមិនកើតដល់ព្រះអយ្យកោរបស់យើងខ្ញុំដោយពិត ។

[ ៤០៤ ] ( ព្រះបាទសញ្ជ័យ... ) នៃចៅ អំពើអាក្រក់យើងបានធ្វើហើយ ទាំងអំពើដែលបង្ខូចសេចក្តីចម្រើនយើងក៏បានធ្វើហើយ ព្រោះជីតាបាននិរទេសបុត្តឥតកំហុស តាមពាក្យនៃពួកអ្នកសិវិរាស្ត្រ ។ វត្ថុណាទីមួយរបស់យើងមានក្នុងទីនេះ ទាំងទ្រព្យនិងធញ្ញជាតិ ( ជីតាក៏នឹងឲ្យវត្ថុនោះដល់បិតា

របស់បា ) សូមវេស្សន្តរបូរមក ចូរជាព្រះរាជាត្រួតត្រាក្នុងដែនសិវិចុះ ។

[ ៤០៥ ] ( ជាលីកុមារ... ) បពិត្រព្រះសម្មតិទេព ព្រះរាជាដ៏ឧត្តម របស់អ្នកសិវិរាស្ត្រ នឹងមិនយាងមកតាមពាក្យរបស់ទូលព្រះបង្គំទេ សូមព្រះសម្មតិទេព ទ្រង់ស្តេចយាងទៅដោយព្រះអង្គឯងវិញហើយស្រោចស្រពព្រះរាជបុត្តបង្កើតដោយកោគៈទាំងឡាយ ។

[ ៤០៦ ] ( អភិសម្ពុទ្ធគាថា ) លំដាប់នោះព្រះរាជាព្រះនាមសញ្ជ័យបានត្រាស់នឹងសេនាបតីថា ពួកសេនាដំរី សេនាសេះ សេនារថ សេនាថ្មើរជើង ចូរសៀត ( អាវុធទាំងឡាយ ) ពួកអ្នកនិគម ព្រាហ្មណ៍ បុរោហិត អាមាត្យ ៦០.០០០ និងពួកទាហានដ៏ល្អមើលចងគ្រឿងក្រោះ ប្រដាប់ដោយគ្រឿងប្រដាប់មានបែបផ្សេងៗ ចូរនាំគ្នាមកឲ្យឆាប់ជូនអញទៅ ។ ពួកទាហានខ្លះស្លៀកពាក់សំពត់ខៀវ ពួកទាហានខ្លះស្លៀកពាក់សំពត់លឿង ពួកទាហានដទៃជូតឈ្នួតក្រហម ពួកទាហានខ្លះស្លៀកពាក់សំពត់ស ចងគ្រឿងក្រោះប្រដាប់ដោយគ្រឿងប្រដាប់មានបែបផ្សេងៗ ចូរនាំគ្នាមកឲ្យឆាប់ ។ ភ្នំហិមពាន្តនិងភ្នំគន្ធមាទន៍ដ៏ទ្រទ្រង់ក្លិនដ៏ដេរដាសដោយពួកឈើផ្សេងៗ ជាលំនៅនៃពួកភូតដ៏ច្រើន ញុំាងទិសទាំងឡាយឲ្យភ្លឺផ្សាយទៅដោយឱសថទាំងឡាយជាទិព្វយ៉ាងណា ពួកទាហាននាំគ្នាចងគ្រឿងក្រោះចូរមកឲ្យឆាប់ ចូរញុំាងទិសទាំងឡាយឲ្យភ្លឺរុងរឿងផ្សាយទៅយ៉ាងនោះដែរ ។ ពួកអ្នកជិះដំរីចូររៀបចំដំរី ១៤ ពាន់ ជាសត្វមានសរីរៈធំ មានខ្សែជង្គន់ជាវិការៈនៃមាស មានសរីរៈស្រោបដោយគ្រឿងតែងតួជាវិការៈនៃមាស ។ ពួកអ្នកបង្ហឹកដំរីមានដៃកាន់ដែកចំពុះ

ទុងនិងកង្វេរ មានគ្រឿងស្អិតស្អាងប្រាកដហើយ ចងគ្រឿងក្រោះហើយ ចូរនាំគ្នាឡើងជិះកដំរីទាំងឡាយបរមកឲ្យឆាប់ ។ ពួកអ្នកជិះសេះចូររៀបចំសេះទាំង ១៤ ពាន់ ជាជាតិសេះសិន្ធពអាជានេយ្យមានសន្ទុះដ៏លឿន ។ ពួកអ្នកបង្ហឹកសេះទ្រទ្រង់ស៊ើនិងធ្នូ ចងគ្រឿងក្រោះប្រដាប់លើខ្នងសេះហើយ ចូរឡើងជិះបរមកឲ្យឆាប់ ។ លំដាប់ពីនោះមកពួកអ្នកបររថ ចូររៀបចំរថទាំង ១៤ ពាន់ជារថមានខ្នងកង់ពាសដោយដែកដ៏ល្អ មានផ្ទះរំលេចដោយមាស ។ ពួកខ្មាន់ធ្នូស្ទាត់ក្នុងការប្រហារ ពួកជាងរថចូរនាំគ្នាលើកទង់ជ័យ ខែលនិងគ្រឿងក្រោះទាំងឡាយ ក្នុងរថទាំងនោះចូរដំឡើងធ្នូ ចងគ្រឿងក្រោះហើយចូរបររថទាំងឡាយមកឲ្យឆាប់ ។

[ ៤០៧ ] អ្នកទាំងឡាយ ចូរតាក់តែងផ្កាទាំងឡាយ ( មានលាជជាគម្រប់ ៥ ) និងផ្កាសម្រាប់រោយរាយ កម្រងផ្កា គ្រឿងក្រអូប គ្រឿងលាបស្រឡាបនិងផ្កាដ៏មានតម្លៃទាំងឡាយ ចូរឋិតនៅត្រង់ផ្លូវដែលបុត្តរបស់អញមក ។ គ្រប់ទ្វារស្រុកចូរតាក់តែងតាំងទុកឪទិនមេរ័យនិងសុរាច្រើន ត្រង់ផ្លូវដែលបុត្តរបស់អញមក ។ ចូរតាក់តែងតាំងទុកសាច់ នំទ្រាបល្ង នំកុម្មាសដែលលាយសាច់ត្រី ត្រង់ផ្លូវដែលបុត្តរបស់អញមក ។ ចូរតាក់តែងតាំងទុកទឹកដោះរាវ ប្រេង ទឹកដោះជូរ ទឹកដោះស្រស់និងសុរាដ៏ច្រើនដែលធ្វើដោយម្សៅថ្មៅ ត្រង់ផ្លូវដែលបុត្តរបស់អញមក ។ ពួកអ្នកធ្វើម្ហូប អ្នកធ្វើបាយ អ្នករាំនិងអ្នកច្រៀង អ្នកច្រៀងទះដៃ អ្នកវាយស្គរ អ្នកច្រៀងដោយសំឡេងដ៏ស្រទន់និងពួកអ្នកចាក់ក្តក ។ ពួកជនចូរដេញពិណាគ្រប់បែប ចូរវាយស្គរនិង

មហោរធឹកទាំងឡាយ ចូរផ្លុំស័ង្ខនិងទះស្គរទាំងឡាយ ។ ជនទាំងឡាយចូរទះសម្ភោរ វាយស្គរធំ ផ្លុំស័ង្ខ ដេញតះខេ ដេញពិណាខ្សែ ៧ វាយមហោរធឹក វាយស្គរទង់ដែង វាយស្គរមន្តល ។

[ ៤០៨ ] សេនាដ៏ច្រើននោះជាកងទ័ពក្នុងដែនសិវិលើកចេញទៅ មានជាលីកុមារជាមគ្គនាយកបានដើរសំដៅទៅកាន់វង្កតបពិត ។ ដំរីដ៏ប្រសើរមានអាយុ ៦០ ខួប បន្លឺកោញ្ចនាទ ដំរីកាលបើមានខ្សែជង្គន់ជាប់នៅហើយក៏បន្លឺកោញ្ចនាទ ។ សេះអាជានីយទាំងឡាយស្រែកកង់រំពង សំឡេងគឹកកងនៃខ្នងកង់ក៏កើតមាន ក្នុងកាលនោះធូលីក៏ហុយបាំងដូចពពក កងទ័ពក្នុងដែនសិវិបានលើកចេញទៅ ។ សេនាដ៏ច្រើននោះអាចនាំយករបស់ដែលគួរនាំយកទៅបានលើកចេញទៅ មានជាលីកុមារជាមគ្គនាយកបានដើរសំដៅទៅកាន់វង្កតបពិត ។ កងទ័ពទាំងនោះបានចូលទៅកាន់ព្រៃធំ មានមែកឈើច្រើន មានទឹកច្រើន ដេរដាសដោយឈើមានផ្កានិងឈើមានផ្លែទាំងសងខាងផ្លូវ ។ ពួកសត្វស្លាបដ៏ច្រើនក្នុងព្រៃធំនោះមានសំឡេងមូល មានសំឡេងពីរោះ មានត្រកូលផ្សេងៗស្រែកហៅសត្វស្លាបដែលកំពុងស្រែកលើដើមឈើដែលផ្កាតាមរដូវ ។ កងទ័ពទាំងនោះទៅកាន់ផ្លូវឆ្ងាយជាច់ស្រយាល ក្នុងកាលអំណើះទៅនៃថ្ងៃនិងយប់បានចូលទៅដល់ប្រទេសដែលព្រះបាទវេស្សន្តរទ្រង់គង់នៅ ។

**ចប់ មហារាជបព្វៈ ។**

[ ៤០៩ ] ( អភិសម្ពុទ្ធគាថា ) ព្រះបាទវេស្សន្តរទ្រង់ឮសំឡេងគឹកកង នៃកងទ័ពទាំងនោះហើយ ក៏ភិតភ័យទ្រង់ឡើងទៅលើភ្នំ ហើយទ្រង់ទតមើល នូវពួកសេនាទាំងភិតភ័យមានបន្ទូលថា នែនាងមទ្រី នាងចូរពិចារណាមើល សំឡេងគឹកកងក្នុងព្រៃយ៉ាងនេះ មានទាំងសេះអាជានីយស្រែកកងរំពង ទាំង ចុងទង់ជ័យក៏ប្រាកដ ។ ជនទាំងនេះដូចជាព្រានបោមព័ទ្ធហ្វូងម្រឹគក្នុងព្រៃដោយ បណ្ដាត់ទាំងឡាយ ដេញទម្លាក់ក្នុងរណ្ដៅហើយចាក់កាប់សម្លាប់ ពន្លះយកតែ សាច់ល្អៗនៃម្រឹគទាំងនោះ ដោយកាំបិតដ៏មុតដោយពិត ។ ពួកយើងមិនមាន ទោស ត្រូវគេនិរទេសមកនៅក្នុងព្រៃ ដល់នូវសេចក្ដីវិនាសក្នុងកណ្ដាប់ដៃ សត្រូវក៏ដូចជាម្រឹគយ៉ាងនោះដែរ នាងចូរមើលអ្នកសម្លាប់បុគ្គលខ្សោយ ។

[ ៤១០ ] ( ព្រះនាងមទ្រី... ) ពួកសត្រូវមិនអាចគ្របសង្កត់ ( ព្រះ អង្គ ) បានទេដូចជាភ្លើងមិនអាចគ្របសង្កត់ទឹកសមុទ្របាន សូមព្រះអង្គទ្រង់ ព្រះចិន្ដាដល់ពាក្យដែលសក្កទេវរាជពោលហើយ នោះឯងទំនងជាសួស្ដីនឹង មានដល់ព្រះអង្គព្រោះពួកពលនេះ ។

[ ៤១១ ] ( អភិសម្ពុទ្ធគាថា ) លំដាប់នោះព្រះបាទវេស្សន្តរយាងចុះ អំពីភ្នំ ទ្រង់ធ្វើព្រះហឫទ័យឲ្យមាំហើយគង់នៅក្នុងបណ្ណសាលា ។

[ ៤១២ ] ព្រះបិតាទ្រង់ឲ្យបញ្ឈប់រថ ទ្រង់ឲ្យពួកសេនាត្រៀមចាំហើយ ទ្រង់ស្ដេចចូលទៅចួបនឹងព្រះរាជបុត្ត ដែលគង់នៅក្នុងព្រៃតែម្នាក់ឯង ។ លុះព្រះ បិតាយាងចុះអំពីកដំរីហើយទ្រង់ឧត្តរាសង្គៈចៀងស្មាម្ខាង ផ្គងអញ្ជលី មានពួក អាមាត្យហែហមបានចូលទៅដើម្បីអភិសេកបុត្ត ។ ព្រះអង្គបានទតឃើញកុមារ

មានរូបគួរឲ្យត្រេកអរ សម្រឹងព្រះហឫទ័យកំពុងត្រិះរិះមិនមានភ័យអំពីទីណាមួយដែលគង់នៅក្នុងបណ្ណសាលានោះ ។

[ ៤១៣ ] ព្រះបាទវេស្សន្តរនិងព្រះនាងមទ្រីបានទតឃើញព្រះបិតានោះមានសេចក្ដីជាប់ព្រះហឫទ័យក្នុងបុត្តកំពុងយាងមកក៏ក្រោកទៅទទួលថ្វាយបង្គំ ។ ចំណែកព្រះនាងមទ្រីថ្វាយបង្គំព្រះបាទទាំងគូរបស់ព្រះសុស្សរះដោយព្រះសិរ្ស ( ហើយក្រាបទូលថា ) បពិត្រព្រះសម្មតិទេព ខ្ញុំឈ្មោះមទ្រី ជាសុណិសារបស់ព្រះអង្គ សូមថ្វាយបង្គំព្រះបាទទាំងគូរបស់ព្រះអង្គ ព្រះបិតាទ្រង់ឱបរឹតជនទាំងពីរនោះ ហើយបបោសអង្អែលដោយព្រះហស្ត ។

[ ៤១៤ ] ( ព្រះរាជា... ) នែបុត្ត អ្នកទាំងពីរសុខសប្បាយទេឬ នែបុត្ត អ្នកទាំងពីរមិនមានជំងឺតម្កាត់ទេឬ អ្នកទាំងពីរចិញ្ចឹមជីវិតដោយការស្វែងរកស្រួលទេឬ មើមឈើនិងផ្លែឈើមានច្រើនឬទេ ។ ពួករបោម មូស ពស់មានតិចទេឬ ក្នុងព្រៃដ៏កុះករដោយម្រឹគយង់ឃ្នងមិនមានការបៀតបៀនទេឬ ។

[ ៤១៥ ] ( ព្រះមហាសត្វ... ) បពិត្រព្រះសម្មតិទេព ការរស់នៅរបស់យើងខ្ញុំជាការរស់នៅផ្ដេសផ្ដាសទេ យើងខ្ញុំជាអ្នករស់នៅត្រដាបត្រដួសព្រោះការរស់នៅដោយការស្វែងរក (ផលាផល) ។ បពិត្រមហារាជ ( សេចក្ដីខ្វះ ខាត ) រមែងទូន្មាន ( បុរសកម្សត់ ) ដូចជានាយសារថីទូន្មានសេះ យើងខ្ញុំទាំងនោះជាបុគ្គលមានសេចក្ដីខ្វះខាតទូន្មានហើយ សេចក្ដីខ្វះខាតរមែងទូន្មានយើងខ្ញុំ ។ បពិត្រមហារាជ យើងខ្ញុំត្រូវគេនិរទេសហើយមានសេចក្ដីរស់នៅទាំងទុក្ខសោកក្នុងព្រៃ ទាំងសាច់ឈាមទៀតសោត ក៏ស្គាំងស្គមព្រោះមិនបានឃើញ

ព្រះមាតាបិតា ។

[ ៤១៦ ] កុមារទាំងពីរ គឺជាលីនិងកណ្ហាជិនាណា ដែលជាទាយាទ ( ព្រះរាជនត្តា ) របស់ព្រះអង្គ ជាបុគ្គលប្រសើរបំផុតក្នុងដែនសិវិ មានបំណងមិនទាន់បានសម្រេចនៅឡើយ លុះអំណាចព្រាហ្មណ៍ជាបុគ្គលឃោរពានលើសលន់វាយកុមារទាំងពីរនោះដូចជាគេវាយហ្វូងគោ ។ បើព្រះអង្គជ្រាបបុត្តទាំងនោះរបស់រាជបុត្រី សូមប្រាប់ដល់យើងខ្ញុំឲ្យឆាប់ដូចជា ( ពួកពេទ្យដែលព្យាបាល ) នូវមាណពត្រូវពស់ចឹក ។

[ ៤១៧ ] ( ព្រះរាជា... ) កុមារទាំងពីរ គឺជាលីនិងកណ្ហាជិនាទុំះ បិតាបានប្រគល់ទ្រព្យឲ្យដល់ព្រាហ្មណ៍លោះមកហើយ បាកុំភ័យឡើយ បាចូរស្រួលចិត្តចុះ ។

[ ៤១៨ ] ( ព្រះមហាសត្វ... ) បពិត្រព្រះបិតា ព្រះអង្គសុខសប្បាយទេឬ បពិត្រព្រះបិតា ព្រះអង្គមិនមានរោគាពាធទេឬ បពិត្រព្រះបិតា ព្រះនេត្ររបស់ព្រះមាតានៃខ្ញុំព្រះអង្គមិនទាន់ងងឹតទេឬ ។

[ ៤១៩ ] ( ព្រះរាជា... ) នែបុត្ត យើងសុខសប្បាយទេ នែបុត្ត យើងមិនមានជំងឺតម្កាត់ទេ នែបុត្តចក្ខុមាតារបស់បាមិនទាន់ងងឹតទេ ។

[ ៤២០ ] ( ព្រះមហាសត្វ... ) យានរបស់ព្រះអង្គមិនទាន់ចាស់ទេឬ វាហនៈរមែងនាំទៅបានទេឬ ជនបទសម្បូរដែរឬ ភ្លៀងមិនដាច់ទេឬ ។

[ ៤២១ ] ( ព្រះរាជា... ) យានរបស់យើងមិនទាន់ចាស់ទេ ទាំងវាហនៈក៏នាំទៅបាន ជនបទក៏សម្បូរ ទាំងភ្លៀងក៏មិនដាច់ទេ ។

[ ៤២២ ] ( អភិសម្ពុទ្ធគាថា ) កាលដែលក្សត្រិយ៍ទាំងបីអង្គកំពុងចរចាគ្នាយ៉ាងនេះឯង ព្រះរាជបុត្រីជាព្រះមាតា ស្តេចមកដោយព្រះបាទាឥតមានសុព័ណ៌បាទ ប្រាកដដល់ក្សត្រិយ៍ទាំងនោះទៀបទ្វារភ្នំ ។ ឯព្រះបាទវេស្សន្តរនិងព្រះនាងមទ្រី បានឃើញព្រះមាតានោះ ដែលមានហឫទ័យជាប់ក្នុងបុត្តកំពុងយាងមកក៏ក្រោកទទួលហើយថ្វាយបង្គំ ។ ចំណែកខាងព្រះនាងមទ្រីថ្វាយបង្គំព្រះបាទទាំងគូរបស់ព្រះមាតាក្មេកដោយព្រះសិរ្ស៍ ( ហើយក្រាបបង្គំទូលថា ) បពិត្រព្រះមេម្ចាស់ ខ្ញុំម្ចាស់ឈ្មោះនាងមទ្រី ជាព្រះសុណិសារបស់ព្រះអង្គ សូមថ្វាយបង្គំព្រះបាទទាំងគូរបស់ព្រះមេ ។

[ ៤២៣ ] ចំណែកខាងព្រះរាជបុត្រទាំងពីរដែលមកអំពីទីឆ្ងាយដោយសួស្តីបានឃើញព្រះនាងមទ្រីហើយក៏ទ្រង់ព្រះកន្សែង អួលអាក់នាំគ្នាស្ទុះចូលទៅរកដូចកូនគោតូចស្ទុះទៅរកមេ ។ ឯព្រះនាងមទ្រីបានឃើញបុត្តទាំងពីរដែលមកអំពីទីឆ្ងាយដោយសួស្តី ក៏ញាប់ញ័រដូចជាស្រីមេមត់ទនៃទឹកក្សីរក៏ហូរចេញមក ។

[ ៤២៤ ] កាលពួកព្រះញាតិជួបជុំគ្នាហើយ សំឡេងគឹកកងខ្លាំង ក៏កើតឡើង ភ្នំទាំងឡាយក៏បន្លឺឡើងទាំងផែនពសុធាក៏រំភើបញាប់ញ័រ ។ ភ្លៀងក៏ញុំាងធ្មារទឹកឲ្យធ្លាក់ក្នុងខណៈនោះ ព្រះបាទវេស្សន្តរក៏បានជួបនឹងញាតិទាំងឡាយក្នុងខណៈនោះ ។ ព្រះនត្តាទាំងពីរ ព្រះសុណិសា ព្រះរាជបុត្ត ព្រះរាជានិងព្រះទេវីបានជួបក្នុងទីជាមួយគ្នាក្នុងកាលណា សេចក្តីព្រឺព្រួចរោម ក៏មានក្នុងកាលនោះ ពួកអ្នកនគរទាំងអស់បានផ្គងអញ្ជលីចំពោះព្រះបាទវេស្សន្តរនោះ

នាំគ្នាយំក្នុងព្រៃ មុខគួរឲ្យស្រឡាំងស្រងទួលអាពាធនា ។ ពួកពស្ត្រទាំងអស់ជួបជុំគ្នា ( បានពោល ) នឹងព្រះបាទវេស្សន្តរផង នឹងព្រះនាងមទ្រីផងថា ព្រះអង្គជាព្រះរាជាឥស្សរៈរបស់ពួកយើង សូមព្រះអង្គទាំងពីរព្រះអង្គរបស់ពួកយើងសោយរាជសម្បត្តិ ។

**ចប់ ឆក្ខត្តិយបព្វៈ ។**

[ ៤២៥ ] ( ព្រះមហាសត្វ... ) ព្រះអង្គនិងពួកអ្នកជនបទ អ្នកនិគមបានព្រមព្រៀងគ្នានិរទេសខ្ញុំព្រះអង្គដែលកំពុងសោយរាជ្យតាមធម៌ចាកដែនហើយ ។

[ ៤២៦ ] ( ព្រះរាជា... ) ម្នាលបុត្ត ( នេះ ) ពិតជាកំហុសរបស់យើង យើងបានធ្វើអំពើបំផ្លិចបំផ្លាញសេចក្តីចម្រើន បាននិរទេសបា ដែលមិនមានកំហុស ព្រោះតាមពាក្យពួកអ្នកសិវិរាស្ត្រ ។

[ ៤២៧ ] ( កូន ) គួរដោះទុក្ខរបស់បិតាមាតាឬរបស់បងប្អូនស្រីដោយហេតុណានីមួយ សូម្បីដោយជីវិតរបស់ខ្លួន ។ ( ពួកអាមាត្យបានពោលថា បពិត្រមហារាជ កាលនេះជាកាលគួរស្រង់ទឹក សូមទ្រង់ដុសជម្រះព្រះរជោជលៈ ) ។

[ ៤២៨ ] ( អភិសម្ពុទ្ធគាថា ) គ្រានោះព្រះបាទវេស្សន្តរក៏ដុសជម្រះក្អែល លុះដុសជម្រះក្អែលហើយបានទ្រទ្រង់ព្រះពស្ត្រមានពណ៌ដូចស័ង្ខ ។

[ ៤២៩ ] ព្រះបាទវេស្សន្តរទ្រង់កក់ព្រះសិរ្ស៍ មានព្រះពស្ត្រដ៏ស្អាតស្អិតស្អាងដោយអាភរណៈគ្រប់យ៉ាង ទ្រង់សៀតព្រះខាន់ដែលដុតកម្តៅសត្រូវ

ហើយទ្រង់ឡើងគង់លើដំរីដ៏ប្រសើរឈ្មោះ បច្ច័យ ។ កាលនោះពួកទាហាន ៦០.០០០ នាក់ កើតក្នុងថ្ងៃជាមួយគ្នាគួររមិលមើល ញ៉ាំងព្រះរាជាជាធំក្នុងរថឲ្យរីករាយ ចោមរោម ។ កាលនោះពួកកញ្ញារបស់ព្រះបាទសិវិ បានចួបជុំគ្នាហើយញ៉ាំងព្រះនាងមទ្រីឲ្យស្រង់ទឹក ( ហើយពោលថា ) សូមព្រះបាទវេស្សន្តរនិងជាលីកណ្ហាជិនាទាំងពីរបីបាច់ថែរក្សាព្រះនាង ទាំងមហារាជព្រះនាមសញ្ជ័យក៏សូមឲ្យថែរក្សាព្រះនាងដែរ ។

[ ៤៣០ ] ព្រះបាទវេស្សន្តរនិងព្រះនាងមទ្រីបាននូវទីពឹងនេះ ( បានតម្កល់ក្នុងរាជសម្បត្តិហើយភ្លករឭក ) នូវសេចក្តីសៅហ្មងរបស់ព្រះអង្គ ( ដែលទ្រង់ធ្លាប់នៅក្នុងព្រៃពីដើម ) ក៏ទ្រង់ឲ្យទួងអានទ្ទីយភេរីត្រាច់ទៅទៀបក្នុំវង្កតដែលគួរជាទីរីករាយ ។ ព្រះនាងមទ្រីបរិបូណ៌ដោយលក្ខណៈ បានទីពឹងនេះហើយ ( ក៏ភ្លករឭក ) នូវសេចក្តីសៅហ្មងរបស់ព្រះនាងដែលធ្លាប់នៅក្នុងព្រៃពីដើមបានចួបនឹងបុត្តទាំងពីរហើយក៏ត្រេកអររីករាយ ។ ព្រះនាងមទ្រីបរិបូណ៌ដោយលក្ខណៈបានទីពឹងនេះហើយក៏មានព្រះហឫទ័យភ្លករឭកសេចក្តីសៅហ្មងរបស់ព្រះនាងដែលធ្លាប់នៅក្នុងព្រៃពីដើម មានចិត្តត្រេកអររីករាយជាមួយនឹងបុត្តទាំងពីរ ។

[ ៤៣១ ] ( ព្រះនាងមទ្រី... ) នៃបុត្តទាំងពីរ កាលពីដើមមាតាជាអ្នកបរិភោគភត្តតែមួយពេល ដេកផ្ទាល់នឹងផែនដីជានិច្ច នេះជាវត្តរបស់មាតាដូច្នេះ ព្រោះសេចក្តីប្រាថ្នាចង់ ( ចួប ) នឹងបាទាំងពីរ ម្នាលបុត្តទាំងពីរវត្តនោះសម្រេចដល់មាតាក្នុងថ្ងៃនេះហើយព្រោះបានចួបនឹងបាទាំងពីរ ម្នាលបុត្ត

ទាំងពីរ សូមឲ្យបុណ្យដែលកើតអំពីមាតា នឹងកើតអំពីបិតារក្សាបា ទាំងមហារាជព្រះនាមសញ្ជ័យក៏សូមឲ្យរក្សាបា ។ បុណ្យណានីមួយដែលមាតាក្តី បិតាក្តីរបស់បាបានធ្វើហើយដោយកុសលទាំងអស់នោះ សូមបាកុំចាស់ កុំស្លាប់ឡើយ ។

[ ៤៣២ ] ( *អភិសម្ពុទ្ធគាថា* ) ព្រះសស្សុបានបញ្ជូនកប្បាសិកពស្ត្រ កោសេយ្យពស្ត្រ ខោមពស្ត្រនិងកោទុម្ពរពស្ត្រទៅថ្វាយព្រះសុណ្ហា ដែលជាសំពត់សម្រាប់លំអព្រះនាងមទ្រី ។ លំដាប់តមកព្រះសស្សុបានបញ្ជូនគ្រឿងប្រដាប់ព្រះសូវណ្ណជាវិការៈនៃមាសនិងគ្រឿងប្រដាប់ព្រះសូវណ្ណ ជាវិការៈនៃកែវទៅថ្វាយព្រះសុណ្ហាដែលជាគ្រឿងប្រដាប់សម្រាប់លំអរបស់ព្រះនាងមទ្រី ។ លំដាប់តមកទៀត ព្រះសស្សុបានបញ្ជូនគ្រឿងប្រដាប់ព្រះសូវណ្ណ ជាវិការៈនៃមាសនិងកុន្ទ្រំនិងខ្សែក្រវាត់ជាវិការៈនៃកែវមណី ទៅថ្វាយព្រះសុណ្ហា ដែលជាគ្រឿងប្រដាប់លំអរបស់ព្រះនាងមទ្រី ។ ព្រះសស្សុបានបញ្ជូនគ្រឿងប្រដាប់នលាដៈ ជាគ្រឿងប្រដាប់សម្រាប់ព្រះភក្ត្រមានពណ៌ផ្សេងៗ ដែលជាវិការៈនៃកែវមណីទៅថ្វាយព្រះសុណ្ហា ដែលជាគ្រឿងប្រដាប់លំអរបស់ព្រះនាងមទ្រី ។ ព្រះសស្សុ បានបញ្ជូននូវគ្រឿងប្រដាប់សម្រាប់ព្រះស្តនទិនិងគ្រឿងប្រដាប់ស្មានិងខ្សែក្រវាត់ កងជើងទៅថ្វាយព្រះសុណ្ហា ដែលជាគ្រឿងប្រដាប់លំអព្រះមទ្រី ។ ព្រះរាជបុត្រីជាស្ត្រីប្រសើរ បានគយគន់មើលគ្រឿងប្រដាប់ល្បើកដោយអំបោះនិងគ្រឿងប្រដាប់វៀរចាកអំបោះ ដ៏ល្អក្រៃពេកហាក់ដូចទេវកញ្ញាក្នុងនន្ទនឧទ្យាន ។ ព្រះរាជបុត្រីកក់ព្រះសិរ្ស មានព្រះពស្ត្រដ៏ស្អាត ស្អិត

ស្អាងដោយអាករណៈគ្រប់យ៉ាងដ៏ល្អក្រៃពេក ហាក់ដូចស្រ្តីអប្សរ ក្នុងឋានត្រៃត្រិង្ស ។ ព្រះរាជបុត្រីបរិបូណ៌ដោយរបៀបនៃអញ្ចាញធ្មេញល្អក្រៃពេក ហាក់ដូចដើមចេកដែលកើតក្នុងចិត្តលតាវ័ន ត្រូវខ្យល់បក់បោកហើយ ។ ព្រះរាជបុត្រីមានបបូរមាត់ដូចផ្លែជ្រៃទុំនិងផ្លែបាសទុំ ល្អក្រៃពេកហាក់ដូចបក្សីមានសរីរៈសព្វគ្រប់ដូចជាសរីរៈនៃមនុស្ស មានស្លាបដ៏វិចិត្រ ( ហើរទៅដ៏អាកាស ) ។

[ ៤៣៣ ] ពួកអាមាត្យនាំដំរីដ៏ប្រសើរមិនចាស់ពេក អត់ទ្រាំលំពែងបាន អត់ទ្រាំកូនសរបាន មានភ្លុកង៝ទន្ទាំអាចគាស់រំលើងសត្រូវ បានមកថ្វាយព្រះនាងមទ្រីនោះ ។ ព្រះនាងមទ្រីនោះឡើងកាន់ដំរីដ៏ប្រសើរ មិនចាស់ពេក អត់ទ្រាំលំពែងបាន អត់ទ្រាំកូនសរបាន មានភ្លុកង៝ទន្ទាំអាចគាស់រំលើងសត្រូវបាន ។

[ ៤៣៤ ] ពួកម្រឹគទាំងប៉ុន្មានដែលមាននៅក្នុងព្រៃទាំងអស់ទ៉ុះ មិនបៀតបៀនគ្នានឹងគ្នា ដោយតេជះនៃព្រះបាទវេស្សន្តរ ។ ពួកបក្សីទាំងប៉ុន្មានដែលមាននៅក្នុងព្រៃទាំងអស់ទ៉ុះមិនបៀតបៀនគ្នានឹងគ្នាដោយតេជះនៃព្រះបាទវេស្សន្តរ ។ កាលព្រះបាទវេស្សន្តរញុំាងពួកអ្នកសិវិរាស្រ្តឲ្យចម្រើន ទ្រង់យាងចេញ ( អំពីព្រៃ ) ពួកម្រឹគទាំងប៉ុន្មានដែលមាននៅក្នុងព្រៃទាំងអស់ទ៉ុះបានមកប្រជុំក្នុងទីជាមួយគ្នា ។ កាលព្រះបាទវេស្សន្តរញុំាងពួកអ្នកសិវិរាស្រ្តឲ្យចម្រើនទ្រង់យាងចេញ ( អំពីព្រៃ ) ពួកបក្សីទាំងប៉ុន្មានដែលមាននៅក្នុងព្រៃទាំងអស់ទ៉ុះ បានមកប្រជុំក្នុងទីជាមួយគ្នា ។ កាលព្រះបាទវេស្សន្តរ ញុំាងពួកអ្នកសិវិ

រាស្ត្រឲ្យបម្រើន ទ្រង់យានចេញ ( អំពីព្រៃ ) ពួកម្រឹគទាំងប៉ុន្មានដែលមាននៅក្នុងព្រៃទាំងអស់ទុំះ លែងស្រែកសំឡេងពីរោះ ។ កាលព្រះបាទវេស្សន្តរញ៉ាំងពួកអ្នកសិវិរាស្ត្រឲ្យបម្រើន ទ្រង់យានចេញ ( អំពីព្រៃ ) ពួកបក្សីទាំងប៉ុន្មានដែលមាននៅក្នុងព្រៃទាំងអស់ទុំះ លែងស្រែកសំឡេងពីរោះ ។

[ ៤៣៥ ] ពួកអាមាត្យបានរៀបចំរាជមាគ៌ាឲ្យរំលេចផ្ទុះផ្ទាស់ ត្រៀបត្រាដោយផ្កា តាំងអំពីទីដែលព្រះបាទវេស្សន្តរទ្រង់គង់នៅ រហូតដល់ក្រុងជេតុត្តរ ។ លំដាប់នោះកាលព្រះបាទវេស្សន្តរ ញ៉ាំងអ្នកសិវិរាស្ត្រឲ្យបម្រើន ទ្រង់យានចេញ ( អំពីព្រៃ ) ពួកយោធាទាំង ៦០.០០០ ល្អមើល បានហែហមជុំវិញ ។ កាលព្រះបាទវេស្សន្តរញ៉ាំងពួកអ្នកសិវិរាស្ត្រឲ្យបម្រើន ទ្រង់យានចេញ ( អំពីព្រៃ ) ពួកស្រីស្នំផង ពួករាជកុមារផង ពួកអ្នកជំនួញផងពួកព្រាហ្មណ៍ផងហែហមជុំវិញ ។ កាលព្រះបាទវេស្សន្តរ ញ៉ាំងពួកអ្នកសិវិរាស្ត្រឲ្យបម្រើន ទ្រង់យានចេញ ( អំពីព្រៃ ) ពួកពលដំរី ពលសេះពលរថ ពលថ្មើរជើងហែហមជុំវិញ ។ កាលព្រះបាទវេស្សន្តរញ៉ាំងពួកអ្នកសិវិរាស្ត្រឲ្យបម្រើន ទ្រង់យានចេញ ( អំពីព្រៃ ) ពួកអ្នកជនបទក៏បានមកជួបជុំគ្នានិងអ្នកនិគមក៏បានមកចួបជុំគ្នាហែហមជុំវិញ ។ កាលព្រះបាទវេស្សន្តរញ៉ាំងពួកអ្នកសិវិរាស្ត្រឲ្យបម្រើន ទ្រង់យានចេញ ( អំពីព្រៃ ) ពួកទាហានពាក់មួក ទ្រទ្រង់ខែល កាន់ធ្នូ ចងគ្រឿងក្រោះដ៏ល្អដើរហែខាងមុខ ។

[ ៤៣៦ ] ក្សត្រិយ៍ទាំងនោះបានយាងចូលទៅកាន់បុរី ជាក្រុងគួរឲ្យត្រេកអរ មានកំពែងនិងទ្វារខាងក្រៅដ៏ច្រើន ប្រកបដោយគ្រឿងស៊ីនិងគ្រឿង

ផឹក មានទាំងល្បែងពីរយ៉ាង គឺរាំនិងច្រៀង ។ កាលរាជកុមារញ៉ាំងពួកអ្នកសិវិរាស្ត្រឲ្យចម្រើន ស្តេចមកដល់ ពួកអ្នកជនបទនិងពួកអ្នកនិគម បានមកជួបជុំគ្នាត្រេកអរ ។ កាលព្រះមហាក្សត្រិយ៍ជាអ្នកប្រទានព្រះរាជទ្រព្យ ស្តេចមកដល់ហើយ ពួកមហាជនក៏នាំគ្នាលើកទង់ជ័យ ទួងទន្ទិភេរីហើយចូលទៅព្រះនគរ ព្រះបាទវេស្សន្តរក៏ទ្រង់ឲ្យឃោសនា ដើម្បីឲ្យដោះលែងសព្វសត្វចាកចំណង ។

[ ៤៣៧ ] កាលព្រះបាទវេស្សន្តរញ៉ាំងពួកអ្នកសិវិរាស្ត្រឲ្យចម្រើន ស្តេចចូលមកដល់ សក្កទេវរាជដែលជាឧបបត្តិទេពបានបង្អុរភ្លៀងជាវិការៈនៃមាស ។ លំដាប់នោះព្រះបាទវេស្សន្តរជាក្សត្រិយ៍ប្រកបដោយប្រាជ្ញា ទ្រង់ឲ្យទាន លុះបែកធ្លាយរាងកាយនោះទៅ ក៏បានស្តេចទៅកើតក្នុងឋានសួគ៌ទេវលោក ។

ចប់ នគរកណ្ឌ

ចប់ មហាវេស្សន្តរជាតក ទី ១០

ចប់ មហានិបាត

# អដ្ឋកថា

## វេស្សន្តរជាតក

## ទសពរគាថា

[ ២១២-៤៣៧ ] ព្រះសាស្តា កាលអាស្រ័យក្រុងកបិលពស្តុរាជធានី ទ្រង់គង់នៅនានិគ្រោធារាម ទ្រង់ប្រារព្ធភ្លៀងបោក្ខរព័ស៌ ត្រាស់ព្រះធម្មទេសនានេះថា **ផុស្សតី វរវណ្ណាភេ** ដូច្នេះជាដើម ។

សេចក្តីពិស្តារថា ព្រះសាស្តាទ្រង់ញុំាងធម្មចក្រដ៏ប្រសើរឲ្យប្រព្រឹត្តទៅហើយ ទ្រង់ចូលកាន់ក្រុងរាជគ្រឹះដោយលំដាប់ គង់នៅក្នុងក្រុងរាជគ្រឹះនោះអស់ហេមន្តរដូវ មានព្រះឧទាយិត្ថេរជាមគ្គុទ្ទេសក៍ចោមរោមដោយព្រះខីណាស្រព ២ ម៉ឺនអង្គ ទ្រង់យាងដល់នគរកបិលពស្តុគ្រាដំបូងក្នុងកាលណា ក្នុងកាលនោះ សក្យរាជទាំងឡាយប្រជុំគ្នាដោយគិតថា ពួកយើងនឹងបានឃើញសិទ្ធត្ថកុមារនេះ ដែលជាព្រះញាតិដ៏ប្រសើររបស់ពួកយើង ជ្រើសរើសទីគង់របស់ព្រះសាស្តាក៏កំណត់គ្នាថា រាជឧទ្យានរបស់និគ្រោធសក្យរាជ គួរជាទីត្រេកអរទើបធ្វើវិធីបដិបត្តិចាត់ចែងគ្រប់យ៉ាងក្នុងនិគ្រោធារាមនោះ កាន់យកគ្រឿងក្រអូប កម្រងផ្កានិងលម្អិតជាដើមទទួលព្រះសាស្តា បញ្ជូនទារក ទារិកាក្មេងៗ ប្រដាប់ដោយគ្រឿងអលង្ការទាំងពួងទៅមុន បន្ទាប់អំពីនោះទើបបញ្ជូនរាជកុមារនិងរាជកុមារីទៅហើយយាងទៅឯង ក្នុងរវាងរាជកុមាររាជកុមារីទាំងនោះ បូជាព្រះសាស្តាដោយផ្កា គ្រឿងក្រអូបនិងលម្អិតជាដើម នាំព្រះសាស្តាទៅកាន់និគ្រោធារាមនោះឯង ។ ព្រះមានព្រះភាគមានព្រះខីណាស្រព ២ ម៉ឺនចោមរោមគង់ត្រង់បវរពុទ្ធាសនៈ ដែលគេក្រាលទុកក្នុងនិគ្រោធារាមនោះ ។

កាលនោះស្តេចសក្យៈទាំងឡាយប្រកាន់ខ្លួន ជាអ្នករឹងត្អឹងគិតគ្នាថា សិទ្ធត្ថកុមារនេះក្មេងជាងពួកយើង ជាប្អូន ជាក្មួយ ជាកូន ជាចៅរបស់ពួកយើង ទើបពោលនឹងព្រះរាជកុមារកំលោះៗទាំងនោះថា អ្នកទាំងឡាយចូរថ្វាយ បង្គំព្រះមានព្រះភាគ ពួកយើងអង្គុយខាងក្រោយពួកអ្នក កាលស្តេចសក្យៈទាំងនោះមិនអភិវាទព្រះមានព្រះភាគនាំគ្នាអង្គុយយ៉ាងនេះ ព្រះមានព្រះភាគទ្រង់ជ្រាបអធ្យាស្រ័យរបស់ស្តេចសក្យៈទាំងនោះទើបទ្រង់ព្រះតម្រិះថា ព្រះញាតិទាំងឡាយមិនថ្វាយបង្គំតថាគត ណ្ហើយចុះ តថាគតនឹងធ្វើព្រះញាតិទាំងនោះឲ្យថ្វាយបង្គំ ទើបទ្រង់ចូលចតុត្ថជ្ឈានដែលជាបាទរបស់អភិញ្ញា ចាប់តាំងពីនោះក៏យាងឡើងកាន់អាកាស ទ្រង់ជម្រុះធូលីដែលជាប់ព្រះបាទលើសិរសានៃព្រះញាតិទាំងនោះ ទ្រង់ធ្វើបាដិហារ្យដូចគ្នានឹងយមកប្បាដិហារ្យត្រង់គល់គណ្ឌម្ពព្រឹក្ស ។

ក្នុងកាលនោះព្រះបាទសុទ្ធោទនមហារាជ បានទតឃើញភាពអស្ចារ្យនោះទើបត្រាស់ថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងថ្ងៃដែលទ្រង់ប្រសូតកាលគីលៀងយកទ្រង់ចូលទៅ ដើម្បីឲ្យនមស្ការជដិលឈ្មោះកាឡទេវល ខ្ញុំក៏បានឃើញព្រះបាទទាំង ២ របស់ទ្រង់ទៅប្រតិស្ឋានលើក្បាលរបស់ព្រាហ្មណ៍ ខ្ញុំក៏បានថ្វាយបង្គំទ្រង់ នេះជាការថ្វាយបង្គំរបស់ខ្ញុំលើកទី ១ ក្នុងថ្ងៃវប្បមង្គល កាលទ្រង់ផ្ទំលើព្រះពស្រ្តដ៏មានសិរីក្រោមម្លប់ព្រីង ខ្ញុំបានឃើញស្រមោលម្លប់ព្រីងមិនជ្រេទៅ ខ្ញុំក៏បានថ្វាយបង្គំបាទារបស់ទ្រង់ នេះជាការថ្វាយបង្គំលើកទី ២ របស់ខ្ញុំ ឥឡូវនេះ ខ្ញុំឃើញបាដិហារ្យដែលមិនធ្លាប់ឃើញនេះ ទើបថ្វាយបង្គំ

បាទារបស់ទ្រង់ នេះជាការថ្វាយបង្គំលើកទី ៣ របស់ខ្ញុំ ។ កាលព្រះបាទសុទ្ធោទនៈថ្វាយបង្គំហើយ សក្យៈសូម្បីត្រឹមតែមួយអង្គដែលមិនថ្វាយបង្គំមិនមាន ជនទាំងនោះបានថ្វាយបង្គំហើយ ។

ព្រះមានព្រះភាគញ៉ាំងព្រះញាតិទាំងឡាយឲ្យថ្វាយបង្គំហើយ ទ្រង់ចុះអំពីអាកាស គង់លើបវរពុទ្ធាសនៈដែលគេក្រាលទុកហើយដោយប្រការដូច្នេះ ។ កាលព្រះមានព្រះភាគគង់ហើយ សមាគមព្រះញាតិ បានដល់នូវការសិក្សាហើយ មនុស្សទាំងអស់មានចិត្តតែមួយអង្គុយហើយ ។ លំដាប់នោះមហាមេឃតាំងឡើងញ៉ាំងភ្លៀងបោក្ខរព័ស៌ឲ្យធ្លាក់ហើយ ទឹកភ្លៀងនោះពណ៌ក្រហមក៏បានស្រក់ចុះមក បុគ្គលត្រូវការសើមក៏សើម បើមិនត្រូវការសើម ភ្លៀងនោះក៏មិនធ្លាក់ចំសូម្បីត្រឹមតែមួយតំណក់ ជនទាំងពួងនោះឃើញអស្ចារ្យនោះក៏ភ្ញាក់ផ្អើល ភិក្ខុទាំងឡាយនាំគ្នាពោលថា ឱ គួរអស្ចារ្យ ឱ មិនធ្លាប់មាន ឱ អានុភាពនៃព្រះពុទ្ធ មហាមេឃញ៉ាំងភ្លៀងបោក្ខរព័ស៌ឲ្យធ្លាក់ក្នុងសមាគមនៃព្រះញាតិទាំងឡាយ ព្រះសាស្តាទ្រង់ស្តាប់ដូច្នោះហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកទាំងឡាយអង្គុយសន្ទនាគ្នាដោយរឿងអ្វី កាលភិក្ខុទាំងនោះក្រាបទូលឲ្យទ្រង់ជ្រាបហើយ ទើបទ្រង់មានព្រះតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេដែលមហាមេឃញ៉ាំងភ្លៀងបោក្ខរព័ស៌ឲ្យធ្លាក់ សូម្បីក្នុងកាលមុនកាលតថាគតនៅជាពោធិសត្វ មហាមេឃបែបនេះក៏ធ្លាក់ចុះក្នុងញាតិសមាគមដូចគ្នា ត្រាស់ដូច្នេះហើយទ្រង់ក៏តុណ្ហីភាព ភិក្ខុទាំងឡាយអារាធនា ទើបទ្រង់នាំអតីតនិទានមកត្រាស់ដូចត

ទៅនេះថា

ម្នាលភិក្ខុទាំងឡាយ ក្នុងអតីតកាលមានព្រះរាជាព្រះនាមថា សិវិមហារាជ គ្រងរាជសម្បត្តិក្នុងនគរជេតុត្តរដែនសិវិ មានព្រះឱរសព្រះនាមថា សញ្ជយ-កុមារ កាលសញ្ជយកុមារនោះចម្រើនវ័យ ព្រះបាទសិវិមហារាជនាំរាជកញ្ញាឈ្មោះផុស្សតីដែលជាបុត្រីរបស់ព្រះបាទមទ្ទរាជមក ទ្រង់ប្រគល់រាជសម្បត្តិដល់សញ្ជយកុមារនោះហើយ ក៏តាំងព្រះនាងផុស្សតីជាអគ្គមហេសី ។

តទៅនេះជាបុព្វប្បយោគ គឺសេចក្ដីព្យាយាមដែលធ្វើក្នុងសាសនារបស់ព្រះពុទ្ធក្នុងកាលមុនរបស់ព្រះនាង គឺក្នុងទីបំផុតនៃកប្បទី ៩១ អំពីកប្បនេះ ព្រះសាស្ដាព្រះនាមថាវិបស្សីកើតឡើងក្នុងលោក ។ កាលនោះព្រះរាជាព្រះនាមថា ពន្ធុមរាជសោយរាជសម្បត្តិក្នុងពន្ធុមតីនគរ ។ កាលព្រះវិបស្សីសាស្ដា ទ្រង់អាស្រ័យពន្ធុមតីនគរ គង់នៅក្នុងខេមមិគទាយវ័ន កាលនោះមានព្រះរាជាមួយអង្គបញ្ជូនសុវណ្ណមាលា មានតម្លៃមួយសែនកហាបណៈនិងខ្លឹមចន្ទន៍ដែលមានតម្លៃច្រើនមកថ្វាយដល់ព្រះបាទពន្ធុមរាជ ។ ព្រះបាទពន្ធុ-មរាជមានបុត្រី ២ អង្គ ទ្រង់មានព្រះរាជបំណងនឹងប្រទានបណ្ណាការនោះដល់ព្រះរាជធីតាទាំង ២ ទើបប្រទានខ្លឹមចន្ទន៍ដល់បុត្រីច្បង ប្រទានកម្រងមាសដល់បុត្រីជាប្អូន ។ បុត្រីទាំង ២ នោះគិតថាយើងទាំង ២ មិននាំបណ្ណាការនេះ មកប្រើប្រាស់ត្រង់សរីរៈរបស់យើង យើងនឹងបូជាព្រះសាស្ដាប៉ុណ្ណោះ ទើបទូលព្រះរាជាថា បពិត្រព្រះបិតា ខ្ញុំម្ចាស់ទាំង ២ នឹងយកខ្លឹមចន្ទន៍និងសុវណ្ណមាលាបូជាព្រះទសពល ។ ព្រះបាទពន្ធុមរាជទ្រង់ស្ដាប់ដូច្នោះ ក៏

អនុញ្ញាតថា សាធុ ។ រាជធីតាអង្គច្បងបានបុកខ្លឹមចន្ទន៍ជាលម្អិតដាក់ក្នុងប្រអប់មាស ។ រាជធីតាប្អូនឲ្យធ្វើសុវណ្ណមាលាជាគ្រឿងប្រដាប់ទ្រូង ដាក់ក្នុងប្រអប់មាស ។ រាជធីតាទាំង ២ យាងទៅកាន់មិគទាយវ័នវិហារ ។ បណ្តារាជធីតា ២ អង្គនោះ រាជធីតាច្បងបូជាព្រះពុទ្ធសរីរៈ ដែលមានពណ៌ដូចមាសរបស់ព្រះទសពលដោយលម្អិតខ្លឹមចន្ទន៍ បាចសាចលម្អិតខ្លឹមចន្ទន៍ដ៏សេសក្នុងព្រះគន្ធកុដិ បានធ្វើនូវសេចក្តីប្រាថ្នាថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំម្ចាស់សូមបានជាមាតានៃព្រះពុទ្ធដូចទ្រង់ក្នុងអនាគតហើយពោលគាថានេះថា

ខ្ញុំម្ចាស់បានធ្វើនូវការបូជាដល់ទ្រង់ ដោយលម្អិតនៃខ្លឹមចន្ទន៍
នេះ សូមឲ្យខ្ញុំម្ចាស់បានជាមាតានៃព្រះពុទ្ធ ដូចជាទ្រង់ក្នុង
អនាគតកាលឯមុខនោះហោង ដូច្នេះ ។

ឯព្រះរាជធីតាជាប្អូន បូជាព្រះសរីរៈ ដែលមានពណ៌ដូចមាសរបស់ព្រះទសពលដោយគ្រឿងប្រដាប់ទ្រូងដែលធ្វើអំពីសុវណ្ណមាលា បានធ្វើសេចក្តីប្រាថ្នាថា បពិត្រព្រះអង្គដ៏ចម្រើន គ្រឿងប្រដាប់នេះកុំបីឃ្លាតអំពីសរីរៈនៃខ្ញុំដរាបណាមិនទាន់សម្រេចអរហត្តហើយពោលគាថានេះថា

បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបូជាទ្រង់ដោយសុវណ្ណមាលា
ដោយអំណាចពុទ្ធបូជានេះ សូមបុណ្យបណ្តាលឲ្យសុវណ្ណ-
មាលា មានត្រង់ទ្រូងរបស់ខ្ញុំម្ចាស់អស់កាលជានិច្ច ដូច្នេះ ។

ចំណែកព្រះបរមសាស្តា ទ្រង់ធ្វើបូជានុមោទនាដល់រាជធីតាទាំង ២ នោះថា

នាងទាំង ២ បានប្រតិស្ឋានទូវការបូជាឯណា ដល់តថាគត ក្នុងភពនេះ វិបាកនៃការបូជានោះ ចូរសម្រេចដល់នាងទាំង ២ សេចក្តីប្រាថ្នារបស់នាងទាំង ២ យ៉ាងណា ចូរសម្រេចយ៉ាង នោះចុះ ដូច្នេះ ។

រាជធីតាទាំង ២ នោះតាំងនៅដរាបដល់អស់ព្រះជន្ម ឃ្លាតចាកមនុស្ស លោកទៅកើតក្នុងទេវលោក ។ ក្នុងក្សត្រីទាំង ២ អង្គនោះព្រះរាជធីតាច្បង ឃ្លាតចាកទេវលោកអន្ទោលទៅកាន់មនុស្សលោក ឃ្លាតចាកមនុស្សលោក អន្ទោលទៅកាន់ទេវលោក ក្នុងទីបំផុតនៃកប្បទី ៩១ បានជាពុទ្ធមាតាព្រះនាម ថា មហាមាយាទេវី ។ ឯព្រះរាជកុមារីជាប្អូនអន្ទោលទៅយ៉ាងនោះក្នុងកាល ព្រះទពលព្រះនាមថាកស្សបៈ បានកើតជាព្រះរាជធីតារបស់ព្រះរាជាព្រះនាម ថាកិកិរាជ ព្រះនាងជាកុមារិកាឈ្មោះថាឧរច្ឆទា ព្រោះមានគ្រឿងប្រដាប់ទ្រូង ហាក់បីដូចធ្វើហើយដោយចិត្រកម្ម កើតហើយដល់ព្រះនាងគ្រង់ទ្រូវដែលតាក់ តែងហើយ ក្នុងកាលរាជកុមារិកាមានព្រះជន្មវស្សា ១៦ បានស្តាប់កត្តានុ-មោទនានៃព្រះតថាគតក៏តាំងនៅក្នុងសោតាបត្តិផល ។ ក្នុងកាលតមកក្នុងថ្ងៃ ដែលព្រះបិតារបស់ព្រះនាងស្តាប់កត្តានុមោទនា បានសម្រេចសោតាបត្តិផល ព្រះនាងក៏បានសម្រេចអរហត្តបួសហើយបរិនិព្វាន ព្រះបាទកិកិរាជមានបុត្រី ៧ អង្គ គឺព្រះនាងសមណី ១ សមណាគុត្តា ១ ភិក្ខុនី ១ ភិក្ខុទាសិកា ១ ធម្មា ១ សុធម្មា ១ សង្ឃទាសី ១ ជាគម្រប់ ៧ ។ រាជធីតាទាំង ៧ អង្គ នោះក្នុងពុទ្ធុប្បាទកាលនេះមានឈ្មោះថា ខេមា ១ ឧប្បលវណ្ណា ១ បដាចារា

១ គោតមី ១ ធម្មទិន្នា ១ មហាមាយា ១ វិសាខា ១ ជាគម្រប់ ៧ ។

បណ្ដារាជធីតាទាំងនោះព្រះនាងផុស្សតី គឺព្រះនាងសុធម្មា បានបំពេញបុណ្យមានទានជាដើម បានមកជាកុមារិកាឈ្មោះផុស្សតី ព្រោះជាអ្នកមានសរីរៈដូចបុគ្គលប្រោះព្រំហើយដោយខ្លឹមចន្ទន៍ក្រហមកើតហើយ ដោយផលនៃការបូជាលម្អិតខ្លឹមចន្ទន៍ ដែលនាងបានធ្វើហើយដល់ព្រះវិបស្សីសម្មាសម្ពុទ្ធ អន្ទោលទៅនៅក្នុងទេវតានិងមនុស្សបានមកជាអគ្គមហេសីនៃសក្កទេវរាជ ។ កាលនោះបុព្វនិមិត្តទាំង ៥ កើតឡើងក្នុងវេលាជិតអស់អាយុដល់នាងផុស្សតី សក្កទេវរាជដឹងភាពដែលនាងអស់អាយុ ទើបនាំទៅកាន់នន្ទនវ័នឧទ្យានដោយយសធំ ប្រថាប់លើតាំងដ៏មានសិរី ត្រាស់យ៉ាងនេះនឹងនាងដែលកំពុងផ្ទំលើដំណេកដ៏មានសិរីដែលប្រដាប់តាក់តែងហើយថា នែនាងផុស្សតី អញឲ្យពរ ១០ ប្រការដល់នាង ចូរនាងទទួលពរ ១០ ប្រការនេះ ។ សក្កទេវរាជកាលប្រទានពរនោះបានភាសិតនូវបឋមគាថាក្នុងមហាវេស្សន្តរជាតក ដែលប្រដាប់ដោយគាថា ១០០០ ថា

ម្នាលនាងផុស្សតីដ៏មានពន្លឺនៃសម្បុរដ៏ប្រសើរ មានអវយវៈខាងដើមដ៏ល្អ នាងចូរទទួលពរ ១០ ប្រការលើផែនដីដែលជាពរពេញចិត្តរបស់នាង ដូច្នេះ ។

ធម្មទេសនាមហាវេស្សន្តរជាតកនេះឈ្មោះថា សក្កទេវរាជឲ្យតាំងឡើងហើយក្នុងទេវលោកដោយប្រការដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ផុស្សតី** ជាពាក្យដែលសក្កទេវរាជហៅនាង

ដោយឈ្មោះ ។ បទថា **វរវណ្ណាភេ** សេចក្តីថា ប្រកបដោយរស្មីនៃពណ៌សម្បុរដ៏ប្រសើរ ។ បទថា **ទសធា** បានដល់ ១០ ប្រការ ។ បទថា **ប-ថព្យា** បានដល់ ធ្វើឲ្យជាវត្ថុដែលគប្បីកាន់យកលើផែនដី ។ បទថា **វរស្សុ** សេចក្តីថា សក្កទេវរាជត្រាស់ថា ចូរនាងកាន់យក ។ បទថា **ចារុបុព្វង្គី** សេចក្តីថា ប្រកបដោយចំណែកខាងមុខដ៏ស្អាត គឺដោយលក្ខណៈដ៏ប្រសើរ ។ បទថា **យំ តុយ្ហំ មនសោ បិយំ** សេចក្តីថា សក្កទេវរាជត្រាស់ថា ចូរនាងកាន់យកពរដែលជាទីស្រឡាញ់នៃចិត្តរបស់នាងទាំង ១០ ប្រការ ។

ផុស្សតីទេវកញ្ញាមិនដឹងថាខ្លួនត្រូវចុតិ ជាអ្នកប្រមាទ ទើបពោលគាថាទី ២ ថា

> បពិត្រទេវរាជ ខ្ញុំម្ចាស់សូមថ្វាយបង្គំព្រះអង្គ ចុះខ្ញុំម្ចាស់បាន
> ធ្វើអំពើអាក្រក់ដូចម្តេច បានជាព្រះអង្គមកញ៉ាំងខ្ញុំម្ចាស់ឲ្យ
> ឃ្លាតចាករមណីយដ្ឋាន ដូចជាខ្យល់ដែលបក់រំលើងដើមឈើ
> ដូច្នោះ ។

បណ្តាបទទាំងនោះ បទថា **នមោ ត្យត្ថុ** កាត់ជា **នមោ តេ អត្ថុ** សេចក្តីថា ខ្ញុំសូមថ្វាយបង្គំទ្រង់ ។ បទថា **កឹ បាបំ** សេចក្តីថា នាងផុស្សតីទូលសួរថា ខ្ញុំម្ចាស់បានធ្វើបាបអ្វីទុកក្នុងសម្នាក់របស់ព្រះអង្គ ។ បទថា **ធរ-ណីរុហំ** បានដល់ ដើមឈើ ។

លំដាប់នោះសក្កទេវរាជទ្រង់ជ្រាបថានាងជាអ្នកប្រមាទ ទើបពោលគាថា ២ នេះថា

នាងឥតបានធ្វើអំពើអាក្រក់ទេ មួយទៀតនាងមិនមែនជាទីស្អប់នៃខ្ញុំទេ តែថានាងអស់បុណ្យហើយ បានជាខ្ញុំនិយាយនឹងនាងយ៉ាងនេះ ។ នាងមានសេចក្តីស្លាប់កៀកជិតណាស់ហើយមុខជានឹងមានសេចក្តីព្រាត់ប្រាស កាលបើខ្ញុំឲ្យនូវពរ ១០ ប្រការនេះ នាងចូរទទួលយកចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យេន តេវំ** សេចក្តីថា ដែលជាហេតុឲ្យយើងពោលនឹងនាងយ៉ាងនេះ ។ បទថា **តុយ្ហំ វិនាភាវោ** សេចក្តីថា នាងនិងពួកយើងនឹងព្រាត់ប្រាសចាកគ្នា ។ បទថា **បវេច្ឆតោ** បានដល់ អ្នកឲ្យ ។ ផុស្សតីទេវកញ្ញាបានស្តាប់ពាក្យរបស់សក្កទេវរាជក៏ដឹងថាខ្លួនចុតិពិត កាលនឹងសូមពរក៏ពោលថា

បពិត្រសក្កទេវរាជដ៏ចម្រើន ជាឥស្សរៈលើពួកទេវតាទាំងអស់ បើព្រះអង្គទ្រង់ប្រទានពរដល់ខ្ញុំម្ចាស់ ខ្ញុំម្ចាស់សូមឲ្យបានទៅក្នុងព្រះរាជនិវេសន៍នៃព្រះបាទសិវិរាជនោះ ១ សូមឲ្យមាននេត្រាដ៏ខ្មៅដូចជាកូនម្រឹគញីមានភ្នែកខ្មៅ ១ សូមឲ្យមានចិញ្ចើមខ្មៅ ១ បពិត្រព្រះអង្គ ទ្រង់បានបំពេញទានក្នុងកាលមុន ខ្ញុំម្ចាស់ទៅកើតក្នុងព្រះរាជនិវេសន៍នោះ សូមឲ្យមានឈ្មោះថា ផុស្សតី ( ដូចដើម ) សូមឲ្យបានបុត្តដ៏ប្រសើរ ដែលចូលចិត្តឲ្យទានជាអ្នកគួរដល់ស្តូម មិនមានសេចក្តីកំណាញ់ ជាបុគ្គលដែលព្រះរាជាប្រទេសដទៃបូជា ជាអ្នកមានកេរ្តិ៍ឈ្មោះ មានយស ១ ។

កាលខ្ញុំម្ចាស់ទ្រទ្រង់គភ៌ សូមកុំឲ្យមានពោះប៉ោងឡើងដូចជាជង្ឃដែលគេសិតស្មើដូច្នោះ ១ ។ បពិត្រព្រះវាសវៈ ខ្ញុំម្ចាស់សូមកុំឲ្យមានដោះយារវែង ១ សក់ខ្ញុំម្ចាស់សូមកុំឲ្យមានសក់ស្កូវ ១ ខ្ញុំម្ចាស់សូមកុំឲ្យធូលីជាប់លើកាយ ១ ខ្ញុំម្ចាស់សូមដោះលែងចោរដែលមានកំហុសគួរគេសម្លាប់ ១ ។ បពិត្រទេវរាជដ៏ចម្រើន ខ្ញុំម្ចាស់សូមឲ្យបានជាអគ្គមហេសីជាទីស្រឡាញ់នៃព្រះបាទសិវិ ក្នុងព្រះរាជនិវេសន៍នោះដែលជាទីកងរំពង ដោយសំឡេងក្ងោក និងក្រៀល ប្រកបដោយពួកនាងនារីដ៏ប្រសើរដេរដាសដោយមនុស្សគមនិងមនុស្សតឿជាព្រះរាជនិវេសន៍ដែលពួកអ្នកសូទ្រៈ និងពួកអ្នកមគធៈ សរសើរហើយ ដ៏គឹកកងដោយសំឡេងនៃសន្ទះទ្វារបន្ទុចដ៏ពិចិត្រ ដែលជាទីមានពួកជនជាសគ្នាឲ្យផឹកសុរានិងឲ្យបរិភោគសាច់ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សិវិរាជស្ស** សេចក្តីថា ផុស្សតីទេវកញ្ញានោះប្រមើលមើលផ្ទៃជម្ពូទ្វីបឃើញព្រះរាជនិវេសន៍របស់ព្រះបាទសិវិរាជសមគួរដល់ខ្លួន កាលប្រាថ្នាជាអគ្គមហេសីក្នុងព្រះរាជនិវេសន៍នោះ ទើបពោលយ៉ាងនេះ ។ បទថា **យថា មិគី** សេចក្តីថា ដូចកូនម្រឹគញីអាយុ ១ ឆ្នាំ ។ បទថា **នីលក្ខី** សេចក្តីថា សូមមានភ្នែកខ្មៅថ្លាស្អាត ព្រោះហេតុនោះទើបពោលយ៉ាងនេះ ។ ក្នុងព្រះរាជនិវេសន៍នោះខ្ញុំគប្បីមានឈ្មោះថា ផុស្សតី ។ បទថា **លភេថ** បានដល់ គប្បីមាន ។ បទថា **វរធំ** សេចក្តីថា ជាអ្នកឲ្យ

វត្ថុប្រសើរមានសីសៈដែលប្រដាប់ហើយ ក្អែកទាំងគូ ហទយៈ សាច់ ឈាម ស្វេតច្ឆត្រ បុត្តនិងភរិយាជាដើមដល់យាចកដែលសូមហើយ ។ បទថា **កុច្ឆិ** បានដល់ អវយវៈដែលនៅត្រង់កណ្តាលខ្លួន លោកសម្តែងពាក្យនេះដោយសរុប ។ បទថា **លិខិតំ** បានដល់ ដូចជង្គង់ដែលជាងព្រញអ្នកឈ្លាសខាត់យ៉ាងល្អ ។ បទថា **អនុន្នតំ** សេចក្តីថា ត្រង់កណ្តាលជង្គង់មិនប៉ោងឡើងស្មើដូចជងជញ្ជីង គភ៌របស់ខ្ញុំគប្បីយ៉ាងនោះ ។ បទថា **ឧប្បរិត្តេយ្យំ** សេចក្តីថា មិនគប្បីជាដោះសណ្តាយ ។ បទថា **បលិតា ឧស្សន្នុ វាសវ** សេចក្តីថា បពិត្រវាសវៈដ៏ប្រសើរបំផុតក្នុងពួកទេវតាសូមរីសក់ស្កូវទាំងឡាយលើសីសៈរបស់ខ្ញុំក៏សូមបាត់ទៅ គឺកុំប្រាកដលើក្បាលរបស់ខ្ញុំ បាឋៈថា **បលិតានិ សិ-រោរុហា** ដូច្នេះក៏មាន ។ បទថា **វជ្ឈញ្ញាបិ** សេចក្តីថា ខ្ញុំគប្បីជាអ្នកអាចដោះលែងចោរដែលធ្វើខុស គឺខុសចំពោះព្រះរាជាដល់ទោសប្រហារ ដោយកម្លាំងរបស់ខ្លួន នាងផុស្សតីសម្តែងភាពជាធំរបស់ខ្លួនដោយបទនេះ ។ បទថា **សូទមាគធវណ្ណិតេ** សេចក្តីថា ដែលពួកពិសេសនិងពួកអ្នកមគធៈទាំងឡាយប្រាប់ពេលបរិភោគអាហារជាដើម ពោលសរសើរហើយ ។ បទថា **ចិត្រគ្គឡេរុឃុសិតេ** សេចក្តីថា កងរំពងទៅដោយសំឡេងវទុកទ្វារនិងបង្អួចដ៏វិចិត្រដោយរតនៈ ៧ ដែលបញ្ចេញសំឡេងពីរោះគួរត្រេកអរ ដូចសំឡេងតន្ត្រីទាំង ៥ ។ បទថា **សុរាមំសប្បពោធនេ** សេចក្តីថា នាងផុស្សតីទទួលយកពរ ១០ ប្រការនេះថា ខ្ញុំម្ចាស់គប្បីជាអគ្គមហេសីរបស់ព្រះបាទសិវិរាជក្នុងព្រះរាជនិវេសន៍របស់ព្រះបាទសិវិរាជបែបនេះ ដែលមានមនុស្សអញ្ជើញ

បរិភោគសុរានិងសាច់ថា ពួកលោកចូរមកផឹក ពួកលោកចូរមកស៊ីដូច្នេះ ។

បណ្ដាពរ ១០ ប្រការនោះ ភាពជាអគ្គមហេសីរបស់ព្រះបាទសិវិរាជ ជាពរទី ១ ភ្នែកខ្មៅជាពរទី ២ ចិញ្ចើមខ្មៅជាពរណ៍ទី ៣ ឈ្មោះថា ផុស្សតី ជាពរទី ៤ ការបានកូនច្បងជាឱរសជាពរទី ៥ មានគភ៌មិនប៉ោងឡើងជាពរទី ៦ មានព្រះថនាមិនយារជាពរទី ៧ មានសក់មិនស្កូវជាពរទី ៨ មានពណ៌សម្បុរល្អិតជាពរទី ៩ អាចដោះអ្នកទោសដែលប្រហារបានជាពរទី ១០ សក្កទេវរាជបានស្ដាប់ដូច្នោះទើបត្រាស់ថា

ម្នាលនាងមានអវយវៈទាំងអស់ដ៏ល្អ ពរ ១០ ប្រការណា ដែល
ខ្ញុំឲ្យដល់នាងហើយ នាងនឹងបានពរទាំងអស់នោះក្នុងដែនព្រះ
បាទសិវិ ដូច្នេះ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូត្រសាទូវព្រះគាថាដូច្នេះថា

ព្រះមឃវៈទេវរាជសុជម្បតិវាសវៈ លុះទ្រង់មានព្រះបន្ទូល
យ៉ាងនេះហើយក៏ប្រទានពរដល់ព្រះនាងផុស្សតី ហើយក៏មាន
ព្រះហឫទ័យរីករាយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អនុមោទិត្ថ** សេចក្ដីថា មានចិត្តត្រេកអរ គឺទ្រង់សោមនស្ស ។ បទថា **សព្វេ តេ លច្ឆសី វរេ** សេចក្ដីថា នាងនឹងបានពរទាំងអស់នោះ ។

សក្កទេវរាជទ្រង់ប្រទានពរ ១០ ប្រការហើយ ជាអ្នកមានចិត្តត្រេកអរ មានចិត្តរីករាយហើយដោយប្រការដូច្នេះ ។

**ទសពរគាថា ចប់**

# ហិមវន្តវណ្ណនា

ផុស្សតីទេវកញ្ញាទទួលពរដូច្នេះហើយ ចុតិអំពីតាវត្តិង្សពិភពនោះ កើតក្នុងព្រះឧទរអគ្គមហេសីរបស់ព្រះបាទមទ្ទរាជ ក្នុងថ្ងៃថ្វាយព្រះនាមរបស់ព្រះនាងនោះញាតិទាំងឡាយបានដាក់ឈ្មោះថា ផុស្សតី ដដែលនោះឯង ព្រោះកាលព្រះនាងប្រសូត មានព្រះសរីរៈហាក់បីដូចជាប្រោះព្រំដោយលម្អិតខ្លឹមចន្ទន៍ប្រសូតហើយ ។ ព្រះនាងផុស្សតីរាជធីតានោះចម្រើនដោយរាជបរិវារធំ ក្នុងកាលមានព្រះជន្មបាន ១៦ វស្សា បានជាអ្នកទ្រទ្រង់នូវព្រះរូបដ៏ឧត្តម កាលនោះ ព្រះបាទសិវិរាជទ្រង់នាំព្រះនាងផុស្សតីមក ដើម្បីប្រយោជន៍ដល់សញ្ជយកុមារជឱរស បានលើកឆត្រដល់រាជឱរសនោះ ឲ្យព្រះនាងផុស្សតីជាធំជាងស្រី ១៦០០០ នាក់ ទ្រង់តាំងទុកក្នុងតំណែងអគ្គមហេសីរបស់ព្រះបាទសញ្ជយរាជឱរស ។ ព្រោះហេតុនោះទើបព្រះមានព្រះភាគត្រាស់ថា

> នាងផុស្សតីទេវធីតានោះច្យុតចាកទេវលោកនោះមកហើយ ក៏ទៅកើតក្នុងខត្តិយត្រកូល បាននៅរួមនឹងព្រះបាទសញ្ជ័យ ក្នុងនគរជេតុត្តរ ដូច្នេះ ។

ព្រះនាងផុស្សតីបានជាទីស្រឡាញ់ពេញព្រះហឫទ័យនៃព្រះបាទសញ្ជ័យ គ្រានោះសក្កទេវរាជកាលទ្រង់អាវជ្ជនាការក៏ជ្រាបថាបណ្តាពរទាំង ១០ ប្រការដែលអញឲ្យដល់នាងផុស្សតី ពរ ៩ ប្រការសម្រេចហើយទើបទ្រង់ព្រះតម្រិះថា ឱរសដ៏ប្រសើរជាពរ ១ មិនទាន់សម្រេច អញនឹងឲ្យពរនោះសម្រេចដល់នាង ។ ក្នុងកាលនោះព្រះមហាសត្វនៅក្នុងតាវត្តិង្សទេវលោកអាយុរបស់

មហាសត្វនោះអស់ហើយ សក្កទេវរាជទ្រង់ជ្រាបសេចក្ដីនោះ ទើបទៅកាន់សម្នាក់របស់ព្រះពោធិសត្វត្រាស់ថា នែលោកនិទ្ទុក្ខ គួរលោកទៅកាន់មនុស្សលោក គួរកាន់យកបដិសន្ធិក្នុងផ្ទៃនៃព្រះនាងផុស្សតីអគ្គមហេសី នៃព្រះបាទសិវិរាជក្នុងជេតុត្តរនគរ ដូច្នេះហើយកាន់យកនូវបេ្ដជ្ញា នៃព្រះពោធិសត្វនិងទេវបុត្ត ៦០០០០ ដទៃដែលនឹងចុតិ ហើយត្រឡប់ទៅវិមានដែលជាទីប្រថាប់របស់ខ្លួន ឯព្រះមហាសត្វចុតិអំពីទេវលោកនោះកើតក្នុងផ្ទៃនៃព្រះនាងផុស្សតីទេវបុត្ត ៦០០០០ កើតក្នុងគេហដ្ឋាននៃអាមាត្យ ៦០០០០ នាក់ ៗ ក្នុងកាលព្រះមហាសត្វនៅក្នុងផ្ទៃព្រះមាតា ព្រះនាងផុស្សតីចាញ់គភ៌មានបំណងឲ្យសាងរោងទាន ៦ កន្លែង គឺត្រង់ទ្វារនគរទាំង ៤ កណ្ដាលព្រះនគរ ១ ត្រង់ទ្វារព្រះរាជវាំង ១ ព្រះនាងលះទ្រព្យសម្បត្តិ ៦ សែនកហាបណៈរាល់ៗថ្ងៃបរិច្ចាគទាន ។ កាលព្រះបាទសញ្ជយសិវិរាជជ្រាបសេចក្ដីប្រាថ្នារបស់ព្រះនាងទើបឲ្យហៅព្រាហ្មណ៍ទាំងឡាយដែលស្គាល់និមិត្ត មកធ្វើសក្ការៈធំហើយត្រាស់សួរសេចក្ដីនោះ ។ ព្រាហ្មណ៍អ្នកដឹងនិមិត្តទាំងឡាយក៏ទូលព្យាករថាបពិត្រមហារាជ លោកអ្នកត្រេកអរក្រៃលែងក្នុងទាន មកកើតក្នុងព្រះឧទរនៃព្រះទេវី នឹងមិនឆ្អែតក្នុងការឲ្យទាន ព្រះរាជាបានស្ដាប់ព្យាករណ៍នោះក៏មានព្រះហឫទ័យត្រេកអរក៏ប្រោសឲ្យសាងរោងទាន ៦ កន្លែង មានប្រការដូចពោលមកហើយ ឲ្យផ្ដើមតាំងទានដូចប្រការដែលពោលមកហើយ ចាប់តាំងពីពេលដែលព្រះពោធិសត្វបដិសន្ធិ ពន្ធអាកររបស់ព្រះរាជាបានចម្រើនឡើងលើសប្រមាណ ពួកព្រះរាជាក្នុងជម្ពូទ្វីប បញ្ជូនគ្រឿងបណ្ណាការមកថ្វាយព្រះ

បាទសញ្ជ័យ ដោយបុញ្ញានុភាពនៃព្រះពោធិសត្វ ។ ព្រះនាងផុស្សតីរាជទេវី មានបរិវារធំ កាលព្រះនាងទ្រង់គភ៌គ្រប់ ១០ ខែបរិបូណ៌ មានបំណងនឹងទតព្រះនគរទើបក្រាបទូលព្រះរាជស្វាមីព្រះបាទក្រុងសិវិ ព្រះរាជាឲ្យតាក់តែងព្រះនគរដូចទេវនគរ ឲ្យព្រះទេវីទ្រង់រថព្រះទីន័ងដ៏ប្រសើរ ធ្វើប្រទក្សិណព្រះនគរ ក្នុងគ្រាព្រះនាងយាងដល់ពាក់កណ្ដាលផ្លូវរបស់ពួកឈ្មួញ ខ្យល់កម្មជវាតក៏បក់ឡើង រាជបុរសក្រាបទូលសេចក្ដីនោះដល់ព្រះរាជា ។ ព្រះរាជាទ្រង់ជ្រាបទើបឲ្យធ្វើទីសម្រាប់ប្រសូតិដល់ព្រះទេវីត្រង់កណ្ដាលវិថីនៃពួកឈ្មួញ ហើយឲ្យធ្វើការរក្សា ព្រះនាងផុស្សតីព្រះសូតព្រះរាជឱរសក្នុងទីនោះឯង ។

ដោយហេតុនោះទើបព្រះមានព្រះភាគត្រាស់ថា

ព្រះនាងទេវីទ្រង់ព្រះនាមផុស្សតី ទ្រង់គភ៌អស់ ១០ ខែ ក៏ធ្វើ
ប្រទក្សិណព្រះរាជបុរី រួចប្រសូតតថាគតត្រង់កណ្ដាលផ្លូវនៃ
ពួកឈ្មួញ ដូច្នេះ ។

ព្រះមហាសត្វប្រសូតចាកផ្ទៃនៃព្រះមាតា ជាបុគ្គលបរិសុទ្ធបើកភ្នែកទាំង ២ លាព្រះហស្តត្រាស់នឹងព្រះមាតាថា បពិត្រអ្នកម៉ែ ខ្ញុំនឹងបរិច្ចាគទាន មានទ្រព្យអ្វីខ្លះឬ កាលនោះព្រះជននីត្រាស់តបថា នែបា ចូរបរិច្ចាគទានតាមអ-ធ្យាស្រ័យចុះ ហើយដាក់ថង់កហាបណៈ ១០០០ ត្រង់ដៃ ។

ព្រះពោធិសត្វប្រសូតហើយបាននិយាយនឹងម្ដាយ ៣ ជាតិ គឺក្នុងឧម្មង្គជាតកជាមហោសធ ១ ជាតកនេះ ១ ក្នុងអត្តភាពចុងក្រោយ គឺព្រះសិទ្ធត្ថ ១ ។

កាលនោះក្នុងថ្ងៃថ្វាយនាមព្រះពោធិសត្វ ញាតិទាំងឡាយបានដាក់ឈ្មោះថា វេស្សន្តរ ព្រោះកើតក្នុងវិថីនៃពួកឈ្មួញ ដោយហេតុនោះទើបព្រះមានព្រះភាគត្រាស់ថា

នាមតថាគតមិនមែនជារបស់មាតា ទាំងមិនមែនកើតមកពីបិតាទេ តថាគតកើតត្រង់ ( កណ្តាល ) ផ្លូវនៃពួកឈ្មួញព្រោះហេតុនោះបានជាតថាគតឈ្មោះវេស្សន្តរ ដូច្នេះ ។

ក្នុងថ្ងៃដែលព្រះពោធិសត្វ កើតដំរីញី ១ នាំកូនដំរីពណ៌ស ដែលជាដំរីមង្គលមកតាមអាកាសឲ្យស្ថិតនៅក្នុងទីមង្គលហត្ថី ហើយចៀសចេញទៅ ជនទាំងឡាយដាក់ឈ្មោះដំរីនោះថា បច្ចយនាគ ព្រោះដំរីនោះកើតឡើងព្រោះមានមហាសត្វជាបច្ច័យ ។ ព្រះរាជាបានប្រទានស្រីស្នំ ៦៤ នាក់ ដែលវៀរចាកទោសមានខ្ពស់ពេកជាដើម មានដោះមិនសណ្តាយ មានទឹកដោះផ្អែមដល់មហាសត្វ បានព្រះរាជទានស្រីស្នំម្នាក់ៗដល់ពួកទារក ៦០០០០ ដែលជាសហជាតិជាមួយព្រះមហាសត្វ ។ ព្រះមហាសត្វនោះ កើតព្រមជាមួយទារក ៦០០០០ នាក់ ទ្រង់ចម្រើនដោយបរិវារធំ ។ កាលនោះព្រះរាជាឲ្យធ្វើគ្រឿងប្រដាប់សម្រាប់រាជកុមារដែលមានតម្លៃមួយសែន ព្រះរាជទានដល់វេស្សន្តររាជកុមារ រាជកុមារនោះដោះគ្រឿងប្រដាប់នោះប្រទានដល់ស្នំទាំងឡាយ ក្នុងកាលដែលមានព្រះជន្ម ៤-៥ ឆ្នាំ ទ្រង់មិនទទួលគ្រឿងប្រដាប់ដែលស្នំទាំងឡាយនោះថ្វាយមកវិញ ស្រីស្នំទាំងនោះក្រាបទូលព្រឹត្តិការណ៍នោះដល់ព្រះរាជា ។ ព្រះរាជាទ្រង់ជ្រាបព្រឹត្តិ-ហេតុនោះក៏ឲ្យធ្វើគ្រឿងប្រដាប់ដទៃទៀតព្រះរាជទាន ដោយទ្រង់យល់ឃើញថា

អាករណៈដែលកូនយើងឲ្យហើយក៏ជាការឲ្យហើយដោយល្អ ចូរជាព្រហ្មទេយ្យ ព្រះរាជកុមារក៏ប្រទានគ្រឿងប្រដាប់នោះដល់ស្រីស្នំ ក្នុងកាលទ្រង់នៅក្មេងអស់ ៩ ដង ។

ក្នុងកាលព្រះរាជកុមារមានព្រះជន្ម ៨ ឆ្នាំ ព្រះរាជកុមារយាងទៅកាន់ប្រាសាទដ៏ប្រសើរគង់ប្រថាប់លើព្រះពស្រ្តទ្រង់គិតថា អញឲ្យទានខាងក្រៅតែម្យ៉ាង ទាននោះមិនញ៉ាំងអញឲ្យត្រេកអរឡើយ អញគួរឲ្យទានខាងក្នុង បើអ្នកឯណាមកសុំបេះដូងអញ អញនឹងពុះឧរបេទេសនាំបេះដូងចេញមកឲ្យដល់បុគ្គលនោះ បើគេសុំចក្ខុទាំងឡាយរបស់អញ អញក៏ខ្វេះភ្នែកនោះឲ្យ បើសុំសាច់ក្នុងសរីរៈ អញនឹងពុះវះពន្ទះរាងកាយទាំងមូលឲ្យ បើអ្នកឯណាសុំនូវឈាមរបស់អញ អញនឹងបង្ហូរឈាមឲ្យឬបើអ្នកឯណាមកពោលនឹងអញថា សូមទ្រង់ធ្វើជាទាសៈរបស់ខ្ញុំ អញក៏ត្រេកអរត្រៀមខ្លួនធ្វើទាសៈនៃបុគ្គលនោះ ។

ព្រះវេស្សន្តរបរមពោធិសត្វទ្រង់អាវជ្ជនៈដល់អជ្ឈត្តិកទាន ដែលជាព្រះតម្រិះស្មុះទៅឯងយ៉ាងនេះ មហាប្រឹថពីដែលមានកម្រាស់ ២ សែន ៤ ម៉ឺនយោជន៍ ក៏លាន់ញាប់ញ័រ ដូចដំរីដ៏ប្រសើរចុះប្រេង ឬដូចអាលវាំតគំរាមដូច្នោះ ភ្នំសិនេរុក៏ទោរទន់ទៅមករកជេតុត្តរនគរដូចផ្កាខ្ចីទោរទន់ទៅមកដូច្នោះ អាកាសក៏លាន់ឮសំឡេងតាមមហាប្រឹថពី ញ៉ាំងភ្លៀងដែលមានព្រិលឲ្យធ្លាក់ចុះ រន្ទះមានក្នុងសម័យពុំដូកាល ផ្ទេកបន្ទោរក៏ជាលប្រវាត់ មហាសមុទ្ទកើតជារលកគគ្រាំគគ្រេង សក្កទេវរាជក្រាក់ផ្អើលទះនូវដៃ មហាព្រហ្មក៏ឲ្យសាធុការ សំឡេងកោលាហលដូចគ្នាតែមួយ លាន់ឮដល់ព្រហ្មលោក ។

សមដូចព្រះតម្រាស់ដែលព្រះមានព្រះភាគត្រាស់ទុកថា

កាលដែលតថាគតនៅក្មេងតូច ទើបនឹងមានអាយុ ៨ ឆ្នាំអំពីកំណើត តថាគតបានអង្គុយលើប្រាសាទ រិះគិតនឹងឲ្យទានថា បើមានស្មូមណាមួយមកបន្ទឹវាចាសុំអាត្មាអញៗ គួរឲ្យបេះដូង គួរឲ្យភ្នែក គួរឲ្យសាច់ គួរឲ្យឈាម គួរឲ្យរាងកាយ ( ដល់ស្មូមនោះឯង ) ។ កាលតថាគតនោះកំពុងគិតសភាវធម៌ដែលមិនកម្រើក មិនតាំងនៅក្នុងកាលនោះ ប្រឹថពីមានភ្នំសិនេរុនិងព្រៃជាគ្រឿងប្រដាប់ពីខាងលើក៏ញាប់ញ័រ ដូច្នេះ ។

ក្នុងកាលព្រះពោធិសត្វមានព្រះជន្ម ១៦ ឆ្នាំ ព្រះពោធិសត្វទ្រង់បានសិក្សាសិប្បៈទាំងពួងសម្រេច កាលនោះ ព្រះរាជបិតាប្រាថ្នាប្រទានរាជសម្បត្តិដល់មហាសត្វ ទ្រង់ប្រឹក្សាជាមួយព្រះនាងផុស្សតីដ៏ជាមាតា ក៏នាំរាជកញ្ញាព្រះនាមថាមទ្រី ដែលជាបុត្រីរបស់ព្រះមាតុលៈនៃត្រកូលមទ្ទរាជ ឲ្យតាំងនៅក្នុងតំណែងអគ្គមហេសី ឲ្យជាធំជាងស្រី ១៦០០០ អភិសេកព្រះមហាសត្វក្នុងរាជសម្បត្តិ ។ ព្រះមហាសត្វទ្រង់លះទ្រព្យសម្បត្តិ ៦ សែនរាល់ៗថ្ងៃចាប់តាំងពីតាំងនៅក្នុងរាជសម្បត្តិ ។

សម័យតមកព្រះនាងមទ្រីប្រសូតព្រះរាជឱរស ព្រះញាតិទាំងឡាយទទួលព្រះរាជបុត្តនោះដោយបណ្តាញមាស ព្រោះដូច្នោះ ទើបថ្វាយព្រះនាមថា ជាលីរាជកុមារ លុះព្រះរាជកុមារនោះចេះដើរ ព្រះនាងមទ្រីក៏ប្រសូតរាជធីតា ព្រះញាតិទាំងឡាយទទួលព្រះរាជបុត្រីនោះដោយស្បែកខ្លាឃ្មុំ ព្រោះ

ដូច្នោះទើបថ្វាយព្រះនាមថា កណ្ហាជិនារាជកុមារី ។ ព្រះវេស្សន្តរមហាសត្វប្រថាប់លើកដីរដ៏ប្រសើរដែលគេតាក់តែងហើយ យានទតរោងទានទាំង ៦ មួយខែ ៦ ដង ។

កាលនោះក្នុងកាលិង្គរដ្ឋភ្លៀងមិនធ្លាក់សន្ទុនមិនបរិបូណ៌ ភ័យ គឺការអត់ឃ្លានក៏កើតឡើង មនុស្សទាំងឡាយមិនអាចរស់នៅបាន ក៏នាំគ្នាធ្វើចោរកម្ម អ្នកជនបទត្រូវទុព្ភិក្ខភ័យបៀតបៀនក៏ប្រជុំគ្នាត្រង់លានព្រះរាជវាំង កាលព្រះរាជាត្រាស់សួរដល់ហេតុក៏ក្រាបទូលសេចក្តីនោះ ព្រះរាជាក៏ត្រាស់ថា សាធុ អញនឹងធ្វើភ្លៀងឲ្យធ្លាក់ហើយបញ្ជូនអ្នកស្រុកឲ្យត្រឡប់ ទ្រង់សមាទានសីលរក្សាឧបោសថអស់ ៧ ថ្ងៃ ទ្រង់មិនអាចធ្វើភ្លៀងឲ្យធ្លាក់ទើបឲ្យប្រជុំអ្នកស្រុកហើយត្រាស់សួរថា អញបានសមាទានសីលរក្សាឧបោសថអស់ ៧ ថ្ងៃក៏មិនអាចញុំាងភ្លៀងឲ្យធ្លាក់បាន គប្បីធ្វើដូចម្តេច ។ អ្នកស្រុកក្រាបទូលថា បពិត្រសម្មតិទេព បើទ្រង់មិនអាចឲ្យភ្លៀងធ្លាក់ ព្រះរាជបុត្ររបស់ព្រះបាទសញ្ជ័យក្នុងជេតុត្តរនគរព្រះនាមថាវេស្សន្តរជាអ្នកត្រេកអរក្នុងទាន ដំរីមង្គលពណ៌សនោះទៅដល់ទីណាភ្លៀងក៏ធ្លាក់ សូមទ្រង់ឲ្យព្រាហ្មណ៍ទាំងឡាយ ទៅសូមដំរីនោះនាំមក ។ ព្រះរាជាត្រាស់ថា សាធុ ហើយឲ្យប្រជុំពួកព្រាហ្មណ៍ ជ្រើសរើសយកព្រាហ្មណ៍ ៨ នាក់ គឺរាមព្រាហ្មណ៍ ១ ធជព្រាហ្មណ៍ ១ លក្ខណព្រាហ្មណ៍ ១ សុជាតិមន្តព្រាហ្មណ៍ ១ យញ្ញព្រាហ្មណ៍ ១ សុជាតព្រាហ្មណ៍ ១ សុយាមព្រាហ្មណ៍ ១ កោណ្ឌញ្ញព្រាហ្ម ១ ព្រាហ្មណ៍ឈ្មោះរាមៈជាប្រមុខនៃព្រាហ្មណ៍ទាំង ៧ ទ្រង់ប្រទានស្បៀងបញ្ជូនទៅដោយព្រះរាជបញ្ជាថា អ្នក

ទាំងឡាយ ចូរទូលសូមដំរីនឹងព្រះបាទវេស្សន្តរហើយនាំមក ។ ព្រាហ្មណ៍ទាំង ៨ ទៅដោយលំដាប់ដល់ជេតុត្តរនគរហើយបរិភោគកត្តក្នុងរោងទាន ប្រាថ្នានឹងធ្វើសរីរៈរបស់ខ្លួនឲ្យប្រឡាក់ដោយធូលី លាបខ្លួនប្រាណដោយធូលីហើយទូលសូមដំរីនឹងព្រះបាទវេស្សន្តរ ។ ក្នុងថ្ងៃស្អែកឡើងទៅកាន់ទ្វារនគរទិសខាងកើត ក្នុងពេលព្រះវេស្សន្តរយាងទៅកាន់រោងទាន ។ ឯព្រះវេស្សន្តររាជទ្រង់អាវជ្ជនៈថា អញនឹងត្រួតមើលរោងទាន ទើបទ្រង់សោយភោជនមានរសដ៏ប្រសើរផ្សេងៗអំពីព្រលឹមហើយប្រថាប់លើកដំរីដ៏ប្រសើរ ដែលប្រដាប់តាក់តែងហើយយាងទៅតាមទ្វារទិសខាងកើត ។ ព្រាហ្មណ៍ទាំង ៨ មិនបានឱកាសក្នុងទីនោះទើបទៅកាន់ទ្វារនគរទិសទក្សិណ ឈរក្នុងទីខ្ពស់ ក្នុងកាលដែលព្រះរាជាទតរោងទានទិសខាងកើតហើយយាងមកកាន់ទ្វារខាងត្បូង ក៏លាដៃខាងស្តាំទូលថា បពិត្រព្រះវេស្សន្តររាជ សូមទ្រង់មានជ័យជម្នះ បពិត្រព្រះវេស្សន្តររាជ សូមទ្រង់មានជ័យជម្នះ ព្រះវេស្សន្តរមហាសត្វទតឃើញព្រាហ្មណ៍ទាំងឡាយក៏បញ្ជូដំរីទីនឹងទៅកាន់ទីដែលព្រាហ្មណ៍ទាំងនោះឈរ ប្រថាប់លើកដំរីត្រាស់ព្រះគាថាដូច្នេះថា

> ពួកព្រាហ្មណ៍មានរោមក្លៀកនិងក្រចកដុះវែង មានធ្មេញប្រកប
> ដោយមន្ទិល មានក្បាលប្រឡាក់ដោយធូលី ផ្គងដើមដៃខាង
> ស្តាំ តើសុំអ្វីនឹងអញ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បរុឡ្ហកច្ឆនខលោមា** សេចក្តីថា មានរោមក្លៀកវែង មានក្រចកវែង មានរោមវែង គឺមានក្រចកវែង មានរោមវែង ។

មានរោមកើតត្រង់ក្លៀក ។ ក្លៀកផង ក្របកផង រោមផង ហៅថា **កច្ឆនខ-លោមា** ។ ក្លៀក ក្របក រោមរបស់ព្រាហ្មណ៍ទាំងឡាយណា ដុះហើយ ព្រាហ្មណ៍ទាំងនោះមានឈ្មោះថា ជាអ្នកមានរោមក្លៀកវែង មានក្របកវែង មានរោមវែង ។

ព្រាហ្មណ៍ទាំង ៨ ក៏ក្រាបទូលថា

បពិត្រព្រះសម្មតិទេព ពួកទូលព្រះបង្គំសុំហត្ថិរតន៍ដែលញុំាង
ដែននៃពួកអ្នកសិវិរាស្ត្រឲ្យចម្រើន សូមព្រះអង្គទ្រង់ប្រទានដំរី
ដ៏ប្រសើរដែលមានភ្លុកងទន្ទាំ អាចញុំាញីសត្រូវបាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧរូឡ្ហវំ** បានដល់ អាចជារាជពាហនៈបាន ។

ព្រះមហាសត្វបានស្តាប់ដូច្នោះហើយទ្រង់ត្រិះរិះថា អញប្រាថ្នានឹងបរិច្ចាគ-អជ្ឈត្តិកទានខាងក្នុង មានក្បាលជាដើម ព្រាហ្មណ៍ទាំងនេះមកសុំតែវត្ថុខាងក្រៅ អញនឹងញុំាងសេចក្តីប្រាថ្នារបស់ព្រាហ្មណ៍ទាំងនេះឲ្យបរិបូណ៌ គង់លើកដំរីដ៏ប្រសើរត្រាស់គាថានេះថា

ព្រាហ្មណ៍ទាំងឡាយសុំដំរីណានឹងអញ ជាដំរីចុះប្រេង ជា
កុញ្ជរជាតិ មានភ្លុកដ៏ល្អ ជាដំរីដ៏ប្រសើរ គួរជារាជពាហនៈ
អញនឹងឲ្យ ( ដំរីនោះ ) អញមិនញាប់ញ័រទេ ដូច្នេះ ។

ដោយហេតុនោះកាលឲ្យនូវបេ្តជ្ញាទើបព្រះសាស្តាត្រាស់ថា

ព្រះរាជាដែលជាអ្នកញុំាងពួកអ្នកសិវិរាស្ត្រឲ្យចម្រើន ទ្រង់មាន
ព្រះហឫទ័យប្រាថ្នាយ៉ាងលើសលុបក្នុងការបរិច្ចាគ ទ្រង់ចុះចាក

កនៃដំរី រួចទ្រង់ប្រទាន ( ដំរី ) ជាទាន ដល់ពួកព្រាហ្មណ៍ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឱបវយ្ហំ** បានដល់ រាជពាហនៈ ។ បទថា **ចាគាធិមានសោ** បានដល់ មានព្រះហឫទ័យក្រៃលែង ដោយបរិច្ចាគ ។ បទថា **អទា** សេចក្ដីថា បានព្រះរាជទានដល់ព្រាហ្មណ៍ទាំងឡាយ ។

ព្រះមហាសត្វទ្រង់ធ្វើប្រទក្សិណដំរី ៣ ជុំ ដើម្បីត្រួតមើលត្រង់កាយដំរីដែលប្រដាប់ហើយ មិនឃើញទីដែលមិនបានប្រដាប់ទើបចាប់ព្រះកុណ្ឌីមាសដែលពេញដោយទឹកក្រអូបលាយដោយផ្កា ត្រាស់នឹងព្រាហ្មណ៍ទាំងឡាយថា អើមហាព្រាហ្មណ៍ទាំងឡាយ ចូរអ្នកទាំងឡាយមកខាងនេះ ទ្រង់ចាប់ប្រមោយដំរីដែលប្រដាប់ហើយដូចគ្នានឹងកម្រងប្រាក់ ដាក់ក្នុងដៃនៃពួកព្រាហ្មណ៍ទាំងនោះ ប្រួចទឹកព្រះរាជទានដំរីដែលប្រដាប់ហើយ ។ អលង្ការត្រង់ជើងទាំង ៤ មានតម្លៃ ៤ សែន អលង្ការត្រង់ចំហៀងទាំងសងខាងមានតម្លៃ ២ សែន សំពត់កម្ពលក្រហមខាងក្រោមពោះ មានតម្លៃ ១ សែន បណ្ដាញដែលគ្របខ្នង ៣ គឺបណ្ដាញកែវមុក្តា បណ្ដាញកែវមណីនិងបណ្ដាញមាសមានតម្លៃ ៣ សែន កណ្ដឹងដែលសំយុងទាំងសងខាងត្រចៀកមានតម្លៃ ២ សែន សំពត់កម្ពលដែលក្រាលលើខ្នងមានតម្លៃ ១ សែន អលង្ការដែលប្រដាប់ពោងមានតម្លៃ ១ សែន ខ្សែជង្គន់ទាំង ៣ មានតម្លៃ ៣ សែន សំណុំគ្រឿងប្រដាប់ត្រង់ត្រចៀកទាំង ២ មានតម្លៃ ២ សែន ចង្កឹះភ្លុកទាំង ២ មានតម្លៃ ២ សែន កម្រងភ្ជីរល្មិដែលប្រដាប់ត្រង់ប្រមោយ មានតម្លៃ ១ សែន

អលង្ការដែលប្រដាប់ត្រង់កន្ទុយមានតម្លៃ ១ សែន គ្រឿងអលង្ការដែលពាក់តែងលំអកាយដំរី វៀរកណ្ឌះដែលមិនមានតម្លៃរួបរួមកណ្ឌះដែលមានតម្លៃជា ២២ សែន កំណល់សម្រាប់ឡើងតម្លៃ ១ សែន ប្រដាប់សម្រាប់ដាក់ចំណីបរិភោគមានស្មៅនិងទឹកជាដើមមានតម្លៃ ១ សែន រួមបញ្ចូលគ្នាជា ២៤ សែន មានរបស់មានតម្លៃកាត់ថ្លៃមិនបាន ៦ យ៉ាង គឺកែវមណីដែលរំលេចត្រង់ផ្អឹងធត្រ ត្រង់កំពូលធត្រ ត្រង់កម្រងមុក្តា ត្រង់កង្វេរ ត្រង់កម្រងមុក្តាដែលចងត្រង់កដំរី ត្រង់ពោងនិងត្រង់ខ្នងស្តេចដំរីជាគម្រប់ ៧ យ៉ាង ជារបស់កាត់ថ្លៃមិនបាន ទ្រង់បានព្រះរាជទានទាំងអស់ដល់ព្រាហ្មណ៍ទាំងឡាយនិងព្រះរាជទានត្រកូលអ្នកថែដំរី ៥០០ ត្រកូលមួយអន្លើដោយហ្មដំរីនិងអ្នកចិញ្ចឹមដំរីផងដែរ ។ ការអស្ចារ្យ មានផែនដីកម្រើកជាដើម មានហើយដំណាលគ្នានឹងព្រះបាទវេស្សន្តរមហារាជទ្រង់បរិច្ចាគទាន ដោយន័យដូចពោលមកហើយខាងដើមនោះឯង ។

**តមត្ថំ បកាសេន្តោ សត្ថា អាហា** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសានូវព្រះគាថាដូច្នេះថា

កាលដែលព្រះរាជាទ្រង់ប្រទានដំរីដ៏ប្រសើរ ផែនដីកម្រើកញាប់ញ័រ ការកើតហេតុគួរខ្លាចគួរព្រឺរោម ក៏មានក្នុងកាលនោះ ។

កាលព្រះរាជាទ្រង់ប្រទានដំរីដ៏ប្រសើរ ការកើតហេតុគួរខ្លាចគួរព្រឺរោមក៏មានក្នុងកាលនោះ អ្នកនគរក៏ជ្រួលជ្រើមក្នុងកាល

នោះ ។ កាលព្រះរាជាទ្រង់ប្រទានដំរីដ៏ប្រសើរ ដែលជាដំរី
ញ៉ាំងពួកអ្នកសិវិរាស្ត្រឲ្យចម្រើន អ្នកបុរីក៏ជ្រួលច្របល់ ទាំង
សំឡេងក៏គឹកកងរំពងខ្លាំង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តទាសិ** បានដល់ កើតមានក្នុងកាលនោះ ។ បទថា **ហត្ថិនាគេ** បានដល់ សត្វដ៏ប្រសើរ គឺដំរី ។ បទថា **ខុភិត្ត នគរំ តទា** សេចក្តីថា បានរំជើបរំជួលហើយ ។

បានឮថា ព្រាហ្មណ៍ទាំងឡាយបាននូវដំរីទៀបទ្វារទិសខាងត្បូង អង្គុយលើខ្នងដំរី មានមហាជនចោមរោមបរទៅត្រង់កណ្តាលព្រះនគរ មហាជនឃើញហើយពោលនឹងព្រាហ្មណ៍ទាំងនោះថា អើព្រាហ្មណ៍ដ៏ចម្រើន លោកជិះដំរីរបស់យើងទាំងឡាយ លោកបានមកអំពីណា ព្រាហ្មណ៍ទាំងនោះឆ្លើយថា ដំរីនេះ ព្រះវេស្សន្តរមហារាជឲ្យដល់ពួកយើង ពួកលោកជាអ្នកណា កាលឆ្លើយឆ្លងនឹងមហាជនដោយវិការនៃដៃជាដើម ក៏បរដំរីកាត់ត្រង់កណ្តាលព្រះនគរចេញទៅតាមទ្វារទិសខាងជើង ។ ពួកអ្នកនគរខឹងក្រោធនឹងព្រះពោធិសត្វ ដោយអំណាចទេវតាបណ្តាលចិត្តឲ្យគិតខុសទើបប្រជុំគ្នាពោលតិះដៀលដោយពាក្យធ្ងន់ត្រង់ទ្វារព្រះរាជវាំង ព្រោះហេតុនោះទើបព្រះសាស្តាត្រាស់ថា

កាលព្រះរាជាទ្រង់ប្រទាននូវដំរីដ៏ប្រសើរ គ្រានោះសំឡេងយ៉ាង
ខ្លាំងពន្លឹក ជាសំឡេងគួរខ្លាចក៏ប្រព្រឹត្តទៅក្នុងនគរនោះ ក្នុង
កាលនោះអ្នកនគរក៏ជ្រួលជ្រើម ។ កាលព្រះរាជាទ្រង់ប្រទានដំរី
ដ៏ប្រសើរ ជាដំរីញ៉ាំងពួកអ្នកសិវិរាស្ត្រឲ្យចម្រើន គ្រានោះ

សំឡេងយ៉ាងខ្លាំងពន្លឺកគួរខ្លាចប្រព្រឹត្តទៅក្នុងនគរនោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឃោសោ** បានដល់ សំឡេងតិះដៀល ។ បទថា **វិបុលោ** បានដល់ ចម្រើន ព្រោះផ្សាយចេញទៅ ។ បទថា **មហា** បានដល់ ច្រើនព្រោះច្រើនក្រៃលែងឡើង ។ បទថា **សិវីនំ រដ្ឋវឌ្ឍនេ** បានដល់ ធ្វើនូវសេចក្តីចម្រើនដល់ប្រជារាស្ត្រក្នុងសិវិនគរ ។

កាលអ្នកនគរមានចិត្តមិនត្រេកអរ ព្រោះព្រះបាទវេស្សន្តរព្រះរាជទានដំរីដែលសំខាន់សម្រាប់ព្រះនគរទើបក្រាបទូលព្រះបាទសញ្ជ័យ ព្រោះហេតុនោះ ទើបព្រះសាស្តាត្រាស់អភិសម្ពុទ្ធគាថានេះថា

ពួកជនអ្នកមានកេរ្តិ៍ឈ្មោះ ពួករាជបុត្ត ពួកអ្នកជំនួញ ពួកព្រាហ្មណ៍ ពួកទាហានដំរី ទាហាន ( សេះ ) ទាហានរថនិងពលថ្មើរជើង អ្នកនិគមទាំងអស់និងពួកអ្នកសិវិរាស្ត្រក៏មកប្រជុំគ្នា ពួកជនទាំងនោះបានឃើញដំរី ដែលពួកព្រាហ្មណ៍កំពុងនាំទៅ ក៏ក្រាបទូលចំពោះព្រះរាជា ( ទ្រង់ព្រះនាមសញ្ជ័យ ) ថា បពិត្រព្រះសម្មតិទេព ដែនរបស់ព្រះអង្គសាបសូន្យហើយ ព្រះវេស្សន្តរ ជាព្រះរាជបុត្តរបស់ព្រះអង្គ ម្តេចក៏ប្រទានដំរីដ៏ប្រសើររបស់យើង ជាដំរីដែលអ្នកដែនបូជាហើយ ម្តេចក៏ប្រទានដំរីកុញ្ជររបស់យើងដែលជាដំរីមានភ្លុកងទន្ទាំ អាចញាំញីសត្រូវបាន ជាសត្វស្គាល់ខេត្តចម្បាំងទាំងអស់ ជាដំរីដ៏ឧត្តមសសុទ្ធ ។ ដំរីនោះមានខ្លួនពាសដោយសំពត់កម្ពលលឿង ជា

ដំរីចុះប្រេង ញាំញីសត្រូវបាន មានក្ងុកដ៏ល្អប្រកបដោយស៊ែ ជាដំរីសប្រហែលនឹងភ្នំកៃលាស ។ ព្រះរាជបុត្តរបស់ព្រះអង្គ បានប្រទានដំរីរាជពាហនៈ ជាយានដ៏ប្រសើរព្រមទាំងស្វេត-ច្ឆត្រព្រមទាំងកម្រាលសម្រាប់ក្រាលលើខ្នង ព្រមទាំងពេទ្យ ព្រមទាំងអ្នករក្សាដំរី ទៅជាទានដល់ពួកព្រាហ្មណ៍ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧគ្គា** បានដល់ ច្បាស់ គឺស្គាល់ទូទៅ គឺប្រាកដ ។ បទថា **និគមោ** បានដល់ អ្នកនិគមដែលមានទ្រព្យ ។ បទថា **វិធមំ ទេវ តេ រដ្ឋំ** សេចក្តីថា បពិត្រព្រះសម្មតិទេព ដែនរបស់ព្រះអង្គត្រូវបំផ្លាញហើយ ។ បទថា **កថំ នោ ហត្ថិនំ ទជ្ជា** សេចក្តីថា ព្រះរាជទានដំរីដែលគេស្គាល់ថាជាដំរីមង្គលនៃយើងទាំងឡាយដល់ព្រាហ្មណ៍អ្នកកាលិង្គរដ្ឋ ។ បទថា **ខេត្តញ្ញុំ សព្វយុទ្ធានំ** សេចក្តីថា អាចដឹងនូវការសម្គាល់របស់ជ័យភូមិនៃចម្បាំងគ្រប់យ៉ាង ។ បទថា **ទន្តឹ** បានដល់ ប្រកបដោយភ្លុកដែលគួរជាទីត្រេកអរ ។ បទថា **សវាលវីជនឹ** បានដល់ ប្រកបដោយផ្លិតវាលវីជនី ។ បទថា **សឧត្តរច្ឆទំ** បានដល់ ប្រកបដោយកម្រាល ។ បទថា **សាជីវំ** បានដល់ មួយអន្លើដោយហ្មដំរី ។ បទថា **សហត្ថិបំ** សេចក្តីថា មួយអន្លើដោយអ្នកចិញ្ចឹមដំរី គឺ ៥០០ ត្រកូលដែលរក្សាដំរីនិងពួកហ្មដំរី មួយអន្លើដោយពេទ្យអ្នករក្សាដំរី ។ កាលក្រាបទូលយ៉ាងនេះហើយ បានក្រាបទូលបន្តថា

ព្រះរាជបុត្តរបស់ព្រះអង្គនោះ គួរតែឲ្យបាយ ទឹក សំពត់និង

សេនាសនៈ ( ព្រោះថា ) វត្ថុទាំងឯងជារបស់គួរដល់ទាន វត្ថុទាំងឯងជារបស់គួរដល់ព្រាហ្មណ៍ ។ បពិត្រព្រះបាទសញ្ជ័យ ព្រះវេស្សន្តរជាបុត្តរបស់ព្រះអង្គនោះ ជាព្រះឱរសកើតក្នុងវង្សរបស់ព្រះអង្គ ជាអ្នកញ៉ាំងពួកអ្នកសិវិរាស្ត្រឲ្យចម្រើន ម្ដេចក៏ចែកដំរីទៅឲ្យព្រាហ្មណ៍ ។ ថាបើព្រះអង្គនឹងមិនធ្វើតាមសំដីរបស់ពួកអ្នកដែនសិវិនេះទេ មុខជាពួកអ្នកសិវិរាស្ត្រ ធ្វើព្រះអង្គព្រមទាំងព្រះរាជបុត្ត ឲ្យឋិតនៅក្នុងកណ្ដាប់ដៃមិនខាន ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **វំសរាជាគោ** បានដល់ ជាមហារាជមកតាមវង្សត្រកូល ។ បទថា **ភាជេតិ** បានដល់ ព្រះរាជទាន ។ បទថា **សិវិ-ហត្ថេ ករិស្សរេ** សេចក្ដីថា អ្នកដែនសិវិរដ្ឋទាំងឡាយនឹងធ្វើទ្រង់មួយអន្លើដោយព្រះឱរសឲ្យនៅក្នុងកណ្ដាប់ដៃរបស់ខ្លួន ។

ព្រះបាទសញ្ជ័យបានស្ដាប់ដូច្នោះ ទ្រង់សម្គាល់ថា អ្នកនគរទាំងនេះនឹងផ្ដាច់ព្រះជន្មព្រះវេស្សន្តរទើបត្រាស់ថា

ជនបទសាបសូន្យទៅចុះទាំងដែនទៀតក៏វិនាសទៅចុះ យើងនឹងមិនបណ្ដេញរាជបុត្តដែលជាអ្នកមិនប្រទូស្ត ឲ្យចេញចាកដែនរបស់ខ្លួនតាមសំដីពួកអ្នកសិវិរាស្ត្រទេ ដ្បិតកូនប្រុសនេះពិតជាកើតអំពីទ្រូងរបស់យើង ។ ជនបទសាបសូន្យទៅចុះទាំងដែនទៀតក៏វិនាសទៅចុះ យើងនឹងមិនបណ្ដេញរាជបុត្ត ដែលជាអ្នកមិនប្រទូស្តឲ្យចេញចាកដែនរបស់ខ្លួនតាម សំដីពួកអ្នក

សិរិវាស្ត្រទេ ដ្បិតកូនប្រុសនេះពិតជាកើតអំពីខ្លួនរបស់យើង ។ មួយទៀតយើងមិនគួរប្រទូស្តចំពោះកូនយើងនោះទេ ព្រោះថាកូនយើងនោះជាអ្នកមានសីលនិងវត្តដ៏ប្រសើរ តំណិះដំណៀលនឹងមានដល់យើងផង យើងត្រូវសោយបាបច្រើនផង យើងនឹងសម្លាប់វេស្សន្តរជាកូនដោយគ្រឿងសស្ត្រាដូចម្តេចបាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មាសិ** កាត់បទជា **មា អហោសិ** ។ បទថា **អរិយសីលវតោ** បានដល់ ជាអ្នកប្រកបដោយសីលនិងវត្តដ៏ប្រសើរ គឺសមាចារសម្បត្តិដ៏ប្រសើរ ។ បទថា **ឃាតយាមសេ** បានដល់ យើងនឹងសម្លាប់ ។ បទថា **ឧព្ភេយ្យំ** សេចក្តីថា មិនគប្បីប្រទូស្តកូនរបស់យើងមិនមានទោស គឺប្រាសចាកកំហុស ។

អ្នកសិរិវាស្ត្របានស្តាប់ដូច្នោះក៏ក្រាបទូលថា

សូមព្រះអង្គកុំសម្លាប់ព្រះរាជបុត្តនោះ ដោយដំបង ឬគ្រឿងសស្ត្រាឡើយព្រោះព្រះរាជបុត្តនោះមិនគួរដល់ចំណាងទេ ព្រះអង្គគ្រាន់តែបណ្តេញព្រះរាជបុត្តនោះចេញអំពីដែនទៅចុះ សូមឲ្យព្រះរាជបុត្តនោះទៅគង់នៅឯវង្កតបព៌តចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មា ឆំ ឧណ្ឌេន សត្ថេន** សេចក្តីថា បពិត្រព្រះសម្មតិទេព ទ្រង់កុំប្រហារព្រះវេស្សន្តរនោះដោយដំបង ឬដោយសស្ត្រាឡើយ ។ បទថា **ន ហិ សោ ពន្ធនារហោ** សេចក្តីថា ព្រះវេស្សន្តរនោះជាអ្នកមិនគួរដល់ចំណាងឡើយ ។

ព្រះបាទសញ្ជ័យបានស្តាប់ដូច្នោះក៏ត្រាស់ថា

ថាបើពួកអ្នកដែនសិវិ មានចំណង់បែបនេះហើយ យើងក៏មិនអាចបន្ទាបង់ចំណង់នេះបានទេ តែសូមឲ្យកូនយើងនោះ នៅបរិភោគកាមបានមួយរាត្រីនេះសិនចុះ ។ នាកាលរាត្រីនោះអស់ហើយព្រះអាទិត្យរះឡើង ទើបសូមឲ្យពួកអ្នកសិវិរាស្ត្រព្រមព្រៀងគ្នាបណ្តេញកូនរបស់យើងនោះ ចេញអំពីដែនចុះដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វសតុ** សេចក្តីថា ព្រះបាទសញ្ជ័យត្រាស់ថា វេស្សន្តរកូនរបស់យើងចូរឲ្យឱវាទដល់បុត្តនិងភរិយា ពួកអ្នកចូរឲ្យឱកាសមួយរាត្រី ។

អ្នកក្រុងសិវិទទួលព្រះតម្រាស់ថា ព្រះរាជាឱរសនោះ ចូរស្នាក់អាស្រ័យមួយរាត្រីចុះ ។ លំដាប់នោះព្រះបាទសញ្ជ័យបញ្ជូនអ្នកនគរឲ្យត្រឡប់ ហើយកាលនឹងបញ្ជូនដំណឹងដល់ព្រះរាជឱរសទើបត្រាស់ហៅអាមាត្យមកបញ្ជូនទៅកាន់សម្នាក់ព្រះរាជឱរស អាមាត្យទទួលព្រះតម្រាស់ហើយ ទៅកាន់ព្រះរាជនិវេសន៍របស់ព្រះវេស្សន្តរ ក្រាបទូលព្រឹត្តិការណ៍នោះ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសាធ្យនូវព្រះគាថាដូច្នេះថា

នែអាមាត្យ អ្នកចូរក្រោកឡើង អ្នកចូរប្រញាប់ទៅប្រាប់

វេស្សន្តរថា បពិត្រព្រះទេវៈ ពួកអ្នកសិវិរាស្ត្រ ពួកអ្នកនិគម ពួកអ្នកមានកេរ្តិ៍ឈ្មោះ ពួករាជបុត្ត ពួកអ្នកជំនួញនិងពួកព្រាហ្មណ៍មកប្រជុំគ្នាទីងទីងព្រះអង្គហើយ ។ ពួកទាហានដំរី ទាហាន ( សេះ ) ទាហានរថនិងពលថ្មើរជើង ពួកអ្នកនិគមទាំងអស់និងពួកអ្នកសិវិរាស្ត្រ ក៏មកប្រជុំគ្នាដែរ លុះរាត្រីនេះអស់ហើយព្រះអាទិត្យរះឡើង ពួកអ្នកដែនសិវិព្រមព្រៀងគ្នានឹងបណ្តេញព្រះអង្គចាកដែន ។

អាមាត្យនោះ លុះព្រះបាទសិវិទ្រង់បញ្ជូនទៅ ក៏ប្រញាប់ប្រញាល់ងូតទឹកកក់ក្បាល ពាក់គ្រឿងប្រដាប់ដៃ ស្លៀកសំពត់ល្អ ប្រោះព្រំដោយខ្លឹមចន្ទន៍ ពាក់កុណ្ឌលកែវមណីចូលទៅកាន់ព្រះរាជនិវេសន៍នៃព្រះបាទវេស្សន្តរដែលជាទីបុរីរម្យ ។ អាមាត្យនោះបានឃើញព្រះរាជកុមារ ( វេស្សន្តរ ) កំពុងរីករាយក្នុងបុរីរបស់ព្រះអង្គនោះដ៏កុះករដោយពួកអាមាត្យ ដូចព្រះវាសវៈរបស់ទេវតាជាន់ត្រៃត្រិង្ស ។

អាមាត្យនោះប្រញាប់ប្រញាល់ទៅក្នុងបុរីនោះហើយ ក្រាបទូលព្រះបាទវេស្សន្តរថា បពិត្រព្រះអង្គដ៏ប្រសើរក្នុងរថ ទូលព្រះបង្គំជាខ្ញុំនឹងក្រាបទូលសេចក្តីទុក្ខរបស់ព្រះអង្គ សូមព្រះអង្គកុំខ្ញាល់នឹងទូលព្រះបង្គំជាខ្ញុំឡើយ ។ អាមាត្យនោះលុះថ្វាយបង្គំហើយក៏យំទួញក្រាបបង្គំទូលព្រះរាជាថា បពិត្រមហារាជ ព្រះ

អគ្គរមែងនាំនូវសេជាទីប្រាថ្នាគ្រប់យ៉ាង មកចិញ្ចឹមទូលព្រះបង្គំៗ នឹងក្រាបទូលសេចក្តីទុក្ខរបស់ព្រះអង្គ សូមល្អងធូលីព្រះបាទឲ្យទូលព្រះបង្គំដកជង្រ្គឹមស្រួលក្នុងជំណើរក្រាបទូលនោះ ។ បពិត្រព្រះទេវៈ ពួកអ្នកសិវិរាស្រ្ត ពួកអ្នកនិគម ពួកអ្នកមានកេរ្តិ៍ឈ្មោះ ពួករាជបុត្ត ពួកអ្នកជំនួញនិងពួកព្រាហ្មណ៍ ប្រជុំគ្នាខឹងនឹងព្រះអង្គហើយ ។ ពួកទាហានជើរ ទាហាន ( សេះ ) ពលរថ និងពលថ្មើរជើង ព្រមទាំងអ្នកនិគមទាំងអស់និងពួកអ្នកសិវិរាស្រ្តក៏មកប្រជុំគ្នាដែរ ។ លុះរាត្រីនោះអស់ហើយព្រះអាទិត្យក៏រះឡើង ពួកអ្នកសិវិរាស្រ្តព្រមព្រៀងគ្នានឹងបណ្តេញព្រះអង្គចាកដែន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កុមារំ** បានដល់ ព្រះរាជាដែលឈ្មោះថាជាកុមារ ព្រោះនៅមានព្រះមាតានិងព្រះបិតា ។ បទថា **រមមានំ** បានដល់ ជាអ្នកមានសោមនស្ស ប្រថាប់គង់ត្រាស់សរសើរទាន ដែលទ្រង់ឲ្យហើយ ។ បទថា **អមច្ចេហិ** បានដល់ ហោមរោមទៅដោយពួកអាមាត្យដែលជាសហជាតប្រមាណ ៦ ម៉ឺននាក់ គង់ប្រថាប់លើព្រះរាជអាសនៈ ក្រោមស្វេតច្ឆត្រដែលលើកឡើងហើយ ។ បទថា **វេទយិស្សាមិ** បានដល់ នឹងក្រាបទូល ។ អាមាត្យក្រាបទូលពាក្យថា **តត្ថ អស្សាសយន្តុ មំ** ដោយបំណងថា បពិត្រព្រះសម្មតិទេព កាលជំណឹងសម្តែងនូវសេចក្តីទុក្ខនោះដែលទូលព្រះបង្គំក្រាបទូលហើយ សូមទ្រង់ញ៉ាំងទូលព្រះបង្គំដែលលំបាកឲ្យធូរស្បើយ គឺសូមទ្រង់

ត្រាស់នឹងទូលព្រះបន្ទំថា ចូរអ្នកពោលតាមសប្បាយចុះ ។ ព្រះពោធិសត្វត្រាស់ថា

ព្រោះដំណើរដូចម្តេច បានជាពួកអ្នកសិវិរាស្ត្រ ខឹងនឹងយើង ដ្បិតយើងរកមិនឃើញអំពើអាក្រក់ទេ ម្នាលអាមាត្យ អ្នកចូរប្រាប់ដំណើរនោះដល់យើង ព្រោះហេតុអ្វីបានជាគេបណ្តេញដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កិស្មឹ** បានដល់ ព្រោះហេតុអ្វី ។ បទថា **វិយាចិក្ខ** សេចក្តីថា ចូរពោលដោយពិស្តារ ។

អាមាត្យក្រាបទូលថា

ពួកអ្នកមានកេរ្តិ៍ឈ្មោះ ពួករាជបុត្ត ពួកអ្នកជំនួញ ពួកព្រាហ្មណ៍ ពួកទាហានដំរី ទាហាន ( សេះ ) ពលរថនិងពលថ្មើរជើងខឹងនឹងព្រះអង្គព្រោះតែការប្រទានដំរី ហេតុនោះបានជាគេបណ្តេញព្រះអង្គ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ខីយន្តិ** បានដល់ អាក់អន់ ។ ព្រះមហាសត្វបានស្តាប់ដូច្នោះក៏ទ្រង់សោមនស្សត្រាស់ថា

យើងចង់ឲ្យបេះដូង ឬភ្នែកផង ទ្រព្យជាខាងក្រៅរបស់យើង គឺប្រាក់ មាស កែវមុក្តា កែវពិទូរ្យនិងកែវមណីជាប្រយោជន៍អ្វី បើយើងបានឃើញស្មូមមកសុំដៃស្តាំឬដៃឆ្វេង គួរតែឲ្យមិនគប្បីរំកើបទេ ( ព្រោះថា ) ចិត្តរបស់យើងរីករាយក្នុងការឲ្យ

( ទាន ) ។ ពួកអ្នកសិវិរាស្ត្រទាំងអស់នោះចង់បណ្តេញ ឬចង់សម្លាប់យើងក៏ដោយចុះ យើងនឹងមិនវៀរចាកការឲ្យ ( ទាន ) ទេ អ្នកដែនទាំងអស់ចង់កាត់យើងជាប្រាំពីរកំណាត់ ក៏ដោយចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យាចកមាគតេ** សេចក្តីថា កាលយាចកមកហើយបានឃើញយាចកនោះ ។ បទថា **នេវ ទានា វិរមិស្សំ** សេចក្តីថា នឹងមិនវៀរចាកការឲ្យទានជាដាច់ខាត ។

អាមាត្យស្តាប់ដូច្នោះ កាលក្រាបទូលតាមមតិរបស់ខ្លួន ដែលព្រះបាទសញ្ជ័យឬអ្នកនគរមិនបានឲ្យទូលឡើយទើបក្រាបទូលថា

ពួកអ្នកសិវិរាស្ត្រនិងពួកអ្នកនិគម ប្រជុំគ្នានិយាយអំពីព្រះអង្គយ៉ាងនេះថា ពួកអ្នកទោសត្រូវនិរទេស តែងទៅតាមច្រាំងទន្លេកោន្តិមារាណាព្រះបាទវេស្សន្តរដែលមានវត្តល្អ ចូរយាងសំដៅទៅកាន់ភ្នំអារញ្ជរតាមច្រាំងទន្លេកោន្តិមារានោះចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កោន្តិមារាយ** បានដល់ តាមច្រាំងនៃស្ទឹងឈ្មោះថា កោន្តិមារា ។ បទថា **គិរិមារញ្ជរំ បតិ** សេចក្តីថា ជាអ្នកមានមុខត្រង់ឆ្ពោះភ្នំឈ្មោះអារញ្ជរៈ ។ បទថា **យេន** សេចក្តីថា អាមាត្យក្រាបទូលថា អ្នកសិវិទាំងឡាយពោលយ៉ាងនេះថា ព្រះរាជាទាំងឡាយដែលត្រូវនិរទេសហើយរមែងទៅអំពីដែនដោយផ្លូវណា សូមឲ្យព្រះវេស្សន្តរដែលមានវត្តល្អ ក៏ចូរទៅតាមផ្លូវនោះ បានឮថា អាមាត្យនោះត្រូវទេវតាបណ្តាលចិត្តទើបពោល

ពាក្យនេះ ។

ព្រះមហាសត្វបានស្តាប់ដូច្នោះ ទើបត្រាស់ថា សាធុ យើងនឹងទៅដោយផ្លូវដែលទៅនៃព្រះរាជាទាំងឡាយ ដែលជាអ្នកទទួលទោស តែអ្នកនគរទាំងឡាយមិនបានដេញយើងដោយទោសដទៃ ដេញយើងព្រោះយើងឲ្យដំរីជាទាន កាលបើដូច្នេះ យើងនឹងឲ្យសត្តមហាទានមួយថ្ងៃ អ្នកនគរចូរឲ្យឱកាសដើម្បីយើងបានឲ្យទានត្រឹមតែមួយថ្ងៃ ស្អែកឡើងយើងឲ្យទានហើយនឹងទៅក្នុងថ្ងៃទី ៣ ទើបត្រាស់ថា

ពួកជនអ្នកប្រទូស្ត តែងទៅតាមផ្លូវណា យើងនឹងទៅតាមផ្លូវ
នោះឯង តែសូមឲ្យអ្នកទាំងឡាយអត់ទោសឲ្យយើងបានមួយ
យប់មួយថ្ងៃ ចាំយើងឲ្យទានសិន ដូច្នេះ ។

អាមាត្យបានស្តាប់ដូច្នោះហើយក្រាបទូលថា សាធុព្រះអង្គ ទូលព្រះបង្គំនឹងប្រាប់សេចក្តីនោះដល់អ្នកនគរនិងដល់ព្រះរាជា ទូលដូច្នេះហើយក៏ចៀសចេញទៅ ។

ព្រះមហាសត្វបញ្ជូនអាមាត្យនោះទៅហើយ ទើបហៅមហាសេនាគុត្តៈមកគាល់ ត្រាស់ឲ្យរៀបចំសត្តសតកមហាទានថា ស្អែកនេះយើងនឹងបរិច្ចាគសត្តសតកមហាទាន អ្នកទាំងឡាយចូររៀបចំដំរី ៧០០ សេះ ៧០០ រថ ៧០០ ស្ត្រី ៧០០ គោទឹកដោះ ៧០០ ទាសៈ ៧០០ ទាសី ៧០០ ចូរតម្កល់បាយទឹកជាដើម មានប្រការផ្សេងៗដោយហោចសូម្បីស្រាដែលជារបស់មិនគួរឲ្យ ហើយបញ្ជូនអាមាត្យទាំងឡាយឲ្យត្រឡប់ យាងទៅកាន់ទីប្រថាប់របស់

នាងមទ្រីតែមួយព្រះអង្គឯង គង់ប្រថាប់លើកម្រាលដ៏មានសិរីត្រាស់នឹងនាងមទ្រីនោះ ។

**តមត្ថំ បក្កាសេន្តោ សត្ថា អាហា** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសាន្ទូវព្រះគាថាដូច្នេះថា

ព្រះរាជាទ្រង់ត្រាស់ហៅព្រះនាងមទ្រីទេវី ដែលមានអវយវៈល្អ
ទាំងអស់នោះមកប្រាប់ថា ទ្រព្យស្រូវណាមួយដែលយើងឲ្យដល់
នាងនៅមានក្តី ប្រាក់មាសកែវមុក្តាកែវពិទូរ្យណា ដ៏ច្រើនក្តី
ទ្រព្យណាជារបស់ព្រះបិតានាងក្តី នាងគប្បីកប់ទ្រព្យទាំងអស់
នោះទុកចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **និធេហេយ្យាសិ** សេចក្តីថា ចូរនាងកប់ទ្រព្យនោះទុក ។ បទថា **បេត្តិកំ** បានដល់ ដែលនាងនាំមកអំពីព្រះជនក ។

ព្រះរាជបុត្រីទ្រង់ព្រះនាមមទ្រី ដែលមានអវយវៈល្អទាំងអស់
បានក្រាបបង្គំទូលសួរព្រះរាជានោះថា បពិត្រព្រះទេវៈ ខ្ញុំម្ចាស់
នឹងកប់ក្នុងទីណា ខ្ញុំម្ចាស់ក្រាបទូលសួរហើយ សូមព្រះអង្គ
ប្រាប់ដំណើរនោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តមព្រវិ** សេចក្តីថា ព្រះនាងមទ្រីមានព្រះតម្រិះថា ព្រះវេស្សន្តរស្វាមីរបស់អញមិនធ្លាប់ត្រាស់ថា ចូរនាងកប់ទ្រព្យអស់កាលមានប្រមាណប៉ុណ្ណេះតែពេលនេះទ្រង់ត្រាស់ អញនឹងទូលសួរថាទ្រព្យ

នោះទ្រង់ឲ្យកប់ក្នុងទីណាហ្ន៎ ទើបទូលសួរព្រះវេស្សន្តរនោះ ។

ព្រះវេស្សន្តរបរមក្សត្រក៏មានព្រះតម្រាស់ថា

ម្នាលនាងមទ្រី នាងគួរឲ្យទានចំពោះអ្នកមានសីលទាំងឡាយ តាមសមគួរ ព្រោះថា ទីពឹងរបស់សព្វសត្វដទៃក្រៅអំពីទាន មិនមានទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧជ្ជេសិ** សេចក្តីថា នែនាងមទ្រីដ៏ចម្រើន នាងកុំកប់ទ្រព្យមានក្នុងឃ្លាំងជាដើម កាលកប់ចូរកប់ទ្រព្យដែលជាប់តាមខ្លួនទៅ គប្បីឲ្យទានក្នុងបុគ្គលមានសីលទាំងឡាយក្នុងដែនរបស់យើង ។ បទថា **ន ហិ ទានា បរំ** សេចក្តីថា ឈ្មោះថា ទីពឹងអាស្រ័យដែលក្រៃលែងជាងទានមិនមានឡើយ ។

ព្រះនាងមទ្រីត្រាស់ថា សាធុ ។ កាលនោះព្រះបរមពោធិសត្វកាលនឹងប្រទានព្រះឱវាទដល់នាងឲ្យក្រៃលែងទើបត្រាស់ថា

ម្នាលនាងមទ្រី នាងត្រូវមេត្តាបុត្ត ព្រះមាតាក្មេកនិងព្រះបិតាក្មេក មួយទៀតបើអ្នកណាសំគាល់ថានឹងធ្វើជាប្តីនាង នាងចូរបម្រើអ្នកនោះដោយគោរពចុះ ។ បើគ្មានគេសំគាល់ថានឹងធ្វើជាប្តីនាងទេ កាលនាងព្រាត់ប្រាសអំពីយើងទៅហើយ នាងចូរស្វែងរកប្តីដទៃទៀតចុះ កុំឲ្យនាងលំបាកព្រោះព្រាត់ប្រាសអំពីយើងឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧយេសិ** សេចក្តីថា គប្បីអាណិតអាសូរ គឺ

ធ្វើនូវមេត្តា ។ បទថា **យោ ច តំ ភត្តា មញ្ញេយ្យ** សេចក្តីថា នែនាង បើអញទៅហើយ បើស្តេចណាមកសម្គាល់ថា ខ្ញុំជាកស្តាររបស់នាង នាងគប្បីបម្រើស្តេចនោះដោយគោរព ។ បទថា **មយា វិប្បវសេន តេ** សេចក្តីថា បើបុគ្គលណាមិនសម្គាល់ថា យើងនឹងជាប្តីរបស់នាង ព្រោះនាងមិនបាននៅជាមួយអញ កាលបើដូច្នោះចូរនាងស្វែងរកប្តីដទៃដោយខ្លួនឯងចុះ ។ បទថា **មា កិលិត្ថ មយា វិនា** សេចក្តីថា នាងប្រាសព្រាត់អំពីអញហើយកុំលំបាក គឺកុំលំបាកឡើយ ។

កាលនោះព្រះនាងមទ្រីមានព្រះតម្រិះថា ព្រះវេស្សន្តរព្រះកស្តាររបស់អញត្រាស់ពាក្យនេះព្រោះហេតុអ្វីហ្ន៎ ទើបក្រាបទូលសួរថា បពិត្រព្រះសម្មតិទេពទ្រង់ត្រាស់វាចាមិនសមគួរនេះ ព្រោះហេតុអ្វី ។ លំដាប់នោះព្រះវេស្សន្តរក៏ត្រាស់នឹងព្រះនាងថា នែមទ្រីដ៏ចម្រើន អ្នកដែនសិវិអាក់អន់ក្នុងអញព្រោះឲ្យនូវដំរីទើបបំបរបង់អញចាកដែន ស្អែកនេះអញនឹងឲ្យសត្តកមហាទានហើយនឹងចេញអំពីព្រះនគរក្នុងថ្ងៃទី ៣ ត្រាស់ដូច្នេះហើយក៏មានព្រះតម្រាស់ថា

ព្រោះយើងនឹងទៅកាន់ព្រៃ ប្រកបដោយម្រឹគសាហាវពន្ទឹក
សេចក្តីសង្ស័យនឹងជីវិត រមែងមានដល់យើងដែលនៅម្នាក់ឯង
ក្នុងព្រៃធំ ដូច្នេះ ។

បណ្តាបទទាំងនោះព្រះវេស្សន្តរពោលពាក្យថា **សំសយោ** ដោយបំណងថា កាលអញដែលជាសុខុមាលជាតិដោយចំណែកមួយនៅក្នុងព្រៃដែលមានសត្រូវមិនតិច នឹងមានជីវិតអំពីណា អញនឹងស្លាប់ពិត ។

ព្រះរាជបុត្រីទ្រង់ព្រះនាមមទ្រី មានអវយវៈល្អទាំងអស់ នាង បានក្រាបទូលព្រះបាទវេស្សន្តរនោះថា ប្តីក៏ព្រះអង្គមានព្រះ បន្ទូលនូវព្រះវាចាដែលមិនធ្លាប់មាន ព្រះអង្គមានព្រះបន្ទូលនូវ ព្រះវាចាដ៏អាក្រក់អ្វីម៉្លេះ ។ បពិត្រមហារាជ ដំណើរនោះមិន ត្រូវតាមធម៌ទេ ដ្បិតព្រះអង្គទ្រង់ស្តេចយាងទៅតែមួយអង្គឯង បពិត្រក្សត្រិយ៍ ព្រះអង្គស្តេចយាងទៅតាមផ្លូវណា ខ្ញុំម្ចាស់ នឹងទៅតាមផ្លូវនោះដែរ ។ សេចក្តីស្លាប់ជាមួយនឹងព្រះអង្គក្តី សេចក្តីរស់នៅតែព្រាត់ប្រាសចាកព្រះអង្គក្តី សេចក្តីស្លាប់នោះ ឯងប្រសើរជាង ខ្ញុំម្ចាស់រស់នៅតែព្រាត់ប្រាសចាកព្រះអង្គមិន ប្រសើរទេ ។ ខ្ញុំម្ចាស់នឹងដុតភ្លើង ឲ្យមានអណ្តាតឆេះមូល ទ្រលោម សេចក្តីស្លាប់នៅក្នុងភ្លើងនោះឯងប្រសើរជាង ខ្ញុំម្ចាស់ រស់នៅតែព្រាត់ប្រាសចាកព្រះអង្គមិនប្រសើរទេ ។ មេដំរីតែង ដើរតាមដំរីឈ្មោលដែលមានភ្លុកល្អដែលនៅក្នុងព្រៃ កាលត្រាច់ ទៅក្នុងជ្រោះ ជ្រលងភ្នំស្មើខ្ពស់ មិនស្មើខ្ពស់យ៉ាងណាមិញ ។ ខ្ញុំ ម្ចាស់នឹងនាំបុត្តទាំងឡាយ ដើរតាមក្រោយព្រះអង្គយ៉ាងនោះ ដែរ ខ្ញុំម្ចាស់ជាស្រីដែលព្រះអង្គចិញ្ចឹមបានដោយងាយ មិន មែនជាស្រីដែលព្រះអង្គចិញ្ចឹមបានដោយក្រទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អភុម្មេ** សេចក្តីថា ទ្រង់ត្រាស់នឹងខ្ញុំនូវវាចា ដែលមិនធ្លាប់មានហ្ន៎ ។ បទថា **គច្ឆេយ្យ** បានដល់ យាងទៅ ។ បទថា

**នេស ធម្មោ** សេចក្ដីថា នុ៎ះមិនមែនជាសភាវៈ គឺនោះមិនមែនហេតុ ។ បទថា **តនេវ** សេចក្ដីថា ខ្ញុំស្វាប់ជាមួយទ្រង់នោះឯងប្រសើរជាង ។ បទថា **តត្ថ** បានដល់ ក្នុងជើងថ្ករដែលមានសុទ្ធតែអណ្ដាតភ្លើង ។ បទថា **ជេស្សន្តំ** បានដល់ ត្រាច់ទៅ ។

ព្រះនាងមទ្រីរាជកញ្ញាក្រាបទូលព្រះស្វាមីយ៉ាងនោះហើយ កាលទ្រង់ពណ៌នាដល់ហិមវន្តប្បទេសហាក់ដូចជាធ្លាប់ទតឃើញ ដោយព្រះសវនីយ៍ថា

ព្រះអង្គកាលទតឃើញកុមារទាំងនេះ ដែលមានសំឡេងពីរោះ និយាយសំដីជាទីស្រឡាញ់ អង្គុយក្បែរគុម្ពឈើនឹងមិនរឭករាជសម្បត្តិ ។ ព្រះអង្គកាលទតឃើញកុមារទាំងនេះ មានសំឡេងពីរោះនិយាយសម្ដីជាទីស្រឡាញ់ កំពុងលេងក្បែរគុម្ពឈើនឹងមិនរឭករាជសម្បត្តិ ។ ព្រះអង្គកាលទតឃើញកុមារទាំងនេះមានសំឡេងពីរោះ និយាយពាក្យជាទីស្រឡាញ់ ក្នុងអាស្រមជារមណីយដ្ឋាន នឹងមិនរឭករាជសម្បត្តិ ។ ព្រះអង្គកាលទតឃើញរាជកុមារទាំងនេះមានសំឡេងពីរោះ និយាយពាក្យជាទីស្រឡាញ់ កំពុងលេងក្បែរអាស្រមជាទីត្រេកអរនឹងមិនរឭករាជសម្បត្តិ ។ ព្រះអង្គកាលទតឃើញកុមារទាំងនេះពាក់កម្រងផ្កា មានខ្លួនប្រដាប់ហើយក្នុងអាស្រមជារមណីយដ្ឋាន នឹងមិនរឭករាជសម្បត្តិ ។ ព្រះអង្គកាលទតឃើញកុមារទាំងនេះពាក់កម្រងផ្កា មានខ្លួនប្រដាប់ហើយកំពុងលេងក្បែរអាស្រម

ដែលជាទីត្រេកអរនឹងមិនរឭករាជសម្បត្តិ ។ កាលណាព្រះអង្គ ទតឃើញកុមារពាក់កម្រងផ្កា កំពុងរាំក្នុងអាស្រមជារមណីយ-ដ្ឋាន នឹងមិនរឭករាជសម្បត្តិ ។ កាលណាព្រះអង្គទតឃើញ កុមារពាក់កម្រងផ្កា កំពុងរាំលេងក្នុងអាស្រមជាទីត្រេកអរនឹង មិនរឭករាជសម្បត្តិ ។ កាលណាព្រះអង្គទតឃើញដំរីធំជាកុ-ញ្ជរជាតិ មានអាយុ ៦០ ឆ្នាំ ត្រាច់ទៅក្នុងព្រៃតែម្នាក់ឯងនឹង មិនរឭករាជសម្បត្តិ ។ កាលណាព្រះអង្គទតឃើញដំរីធំ ជា កុញ្ជរជាតិមានអាយុ ៦០ ឆ្នាំ ត្រាច់ទៅមករាល់ល្ងាចរាល់ព្រឹក នឹងមិនរឭករាជសម្បត្តិ ។ កាលណាដំរីធំជាកុញ្ជរជាតិ មាន អាយុ ៦០ ឆ្នាំ កាលដើរទៅខាងមុខនៃហ្វូងដំរីញីនិងហ្វូងដំរី ឈ្មោលហើយបន្លឺកោញ្ចនាទ ព្រះអង្គបានទ្រង់ព្រះសណ្តាប់ ដំរីបន្លឺកោញ្ចនាទនោះហើយ នឹងមិនរឭករាជសម្បត្តិ ។ កាល ណាព្រះអង្គទតឃើញជងព្រៃសងខាងផ្លូវ ជាទីឲ្យសេចក្តីប្រាថ្នា ក្នុងព្រៃដ៏ដេរដាសដោយម្រឹគសាហាវ នឹងមិនរឭករាជសម្បត្តិ ។ ព្រះអង្គទតឃើញម្រឹគជាបញ្ចមាលិនីដើរមក នឹងឃើញពួក កិន្នរដែលកំពុងរាំក្នុងវេលាល្ងាច នឹងមិនរឭករាជសម្បត្តិ ។ កាលណាព្រះអង្គឮស្កូរសំឡេងគឹកកងនៃទន្លេកំពុងហូរទៅផង ឮចម្រៀងនៃពួកកិន្នរផង នឹងមិនរឭករាជសម្បត្តិ ។ កាលណា ព្រះអង្គឮស្កូរសំឡេងគឹកកងនៃសត្វមៀម ដែលត្រាច់ក្នុងញក

នៃភ្នំនឹងមិនរឭករាជសម្បត្តិ ។ កាលណាព្រះអង្គឮសូរសំឡេងគឹកកងនៃម្រឹគសាហាវក្នុងព្រៃ គឺរាជសីហ៍ ខ្លាធំ រមាស គោព្រៃ នឹងមិនរឭករាជសម្បត្តិ ។ កាលណាព្រះអង្គទតឃើញក្ងោកឈ្មោលដែលមានពួកក្ងោកញីចោមរោម ជាសត្វដេរដាសដោយសំណុំកន្ទុយ ទំលើកំពូលភ្នំកំពុងពែនពង់ នឹងមិនរឭករាជសម្បត្តិ ។ កាលណាព្រះអង្គទតឃើញក្ងោកឈ្មោល ដែលមានក្ងោកញីចោមរោម ជាអណ្ឌជាតិ មានស្លែកដ៏វិចិត្រ កំពុងពែនពង់ នឹងមិនរឭករាជសម្បត្តិ ។ កាលណាព្រះអង្គទតឃើញក្ងោកឈ្មោលដែលមានក្ងោកញីចោមរោម ជាសត្វមានផ្លត់កខៀវ មានកំប៉ោយ កំពុងពែនពង់ នឹងមិនរឭករាជសម្បត្តិ ។ កាលណាព្រះអង្គទតឃើញដើមឈើទាំងឡាយ មានផ្ការីកក្នុងហេមន្តរដូវ ផ្សព្វផ្សាយដោយក្លិនក្រអូប នឹងមិនរឭករាជ-សម្បត្តិ ។ កាលណាព្រះអង្គទតឃើញផែនដី មានស្មៅខៀវខ្ចីក្នុងខែខាងក្នុងហេមន្តរដូវដ៏ដេរដាសដោយមេក្អៀង នឹងមិនរឭករាជសម្បត្តិ ។ កាលណាព្រះអង្គទតឃើញដើមឈើទាំងឡាយដែលមានផ្ការីកស្កុសស្កាយ ក្នុងហេមន្តរដូវផង ដើមខ្ទឹងគន់និងឈើដែលមានត្រួយ មានស្លឹកក្រហមផង ដើមលោទនិងដើមឈូក មានផ្ការីកផ្សព្វផ្សាយក្លិនក្រអូបផង នឹងមិនរឭករាជសម្បត្តិ ។ កាលណាព្រះអង្គទតឃើញព្រៃមានផ្ការីកក្នុង

ខែខាងក្នុងហេមន្តរដូវផង ឈូកទាំងឡាយមានផ្កាជ្រុះហើយ
ផង នឹងមិនរឭករាជសម្បត្តិ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មញ្ជុកេ** បានដល់ មានសំឡេងពីរោះមាន ពាក្យពីរោះ ។ បទថា **ករេណុសង្ឃស្ស** បានដល់ ហ្វូងដំរីញី ។ បទថា **យូថស្ស** បានដល់ ទៅខាងមុខហ្វូងដំរី ។ បទថា **ឧភតោ** បានដល់ សង ខាងផ្លូវ ។ បទថា **វនវិកាសេ** បានដល់ ព្រៃក្រាស់ ។ បទថា **កាមទំ** បានដល់ ឲ្យវត្ថុដែលគួរប្រាថ្នាគ្រប់យ៉ាងដល់ខ្ញុំ ។ បទថា **សិង្គុយា** បានដល់ ស៊ីង ។ បទថា **វសមានស្សស្សុកស្ស** បានដល់ សត្វមៀមដែលកំពុងទំ ។ បទថា **វាឡានំ** បានដល់ ពាលម្រឹគទាំងឡាយ ។ ដ្បិតថាក្នុងវេលាល្ងាច សំឡេងនៃរាជសីទាំងនោះជាដើមហាក់បីដូចជាសំឡេងតន្ត្រីដែលប្រកបដោយ អង្គ ៥ ព្រោះហេតុនោះ ទើបព្រះនាងមទ្រីទូលថា កាលណាព្រះអង្គឮស្នូរ សំឡេងគឹកកងនៃម្រឹគសាហាវក្នុងព្រៃ នឹងមិនរឭករាជសម្បត្តិ ។ បទថា **វ-រហិនំ** បានដល់ គ្របដណ្តប់ដោយសំណុំកន្ទុយ ។ បទថា **មត្តកាសិនំ** បាន ដល់ ទំត្រង់កំពូលភ្នំជានិច្ច បាឋៈថា **មត្តកាសិនំ** ក៏មាន សេចក្តីថា ជា សត្វស្រវឹងដោយការស្រវឹងក្នុងកាមទំនៅ ។ បទថា **តិម្ពជាលំ** បានដល់ ដើមឈើដែលមានត្រួយពណ៌ក្រហម ។ បទថា **ឱបុប្ផានិ** បានដល់ មានផ្កា សំយុងចុះ គឺមានផ្កាជ្រុះចុះ ។

ព្រះនាងមទ្រីពណ៌នាដល់ហិមវន្តប្បទេស ដោយគាថាមានប្រមាណ ប៉ុណ្ណេះហាក់ដូចជាព្រះនាងធ្លាប់អាស្រ័យនៅក្នុងហិមវន្តប្បទេសដូច្នោះឯង ។

**ហិមវន្តវណ្ណនា ចប់**

## ធានកាណ្ឌ

សូម្បីព្រះនាងផុស្សតីរាជទេវីមានព្រះតម្រិះថា សេចក្ដីក្ដៅក្រហាយមកដល់កូនរបស់អញ កូនរបស់អញនឹងធ្វើដូចម្ដេចហ្ន៎ អញនឹងទៅឲ្យដឹងសេចក្ដី ទើបយាងទៅដោយវិមាសដែលមានវាំងននបិទជិត គង់ត្រង់ទ្វារបន្ទប់ដ៏មានសិរីបានស្ដាប់សំឡេងសន្ទនានៃស្ដេចទាំង ២ អង្គ គឺព្រះវេស្សន្តរនិងព្រះនាងមទ្រី ព្រះនាងក៏ទ្រង់ព្រះកន្សែង ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** វីអាចិជមិឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសាទូវព្រះគាថាដូច្នេះថា

ព្រះនាងផុស្សតី ជារាជបុត្រីមានយស បានទ្រង់ព្រះសណ្ដាប់ការបរបាចនៃព្រះរាជបុត្តនិងព្រះរាជសុណិសា ទាំងនោះហើយ ទ្រង់ព្រះកន្សែង មុខគួរអណោចអធម្មថា ឱអាត្មាអញគួរតែបរិភោគថ្នាំពិស ឬអាត្មាអញលោតទម្លាក់ខ្លួនក្នុងជ្រោះ ... ពុំនោះចង ( ក ) នឹងខ្សែ ( ឲ្យស្លាប់ ) ប្រសើរជាង ។ ម្ដេចឡើយក៏ពួកអ្នកសិវិរាស្ត្របណ្ដេញបាវេស្សន្តរជាកូនអញដែលជាអ្នកមិនប្រទូស្ត ។ ម្ដេចឡើយក៏ពួកអ្នកសិវិរាស្ត្របណ្ដេញបាវេស្សន្តរជាកូនអញដែលជាអ្នកចេះចប់ត្រៃវេទ ជាម្ចាស់ទាន ជាអ្នកគួរដល់ស្ដូម ឥតមានសេចក្ដីកំណាញ់ ជាអ្នកមិនប្រទូស្ត ។ ម្ដេចឡើយក៏ពួកអ្នកសិវិរាស្ត្រ បណ្ដេញបាវេស្សន្តរ ជាកូនអញ

ដែលពួកព្រះរាជាប្រទេសដទៃបូជា មានកិត្តិយស ជាអ្នកមិន
ប្រទូស្ត ។ ម្តេចឡើយក៏ពួកអ្នកសិវិរាស្រ្តបណ្តេញបាវេស្សន្តរ
ជាកូនអញ ដែលជាបុគ្គលចិញ្ចឹមមាតានិងបិតា ជាអ្នកគោរព
ចំពោះបុគ្គលជាធំក្នុងត្រកូល ជាអ្នកមិនប្រទូស្ត ។ ម្តេចឡើយ
ក៏ពួកអ្នកសិវិរាស្រ្តបណ្តេញបាវេស្សន្តរជាកូនអញ ជាប្រយោ-
ជន៍ដល់ព្រះរាជា ជាប្រយោជន៍ដល់ទេវតា ជាប្រយោជន៍ដល់
ពួកញាតិនិងសម្លាញ់ ជាប្រយោជន៍ដល់អ្នកដែនទាំងអស់ ជា
អ្នកមិនប្រទូស្ត ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **រាជបុត្តី** បានដល់ ព្រះនាងផុស្សតីរាជធីតា របស់ព្រះបាទមទ្ទរាជ ។ បទថា **បបតេយ្យហំ** កាត់បទជា **បបតេយ្យំ អហំ** ។ បទថា **រជ្ជុយា ពជ្ឈមិយាហំ** សេចក្តីថា អញគប្បីយកខ្សែចងកឲ្យស្លាប់ ។ បទថា **កស្មា** សេចក្តីថា កាលអញនៅមានជីវិតយ៉ាងនេះ ហេតុអ្វីទើបអ្នកដែនសិវិបណ្តេញកូនរបស់អញ ដែលមិនមានកំហុស ។ បទថា **អជ្ឈាយកំ** សេចក្តីថា ដែលដល់នូវត្រើយនៃវេទ គឺដល់នូវការសម្រេចក្នុងសិប្បៈផ្សេងៗ ។

ព្រះនាងផុស្សតីខ្សឹកខ្សួល មុខគួរអណោចយ៉ាងនេះហើយ ព្រះនាងលួងលោមព្រះរាជឱរសនិងកូនប្រសាឲ្យធូរស្បើយព្រះហឫទ័យ ហើយយាងទៅគាល់ព្រះបាទសញ្ជ័យហើយក្រាបទូលថា

ដៃនរបស់ព្រះអង្គ មុខជានឹងសាធារណ៍ដល់ជនទាំងឡាយ ដូច
ផ្លិតឃ្មុំដែលមេឃ្មុំហើរចោល ពុំនោះដូចផ្លែស្វាយដែលជ្រុះលើ

ផែនដី ( ព្រោះ ) ពួកអ្នកសិវិរាស្ត្របណ្តេញវេស្សន្តរជាអ្នក
មិនប្រទូស្ត ។ ព្រះអង្គដែលពួកអាមាត្យបោះបង់ហើយ ជាព្រះ
រាជាម្នាក់ឯងរមែងនឿយព្រួយ ដូចហង្សដែលអស់ស្លាបលើកក់
ដែលគ្មានទឹក ។ បពិត្រមហារាជ ព្រោះហេតុនោះបានជាខ្ញុំ
ម្ចាស់ក្រាបទូលព្រះអង្គ កុំឲ្យប្រយោជន៍កន្លងផុតព្រះអង្គឡើយ
សូមព្រះអង្គកុំបំបរបង់វេស្សន្តរ ដែលជាអ្នកមិនប្រទូស្តនោះតាម
សម្តីពួកអ្នកសិវិរាស្ត្រឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បលិតានិ** បានដល់ ដូចសម្បុកឃ្មុំដែល
មេហើរចេញទៅហើយ ។ បទថា **បតិតា ឆមា** បានដល់ ដូចផ្លែស្វាយទុំ
ដែលជ្រុះលើផែនដី ។ ព្រះនាងផុស្សតីសម្តែងថា បពិត្រព្រះសម្មតិទេព កាល
បណ្តេញកូនរបស់ខ្ញុំម្ចាស់ទៅយ៉ាងនេះហើយ ដែនរបស់ទ្រង់នឹងជាសាធារណៈ
ដល់មនុស្សទូទៅ ។ បទថា **និក្ខីណបត្តោ** បានដល់ មានរោមស្លាបជ្រុះ
ហើយ ។ បទថា **អបវិដ្ឋោ អមច្ចេហិ** សេចក្តីថា ពួកអាមាត្យ ៦ ម៉ឺន
ដែលជាសហជាតិជាមួយកូនរបស់អញ លះចោលហើយ ។ បទថា **វិហិ-
យ្យសិ** បានដល់ នឹងលំបាក ។ បទថា **សិវីនំ វចនា** សេចក្តីថា សូមទ្រង់
កុំបំបរបង់កូនខ្ញុំដែលមិនមានកំហុសនោះតាមពាក្យរបស់អ្នកសិវិរាស្ត្រឡើយ ។
ព្រះបាទសញ្ជ័យបានស្តាប់ដូច្នោះ ទើបត្រាស់ថា

យើងបណ្តេញបាវេស្សន្តរដែលជាទង់ជ័យនៃពួកអ្នកសិវិរាស្ត្រ
ឈ្មោះថា ធ្វើនូវសេចក្តីគោរពចំពោះបវេណីធម៌ ទុកជាបា

វេស្សន្តរ ជាទីស្រឡាញ់ដ៏លើសជាងជីវិតរបស់យើង ក៏យើង
នៅតែបណ្តេញបាវេស្សន្តរ ដែលជាកូនរបស់យើងមិនខាន
ដូច្នេះ ។

អត្ថនៃគាថានោះថា នៃនាងផុស្សតីដ៏ចម្រើន កាលអញបណ្តេញ គឺនិរ-ទេសវេស្សន្តរកូនអញដែលជាទង់ជ័យរបស់អ្នកសិវិក៏ធ្វើដោយការកោតក្រែងចំពោះរាជបវេណីធម៌បុរាណក្នុងសិវិរដ្ឋ ព្រោះហេតុនោះទោះបីវេស្សន្តរនោះជាទីស្រឡាញ់ជាងជីវិតរបស់អញ ក៏ត្រូវតែបំបរបង់ ។

ព្រះនាងផុស្សតីទេវីបានស្តាប់ដូច្នោះព្រះនាងក៏ខ្សឹកខ្សួលថា

ក្នុងកាលមុនចុងទង់ជ័យទាំងឡាយ ដូចជាផ្កាកណិការរីករមែង
ទៅតាមបាវេស្សន្តរណាកាលទៅ ( កាន់ឧទ្យានជាដើម ) តែ
ក្នុងថ្ងៃនេះបាវេស្សន្តរនោះនឹងទៅតែម្នាក់ឯង ។ ក្នុងកាលមុន
ចុងទង់ជ័យទាំងឡាយ ដូចជាព្រៃផ្កាកណិការ រមែងទៅតាមបា
វេស្សន្តរណាកាលទៅ ( កាន់ឧទ្យានជាដើម ) តែក្នុងថ្ងៃនេះ
បាវេស្សន្តរនោះ នឹងទៅតែម្នាក់ឯង ។ ក្នុងកាលមុនពលទាំង
ឡាយដូចជាដើមកណិការរីក រមែងទៅតាមបាវេស្សន្តរណា
កាលទៅ ( កាន់ឧទ្យានជាដើម ) តែក្នុងថ្ងៃនេះបាវេស្សន្តរនោះ
នឹងទៅតែម្នាក់ឯង ។ ក្នុងកាលមុនពលទាំងឡាយ ដូចជាព្រៃ
ផ្កាកណិការរមែងទៅតាមបាវេស្សន្តរណា កាលទៅ ( កាន់
ឧទ្យានជាដើម ) តែក្នុងថ្ងៃនេះបាវេស្សន្តរនោះនឹងទៅតែម្នាក់

ឯង ។ ពួកសេនាស្លៀកសំពត់កម្ពលមានពណ៌លឿង ដែលកើតក្នុងដែនគន្ធារៈ មានរស្មីដូចជាសម្បុរមេភ្លៀង រមែងទៅតាមបាវេស្សន្តរណាកាលទៅ ( កាន់ឧទ្យានជាដើម ) តែក្នុងថ្ងៃនេះបាវេស្សន្តរនោះ នឹងទៅតែម្នាក់ឯង ។ ក្នុងកាលមុនបាវេស្សន្តរណាទៅដោយដំរីដោយសាលៀងនិងរថ តែក្នុងថ្ងៃនេះព្រះរាជាវេស្សន្តរនោះនឹងដើរទៅដូចម្តេចបាន ។ បាវេស្សន្តរដែលមានអវយវៈលាបដោយខ្លឹមចន្ទន៍ ធ្លាប់ភ្ញាក់រឭកដោយរបាំនិងចម្រៀង ( ស្លៀកជណ្តប់ ) ស្បែកខ្លា ទាំងក្រចកគ្រោតគ្រាតផង រែកអម្រែកទម្ងន់មួយខារិផងដូចម្តេចកើត ។ ព្រោះហេតុដូចម្តេចក៏ជនទាំងឡាយមិននាំសំពត់កាសាវៈផង ស្បែកខ្លាផង ដើម្បីបាវេស្សន្តរកាលចូលទៅក្នុងព្រៃធំ ព្រោះហេតុអ្វីក៏ជនទាំងឡាយមិនត្បាញសំពត់សម្បកឈើថ្វាយ ។ ពួកជនជារាជបព្វជិត នឹងស្លៀកសំពត់សម្បកឈើដូចម្តេចកើត នាងមទ្រីនឹងស្លៀកសំពត់ដែលក្រងដោយស្បូវភ្លាំងដូចម្តេចកើត ។ នាងមទ្រីធ្លាប់តែស្លៀកសំពត់ ដែលកើតក្នុងដែនកាសីផង សំពត់ដែលកើតក្នុងដែនខោមៈនិងដែនកោទុម្ពរៈផង ឥឡូវនេះមកស្លៀកសំពត់ដែលក្រងដោយស្បូវភ្លាំង តើនឹងធ្វើអ្វីកើត ។ នាងមទ្រីនោះមានអវយវៈគួរសរសើរ ធ្លាប់ទៅដោយវ ព្រះ-សាលៀងនិងរថ ក្នុងថ្ងៃនេះនឹងដើរដោយជើងតាមផ្លូវដូចម្តេច

បាន ។ នាងមទ្រីណាមានផ្ទៃដៃដ៏ទន់ មានចិត្តញាប់ញ័រ ធ្លាប់ឋិតនៅក្នុងសេចក្តីសុខ ថ្ងៃនេះនាងមទ្រីមានអវយវៈគួរសរសើរនោះនឹងដើរដោយជើងតាមផ្លូវ ដូចម្តេចបាន ។ នាងមទ្រីណាមានផ្ទៃជើងដ៏ទន់ មានចិត្តញាប់ញ័រ ធ្លាប់ឋិតនៅក្នុងសេចក្តីសុខ នាងមទ្រីមានអវយវៈគួរសរសើរនោះតែងពាក់ស្បែកជើងមាសហើយដើរទៅ ថ្ងៃនេះនឹងដើរដោយជើងទៅតាមផ្លូវដូចម្តេចបាន ។ នាងមទ្រីណាតែងពាក់កម្រងផ្កា ដើរទៅខាងមុខនៃស្ត្រីមួយពាន់ ថ្ងៃនេះនាងមទ្រីមានអវយវៈគួរសរសើរនោះនឹងដើរទៅព្រៃតែម្នាក់ឯងដូចម្តេចបាន ។ នាងមទ្រីណាដែលនៅក្នុងបុរីគ្រាន់តែបានឮសំឡេងចចកលូវៀយៗ រមែងតក់ស្លុត ថ្ងៃនេះនាងមទ្រីមានអវយវៈគួរសរសើរនោះ ជាស្ត្រីរន្ធត់នឹងទៅព្រៃដូចម្តេចបាន ។ នាងមទ្រីណាគ្រាន់តែបានឮសំឡេងមៀម ជាកោសិយគោត្ត កាលស្រែកបន្លឺក៏ខ្លាចរន្ធត់ដូចមេមត់ដែលខ្លាចចូល ថ្ងៃនេះនាងមទ្រីមានអវយវៈគួរសរសើរនោះ ជាស្ត្រីមានសេចក្តីរន្ធត់នឹងដើរទៅព្រៃដូចម្តេចបាន ។ ខ្ញុំម្ចាស់លុះមកកាន់បុរីនេះសូន្យទទេហើយ មុខជានឹងឆេះដោយសេចក្តីទុក្ខ អស់កាលយូរ ដូចមេបក្សីដែលបាត់កូនឃើញតែសម្បុកសូន្យទទេដូច្នោះ ។ ខ្ញុំម្ចាស់កាលមិនឃើញកូន ( ទាំងពីរ ) ហើយមុខជានឹងស្គមស្លេកស្លាំង ដូចជាមេបក្សីដែលបាត់កូន ឃើញតែ

សម្បុកសូន្យទទេដូច្នោះ ។ ខ្ញុំម្ចាស់កាលមិនឃើញកូន ( ទាំងពីរ ) ជាទីស្រឡាញ់ហើយមុខជានឹងស្គុះទៅតាមទីនោះៗ ដូចជាមេបក្សីដែលបាត់កូន ឃើញតែសម្បុកសូន្យទទេដូច្នោះ ។ ខ្ញុំម្ចាស់ លុះមកកាន់បុរីនេះសូន្យទទេហើយ នឹងឆេះដោយសេចក្តីទុក្ខអស់កាលយូរ ដូចមេអកដែលបាត់កូន ឃើញតែសម្បុកសូន្យទទេដូច្នោះ ។ ខ្ញុំម្ចាស់កាលមិនឃើញកូន ( ទាំងពីរ ) ជាទីស្រឡាញ់ហើយមុខជានឹងស្គមស្លេកស្លាំង ដូចជាមេអកដែលបាត់កូន ឃើញតែសម្បុកសូន្យទទេដូច្នោះ ។ ខ្ញុំម្ចាស់កាលមិនឃើញកូន ( ទាំងពីរ ) ជាទីស្រឡាញ់ហើយមុខជានឹងស្ទុះទៅតាមទីនោះៗ ដូចជាមេអកដែលបាត់កូន ឃើញតែសម្បុកសូន្យទទេដូច្នោះ ។ ខ្ញុំម្ចាស់នោះ មកកាន់បុរីនេះសូន្យទទេហើយមុខជានឹងឆេះដោយសេចក្តីទុក្ខអស់កាលយូរដោយពិតដូចជាមេចាក្រពាកដែល ( សំកុក ) លើភក់មិនមានទឹក ។ ខ្ញុំម្ចាស់នោះមិនឃើញកូន ( ទាំងពីរ ) ជាទីស្រឡាញ់ហើយមុខជានឹងស្គមស្លេកស្លាំងដោយពិត ដូចជាមេចាក្រពាកដែល ( សំកុក ) នៅលើភក់មិនមានទឹក ។ ខ្ញុំម្ចាស់កាលមិនឃើញកូន ( ទាំងពីរ ) ជាទីស្រឡាញ់ហើយមុខជានឹងស្ទុះទៅតាមទីនោះៗដោយពិត ដូចជាមេចាក្រពាកដែលនៅលើភក់មិនមានទឹក ។ កាលបើខ្ញុំម្ចាស់យំរៀបរាប់យ៉ាងនេះហើយ ព្រះអង្គ

នៅតែបណ្តេញរាជបុត្តនោះ ដែលជាអ្នកមិនប្រទូស្ត ឲ្យចេញ
ចាកដែន ខ្ញុំម្ចាស់ទំនងជានឹងលះបង់ជីវិតមិនខាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កណិការោវ** សេចក្តីថា ដូចផ្កាកណិការ ដែលរីកល្អហើយ ព្រោះកំពូលទង់ប្រដាប់ដោយគ្រឿងតាក់តែងដែលជាសុវ-ណ្ណវត្ថាករណៈ ។ បទថា **យាយន្តមនុយាយន្តិ** សេចក្តីថា តាមព្រះវេស្សន្តរ ដែលយាងដើម្បីប្រពាសឧទ្យានជាដើម ។ បទថា **ស្វជ្ជេកោវ** សេចក្តីថា ថ្ងៃ នេះព្រះវេស្សន្តរនឹងយាងទៅមួយព្រះអង្គឯងប៉ុណ្ណោះ ។ បទថា **អនីកានិ** បានដល់ មានកងទ័ពដំរីជាដើម ។ បទថា **គន្ធារា បណ្ឌុកម្ពលា** សេចក្តីថា សំពត់កម្ពលក្រហមដែលសេនាស្លៀកដណ្តប់មានតម្លៃមួយសែន ដែលកើត ក្នុងដែនគន្ធារៈ ។ បទថា **ហារិតិ** សេចក្តីថា លើកឡើងរែកទៅ ។ បទថា **បវិសន្តំ** បានដល់ កាលព្រះវេស្សន្តរយាងចូលទៅ ។ បទថា **កស្មា ចីរំ ន ពជ្ឈរេ** សេចក្តីថា បុគ្គលណាដែលតែងខ្លួនបាននឹងជួយតែងខ្លួនដោយសំពត់ សម្បកឈើក៏មិនមាន ព្រោះហេតុអ្វី ។ បទថា **រាជបព្វជិតា** បានដល់ ពួក អ្នកបួសដែលជាក្សត្រ ។ បទថា **ខោមកោទុម្ពរានិ** បានដល់ សំពត់សាដក ដែលកើតក្នុងខោមរដ្ឋនិងក្នុងកោទុម្ពររដ្ឋ ។ បទថា **សា កជ្ជ** កាត់បទជា **សា កជំ អជ្ជ** ។ បទថា **អនុច្ចង្គី** បានដល់ អ្នកមានវរកាយមិនមានទីតិះ ដៀល ។ បទថា **បីឡមានាវ** សេចក្តីថា យាងទៅដូចហាក់នឿយ ។ បទថា **អស្សុ** ក្នុងបទជាដើមថា **យស្សុ ឥត្ថីសហស្សស្ស** ជានិបាត សេចក្តីថា ណា អធិប្បាយថា នាងមទ្រីណា ។ បាឋៈថា **យាសា** ក៏មាន ។ បទថា

**សិវាយ** បានដល់ ក្តែចចក ។ បទថា **បុរេ** សេចក្តីថា នៅក្នុងព្រះនគរក្នុងកាលមុន ។ បទថា **ឥន្ទសគោត្តស្ស** បានដល់ កោសិយគោត្ត ។ បទថា **វារុណីវ** បានដល់ ដូចយក្ខទាសីដែលទេវតាសណ្ឋិត ។ បទថា **ឧក្កេន្ទ** បានដល់ ទុក្ខ គឺសេចក្តីសោកព្រោះការព្រាត់ប្រាសចាកកូន ។ បទថា **អាគម្មិមំ បុរំ** សេចក្តីថា កាលកូនទៅហើយមាតាមកដំណាក់នេះ គឺដំណាក់របស់កូន ។ បទថា **បិយេ បុត្តេ** ព្រះនាងផុស្សតីត្រាស់សំដៅដល់ព្រះវេស្សន្តរនិងព្រះនាងមទ្រី ។ បទថា **ហតច្ឆាចា** បានដល់ មានកូនត្រូវបៀតបៀន គឺមានកូនតូចត្រូវបៀតបៀនហើយ ។ បទថា **បព្វាជេសិ ច ឆំ** បានដល់ បើទ្រង់បណ្តេញវេស្សន្តរកូនខ្ញុំចេញអំពីដែន ។

ពួកកញ្ញាទាំងពួងក្នុងដែនសិវិរបស់ព្រះបាទសញ្ជ័យ បានឮសំឡេងខ្សឹកខ្សួលរបស់ព្រះនាងផុស្សតីទេវី ក៏ប្រជុំគ្នាយំ ឯរាជបរិចារិកាទាំងឡាយក្នុងព្រះរាជនិវេសន៍របស់ព្រះវេស្សន្តរ បានឮសំឡេងពួកបរិចារិការបស់ព្រះបាទសញ្ជ័យក៏យំតាមគ្នា បុគ្គលណាមួយក្នុងរាជត្រកូលទាំង ២ ដែលអាចតម្កល់ខ្លួនបានមិនមានឡើយ នាំគ្នាទ្រហោយំដូចព្រៃរាំងត្រូវខ្យល់ញាំញីដួលចុះតាមលំដាប់ដូច្នោះ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសានូវព្រះគាថាដូច្នេះថា

ពួកកញ្ញារបស់ព្រះបាទសិវិទាំងអស់ដែលនៅក្នុងបុរី លុះបាន

ពួកអ្នកទំនួញរៀបរាប់នៃព្រះនាងផុស្សតីនោះហើយ ក៏មកចួបជុំគ្នា ផ្គងដើមដៃកន្ទក់កន្ទេញ ។ កូននិងប្រពន្ធទាំងឡាយក៏ដួលដេក ក្នុងព្រះរាជនិវេសន៍ព្រះបាទវេស្សន្តរ ដូចដើមឈើដែលត្រូវ ខ្យល់បក់បោកខ្ទេចខ្ទី ។ ពួកស្រីស្នំ ពួករាជកុមារ ពួកអ្នក ជំនួញនិងពួកព្រាហ្មណ៍ ផ្គងដើមដៃកន្ទក់កន្ទេញ ក្នុងព្រះរាជ និវេសន៍ព្រះបាទវេស្សន្តរ ។ ពួកពលដំរី ពល ( សេះ ) ពល រថ ពលថ្មើរជើង ផ្គងដើមដៃកន្ទក់កន្ទេញក្នុងព្រះរាជនិវេសន៍ ព្រះបាទវេស្សន្តរ ។ រាត្រីនោះអស់ហើយ ព្រះអាទិត្យរះឡើង គ្រានោះព្រះបាទវេស្សន្តរស្តេចចូលទៅដើម្បីឲ្យទាន ។ មាន ព្រះរាជបញ្ជាថា អ្នកទាំងឡាយ ចូរឲ្យសំពត់ដល់ពួកជនដែល ត្រូវការសំពត់ ឲ្យសុរាដល់ពួកអ្នកលេង ឲ្យភោជនដល់ពួក អ្នកត្រូវការដោយភោជន ចូរឲ្យដោយប្រពៃចុះ ។ អ្នកទាំង ឡាយកុំបៀតបៀនពួកវណិព្វកៈដែលមកក្នុងទីនេះតិចតួចឡើយ អ្នកទាំងឡាយ ចូរញុំាងពួកវណិព្វកៈឲ្យស្កប់ស្កល់ដោយបាយ និងទឹក ពួកវណិព្វកៈដែលយើងបានឲ្យរួចហើយចូរទៅចុះ ។ ( លំដាប់នោះស្រាប់តែសំឡេងគ្រលួចយ៉ាងពន្លឹក ប្រព្រឹត្តទៅ ក្នុងព្រះនគរនោះថា ពួកអ្នកសិវិរាស្រ្តបានបណ្តេញព្រះអង្គ ព្រោះតែឲ្យទាន ឥឡូវនេះព្រះអង្គឲ្យទានទៀតហើយ ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សិវិកញ្ញា** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ

ស្រីទាំងឡាយរបស់សញ្ជយរាជានៃដែនសិវិទាំងអស់ បានស្តាប់សំឡេងយំទួញរបស់ព្រះនាងផុស្សតីហើយ ប្រជុំគ្នាទ្រហោយំ ។ បទថា **វេស្សន្តរនិវេ-សនេ** សេចក្តីថា ពួកជនដែលនៅក្បែរជំណាក់របស់ព្រះវេស្សន្តរបានស្តាប់សំឡេងខ្សឹកខ្សួលរបស់ស្រីទាំងឡាយ ក្នុងវាំងនៃព្រះបាទសញ្ជ័យនោះ ក៏កន្ទក់កន្ទេញតាមគ្នា ក្នុងរាជត្រកូលទាំង ២ មិនមានបុគ្គលណាម្នាក់ដែលអាចតាំងនៅបានតាមភាវៈនៃខ្លួន ក៏ដួលចុះបម្រះនទៀលទៅមក ដូចដើមរាំងដួលចុះដោយកម្លាំងខ្យល់ដូច្នោះ ។ បទថា **តតោ រត្យា វិវសនេ** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ កាលរាត្រីនោះកន្លងទៅព្រះអាទិត្យរះឡើងហើយ ពួកជនដែលខ្វល់ខ្វាយក្នុងទានបានក្រាបទូលដល់ព្រះវេស្សន្តរថា ទានបានរៀបចំស្រេចហើយ លំដាប់នោះព្រះវេស្សន្តរទ្រង់ស្រពស្រង់អំពីព្រលឹម ប្រដាប់ដោយសព្វាលង្ការ សោយភោជនាហារដែលមានរសឆ្ងាញ់ ចោមរោមទៅដោយមហាជនចូលទៅកាន់រោងទានដើម្បីព្រះរាជទានសត្តសតកមហាទាន ។ បទថា **ទេថ** សេចក្តីថា ព្រះវេស្សន្តរយាងទៅក្នុងទីនោះហើយ កាលត្រាស់នឹងអាមាត្យ ៦ ម៉ឺន បានត្រាស់យ៉ាងនេះ ។ បទថា **វារុណឹ** សេចក្តីថា ព្រះវេស្សន្តរទ្រង់ដឹងថា ការឲ្យទឹកស្រវឹងជាទានមិនមានផល តែទោះជាយ៉ាងនោះក៏ទ្រង់ត្រិះរិះថា ពួកអ្នកលេងសុរាមកដល់រោងទានហើយ កុំបីពោលថា អញមិនបានផឹកស្រាក្នុងរោងទានព្រះវេស្សន្តរ ដូច្នេះទើបទ្រង់ព្រះរាជទាន ។ បទថា **វនិព្វកេ** សេចក្តីថា បណ្តាពួកស្មូម ពួកអ្នកកុំបីបៀតបៀនបុគ្គលណាម្នាក់ ។ បទថា **បដិបូជិតា** សេចក្តីថា ព្រះវេស្សន្តរត្រាស់ថា អ្នកទាំង

ឡាយ ចូរធ្វើដោយប្រការដែលពួកគេ ដែលយើងបូជាហើយនាំគ្នាសរសើរយើង ចៀសចេញទៅ ។

ព្រះបាទវេស្សន្តរបានព្រះរាជទានសត្តសតកមហាទាន គឺដំរី ៧០០ មានគ្រឿងប្រដាប់មាស មានទង់មាសបំពាក់ដោយបណ្ដាញមាស សេះ ៧០០ ក៏ដូចគ្នានោះឯង រថ ៧០០ ដែលស្រោបដោយស្បែករាជសីហ៍ជាដើម វិចិត្រដោយរតនៈផ្សេងៗ មានទង់មាសជាដើម ស្ត្រីមានខត្តិយកញ្ញាជាដើម ៧០០ ប្រដាប់ដោយគ្រឿងអលង្ការផ្សេងៗ ទ្រទ្រង់នូវរូបដ៏ឧត្តម ។ មេគោ ៧០០ ដែលជាប្រធាននៃគោដ៏ប្រសើរ រឹតទឹកដោះបានមួយថ្ងៃមួយក្អម ។ ទាសី ៧០០ ជាអ្នកបានទទួលការហ្វឹកហាត់និងសិក្សាល្អហើយ ។ ទាសៈ ៧០០ ក៏ដូចគ្នាយ៉ាងនោះមួយអន្លើដោយគ្រឿងផឹកនិងភោជនីយាហារមិនមានប្រមាណដោយប្រការដូច្នេះ ។

កាលព្រះមហាសត្វ ទ្រង់បរិច្ចាគទានយ៉ាងនេះអ្នកជេតុត្តរមាន ក្សត្រព្រាហ្មណ៍ វេស្សៈ សូទ្រៈជាដើមក៏យំរៀបរាប់ថា បពិត្រព្រះវេស្សន្តរ អ្នកសិវិរដ្ឋបណ្ដេញទ្រង់ដែលជាអ្នកបរិច្ចាគទានចេញអំពីរដ្ឋមណ្ឌល ទ្រង់នៅតែឲ្យទានទៀត ព្រោះហេតុនោះទើបព្រះមានព្រះភាគត្រាស់ថា

គ្រានោះសំឡេងគ្រលួចយ៉ាងពន្លឹក ប្រព្រឹត្តទៅក្នុងព្រះរាជ
និវេសន៍ទ៉ុះថា ពួកអ្នកសិវិរដ្ឋបណ្ដេញព្រះវេស្សន្តរនោះ
ព្រោះតែឲ្យទាន ព្រះវេស្សន្តរនោះនៅតែឲ្យទានទៀត ដូច្នេះ ។

ឯបុគ្គលអ្នកទទួលទានបានទទួលទានហើយក៏នាំគ្នាពិចារណាថា បានឮថា

ឥឡូវនេះ ព្រះវេស្សន្តរយាងចូលកាន់ព្រៃ ធ្វើឲ្យពួកយើងអស់ទីពឹងចាប់អំពីនេះទៅ ពួកយើងទៅរកអ្នកណា គិតដូច្នេះក៏ដេកបម្រះនបៀលទៅមកហាក់ដូចមានជើងដាច់ ស្រែកយំដោយសំឡេងខ្លាំង ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** វីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសានូវព្រះគាថាដូច្នេះថា

កាលមហារាជព្រះអង្គញុាំងពួកអ្នកសិវិរាស្ត្រឲ្យចម្រើន ទ្រង់យានចេញទៅ វណិព្វកៈទាំងនោះក៏ដួលចុះដូចជាបុគ្គលស្រវឹង ឬដូចជាបុគ្គលនឿយហត់ខ្លាំង ( ដោយពាក្យថា ) ម្នាលអ្នកទាំងឡាយដ៏ចម្រើន ពួកអ្នកសិវិរាស្ត្របានបណ្តេញព្រះបាទវេស្សន្តរ ដែលជាអ្នកមិនប្រទូស្តឲ្យចេញចាកដែន ដូចគេកាត់ផ្តាច់ដើមឈើ ជាឈើឲ្យផ្លែផ្សេងៗ ។ ម្នាលអ្នកទាំងឡាយដ៏ចម្រើន ពួកអ្នកសិវិរាស្ត្របានបណ្តេញព្រះបាទវេស្សន្តរ ដែលជាអ្នកមិនប្រទូស្តឲ្យចេញចាកដែន ដូចជាគេកាត់ចោលនូវដើមឈើជាឈើទ្រទ្រង់ផ្លែផ្សេងៗ ។ ម្នាលអ្នកទាំងឡាយដ៏ចម្រើន ពួកអ្នកសិវិរាស្ត្របានបណ្តេញព្រះបាទវេស្សន្តរ ដែលជាអ្នកមិនប្រទូស្តឲ្យចេញចាកដែនដូចជាគេកាត់ដើមឈើ ជាឈើឲ្យសេចក្តីប្រាថ្នាគ្រប់យ៉ាង ។ ម្នាលអ្នកទាំងឡាយដ៏ចម្រើន ពួកអ្នកសិវិរាស្ត្រ បានបណ្តេញព្រះបាទវេស្សន្តរ ដែលជាអ្នកមិន

ប្រទូស្តឲ្យចេញចាកដែន ដូចជាគេកាត់ដើមឈើជាឈើនាំមកនូវរសជាទីប្រាថ្នាគ្រប់យ៉ាង ។ ពួកជនណាដែលចាស់ក្តី ពួកជនណាដែលនៅក្មេងក្តី ពួកជនណាដែលមានវ័យកណ្តាលក្តី ជនទាំងនោះកាលដែលមហារាជព្រះអង្គញ៉ាំងដែនរបស់ពួកអ្នកសិវិរាស្ត្រឲ្យចម្រើន ទ្រង់យាងចេញទៅក៏ផ្គងដៃកន្ទក់កន្ទេញ ។ កាលមហារាជព្រះអង្គញ៉ាំងដែនអ្នកសិវិឲ្យចម្រើន ទ្រង់យាងចេញទៅ ពួកពេទ្យចាប់ខ្មោច ពួកអ្នករក្សាស្រីស្នំនិងពួកស្រីស្នំរបស់ព្រះរាជាក៏ផ្គងដើមដៃកន្ទក់កន្ទេញ ។ កាលមហារាជព្រះអង្គញ៉ាំងអ្នកដែនសិវិឲ្យចម្រើន ទ្រង់យាងចេញទៅ ពួកស្ត្រីដែលនៅក្នុងព្រះនគរនោះ ក៏កន្ទក់កន្ទេញ ។ ពួកព្រាហ្មណ៍សមណៈនិងវណិព្វកៈដទៃៗផ្គងដើមដៃកន្ទក់កន្ទេញថា ម្នាលគ្នាយើងដ៏ចម្រើន បានឮថា នេះមិនមែនជាធម៌ទេ ។ ដូចយ៉ាងព្រះបាទវេស្សន្តរ កាលបូជាក្នុងបុរីរបស់ព្រះអង្គ ទ្រង់យាងចេញចាកដែនរបស់ព្រះអង្គ ព្រោះហេតុតែសម្តីពួកអ្នកសិវិរាស្ត្រ ។ ព្រះបាទវេស្សន្តរទ្រង់បានប្រទានដំរីមាតង្គៈប្រាំពីររយដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង មានខ្សែជង្គន់មាស មានគ្រឿងប្រដាប់ក្បាលជាវិការៈនៃមាស ដែលពួកហ្មដំរីមានលំពែងស្នែងក្របីនិងកង្វេរក្នុងដៃឡើងជិះហើយ ក៏យាងចេញទៅចាកដែនរបស់ព្រះអង្គ ។ ព្រះបាទវេស្សន្តរទ្រង់ បានប្រទានសេះ

អាជានីយប្រាំពីររយ ជាសេះសិន្ធពដោយជាតិ ជាពាហនៈមាន សន្ទុះលឿនដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួងដែល ពួកអ្នកជិះសេះកាន់ស៊ែនិងធ្នូឡើងជិះហើយ ក៏យាងចេញចាក ដែនរបស់ព្រះអង្គ ។ ព្រះបាទវេស្សន្តរទ្រង់ បានប្រទានរថប្រាំ ពីររយដែលប្រដាប់ហើយ មានទង់លើកឡើងហើយ បិទបាំង ដោយស្បែកខ្លាជំបង់និងស្បែកខ្លាធំ ស្អិតស្អាងដោយគ្រឿង អលង្ការទាំងពួង ដែលពួកនាយសារថីមានធ្នូក្នុងដៃ និងពាក់ អាវក្រោះឡើងជិះហើយក៏យាងចេញចាកដែនរបស់ព្រះអង្គ ។ ព្រះបាទវេស្សន្តរទ្រង់ បានប្រទានស្ត្រីប្រាំពីររយឋិតនៅលើរថ មួយម្នាក់ៗដែលស្អិតស្អាងហើយ ប្រដាប់ដោយខ្សែជាវិការៈនៃ មាសត្ពោរ មានគ្រឿងប្រដាប់លឿង មានសម្លៀកបំពាក់លឿង ស្អិតស្អាងដោយគ្រឿងអាភរណៈលឿង មានថ្ពាល់និងភ្នែកដ៏ ល្អ ញញឹមហើយទើបនិយាយ ជាស្ត្រីមានត្រគាកល្អ មាន ចង្កេះរៀវ ក៏យាងចេញចាកដែនរបស់ព្រះអង្គ ។ ព្រះបាទ វេស្សន្តរទ្រង់ បានប្រទានមេគោប្រាំពីររយព្រមទាំងភាជន៍មាស សម្រាប់ត្រងទឹកដោះទាំងអស់ហើយយាងចេញចាកដែនរបស់ ព្រះអង្គ ។ ព្រះបាទវេស្សន្តរទ្រង់ បានប្រទានខ្ញុំស្រីប្រាំពីររយ ខ្ញុំ ប្រុសប្រាំពីររយ ហើយយាងចេញចាកដែនរបស់ព្រះអង្គ ។ ព្រះបាទវេស្សន្តរទ្រង់ បានប្រទានដំរី សេះ រថនិងនាងនារីដែល

ប្រជាប់ហើយក៏យានចេញចាកដែនរបស់ព្រះអង្គ ។ កាលដែលព្រះបាទវេស្សន្តរប្រទានមហាទាន ការស្ញប់ស្ញែង ការព្រឺរោមក៏កើតមានក្នុងកាលនោះ ផែនដីក៏ញាប់ញ័រ ។ ព្រះរាជាដែលមហាជនកំពុងផ្គងអញ្ជលី ទ្រង់យានចេញចាកដែនរបស់ព្រះអង្គ ដោយហេតុណា ហេតុនោះជាការគួរស្ញប់ស្ញែងគួរព្រឺរោមកើតមានក្នុងកាលនោះ ។

គ្រានោះសំឡេងគ្រលួចយ៉ាងពន្លឹក ប្រព្រឹត្តទៅក្នុងព្រះរាជនិវេសន៍ទុំះថា ពួកអ្នកសិវិរាស្ត្រ បណ្តេញព្រះវេស្សន្តរនោះ ព្រោះតែឲ្យទាន ព្រះវេស្សន្តរនោះនៅតែឲ្យទានទៀត ។

កាលមហារាជ ព្រះអង្គញុំាងពួកអ្នកសិវិរាស្ត្រឲ្យបម្រើនយានចេញទៅ ពួកវណិព្វកៈទាំងនោះ ក៏ដួលចុះដូចបុគ្គលស្រវឹង ឬដូចបុគ្គលនឿយហត់ខ្លាំង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សុ** អក្ខរៈក្នុងបទថា **តេ សុ មត្តា** នេះត្រឹមតែជានិបាត សេចក្តីថា ស្ទួមទាំងនោះ ។ បទថា **មត្តា កិលន្តាវ** សេចក្តីថា ជាមនុស្សដូចគ្នានឹងបុគ្គលស្រវឹងនិងមនុស្សដែលហត់នឿយ ។ បទថា **សម្បតន្តិ** សេចក្តីថា ដួលចុះលើផែនដី បម្រះននៀលទៅមក ។ បទថា **អច្ឆេជ្ជំ វត** ប្រែថា កាត់ហើយហ្ន៎ ។ បទថា **យថា** ប្រែថា ដោយហេតុណា ។ បទថា **អតិយក្ខា** បានដល់ គ្រូខ្មោចខ្វះ មេមត់ខ្វះ ។ បទថា **វេស្សវរា** បានដល់ ពួកអ្នកមើលថៃស្រីស្នំ ។ បទថា **វចឈត្ថេន** បានដល់

ព្រោះហេតុនៃពាក្យ ។ បទថា **សម្ភា រដ្ឋា និរជ្ជតិ** សេចក្ដីថា ចេញអំពីដែនរបស់ព្រះអង្គ ។ បទថា **គាមណីយេភិ** បានដល់ អាចារ្យបង្ហាត់ដំរី ។ បទថា **ជាតិយេ** បានដល់ សម្បូរដោយជាតិ ។ បទថា **គាមណីយេភិ** បានដល់ អាចារ្យទូន្មានសេះ ។ បទថា **ឥដ្ឋិយាចាបធារិភិ** បានដល់ អ្នកទ្រទ្រង់ទុកនូវដាវនិងធ្នូ ។ បទថា **ធីបេ អថោបិ វេយ្យគ្ឃេ** បានដល់ ស្រោបដោយស្បែកខ្លាដំបងនិងស្បែកខ្លាធំ ។ បទថា **ឯកមេកា រថេ ឋិតា** សេចក្ដី-ថា បានឮថា ព្រះវេស្សន្តរបានព្រះរាជទាននារីរត្ន ម្នាក់ៗឈរនៅលើរថដែលមានទាសី ៨ នាក់ចោមរោម ។ បទថា **និក្ខរជ្ជុហិ** បានដល់ ខ្សែដែលសម្រេចដោយមាស ។ បទថា **អាឡារប្បមុខា** បានដល់ មានភ្នែកធំ ។ បទថា **ហសុលា** បានដល់ ញញឹមសិនទើបនិយាយ ។ បទថា **សុសញ្ញា** បានដល់ មានត្រគាកសាយ ។ បទថា **តនុមជ្ឈិមា** បានដល់ មានចង្កេះរៀវ ។ បទថា **កង្ស** ក្នុងបទថា **កង្សុបធារិនោ** នេះជាឈ្មោះរបស់ប្រាក់ សេចក្ដីថា បានព្រះរាជទានមួយអន្ទើដោយភាជនៈដាក់ទឹកដោះ ដែលធ្វើអំពីប្រាក់ ។ បទថា **បធិន្នម្ហិ** បានដល់ឲ្យ ។ បទថា **សមកម្បថ** សេចក្ដីថា ញាប់ញ័រដោយអានុភាពនៃទាន ។ បទថា **យំ បញ្ជលីកតោ** សេចក្ដីថា ព្រះវេស្សន្តរឲ្យទានហើយ ផ្គងអញ្ជលីនមស្ការទានរបស់ទ្រង់ ទ្រង់បានធ្វើអញ្ជលីអធិដ្ឋានថា សូមទាននេះបានជាបច្ច័យដល់សព្វញ្ញុតញ្ញាណរបស់អាត្មាអញ សូម្បីសេចក្ដីនោះក៏ជាមហស្ចារ្យគួរព្រឺរោមព្រឺស្បែកនោះឯង អធិប្បាយថា ផែនដីបានញាប់ញ័រក្នុងខណៈនោះ ។ បទថា **និរជ្ជតិ** សេចក្ដីថា ព្រះ

វេស្សន្តរ បានព្រះរាជទានយ៉ាងនេះហើយ ក៏ត្រូវនិរាសទៅមិនមានអ្នកឃាត់ទ្រង់បានឡើយ ។

ក្នុងកាលនោះទេវតាទាំងឡាយ ប្រាប់ដល់ស្តេចក្នុងជម្ពូទ្វីបថា ព្រះបាទវេស្សន្តរទ្រង់ឲ្យមហាទាន មានឲ្យខត្តិយកញ្ញាជាដើម ព្រោះហេតុនោះក្សត្រទាំងឡាយ ទើបយាងមកដោយទេវានុភាព ទទួលយកខត្តិយកញ្ញាទាំងនោះហើយចៀសចេញទៅ ។

ក្សត្រ ព្រាហ្មណ៍ វេស្សៈ សូទ្រៈជាដើម ទទួលព្រះរាជទានរបស់ព្រះវេស្សន្តរហើយចៀសចេញទៅដោយប្រការដូច្នេះ ។ ព្រះវេស្សន្តរទ្រង់បរិច្ចាគរហូតដល់ពេលល្ងាច ទើបយាងត្រឡប់ទៅកាន់ព្រះរាជនិវេសន៍របស់ព្រះអង្គវិញ ទ្រង់ព្រះតម្រិះថា អញនឹងថ្វាយបង្គំលាព្រះរាជមាតាបិតាហើយនឹងទៅក្នុងថ្ងៃស្អែកនេះ ទើបយាងទៅកាន់ទីប្រថាប់របស់ព្រះជនកព្រះជននី ដោយព្រះទីន័ង គឺរថដែលតាក់តែងហើយ ឯព្រះនាងមទ្រីក៏ត្រិះរិះថាសូម្បីអញក៏នឹងទៅតាមព្រះស្វាមី អញនឹងញ៉ាំងព្រះបិតាក្មេកនិងព្រះមាតាក្មេកឲ្យអនុញ្ញាតផង ទើបយាងទៅជាមួយព្រះវេស្សន្តរ ព្រះមហាសត្វថ្វាយបង្គំព្រះរាជបិតាហើយក្រាបទូលភាពដែលទ្រង់យាងទៅ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** វីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសានូវព្រះគាថាដូច្នេះថា

ព្រះបាទវេស្សន្តរបានក្រាបទូលព្រះរាជា ព្រះនាមសញ្ជ័យ ជា

ធម្មិករាជដ៏ប្រសើរថា បពិត្រព្រះទេវៈ ព្រះអង្គទ្រង់បណ្តេញទូលព្រះបង្គំជាខ្ញុំ ទូលព្រះបង្គំជាខ្ញុំនឹងទៅឯវង្កតបពិត។ បពិត្រមហារាជ សត្វទាំងឡាយណាមួយកើតហើយក្តីទាំងសត្វទាំងឡាយណានឹងកើតក្តី ( ពួកសត្វដែលកំពុងកើតក្តី ) សត្វទាំងនោះសុទ្ធតែមិនឆ្អែតដោយកាមទាំងអស់ រមែងទៅកាន់ទីរបស់យមៈ ។ ទូលព្រះបង្គំជាខ្ញុំនោះ កាលឲ្យទានក្នុងបុរីជារបស់ខ្លួនឈ្មោះថា បៀតបៀនពួកអ្នកដែនរបស់ខ្លួន ទូលព្រះបង្គំជាខ្ញុំ កាលចេញចាកដែនរបស់ខ្លួន ព្រោះហេតុតែសម្តីពួកអ្នកសិវិរាស្ត្រ ទូលព្រះបង្គំក៏នឹងរងទុក្ខក្នុងព្រៃដែលប្រេបូកប្របល់ដោយម្រឹគសាហាវ ដែលរមាសនិងខ្លាដំបងអាស្រ័យហើយ ទូលព្រះបង្គំជាខ្ញុំ នឹងធ្វើបុណ្យទាំងឡាយ ឯព្រះអង្គលិចក្នុងភក់ គឺកាមបុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ធម្មិកំ វរំ** បានដល់ ជាបុគ្គលឧត្តមក្នុងព្រះរាជាដែលជាអ្នកទ្រទ្រង់ធម៌ទាំងឡាយ ។ បទថា **អវរុទ្ធសិ** សេចក្តីថា នាំចេញចាកដែន ។ បទថា **ភូតា** បានដល់ អតីតកាល ។ បទថា **ភវិស្សរេ** សេចក្តីថា ជនពួកណានឹងមានក្នុងអនាគតនិងកើតក្នុងបច្ចុប្បន្ន ។ បទថា **សោហំ សកេ អភិសសឹ** សេចក្តីថា ខ្ញុំនោះហេតុអ្វីទើបឈ្មោះថាបៀតបៀនអ្នកនគររបស់ខ្លួន ។ បទថា **យជមានោ** បានដល់ បរិច្ចាគទាន ។ បទថា **សកេ បុរេ** បានដល់ ក្នុងប្រាសាទរបស់ខ្លួន តែក្នុងបាលីរចនាទុកថា **សោ**

**អហំ** ដូច្នេះ ។ បទថា **និរជ្ជហំ** បានដល់ កាលខ្ញុំចេញ ។ បទថា **អរញ្ញំ** សេចក្តីថា ខ្ញុំនឹងសោយទុក្ខដែលបុគ្គលអ្នកនៅក្នុងព្រៃគប្បីសោយ ។ បទថា **បង្កម្ហិ** សេចក្តីថា ព្រះវេស្សន្តរទូលថា តែទ្រង់ជាអ្នកលិចចុះក្នុងភក់ គឺកាម ។

មហាសត្វទូលនឹងព្រះជនកដោយគាថាទាំង ៤ នេះហើយ យាងទៅគាល់ព្រះជននី ថ្វាយបង្គំហើយ កាលទ្រង់សូមអនុញ្ញាតបព្វជ្ជាទើបត្រាស់ថា

បពិត្រព្រះមាតា សូមទ្រង់អនុញ្ញាតទូលព្រះបង្គំជាខ្ញុំ ទូលព្រះបង្គំជាខ្ញុំគាប់ចិត្តនឹងបព្វជ្ជា ទូលព្រះបង្គំជាខ្ញុំនោះកាលឲ្យទានក្នុងបុរីជារបស់ខ្លួនឈ្មោះថា បៀតបៀនពួកអ្នកដែនរបស់ខ្លួន ទូលព្រះបង្គំជាខ្ញុំ កាលចេញចាកដែនរបស់ខ្លួន ព្រោះហេតុតែសម្តីពួកអ្នកសិវិរាស្ត្រ ទូលព្រះបង្គំជាខ្ញុំនឹងសោយទុក្ខក្នុងព្រៃដែលច្របូកច្របល់ដោយម្រឹគសាហាវដែលរមាសនិងខ្លាដំបងអាស្រ័យហើយ ទូលព្រះបង្គំជាខ្ញុំតែងធ្វើបុណ្យទាំងឡាយនឹងទៅឯគិរីវង្កត ។

ព្រះនាងផុស្សតីបានស្តាប់ដូច្នោះហើយទើបត្រាស់ថា

ម្នាលកូន យើងអនុញ្ញាតអ្នកហើយ បព្វជ្ជាចូរសម្រេចដល់អ្នកចុះតែនាងមទ្រីកល្យាណីនេះ នាងមានត្រគាកដ៏ល្អ មានចង្កេះរៀវ ចូរនៅជាមួយនឹងកូនទាំងពីរចុះ នាងនឹងធ្វើអ្វីក្នុងព្រៃដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សមិជ្ឈតុ** សេចក្តីថា ចូរមានសេចក្តីសម្រេច

ដោយឈាន ។ បទថា **អច្ឆតំ** សេចក្ដីថា ព្រះនាងផុស្សតីត្រាស់ថា ចូរនៅ គឺចូរមានក្នុងទីនេះឯង ។

ព្រះវេស្សន្តរត្រាស់ថា

សូម្បីតែទាសីដែលប្រាថ្នានឹងទៅ ទូលព្រះបង្គំជាខ្ញុំក៏មិនអាច នាំទៅកាន់ព្រៃទេ ប្រសិនបើនាងមទ្រីចង់ចូរទៅតាមចុះ បើមិន ចង់ចូរនៅចុះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អកាមា** សេចក្ដីថា បពិត្រព្រះមាតា ទ្រង់ត្រាស់អ្វីយ៉ាងនោះ សូម្បីទាសីខ្ញុំក៏មិនអាចនាំទៅព្រោះគេមិនប្រាថ្នា ។

លំដាប់នោះព្រះបាទសញ្ជ័យ បានស្ដាប់ព្រះតម្រាស់របស់ព្រះរាជឱរស ទ្រង់ក៏យល់ស្របហើយក៏អង្វរព្រះសុណិសា ។

**តមត្ថំ បកាសេន្តោ សត្ថា អាហា** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសានូវព្រះគាថាដូច្នេះថា

លំដាប់នោះមហារាជទ្រង់យាងទៅអង្វរព្រះសុណិសាថា ម្នាលនាងមានរាងកាយប្រោះព្រំដោយខ្លឹមចន្ទន៍ នាងកុំស្លៀកដណ្ដប់សំពត់ឲ្យប្រឡាក់ក្អែលឡើយ ។ នាងធ្លាប់ស្លៀកដណ្ដប់សំពត់អ្នកដែនកាសី ហើយត្រឡប់ជាស្លៀកដណ្ដប់សំពត់ដែលក្រងដោយស្បូវក្ញាំងវិញ ការនៅក្នុងព្រៃតែងនាំមកនូវសេចក្ដីទុក្ខ ម្នាលនាងមានលក្ខណ៍ នាងកុំទៅឡើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បដិបជ្ជេ** សេចក្ដីថា ម្នាលភិក្ខុទាំងឡាយ ព្រះបាទសញ្ជ័យបានស្ដាប់ពាក្យព្រះរាជឱរសហើយបានអនុលោមតាម ដើម្បីអង្វរព្រះសុណិសា ។ បទថា **មា ចន្ទនសមាចរេ** សេចក្ដីថា នែនាងដែលមានខ្លួនប្រោះព្រំដោយខ្លឹមចន្ទន៍ក្រហម ។ បទថា **មា ហិ ត្វំ លក្ខណេ គមិ** សេចក្ដីថា នែនាងប្រកបដោយលក្ខណៈល្អ នាងកុំទៅព្រៃឡើយ ។

ព្រះរាជបុត្រីព្រះនាមមទ្រីមានអវយវៈទាំងអស់ដ៏ល្អ បានក្រាបបង្គំទូលព្រះបិតាក្មេកថា ខ្ញុំម្ចាស់បើប្រាសចាកព្រះវេស្សន្តររបស់ខ្ញុំម្ចាស់ហើយ មិនចង់បានសេចក្ដីសុខទេ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **តមព្រវិ** សេចក្ដីថា បានក្រាបទូល គឺបានប្រាប់បិតាក្មេកនោះ ។

មហារាជ ជាអ្នកញុំាងពួកអ្នកសិវិរាស្ត្រឲ្យចម្រើន មានព្រះបន្ទូលនឹងនាងមទ្រីនោះថា ម្នាលនាងមទ្រី បើដូច្នោះនាងចូរស្ដាប់សេចក្ដីអន្តរាយទាំងឡាយ ដែលនាងអត់ទ្រាំបានដោយក្រក្នុងព្រៃចុះ ។ កណ្ដូប របោម មូសនិងឃ្មុំ ដ៏ច្រើន សត្វទាំងនោះគប្បីបៀតបៀននាងក្នុងព្រៃនោះ ការបៀតបៀននោះមុខជានាំមកនូវទុក្ខយ៉ាងខ្លាំងដល់នាង ។ នាងចូរមើលពួកសត្វដទៃដែលគួរឲ្យតក់ស្លុតដែលអាស្រ័យនៅនឹងទន្លេ គឺពស់ថ្លាន់ពស់ទាំងនោះមិនមានពិសទេ តែមានកម្លាំងច្រើន ។ ពស់ថ្លាន់ទាំងនោះតែងយកក្មេនរឹតមនុស្ស ឬម្រឹគដែលមកជិតវាហើយ

នាំមកកាន់អំណាចខ្លួន ។ ខ្លាឃ្មុំដទៃទៀតមានសម្បុរខ្មៅ ពេម រឹង ជាម្រឹគឲ្យទុក្ខ បុរសដែលខ្លាទាំងនោះឃើញហើយ វត់ឡើងដើមឈើក៏មិនរួច ។ ក្របីជាសត្វប្រហារតែងវែធនឹងស្នែង មានចុងដ៏មុត តែងត្រាច់ទៅមកក្នុងព្រៃនោះ ជិតទន្លេឈ្មោះសោតុម្ពា ។ ម្នាលនាងមទ្រី នាងដូចជាមេគោដែលមានចិត្តជាប់នឹងកូន ឃើញគោឈ្មោលកំពុងទៅតាមហ្វូងម្រឹគក្នុងព្រៃ នឹងធ្វើដូចម្តេច ។ ម្នាលនាងមទ្រី ភ័យធំមុខជានឹងមានដល់នាងដែលជាស្រ្តីមិនដឹងទីខេត្ត ព្រោះឃើញស្វាទាំងឡាយដ៏ពន្លឹកដែលផ្តុំគ្នាក្បែរផ្លូវ ដែលទៅមកបានដោយក្រ ។ ម្នាល នាងមទ្រី ក្នុងបុរីនាងគ្រាន់តែឮ ( សូរសំឡេង ) ចចករមែងតក់ស្លុតរឿយៗ ដល់ទៅគិរីវង្កតើនឹងធ្វើដូចម្តេចទៅ ។ កាលដែលពួកបក្សីប្រជុំគ្នាក្នុងវេលា ដែលព្រះអាទិត្យឋិតនៅត្រង់កណ្តាល ( ថ្ងៃត្រង់ ) ព្រៃធំក៏លាន់ឮសំឡេងគឹកកង ចុះនាងចង់ទៅក្នុងព្រៃធំនោះធ្វើអ្វី ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តមព្រាំ** សេចក្តីថា បានត្រាស់នឹងកូនប្រសានោះ ។ បទថា **អបរេ បស្ស សន្តាសេ** សេចក្តីថា ចូរមើល គឺចូរឃើញហេតុដែលឲ្យកើតភ័យដែលគួរតក់ស្លុត ។ បទថា **ឆទីន្ទបដិសេវិតេ** សេចក្តីថា ចូលទៅអាស្រ័យប្រាំងស្ទឹងក្នុងទីជិត ។ បទថា **អាវិសា** បានដល់ ប្រាសចាកពិស ។ បទថា **អបិចាសន្នំ** សេចក្តីថា ជិត គឺមកប៉ះពាល់សរីរៈ

របស់ខ្លួន ។ បទថា **អឃម្មិគា** បានដល់ ម្រឹគដែលធ្វើសេចក្តីលំបាក អធិប្បាយថា ម្រឹគដែលនាំទុក្ខមកឲ្យ ។ បទថា **ឆគី សោតុម្ពរំ បតិ** បានដល់ មាត់ស្ទឹងឈ្មោះ សោតុម្ពរៈ ។ បទថា **យូថានំ** បានដល់ នូវហ្វូងបាបៈក៏យ៉ាងនេះឯង ។ បទថា **ធេនុំ វច្ឆគិទ្ធាវ** សេចក្តីថា នាងដូចមេគោទឹកដោះស្រឡាញ់កូន កាលមិនឃើញកូនរបស់នាងនឹងធ្វើដូចម្តេច ។ **វ** អក្ខរៈក្នុងបទថា **វច្ឆគិទ្ធាវ** នេះត្រឹមតែជានិបាតប៉ុណ្ណោះ ។ បទថា **សម្បតិតេ** បានដល់ ធ្លាក់ចុះមក ។ បទថា **ឃោរេ** បានដល់ មានរូបចម្លែកគួរខ្លាច ។ បទថា **បលង្គមេ** បានដល់ ហ្វូងសត្វ ។ បទថា **អខេត្តញ្ញាយ** បានដល់ មិនឈ្លាសក្នុងមិសាស្រ្តក្នុងព្រៃ ។ បទថា **ភវិស្សន្តេ** សេចក្តីថា នឹងមានដល់នាង ។ បទថា **យោ តុំ សិវាយ សុត្វាន** សេចក្តីថា បានឮសំឡេងរបស់ឆ្កែចចក ។ បទថា **មុហុំ** សេចក្តីថា កាលនៅក្នុងនគរ ក៏ភិតភ័យរឿយៗ ។ បទថា **សុណោតេវ** បានដល់ បន្លឺ គឺបញ្ចេញសំឡេង ។

ព្រះរាជបុត្រីព្រះនាមមទ្រីមានអវយវៈទាំងអស់ដ៏ល្អ បានក្រាបបង្គំទូលព្រះរាជបិតាក្មេកនោះថា ព្រះអង្គទ្រង់ត្រាស់ប្រាប់ដល់ខ្ញុំម្ចាស់នូវភ័យដែលមានចំពោះមុខទាំងឡាយណាក្នុងព្រៃ ឯខ្ញុំម្ចាស់អាចទទួលអត់ទ្រាំភ័យ ដែលមានចំពោះមុខទាំងអស់នោះបាន បពិត្រព្រះអង្គដ៏ប្រសើរក្នុងរថ ខ្ញុំម្ចាស់នឹងទៅពុំខានឡើយ ។ ខ្ញុំម្ចាស់នឹងយកទ្រង់រុលវែកដើមអំពៅព្រៃ ស្បូវក្លាំងស្មៅសសិត ស្មៅរណ្តាស ស្មៅយាប្លង់និងស្មៅជំណោកទន្សាយ

( ដើរមុខព្រះវេស្សន្តរជាប្តីខ្ញុំម្ចាស់ ) ខ្ញុំម្ចាស់នឹងនាំព្រះភស្តាទៅមិនឲ្យលំបាក ។ កុមារីរមែងបានប្តីដោយការប្រព្រឹត្តវត្តដ៏ច្រើន គឺដោយការបិទពោះ ( បន្ថយអាហារឲ្យពោះតូច ) ដោយការជំចង្កេះ ដោយឈើមានសណ្ឋានដូចចង្កាគោនិងការរឹតចង្កេះខ្លួនដោយឈ្នួត ( ធ្វើឲ្យចង្កេះរៀវ ) ដោយការបម្រើភ្លើង ( អាំងភ្លើង ) និងដោយការជុសលាងសម្អាតដោយទឹក ភាពជាស្ត្រីមេម៉ាយ រមែងក្តៅក្រហាយក្នុងលោក បពិត្រព្រះអង្គប្រសើរក្នុងរថ ខ្ញុំម្ចាស់នឹងទៅពុំខានឡើយ ។ ម្យ៉ាងទៀតបុរសមិនគួរបរិភោគរបស់សំណល់អំពីស្ត្រីមេម៉ាយនោះ បុរសណាសូម្បី ( មានជាតិទាបបុរសនោះ ) ក៏ចាប់ដៃទង់ទាញស្ត្រីមេម៉ាយនោះដែលមិនប្រាថ្នាផង ភាពជាស្ត្រីមេម៉ាយរមែងក្តៅក្រហាយក្នុងលោក បពិត្រព្រះអង្គដ៏ប្រសើរក្នុងរថ ខ្ញុំម្ចាស់នឹងទៅពុំខានឡើយ ។ បុរសតែងឲ្យសេចក្តីទុក្ខយ៉ាងច្រើនលើសលុបដោយការចាប់សក់កញ្ឆក់ឡើង ដោយការផ្តួលលើផែនដីហើយក៏មិនដើរចេញទៅណា ( នៅឈរមើលព្រងើយ ) ភាពជាស្ត្រីមេម៉ាយរមែងក្តៅក្រហាយក្នុងលោក បពិត្រព្រះអង្គដ៏ប្រសើរក្នុងរថ ខ្ញុំម្ចាស់នឹងទៅមិនខានឡើយ ។ ពួកបុរសដែលមានសម្បុរស ជាអ្នកត្រូវការនឹងស្ត្រីមេម៉ាយ ប្រកាន់ខ្លួនថាមានលំអដ៏ប្រសើរ បានឲ្យ ( ទ្រព្យបន្តិចបន្តួច ) ហើយ

ទន់ទាញស្ត្រីមេម៉ាយ ដែលមិនត្រូវការនឹងខ្លួន ដូចក្អែកដែលធាបមៀមដូច្នោះ ភាពជាស្ត្រីមេម៉ាយ រមែងក្តៅក្រហាយក្នុងលោក បពិត្រព្រះអង្គដ៏ប្រសើរក្នុងរថ ខ្ញុំម្ចាស់នឹងទៅពុំខានឡើយ ។ ម្យ៉ាងទៀតស្ត្រីមេម៉ាយ កាលនៅក្នុងត្រកូលញាតិដ៏ស្តុកស្តម្ភរុងរឿងដោយភាជន៍មាស ក៏នៅតែបានពាក្យតិះដៀលអំពីបងប្អូនប្រុសនិងពួកស្ត្រីជាសម្លាញ់ពុំខាន ភាពជាស្ត្រីមេម៉ាយរមែងក្តៅក្រហាយក្នុងលោក បពិត្រព្រះអង្គដ៏ប្រសើរក្នុងរថ ខ្ញុំម្ចាស់នឹងទៅពុំខានឡើយ ។ ទន្លេដែលគ្មានទឹកហៅថាទន្លេស្រាត ដែនដែលគ្មានព្រះរាជាហៅថា ដែនស្រាត ចំណែកស្ត្រីមេម៉ាយបើទុកជាមានបងប្អូនប្រុសដល់ ១០ នាក់ ក៏ហៅថា ស្ត្រីស្រាត ភាពជាស្ត្រីមេម៉ាយរមែងក្តៅក្រហាយក្នុងលោក បពិត្រព្រះអង្គដ៏ប្រសើរក្នុងរថ ខ្ញុំម្ចាស់នឹងទៅពុំខានឡើយ ។ ទង់ជាគ្រឿងប្រាកដរបស់រថ ផ្សែងជាគ្រឿងប្រាកដរបស់ភ្លើង ព្រះរាជាជាគ្រឿងប្រាកដរបស់ដែន ភស្តាជាគ្រឿងប្រាកដរបស់ស្ត្រី ភាពជាស្ត្រីមេម៉ាយ រមែងក្តៅក្រហាយក្នុងលោក បពិត្រព្រះអង្គដ៏ប្រសើរក្នុងរថ ខ្ញុំម្ចាស់នឹងទៅពុំខានឡើយ ។ ស្ត្រីណាដែលមានកេរ្តិ៍ឈ្មោះ កាលស្វាមីទ័លក្រក៏ជាស្ត្រីទ័លក្រ ( ជាមួយ ) កាលស្វាមីស្តុកស្តម្ភក៏ជាស្ត្រីស្តុកស្តម្ភ ( ជាមួយ ) ពួកទេវតារមែងសរសើរស្ត្រីនោះឯង ព្រោះថាស្ត្រីនោះធ្វើអំពើ

ដែលគេធ្វើបានដោយក្រ ។ ខ្ញុំម្ចាស់នឹងស្លៀកសំពត់កាសាយៈ ហើយដើរតាមប្តីសព្វៗកាល ភាពជាស្ត្រីមេម៉ាយ ទោះបីមានផែនដីមិនបែក ( បានជាធំលើផែនដីទាំងមូល ) ក៏នៅតែក្តៅក្រហាយដែរ ។ ម្យ៉ាងទៀតខ្ញុំម្ចាស់បើប្រាសព្រាត់ព្រះវេស្សន្តរជាប្តីហើយមិនចង់បានផែនដីដែលមានសមុទ្ទព័ទ្ធជុំវិញ ទ្រទ្រង់ទ្រព្យដ៏ច្រើន ជាផែនដីបរិបូណ៌ដោយរតនៈផ្សេងៗទេ ។ ពួកស្ត្រីណាជាស្ត្រីរឹងរូសយ៉ាងក្រៃលែង កាលដែលស្វាមីដល់នូវសេចក្តីទុក្ខហើយប្រាថ្នាសេចក្តីសុខដល់ខ្លួនតែម្យ៉ាង ហឫទ័យរបស់ស្ត្រីទាំងនោះនឹងទៅជាដូចម្តេចហ្ន៎ ។ កាលបើមហារាជដែលញុំាងពួកអ្នកសិវិរាស្ត្រឲ្យចម្រើន ទ្រង់ចេញទៅហើយ ខ្ញុំម្ចាស់នឹងទៅតាមមហារាជនោះ ព្រោះថាព្រះអង្គជាអ្នកឲ្យវត្ថុជាទីប្រាថ្នាគ្រប់យ៉ាងដល់ខ្ញុំម្ចាស់ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តមព្រវិ** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ ព្រះនាងមទ្រីបានស្តាប់ព្រះតម្រាស់របស់ព្រះបាទសញ្ជ័យហើយ បានទូលតបនឹងព្រះបាទសញ្ជ័យនោះ ។ បទថា **អភិសម្ភោស្សំ** បានដល់ នឹងស៊ូទ្រាំ គឺនឹងអត់ធ្មត់ ។ បទថា **ចោតកិលំ** បានដល់ ស្មៅដែលមានជ្រុងមុត ។ បទថា **បន្ថមហិស្សាមិ** សេចក្តីថា ខ្ញុំនឹងវែកទៅខាងមុខព្រះវេស្សន្តរ ។ បទថា **ឧទរស្សុបរោធេន** បានដល់ ការវៀរ គឺបរិភោគអាហារបន្តិចបន្តួច ។ បទថា **គោហនុវេដ្ឋនេន** សេចក្តីថា ពួកកុមារិកាដឹងថាស្ត្រីមានត្រគាកធំ និងមាន

ឆ្អឹងជំនីរមូលរមែងបានប្តី ទើបយកឈើមានសណ្ឋានដូចចង្កាគោវាយត្រគាក រឿយៗ យកសំពត់រឹតឆ្អឹងជំនីរទាំង ២ ឲ្យមូលរមែងបានប្តី ។ បទថា **កដុកំ** បានដល់ មិនគួរត្រេកអរ ។ បទថា **គច្ឆញ្ញោវ** បានដល់ ត្រូវទៅឲ្យបាន ។ បទថា **អប្បវេត្តា** សេចក្តីថា មិនសមគួរបរិភោគរបស់ដែលជាសំណល់នៃស្រីមេម៉ាយនោះឯង ។ បទថា **យោ ធំ** សេចក្តីថា បុរសណាមានជាតិទាបចាប់ដៃទាំង ២ អូសស្រីមេម៉ាយនោះដែលមិនប្រាថ្នាឡើយ ។ បទថា **កេសគ្គហាណមុក្ខេថា ភូម្យា ច បរិសុម្ភនា** សេចក្តីថា ពួកបុរសចាប់ផ្នួងសក់ស្រីដែលមិនមានប្តីទាញឲ្យដួលចុះលើផែនដី មើលងាយ ប្រព្រឹត្តកន្ទង់នូវស្រីនោះ ។ បទថា **ទត្វា ច** សេចក្តីថា បុរសជទៃឲ្យនូវសេចក្តីទុក្ខជាច្រើនគឺមិនមែនតិចបែបនេះ ដល់ស្រីដែលមិនមានប្តី ។ បទថា **ឆោ បក្កមតិ** សេចក្តីថា ជាអ្នកប្រាសចាកសេចក្តីរង្កៀស ឈរមើលស្រីនោះ ។ បទថា **សុក្កច្ឆវី** បានដល់ មានពណ៌សម្បុរដែលដុសខាត់ដោយលម្អិតសម្រាប់ផ្ងូត ។ បទថា **វេធវេរា** សេចក្តីថា មានសេចក្តីត្រូវការស្រីមេម៉ាយ ។ បទថា **ទត្វា** បានដល់ ឲ្យទ្រព្យមានប្រមាណតិចតួចណាមួយក៏ដោយ ។ បទថា **សុភគ្គមានិនោ** បានដល់ យល់ថាខ្លួនពួកយើងស្អាតក្រៃលែង ។ បទថា **អកាមំ** បានដល់ ស្រីមេម៉ាយ គឺស្រីមិនមានប្តីដែលមិនប្រាថ្នានោះ ។ បទថា **ឧលូកញ្ញោវ វាយសា** សេចក្តីថា ដូចហ្វូងក្អែកចោមចឹកនូវសត្វមៀម ។ បទថា **កំសបជ្ជោតនេ** បានដល់ រុងរឿងដោយភាជនៈមាស ។ បទថា **វសំ** បានដល់ នៅក្នុងត្រកូលញាតិបែបនោះ ។ បទថា **នេវាតិ វាក្យំ ន លភេ**

សេចក្តីថា គប្បីបាន គឺរមែងបាននោះឯង នូវពាក្យដែលជាពាក្យកន្ទង់ល្មើស គឺជាពាក្យតិះដៀលនេះអំពីបងប្អូនក្តី អំពីសម្លាញ់ក្តីដែលពោលពាក្យជាដើមថា ស្រីនេះមិនមានប្តីលំបាកដល់ពួកយើងអស់មួយជីវិត ។ បទថា **បញ្ញាណំ** បានដល់ ធ្វើការៈឲ្យប្រាកដ ។ បទថា **យា ទលិទ្ទី ទលិទ្ទស្ស** សេចក្តីថា ខ្ញុំម្ចាស់ជាស្រីដែលមានកិត្តិយស គឺស្រីក្នុងពេលដែលប្តីក្រីក្រ មានសេចក្តីទុក្ខខ្លួនឯងក៏ក្រីក្ររួមទុក្ខជាមួយដែរ ក្នុងពេលដែលប្តីនោះមានស្តុកស្តម្ភ មាននូវសេចក្តីសុខ ខ្លួនឯងក៏ស្តុកស្តម្ភមានសេចក្តីសុខជាមួយប្តីនោះដូចគ្នា ។ បទថា **តំ វេ ទេវា បសំសន្តិ** សេចក្តីថា សូម្បីទេវតាទាំងឡាយក៏សរសើរស្រីនោះ គឺស្រីបែបនោះ ។ បទថា **អភិជ្ជន្តា** បានដល់ មិនបែក អធិប្បាយថា បើផែនដីទាំងមូលរបស់ស្រីមិនបែក ស្រីនោះក៏នឹងជាធំក្នុងផែនដីទាំងមូលកាពជាស្រីមេម៉ាយ ជាសេចក្តីលំបាកយ៉ាងនោះឯង ។ បទថា **សុខា វត ឥត្ថិយោ** បានដល់ ជាស្រីគ្រោតគ្រាតហ្ន៎ ។

ព្រះបាទសញ្ជយមហារាជ មានព្រះរាជឱង្ការនឹងព្រះនាងមទ្រី
ដែលមានអវយវៈទាំងអស់ដ៏ល្អនោះថា ម្នាលនាងមានលក្ខណ៍
នាងចូរទុកកូនតូចទាំងពីររបស់នាង គឺបាជាលីនិងនាងកណ្ហា-
ជិនានេះហើយទៅចុះ យើងនឹងចិញ្ចឹមកូនតូចទាំងនោះ ។

បណ្តាបទទាំងនោះ បទថា **ជាលី កណ្ហាជិនា ចុភោ** បានដល់ កូនទាំង ២ គឺបាជាលីនិងមេកណ្ហាជិនា ។ បទថា **និក្ខិប្ប** សេចក្តីថា ចូរនាងលះចៅទាំង ២ នេះ ទៅតែខ្លួនចុះ ។

ព្រះរាជបុត្រីព្រះនាមមទ្រីដែលមានអវយវៈទាំងអស់ដ៏ល្អ បាន ក្រាបទូលព្រះរាជានោះវិញថា បពិត្រព្រះទេវៈ កូនតូចទាំងពីរ គឺបុជាលីនិងនាងកណ្ហាជិនា ជាទីស្រឡាញ់របស់ខ្ញុំម្ចាស់ កូនតូចទាំងពីរនោះនឹង ( ញុំាំងហឫទ័យ ) នៃយើងខ្ញុំដែល មិនទាន់ប្រាសចាកសេចក្តីសោកឲ្យត្រេកអរក្នុងព្រៃនោះបាន ។

បណ្តាបទទាំងនោះ បទថា **តេ្យម្ហំ** សេចក្តីថា គេទាំងនោះនឹងញុំាំងហឫទ័យនៃយើងទាំងឡាយឲ្យត្រេកអរក្នុងព្រៃនោះ ។ បទថា **ជីវសោកិនំ** សេចក្តីថា នឹងញុំាំងហឫទ័យរបស់ពួកយើង ដែលមិនទាន់ប្រាសចាកសេចក្តីសោក ឲ្យត្រេកអរ ។

ព្រះបាទសញ្ជយមហារាជ ទ្រង់ញុំាំងពួកអ្នកសិវិរាស្ត្រឲ្យបម្រើន មានព្រះបន្ទូលនឹងព្រះនាងមទ្រីនោះថា ក្មេងទាំងពីរធ្លាប់បរិភោគបាយអង្ករសាលីលាយដោយសាច់ដ៏ស្អាត នឹងបរិភោគផ្លែឈើធ្វើម្តេចកើត ។ ក្មេងទាំងពីរធ្លាប់បរិភោគភោជនក្នុងភាជន៍មាស ដែលមានទម្ងន់ ១០០ បល្វៈ មានស្នាមចម្លាក់មួយ ១០០ នឹងបរិភោគភោជនដែលដាក់ក្នុងស្លឹកឈើធ្វើម្តេចកើត ។ ក្មេងទាំងពីរធ្លាប់ស្លៀកដណ្តប់សំពត់អ្នកដែនកាសីផង សំពត់ខោមៈផង សំពត់កោទុម្ពរៈផង នឹងស្លៀកដណ្តប់សំពត់ ដែលក្រងដោយស្បូវក្លាំងធ្វើម្តេចកើត ។ ក្មេងទាំងពីរធ្លាប់ទៅដោយវ ដោយគ្រែស្នែង ដោយរថ នឹងដើរទៅដោយជើងធ្វើម្តេចកើត ។ ក្មេង

ទាំងពីរធ្លាប់ដេកក្នុងផ្ទះមានកំពូល មានសន្ទះទ្វារនិងបង្អួចដ៏ជិតស្និទ្ធ ខ្យល់ចេញចូលមិនបាន នឹងដេកទៀបគល់ឈើធ្វើម្ដេចកើត ។ ក្មេងទាំងពីរធ្លាប់ដេកលើបល្ល័ង្ក លើកម្រាលរោមវែងនិងលើកម្រាលដ៏វិចិត្រ នឹងដេកលើកម្រាលស្មៅធ្វើម្ដេចកើត ។ ក្មេងទាំងពីរធ្លាប់លាបស្រឡាបដោយគ្រឿងក្រអូប គឺខ្លឹមក្រស្នាខ្លឹមចន្ទន៍ នឹងស្លៀកដណ្ដប់សំពត់ប្រឡាក់ក្អែលធ្វើម្ដេចកើត ។ ក្មេងទាំងពីរ ធ្លាប់បិតនៅក្នុងសេចក្ដីសុខ មានអវយវៈគេតែងបក់ដោយផ្លិតរោមចាមរីនិងសំណុំកន្ទុយក្ងោក ត្រូវរបោមមូសប៉ះពាល់នឹងធ្វើដូចម្ដេចកើត ។

បណ្ដាបទទាំងនោះ បទថា **សតបលេ កំសេ** បានដល់ ក្នុងថាសមាសដែលធ្វើដោយមាសទម្ងន់ ១០០ បល្ល: ។ បទថា **គោណកេ ចិត្រសន្ថតេ** បានដល់ កម្រាលដែលធ្វើដោយសំពត់កោជវៈខ្មៅនិងកម្រាលដ៏វិចិត្រលើគ្រែធំ ។ បទថា **ចាមរមោរហត្ថេហិ** សេចក្ដីថា មានមនុស្សបក់ដោយផ្លិតរោមចាមរីនិងដោយផ្លិតកន្ទុយក្ងោក ។

កាលស្ដេចទាំងនោះចរចាគ្នាយ៉ាងនេះរាត្រីក៏អស់ទៅ ព្រះអាទិត្យក៏រះឡើង អាមាត្យទាំងឡាយ នាំរថព្រះទីន័ងដែលតាក់តែងហើយ មកទឹមដោយសេះសិន្ធព ៤ ត្រង់ទ្វារព្រះរាជវាំងដើម្បីព្រះមហាសត្វ ។ ព្រះនាងមទ្រីទេវីថ្វាយបង្គំមាតាបិតាក្មេកហើយលាស្ត្រីដ៏សេសទាំងឡាយ នាំជាលីកុមារនិងកណ្ហាជិនាយាងទៅមុនព្រះវេស្សន្តរ ប្រថាប់នៅលើរថព្រះទីន័ង ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសានូវព្រះគាថាដូច្នេះថា

ព្រះរាជបុត្រីទ្រង់ព្រះនាមមទ្រី ដែលមានអវយវៈទាំងអស់ដ៏ល្អ ក្រាបទូលព្រះរាជបិតានោះថា បពិត្រព្រះទេវៈ ព្រះអង្គកុំទ្រង់ព្រះកន្សែងឡើយ សូមព្រះអង្គកុំមានព្រះហឫទ័យអាក់អន់ឡើយ ខ្ញុំម្ចាស់ទាំងពីរនាក់នឹងរស់នៅយ៉ាងណា ក្មេងទាំងពីរនាក់ក៏រស់នៅយ៉ាងនោះដែរ ។ ព្រះនាងមទ្រីដែលមានអវយវៈទាំងអស់ដ៏ល្អ ដ៏ទ្រង់លក្ខណ៍ លុះបានពោលពាក្យយ៉ាងនេះហើយ ក៏នាំព្រះរាជបុត្រាបុត្រីទៅតាមផ្លូវ ដែលព្រះបាទសិវិ (វេស្សន្តរ) ទ្រង់ស្តេចទៅ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សិវិមគ្គេន** បានដល់ តាមផ្លូវដែលព្រះបាទសិវិរាជយាងទៅនោះឯង ។ បទថា **អន្វេសិ** បានដល់ យាងទៅកាន់ផ្លូវនោះ គឺយាងចុះអំពីប្រាសាទ ឡើងប្រថាប់លើរថព្រះទីន័ង ។

លំដាប់នោះព្រះវេស្សន្តរជាក្សត្រ ទ្រង់បានឲ្យទានហើយ ក៏ថ្វាយបង្គំព្រះបិតានិងព្រះមាតា ធ្វើប្រទក្សិណព្រះបិតានិងព្រះមាតានោះ ។ ព្រះវេស្សន្តរឡើងកាន់រថដែលទឹមដោយសេះ ៤ មានសន្ទុះដ៏លឿន នាំបុត្រាបុត្រីនិងព្រះជាយា ស្តេចទៅកាន់គិរីវង្កត ។

បណ្តាបទទាំងនោះ បទថា **តទោ** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ ក្នុងកាលដែលព្រះនាងមទ្រីនោះឡើងរថព្រះទីន័ងប្រថាប់ ។ បទថា **ឧត្វាន** បានដល់ ទ្រង់បំពេញទានកាលពីម្សិលមិញ ។ បទថា **កត្វា ច ឆំ បទក្ខិណំ** បានដល់ ហើយទ្រង់ធ្វើប្រទក្សិណសម្តែងសេចក្តីគោរព ។ បទថា **ឆំ** ត្រឹមតែជានិបាតប៉ុណ្ណោះ ។

លំដាប់នោះ ព្រះរាជាទ្រង់ព្រះនាមវេស្សន្តរ ទ្រង់បររថសំដៅ
ទៅរកទីដែលមានជនច្រើនហើយត្រាស់ថា យើងសូមលាអ្នក
រាល់គ្នាទៅហើយ សូមឲ្យពួកញាតិកុំមានរោគឡើយ ។

អត្ថនៃគាថានោះដូច្នេះថា ម្នាលភិក្ខុទាំងឡាយ លំដាប់នោះព្រះរាជាវេស្សន្តរទ្រង់បររថព្រះទីន័ងទៅកាន់ទីដែលមហាជនឈរដែលបំណងថា អញនឹងឃើញព្រះវេស្សន្តរ កាលទ្រង់លាមហាជនត្រាស់ថា ពួកយើងសូមលាពួកអ្នកទៅ សូមញាតិទាំងឡាយកុំបីមានរោគឡើយ ។ បទថា **តំ** ក្នុងគាថានោះ ត្រឹមតែជានិបាត ។ ម្នាលភិក្ខុទាំងឡាយ ព្រះរាជាវេស្សន្តរត្រាស់នឹងញាតិទាំងឡាយថា ញាតិទាំងឡាយ យើងទាំងឡាយសូមលាពួកអ្នកទៅ សូមអ្នកទាំងឡាយមានសេចក្តីសុខ ប្រាសចាកសេចក្តីទុក្ខចុះ ។

កាលមហាសត្វត្រាស់ហៅមហាជនមក ប្រទានឱវាទថា អ្នកទាំងឡាយចូរជាបុគ្គលកុំប្រមាទ ចូរបំពេញកុសលមានទានជាដើម ដូច្នេះហើយយាងទៅ ព្រះនាងផុស្សតីរាជមាតានៃព្រះពោធិសត្វត្រិះរិះថា កូនរបស់យើងមានចិត្តបង្អោនទៅក្នុងទាន ចូរបំពេញទាន ទើបបញ្ជូនរទេះទាំងឡាយពេញទៅ

ដោយរតនៈ ៧ ប្រការមួយអន្លើដោយអាភរណៈទាំងឡាយ ទៅសងខាងផ្លូវដែលព្រះវេស្សន្តរទ្រង់យាង ។ ចំណែកព្រះវេស្សន្តរក៏ដោះគ្រឿងប្រដាប់ដែលមានក្នុងព្រះវរកាយ ព្រះរាជទានដល់យាចកដែលមកដល់អស់ ១៨ ដង បានព្រះរាជទាននូវវត្ថុដ៏សេសទាំងអស់ ។ ព្រះវេស្សន្តរ ទ្រង់ចេញចាកព្រះនគរ មានបំណងទតមើលរាជធានី ខណៈនោះអាស្រ័យចិត្តគិតរបស់ទ្រង់ មហាប្រឹថពីដែលមានប្រមាណប៉ុនរថព្រះទីន័ង ក៏វិលដូចក្តារយន្ត របស់ស្មូនឆ្នាំង បន្ទិលរថឲ្យបែរមុខមកជេតុត្តររាជធានី ព្រះវេស្សន្តរ ទតទីប្រថាប់របស់ព្រះជនកព្រះជននី ហេតុដ៏អស្ចារ្យទាំងឡាយមានផែនដីកម្រើកជាដើមមានហើយដោយករុណាការនោះ ។

ដោយហេតុនោះទើបព្រះសាស្តាត្រាស់ថា

កាលដែលព្រះបាទវេស្សន្តរ ស្តេចចេញអំពីព្រះនគរ ហើយ
ងាកក្រឡេកទតព្រះរាជនិវេសន៍ គ្រានោះឯងផែនដីដែលមាន
ភ្នំសិនេរុនិងព្រៃជាគ្រឿងប្រដាប់ក៏ញាប់ញ័រ ដូច្នេះ ។

កាលព្រះមហាសត្វទតហើយត្រាស់ព្រះគាថាឲ្យនាងមទ្រីទតដែរថា
នែនាងមទ្រី នាងចូរគន់មើលចុះ ( នុ៎ះ ) និវេសន៍របស់ព្រះបាទ
សិវិដ៏ប្រសើរ ( នុ៎ះ ) វាំងរបស់យើង ដែលព្រះបិតាប្រទានឲ្យ
ប្រាកដជារូបគួរត្រេកអរ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **និសាមេហិ** បានដល់ ចូរទត ។ កាលនោះព្រះវេស្សន្តរមហាសត្វញ៉ាំងអាមាត្យ ៦ ម៉ឺន ដែលជាសហជាតិនិងមនុស្ស

ដទៃៗឲ្យត្រឡប់ហើយទ្រង់បររថទៅជាមួយព្រះនាងមទ្រីហើយត្រាស់នឹងព្រះនាងមទ្រីថា នែនាងដ៏ចម្រើន នាងគប្បីមើលទៅខាងក្រោយ បើឃើញយាចកមក ចូរប្រាប់អញ ព្រះនាងកំពុងទតនោះឯង គ្រានោះមានពួកព្រាហ្មណ៍ ៤ នាក់ មកមិនទាន់សត្តសតកមហាទានរបស់ព្រះវេស្សន្តរ ទើបទៅកាន់ព្រះនគរសួរថា ព្រះវេស្សន្តរយាងទៅឯណា បានដឹងថា ទ្រង់បរិច្ចាគទានយាងទៅហើយ ទើបសួរថាទ្រង់នាំយកអ្វីទៅខ្លះ បានដឹងថាទ្រង់បររថទៅ ទើបរត់តាមដោយគិតថា ពួកយើងនឹងសូមសេះទាំង ៤ ជាមួយទ្រង់ កាលនោះព្រះនាងមទ្រីទតឃើញព្រាហ្មណ៍ទាំង ៤ តាមមកក៏ក្រាបទូលព្រះភស្តាថា បពិត្រព្រះសម្មតិទេព យាចកទាំងឡាយកំពុងមក ព្រះមហាសត្វទ្រង់បញ្ឈប់រថព្រះទីន័ង ព្រាហ្មណ៍ទាំង ៤ មកទូលសូមសេះទាំងឡាយដែលទឹមដោយរថ ព្រះពោធិសត្វបានប្រទានសេះទាំង ៤ ដល់ព្រាហ្មណ៍ ៤ នាក់នោះ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** វែអាចិធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសានូវព្រះគាថាដូច្នេះថា

> ពួកព្រាហ្មណ៍បានទៅតាមព្រះបាទវេស្សន្តរនោះ ព្រាហ្មណ៍ទាំង
> នោះបានសុំសេះទាំងឡាយអំពីព្រះបាទវេស្សន្តរនោះ ព្រះបាទ
> វេស្សន្តរលុះពួកព្រាហ្មណ៍សុំហើយ ក៏បានប្រទានសេះទាំង ៤
> ដល់ព្រាហ្មណ៍ទាំង ៤ នាក់ ។

កាលព្រះវេស្សន្តរព្រះរាជទានសេះ ៤ ទៅហើយ នឹមនិងចន្ទោលរថមិន

ធ្លាក់ដល់ដី តាំងនៅក្នុងអាកាសនោះឯង គ្រាន់តែពួកព្រាហ្មណ៍ទៅប៉ុណ្ណោះ ទេវបុត្ត ៤ អង្គ កាឡាខ្លួនជារមាំងមាសមកទ្រទ្រង់នឹមអូសទៅ ព្រះមហាសត្វ ដឹងថារមាំងទាំង ៤ ជាទេវបុត្តទើបត្រាស់គាថានេះថា

នែមទ្រី នាងចូរគន់មើលចុះម្រឹគទាំងឡាយ មានភេទជារមាំង នាំខ្ញុំទៅដូចសេះដែលគេទូន្មានល្អហើយ ប្រាកដជារូបដ៏វិចិត្រ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ទក្ខិណស្សា វហន្តិ មំ** សេចក្ដីថា បីដូចជាសេះដែលសិក្សាល្អហើយ នាំយើងទៅ ។

កាលនោះ មានព្រាហ្មណ៍ម្នាក់មកទូលសូមរថចំពោះព្រះវេស្សន្តរ ដែលកំពុងទៅយ៉ាងនោះ ។ ព្រះមហាសត្វញ៉ាំងព្រះរាជឱរសនិងព្រះរាជធីតា មួយអន្លើដោយព្រះទេវីឲ្យយាងចុះហើយព្រះរាជទានរថដល់ព្រាហ្មណ៍នោះ កាលមហាសត្វព្រះរាជទានរថនោះហើយទេវបុត្តទាំងឡាយក៏អន្តរធានទៅ ។

ព្រះសាស្ដាកាលទ្រង់ប្រកាសភាពដែលមហាសត្វបរិច្ចាគរថ ទើបត្រាស់ថា

លំដាប់នោះព្រាហ្មណ៍ទី ៥ ក៏មកក្នុងព្រៃនោះ ព្រាហ្មណ៍នោះ បានសុំរថអំពីព្រះបាទវេស្សន្តរនោះ ព្រះបាទវេស្សន្តរក៏ប្រទាន រថដល់ព្រាហ្មណ៍នោះ ព្រះហឫទ័យរបស់ព្រះបាទវេស្សន្តរមិន បានរួញរាឡើយ ។

ព្រះបាទវេស្សន្តរទ្រង់ឲ្យជន គឺព្រះទេវី បុត្រាបុត្រីរបស់ព្រះ

អង្គ ( ចុះពីរថនោះ ) រួចប្រទានអស្សរថដល់ព្រាហ្មណ៍ អ្នក
ស្វែងរកទ្រព្យ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អថេត្ថ** បានដល់ កាលនោះក្នុងព្រៃនេះ ។ បទថា **ន ចស្ស បហាតោ មនោ** សេចក្តីថា ព្រះហឫទ័យរបស់ព្រះវេស្សន្តរមិនរួញរាទ្បើយ ។ បទថា **អស្សាសយិ** សេចក្តីថា ទ្រង់ឲ្យដោយត្រេកអរ ។

តាំងអំពីនោះមកក្សត្រទាំងនោះក៏យាងទៅដោយព្រះបាទ ។ លំដាប់នោះព្រះមហាសត្វមានព្រះតម្រាស់នឹងព្រះនាងមទ្រីថា

នែមទ្រី នាងចូរពរកណ្ហាចុះ ដ្បិតកណ្ហានុះជាប្អូននៅតូចស្រាល
ខ្ញុំនឹងពរជាលី ដ្បិតជាលីនោះជាបងដ៏ធ្ងន់ ដូច្នេះ ។

កាលត្រាស់ដូច្នេះហើយស្តេចទាំង ២ ក៏ពរព្រះរាជឱរសនិងព្រះរាជធីតាយាងទៅ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** វីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសាទូវព្រះគាថាដូច្នេះថា

ព្រះរាជាទ្រង់ពរជាលីកុមារ ចំណែកព្រះរាជបុត្រីទ្រង់ពរនាង
កណ្ហាជិនាទ្រង់យាងទៅ មានព្រះបន្ទូលព្រះវាចាជាទីស្រឡាញ់
សំណេះសំណាលទៅវិញទៅមក ដូច្នេះ ។

**ទានកណ្ឌ ចប់**

# វនប្បវេសនកណ្ឌ

ក្សត្រទាំង ៤ អង្គ មានព្រះវេស្សន្តរជាដើមទតឃើញមនុស្សទាំងឡាយធ្វើដំណើរមកទើបត្រាស់សួរថា ភ្នំវង្កតនៅឯណា មនុស្សទាំងឡាយទូលថា នៅឆ្ងាយណាស់ ព្រោះហេតុនោះទើបព្រះសាស្ដាត្រាស់ថា

( ក្សត្រទាំងនោះមានព្រះបន្ទូលសំណេះសំណាលថា ) ប្រសិនបើពួកមនុស្សណាមួយមកចួបក្នុងផ្លូវជាលំដាប់ យើងនឹងសួររកផ្លូវនឹងមនុស្សទាំងនោះថា វង្កតបព៌តនៅក្នុងទីណា ។ មនុស្សទាំងនោះ បានឃើញយើងក្នុងទីនោះហើយសមជាទួញយំ មុខគួរឲ្យអណោចអធម្ម មនុស្សទាំងនោះក៏ប្រាប់សេចក្ដីទុក្ខថា វង្កតបព៌តនៅក្នុងទីឆ្ងាយ ដូច្នេះ ។

ជាលីនិងកណ្ហាជិនាបានទតឃើញដើមឈើ ទ្រទ្រង់នូវផ្លែផ្សេងៗ សងខាងមាគ៌ា ក៏ទ្រង់ព្រះកន្សែងទារនូវផ្លែឈើផ្សេងៗ ដោយបុញ្ញានុភាពនៃព្រះមហាសត្វ ដើមឈើទាំងនោះក៏យោនយានទោរទន់មករកព្រះហស្តរបស់ព្រះមហាសត្វ ព្រះវេស្សន្តរក៏បេះផ្លែឈើតូចធំដែលទុំល្អឲ្យដល់កុមារកុមារីនោះ ព្រះនាងមទ្រី ទតឃើញដូច្នោះព្រះនាងដឹងថានេះជាហេតុអស្ចារ្យហ្ន៎ ។ ព្រោះហេតុនោះទើបព្រះសាស្ដាត្រាស់ថា

បើក្មេងទាំងពីរបានឃើញដើមឈើដែលមានផ្លែក្នុងព្រៃ ក្មេងទាំងពីររមែងយំទារព្រោះហេតុចង់បានផ្លែឈើទាំងនោះ ។ ដើមឈើទាំងឡាយដ៏ខ្ពស់ ឃើញក្មេងទាំងពីរកំពុងយំ ក៏ទោរទន់

មកជិតក្មេងទាំងពីរដោយខ្លួនឯងតែម្តង ។ ព្រះនាងមទ្រីដែល
មានអវយវៈទាំងអស់ដ៏ល្អបានឃើញហេតុនេះជាហេតុអស្ចារ្យ
ចម្លែកគួរឲ្យព្រឺរោម ក៏ញុំាងសាធុការឲ្យប្រព្រឹត្តទៅថា ឱហ្ន៎
(នេះ) គួរអស្ចារ្យណាស់ចម្លែកណាស់ គួរឲ្យព្រឺរោមក្នុងលោក
ដើមឈើទាំងឡាយស្រោប់តែទោរចុះមកឯង ដោយតេជះនៃព្រះ
វេស្សន្តរ ដូច្នេះ ។

តាំងអំពីជេតុត្តររាជធានីមកភ្នំឈ្មោះ សុវណ្ណគិរីតាល មានចម្ងាយ ៥ យោជន៍ ពីភ្នំសុវណ្ណគិរីតាលមកដល់ស្ទឹងឈ្មោះកោន្តិមារា មានចម្ងាយ ៥ យោជន៍ ពីស្ទឹងកោន្តិមារាដល់ភ្នំអញ្ចរគិរីមានចម្ងាយ ៥ យោជន៍ តាំងអំពីភ្នំអញ្ចរគិរីដល់ស្រុកព្រាហ្មណ៍ឈ្មោះទុន្និវិដ្ឋៈ មានចម្ងាយ ៥ យោជន៍ ពីស្រុកព្រាហ្មណ៍ឈ្មោះ ទុន្និវិដ្ឋៈដល់មាតុលនគរមានចម្ងាយ ១០ យោជន៍ រួមតាំងអំពីជេតុត្តរនគរដល់ដែននោះជា ៣០ យោជន៍ ទេវតាបំព្រួញផ្លូវនោះ ទើបស្តេចទាំង ៤ អង្គ មកដល់មាតុលនគរត្រឹមតែមួយថ្ងៃប៉ុណ្ណោះព្រោះហេតុនោះ ទើបព្រះសាស្តាត្រាស់ថា

យក្ខទាំងឡាយបំប្រួញផ្លូវ ដោយសេចក្តីអនុគ្រោះចំពោះក្មេង
ទាំងពីរ ក្សត្រទាំងនោះបានទៅដល់ដែនឈ្មោះចេតៈតែមួយថ្ងៃ
រាប់ពីស្តេចចេញទៅ ដូច្នេះ ។

ក្សត្រទាំង ៤ កាលយាងទៅបានយាងចេញអំពីជេតុត្តរនគរ ក្នុងកាលសោយអាហារព្រឹកហើយ លុះមកដល់មាតុលនគរក្នុងចេតរដ្ឋក៏មកដល់ក្នុង

វេលាល្ងាច ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសាទូវព្រះគាថាដូច្នេះថា

ក្សត្រទាំងនោះយាងទៅកាន់ផ្លូវឆ្ងាយ ក៏បានដល់ដែនឈ្មោះ

ចេតៈ ដែលជាជនបទស្តុកស្តម្ភធំទូលាយមានសាច់ សុរានិង

ទឹកច្រើន ដូច្នេះ ។

កាលនោះស្តេចគ្រប់គ្រងក្នុងមាតុលនគរ មាន ៦ ម៉ឺនអង្គ ព្រះមហាសត្វមិនយាងចូលទៅខាងក្នុងនគរ ស្នាក់នៅត្រង់សាលាក្បែរទ្វារនគរ គ្រានោះព្រះនាងមទ្រីជូតធូលីត្រង់ព្រះបាទរបស់ព្រះមហាសត្វហើយធ្វើការគក់ប្របាច់ព្រះបាទាព្រះនាងគិតថា អញនឹងញុំាងមហាជនឲ្យដឹងភាពដែលព្រះវេស្សន្តរយាងមកទើបយាងចេញអំពីសាលា ប្រថាប់ឈរត្រង់ទ្វារសាលាក្នុងទីដែលព្រះមហាសត្វទតឃើញបាន ព្រោះហេតុនោះស្រីទាំងឡាយដែលចូលកាន់នគរនិងចេញអំពីនគរ ក៏បានឃើញព្រះនាងមទ្រីទើបនាំគ្នាចោមរោម ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសាទូវព្រះគាថាដូច្នេះថា

អ្នកដែនចេតៈទាំងឡាយបានឃើញព្រះនាងមទ្រី ដែលប្រកប

ដោយលក្ខណៈ ស្តេចមកដល់ហើយ ក៏នាំគ្នាចោមរោមចរចា

ថា ឱហ្ន៎ ព្រះនាងម្ចាស់ជាសុខុមាលជាតិ ស្តេចសញ្ចរមកដោយព្រះបាទទទេ ។ សម្តេចព្រះមទ្រីនោះធ្លាប់ស្តេចទៅដោយរ តែគ្រស្នែងនិងរថ តែក្នុងថ្ងៃនេះស្តេចទៅក្នុងព្រៃដោយព្រះបាទទទេដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **លក្ខណាមាគតំ** សេចក្តីថា ព្រះនាងមទ្រីដែលដល់ព្រមដោយលក្ខណៈទាំងពួងយាងមក ។ បទថា **បរិភាវតិ** សេចក្តីថា ព្រះនាងជាក្សត្រសុខុមាលជាតិយ៉ាងនេះត្រូវយាងដោយព្រះបាទត្រាច់ទៅ ។ បទថា **បរិយាយិត្វា** សេចក្តីថា ព្រះនាងយាងទៅក្នុងជេតុត្តរនគរក្នុងកាលមុន ។ បទថា **សិវិកាយ** បានដល់ ដោយវមាស ។

មហាជនឃើញនាងមទ្រី ព្រះវេស្សន្តរនិងកូនទាំង ២ របស់ទ្រង់យាងមកដោយភាពជាបុគ្គលគួរករុណា ទើបទៅប្រាប់ដល់ព្រះបាទចេតរាជទាំងឡាយ ស្តេចចេតរាជទាំង ៦ ម៉ឺន អង្គ ក៏នាំគ្នាព្រះកន្សែងមកគាល់ព្រះវេស្សន្តរ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសានូវព្រះគាថាដូច្នេះថា

ព្រះរាជាចេតៈទាំងឡាយ លុះបានឃើញព្រះបាទវេស្សន្តរនោះ ហើយក៏ទ្រង់ព្រះកន្សែងចូលទៅជិតថា បពិត្រព្រះទេវៈ ព្រះអង្គសុខស្រួលទេឬ បពិត្រព្រះទេវៈ ព្រះអង្គមិនមានជំងឺតម្កាត់ទេឬ ។ ព្រះបិតារបស់ព្រះអង្គមិនមានរោគទេឬ ពួកអ្នកសិវិរាស្ត្រ

មិនមានជំងឺតម្កាត់ទេឬ បពិត្រមហារាជ ទៅណាទៅពួកពល
របស់ព្រះអង្គ ទៅណាទៅរថមណ្ឌលរបស់ព្រះអង្គ ។ ព្រះអង្គ
ទ្រង់ស្តេចមកកាន់ផ្លូវឆ្ងាយមិនមានសេះ មិនមានរថ ពួកបច្ចា
មិត្តគ្របសង្កត់ព្រះអង្គឬទើបស្តេចយាងមកកាន់ទិសនេះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ទិស្វា** បានដល់ ឃើញអំពីចម្ងាយ ។ បទថា **ជេតចាមោក្ខា** បានដល់ ស្តេចចេតរាជទាំងឡាយ ។ បទថា **ឧចាគមុំ** បានដល់ ចូលទៅរក ។ បទថា **កុសលំ** បានដល់ ការមិនមានរោគ ។ បទថា **អនាមយំ** បានដល់ ការមិនមានទុក្ខ ។ បទថា **កោ តេ ពលំ** សេចក្តីថា កងទាហានរបស់ព្រះអង្គនៅឯណា ។ បទថា **រថមណ្ឌលំ** សេចក្តីថា ពួកស្តេចចេតរាជទូលសួរថា រថដែលប្រដាប់ហើយដែលទ្រង់យាងមកនោះនៅឯណា ។ បទថា **អនស្សកោ** បានដល់ មិនមានសេះឡើយ ។ បទថា **អរថកោ** បានដល់ មិនមានរថឡើយ ។ បទថា **ទីឃមទ្ធានមាគតោ** សេចក្តីថា ទ្រង់មកអស់ផ្លូវឆ្ងាយ ។ បទថា **បរេតោ** បានដល់ ត្រូវសត្រូវគ្របសង្កត់ ។

កាលនោះមហាសត្វកាលត្រាស់ដល់ហេតុការណ៍ដែលទ្រង់យាងមកដល់ស្តេចចេតរាជទាំង ៦ ម៉ឺននោះទើបត្រាស់ថា

ម្នាលសម្លាញ់ទាំងឡាយយើងមានសេចក្តីសុខស្រួលទេ
ម្នាលសម្លាញ់ទាំងឡាយ យើងមិនមានជំងឺតម្កាត់អ្វីទេ ព្រះ
បិតារបស់យើងក៏មិនមានរោគទេ ទាំងពួកអ្នកសិវិរាស្ត្រក៏មិន

មានជំងឺតម្កាត់ដែរ ។ យើងបានឲ្យដំរីមានភ្លុកដូចនង្គ័ល អាចពុះពារសត្រូវ ស្គាល់ខេត្តនៃចម្បាំងគ្រប់យ៉ាង ជាដំរីដ៏ឧត្តម សសុទ្ធ បិទបាំងដោយសំពត់កម្ពលលឿង ជាដំរីចុះប្រេងអាចញាំញីសត្រូវបាន មានភ្លុក ( ល្អ ) ប្រកបដោយស៊ែ ជាដំរីសប្រហែលនឹងភ្នំកៃលាស ។ ខ្ញុំបានឲ្យដំរីនោះព្រមទាំងស្វេតច្ឆត្រ ព្រមទាំងកម្រាលលើខ្នងដ៏ល្អ ព្រមទាំងពេទ្យ ព្រមទាំងអ្នករក្សា ជាយានដ៏ប្រសើរ ជារាជពាហនៈដល់ពួកព្រាហ្មណ៍ ។ ព្រោះដំណើរនោះហើយបានជាពួកអ្នកសិវិរាស្ត្រខឹងនឹងខ្ញុំ ទាំងព្រះបិតាក៏មានព្រះហឫទ័យអាក់អន់នឹងខ្ញុំ ព្រះរាជាទ្រង់ដេញខ្ញុំ ខ្ញុំនឹងទៅឯភ្នំវង្កត នៃសម្លាញ់ទាំងឡាយ អ្នកទាំងឡាយ ចូរដឹងឱកាសជាទីនៅក្នុងព្រៃ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តស្មឹ មេ** សេចក្តីថា អ្នកសិវិទាំងឡាយខឹងនឹងខ្ញុំព្រោះហេតុនោះ ។ បទថា **ឧបហតោមនោ** សេចក្តីថា ព្រះរាជបិតាក៏ពិរោធ គឺទ្រង់អាក់អន់ទើបទ្រង់បណ្តេញខ្ញុំចាកដែន ។ បទថា **យត្ថ** សេចក្តីថា ព្រះវេស្សន្តរត្រាស់ថា ពួកយើងគួរនៅក្នុងព្រៃណា អ្នកទាំងឡាយចូរដឹងឱកាសដែលជាលំនៅរបស់ពួកយើងក្នុងព្រៃនោះ ។

លំដាប់នោះ ស្តេចចេតរាជទាំងឡាយទូលព្រះវេស្សន្តរថា

បពិត្រមហារាជ ព្រះអង្គទ្រង់យាងមកស្រួលហើយ ព្រះអង្គមិនមែនយាងមកដោយអាក្រក់ទេ ព្រះអង្គជាធំទ្រង់ស្តេចមក

ដល់ហើយ សូមព្រះអង្គមានព្រះបន្ទូលប្រាប់របស់ដែលមានក្នុងទីនេះ ។ បពិត្រមហារាជ សូមព្រះអង្គទ្រង់សោយអន្ទក់ក្រអៅឈូក ទឹកឃ្មុំ សាច់និងបាយនៃអង្ករស្រូវសាលីដ៏ស្អាត ដ្បិតព្រះអង្គយាងមកហើយ ទុកជាភ្ញៀវរបស់ទូលព្រះបង្គំជាខ្ញុំទាំងឡាយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បវេទយ** សេចក្ដីថា សូមទ្រង់ត្រាស់ប្រាប់ចុះយើងទាំងឡាយថ្វាយវត្ថុគ្រប់យ៉ាង ។ បទថា **ភិសំ** បានដល់ ក្រអៅឈូក គឺក្រអៅឈូកឯណាមួយ ។

លំដាប់នោះព្រះបាទវេស្សន្តរត្រាស់ថា

វត្ថុណាដែលអ្នកទាំងអស់ធ្វើឲ្យជារបស់មានតម្លៃ បានឲ្យដល់ខ្ញុំ វត្ថុនោះខ្ញុំក៏បានទទួលហើយ ( តែថា ) ព្រះរាជាទ្រង់បណ្ដេញខ្ញុំ ខ្ញុំនឹងទៅឯភ្នំវង្កត នៃសម្ងាញ់ទាំងឡាយ អ្នកទាំងឡាយចូរដឹងឱកាសជាទីនៅក្នុងព្រៃ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បដិគ្គហិតំ** សេចក្ដីថា វត្ថុទាំងនោះដែលអ្នកទាំងឡាយឲ្យហើយឈ្មោះថាខ្ញុំទទួលហើយនោះឯង ។ បទថា **សព្វស្ស អគ្ឃិយំ កតំ** សេចក្ដីថា បណ្ណាការ គឺរបស់ប្រគល់ឲ្យដែលអ្នកទាំងឡាយធ្វើហើយដល់ខ្ញុំគ្រប់យ៉ាង ។ បទថា **អវរុទ្ធសិ មំ រាជា** សេចក្ដីថា ព្រះបិតាបណ្ដេញ គឺនិរទេសខ្ញុំចាកដែន ព្រោះហេតុនោះខ្ញុំនឹងទៅភ្នំវង្កតប៉ុណ្ណោះ អ្នកទាំងឡាយ ចូរដឹងទីនៅក្នុងព្រៃរបស់ខ្ញុំនោះ ។ ស្ដេចចេតរាជទាំងឡាយ

ទូលថា

បពិត្រព្រះអង្គដ៏ប្រសើរក្នុងរថ សូមព្រះអង្គ ស្តេចគង់នៅក្នុងដែនឈ្មោះចេតៈនេះសិនចុះ ទម្រាំពួកព្រះរាជាចេតៈនឹងទៅកាន់សំណាក់ព្រះរាជាដើម្បីទូលអង្វរ ។ ពួកព្រះរាជាចេតត្រេកអរបានទីពឹងហើយ ហែហមចោមរោមព្រះអង្គទៅ ដើម្បីញុំាងមហារាជ ដែលញុំាងពួកអ្នកសិវិរាស្ត្រឲ្យចម្រើន ឲ្យលើកទោសចោល បពិត្រក្សត្រ សូមព្រះអង្គទ្រង់ជ្រាបយ៉ាងនេះចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **រញ្ញោ សន្តិក យាចិតុំ** សេចក្តីថា នឹងចូលទៅគាល់ព្រះរាជបិតា ដើម្បីទូលសូមអភ័យទោស ។ បទថា **និជ្ឈាបេតុំ** បានដល់ ដើម្បីឲ្យទ្រង់ជ្រាបថា ព្រះអង្គមិនមានកំហុស ។ បទថា **លទ្ធប-ច្ចយា** បានដល់ បាននូវទីពឹងហើយ ។ បទថា **គច្ឆន្តិ** បានដល់ នឹងទៅ ។ ព្រះមហាសត្វបានឮថាក៏ត្រាស់នឹងស្តេចចេតៈថា

អ្នកទាំងឡាយ កុំពេញចិត្តនឹងការទៅកាន់សំណាក់ព្រះរាជាដើម្បីទូលអង្វរមហារាជឲ្យលើកទោសចោល ព្រោះព្រះរាជាមិនជាធំក្នុងការនោះទេ ។ ព្រោះថាពួកអ្នកសិវិរាស្ត្រណា ជានាយពលក្តី ជាអ្នកនិគមក្តីសុទ្ធតែជាអ្នកខឹង ពួកអ្នកសិវិរាស្ត្រនោះចង់បណ្តេញទាំងព្រះរាជាព្រោះហេតុតែយើងផង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តត្ថ** សេចក្តីថា សូម្បីព្រះរាជបិតាក៏មិនជា

ជំក្នុងការឲ្យមហាជនជ្រាបថា យើងមិនមានកំហុសក្នុងរឿងនោះ ។ បទថា **អច្ចុគ្គតា** បានដល់ ខឹងក្រៃលែង ។ បទថា **ពលគ្គា** បានដល់ ពលនិកាយគឺមេទ័ព ។ បទថា **បជំសេតុំ** បានដល់ ដើម្បីនាំចេញចាករាជសម្បត្តិ ។ បទថា **រាជានំ** បានដល់ សូម្បីព្រះរាជបិតា ។

ស្តេចចេតរាជទាំងនោះទូលថា

បពិត្រព្រះអង្គអ្នកញ៉ាំងដែនឲ្យចម្រើន បើដំណើរហ្នឹងមានក្នុងដែនទុំរមែន សូមព្រះអង្គដែលពួកព្រះរាជាចេតៈចោមរោមទ្រង់សោយរាជ្យក្នុងដែននេះចុះ ។ ឯដែននេះ ជាដែនស្តុកស្តម្ភទូលាយជនបទក៏ស្តុកស្តម្ភជំ បពិត្រព្រះទេវៈ សូមព្រះអង្គទ្រង់ធ្វើសេចក្តីពេញព្រះហឫទ័យ ដើម្បីនឹងគ្រប់គ្រងរាជ្យដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សចេ ឯសា បវត្តេត្ថ** សេចក្តីថា បើក្នុងដែននោះមានព្រឹត្តិការណ៍យ៉ាងនេះ ។ បទថា **រដ្ឋស្ស មនុសាសិតុំ** បានដល់ ដើម្បីគ្រប់គ្រងសម្បត្តិម្យ៉ាងទៀត បាឋៈក៏យ៉ាងនេះឯង ។

លំដាប់នោះព្រះវេស្សន្តរត្រាស់ថា

យើងដែលគេបណ្តេញអំពីដែនហើយ មិនមានសេចក្តីប្រាថ្នាមិនមានសេចក្តីពេញចិត្តដើម្បីនឹងគ្រប់គ្រងរាជ្យទេ ម្នាលពួកចេតបុត្ត អ្នកចូរស្តាប់ខ្ញុំ ។ បើពួកព្រះរាជាចេតៈអភិសេកយើងដែលគេបណ្តេញចាកដែន ក្នុងរាជ្យហើយ ពួកអ្នកសិវិរាស្ត្រ

ណា ជានាយពលក្តី ជាអ្នកនិគមក្តី ពួកអ្នកសិវិរាស្ត្រនោះ មិនត្រេកអរទេ ។ ទាំងមិនមានសេចក្តីស្មោះស្ម័គ្រនឹងអ្នកទាំងឡាយ ព្រោះហេតុតែខ្ញុំដោយពិត ខ្ញុំមិនគាប់ចិត្តនឹងការប្រកួតប្រកាន់ ទាស់ទែងជាមួយពួកអ្នកសិវិរាស្ត្រ ។ តទៅនឹងកើតមានការប្រកួតប្រកាន់ដ៏ពន្ទឹក ការវាយដំគ្នាយ៉ាងសម្បើមនឹងមានមិនខាន ជនជាច្រើនគប្បីបៀតបៀនគ្នា ព្រោះហេតុតែខ្ញុំម្នាក់ឯង ។ វត្ថុណាដែលអ្នកទាំងអស់គ្នាធ្វើឲ្យជារបស់មានតម្លៃបានឲ្យដល់ខ្ញុំ វត្ថុនោះខ្ញុំបានទទួលហើយ ព្រះរាជាទ្រង់បណ្តេញខ្ញុំ ខ្ញុំនឹងទៅភ្នំវង្កត ម្នាលសម្លាញ់ទាំងឡាយ អ្នកទាំងឡាយចូរដឹងឱកាសជាទីនៅក្នុងព្រៃ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ចេតា រដ្ឋាភិសេចយុំ** សេចក្តីថា ពួកអ្នកសិវិទាំងនោះដឹងថា ស្តេចចេតរដ្ឋអភិសេកស្តេចជេតុត្តរក្នុងរាជសម្បត្តិ គង់មិនពេញចិត្តពួកអ្នក ។ បទថា **អសម្មោទិយំ** បានដល់ ការមិនត្រូវរ៉ូវ ។ បទថា **អស្ស** កែជា **ភវេយ្យ** ។ បទថា **អជស្ស** សេចក្តីថា កាលនោះពួកអ្នកនឹងឈ្លោះគ្នាព្រោះខ្ញុំតែម្នាក់ជាហេតុ ។

កាលត្រាស់យ៉ាងនេះហើយព្រះមហាសត្វសូម្បីព្រះបាទចេតរាជទូលអង្វរដោយអនេកបរិយាយ ក៏ទ្រង់មិនប្រាថ្នារាជសម្បត្តិ កាលនោះស្តេចចេតរាជទាំងឡាយបានធ្វើសក្ការៈធំដល់ព្រះមហាសត្វ ។ ព្រះមហាសត្វមិនប្រាថ្នានឹងយាងចូលទៅខាងក្នុងព្រះនគរ កាលនោះ ពួកស្តេចចេតរាជក៏រៀបចំសាលា

នោះ បាំងរាំងនន រៀបចំទីបន្ទំ ក្សត្រទាំងនោះនាំគ្នាចោមរោមរក្សាព្រះវេស្សន្តរ ស្នាក់នៅក្នុងទីនោះមួយរាត្រី ស្តេចចេតរាជទាំងនោះសង្គ្រោះ រក្សា ផ្ទុំត្រង់សាលា ស្អែកឡើងទ្រង់ស្រង់ទឹកអំពីព្រលឹម សោយភោជនាហារដែលមានរសផ្សេងៗ ស្តេចចេតរាជទាំងនោះចោមរោមមហាសត្វ ចេញអំពីសាលា ស្តេចចេតរាជ ៦ ម៉ឺននោះយាងជូនដំណើរព្រះវេស្សន្តរអស់ផ្លូវ ១៥ យោជន៍ ឈប់ត្រង់មាត់ព្រៃកាលនឹងទូលរយៈផ្លូវខាងមុខ ១៥ យោជន៍ ទើបពោលថា

ពួករាជបព្វជិត ជាអ្នកឈ្លាស ជាអ្នកបូជាភ្លើង មានចិត្តតម្កល់មាំតែងគង់នៅក្នុងទីណា ពួកទូលព្រះបង្គំជាខ្ញុំនឹងក្រាបទូលដល់ព្រះអង្គយ៉ាងនោះ បពិត្រមហារាជ ព្រះអង្គគង់នៅជាមួយព្រះរាជបុត្តព្រមទាំងព្រះអគ្គជាយា ក្បែរភ្នំណា ភ្នំនោះហៅថាភ្នំគន្ធមាទន៍ ជាវិការៈនៃថ្មសុទ្ធ ។

ពួកព្រះរាជាចេតៈ កាលយំមានមុខជោកដោយទឹកភ្នែក ក៏ក្រាបទូលព្រះបាទវេស្សន្តរនោះថា បពិត្រមហារាជ សូមព្រះអង្គ ទ្រង់យាងទៅអំពីទីនេះ សំដៅត្រង់ទៅទិសខាងជើង ។ បពិត្រព្រះអង្គដ៏ចម្រើន គ្រានោះព្រះអង្គនឹងទតឃើញភ្នំឈ្មោះវេបុល្លៈ ជាភ្នំដេរដាសដោយពួកឈើផ្សេងៗ មានម្លប់ត្រជាក់ ជាទីរីករាយចិត្ត ។ បពិត្រព្រះអង្គដ៏ចម្រើន លុះព្រះអង្គឆ្លងផុតភ្នំនោះហើយនឹងបានឃើញស្ទឹងមួយ ជាទីហូរទៅនៃទឹកឈ្មោះកេតុមតីជាស្ទឹងជ្រៅហូរចេញអំពីផ្ទៃភ្នំ ។ ដេរដាសដោយហ្វូង

ត្រីច្រើន មានកំពង់រាបស្មើល្អ មានទឹកច្រើន ព្រះអង្គស្រង់ផង សោយផង លួងលោមព្រះរាជបុត្ររបស់ព្រះអង្គក្នុងស្ទឹងនោះ ។ បពិត្រព្រះអង្គដ៏ចម្រើន តទៅព្រះអង្គនឹងទតឃើញដើមជ្រៃ មានផ្លែផ្អែម ដុះនៅលើកំពូលភ្នំជាទីត្រេកអរ មានម្លប់ត្រជាក់ ជាទីរីករាយនៃចិត្ត ។ បពិត្រព្រះអង្គដ៏ចម្រើន លំដាប់នោះព្រះអង្គនឹងទតឃើញភ្នំមួយឈ្មោះ នាលិកៈ ជាវិការៈនៃថ្មដេរដាសដោយពួកសត្វស្វាបផ្សេងៗ កុះករដោយពួកកិន្នរ ។ នៅភាគខាងជើងឆៀងខាងកើតនៃភ្នំនោះមានស្រះឈ្មោះ មុចលិន្ទដេរដាសដោយឈូកសផង ឧប្បលសផង ចង្កុលណីផង ។ ព្រះអង្គចូលទៅកាន់ព្រៃ ដូចផ្ទៃមេឃ មានស្មៅចិញ្ចៀនខៀវស្រស់ជានិច្ច ចូលទៅកាន់ដងព្រៃដេរដាសដោយឈើមានផ្កានិងឈើមានផ្លែទាំងពីរ ដូចសីហៈប្រាថ្នាចំណី ។ ក្នុងព្រៃនោះមានបក្សីជាច្រើនមានសម្បុរប្លែកៗគ្នា មានសំឡេងមូល មានសំឡេងពីរោះ ស្រែកយំឆ្លងឆ្លើយគ្នាទៅមក លើដើមឈើមានផ្ការីកតាមរដូវ ។ ព្រះអង្គទ្រង់ស្តេចទៅកាន់ជង្ហុកភ្នំនិងកន្លែងកកើតនៃស្ទឹងទាំងឡាយនឹងបានទតឃើញ ស្រះបោក្ខរណីដេរដាសដោយដើមកញ្ជើបាយដាចនិងដើមថ្ងាន់ ។ ជាស្រះដេរដាសដោយហ្វូងត្រីដ៏ច្រើនមានកំពង់រាបស្មើល្អ មានទឹកច្រើន មានសណ្ឋាន ៤ ជ្រុងស្មើ មានទឹកមានរសឆ្ងាញ់ មានក្លិនមិនគួរ

ខ្ពើម ។ សូមព្រះអង្គទ្រង់សាងបណ្ណសាលា ត្រង់ទិសខាងជើងធៀងខាងកើត នៃស្រះបោក្ខរណីនោះ លុះទ្រង់បានសាងបណ្ណសាលាហើយសូមទ្រង់ព្យាយាមត្រាច់ស្វែងរកផលាផលចិញ្ចឹមព្រះអង្គចុះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **រាជិសី** បានដល់ បុគ្គលដែលជាព្រះរាជាហើយបួស ។ បទថា **សមាហិតា** បានដល់ ជាអ្នកមានចិត្តស្មើ ស្ដេចចេតរាជទាំងឡាយកាលលើកដៃស្ដាំឡើងចង្អុលប្រាប់ថា សូមទ្រង់យាងតាមជើងភ្នំនេះដោយបទថា **ឯស** នេះ ។ បទថា **អច្ចសិ** បានដល់ នឹងប្រថាប់នៅ ។ បទថា **អាបថំ** បានដល់ ស្ទឹងជាផ្លូវនៃទឹកហូរ គឺនាំទឹកមក ។ បទថា **គិរិគព្ភរំ** បានដល់ មានប្រភពហូរមកអំពីភ្នំទាំងឡាយ ។ បទថា **មធុវិប្ផលំ** បានដល់ មានផ្លែឆ្ងាញ់ ។ បទថា **រម្មកោ** បានដល់ គួរជាទីត្រេកអរ ។ បទថា **កឹបុរិសាយុតំ** បានដល់ ប្រកប គឺដេរដាសទៅដោយកិន្នរទាំងឡាយ ។ បទថា **សេតសោគន្ធិយេហិ** ច សេចក្ដីថា ប្រកបដោយឧប្បលសនិងផ្កាឈូកក្រហម មានប្រការផ្សេងៗ ។ បទថា **សីហោវាមិសបេក្ខីវ** សេចក្ដីថា ដូចរាជសីហ៍ត្រូវការចំណី ។ បទថា **ពិន្ទុស្សរា** បានដល់ មានសំឡេងមូល ។ បទថា **វគ្គូ** បានដល់ មានសំឡេងពីរោះ ។ បទថា **កូជន្តមុបកូជន្តិ** សេចក្ដីថា ចូលទៅយំខាងក្រោយជាមួយបក្សីដែលយំមុន ។ បទថា **ឧតុសម្បុប្ផិតេ ទុមេ** សេចក្ដីថា ត្រង់ដើមឈើមានផ្កាតាមរដូវកាល ធ្វើនូវសំឡេងជាមួយនឹងបក្សីដែលកំពុងយំ ។ បទថា **សោ អទ្ទស** សេចក្ដីថា

ទ្រង់នោះនឹងបានទត ។ បទថា **ករញ្ជកកុជាយុតំ** សេចក្ដីថា ដេរដាសទៅដោយដើមករញ្ជីបាយដាចនិងដើមថ្ងាន់ទាំងឡាយ ។ បទថា **អប្បដិគន្ធិយំ** បានដល់ ប្រាសចាកក្លិនស្អុយ ពេញទៅដោយទឹកផ្អែម ដេរដាសដោយឈូកនិងឧប្បលជាដើម មានប្រការផ្សេងៗ ។ បទថា **បណ្ណសាលំ អមាបយ** សេចក្ដីថា គប្បីសាងបណ្ណសាលា ។ បទថា **អមាបេត្វា** បានដល់ កាលសាងហើយ ។ បទថា **ឧញ្ឆាចរិយាយ ឦហាថ** សេចក្ដីថា បពិត្រព្រះសម្មតិទេព លំដាប់នោះទ្រង់គប្បីតម្កល់ជីវិតដោយការស្វែងរក ជាអ្នកមិនប្រមាទចុះ គឺគប្បីជាអ្នកប្រារព្ធសេចក្ដីព្យាយាមចុះ ។

ស្ដេចចេតរាជទាំងឡាយក្រាបទូលផ្លូវ ១៥ យោជន៍ ដល់ព្រះវេស្សន្តរយ៉ាងនេះហើយ ក៏បញ្ជូនទ្រង់ទៅគិតថា សត្រូវឯណានីមួយកុំបីបានឱកាសប្រទូស្តឡើយ ដើម្បីបន្ទោបង់ភយន្តរាយដល់ព្រះវេស្សន្តរទើបហៅព្រានព្រៃម្នាក់ឈ្មោះចេតបុត្ត ជាមនុស្សវាងវៃ សិក្សាមកល្អហើយប្រាប់ថា ចូរឯងពិនិត្យមើលមនុស្សទាំងឡាយដែលទៅមក ប្រាប់ដូច្នេះហើយក៏ឲ្យនៅរក្សាផ្លូវហើយត្រឡប់មកកាន់នគររបស់ខ្លួន ។

ឯព្រះវេស្សន្តរមួយអន្លើដោយកូនប្រុសស្រីនិងព្រះរាជទេវី យាងដល់ភ្នំគន្ធមាទន៍ ប្រថាប់នៅក្នុងទីនោះអស់មួយថ្ងៃហើយបែរមុខទៅទិសឧត្តរ ដល់ជើងភ្នំវេបុល្លបព៌ត គង់ប្រថាប់ត្រង់ស្ទឹងកេតុមតីនទី សោយសាច់ដែលមានរសឆ្ងាញ់ដែលនាយព្រានព្រៃម្នាក់ថ្វាយ ព្រះរាជា ក៏ប្រទានស្នៀតសក់មាសដល់ព្រានព្រៃនោះ ទ្រង់ស្រង់ទឹកក្នុងស្ទឹងនោះរម្ងាប់នូវសេចក្ដីក្រវល់ក្រវាយ

ឡើងអំពីស្ទឹង គង់ប្រថាប់ក្រោមម្លប់ជ្រៃ ដែលតាំងនៅលើកំពូលសានុបព៌ត មួយស្របក់សោយផ្លែជ្រៃ ទ្រង់ក្រោកឡើងធ្វើដំណើរដល់នាឡិកបព៌តរហូតដល់ស្រះមុចលិន្ទ ទ្រង់សរសៀរតាមឆ្នេរស្រះ ឆ្ពោះទៅទិសឦសានដល់ព្រៃជ្រៅដែលមានផ្លូវដើរបានតែមនុស្សម្នាក់ ហួសអំពីនោះក៏ដល់ស្រះបោក្ខរណី រាង ៤ ជ្រុង នៅខាងមុខភ្នំជាផ្លូវលំបាក ជាដែនកើតនៃស្ទឹងទាំងឡាយ ។

ខណៈនោះភពរបស់សក្កទេវរាជ សម្តែងអាការក្តៅ សក្កទេវរាជទ្រង់ពិចារណាក៏ជ្រាបហេតុការណ៍នោះទើបទ្រង់ត្រិះរិះថា មហាសត្វទ្រង់ចូលកាន់ហិមវន្តប្បទេស ទ្រង់គួរបានទីប្រថាប់ ទើបហៅវិស្សកម្មទេវបុត្តមកត្រាស់ថា នែបា ចូរបាទៅសាងអាស្រមបទក្នុងទីដែលគួរត្រេកអរត្រង់ភ្នំវង្កត ហើយចូរត្រឡប់មក ត្រាស់ដូច្នោះហើយទ្រង់បញ្ជូនវិស្សកម្មទេវបុត្តទៅ ។ វិស្សកម្មទទួលរាជបញ្ជាថា សាធុ ហើយចុះចាកទេវលោកទៅកាន់ទីនោះ និម្មិតសាលាស្លឹក ២ ខ្នង ទីចង្ក្រម ២ កន្លែង ទីសម្រាកពេលយប់និងទីសម្រាកពេលថ្ងៃហើយធ្វើគុម្ពឈើវិចិត្រដោយផ្កាផ្សេងៗនិងព្រៃចេកក្នុងទីនោះៗ ខាងចុងទីចង្ក្រមនិម្មិតបព្វជិតបរិក្ខារទាំងពួង សរសេរអក្សរទុកថា អ្នកឯណាមួយចង់បួស ចូរប្រើប្រាស់បរិក្ខារទាំងនេះហើយដេញពួកអមនុស្សនិងពួកម្រឹគ មួយអន្ទើដោយពួកបក្សីដែលមានសំឡេងគួរខ្លាចហើយត្រឡប់ទៅក្នុងលំនៅរបស់ខ្លួន ។

ឯមហាសត្វទតឃើញផ្លូវដែលដើរបានតែម្នាក់ ទ្រង់កំណត់ថានឹងមានលំនៅរបស់បព្វជិត ទើបឲ្យព្រះនាងមទ្រី និងកូនប្រុសស្រីសម្រាកត្រង់ទ្វារអា-

ស្រមបទ ទ្រង់ចូលទៅកាន់អាស្រម ទតឃើញអក្សរទាំងឡាយ ក៏ដឹងភាព ដែលសក្កៈប្រទាន ទ្រង់ឈ្វេងយល់ថាសក្កទេវរាជមើលឃើញអញហើយទើប បើកទ្វារបណ្ណសាលាចូលទៅ ទ្រង់ដោះព្រះខ័ននិងធ្នូមួយអន្លើដោយសំពត់ ស្លៀកនូវសំពត់សម្បកឈើពណ៌ក្រហម ដាក់ស្បែកខ្លាលើស្មា ចងមណ្ឌល ជដា កាន់យកភេទជាឥសី ទ្រង់ចាប់ឈើច្រត់ចេញពីបណ្ណសាលា ញុំាងសិរី នៃបព្វជិតឲ្យតាំងឡើងព្រមទ្រង់បន្លឺឧទានថា ឱសុខហ្ន៎ ជាសុខក្រៃលែង អញ បានដល់បព្វជ្ជាហើយ ទ្រង់ឡើងកាន់ទីចង្រ្កមហើយយាងចង្រ្កមទៅមក ៗ ។ មហាសត្វយាងទៅកាន់សម្នាក់ព្រះរាជឱរសនិងព្រះរាជធីតា មួយអន្លើដោយ ព្រះរាជទេវីដោយសេចក្ដីស្ងប់ ដូចព្រះបច្ចេកពុទ្ធ ឯនាងមទ្រីកាលទតឃើញ ព្រះនាងចាំបាន ព្រះនាងក្រាបចុះទៀបបាទាព្រះមហាសត្វ ព្រះនាងថ្វាយបង្គំ ហើយទ្រង់ព្រះកន្សែង ចូលកាន់អាស្រមបទ មួយអន្លើដោយព្រះមហាសត្វ ហើយទៅកាន់បណ្ណសាលារបស់ព្រះនាង ព្រះនាងទ្រទ្រង់សំពត់សម្បកឈើ ពណ៌ក្រហម ពានាស្បែកខ្លាលើព្រះអង្សា ក្ដួចនូវមណ្ឌលជដា កាន់យកភេទ ជាតាបសិនី បន្ទាប់មកក៏ឲ្យព្រះរាជឱរសនិងព្រះរាជធីតាបួសជាតាបសកុមារ និងតាបសិនីកុមារី ។ ស្ដេចទាំង ៤ ព្រះអង្គប្រថាប់នៅត្រង់ភ្នំគិរីវង្កត កាល នោះព្រះនាងមទ្រីទូលសូមពរនឹងព្រះវេស្សន្តរថា បពិត្រព្រះសម្មតិទេព ទ្រង់ មិនបាច់យាងទៅកាន់ព្រៃដើម្បីស្វែងរកផលាផល សូមទ្រង់នៅក្នុងបណ្ណសា-លាជាមួយកូនប្រុសស្រី ខ្ញុំម្ចាស់នឹងនាំផ្លែឈើតូចធំមកថ្វាយ ។

ចាប់តាំងពីនោះមកព្រះនាងនាំយកផលាផលមកអំពីព្រៃ ទំនុកបម្រុង

បដិបត្តិព្រះរាជស្វាមីនិងព្រះរាជបុត្រាបុត្រី ។ ឯព្រះវេស្សន្តរបរមពោធិសត្វក៏សូមពរនឹងព្រះនាងមទ្រីថា នែមទ្រីដ៏ចម្រើន ចាប់ពីថ្ងៃនេះទៅយើងទាំងពីរជាបព្វជិតហើយ ឈ្មោះថាស្រីជាមន្ទិលដល់ព្រហ្មចរិយៈ តាំងអំពីនេះទៅនាងកុំមកកាន់សម្នាក់អញក្នុងពេលដែលមិនសមគួរ ព្រះនាងទទួលថា សាធុ ។ ពួកសត្វតិរច្ឆានទាំងពួងក្នុងទី ៣ យោជន៍ដោយជុំវិញ បានទទួលមេត្តាចិត្តដល់គ្នានឹងគ្នា ដោយអានុភាពមេត្តារបស់ព្រះមហាសត្វ ។ ព្រះនាងមទ្រីទេវីទ្រង់ក្រោកឡើងតាំងអំពីព្រលឹម តម្កល់ទឹកផឹក ទឹកប្រើប្រាស់ហើយនាំយកទឹកខ្ទរព្រះឱស្ឋ ទឹកលុបព្រះភក្ត្រមក ថ្វាយឈើស្ទន់ បោសអាស្រមបទ ផ្ញើព្រះរាជឱរសនិងព្រះរាជធីតាទាំង ២ ក្នុងសម្នាក់ព្រះមហាសត្វហើយកាន់ល្អី ចបជីកនិងតម្លក់ យាងចូលទៅកាន់ព្រៃរកផ្លែឈើតូចធំដាក់ពេញល្អី ត្រឡប់មកអំពីព្រៃក្នុងពេលល្ងាចទុកដាក់ផ្លែក្នុងបណ្ណសាលា ហើយស្រង់ទឹកឲ្យកូនប្រុសស្រីស្រង់ដែរ ។ កាលនោះស្តេចទាំង ៤ អង្គ ប្រថាប់គង់សោយផ្លែឈើទៀបទ្វារបណ្ណសាលា ។ តអំពីនោះព្រះនាងមទ្រីនាំជាលីនិងកណ្ហាជិនាទៅកាន់បណ្ណសាលារបស់ខ្លួន ។ ស្តេចទាំង ៤ ប្រថាប់នៅលើភ្នំគិរីវង្កតអស់ ៧ ខែដោយទំនងនេះឯង ។

**វនប្បវេសនកណ្ឌ ចប់**

# ជូជកបព្វ

កាលនោះមានព្រាហ្មណ៍ម្នាក់ឈ្មោះថាជូជកជាអ្នកស្រុកព្រាហ្មណ៍ឈ្មោះថា ទុន្និវិដ្ឋៈក្នុងកាលិង្គរដ្ឋត្រាច់ស្វែងរកអាហារបានទ្រព្យ ១០០ កហាបណៈ ផ្ញើទុកត្រង់ត្រកូលព្រាហ្មណ៍ម្នាក់ ហើយទៅដើម្បីជាប្រយោជន៍ស្វែងរកទ្រព្យទៀត។ កាលជូជកទៅអស់កាលយូរត្រកូលព្រាហ្មណ៍នោះក៏ចាយកហាបណៈអស់ លុះក្រោយមកជូជកត្រឡប់មកតឹងទារ ក៏មិនអាចរកទ្រព្យសងបានទើបលើកកូនស្រីឈ្មោះ អមិត្តតាបនាឲ្យជូជក ។ ជូជកក៏នាំអមិត្តតាបនាទៅកាន់ស្រុកព្រាហ្មណ៍ទុន្និវិដ្ឋក្នុងកាលិង្គរដ្ឋ នាងអមិត្តតាបនា បានបដិបត្តិព្រាហ្មណ៍ដោយប្រពៃ ។

កាលនោះពួកព្រាហ្មណ៍កំលោះៗឃើញអាចារសម្បត្តិរបស់នាងក៏សម្លុតភរិយារៀងៗខ្លួនថា នាងអមិត្តតាបនាបដិបត្តិព្រាហ្មណ៍ចាស់ដោយប្រពៃ ហេតុអ្វីពួកឯងប្រមាទចំពោះអញ ។ ភរិយាព្រាហ្មណ៍ទាំងនោះគិតថា ពួកយើងនឹងញ៉ាំងនាងអមិត្តតាបនា ឲ្យគេចទៅអំពីស្រុកនេះ គិតដូច្នេះហើយទើបទៅប្រជុំគ្នាជេរនាងអមិត្តតាបនាត្រង់កំពង់ទឹកជាដើម ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសាធូវព្រះគាថាដូច្នេះថា

មានព្រាហ្មណ៍ម្នាក់ឈ្មោះជូជក នៅក្នុងដែនកលិង្គៈ ឯភរិយា
របស់គាត់នៅក្មេងឈ្មោះ នាងអមិត្តតាបនា ។ ពួកស្រីជាអ្នក

ជងទឹកស៊ឹងក្នុងស្រុកនោះបានទៅស្តីថា នាងអមិត្តតាបនានោះ ផ្អើលជ្រួលជ្រើមចោមរោម ជេរប្រទេចនាងអមិត្តតាបនានោះ ថា ម្តាយនាងជាសត្រូវពិត ឪពុកនាងជាសត្រូវពិត បានជាឲ្យនាងដែលនៅកំពុងក្រមុំយ៉ាងនេះដល់ព្រាហ្មណ៍ចាស់ ។ ពួកញាតិរបស់នាង នាំគ្នាទៅប្រឹក្សាក្នុងទីស្ងាត់ មិនជាប្រយោជន៍ដល់នាងពិត ហើយបានជានាំគ្នាលើកនាងដែលនៅកំពុងក្រមុំយ៉ាងនេះឲ្យដល់ព្រាហ្មណ៍ចាស់ ។ ពួកញាតិរបស់នាងនាំគ្នាទៅប្រឹក្សាក្នុងទីស្ងាត់ ជាការអាក្រក់របស់នាងប្រាកដ ហើយបានជានាំគ្នាលើកនាងដែលនៅក្រមុំយ៉ាងនេះឲ្យដល់ព្រាហ្មណ៍ចាស់ ។ ពួកញាតិរបស់នាងនាំគ្នាទៅប្រឹក្សាក្នុងទីស្ងាត់ ជាការលាមករបស់នាងប្រាកដ ហើយបានជានាំគ្នាលើកនាងដែលនៅក្រមុំយ៉ាងនេះឲ្យដល់ព្រាហ្មណ៍ចាស់ ។ ពួកញាតិរបស់នាងនាំគ្នាទៅប្រឹក្សាក្នុងទីស្ងាត់មិនជាទីគាប់ចិត្តរបស់នាងពិត ហើយបានជានាំគ្នាលើកនាងដែលនៅក្រមុំយ៉ាងនេះឲ្យដល់ព្រាហ្មណ៍ចាស់ ។ នាងនៅទាំងមិនគាប់ចិត្តជាមួយនឹងប្តីចាស់ ដ្បិតនាងនៅក្នុងផ្ទះនៃប្តីចាស់បែបនេះ នាងស្លាប់ទៅប្រសើរជាងការរស់នៅ ។ នែនាងមានលំអយ៉ាងធើត មាតាបិតារបស់នាងជាក់ជារកប្តីដទៃឲ្យនាងមិនបាន បានជានាំគ្នាលើកនាងដែលនៅក្រមុំយ៉ាងនេះឲ្យដល់ព្រាហ្មណ៍ចាស់ ។ នាងបានធ្វើការបូជា

មិនល្អក្នុងថ្ងៃទី ៩ ទាំងមិនបានធ្វើការបូជាព្រះអគ្គី បានជាពួកញាតិនាំគ្នាលើកនាងដែលនៅក្រមុំយ៉ាងនេះ ឲ្យដល់ព្រាហ្មណ៍ចាស់ ។ នាងជាក់ជាជេរប្រទេចពួកសមណៈនិងព្រាហ្មណ៍មានព្រហ្មចរិយៈប្រព្រឹត្តទៅខាងមុខ ជាអ្នកមានសីល មានការចេះដឹងច្រើនក្នុងលោក បានជានាងដែលនៅក្រមុំយ៉ាងនេះនៅ ( ក្នុងផ្ទះ ) ព្រាហ្មណ៍ចាស់ ។ ពស់ចឹកមិនទាន់ជាទុក្ខទេ ទាំងលំពែងមុតក៏មិនទាន់ជាទុក្ខដែរ ត្រង់នាងឃើញប្តីចាស់នោះទើបជាទុក្ខទាំងជាគ្រឿងក្តៅក្រហាយ ។ ល្បែងមិនមាន តម្រេកមិនមាន ការចរចាទៅមកជាមួយនឹងប្តីចាស់មិនមាន ទាំងការសើចក៏មិនសមល្អ ។ កាលណាប្តីក្មេង ប្រពន្ធក្មេងទៅប្រឹក្សាគ្នាក្នុងទីស្ងាត់ កាលណោះ សេចក្តីសោកគ្រប់យ៉ាងណាមួយដែលអាស្រ័យនៅហឫទ័យក៏រមែងវិនាស បាត់ទៅ នាងក្មេងមានរូបល្អរមែងជាទីប្រាថ្នានៃពួកបុរសណាស់ ចូរនាងវិលទៅនៅឯត្រកូលញាតិវិញទៅ ព្រាហ្មណ៍ចាស់នឹងធ្វើនាងឲ្យរីករាយដូចម្តេចកើត ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អហុ** ប្រែថា មាន ។ បទថា **វាសី ក-លិង្គេសុ** សេចក្តីថា ជាអ្នកស្រុកព្រាហ្មណ៍ឈ្មោះទុន្និវិដ្ឋៈដែនកាលិង្គ ។ បទថា **តា ធំ តត្ថ គតាវោចុំ** សេចក្តីថា ស្រីក្នុងស្រុកទាំងនោះទៅដងទឹកត្រង់កំពង់ទឹក បានពោលនឹងនាងអមិត្តតាបនានោះ ។ បទថា **ឋិយោ ធំ**

**បរិភាសិសុ** សេចក្តីថា ស្រីទាំងនោះមិនបានពោលនឹងបុគ្គលណាដទៃ ជេរប្រទេចនាងអមិត្តតាបនានោះដោយពិត ។ បទថា **កុត្ថហារា** បានដល់ ជ្រួលប្របល់ ។ បទថា **សមាគន្ត្វា** បានដល់ ចោមរោមដោយជុំវិញ ។ បទថា **ឧទហារិយំ** បានដល់ នៅក្នុងស្អាតក្រែលែង ។ បទថា **ជិណ្ណស្ស** បានដល់ ក្នុងផ្ទះរបស់ព្រាហ្មណ៍ចាស់ជរា ។ បទថា **ទុយិដ្ឋន្តេ នវមិយំ** សេចក្តីថា នាងនឹងបូជាយញ្ញទុកមិនល្អក្នុងតិថីទី ៩ គឺគ្រឿងបូជាយញ្ញរបស់នាងជារបស់ដែលក្អែកចាស់កាន់យកហើយមុន ។ បាឋៈថា **ទុយិត្ថា តេ នវមិយា** ដូច្នេះក៏មាន សេចក្តីថា នាងបូជាយញ្ញក្នុងតិថីទី ៩ មិនល្អ ។ បទថា **អកតំ អគ្គិហុត្តកំ** សេចក្តីថា ការបូជាភ្លើង នាងក៏ប្រហែលមិនធ្លាប់ធ្វើ ។ បទថា **អភិសបិ** សេចក្តីថា ជេរនូវសមណព្រាហ្មណ៍ដែលមានបាបស្ងប់ហើយ ឬមានបាបបន្សាត់ហើយ ស្រីទាំងឡាយពោលយ៉ាងនេះដោយបំណងថានេះជាផលនៃបាបរបស់នាងនោះ ។ បទថា **ជគ្ឃិតម្បិ ន សោភតិ** សេចក្តីថា សូម្បីការសើចរបស់មនុស្សចាស់ចេញធ្មេញបាក់ រមែងមិនស្អាត ។ បទថា **សព្វេ សោកា វិនស្សន្តិ** សេចក្តីថា សេចក្តីសោកនៃបុគ្គលនោះគ្រប់យ៉ាងរមែងវិនាសទៅ ។ បទថា **កាំ ជិណ្ណោ** សេចក្តីថា ព្រាហ្មណ៍នេះនឹងញុំាងនាងឲ្យត្រេកអរដោយកាមគុណ ៥ បានដូចម្តេច ។ នាងអមិត្តតាបនាបានទទួលនូវការជេរប្រទេចអំពីសម្នាក់នាងព្រាហ្មណីទាំងនោះ ក៏កាន់យកក្អមទឹកយំត្រឡប់ទៅផ្ទះ កាលជូជកសួរថា ហេតុអ្វីនាងយំ កាលនឹងប្រាប់សេចក្តីនោះដល់ជូជកទើបពោលគាថានេះថា

នែព្រាហ្មណ៍ ខ្ញុំមិនទៅដងទឹកស៊ីងឲ្យអ្នកទេ នែព្រាហ្មណ៍ ដ្បិត
ពួកស្រីៗជេរប្រទេចខ្ញុំព្រោះតែអ្នកចាស់ ដូច្នេះ ។

សេចក្ដីនៃគាថានោះ ដូច្នេះថា បពិត្រព្រាហ្មណ៍ ព្រាហ្មណីទាំងឡាយ ជេរបរិភាសខ្ញុំព្រោះលោកចាស់ ព្រោះហេតុនោះចាប់ពីថ្ងៃនេះទៅ ខ្ញុំមិនទៅកាន់ស៊ឹងដងទឹកមកឲ្យអ្នកឡើយ ។

ជូជកពោលថា

នាងកុំធ្វើកិច្ចការឲ្យអញឡើយ នាងកុំដងទឹកមកឲ្យអញឡើយ
អញនឹងដងទឹក ( ខ្លួនឯង ) ម្នាលនាងដ៏ចម្រើន នាងកុំក្រេវ
ក្រោធឡើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឧទកមាហិស្សំ** សេចក្ដីថា អញនឹងដងទឹកខ្លួនឯង ។

ព្រាហ្មណីអមិត្តតាបនាពោលថា

ខ្ញុំមិនមែនកើតក្នុងត្រកូល ( ស្រីអ្នកប្រើប្ដី ) នោះទេ អ្នកដង
ទឹកណា ( ខ្ញុំមិនត្រូវការទឹកនោះទេ ) នែព្រាហ្មណ៍ អ្នកចូរដឹង
យ៉ាងនេះចុះ ខ្ញុំនឹងមិននៅក្នុងផ្ទះអ្នកទេ ។ នែព្រាហ្មណ៍ បើអ្នក
មិននាំខ្ញុំប្រុសឬខ្ញុំស្រីមកឲ្យខ្ញុំទេ នែព្រាហ្មណ៍ អ្នកចូរដឹងយ៉ាង
នេះចុះ ខ្ញុំមិននៅក្នុងសំណាក់អ្នកទេ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **នាហំ តម្ហិ** សេចក្ដីថា ខ្ញុំមិនមែនកើតក្នុងត្រកូលដែលប្រើប្ដីឲ្យធ្វើការងារទេ ។ បទថា **យំ ត្វំ** សេចក្ដីថា ខ្ញុំមិនត្រូវ

ការទឹកដែលអ្នកដងមកទេ ។

ជូជកពោលថា

ម្នាលនាងព្រាហ្មណី ហេតុជាទីតាំងនៃសិល្បៈក្តី ទ្រព្យក្តី ស្រូវក្តីរបស់អញមិនមានទេ អញនឹងនាំយកខ្ញុំប្រុសឬខ្ញុំស្រីមកឲ្យនាងដ៏ចម្រើនអំពីណាបាន អញនឹងបម្រើនាងដ៏ចម្រើន នាងដ៏ចម្រើនកុំក្រេវក្រោធឡើយ ដូច្នេះ ។

នាងអមិត្តតាបនាកាលទេវតាបណ្តាលចិត្ត ក៏ពោលនឹងជូជកនោះថា

អ្នកចូរមក ខ្ញុំនឹងប្រាប់អ្នកតាមពាក្យដែលខ្ញុំឮមកថា ព្រះរាជាទ្រង់ព្រះនាមវេស្សន្តរនោះ ស្តេចគង់នៅនាគិរីវង្កត ។ ម្នាលព្រាហ្មណ៍ អ្នកចូរទៅសុំខ្ញុំប្រុសខ្ញុំស្រីនឹងព្រះបាទវេស្សន្តរនោះ ។ ក្សត្រនោះដែលអ្នកសុំហើយមុខជាប្រទានខ្ញុំប្រុស ខ្ញុំស្រីដល់អ្នកពុំខាន ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឯហិ តេ អហមក្ខិស្សំ** សេចក្តីថា ខ្ញុំនឹងប្រាប់ដល់អ្នក ។ នាងអមិត្តតាបនានោះត្រូវទេវតាបណ្តាលចិត្ត ទើបពោលយ៉ាងនេះ ។

ជូជក ក៏ពោលថា

អញចាស់ហើយ មានកម្លាំងថយ ទាំងផ្លូវក៏ឆ្ងាយលំបាកទៅណាស់ នាងដ៏ចម្រើនកុំយំយែកឡើយ នាងដ៏ចម្រើន កុំអាក់អន់ចិត្តឡើយ អញនឹងបម្រើនាងដ៏ចម្រើន នាងដ៏ចម្រើនកុំ

ក្រេវក្រោធឡើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ជិណ្ណាហាមស្មិ** សេចក្ដីថា នែនាងដ៏ចម្រើន អញជាមនុស្សចាស់ តើនឹងទៅបានដូចម្ដេច ។

ព្រាហ្មណីឈ្មោះអមិត្តតាបនាក៏ពោលថា

ទាហានមិនទាន់ទៅធ្វើសង្គ្រាម មិនទាន់ច្បាំងចាញ់មុនទៅហើយ ម្នាលព្រាហ្មណ៍ អ្នកមិនទាន់ទាំងទៅផងចាញ់យ៉ាងនោះដែរ ។ នែព្រាហ្មណ៍ បើអ្នកមិននាំខ្ញុំប្រុស ខ្ញុំស្រីមកឲ្យខ្ញុំទេ នែព្រាហ្មណ៍ អ្នកចូរដឹងយ៉ាងនេះចុះ ខ្ញុំនឹងមិននៅក្នុងផ្ទះអ្នកទេ ខ្ញុំនឹងធ្វើអំពើមិនគាប់ចិត្តដល់អ្នក អំពើនោះនឹងជាទុក្ខដល់អ្នកមិនខាន កាលណាអ្នកនឹងឃើញខ្ញុំតាក់តែង ( ខ្លួន ) ត្រេកត្រអាលជាមួយនឹងពួកប្រុសឯទៀតក្នុងថ្ងៃនក្ខត្តឫក្ស ក្នុងខាងដើមរដូវទាំងឡាយ ដំណើរនោះ នឹងជាទុក្ខដល់អ្នកក្នុងកាលនោះ ។ ម្នាលព្រាហ្មណ៍ កាលអ្នកជាបុគ្គលចាស់ទ្រូញយំរៀបរាប់ព្រោះតែមិនបានឃើញខ្ញុំ ខ្នងរឹតតែកោងទៅ សក់នឹងស្កូវច្រើនឡើង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អមណាបន្តេ** សេចក្ដីថា បើអ្នកមិនទៅគាល់ព្រះបាទវេស្សន្តរ ទូលសូមទាសានិងទាសីមក ខ្ញុំនឹងធ្វើកម្មដែលអ្នកមិនគាប់ចិត្ត ។ បទថា **ឆក្ខត្តេ ឧតុបុព្វេសុ** សេចក្ដីថា ក្នុងការរីករាយមហោស្រពដែលប្រព្រឹត្តទៅដោយអំណាចដែលរៀបចំឡើងក្នុងកាលនក្ខត្តឫក្សឬដោយអំណាច

គេរៀបចំឡើងប្រចាំរដូវកាលក្នុងបណ្តារដូវទាំង ៦ ។ ជូជកព្រាហ្មណ៍បាន ស្តាប់ដូច្នោះក៏កិតភ័យក្រៃលែង ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទ ព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូល សូធ្យសានូវព្រះគាថាដូច្នេះថា

លំដាប់នោះព្រាហ្មណ៍នោះកិតភ័យ លុះក្នុងអំណាចនាងព្រា-ហ្មណី ត្រូវកាមរាគគ្របសង្កត់ បានពោលនឹងនាងព្រាហ្មណី យ៉ាងនេះថា ម្នាលនាងព្រាហ្មណី នាងចូរធ្វើទ្រាបល្ង ផងទ្រាប លាជផង នំទឹកឃ្មុំដែលគេធ្វើល្អហើយផង កត្តុ គឺសដូវផង ឲ្យជាស្បៀងដល់អញ ។ អញនឹងនាំកុមារជាខ្ញុំពីរនាក់ មាន ជាតិ គោត្តត្រកូលនិងប្រទេសដើម្បីនាង កុមារទាំងនោះនឹង បម្រើនាងទាំងយប់ទាំងថ្ងៃ មិនខ្ជិលច្រអូសឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អជ្ឈេនោ** បានដល់ ត្រូវបៀតបៀន គឺរុកកួន ។ បទថា **សង្គុលា** បានដល់ នំដែលធ្វើដោយល្ង ។ បទថា **សគុឡានិ ច** បានដល់ នំដែលធ្វើដោយស្ករ ។ បទថា **សត្តុភត្តំ** បានដល់ សដូវដុំ សដូវ ផង់និងបាយក្រៀម ។ បទថា **មេថុនកេ** បានដល់ ដូចគ្នាដោយជាតិគោត្ត ត្រកូលនិងប្រទេស ។ បទថា **ទាសកុមារកេ** បានដល់ កុមារ ២ នាក់ ដើម្បីជាទាសៈរបស់នាង ។

នាងអមិត្តតាបនាប្រញាប់ត្រៀមស្បៀង ហើយប្រាប់ដល់ជូជកព្រាហ្មណ៍ ។

ជូជកព្រាហ្មណ៍ជួសជុលទ្វារផ្ទះដែលបាក់បែកឲ្យមាំទាំ រកឧសអំពីព្រៃមកទុក យកក្អមដងទឹកដាក់ភាជនៈទាំងពួងក្នុងផ្ទះទាល់តែពេញ ហើយកាន់យកភេទជាតាបស ក្នុងផ្ទះនោះឯងប្រៀនប្រដៅអមិត្តតាបនាថា នែនាង ចាប់ពីថ្ងៃនេះតទៅក្នុងកាលយប់ព្រលប់នាងកុំចេញក្រៅ ចូរកុំប្រមាទ ទម្រាំខ្ញុំត្រឡប់មកដូច្នោះហើយពាក់ស្បែកជើង លើកថង់យាមដែលដាក់ស្បៀងដាក់លើចង្កេះស្មា ធ្វើប្រទក្សិណនាងអមិត្តតាបនាមានភ្នែកជោកដោយទឹកភ្នែកចៀសចេញទៅ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** វីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូត្រសាទូវព្រះគាថាដូច្នេះថា

ជូជកជាព្រហ្មពន្ធុ លុះពោលយ៉ាងនេះហើយក៏ពាក់ស្បែកជើង
លំដាប់នោះគាត់ផ្តើផ្តាំកិរិយា ហើយប្រទក្សិណាចៀសចេញទៅ
ព្រាហ្មណ៍នោះមានមុខយំសស្រោក់ បានសមាទានវត្តត្រាច់ទៅ
កាន់នគររបស់ពួកអ្នកសិវិរាស្រ្ត ជានគរជំទូលាយ ស្វែងរក
ខ្ញុំប្រុសខ្ញុំស្រី ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **រុណ្ណមុខោ** បានដល់ យំមានមុខជោកដោយទឹកភ្នែក ។ បទថា **សមាហិតព្វតោ** បានដល់ មានវត្តសមាទានហើយ អធិប្បាយថា កាន់ភេទជាតាបស ។ បទថា **ចរំ** សេចក្តីថា ជូជកត្រាច់ស្វែងរកទាសានិងទាសីតម្រង់ទៅកាន់នគរសិវិ ។

ជូជកទៅកាន់នគរនោះឃើញជនប្រជុំគ្នាទើបសួរថា ព្រះវេស្សន្តរ ទ្រង់យាងទៅណា ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** រីអាចិជមិងណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសាន្ទូវព្រះគាថាដូច្នេះថា

ព្រាហ្មណ៍នោះបានដើរទៅក្នុងនគរនោះសាកសួរជនទាំងឡាយ
ដែលប្រជុំគ្នាក្នុងនគរនោះថា ព្រះបាទវេស្សន្តរ ស្តេចយាងទៅ
ក្នុងទីណា យើងគប្បីគាល់ក្សត្រអង្គនោះក្នុងទីណា ។ ពួកជន
ដែលមកប្រជុំគ្នាក្នុងទីនោះៗ បាននិយាយនឹងព្រាហ្មណ៍នោះថា
ម្នាលព្រាហ្មណ៍ ក្សត្រត្រូវពួកអ្នកធ្វើឲ្យខ្ចាត់ខ្ចាត់ទៅ ព្រោះ
អតិទាន ( ទានប្រសើរ ) គេបំបរបង់ចាកដែនរបស់ព្រះអង្គៗ
ទៅគង់ឯគិរីវង្កត ។ ម្នាលព្រាហ្មណ៍ ក្សត្រត្រូវពួកអ្នកធ្វើឲ្យ
ខ្ចាត់ខ្ចាត់ទៅព្រោះអតិទាន ទ្រង់នាំព្រះឱរសនិងព្រះទេវីទៅគង់
នៅឯគិរីវង្កត ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បករតា** សេចក្តីថា ព្រះវេស្សន្តរត្រូវបៀតបៀន ទើបមិនបានប្រថាប់នៅក្នុងនគររបស់ព្រះអង្គ ឥឡូវនេះប្រថាប់នៅឯភ្នំវង្កត ។

ជនទាំងនោះនិយាយនឹងជូជកថា ពួកឯងធ្វើព្រះរាជារបស់យើងឲ្យវិនាសហ៊ានមកឈរក្នុងទីនេះទៀត ពោលដូច្នេះហើយក៏កាន់ដុំដីនិងដំបងដេញតាម

ជូជកទៅ ។ ជូជកត្រូវទេវតាបណ្ដាលចិត្ត ក៏កាន់យកផ្លូវដែលទៅភ្នំវង្កតនោះឯង ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** វីអាចិធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូត្រសានូវព្រះគាថាដូច្នេះថា

ជូជកនោះដែលនាងព្រាហ្មណីជាស់តឿនហើយ ជាបុគ្គលមានសេចក្ដីជាប់ចំពាក់នឹងកាម រងទុក្ខក្នុងព្រៃដេរដាសដោយម្រឹគសាហាវ ជាទីដែលរមាសនិងខ្លាដំបងអាស្រ័យនៅហើយ ។ ព្រាហ្មណ៍នោះបានកាន់ដំបង មានសម្បុរដូចផ្លែព្នៅនិងវែកសម្រាប់បូជាភ្លើងព្រមទាំងកុណ្ឌី ចូលទៅកាន់ព្រៃធំដែលគាត់បានឮថាជាទីដែលព្រះវេស្សន្តរ ព្រះអង្គឲ្យសេចក្ដីប្រាថ្នា ( គង់នៅ ) ។ ឆ្កែទាំងឡាយបានចោមរោមគាត់កំពុងចូលទៅកាន់ព្រៃធំនោះ គាត់វង្វេងផ្លូវស្រែកទ្រហោយំ ស្ទុះឃ្លាតទៅក្នុងទីឆ្ងាយអំពីផ្លូវ ( ដែលជាទីទៅកាន់គិរីវង្កត ) ។ លំដាប់នោះព្រាហ្មណ៍ដែលល្មោភក្នុងភោគៈមិនសង្រួម ទៅវង្វេងនៅក្នុងផ្លូវដែលជាទីទៅកាន់គិរីវង្កត ( ត្រូវពួកឆ្កែទាំងឡាយចោមព័ទ្ធក៏ឡើងទៅអង្គុយនៅលើដើមឈើ ) បានពោលគាថាទាំងនេះថា ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អយន្តំ** បានដល់ ទុក្ខនោះ គឺទុក្ខដែលជាប់

តាមដោយមហាជននិងទុក្ខដែលពាល់ត្រូវព្រោះដើរព្រៃ ។ បទថា **អគ្គិហុត្តំ** បានដល់ រែកជាគ្រឿងបូជាភ្លើង ។ បទថា **កោកា ធំ បរិវារយុំ** សេចក្ដីថា ជូជកនោះចូលកាន់ព្រៃទាំងមិនដឹងផ្លូវទៅកាន់ភ្នំវង្កត ទើបវង្វេងផ្លូវត្រាច់ទៅ លំដាប់នោះឆ្កែទាំងឡាយរបស់ចេតបុត្តព្រាហ្មណ៍ អន្ទូយដើម្បីរក្សាព្រះវេស្សន្តរបានចោមរោមជូជកនោះ ។ បទថា **វិក្កន្ទិ សោ** សេចក្ដីថា ជូជកនោះឡើងដើមឈើមួយដើមយំដោយសំឡេងខ្លាំង ។ បទថា **វិប្បនដ្ឋោ** បានដល់ ខុសផ្លូវ ។ បទថា **ទូរេ បន្ថា** សេចក្ដីថា ចៀសចេញទៅឆ្ងាយអំពីផ្លូវដែលទៅកាន់ភ្នំវង្កត ។ បទថា **ភោគលុទ្ធោ** បានដល់ ជាបុគ្គលល្មោភក្នុងលាភ គឺភោគសម្បត្តិ ។ បទថា **អសញ្ញតោ** បានដល់ ជាអ្នកទ្រុស្តសីល ។ បទថា **វង្កស្សោរោហណេ នដ្ឋោ** បានដល់ វង្វេងក្នុងផ្លូវដែលទៅកាន់ភ្នំវង្កត ។

ជូជកត្រូវហ្វូងឆ្កែចោមរោម ឡើងទៅអន្ទូយលើដើមឈើបានពោលគាថានេះថា

> ជនណាហ្ន៎ ប្រាប់ព្រះវេស្សន្តរដែលជារាជបុត្តដ៏ប្រសើរ ឈ្នះសេចក្ដីកំណាញ់មិនចាលចាញ់ ជាអ្នកឲ្យសេចក្ដីក្សេមក្នុងកាលមានភ័យដល់ខ្ញុំ ។ ព្រះបាទវេស្សន្តរណា ជាទីពឹងនៃពួកអ្នកសូម ដូចជាផែនដីជាទីពឹងនៃពួកសត្វ នរណាហ្ន៎ ប្រាប់ព្រះវេស្សន្តរមហារាជមានឧបមាដូចផែនដីដល់ខ្ញុំ ។ ព្រះបាទវេស្សន្តរណាជាទីទៅរបស់ពួកស្មូម ដូចជាសាគរជាទីទៅនៃផ្លូវទឹកទាំងឡាយ នរណាហ្ន៎ប្រាប់ព្រះវេស្សន្តរមហារាជ មានឧបមាដូចជា

សមុទ្ទដល់ខ្ញុំ ។ នរណាហ្ន៎ ប្រាប់ព្រះវេស្សន្តរមហារាជមាន ឧបមាដូចជាអន្លង់ទឹកមានកំពង់ល្អ ឆាយផឹក មានទឹកត្រជាក់ ជាទីមនោរម្យ ដេរដាសដោយផ្កាឈូស ប្រកបដោយលំអងផ្កាដល់ខ្ញុំ ។ នរណាហ្ន៎ប្រាប់ព្រះវេស្សន្តរមហារាជ មានឧបមាដូចជាដើមពោធិ៍បាយដែលដុះក្បែរផ្លូវ មានម្លប់ត្រជាក់ ជាទីមនោរម្យ ជាទីសម្រាករបស់បុគ្គលនឿយហត់ ជាទីពំនាក់នៃបុគ្គលដែលលំបាកដល់ខ្ញុំ ។ នរណាហ្ន៎ ប្រាប់ព្រះវេស្សន្តរមហារាជ មានឧបមាដូចជាដើមជ្រៃដែលដុះក្បែរផ្លូវ មានម្លប់ត្រជាក់ ជាទីមនោរម្យ ជាទីសម្រាកនៃបុគ្គលនឿយហត់ ជាទីពំនាក់នៃបុគ្គលដែលលំបាកដល់ខ្ញុំ ។ នរណាហ្ន៎ ប្រាប់ព្រះវេស្សន្តរមហារាជ មានឧបមាដូចដើមស្វាយ មានម្លប់ត្រជាក់ ជាទីមនោរម្យ ជាទីសម្រាកនៃបុគ្គលនឿយហត់ ជាទីពំនាក់នៃបុគ្គលដែលលំបាកដល់ខ្ញុំ ។ នរណាហ្ន៎ ប្រាប់ព្រះវេស្សន្តរមហារាជ មានឧបមាដូចដើមរាំង ដែលដុះក្បែរផ្លូវ មានម្លប់ត្រជាក់ ជាទីមនោរម្យ ជាទីសម្រាកនៃបុគ្គលនឿយហត់ ជាទីពំនាក់នៃបុគ្គលដែលលំបាកដល់ខ្ញុំ ។ នរណាហ្ន៎ ប្រាប់ព្រះវេស្សន្តរមហារាជ មានឧបមាដូចដើមឈើ ដែលដុះក្បែរផ្លូវ មានម្លប់ត្រជាក់ ជាទីមនោរម្យ ជាទីសម្រាកនៃបុគ្គលនឿយហត់ ជាទីពំនាក់នៃបុគ្គលដែលលំបាកដល់ខ្ញុំ ។ម្យ៉ាងទៀត

បុគ្គលណានិយាយប្រាប់ថា ខ្ញុំឯងស្គាល់កន្លែងនៅនៃព្រះបាទវេស្សន្តរដូច្នេះដល់ខ្ញុំដែលចូលមកក្នុងព្រៃធំ កំពុងយំរៀបរាប់យ៉ាងនេះ បុគ្គលនោះឈ្មោះថា ញ៉ាំងសេចក្តីត្រេកត្រអាលឲ្យកើតដល់ខ្ញុំ ។ មួយទៀតបុគ្គលណានិយាយប្រាប់ថា ខ្ញុំដឹងទីលំនៅនៃព្រះបាទវេស្សន្តរដូច្នេះ ដល់ខ្ញុំដែលចូលមកក្នុងព្រៃធំកំពុងយំរៀបរាប់យ៉ាងនេះ បុគ្គលនោះរមែងប្រទះបុណ្យដ៏ច្រើន ព្រោះតែសម្តីមួយមាត់នោះឯង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ជយន្តំ** បានដល់ ជាអ្នកឈ្នះនូវសេចក្តីកំណាញ់ ។ បទថា **កោ មេ វេស្សន្តរំ វិទូ** សេចក្តីថា ជូជកពោលថា អ្នកណាគប្បីប្រាប់ដំណឹងព្រះវេស្សន្តរដល់ខ្ញុំ ។ បទថា **បតិដ្ឋាសិ** សេចក្តីថា បានជាទីពឹងអាស្រ័យ ។ បទថា **សន្តានំ** បានដល់ ជាអ្នកខ្សោយកម្លាំង ។ បទថា **កិលន្តានំ** បានដល់ ជាអ្នកលំបាកក្នុងផ្លូវ ។ បទថា **បដិគ្គហំ** បានដល់ ជាអ្នកទទួល គឺជាទីពឹងអាស្រ័យ ។ បទថា **អហំ ជានន្តិ យោ វជ្ជា** សេចក្តីថា បុគ្គលណាគប្បីពោលយ៉ាងនេះថា ខ្ញុំដឹងទីប្រថាប់របស់ព្រះវេ-ស្សន្តរ ។

ព្រានឈ្មោះចេតបុត្តជាព្រានដែលពួកស្តេចចេតរាជ តែងតាំងដើម្បីរក្សាព្រះវេស្សន្តរ ត្រាច់ទៅក្នុងព្រៃបានឮសំឡេងយំសោករបស់ជូជកនោះ ក៏គិតថា ព្រាហ្មណ៍នេះយំចង់ជួបព្រះវេស្សន្តរ តែគាត់មិនមកតាមធម្មតា គង់នឹងសូមព្រះនាងមទ្រី ព្រះរាជឱរសឬព្រះរាជធីតា អញនឹងសម្លាប់វាក្នុងព្រៃនេះ

ឯងទើបចូលទៅជិតពោលថា អីតាព្រាហ្មណ៍ អញនឹងមិនឲ្យជីវិតដល់អាទេ ពោលដូច្នេះហើយលើកធ្នូឡើងបម្រុងនឹងបាញ់ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហា** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសានូវព្រះគាថាដូច្នេះថា

ចេតបុត្តព្រានព្រៃ អ្នកចូលទៅក្នុងព្រៃបានស្រេជីតបទៅនឹងជូជកព្រាហ្មណ៍នោះថា នៃព្រាហ្មណ៍ ក្សត្រត្រូវពួកអ្នកធ្វើឲ្យខ្ចាត់ខ្ចាត់ទៅព្រោះអតិទាន ត្រូវគេបណ្តេញចេញចាកដែនរបស់ព្រះអង្គទៅគង់ឯគិរីវង្កត ។ ម្នាលព្រាហ្មណ៍ ក្សត្រត្រូវពួកអ្នកធ្វើឲ្យខ្ចាត់ខ្ចាត់ទៅព្រោះអតិទាន ទ្រង់នាំព្រះរាជបុត្តនិងព្រះទេវីទៅគង់ឯគិរីវង្កត ។ អ្នកជាបុគ្គលឥតប្រាជ្ញា មិនខំប្រឹងធ្វើការងារ ចេញអំពីដែនចូលមកកាន់ព្រៃធំដើរស្វែងរកព្រះរាជបុត្តដូចជាកុកស្វែងរកត្រីក្នុងទឹក ។ នៃព្រាហ្មណ៍ យើងមុខជាមិនឲ្យជីវិតដល់អ្នកនោះក្នុងទីនេះទេ ព្រោះថា ព្រួញនេះដែលយើងបាញ់សំដៅអ្នកហើយ មុខជាផឹកឈាមអ្នក ។ ម្នាលព្រាហ្មណ៍ យើងមុខជានឹងកាត់ក្បាលអ្នក ពន្ទះកាត់យកបេះដូងព្រមទាំងទងហើយបូជាបន្ថសកុណយញ្ញ ( បូជាទេវតាក្នុងផ្លូវ ) ដោយសាច់របស់អ្នក ។ ម្នាលព្រាហ្មណ៍ យើងនឹងកាត់យកបេះដូងរបស់អ្នក រួចផ្គងការបូជាដោយសាច់ ខ្លាញ់ខាប់និងក្បាល

របស់អ្នក ។ ម្នាលព្រាហ្មណ៍ ការបូជានោះដោយសាច់របស់អ្នកនោះឈ្មោះថា យើងបូជាល្អហើយ មួយទៀតអ្នកនឹងនាំព្រះទេពីនិងព្រះរាជបុត្រាបុត្រីនៃព្រះរាជបុត្តមិនបានទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អកិច្ចការី** សេចក្តីថា ឯងជាអ្នកធ្វើវត្ថុដែលមិនមែនជាកិច្ចការងារ ។ បទថា **ទុម្មេធោ** បានដល់ មិនមានបញ្ញា ។ បទថា **រដ្ឋា វិវនមាគតោ** សេចក្តីថា ចាកដែនមកកាន់ព្រៃធំ ។ បទថា **សពោចាស្សតិ** សេចក្តីថា ព្រួញនេះនឹងផឹកឈាមរបស់ឯង ។ បទថា **វជ្ឈយិត្វាន** សេចក្តីថា យើងនឹងសម្លាប់ឯង ហើយកាត់ក្បាលរបស់ឯងដែលធ្លាក់ពីលើដើមឈើឲ្យដូចផ្លែត្នោត ហើយវះយកសាច់បេះដូងមួយអន្ទើដោយពោះវៀនបូជាយញ្ញឈ្មោះបន្ទសកុណ ដល់ទេវតាដែលរក្សាផ្លូវ ។ បទថា **ន ច តុំ** សេចក្តីថា កាលបើដូច្នោះឯងនឹងនាំព្រះមហេសីព្រះរាជឱរសនិងព្រះរាជធីតារបស់ព្រះវេស្សន្តរទៅមិនបាន ។

ជូជកបានស្តាប់ពាក្យរបស់ចេតបុត្តហើយក៏ខ្លាចចំពោះមរណភ័យ កាលនឹងពោលមុសាវាទទើបពោលថា

នែចេតបុត្ត អ្នកចូរស្តាប់យើងព្រាហ្មណទូត អ្នកមិនត្រូវ
សម្លាប់ទេ ព្រោះហេតុនោះឯងបានជាគេមិនសម្លាប់ទូត នេះ
ជាធម៌មានមកយូរយារណាស់ហើយ ពួកអ្នកសិវិរាស្ត្រទាំង
អស់បាត់ខឹងហើយ ព្រះបិតាចង់ចួបព្រះបាទវេស្សន្តរនោះទាំង
ព្រះមាតាព្រះអង្គក៏មានកម្លាំងថយ ពុំយូរឡើយមុខជានឹងងងឹត

ព្រះនេត្រ ( ដោយទ្រង់ព្រះពិលាប ) ។ នែចេតបុត្ត អ្នកចូរ
ស្តាប់ពាក្យយើង យើងជារាជទូត ដែលក្សត្រទាំងនោះបញ្ជូន
មកហើយ យើងនឹងនាំទៅនូវព្រះរាជបុត្ត បើអ្នកដឹងអ្នកចូរ
ប្រាប់យើង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **និជ្ឈត្តា** បានដល់ យល់ហើយ ។ បទថា **អចិរា ចក្ខូនិ ជីយរេ** សេចក្តីថា ព្រះនេត្រទាំង ២ នឹងទ្រុឌទ្រោមក្នុងកាលមិនយូរឡើយ ព្រោះទ្រង់ព្រះកន្សែងជានិច្ច ។

កាលនោះព្រានចេតបុត្តក៏មានសោមនស្សដោយគិតថា បានឮថា ឥឡូវនេះព្រាហ្មណ៍នេះមកអញ្ជើញព្រះវេស្សន្តរត្រឡប់ ទើបចងឆ្កែទាំងឡាយទុកឲ្យនៅក្នុងចំណែកម្ខាងហើយឲ្យជូជកចុះអំពីលើដើមឈើ ឲ្យអង្គុយលើកម្រាលស្លឹកឈើឲ្យភោជនីយាហារ កាលធ្វើបដិសណ្ឋារៈបានពោលគាថានេះថា

នែព្រាហ្មណ៍ អ្នកជាទូត ជាទីស្រឡាញ់នៃព្រះបាទវេស្សន្តរ
ដែលជាទីស្រឡាញ់របស់យើង យើងខ្ញុំនឹងឲ្យភាជន៍ ដ៏ពេញ
ដោយទឹកផង តុម្ពទឹកឃ្មុំនេះផង ភ្លៅម្រឹគ ( ដែលចម្អិនស្រេច )
ផងដល់អ្នក មួយទៀតព្រះបាទវេស្សន្តរដែលជាអ្នកឲ្យវត្ថុជា
ទីប្រាថ្នា គង់នៅក្នុងប្រទេសណា យើងនឹងប្រាប់ប្រទេសនោះ
ដល់អ្នក ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បិយស្ស មេ** សេចក្តីថា តាជាទូតជាទីស្រឡាញ់របស់ព្រះវេស្សន្តរ ក៏ជាទីស្រឡាញ់របស់ខ្ញុំ ខ្ញុំឲ្យបណ្ណាការដល់តា

ដើម្បីបំពេញអធ្យាស្រ័យ ។

ជូជកកណ្ឌ ចប់

## ចូឡវនវណ្ណនា

ព្រានឈ្មោះចេតបុត្ត ឲ្យជូជកព្រាហ្មណ៍បរិភោគហើយ ឲ្យត្រុម្ពទឹកឃ្មុំនិងភ្លៅម្រឹគដែលអាំងដល់ជូជកដើម្បីជាស្បៀងធ្វើយ៉ាងនេះហើយ ឈរត្រង់ផ្លូវលើកដៃខាងស្តាំឡើង កាលនឹងប្រាប់ឱកាសទីប្រថាប់នៅ នៃព្រះវេស្សន្តរមហាសត្វទើបពោលថា

នែមហាព្រាហ្មណ៍ នោះហ្ន៎ភ្នំគន្ធមាទន៍ ជាវិការៈនៃថ្មដែលព្រះបាទវេស្សន្តរស្តេចគង់នៅជាមួយនឹងព្រះរាជបុត្តនិងព្រះទេវី ។ ព្រះរាជាទ្រទ្រង់ភេទអ្នកបួសដ៏ប្រសើរផង មានតម្ពក់និងវែកសម្រាប់បូជាភ្លើងនិងជដាផង ទ្រង់ស្លៀកដណ្តប់ស្បែកខ្លា ផ្ទំលើផែនដី នមស្ការនូវភ្លើង ។ ឈើទាំងឡាយនុ៎ះដ៏ខៀវ ទ្រទ្រង់ផ្លែផ្សេងៗ ដ៏ខ្ពស់មានកំពូលទើសមេឃ ដ៏ខៀវដូចភ្នំផ្កាអញ្ចន ។ មានដើមត្របែកព្រៃ ដើមត្រចៀកប្រើស ដើមគគីរ ដើមរាំង ដើមពន្រនិងដើមជ្រៃ ទោរទន់ទៅមកដោយខ្យល់ ដូចជាមាណពទើបផឹក ( ស្រា ) មួង ។ នៅខាងលើមែកឈើទាំងឡាយពួកសួរស័ព្ទដូចជាចម្រៀងទិព្វ ( ព្រោះ ) មានហ្វូង

ប៉ោលតោកនិងតាវ៉ៅ ចុះទំពីឈើមួយទៅឈើមួយ ។ មែកឈើនិងស្លឹកឈើទាំងឡាយដែលខ្យល់បក់ត្រូវហើយ ឮដូចជាហៅរកជនកំពុងដើរ ដូចជារីករាយនឹងជនដែលមកដល់ ត្រេកត្រអាលនឹងជនដែលនៅអាស្រ័យ ។ អ្នកនឹងចូលទៅក្នុងអាស្រមដែលជាកន្លែងព្រះបាទវេស្សន្តរស្តេចគង់នៅជាមួយនឹងព្រះរាជបុត្រាបុត្រីទាំងឡាយ ស្តេចទ្រទ្រង់ភេទជាអ្នកបួស ដ៏ប្រសើរ មានតម្ពក់និងវែកសម្រាប់បូជានិងព្រះជដា ទ្រង់ស្លៀកស្បែកខ្លា ផ្ទុំលើផែនដី នមស្ការភ្លើង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **គន្ធមាទនោ** សេចក្តីថា ទ៊ុះភ្នំគន្ធមាទន៍ តាបែរមុខទៅទិសឧត្តរ ដើរទៅតាមជើងភ្នំគន្ធមាទន៍នឹងឃើញអាស្រម ដែលសក្កៈប្រទាន ជាទីដែលព្រះរាជាឈ្មោះវេស្សន្តរមួយអន្លើដោយព្រះរាជឱរសព្រះរាជធីតានិងព្រះមហេសីគង់ប្រថាប់ ។ បទថា **ព្រាហ្មណវណ្ណំ** បានដល់ជាភេទបព្វជិតដ៏ប្រសើរ ។ បទថា **អាសទញ្ច មសញ្ជដំ** សេចក្តីថា ទ្រទ្រង់នូវតម្ពក់សម្រាប់បេះផ្លែឈើ ភាជនៈសម្រាប់ប្រើក្នុងការបូជាភ្លើងនិងជដា ។ បទថា **ចម្មវាសី** បានដល់ ទ្រទ្រង់នូវស្បែកខ្លាដំបង ។ បទថា **ឆមា សេតិ** សេចក្តីថា ផ្ទុំលើកម្រាលស្លឹកឈើលើផែនដី ។ បទថា **ធវស្សកណ្ណា ខទិរា** បានដល់ ដើមត្របែកព្រៃ ដើមត្រចៀកប្រើសនិងដើមគគីរ ។ បទថា **សកឹ បីតាវ មាណវា** សេចក្តីថា ហាក់បីដូចអ្នកលេងផឹកទឹកស្រវឹង គឺផឹកម្តងប៉ុណ្ណោះ ។ បទថា **ឧបរិ ទុមបរិយាយេសុ** បានដល់ ត្រង់មែកនៃដើមឈើ

ទាំងឡាយ ។ បទថា **សង្គតិយោវ សុយ្យរ** សេចក្តីថា នឹងបានស្តាប់សំឡេង របស់ពួកបក្សីផ្សេងៗដែលនៅជាមួយគ្នាដូចទិព្វតន្ត្រី ។ បទថា **ឆដ្ឋុហា** បាន ដល់ សត្វប៉ោលតោក ។ បទថា **សម្បតន្តិ** បានដល់ ត្រាច់បន្លឺសំឡេងយំ ខ្សៀវខ្សារ ។ បទថា **សាខាបត្តសមីរិតា** សេចក្តីថា ពួកបក្សីត្រូវស្ទឹកនិង មែកឈើប៉ះគ្នាក៏នាំគ្នាយំខ្សៀវខ្សារ ឬមែកឈើមានខ្យល់បក់ហើយនោះឯង ។ បទថា **អាគន្តុំ** បានដល់ មនុស្សដែលនឹងចេញទៅ ។ បទថា **យត្ថ** សេចក្តី ថា តាទៅក្នុងអាស្រមបទ ដែលជាទីគង់ប្រថាប់នៃព្រះវេស្សន្តរ ហើយនឹង ឃើញសម្បត្តិនៃអាស្រមបទនេះ ។

ព្រានចេតបុត្តកាលពណ៌នាដល់អាស្រមបទ ឲ្យក្រៃលែងឡើងជាងដែល ពោលមកហើយនោះ ទើបពោលថា

ក្នុងទីនុ៎ះមានដើមស្វាយ ខ្វិត ខ្នុរ រាំង ព្រីង សម៉ពិភេទក៍ សម៉ ភ្នក កន្ទួតព្រៃ ពោធិ ពុទ្រា ទន្លាប់មាស ជ្រៃនិងក្រសាំង មាក់សាង មានផ្លែដ៏ផ្អែមរុងរឿងនិងល្វាមានផ្លែទុំ ដើមទាបៗ មានចេកអំបូងភ្នក ចេកអំបូងស្នែងនិងចន្ទួ៍ មានផ្លែផ្អែមដូច ទឹកឃ្មុំ គេតែងយកឃ្មុំឥតមេក្នុងទីនោះមកជារបស់ខ្លួន ហើយ បរិភោគ ។ ក្នុងទីនុ៎ះមានស្វាយខ្លះកំពុងផ្កា ស្វាយខ្លះទើបជា ក្បាលរុយ ស្វាយខ្លះមានផ្លែខ្ចីនិងទុំ ផ្លែទាំងពីរបែបនោះមាន សម្បុរដូចខ្នងកញ្ចាញ់ចេក ។ ក្នុងទីនុ៎ះបុរស ( ឈរ ) ខាង ក្រោមបេះផ្លែស្វាយទុំទាំងឡាយ ស្វាយទាំងឡាយទាំងខ្ចីទាំងទុំ

មានសម្បុរ ក្លិននិងរសដ៏ឧត្តម ។ ខ្ញុំតែងមានសេចក្តីអស្ចារ្យក្រៃពេក ទាំងការលាន់ឮថាហឹងៗក៏ប្រាកដដល់ខ្ញុំ ប្រទេសនោះឧបមាដោយនន្ទនវ័ន ល្អដូចជាទីនៅរបស់ពួកទេវតា ។ ត្នោតដូងដុះចម្រុះគ្នាក្នុងព្រៃល្មើដ៏ធំ ផ្កាទាំងឡាយដូចជាកម្រងដែលគេក្រងហើយ ឬប្រាកដដូចជាជាយទង់ជ័យ ។ ខ្វែងគង់ គុម្ពកោដ្ឋ គុម្ពក្រស្នា ប្រទៀង បុន្នាគតូច បុន្នាគធំនិងរលួសមានផ្កាពណ៌ផ្សេងៗ រីកស្គុសស្គាយ ដូចផ្កាយដែលភ្លឺព្រោងព្រាតឮដ៏អាកាស ។ រាជព្រឹក្ស ខ្នុញ កំញាន រាក់ខ្មៅ ជ្រៃធំ ទន្លានិងផ្ចង់ជាច្រើនបញ្ចេញផ្កាក្នុងទីនោះ ។ ខ្វែងគង់ ស្រល់ស្មោល សង្ស័រ ខ្នុរសម្ភ ត្របែកព្រៃនិងរាំងជ្រុះផ្កាក្នុងទីនោះដូចជាលានចំបើង ។ ក្នុងភូមិភាគជាទីមនោរម្យជិតអាស្រមនោះមានស្រះបោក្ខរណី ដេរដាសដោយផ្កាឈូកនិងផ្កាព្រលិតដូចជាក្នុងនន្ទនវ័នរបស់ពួកទេវតា ។ មួយទៀតពួកតាវ៉ៅដែលស្រវឹងដោយរសផ្កា យំពីរោះនៅលើឈើ ដែលមានផ្ការីកតាមរដូវ ញុំាងព្រៃនោះឲ្យលាន់ឮគឹកកង ។ លំអងដែលរោយរាយចេញអំពីកេសរដែលមាននៅគ្រប់ស្លឹកឈូកមានរសផ្អែម បើខ្យល់បក់ផាត់មកក្នុងទីអាស្រមនុ៎ះ អំពីទិសខាងត្បូងនិងខាងលិច ។ អាស្រមក៏ដេរដាសដោយលំអងកេសរផ្កាឈូក ក្នុងស្រះបោក្ខរណីនុ៎ះ មានផ្លែក្រចាប់ដ៏ថ្លោសៗនិងស្រូវសាលីជ្រុះ

រោយរាយលើផែនដី ។ មួយទៀតមានត្រី អណ្តើកនិងក្តាម ច្រើនបែប ហែបហែលទៅមកក្នុងស្រះនោះ រសដែលហូរចេញអំពីក្រអៅឈូកមានឱជាដូចទឹកឃ្មុំនិងរសដែលហូរចេញអំពីមើមឈូកមានឱជាដូចទឹកដោះស្រស់ និងទឹកដោះថ្លា ព្រៃនោះមានក្លិនក្រអូបផ្សេងៗ ផ្សព្វផ្សាយក្លិនឈ្ងុយឈ្ងប់ ។ ព្រៃនោះដូចជា ( ញុំាងជនដែលមកដល់ ) ឲ្យរីករាយដោយក្លិនដោយផ្កានិងមែកឈើ កន្ទន់ទាំងឡាយ ក៏ញុំាងព្រៃឲ្យគឹកកងដោយជុំវិញព្រោះតែក្លិនផ្កា ។ មិនតែប៉ុណ្ណោះសោតមានសត្វបក្សីទិជាតិជាច្រើនមានសម្បុរផ្សេងៗគ្នា ត្រេកត្រអាលជាមួយនឹងមេយំរកគ្នាទៅវិញទៅមកក្នុងស្រះនោះ ។ ពួកបក្សីដែលនៅក្នុងស្រះបោក្ខរណី គឺសត្វនន្ទិកា ១ សត្វជីវបុត្តា ១ សត្វជីវបុត្តាបិយាចនោ ១ សត្វបិយាបុត្តាបិយានន្ទា ១ ។ ផ្កាទាំងឡាយដូចជាកម្រងផ្កាដែលគេក្រងហើយ ប្រាកដដូចជាជាយទង់ជ័យ ពុំនោះដូចជាកម្រងផ្កាដែលមាលាការ ដ៏ឈ្លាសក្រងយ៉ាងល្អ ដោយផ្កាមានពណ៌ផ្សេងៗ ។ ក្នុងទីដែលព្រះបាទវេស្សន្តរទ្រង់គង់នៅជាមួយនឹងព្រះរាជបុត្រាបុត្រី ព្រះអង្គទ្រង់ភេទជាអ្នកបួសដ៏ប្រសើរ មានតម្ពក់និងវែកសម្រាប់បូជាភ្លើង ផងនិងព្រះជដា ទ្រង់ស្លៀកស្បែកខ្លា ផ្ទំនៅលើផែនដី នមស្ការភ្លើង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ចារុតិម្ពរុក្ខា** បានដល់ ដើមទន្លាប់មាស ។ បទថា **មធុមធុកា** បានដល់ ដើមស្រគំដែលមានរសផ្អែម ។ បទថា **ថេវន្តិ** បានដល់ រមែងរុងរឿង ។ បទថា **មធុត្ថិកា** បានដល់ ដូចទឹកឃ្មុំឬសម្បុកឃ្មុំព្រោះមានទឹកជានិច្ច ។ បទថា **ចារេវតា** បានដល់ ដើមចេកអំបូងភ្លុក ។ បទថា **ករេយ្យា** បានដល់ ដើមចេកដែលមានផ្លែវែង ។ បទថា **សកមា-ទាយ** សេចក្តីថា កាន់យកនូវសម្បុកឃ្មុំនោះបរិភោគបានឯងនោះឯង ។ បទថា **ធោវិលា** បានដល់ មានផ្កានិងស្លឹករុះរោយ មានផ្លែជេរជាស ។ បទថា **ភេកវណ្ណា តទុភយំ** សេចក្តីថា ស្វាយទាំង ២ យ៉ាងនោះ គឺខ្ចីខ្លះ ទុំខ្លះ មានពណ៌ដូចខ្នងកញ្ចាញ់ចេក ។ បទថា **អថេត្ថ ហេដ្ឋា បុរិសោ** សេចក្តីថា ម្យ៉ាងទៀតក្នុងអាស្រមនោះ បុរសឈរក្រោមដើមស្វាយទាំងនោះរមែងបេះផ្លែស្វាយបានមិនចាំបាច់ឡើង ។ បទថា **វណ្ណគន្ធរសុត្តមា** បានដល់ ប្រសើរដោយពណ៌ជាដើម ។

បទថា **អតេវ មេ អច្ឆរិយំ** សេចក្តីថា ជាទីអស្ចារ្យដល់ខ្ញុំពន់ពេក ។ បទថា **ហិង្ការោ** បានដល់ ធ្វើសំឡេងថា **ហឹ ហឹ** ។ បទថា **វិភេទកា** បានដល់ ដើមស្មោត ។ បទថា **មាលាវ គន្ថិតា** សេចក្តីថា ផ្កាទាំងឡាយតាំងនៅលើដើមឈើដែលមានផ្ការីកស្គុសស្គាយ ដូចកម្រងផ្កាដែលនាយមាលាការក្រងទុក ។ បទថា **ធជគ្គានេវ ទិស្សរេ** សេចក្តីថា ដើមឈើទាំងនោះប្រាកដបីដូចទង់ដែលប្រដាប់ហើយ ។ បទថា **កុដជី កុដ្ឋតគរា** បានដល់ វុក្ខជាតិឯណាមួយដែលមានឈ្មោះថា ដើមខ្ទឹងគង់ គុម្ពកោដ្ឋនិងគុម្ព

*ក្រស្នា ។ បទថា* **គិរិបុន្នាគា** *បានដល់ បុន្នាគធំ ។ បទថា* **កោវិឡារា** *បានដល់ ដើមរលួសផ្អុង ។ បទថា* **ឧទ្ទាលកា** *បានដល់ ដើមរាជព្រឹក្សដែលមានផ្កាពណ៌លឿង ។ បទថា* **ភល្លិយា** *បានដល់ ដើមរាក់ខ្មៅ ។ បទថា* **លពុជា** *បានដល់ ដើមខ្នុរសម្ល ។ បទថា* **បុត្តជីវា** *បានដល់ ដើមជ្រៃធំ ។ បទថា* **បលាលខលសន្និភា** *សេចក្តីថា ព្រានចេតបុត្តពោលថា ផ្កាដែលរុះរោយក្រោមដើមឈើទាំងនោះ ដូចគ្នានឹងពំនូកចំបើង ។ បទថា* **ពោក្ខរណី** *បានដល់ ស្រះបោក្ខរណីរាង ៤ ជ្រុង ។ បទថា* **ឆន្នេ** *បានដល់ ហាក់បីដូចទន្ទនបោក្ខរណី ក្នុងទន្ទនវនឧទ្យាន ។ បទថា* **បុប្ផរសមត្តា** *បានដល់ស្រវឹងដោយរសនៃបុប្ផជាតិ គឺត្រូវរសរបស់បុប្ផជាតិជាស់តឿន ។ បទថា* **មករន្ទេហិ** *បានដល់ អំពីកេសរផ្កា ។ បទថា* **ពោក្ខរេ ពោក្ខរេ** *សេចក្តីថា លំអងជ្រុះអំពីកេសរឈូកទាំងនោះទៅលើស្លឹកឈូកឈ្មោះបោក្ខរមធុ គឺទឹកឃ្មុំក្នុងស្លឹកឈូក ។ បទថា* **ទក្ខិណា អថ បច្ឆិមា** *សេចក្តីថា ខ្យល់អំពីទិសតូចធំគ្រប់ទិស លោកសម្តែងដោយពាក្យមានប្រមាណប៉ុណ្ណេះ ។ បទថា* **ថូលា សិង្ឃាដកា** *បានដល់ ក្រចាប់ដែលមានទំហំធំ ។ បទថា* **សសាទិយា** *បានដល់ ស្រូវសាលីតូចៗដែលជាស្រូវសាលីកើតឯងហៅថា ស្រូវសាលីសក៏មាន ។ បទថា* **បសាទិយា** *បានដល់ ស្រូវសាលីទាំងនោះឯងជ្រុះលើផែនដី ។ បទថា* **ព្យាវិធា** *សេចក្តីថា ពួកសត្វទឹកប្រភេទផ្សេងៗត្រាច់ទៅជាក្រុមៗក្នុងទឹកថ្លាហែលទៅតាមលំដាប់នៅប្រាកដ ។ បទថា* **មុបយានកា** *បានដល់ ក្តាម ។ បទថា* **មធុំ ភិសេហិ** *សេចក្តីថា កាលក្រអៅ*

ឈូកបែកទឹកផ្អែមក៏ហូរចេញដូចទឹកឃ្មុំ ។ បទថា **ខីរំ សប្បិ ម្ធុឡាលិភិ** សេចក្តីថា ទឹកផ្អែមដែលហូរអំពីក្រអៅឈូកបីដូចជានវនីតសប្បិដែលលាយដោយទឹកដោះស្រស់ ។ បទថា **សម្មោធិតេវ** សេចក្តីថា ដូចនឹងញុំាងជនដែលដល់ហើយឲ្យត្រេកអរ ។ បទថា **សមន្តាមភិឆាធិតា** សេចក្តីថា ហើរយំដោយជុំវិញ ។ បទថា **ឆន្ទិកា** ជាដើម ជាឈ្មោះរបស់បក្សីទាំងនោះ ។ បណ្តាបក្សីទាំងនោះបក្សីទី ១ ស្រែកថ្វាយព្រះពរថា បពិត្រព្រះវេស្សន្តរ សូមទ្រង់ត្រេកអរប្រថាប់នៅក្នុងព្រៃនេះចុះ បក្សីពួកទី ២ យំថ្វាយព្រះពរថា សូមទ្រង់ មួយអន្លើដោយព្រះរាជឱរសនិងព្រះរាជធីតានិងមហេសី សូមមានព្រះជន្មយឺនយូរដោយសេចក្តីសុខចុះ បក្សីពួកទី ៣ ស្រែកយំថ្វាយព្រះពរថា សូមទ្រង់មួយអន្លើដោយព្រះរាជឱរសព្រះរាជធីតានិងមហេសី ជាទីស្រឡាញ់របស់ព្រះអង្គសូមមានសេចក្តីសុខ មានជន្មជន្មយឺនយូរ មិនមានសត្រូវចុះ បក្សីទី ៤ ស្រែកថ្វាយព្រះពរថា សូមព្រះរាជឱរស ព្រះរាជធីតានិងមហេសីជាទីស្រឡាញ់របស់ទ្រង់ សូមទ្រង់ជាទីស្រឡាញ់របស់ព្រះរាជឱរស ព្រះរាជធីតានិងមហេសី សូមទ្រង់រីករាយដល់គ្នានឹងគ្នាចុះ ព្រោះហេតុនោះទើបបក្សីទាំងនោះមាននូវឈ្មោះយ៉ាងនេះឯង ។ បទថា **ចោក្ខរណីយា** បានដល់ ធ្វើសម្បុកនៅជិតស្រះបោក្ខរណី ។ ព្រានឈ្មោះចេតបុត្ត ប្រាប់ទីប្រថាប់របស់ព្រះវេស្សន្តរយ៉ាងនេះហើយ ជូជកក៏ត្រេកអរកាលធ្វើបដិសណ្ឋារៈទើបពោលគាថានេះថា

ភត្តុ គឺសដូវនេះដែលយើងលាយហើយដោយទឹកឃ្មុំ យើងនឹង

*ឲ្យនូវទឹកឃ្មុំដែលយើងធ្វើល្អហើយផងនិងភត្ត គឺសដូវផងដល់អ្នក ដូច្នេះ ។*

*បណ្តាបទទាំងនោះ បទថា* **សត្តុភត្តំ** *បានដល់ ភត្តាហារ គឺសដូវដែលដូចគ្នានឹងទឹកឃ្មុំម្ចាស់ មានពាក្យអធិប្បាយថា សដូវរបស់មាមាន មានឹងឲ្យដល់ឯង ចូរឯងទទួលយកចុះ ។*

*ចេតបុត្តព្រានបានស្តាប់ដូច្នោះហើយទើបពោលថា*

*ស្បៀងចូរនៅជារបស់អ្នកឯងចុះ យើងមិនត្រូវការស្បៀងទេ នែព្រាហ្មណ៍ អ្នកចូរយកស្បៀងអំពីនេះទៅ នែព្រាហ្មណ៍ អ្នកចូរទៅតាមស្រួលចុះ ។ ផ្លូវនេះជាផ្លូវល្មមដើរចុះបុគ្គលម្នាក់ត្រង់ទៅកាន់អាស្រម ក្នុងអាស្រមនោះមានឥសីឈ្មោះអច្ចុតៈ មានធ្មេញប្រកបដោយមន្ទិល មានសរីរៈប្រឡាក់ដោយធូលី ទ្រទ្រង់ភេទជាអ្នកបួសដ៏ប្រសើរផង តម្បក់ផង វែកសម្រាប់បូជាភ្លើងផង ជដាផង ។ ឥសីឈ្មោះអច្ចុតៈនោះជាអ្នកស្លៀកស្បែកខ្លា ដេកនៅលើកម្រាលស្លឹកឈើលើផែនដី នមស្ការភ្លើង អ្នកចូរទៅសួរលោកចុះ លោកនឹងប្រាប់ផ្លូវដល់អ្នកពុំខាន ដូច្នេះ ។*

*បណ្តាបទទាំងនោះ បទថា* **សម្ពលំ** *បានដល់ ស្បៀងធ្វើដំណើរ ។ បទថា* **ឯតិ** *សេចក្តីថា ផ្លូវដើរបានចំពោះបុគ្គលតែម្នាក់ ត្រង់ចំពោះមុខយើងទាំង ២ នេះត្រង់ទៅកាន់អាស្រមបទ ។ បទថា* **អច្ចុតោ** *សេចក្តីថា ឥសីមួយ*

អន្ទមានឈ្មោះយ៉ាងនេះនៅក្នុងអាស្រមនោះ ។

ជូជកជាព្រហ្មពន្ធុ លុះបានឮពាក្យនេះហើយក៏មានចិត្តរីករាយ ប្រទក្សិណបេតបុត្តព្រានព្រៃ រួចដើរតម្រង់ទៅកាន់អច្ចុតឫសី ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **យេនាសិ** សេចក្ដីថា អច្ចុតឥសីនៅក្នុងទីណា ជូជកក៏ទៅហើយក្នុងទីនោះ ។

**ចូឡវនវណ្ណនា ចប់**

# មហាវនវណ្ណនា

កាលជូជកព្រាហ្មណ៍នោះ ដើរទៅជួបឥសីឈ្មោះអច្ចុតៈ លុះជូជកបានឃើញឥសីនោះហើយ ក៏សំណេះសំណាលជាមួយនឹងឥសីថា លោកដ៏ចម្រើន សុខសប្បាយទេឬ លោកដ៏ចម្រើនមិនមានរោគាពាធទេឬ លោកចិញ្ចឹមជីវិតដោយការស្វែងរក (ស្រួល) ទេឬ មើមឈើនិងផ្លែឈើមានច្រើនដែរឬ ។ ពួករបោម មូស ពស់មានតិចទេឬ ក្នុងព្រៃដែរដាសដោយម្រឹគសាហាវមិនមានការបៀតបៀនទេឬ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ភារទ្វាជោ** បានដល់ ជូជក ។ បទថា **អប្បមេវ** បានដល់ តិចតួចនោះឯង ។ បទថា **ហឹសា** បានដល់ ការបៀត

បៀនឲ្យលោកលំបាកដោយអំណាចនៃសត្វទាំងនោះ ។

តាបសពោលថា

ម្នាលព្រាហ្មណ៍ អាត្មាសុខសប្បាយទេ អាត្មាមិនមានរោគាពាធទេ មួយទៀតអាត្មាចិញ្ចឹមជីវិតដោយការស្វែងរក (ស្រួល) ទេ ទាំងមើមឈើផ្លែឈើក៏មានច្រើនដែរ ។ មួយវិញទៀតពួករបោម មូស ពស់មានតិចទេ ក្នុងព្រៃដ៏ដេរដាសដោយម្រឹគសាហាវ មិនមានការបៀតបៀនអាត្មាទេ ។ អាត្មានៅក្នុងអាស្រមនេះអស់ប្រជុំនៃឆ្នាំជាច្រើន អាត្មាមិនដែលស្គាល់អាពាធ មិនជាទីត្រេកអរនៃចិត្តកើតហើយទេ ។ នែមហាព្រាហ្មណ៍ អ្នកមកល្អហើយ អ្នកមិនមែនមកអាក្រក់ទេ ម្នាលព្រាហ្មណ៍ដ៏ចម្រើន អ្នកអញ្ជើញចូលមកខាងក្នុង អ្នកចូរលាងជើងទាំងឡាយរបស់អ្នកចុះ ។ នែព្រាហ្មណ៍ អ្នកចូរបរិភោគផ្លែទន្លាប់ ផ្លែទ្រយឹង ផ្លែមាក់សាង ផ្លែមាក់ដោកមានរសឆ្ងាញ់ពីសាដូចជាទឹកឃ្មុំ ។ ទាំងទឹកត្រជាក់នេះ អាត្មាបានដងមកអំពីជ្រោះភ្នំ នែមហាព្រាហ្មណ៍ អ្នកចូរផឹកទឹកនោះចុះ ប្រសិនបើអ្នកត្រូវការដូច្នេះ ។

ជូជកពោលថា

វត្ថុដែលលោកបានឲ្យ ខ្ញុំបានទទួលយកហើយដែលលោកបានធ្វើឲ្យជាជំនូន ដល់ខ្ញុំទាំងអស់ ខ្ញុំមកដើម្បីចង់ចួបនឹងព្រះរាជ

បុត្តបង្កើតរបស់ព្រះបាទសញ្ជ័យ ដែលពួកអ្នកសិវិរាស្ត្របំបរ
បង់ហើយនោះ ប្រសិនបើលោកជ្រាបសូមប្រាប់ខ្ញុំផង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តមហំ ធស្សនមាគតោ** សេចក្តីថា ខ្ញុំមក
ដើម្បីជួបព្រះវេស្សន្តរនោះ ។

តាបសពោលថា

អ្នកមិនមែនមកគាល់ព្រះបាទសិវិដើម្បីបុណ្យទេ អ្នកទំនងជា
ចង់បានព្រះទេវីរបស់ព្រះរាជាដែលជាស្ត្រីប្រតិបត្តិក្នុងកស្តា ។
អ្នកទំនងជាចង់បានកុមារីឈ្មោះ កណ្ហាជិនាធ្វើជាទាសីនិងកុមារ
ឈ្មោះជាលីធ្វើជាទាសៈ ឬក៏អ្នកមកដើម្បីនាំយកជនទាំង ៣
នាក់ គឺមាតានិងបុត្រីបុត្រាទៅអំពីព្រៃ នែព្រាហ្មណ៍ ឯព្រះ
បាទវេស្សន្តរនោះមិនមានភោគៈ មិនមានទ្រព្យ មិនមានធញ្ញ-
ជាតិទេ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ន តស្ស ភោគា វិជ្ជន្តិ** សេចក្តីថា នែ
ព្រាហ្មណ៍ដ៏ចម្រើន ព្រះវេស្សន្តរនោះ នៅក្នុងព្រៃរមែងមិនមានភោគសម្បត្តិ
និងស្រូវអង្ករ ទ្រង់នៅយ៉ាងក្រីក្រអ្នកទៅគាល់ទ្រង់ធ្វើអ្វី ។

ជូជកបានស្តាប់ដូច្នោះហើយក៏ពោលថា

ខ្ញុំមិនមែនមានសភាពជាអ្នកខឹងនឹងលោកទេ ខ្ញុំមិនមែនមក
ដើម្បីសូមទេ កាលចួបប្រទះនឹងពួកលោកដ៏ប្រសើរ ជាការល្អ
ការនៅរួមនាំមកនូវសេចក្តីសុខសព្វៗកាល ។ ព្រះបាទសិវិ

ដែលពួកអ្នកសិវិរាស្ត្រ បំបរបង់ហើយ ខ្ញុំមិនដែលបានឃើញ
បានជាខ្ញុំមកគាល់ព្រះអង្គ ប្រសិនបើលោកជ្រាបសូមប្រាប់ខ្ញុំ
ផង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ជាតាសិ សំស មេ** មានពាក្យអធិប្បាយថា ខ្ញុំជាបុគ្គលមិនគួរលោកក្រោធ ដោយហេតុត្រឹមប៉ុណ្ណេះ ដ្បិតថាខ្ញុំមកដើម្បីសូមអ្វីមួយនឹងព្រះវេស្សន្តរ ក៏មិនមែន ម្យ៉ាងទៀតការបានឃើញលោកដ៏ប្រសើរទាំងឡាយ ញុំាងប្រយោជន៍ឲ្យសម្រេច ការនៅរួមជាមួយនឹងបុគ្គលប្រសើរទាំងនោះក៏ជាសេចក្តីសុខ ខ្ញុំជាព្រាហ្មណ៍ ជាអាចារ្យរបស់ព្រះវេស្សន្តរនោះ ចាប់តាំងពីព្រះអង្គត្រូវអ្នកសិវិរាស្ត្របំបរបង់នោះ ខ្ញុំមិនបានឃើញព្រះអង្គឡើយ ព្រោះហេតុនោះទើបខ្ញុំមកដើម្បីឃើញព្រះអង្គ បើលោកម្ចាស់ដឹងទីប្រថាប់របស់ព្រះវេស្សន្តរ ក៏ចូរប្រាប់ដល់ខ្ញុំ ។

អច្ចុតតសីបានស្តាប់ពាក្យរបស់ជូជកក៏ជឿពោលថា អើ ស្អែកនេះយើងនឹងបង្ហាញប្រទេស គឺទីប្រថាប់របស់ព្រះវេស្សន្តរដល់អ្នក ថ្ងៃនេះអ្នកនៅក្នុងទីនេះសិន ពោលដូច្នេះហើយឲ្យជូជកបរិភោគផលាផលរហូតឆ្អែតស្កប់ស្កល់ ស្អែកឡើងកាលនឹងចង្អុលផ្លូវទើបលាដៃស្តាំពោលថា

នែមហាព្រាហ្មណ៍ នុ៎ះហ្ន៎ភ្នំគន្ធមាទន៍ ជាវិការៈនៃថ្មដែលព្រះ
បាទវេស្សន្តរស្តេចគង់នៅជាមួយព្រះរាជបុត្តនិងព្រះទេពី ។ ព្រះ
រាជាទ្រទ្រង់ភេទនៃបព្វជិតដ៏ប្រសើរ មានតម្បក់និងវែកសម្រាប់
បូជាភ្លើង សក់កណ្តាញ់ ស្លៀកដណ្តប់ស្បែកខ្លា ផ្ទំផ្ទាល់ផែនដី

នមស្ការភ្លើង ។ ពួកឈើដែលមើលទៅឃើញទុំៈ ជាឈើមាន ពណ៌ខៀវទ្រទ្រង់ផ្លែផ្សេងៗ ខ្ពស់មានចុងស្មើនឹងពពក មាន ពណ៌ខៀវដូចភ្នំផ្កាអញ្ជ័ន គឺដើមត្របែកព្រៃ ត្រចៀកប្រើស គគីរ រាំងភ្នំ ពង្រនិងជ្រៃញ័រទ្រេតទ្រោតដោយខ្យល់ដូចពួកមាណព ទើបផឹក ( សុរា ) ម្តង ។ ( សំឡេងរបស់ពួកសត្វស្លាប ផ្សេងៗ ) លើមែកឈើទាំងឡាយលាន់ឮដូចចម្រៀង ( ទិព្វ ) ពួកសត្វប៉ោលតោក សត្វតាវៅនាំគ្នាហើរឆ្មៀលឆ្វាត់អំពីដើម ឈើមួយទៅកាន់ដើមឈើមួយ ។ អស់ទាំងមែកឈើមាន ស្លឹកដែលត្រូវខ្យល់បក់មកក៏ហាក់ដូចជាជង្ហោយហៅជនដែល កំពុងដើរ ដូចជាត្រេកអរនឹងជនដែលមកដល់ រីករាយនឹងជន ដែលនៅអាស្រ័យ ។ ( អ្នកនឹងឃើញសម្បត្តិនៃអាស្រមបទ ) ក្នុងអាស្រម ដែលព្រះបាទវេស្សន្តរ ស្តេចគង់នៅជាមួយព្រះ រាជបុត្តនិងព្រះទេពី ព្រះអង្គទ្រទ្រង់ភេទបព្វជិតដ៏ប្រសើរមាន តម្ពក់និងរែកសម្រាប់បូជាភ្លើងនិងសក់កណ្តាញ់ ស្លៀកជណ្តប់ ស្បែកខ្លា ផ្ទំផ្ទាល់ផែនដី នមស្ការភ្លើង ។ មានផ្កាទន្លាជ្រុះរាយ រាយ ដេរដាសលើភូមិភាគជាទីត្រេកអរនៃចិត្ត ទាំងផ្ទៃផែនដីក៏ មានពណ៌ខៀវស្រងាត់ដោយស្មៅចិញ្ចៀន ឥតមានធូលីហុយ ក្នុងទីនោះឡើយ ។ ទាំងស្មៅសោតក៏មានពណ៌ដូចជាផ្ចិតកនៃ ក្ងោក មានឧបមាស្មើដោយសម្ផស្សនៃសំឡី មិនហួសអំពី ៤

ធ្លាប់ដោយជុំវិញ ។ មានស្វាយ ព្រីង ក្ទិដ្ឋ ល្វាមានផ្លែទុំក្នុងទីទាបព្រៃនោះ សម្រាប់ញ៉ាំងតម្រេកឲ្យចម្រើន ដោយពួកឈើសម្រាប់បរិភោគ ។ ទឹកស្អាត មានក្លិនក្រអូប មានសម្បុរប្រហែលគ្នានឹងពណ៌នៃកែវពៃទូរ្យ កុះករដោយហ្វូងត្រី រមែងហូរទៅក្នុងព្រៃនោះ ។ ក្នុងទីជិតនៃអាស្រមបទនោះមានស្រះបោក្ខរណីដ៏ ដេរដាសដោយឈូកនិងឧប្បលក្នុងភូមិភាគជាទីត្រេកអរនៃចិត្ត ដូចជាក្នុងនន្ទនវ័ននៃពួកទេវតា ។ ម្នាលព្រាហ្មណ៍ ក្នុងស្រះនោះសឹងធូកធ្លាស់ដោយឧប្បលជាតបី ( នេះ ) គឺឧប្បលខៀវ ឧប្បលសនិងឧប្បលក្រហម ដូច្នេះ ។

អត្ថនៃគាថានោះ ដូចគាថាដែលបានមកហើយក្នុងខាងដើមនោះឯង ។ បទថា **ករេរិមាលា វិតតា** សេចក្តីថា ដេរដាសដោយផ្កាថ្ងាន់ទាំងឡាយ ។ បទថា **សទ្ទលា ហរិតា** សេចក្តីថា ផ្ទៃដីខៀវដោយស្មៅចិញ្ចៀនជាប្រចាំ ។ បទថា **ន តត្ថុទ្ធំសតេ រជោ** សេចក្តីថា ធូលីសូម្បីមានប្រមាណតិចក៏មិនហុយឡើងក្នុងទីនោះ ។ បទថា **តូលជសុស្សមូបមា** បានដល់ ដូចគ្នានឹងសម្ផស្សនៃសំឡី ព្រោះមានសម្ផស្សទន់ ។ បទថា **តិណានិ ណាតិវត្តន្តិ** សេចក្តីថា ស្មៅដែលមានពណ៌ដូចកក្អោកក្នុងទីនោះ កម្ពស់ត្រឹមតែ ៤ ធ្នាប់ប៉ុណ្ណោះដោយជុំវិញមិនដុះវែងជាងនេះឡើយ ។ បទថា **អម្ពា ជម្ពូ កបិដ្ឋា** ច បានដល់ ស្វាយផង ព្រីងផង ក្ទិដ្ឋផង ។ បទថា **បរិភោគេហិ** បានដល់ ដើមឈើដែលបរិភោគបាន មានផ្កា មានផ្លែច្រើនយ៉ាង ។ បទថា **សន្ទតិ**

សេចក្តីថា ទឹកហូរអំពីភ្នំប្រព្រឹត្តទៅក្នុងដងព្រៃនោះ ។ បទថា **វិចិត្រនីលា-ឆេកានិ សេតា លោហិតកានិ ច** សេចក្តីថា អច្ចុតឥសីប្រាប់ថា ស្រះនោះលំអដោយឧប្បលជាត ៣ យ៉ាង គឺឧប្បលខៀវ ១ ឧប្បលស ១ និងឧប្បលក្រហម ១ ដូចគ្នានឹងប្រអប់ផ្កាដែលរៀបចំទុកយ៉ាងវិចិត្រ ។

អច្ចុតឥសីពណ៌នាស្រះបោក្ខរណី ៤ ជ្រុងយ៉ាងនេះហើយ កាលនឹងពណ៌នាស្រះមុចលិន្ទទៀតទើបពោលថា

> ក្នុងស្រះនោះ ( ស ) ដូចជាសំពត់សម្បកឈើ ស្រះនោះឈ្មោះថា មុចលិន្ទស្រះ ដេរដាសដោយព្រលិតនិងស្ពន់ទាំងឡាយផង ដោយត្រកួនទាំងឡាយផង ។ មួយទៀតពួកផ្កាឈូកក្នុងស្រះនោះរីកស្គុសស្គាយ ឃើញហាក់ដូចជាគ្មានទីបំផុត ខ្លះក៏រីកក្នុងគិម្ហរដូវ ខ្លះរីកក្នុងហេមន្តរដូវបិតនៅក្នុងទឹកត្រឹមជង្គង់ ។ ផ្ទៃទឹកនោះ សឹងវិចិត្រល្អ ដ៏ដេរដាសដោយផ្កាមានក្លិនក្រអូបឈ្ងុយឈ្ងប់បក់ផ្សាយទៅ ពួកមេឃ្មុំ កន្ទង់ទ្រហឹងអឹងកងជុំវិញព្រោះក្លិនផ្កា ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ខោមាវ** បានដល់ ពណ៌សហាក់ដូចជាសម្រេចអំពីសំពត់សម្បកឈើ ។ បទថា **សេតសោគន្ធិយេហិ ច** សេចក្តីថា ស្រះនោះដេរដាសទៅដោយផ្កាឧប្បលស ចង្កុលណីនិងត្រកួនទាំងឡាយ ។ បទថា **អបរិយន្តាវ ទិស្សរេ** សេចក្តីថា ប្រាកដរកប្រមាណមិនបាន ។ បទថា **គិម្ហា ហេមន្តិកា** បានដល់ បទុមជាតិដែលរីកស្គុសស្គាយក្នុងគិម្ហរដូវ

និងហិមន្តរដូវ ។ បទថា **ជណ្ណុតគ្ឃា ឧបត្ថរា** សេចក្តីថា ផ្សាយទៅ បាន ដល់រីក គឺប្រាកដហាក់បីដូចតាំងនៅក្នុងទឹកប្រមាណត្រឹមជង្គង់ ។ បទថា **វិ-ចិត្រា បុប្ផសន្ថតា** សេចក្តីថា បទុមជាតិទាំងឡាយល្អវិចិត្រ បញ្ចេញផ្ការីក ស្គុសស្គាយជះក្លិនក្រអូបសព្វកាល ។

ម្នាលព្រាហ្មណ៍ មួយទៀតមានពួកដើមឈើ គឺក្តុម្ពប្រទៀងនិង រលួសផ្អុងមានផ្ការីកស្គុសស្គាយ ជុះក្បែរមាត់ទឹកមុចលិន្ទស្រះ ទុំ ។ មានទាំងដើមព្រូស ជន្ទូស ស្វាត ខ្លឹងមានផ្ការីកអមសងខាងមុចលិន្ទស្រះ ។ មានពួកជីរខ្មៅ ជីរស ឈូក ត្រាញ់ គណ្ឋីស គណ្ឋីខ្មៅ ធ្នង់បញ្ចេញផ្កាក្បែរមុចលិន្ទស្រះទុំ មាន ក្លិនក្រអូបបក់ផ្សាយទៅ ។ មានពួកដើមសុក្រំ ដកត ពពូល ថ្ម ម្រុំមានផ្ការីក ពួកដើមកេតកៈ កណិការ ច្បាទេសមាន ផ្ការីក ។ ពួកថ្វាន់ស ថ្វាន់ខ្មៅ ជន្ទាត់ដៃមានផ្ការីក មានត្រួយ រីកល្អ ជុះនៅប្រាលរន្ទាលដូចជាផ្កាចារ ។ ពួកដើមសត្បាស សត្បាខ្មៅ ដើមចេកមាស ដើមដកគាំ ( ព្រៃនោះរុងរឿង ) ដោយផ្កាទឹកដោះខ្លាទិនគន្ធាផង ដោយផ្កាធ្នង់និងទន្ធាផង ។ ដើមដកខិម រកា អំពៅព្រៃ អង្កាជី ក្រស្នា គ្រញូង កោដ្ឋស កោដ្ឋខ្មៅមានផ្ការីក ។ ព្រឹក្សា ( ទាំងនោះ ) ទោះខ្ចីស៊ីងមានដើម ដ៏ត្រង់ មានផ្ការីកក្បែរមុចលិន្ទស្រះទុំ ជុះនៅទាំងសងខាងអា-ស្រម ( ព័ន្ធព័ទ្ធ ) ជុំវិញរោងភ្លើង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **តិដ្ឋន្តិ** សេចក្ដីថា ព័ទ្ធជុំវិញស្រះ ។ បទថា **កកុដ្ឋា** បានដល់ ដើមកុដ្ឋ ។ បទថា **កច្ចិការា ច** បានដល់ ដើមឈើដែលមានឈ្មោះយ៉ាងនោះ ។ បទថា **ចារិជញ្ញា** បានដល់ ដើមឈើមានផ្កាក្រហម ។ បទថា **វារណា វុយ្ហជា** បានដល់ ដើមនាគព្រឹក្ស ( ខ្ទឹង ) ។ បទថា **មុចលិន្ទមុភតោ** បានដល់ សងខាងស្រះមុចលិន្ទ ។ បទថា **សេតចារិសា** បានដល់ រុក្ខជាតិដែលមានគុម្ពពណ៌ស ។ បានឮថា ដើមជីរសទាំងនោះមានដើមពណ៌សស្លឹកធំ មានផ្កាដូចគ្នានឹងផ្កាកណិការ ។ បទថា **និគ្គុណ្ឌី សរនិគ្គុណ្ឌី** បានដល់ ដើមគណ្ឌីសនិងដើមគណ្ឌីខ្មៅ ។ បទថា **បណ្ឌុរា** បានដល់ ដើមឈើពណ៌ស ។ បទថា **កុសុម្ភា** បានដល់ ឈើគុម្ពមួយប្រភេទ ។ បទថា **ធនុតក្ការិបុប្ផេហិ** សេចក្ដីថា ល្អដោយផ្កាទឹកដោះខ្លានិងផ្កាគន្ធាទាំងឡាយ។ បទថា **សីសចាវរណានិ ច** បានដល់ ស្រស់ល្អដោយដើមធ្នង់និងដើមទន្លាទាំងឡាយ ។ បទថា **អជ្ជុនា** ជាដើមក៏ជាឈ្មោះដើមឈើទាំងនោះ ។ បទថា **សេតគេរុតគរិកា** បានដល់ ដើមអង្គាដីនិងដើមក្រស្នា ។ បទថា **ចំសិកោដ្ឋកុលាវកា** បានដល់ ដើមគ្រញូង ដើមកោដ្ឋនិងដើមប្រស់ក្រអូប[១]។ បទថា **អកុដិលា** បានដល់ មានដើមត្រង់ ។ បទថា **អគ្យាគារំ សមន្តតោ** សេចក្ដីថា ដុះជុំវិញរោងភ្លើង ។

មួយទៀតមានទាំងស្លឹកគ្រៃ សណ្ដែកបាយ សណ្ដែករាជមាស

ជាច្រើន សារាយនិងកំពីងពួយជាច្រើន ដុះក្បែរមាត់ទឹកមុច-

---

១-បិដកខ្មែរជា កោដ្ឋខ្មៅ ។

លិន្ទស្រះនុ៎ះ ។ ( ទឹកនោះ ) មានច្រាំងជាទំនប់ ត្រូវខ្យល់បក់មករលកក៏ខ្វាយខ្វារឡើង មានពួកមេឃ្មុំយំដោយសំឡេងដ៏ពីរោះ ហើរត្រៀលច្ចាត់គុម្ពឈើមានមូក្នុំ ស្វាស្នាប់ ស្វាជំក្នុងទីទំនាបទៀបមុចលិន្ទស្រះនោះ មានត្រកួនជាច្រើន ។ ម្នាលព្រាហ្មណ៍ ពួកព្រឹក្សាសឹងដ៏ដេរដាសដោយពួកវល្លិឈ្មោះឯឡម្ពកៈដុះនៅ ក្លិនរបស់ផ្កានៃវល្លិទាំងនោះដែលគេទ្រទ្រង់អស់ ៧ ថ្ងៃមិនទាន់បាត់ក្រអូបឡើយ ។ ពួកផ្កាដុះនៅក្នុងចំណែកទាំងពីរនៃមុចលិន្ទស្រះ ព្រៃនោះដ៏ដេរដាសដោយពួកផ្កាលំចង់ដ៏រុងរឿង ក្លិនរបស់ផ្កាទាំងនោះដែលគេទ្រទ្រង់អស់កន្លះខែក៏មិនទាន់បាត់ក្រអូបឡើយ ។ រីឯអញ្ចាញខៀវ អញ្ចាញស អញ្ចាញលឿងមានផ្ការីកស្គុសស្គាយ ព្រៃនោះដ៏ដេរដាសដោយម្ទិះរូតម្ទិះលា ។ រីឯព្រៃនោះដូចជា ( ញុំាងជនដែលមកដល់ ) ឲ្យរីករាយដោយក្លិនផង ដោយមែកមានផ្កាទាំងឡាយផង ឯពួកកន្ទន់មានស្បូវសេពទ្រហឹងអឹងកងជុំវិញ ព្រោះក្លិនផ្កា ។ ម្នាលព្រាហ្មណ៍ ក្នុងមុចលិន្ទស្រះនោះមានពួកត្រឡាចបីមុខ គឺមួយពួកផ្លែប៉ុនក្អម ពីរពួកទៀតផ្លែប៉ុនសម្ភោរ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ជលជិជ្ជកា** បានដល់ តិណជាតិដែលកើតឯង ។ បទថា **មុគ្គតិយោ** បានដល់ សណ្ដែកបាយមួយប្រភេទ ។ បទថា **ការតិយោ** បានដល់ សណ្ដែកកជមាស ។ បទថា **សេវាលំ សីសកំ** បាន

ដល់ ដើមឈើទាំងនេះជាឈើគុម្ពនោះឯង ។ ម្យ៉ាងទៀត បទថា **សីសកំ** លោកពោលថាជាចន្ទន៍ក្រហម ។ បទថា **ឧទ្ធាបវត្តំ ឧល្លុង្ឃិតំ** សេចក្ដីថា ទឹកនោះខ្យល់បក់រលកឡើងដល់មាត់ច្រាំង ។ បទថា **មក្ខិកា ហិង្គុជាលិកា** សេចក្ដីថា មេឃ្មុំ ៥ ប្រភេទត្រង់គុម្ពផ្កាដែលរីកដែលហៅថាហិង្គុជាល តែងហើរក្រឡឹងយំដោយសំឡេងដ៏ពីរោះក្នុងស្រះនោះ ។ បទថា **ធាសិមកញ្ញ-កោ ចេត្ថ** សេចក្ដីថា រុក្ខជាតិ ២ យ៉ាងនេះក៏មានក្នុងស្រះនោះ ។ បទថា **នីចេ កលម្ពកា** បានដល់ ដើមត្រកួនមានខាងក្រោម ។ បទថា **ឯលម្ពុរ-កសញ្ឆន្នា** សេចក្ដីថា ដែលវល្លិមានឈ្មោះយ៉ាងនេះគ្របដណ្ដប់ ។ បទថា **តេសំ** បានដល់ ផ្កាទាំងនោះនៃវល្លិនោះ ក្លិនរបស់ផ្កាស្រលិតជាដើមរមែងក្រអូបអស់ ៧ ថ្ងៃ ផ្កាទាំងឡាយសម្បូរដោយក្លិនក្រអូប ត្រង់ភូមិភាគដែលពេញទៅដោយខ្សាច់ដូចគ្នានឹងកម្រាលប្រាក់ ។ បទថា **គន្ធោ តេសំ** សេចក្ដីថា ក្លិននៃផ្ការាជព្រឹក្សជាដើមនោះក្រអូបបានកន្លះខែ ។ បទថា **នីលបុប្ផិ** ជាដើម បានដល់ វល្លិមានផ្កា ។ បទថា **តុលសីហិ ច** បានដល់ និងដោយគុម្ព ។ បទថា **កណ្ណារុជាតាធិ** សេចក្ដីថា ផ្លែរបស់វល្លិទាំងឡាយ ( ៣ ប្រភេទ ) ។ វល្លិទាំងនោះវល្លិមួយប្រភេទមានផ្លែប៉ុនក្អមធំ ២ ប្រភេទទៀតផ្លែប៉ុនស្គរសម្ភោរ ព្រោះហេតុនោះទើបលោកពោលទុកថា ម្យ៉ាងទៀតវល្លិ ២ ប្រភេទមានផ្លែប៉ុនស្គរសម្ភោរ ។

មួយទៀតមានស្ពៃដ៏ច្រើននិងវីមស លាយដោយវីមក្រហម
ជាច្រើន ដើមរកាទាំងឡាយដុះនៅដូចជាដើមត្នោត មានទាំង

ពួកលំចង់ដ៏ច្រើនដែលគេគប្បីក្តិច ដុះនៅក្បែរមុចលិន្ទស្រះនុ៎ះ ។ មានវល្លិម្ទិះរួត ម្ទិះលា ក្ទាំពាក់ ឈើឯម ពួកអសោកព្រឹក្សនិង ដើមទៀនព្រៃ ល្ពៅ វល្លិផ្កាថ្ទាំង ។ ស្មៅកន្ទុយដំរី នននោងព្រៃ ដើមខ្ទឹម ដើមម្ទិះសឹងដ៏មានផ្ការីកស្គុសស្គាយ វល្លិចារមានផ្កា រីកដុះព័ទ្ធព័ន្ធដើមឈើ ។ ពួកឈើនាងនួន មៀនព្រៃ យុថ្កា មានក្លិនដូចជាទឹកឃ្មុំ ម្ទិះវល្លិ ម្ទិះប្រក្រតី ច្បា បទុមុត្តព្រឹក្ស សឹងដ៏រុងរឿងល្អ ។ ពួកប្រទៀង កប្បាសសមុទ្ទ កណិការសឹង ដ៏មានផ្ការីកស្គុសស្គាយប្រាកដដូចជាបណ្តាញមាស សឹងដ៏រុង រឿងល្អដូចជាអណ្តាតភ្លើង ។ ពួកផ្កាណាកើតលើគោកនិងកើត ក្នុងទឹក ពួកផ្កាទាំងអស់នោះប្រាកដក្នុងមុចលិន្ទស្រះនោះ មុច-លិន្ទស្រះទ្រទ្រង់ទឹកច្រើនគួរឲ្យត្រេកអរយ៉ាងនេះឯង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សាសនោ** បានដល់ ស្តែទាំងឡាយ ។ បទថា **ពហុកោ** ប្រែថា ច្រើន ។ បទថា **ឆាធិយោ ហរិតាយុតោ** សេចក្តីថា ខ្ទឹមប្រកបដោយស្លឹកខៀវ ធម្មជាតិខ្ទឹមទាំងនេះមាន ២ ប្រភេទ សូម្បី ខ្ទឹមនោះមានច្រើនត្រង់ស្រះនោះ ។ បទថា **អសី តាលាវ តិដ្ឋន្តិ** សេចក្តីថា ដើមឈើមានឈ្មោះថា ដើមរកាយ៉ាងនេះប្រាកដក្នុងភូមិភាគដែលរាបស្មើតាំង នៅដូចដើមត្នោត ។ បទថា **ឆេជ្ជា ឥន្ទវារា ពហូ** សេចក្តីថា ត្រង់មាត់ទឹក ដែលមានដើមលំចង់ជាច្រើនល្មមក្តិចបានដោយដៃ ។ បទថា **អច្ឆោជា** បាន ដល់ វល្លិម្ទិះរួត ។ បទថា **វល្លិភោ ខុទ្ទបុប្ផិយោ** បានដល់ ម្ទិះលានិងក្ទាំ-

ពាក់ ។ បទថា **នាគមល្លិកា** បានដល់ ដើមខ្ទឹងនិងដើមម្លិះរួត ។ បទថា **កឹសុករល្លិយោ** បានដល់ ធម្មជាតិវល្លិដែលមានក្លិនក្រអូបជាប្រមាណ ។ បទថា **កដេរុហា បវាសេន្តិ** បានដល់ ទាំង ២ យ៉ាងនេះជាឈើគុម្ពសម្បូរដោយផ្កា ។ បទថា **មធុគន្ធិយា** បានដល់ មានក្លិនដូចទឹកឃ្មុំ ។ បទថា **និលិយា សុមនា ភណ្ឌី** បានដល់ ម្លិះលា ម្លិះប្រក្រតីនិងដើមច្បា ។ បទថា **បទុមុត្តរោ** បានដល់ ដើមឈើមួយប្រភេទ ។ បទថា **កណិការា ច** បានដល់ ដើមកណិការខ្លះ វល្លិកណិការខ្លះ ។ បទថា **ហេមជាលាវ** សេចក្ដីថា ប្រាកដដូចបណ្ដាញមាសដែលពាសទុក ។ បទថា **មហោទធិ** បានដល់ ស្រះមុចលិន្ទដក់ទឹកបានច្រើន ។

មួយទៀតក្នុងស្រះបោក្ខរណីនោះ មានពួកសត្វដែលត្រាច់ទៅក្នុងទឹកជាច្រើន គឺត្រីឆ្ពិន ត្រីរ៉ស់ ត្រីអណ្ដែង ក្រពើ មករ ឆ្លាម ។ មានទាំងផ្ចិតឃ្មុំ ឈើឯម ឆ្នាំពូ ប្រយង្គ ស្មៅក្រវាញ ជ្រូក ស្មៅមាត់ក្អែក ដើមសត្តបុស្ស សម្បុរល្វែង ។ ដើមពុំសែន ដើមឫសសាមសិប ក្រស្នា វល្លិជណ្ដើរស្វា ឈូកត្រាញ់ ក្រវាន់ កោដ្ឋ ព្រហូត បាយម៉ាត ។ ពួករមៀត ហរតានយ៉ាងណា ហិរិវេរព្រឹក្ស គ្រើល សម៉ពិភេទក៍ ប្រោះ កប្បូរ វង្គក្រហម ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អចស្សា បោក្ខរណិយា** សេចក្ដីថា អច្ចុតឥសីហៅស្រះនោះថា បោក្ខរណីក្នុងទីនេះ ព្រោះដូចគ្មានទឹងស្រះបោក្ខរណី ។

*បទថា* **រោហិតា** *ជាដើម ជាឈ្មោះនៃសត្វដែលរកស៊ីក្នុងទឹកទាំងនោះ ។ បទថា* **មធុ** **ច** *បានដល់ ឃ្មុំដែលមិនមានមេ ។ បទថា* **មធុលដ្ឋិ** **ច** *បានដល់ វល្លិឈើឯម ។ បទថា* **តាលិសា** *ជាដើម ទាំងអស់នេះជាឈើមានក្លិនក្រអូបតាមធម្មជាតិ ។*

*មួយទៀតក្បែរស្រះបោក្ខរណីនោះ មានពួករាជសីហ៍ ខ្លាធំ យក្ខិនី មានមុខដូចជាមុខមេសេះ ដំរី ទ្រាយ ស្វាន រមាំងសរកម្រឹគ ។ ហ្វូងចចក ទន្សាយ ធ្នាបា ឆ្កែព្រៃ មានសម្បុរដូចជាផ្កាបបុស ចាមរី ទោច ឈ្លូស ស្វាព្រាម ស្វាក្រិសស្វាខោល ។ ទន្សោង ខ្ទីង ខ្លាឃ្មុំ គោព្រៃជាច្រើន ហ្វូងរមាសជ្រូកព្រៃ ស្កា កន្ធែនដោយច្រើនក្បែរមុច្ចលិន្ទស្រះនុ៎ះ ។ មានទាំងហ្វូងក្របី ឆ្កែព្រៃ ចចក មានស្នាប់ឫស្សីធំព័ន្ធព័ទ្ធជុំវិញអាស្រមបទ ទន្សង បចលាកម្រឹគ វិចិត្តម្រឹគ ខ្លាដំបង ។ ហ្វូងទន្សាយ ត្មាត កេសរសីហៈ កោកនិសាតកម្រឹគ សរភៈក្ងោក ក្ងាន អាអូតភ្លើង ។ ពួកមាន់ទឹក មាន់ព្រៃ ដំរីស្រែកយំឆ្លើយឆ្លងរកគ្នាទៅវិញទៅមក ពួកកុកសាប់ កុកក្រែកប៉ោលតោក ត្រដេវវិច ក្រៀល រនាល ។ ពួកខ្វែង ប្រមង់ចង្កៀលខ្យង ចាបស្រុក ចចាត ទទា ខ្វែក អាអូត ។ ពួកចចាតធំ ប្រទ្បែ ក្រួច ទទា ចាបស្រុក ចាបព្រៃ សាលិកា-កែវគោ គ្រលីងគ្រលោង ។ ពួកករវិកផង ត្រចៀកកាំផង*

មៀមផង អកផង ( មុចលិន្ទស្រះនោះ ) កុះករដោយហ្វូងបក្សី ផ្សេងៗ ជាទីទ្រហឹងអឺងកងដោយសំឡេងផ្សេងៗ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឃុំសាលូ** បានដល់ យក្ខិនីមានមុខដូចសេះ ។ បទថា **រោហិតា សរភា មិគា** បានដល់ ស្វាន រមាំងនិងសរកម្រឹគ ។ បទថា **កោដ្ឋសុណា** បានដល់ ឆ្កែចចក ។ បាឋៈថា **កោដ្ឋសោណា** ក៏មាន ។ បទថា **សុណោបិ ច** បានដល់ ម្រឹគជាតិតូចៗដែលឈ្មោសវាំងវែមួយប្រភេទ ។ បទថា **តុលិយា** បានដល់ សត្វឆ្មាបា ។ បទថា **ឆឡសន្និភា** បានដល់ ឆ្កែព្រៃមានពណ៌ដូចផ្កាបបុស ។ បទថា **ចាមរី ចលនី លង្ឃី** បានដល់ ចាមរីទោចនិងឈ្លូស ។ បទថា **ឈាបិតា មកដា** បានដល់ ស្វាធំ ២ ប្រភេទនោះឯង ។ បទថា **បិចុ** បានដល់ ស្វាញីមួយប្រភេទរកស៊ីតាមមាត់ស្រះ ។ បទថា **កក្កដា កតមាយា ច** បានដល់ ម្រឹគធំ ២ ប្រភេទ ។ បទថា **ឥក្កា** បានដល់ ខ្លាឃ្មុំ ។ បទថា **គោណសិរា** បានដល់ គោព្រៃ ។ បទថា **កាឡកេត្តពហុតសោ** សេចក្តីថា ឈ្មោះថាកាឡម្រឹគមានច្រើនក្នុងស្រះនោះ ។ បទថា **សោណា សិង្គាលា** បានដល់ ឆ្កែព្រៃនិងចចក ។ បទថា **បម្បកា** បានដល់ ពួកស្វាដែលអាស្រ័យលើគុម្ពឫស្សីធំតាំងនៅជុំវិញអាស្រម ។ បទថា **អាកុច្ឆា** បានដល់ សត្វទន្សង ។ បទថា **បចលាកា** បានដល់ ម្រឹគមានក្បាលដូចដំរី ( គជសីហ: ) ។ បទថា **ចិត្រកា ចាបិ ឌីបិយោ** បានដល់ វិចិត្រម្រឹគនិងខ្លាដំបង ។ បទថា **បេលកា ច** បានដល់ ទន្សាយ ។ បទថា **វិឃាសាទា** បានដល់ សត្វត្មាតទាំងនោះ ។ បទថា **សីហា** បានដល់ កេសរ-

សីហៈ ។ បទថា **កោកនិសាទកា** បានដល់ ម្រឹគសាហាវដែលមានប្រក្រតីចាប់ឆ្កែព្រៃស៊ី ។ បទថា **អដ្ឋចាធា** បានដល់ សត្វសរភៈ ។ បទថា **ភស្សរា** បានដល់ ហង្សស ។ បទថា **កុកុត្ថកា** បានដល់ អាអូតក្ងើង ។ បទថា **ចង្កោរា** បានដល់ មាន់ទឹក ។ បទថា **កុក្កុដា** បានដល់ មានព្រៃ ។ បទថា **ធិង្គិភា កោញ្ចវាធិកា** បានដល់ ពួកសត្វទាំង ៣ ប្រភេទនេះឯង ។ បទថា **ព្យគ្ឃិនសា** បានដល់ សត្វខ្លែង ។ បទថា **លោហបិដ្ឋា** បានដល់ បក្សីដែលមានពណ៌ក្រហម ។ បទថា **ចប្បកា** បានដល់ សត្វប៉ោលតោក ។ បទថា **កបិញ្ជរា តិត្តិរាយោ** បានដល់ សត្វចចាតនិងសត្វទទា ។ បទថា **កុលាវា បដិកុដ្ឋកា** បានដល់ បក្សីទាំងឡាយ ២ ប្រភេទនេះ ។ បទថា **មណ្ឌាលកា ចេលកេឌុ** បានដល់ ចចាតជំនិងប្រឡៃ ។ បទថា **ភណ្ឌុតិត្តិរនាមកា** បានដល់ សត្វក្រួច ទទា ចាបស្រុកនិងចាបព្រៃ ។ បទថា **ចេលាវកា បិង្គុលាយោ** បានដល់ សកុណជាតិ ២ ប្រភេទគឺសាលិកាកែវគោគ្រលីងគ្រលោង សត្វ ២ ប្រភេទនេះជាសត្វដូចគ្នា ។ បទថា **សគ្គា** បានដល់ សត្វត្រចៀកកាំ ។ បទថា **ឧហុង្ការា** បានដល់ សត្វមៀម ។

មួយទៀតក្បែរមុចលិន្ទស្រះនុ៎ះមានសត្វស្លាបទាំងឡាយ គឺពួកសាលិកាកែវមានសំឡេងពីរោះ ស្រែកយំឆ្លើយឆ្លងរកគ្នាទៅវិញទៅមក រីករាយជាមួយនឹងញី ( របស់ខ្លួន ) ។ មួយទៀតក្បែរមុចលិន្ទស្រះនុ៎ះមានពួកសត្វស្លាបកើតពីរដង មានសំឡេងពីរោះ មានវង្វង់ភ្នែកស មានភ្នែកល្អ កើតក្នុងពង មានស្លាប

ដ៏វិចិត្រ ។ មួយទៀតក្បែរមុចលិន្ទស្រះនុ៎ះមានពួកបក្សី មាន សំឡេងពីរោះ គឺក្ងោកមានកខៀវស្រែកយំឆ្លើយឆ្លងគ្នាទៅវិញ ទៅមក ។ អាអូតភ្លើង មាន់ព្រៃ កោដ្ឋបក្សី ពញ្ញាក់ ត្រចៀកកាំសមុទ្ទ ខ្វែងជ្រក បក្សីប្រវឹក សេកនិងសាលិកា ។ មួយទៀតក្បែរមុចលិន្ទស្រះនុ៎ះ មានពួកហង្សច្រើនមានសម្បុរលឿង ក្រហម ស សត្វហត្ថិលិង្គ សម្បកត្រពាំង ប្រវឹក សេកនិង តាវៅ ។ ពួកអន្កត់ខ្មៅ អន្កត់ស ហង្ស រអាត ខ្វែងស្រាក ចាកហង្ស កុកគ្រោង ប៉ោលតោក ចាបស្រុក ។ ហ្វូងព្រាប គ្រលែងវែក ចាក្រពាក ក្អែកទឹក វារណបក្សីមានសំឡេងគួរ ឲ្យត្រេកអរ ស្រែកយំហៅគ្នាក្នុងកាលទាំងពីរ គឺព្រឹកល្ងាច មួយទៀតក្បែរមុចលិន្ទស្រះនុ៎ះ មានពួកសត្វស្លាបកើតពីរជង មានសម្បុរផ្សេងៗជាច្រើន ស្រែកយំឆ្លើយឆ្លងគ្នាទៅវិញទៅ មក រីករាយជាមួយនឹងញី ។ មួយទៀតក្បែរមុចលិន្ទស្រះនុ៎ះ មានពួកសត្វស្លាបមានកំណើតពីរជង មានសម្បុរផ្សេងៗ ជាច្រើន សុទ្ធតែមានសំឡេងពីរោះស្រែកស័ព្ទស៊ានត្រង់ឆ្នេរទាំងសងខាងមុចលិន្ទស្រះ ។ មួយទៀតក្បែរមុចលិន្ទស្រះនុ៎ះ មាន ពួកករវិក សត្វទាំងនោះមានកំណើតពីរជង រមែងស្រែកហៅ គ្នារីករាយជាមួយនឹងញី ។ មួយទៀតក្បែរមុចលិន្ទស្រះនុ៎ះមាន ពួកករវិក សត្វទាំងនោះមានកំណើតពីរជង សុទ្ធតែមាន

សំឡេងដ៏ពីរោះស្រែកសព្ទសោនត្រង់ឆ្នេរ ទាំងសងខាងមុចលិន្ទស្រះ ។ ព្រៃ ( ជិតស្រះបោក្ខរណីនោះ ) ដែលពួកដំរីអាស្រ័យនៅហើយសឹងដ៏កុះករដោយទ្រាយ ស្វាន ទាំងជេរជាសដោយពួកវល្លិផ្សេង ៗ ដែលពួកសត្វឈ្មុសអាស្រ័យនៅហើយ ។ មួយយ៉ាងទៀតក្បែរមុចលិន្ទស្រះនុ៎ះ មានស្រងែច្រើន ស្ពួយច្រើន ពោតច្រើន ស្រូវសាលីដុះឯងមិនបាច់មានអ្នកណាភ្ជួររាស់ដាំឡើយទាំងអំពៅសោតក៏មានច្រើនដុះក្បែរមុចលិន្ទស្រះនុ៎ះ ។ ផ្លូវដើរនេះចុះតែដើងមួយ បុគ្គលដើរទៅត្រង់អាស្រមដល់ទៅទីនោះហើយក៏មិនបានសម្រេកគម្លាននិងសេចក្តីអផ្សុកឡើយ ។ ជាអាស្រមដែលព្រះបាទវេស្សន្តរគង់នៅព្រមទាំងព្រះរាជបុត្តនិងព្រះរាជទេពី ព្រះអង្គទ្រទ្រង់ភេទបព្វជិតដ៏ប្រសើរមានតម្ពក់និងវែក សម្រាប់បូជាភ្លើងនិងសក់កណ្តាញ់ ទ្រង់ស្បែកខ្លា ផ្ទំផ្ទាល់ផែនដី នមស្ការភ្លើង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឆីលកា** បានដល់ មានរោមស្វាបវិចិត្រល្អ ។ បទថា **មញ្ជុស្សរាសិតា** បានដល់ មានសំឡេងពីរោះជានិច្ច ។ បទថា **សេតក្កិក្កជា ភទ្រក្ខា** សេចក្តីថា មានក្អែកស្អាត ប្រកបដោយវង្វង់ក្អែកសទាំងសងខាង ។ បទថា **ចិត្របេក្ខុណា** បានដល់ មានរោមស្វាបដ៏វិចិត្រ ។ បទថា **កុឡីរកា** បានដល់ អាអូតភ្លើង ។ បទថា **កោដ្ឋា** ជាដើម ជាពួកសកុណជាតិ ។ បទថា **វារណា** បានដល់ សត្វហត្ថីលិង្គ ។ បទថា **ក-**

**ឧម្មា** លោកកំណត់យកសត្វសេកធំ[១] ។ បទថា **សុវកោកិលា** បានដល់ សត្វសេកដែលត្រាច់ទៅជាមួយសត្វតាវ៉ៅនិងសត្វតាវ៉ៅទាំងឡាយ ។ បទថា **កុក្កុសា** បានដល់ សត្វអកខ្មៅ ។ បទថា **កុរុរា** បានដល់ សត្វអកស ។ បទថា **ហំសា** បានដល់ ហង្សស ។ បទថា **អាដា** បានដល់ បក្សីដែលមានចំពុះដូចវែក ។ បទថា **បរិវទេន្តិកា** បានដល់ សកុណជាតិមួយប្រភេទ ។ បទថា **វារណាភិរុទា រម្មា** បានដល់ សត្វហត្ថីលិង្គយំគួរត្រេកអរ ។ បទថា **ឧភោ កាលុបកូជិនោ** សេចក្តីថា សំឡេងយំគឹកកងតែមួយពេញជើងភ្នំទាំងល្ងាចព្រឹក ។ បទថា **ឃណោយ្យបសទាកិណ្ណំ** សេចក្តីថា ដេរដាសទៅដោយទ្រាយ ប្រើស[២]និងឈ្លូសទាំងឡាយ ។ បទថា **តត្ថ បត្តោ ន រិន្ទតិ** សេចក្តីថា ម្នាលព្រាហ្មណ៍ បុគ្គលដែលទៅដល់អាស្រមរបស់ព្រះវេស្សន្តរហើយ នឹងមិនបានទូវការស្រេកឃ្លាន ឬការមិនពេញចិត្តក្នុងអាស្រមនោះ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូត្រសាទូវព្រះគាថាដូច្នេះថា

ជូជកជាផៅពង្សនៃព្រហ្ម ឮពាក្យនេះហើយ ក៏ធ្វើប្រទក្សិណឥសី មានចិត្តត្រេកអរក៏ដើរចេញទៅសំដៅទៅអាស្រមដែលព្រះបាទវេស្សន្តរគង់នៅ ដូច្នេះ ។

---

១-បិដកខ្មែរជាសត្វប្រវឹក ។

២-បិដកខ្មែរជាស្វាន ។

បណ្ដាបទទាំងនោះ បទថា **វេស្សន្តរោ អហុ** សេចក្ដីថា ព្រះវេស្សន្តរ នៅក្នុងទីណា ជូជកក៏ទៅកាន់ទីនោះ ។

## មហាវនកណ្ឌ ចប់

# ធារកបព្វៈ

ចំណែកជូជកទៅដល់ស្រះបោក្ខរណី តាមផ្លូវដែលអច្ចុតតាបសប្រាប់គិតថា ថ្ងៃនេះល្ងាចជ្រុលទៅហើយ ឥឡូវនេះព្រះនាងមទ្រីក៏យាងត្រឡប់មកអំពីព្រៃ ឈ្មោះថា មនុស្សស្រីរមែងធ្វើអន្តរាយដល់ទាន ស្អែកនេះគ្រាព្រះនាងយាងទៅព្រៃ សឹមអញទៅកាន់អាស្រមបទគាល់ព្រះវេស្សន្តររាជឥសី ទូលសូមកុមារកុមារីទាំង ២ កាលព្រះនាងមិនទាន់យាងត្រឡប់និងនាំកុមារកុមារីទាំងនោះចៀសចេញទៅ ទើបឡើងកាន់ទីទួលមួយកន្លែង មិនឆ្ងាយអំពីស្រះនោះដេកក្នុងទីដែលជាផាសុក ។

រាត្រីទៀបភ្លឺព្រះនាងមទ្រីបានសុបិន សេចក្ដីក្នុងសុបិននោះថា មានបុរសម្នាក់ស្បែកខ្មៅ ស្លៀកសំពត់កាសាវៈ ២ ផ្ទាំង សៀតផ្កាពណ៌ក្រហមត្រង់ត្រចៀក កាន់អាវុធចូលមកកាន់បណ្ណសាលាចាប់ជដារបស់ព្រះនាងទាញមកឲ្យព្រះនាងដួលផ្ងារលើផែនដី ខ្វេះភ្នែកទាំង ២ កាត់នូវដើមដៃទាំង ២ របស់ព្រះនាងដែលកំពុងយំ ពុះទ្រូងកាន់យកបេះដូងដែលមានតំណក់ឈាមកំពុងហូរហើយចេញទៅ ។ ព្រះនាងមទ្រីភ្ញាក់ឡើងមានព្រះហឫទ័យតក់ស្លុត ព្រះនាងត្រិះរិះថា អញយល់សប្តិអាក្រក់ បុគ្គលដែលព្យាករយល់សប្តិដូចគ្នានឹងព្រះវេស្សន្តរមិនមាន អញនឹងទូលសួរព្រះអង្គ ព្រះនាងគិតដូច្នេះហើយយាងទៅគោះទ្វារបណ្ណសាលារបស់មហាសត្វ ។

លំដាប់នោះព្រះមហាសត្វស្ដាប់សំឡេងគោះទ្វារនោះ ទើបត្រាស់សួរថា នុ៎ះជានរណា ព្រះនាងទូលស្នងថា ខ្ញុំម្ចាស់ គឺមទ្រី ព្រះវេស្សន្តរត្រាស់ថា

នាងទម្លាយកតិកាវត្តរបស់យើងទាំង ២ ចោលហើយ ព្រោះហេតុអ្វីក៏មកក្នុងកាលដែលមិនគួរ ព្រះនាងមទ្រីក្រាបទូលថា បពិត្រព្រះសម្មតិទេព ខ្ញុំម្ចាស់មិនមែនមកគាល់ដោយអំណាចកិលេសឡើយតែខ្ញុំម្ចាស់យល់សប្តិអាក្រក់ ។ ព្រះវេស្សន្តរត្រាស់ថា បើដូច្នោះ ចូរនាងនិយាយមកចុះ ។ ព្រះនាងមទ្រីក៏តំណាលថ្វាយតាមទំនងដែលនាងសុបិននោះឯង ។ ព្រះមហាសត្វទ្រង់កំណត់ព្រះសុបិននោះហើយ ទ្រង់ត្រិះរិះថា ទានបារមីរបស់អញនឹងគ្រប់បរិបូណ៌ព្រឹកនេះនឹងមានយាចកមកសូមបុត្តទាំងទ្វេ អញនឹងញុំាំងនាងមទ្រីឲ្យធូរចិត្តហើយសឹមឲ្យត្រឡប់ទៅ ទ្រង់ព្រះតម្រិះដូច្នេះហើយត្រាស់ថា នែមទ្រី ចិត្តរបស់នាងសៅហ្មងព្រោះផ្ទំមិនល្អ សោយមិនល្អ នាងកុំភ័យខ្លាចឡើយហើយត្រាស់លួងលោមយកចិត្តឲ្យព្រះនាងកក់ក្តៅហើយក៏បញ្ជូនទៅ ។

លុះរាត្រីអស់ហើយ ព្រះនាងមទ្រីធ្វើកិច្ចដែលគួរធ្វើទាំងពួង ហើយឱបព្រះរាជឱរសព្រះរាជធីតា ថើបត្រង់ក្បាលហើយប្រទានឱវាទថា នែបាជាលីនិងនាងកណ្ហាជិនា ថ្ងៃនេះម៉ែយល់សប្តិអាក្រក់ឯងទាំង ២ កុំបីប្រមាទឡើយហើយយាងទៅគាល់ព្រះមហាសត្វផ្ញើព្រះរាជឱរសនិងព្រះរាជធីតាដោយពាក្យថា សូមទ្រង់កុំប្រហែសធ្វេសក្នុងទារកទាំង ២ ឡើយ ហើយកាន់យកល្អីនិងចបជីកជាដើម ជូតទឹកភ្នែកចូលទៅកាន់ព្រៃដើម្បីបេះផ្លែឈើតូចធំ ។

ឯជូជកគិតថា ឥឡូវនេះព្រះនាងមទ្រីចេញទៅព្រៃហើយ ចុះអំពីទួលបែរមុខទៅកាន់អាស្រមដើរតាមផ្លូវដែលចុះមនុស្សតែម្នាក់ ។ លំដាប់នោះមហាសត្វចេញពីបណ្ណសាលា ប្រថាប់គង់ដូចបដិមាមាសតាំងនៅលើផ្ទាំងថ្ម ទ្រង់

គិតថា ឥឡូវនេះយាចកនឹងមក ក៏ប្រថាប់ចាំមើលការមករបស់យាចកនោះ ដូចអ្នកលេងសុរាចង់ផឹកស្រាដូច្នោះ ។ ព្រះរាជឱរស ព្រះរាជធីតាលេងនៅទៀបបាទមូលនៃព្រះរាជបិតា ។ ព្រះពោធិសត្វចាំមើលការមក ក៏ទតឃើញជូជកព្រាហ្មណ៍មក ទ្រង់ហាក់ដូចលើកទានធុរៈដែលបោះបង់មកអស់ ៧ ខែ ទើបត្រាស់ថា នែព្រាហ្មណ៍ អ្នកចូរមកចុះ ទ្រង់សោមនស្សកាលត្រាស់ហៅជាលីរាជកុមារទើបត្រាស់គាថានេះថា

ហៃបាជាលី អ្នកចូរក្រោកឈរឡើង ( ដំណើរមករបស់ស្មូម )
ប្រាកដដូចជាដំណើរមកអំពីមុនៗ បិតាមើលទៅឃើញដូចជា
ព្រាហ្មណ៍ សេចក្តីរីករាយក៏មកស្រោចស្រពលើបិតា ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ចោរាណំ វិយ ទិស្សតិ** សេចក្តីថា ការមករបស់យាចកក្នុងថ្ងៃនេះ ប្រាកដដូចការមករបស់យាចកទាំងឡាយ អំពីទិសផ្សេងៗក្នុងជេតុត្តរនគរក្នុងកាលមុន ។ បទថា **នន្ទិយោ មាភិកីររេ** សេចក្តីថា ចាប់តាំងពីកាលដែលយើងឃើញព្រាហ្មណ៍នេះ សោមនស្សប្រាកដឡើងគ្របដណ្តប់យើង ដូចស្រោចទឹក ១០០០ ក្អម លើសីសៈរបស់បុគ្គលដែលត្រូវកម្តៅថ្ងៃក្នុងរដូវក្តៅ ។

ជាលីរាជកុមារបានស្តាប់ព្រះបិតាត្រាស់ដូច្នោះ ក៏ក្រាបទូលថា

បពិត្រព្រះវរបិតា ខ្ញុំមិលមើលទៅ ឃើញប្រាកដ ដូចជា
ព្រាហ្មណ៍ ដូចជាមានអ្នកដំណើរមក នឹងជាភ្ញៀវរបស់យើង
ដូច្នេះ ។

កាលក្រាបទូលដូច្នោះហើយ បានធ្វើសេចក្ដីគោរពព្រះមហាសត្វ ក្រោកទៅទទួលជូជកព្រាហ្មណ៍ត្រាស់សួរដល់ការជួយទទួលគ្រឿងបរិក្ខារជាដើម ។ ជូជកព្រាហ្មណ៍ឃើញជាលីរាជកុមារគិតថា ក្មេងនេះពិតជាជាលីរាជកុមារព្រះរាជឱរសរបស់ព្រះវេស្សន្តរ អញនឹងពោលផរុសវាចាដល់វាតាំងពីដំបូងឲ្យហើយ គិតដូច្នេះហើយក៏យកដៃចង្អុលឲ្យដឹងថា ថយចេញ ថយចេញដូច្នេះ ជាលីកុមារចៀសចេញទៅគិតថា តាព្រាហ្មណ៍នេះ គ្រោតគ្រាតពន់ពេក ទតសរីរៈរបស់ជូជក ឃើញទោសរបស់បុរស ១៨ ប្រការ ឯជូជកព្រាហ្មណ៍កាលចូលទៅគាល់ព្រះពោធិសត្វ ដើម្បីធ្វើបដិសណ្ឋារៈក៏ទូលថា

ព្រះអង្គបានសេចក្ដីសុខសប្បាយទេឬ ព្រះអង្គមិនមានរោគាពាធទេឬ ព្រះអង្គចិញ្ចឹមជីវិតដោយការស្វែងរក ( ស្រួល ) ទេឬ មើមឈើនិងផ្លែឈើមានច្រើនឬ ។ ពួករបោម មូស ពស់មានតិចទេឬ ក្នុងព្រៃដ៏កុះករដោយម្រឹគយង់ឃ្នងមិនមានការបៀតបៀនព្រះអង្គទេឬ ដូច្នេះ ។

ចំណែកព្រះពោធិសត្វកាលទ្រង់ធ្វើបដិសណ្ឋារៈជាមួយជូជកនោះក៏ត្រាស់ថា

ម្នាលព្រាហ្មណ៍ យើងបានសេចក្ដីសុខសប្បាយទេ ម្នាលព្រាហ្មណ៍ មួយទៀតយើងមិនមានរោគាពាធទេ យើងចិញ្ចឹមជីវិតដោយការស្វែងរកស្រួលទេ ទាំងមើមឈើ និងផ្លែឈើក៏មានច្រើនដែរ ។ មួយវិញទៀតពួករបោម មូស ពស់ក៏មានតិចទេ

ក្នុងព្រៃដ៏កុះករដោយម្រឹគយង់ឃ្នង មិនមានការបៀតបៀនយើង
ទេ ។ យើងនៅក្នុងព្រៃអស់ ៧ ខែហើយរស់នៅទាំងទុក្ខសោក
ទើបតែនឹងបានឃើញព្រាហ្មណ៍ឯងជាដំបូង មានភេទដ៏ប្រសើរ
កាន់ឈើច្រត់មានសម្បុរដូចផ្លែញ្ញៅទុំ មានវែកសម្រាប់បូជាភ្លើង
និងកុណ្ឌី ។ ហៃមហាព្រាហ្មណ៍ អ្នកមកល្អហើយ មួយទៀត
អ្នកមិនមែនមកអាក្រក់ទេ អ្នកចូរចូលមកខាងក្នុង សេចក្តី
ចម្រើន ( ចូរមាន ) ដល់អ្នក អ្នកចូរលាងជើងរបស់អ្នក ។
ម្នាលព្រាហ្មណ៍ អ្នកចូរបរិភោគផ្លែឈើ ដ៏ឆ្ងាញ់ពីសាដូចទឹក
ឃ្មុំ គឺផ្លែទន្លាប់ ផ្លែទ្រយឹង ផ្លែមាក់ប្រាង ផ្លែមាក់ដោក ។ ទឹក
ដ៏ត្រជាក់នេះឯងដែលជងមកអំពីជ្រោះភ្នំ ម្នាលមហាព្រាហ្មណ៍
បើអ្នកប្រាថ្នាចង់ផឹក ចូរដងយកអំពីពេងទឹកនោះ ហើយផឹកចុះ
ដូច្នេះ ។

កាលត្រាស់ដូច្នេះហើយព្រះមហាសត្វទ្រង់ត្រិះរិះថា ព្រាហ្មណ៍នេះមិនមែន មកកាន់ព្រៃធំនេះដោយមិនមានហេតុ អញនឹងសួរដល់ហេតុដែលមក កុំឲ្យ យឺតយូរទើបត្រាស់គាថានេះថា

អ្នកមកដល់ព្រៃធំ ដោយហេតុដូចម្តេច ដោយបច្ច័យដូចម្តេច
យើងសួរហើយ អ្នកចូរប្រាប់ហេតុនោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វណ្ណោន** បានដល់ ដោយហេតុ ។ បទថា **ហេតុនា** បានដល់ ដោយបច្ច័យ ។

ជូជកទូលតបថា

ផ្លូវទឹក ( មានទន្លេនិងស្ទឹងជាដើម ) ដ៏ពេញប្រៀបមិនចេះ
អស់ទៅសព្វកាលយ៉ាងណាមិញ ទូលព្រះបង្គំជាខ្ញុំមកដើម្បី
សូមទានព្រះអង្គ ទូលព្រះបង្គំជាខ្ញុំសូមហើយ សូមប្រទាន
ព្រះរាជបុត្តទាំងពីរក៏យ៉ាងនោះដែរ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វារិវហោ** បានដល់ អន្លង់ទឹកក្នុងបញ្ចមហានទី ។ បទថា **ន ខីយតិ** សេចក្តីថា បុគ្គលដែលស្រេកទឹក មកកាន់ស្ទឹងយកដៃទាំង ២ ខ្វះ ភាជនៈទាំងឡាយខ្វះ ដងទឹកផឹកក៏មិនអស់ទៅ ។ បទថា **ឯវន្តំ យាចិតាគញ្ឆឹ** សេចក្តីថា ទូលព្រះបង្គំយល់ថា ទ្រង់ក៏មានសភាពយ៉ាងនេះដែរព្រោះពេញដោយសទ្ធា ទើបមកទូលសូមជាមួយព្រះអង្គ ។ បទថា **បុត្តេ មេ ទេហិ យាចិតោ** សេចក្តីថា កាលទូលព្រះបង្គំសូមហើយ សូមទ្រង់ព្រះរាជទានព្រះរាជឱរសព្រះរាជធីតាទាំង ២ ដល់ទូលព្រះបង្គំ ដើម្បីប្រយោជន៍ជាទាសៈចុះ ។ ព្រះវេស្សន្តរមហាសត្វបានស្តាប់ពាក្យរបស់ជូជកដូច្នោះ ក៏ពេញដោយសោមនស្ស ទ្រង់ញ៉ាំងបពិតឲ្យលាន់ឮដូចបុគ្គលដាក់ថង់ប្រាក់ឲ្យពេញដោយកហាបណៈ ១០០០ ក្នុងដៃរបស់បុគ្គលដែលលាចេញមកទទួលដូច្នោះត្រាស់ថា

ម្នាលព្រាហ្មណ៍ យើងឲ្យ យើងមិនរួញរាទេ អ្នកជាម្ចាស់ ( នៃ
ពួកបុត្តរបស់យើង ) ចូរនាំយកទៅចុះ រាជបុត្រី ( ជាមាតានៃ
បុត្តទាំងពីរនុ៎ះ ) បានចេញទៅរកផលានុផលអំពីព្រឹកនាងនឹង

ត្រឡប់មកអំពីការស្វែងរកក្នុងវេលាល្ងាច ម្នាលព្រាហ្មណ៍ អ្នកចូរឈប់សម្រាកបានមួយយប់សិន លុះព្រឹកឡើងសឹមទៅចុះ ។ ម្នាលព្រាហ្មណ៍ អ្នកឈប់សម្រាកបានមួយយប់ លុះព្រឹកឡើង ( សឹមនាំយក ) កុមារទាំងពីរនោះ ដែលមាតានោះដុសក្បាល ហើយប្រដាប់ដោយផ្កាកម្រង ហើយទៅចុះ ។ ម្នាលព្រាហ្មណ៍ អ្នកចូរនាំយក ( កុមារទាំងពីរនោះ ) ដែលពាក់ដោយផ្កាផ្សេងៗ ស្អិតស្អាងដោយគ្រឿងក្រអូបផ្សេងៗ សម្បូណ៌ដោយមើមឈើ និងផ្លែឈើផ្សេងៗហើយទៅចុះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឥស្សរោ** សេចក្ដីថា សូមអ្នកជាធំ គឺជាម្ចាស់របស់ព្រះរាជឱរសព្រះរាជធីតាទាំង ២ របស់យើង ចូរនាំពួកគេទៅចុះ តែនៅមានហេតុការណ៍មួយទៀត គឺនាងមទ្រីជាមាតានៃកុមារកុមារីទាំងនេះ ទៅរកផ្លែឈើអំពីព្រលឹម នឹងត្រឡប់មកអំពីព្រៃក្នុងវេលាល្ងាច អ្នកបរិភោគផ្លែឈើឆ្ងាញ់ដែលនាងមទ្រីនោះនាំមក ថ្ងៃនេះចូរស្នាក់នៅមួយយប់ក្នុងព្រៃនេះឯងហើយសឹមនាំកុមារទាំង ២ នេះទៅអំពីព្រលឹម ។ បទថា **តស្សា ន្ហាតេ** បានដល់ នាងមទ្រីងូតទឹកឲ្យក្មេងហើយ ។ បទថា **ឧបគ្ឃាតេ** បានដល់ ដុសក្បាលហើយ ។ បទថា **អថ នេ មាលធារិនេ** បានដល់ តាក់តែងដោយកម្រងផ្កាដ៏វិចិត្រ នាំកម្រងផ្កានោះទៅផង ។ បទថា **អថ នេ** លោករបនាទុកក្នុងបាលី អត្ថនៃបទនោះលោកមិនបានពិចារណា ( វិភាគ ) ទុក ។ បទថា **នានាបុប្ផមាល្យាភិកិណ្ណេ**? សេចក្ដីថា ដេរដាសទៅដោយមើមឈើ ផ្លែឈើ

ផ្សេងៗ ដែលឲ្យដើម្បីជាស្បៀងតាមផ្លូវ ។

ជូជកក៏ពោលថា

បពិត្រព្រះអង្គប្រសើរក្នុងរថ ទូលព្រះបង្គំ មិនគាប់ចិត្តនឹងការនៅទេ គាប់ចិត្តតែនឹងការទៅ ក្រែងអន្តរាយមានដល់ទូលព្រះបង្គំ ឯទូលព្រះបង្គំនឹងទៅខានពុំបាន ។ ជម្ពូតាពួកស្រីនុ៎ះ មិនមែនជាអ្នកគួរដល់ស្ងួមទេ តែងធ្វើសេចក្តីអន្តរាយ ពួកស្រីរមែងចេះកិច្ចកលមាយា តែងកាន់យកកិច្ចការទាំងពួងដោយខាងឆ្វេង ។ បពិត្រព្រះអង្គប្រសើរក្នុងរថ កាលបើព្រះអង្គប្រទានដោយសទ្ធា សូមកុំឲ្យ ( ទូលព្រះបង្គំជាខ្ញុំ ) ចួបនឹងព្រះមាតា ( របស់កុមារទាំងនោះឡើយ ) ក្រែងព្រះនាងនោះធ្វើសេចក្តីអន្តរាយ ទូលព្រះបង្គំនឹងទៅខានពុំបាន ។ សូមព្រះអង្គត្រាស់ហៅបុត្តទាំងគូរបស់ព្រះអង្គមក កុំឲ្យបុត្តទាំងនោះបានឃើញព្រះមាតាឡើយ កាលបើព្រះអង្គប្រទានដោយសទ្ធា បុណ្យតែងចម្រើនលូតលាស់យ៉ាងនេះ ។ សូមព្រះអង្គត្រាស់ហៅបុត្តទាំងគូរបស់ព្រះអង្គមក កុំឲ្យបុត្តទាំងនោះបានឃើញព្រះមាតាឡើយ បពិត្រព្រះរាជា លុះព្រះអង្គប្រទានព្រះរាជទ្រព្យដល់បុគ្គលប្រាកដដូចជាខ្ញុំហើយ ព្រះអង្គនឹងយាងទៅកាន់ឋានសួគ៌ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ធំ** ក្នុងគាថាថា **ឆ ហោតា យាចយោគី ធំ**

នេះត្រឹមតែជានិបាត មានពាក្យអធិប្បាយថា បពិត្រមហារាជ ធម្មតាស្រីទាំង នេះជាអ្នកមិនគួរដល់ការសូម គឺរមែងជាអ្នកមិនសមគួរដោយការសូមដោយ ពិត ។ បទថា **អន្តរាយស្ស ការិយា** សេចក្តីថា រមែងធ្វើអន្តរាយដល់បុណ្យ របស់ទាយក ធ្វើអន្តរាយដល់លាភរបស់យាចក ។ បទថា **មន្តុំ** បានដល់ ស្រីទាំងឡាយរមែងចេះមាយា ។ បទថា **វាមតោ** សេចក្តីថា កាន់យករបស់ ទាំងពួងដោយចំណែកខាងឆ្វេង មិនកាន់យកដោយចំណែកខាងស្តាំ ។ បទ ថា **សទ្ធាយ ទានំ ទទតោ** សេចក្តីថា កាលទ្រង់ជឿកម្មនិងផលនៃកម្មបរិ- ច្ចាគទាន ។ បទថា **មាសំ** សេចក្តីថា កុំចាំបាច់ជួបមាតារបស់កុមារ កុមារី ទាំងនោះឡើយ ។ បទថា **កយិរា** ប្រែថា គប្បីធ្វើ ។ បទថា **អាមន្តយស្សុ** សេចក្តីថា ជូជកទូលថា សូមទ្រង់ឲ្យជ្រាបថានឹងបញ្ជូនទៅជាមួយទូលព្រះ បង្គំ ។ បទថា **ទទតោ** បានដល់ កាលទ្រង់បរិច្ចាគ ។

ព្រះវេស្សន្តរត្រាស់ថា

បើអ្នកមិនប្រាថ្នាចង់ចួបនឹងភរិយារបស់យើង ដែលជាស្ត្រីមាន វត្តក្នុងស្វាមីទេ អ្នកចូរឲ្យកុមារទាំងពីរ គឺជាលីនិងកណ្ហាជិនា នេះដល់ព្រះអយ្យកោចុះ ។ ព្រះអយ្យកោនោះ ទ្រង់ទតឃើញ កុមារទាំងនេះដែលមានសំដីពីរោះ និយាយពាក្យជាទីស្រឡាញ់ ហើយ ទ្រង់សប្បាយរីករាយត្រេកអរ នឹងប្រទានទ្រព្យច្រើន ដល់អ្នក ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អយ្យកស្ស** បានដល់ ដល់ព្រះបាទសញ្ជយ

មហារាជដែលជាព្រះជនករបស់យើង ។ បទថា **ទស្សតិ តេ** សេចក្តីថា ព្រះបាទសញ្ជយមហារាជអង្គនោះ នឹងព្រះរាជទានទ្រព្យជាច្រើនដល់អ្នក ។

ជូជកក្រាបទូលថា

បពិត្រព្រះរាជបុត្ត សូមព្រះអង្គទ្រង់ព្រះសណ្តាប់ ( ពាក្យ ) របស់ទូលព្រះបង្គំ ទូលព្រះបង្គំខ្លាចក្រែងព្រះអយ្យកោដណ្តើមយក ( ព្រះរាជកុមារ ) ព្រះអយ្យកោនឹងប្រទានទូលព្រះបង្គំ ( ដល់ពួកអាមាត្យ ) ដើម្បីព្រះរាជទណ្ឌឬលក់ពិន័យ ពុំនោះសោត នឹងសម្លាប់ពុំខាន ទូលព្រះបង្គំមុខជានឹងដាច់ចាកទ្រព្យផង ចាកពួកទាសៈផង ត្រូវនាងព្រាហ្មណីតិះដៀលផង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អច្ឆេទនស្ស** បានដល់ ដណ្តើមព្រះរាជកុមារព្រះរាជកុមារីហើយចាប់ ។ បទថា **រាជទណ្ឌាយ មំ ទជ្ជា** សេចក្តីថា ព្រះបាទសញ្ជ័យ គប្បីព្រះរាជទានខ្ញុំដល់អាមាត្យទាំងឡាយ ដើម្បីដាក់រាជទណ្ឌដោយចោទថា ព្រាហ្មណ៍នេះជាចោរលួចក្មេង ចូរដាក់រាជទណ្ឌដល់វា ។ បទថា **គារយ្ហស្ស ព្រហ្មពន្ធុយា** សេចក្តីថា ខ្ញុំគប្បីត្រូវនាងអមិត្តតាបនាព្រាហ្មណីតិះដៀល ។

ព្រះវេស្សន្តរត្រាស់ថា

ព្រះមហារាជទ្រង់ឋិតនៅក្នុងធម៌ ញុំាំងពួកអ្នកសិវិរាស្ត្រឲ្យចម្រើន ទ្រង់ទតឃើញកុមារទាំងនេះ ដែលមានសម្តីពីរោះនិយាយពាក្យជាទីស្រឡាញ់ ទ្រង់បានបីតិនិងសោមនស្សនឹង

ព្រះរាជទានព្រះរាជទ្រព្យជាច្រើនដល់អ្នក ដូច្នេះ ។

ជូជកក្រាបទូលថា

ទូលព្រះបង្គំមិនធ្វើតាមព្រះបន្ទូលដែលទ្រង់បង្គាប់នោះទេ ទូលព្រះបង្គំ សូមនាំយកទារកទាំងពីរទៅឲ្យបម្រើនាងព្រាហ្មណី ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឆារកោ** សេចក្តីថា ខ្ញុំមិនត្រូវការទ្រព្យដទៃ ខ្ញុំនឹងនាំទារកទាំង ២ នេះទៅឲ្យបម្រើព្រាហ្មណីរបស់ខ្ញុំ ។

ជាលីរាជកុមារនិងកណ្ហាជិនារាជកុមារីបានស្តាប់ផរុសវាចានោះ នៃជូជកក៏មានការភ័យខ្លាច នាំគ្នាទៅក្រោយបណ្ណសាលា ហើយគេចទៅអំពីទីនោះពួនត្រង់គុម្ពឈើមានខ្ទនញ៉ចំប្រប់ ទតឃើញព្រះអង្គដូចត្រូវជូជកមកចាប់ទៅក្នុងទីនោះ កាលមិនអាចតាំងនៅក្នុងទីណាមួយបានក៏រត់ទៅក្នុងទីផ្សេងៗដល់ស្រះបោក្ខរណី ទ្រង់ស្លៀកសំពត់សម្បកឈើយ៉ាងមាំ មានព្រះហឫទ័យតក់ស្លុត ចុះក្នុងទឹកហើយយកស្លឹកឈូកដាក់លើក្បាល ឈរប្រថាប់ពួនក្នុងទឹក ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសាទូវព្រះគាថាដូច្នេះថា

លំដាប់នោះព្រះរាជកុមារទាំងពីរ គឺជាលីនិងកណ្ហាជិនា លុះឮសម្តីព្រាហ្មណ៍ឈ្លានពានហើយក៏តក់ស្លុតនាំគ្នាស្ទុះរត់ទៅតាមទីនោះៗ ដូច្នេះ ។

ឯជូជក មិនឃើញកុមារទាំង ២ ក៏និយាយបៀតបៀនព្រះពោធិសត្វថា បពិត្រព្រះវេស្សន្តរ ទ្រង់ប្រទានកុមារកុមារីដល់ទូលព្រះបង្គំ ឥឡូវនេះកាលទូលព្រះបង្គំទូលថា ទូលព្រះបង្គំនឹងមិនទៅជេតុត្តររាជធានី នឹងនាំកុមារកុមារីទៅឲ្យបម្រើអមិត្តតាបនាព្រាហ្មណីរបស់ទូលព្រះបង្គំ ទ្រង់ក៏ឲ្យសញ្ញាបួញមាត់បត់ជុំដៃឲ្យកូនទាំង ២ រត់ទៅ ហើយអង្គុយធ្វើជាមិនដឹង អ្នកនិយាយកុហកដូចទ្រង់ប្រហែលជាមិនមានក្នុងលោក ។

ឯព្រះមហាសត្វបានស្តាប់ដូច្នោះ ក៏ស្លុតព្រះហឫទ័យ ទ្រង់ព្រះតម្រិះថា កុមារទាំង ២ នឹងរត់ទៅទើបត្រាស់ថា នែព្រាហ្មណ៍ អ្នកកុំគិតឡើយ យើងនឹងនាំខ្លួនក្មេងទាំង ២ មក ត្រាស់ដូច្នេះហើយទ្រង់ក្រោក យាងទៅក្រោយបណ្ណសាលា ទ្រង់ជ្រាបថាព្រះរាជឱរសនិងព្រះរាជធីតាចូលទៅកាន់ព្រៃ ទើបយាងទៅកាន់ច្រាំងស្រះបោក្ខរណី តាមស្នាមព្រះបាទរបស់កុមារទាំង ២ នោះ ឃើញស្នាមព្រះព្រះបាទចុះកាន់ទឹក ក៏ជ្រាបថា ព្រះរាជឱរសនិងព្រះរាជធីតាចុះទៅឈរក្នុងទឹកទើបត្រាស់ហៅថាបាជាលីហើយត្រាស់គាថានេះថា

> ហៃបាជាកូនស្ងួនសម្លាញ់ កូនចូរមកអាយ ចូរបំពេញបារមីរបស់បិតា កូនចូរស្រោចស្រពហឫទ័យរបស់បិតា កូនចូរធ្វើតាមពាក្យរបស់បិតា ។ កូនចូរដូចជាយាននាវារបស់បិតា ឲ្យនឹងថ្កល់ក្នុងសាគរ គឺភព បិតានឹងឆ្លងចាកត្រើយ គឺជាតិ នឹងចម្លងមនុស្សព្រមទាំងទេវតា ( ទៅកាន់ត្រើយគឺព្រះនិព្វាន ) ដូច្នេះ ។

ជាលីរាជកុមារ បានស្តាប់ពាក្យរបស់បិតា ក៏គិតថា ព្រាហ្មណ៍ចូរធ្វើអញតាមគាប់ចិត្តចុះ អញមិនឲ្យបិតាហៅគម្រប់ជា ២ ដង ទើបផុសឡើងអំពីទឹក វែកស្លឹកឈូកហើយឡើងមកក្រាបទៀបបាទាខាងស្តាំរបស់ព្រះមហាសត្វ ឱបព្រះបាទាយំ ។ លំដាប់នោះមហាសត្វក៏ត្រាស់សួរជាលីថា នែបា ប្អូនស្រីរបស់បានៅឯណា ជាលីទូលថា បពិត្រព្រះបិតា ធម្មតាសត្វទាំងឡាយកាលភ័យកើតឡើង រមែងរក្សាខ្លួន ។ លំដាប់នោះមហាសត្វក៏ដឹងថាកូនទាំង ២ ណាត់គ្នាទើបត្រាស់ហៅថា កណ្ហាជិនាចូរនាងមក ហើយត្រាស់គាថានេះថា

> ហៃធីតាស្ងួនសម្លាញ់ ( ឪពុក ) នាងចូរមកព្រោះទានបារមីជាសម្លាញ់របស់បិតា នាងចូរស្រោចស្រពហឫទ័យរបស់បិតា ចូរធ្វើតាមពាក្យរបស់បិតា ។ នាងចូរដូចជាយាននាវារបស់បិតា ឲ្យនឹងថ្កល់ក្នុងសាគរ គឺភព បិតានឹងឆ្លងចាកត្រើយ គឺជាតិ នឹងចម្លងពួកមនុស្សព្រមទាំងទេវតា ដូច្នេះ ។

ព្រះនាងកណ្ហាជិនារាជកុមារីបានស្តាប់ពាក្យរបស់បិតាគិតថា អញនឹងមិនឲ្យបិតាត្រាស់ហៅជាគម្រប់ ២ ដង ទើបឡើងអំពីទឹកដូចគ្នា ក្រាបចុះទៀបព្រះបាទខាងឆ្វេងរបស់ព្រះមហាសត្វ ឱបជើងយំ ។ ទឹកភ្នែកនៃកុមារទាំង ២ ស្រក់លើខ្នងព្រះបាទារបស់មហាសត្វដែលមានពណ៌ដូចផ្កាឈូករីក ទឹកភ្នែករបស់មហាសត្វក៏ស្រក់លើខ្នងរបស់កុមារទាំង ២ ដែលមានពណ៌ដូចមាស ។ គ្រានោះមហាសត្វដល់នូវការញាប់ញ័រ មានព្រះហឫទ័យរួញរា ទ្រង់អង្អែលខ្នងរាជកុមារ កុមារីដោយបាតដៃដ៏ទន់ ញ៉ាំងកុមារទាំង ២ ឲ្យក្រោកឡើង

លួងលោមហើយត្រាស់ថា នែបាជាលី ឯងជីងទេថា ឪពុកត្រិះរិះដល់ទាន បារមី ចូរបាញុំាងអធ្យាស្រ័យរបស់ឪពុកឲ្យដល់ទីបំផុត ត្រាស់ដូច្នេះហើយ ឈរប្រថាប់កំណត់តម្លៃរាជបុត្រាបុត្រីក្នុងទីនោះ ដូចនាយគោបាលវាយតម្លៃ គោដូច្នោះ ។

បានឮថា មហាសត្វហៅព្រះរាជឱរសមកត្រាស់ថា នែបាជាលី បើបា ប្រាថ្នាជាអ្នកជាបាគួរឲ្យមាស ១០០០ ដុំដល់ជូជកព្រាហ្មណ៍ ទើបគួរជាអ្នក ជា ឯប្អូនស្រីរបស់បាជាទារិកាល្អដោយរូប បុគ្គលណាមានជាតិថោកថយ គប្បីឲ្យទ្រព្យបន្តិចបន្តួចដល់ព្រាហ្មណ៍ ធ្វើប្អូនស្រីរបស់បាឲ្យជាអ្នកជា ធ្វើឲ្យ បែកជាតិ វៀរតែព្រះរាជាណាឲ្យវត្ថុទាំងពួងមួយមុខ ១០០ ព្រោះហេតុនោះ ប្អូនស្រីរបស់បា បើចង់ក្លាយជាអ្នកជាគប្បីឲ្យវត្ថុទាំងពួងមួយមុខ ១០០ គឺ ទាសី ទាសា ដំរី សេះ គោ មួយមុខ ១០០ មាសត្ថោរ ១០០ ដុំ ដល់ជូជកទើបបានជាអ្នកជា ។ ព្រះវេស្សន្តរពោធិសត្វ កំណត់តម្លៃរាជកុមារ កុមារីយ៉ាងនេះហើយ លួងលោមហើយយាងទៅកាន់អាស្រមបទ ចាប់កុណ្ឌី ហៅជូជកមកត្រាស់ថា នែព្រាហ្មណ៍ដ៏ចម្រើន ចូរអ្នកមក ហើយទ្រង់ច្រួច ទឹកក្នុងដៃជូជក ធ្វើឲ្យទាក់ទងដោយសព្វញ្ញុតញ្ញាណត្រាស់ថា នែព្រាហ្មណ៍ សព្វញ្ញុតញ្ញាណ រមែងជាទីស្រឡាញ់ក្រៃលែងជាងកូនប្រុសកូនស្រីដែលជាទី ស្រឡាញ់រាប់រយ រាប់ពាន់ រាប់សែនដង កាលទ្រង់ញុំាងប្រឹថពីឲ្យបន្លឺឡើង បានព្រះរាជទានបិយបុត្តដល់ជូជកព្រាហ្មណ៍ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដបទ

ព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសួច្បសានូវព្រះគាថាដូច្នេះថា

លំដាប់នោះព្រះបរមពោធិសត្វ ញុំាងពួកអ្នកសិវិកស្រ្តឲ្យចម្រើន ទ្រង់នាំយកកុមារទាំងពីរ គឺជាលីនិងកណ្ហាជិនា ហើយទ្រង់ប្រទានដល់ព្រាហ្មណ៍ ។ ក្នុងលំដាប់នោះព្រះរាជាទ្រង់មានព្រះហឫទ័យរីករាយ នាំយកកុមារទាំងពីរ គឺជាលីនិងកណ្ហាជិនាជាបុត្ត ឲ្យជាទានដ៏ឧត្តមដល់ព្រាហ្មណ៍ ។ ហេតុដែលគួរឲ្យស្ញប់ស្ញែងក៏កើតមានក្នុងកាលនោះ សេចក្ដីព្រឺព្រួចរោមក៏កើតមានក្នុងកាលនោះ កាលដែលព្រះរាជាបានប្រទានកុមារទាំងពីរ ហើយផែនដីក៏កម្រើកញាប់ញ័រ ។ ហេតុដែលគួរឲ្យស្ញប់ស្ញែងក៏កើតមានក្នុងកាលនោះ សេចក្ដីព្រឺព្រួចរោមក៏កើតមានក្នុងកាលនោះព្រោះព្រះរាជាញុំាងពួកអ្នកសិវិកស្រ្តឲ្យចម្រើន ទ្រង់ផ្គងអញ្ជលី បានប្រទានកុមារទាំងពីរ ដ៏ចម្រើនដោយសេចក្ដីសុខឲ្យជាទានដល់ព្រាហ្មណ៍ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ចិត្តោ** បានដល់ ទ្រង់កើតបីតិសោមនស្ស ។ បទថា **តទាសិ យំ ភឹសនកំ** សេចក្ដីថា ក្នុងកាលនោះផែនដីធំកម្រាស ២ សែន ៤ ម៉ឺនយោជន៍ ក៏ញាប់ញ័រ លាន់ឮដូចដំរីចុះប្រេងជាន់នូវដើមបបុសដោយតេជះនៃទានបារមី ក្នុងកាលនោះសមុទ្រក៏រញ្ជួយ ស្ដេចភ្នំឈ្មោះសិនេរុក៏ទោរទន់ទៅមករកភ្នំគិរីវង្កតដូចផ្ដៅដែលគេរោលក្ដៅហើយគ្រវីទៅមកដូច្នោះ

សក្កទេវរាជទះដៃ មហាព្រហ្មបានប្រទានសាធុការ ទេវតាទាំងអស់ក៏ឲ្យសាធុការ កោលាហលកើតដូចគ្នាតែមួយរហូតដល់ព្រហ្មលោក ផ្ទៃមេឃក៏គំរាមជាមួយសំឡេងប្រឹថពីញុំាងភ្លៀងឲ្យធ្លាក់ពុំជួកាល ផ្លេកបន្ទោរក៏វាសពុំជួកាល សត្វចតុប្បាទ មានសីហៈជាដើមដែលនៅក្នុងហិមវន្តប្បទេស ក៏បន្លឺសំឡេងដូចគ្នា ពេញហិមវន្តប្បទេសគួរអស្ចារ្យ គួរស្រយុតស្រយង់តែបាលីលោកពោលត្រឹមតែផែនដីកម្រើកប៉ុណ្ណោះឯង ។ បទថា **យំ** ប្រែថា ក្នុងកាលណា ។ បទថា **កុមារេ សុខវច្ឆិតេ** សេចក្តីថា បានព្រះរាជទាននូវកុមារ កុមារីដែលចម្រើននៅក្នុងសេចក្តីសុខ គឺនៅក្នុងសេចក្តីសុខ ឲ្យជាគ្រឿងបរិច្ចាគ ។ បទថា **អទា ទានំ** សេចក្តីថា នែព្រាហ្មណ៍ សព្វញ្ញុតញ្ញាណ រមែងជាទីស្រឡាញ់ក្រៃលែងជាងកូនរបស់យើងរាប់រយ រាប់ពាន់ដងដូច្នោះ ទើបព្រះរាជទានដើម្បីប្រយោជន៍ដល់សព្វញ្ញុតញ្ញាណនោះ ។

ព្រះមហាសត្វទ្រង់បំពេញបុត្តកទានហើយ ញុំាងព្រះបីតិឲ្យកើតឡើងថា ឱ ទានរបស់អញបានឲ្យល្អហើយហ្ន៎ហើយប្រថាប់ឈរទតមើលកុមារកុមារី ។

ចំណែកជូជកចូលទៅកាន់ព្រៃយកធ្មេញខាំវល្លិ កាន់មកចងដៃស្តាំនៃជាលីកុមារជាមួយដៃខាងឆ្វេងរបស់កណ្ហាជិនាកុមារី កាន់ចុងវល្លិនោះទុកវាយហើយនាំទៅ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** វីអាចិធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសួធ្យសានូវព្រះគាថាដូច្នេះថា

លំដាប់នោះព្រាហ្មណ៍ជាអ្នកល្មោភនោះ បានខាំកាត់វល្លិដោយធ្មេញទាំងឡាយ ហើយចងដៃទាំងឡាយដោយវល្លិ ហើយយកវល្លិវាយបណ្តើរ ។ លំដាប់តពីនោះមកព្រាហ្មណ៍នោះកាន់ខ្សែផង កាន់ឈើច្រត់ផង វាយកុមារទាំងពីរនោះនាំបណ្តើរទៅ ( ក្នុងទី ) ចំពោះព្រះភក្ត្រនៃព្រះបាទសិវិ ( វេស្សន្តរ ) ដូច្នេះ ។

ព្រះឆវីវណ្ណរបស់ជាលី និងកណ្ហាជិនា បានបែកត្រង់ទីដែលវាយហើយនោះៗ ឈាមក៏ហូរ ជាលីនិងកណ្ហាជិនាយកខ្នងរងរំពាត់ជំនួសគ្នានឹងគ្នាក្នុងទីដែលត្រូវវាយ ។ លំដាប់នោះដូជករអិលជើងដួល ក្នុងទីដែលមិនរាបស្មើមួយកន្លែង វល្លិដែលរឹងក៏របូតចេញអំពីដៃដ៏ទន់នៃកុមារទាំង ២ កុមារកុមារីនាំគ្នាយំរត់ទៅរកព្រះមហាសត្វ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូត្យសានូវព្រះគាថាដូច្នេះថា

ក្នុងកាលដែលព្រាហ្មណ៍នាំទៅនោះ កុមារទាំងពីរបានរបូតរួច ( អំពីចំណង ) នៃព្រាហ្មណ៍ ហើយរត់ចៀសចេញទៅ កុមារនោះ មាននេត្រាទាំងពីរដ៏ពោរពេញដោយទឹកភ្នែក ងើបមើលព្រះបិតា ។ កុមារក៏ញាប់ញ័រចំប្រប់ដូចជាស្លឹកពោធិ៍ ថ្វាយបង្គំព្រះបាទទាំងគូរបស់ព្រះបិតា លុះថ្វាយបង្គំព្រះបាទទាំងគូ

របស់ព្រះបិតាហើយ បានពោលពាក្យនេះថា បពិត្រព្រះបិតា ព្រះមាតាចេញទៅព្រៃហើយ បពិត្រព្រះបិតា ឯព្រះអង្គប្រទាន យើងខ្ញុំ បពិត្រព្រះបិតា ចាំយើងខ្ញុំចួបនឹងព្រះមាតាសិនសឹម ព្រះអង្គប្រទានយើងខ្ញុំ ។ បពិត្រព្រះបិតា ព្រះមាតាចេញទៅ ព្រៃហើយ បពិត្រព្រះបិតា ឯព្រះអង្គប្រទានយើងខ្ញុំ បពិត្រ ព្រះបិតា ព្រះអង្គកុំអាលប្រទានយើងខ្ញុំឡើយ រង់ចាំព្រះមាតា របស់យើងខ្ញុំត្រឡប់មកសិន ។ ក្នុងពេលនោះ ព្រាហ្មណ៍នេះ ចង់លក់ឬចង់សម្លាប់ ក៏តាមប្រាថ្នាចុះ ( ដូជកព្រាហ្មណ៍នេះ ) មានជើងត្រប៉ាត ក្រចកស្អុយ មួយទៀតមានដុំសាច់យុរយារ បបូមាត់ខាងលើវែង មានទឹកមាត់ហៀរចេញធ្មេញស្រេញ ( ដូច ខ្លាយជ្រូក ) ប្រមុះបាក់ ។ មានពោះធំ កំប៉ោង ខ្នងកោង ភ្នែកស្រលៀង ពុកមាត់ពុកចង្កាក្រហម សក់លឿង ស្បែក ជ្រួញជ្រីវទុះដោយអាចម៍រុយ ។ មានភ្នែកលៀនក្លោត ( ដូច ភ្នែកឆ្មា ) ចង្កេះ ខ្នង ករវៀច សន្ទាក់ឆ្អឹងលាន់ឮប្រសៗ ធំ ដំបង ឈ្លានពានទុកជាស្លៀកដណ្តប់ស្បែកខ្លាក៏ដូចជាអមនុស្ស គួរស្បើម ។ បពិត្រព្រះបិតា ( ព្រាហ្មណ៍នេះ ) ជាមនុស្ស ឬជាយក្ស ជាអ្នកស៊ីសាច់និងឈាមចេញអំពីស្រុកមកកាន់ព្រៃ សូមទ្រព្យ គឺកូននឹងព្រះបិតាទេដឹង ។ បពិត្រព្រះបិតា យើង ខ្ញុំត្រូវបិសាចកំពុងនាំទៅ ព្រះបិតាទ្រង់ទតឃើញឬទេ ព្រះ

ហឫទ័យរបស់ព្រះបិតា ( ធូន់ដូចថ្ម ) ឬដូចជាចំណងដែកដ៏
មាំ ព្រះអង្គមិនជ្រាបយើងខ្ញុំដែលព្រាហ្មណ៍ជាអ្នកស្វែងរកទ្រព្យ
លោភហួសប្រមាណចាប់ចង ហើយវាយយើងខ្ញុំ ដូចជាគេ
វាយគោ ។ នាងកណ្ហាជិនាចូរនៅក្នុងទីនេះចុះ ដ្បិតនាងមិនទាន់
ដឹងក្ដីនៅឡើយរមែងកន្ទក់កន្ទេញ ដូចជាកូនម្រឹគនៅបៅដោះ
ហើយព្រាត់ប្រាសចាកហ្វូង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឧទិក្ខតិ** សេចក្ដីថា ទៅកាន់សម្នាក់ព្រះមហាសត្វញាប់ញ័រចំប្រប់ហើយសម្លឹងមើល ។ បទថា **វេធំ** បានដល់ មានខ្លួនញ័រ ។ បទថា **ត្វញ្ច នោ តាត ទស្សសិ** សេចក្ដីថា បពិត្របិតា ទ្រង់បានប្រទានខ្ញុំទាំង ២ ឲ្យដល់ព្រាហ្មណ៍ កាលមាតាមិនទាន់ត្រឡប់មក សូមទ្រង់កុំធ្វើយ៉ាងនេះឡើយ សូមមេត្តាបង្អង់សិនទម្រាំខ្ញុំទាំង ២ បានឃើញមាតា បន្ទាប់អំពីនោះ សឹមទ្រង់ប្រទានក្នុងកាលដែលខ្ញុំទាំង ២ បានឃើញមាតាហើយ ។ បទថា **វិក្កីណាតុ ហនាតុ វា** សេចក្ដីថា បពិត្រព្រះបិតា ក្នុងកាលដែលព្រះមាតាយាងមក ជូជកព្រាហ្មណ៍នេះ ចូរលក់ឬចូរសម្លាប់ខ្ញុំទាំង ២ ក៏ដោយ ចូរធ្វើតាមសេចក្ដីប្រាថ្នាចុះ ។ម្យ៉ាងទៀតជាលីរាជកុមារ បានក្រាបទូលបុរសទោស ១៨ ប្រការ ព្រាហ្មណ៍អាក្រក់នោះប្រកបដោយទោស ១៨ ប្រការ ។

បណ្ដាបទទាំងនោះ បទថា **ពលង្កបាទោ** បានដល់ មានជើងត្រប៉ាត ។ បទថា **អទ្ធនខោ** បានដល់ ក្រចកស្អុយ ។ បទថា **ឱពទ្ធបិណ្ឌិកោ** បានដល់

មានសាច់ដុំកំភួនយុរយារ ។ បទថា **ទីឃោត្តរោដ្ឋោ** បានដល់ មានបបូរមាត់លើវែងគ្របមកលើបបូរមាត់ខាងក្រោម ។ បទថា **ចបលោ** បានដល់ មានទឹកមាត់ហូរមិនដាច់ ។ បទថា **កាឡារោ** បានដល់ មានធ្មេញចង្កូមចេញមកក្រៅដូចខ្នាយជ្រូក ។ បទថា **ភគ្គនាសកោ** បានដល់ មានច្រមុះបាក់ គឺមិនស្មើគ្នា ។ បទថា **លោហមស្សុ** បានដល់ ពុកមាត់ពុកចង្កាមានពណ៌ដូចលោហៈក្រហម ។ បទថា **ហរិតកេសោ** បានដល់ មានសក់ពណ៌លឿង រីងក្រញាង ។ បទថា **វលីនំ** បានដល់ ស្បែករមូរពេញខ្លួន ។ បទថា **តិលកាហតោ** បានដល់ ដេរដាសដោយប្រជ្រុយនិងអាចម៍រុយ ។ បទថា **បិង្គលោ** បានដល់ មានភ្នែកស្រលៀងពណ៌លឿង គឺប្រកបដោយភ្នែកទាំង ២ ដូចគ្នានឹងភ្នែកឆ្មា ។ បទថា **វិនតោ** បានដល់ វៀចក្នុងទី ៣ កន្លែង គឺចង្កេះ ខ្នងនិងក ។ បទថា **វិកដោ** បានដល់ មានជើងលាន់ឮលោកពោលថា មានទិត គឺត្រង់ឆ្អឹងលាន់នូវមានសំឡេងក៏មាន គឺប្រកបដោយទិតត្រង់ឆ្អឹងមានសំឡេង កដៈ កដៈ ។ បទថា **ព្រហា** បានដល់ វែង ។

បទថា **អមនុស្សោ** សេចក្តីថា ព្រាហ្មណ៍នេះមិនមែនមនុស្ស ជាយក្ខដែលត្រាច់ទៅក្នុងព្រៃ ដោយភេទរបស់មនុស្សដោយពិត ។ បទថា **ភយា-នកោ** បានដល់ គួរខ្លាចពន់ពេក ។ បទថា **មនុស្សោ ឧទាហុ យក្ខោ** សេចក្តីថា បពិត្រព្រះបិតា បើបុគ្គលណាឃើញព្រាហ្មណ៍នោះហើយសួរ ក៏គួរឆ្លើយថា ស៊ីសាច់និងឈាមជាអាហារ ។ បទថា **ធនំ តំ តាត យាចតិ** សេចក្តីថា បពិត្រលោកឪពុក ព្រាហ្មណ៍នេះបំណងនឹងស៊ីសាច់នៃខ្ញុំទាំង ២

ទើបទូលសូមទ្រព្យ គឺបុត្តចំពោះព្រះអង្គ ។ បទថា **ឧបិក្ខសិ** បានដល់ ស្ងៀមព្រងើយ ។ បទថា **អស្មា ទុក្ខ តេ ហទយំ** សេចក្តីថា បពិត្រលោកឪពុក ធម្មតាមាតាបិតាទាំងឡាយ រមែងមានហទយៈទន់ក្នុងកូនទាំងឡាយ មិនអត់ធន់មើលសេចក្តីទុក្ខនៃកូនទាំងឡាយបានទេ តែព្រះហឫទ័យរបស់ទ្រង់ដូចគ្នានឹងផ្ទាំងថ្ម ។ ម្យ៉ាងទៀតហឫទ័យរបស់ព្រះអង្គ គង់ប្រើដែកចងទុកយ៉ាងមាំដូច្នោះ កាលខ្ញុំទាំង ២ មានសេចក្តីទុក្ខកើតឡើងបែបនេះ ទ្រង់ក៏មិនក្តៅក្រហាយ ។ បទថា **ន ជានាសិ** សេចក្តីថា ទ្រង់ប្រថាប់គង់ដូចមិនដឹង ។

បទថា **អច្ចាយិកេន លុទ្ទេន** បានដល់ កាចពន់ពេក គឺហួសប្រមាណ ។ បទថា **យោ នោ** សេចក្តីថា ទ្រង់មិនជ្រាបទេឬថាខ្ញុំទាំង ២ ត្រូវព្រាហ្មណ៍ចងទុក ។ បទថា **សុម្ភតិ** បានដល់ វាយវែធ ។ បទថា **ឥធេវ អច្ឆតំ** សេចក្តីថា បពិត្របិតា កណ្ហាជិនានេះ មិនអាចអត់ធន់នូវសេចក្តីទុក្ខបានទេ បើមិនឃើញព្រះមាតាក៏នឹងយំនឹងអស់ជីវិត ដូចកូនម្រឹគដែលដាច់ដោះប្រាសចាកហ្វូងមិនឃើញមេរមែងស្រែកយំចង់បៅដោះដូច្នោះ ព្រោះហេតុនោះសូមទ្រង់ឲ្យតែខ្ញុំប៉ុណ្ណោះដល់ព្រាហ្មណ៍ ខ្ញុំនឹងទៅ សូមឲ្យកណ្ហាជិនានេះនៅក្នុងទីនេះឯង ។

កាលជាលីរាជកុមារក្រាបទូលយ៉ាងនេះហើយ ព្រះមហាសត្វក៏មិនបានត្រាស់អ្វីឡើយ ។ បន្ទាប់អំពីនោះជាលីរាជកុមារ កាលខ្សឹកខ្សួលប្រារព្ធដល់ព្រះជននីទើបត្រាស់ថា

ទុក្ខដូច្នោះនេះ មិនមែនជាទុក្ខដល់អញទេ ព្រោះទុក្ខនេះបុរស

( ដែលវង្គត់ទៅក្នុងភព ) ត្រូវបាន អញមិនឃើញព្រះមាតាណា ការមិនឃើញព្រះមាតានោះជាសេចក្តីទុក្ខក្រៃលែងរបស់អញជាងសេចក្តីទុក្ខដែលព្រាហ្មណ៍វាយដំនេះទៅទៀត ។ ទុក្ខដូច្នោះនេះ មិនមែនជាទុក្ខដល់អញទេ ព្រោះទុក្ខនេះបុរសត្រូវបាន អញមិនឃើញព្រះមាតាណា ការមិនឃើញព្រះមាតានោះជាសេចក្តីទុក្ខក្រៃលែងរបស់អញ ជាងសេចក្តីទុក្ខដែលព្រាហ្មណ៍វាយដំនេះទៅទៀត ។ ព្រះមាតានោះជាមនុស្សកំព្រាពិតកាលបើមិនឃើញកុមារីឈ្មោះកណ្ហាជិនា ល្អគួរមើល មុខជានឹងទ្រង់ព្រះកន្សែងអស់កាលយូរ ។ ព្រះបិតានោះជាមនុស្សកំព្រាដោយពិតកាលបើមិនឃើញកុមារីឈ្មោះកណ្ហាជិនា ល្អគួរមើល មុខជានឹងទ្រង់ព្រះកន្សែងអស់កាលយូរ ។ ព្រះមាតានោះជាមនុស្សកំព្រាពិតកាលបើមិនឃើញកុមារីឈ្មោះកណ្ហា-ជិនា ល្អគួរមើល មុខជានឹងទ្រង់ព្រះកន្សែងក្នុងអាស្រមអស់កាលយូរ ។ ព្រះបិតានោះជាមនុស្សកំព្រាពិត កាលបើមិនឃើញកុមារីឈ្មោះកណ្ហាជិនា ល្អគួរមើល មុខជានឹងទ្រង់ព្រះកន្សែងក្នុងអាស្រមអស់កាលយូរ ។ ព្រះមាតានោះជាមនុស្សកំព្រាពិត ( រឭកពួកយើង ) ក្នុងពាក់កណ្តាលអធ្រាត្រ ឬក្នុងរាត្រីទាំងមូល នឹងទ្រង់ព្រះកន្សែងអស់កាលយូរ នឹងរីងស្ងួតដូចស្ទឹង ។ ព្រះបិតានោះជាមនុស្សកំព្រាដោយពិត ( រឭកពួក

យើង ) ក្នុងកណ្ដាលអជ្រាត្របូក្នុងរាត្រីទាំងមូល នឹងទ្រង់ព្រះកន្សែងអស់កាលយូរ នឹងរីងស្ងួតដូចជាស្មឹង ។ រុក្ខជាតិផ្សេងៗទាំងនេះ គឺដើមព្រីង ឈើទាលខ្សាច់មានមែកត្រសុំត្រសាយ ថ្ងៃនេះ យើងនឹងបោះបង់ពួករុក្ខជាតិទាំងនោះចោលហើយ ។ ពួកផលជាតិផ្សេងៗទាំងនេះ គឺពោធិ៍ ខ្នុរ ជ្រៃ ក្រសាំង ថ្ងៃនេះយើងនឹងបោះបង់ផលជាតិទាំងនោះចោលហើយ ។ នេះសួនច្បារ នេះស្ទឹងមានទឹកត្រជាក់ ពីដើមយើងលេងក្នុងទីណា ថ្ងៃនេះយើងនឹងបោះបង់ទីទាំងនោះ ។ ពីដើមពួកយើងទ្រទ្រង់ផ្កាណាច្រើនយ៉ាងលើភ្នំនេះ ថ្ងៃនេះយើងនឹងបោះបង់ផ្កាទាំងនោះ ។ ពីដើមពួកយើងបរិភោគផ្លែឈើណាច្រើនយ៉ាងលើភ្នំនេះ ថ្ងៃនេះយើងនឹងបោះបង់ផ្លែឈើទាំងនោះ ។ នេះរូបដំរី រូបសេះរបស់យើង នេះរូបគោរបស់យើង ពីដើមយើងលេងដោយរូបណា ថ្ងៃនេះយើងនឹងបោះបង់រូបទាំងនោះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បុមុញា** សេចក្ដីថា ទុក្ខនេះដែលបុរសគ្រាច់ទៅក្នុងភពគប្បីបាន ។ បទថា **តំ មេ ទុក្ខតរំ ឥតោ** សេចក្ដីថា ទុក្ខនៃយើងកាលមិនបានឃើញព្រះមាតានោះ ជាទុក្ខក្រៃលែងជាងទុក្ខដែលកើតអំពីការវាយនេះរាប់រយ រាប់ពាន់ រាប់សែនដង ។ បទថា **រុច្ចតិ** បានដល់ ទ្រង់នឹងព្រះកន្សែង ។ បទថា **អឌ្ឍរត្តេ វា រត្តេ វា** សេចក្ដីថា ទ្រង់នឹកដល់យើងទាំង ២ នឹងព្រះកន្សែងអស់កាលយូរហួតកន្លះរាត្រីឬអស់មួយរាត្រី ។ បទ

ថា **អវសុស្សតិ** សេចក្តីថា ជាលិកុមារត្រាស់ដោយបំណងយ៉ាងនេះថា ព្រះមាតានឹងរីងស្ងួតដូចស្ទឹងតូចៗដែលមានទឹកតិច គឺកាលអរុណរះឡើងនឹងរីងស្ងួតអស់ព្រះជន្មដូចស្ទឹងនោះដែលរីងស្ងួតមួយរំពេចដូច្នោះ ។ បទថា **វេធិ-សា** បានដល់ មានមែកសំយុងចុះ ។ បទថា **តានិ** សេចក្តីថា ឫសឈើ ផ្កាឈើ ផ្លែនៃដើមឈើពួកណាដែលយើងចាប់លេងអស់កាលដ៏យូរ យើងទាំង ២ នឹងត្រូវលះបង់ដើមឈើទាំងនោះទៅក្នុងថ្ងៃនេះ ។ បទថា **ហត្ថិកា** បានដល់ រូបតូចៗ មានរូបដំរីជាដើមដែលបិតាធ្វើឲ្យយើងទាំង ២ លេង ។

កាលជាលិរាជកុមារខ្សឹកខ្សួលយ៉ាងនេះ ជាមួយកណ្ហាជិនា ជូជកក៏មកវាយវែកកុមារកុមារីនាំខ្លួនចៀសចេញទៅ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសានូវព្រះគាថាដូច្នេះថា

កុមារទាំងនោះកាលជូជកព្រាហ្មណ៍កំពុងនាំទៅ បានពោលនឹងព្រះបិតាដូច្នេះថា បពិត្រព្រះបិតា សូមព្រះអង្គប្រាប់នូវភាព ( របស់យើងខ្ញុំ ) ជាបុគ្គលមិនមានរោគ ដល់ព្រះមាតាផងទាំងព្រះអង្គសោតក៏សូមឲ្យបានសេចក្តីសុខ ។ នេះរូបដំរី រូបសេះរបស់យើងខ្ញុំ នេះរូបគោរបស់យើងខ្ញុំ សូមព្រះអង្គប្រទានរូបទាំងនោះ ដល់ព្រះមាតាៗនឹងបន្ទោបង់សំណោក ព្រោះរូបទាំងនោះ ។ នេះរូបដំរី រូបសេះរបស់យើងខ្ញុំ នេះរូបគោរបស់

យើងខ្ញុំ ព្រះមាតាកាលបើក្រឡេកឃើញរូបទាំងនោះហើយនឹង
បន្ទោបង់សំណោកចេញបាន ដូច្នេះ ។

កាលនោះ សេចក្ដីសោកមានកម្លាំង ព្រោះប្រារព្ធកូនប្រុសស្រីបានកើតឡើងដល់មហាសត្វ សាច់បេះដូងរបស់មហាសត្វមានសភាពក្ដៅ ទ្រង់ញាប់ញ័រដោយសេចក្ដីសោក ដូចដំរីចុះប្រេងត្រូវកេសរសីហៈចាប់និងដូចព្រះចន្ទក្នុងមាត់រាហូ មិនអាចតាំងនៅបានដោយភាវៈរបស់ព្រះអង្គ មានព្រះភក្ត្រជិតជាមដោយព្រះអស្សុជល ទ្រង់ចូលកាន់បណ្ណសាលាទ្រង់បរិទេវនាការ មុខគួរអណោច ។

**តមត្ថំ បកាសេន្តោ សត្ថា អាហា** វីអាចិធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសានូវព្រះគាថាដូច្នេះថា

លំដាប់នោះ ព្រះបាទវេស្សន្តរជាក្សត្រិយ៍ ទ្រង់ដាក់ទានរួច
ហើយក៏យាងចូលទៅកាន់បណ្ណសាលា ហើយខ្សឹកខ្សួលគួរឲ្យ
អាណោចអាធ័ម ។

គាថាសម្ដែងការពិលាករបស់ព្រះមហាសត្វមានដូចតទៅនេះថា

ក្នុងថ្ងៃនេះទារកទាំងពីរមានសេចក្ដីស្រេកឃ្លាន ហើយយំទារ
នរណា អ្នកណាហ្នឹងឲ្យភោជនដល់ទារកទាំងពីរនោះ ក្នុង
កាលជាទីអង្គាស ( អាហារ ) ក្នុងវេលាល្ងាច ។ ក្នុងថ្ងៃនេះ
ទារកទាំងពីរមានសេចក្ដីស្រេកឃ្លាន ហើយយំទារនរណា

បពិត្រព្រះមាតា យើងខ្ញុំមានសេចក្តីស្រេកឃ្លានហើយ សូមព្រះមាតាប្រទានភោជនដល់យើងខ្ញុំ ក្នុងកាលជាទីអន្លាស ( អាហារ ) ក្នុងវេលាល្ងាច ។ ទារកទាំងពីរដើរទៅដោយជើងទទេ មិនមានស្បែកជើង នឿយហត់ មានជើងទាំងពីរដ៏ពុះពងទៅកាន់ផ្លូវដូចម្តេចបាន អ្នកណានឹងដឹកដៃទារកទាំងនោះទៅ ។ កោតតែព្រាហ្មណ៍នោះហ៊ានវាយកូនទាំងពីររបស់អញ ជាអ្នកមិនមានកំហុសក្នុងទីចំពោះមុខ មិនអៀនខ្មាស ព្រាហ្មណ៍នេះហៅពេញជាមនុស្សឥតអៀនខ្មាស ។ អ្នកណាមានសេចក្តីអៀនខ្មាសនឹងវាយពួកជន សូម្បីជាខ្ញុំស្រីខ្ញុំប្រុស ឬជាអ្នកបម្រើដទៃរបស់អញដែលលះឲ្យហើយនោះ ។ ព្រាហ្មណ៍ហ៊ានជេរ ហ៊ានវាយដំកូនសម្លាញ់របស់អញដែលកំពុងមើលឃើញ ដូចជាត្រីដែលជាប់នៅក្នុងមាត់លប ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កំ ឆ្វជ្ឈ** កាត់បទជា **កំ នុ អជ្ឈ** ។ បទថា **ឧបរុជ្ឈន្តិ** សេចក្តីថា នឹងដើរយំអស់ចម្ងាយផ្លូវ ៦០ យោជន៍ ។ បទថា **សំវេសនាកាលេ** បានដល់ ក្នុងកាលបរិភោគអាហាររបស់មហាជន ។ បទថា **កោ នេ ទស្សតិ** សេចក្តីថា អ្នកណានឹងឲ្យភោជនីយាហារដល់កូនទាំងឡាយនោះ ។ បទថា **កថន្នុ បថំ គច្ឆន្តិ** សេចក្តីថា នឹងធ្វើដំណើរ ៦០ យោជន៍បានដូចម្តេច ។ បទថា **បត្តិកា** បានដល់ វៀរចាកយាន គឺដំរីជាដើម ។ បទថា **អនុបាហនា** បានដល់ មានជើងទទេមិនមានសូម្បីត្រឹមតែស្បែកជើង ។

បទថា **គហេស្សតិ** សេចក្ដីថា នរណានឹងជួយផ្គង ដើម្បីបន្ទោបង់សេចក្ដីលំបាក ។ បទថា **ទាសីទាសស្ស** សេចក្ដីថា ជាទាសី ជាទាសៈ ។ បទថា **អញ្ញោ វា បន បេសិយោ** សេចក្ដីថា ដែលដឹងថា បុគ្គលណាជាអ្នកបម្រើជាអ្នករង់ចាំប្រតិបត្តិលំដាប់ទី ៤ របស់យើង បុគ្គលនោះសូម្បីថោកទាបយ៉ាងនេះ បុគ្គលនេះក៏គង់ជាទាសៈរបស់ព្រះវេស្សន្តរដោយបន្តជាទាសៈនិងទាសៈយ៉ាងនេះថា ជាទាសៈរបស់បុគ្គលនោះៗ ។ បទថា **កោ លជ្ជី** សេចក្ដីថា អ្នកណាដែលមានការអៀនខ្មាសហ៊ានវាយ គឺការដែលបុគ្គលមិនមានខ្មាសនោះ នឹងវាយកូនរបស់អញមិនសមគួរហ្ន៎ ។ បទថា **វារិជស្សេវ** សេចក្ដីថា កូនរបស់អញដូចត្រីដែលជាប់ក្នុងមាត់លប ។ **អ** អក្ខរៈក្នុងបទថា **អបស្ស-តោ** ត្រឹមតែជានិបាត ។ ដូជកជេរកូនអញផង វាយកូនជាទីស្រឡាញ់របស់អញផង ក្នុងទីដែលឃើញនឹងភ្នែក ឱ តានេះឃោរឃៅពន់ពេក ។

កាលនោះការត្រិះរិះកើតឡើងដល់ព្រះវេស្សន្តរមហាសត្វ ដោយទ្រង់ស្រឡាញ់ក្នុងព្រះរាជឱរសនិងព្រះរាជធីតាយ៉ាងនេះថា អញកាលមិនអាចអត់ធន់សេចក្ដីសោកទុកបាន ដោយគិតថាព្រាហ្មណ៍នេះបៀតបៀនកូនទាំង ២ របស់អញពន់ពេកអញ នឹងដេញតាមទៅសម្លាប់ព្រាហ្មណ៍ចោល នាំកូនទាំង ២ មក បន្ទាប់អំពីនោះទ្រង់រឭកបានថា ការបៀតបៀននូវកុមារកុមារីទាំងឡាយហើយនាំឲ្យកើតទុក្ខយ៉ាងក្រៃលែងដល់អញ ទុំះមិនមែនជាឋានៈឈ្មោះថាការបរិច្ចាគទានហើយក្ដៅក្រហាយក្នុងកាលជាខាងក្រោយ មិនមែនជាធម៌របស់សប្បុរសឡើយ គាថាសម្ដែងបរិវិតក្ក ២ គាថាមានដូច្នេះថា

អញនឹងកាន់យកធ្នូ ស្ពាយព្រះខាន់លើស្មាខាងឆ្វេង ហើយនាំ
យកកូនទាំងពីររបស់ខ្លួនមកវិញឬ ព្រោះថាការដែលគេវាយ
ដំកូនទាំងពីរនាំមកនូវសេចក្តីទុក្ខ ។ កុមារទាំងពីរ គប្បីលំបាក
ដោយហេតុណា ហេតុនុ៎ះមិនមែនជាទីតាំងមានសភាពជាទុក្ខ
ទេ នរណាយល់ធម៌របស់ពួកសប្បុរសហើយឲ្យទាន រមែង
ក្តៅក្រហាយរឿយៗ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សតំ** បានដល់ ធម៌ គឺបវេណីរបស់ពោធិសត្វ
ក្នុងកាលមុន ។ បានឮថា ព្រះពោធិសត្វទ្រង់រឭកដល់បវេណីរបស់ព្រះពោធិ-
សត្វទាំងឡាយក្នុងខណៈនោះ បន្ទាប់អំពីនោះទ្រង់ព្រះតម្រិះថា ព្រះពោធិសត្វ
ទាំងពួងមិនបរិច្ចាគមហាបរិច្ចាគ ៥ គឺបរិច្ចាគទ្រព្យ បរិច្ចាគអវយវៈ បរិច្ចាគ
ជីវិត បរិច្ចាគកូន បរិច្ចាគភរិយាហើយបានជាព្រះពុទ្ធមិនមានទេ ឯអញក៏នៅ
ក្នុងពួកពោធិសត្វទាំងនោះ បើអញមិនបរិច្ចាគកូននិងប្រពន្ធក៏មិនអាចជាព្រះ
ពុទ្ធបានឡើយ ទ្រង់ត្រិះរិះដូច្នេះហើយញុំាងសញ្ញាឲ្យកើតឡើងថា នៃវេស្សន្តរ
អ្នកមិនដឹងភាពដែលកូនប្រុសនិងកូនស្រីដែលឲ្យជាទាសា ទាសីដល់ជនដទៃ
នាំមកនូវសេចក្តីទុក្ខទេឬ អញនឹងតាមទៅសម្លាប់ជូជកដោយហេតុអ្វី ហើយ
ទ្រង់ត្រិះរិះបន្តថា ឈ្មោះថា បរិច្ចាគទានហើយតាមក្តៅក្រហាយក្នុងកាលជា
ខាងក្រោយមិនសមគួរដល់អញឡើយ ទ្រង់សម្រេចឯងយ៉ាងនេះហើយទ្រង់
អធិដ្ឋានសមាទានសីលឲ្យជាថាវរៈ ដោយមនសិការថា បើជូជកសម្លាប់កូន
ទាំង ២ របស់អញ ចាប់តាំងពីពេលដែលអញបរិច្ចាគហើយ អញនឹងមិន

ខ្វល់អ្វីឡើយ ទ្រង់អធិដ្ឋានមាំដូច្នេះហើយយាងចេញអំពីបណ្ណសាលា គង់ប្រថាប់លើថ្មទៀបបណ្ណសាលាដូចបដិមាសដូច្នោះ ។

ចំណែកដូជកវាយជាលីនិងកណ្ហាជិនា ក្នុងទីចំពោះមុខនៃមហាសត្វនាំទៅ ។

លំដាប់នោះជាលីរាជកុមារខ្សឹកខ្សួលថា

បានឮថា ជនពួកខ្លះក្នុងលោកនេះ បានពោលពាក្យពិតយ៉ាងនេះថា បុគ្គលណាមិនមានមាតាបង្កើត បុគ្គលនោះឈ្មោះថាមិនមានបិតាដូចគ្នាដែរ ។ នែនាងកណ្ហាប្អូន នាងចូរមក យើងមុខជានឹងស្លាប់ យើងមិនមានសេចក្ដីត្រូវការដោយជីវិតទេ ដោយយើងត្រូវព្រះជនិន្ទប្រទានដល់ព្រាហ្មណ៍ អ្នកស្វែងរកទ្រព្យជាមនុស្សកំណាចលើសលន់ វាយដំយើងដូចជាគេវាយហ្វូងគោ ។ នែនាងកណ្ហា ពួករុក្ខជាតិផ្សេងៗនេះ គឺដើមព្រីងឈើទាលខ្សាច់ មានមែកត្រសុំត្រសាយ យើងនឹងបោះបង់រុក្ខជាតិទាំងនោះ នែនាងកណ្ហា ពួកផលជាតិផ្សេងៗនេះ គឺពោធិ៍ ខ្នុរ ជ្រៃ ក្រសាំង យើងនឹងបោះបង់ផលជាតិទាំងនោះ ។ ហៃនាងកណ្ហា នេះសួនច្បារ នេះស្ទឹងមានទឹកត្រជាក់ ពីដើមយើងលេងក្នុងទីណាយើងនឹងបោះបង់ទីទាំងនោះ ហៃនាងកណ្ហា ពីដើមយើងទ្រទ្រង់ផ្កាទាំងឡាយណាផ្សេងៗលើភ្នំនេះ យើងនឹងបោះបង់ផ្កាទាំងនោះ ។ ហៃនាងកណ្ហា ពីដើមយើងបរិភោគផ្លែ

ឈើផ្សេងៗទាំងឡាយណា យើងនឹងបោះបង់ផ្លែឈើទាំងនោះ ។ ហៃនាងកណ្ហា នេះរូបដំរី រូបសេះរបស់យើង នេះរូបគោរបស់យើង ជារូបដែលយើងធ្លាប់លេង យើងនឹងបោះបង់រូបនោះដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យស្ស** សេចក្តីថា មាតារបស់ខ្លួនមិនមានក្នុងសម្នាក់នៃបុគ្គលណា ។

ជូជកព្រាហ្មណ៍ភ្ញាត់ដួលក្នុងទីមិនរាបស្មើមួយកន្លែងទៀត វល្លិដែលចងក៏របូតចេញអំពីដៃរាជកុមារកុមារី កុមារទាំង ២ មានការញ័រចំប្រប់ ដូចមាន់ដែលត្រូវវាយរត់មករកព្រះរាជបិតាដោយរហ័សព្រមគ្នា ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសួធ្យសានូវព្រះគាថាដូច្នេះថា

កុមារទាំងពីរនោះ គឺជាលីនិងកណ្ហាជិនា កាលដែលព្រាហ្មណ៍កំពុងនាំទៅក៏របូតចេញ ( អំពីចំណង ) ហើយនាំគ្នាស្ទុះចូលទៅក្នុងទីនោះក្នុងខណៈនោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តេន តេន** សេចក្តីថា បានរត់ទៅរកព្រះ-រាជបិតារបស់គេទាំង ២ ខណៈដែលរួចផុតអំពីជូជកព្រាហ្មណ៍ អធិប្បាយថា រត់មកកាន់សម្នាក់រាជបិតានោះឯង ។

ឯជូជកក្រោកឡើងដោយរហ័សកាន់វល្លិនិងឈើច្រត់ពោរពេញទៅដោយ

សេចក្ដីក្រោធ ដូចភ្លើងប្រល័យកប្បដូច្នោះ មកហើយពោលថា ក្មេងទាំង ២ ប៉ិនប្រសប់ក្នុងការរត់ពន់ពេក ចងដៃទាំង ២ ហើយនាំកុមារកុមារី ទៅម្ដងទៀត ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** វីអាចិធមិឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូច្យសានូវព្រះគាថាដូច្នេះថា

លំដាប់នោះជូជកព្រាហ្មណ៍នោះ កាន់យកខ្សែនិងឈើច្រត់វាយ

ដំកុមារទាំងពីរនោះ ហើយនាំទៅក្នុងទីចំពោះព្រះភក្ត្រនៃព្រះបាទ

សិវិ ( វេស្សន្តរ ) ដូច្នេះ ។

កាលជលីនិងកណ្ហាជិនាត្រូវជូជកនាំទៅយ៉ាងនេះ កណ្ហាជិនាបែរមកទតព្រះបិតាហើយទូលព្រះរាជបិតា ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** វីអាចិធមិឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូច្យសានូវព្រះគាថាដូច្នេះថា

នាងកណ្ហាជិនា បានពោលនឹងព្រះបិតានោះថា បពិត្រព្រះបិតា

ព្រាហ្មណ៍នេះវាយដំខ្ញុំម្ចាស់ដោយឈើច្រត់ ដូចជាទាសីដែល

កើតក្នុងផ្ទះ ។ បពិត្រព្រះបិតា នេះមិនមែនជាព្រាហ្មណ៍ទេដ្បិត

ពួកព្រាហ្មណ៍ជាអ្នកប្រកបដោយធមិ បពិត្រព្រះបិតា យក្ស

ក្លែងភេទជាព្រាហ្មណ៍នាំយើងខ្ញុំយកទៅស៊ីទេដឹង បពិត្រព្រះបិតា

យើងខ្ញុំត្រូវបិសាចកំពុងនាំទៅ ហេតុអ្វីក៏ព្រះអង្គទ្រង់ទតព្រងើយ
ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **តំ** បានដល់ ព្រះបាទសិវិរាជដែលជាព្រះជនក កំពុងប្រថាប់គង់ទតនោះ ។ បទថា **ធាសិយំ** គឺ **ធាសិកំ** (ទាសៈ) ។ បទថា **ខាទិតុំ** បានដល់ ដើម្បីទំពាស៊ី កណ្ហាជិនារាជកុមារីខ្សឹកខ្សួលថា បពិត្រព្រះបិតា តាព្រាហ្មណ៍នេះមានភ្នែកទាំងគូក្រហមដូចមានឈាមហូរ នាំខ្ញុំទាំង ២ នាក់បងប្អូនទៅមិនទាន់ដល់ប្រកក្នុំឡើយនឹងទំពាស៊ី គឺនាំទៅដោយបំណងថា នឹងទំពាស៊ីទាំងអស់ ទ្រង់ឃើញខ្ញុំ ២ នាក់បងប្អូនត្រូវនាំទៅដើម្បីទំពាស៊ី ឬដើម្បីស្ងោរ សូមទ្រង់មានសេចក្ដីសុខគ្រប់កាលចុះ ។

កាលកណ្ហាជិនារាជកុមារីពិលាបរៀបរាប់យាងទៅ ព្រះវេស្សន្តរមហាសត្វទ្រង់មានសេចក្ដីសោកជាកម្លាំង មានបេះដូងក្ដៅ កាលព្រះនាសៈមិនល្មមក្នុងការដកដង្ហើមក៏ត្រូវបញ្ចេញខ្យល់តាមព្រះឱស្ឋ ទឹកភ្នែកដូចតំណក់ឈាមបានហូរចេញអំពីព្រះនេត្រទាំង ២ ព្រះវេស្សន្តរមហាសត្វ ទ្រង់ត្រិះរិះយ៉ាងនេះថា ទុក្ខបែបនេះកើតព្រោះទោសនៃសេចក្ដីស្នេហាមិនមែនព្រោះហេតុដទៃឡើយ ព្រោះដូច្នោះអញគួរជាបុគ្គលមានចិត្តមាំទាំ ដាក់អារម្មណ៍ជាកណ្ដាលកុំធ្វើសេចក្ដីស្នេហា ទ្រង់ត្រិះរិះដូច្នេះហើយ ទ្រង់បន្ទោបង់នូវការសោកសៅបែបនោះចោលដោយកម្លាំងញាណរបស់ព្រះអង្គ គង់ប្រថាប់ដោយអាការជាប្រក្រតី ។

កណ្ហាជិនារាជកុមារីដល់ប្រកក្នុំ នាងពិលាបរៀបរាប់បណ្ដើរ យាងទៅ

បណ្តីរថា

ជើងទាំងឡាយរបស់យើងខ្ញុំនេះ ក៏សែនលំបាក ផ្លូវសោតក៏ឆ្ងាយដាច់ស្រយាល លំបាកនឹងដើរទៅណាស់ ព្រះសុរិយាក៏កាន់តែទន់ទាបជិតអស្តង្គតណាស់ហើយ ព្រាហ្មណ៍ក៏នាំយើងខ្ញុំទៅប្រញាប់ប្រញាល់ ។ យើងខ្ញុំសូមថ្វាយបង្គំនូវពួកភូតដែលនៅអាស្រ័យលើភ្នំនិងព្រៃ សូមថ្វាយបង្គំដោយសិរសានូវពួកទេវតាដែលរក្សាស្រះនិងទេវតាដែលនៅអាស្រ័យក្នុងស្ទឹងមានកំពង់ដ៏ល្អ ។ ( យើងខ្ញុំសូមថ្វាយបង្គំ ) នូវពួកទេវតាដែលនៅអាស្រ័យលើស្មៅនិងវល្លិ និងឈើឱសថ និងភ្នំ និងព្រៃសូមទេវតាទាំងឡាយ ទូលព្រះមាតានូវភាពរបស់យើងខ្ញុំជាអ្នកមិនមានរោគ ដ្បិតព្រាហ្មណ៍នេះកំពុងនាំយកយើងខ្ញុំទៅ ។ សូមពួកលោកដ៏ចម្រើន ទូលដល់ព្រះមទ្រីជាព្រះមាតារបស់យើងខ្ញុំថា បើលោកចង់អញ្ជើញមកតាមយើងខ្ញុំ គប្បីអញ្ជើញមកឲ្យឆាប់ ។ ផ្លូវនេះដើរចុះតែជើងមួយ ត្រង់ទៅកាន់អាស្រម ព្រះមាតាគប្បីស្តេចអញ្ជើញមកតាមផ្លូវនោះឯង មុខជានឹងឃើញយើងខ្ញុំភ្លាម ។ បពិត្រព្រះមាតាដ៏មានជដាអើយ ទុក្ខនោះនឹងមានដល់លោកដែលនាំមើមឈើនិងផ្លែឈើអំពីព្រៃមក ព្រោះឃើញអាស្រមស្ងាត់ជ្រងំ ។ ព្រះមាតាបាន ( មើមឈើនិងផ្លែឈើអំពីព្រៃនិងចំណី ) ច្រើន ដោយការស្វែងរកហួសវេលា

មិនជ្រាបយើងខ្ញុំដែលព្រាហ្មណ៍ អ្នកស្វែងរកទ្រព្យ កំណាច លើសលន់ ចងវាយដំយើងខ្ញុំដូចជាគេវាយហ្វូងគោ ថ្ងៃនេះ យើងខ្ញុំសូមចួបនឹងព្រះមាតា ដែលអញ្ជើញមកអំពីការស្វែងរក ផ្លែឈើក្នុងវេលាល្ងាច ។ ព្រះមាតាគប្បីប្រទានផ្លែឈើលាយ ដោយទឹកឃ្មុំដល់ព្រាហ្មណ៍ៗនេះបានបរិភោគផ្លែឈើនោះឆ្អែត ហើយមុខជាមិនបង្ខំនាំយើងខ្ញុំទៅ ។ កុមារទាំងពីរមានសេចក្តី ជាប់ចិត្តក្នុងព្រះមាតា ពិលាបក្នុងកាលនោះថា ឱហ្ន៎ បាតជើង ទាំងឡាយរបស់យើងពុះពងអស់ហើយ ព្រាហ្មណ៍ដឹកនាំយើង ទៅប្រញាប់ប្រញាល់ខ្លាំងណាស់ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ធានកា** បានដល់ ជើងតូចៗ ។ បទថា **ឱកន្ទាម្ហសេ** បានដល់ ខ្សឹកខ្សួល ។ ខ្ញុំ ២ នាក់បងប្អូន សូមសម្តែងនូវការ រាប់អាន គឺការប្រព្រឹត្តឱនលំទោនឲ្យជ្រាប ។ បទថា **សរស្ស** សេចក្តីថា សូម ក្រាបថ្វាយបង្គំពួកទេវតា គឺត្រកូលនាគដែលរក្សាស្រះឈូកនេះដោយសិរសា គឺត្បូង ។ បទថា **សុបតិត្ថេ ច អាបកេ** សេចក្តីថា សូមក្រាបថ្វាយបង្គំដល់ ទេវតាដែលស្ថិតនៅក្នុងស្ទឹង ដែលមានកំពង់ល្អ ។ បទថា **តិណាលតានិ** បានដល់ តិណជាតិនិងលតាជាតិដែលសំយុងចុះ ។ បទថា **ឱសធ្យោ** បាន ដល់ ព្រឹក្សជាតិដែលជាឱសថ ។ កណ្ហាជិនាកុមារីត្រាស់យ៉ាងនេះសំដៅដល់ ពួកទេវតាដែលស្ថិតនៅក្នុងទីទាំងពួង ។ បទថា **អនុប្បតិតុកាមា** សេចក្តី ថា បើមាតានោះមានបំណងនឹងយាងមក តាមស្នាមជើងរបស់ខ្ញុំទាំង ២ ។

បទថា **អបិ បស្សេសិ នោ លហុំ** សេចក្តីថា លោកទាំងឡាយ គប្បីប្រាប់យ៉ាងនេះថា បើមាតាយាងមកតាមផ្លូវដែលអាចដើរបានតែម្នាក់នោះក៏នឹងបានជួបកូនតូចទាំង ២ របស់ទ្រង់ ។ កណ្ហាជិនារាជកុមារី ហៅព្រះមាតាដោយពាក្យកំបាំងមុខថា **យដិនី** ដូច្នេះ ។ បទថា **អតិវេលំ** បានដល់ ធ្វើឲ្យលើសប្រមាណ ។ បទថា **ឧញ្ឆា** បានដល់ បានមកដោយការស្វែងរក ។ បទថា **ផលំ** បានដល់ មើមឈើផ្លែឈើតូចធំក្នុងព្រៃ ។ បទថា **ខុទ្ទេន មិស្សកំ** បានដល់ លាយដោយទឹកឃ្មុំបន្តិចបន្តួច ។ បទថា **អាសិតោ** បានដល់ បានស៊ីគឺបរិភោគផ្លែឈើហើយ ។ បទថា **ធាតោ** បានដល់ ឆ្អែតស្កប់ស្កល់ហើយ ។ បទថា **ន ពាឡ្ហំ តរយេយ្យ** សេចក្តីថា មិនគប្បីនាំទៅដោយភាពរហ័ស ។ បទថា **មាតុគិទ្ធិនោ** សេចក្តីថា ជាលីនិងកណ្ហាជិនា ប្រកបដោយសេចក្តីស្រឡាញ់ក្នុងមាតាមាននូវសេចក្តីស្នេហាជាកម្លាំងទើបយំរៀបរាប់យ៉ាងនេះ ។

**ទារកបព្វៈ ចប់**

# មទ្រីបព្វៈ

*ក្នុងកាលព្រះវេស្សន្តររាជឥសី ទ្រង់បរិច្ចាគបិយបុត្តមហាទានដល់ព្រាហ្មណ៍ ក៏កើតអស្ចារ្យ មហាប្រឹថពីបន្លឺសំឡេងជាកោលាហលតែមួយ រហូតដល់ព្រហ្មលោក ពួកទេវតាដែលនៅក្នុងហិមវន្តប្បទេស ហាក់បីដូចមានហទយៈបែកធ្លាយ ព្រោះបានឮសំឡេងរៀបរាប់នៃជាលីរាជកុមារ និងកណ្ហាជិនារាជកុមារីដែលជូជកព្រាហ្មណ៍នាំទៅ ប្រឹក្សាគ្នាថា បើនាងមទ្រីយាងមកកាន់អាស្រមដ្ឋានអំពីថ្ងៃ ព្រះនាងមិនឃើញកូនប្រុសស្រីក្នុងអាស្រម ទូលសួរព្រះវេស្សន្តរដឹងថាព្រះរាជទានដល់ជូជកព្រាហ្មណ៍ទៅហើយ ព្រះនាងនឹងរត់តាមដោយសេចក្ដីស្នេហាជាកម្លាំងគប្បីសោយនូវទុក្ខធំ ។*

*លំដាប់នោះទេវតាទាំងនោះក៏ចាត់ទេវបុត្ត ៣ អង្គដោយពាក្យថា អ្នកទាំង ៣ ចូរកាឡាខ្លួនជារាជសីហ៍ ខ្លាធំនិងខ្លាដំបង ស្ទាក់ផ្លូវព្រះនាងមទ្រី ទោះបីព្រះនាងអង្វរក៏កុំឲ្យចាំព្រះអាទិត្យលិចហើយគប្បីថែរក្សាឲ្យល្អ កុំឲ្យរាជសីហ៍ជាដើមបៀតបៀនព្រះនាងបាន រហូតដល់នាងយាងដល់អាស្រមដោយពន្លឺព្រះចន្ទ ។*

**តមត្ថំ បកាសេន្តោ សត្ថា អាហ** *រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសានូវព្រះគាថាដូច្នេះថា*

*ពួកទេវតាបានឮពិលាបនៃកុមារទាំងពីរនោះហើយ បានពោលពាក្យនេះថា អ្នកទាំងឡាយចូរធ្វើជាម្រឹគសាហាវបីក្នុងព្រៃ គឺ*

សីហៈ ១ ខ្លាធំ ១ ខ្លាដំបង ១ ។ កុំឲ្យព្រះរាជបុត្រីមកអំពីការ ស្វែងរកផ្លែឈើក្នុងវេលារសៀលឡើយ កុំឲ្យពួកម្រឹគក្នុងព្រៃ ជាដែនរបស់យើងបៀតបៀនឡើយ ។ ប្រសិនបើសីហៈក្តី ខ្លាធំ ក្តី ខ្លាដំបងក្តីបៀតបៀននាងមទ្រី ដែលប្រកបដោយលក្ខណា នោះហើយ ជាលីកុមារនិងនាងកណ្ហាជិនា នឹងរស់នៅដូចម្តេច បាន នាងមទ្រីដែលប្រកបដោយលក្ខណានឹងព្រាត់ប្រាសចាក ចំណែកទាំងពីរ គឺកស្តានិងបុត្តទាំងពីរ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឥធំ វចនមព្រុំ** សេចក្តីថា ទេវតាទាំងនោះ បានពោលពាក្យនេះនឹងទេវបុត្តទាំង ៣ ថា អ្នកទាំង ៣ ចូរកាឡាខ្លួនជាម្រឹគ កាចក្នុងព្រៃ គឺរាជសីហ៍ ១ ខ្លាធំ ១ ខ្លាដំបង ១ ។ បទថា **មា ហោវ នោ** សេចក្តីថា ទេវតាទាំងឡាយពោលថា ព្រះនាងមទ្រីរាជបុត្រីមិនគប្បីត្រឡប់ មកពីស្វែងរកផ្លែឈើ ក្នុងវេលាល្ងាចឡើយ ចូរយាងមកក្នុងពេលព្រលប់ អាស្រ័យពន្លឺព្រះចន្ទ ។ បទថា **មា ហោវម្ហាក និក្ខោគេ** សេចក្តីថា ទេវតា ទាំងឡាយពោលថា ពាឡម្រឹគណាមួយក្នុងព្រៃដែលជាដែន គឺដែនរបស់ពួក យើង កុំបីបានបៀតបៀនព្រះនាងក្នុងព្រៃរបស់ពួកយើងឡើយ ពួកលោកចូរ រក្សាព្រះនាងមទ្រីកុំឲ្យសត្វសាហាវទាំងឡាយបៀតបៀនព្រះនាងបាន ។ បទ ថា **សីហោ ចេ ឆំ** សេចក្តីថា បើសត្វកាចណាមួយ មានរាជសីហ៍ជាដើម គប្បីបៀតបៀនព្រះនាងមទ្រី ដែលមិនមានការរក្សា កាលព្រះនាងមទ្រីអស់ ជីវិត ជាលីរាជកុមារមិនគប្បីមានជីវិត កណ្ហាជិនារាជកុមារីនឹងមានជីវិតមក

អំពីណា ព្រះនាងដល់ព្រមដោយលក្ខណៈនោះ គប្បីវិនាសចាកកូនជាទីស្រឡាញ់ទាំង ២ នោះឯង ។ បទថា **បតិបុត្តេ ច** សេចក្តីថា ព្រះនាងមទ្រីគប្បីសាបសូន្យចាកចំណែកទាំង ២ គឺប្តីនិងកូន ព្រោះដូច្នោះអ្នកទាំង ៣ ចូររក្សាឲ្យល្អ ។

កាលនោះទេវបុត្តទាំង ៣ ទទួលពាក្យរបស់ទេវតាទាំងនោះថា សាធុ ហើយកាឡាខ្លួនជារាជសីហ៍ ខ្លាធំ ខ្លាដំបង មកដេកតម្រៀបគ្នាក្នុងផ្លូវដែលព្រះនាងមទ្រីយាងមក ។ ចំណែកព្រះនាងមទ្រីចំបែងក្នុងព្រះហឫទ័យថា ថ្ងៃនេះអញយល់សប្តិអាក្រក់ អញនឹងរកផ្លែឈើក្នុងព្រៃហើយត្រឡប់មកអំពីថ្ងៃ ពិចារណាមើលផ្លែឈើទាំងឡាយ ។ លំដាប់នោះក៏កើតប្រផ្នូលអាក្រក់ ជន្ទីកក៏ធ្លាក់អំពីដៃ ដងវែកក៏ជ្រុះអំពីស្មា ព្រះនេត្រឆ្វេងរកាំ ព្រះនេត្រស្តាំក៏កម្រើក ព្រឹក្សាទាំងឡាយដែលធ្លាប់តែមានផ្លែ ក៏មិនមានផ្លែ ព្រឹក្សាដែលមិនធ្លាប់មានផ្លែក៏ប្រាកដជាមានផ្លែ ទិសទាំងពួងក៏មិនប្រាកដ ។ ព្រះនាងមទ្រីពិចារណាថា នេះជាអ្វីហ្ន៎មិនធ្លាប់មានអំពីមុន ថ្ងៃនេះហេតុការណ៍អ្វីនឹងមានដល់អញ ដល់កូនទាំងទ្វេរបស់អញឬដល់ព្រះវេស្សន្តររាជស្វាមីទេដឹងហ្ន៎ ព្រះនាងគិតហើយក៏ត្រាស់ថា

ជន្ទីកធ្លាក់ចុះ ( អំពីដៃ ) របស់អញ ភ្នែកស្តាំក៏កម្រើក ទាំងដើមឈើមានផ្លែក៏ប្រែជាមិនមានផ្លែ អញវង្វេងទិសទាំងអស់ ។ កាលដែលអញនោះមកកាន់អាស្រមក្នុងវេលាល្ងាច ក្នុងពេលដែលព្រះអាទិត្យអស្តង្គតហើយក៏មានពួកម្រឹគសាហាវមកឈរ

រាំងក្នុងផ្លូវ កាលបើព្រះអាទិត្យទៀបអស្តង្គតហើយអាស្រមក៏នៅឆ្ងាយណាស់ អញនឹងនាំយកមើមឈើនិងផ្លែឈើណាអំពីទីនេះដើម្បីជនទាំងនោះ ជនទាំងនោះ គប្បីនាំគ្នាបរិភោគមើមឈើនិងផ្លែឈើនោះជាភោជន ។ ក្សត្រិយ៍នោះគង់នៅតែមួយអង្គឯងក្នុងបណ្ណសាលាពិត ម៉្លេះសមឃើញអាត្មាអញដែលមិនទាន់មកដល់ ក៏ខំលួងលោមទារកទាំងពីរ ដែលមានសេចក្តីស្រេកឃ្លាន ។ កូនតូចទាំងនោះរបស់អញជាស្ត្រីកំព្រា កម្សត់ដោយពិត នៅអង្គុយ ( ចាំមើលផ្លូវ ) ដូចកូនម្រឹគនៅជៅទឹកដោះក្នុងវេលាល្ងាចឬក្នុងវេលាដែលបរិភោគ ។ កូនតូចទាំងនោះរបស់អញជាស្ត្រីកំព្រា កម្សត់ដោយពិត នៅអង្គុយ ( ចាំមើលផ្លូវ ) ដូចកូនម្រឹគប្រាថ្នារកទឹកផឹកក្នុងវេលាល្ងាច ឬក្នុងវេលាដែលបរិភោគ ។ កូនតូចទាំងនោះរបស់អញ ជាស្ត្រីកំព្រាកម្សត់ដោយពិត នាំគ្នាឈរចាំទទួលអញដូចជាពួកកូនគោតូចឈរចាំទទួលមេ ។ កូនតូចទាំងនោះរបស់អញ ជាស្ត្រីកំព្រាកម្សត់ដោយពិត នាំគ្នាឈរចាំទទួលអញដូចជាពួកហង្សឈរនៅលើភក់ ។ កូនតូចទាំងនោះរបស់អញជាស្ត្រីកំព្រា កម្សត់ដោយពិត នាំគ្នាឈរចាំទទួលអញក្នុងទីមិនឆ្ងាយអំពីអាស្រម ។ ផ្លូវតែមួយចុះបានតែជើងនៃបុគ្គលម្នាក់ ក្បែរខាងផ្លូវមានស្រះមានជ្រោះ អញមិនឃើញផ្លូវដទៃសម្រាប់ទៅកាន់អាស្រមបាន

ទេ ។ បពិត្រម្រឹគទាំងឡាយ ខ្ញុំសូមថ្វាយបង្គំលោកទាំងឡាយ ជាស្តេចមានកម្លាំងច្រើនក្នុងព្រៃធំ សូមលោកជាបងប្អូននឹងគ្នា ដោយធម៌ លោកទាំងឡាយកាលបើខ្ញុំអង្វរហើយ ក៏សូមឲ្យផ្លូវដល់ខ្ញុំ ។ ខ្ញុំជាភរិយារបស់ព្រះរាជបុត្តដ៏មានសិរី ដែលគេនិរទេស ខ្ញុំមិនហ៊ានមើលងាយព្រះរាជស្វាមីនោះ ដូចនាងសិតាជាស្ត្រីមានវត្តមិនហ៊ានមើលងាយព្រះរាម ។ លោកទាំងឡាយចូរឃើញបុត្តទាំងឡាយចុះ ចំណែកខ្ញុំសូមឃើញស្វាមីនិងបុត្តទាំងពីរ គឺជាលីនិងកណ្ហាជិនាក្នុងពេលល្ងាច គឺកាលជាទីទទួលចំណី ។ មើមឈើនិងផ្លែឈើនេះសោតក៏ច្រើន ចំណីនេះមិនមែនតិចទេ ខ្ញុំនឹងបែងចំណីនោះពាក់កណ្តាលជូនលោកទាំងឡាយ កាលបើខ្ញុំអង្វរហើយសូមឲ្យផ្លូវខ្ញុំ ។ ព្រះមាតារបស់យើងជាព្រះរាជបុត្រី ព្រះបិតារបស់យើងជាព្រះរាជបុត្រា លោកទាំងឡាយចូរជាបងប្អូនដោយធម៌ លោកទាំងឡាយកាលបើខ្ញុំអង្វរហើយ សូមឲ្យផ្លូវខ្ញុំ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តស្សា** បានដល់ កាលយើងនោះ ។ បទថា **អស្សមាគមនំ បតិ** សេចក្តីថា ត្រឡប់មកសំដៅចំពោះអាស្រម ។ បទថា **ឧបដ្ឋហុំ** បានដល់ ប្រាកដឡើង បានឮថា សត្វទាំង ៣ នោះដេករៀងគ្នា ពេលព្រះនាងមទ្រីយាងមកទើបក្រោកឡើងពត់ខ្លួន ពត់ប្រាណហើយរាំងផ្លូវឈរតម្រៀបគ្នា ។ បទថា **យញ្ច តេសំ** សេចក្តីថា ជនទាំង ៣ នោះ

គឺព្រះវេស្សន្តរនិងកូនតូចទាំង ២ របស់ព្រះអង្គ គប្បីបរិភោគមើមឈើ ផ្លែឈើដែលខ្ញុំនាំទៅអំពីព្រៃនេះដើម្បីជនទាំងនេះ ភោជនីយាហារដទៃមិនមានដល់ជនទាំងនោះឡើយ ។ បទថា **អជាយតី** សេចក្តីថា ព្រះវេស្សន្តរជ្រាបថា ខ្ញុំមិនទាន់ត្រឡប់មក ទ្រង់នោះឯងនឹងអង្គុយលួងកូនទាំង ២ ពិត ។ បទថា **សំវេសនាកាលេ** បានដល់ ក្នុងពេលដែលខ្លួនឲ្យបរិភោគអាហារ ឲ្យផឹកទឹកក្នុងថ្ងៃដទៃៗ ។ បទថា **ខីរបីតាវ** សេចក្តីថា ព្រះនាងមទ្រីត្រាស់ថា កូនតូចរបស់ម្រឹគដែលមិនទាន់ដាច់ដោះរមែងយំព្រោះស្រេកទឹកដោះ កាលមិនបានទឹកដោះក៏យំរហូតដេកលក់ទៅយ៉ាងណា កូនតូចនៃខ្ញុំទាំង ២ យំចង់បានផ្លែឈើ កាលមិនបានផ្លែឈើក៏យំរហូតដេកលក់យ៉ាងនោះ ។ បទថា **វារិបីតាវ** សេចក្តីថា គប្បីឃើញអត្ថដោយន័យនេះថា ដូចកូនម្រឹគតូចស្រេកយំព្រោះស្រេកទឹក កាលមិនបានទឹកក៏យំរហូតដេកលក់ទៅយ៉ាងណា ក្នុងអាស្រមបទកូនតូចរបស់ខ្ញុំក៏យ៉ាងនោះ ។ បទថា **អច្ចរេ** បានដល់ នឹងរង់ចាំ ។ បទថា **បច្ចុគ្គតា មំ តិដ្ឋន្តិ** សេចក្តីថា ឈររង់ចាំទទួលខ្ញុំ បាឋៈថា **បច្ចុគ្គតុំ** ដូច្នេះក៏មាន ។ បទថា **ឯកាយនោ** បានដល់ ជាទីទៅនៃបុគ្គលម្នាក់ប៉ុណ្ណោះ គឺជាផ្លូវដើរបានតែម្នាក់ ។ បទថា **ឯកបថោ** សេចក្តីថា ផ្លូវនោះចំពោះបុគ្គលម្នាក់ប៉ុណ្ណោះ ដើរទន្ទឹមគ្នាមិនបាន គឺមិនអាចឈានទៅបានឡើយព្រោះហេតុអ្វី ព្រោះមានស្រះរណ្តៅជ្រៅនៅក្បែរផ្លូវ ។ បទថា **ឧមត្តុ** សេចក្តីថា ព្រះនាងមទ្រីទតមិនឃើញផ្លូវដទៃ គិតថាអញនឹងអង្វរសត្វទាំង ៣ នេះ ឲ្យជួយអញត្រឡប់ទៅបាន ទើបដោះអំរែកផ្លែឈើអំពីស្មា ផ្គងអញ្ជលីនមស្ការ

យ៉ាងនេះ ។ បទថា **ភាតរោ** សេចក្តីថា ពួកយើងជាកូនរបស់ស្តេចមនុស្ស សូម្បីពួកអ្នកក៏ជាកូនរបស់ស្តេចម្រឹគ ដូច្នោះពួកយើងចូរជាបងប្អូនដោយធម៌នឹងគ្នាចុះ ។ បទថា **អវរុទ្ធស្ស** បានដល់ ត្រូវនិរទេសចាកដែន ។ បទថា **រាមំ សីតាវនុព្វតា** សេចក្តីថា ព្រះនាងមទ្រីពោលថា ព្រះទេវីឈ្មោះសិតាដែលជាប្អូនស្រីរបស់ព្រះរាម ជាអគ្គមហេសីរបស់ព្រះរាមនោះឯង ជាអ្នកបដិបត្តិតាមព្រះរាម គឺគោរពកោតក្រែងព្រះរាមដែលជាស្វាមីដូចទេវតា ជាបុគ្គលមិនប្រមាទ បម្រើព្រះរាមរាជឱរសរបស់ព្រះបាទទសរថមហារាជយ៉ាងណា ខ្ញុំក៏ជាអ្នកមិនប្រមាទបម្រើព្រះវេស្សន្តរយ៉ាងនោះ ។ បទថា **តុម្ហេ ច** សេចក្តីថា ព្រះនាងមទ្រីអង្វរថា សូមអ្នកទាំងឡាយ ឲ្យផ្លូវដល់ខ្ញុំហើយទៅជួបកូនរបស់អ្នកក្នុងពេលដែលបរិភោគអាហារល្ងាច ឯខ្ញុំក៏ទៅជួបកូនរបស់ខ្ញុំ ចូរអ្នកទាំងឡាយឲ្យផ្លូវចុះ ។

កាលនោះ ទេវបុត្តទាំង ៣ នោះ សម្លឹងមើលពេលក៏ដឹងថា ឥឡូវនេះជាកាលគួរឲ្យផ្លូវដល់ព្រះនាងហើយ ក៏ក្រោកឡើងចៀសចេញទៅ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** វីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសាទូវព្រះគាថាដូច្នេះថា

> ពួកម្រឹគសាហាវ បានស្តាប់វាចាពីរោះពិសា ជាវាចាប្រកប
> ដោយសេចក្តីករុណាច្រើនរបស់នាងមទ្រីនោះ ដែលកំពុងល្ហួង
> លោមហើយក៏នាំគ្នាថយចេញអំពីផ្លូវបាត់ទៅ ដូច្នេះ ។

បណ្ដាបទទាំងនោះបទថា **ឆេលបតឹ** សេចក្ដីថា វាចាផ្អែមល្អែម ពីរោះ មិនមានទោស គឺប្រាសចាកទោស ។

កាលពាឡម្រឹគទាំង ៣ អន្តរធានទៅហើយព្រះនាងមទ្រីក៏យាងទៅដល់អាស្រម ក្នុងកាលនោះជាថ្ងៃពេញបូណ៌មីឧបោសថ ១៥ កើត ព្រះនាងយាងទៅដល់ខាងចុងទីចង្ក្រមមិនឃើញកូនសម្លាញ់ទាំង ២ ដែលធ្លាប់ឃើញក្នុងទីនោះៗទើបត្រាស់ថា

កូនតូចទាំងពីរប្រឡាក់ដោយអាចម៍ដី រមែងឈរចាំទទួលអញក្នុងប្រទេសនេះដូចជាពួកកូនគោឈរចាំទទួលមេ ។ កូនតូចទាំងពីរប្រឡាក់ដោយអាចម៍ដី រមែងឈរចាំទទួលអញក្នុងប្រទេសនេះដូចជាពួកហង្សឈរនៅលើភក់ ។ កូនតូចទាំងពីរប្រឡាក់ដោយអាចម៍ដី រមែងឈរចាំទទួលអញក្នុងប្រទេសនេះ ក្នុងទីជិតអាស្រម ។ កូនតូចទាំងនោះធ្លាប់តែស្ទុះមកព័ទ្ធជុំវិញមានសេចក្ដីត្រេកអររីករាយនាំគ្នាលោតមក ហាក់ដូចជា ( ញុំាងហឫទ័យរបស់មាតា ) ឲ្យកម្រើកដូចកូនម្រឹគទាំងឡាយ ( ឃើញមេ ) ហើយដំឡើងស្លឹកត្រចៀក ( អើតកចូលទៅជិតមេរីករាយត្រេកអរស្ទុះទៅព័ទ្ធជុំវិញ ) ថ្ងៃនេះអញមិនបានឃើញកូនទាំងពីរ គឺជាលីនិងនាងកណ្ហាជិនានោះ ។ អញលះបង់កូនទាំងពីរហើយចេញទៅ ដូចមេពពែឬមេម្រឹគលះបង់កូន ដូចមេបក្សីចេញអំពី ( សម្បុក ) ឬដូចមេសីហៈប្រាថ្នាសាច់

( លះបង់កូនរបស់ខ្លួនដើរចេញទៅរកចំណី ) ថ្ងៃនេះអញមិនបានឃើញកូនទាំងពីរ គឺជាលីនិងនាងកណ្ហាជិនានោះ ។ នេះស្នាមជើងនៃកូនទាំងនោះដូច ( ស្នាមជើង ) នៃហ្វូងដំរីក្បែរភ្នំពំនូកខ្សាច់ដែលកូនទាំងពីរនាំគ្នាពូន ក៏ខ្ចាត់ខ្ចាយក្នុងទីជិតនៃអាស្រម ថ្ងៃនេះអញមិនបានឃើញកូនទាំងពីរ គឺជាលីនិងនាងកណ្ហាជិនានោះ ។ កូនតូចទាំងពីររោយរាយដោយខ្សាច់ប្រឡាក់ដោយអាចម៍ដីរ មែងស្ទុះមកព័ទ្ធជុំវិញ អញមិនបានឃើញទារកទាំងនោះ ។ កាលពីដើមកូនទាំងពីរណាទទួលអញដែលមកអំពីព្រៃឆ្ងាយ ថ្ងៃនេះអញមិនបានឃើញកូនទាំងពីរនោះ គឺជាលីនិងនាងកណ្ហាជិនា ។ ទារកទាំងពីរ តែងរមិលមើលផ្លូវអញក្នុងទីឆ្ងាយ ដូចកូនម្រឹគទទួលមេពពែឬម្រឹគជាមេ ។ ផ្លែព្នៅលឿងខ្ចីដែលជ្រុះមកនេះឯង ជាល្បែងរបស់ទារកទាំងនោះ ថ្ងៃនេះអញមិនបានឃើញកូនទាំងពីរ គឺជាលីនិងនាងកណ្ហាជិនានោះ ។ ស្តនរបស់អញទាំងពីរនេះពេញ ( ដោយទឹកដោះ ) ទាំងទ្រូងសោត ក៏ស្ទើរតែនឹងធ្លាយ អញមិនបានឃើញកូនទាំងពីរ គឺជាលីនិងនាងកណ្ហាជិនានោះ ។ កូនមួយរាវរកផ្លែឈើក្នុងថ្នក់របស់អញកូនមួយតោងដោះទាំងគូរបស់អញ ថ្ងៃនេះអញមិនបានឃើញកូនទាំងពីរ គឺជាលីនិងនាងកណ្ហាជិនានោះ ។ វេលាថ្ងៃល្ងាច កូនតូចទាំងពីរប្រឡាក់ដោយអាចម៍ដី នទៀល

លើភ្លៅរបស់អញ អញមិនបានឃើញទារកទាំងនោះ ។ កាលពីដើមអាស្រមនេះប្រាកដដល់អញ ( ដូចជា ) កន្ទែងមហោស្រព ថ្ងៃនេះអាស្រមហាក់ដូចវិលដល់អញ ដែលមិនបានឃើញកូនទាំងនោះ ។ ហេតុដូចម្ដេចបានជាអាស្រមនេះហាក់ដូចជាស្ងាត់សូន្យឈឹង ប្រាកដដល់អញ សូម្បីពួកក្អែកព្រៃក៏មិនកញ្ច្រៀវ ទារកទាំងពីររបស់អញប្រាកដជាស្លាប់ហើយ ។ ហេតុដូចម្ដេចបានជាអាស្រមនេះ ហាក់ដូចជាស្ងាត់សូន្យឈឹង ប្រាកដដល់អញ សូម្បីពួកសត្វហើរក៏មិនកញ្ច្រៀវ ទារកទាំងពីររបស់អញប្រាកដជាស្លាប់ហើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ធំ** ត្រឹមតែជានិបាត ។ បទថា **បំសុកុណ្ឋិតា** បានដល់ ប្រឡាក់ដោយធូលី ។ បទថា **បច្ចុគ្គតា មំ** សេចក្ដីថា រង់ចាំទទួលអញ បាឋៈថា **បច្ចុគ្គន្តុំ** ដូច្នេះក៏មាន សេចក្ដីថា ទទួល ។ បទថា **ឧក្កណ្ណា** សេចក្ដីថា ដូចពួកកូនម្រឹគតូចៗឃើញមេក៏លើកត្រចៀក អើតកចូលទៅរកមេ ត្រេកអររត់លេងដោយជុំវិញ ។ បទថា **វត្តមានាវ កម្បរេ** សេចក្ដីថា ប្រព្រឹត្តទៅហាក់បីដូចញាំងបេះដូងរបស់មេឲ្យត្រេកអរ កាលមុនកូនទាំង ២ របស់អញមានសភាពយ៉ាងនេះ ។ បទថា **ត្យជ្ជ** សេចក្ដីថា ថ្ងៃនេះអញមិនឃើញកូនសម្លាញ់ទាំង ២ នោះ ។ បទថា **ឆកិលីវ មិគី ឆាបំ** សេចក្ដីថា ព្រះនាងមទ្រីពោលថា មេពពែ មេម្រឹគនិងមេបក្សីដែលចេញផុតពីសម្បុក និងមេរាជសីហ៍ដែលចង់បានចំណី លះបង់កូនតូចរបស់ខ្លួនចេញទៅរកចំណី

យ៉ាងណា អញក៏លះបង់កូនទាំង ២ ចេញទៅក៏យ៉ាងនោះ ។ បទថា **ឥទំ នេសំ បទក្កន្តំ** សេចក្តីថា ស្នាមជើងដែលរត់ទៅរត់មកក្នុងទីលេងនៃកូនទាំង ២ នៅប្រាកដនៅឡើយ ដូចស្នាមជើងដំរីត្រង់កំពូលភ្នំក្នុងរដូវវស្សា ។ បទថា **ចិតកា** បានដល់ គំនរខ្សាច់ដែលកូនទាំង ២ ពូកទុក ។ បទថា **បរិកិណ្ណាយោ** បានដល់ ខ្ចាត់ខ្ចាយ ។ បទថា **សមន្តាមភិធាវន្តិ** សេចក្តីថា រត់លេងដោយជុំវិញក្នុងថ្ងៃដទៃៗ ។ បទថា **បច្ចុទេន្តិ** បានដល់ ទទួល ។ បទថា **ទូរមាយតី** បានដល់ ដែលមកអំពីឆ្ងាយ ។ បទថា **ឆគិលីវ មិគី ឆាបា** សេចក្តីថា ឃើញម្តាយរបស់ខ្លួនហើយរត់មករកដូចកូនពពែឃើញមេពពែ កូនម្រឹគឃើញមេម្រឹគ ។ បទថា **ឥទញ្ច នេសំ កីឡនំ** សេចក្តីថា ផ្លែព្នៅមានពណ៌ដូចមាសនេះ ជារបស់លេងនៃកូនទាំង ២ និងរូបដំរីជាដើមរមៀលធ្លាក់ហើយ ។

បទថា **មយ្ហិមេ** សេចក្តីថា ដោះទាំង ២ របស់អញពេញដោយទឹកដោះ ។ បទថា **ឧរោ ច សម្បទាលតិ** សេចក្តីថា តែហទយៈហាក់ដូចជាបែកសញ្ជែក ។ បទថា **ឧច្ចង្គេ មេ វិវត្តន្តិ** សេចក្តីថា បម្រះនទៀលលើភ្លៅរបស់អញ ។ បទថា **សម្មជ្ជោ បដិភាតិ មំ** សេចក្តីថា ប្រាកដដល់អញដូចរោងមហោស្រព ។ បទថា **ត្យជ្ជ** កាត់បទជា **តេ អជ្ជ** ។ បទថា **អបស្សន្តិយា** បានដល់ អញមិនឃើញ ។ បទថា **ភមតេ វិយ** សេចក្តីថា រមែងវិលដូចចក្ររបស់ស្មូនឆ្នាំង ។ បទថា **កាកោលា** បានដល់ ហ្វូងក្អែកព្រៃ ។ បទថា **មតា នូន** សេចក្តីថា នឹងស្លាប់ គឺត្រូវបុគ្គលណាម្នាក់នាំទៅដោយពិត ។ បទ

ថា **សកុណាបិ** បានដល់ ហ្វូងបក្សីដ៏សេស ។ បទថា **មតា ឆួន** សេចក្ដីថា នឹងស្លាប់ដោយពិត ។

ព្រះនាងមទ្រី យំរៀបរាប់ដោយប្រការដូច្នេះ ចូលទៅគាល់ព្រះវេស្សន្តរមហាសត្វ ដាក់ល្អីផ្លែឈើចុះ ឃើញមហាសត្វប្រថាប់គង់ស្ងៀម កាលមិនឃើញព្រះរាជឱរសនិងព្រះរាជធីតាក្នុងសម្នាក់នៃព្រះភស្ដាក៏ទូលសួរថា

ហេតុនេះដូចម្ដេច បានជាព្រះអង្គគង់ស្ងៀម ចិត្តរបស់ខ្ញុំម្ចាស់ហាក់ដូច ( យល់សប្ដិ ) ក្នុងរាត្រី សូម្បីពួកក្អែកព្រៃក៏មិនកញ្ជ្រៀវ ទារកទាំងពីររបស់ខ្ញុំម្ចាស់ប្រាកដជាស្លាប់ហើយ ។ ហេតុដូចម្ដេចបានជាព្រះអង្គគង់ស្ងៀម ចិត្តរបស់ខ្ញុំម្ចាស់ហាក់ដូចជា ( យល់សប្ដិ ) ក្នុងរាត្រីសូម្បីពួកសត្វហើរក៏មិនកញ្ជ្រៀវ ទារកទាំងពីររបស់ខ្ញុំម្ចាស់ប្រាកដជាស្លាប់ហើយ ។ បពិត្រព្រះអយ្យបុត្ត ពួកម្រឹគ ស៊ីទារកទាំងពីររបស់ខ្ញុំម្ចាស់ហើយទេដឹង ឬនរណានាំ យកទារករបស់ខ្ញុំម្ចាស់ទៅក្នុងព្រៃដ៏ស្ងាត់ឥតជាតិជៅ ។ ព្រះអង្គធ្វើទារកទាំងនោះឲ្យជាទូតហើយប្រើទៅឬ ឬក៏ទារកទាំងនោះ ជាអ្នកពោលពាក្យពីរោះ ដេកលក់អស់ហើយ ឬទារកទាំងនោះ ខ្វល់ខ្វាយក្នុងល្បែងទាំងឡាយ ហើយនាំគ្នាចេញទៅខាងក្រៅ ។ សក់ទាំងឡាយក្ដី ដៃជើងទាំងឡាយក្ដីដ៏វិចិត្រដោយបណ្ដាញរបស់ទារកទាំងនោះ ក៏មិនឃើញសោះក្រែងពួកបក្សីធាបនាំយកទៅទេដឹង ឬនរណានាំយកទារករបស់

ខ្ញុំម្ចាស់ទៅ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អបិ រត្តេវ មេ មនោ** សេចក្តីថា អើ ចិត្តរបស់ខ្ញុំដូចឃើញសុបិនក្នុងកាលទៀបភ្លឺ ។ បទថា **មិគា** បានដល់ ពាឡម្រឹគមានរាជសីហ៍ជាដើម ។ បទថា **សរណោ** បានដល់ ប្រាសចាកការត្រេកអរ ។ បទថា **វិរវេ** បានដល់ ស្ងប់ស្ងាត់ ។ បទថា **អាទូតេ** សេចក្តីថា ឬទ្រង់ឲ្យធ្វើជាទូត បញ្ជូនទៅគាល់ព្រះបាទសិវិរាជក្នុងជេតុត្តរនគរ ។ បទថា **អាទូ សុត្តា** សេចក្តីថា យាងចូលផ្ទំក្នុងបណ្ណសាលា ។ បទថា **អាទូ ពហិ នោ** សេចក្តីថា ព្រះនាងមទ្រីទូលសួរថា ឬកូនទាំង ២ របស់ខ្ញុំនោះខ្វល់ខ្វាយក្នុងការលេងចេញទៅខាងក្រៅ ។ បទថា **នេវាសំ កេសា ទិស្សន្តិ** សេចក្តីថា បពិត្រព្រះវេស្សន្តរស្វាមី សក់ដូចផ្កាអញ្ចន់នៃកូនទាំង ២ នោះ មិនប្រាកដឡើយ ដៃនិងជើងមានក្រឡាសំណាញ់ប្រទាក់ក៏មិនប្រាកដ ។ បទថា **សកុណានញ្ច ឱទាតោ** សេចក្តីថា ក្នុងហិមវន្តប្បទេសមានសត្វហត្ថីលិង្គ សត្វទាំងនោះហើរមកឆាបកូនយើងទៅតាមអាកាសនោះឯង ហេតុនោះខ្ញុំសូមសួរទ្រង់ថា កូនទាំង ២ ត្រូវបក្សីទាំងនោះនាំទៅឬ ឬមានបក្សីណាមួយដទៃដែលមានសភាពប្រហែលនិងបក្សីទាំងនោះឆាបយកទៅ សូមទ្រង់ប្រាប់ចុះ កូនទាំង ២ របស់ខ្ញុំអ្នកណាយកទៅ ។

កាលព្រះនាងមទ្រី ក្រាបទូលយ៉ាងនេះហើយ មហាសត្វក៏មិនត្រាស់អ្វីឡើយ លំដាប់នោះព្រះនាងក៏ក្រាបទូលថា បពិត្រព្រះសម្មតិទេព ហេតុអ្វីទ្រង់មិនត្រាស់នឹងខ្ញុំ ខ្ញុំមានកំហុសអ្វី ទូលដូច្នេះហើយត្រាស់ថា

ការដែលព្រះអង្គមិនមានព្រះបន្ទូលនេះជាទុក្ខក្រៃលែង ជាង
ទុក្ខរបស់ខ្ញុំម្ចាស់ ដែលមិនឃើញកូនទាំងពីរ គឺជាលីនិងនាង
កណ្ហាជិនានោះដូចជាដំបៅដែលមុតដោយព្រួញ នេះជាព្រួញទី
ពីរ គឺត្រង់ដែលខ្ញុំម្ចាស់មិនឃើញបុត្តទាំងពីរ ១ ដែលព្រះអង្គ
មិនត្រាស់ប្រាប់ខ្ញុំម្ចាស់ ១ នាំឲ្យកម្រើកហឫទ័យរបស់ខ្ញុំម្ចាស់ ។
បពិត្រព្រះរាជបុត្ត បើព្រះអង្គមិនត្រាស់ប្រាប់ដល់ខ្ញុំម្ចាស់អស់
រាត្រីនេះក្នុងថ្ងៃនេះទេ ព្រះអង្គមុខជានឹងឃើញខ្ញុំម្ចាស់អស់
ជីវិត ស្លាប់ក្នុងពេលព្រឹកមិនខាន ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឥទំ តតោ ទុក្ខតរំ** សេចក្ដីថា បពិត្រព្រះវេស្សន្តរស្វាមី ការដែលទ្រង់មិននិយាយនឹងខ្ញុំជាទុក្ខដល់ខ្ញុំក្រៃលែង ជាងទុក្ខដែលខ្ញុំត្រូវគេនិទេសចាកដែនមកកាន់ព្រៃនិងទុក្ខដែលខ្ញុំមិនឃើញកូនទាំង ២ នោះ ព្រោះទ្រង់ធ្វើឲ្យខ្ញុំលំបាក ព្រោះការស្ងៀមដូចផ្ទះត្រូវភ្លើងឆេះ ដូចយកឈើវាយបុគ្គល ដែលធ្លាក់ពីលើដើមត្នោត ដូចយកព្រួញចាក់ត្រង់មុខដំបៅ ដ្បិតថាហទយៈរបស់ខ្ញុំនេះរមែងញាប់ញ័រនិងឈឺផ្សាដូចដំបៅដែលចាក់ដោយព្រួញ ។ បាឋៈថា **សមប្បិតោ** ដូច្នេះក៏មាន សេចក្ដីថា ចាក់ទម្លុះ ។ បទថា **ឧក្កន្តសន្តំ មំ** បានដល់ ដែលខ្ញុំជាអ្នកប្រាសចាកជីវិត ។ **ណោ** អក្ខរៈក្នុងបទថា **ទក្ខសិ ណោ** នេះត្រឹមតែជានិបាត សេចក្ដីថា ទ្រង់នឹងបានឃើញខ្ញុំស្លាប់ក្នុងពេលព្រឹកនេះឯង ។

លំដាប់នោះព្រះមហាសត្វត្រិះរិះថាអញនឹងឲ្យនាងមទ្រីលះបង់នូវសេចក្ដី

សោកក្នុងកូន ដោយពាក្យអាក្រក់ទើបត្រាស់គាថានេះថា

ក្រែងនាងមទ្រី មានកម្ពស់និងទំហំដ៏ប្រសើរ ជារាជបុត្រីមានយសឬ នាងទៅដើម្បីស្វែងរក ( ផ្លែឈើតូចធំ ) តាំងពីពេលព្រឹក ហេតុដូចម្តេចបានជាដល់ពេលល្ងាចហើយ ទើបមកដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កិមិទំ សាយមាគតា** សេចក្តីថា ព្រះវេស្សន្តរពោធិសត្វត្រាស់សម្ពុតនិងបញ្ឆោតនាងថា នៃមទ្រី ហងមានរូបស្អាតគួរជ្រះថ្លាហើយក្នុងហិមវន្តប្បទេស ក៏មានព្រានព្រៃតាបសនិងវិទ្យាធរជាដើមដើរទៅមកជាច្រើន អ្នកណានឹងដឹងរឿងអ្វីដែលនាងធ្វើហើយ នាងទៅព្រៃតាំងអំពីព្រឹកថ្មើរនេះទើបត្រឡប់មក ធម្មតាស្ត្រីដែលលះកូនតូចៗទៅព្រៃទោះជាស្រីមានប្តីក្តី មិនមានក្តីរមែងមិនធ្វើដូចនាងយ៉ាងនេះ ការគិតត្រឹមតែប៉ុណ្ណោះថា កូនតូចរបស់អញនឹងទៅជាយ៉ាងណា ឬប្តីរបស់អញគិតដូចម្តេច ដូច្នេះក៏មិនមានដល់នាង នាងទៅតាំងអំពីព្រលឹម ត្រឡប់មកវិញដោយពន្លឺព្រះចន្ទនេះជាទោសនៃភាពក្រីក្ររបស់អញ ។ ព្រះនាងមទ្រីស្តាប់ព្រះតម្រាស់ដូច្នោះហើយក៏ទូលថា

ក្រែងព្រះអង្គទ្រង់ព្រះសណ្តាប់សំឡេង ទ្រហឹងអឺងកងនៃសីហៈនិងខ្លាដែលស្រែកបន្ទឺឡើង ( ព្រមទាំងម្រឹគដទៃមានដំរីជាដើម ) ដែលមកកាន់ស្រះ ( នេះ ) ដើម្បីផឹកទឹកដែរឬទេ ។ បុព្វនិមិត្តបានកើតឡើងដល់ខ្ញុំម្ចាស់ ដែលដើរវង្វាត់ក្នុងព្រៃធំ

ជ្រនីកក៏ធ្លាក់អំពីដៃរបស់ខ្ញុំម្ចាស់ ទាំងកញ្ច្រែងដែលលីលើចង្កេះ ស្មាក៏ធ្លាក់អំពីស្មា ។ ក្នុងពេលនោះ ខ្ញុំម្ចាស់មានសេចក្ដីភិតភ័យក្រៃពេក ក៏ប្រណម្យអញ្ជលីនមស្ការគ្រប់ទិសផ្សេងៗសូមឲ្យសួស្ដីគប្បីមាន ព្រោះការនមស្ការនេះ ។ សូមកុំឲ្យសីហៈនិងខ្លាដំបងបៀតបៀនព្រះរាជបុត្ររបស់យើងបាន មួយទៀតសូមកុំឲ្យខ្លាឃ្មុំ ឆ្កែព្រៃ និងខ្លារខិនចាប់ខាំស៊ីទារកទាំងពីរបាន ពួកពាឡម្រឹគទាំងបីក្នុងព្រៃ គឺសីហៈមួយ ខ្លាធំមួយ ខ្លាដំបងមួយរាំងផ្លូវខ្ញុំម្ចាស់ ព្រោះហេតុនោះ បានជាខ្ញុំម្ចាស់មកក្នុងវេលាល្ងាច ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **យេ សរំ ឋាតុំ** សេចក្ដីថា សត្វពួកណាមកកាន់ស្រះនេះដើម្បីផឹកទឹក ។ បទថា **ព្យគ្ឃស្ស ច** សេចក្ដីថា ព្រះនាងមទ្រីទូលសួរថា ទ្រង់បានស្ដាប់សំឡេងខ្លាធំនិងសត្វជើង ៤ ដទៃៗ មានដំរីជាដើមនិងហ្វូងបក្សីដែលមានសំឡេងគឹកកងហើយមិនមែនឬ សំឡេងនោះមានក្នុងកាលដែលមហាសត្វប្រទានព្រះរាជឱរសនិងព្រះរាជធីតា ។ បទថា **អហុ បុព្វនិមិត្តំ** សេចក្ដីថា បពិត្រព្រះសម្មតិទេព បុព្វនិមិត្តដើម្បីសោយទុក្ខនេះមានដល់ខ្ញុំហើយ ។ បទថា **ឧគ្គីវំ** បានដល់ ល្អីដែលពាក់លើស្មាក៏រអិលធ្លាក់ចុះ ។ បទថា **បុថុំ** សេចក្ដីថា ខ្ញុំនមស្ការដល់ទិសទាំង ១០ ។ បទថា **មា ហេវ នោ** សេចក្ដីថា ខ្ញុំនមស្ការប្រាថ្នាថា សូមព្រះរាជបុត្រវេស្សន្តររបស់ពួកយើងកុំត្រូវពាឡម្រឹគ មានរាជសីហ៍ជាដើមសម្លាប់ សូមកូនទាំង ២ កុំបីត្រូវខ្លាឃ្មុំ

ជាដើមប៉ះពាល់ ។ បទថា **តេ មំបរិយាវរុំ មគ្គំ** សេចក្តីថា ព្រះនាងមទ្រី ក្រាបទូលថា បពិត្រព្រះស្វាមី ខ្ញុំគិតថា ខ្ញុំបានឃើញហេតុដែលគួរខ្លាចទាំងនេះជាច្រើននិងសុបិនអាក្រក់ ថ្ងៃនេះខ្ញុំនឹងត្រឡប់មកឲ្យទាន់កាលឃើញដើមឈើដែលមានផ្លែដូចមិនមានផ្លែ ដើមឈើដែលមិនមានផ្លែដូចមានផ្លែ បេះផ្លែឈើបានដោយលំបាក មិនអាចមកដល់មាត់ព្រៃ ទាំងរាជសីហ៍ជាដើមឃើញខ្ញុំហើយ បានឈររាយគ្នាស្ទាក់ផ្លូវ ព្រោះហេតុនោះទើបខ្ញុំមកក្នុងវេលាល្ងាច សូមទ្រង់អត់ទោសដល់ខ្ញុំចុះ ។

ព្រះមហាសត្វត្រាស់វាចាតែប៉ុណ្ណោះជាមួយព្រះនាងមទ្រីហើយ មិនបានត្រាស់ពាក្យណាមួយទៀតឡើយរហូតដល់ភ្លឺ ។ ចាប់ពីពេលនេះព្រះនាងមទ្រីពិលាបរៀបរាប់មានប្រការផ្សេងៗថា

ខ្ញុំម្ចាស់មានសក់កណ្តាញ់ប្រព្រឹត្តធម៌ដ៏ប្រសើរ ស្រវាស្រទេញ ( ផ្គត់ផ្គង់ ) ប្តីផង បុត្តទាំងពីរផង អស់ថ្ងៃនិងយប់ដូចជាមាណព ( ផ្គត់ផ្គង់ ) អាចារ្យ ។ ហៃបុត្តកម្សត់ទាំងពីរមាតាស្លៀកដណ្តប់ស្បែកខ្លា ខំស្វែងរកមើមឈើនិងផ្លែឈើក្នុងព្រៃទាំងថ្ងៃទាំងយប់ ព្រោះតែសេចក្តីស្រឡាញ់កូនឯងទាំងពីរ ។ រមៀតមានពណ៌ដូចជាមាសនិងផ្លែព្នៅនេះមាតាបាននាំមកដល់ហើយមាតាបាននាំទាំងផ្លែឈើទាំងឡាយ ( ឯទៀតផង ) ហៃបុត្តកម្សត់ទាំងពីរ ផ្លែឈើទាំងនេះជាល្បែងរបស់កូនឯងទាំងពីរ ។ មើមឈូក ក្រអៅឧប្បល ក្រចាប់នេះ បពិត្រក្សត្រិយ៍

សូម ព្រះអង្គព្រមទាំងបុត្តទាំងពីរសោយ ( វត្ថុទាំងនោះ ) ដែល លាយដោយទឹកឃ្មុំចុះ ។ បពិត្រព្រះបាទសិវិ សូមព្រះអង្គប្រទាន ផ្កាឈូកដល់ជាលិ សូមព្រះអង្គប្រទានផ្កាកុមុទដល់នាងកុមារី សូមទត ( កុមារទាំងពីរ ) ដែលប្រដាប់ដោយកម្រងផ្កាហើយ រាំ សូមព្រះអង្គត្រាស់ហៅបុត្តទាំងពីរមក ។ បពិត្រព្រះអង្គជា ជំនួនរថ បណ្តាបុត្តទាំងពីរនោះបុត្រីឈ្មោះកណ្ហាជិនារមែងទៅ សូមព្រះអង្គ ទ្រង់ព្រះសណ្តាប់ ( សំឡេង ) របស់វាដែល ពីរោះគួរចាប់ចិត្ត ពាក្យពីរោះចូលទៅកាន់អាស្រម ។ បពិត្រ ព្រះបាទសិវិ យើងទាំងពីរនាក់ត្រូវគេនិរទេសចាកដែនហើយ ជាអ្នករួមសុខរួមទុក្ខជាមួយគ្នា ព្រះអង្គឃើញបុត្តទាំងពីរ គឺ ជាលីនិងកណ្ហាជិនាដែរឬ ។ ខ្ញុំបានជេរប្រទេចពួកស្រមណ៍ និងព្រាហ្មណ៍ ក្នុងលោក មានព្រហ្មចរិយធម៌ប្រព្រឹត្តទៅខាង មុខ មានសីលជាពហុស្សូតដោយពិត បានជាខ្ញុំម្ចាស់មិនឃើញ បុត្តទាំងពីរ គឺជាលីនិងកណ្ហាជិនានោះក្នុងថ្ងៃនេះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អាចរិយមិវ មាណវោ** សេចក្តីថា ដូច អន្តេវាសិកដែលសម្បូរដោយវត្តប្រតិបត្តិអាចារ្យ ។ បទថា **អនុដ្ឋិតា** សេចក្តី ថា ខ្ញុំម្ចាស់បម្រើ គឺមិនប្រមាទបដិបត្តិដោយការក្រោកឡើងបម្រើនិងដោយ សេចក្តីខ្មីឃ្មាត ។ បទថា **តុម្ហំ កាមា** សេចក្តីថា ប្រាថ្នាពួកកូនដោយការ ស្រឡាញ់ពួកកូន ។ ព្រះនាងមទ្រីខ្សឹកខ្សួលដល់កុមារទាំង ២ ដោយបទថា

**បុត្តកា** ។ បទថា **សុវណ្ណហាលិទ្ទំ** សេចក្តីថា មាតាដុស គឺបុករមៀតដែលមានពណ៌ដូចមាសកាន់មកដើម្បីផ្ងូតទឹកឲ្យកូនទាំង ២ ។ បទថា **បណ្ឌុវេលុវំ** សេចក្តីថា សូម្បីផ្លែញ្ញោទុំដែលមានពណ៌ដូចមាស ក៏មាតានាំមកដើម្បីឲ្យកូនទាំង ២ លេង ។ បទថា **រុក្ខបក្កានិ** សេចក្តីថា ផ្លែឈើដទៃៗ ដែលជាទីគាប់ចិត្ត ក៏មាតាបាននាំមកដើម្បីឲ្យកូនទាំង ២ លេង ។ បទថា **ឥមេ វោ** សេចក្តីថា ព្រះនាងមទ្រីពោលថា ឱកូនសម្លាញ់ របស់នេះជាគ្រឿងលេងរបស់ពួកកូន ។ បទថា **មូឡាលិវត្តកំ** បានដល់ ក្រអៅឈូក ។ បទថា **សាលុកំ** សេចក្តីថា សូម្បីមើមឈូកមានឧប្បលជាដើមនេះ ក៏មាតានាំមកជាច្រើន ។ បទថា **ឯញ្ជភោគកំ** បានដល់ មើមក្រចាប់ ។ បទថា **ភុញ្ជ** សេចក្តីថា ព្រះនាងមទ្រីខ្សឹកខ្សួលថា សូមទ្រង់សោយរបស់ទាំងអស់នេះដែលជ្រលក់ដោយទឹកឃ្មុំបន្តិចបន្តួច មួយអន្លើដោយកូនប្រុសស្រី ។ បទថា **សិវិ បុត្តានិ អវ្ហាយ** សេចក្តីថា បពិត្រព្រះបាទសិវិរាជ សូមទ្រង់ប្រញាប់ត្រាស់ហៅព្រះរាជឱរសព្រះរាជធីតា អំពីទីបន្ទុំក្នុងបណ្ណសាលា ។ បទថា **អបិ សិវិបុត្តេ បស្សេសិ** សេចក្តីថា បពិត្រព្រះបាទសិវិរាជ សូមទ្រង់ទតមើលព្រះរាជឱរសព្រះរាជធីតាទាំង ២ ចុះ បើទ្រង់ឃើញ ក៏សូមប្រាប់ដល់ខ្ញុំ កុំធ្វើឲ្យខ្ញុំលំបាកពេកឡើយ ។ បទថា **អភិសសឹ** សេចក្តីថា ខ្ញុំបានជេរយ៉ាងនេះថា អ្នកទាំងឡាយចូរកុំជួបបុត្តធីតារបស់ពួកអ្នកឡើយ ។

ព្រះនាងមទ្រីពិលាបរៀបរាប់យ៉ាងនេះ ព្រះវេស្សន្តរមហាសត្វក៏មិនបានត្រាស់ពាក្យណាមួយឡើយ កាលព្រះមហាសត្វមិនត្រាស់ ព្រះនាងមទ្រីក៏

ញាប់ញ័រព្រះហឫទ័យ រត់រកព្រះរាជឱរសព្រះរាជធីតារបស់ព្រះនាងដោយអាស្រ័យពន្លឺព្រះចន្ទ យាងដល់ទីទាំងពួងនោះៗមានដើមព្រីងជាដើម ដែលជាទីព្រះរាជឱរសព្រះរាជធីតាធ្លាប់លេងព្រះនាងយំសោកថា

នេះរុក្ខជាតិផ្សេងៗ គឺព្រីង ឈើទាលខ្សាច់ មានមែកត្រសុំត្រសាយ កុមារទាំងនោះអញមិនបានឃើញ ។ នេះផលជាតិផ្សេងៗ គឺពោធិ៍ ខ្នុរ ជ្រៃ ក្រសាំង កុមារទាំងនោះអញមិនបានឃើញ ។ នេះសួនច្បារទាំងឡាយ នេះស្ទឹងមានទឹកត្រជាក់ជាទីដែលកុមារទាំងពីរធ្លាប់លេង កុមារទាំងនោះអញមិនបានឃើញ ។ ផ្កាឈើច្រើនយ៉ាងលើភ្នំនេះ ជាផ្កាដែលកុមារទាំងពីរធ្លាប់ទ្រទ្រង់ កុមារទាំងនោះអញមិនបានឃើញ ។ ផ្លែឈើច្រើនយ៉ាងលើភ្នំនេះជាផ្លែ ដែលកុមារទាំងពីរធ្លាប់បរិភោគ កុមារទាំងនោះអញមិនបានឃើញសោះ ។ រូបដំរី រូបសេះទាំងនេះក្តី រូបគោទាំងនេះក្តីជារូបដែលកុមារទាំងពីរធ្លាប់លេង កុមារទាំងនោះអញមិនបានឃើញ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឥមេ តេ ហត្ថិកា** សេចក្ដីថា ព្រះនាងមទ្រីគយគន់រកព្រះរាជឱរសព្រះរាជធីតាលើភ្នំ មិនឃើញព្រះនាងក៏ខ្សឹកខ្សួលចុះអំពីភ្នំមកកាន់អាស្រមបទវិញ ទ្រង់ខ្សឹកខ្សួលដល់ព្រះរាជឱរសនិងព្រះរាជធីតាក្នុងអាស្រមបទនោះ ទតឃើញរបស់លេងទាំងឡាយរបស់ព្រះរាជឱរសព្រះរាជធីតាទើបត្រាស់យ៉ាងនេះ ។ កាលនោះហ្វូងម្រឹគនិងបក្សីក៏នាំគ្នាចេញ

ពីលំនៅ ព្រោះសំឡេងជង្រ្គាយហៅនិងស្នូរជើងរបស់ព្រះនាងមទ្រី ។

ព្រះនាងមទ្រីទតឃើញសត្វទាំងនោះទើបត្រាស់ថា

រូបម្រឹគមានសម្បុរពព្រុស រូបទន្សាយ រូបមៀម រូបម្រឹគ ឈ្លូសជាច្រើន ទាំងនេះជារូបដែលកុមារទាំងពីរធ្លាប់លេងកុមារ ទាំងនោះអញមិនបានឃើញ ។ រូបហង្ស រូបក្រៀល រូបក្ងោក មានស្លាបដ៏វិចិត្រ ជារូបដែលកុមារទាំងពីរធ្លាប់លេង កុមារ ទាំងនោះអញមិនបានឃើញ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សាមា** បានដល់ ទ្រាយមាសខ្លួនតូចៗ ។ បទថា **សសោលូកា** បានដល់ រូបទន្សាយនិងរូបមៀម ។

ព្រះនាងមទ្រីមិនឃើញបិយបុត្តទាំង ២ ក្នុងអាស្រមបទ ទើបចេញចាក អាស្រមបទទៅកាន់ព្រៃផ្កាទតមើលទីនោះត្រាស់ថា

គុម្ពឈើទាំងនេះមានផ្ការីកសព្វកាល ជាផ្កាដែលកុមារទាំងពីរ ធ្លាប់លេង កុមារទាំងនោះអញមិនបានឃើញ ។ ស្រះបោក្ខរណី ទាំងនេះគួរជាទីត្រេកអរ ទ្រហឹងអឺងកងដោយសត្វចាក្រពាក ដេរដាសដោយផ្កាមណ្ឌាលកៈផង ដោយផ្កាឈូកនិងផ្កាឧប្បល ផងជាទីដែលកុមារទាំងពីរធ្លាប់លេង កុមារទាំងនោះអញមិន បានឃើញ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **វនគុម្ពាយោ** បានដល់ គុម្ពផ្កាព្រៃនោះឯង ។ ព្រះនាងមទ្រីមិនជួបនូវកូនសម្លាញ់ទាំង ២ ក្នុងទីណាឡើយក៏យាងមក

គាល់មហាសត្វទៀត ឃើញមហាសត្វប្រថាប់គន់មានព្រះភក្ត្រសៅហ្មងក៏ទូល ថា

ឧសទាំងឡាយព្រះអង្គមិនកាច់ ទឹកព្រះអង្គមិនដង ភ្លើងព្រះអង្គមិនបង្កាត់ ហេតុអ្វីបានជាព្រះអង្គសញ្ជប់សញ្ជឹងដូចមនុស្សខ្វៅ ។ ( ព្រះវេស្សន្តរ ) ជាទីស្រឡាញ់ ( របស់ខ្ញុំម្ចាស់ ) សេចក្តីព្រួយតែងសោយព្រោះបានជួបជុំដោយព្រះអង្គ ជាទីស្រឡាញ់ក្នុងថ្ងៃនេះខ្ញុំម្ចាស់មិនឃើញបុត្តទាំងពីរ គឺជាលីនិងនាងកណ្ហាជិនានោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ន ហាសិតោ** បានដល់ មិនបង្កាត់ឲ្យឆេះ លោកអធិប្បាយថា បពិត្រព្រះស្វាមី កាលមុនទ្រង់កាច់ឧសនាំទឹកមកតម្កល់ទុក បង្កាត់ភ្លើងក្នុងជើងក្រាន ថ្ងៃនេះទ្រង់មិនធ្វើសូម្បីតែមួយក្នុងរឿងទាំងនេះ ទ្រង់ហាក់ដូចជាខ្សោយកម្លាំង សុបសៅព្រោះហេតុអ្វីហ្ន៎ ខ្ញុំម្ចាស់មិនគាប់ចិត្តក្នុងកិរិយារបស់ព្រះអង្គឡើយ ។ បទថា **បិយោ បិយេន** សេចក្តីថា ព្រះវេស្សន្តរជាទីស្រឡាញ់របស់ខ្ញុំ អ្នកដទៃជាទីស្រឡាញ់ក្រៃលែង ជាងព្រះវេស្សន្តរនេះមិនមាន កាលមុនសេចក្តីទុក្ខរមែងបាត់ទៅ គឺរមែងប្រាសទៅព្រោះបានជួបជុំ គឺមកប្រជុំជាមួយទ្រង់ដែលជាទីស្រឡាញ់របស់ខ្ញុំនេះ តែថ្ងៃនេះសូម្បីខ្ញុំឃើញទ្រង់ សេចក្តីសោកក៏មិនប្រាសទៅព្រោះហេតុអ្វីហ្ន៎ ។ បទថា **តស្មា** សេចក្តីថា ហេតុការណ៍ដែលខ្ញុំឃើញហើយ ចូរលើកទុកចុះ ថ្ងៃនេះខ្ញុំមិនឃើញកូនទាំង ២ នោះ ព្រោះហេតុនោះកាលខ្ញុំឃើញទ្រង់សេចក្តី

សោករបស់ខ្ញុំក៏មិនរសាយ ។

ព្រះនាងមទ្រីក្រាបទូលយ៉ាងនេះ ព្រះមហាសត្វក៏ប្រថាប់គង់ស្ងៀមនោះ ឯងកាលព្រះមហាសត្វមិនត្រាស់ ព្រះនាងក៏ពេញទៅដោយព្រួញ គឺសេចក្តីសោកមានកាយញ័រចំប្រប់ដូចមាន់ដែលត្រូវវាយ ព្រះនាងដើររកតាមទីដែលដើរម្តងហើយនោះ ហើយត្រឡប់មកគាល់ព្រះមហាសត្វក្រាបទូលថា

បពិត្រព្រះទេវៈ ខ្ញុំម្ចាស់មិនឃើញបុត្តរបស់យើងទាំងពីរសោះ ខ្ញុំម្ចាស់មិនដឹងជា ( អ្នកណា ) នាំយកបុត្តទាំងនោះទៅ ទាំងពួកក្អែកព្រៃសោត ក៏មិនកញ្ជ្រៀវ ទារកទាំងពីររបស់ខ្ញុំម្ចាស់ប្រាកដជាស្លាប់ហើយ ។ បពិត្រព្រះទេវៈ ខ្ញុំម្ចាស់មិនឃើញបុត្តរបស់យើងទាំងពីរសោះ ខ្ញុំម្ចាស់មិនដឹងជា ( អ្នកណា ) នាំយកបុត្តទាំងនោះទៅ ទាំងពួកសត្វស្លាបសោតក៏មិនកញ្ជ្រៀវ ទារកទាំងពីររបស់ខ្ញុំម្ចាស់ប្រាកដជាស្លាប់ហើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ន ទេ បស្សេ** សេចក្តីថា បពិត្រព្រះសម្មតិទេព ខ្ញុំមិនឃើញកូនទាំង ២ របស់យើងឡើយ ។ បទថា **យេន តេ នីហតា មតា** សេចក្តីថា ព្រះនាងមទ្រីទូលសួរដោយបំណងថា ខ្ញុំមិនដឹងថាអ្នកណានាំកូនទាំង ២ ទៅ ។

ព្រះនាងមទ្រី ក្រាបទូលយ៉ាងនេះ ព្រះមហាសត្វមិនបានត្រាស់អ្វីឡើយ ព្រះនាងមទ្រីត្រូវសេចក្តីសោកព្រោះព្រះរាជឱរសពាល់ត្រូវហើយ ព្រះនាងពិចារណាបុត្តទាំង ២ ត្រាច់ទៅកាន់ទីនោះៗដោយសម្ទុះដូចខ្យល់អស់វារៈ ៣

ជន បានឮថា ទីដែលព្រះនាងត្រាច់ទៅអស់មួយរាត្រីចម្ងាយប្រមាណ ១៥ យោជន៍ ។ លំដាប់នោះរាត្រីអស់ហើយអរុណក៏រះឡើង ព្រះនាងយាងមកប្រថាប់ឈរខ្សឹកខ្សួលក្នុងទីជិតព្រះមហាសត្វទៀត ។

**តមត្ថំ បកាសេន្តោ សត្ថា អាហា** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសានូវព្រះគាថាដូច្នេះថា

នាងមទ្រីនោះ ( បានត្រាច់ទៅ ) កាន់ភ្នំនិងព្រៃខ្សឹកខ្សួលក្នុងទីនោះ ហើយត្រឡប់មកអាស្រមវិញ ក៏ទ្រង់ព្រះកន្សែងក្នុងសំណាក់ព្រះរាជស្វាមីថា បពិត្រព្រះទេវៈ ខ្ញុំម្ចាស់មិនឃើញ ( បុត្តទាំងពីរ ) របស់យើងសោះ ខ្ញុំម្ចាស់មិនដឹងជា ( អ្នកណា ) នាំយកបុត្តទាំងនោះទៅ ទាំងពួកក្អែកព្រៃសោតក៏មិនកញ្ជ្រៀវ ទារកទាំងពីររបស់ខ្ញុំម្ចាស់ប្រាកដជាស្លាប់ហើយ ។ បពិត្រព្រះទេវៈ ខ្ញុំម្ចាស់មិនឃើញ ( បុត្តទាំងពីរ ) របស់យើងសោះ ខ្ញុំម្ចាស់មិនដឹងជា ( អ្នកណា ) នាំយកបុត្តទាំងនោះទៅ ទាំងពួកសត្វស្លាបសោត ក៏មិនកញ្ជ្រៀវ ទារកទាំងពីររបស់ខ្ញុំម្ចាស់ប្រាកដជាស្លាប់ហើយ ។ បពិត្រព្រះទេវៈ ខ្ញុំម្ចាស់មិនឃើញ ( បុត្តទាំងពីរ ) របស់យើងសោះ ខ្ញុំម្ចាស់មិនដឹងជា ( អ្នកណា ) នាំយកបុត្តទាំងនោះទៅ ម្នាលភិក្ខុទាំងឡាយ នាងមទ្រីត្រាច់ទៅក្រោមម្លប់ឈើនិងភ្នំ និងគុហា ។ នាងមទ្រី

មាន កម្ពស់និងទំហំដ៏ប្រសើរជារាជបុត្រីមានយស ក៏ផ្គងដើម
ដៃទាំងពីរ កន្ទក់កន្ទេញយ៉ាងនេះហើយ ក៏ដួលទៅលើផែនដី
ក្នុងទីនោះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សាមិកស្សន្តិ ភោគតិ** សេចក្ដីថា ម្នាលភិក្ខុទាំងឡាយ នាងមទ្រីនោះត្រាច់ខ្សឹកខ្សួលតាមទីទួលនិងដងព្រៃ ត្រង់ជើងភ្នំវង្កតនោះហើយយាងមកអាស្រ័យព្រះស្វាមីទៀត ឈរប្រថាប់ក្នុងទីជិតព្រះភស្ដា ព្រះនាងទ្រង់ព្រះកន្សែង គឺកន្ទក់កន្ទេញថា **ឆ ខោ ឆោ** ជាដើម ដើម្បីត្រូវព្រះរាជឱរសនិងរាជព្រះធីតា ។ បទថា **ឥតិ មទ្ទី វរារោហា** សេចក្ដីថា ម្នាលភិក្ខុទាំងឡាយ ព្រះនាងមទ្រីទ្រទ្រង់នូវរូបដ៏ប្រសើរ ឈ្មោះថាជាអ្នកទ្រទ្រង់នូវសម្រស់ ត្រាច់ទៅត្រង់គល់ឈើជាដើម មិនឃើញព្រះរាជឱរសនិងព្រះរាជធីតា ផ្គងដើមដៃកន្ទក់កន្ទេញថា កូនទាំង ២ នឹងស្លាប់ប្រាកដហើយដូច្នេះ ហើយក៏ដួលចុះ ក្នុងភូមិភាគទៀបព្រះយុគលបាទនៃព្រះវេស្សន្តរនោះឯង ដូចដើមចេកមាសត្រូវកាប់ដូច្នោះ ។

លំដាប់នោះមហាសត្វទ្រង់មានព្រះកាយញាប់ញ័រ ព្រោះទ្រង់សម្គាល់ថា ព្រះនាងមទ្រីអស់ព្រះជន្មទៅហើយ ទ្រង់ព្រះតម្រិះថា មទ្រីអស់ព្រះជន្មក្នុងទីដែលមិនមែនជាឋានៈ បើនាងធ្វើកាលកិរិយាក្នុងជេតុត្តររាជធានី ការបរិហារនឹងប្រព្រឹត្តទៅដ៏ធំ រដ្ឋទាំង ២ នឹងកក្រើករំពើកដល់គ្នា ឯខ្ញុំនអញនៅក្នុងអារញ្ញប្បទេសម្នាក់ឯងប៉ុណ្ណោះនឹងធ្វើដូចម្ដេចល្អហ្ន៎ ទ្រង់ពិចារណាដូច្នេះហើយ ជាអ្នកមានសេចក្ដីសោកជាកម្លាំង ទ្រង់តាំងព្រះសតិមាំក្រោកឡើង ដោយ

សម្គាល់ថាអញត្រូវជីងសិន ទើបដាក់ព្រះហត្ថាខាងស្តាំត្រង់ហទយវត្ថុនៃព្រះនាង ទ្រង់ជ្រាបថាមានកម្តៅប្រព្រឹត្តទៅ ទើបទ្រង់នាំយកកុណ្ឌីទឹកមក ទ្រង់មិនបានពាល់ត្រូវព្រះកាយព្រះនាងអស់ ៧ ខែ តែមិនអាចកំណត់ភាពដែលទ្រង់ជាបព្វជិត ព្រោះសេចក្តីសោកមានកម្លាំង មានព្រះនេត្រពេញទៅដោយព្រះអស្សុជល ត្រកងព្រះសីសៈរបស់ព្រះនាងឡើងដាក់លើភ្លៅ ប្រោះព្រំដោយទឹក លាបព្រះភក្ត្រនិងត្រង់ព្រះហទយៈប្រថាប់គង់ ។ ចំណែកព្រះនាងមទ្រីលុះបានមួយស្របក់ក៏បាននូវស្មារតី តាំងនៅក្នុងហិរិនិងឱត្តប្បៈ ក្រោកឡើងថ្វាយបង្គំមហាសត្វ ទូលសួរថា បពិត្រព្រះស្វាមី កូនទាំង ២ របស់ខ្ញុំម្ចាស់ទៅណា ។ មហាសត្វត្រាស់តបថា នែមទ្រី អញឲ្យជាទាសៈនៃព្រាហ្មណ៍ម្នាក់ទៅហើយ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** រឿងធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូត្រសានូវព្រះគាថាដូច្នេះថា

ព្រះបាទវេស្សន្តរទ្រង់ស្រោចស្រពព្រះរាជបុត្រីនោះ ដែលបានមកដល់សំណាក់ព្រះអង្គ បន្ទាប់អំពីនោះមកព្រះអង្គជ្រាបព្រះរាជបុត្រីនោះដែលស្រួលចិត្តហើយទើបបានត្រាស់នឹងព្រះរាជបុត្រីនោះយ៉ាងនេះថា ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អជ្ឈ បត្តំ** សេចក្តីថា ដែលដួលចុះក្នុងទីជិតព្រះអង្គ អធិប្បាយថា ដែលដួលចុះដល់នូវវិសញ្ញីភាពទៀបព្រះយុគល

បាទ ។ បទថា **ឯតទព្រវិ** សេចក្តីថា បានត្រាស់ពាក្យនេះ គឺពាក្យថា អញឲ្យជាទាសៈដល់ព្រាហ្មណ៍ម្នាក់ទៅហើយ ។

បន្ទាប់អំពីនោះកាលព្រះនាងមទ្រីទូលថា បពិត្រព្រះសម្មតិទេព ទ្រង់ឲ្យកូនទាំង ២ ដល់ព្រាហ្មណ៍ហើយទ្រង់មិនត្រាស់ឲ្យខ្ញុំម្ចាស់ដឹង ឲ្យខ្ញុំម្ចាស់ខ្វឹកខ្វួលអស់មួយរាត្រីព្រោះហេតុអ្វី ទើបព្រះមហាសត្វត្រាស់ថា

ហៃនាងមទ្រី អញមិនចង់ប្រាប់សេចក្តីទុក្ខដល់នាងអំពីដំបូងទេ មានព្រាហ្មណ៍ចាស់កម្សត់ ជាស្មូមបានមកកាន់លំនៅ ។ ហៃនាងមទ្រី អញបានឲ្យបុត្តទាំងពីរ ដល់ព្រាហ្មណ៍នោះហើយ នាងកុំភិតភ័យអ្វី នាងចូរស្រួលចិត្តចុះ ហៃនាងមទ្រីនាងចូរមើលមកអញកុំមើលបុត្តទាំងពីរ កុំខ្វឹកខ្វួលខ្លាំងឡើយ កាលបើយើងរស់នៅបានសុខសប្បាយ ក៏គង់បាន ( ចួបប្រទះ ) នឹងបុត្តវិញ ។ សប្បុរសបានឃើញពួកស្មូមមកហើយ គប្បីឲ្យកូន សត្វចិញ្ចឹម ធញ្ញជាតិនិងទ្រព្យដទៃដែលមានក្នុងផ្ទះជាទាន ហៃនាងមទ្រី នាងចូររីករាយតាមនូវអំណោយបុត្តដ៏ឧត្តមរបស់អញ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អាទិយេនេវ** បានដល់ អំពីដំបូង មានអធិប្បាយថា បើអញប្រាប់រឿងនេះដល់នាងអំពីដំបូង កាលនាងបានស្តាប់ដូច្នោះមិនអាចអត់ធន់នឹងសេចក្តីសោកបាន ហឫទ័យគប្បីបែក ព្រោះដូច្នោះទើបអញមិនប្រាថ្នានឹងប្រាប់ដល់នាងអំពីដំបូង ។ បទថា **យាចមាគតោ**

សេចក្តីថា មកកាន់លំនៅរបស់ពួកយើងនេះ ។ បទថា **អរោគា ច ភវាមសេ** សេចក្តីថា ព្រះវេស្សន្តរមហាសត្វត្រាស់ថា ទាំងអស់នេះយើងទាំង ២ ជាអ្នកមិនមានរោគ នៅមានជីវិតនឹងជួបកូនទាំង ២ ដែលព្រាហ្មណ៍នាំទៅពិត ។ បទថា **យញ្ច អញ្ញំ** បានដល់ សវិញ្ញាណកទ្រព្យនិងអវិញ្ញាណកទ្រព្យដទៃក្នុងផ្ទះ ។ បទថា **ឧដ្ឋា សប្បុរិសោ ទានំ** សេចក្តីថា សប្បុរសកាលប្រាថ្នាប្រយោជន៍ឧត្តមគប្បីពុះទ្រូងរូងយកបេះដូងឲ្យជាទាន ។

ព្រះនាងមទ្រីទូលថា

បពិត្រព្រះទេវ: ខ្ញុំម្ចាស់សូមរីករាយតាម នូវអំណោយបុត្តដ៏ឧត្តមរបស់ព្រះអង្គ ព្រះអង្គប្រទានហើយ សូមធ្វើព្រះហឫទ័យឲ្យជ្រះថ្លាចុះ សូមព្រះអង្គទ្រង់ឲ្យទានជាកិយ្យោភាពចុះ ។ បពិត្រព្រះជនាធិប: កាលដែលពួកមនុស្សកំពុងមានសេចក្តីកំណាញ់ ព្រះអង្គជាអ្នកញ៉ាំងអ្នកសិវិរាស្ត្រឲ្យបម្រើន ទ្រង់បានដាក់ទានដល់ព្រាហ្មណ៍ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អនុមោទាមិ តេ** សេចក្តីថា ព្រះនាងមទ្រីទ្រង់ពពោះ ១០ ខែ ប្រសូតហើយឲ្យស្រង់ ឲ្យផឹក ឲ្យសោយមួយថ្ងៃ ២-៣ ដងផ្គត់ផ្គង់កូនតូចទាំង ២ នោះ ឲ្យផ្ទុំលើព្រះឧរប្បទេស កាលព្រះពោធិសត្វព្រះរាជទានកូនទាំង ២ ទៅ ព្រះនាងអនុមោទនាចំណែកបុណ្យឯង ទើបត្រាស់យ៉ាងនេះ ។ គប្បីជ្រាបដោយហេតុនេះថា ឪពុកប៉ុណ្ណោះជាម្ចាស់នៃកូនទាំងឡាយ ។ បទថា **ភិយ្យោ ទានំ ទទោ ភវ** សេចក្តីថា បពិត្រមហារាជ

សូមទ្រង់ជាអ្នកបរិច្ចាគទានរឿយៗឲ្យក្រៃលែងចុះ ក្នុងកាលសត្វទាំងឡាយមានសេចក្តីកំណាញ់ សូមទ្រង់បានព្រះរាជទានបិយបុត្តទាំង ២ សូមញុំាងព្រះហឫទ័យឲ្យជ្រះថ្លាចុះថា ទានអញឲ្យល្អហើយ ។

កាលព្រះនាងមទ្រីទូលយ៉ាងនោះហើយ ព្រះមហាសត្វក៏ត្រាស់ដល់ហេតុអស្ចារ្យទាំងពួងមានផែនដីកម្រើកជាដើមថា នែនាងមទ្រី នាងនិយាយថ្វី បើអញឲ្យកូនទាំង ២ ហើយ មិនធ្វើចិត្តឲ្យជ្រះថ្លា ការអស្ចារ្យទាំងឡាយរបស់អញក៏មិនគប្បីប្រព្រឹត្តទៅ ។ បន្ទាប់អំពីនោះព្រះនាងមទ្រី បានប្រកាសភាពអស្ចារ្យនោះឯង កាលព្រះនាងអនុមោទនាបិយបុត្តទានទើបត្រាស់ថា

ព្រះអង្គ បានញុំាងផែនដីឲ្យខ្ទរខ្ទារ កិត្តិសព្ទរបស់ព្រះអង្គទៅ
ដល់ទេវលោក ផ្លេកបន្ទោរពុំជូកាលជាលប្រវាត់ ជុំវិញព្រៃ
ហិមពាន្ត ដូចជាសំឡេងលាន់នៃភ្នំទាំងឡាយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វិជ្ជុតា អាគុំ** សេចក្តីថា ផ្លេកបន្ទោរពុំជូ-កាលជាលប្រវាត់ជុំវិញហិមវន្តប្បទេស ។ បទថា **គិរីនំវ បដិស្សុតា** សេចក្តីថា សំឡេងកោលាហលប្រាកដហាក់ដូចភ្នំបាក់ ។

ពួកទេវតាទាំងពីរក្រុម គឺនារទៈនិងបព្វតៈព្រមទាំងព្រះឥន្ទ្រ
ព្រះព្រហ្មនិងបជាបតិទេវបុត្ត សោមទេវបុត្ត ព្រះបាទយមៈ
និងព្រះបាទវេស្សវ័ណ ក៏នាំគ្នារីករាយតាមព្រះអង្គនោះ ពួក
ទេវតាទាំងអស់ដែលកើតក្នុងឋានតាវត្តិង្ស ព្រមទាំងព្រះឥន្ទ
ក៏រីករាយតាម ។ ( ព្រះសាស្តាបានត្រាស់គាថានេះថា ) ព្រះ

នាងមទ្រី មានកម្ពស់និងទំហំដ៏ប្រសើរ ជារាជបុត្រីមានយស
បានរីករាយតាមនូវអំណោយបុត្តដ៏ឧត្តម របស់ព្រះបាទវេស្សន្តរ
ដោយប្រការដូច្នេះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឆារធបព្វតា** សេចក្តីថា ទេវនិកាយទាំង ២ នេះស្ថិតនៅត្រង់ទ្វារវិមានរៀងៗខ្លួននោះឯង អនុមោទនាដល់ព្រះអង្គថា ទាន ព្រះអង្គប្រទានល្អហើយហ្ន៎ ។ បទថា **តាវតឹសា សឥន្ទកា** សេចក្តីថា ពួកទេវតាជាន់តាវត្តិង្ស ដែលមានព្រះឥន្ទជាប្រធាន នាំគ្នាអនុមោទនាទានរបស់ព្រះអង្គ ។

មហាសត្វទ្រង់សរសើរទានរបស់ព្រះអង្គយ៉ាងនេះហើយ ព្រះនាងមទ្រីក៏នាំយកសេចក្តីនោះឯងមកសរសើរថា បពិត្រមហារាជ ទានទ្រង់ប្រទានល្អហើយ ដូច្នេះហើយព្រះនាងអនុមោទនាប្រថាប់គង់ ដោយហេតុនោះទើបព្រះសាស្តាត្រាស់ថា **ឥតិ មទ្ទី វរារោហា** ដូច្នេះជាដើម ។

## មទ្រីបព្វ ចប់

## សត្តបញ្ច:

កាលក្សត្រទាំង ២ អង្គ គឺព្រះវេស្សន្តរនិងព្រះនាងមទ្រីត្រាស់សម្មោទ-និយកថាដល់គ្នានឹងគ្នាយ៉ាងនេះ សក្កទេវរាជទ្រង់ព្រះតម្រិះថា ម្សិលមិញនេះព្រះវេស្សន្តរមហារាជបានប្រទានកូនជាទីស្រឡាញ់ដល់ជូជកធ្វើឲ្យផែនដីញាប់ញ័រ ឥឡូវនេះបើមានមនុស្សអាក្រក់ណាមួយទៅគាល់ព្រះវេស្សន្តរ ទូលសូមព្រះនាងមទ្រី ដែលសម្បូរដោយលក្ខណៈទាំងពួង មានសិលាចារវត្តបរិបូណ៌នាំព្រះនាងមទ្រីទៅធ្វើឲ្យទ្រង់នៅតែឯង បន្ទាប់អំពីនោះទ្រង់ក៏នឹងទទេមិនមានអ្នកបដិបត្តិ ណ្ហើយចុះអញនឹងកាឡាខ្លួនជាព្រាហ្មណ៍ ចូលទៅគាល់ទ្រង់ទូលសូមនាងមទ្រី ឲ្យកាន់យកទាននោះជាកំពូលនៃទានបារមី ធ្វើឲ្យមិនគួរលះដល់អ្នកណា ហើយថ្វាយព្រះនាងដល់ទ្រង់វិញ សឹមត្រឡប់មកកាន់ទេវស្ថានរបស់អញ ។ សក្កទេវរាជបានយាងទៅកាន់សម្នាក់ នៃព្រះបរម-ពោធិសត្វក្នុងកាលព្រះអាទិត្យរះ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសាទូវព្រះគាថាដូច្នេះថា

> លំដាប់នោះក្នុងកាលដែលរាត្រីកន្លងទៅហើយ ព្រះអាទិត្យក៏
> រះឡើង សក្កទេវរាជមានភេទជាព្រាហ្មណ៍ ប្រាកដដល់ក្សត្រ
> ទាំងពីរនោះក្នុងពេលព្រឹក ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ចាតោ ផេសំ អទិស្សថ** សេចក្តីថា មានរូប

ប្រាកដឈរខាងមុខក្សត្រទាំង ២ អំពីព្រលឹម ។

កាលប្រថាប់ឈរហើយកាលទ្រង់ធ្វើបដិសណ្ឋារៈទើបត្រាស់ថា

ព្រះអង្គសុខសប្បាយទេឬ ព្រះអង្គមិនមានរោគាពាធទេឬ ព្រះអង្គញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយការស្វែងរកស្រួលទេឬ មើមឈើនិងផ្លែឈើមានច្រើនដែរឬ ។ ពួករបោម មូសនិងពស់មានតិចទេឬ ក្នុងព្រៃដ៏កុះករដោយម្រឹគយង់ឃ្នងមិនមានការបៀតបៀនទេឬ ដូច្នេះ ។

កាលសក្កទេវរាជទូលយ៉ាងនេះហើយ មហាសត្វកាលទ្រង់ធ្វើបដិសណ្ឋារៈជាមួយសក្កទេវរាជនោះ ទើបត្រាស់ថា

ម្នាលព្រាហ្មណ៍ពួកយើងសុខសប្បាយទេ ម្នាលព្រាហ្មណ៍ មិនមានរោគាពាធអ្វីទេ មួយទៀត យើងញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយការស្វែងរកស្រួលទេ មើមឈើនិងផ្លែឈើទាំងឡាយដ៏បរិបូណ៌ដែរទេ ។ ទាំងពួករបោម មូសនិងពស់មានតិចទេ ក្នុងព្រៃដ៏កុះករដោយម្រឹគយង់ឃ្នង មិនមានការបៀតបៀនយើងទេ ។ យើងនៅក្នុងព្រៃអស់ ៧ ខែ រស់នៅទាំងសំណោកទើបឃើញព្រាហ្មណ៍ជាគម្រប់ពីរនេះ មានភេទដ៏ប្រសើរ កាន់ឈើប្រត់មានពណ៌ដូចជាផ្លែព្នៅទុំ ទ្រទ្រង់ស្បែកខ្លាទាំងក្រចក ។ នែមហាព្រាហ្មណ៍ អ្នកមកល្អហើយ មួយទៀតអ្នកមិនមែនមកអាក្រក់ទេ អញ្ជើញអ្នកចូលទៅខាងក្នុង សេចក្តីចម្រើន ( ចូរ

មាន ) ដល់អ្នក អ្នកចូរលាងជើងទាំងឡាយរបស់អ្នក ។ ម្នាលព្រាហ្មណ៍ អ្នកចូរបរិភោគផ្លែឈើយ៉ាងឆ្ងាញ់ៗដូចទឹកឃ្មុំ គឺផ្លែទន្លាប់ ទ្រយឹង មាក់ប្រាង មាក់ដោក ។ ទឹកត្រជាក់នេះ ដងមកអំពីជ្រោះភ្នំ ម្នាលមហាព្រាហ្មណ៍ អ្នកចូរផឹកទឹកនេះចុះ បើអ្នកប្រាថ្នាចង់ផឹក ដូច្នេះ ។

ព្រះមហាសត្វទ្រង់ធ្វើបដិសណ្ឋារៈជាមួយព្រាហ្មណ៍នោះយ៉ាងនេះ ហើយ ត្រាស់សួរថា

យើងសូមសួរអ្នក អ្នកបានមកដល់ព្រៃធំ ដោយរឿងដូចម្តេច ឬដោយហេតុដូចម្តេច អ្នកកាលបើយើងសួរហើយ ចូរប្រាប់ រឿងនោះ ដូច្នេះ ។

ព្រះមហាសត្វ ត្រាស់សួរដល់ហេតុដែលសក្កៈមក ដោយប្រការដូច្នេះ លំដាប់នោះសក្កទេវរាជទូលថា បពិត្រមហារាជ ទូលព្រះបង្គំជាមនុស្សចាស់ មកក្នុងទីនេះ មកដើម្បីសូមព្រះនាងមទ្រីអគ្គមហេសីរបស់ព្រះអង្គ សូមទ្រង់ ព្រះរាជទានព្រះនាងដល់ខ្ញុំ កាលទូលដូច្នេះហើយបានពោលគាថាថា

ផ្លូវទឹកដ៏ពេញប្រៀបមិនអស់ទៅសព្វកាលយ៉ាងណាមិញ ទូល បង្គំជាខ្ញុំ មកដើម្បីសូមទានព្រះអង្គ ទូលបង្គំជាខ្ញុំសូមហើយ សូមព្រះអង្គប្រទានភរិយាក៏យ៉ាងនោះដែរ ដូច្នេះ ។

កាលសក្កទេវរាជ ទូលយ៉ាងនេះហើយ ព្រះមហាសត្វមិនបានត្រាស់ថា ម្សិលមិញនេះ យើងឲ្យកូនប្រុសកូនស្រីដល់ព្រាហ្មណ៍ទៅហើយ យើងត្រូវ

នៅក្នុងព្រៃម្នាក់ឯងប៉ុណ្ណោះ នឹងឲ្យមទ្រីដល់អ្នកដូចម្ដេចកើតដូច្នេះ តែហាក់ដូចដាក់ចនក់ហាបណៈ ១០០០ លើបាតដៃរបស់បុគ្គលដែលលាចេញទទួល មានព្រះហឫទ័យមិនជាប់ជំពាក់ មិនរួញរា ហាក់ដូចនឹងញ៉ាំងក្ដីឲ្យលាន់ឮ ហើយត្រាស់ថា

ម្នាលព្រាហ្មណ៍ យើងឲ្យរបស់ដែលអ្នកសូមនឹងយើង យើងមិនរួញរាទេ យើងមិនលាក់លៀមវត្ថុដែលមាន ចិត្តរបស់យើងត្រេកអរក្នុងទាន ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សន្តំ ឆប្បដិគុយ្ហាមិ** សេចក្ដីថា មិនលាក់វត្ថុដែលមាន ។

កាលព្រះមហាសត្វត្រាស់យ៉ាងនេះហើយទ្រង់នាំកុណ្ឌីមកមួយរំពេច ច្រួចទឹកចុះក្នុងដៃរបស់ព្រាហ្មណ៍ ព្រះរាជទានបិយទារទានដល់ព្រាហ្មណ៍ អស្ចារ្យទាំងពួងមានប្រការដូចពោលហើយខាងដើម បានប្រាកដក្នុងខណៈនោះឯង ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** វីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសាធូវព្រះគាថាដូច្នេះថា

ព្រះបាទវេស្សន្តរជាអ្នកញ៉ាំងពួកអ្នកសិវិរាស្ត្រឲ្យចម្រើន ចាប់ដៃនាងមទ្រីនិងកុណ្ឌីទឹកហើយ បានដាក់ទានដល់ព្រាហ្មណ៍ ។ កាលដែលព្រះវេស្សន្តរទ្រង់លះបង់ព្រះនាងមទ្រី ហេតុដែលគួរស្ញប់ស្ញែងក៏កើតមានក្នុងកាលនោះ សេចក្ដីព្រឺរោមក៏កើត

មានក្នុងកាលនោះ ផែនដីក៏ញាប់ញ័រ ។ ព្រះនាងមទ្រីមិនមាន
មុខក្រញូវ មិនអៀន មិនឃាំព្រះនាងស្មៀមសម្ងំ ( ព្រះភក្ត្រ )
របស់ព្រះបាទវេស្សន្តរនោះ ( ដោយគិតថា ) ព្រះរាជានេះ
ជ្រាបហេតុដ៏ប្រសើរ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អទា ទានំ** សេចក្ដីថា ព្រះវេស្សន្តរមហាសត្វត្រាស់ថា នែព្រាហ្មណ៍ សព្វញ្ញុតញ្ញាណប៉ុណ្ណោះជាទីស្រឡាញ់របស់អាត្មាក្រៃលែងជាងនាងមទ្រីរាប់រយ រាប់ពាន់ រាប់សែនដង ទានរបស់អាត្មាចូរជាបច្ច័យ ឲ្យបានសម្រេចព្រះសព្វញ្ញុតញ្ញាណ ដូច្នេះហើយបានបរិច្ចាគបិយទារទានសមដូចព្រះពុទ្ធតម្រាស់ដែលត្រាស់ទុកថា

តថាគតកាលដែលលះរាជបុត្រាឈ្មោះជាលី រាជធីតាឈ្មោះ
កណ្ហាជិនានិងនាងទេវីឈ្មោះមទ្រី ដែលមានវត្តដ៏ល្អក្នុងប្ដីមិន
គិត ( ស្ដាយ ) ព្រោះហេតុតែពោធិញ្ញាណដោយពិត ។ បុត្ត
ទាំងពីរ មិនមែនជាទីស្អប់របស់តថាគតទេ នាងទេវីឈ្មោះមទ្រី
មិនមែនមិនជាទីស្រឡាញ់របស់តថាគតទេ សព្វញ្ញុតញ្ញាណជា
ទីស្រឡាញ់របស់តថាគត ព្រោះហេតុនោះ បានជាតថាគតឲ្យ
ជនទាំង ៣ នាក់ជាទីស្រឡាញ់ ( ដល់ព្រាហ្មណ៍ ) ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សម្មកម្បថ** សេចក្ដីថា ផែនដីញាប់ញ័រទល់គ្នានឹងទឹកទ្រផែនដី ។ បទថា **នេវស្ស មទ្ទី ភកុដី** សេចក្ដីថា ម្នាលភិក្ខុទាំងឡាយ ខណៈនោះព្រះនាងមទ្រីមិនមានព្រះភក្ត្រស្រពោន ព្រោះអាក់អន់ថា

ព្រះវេស្សន្តរឲ្យអញដល់ព្រាហ្មណ៍ចាស់ ។ បទថា **ន សន្ធិយតិ ន រោទតិ** សេចក្ដីថា ព្រះនាងមិនខ្មាសអៀន មិនព្រះកន្សែងហូតទឹកក្អែកពេញព្រះនេត្រទាំងសងខាងឡើយដោយព្រះនាងគិតថា ព្រះវេស្សន្តរទតមើលព្រាហ្មណ៍នេះទាំងទ្រង់តុណ្ហីភាពដោយយល់ថា កាលទ្រង់ព្រះរាជទានស្រីកែវដូចអញនឹងមិនព្រះរាជទានដោយឥតហេតុផលឡើយ ព្រះស្វាមីរបស់អញនេះទ្រង់ជ្រាបនូវវត្ថុដ៏ប្រសើរ អធិប្បាយថា ព្រះនាងមទ្រីប្រឋាប់ឈរមើលមុខព្រះវេស្សន្តរដែលមានពណ៌ដូចផ្កាឈូករីក ។

គ្រានោះព្រះមហាសត្វទតព្រះភក្ត្ររបស់ព្រះនាងមទ្រី ដោយទ្រង់គិតថា ព្រះនាងមទ្រីគិតដូចម្ដេចហ្ន៎ ព្រះនាងក៏ក្រាបទូលសួរថា បពិត្រព្រះសម្មតិទេព ទ្រង់ទតមុខខ្ញុំម្ចាស់ធ្វើអ្វី កាលបន្លឺនូវសីហនាទទើបត្រាស់គាថានេះថា

> ខ្ញុំម្ចាស់ជាករិយារបស់ព្រះអង្គអំពីក្មេង ព្រះអង្គជាស្វាមី ជាឥស្សរៈរបស់ខ្ញុំម្ចាស់ស្រាប់ហើយ ចង់ឲ្យខ្ញុំម្ចាស់ដល់អ្នកណា គប្បីឲ្យដល់អ្នកនោះចុះ ចង់លក់ ឬចង់សម្លាប់ ( ក៏បាន )
> ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **យស្ស** សេចក្ដីថា ខ្ញុំម្ចាស់ជាទេវីក្មេងរបស់ព្រះអង្គយ៉ាងណា ទ្រង់នោះឯងជាកស្ដាផង ជាធំផងរបស់ខ្ញុំ ទ្រង់ប្រាថ្នានឹងព្រះរាជទានដល់អ្នកណា គប្បីព្រះរាជទានដល់អ្នកនោះចុះ ឬបើត្រូវការទ្រព្យក៏គប្បីលក់ខ្ញុំ ឬបើត្រូវការសាច់ក៏គប្បីសម្លាប់ខ្ញុំ ព្រោះដូច្នោះសូមទ្រង់ធ្វើវត្ថុដែលទ្រង់គាប់ចិត្តចុះ ខ្ញុំម្ចាស់មិនក្រោធឡើយ ។

លំដាប់នោះសក្កទេវរាជ ជ្រាបអធ្យាស្រ័យដ៏ប្រណីតរបស់ស្តេចទាំង ២ ទ្រង់ក៏សរសើរស្តេចទាំង ២ នោះ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូត្រសានូវព្រះគាថាដូច្នេះថា

ព្រះឥន្ទជាធំជាងទេវតា ជ្រាបសេចក្តីត្រិះរិះរបស់ជនទាំងនោះ ហើយក៏បានពោលដូច្នេះថា ពួកសត្រូវទាំងអស់ដែលឃាត់នូវទិព្វសម្បត្តិនិងមនុស្សសម្បត្តិ ព្រះអង្គក៏បានឈ្នះហើយ ព្រះអង្គបានញ៉ាំងផែនដីឲ្យខ្ទរខ្ទារ កិត្តិសព្ទរបស់ព្រះអង្គផ្សាយទៅដល់ទេវលោក ផ្គរបន្ទោរក៏ដាលប្រវាត់ជុំវិញដូចជាសំឡេងលាន់នៃភ្នំទាំងឡាយ ។ ពួកទេវតាទាំង ២ ក្រុម គឺនារទៈនិងបព្វតៈទាំងព្រះឥន្ទ ព្រះព្រហ្មនិងបជាបតិទេវបុត្ត សោមទេវ-បុត្ត ព្រះបាទយមៈនិងព្រះបាទវេស្សវ័ណ រីករាយតាមព្រះអង្គនោះ ពួកទេវតាទាំងអស់ក៏រីករាយតាម ( យ៉ាងនេះថា ) មែនពិតព្រះបាទវេស្សន្តរនោះធ្វើអំពើ ដែលគេធ្វើបានដោយកម្រ ។ កាលដែលពួកជនកំពុងឲ្យវត្ថុដែលគេឲ្យបានដោយកម្រ កំពុងធ្វើអំពើដែលគេធ្វើបានដោយកម្រ ពួកអសប្បុរសរមែងមិនធ្វើតាម ( អំពើនោះ ) ឡើយ ធម៌របស់ពួកសប្បុរស គឺគេដឹងបានដោយក្រ ។ ព្រោះហេតុនោះដំណើរទៅអំពីលោកនេះ ( ទៅ

កាន់បរលោក ) នៃពួកសប្បុរសនិងពួកអសប្បុរសជាដំណើរ ផ្សេងគ្នា ពួកអសប្បុរសទៅកាន់នរក ពួកសប្បុរសមានឋាន សួគ៌ប្រព្រឹត្តទៅក្នុងខាងមុខ ។ ព្រះអង្គកាលដែលគង់នៅក្នុងព្រៃ បានប្រទានកុមារទាំងពីរ ទាំងបានប្រទានភរិយា ទានទាំងពីរ នោះឈ្មោះថាជាយានដ៏ប្រសើរ មិននាំចុះទៅ ( កាន់អបាយ ភូមិ ) ទេ យានដ៏ប្រសើរនោះ សូមសម្រេចដល់ព្រះអង្គក្នុង ឋានសួគ៌ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បច្ចូហា** បានដល់ បុគ្គលដែលជាសត្រូវ ។ បទថា **ទិព្វា** បានដល់ ហាមនូវទិព្វសម្បត្តិ ។ បទថា **មានុសា** បានដល់ ហាមនូវមនុស្សសម្បត្តិ ។ សួរថា ធម៌ទាំងនោះគឺធម៌ពួកណា ឆ្លើយថា ធម៌ គឺសេចក្ដីកំណាញ់ កាលសេចក្ដីកំណាញ់គ្រប់យ៉ាងនោះដែលមហាសត្វប្រទាន ព្រះឱរស ធីតានិងមហេសីទ្រង់ឈ្នះហើយ ព្រោះហេតុនោះទើបសក្កទេវរាជ ត្រាស់ថា **សព្វេ ជិតា តេ បច្ចូហា** ដូច្នេះ ។ បទថា **ទុក្ករំ ហិ ករោតិ សោ** សេចក្ដីថា សក្កទេវរាជត្រាស់ថា ទេវតាទាំងពួងនោះអនុមោទនាយ៉ាង នេះថា ព្រះវេស្សន្តរនោះប្រថាប់នៅក្នុងព្រៃមួយព្រះអង្គឯងប៉ុណ្ណោះ កាល ប្រទានមហេសីដល់ព្រាហ្មណ៍ រមែងធ្វើកម្មដែលធ្វើបានដោយលំបាក សក្ក- ទេវរាជកាលទ្រង់ធ្វើអនុមោទនា ទើបត្រាស់គាថានេះថា **យមេតំ** ជាដើម ។ បទថា **វនេ វសំ** បានដល់ ប្រថាប់នៅក្នុងព្រៃ ។ បទថា **ព្រហ្មយានំ** បាន ដល់ យានដ៏ប្រសើរ ឯធម៌ គឺសុចរិត ៣ និងធម៌ គឺការបរិច្ចាគបែបនេះរមែង

ជាបច្ច័យនៃអរិយមគ្គ ហេតុនោះទើបលោកហៅថា ព្រហ្មយាន ព្រោះហេតុនោះព្រហ្មយាននេះទើបសម្រេចដល់ទ្រង់ បុគ្គលឲ្យទានក្នុងថ្ងៃនេះព្រោះមិនត្រូវទៅកាន់អបាយភូមិ ។ បទថា **សគ្គេ តេ តំ វិបច្ចតុ** សេចក្តីថា សូមឲ្យមហាទានសម្រេចសព្វញ្ញុតញ្ញាណក្នុងទីបំផុតនៃវិបាកនោះឯង ។

សក្កទេវរាជទ្រង់អនុមោទនាដល់ព្រះវេស្សន្តរយ៉ាងនេះហើយ ទ្រង់ក៏ត្រិះរិះថា ឥឡូវនេះអញគួរមិនយឺតយូរក្នុងទីនេះ គួរសងព្រះនាងមទ្រីដល់ព្រះវេស្សន្តរហើយត្រឡប់ទៅ ទ្រង់ត្រិះរិះដូច្នេះហើយត្រាស់ថា

ឥឡូវខ្ញុំសូមថ្វាយនាងមទ្រី ជាស្ត្រីមានសព៌ាង្គដ៏ល្អ ជាកិរិយារបស់ព្រះអង្គវិញ ព្រះអង្គសមគួរនឹងនាងមទ្រីដោយពិត នាងមទ្រីក៏សមគួរនឹងព្រះអង្គដែលជាកស្វាដែរ ។ វត្ថុទាំងពីរ គឺទឹកដោះស្រស់មួយ ស័ង្ខមួយមានសម្បុរស្មើគ្នាយ៉ាងណាមិញ ព្រះអង្គនឹងនាងមទ្រីមានព្រះហឫទ័យស្មើគ្នាក៏យ៉ាងនោះដែរ ។ ព្រះអង្គទាំងពីរជាក្សត្រិយ៍បរិបូណ៌ដោយគោត្ត មានព្រះជាតិល្អខាងមាតានិងបិតា ត្រូវគេនិរទេសមកគង់នៅក្នុងអាស្រមនាព្រៃនេះ ព្រះអង្គគប្បីធ្វើបុណ្យឲ្យទាន តាមសមគួរតៗទៅដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ជាន្ទោ** បានដល់ សមគួរ ។ បទថា **ឧភោ សមានវណ្ណិនោ** សេចក្តីថា ជនទាំង ២ មានពណ៌សម្បុរស្មើគ្នាបរិសុទ្ធិពិត ។ បទថា **សមានមនចេតសា** សេចក្តីថា ប្រកបដោយចិត្ត ពោលគឺមនៈដែល

ស្មើគ្នាដោយគុណ មានអាចារជាដើម ។ បទថា **អវរុទ្ធេត្ថ** សេចក្តីថា ត្រូវនិរទេសចាកដែន ប្រថាប់នៅក្នុងអារញ្ញប្បទេសនេះ ។ បទថា **យថា បុញ្ញានិ** សេចក្តីថា ទ្រង់ត្រេកអរដោយបុណ្យត្រឹមប៉ុណ្ណោះ គឺបុណ្យដែលទ្រង់ធ្វើទុកជាច្រើនក្នុងជេតុត្តរនគរ បុណ្យដែលទ្រង់ធ្វើដូចកាលពីម្សិលមិញព្រះរាជទានព្រះរាជឱរសព្រះរាជធីតា ថ្ងៃនេះព្រះរាជទានអគ្គមហេសី ទ្រង់បរិច្ចាគបន្តក្រៃលែងឡើងជាងដែលពោលហើយនោះ គប្បីបំពេញបុណ្យទាំងឡាយតាមសមគួរចុះ ។ លំដាប់នោះសក្កទេវរាជទ្រង់ប្រគល់ព្រះនាងមទ្រី ដល់ព្រះមហាសត្វហើយ កាលទ្រង់ប្រាប់ថាជាព្រះឥន្រ្ទដើម្បីថ្វាយព្រះពរទើបត្រាស់ថា

> ខ្ញុំជាទេវិន្ទឈ្មោះសក្កៈ បានមកក្នុងសំណាក់ព្រះអង្គ បពិត្រព្រះរាជាជាឥសី សូមព្រះអង្គទទួលយកពរចុះ ខ្ញុំសូមថ្វាយពរ ៨ យ៉ាងចំពោះព្រះអង្គ ដូច្នេះ ។

កាលសក្កទេវរាជត្រាស់យ៉ាងនោះឯង អត្តភាពរបស់ទ្រង់ក៏រុងរឿងជាទិព្វស្ថិតនៅក្នុងអាកាសហាក់បីដូចពន្លឺព្រះអាទិត្យស្រទន់ដូច្នោះ តែព្រះពោធិសត្វកាលទ្រង់ទទួលពរក៏ត្រាស់ថា

> បពិត្រសក្កៈជាធំជាងទេព្តាទាំងពួង បើព្រះអង្គនឹងប្រទានពរដល់ខ្ញុំ ( ខ្ញុំ ) សូមព្រះបិតាស្រុះស្រួលទទួលខ្ញុំដែលទៅអំពីព្រៃនេះដល់សំណាក់របស់ខ្លួន សូមអញ្ជើញខ្ញុំដោយអាសនៈ ( រាជសម្បត្តិ ) ខ្ញុំសូមពរទី ១ នេះ ។ ខ្ញុំសូមមិនចូលចិត្តនឹងការសម្លាប់បុរស ខ្ញុំសូមដោះអំពីការសម្លាប់នូវមនុស្សដែលគេត្រូវ

សម្ងាប់ សូម្បីមនុស្សនោះធ្វើអំពើមោះមៃ ( មានកំហុសក្នុងព្រះរាជា ) ក៏ដោយ ខ្ញុំសូមពរទី ២ នេះ ។ សូមឲ្យពួកបុរសទាំងចាស់ក្មេង ទាំងកណ្ដាលរស់នៅអាស្រ័យនឹងខ្ញុំ ខ្ញុំសូមពរទី ៣ នេះ ។ ខ្ញុំសូមមិនគប់រកប្រពន្ធអ្នកដទៃ ខ្ញុំសូមជាអ្នកខ្វល់ខ្វាយចំពោះតែប្រពន្ធរបស់ខ្លួន ខ្ញុំសូមមិនលុះក្នុងអំណាចពួកស្ត្រី ខ្ញុំសូមពរទី ៤ នេះ ។ បពិត្រសក្កៈ បុត្ររបស់ខ្ញុំកើតហើយ សូមឲ្យបុត្រនោះមានអាយុវែង សូមឲ្យបានគ្រួតត្រាផែនដីដោយធម៌ ខ្ញុំសូមពរទី ៥ នេះ ។ តអំពីនោះមកនាកាលរាត្រីកន្លងទៅ ព្រះអាទិត្យរះឡើងសូមចំណីជាទិព្វទាំងឡាយមានប្រាកដ ខ្ញុំសូមពរទី ៦ នេះ ។ កាលបើខ្ញុំកំពុងឲ្យ សូម ( ទេយ្យធម៌ ) កុំបីអស់ទៅ លុះខ្ញុំឲ្យហើយសូមកុំឲ្យក្ដៅក្រហាយស្ដាយក្រោយ ខ្ញុំកំពុងឲ្យសូមឲ្យចិត្តជ្រះថ្លា ខ្ញុំសូមពរទី ៧ នេះ ។ កាលបើខ្ញុំច្យុតចាកអត្តភាពនេះ សូមឲ្យបានទៅកាន់ឋានសួគ៌ដល់នូវឋានដ៏វិសេស គឺកើតក្នុងតុសិតបុរី ( កាលបើខ្ញុំច្យុតចាកតុសិតភពនោះមក ) សូមកុំឲ្យកើត ( ក្នុងភពថ្មីទៀត ) ខ្ញុំសូមពរទី ៨ នេះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អនុមោទេយ្យ** បានដល់ គប្បីទទួល គឺមិនក្រោធ ។ បទថា **ឥតោ បត្តំ** បានដល់ ចេញអំពីព្រៃនេះ ដល់និវេសន៍នៃខ្លួន ។ បទថា **អាសនេន** បានដល់ ដោយរាជបល្ល័ង្ក គឺព្រះវេស្សន្តរត្រាស់

ថា សូមព្រះជនកប្រទានរាជសម្បត្តិដល់ខ្ញុំ ។ បទថា **អបិ កិព្ពិសការកំ** សេចក្តីថា ខ្ញុំជាព្រះរាជាគប្បីលែងអ្នកទោសប្រហារ ( ជីវិត ) សូម្បីធ្វើខុសចំពោះព្រះរាជាឲ្យផុតចាកការប្រហារ ទោះបីខ្ញុំមានសភាពយ៉ាងនេះក៏មិនពេញចិត្តក្នុងការប្រហារ ។ បទថា **មមេវ ឧបជីវេយ្យុំ** សេចក្តីថា សូមពួកជនទាំងនោះគប្បីអាស្រ័យខ្ញុំនេះឯងចិញ្ចឹមជីវិត ។ បទថា **ធម្មេន ជិនេ** សេចក្តីថា ចូរឈ្នះដោយធម៌ គឺចូរគ្រងរាជសម្បត្តិដោយស្មើ ។ បទថា **វិសេសគូ** សេចក្តីថា ព្រះវេស្សន្តរត្រាស់ថា ខ្ញុំសូមជាបុគ្គលទៅកាន់ស្ថានសួគ៌ជាន់វិសេស គឺជាអ្នកកើតក្នុងជាន់តុសិត ។ បទថា **អនិវត្តិ តតោ អស្សំ** សេចក្តីថា ព្រះវេស្សន្តរត្រាស់ថា ខ្ញុំចុតិអំពីតុសិតភពនោះហើយមកជាមនុស្ស គប្បីជាមនុស្សមិនកើតក្នុងភពថ្មីនោះឯង គឺគប្បីសម្រេចសព្វញ្ញុតញ្ញាណ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** វីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសាទូវព្រះគាថាដូច្នេះថា

ព្រះឥន្ទ្រ ជាធំជាងទេវតា បានទ្រង់ព្រះសណ្តាប់ព្រះបន្ទូលព្រះ
បាទវេស្សន្តរនោះហើយ ក៏ពោលពាក្យយ៉ាងនេះថា ព្រះបិតា
បង្កើតរបស់ព្រះអង្គមិនយូរទេ នឹងមកចួបព្រះអង្គ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧជ្ជមេស្សតិ** សេចក្តីថា បពិត្រមហារាជ ព្រះបិតារបស់ព្រះអង្គនឹងមកសួរសុខទុក្ខព្រះអង្គ នឹងយាងមកទីនេះក្នុងកាលមិនយូរឡើយ កាលយាងមកហើយនឹងព្រះរាជទានស្វេតច្ឆត្រដល់ទ្រង់ យាង

ទ្រង់ទៅជេតុត្តរនគរនោះឯង សេចក្តីប្រាថ្នារបស់ព្រះអង្គគ្រប់យ៉ាង នឹងដល់នូវទីបំផុត ទ្រង់កុំក្តៅក្រហាយឡើយ សូមទ្រង់កុំប្រមាទ ។

កាលប្រទានឱវាទដល់ព្រះមហាសត្វយ៉ាងនេះហើយ សក្កទេវរាជក៏យាងទៅកាន់ទិព្វស្ថានរបស់ទ្រង់នោះឯង ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសានូវព្រះគាថាដូច្នេះថា

> មឃទេវរាជ ជាប្តីនៃនាងសុជាតា លុះត្រាស់ព្រះតម្រាស់នេះ
> ហើយប្រទានពរដល់ព្រះបាទវេស្សន្តរ ហើយក៏ចៀសចេញទៅ
> កាន់ពួកទេវតាក្នុងឋានសួគ៌ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វេស្សន្តរេ** បានដល់ ដល់ព្រះវេស្សន្តរ ។ បទថា **អបក្កមិ** បានដល់ យាងទៅហើយ គឺយាងទៅមួយរំពេចនោះឯង ។

**សក្កបព្វៈ ចប់**

# មហាភាជបត្ត:

កាលនោះព្រះវេស្សន្តរពោធិសត្វនិងព្រះនាងមទ្រី ទ្រង់ត្រេកអរស្នាក់នៅក្នុងអាស្រមដែលសក្កៈប្រទាន គ្រានោះជូជកព្រាហ្មណ៍នាំជាលីនិងកណ្ហាជិនាធ្វើដំណើរក្នុងផ្លូវ ៦០ យោជន៍ ពួកទេវតាបានរក្សាព្រះរាជកុមារកុមារី ឯជូជកកាលព្រះអាទិត្យអស្តង្គតក៏ចងកុមារទាំង ២ ទុកត្រង់គុម្ពឈើ ឲ្យផ្ទុំលើផែនដីខ្លួនឯងឡើងដើមឈើ ដេកត្រង់ប្រគាបឈើព្រោះខ្លាចសត្វសាហាវ ។

ក្នុងខណៈនោះ មានទេវបុត្តមួយអង្គកាឡាខ្លួនជាព្រះវេស្សន្តរ ទេពធីតាមួយអង្គកាឡាខ្លួនជាព្រះនាងមទ្រី មកស្រាយកុមារទាំង ២ ប្រេបាច់ព្រះហស្តនិងព្រះបាទទាំង ២ ឲ្យស្រង់ទឹក ឲ្យប្រដាប់និងសោយទិព្វភោជនីយាហារតាក់តែងដោយគ្រឿងអលង្ការសព្វយ៉ាង ឲ្យផ្ទុំលើកម្រាលទិព្វ លុះអរុណរះឡើងក៏ឲ្យផ្ទុំដោយគ្រឿងពន្ធនាការដូចមុន ហើយក៏អន្តរធានបាត់ទៅ ។ រាជកុមារទាំង ២ នោះ ជាអ្នកមិនមានរោគ យាងទៅដោយទេវសង្គ្រោះយ៉ាងនេះ កាលរាត្រីអស់ហើយជូជកក៏ចុះអំពីដើមឈើ លុបមុខ ខ្ពុរមាត់ ទំពាឈើស្ទន់ហើយបរិភោគផ្លែឈើ ស្រាយកុមារទាំង ២ ដឹកទៅដល់ផ្លូវមួយគិតថាអញនឹងទៅកាលិង្គរដ្ឋ ហើយដើរទៅឃើញផ្លូវបែកជា ២ មួយទៅកាលិង្គរដ្ឋមួយទៅជេតុត្តរនគរ ទេវតាបណ្ដាលចិត្តគាត់ក៏លះផ្លូវទៅកាលិង្គរដ្ឋឃើញផ្លូវមួយទៅជេតុត្តរនគរក៏នាំកុមារទៅដោយសម្គាល់ថា ផ្លូវនេះជាផ្លូវទៅកាលិង្គរដ្ឋគាត់គិតថា អញនឹងទៅកាលិង្គរដ្ឋ ធ្លងជើងភ្នំដែលទៅបានដោយលំបាកទាំងឡាយ ដល់នគរជេតុត្តរក្នុងកាលកន្ទះខែ ។

ថ្ងៃនោះក្នុងពេលទៀបភ្លឺព្រះបាទសញ្ជ័យសិវិរាជ ទ្រង់ព្រះរាជសុបិនថា កាលព្រះបាទសញ្ជយមហារាជប្រថាប់គង់ក្នុងទីវិនិច្ឆ័យ មានបុរសម្នាក់សម្បុរខ្មៅនាំផ្កាឈូក ២ ទង មកដាក់ក្នុងព្រះហស្តរបស់ទ្រង់ ព្រះរាជាទទួលផ្កាទាំង ២ នោះ ទ្រង់ប្រដាប់ត្រង់ត្រចៀកទាំងសងខាង លម្អងកេសរនៃផ្កាឈូកទាំង ២ នោះ ក៏ជ្រុះរោយរាយលើព្រះឧរៈនៃព្រះរាជា ព្រះបាទសញ្ជ័យទ្រង់តើនអំពីទីបន្ទំ ត្រាស់ហៅពួកព្រាហ្មណ៍ដែលទាយសុបិន មកត្រាស់សួរព្រាហ្មណ៍ទាំងនោះទូលព្យាករថា បពិត្រព្រះសម្មតិទេព ព្រះញាតិរបស់ព្រះអង្គដែលព្រាត់ទៅឆ្ងាយនឹងត្រឡប់មក ព្រះបាទសញ្ជ័យបានស្តាប់ពាក្យព្យាករណ៍នោះទ្រង់ត្រេកអរ ឲ្យព្រាហ្មណ៍ទាំងនោះត្រឡប់ទៅ ទ្រង់កក់សក់អំពីព្រលឹមហើយសោយភោជនាហារមានរសប្រសើរផ្សេងៗ តាក់តែងព្រះកាយដោយគ្រឿងអលង្ការ គឺអាភរណៈទាំងពួង គង់ប្រថាប់ក្នុងមហាវិនិច្ឆ័យ ។ ទេវតានាំព្រាហ្មណ៍និងកុមារទាំង ២ មកឈរត្រង់លានព្រះរាជវាំង ។ ខណៈនោះព្រះបាទសញ្ជ័យទតមាគ៌ា ទ្រង់ឃើញកុមារទាំង ២ ទើបត្រាស់ថា

មុខអ្នកណាទុំះ ភ្លឺដូចមាសដែលគេរំលាយដោយភ្លើង ឬដូច
មាសត្ពោរ ភ្លឺចិញ្ចែងចិញ្ចាចក្នុងមាត់បាវ ។ កុមារទាំងពីរមាន
អវយវៈស្រដៀងគ្នា កុមារទាំងពីរ មានលក្ខណៈស្រដៀងគ្នា
កុមារម្នាក់ស្រដៀងនឹងជាលី កុមារីម្នាក់ដូចនាងកណ្ហាជិនា ។
កុមារទាំងពីរបរិបូណ៌ដោយរូបសម្បត្តិ ដូចជាពួកសីហៈដែល
ចេញអំពីរូង ទារកទាំងនេះប្រាកដដូចរូបជាវិការៈនៃមាស

ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **វុត្តត្តមគ្គិនា** បានដល់ រំលាយដោយភ្លើង ។ បទថា **សីហា វិលាវ និក្ខន្តា** សេចក្ដីថា ដូចគ្នានឹងរាជសីហ៍ចេញអំពីគុហាមាស ។

ព្រះបាទសញ្ជ័យត្រាស់សរសើរកុមារដោយគាថា ៣ យ៉ាងនេះហើយមានព្រះរាជតម្រាស់ត្រាស់នឹងអាមាត្យអ្នកឈ្លាស ដែលសិក្សាល្អហើយថា ចូរអ្នកទៅនាំព្រាហ្មណ៍និងកុមារទាំង ២ មក អាមាត្យនោះបានស្ដាប់ដូច្នោះ ក៏ក្រោកឡើងទៅដោយរហ័ស នាំព្រាហ្មណ៍និងទារកទាំង ២ មកបង្ហាញដល់ព្រះបាទសញ្ជ័យ គ្រានោះព្រះបាទសញ្ជ័យកាលត្រាស់សួរជូជកព្រាហ្មណ៍ទើបមានព្រះតម្រាស់ថា

ម្នាលភារទ្វាជៈ អ្នកនាំទារកទាំងពីរនេះមកអំពីទីណាហ្ន៎ ម្នាលព្រាហ្មណ៍ អ្នកមកដល់ដែនក្នុងថ្ងៃនេះ តើអ្នកមកអំពីទីណា ដូច្នេះ ។

ជូជកទូលស្នងព្រះរាជតម្រាស់ថា

បពិត្រព្រះទេវៈទ្រង់ព្រះនាមសញ្ជ័យ ព្រះបាទវេស្សន្តរទ្រង់មានព្រះហឫទ័យត្រេកអរ បានប្រទានទារកទាំងនោះដល់ទូលព្រះបង្គំជាខ្ញុំ តាំងពីថ្ងៃដែលទូលព្រះបង្គំជាខ្ញុំបានទារកមក ១៥ រាត្រីក្នុងថ្ងៃនេះហើយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **វិត្តេន** បានដល់ ត្រេកអរ គឺជ្រះថ្លា ។ បទ

ថា **អជ្ជ បណ្ណរសា រត្តិ** សេចក្តីថា ជូជកទូលថា ចាប់តាំងពីទូលព្រះបង្គំបានកុមារកុមារីទាំងនេះមក ១៥ ថ្ងៃក្នុងថ្ងៃនេះហើយ ។

ព្រះបាទសញ្ជ័យត្រាស់ថា

អ្នកឯងធ្វើយើងឲ្យជឿដោយពាក្យជាទីស្រឡាញ់ តាមហេតុត្រឹមត្រូវដូចម្តេចបាន នរណាហ៊ានលើកបុត្តទាំងពីរឲ្យជាទានដ៏ឧត្តមហើយឲ្យដល់អ្នក ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កេន វាចាយ បេយ្យេន** សេចក្តីថា នែតាព្រាហ្មណ៍ ឯងបានកុមារកុមារីទាំងនោះដោយពាក្យជាទីស្រឡាញ់ដូចម្តេច ។ បទថា **សទ្ធា ញាយេន សទ្ទហេ** សេចក្តីថា ឯងកុំធ្វើមុសាវាទឲ្យពួកយើងជឿដោយហេតុការណ៍ដោយប្រពៃនោះឯង ។ បទថា **បុត្តកេ** សេចក្តីថា អ្នកណានឹងធ្វើកូនតូចៗ ដែលគួរស្រឡាញ់របស់ខ្លួនឲ្យជាទានដ៏ប្រសើរ រួចឲ្យទាននោះដល់ឯង ។

ជូជកក្រាបទូលថា

ព្រះបាទវេស្សន្តរណា ជាទីពឹងរបស់ពួកស្ងួម ដូចជាព្រះធរណីជាទីពឹងរបស់ពួកសត្វ ព្រះបាទវេស្សន្តរនោះទ្រង់គង់នៅក្នុងព្រៃបានប្រទានបុត្តទាំងពីរដល់ទូលព្រះបង្គំជាខ្ញុំ ។ ព្រះវេស្សន្តរណាជាទីប្រព្រឹត្តទៅនៃពួកស្ងួមដូចសាគរជាទីប្រព្រឹត្តទៅនៃស្ទឹងទាំងឡាយ ព្រះបាទវេស្សន្តរនោះទ្រង់គង់នៅក្នុងព្រៃ បានប្រទានបុត្តទាំងពីរដល់ទូលព្រះបង្គំជាខ្ញុំ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បតិដ្ឋាសិ** បានដល់ ជាទីពឹងអាស្រ័យ ។

អាមាត្យទាំងឡាយបានស្ដាប់ដូជកពោលដូច្នោះ កាលនឹងតិះដៀលព្រះវេស្សន្តរក៏ពោលថា

ម្នាលគ្នាយើង ព្រះរាជាកាលទ្រង់គង់នៅក្នុងព្រះរាជដំណាក់ ទ្រង់មានសទ្ធា ធ្វើអាក្រក់ណាស់ ព្រះបាទវេស្សន្តរត្រូវគេនិរទេសទៅគង់នៅក្នុងព្រៃហើយ ម្ដេចក៏នៅតែប្រទានបុត្តទាំងពីរទៀត ។ នែអ្នកដ៏ចម្រើនទាំងឡាយ អ្នកទាំងប៉ុន្មាននាក់ដែលបានមកចួបជុំគ្នាក្នុងទីនេះ ចូរស្ដាប់រឿងនេះចុះ ហេតុដូចម្ដេចបានជាព្រះបាទវេស្សន្តរទៅគង់នៅក្នុងព្រៃហើយ ក៏ប្រទានបុត្តទាំងពីរ ។ ព្រះអង្គគួរប្រទានទាសា ទាសី សេះ រថ ដែលទឹមដោយសេះអស្សតរផង គួរប្រទានដំរីកុញ្ជរផង ហេតុដូចម្ដេចបានជាដាក់ទានទារកទាំងពីរទៀត ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សទ្ធេន** សេចក្ដីថា បពិត្រព្រះអង្គ ព្រះរាជាទ្រង់មានសទ្ធាទ្រង់ប្រកបដោយសេចក្ដីជ្រះថ្លា ។ បទថា **យរមេសិនា** សេចក្ដីថា រឿងនេះព្រះវេស្សន្តរកាលទ្រង់នៅជាយរាវាសវិស័យ ទ្រង់ធ្វើមិនត្រឹមត្រូវ គឺទ្រង់ធ្វើមិនគួរប្ញ៉ះ ។ បទថា **អវរុទ្ធកោ** សេចក្ដីថា ព្រះវេស្សន្តរត្រូវបណ្ដេញចាកដែនប្រថាប់នៅក្នុងព្រៃ ។ បទថា **ឥមំ ភោន្តោ** សេចក្ដីថា អាមាត្យទាំងឡាយពោលយ៉ាងនេះដោយបំណងថា អ្នកនគរដ៏ចម្រើនទាំងឡាយដែលមកប្រជុំគ្នាក្នុងទីនេះទាំងអស់ ចូរពិចារណា គឺពិចារណាមើលរឿងនេះចុះ ព្រះ

វេស្សន្តរនេះព្រះរាជទានកូនតូចៗរបស់ទ្រង់ឲ្យជាទាសៈទៅកើត រឿងយ៉ាងនេះមិនធ្លាប់មានអ្នកណាធ្វើឡើយ ។ បទថា **ឧដ្ឋា** សេចក្តីថា ចូរព្រះរាជទានទ្រព្យណាមួយបណ្តាទ្រព្យទាំងឡាយមានទាសៈជាដើម ។ បទថា **កថំ សោ ឧដ្ឋា ទារកេ** សេចក្តីថា អាមាត្យទាំងឡាយពោលថា ព្រះវេស្សន្តរបានព្រះរាជទានព្រះរាជឱរសព្រះរាជធីតាទាំងនេះ ព្រោះហេតុអ្វី ។

ជាលីរាជកុមារ បានស្តាប់ពាក្យអាមាត្យទាំងនោះ កាលទ្រង់អត់ធន់នឹងពាក្យនិន្ទាព្រះជនកមិនបាន ហាក់បីដូចជាបុគ្គលទ្រទ្រង់ភ្នំសិនេរុដែលត្រូវខ្យល់ប្រហារដោយដៃទាំង ២ របស់ទ្រង់ ទើបត្រាស់គាថានេះថា

បពិត្រព្រះអយ្យកោ ទាសៈ សេះ ឬរថដែលទឹមដោយសេះ
អស្សតរនិងដំរីកុញ្ជរមិនមានក្នុងផ្ទះនៃបុគ្គលណា បុគ្គលនោះ
នឹងឲ្យដូចម្តេចកើត ដូច្នេះ ។

ព្រះបាទសញ្ជ័យបានស្តាប់ដូច្នោះ ទើបត្រាស់ថា

នែចៅ យើងសរសើរទានបិតារបស់អ្នក យើងមិនមែនបន្តុះ
បង្អាប់ទេ ចុះហឫទ័យ ( នៃបិតារបស់បា ) តើដូចម្តេចបាន
ជាឲ្យបាទាំងពីរដល់ស្មូម ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ទានមស្ស បសំសាម** សេចក្តីថា នែចៅតូច ពួកយើងសរសើរទានរបស់បិតាឯង មិនមែនតិះដៀលឡើយ ។

ជាលីរាជកុមារបានស្តាប់ដូច្នោះ ក៏ត្រាស់ថា

បពិត្រមហារាជ ( ការណ៍ដែល ) ព្រះបិតារបស់ទូលព្រះបង្គំ

ជាខ្ញុំទ្រង់ប្រទានយើងខ្ញុំដល់ស្មូម ( នោះ ) សូមព្រះអង្គទ្រង់ព្រះសណ្ដាប់នូវវាចាគួរឲ្យអាណោចអាធ័ម ដែលនាងកណ្ហាជិនាជាប្អូនពោលចុះ ។

ហឫទ័យនៃព្រះបិតារបស់ទូលព្រះបង្គំជាខ្ញុំនោះជាទុក្ខ ទាំងទ្រង់មានអស្សាសបស្សាសៈដ៏ក្ដៅ ព្រះបិតាមានព្រះនេត្រក្រហមដូចជាផ្កាយរោហិណី ទ្រង់សម្រក់ទឹកព្រះនេត្រ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ទុក្ខស្ស** សេចក្ដីថា បពិត្រព្រះអយ្យកា បិតានោះស្ដាប់ពាក្យរបស់នាងកណ្ហាជិនាពោល ទ្រង់មានព្រះហឫទ័យជាទុក្ខ ។ បទថា **រោហិណីហេវ តម្ពក្ខី** សេចក្ដីថា បិតារបស់ខ្ញុំមានព្រះនេត្រក្រហមដូចផ្កាយរោហិណី ដែលមានពណ៌ក្រហមដូច្នោះ ទ្រង់មានទឹកភ្នែកហូរដូចតំណក់ឈាមដូច្នោះ ។

ឥឡូវនេះជាលីកុមារកាលទ្រង់សម្ដែងព្រះវាចា ដែលកណ្ហាជិនានោះពោលទើបត្រាស់ថា

នាងកណ្ហាជិនាបានពោលនឹងព្រះបិតានោះថា បពិត្រព្រះបិតាព្រាហ្មណ៍នេះវាយខ្ញុំម្ចាស់ដោយឈើប្រត់ដូច ( ម្ចាស់ ) វាយទាសីដែលកើតក្នុងផ្ទះ ។ បពិត្រព្រះបិតា អ្នកនេះមិនមែនជាព្រាហ្មណ៍ទេព្រោះពួកព្រាហ្មណ៍តែងជាអ្នកប្រព្រឹត្តធម៌ បពិត្រព្រះបិតា យក្សក្លែងភេទជាព្រាហ្មណ៍ នាំពួកយើងខ្ញុំយកទៅស៊ីទេដឹង ។ បពិត្រព្រះបិតា យើងខ្ញុំកាលបិសាចនាំយកទៅ ហេតុ

អ្វីក៏ព្រះអង្គទ្រង់ទតព្រងើយ ដូច្នេះ ។

លំដាប់នោះព្រះបាទសញ្ជ័យទតព្រះរាជនត្តាទាំងទ្វេ ដែលមិនទាន់ផុតអំពីដៃជូជកព្រាហ្មណ៍ទើបត្រាស់គាថានេះថា

មាតារបស់អ្នកជាព្រះរាជបុត្រី បិតារបស់អ្នកជាព្រះរាជបុត្រា
ក្នុងកាលពីដើមបាទាំងពីរឡើងកាន់ភ្លៅរបស់អញ ចុះហេតុអ្វី
បានជាបាទាំងពីរឋិតនៅក្នុងទីឆ្ងាយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បុព្វេ មេ** សេចក្តីថា អំពីមុននេះចៅទាំង ២ ឃើញជីតាហើយចូលមកដោយរហ័សឡើងមកអង្គុយលើភ្លៅ ឥឡូវនេះហេតុអ្វីហ្ន៎ទើបចៅទាំង ២ ឈរនៅឆ្ងាយ ។

ជាលីរាជកុមារក្រាបទូលថា

ព្រះមាតារបស់ពួកទូលព្រះបង្គំជាខ្ញុំ ជាព្រះរាជបុត្រី ព្រះបិតា
របស់ពួកទូលព្រះបង្គំជាខ្ញុំ ជាព្រះរាជបុត្រា ទូលព្រះបង្គំជាខ្ញុំ
ទាំងពីរនាក់ ជាទាសារបស់ព្រាហ្មណ៍ ហេតុនោះបានជាទូល
ព្រះបង្គំជាខ្ញុំឋិតនៅក្នុងទីឆ្ងាយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ទាសា មយំ** សេចក្តីថា បពិត្រព្រះសម្មតិទេព កាលមុនទូលបង្គំទាំង ២ ជារាជបុត្តតែឥឡូវនេះជាទាសៈរបស់ព្រាហ្មណ៍ មិនមែនជាចៅរបស់ទ្រង់ឡើយ ។

ព្រះបាទសញ្ជ័យត្រាស់ថា

នែចៅសម្លាញ់ទាំងពីរ បាទាំងពីរកុំពោលយ៉ាងនេះឡើយនាំ

ឲ្យក្តៅហឫទ័យរបស់ជីតាណាស់ កាយរបស់ជីតាហាក់ដូចជា ( គេលើកដាក់ ) លើជើងថ្ករ ជីតាមិនបានសុខលើអាសនៈទេ ។

នែចៅសម្លាញ់ទាំងពីរ បាទាំងពីរកុំពោលយ៉ាងនេះឡើយ បាឯងរីងរឹតតែញុំាងសំណោកឲ្យកើតដល់ជីតា ជីតានឹងលោះដោះសាបាដោយទ្រព្យ មិនឲ្យបានៅជាទាសាគេទេ ។ នែបា បិតារបស់បាបានកាត់ថ្លៃប៉ុន្មាន ហើយបានឲ្យបាទាំងពីរដល់ព្រាហ្មណ៍ បាចូរប្រាប់ដល់ជីតាឲ្យត្រង់ ពួកអាមាត្យចូរញុំាងព្រាហ្មណ៍ឲ្យទទួលទ្រព្យ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សម្ម** ជាពាក្យសម្តែងសេចក្តីស្រឡាញ់ ។ បទថា **ចិតកាយំវ មេ កាយោ** សេចក្តីថា ឥឡូវនេះកាយរបស់ជីតាដូចគេលើកឡើងដាក់លើជើងថ្ករដែលមានរងើកភ្លើង។ បទថា **ជនេថ មំ** សេចក្តីថា ឲ្យកើតដល់ជីតា ។ បាលីក៏យ៉ាងនេះឯង ។ បទថា **និក្កិនិស្សាមិ ធនេន** សេចក្តីថា នឹងឲ្យទ្រព្យហើយលោះចៅអំពីភាពជាទាសៈ ។ បទថា **កិមគ្ឃិយំ** សេចក្តីថា កាត់ថ្លៃប៉ុន្មាន ។ បទថា **បដិចាទេន្តុ** សេចក្តីថា ចូរឲ្យព្រាហ្មណ៍ទទួលទ្រព្យ ។

ជាលីរាជកុមារបានស្តាប់ដូច្នោះ ទើបត្រាស់ថា

បពិត្រព្រះអយ្យកោ ព្រះបិតាបានប្រទានទូលព្រះបង្គំជាខ្ញុំដល់ព្រាហ្មណ៍ ដោយកាត់ថ្លៃមួយពាន់និក្ខៈ ប្រទានកញ្ញាឈ្មោះ

កណ្ហាជិនាជាប្អូនស្រីដោយកាត់ថ្លៃមួយរយនៃវត្ថុគ្រប់មុខ មាន ដំរីជាដើម ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សហស្សគ្ឃំ ហិ មំ** សេចក្តីថា បពិត្រព្រះសម្មតិទេព ព្រះបិតាព្រះរាជទានខ្ញុំដល់ព្រាហ្មណ៍ទ្រង់កាត់ថ្លៃជាមាស ១០០០ ដុំ ។ បទថា **អច្ឆំ** សេចក្តីថា ចំណែកប្អូនស្រីកណ្ហាជិនារបស់ខ្ញុំ ។ បទថា **ហត្ថិ អាទិសតេន** សេចក្តីថា ជាលីទូលថា ព្រះបិតាកាត់ថ្លៃដោយដំរី សេះ រថ សុទ្ធតែមួយរយៗ ដោយហោចគ្រែនិងតាំងក៏មួយរយទាំងអស់ ។

ព្រះបាទសញ្ជ័យ បានស្តាប់ជាលីកុមារក្រាបទូល កាលទ្រង់លោះកុមារកុមារីទាំងទ្វេទើបត្រាស់ថា

នែនាយអាមាត្យ អ្នកចូរក្រោកឲ្យចាប់ហើយចូរឲ្យទាសី ១០០ ទាសា ១០០ គោ ១០០ ដំរី ១០០ គោបា ១០០ ( សេះ ១០០ និក្ខ: ១០០ ) និងមាស ១០០០ តម្លឹងដល់ព្រាហ្មណ៍ឲ្យជាតម្លៃ លោះយកចៅទាំងពីរ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អទាការិ** បានដល់ ចូរឲ្យ ។ បទថា **និក្កយំ** សេចក្តីថា ចូរឲ្យថ្លៃលោះ ។

សេវកាមាត្យទាំងឡាយ បានស្តាប់ដូច្នោះហើយក៏ធ្វើតាមនោះ បានចាត់ចែងតម្លៃសម្រាប់លោះកុមារទាំង ២ ឲ្យដល់ព្រាហ្មណ៍មួយរំពេច ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** វិអាចិធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូល

សូធ្យសានូវព្រះគាថាដូច្នេះថា

លំដាប់នោះពួកនាយអាមាត្យ ក៏ប្រញាប់ប្រញាល់ឲ្យទាសី ១០០ ទាសា ១០០ គោ ១០០ ដំរី ១០០ គោបា ១០០ ( សេះ ១០០ និក្ខ: ១០០ ) និងមាស ១០០០ តម្លឹងដល់ព្រាហ្មណ៍ ឲ្យជាតម្លៃលោះយកព្រះរាជនត្តាទាំងពីរ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អទំសុ** បានដល់ បានឲ្យហើយ ។ បទថា **និក្កយំ** សេចក្តីថា ឲ្យនូវថ្លៃលោះ ។

ព្រះបាទសញ្ជ័យបានព្រះរាជទាននូវវត្ថុទាំងពួង មួយមុខ ១០០ និងមាស ១០០០ ដុំ ដល់ជូជកព្រាហ្មណ៍ជាតម្លៃសម្រាប់លោះរាជកុមារារាជកុមារី រួចប្រទានប្រាសាទ ៧ ជាន់ដល់ជូជក ដោយប្រការដូច្នេះ ។ ចាប់អំពីនោះជូជកក៏មានបរិវារច្រើន ជញ្ជូនទ្រព្យឡើងលើប្រាសាទ ឡើងអង្គុយលើមហាបល្ល័ង្ក បរិភោគភោជនមានរសល្អ ហើយដេកលើមហាសយនា ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណា ពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសានូវព្រះគាថាដូច្នេះថា

( នាយអាមាត្យបានឲ្យទ្រព្យទាំងអស់មួយរយៗ គឺទាសី ១០០ ទាសា ១០០ គោ ១០០ ដំរី ១០០ គោបា ១០០ រថទឹមដោយសេះ ១០០ និងមាស ១០០០ តម្លឹងដល់ព្រាហ្មណ៍ ជាអ្នកស្វែងរកទ្រព្យ ជាមនុស្សឈ្លានពានលើសលន់ ឲ្យជាតម្លៃ

លោះយកព្រះរាជនត្តាទាំងពីរ ) ដូច្នេះ ។

លំដាប់នោះព្រះបាទសញ្ជ័យមហារាជ ឲ្យជាលីនិងកណ្ហាជិនាកក់សក់ ហើយឲ្យសោយភោជនីយាហារ ទ្រង់ប្រដាប់តាក់តែងព្រះរាជកុមារទាំង ២ ក្សត្រទាំងពីរ គឺព្រះបាទសញ្ជ័យឲ្យជាលីប្រថាប់គង់លើភ្លៅ ព្រះនាងផុស្សតី បានឲ្យកណ្ហាជិនាប្រថាប់គង់លើភ្លៅ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសាទូវព្រះគាថាដូច្នេះថា

ក្សត្រទាំងពីរព្រះអង្គ បានលោះទារកទាំងពីរហើយផ្ងូតទឹក ឲ្យបរិភោគភោជន ប្រដាប់ដោយគ្រឿងប្រដាប់ទាំងឡាយ រួចឲ្យអង្គុយលើភ្នែន ។ ព្រះរាជាជាព្រះអយ្យកោ ដាក់ជាលីកុមារលើភ្នែនហើយសាកសួរទារកទាំងពីរ ដែលកក់សីសៈហើយ មានសំពត់ដ៏ស្អាត ស្អិតស្អាងដោយអាភរណៈគ្រប់យ៉ាង ។ ព្រះរាជាបានដាក់លើភ្នែននូវកុមារទាំងពីរ ដែលមានកុណ្ឌលព្ឋសូរគឹកកង មានផ្កាកម្រងស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួងហើយត្រាស់ព្រះរាជតម្រាស់នេះថា នៃជាលី មាតានិងបិតារបស់បាទាំងពីរនោះសុខសប្បាយទេឬ ប្រព្រឹត្តចិញ្ចឹមជីវិតដោយការស្វែងរក ( ផលាផល ) ស្រួលទេឬ ទាំងមើមឈើនិងផ្លែឈើមានច្រើនដែរឬ ពួករបោម មូសនិងពស់មានតិចតួច

ទេឬ ក្នុងព្រៃដ៏កុះករដោយម្រឹគយង់ឃ្នង មិនមានការបៀត
បៀនទេឬ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កុណ្ឌលេ** បានដល់ ឲ្យប្រដាប់ដោយកុណ្ឌល ទាំងឡាយ ។ បទថា **ឃុសិតេ** បានដល់ កុណ្ឌលដែលមានសំឡេង គឺឮ សំឡេងគួរជាទីត្រេកអរនៃចិត្ត ។

បទថា **មាលេ** បានដល់ ឲ្យកុមារទាំង ២ ប្រដាប់ផ្កាន៉ុះៗ ។ បទថា **អង្គេ ករិត្វាន** បានដល់ ឲ្យជាលីរាជកុមារអង្គុយលើភ្លៅ ។

ជាលីរាជកុមារបានស្តាប់ព្រះរាជសំណួរនោះក៏ក្រាបទូលថា

បពិត្រព្រះទេវៈ មាតានិងបិតារបស់ទូលព្រះបង្គំជាខ្ញុំទាំងពីរ នោះសុខសប្បាយជាទេ ប្រព្រឹត្តចិញ្ចឹមជីវិតដោយការស្វែងរក ( ផលាផល ) ស្រួលទេ មើមឈើនិងផ្លែឈើមានច្រើន ។ ឯពួករបោម មូសនិងពស់មានតិចទេ ក្នុងព្រៃដ៏កុះករដោយ ម្រឹគយង់ឃ្នង មិនមានការបៀតបៀនព្រះអង្គទេ ។ ព្រះមាតា នោះជីកយកមើមដំឡូងស្បា ដំឡូងដូង ដំឡូងដៃខ្លា ដំឡូង ទៀន ទាំងបាននាំយកផ្លែពុទ្រា ផ្លែរកខ្មៅ ផ្លែព្នៅមកចិញ្ចឹម យើងខ្ញុំផង ។ បើព្រះមាតានោះជាអ្នកនាំយកមើមឈើនិងផ្លែ ឈើក្នុងព្រៃ នាំយកវត្ថុណាមក យើងខ្ញុំទាំងអស់គ្នាក៏មកជុំគ្នា បរិភោគវត្ថុនោះតែក្នុងវេលាយប់ មិនបានបរិភោគក្នុងវេលាថ្ងៃ ទេ ។ ព្រះមាតារបស់យើងខ្ញុំជាស្រីធ្លាប់សុខស្រួល ខំនាំយក

ផ្លែឈើមក ក៏ទៅជាមានកាយស្គមស្លេកស្លាំង ដោយត្រូវខ្យល់និងកម្តៅថ្ងៃដូចជាផ្កាឈូកដែលគេឈ្លីដោយដៃ ។ ព្រះកេសាទាំងឡាយរបស់ព្រះមាតាក៏ជ្រុះ ព្រោះត្រាច់ទៅក្នុងព្រៃធំ ជាព្រៃដ៏កុះករដោយម្រឹគយង់ឃ្នង ជាទីដែលរមាសនិងខ្លាដំបងអាស្រ័យហើយ ។ ព្រះបិតាបួងផ្នួងសក់ទាំងឡាយ ទ្រទ្រង់ញើសក្អែលឭដ៏ក្បៀក ( ទ្រទ្រង់ភេទនៃបព្វជិតដ៏ប្រសើរ ទ្រទ្រង់ទម្ពក់ ស្បែកខ្លា ផ្ទុំលើផែនដី នមស្ការភ្លើង ដូច្នេះ ។ ស្លាបព្រាសម្រាប់បូជាភ្លើងនិងជដា ) ស្លៀកពាក់ស្បែកខ្លា ផ្ទុំលើផែនដី នមស្ការភ្លើង ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឲណាគ្គាលុកលម្ពាធិ** សេចក្តីថា ជាលីរាជកុមារពោលដល់ជីវិតក្រីក្ររបស់ព្រះមាតាដោយពាក្យថា ជីកដំឡូងស្បាដំឡូងដូងទាំងឡាយ ។ បទថា **ឆោ** ក្នុងបទថា **តំ ឆោ** នេះត្រឹមតែជានិបាត ។ បទថា **បទុមំ ហត្ថគតាមិវ** សេចក្តីថា ដូចផ្កាបទុមដែលត្រូវគេប្របាច់ដោយដៃ ។ បទថា **បតន្ធកេសា** សេចក្តីថា បពិត្រព្រះសម្មតិទេពមាតារបស់ខ្ញុំដើរទៅរកផលាផលក្នុងព្រៃធំ សក់ដែលមានពណ៌ខ្មៅដូចស្លាបកំភេមប៉ះពាល់នឹងមែកឈើជាដើមក៏ទៅជាសក់កន្ទ្រើង ។ បទថា **ជល្លមធារយំ** សេចក្តីថា មានក្បៀកទាំងសងខាងប្រឡាក់ដោយញើសក្អែល ទ្រង់យាងទៅដោយគ្រឿងតាក់តែងទុព្វល ។

ជាលីរាជកុមារក្រាបទូលដល់ព្រះជននីដែលលំបាកលំបិនយ៉ាងនេះកាលទូលសួរព្រះអយ្យកាទើបត្រាស់ថា

បុត្តជាទីស្រឡាញ់នៃមនុស្សលោក ចម្លែកតែសេចក្ដីស្នេហាក្នុងបុត្ត មិនកើតដល់ព្រះអយ្យកោរបស់យើងខ្ញុំដោយពិតដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឧទបជ្ជិសុ** សេចក្ដីថា រមែងកើតឡើង ។ លំដាប់នោះព្រះបាទសញ្ជ័យ កាលចន្លុលទោសរបស់ព្រះអង្គ ក៏ត្រាស់ថា

នែចៅ អំពើអាក្រក់យើងបានធ្វើហើយ ទាំងអំពើដែលបន្ថិចសេចក្ដីចម្រើនយើងក៏បានធ្វើហើយ ព្រោះជីតាបាននិរទេសបុត្តឥតកំហុស តាមពាក្យនៃពួកអ្នកសិវិរដ្ឋ ។ វត្ថុណានីមួយរបស់យើងមានក្នុងទីនេះ ទាំងទ្រព្យនិងធញ្ញជាតិ ( ជីតាក៏នឹងឲ្យវត្ថុនោះដល់បិតារបស់បា ) សូមវេស្សន្តរចូរមក ចូរជាព្រះរាជាត្រួតត្រាក្នុងដែនសិវិចុះ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ចោត** សេចក្ដីថា នែជាលីកុមារចៅ នុ៎ះជាកម្មរបស់ពួកអញធ្វើទុកពិត ។ បទថា **ភ្រូណហច្ចំ** បានដល់ ជាកម្មដែលទម្លាយនូវសេចក្ដីចម្រើន ។ បទថា **យំ មេ កិញ្ចិ** សេចក្ដីថា វត្ថុណាមួយរបស់ជីតាមានក្នុងព្រះនគរនេះ របស់ទាំងអស់អញនឹងឲ្យដល់បិតារបស់ឯង ។ បទថា **សិវិរដ្ឋេ បសាសតុ** សេចក្ដីថា សូមព្រះវេស្សន្តរនោះជាព្រះរាជាគ្រងរាជ-សម្បត្តិក្នុងនគរនេះ ។

ជាលីរាជកុមារក្រាបទូលថា

បពិត្រព្រះសម្មតិទេព ព្រះរាជាដ៏ឧត្តមរបស់អ្នកសិវិរដ្ឋ នឹង

មិនយាងមកតាមពាក្យរបស់ទូលព្រះបង្គំទេ សូមព្រះសម្មតិទេព ទ្រង់ស្តេចយាងទៅដោយព្រះអង្គឯងវិញ ហើយស្រោចស្រព ព្រះរាជបុត្តបង្កើត ដោយភោគៈទាំងឡាយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សិរិសុត្តមោ** បានដល់ ជាអ្នកប្រសើរបំផុតរបស់អ្នកសិរិ ។ បទថា **សិញ្ច** សេចក្តីថា អភិសេកដោយរាជសម្បត្តិ ដូចមហាមេឃបាចសាចនូវតំណក់ទឹកភ្លៀងដូច្នោះ ។

ព្រះបាទសញ្ជ័យបានស្តាប់ពាក្យរបស់ជាលីកុមារ ទើបត្រាស់ហៅសេនាគុត្តមាត្យមកប្រាប់ឲ្យវាយស្គរធំប្រកាសពេញនគរ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសានូវព្រះគាថាដូច្នេះថា

លំដាប់នោះព្រះរាជាព្រះនាមសញ្ជ័យ បានត្រាស់នឹងសេនាបតីថា ពួកសេនាដំរី សេនាសេះ សេនារថ សេនាថ្មើរជើងចូរស្ទៀត ( អាវុធទាំងឡាយ ) ពួកអ្នកនិគម ព្រាហ្មណ៍ បុរោហិត អាមាត្យ ៦០.០០០ និងពួកទាហានដ៏ល្អ មើលចងគ្រឿងក្រោះប្រដាប់ដោយគ្រឿងប្រដាប់មានបែបផ្សេងៗ ចូរនាំគ្នាមកឲ្យឆាប់ ជូនអញទៅ ។ ពួកទាហានខ្លះស្លៀកពាក់សំពត់ខៀវ ពួកទាហានខ្លះស្លៀកពាក់សំពត់លឿង ពួកទាហានដទៃជួតឈ្នួតក្រហម ពួកទាហានខ្លះស្លៀកពាក់សំពត់ស ចងគ្រឿងក្រោះ

ប្រដាប់ដោយគ្រឿងប្រដាប់មានបែបផ្សេង ៗ ចូរនាំគ្នាមកឲ្យឆាប់ ។ ភ្នំហិមពាន្តនិងភ្នំគន្ធមាទន៍ ដ៏ទ្រទ្រង់ក្លិន ដ៏ដេរដាសដោយពួកឈើផ្សេងៗ ជាលំនៅនៃពួកភូតដ៏ច្រើន ញ៉ាំងទិសទាំងឡាយឲ្យភ្លឺផ្សាយទៅដោយ ឱសថទាំងឡាយជាទិព្វយ៉ាងណា ពួកទាហាននាំគ្នាចងគ្រឿងក្រោះ ចូរមកឲ្យឆាប់ ចូរញ៉ាំងទិសទាំងឡាយ ឲ្យភ្លឺរុងរឿងផ្សាយទៅយ៉ាងនោះដែរ ។ ពួកអ្នកជិះដំរីចូររៀបចំដំរី ១៤ ពាន់ ជាសត្វមានសរីរៈធំមានខ្សែជង្គន់ជាវិការៈនៃមាស មានសរីរៈស្រោបដោយគ្រឿងតែងតួ ជាវិការៈនៃមាស ។ ពួកអ្នកបង្ហឹកដំរីមានដៃកាន់ដែកចំពុះទុងនិងកង្វេរ មានគ្រឿងស្អិតស្អាងប្រាកដហើយចងគ្រឿងក្រោះហើយ ចូរនាំគ្នាឡើងជិះកដំរីទាំងឡាយបរមកឲ្យឆាប់ ។ ពួកអ្នកជិះសេះចូររៀបចំសេះទាំង ១៤ ពាន់ ជាជាតិសេះសិន្ធពអាជានេយ្យ មានសន្ទុះដ៏លឿន ។ ពួកអ្នកបង្ហឹកសេះទ្រទ្រង់ស៊ែនិងធ្នូ ចងគ្រឿងក្រោះប្រដាប់លើខ្នងសេះហើយ ចូរឡើងជិះបរមកឲ្យឆាប់ ។ លំដាប់ពីនោះមកពួកអ្នកបររថ ចូររៀបចំរថទាំង ១៤ ពាន់ ជារថមានខ្នងកង់ពាសដោយដែកដ៏ល្អ មានផ្ទះរំលេចដោយមាស ។ ពួកខ្មាន់ធ្នូស្ទាត់ក្នុងការប្រហារ ពួកជាងរថចូរនាំគ្នាលើកទង់ជ័យ ខែលនិងគ្រឿងក្រោះទាំងឡាយក្នុងរថទាំងនោះចូរដំឡើងធ្នូ ចងគ្រឿងក្រោះហើយចូរបររថទាំង

ឡាយមកឲ្យធាប់ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សន្នាហយន្តុ** បានដល់ ចងអាវុធទាំងឡាយ ។ បទថា **សដ្ឋិសហស្សានិ** បានដល់អាមាត្យ ៦០០០០ នាក់ដែលជាសហជាត ជាមួយកូនរបស់យើង ។ បទថា **នីលវត្ថធរានេកេ** សេចក្ដីថា ទាហានមួយពួកទ្រទ្រង់នូវសំពត់ពណ៌ខៀវ គឺចូរជាបុគ្គលដែលដណ្ដប់សំពត់ពណ៌ខៀវចូរមក ។ បទថា **មហាភូតគណាលយោ** បានដល់ ជាលំនៅរបស់ពួកយក្ខទាំងឡាយ ។ បទថា **និសា ភន្តុ បវន្តុ ច** សេចក្ដីថា អាមាត្យទាំងឡាយ ចូរឲ្យរុងរឿងនិងដេរដាសដោយអាភរណៈនិងគ្រឿងលាបទាំងឡាយ ដូចព្រៃហិមពាន្តមានប្រការដូចពោលហើយដូច្នោះ ។ បទថា **ហត្ថិក្ខន្ធេហិ** សេចក្ដីថា ហ្វូងដំរីទាំងនោះចូរឡើងកដំរីត្រឡប់មក ។ បទថា **ឧស្សិតា** បានដល់ មានគ្រឿងប្រដាប់ប្រាកដ ។ បទថា **អយោសុកតនេមិយោ** បានដល់ មានកង់រថដែលប្រើដែកស្រោបយ៉ាងល្អ ។ បទថា **សុវណ្ណចិត្រចោក្ខរេ** សេចក្ដីថា ព្រះបាទសញ្ជ័យត្រាស់ថា ចូរទឹមនូវរថ ១ ម៉ឺន ៤ ពាន់គ្រឿងនេះដែលមានផ្ទះរថវិចិត្រដោយមាស ។ បទថា **វិច្ឆាលេន្តុ** បានដល់ ចូរលើកឡើង ។

ព្រះបាទសញ្ជ័យរៀបចំកងទ័ពយ៉ាងនេះហើយត្រាស់ថា ពួកអ្នកចូររៀបចំផ្លូវជាទីមកឲ្យរាបស្មើល្អ ទទឹង ៨ ឧសភ តាំងអំពីជេតុត្តររាជធានីរហូតដល់ភ្នំវង្កតហើយធ្វើវត្ថុនេះផង វត្ថុនេះផងដើម្បីតាក់តែងផ្លូវឲ្យស្អាតហើយត្រាស់ថា

អ្នកទាំងឡាយចូរតាក់តែងផ្កាទាំងឡាយ ( មានលាជជាគម្រប់

៥ ) និងផ្កាសម្រាប់រោយរាយ កម្រងផ្កា គ្រឿងក្រអូប គ្រឿងលាបស្រឡាបនិងផ្កាដ៏មានតម្លៃទាំងឡាយ ចូរបិតនៅត្រង់ផ្លូវដែលបុត្តរបស់អញមក ។ គ្រប់ទ្វារស្រុកចូរតាក់តែង តាំងទុកឪទិនមេរ័យនិងសុរាច្រើន ត្រង់ផ្លូវដែលបុត្តរបស់អញមក ។ ចូរតាក់តែងតាំងទុកសាច់ នំទ្រាបល្ង នំកុម្មាសដែលលាយសាច់ត្រីត្រង់ផ្លូវដែលបុត្តរបស់អញមក ។ ចូរតាក់តែង តាំងទុកទឹកដោះរាវ ប្រេង ទឹកដោះជូរ ទឹកដោះស្រស់និងសុរាដ៏ច្រើនដែលធ្វើដោយម្សៅថ្កោ ត្រង់ផ្លូវដែលបុត្តរបស់អញមក ។ ពួកអ្នកធ្វើម្ហូប អ្នកធ្វើបាយ អ្នករាំនិងអ្នកច្រៀង អ្នកច្រៀងទះដៃ អ្នកវាយស្គរ អ្នកច្រៀងដោយសំឡេងដ៏ស្រទន់និងពួកអ្នកចាក់គុក ។ ពួកជនចូរដេញពិណាគ្រប់បែប ចូរវាយស្គរនិងមហោរធឹកទាំងឡាយ ចូរផ្លុំស័ង្ខនិងទះស្គរទាំងឡាយ ។ ជនទាំងឡាយចូរទះសម្ភោរ វាយស្គរធំ ផ្លុំស័ង្ខ ដេញតះខេ ដេញពិណាខ្សែ ៧ វាយមហោរធឹក វាយស្គរទង់ដែង វាយស្គរមង្គល ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ជាលា ឱលោកិយា បុប្ផា** សេចក្ដីថា ព្រះបាទសញ្ជ័យមានព្រះតម្រាស់ថា ចូររៀបចំបាចផ្កា បាចលាជទាំងឡាយដែលឈ្មោះថាផ្កាមានលាជជាគម្រប់ ៥ រោយនូវផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាបត្រង់ពិតាន ។ បទថា **អគ្ឃិយានិ ច** សេចក្ដីថា ចូរតាំងបុប្ផជាតិនិង

រតនៈដែលមានតម្លៃក្នុងផ្លូវដែលកូនរបស់អញមក ។ បទថា **គាមេ គាមេ** បានដល់ តាំងទុកត្រង់ទ្វារស្រុក ។ បទថា **បតិតា ថន្តុ** សេចក្តីថា ចូររៀបចំតម្កល់ឆ្នាំងសុរានិងមេរ័យជាដើមដើម្បីអ្នកស្រុកបានផឹក ។ បទថា **មច្ឆសំ- យុតា** បានដល់ ប្រកបដោយត្រីទាំងឡាយ ។ បទថា **កណ្ឌុបិដ្ឋា** បានដល់ សម្រេចដោយម្សៅថ្លោ ។ បទថា **មុទ្ទិកា** បានដល់ អ្នកច្រៀងដែលមានសំឡេងពីរោះ ។ បទថា **សោកជ្ឈាយិកា** សេចក្តីថា ពួកមាយាករឬអ្នកដទៃណាក៏ដោយ ដែលអាចរម្ងាប់សេចក្តីសោកដែលកើតឡើងបាន លោកហៅថា **សោកជ្ឈាយិកា** ។ បទថា **ខរមុខានិ** បានដល់ ស័ង្ខធំដែលកើតក្នុងសមុទ្រជាទក្ខិណាវដ្ត ។ បទថា **សង្ខា** បានដល់ ខ្សែ ២ ប្រភេទ គឺ ខ្សែរូបកណ្តាប់ដៃនិងខ្សែរូបដប តន្ត្រី ៤ យ៉ាង គឺតៈខ ស្គរធំ ស្គរតូចនិងស្គរមន្ទល ។

ព្រះបាទសញ្ជ័យទ្រង់រៀបចំតាក់តែងមាគ៌ាដោយប្រការដូច្នេះ កាលនោះ ចំណែកជូជកបរិភោគអាហារលើសប្រមាណមិនអាចឲ្យអាហារដែលបរិភោគលើសចំនួននោះរលួយបានក៏ធ្វើកាលកិរិយាក្នុងទីនោះឯងកាលនោះ ព្រះបាទសញ្ជ័យក៏ធ្វើឈាបនកិច្ចដល់ជូជក បានឲ្យវាយស្គរធំប្រកាសក្នុងព្រះនគរថា អ្នកឯណាមួយដែលជាញាតិសាលោហិតរបស់ជូជក ចូរមកយកទ្រព្យសម្បត្តិដែលជាព្រះរាជប្រទាននេះទៅ កាលមិនជួបសាច់ញាតិក៏ឲ្យដញ្ជូនទ្រព្យទាំងពួងដាក់ក្នុងឃ្លាំងវិញ កាលនោះព្រះបាទសញ្ជ័យប្រជុំកងទ័ពទាំងពួងប្រមាណ ១២ អក្ខោភិនីអស់រយៈកាល ៧ ថ្ងៃ ។ ព្រះបរមក្សត្រមួយអន្លើដោយរាជបរិវារ

ធំ លើកកងទ័ពចេញអំពីព្រះនគរឲ្យជាលីរាជកុមារធ្វើជាមគ្គុទ្ទេសក៍ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** រីអាថិធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូត្យសានូវព្រះគាថាដូច្នេះថា

សេនាដ៏ច្រើននោះជាកងទ័ពក្នុងដែនសិវិលើកចេញទៅ មានជាលីកុមារជាមគ្គនាយក បានដើរសំដៅទៅកាន់វង្កតបព៌ត ។ ដំរីដ៏ប្រសើរមានអាយុ ៦០ ខួប បន្លឺកោញ្ចនាទដំរី កាលបើមានខ្សែជង្គង់ជាប់នៅហើយក៏បន្លឺកោញ្ចនាទ ។ សេះអាជានីយទាំងឡាយស្រែកកងរំពង សំឡេងគឹកកងនៃខ្នងកង់ក៏កើតមានក្នុងកាលនោះ ធូលីក៏ហុយបាំងដូចពពក កងទ័ពក្នុងដែនសិវិបានលើកចេញទៅ ។ សេនាដ៏ច្រើននោះ អាចនាំយករបស់ដែលគួរនាំយកទៅ បានលើកចេញទៅ មានជាលីកុមារជាមគ្គនាយក បានដើរសំដៅទៅកាន់វង្កតបព៌ត ។ កងទ័ពទាំងនោះបានចូលទៅកាន់ព្រៃធំមានមែកឈើច្រើន មានទឹកច្រើនដេរដាសដោយឈើ មានផ្កានិងឈើមានផ្លែទាំងសងខាងផ្លូវ។ ពួកសត្វស្លាបដ៏ច្រើនក្នុងព្រៃធំនោះ មានសំឡេងមូល មានសំឡេងពីរោះ មានត្រកូលផ្សេងៗស្រែកហៅសត្វស្លាបដែលកំពុងស្រែកលើដើមឈើដែលផ្កាតាមរដូវ ។ កងទ័ពទាំងនោះទៅកាន់ផ្លូវឆ្ងាយជាប់ស្រយាល ក្នុងកាលអំណើះទៅនៃថ្ងៃ និង

យប់ បានចូលទៅដល់ប្រទេសដែលព្រះបាទវេស្សន្តរទ្រង់គង់នៅ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **មហាតី** បានដល់ កងទ័ពប្រមាណ ១២ អក្ខោភិនី ។ បទថា **ឧយ្យុត្តា** បានដល់ រួបរួមគ្នា ។ បទថា **កោញ្ចំ នទតិ** សេចក្ដីថា ក្នុងកាលនោះព្រាហ្មណ៍អ្នកកាលិង្គរដ្ឋកាលភ្លៀងធ្លាក់ក្នុងដែនរបស់ខ្លួនហើយ ក៏នាំដំរីបច្ចយនាគដ៏ប្រសើរនោះមកសងដល់ព្រះបាទសញ្ជ័យ ដំរីនោះត្រេកអរថា អញបានជួបម្ចាស់ហើយទើបបន្លឺកោញ្ចនាទ ។ ព្រះតម្រាស់នេះសំដៅយកដំរីនោះ ។ បណ្ដាបទទាំងនោះ បទថា **កច្ឆាយ** សេចក្ដីថា លុះហ្មដំរីចងខ្សែជង្គង់មាស ដំរីត្រេកអរក៏បន្លឺកោញ្ចនាទ ។ បទថា **ហាសិយន្តិ** បានដល់ បានបន្លឺសំឡេងខ្លាំង ។ បទថា **ហារហារិនី** បានដល់ អាចនាំវត្ថុដែលគប្បីនាំទៅ ។ បទថា **ចារីសុ** បានដល់ ចូលទៅហើយ ។ បទថា **ឧ-ហុសាទំ** បានដល់ មានមែកឈើច្រើន ។ បទថា **ទីឃមទ្ធានំ** បានដល់ ចម្ងាយផ្លូវប្រមាណ ៦០ យោជន៍ ។ បទថា **ឧចាគញ្ចុំ** សេចក្ដីថា ដល់ប្រទេសដែលព្រះវេស្សន្តរគង់នៅ ។

**មហារាជបព្វ ចប់**

# ជវត្តិយបត្ត:

ឯជាលីរាជកុមារបានបោះព្រះពន្លាក្បែរស្រះមុចលិន្ទឲ្យរថ ១ ម៉ឺន ៤ ពាន់ ត្រឡប់ឲ្យមានមុខទៅកាន់ផ្លូវដែលទ្រង់ធ្លាប់មកហើយ ឲ្យរៀបចំការរក្សាការ ពារនូវសត្វកាចមានរាជសីហ៍ ខ្លាធំ ខ្លាដំបង រមាសជាដើម ក្នុងប្រទេស នោះៗសំឡេងពាហនៈទាំងឡាយ មានដំរីជាដើមទ្រហឹងអឺងកង ។ គ្រានោះ ព្រះវេស្សន្តរមហាក្សត្រទ្រង់បានស្តាប់សំឡេងនោះ ទ្រង់ក៏ខ្លាចចំពោះមរណ ភ័យដោយយល់ថា ពួកបច្ចាមិត្តរបស់អញ ផ្តាច់ព្រះជន្មព្រះជនករបស់អញ ហើយមកដើម្បីត្រូវការខ្លួនអញឬហ្ន៎ ទើបនាំនាងមទ្រីឡើងលើកំពូលភ្នំ ទត មើលកងទ័ព ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទ ព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូល សូត្រសាទូវព្រះគាថាដូច្នេះថា

ព្រះបាទវេស្សន្តរ ទ្រង់ឮសំឡេងគឹកកងនៃកងទ័ពទាំងនោះ ហើយ ក៏ភិតភ័យទ្រង់ឡើងទៅលើភ្នំ ហើយទ្រង់ទតមើលនូវ ពួកសេនាទាំងភិតភ័យ មានបន្ទូលថា នែនាងមទ្រី នាងចូរ ពិចារណាមើល សំឡេងគឹកកងក្នុងព្រៃយ៉ាងនេះមានទាំងសេះ អាជានីយស្រែកកងរំពង ទាំងចុងទង់ជ័យក៏ប្រាកដ ។ ជនទាំង នេះដូចជាព្រានចោមព័ទ្ធហ្វូងម្រឹគក្នុងព្រៃ ដោយបង្អាត់ទាំង ឡាយ ដេញទម្លាក់ក្នុងរណ្តៅ ហើយចាក់កាប់សម្លាប់ ពន្ទះ

យកតែសាច់ល្អៗនៃម្រឹគទាំងនោះដោយកាំបិតដ៏មុតដោយពិត ។
ពួកយើងមិនមានទោសត្រូវគេនិរទេសមកនៅក្នុងព្រៃ ដល់នូវ
សេចក្ដីវិនាសក្នុងកណ្ដាប់ដៃសត្រូវក៏ដូចជាម្រឹគយ៉ាងនោះដែរ
នាងចូរមើលអ្នកសម្លាប់បុគ្គលខ្សោយ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឥង្ឃ** ជានិបាត ចុះក្នុងអត្ថថា ជាស់តឿន ។ បទថា **និសាមេហិ** សេចក្ដីថា ចូរមើល គឺប្រាថ្នានឹងមើលថា កងទ័ពរបស់អញ ឬកងទ័ពបច្ចាមិត្ត ។ កាលក្លាប់សេចក្ដីនៃគាថាកន្លះគាថាគឺ **ឥមេ នូន អរញ្ញម្ហិ** ជាដើម គប្បីជ្រាបយ៉ាងនេះថា នៃនាងមទ្រី ពួកព្រានព័ទ្ធម្រឹគក្នុងព្រៃដោយសំណាញ់ឬដោយរណ្ដៅពោលក្នុងខណៈនោះថា ពួកអ្នកចូរសម្លាប់សត្វអាក្រក់ចាក់ដោយលំពែងសម្រាប់សម្លាប់ម្រឹគដ៏មុត ជ្រើសរើសសម្លាប់ម្រឹគទាំងនោះយកតែម្រឹគធំៗយ៉ាងណា យើងទាំង ២ នេះ ត្រូវចាក់ដោយវាចាអសប្បុរសថា នឹងសម្លាប់ដោយលំពែងដ៏មុតដូច្នោះដូចគ្នា ម្យ៉ាងទៀត ពួកយើងមិនមានកំហុសត្រូវបណ្ដេញ គឺនិទេសចេញអំពីដែន មកនៅក្នុងព្រៃ កាលបើដូច្នោះពួកយើងនឹងធ្លាក់នៅក្នុងកណ្ដាប់ដៃរបស់ពួកសត្រូវ ។ បទថា **អមិត្តហត្ថត្តគតា** បានដល់ ដល់នូវការវិនាសដោយដៃនៃសត្រូវទាំងឡាយ ។ ព្រះវេស្សន្តរទ្រង់ខ្សឹកខ្សួលព្រោះខ្លាចសេចក្ដីស្លាប់យ៉ាងនេះថា **បស្ស ទុព្វល-ឃាតកំ** ដូច្នេះ ។

ព្រះនាងមទ្រីបានស្ដាប់ព្រះតម្រាស់ទើបទតកងទ័ព ព្រះនាងដឹងថាជាកងទ័ពរបស់ខ្លួន កាលឲ្យព្រះមហាសត្វទ្រង់ធូរស្បើយក្នុងព្រះហឫទ័យ ទើប

ត្រាស់ថា

ពួកសត្រូវមិនអាចគ្របសង្កត់ ( ព្រះអង្គ ) បានទេដូចជាភ្លើង មិនអាចគ្របសង្កត់ទឹកសមុទ្របាន សូមព្រះអង្គទ្រង់ព្រះចិន្តា ដល់ពាក្យដែលសក្កទេវរាជពោលហើយ នោះឯងទំនងជាសួស្តី នឹងមានដល់ព្រះអង្គព្រោះពួកពលនេះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អគ្គិវ ឧទកណ្ណវេ** សេចក្តីថា ភ្លើងដែលជាប់ដោយគប់ស្មៅជាដើមរមែងមិនគ្របសង្កត់ទឹកសមុទ្រដែលធំផង ជ្រៅផង គឺមិនអាចធ្វើឲ្យក្តៅបានយ៉ាងណា បច្ចាមិត្តទាំងឡាយរមែងសង្កត់សង្កិនទ្រង់មិនបាន គឺញាំញីមិនបានយ៉ាងនោះ ។ បទថា **តនេវ** សេចក្តីថា ព្រះនាងមទ្រីឲ្យព្រះមហាសត្វកក់ក្តៅក្នុងព្រះហឫទ័យថា ពរឯណាដែលសក្កទេវរាជបានប្រទានដល់ទ្រង់ថា បពិត្រមហារាជ មិនយូរប៉ុន្មានព្រះជនករបស់ទ្រង់នឹងយាងមក សូមទ្រង់ពិចារណាតាមនោះចុះ សួស្តីគប្បីមានដល់ពួកយើងអំពីពលនិកាយនេះដោយពិត ។

លំដាប់នោះ ព្រះមហាសត្វទ្រង់បន្ទោបង់សេចក្តីសោកហើយ មួយអន្លើដោយនាងមទ្រីចុះអំពីភ្នំ ប្រថាប់គង់ត្រង់ទ្វារបណ្ណសាលា ឯព្រះនាងមទ្រីក៏គង់ប្រថាប់ត្រង់ទ្វារបណ្ណសាលារបស់ព្រះនាង ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូត្យសាទូវព្រះគាថាដូច្នេះថា

លំដាប់នោះព្រះបាទវេស្សន្តរយាងចុះអំពីភ្នំ ទ្រង់ធ្វើព្រះហឫទ័យឲ្យមាំហើយគង់នៅក្នុងបណ្ណសាលា ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧឡ្ហំ កត្វាន មានសំ** សេចក្តីថា ប្រថាប់គង់ធ្វើព្រះហឫទ័យឲ្យមាំថា អញជាបព្វជិត អ្នកណានឹងធ្វើអ្វីអញកើត ។ ខណៈនោះព្រះបាទសញ្ជ័យ ត្រាស់ហៅព្រះនាងផុស្សតីរាជទេវីមកប្រាប់ថា ហៃនាងផុស្សតីដ៏ចម្រើន កាលពួកយើងទាំងអស់ទៅព្រមគ្នានឹងមានសេចក្តីសោកធំ អញទៅមុន បន្ទាប់អំពីនោះចូរនាងកំណត់មើលថា ពួកយើងទៅមុនបន្ទោបង់សេចក្តីសោក អន្លុយហើយសឹមទៅដោយបរិវារធំ លំដាប់នោះជាលីនិងកណ្ហាជិនាត្រូវរង់ចាំមួយស្របក់ហើយសឹមចូលទៅឯក្រោយ ត្រាស់ដូច្នេះហើយឲ្យបំបែររថឲ្យមានមុខទៅកាន់ផ្លូវដែលមកហើយ ធ្វើការរក្សាក្នុងទីនោះៗ ទ្រង់ចុះអំពីកដីរីដ៏ប្រសើរដែលប្រដាប់ហើយ យាងទៅកាន់សម្នាក់របស់ព្រះរាជឱរស ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបាទត្រាស់ហើយ មានព្រះបន្ទូលសូធ្យសានូវព្រះគាថាដូច្នេះថា

ព្រះបិតាទ្រង់ឲ្យបញ្ឈប់រថ ទ្រង់ឲ្យពួកសេនាត្រៀមចាំ ហើយ
ទ្រង់ស្តេចចូលទៅចួបនឹងព្រះរាជបុត្ត ដែលគង់នៅក្នុងព្រៃតែ
ម្នាក់ឯង ។ លុះព្រះបិតាយាងចុះអំពីកដីរីហើយទ្រង់ឧត្តរាសង្គៈ
ធៀងស្មាម្ខាង ផ្គងអញ្ជលី មានពួកអាមាត្យហែហមបានចូល

ទៅដើម្បីអភិសេកបុត្ត ។ ព្រះអង្គបានទតឃើញកុមារមានរូប
គួរឲ្យត្រេកអរ សម្រើងព្រះហឫទ័យកំពុងត្រិះរិះ មិនមានភ័យ
អំពីទីណាមួយដែលគង់នៅក្នុងបណ្ណសាលានោះ ដូច្នេះ ។

បណ្ដាបទទាំងនោះបទថា **វុដ្ឋបេត្វាន សេណិយោ** សេចក្ដីថាឲ្យពលនិកាយរង់ចាំដើម្បីជាប្រយោជន៍ដល់ការរក្សា ។ បទថា **ឯកំសោ** បានដល់ ធ្វើសំពត់ឆៀងស្មាម្ខាង ។ បទថា **សិញ្ចិតុមាគមិ** សេចក្ដីថា យាងចូលទៅដើម្បីអភិសេកក្នុងរាជសម្បត្តិ ។ បទថា **រម្មរូបំ** បានដល់ មិនបានលាបនិងប្រដាប់តាក់តែង ។

ព្រះបាទវេស្សន្តរនិងព្រះនាងមទ្រី បានទតឃើញព្រះបិតានោះ
មានសេចក្ដីជាប់ព្រះហឫទ័យក្នុងបុត្តកំពុងយាងមក ក៏ក្រោក
ទៅទទួលថ្វាយបង្គំ ។ ចំណែកព្រះនាងមទ្រីថ្វាយបង្គំព្រះបាទ
ទាំងគូរបស់ព្រះសុស្សរះដោយព្រះសិរ្ស ( ហើយក្រាបទូលថា )
បពិត្រព្រះសម្មតិទេព ខ្ញុំឈ្មោះមទ្រីជាសុណិសារបស់ព្រះអង្គ
សូមថ្វាយបង្គំព្រះបាទទាំងគូរបស់ព្រះអង្គ ព្រះបិតាទ្រង់ឱបរឹត
ជនទាំងពីរនោះហើយបបោសអង្អែលដោយព្រះហស្ត ។

បណ្ដាបទទាំងនោះ បទថា **បាទេ វន្ទាមិ តេ ហុសា** សេចក្ដីថា ព្រះនាងមទ្រីក្រាបទូលថា បពិត្រព្រះសម្មតិទេព ខ្ញុំម្ចាស់ជាកូនប្រសាររបស់ទ្រង់ សូមថ្វាយបង្គំទៀបព្រះយុគលបាទ ក្រាបទូលដូច្នេះហើយថ្វាយបង្គំ ។ បទថា **តេសុ តត្ថ** បានដល់ ក្សត្រទាំង ២ នោះក្នុងអាស្រមដែលសក្កទេវរាជ

ព្រះរាជទាននោះ ។ បទថា **បលិសជ្ជ** សេចក្តីថា ឱបក្តាប់នឹងដើមទ្រូង ទ្រង់ថើបត្រង់ក្បាល ទ្រង់អង្អែលខ្នងរបស់ស្តេចទាំង ២ ដោយព្រះហស្តដ៏ទន់ ។

បន្ទាប់អំពីនោះព្រះបាទសញ្ជ័យទ្រង់ព្រះកន្សែងខ្សឹកខ្សួល កាលស្វាងនូវសេចក្តីសោកហើយកាលទ្រង់ធ្វើបដិសណ្ឋារៈជាមួយស្តេចទាំង ២ នោះទើបត្រាស់ថា

នែបុត្ត អ្នកទាំងពីរសុខសប្បាយទេឬ នែបុត្តអ្នកទាំងពីរមិនមានជំងឺតម្កាត់ទេឬ អ្នកទាំងពីរចិញ្ចឹមជីវិតដោយការស្វែងរកស្រួលទេឬ មើមឈើនិងផ្លែឈើមានច្រើនឬទេ ។ ពួករបោមមូស ពស់មានតិចទេឬ ក្នុងព្រៃដ៏កុះករដោយម្រឹគយង់ឃ្នងមិនមានការបៀតបៀនទេឬ ដូច្នេះ ។

ព្រះមហាសត្វទ្រង់បានស្តាប់ព្រះតម្រាស់របស់បិតាក៏ក្រាបទូលថា

បពិត្រព្រះសម្មតិទេព ការរស់នៅរបស់យើងខ្ញុំជាការរស់នៅផ្តេសផ្តាសទេ យើងខ្ញុំជាអ្នករស់នៅត្រដាបត្រដួស ព្រោះការរស់នៅដោយការស្វែងរក ( ផលាផល ) ។ បពិត្រមហារាជ ( សេចក្តីខ្វះខាត ) រមែងទូន្មាន ( បុរសកម្សត់ ) ដូចជានាយសារថីទូន្មានសេះ យើងខ្ញុំទាំងនោះជាបុគ្គលមានសេចក្តីខ្វះខាតទូន្មានហើយ សេចក្តីខ្វះខាតរមែងទូន្មានយើងខ្ញុំ ។ បពិត្រមហារាជ យើងខ្ញុំត្រូវគេនិរទេសហើយមានសេចក្តីរស់នៅទាំងទុក្ខសោកក្នុងព្រៃ ទាំងសាច់ឈាមទៀតសោតក៏ស្គាំងស្គមព្រោះ

មិនបានឃើញព្រះមាតាបិតា ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **យាធិសិ កីធិសា** សេចក្ដីថា ការរស់នៅជូនទាបជូនខ្ពស់ ( តាមមានតាមបាន ) ។ បទថា **កសិរា ជីវិកា ហោម** សេចក្ដីថា បពិត្រព្រះបិតា ការរស់នៅរបស់យើងខ្ញុំទាំងឡាយជាទុក្ខ ព្រោះយើងខ្ញុំទាំងឡាយ មានជីវិតដោយការស្វះស្វែងរកមើមឈើនិងផ្លែឈើ ជាអាហារ ។ បទថា **អនិទ្ធិនំ** សេចក្ដីថា បពិត្រមហារាជ ការខ្វះខាតរមែងទូន្មានបុគ្គលក្រីក្រហើយការក្រីក្រនោះរមែងធ្វើឲ្យអស់ព្យសន៍ដូចនាយសារថីអ្នកឈ្លាសទូន្មាននូវសេះដូច្នោះ យើងខ្ញុំទាំងឡាយនៅក្នុងទីនេះត្រូវភាពក្រីក្រលត់ដំហើយក៏ធ្វើឲ្យអស់ព្យសន៍ហើយ ការក្រីក្រនោះឯងទូន្មានយើងខ្ញុំទាំងឡាយ ។ បាឋៈថា **ឧមេថ នោ** ដូច្នេះក៏មាន សេចក្ដីថា ទូន្មានយើងខ្ញុំទាំងឡាយហើយ ។ បទថា **ជីវិសោកិនំ** សេចក្ដីថា ព្រះវេស្សន្តរទូលថា យើងខ្ញុំទាំងឡាយមានសេចក្ដីសោកនៅក្នុងព្រៃនឹងមានសេចក្ដីសុខដូចម្ដេចកើត ។

កាលទ្រង់ក្រាបទូលយ៉ាងនេះហើយព្រះវេស្សន្តរកាលនឹងទូលសួរដំណឹងរបស់ព្រះរាជឱរសនិងព្រះរាជធីតាទៀត ទើបទូលថា

> កុមារទាំងពីរ គឺជាលីនិងកណ្ហាជិនាណាដែលជាទាយាទ ( ព្រះរាជនត្តា ) របស់ព្រះអង្គ ជាបុគ្គលប្រសើរបំផុតក្នុងដែនសិវិ មានបំណងមិនទាន់បានសម្រេចនៅឡើយ លុះអំណាចព្រាហ្មណ៍ជាបុគ្គលឈ្លានពានលើសលន់ វាយកុមារទាំងពីរនោះដូចជាគេវាយហ្វូងគោ ។ បើព្រះអង្គជ្រាបបុត្តទាំងនោះរបស់

រាជបុត្រីសូមប្រាប់ដល់យើងខ្ញុំឲ្យចាប់ដូចជា ( ពួកពេទ្យដែល ព្យាបាល ) នូវមាណពត្រូវពស់ចឹក ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ទាយាទប្បត្តមានសា** សេចក្តីថា ព្រះ-វេស្សន្តរក្រាបទូលថា បពិត្រមហារាជ ទាយាទរបស់ទ្រង់ដ៏ប្រសើររបស់អ្នកសិវិមានមានសៈមិនទាន់ដល់ហើយ គឺមានមនោរថមិនទាន់សម្រេចធ្លាក់នៅក្នុងអំណាចរបស់ព្រាហ្មណ៍ ព្រាហ្មណ៍នោះវាយកុមារទាំងនោះដូចបុរសវាយហ្វូងគោ បើទ្រង់ជ្រាបឬបានស្តាប់ដំណឹងក្មេងទាំង ២ របស់រាជបុត្រីមទ្រីនោះដោយបានទតឃើញ ឬបានដំណឹងក៏ដោយ ។ បទថា **សប្បទដ្ឋំវ មាណវំ** សេចក្តីថា ព្រះវេស្សន្តរក្រាបទូលថា សូមទ្រង់ប្រាប់ឲ្យដឹង គឺប្រាប់ដល់យើងខ្ញុំទាំង ២ ដូចគ្រូពស់ព្យាបាលមាណពដែលត្រូវពស់ចឹកដើម្បីបណ្តេញពិសដូច្នោះ ។

ព្រះបាទសញ្ជ័យត្រាស់ថា

កុមារទាំងពីរ គឺជាលីនិងកណ្ហាជិនាទុំ: បិតាបានប្រគល់ទ្រព្យ ឲ្យដល់ព្រាហ្មណ៍លោះមកហើយ បាកុំភ័យឡើយ បាចូរស្រួល ចិត្តចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **និក្កីតា** បានដល់ ឲ្យទ្រព្យលោះទុកហើយ ។

ព្រះមហាសត្វបានស្តាប់ដូច្នោះក៏ទ្រង់បាននូវការស្រួលព្រះហឫទ័យ កាលទ្រង់ធ្វើបដិសណ្ឋារៈជាមួយព្រះបិតា ទើបត្រាស់ថា

បពិត្រព្រះបិតា ព្រះអង្គសុខសប្បាយទេឬ បពិត្រព្រះបិតា ព្រះ

អង្គមិនមានរោគាពាធទេឬ បពិត្រព្រះបិតា ព្រះនេត្ររបស់

ព្រះមាតានៃខ្ញុំព្រះអង្គមិនទាន់ងងឹតទេឬ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ចក្ខុ** ព្រះវេស្សន្តរទូលសួរថា ភ្នែកមាតាដែលទ្រង់ព្រះកន្សែង ព្រោះសេចក្តីសោកដល់ខ្ញុំមិនងងឹតទេឬ ។

ព្រះបាទសញ្ជ័យត្រាស់ថា

នែបុត្ត យើងសុខសប្បាយទេ នែបុត្ត យើងមិនមានជំងឺតម្កាត់

ទេ នែបុត្ត ចក្ខុមាតារបស់បាមិនទាន់ងងឹតទេ ដូច្នេះ ។

មហាសត្វក្រាបទូលថា

យានរបស់ព្រះអង្គមិនទាន់ចាស់ទេឬ វាហនៈរមែងនាំទៅបាន

ទេឬ ជនបទសម្បូរដែរឬ ភ្លៀងមិនដាច់ទេឬ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វុដ្ឋិ** បានដល់ ភ្លៀង ។

ព្រះបាទសញ្ជ័យត្រាស់ថា

យានរបស់យើងមិនទាន់ចាស់ទេ ទាំងវាហនៈក៏នាំទៅបាន

ជនបទក៏សម្បូរ ទាំងភ្លៀងក៏មិនដាច់ទេ ដូច្នេះ ។

កាលក្សត្រទាំង ៣ សំណេះសំណាលគ្នាយ៉ាងនេះ ព្រះនាងផុស្សតីទេវីកំណត់ថា ឥឡូវនេះស្តេចទាំង ៣ នឹងធ្វើសេចក្តីសោកឲ្យស្រាកស្រាន្តប្រថាប់អង្គុយហើយទើបយាងចូលទៅកាន់សម្នាក់ព្រះរាជឱរសមួយអន្លើដោយបរិវារធំ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** វីអាចិធមិងណាពុំទាន់ប្រាកដបទ

ព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសួចស្យសានូវព្រះគាថាដូច្នេះថា

កាលដែលក្សត្រិយ៍ទាំងបីអង្គកំពុងចរចាគ្នាយ៉ាងនេះឯង ព្រះរាជបុត្រីជាព្រះមាតាស្តេចមកដោយព្រះបាទា ឥតមានសុព័ណ៌បាទ ប្រាកដដល់ក្សត្រិយ៍ទាំងនោះទៀបទ្វារភ្នំ ។ ឯព្រះបាទវេស្សន្តរនិងព្រះនាងមទ្រីបានឃើញព្រះមាតានោះ ដែលមានហឫទ័យជាប់ក្នុងបុត្តកំពុងយាងមក ក៏ក្រោកទទួលហើយថ្វាយបង្គំ ។ ចំណែកខាងព្រះនាងមទ្រីថ្វាយបង្គំព្រះបាទទាំងគូរបស់ព្រះមាតាក្មេកដោយព្រះសិរ្ស៍ ( ហើយក្រាបបង្គំទូលថា ) បពិត្រព្រះមេម្ចាស់ ខ្ញុំម្ចាស់ឈ្មោះនាងមទ្រី ជាព្រះសុណិសារបស់ព្រះអង្គ សូមថ្វាយបង្គំព្រះបាទទាំងគូរបស់ព្រះមេដូច្នេះ ។

ក្នុងកាលដែលព្រះវេស្សន្តរនិងព្រះនាងមទ្រីថ្វាយបង្គំព្រះនាងផុស្សតីទេវី ហើយប្រថាប់ឈរ ជាលីនិងកណ្ហាជិនាទាំងទ្វេ មានកុមារកុមារីចោមរោមយាងមកដល់ ព្រះនាងមទ្រីប្រថាប់ឈរចាំមើលផ្លូវព្រះរាជឱរសនិងព្រះរាជធីតា ព្រះនាងទតឃើញកូនទាំង ២ មកដោយសួស្តីក៏មិនអាចទ្រទ្រង់នូវព្រះវរកាយដោយការៈរបស់ខ្លួនបាន ព្រះនាងទ្រហោយំរត់ទៅកាន់ទីនោះ ដូចមេគោដែលមានកូនខ្ចីដូច្នោះ ។ ឯជាលីនិងកណ្ហាជិនាទតឃើញព្រះមាតាក៏ខ្សឹកខ្សួល រត់តម្រង់ចូលមករកព្រះមាតានោះឯង ។

**តមត្ថំ បកាសេន្តោ សត្ថា អាហា** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដបទ

ព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសួចស្រានូវព្រះគាថាដូច្នេះថា

ចំណែកខាងព្រះរាជបុត្តទាំងពីរ ដែលមកអំពីទីឆ្ងាយ ដោយសួស្តី បានឃើញព្រះនាងមទ្រីហើយក៏ទ្រង់ព្រះកន្សែង អួលអាក់នាំគ្នាស្ទុះចូលទៅរកដូចកូនគោតូចស្ទុះទៅរកមេ ។ ឯព្រះនាងមទ្រីបានឃើញបុត្តទាំងពីរ ដែលមកអំពីទីឆ្ងាយ ដោយសួស្តីក៏ញាប់ញ័រដូចជាស្រីមេមត់ ទនៃទឹកក្សីរក៏ហូរចេញមកដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កន្ទន្តា អភិធាវិំសុ** សេចក្តីថា យំរត់ចូលទៅរក ។ បទថា **វារុណីវ បវេធន្តី** សេចក្តីថា មានខ្លួនញ័រចំប្រប់ដូចមេមត់ដែលត្រូវខ្មោចចូល ។ បទថា **ថនធារាភិសិញ្ចថ** សេចក្តីថា ធ្លារទឹកដោះហូរចេញអំពីព្រះស្តនទាំងទ្វេ ។

បានឮថា ព្រះនាងមទ្រីខ្សឹកខ្សួលដោយសំឡេងខ្លាំង ព្រះកាយញ័រចំប្រប់ដល់នូវវិសញ្ញីដួលដុះលើប្រឹថពី ។ ឯជាលីនិងកណ្ហាជិនាក៏រត់មកយ៉ាងលឿនដល់ព្រះជននីក៏ដួលសន្ធប់សន្កត់លើព្រះមាតា ។ ក្នុងខណៈនោះទឹកដោះក៏ហូរចេញអំពីព្រះថនាទាំងគូរបស់ព្រះនាងចូលក្នុងព្រះឱស្ឋ នៃកុមារកុមារីទាំង ២ នោះ បានឮថា បើមិនមានទឹកដោះហូរចូលប្រមាណប៉ុណ្ណេះ កុមារកុមារីទាំង ២ នឹងមានហទយៈរីងស្ងួតវិនាសទៅ ។

ឯព្រះវេស្សន្តរទតឃើញបុត្តជាទីស្រឡាញ់ទាំង ២ ក៏មិនអាចអត់ធន់នឹង

សេចក្ដីសោកបាន ដល់នូវវិសញ្ញីដួលចុះក្នុងទីនោះឯង ចំណែកព្រះជនកនិង ព្រះជននីនៃព្រះវេស្សន្តរក៏បាត់បង់ស្មារតីដួលចុះក្នុងទីនោះដូចគ្នា ។

ពួកអាមាត្យ ៦ ម៉ឺនដែលជាសហជាតរបស់ព្រះមហាសត្វ ឃើញកិរិយា របស់ស្ដេចទាំង ៦ ដូច្នោះ ក៏ដល់នូវវិសញ្ញីក្នុងទីនោះដូចគ្នា ។

បណ្ដារាជបរិវារទាំងឡាយឃើញហេតុការណ៍ដ៏គួរខ្លោចផ្សានោះ បុគ្គល សូម្បីតែម្នាក់ដែលអាចតាំងនៅក្នុងភាវៈនៃខ្លួនបានមិនមាន អាស្រមបទទាំង មូលហាក់ដូចព្រៃរាំង ដែលខ្យល់យុគន្តវាតញាំញីហើយ ខណៈនោះភ្នំទាំង ឡាយក៏លាន់ឮ មហាប្រឹថពីក៏កម្រើក មហាសមុទ្រក៏រញ្ជួយ ភ្នំសិនេរុក៏ទោរ ទន់ទៅមក កាមាវចរទេវលោកក៏កើតកោលាហលតែមួយ ។

គ្រានោះសក្កទេវរាជទ្រង់ព្រះតម្រិះថា ស្ដេចទាំង ៦ មួយអន្លើដោយរាជ បរិស័ទដល់នូវវិសញ្ញីភាព មិនមាននរណាម្នាក់ដែលអាចក្រោកឡើងយកទឹក ទៅប្រោះលើសរីរៈរបស់បុគ្គលណាមួយបានឡើយ ណ្ហើយចុះ អញនឹងញុំាង នូវភ្លៀងបោក្ខរព័ស្សិឲ្យធ្លាក់ចុះដើម្បីជនទាំងនោះក្នុងកាលឥឡូវនេះ ត្រិះរិះដូច្នេះ ហើយ ទើបញុំាងភ្លៀងបោក្ខរព័ស្សិឲ្យធ្លាក់ចុះក្នុងសមាគមនៃក្សត្រទាំង ៦ អង្គ ជនទាំងឡាយណាប្រាថ្នាឲ្យសើមជនទាំងនោះក៏សើម ជនទាំងឡាយមិនប្រាថ្នា តំណក់ទឹកភ្លៀងតែមួយតំណក់ក៏មិនធ្លាក់ចំជនទាំងនោះ ដូចទឹកដែលធ្លាក់ចុះ ចាកស្លឹកឈូកដូច្នោះ ភ្លៀងបោក្ខរព័ស្សិនោះដូចគ្នានឹងទឹកភ្លៀង ដែលធ្លាក់ចុះ លើស្លឹកឈូកដោយប្រការដូច្នេះ ។

ក្នុងកាលនោះស្ដេចទាំង ៦ អង្គ ក៏ត្រឡប់មានស្មារតី មហាជនដឹងភាព

អស្សារ្យថា ភ្លៀងបោក្ខរព័ស្សធ្លាក់ក្នុងសមាគមព្រះញាតិនៃព្រះមហាសត្វ ផែនដីក៏កម្រើកញាប់ញ័រ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូត្យសាន្តនូវព្រះគាថាដូច្នេះថា

កាលពួកព្រះញាតិជួបជុំគ្នាហើយ សំឡេងគឹកកងខ្លាំងក៏កើតឡើង ភ្នំទាំងឡាយក៏បន្លឺឡើង ទាំងផែនពសុធាក៏រំកើបញាប់ញ័រ ។ ភ្លៀងក៏ញុំាងផ្គារទឹកឲ្យធ្លាក់ក្នុងខណៈនោះ ព្រះបាទវេស្សន្តរក៏បានជួបនឹងញាតិទាំងឡាយក្នុងខណៈនោះ ។ ព្រះនត្តាទាំងពីរ ព្រះសុណិសា ព្រះរាជបុត្ត ព្រះរាជានិងព្រះទេវីបានជួបក្នុងទីជាមួយគ្នា ក្នុងកាលណា សេចក្តីព្រឺព្រួចរោមក៏មានក្នុងកាលនោះ ពួកអ្នកនគរទាំងអស់ បានផ្គងអញ្ជលីចំពោះព្រះបាទវេស្សន្តរនោះនាំគ្នាយំក្នុងព្រៃ មុខគួរឲ្យស្រប់ស្រែង ទូលអារាធនា ។ ពួករាស្ត្រទាំងអស់ជួបជុំគ្នា ( បានពោល ) នឹងព្រះបាទវេស្សន្តរ ផងនឹងព្រះនាងមទ្រីផងថា ព្រះអង្គជាព្រះរាជាឥស្សរៈរបស់ពួក យើងសូមព្រះអង្គទាំងពីរ ព្រះអង្គរបស់ពួកយើងសោយរាជសម្បត្តិ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឃោសោ** បានដល់ សំឡេងកងរំពងដែលប្រកបដោយសេចក្តីករុណា ។ បទថា **បញ្ជលិកា** សេចក្តីថា អ្នកព្រះនគរ

អ្នកនិគមនិងអ្នកជនបទទាំងអស់នាំគ្នាផ្គងអញ្ជលី ។ បទថា **តស្ស យាចន្តិ** សេចក្ដីថា ក្រាបចុះទៀបបាទានៃព្រះវេស្សន្តរ ទូញយំអង្វរថា បពិត្រព្រះ-សម្មតិទេព សូមទ្រង់ជាម្ចាស់ ជាធំ ជាបិតារបស់យើងខ្ញុំទាំងឡាយ មហាជនបំណាងនឹងអភិសេកក្សត្រទាំង ២ ក្នុងទីនោះឯង ហើយនាំទៅកាន់ព្រះនគរ សូមទ្រង់ទទួលស្វេតច្ឆត្រដែលជារបស់នៃរាជត្រកូល ។

**ឆខត្តិយបព្វ ចប់**

## ឆត្តរោកណ្ឌ

ព្រះមហាសត្វបានស្តាប់ដូច្នោះហើយកាលត្រាស់នឹងព្រះជនក ទើបត្រាស់ព្រះគាថានេះថា

ព្រះអង្គនិងពួកអ្នកជនបទ អ្នកនិគមបានព្រមព្រៀងគ្នានិរទេស
ខ្ញុំព្រះអង្គ ដែលកំពុងសោយរាជ្យតាមធម៌ ចាកដែនហើយ
ដូច្នេះ ។

បន្ទាប់ពីនោះព្រះបាទសញ្ជ័យកាលញ៉ាំងព្រះរាជឱរសឲ្យអត់ទោស ដល់ទ្រង់ទើបត្រាស់ថា

ម្នាលបុត្ត ( នេះ ) ពិតជាកំហុសរបស់យើង យើងបានធ្វើអំពើ
បំផ្លិចបំផ្លាញសេចក្តីចម្រើន បាននិរទេសបាដែលមិនមាន
កំហុសព្រោះតាមពាក្យពួកអ្នកសិវិរាស្រ្ត ដូច្នេះ ។

កាលត្រាស់គាថានេះហើយកាលទ្រង់អង្វរព្រះរាជឱរស ដើម្បីនាំសេចក្តីទុក្ខរបស់ទ្រង់ចេញទៅទើបត្រាស់គាថានេះថា

( កូន ) គួរដោះទុក្ខរបស់បិតាមាតាឬរបស់បងប្អូនស្រី ដោយ
ហេតុណានីមួយសូម្បីដោយជីវិតរបស់ខ្លួន[១] ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឧឧព្យហេ** បានដល់ គប្បីនាំទៅ ។ បទថា **អបិ ចាណោហិ អត្តនោ** សេចក្តីថា បានឮថា ព្រះបាទសញ្ជ័យត្រាស់យ៉ាង

---

១-ក្នុងបិដកខ្មែរបន្ទាប់អំពីពាក្យនេះ មានពាក្យក្នុងវង់ក្រចកថា ( ពួកអាមាត្យបានពោលថា បពិត្រមហារាជ កាលនេះជាកាលគួរស្រង់ទឹក សូមទ្រង់ដុសជម្រះព្រះរជោជល: ) តែក្នុងទីនេះយើងមិនបានលើកចូល ព្រោះនេះជាពាក្យរបស់អដ្ឋកថាចារ្យទេ ។

នេះនឹងព្រះវេស្សន្តរដោយទ្រង់បំណាងថា នែបា ធម្មតាកូនរមែងនាំសេចក្តីទុក្ខ គឺសេចក្តីសោករបស់មាតាបិតាចេញទៅសូម្បីត្រូវលះបង់ជីវិត ព្រោះហេតុនោះ កូនកុំរក្សាទោសរបស់បិតាទុកក្នុងចិត្ត ចូរធ្វើតាមពាក្យរបស់បិតា ចូរដោះភេទឥសីចេញហើយកាន់យកភេទជាក្សត្រចុះ ។

ព្រះពោធិសត្វសូម្បីទ្រង់ប្រាថ្នានឹងគ្រងរាជសម្បត្តិ តែបើមិនត្រាស់ពាក្យមានប្រមាណប៉ុណ្ណេះក៏ឈ្មោះថា មិនជាអ្នកធ្ងន់ ព្រោះហេតុនោះទើបត្រាស់ជាមួយនឹងព្រះរាជបិតា ។ ព្រះបាទសញ្ជ័យឲ្យព្រះមហាសត្វព្រមទទួលពាក្យ ។ ព្រះមហាសត្វទ្រង់ទទួលថា សាធុ ។

គ្រានោះពួកអាមាត្យ ៦ ម៉ឺន ជាសហជាតដឹងថា ព្រះមហាសត្វទទួលអារាធនាទើបក្រាបទូលថា បពិត្រមហារាជ កាលនេះជាកាលគួរស្រង់ទឹក សូមទ្រង់ជុសជម្រះព្រះរជោជលៈ ។

លំដាប់នោះមហាសត្វត្រាស់ថា អ្នកទាំងឡាយ ចូរបង្អង់មួយស្របក់ យាងចូលបណ្ណសាលាទ្រង់ដោះនូវគ្រឿងបរិក្ខាររបស់ឥសីទុក ទ្រទ្រង់នូវព្រះភូសាពណ៌ដូចស័ង្ខ ទ្រង់ចេញចាកបណ្ណសាលាពិចារណាថា ទីនេះជាទីដែលអញចម្រើនសមណធម៌អស់ ៩ ខែកន្លះ ទីនេះជាទីដែលផែនដីញាប់ញ័រព្រោះអញបានកាន់យកកំពូលនៃបារមី បរិច្ចាគកូនជាទីស្រឡាញ់និងភរិយាជាទាន ទ្រង់អាវជ្ជនៈដូច្នេះហើយ ធ្វើប្រទក្សិណបណ្ណសាលា ៣ ជុំ ទ្រង់ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋានហើយទ្រង់ឈរ ។

កាលនោះ អាមាត្យមាននាយកូសាមាលាជាដើមក៏ធ្វើកិច្ច មានកាត់កោរ

ព្រះកេសានិងព្រះមស្សុជាដើមដល់ព្រះមហាសត្វ ជនទាំងឡាយបានអភិសេកព្រះមហាសត្វដែលប្រដាប់ដោយរាជាភរណៈទាំងពួងដែលរុងរឿងដូចទេវរាជក្នុងរាជសម្បត្តិ ។

ព្រោះហេតុនោះទើបព្រះមានព្រះភាគត្រាស់ថា

គ្រានោះព្រះបាទវេស្សន្តរក៏ជុសជម្រះក្អែល លុះជុសជម្រះក្អែល
ហើយបានទ្រទ្រង់ព្រះពស្ត្រមានពណ៌ដូចស័ង្ខ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បវាហយិ** សេចក្តីថា ឲ្យនាំទៅ កាលឲ្យនាំទៅហើយឲ្យកាន់យកភេទជាព្រះរាជា ។

កាលនោះព្រះមហាសត្វដែលជាអ្នកមានយសធំ ទីដែលទ្រង់ទតហើយក៏ញាប់ញ័រ ។ ពួកអ្នកចេះមន្តល ទ្រទ្រង់នូវមន្តលទុកដោយមាត់ ក៏ញុំាងនូវមន្តលឲ្យកងរំពង ពួកអ្នកប្រគំក៏ប្រគំតន្ត្រីទាំងពួងឲ្យព្រមគ្នា ការកងរំពងកោលាហលនៃតន្ត្រីគគ្រឹកគគ្រេងពន់ពេក ហាក់បីដូចសំឡេងកងរំពងនៃផ្គរលាន់គំរាមក្នុងមហាសមុទ្ទដូច្នោះ ពួកអាមាត្យប្រដាប់នូវហត្ថីរត្ន ត្រៀមចាំទទួលព្រះរាជា ព្រះវេស្សន្តរមហាសត្វចងនូវព្រះខ័នរត្ន ហើយឡើងហត្ថីរត្ន ពួកអាមាត្យ ៦ ម៉ឺនដែលជាសហជាតប្រដាប់គ្រឿងអលង្ការសព្វយ៉ាង ចោមរោមព្រះមហាសត្វ ឯនាងកញ្ញាទាំងពួងឲ្យព្រះនាងមទ្រីស្រពស្រង់ព្រះកាយហើយតាក់តែងព្រះកាយថ្វាយអភិសេក ប្រូចទឹកសម្រាប់អភិសេកលើសីសៈនៃព្រះនាងមទ្រីបានពោលមន្តលទាំងឡាយថា សូមព្រះវេស្សន្តរទ្រង់អភិបាលជាដើម ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសានូវព្រះគាថាដូច្នេះថា

ព្រះបាទវេស្សន្តរទ្រង់កក់ព្រះសិរ្យ៍មានព្រះពស្ត្រដ៏ស្អាត ស្អិតស្អាងដោយអាករណៈគ្រប់យ៉ាង ទ្រង់សៀតព្រះខាន់ដែលដុតកម្តៅសត្រូវហើយទ្រង់ឡើងគង់លើដំរីដ៏ប្រសើរឈ្មោះបច្ច័យ ។

កាលនោះពួកទាហាន ៦០.០០០ នាក់ កើតក្នុងថ្ងៃជាមួយគ្នា គួររមិលមើលញុំាងព្រះរាជាជាធំក្នុងរថឲ្យរីករាយ ហោមរោម ។

កាលនោះពួកកញ្ញារបស់ព្រះបាទសិវិបានចូបជុំគ្នា ហើយញុំាងព្រះនាងមទ្រីឲ្យស្រង់ទឹក ( ហើយពោលថា ) សូមព្រះបាទវេស្សន្តរនិងជាលីកណ្ហាជិនាទាំងពីរបីបាច់ថែរក្សាព្រះនាង ទាំងមហារាជព្រះនាមសញ្ជ័យក៏សូមឲ្យថែរក្សាព្រះនាងដែរដូច្នេះ ។

បណ្តាបទទាំងនោះបទថា **បច្ចយំ នាគមារុយ្ហ** បានដល់ ដំរីដ៏ប្រសើរដែលកើតក្នុងថ្ងៃព្រះវេស្សន្តរប្រសូតនោះ ។ បទថា **បរន្តបំ** បានដល់ ញុំាងសត្រូវឲ្យកោតញញើត ។ បទថា **បរិកិរិំសុ** បានដល់ ហោមរោម ។ បទថា **នន្ទយន្តា** បានដល់ ឲ្យត្រេកអរ ។ បទថា **សិវិកញ្ញា** សេចក្តីថា ពួកបជាបតីរបស់ព្រះបាទសិវិរាជ ប្រជុំគ្នាឲ្យព្រះនាងមទ្រីស្រពស្រង់ ដោយទឹកក្រអូប ។ បទថា **ជាលី កណ្ហាជិនា ចុភោ** សេចក្តីថា សូម្បីព្រះរាជឱរសព្រះរាជធីតារបស់ព្រះនាង ក៏ចូរថែរក្សាមាតា ។

ព្រះបាទវេស្សន្តរនិងព្រះនាងមទ្រី បាននូវទីពឹងនេះ ( បាន តម្កល់ក្នុងរាជសម្បត្តិហើយភ្ញាករឭក ) នូវសេចក្តីសៅហ្មង របស់ព្រះអង្គ ( ដែលទ្រង់ធ្លាប់នៅក្នុងព្រៃពីដើម ) ក៏ទ្រង់ឲ្យ ទួងអានន្ទិយភេរី ត្រាច់ទៅទៀបភ្នំវង្កតដែលគួរជាទីរីករាយ ។ ព្រះនាងមទ្រីបរិបូណ៌ដោយលក្ខណៈបានទីពឹងនេះហើយ ( ក៏ ភ្ញាករឭក ) នូវសេចក្តីសៅហ្មងរបស់ព្រះនាង ដែលធ្លាប់នៅក្នុង ព្រៃពីដើម បានចួបនឹងបុត្តទាំងពីរហើយក៏ត្រេកអររីករាយ ។ ព្រះនាងមទ្រីបរិបូណ៌ដោយលក្ខណៈ បានទីពឹងនេះហើយក៏មាន ព្រះហឫទ័យភ្ញាករឭកសេចក្តីសៅហ្មងរបស់ព្រះនាង ដែលធ្លាប់ នៅក្នុងព្រៃពីដើម មានចិត្តត្រេកអររីករាយជាមួយនឹងបុត្តទាំង ពីរ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឥទញ្ច បច្ចយំ លទ្ធា** សេចក្តីថា ម្នាល ភិក្ខុទាំងឡាយ ព្រះវេស្សន្តរនិងព្រះនាងមទ្រី ទ្រង់បានបច្ច័យនេះ គឺទីពឹងនេះ ហើយតាំងនៅក្នុងរាជសម្បត្តិ ។ បទថា **បុត្តេ** សេចក្តីថា ក្សត្រទាំង ២ អង្គ រឭកដល់ការស្នាក់នៅក្នុងព្រៃដែលជាសេចក្តីលំបាករបស់ព្រះអង្គក្នុងកាលមុន អំពីនេះទើបឲ្យវាយស្គរអានន្ទិយភេរីប្រកាស ។ បទថា **រមណីយេ គិរិព្វជេ** សេចក្តីថា ឲ្យវាយស្គរអានន្ទិយភេរីដែលចងដោយវល្លិមាស ត្រាច់ទៅត្រង់ ភ្នំវង្កត ដែលជាទីគួរត្រេកអរថា អាណាខេត្តនៃព្រះរាជាវេស្សន្តរនឹងលេង មហោស្រពឲ្យជាទីត្រេកអរ ។ បទថា **អានន្ទចិត្តា សុមនា** បានដល់ ព្រះ

នាងមទ្រីដល់ព្រមដោយព្រះលក្ខណៈ បានជួបព្រះរាជឱរសព្រះរាជធីតា ព្រះនាងត្រេកអរក្នុងព្រះហឫទ័យ គឺត្រេកអរពន់ពេក ។ បទថា **បីតិតា** បានដល់ មានបីតិសោមនស្សប្រព្រឹត្តទៅហើយ ។ កាលព្រះនាងមានព្រះហឫទ័យឆ្អែតដោយសោមនស្សយ៉ាងនេះហើយ ព្រះនាងមទ្រី បានត្រាស់នឹងព្រះរាជឱរសនិងព្រះរាជធីតាថា

នែបុត្តទាំងពីរ កាលពីដើមមាតាជាអ្នកបរិភោគភត្តតែមួយពេល ដេកផ្ទាល់នឹងផែនដីជានិច្ច នេះជាវត្តរបស់មាតាដូច្នេះ ព្រោះសេចក្តីប្រាថ្នាចង់ ( ជួប ) នឹងបាទាំងពីរ ម្នាលបុត្តទាំងពីរ វត្តនោះសម្រេចដល់មាតាក្នុងថ្ងៃនេះហើយ ព្រោះបានជួបនឹងបាទាំងពីរ ម្នាលបុត្តទាំងពីរ សូមឲ្យបុណ្យដែលកើតអំពីមាតានឹងកើតអំពីបិតារក្សាបា ទាំងមហារាជព្រះនាមសញ្ជ័យក៏សូមឲ្យរក្សាបា ។ បុណ្យណានីមួយដែលមាតាក្តី បិតាក្តីរបស់បាបានធ្វើហើយ ដោយកុសលទាំងអស់នោះសូមបាកុំចាស់កុំស្លាប់ឡើយ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **តុម្ហំ កាមា ហិ បុត្តកា** សេចក្តីថា ព្រះនាងមទ្រីត្រាស់ថា នែកូនទាំង ២ មាតាប្រាថ្នាកូនកាលកូនត្រូវព្រាហ្មណ៍នាំទៅក្នុងកាលមុន ម្តាយបរិភោគអាហារតែម្តង ដេកលើផែនដី ម៉ែមានសេចក្តីប្រាថ្នាក្នុងកូនទើបប្រព្រឹត្តវត្តនេះដោយប្រការដូច្នេះ ។ បទថា **សមិទ្ធជ្ជ** សេចក្តីថា វត្តនោះសម្រេចហើយក្នុងថ្ងៃនេះ ។ បទថា **មាតុជំបិ តំ ចាលេតុ បិ–**

**តុជ្ជំបិ ច បុត្តកា** សេចក្តីថា នែកូនទាំងឡាយ សោមនស្សដែលកើតអំពីមាតាក្តី កើតអំពីបិតាក្តី ចូរគ្រប់គ្រងកូនទាំង ២ គឺបុណ្យដែលជារបស់មាតានិងបិតាចូររក្សានូវកូន ព្រោះហេតុនោះឯងទើបព្រះនាងត្រាស់ថា **យញ្ចិញ្ចិត្តិ កតំ បុញ្ញំ** ដូច្នេះ ។

ឯព្រះនាងផុស្សតីទេវីមានព្រះតម្រិះថា តាំងអំពីនេះទៅកូនប្រសាររបស់អញ ចូរទ្រទ្រង់សំពត់ទាំងនេះនិងទ្រទ្រង់អាភរណៈទាំងនេះ ព្រះនាងត្រិះរិះដូច្នេះហើយត្រាស់ឲ្យដាក់វត្ថាភរណៈពេញក្នុងប្រអប់មាស ហើយបញ្ជូនទៅព្រះរាជទាន ។

**តមត្ថំ បកាសេន្តោ សត្ថា អាហា** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូធ្យសានូវព្រះគាថាដូច្នេះថា

> ព្រះសស្សុបានបញ្ជូនកប្បាសិកពស្ត្រ កោសេយ្យពស្ត្រ ខោមពស្ត្រនិងកោទុម្ពរពស្ត្រទៅថ្វាយព្រះសុណ្ហា ដែលជាសំពត់សម្រាប់លំអព្រះនាងមទ្រី ។ លំដាប់តមកព្រះសស្សុបានបញ្ជូនគ្រឿងប្រដាប់ព្រះសួរគ្គជាវិការៈនៃមាសនិងគ្រឿងប្រដាប់ព្រះសួរគ្គជាវិការៈនៃកែវ ទៅថ្វាយព្រះសុណ្ហាដែលជាគ្រឿងប្រដាប់សម្រាប់លំអរបស់ព្រះនាងមទ្រី ។ លំដាប់តមកទៀត ព្រះសស្សុបានបញ្ជូនគ្រឿងប្រដាប់ព្រះសួរគ្គ ជាវិការៈនៃមាសនិងកន្ទ្រុំនិងខ្សែក្រវាត់ជាវិការៈនៃកែវមណី ទៅថ្វាយព្រះសុណ្ហា

ដែលជាគ្រឿងប្រដាប់លំអរបស់ព្រះនាងមទ្រី ។ ព្រះសស្សុ
បានបញ្ជូនគ្រឿងប្រដាប់នលាដៈ ជាគ្រឿងប្រដាប់សម្រាប់ព្រះ
ភក្ត្រមានពណ៌ផ្សេងៗ ដែលជាវិការៈនៃកែវមណីទៅថ្វាយព្រះ
សុណ្ហា ដែលជាគ្រឿងប្រដាប់លំអរបស់ព្រះនាងមទ្រី ។ ព្រះ
សស្សុបានបញ្ជូននូវគ្រឿងប្រដាប់ សម្រាប់ព្រះស្តននិងគ្រឿង
ប្រដាប់ស្មានិងខ្សែក្រវាត់ កងជើង ទៅថ្វាយព្រះសុណ្ហាដែលជា
គ្រឿងប្រដាប់លំអព្រះមទ្រី ។ ព្រះរាជបុត្រីជាស្ត្រីប្រសើរ បាន
គយគន់មើលគ្រឿងប្រដាប់ល្បើកដោយអំបោះនិងគ្រឿងប្រដាប់
វៀរចាកអំបោះដ៏ល្អក្រៃពេកហាក់ដូចទេវកញ្ញាក្នុងនន្ទនឧទ្យាន ។
ព្រះរាជបុត្រីកក់ព្រះសិរ្ស មានព្រះពស្ត្រដ៏ស្អាត ស្អិតស្អាង
ដោយអាភរណៈគ្រប់យ៉ាងដ៏ល្អក្រៃពេក ហាក់ដូចស្ត្រីអប្សរក្នុង
ឋានត្រៃត្រិង្ស ។ ព្រះរាជបុត្រីបរិបូណ៌ដោយរបៀបនៃអញ្ចាញ
ធ្មេញ ល្អក្រៃពេកហាក់ដូចដើមចេកដែលកើតក្នុងចិត្តលតាវ័ន
ត្រូវខ្យល់បក់បោកហើយ ។ ព្រះរាជបុត្រីមានបបូរមាត់ដូចផ្លែ
ជ្រៃទុំនិងផ្លែបាសទុំ ល្អក្រៃពេក ហាក់ដូចបក្សីមានសរីរៈសព្វ
គ្រប់ដូចជាសរីរៈនៃមនុស្ស មានស្លាបដ៏វិចិត្រ ( ហើរឰដ៏
អាកាស ) ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ខោមញ្ច កាយូរំ** បានដល់ គ្រឿងប្រដាប់
ត្រង់ក មានសណ្ឋានដូចផ្លែល្មុ សម្រេចដោយមាស ។ បទថា **រតនាមយំ**

បានដល់ គ្រឿងប្រដាប់កម្មួយប្រភេទទៀត សម្រេចដោយរតនៈ ។ បទថា **អង្គទំ មណិមេខលំ** បានដល់ គ្រឿងប្រដាប់ដៃនិងគ្រឿងប្រដាប់ចង្កេះរបស់ព្រះនាងសម្រេចដោយកែវមណី ។ បទថា **ឧណ្ណាតំ** បានដល់ គ្រឿងប្រដាប់ថ្ងាស ។ បទថា **មុខផុល្លំ** បានដល់ គ្រឿងប្រដាប់ព្រះនលាដមានសណ្ឋានដូចកម្រងគ្រាប់ល្ង ។ បទថា **នានារត្តេ** បានដល់ មានពណ៌ផ្សេងៗ ។ បទថា **មាណិយេ** បានដល់ សម្រេចហើយដោយកែវមណី ។ គ្រឿងប្រដាប់ ២ ប្រភេទនេះ គឺគ្រឿងប្រដាប់ទ្រូងនិងគ្រឿងប្រដាប់ស្មាក៏ចាត់ជាគ្រឿងប្រដាប់ ។ បទថា **មេខលំ** បានដល់ គ្រឿងប្រដាប់ចង្កេះសម្រេចដោយមាសនិងប្រាក់ ។ បទថា **បដិចានកំ** បានដល់ គ្រឿងប្រដាប់ព្រះបាទ ។ បទថា **សុត្តញ្ច សុត្តវជ្ជញ្ច** បានដល់ គ្រឿងប្រដាប់ដែលមានខ្សែដោតនិងគ្រឿងប្រដាប់ដែលមិនមានខ្សែដោត ។ តែក្នុងបាលីរចនាទុកថា **សុប្បញ្ច សុប្បវជ្ជញ្ច** ដូច្នេះក៏មាន ។ បទថា **ឧបនិជ្ឈាយ សេយ្យសិ** សេចក្តីថា ព្រះនាងផុស្សតីរាជទេវីពិនិត្យមើលរាងកាយ ដែលខ្វះខាតដោយគ្រឿងប្រដាប់ មានគ្រឿងប្រដាប់ដែលដោតដោយខ្សែនិងមិនដោតដោយខ្សែ ហើយប្រដាប់ឲ្យបរិបូណ៌ ធ្វើឲ្យព្រះនាងមទ្រីរឹងរឹតតែស្រស់ស្អាតប្រសើរឡើងទៀត ដូចទេវកញ្ញាក្នុងនន្ទនវ័ន ។ បទថា **វាតច្ឆុបិតា** សេចក្តីថា ថ្ងៃនេះព្រះនាងមទ្រីយាងលីលាដូចចេកមាសត្រូវខ្យល់ ដែលកើតត្រង់ចិត្តលតាវ័នដូច្នោះ ។ បទថា **ទន្តាវរណសម្បន្នា** បានដល់ ប្រកបដោយបបូរមាត់ក្រហម មានពណ៌ដូចផ្លែបាសទុំ ។ បទថា **សកុណី មានុសិនីវ ជាតា ចិត្តប្បត្តា បតិ** សេចក្តីថា សកុណីមានឈ្មោះ

ថា មានុសិនី ដែលកើតមកដោយសរីរៈដូចមនុស្ស មានរោមស្លាបដ៏វិចិត្រ បើកស្លាបហើរទៅក្នុងអាកាសរមែងស្រស់ស្អាតយ៉ាងណា ព្រះនាងមទ្រីមានព្រះឱស្ឋដូចផ្លែជ្រៃទុំព្រោះមានព្រះឱស្ឋក្រហមល្អក៏ដូច្នោះ ។

ពួកអាមាត្យនាំដំរីដ៏ប្រសើរ មិនចាស់ពេក អត់ទ្រាំលំពែងបាន អត់ទ្រាំកូនសរបាន មានភ្លុកងទន្ទាំ អាចគាស់រំលើងសត្រូវបាន មកថ្វាយព្រះនាងមទ្រីនោះ ។ ព្រះនាងមទ្រីនោះឡើងកាន់ដំរីដ៏ប្រសើរមិនចាស់ពេក អត់ទ្រាំលំពែងបាន អត់ទ្រាំកូនសរបាន មានភ្លុកងទន្ទាំអាចគាស់រំលើងសត្រូវបាន ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **តស្សា ច** សេចក្ដីថា ម្នាលភិក្ខុទាំងឡាយ អាមាត្យទាំងឡាយបាននាំដំរីក្មេង ១ ដែលមិនចាសពេក ជាដំរីក្នុងមជ្ឈិមវ័យ អត់ធន់នូវការប្រហារដោយលំពែងនិងព្រួញ ប្រដាប់ដោយគ្រឿងអលង្ការទាំងពួងដើម្បីព្រះនាងមទ្រី ។ បទថា **ឆាគមារុហិ** សេចក្ដីថា ព្រះនាងយាងឡើងលើខ្នងដំរី ។

ព្រះវេស្សន្តរនិងព្រះនាងមទ្រីទាំង ២ បានយាងទៅកាន់កងទ័ព ដោយព្រះឥស្សរិយយសធំដោយប្រការដូច្នេះ ។ ឯព្រះបាទសញ្ជ័យមហារាជ ទ្រង់ក្រសាលតាមព្រៃភ្នំ ប្រមាណមួយខែជាមួយនឹងពួកពល ១២ អក្ខោភិនី ។ ពាឡម្រឹគនិងបក្សីក្នុងព្រៃធំដល់ម្ល៉ោះ មិនបានបៀតបៀនសត្វណាមួយឡើយ ដោយតេជានុភាពនៃមហាសត្វ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដបទ

ព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសួច្បសានូវព្រះគាថាដូច្នេះថា

ពួកម្រឹគទាំងប៉ុន្មានដែលមាននៅក្នុងព្រៃទាំងអស់នុ៎ះ មិនបៀតបៀនគ្នានឹងគ្នាដោយតេជះនៃព្រះបាទវេស្សន្តរ ។ ពួកបក្សីទាំងប៉ុន្មានដែលមាននៅក្នុងព្រៃទាំងអស់នុ៎ះ មិនបៀតបៀនគ្នានឹងគ្នា ដោយតេជះនៃព្រះបាទវេស្សន្តរ ។ កាលព្រះបាទវេស្សន្តរញ៉ាំងពួកអ្នកសិវិរាស្រ្តឲ្យបម្រើនទ្រង់យានចេញ ( អំពីព្រៃ ) ពួកម្រឹគទាំងប៉ុន្មានដែលមាននៅក្នុងព្រៃទាំងអស់នុ៎ះ បានមកប្រជុំក្នុងទីជាមួយគ្នា ។ កាលព្រះបាទវេស្សន្តរ ញ៉ាំងពួកអ្នកសិវិរាស្រ្តឲ្យបម្រើន ទ្រង់យានចេញ ( អំពីព្រៃ ) ពួកបក្សីទាំងប៉ុន្មានដែលមាននៅក្នុងព្រៃទាំងអស់នុ៎ះ បានមកប្រជុំក្នុងទីជាមួយគ្នា ។ កាលព្រះបាទវេស្សន្តរ ញ៉ាំងពួកអ្នកសិវិរាស្រ្តឲ្យបម្រើន ទ្រង់យានចេញ ( អំពីព្រៃ ) ពួកម្រឹគទាំងប៉ុន្មានដែលមាននៅក្នុងព្រៃទាំងអស់នុ៎ះ លែងស្រែកសំឡេងពីរោះ ។ កាលព្រះបាទវេស្សន្តរ ញ៉ាំងពួកអ្នកសិវិរាស្រ្តឲ្យបម្រើន ទ្រង់យានចេញ ( អំពីព្រៃ ) ពួកបក្សីទាំងប៉ុន្មានដែលមាននៅក្នុងព្រៃទាំងអស់នុ៎ះ លែងស្រែកសំឡេងពីរោះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **យាវន្តេត្ថ** កាត់បទជា **យាវន្តោ ឯត្ថ** ។ បទថា **ឯកជ្ឈំ សន្និធាតីសុ** សេចក្តីថា មកប្រជុំក្នុងទីតែមួយ កាលប្រជុំគ្នា

ហើយមានទោមនស្សថា តាំងអំពីនេះទៅយើងទាំងឡាយនឹងមិនមានហិរិ មិនមានសំវរៈចំពោះគ្នានឹងគ្នា ។ បទថា **ឆាសុ្ស មញ្ចូសិ ក្ចុជីសុ** សេចក្តីថា មានសេចក្តីទុក្ខ ព្រោះព្រាត់ចាកព្រះមហាសត្វ ទើបមិនស្រែកយំដោយសំឡេងពីរោះ ។

ព្រះបាទសញ្ជយនរិន្ទរាជ កាលយាងប្រពាតតាមភ្នំនិងជងព្រៃប្រមាណ ១ ខែ ជាមួយពួកពល ១២ អក្ខោភិនីហើយត្រាស់ហៅសេនាគុត្តមាត្យមកត្រាស់សួរថា យើងទាំងឡាយនៅក្នុងព្រៃយូរហើយ ផ្លូវសម្រាប់យាងរបស់កូនយើងពួកអ្នកតាក់តែងហើយឬ កាលពួកអាមាត្យក្រាបទូលថា បពិត្រព្រះអង្គ តាក់តែងហើយ ដល់ពេលយាងហើយ ទើបឲ្យទូលព្រះវេស្សន្តរ ឲ្យវាយស្គរប្រកាសឲ្យដឹងពីកាលត្រឡប់ទៅព្រះនគរ ហើយទ្រង់នាំកងទ័ពយាងត្រឡប់ ។ ព្រះវេស្សន្តរមហាសត្វយាត្រាដោយរាជបរិវារធំតាមផ្លូវដែលរៀបចំទុក ៦០ យោជន៍ តាំងពីជើងភ្នំវង្កតរហូតដល់ជេតុត្តរនគរ ។

**តមគ្គំ បក្កាសេន្តោ សត្ថា អាហ** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសួធ្យសានូវព្រះគាថាដូច្នេះថា

ពួកអាមាត្យបានរៀបចំរាជមាគ៌ាឲ្យរំលេចធ្លុះធ្លាស់ ត្រៀបត្រាដោយផ្កា តាំងអំពីទីដែលព្រះបាទវេស្សន្តរទ្រង់គង់នៅ រហូតដល់ក្រុងជេតុត្តរ ។ លំដាប់នោះកាលព្រះបាទវេស្សន្តរ ញ៉ាំងអ្នកសិវិរាស្ត្រឲ្យចម្រើន ទ្រង់យាងចេញ ( អំពីព្រៃ ) ពួក

យោធាទាំង ៦០.០០០ ល្អមើលបានហែហមជុំវិញ ។ កាល ព្រះបាទវេស្សន្តរ ញ៉ាំងពួកអ្នកសិវិរាស្ត្រឲ្យចម្រើន ទ្រង់យាង ចេញ ( អំពីព្រៃ ) ពួកស្រីស្នំផង ពួករាជកុមារផង ពួកអ្នក ជំនួញផង ពួកព្រាហ្មណ៍ផងហែហមជុំវិញ ។ កាលព្រះបាទ វេស្សន្តរ ញ៉ាំងពួកអ្នកសិវិរាស្ត្រឲ្យចម្រើន ទ្រង់យាងចេញ ( អំពីព្រៃ ) ពួកពលដំរី ពលសេះ ពលរថ ពលថ្មើរជើង ហែហមជុំវិញ ។ កាលព្រះបាទវេស្សន្តរញ៉ាំងពួកអ្នកសិវិរាស្ត្រ ឲ្យចម្រើន ទ្រង់យាងចេញ ( អំពីព្រៃ ) ពួកអ្នកជនបទក៏បាន មកជួបជុំគ្នានិងអ្នកនិគមក៏បានមកចួបជុំគ្នា ហែហមជុំវិញ ។ កាលព្រះបាទវេស្សន្តរ ញ៉ាំងពួកអ្នកសិវិរាស្ត្រឲ្យចម្រើន ទ្រង់ យាងចេញ ( អំពីព្រៃ ) ពួកទាហានពាក់មួក ទ្រទ្រង់ខែល កាន់ ធ្នូ ចងគ្រឿងក្រោះដ៏ល្អ ដើរហែខាងមុខ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បដិយត្តោ** បានដល់ តាក់តែងដូចក្នុងកាល បូជាពិសេសក្នុងវិសាខបុណ្ណមី ។ បទថា **វិចិត្តោ** បានដល់ វិចិត្រទៅដោយ ដើមចេក ក្អមទឹក ទង់ជ័យនិងទង់ផ្កាលាជាដើម ។ បទថា **បុប្ផសន្ថតោ** បានដល់ រាយរាយដោយផ្កាទាំងឡាយដែលមានលាជជាគម្រប់ ៥ ។ បទ ថា **យត្ថ** សេចក្ដីថា ប្រដាប់តាក់តែងផ្លូវតាំងអំពីគិរីវង្កត ដែលព្រះវេស្សន្តរ គង់ប្រថាប់ជាប់តគ្នារហូតដល់ជេតុត្តរនគរ ។ បទថា **ករោដិយា** បានដល់ ពួកទាហានដែលពាក់មួកលើក្បាល ដែលបានឈ្មោះថា **សីសករោដិក** ។

បទថា **ចម្មធរា** បានដល់ ទ្រទ្រង់នូវស្បែក ដែលជាគ្រឿងបិទបាំងត្រង់ក ។ បទថា **សុវម្មិកា** បានដល់ ពាក់គ្រោះដោយល្អ ដោយបណ្តាញដ៏វិចិត្រ ។ បទថា **បុរតោ បដិបជ្ជឹសុ** សេចក្តីថា យោធាក្លាហានបែបនេះសូម្បីមានហ្វូងដំរីចុះប្រេងនាំគ្នាមកក៏មិនថយក្រោយ គឺនៅតែដើរទៅខាងមុខព្រះរាជាវេស្សន្តរនោះឯង។

ព្រះវេស្សន្តរយាងមកអស់ផ្លូវ ៦០ យោជន៍ អស់កាល ២ ខែ ដល់ជេតុត្តរនគរ ទ្រង់ចូលព្រះនគរដែលប្រដាប់តាក់តែងហើយទ្រង់ឡើងកាន់ប្រាសាទ ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** វីអាចិជមិឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូត្យសានូវព្រះគាថាដូច្នេះថា

ក្សត្រិយ៍ទាំងនោះ បានយាងចូលទៅកាន់បុរី ជាក្រុងគួរឲ្យត្រេកអរ មានកំពែងនិងទ្វារខាងក្រៅដ៏ច្រើនប្រកបដោយគ្រឿងស៊ីនិងគ្រឿងផឹក មានទាំងល្បែងពីរយ៉ាង គឺរាំនិងច្រៀង ។ កាលរាជកុមារញ៉ាំងពួកអ្នកសិវិរាស្ត្រឲ្យចម្រើន ស្តេចមកដល់ ពួកអ្នកជនបទនិងពួកអ្នកនិគមបានមកជួបជុំគ្នាត្រេកអរ ។ កាលព្រះមហាក្សត្រិយ៍ ជាអ្នកប្រទានព្រះរាជទ្រព្យ ស្តេចមកដល់ហើយ ពួកមហាជនក៏នាំគ្នាលើកទង់ជ័យ ទូងនន្ទិភេរីហើយចូលទៅព្រះនគរ ព្រះបាទវេស្សន្តរក៏ទ្រង់ឲ្យឃោសនា ដើម្បីឲ្យដោះលែងសព្វសត្វចាកចំណង ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ពហុទ្វារការតោរណំ** សេចក្ដីថា ប្រកបដោយកំពែងខ្ពស់និងសសរខឿនជាច្រើន ។ បទថា **នច្ចគីតេហិ ចូភយំ** សេចក្ដីថា ប្រកបដោយការរាំនិងការច្រៀងទាំង ២ ។ បទថា **វិត្តា** បានដល់មានចិត្តត្រេកអរ គឺដល់នូវសោមនស្ស ។ បទថា **អាគតេ ធនធាយកេ** សេចក្ដីថា កាលព្រះមហាសត្វព្រះរាជទានទ្រព្យដល់មហាជនយាងមកដល់ ។ បទថា **នន្ទិប្បវេសិ** សេចក្ដីថា ឲ្យទូងនន្ទភេរីប្រកាសក្នុងព្រះនគរថាជារាជអាណាចក្ររបស់ព្រះបាទវេស្សន្តរមហារាជ ។ បទថា **ពន្ធនា មោក្ខោ អឃោសថ** សេចក្ដីថា បានប្រកាសឲ្យដោះលែងសត្វដែលឃាំងទុក គឺព្រះវេស្សន្តរមហារាជឲ្យដោះលែងសព្វសត្វអំពីទីដែលត្រូវបង្ខាំង ដោយហោចឆ្មាក៏ឲ្យដោះលែង ។

ក្នុងថ្ងៃយាងចូលព្រះនគរនោះឯង ព្រះវេស្សន្តរទ្រង់ព្រះតម្រិះក្នុងពេលទៀបភ្លឺថា ស្អែកនេះកាលរាត្រីអស់ហើយ ពួកយាចកដឹងថាអញត្រឡប់មកហើយក៏នឹងនាំគ្នាមករក អញនឹងឲ្យអ្វីដល់យាចកទាំងនោះហ្ន៎ ។ ខណៈនោះកពនៃសក្កទេវរាជក៏បញ្ចេញអាការក្ដៅ ទ្រង់អាវជ្ជនាការដឹងហេតុនោះ ទើបញ៉ាំងទីខាងមុខនិងទីខាងក្រោយនៃព្រះរាជនិវេសន៍ឲ្យពេញដោយរតនៈ មានកម្ពស់ប្រមាណស្មើចង្កេះ ញ៉ាំងភ្លៀងកែវ ៧ ប្រការឲ្យធ្លាក់ចុះក្នុងព្រះនគរទាំងមូលប្រមាណត្រឹមក្បាលជង្គង់ ។ ស្អែកឡើងព្រះមហាសត្វ បានព្រះរាជទានទ្រព្យដែលធ្លាក់នៅលើផ្ទៃដីខាងមុខ និងខាងក្រោយ នៃរាជត្រកូលនោះៗថាទ្រព្យនេះចូរជារបស់ត្រកូលទាំងនោះឯង ហើយឲ្យនាំទ្រព្យដ៏សេស ដាក់ក្នុង

ឃ្លាំងជាមួយទ្រព្យដែលនៅក្នុងលានព្រះរាជវាំងរបស់ព្រះអង្គ ហើយទ្រង់ផ្តើមឲ្យទាន ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូត្រសាទូវព្រះគាថាដូច្នេះថា

កាលព្រះបាទវេស្សន្តរញ៉ាំងពួកអ្នកសិវិរាស្ត្រឲ្យបម្រើន ស្តេច
ចូលមកដល់ សក្កទេវរាជដែលជាឧបបត្តិទេព បានបង្អុរភ្លៀង
ជាវិការៈនៃមាស ។ លំដាប់នោះព្រះបាទវេស្សន្តរជាក្សត្រិយ៍
ប្រកបដោយប្រាជ្ញាទ្រង់ឲ្យទាន លុះបែកធ្លាយរាងកាយនោះ
ទៅ ក៏បានស្តេចទៅកើតក្នុងឋានសួគ៌ទេវលោក ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សគ្គំ សោ ឧបបជ្ជថ** សេចក្តីថា ចុតិចាកអត្តភាពនោះហើយ យាងដល់តុសិតបុរីដោយអត្តភាពទី ២ ។

ព្រះសាស្តាកាលទ្រង់នាំព្រះធម្មទេសនាមហាវេស្សន្តរជាតកដែលប្រដាប់ដោយគាថា ១០០០ នេះ មកហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សូម្បីក្នុងកាលមុន មហាមេឃក៏ញ៉ាំងភ្លៀងបោក្ខរព័ស្ស ឲ្យធ្លាក់ចុះក្នុងទីប្រជុំនៃពួកញាតិរបស់តថាគតយ៉ាងនេះដូចគ្នា ដូច្នេះហើយទ្រង់ប្រជុំជាតកថា

ជូជកព្រាហ្មណ៍ក្នុងកាលនោះបានមកជាទេវទត្តក្នុងកាលឥឡូវនេះ នាងអមិត្តតាបនា ក្នុងកាលនោះបានមកជានាងចិញ្ចមាណវិកា ព្រានព្រៃចេតបុត្តក្នុងកាលនោះបានមកជាឆន្នភិក្ខុ អច្ចុតតាបសក្នុងកាលនោះបានមកជាសារីបុត្ត

សក្កទេវរាជក្នុងកាលនោះ បានមកជាអនុរុទ្ធ ព្រះបាទសញ្ជយនរិន្ទ្ររាជក្នុងកាលនោះបានមកជាព្រះបាទសុទ្ធោទនមហារាជ ព្រះនាងផុស្សតីទេវីក្នុងកាលនោះបានមកជាព្រះនាងសិរិមហាមាយា ព្រះនាងមទ្រីទេវីក្នុងកាលនោះបានមកជាពិម្ពារាហុលមាតា ជាលីកុមារក្នុងកាលនោះបានមកជារាហុល កណ្ហាជិនាក្នុងកាលនោះបានមកជាឧប្បលវណ្ណាភិក្ខុនី រាជបរិស័ទក្រៅអំពីនេះក្នុងកាលនោះបានមកជាពុទ្ធបរិស័ទក្នុងកាលឥឡូវនេះ ចំណែកព្រះវេស្សន្តររាជ ក្នុងកាលនោះ គឺតថាគតអរហន្តសម្មាសម្ពុទ្ធនេះឯង ។

នគរកណ្ឌ ចប់

មហាវេស្សន្តរជាតកទី ១០ ចប់

មហានិបាត ចប់ បរិបូណ៌ហោង

# ក្បាលទី ៩២

## សុត្តបិដក បាលីប្រែ -៦៣

សន្ទឹកចង្អុលប្រាប់មាតិកា

មាតិកា ទំព័រ


មហានារទកស្សបជាតក .......... .......... .......... .......... ........ ២

អដ្ឋកថា មហានារទកស្សបជាតក .......... .......... .......... .......... ....... ២៨

វិធុរជាតក .......... .......... .......... .......... ....... ១១៣

អដ្ឋកថា វិធុរជាតក .......... .......... .......... .......... ....... ១៦១

វេស្សន្តរជាតក .......... .......... .......... .......... ........ ៣២១

អដ្ឋកថា វេស្សន្តរជាតក .......... .......... .......... .......... ....... ៤២០